# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៥៤

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

# សទ្ធម្មប្បជោតិកា អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ មហានិទ្ទេស

# ទុតិយភាគ-តតិយភាគ

# ៥៤

# បាលីប្រែ ៦៥-៦៦



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៤

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

## បុរាភេទសុត្តនិទ្ទេសទី ១០

[ ៥៤ ] *( ព្រះពុទ្ធនិមិត្តសួរថា ) បុគ្គលមានការឃើញដូចម្ដេច មានសីលដូចម្ដេចដែលព្រះអង្គហៅថា អ្នកស្ងប់ បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់នូវនរជនដ៏ឧត្ដមនោះ ។*

[ ៥៥ ] *អធិប្បាយពាក្យថា បុគ្គលមានការឃើញដូចម្ដេច មានសីលដូចម្ដេចដែលព្រះអង្គហៅថា អ្នកស្ងប់ ត្រង់ពាក្យថា បុគ្គលមានការឃើញដូចម្ដេច គឺបុគ្គលប្រកបដោយការឃើញដូចម្ដេច ប្រាកដដូចម្ដេច មានប្រការដូចម្ដេច មានចំណែកប្រៀបដូចម្ដេច ហេតុនោះ ( ទើបសួរថា ) បុគ្គលមានការឃើញដូចម្ដេច ។ ពាក្យថា មានសីលដូចម្ដេច គឺជាអ្នកប្រកបដោយសីលដូចម្ដេច ប្រាកដដូចម្ដេច មានប្រការដូចម្ដេច មានចំណែកដូចម្ដេច ហេតុនោះ ( ទើបសួរថា ) មានការឃើញដូចម្ដេច មានសីលដូចម្ដេច ។ ពាក្យថា ដែលព្រះអង្គហៅថា អ្នកស្ងប់ គឺដែលព្រះអង្គពោលត្រាស់សម្ដែងពណ៌នាបំភ្លឺថ្លែងថាជាអ្នកស្ងប់ ជាអ្នកស្ងប់ស្ងាត់ មានទុក្ខរលត់ ជាអ្នកស្ងប់រម្ងាប់ ។ ពាក្យថា បុគ្គលមានការឃើញដូចម្ដេច គឺសួរចំពោះអធិប្បញ្ញា ។ ពាក្យថា មានសីលដូចម្ដេច គឺសួរចំពោះអធិសីល ។ សួរចំពោះអធិចិត្តថា អ្នកស្ងប់ ហេតុនោះ ( ទើបសួរថា ) បុគ្គលមានការឃើញដូចម្ដេច មានសីលដូចម្ដេច*

ដែលព្រះអង្គហៅថាអ្នកស្ងប់ ។

[ ៥៦ ] អធិប្បាយពាក្យថា បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំ ( សួរហើយ ) សូមប្រាប់នូវនរជននោះ ត្រង់ពាក្យថា នោះ គឺខ្ញុំសួរចំពោះបុគ្គលណា អង្វរចំពោះបុគ្គលណា អារាធនាចំពោះបុគ្គលណា ញ៉ាំងព្រះអង្គឲ្យជ្រះថ្លាចំពោះបុគ្គលណា ។ ព្រះពុទ្ធនិមិត្តនោះ ហៅព្រះពុទ្ធមានព្រះភាគតាមគោត្តថា បពិត្រព្រះគោតម ។ ពាក្យថា សូមប្រាប់ គឺសូមពោល សូមពណ៌នា សូមសម្តែង សូមបញ្ញត្ត សូមផ្តើម សូមបើក សូមចែក សូមធ្វើឲ្យរាក់ សូមប្រកាស ហេតុនោះ ( ទើបសួរថា ) បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំ ( សួរហើយ ) សូមប្រាប់នូវនរជននោះ ។

[ ៥៧ ] ពាក្យថា ដែលខ្ញុំសួរហើយ ( សូមប្រាប់ ) នូវនរជនដ៏ឧត្តម ត្រង់ពាក្យថា សួរហើយ គឺសួរហើយ ដណ្តឹងហើយ អង្វរហើយ អារាធនាហើយ ឲ្យជ្រះថ្លាហើយ ។ ពាក្យថា នូវនរជនដ៏ឧត្តម គឺនូវនរជនជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធានដ៏ឧត្តម ប្រសើរក្រៃលែង ហេតុនោះ ( ទើបពោលថា ) ព្រះអង្គដែលខ្ញុំសួរហើយ ( សូមប្រាប់ ) នូវនរជនដ៏ឧត្តម ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះត្រាស់សួរថា

បុគ្គលមានការឃើញដូចម្តេច មានសីលដូចម្តេចដែលព្រះអង្គ
ហៅថា អ្នកស្ងប់ បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំសួរហើយ
សូមប្រាប់នូវនរជនដ៏ឧត្តមនោះ ។

[ ៥៨ ] ( ព្រះមានព្រះភាគត្រាស់ថា ) មុនអំពីការបែកធ្លាយសរីរៈទៅ

បុគ្គលណាប្រាសចាកតណ្ហា មិនអាស្រ័យកាលខាងដើម ជាអ្នកដែលគេមិនគួររាប់ក្នុងកាលជាកណ្ដាលទេ ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះមិនមានឡើយ ។

[ ៥៩ ] ពាក្យថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណាប្រាសចាកតណ្ហា អធិប្បាយថា បុគ្គលប្រាសចាកតណ្ហា ឃ្លាតចាកតណ្ហា លះតណ្ហា ខ្ជាក់ចោលតណ្ហា រួចចាកតណ្ហា លះបង់តណ្ហា រលាស់ចោលតណ្ហា ប្រាសចាករាគៈ ឃ្លាតចាករាគៈ លះរាគៈ ខ្ជាក់ចោលរាគៈ រួចចាករាគៈ លះបង់រាគៈ រលាស់ចោលរាគៈ មិនស្រេកឃ្លាន រលត់ទុក្ខ ត្រជាក់ សោយសុខ នៅដោយចិត្តដ៏ប្រសើរ មុនអំពីការបែកធ្លាយកាយ មុនអំពីការបែកធ្លាយអត្តភាព មុនអំពីការដាក់ចុះនូវសាកសព មុនអំពីការដាច់ជីវិតិន្ទ្រិយ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យហៅដោយសេចក្ដីគោរព ។ម្យ៉ាងទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់រាគៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ទោសៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់មោហៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់មានះ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ទិដ្ឋិ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចម្រូង ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់កិលេស ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ចែករំលែកញែកនូវធម្មរតនៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ធ្វើនូវទីបំផុតនៃភពទាំងឡាយ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ចម្រើន

ព្រះកាយ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ចម្រើនសីល ចម្រើនចិត្ត ចម្រើនបញ្ញា ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់គប់រកសេនាសនៈទាំងឡាយដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានចីវរបិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ អសុភសមាបត្តិ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃសតិ-ប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានបុណ្យទ្រង់មានភាគនៃតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថា ព្រះមានព្រះភាគនេះមិនមែនមាតាធ្វើ

មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ ព្រះនាមថា ព្រះមានព្រះភាគនុ៎ះ របស់ព្រះពុទ្ធទាំងឡាយ ដ៏មានព្រះភាគជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ ការបញ្ញត្តថាមានព្រះភាគនុ៎ះ ( កើតហើយ ) អំពីការត្រាស់ដឹងព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះមានពាក្យថា ព្រះមានព្រះភាគ ( ត្រាស់ហើយ ) ថា មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណាប្រាសចាកតណ្ហា ។

[ ៦០ ] ពាក្យថា មិនអាស្រ័យនូវកាលជាខាងដើម អធិប្បាយថា អតីតកាលលោកហៅថា កាលខាងដើម ។ បុគ្គលប្រារព្ធអតីតកាលហើយលះបង់តណ្ហារលាស់ចោលទិដ្ឋិ ព្រោះលះបង់តណ្ហា ព្រោះរលាស់ចោលទិដ្ឋិ ឈ្មោះថា មិនអាស្រ័យកាលខាងដើមយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលមិនដល់នូវសេចក្តីរីករាយក្នុងរូបារម្មណ៍នោះថា អាត្មាអញមានរូបយ៉ាងនេះហើយក្នុងអតីតកាលមិនដល់នូវសេចក្តីរីករាយក្នុងអារម្មណ៍នោះថា អាត្មាអញមានវេទនាយ៉ាងនេះមានសញ្ញាយ៉ាងនេះ មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះក្នុងអតីតកាល ឈ្មោះថា មិនអាស្រ័យកាលខាងដើមយ៉ាងនេះខ្លះ ។ មួយទៀតវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគក្នុងអារម្មណ៍ទាំងនោះថា ចក្ខុរបស់អាត្មាអញមានយ៉ាងនេះ រូបទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាលបុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះព្រោះវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគ អ្នកដែលមិនត្រេកអរ

ក្នុងចក្ខុនិងរូបនោះ ឈ្មោះថា មិនអាស្រ័យកាលខាងដើមយ៉ាងនេះខ្លះ ។ វិញ្ញា-ណមិនជាប់ចំពាក់ដោយឆន្ទរាគ ក្នុងអារម្មណ៍ទាំងនោះថា សោតៈរបស់អញមានយ៉ាងនេះ សំឡេងទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាលថា ឃានៈរបស់អញមានយ៉ាងនេះ ក្លិនទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាលថា ជិវ្ហារបស់អញមានយ៉ាងនេះ រសទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាលថា កាយរបស់អញមានយ៉ាងនេះ ផោដ្ឋព្វៈមានយ៉ាងនេះ ក្នុងអតីតកាលថា ចិត្តរបស់អញមានយ៉ាងនេះ ធម្មារម្មណ៍មានយ៉ាងនេះ ក្នុងអតីតកាលបុគ្គលមិនត្រេកអរនឹងអារម្មណ៍ទាំងនោះព្រោះវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគ អ្នកដែលមិនត្រេកអរនឹងអារម្មណ៍ទាំងនោះ ឈ្មោះថា មិនអាស្រ័យកាលខាងដើមយ៉ាងនេះខ្លះ ។ មួយទៀតការសើច ការចរចា ការនិយាយ ការលេងជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើមណា បុគ្គលមិនត្រេកអរនឹងការសើចជាដើមនោះ មិនប្រាថ្នានឹងការសើចជាដើមនោះ មិនដល់នូវសេចក្តីត្រេកនឹងការសើច ជាដើមនោះ ឈ្មោះថា មិនអាស្រ័យកាលខាងដើមយ៉ាងនេះខ្លះ ។

[ ៦១ ] ពាក្យថា ជាអ្នកដែលគេមិនគួររាប់ក្នុងកាលជាកណ្តាល អធិប្បាយថា បច្ចុប្បន្នកាល លោកហៅថា កាលជាកណ្តាល ។ បុគ្គលប្រារព្ធបច្ចុប្បន្នកាលហើយលះបង់តណ្ហា រលាស់ចោលទិដ្ឋិ ព្រោះលះបង់តណ្ហា ព្រោះរលាស់ចោលទិដ្ឋិ ទើបគេមិនគួររាប់ថាជាអ្នកត្រេកអរ មិនគួររាប់ថាជាអ្នកប្រទូស្ត មិនគួររាប់ថាជាអ្នកវង្វេង មិនគួររាប់ថាជាអ្នកជាប់ចំពាក់ មិនគួររាប់ថាជាអ្នកស្ទាបអង្អែល មិនគួររាប់ថាជាអ្នកដល់នូវសេចក្តីរាយមាយ មិន

គួររាប់ថាជាអ្នកដល់នូវសេចក្តីមិនដាច់ស្រេច មិនគួររាប់ថាជាអ្នកដល់នូវកម្លាំង ។ អភិសង្ខារទាំងនោះបុគ្គលនោះលះបង់ហើយព្រោះលះបង់អភិសង្ខារទាំងឡាយ បុគ្គលនោះទើបគេមិនគួររាប់ដោយគតិថាជាអ្នកកើតក្នុងនរក ឬថាជាអ្នកកើតក្នុងកំណើតតិរច្ឆាន ថាជាអ្នកកើតក្នុងបិត្តិវិស័យ ថាជាមនុស្ស ថាជាទេវតា ថាជារូបព្រហ្ម ថាជាអរូបព្រហ្ម ថាជាសញ្ញីសត្វ ថាជាអសញ្ញីសត្វ ឬថាជានេវសញ្ញីនាសញ្ញីសត្វ ។ បុគ្គលដល់នូវការរាប់ដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន ការណ៍មិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកដែលគេមិនគួររាប់ក្នុងកាលជាកណ្តាល ។

[ ៦២ ] អធិប្បាយពាក្យថា ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមានទេត្រង់ពាក្យថា បុគ្គលនោះបានដល់ព្រះអរហន្តទីណាស្រេច ។ ពាក្យថាការធ្វើឲ្យជាប្រធាន បានដល់ការធ្វើឲ្យជាប្រធានពីរ គឺការធ្វើឲ្យជាប្រធាន គឺតណ្ហា ១ ការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ ១ ។បេ។ នេះការធ្វើឲ្យជាប្រធាន គឺតណ្ហា ។បេ។ នេះការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធាន គឺតណ្ហា បុគ្គលនោះលះបង់ហើយ ការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ បុគ្គលនោះរលាស់ចោលហើយព្រោះលះបង់ការធ្វើឲ្យជាប្រធាន គឺតណ្ហា ព្រោះរលាស់ចោលការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ ( បុគ្គលនោះ ) មិនប្រព្រឹត្តធ្វើនូវតណ្ហាឬទិដ្ឋិឲ្យជាប្រធាន ជាអ្នកមិនមានទង់ជ័យ គឺតណ្ហា មិនមានទង់ គឺតណ្ហា មិនមានតណ្ហាជាអធិបតេយ្យ មិនមានទង់ជ័យ គឺទិដ្ឋិ មិនមានទង់ គឺទិដ្ឋិ មិនមានទិដ្ឋិជាអធិបតេយ្យ មិនត្រូវតណ្ហាឬទិដ្ឋិប្រព្រឹត្តព័ទ្ធឡោមឡើយ ហេតុនោះ ( ទ្រង់

ត្រាស់ថា ) ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមានយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលនោះមិនដល់នូវសេចក្ដីត្រេកអរ ក្នុងរូបារម្មណ៍នោះថា អាត្មាអញសូមមានរូបយ៉ាងនេះក្នុងអនាគតកាល មិនដល់នូវសេចក្ដីត្រេកអរ ក្នុងអារម្មណ៍ទាំងនោះថា អាត្មាអញសូមមានវេទនាយ៉ាងនេះ សូមមានសញ្ញាយ៉ាងនេះ សូមមានសង្ខារយ៉ាងនេះ សូមមានវិញ្ញាយ៉ាងនេះក្នុងអនាគតកាល ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមានយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលនោះមិនតម្កល់ចិត្តដើម្បីបាននូវអារម្មណ៍ដែលមិនទាន់បានថា ចក្ខុរបស់អញសូមមានយ៉ាងនេះ រូបទាំងឡាយសូមមានយ៉ាងនេះក្នុងអនាគតកាល បុគ្គលនោះមិនត្រេកអរក្នុងចក្ខុនិងរូបនោះ ព្រោះការមិនតម្កល់ចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមានយ៉ាងនេះខ្លះ ។ បុគ្គលមិនតម្កល់ចិត្តដើម្បីបាននូវអារម្មណ៍ ដែលខ្លួនមិនទាន់បានថា សោតៈរបស់អញសូមមានយ៉ាងនេះ សំឡេងទាំងឡាយសូមមានយ៉ាងនេះក្នុងអនាគតកាល ថាឃានៈរបស់អញ សូមមានយ៉ាងនេះ គន្ធៈទាំងឡាយសូមមានយ៉ាងនេះក្នុងអនាគតកាល ថាជិវ្ហារបស់អញសូមមានយ៉ាងនេះ រសទាំងឡាយសូមមានយ៉ាងនេះក្នុងអនាគតកាល ថាកាយរបស់អញសូមមានយ៉ាងនេះ ផោដ្ឋព្វៈទាំងឡាយសូមមានយ៉ាងនេះក្នុងអនាគតកាល ថាចិត្តរបស់អញសូមមានយ៉ាងនេះ ធម្មារម្មណ៍ទាំងឡាយ សូមមានយ៉ាងនេះក្នុងអនាគតកាល បុគ្គលនោះមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះ ព្រោះការមិនតម្កល់ចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះភាពនៃការ

ធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមានយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលមិនតម្កល់ចិត្តដើម្បីបាននូវអារម្មណ៍ដែលមិនទាន់បានថា អាត្មាអញសូមឲ្យបានជាទេវតាឬជាទេវតាណាមួយដោយសីល ឬដោយវត្ត ឬដោយតបៈ ឬក៏ដោយព្រហ្មចរិយៈនេះ បុគ្គលនោះមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះ ព្រោះការមិនតម្កល់ចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះមិនមាន យ៉ាងនេះខ្លះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណាប្រាសចាកតណ្ហា
មិនអាស្រ័យកាលខាងដើម ជាអ្នកដែលគេមិនគួររាប់ក្នុងកាល
ជាកណ្តាលទេ ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះមិនមាន
ឡើយ ។

[ ៦៣ ] បុគ្គលអ្នកមិនក្រោធ អ្នកមិនតក់ស្លុត អ្នកមិនអួតអាង អ្នកមិនមានកុក្កុច្ចៈ អ្នកពោលដោយការដឹង អ្នកមិនរាយមាយ បុគ្គលអ្នកសង្រួមវាចានោះឯងឈ្មោះថា មុនិ ។

[ ៦៤ ] អធិប្បាយពាក្យថា បុគ្គលអ្នកមិនក្រោធ អ្នកមិនតក់ស្លុត ត្រង់ពាក្យថា បុគ្គលអ្នកមិនក្រោធ ជាពាក្យដែលព្រះមានព្រះភាគត្រាស់ហើយក៏ពិតមែន ។ តែសេចក្តីក្រោធយើងគប្បីពោលមុន ។ សេចក្តីក្រោធកើតដោយអាការៈ ១០ យ៉ាង គឺក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្តីវិនាសដល់អញ ១ ក្រោធកើតព្រោះគិតថា គេកំពុងប្រព្រឹត្តនូវសេចក្តីវិនាស

ដល់អញ ១ ក្រោធកើតព្រោះគិតថា គេនឹងប្រព្រឹត្តនូវសេចក្ដីវិនាសដល់អញ ១ ក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្ដីវិនាស ១ ថាគេកំពុងប្រព្រឹត្តនូវសេចក្ដីវិនាស ១ ថាគេនឹងប្រព្រឹត្តនូវសេចក្ដីវិនាស ១ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្ដីចម្រើន ១ ថាគេកំពុងប្រព្រឹត្តនូវសេចក្ដីចម្រើន ១ ថាគេនឹងប្រព្រឹត្តនូវសេចក្ដីចម្រើន ១ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ មួយទៀតក្រោធកើតក្នុងអំពើមិនជាហេតុ ១ ( គ្រប់ជា ១០ ) ។ សេចក្ដីគុំគួននៃចិត្ត សេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង សេចក្ដីថ្នាំងថ្នាក់ សេចក្ដីខឹង សេចក្ដីខឹងខ្លាំង សេចក្ដីខឹងក្រៃលែង សេចក្ដីប្រទូស្ត សេចក្ដីប្រទូស្តខ្លាំង សេចក្ដីប្រទូស្តក្រៃលែង ការព្យាបាទនៃចិត្ត ការប្រទូស្តក្នុងចិត្ត ក្រោធ អាការក្រោធ សេចក្ដីក្រោធ ការប្រទូស្ត អាការប្រទូស្ត សេចក្ដីប្រទូស្ត ការព្យាបាទ អាការព្យាបាទ សេចក្ដីព្យាបាទ សេចក្ដីខឹង សេចក្ដីខឹងតប ការកាច ការសម្រក់ទឹកភ្នែក សេចក្ដីមិនត្រេកអរនៃចិត្តណា មានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្ដីក្រោធ ។ មួយទៀតបណ្ឌិតគប្បីជ្រាបសេចក្ដីក្រោធខ្លាំងនិងតិច ។ ជួនកាលសេចក្ដីក្រោធ គ្រាន់តែធ្វើចិត្តឲ្យល្អក់ប៉ុណ្ណោះ តែមិនទាន់ធ្វើមុខឲ្យកញ្ជុបកញ្ជូវនៅឡើយក៏មាន ។ ជួនកាលសេចក្ដីក្រោធគ្រាន់តែធ្វើមុខឲ្យកញ្ជុបកញ្ជូវប៉ុណ្ណោះ តែមិនទាន់ធ្វើចង្កាឲ្យញាក់ញ័រនៅឡើយក៏មាន ។ ជួនកាលសេចក្ដីក្រោធ គ្រាន់តែធ្វើចង្កាឲ្យញាក់ញ័រប៉ុណ្ណោះ តែមិនទាន់បញ្ចេញសម្ដីអាក្រក់នៅឡើយក៏មាន ។ ជួនកាលសេចក្ដី

ក្រោធគ្រាន់តែបញ្ចេញសម្តីអាក្រក់ប៉ុណ្ណោះតែមិនទាន់ក្រឡេកមើលរឿយៗនូវទិសធំនិងទិសតូចនៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែក្រឡេកមើលរឿយៗនូវទិសធំនិងទិសតូចប៉ុណ្ណោះ តែមិនទាន់ចាប់ដំបងនិងសស្ត្រានៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធ គ្រាន់តែចាប់ដំបងនិងសស្ត្រាប៉ុណ្ណោះ តែមិនទាន់យារដំបងនិងសស្ត្រានៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែយារដំបងនិងសស្ត្រាប៉ុណ្ណោះ តែមិនទាន់ចោលពួយដំបងនិងសស្ត្រាតម្រង់ទៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែចោលពួយដំបងនិងសស្ត្រាតម្រង់ប៉ុណ្ណោះ តែមិនទាន់ធ្វើឲ្យដាច់មុតនៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែធ្វើឲ្យដាច់មុតប៉ុណ្ណោះ តែមិនទាន់ធ្វើឲ្យបាក់បែកនៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធ គ្រាន់តែធ្វើឲ្យបាក់បែកប៉ុណ្ណោះ តែមិនទាន់ទាញចេញនូវអវយវៈតូចនិងអវយវៈធំ នៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែទាញចេញនូវអវយវៈតូចនិងអវយវៈធំប៉ុណ្ណោះ តែមិនទាន់ផ្តាច់បង់ជីវិតនៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែផ្តាច់បង់ជីវិតប៉ុណ្ណោះ តែមិនទាន់តាំងនៅដើម្បីផ្តាច់បង់ជីវិតទាំងពួង ( របស់អ្នកដទៃនិងរបស់ខ្លួន ) នៅឡើយក៏មាន ។ សេចក្តីក្រោធសម្លាប់បុគ្គលដទៃហើយទើបសម្លាប់ខ្លួនក្នុងកាលណា កាលណោះសេចក្តីក្រោធឈ្មោះថា ដល់នូវការក្រាស់ឡើងដ៏ក្រៃលែង ដល់នូវសេចក្តីទូលំទូលាយក្រៃលែង ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ សេចក្តីក្រោធនេះបុគ្គលណាលះបង់ហើយ ផ្តាច់បង់ហើយ រម្ងាប់ហើយ គ្របសង្កត់ហើយធ្វើមិនគួរឲ្យកើតឡើងបានដុតដោយភ្លើង គឺញាណ

ហើយបុគ្គលនោះគេហៅថា អ្នកមិនក្រោធ ។ បុគ្គលឈ្មោះថា អ្នកមិនក្រោធ ព្រោះលះបង់ក្រោធ ឈ្មោះថាអ្នកមិនក្រោធ ព្រោះកំណត់ដឹងនូវវត្ថុក្រោធ ឈ្មោះថាអ្នកមិនក្រោធ ព្រោះផ្ដាច់ផ្ដិលនូវហេតុនៃក្រោធ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនក្រោធ ។

[ ៦៥ ] ពាក្យថា អ្នកមិនតក់ស្លុត អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះជាអ្នកតក់ស្លុត តក់ស្លុតខ្លាំង តក់ស្លុតក្រៃលែង ។ បុគ្គលនោះតក់ស្លុត តក់ស្លុតខ្លាំង តក់ស្លុតក្រៃលែង ខ្លាច ដល់នូវសេចក្ដីតក់ស្លុតថា អញមិនបានត្រកូល ឬមិនបានពួក ឬមិនបានអាវាស ឬមិនបានលាភ ឬមិនបានយស ឬមិនបានសេចក្ដីសរសើរ ឬមិនបានសុខ ឬមិនបានចីវរ ឬមិនបានបិណ្ឌបាត ឬមិនបានសេនាសនៈ ឬមិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារ ឬមិនបានគិលា-នុបដ្ឋាកបុគ្គល អញជាអ្នកមិនល្បីល្បាញក៏តក់ស្លុត តក់ស្លុតខ្លាំង តក់ស្លុតក្រៃលែង ខ្លាច ដល់នូវសេចក្ដីតក់ស្លុត ។ ភិក្ខុក្នុងសាសនានេះជាអ្នកមិនតក់ស្លុត មិនតក់ស្លុតខ្លាំង មិនតក់ស្លុតក្រៃលែង ។ លោកមិនតក់ស្លុត មិនតក់ស្លុតខ្លាំង មិនតក់ស្លុតក្រៃលែង មិនខ្លាច មិនដល់នូវសេចក្ដីតក់ស្លុតថា អញមិនបានត្រកូល ឬមិនបានពួក ឬមិនបានអាវាស ឬមិនបានលាភ ឬមិនបានយស ឬមិនបានសេចក្ដីសរសើរ ឬមិនបានសុខ ឬមិនបានចីវរ ឬមិនបានបិណ្ឌបាត ឬមិនបានសេនាសនៈ ឬមិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារ ឬមិនបានគិលានុបដ្ឋាកបុគ្គល អញជាអ្នកមិនល្បីល្បាញ ក៏មិនតក់ស្លុត មិនតក់ស្លុតខ្លាំង មិនតក់ស្លុតក្រៃលែង មិនខ្លាច មិនដល់នូវសេចក្ដីតក់ស្លុត ហេតុ

នោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនក្រោធ អ្នកមិនតក់ស្លុត ។

[ ៦៦ ] ពាក្យថា អ្នកមិនអួតអាង អ្នកមិនមានកុក្កុច្ចៈ អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះជាអ្នកអួតអាង អួតអាងផ្សេងៗ ។ បុគ្គលនោះរមែងអួតអាង អួតអាងផ្សេងៗ ថាអញជាអ្នកបរិបូណ៌ដោយសីលក្តី ថាជាអ្នកបរិបូណ៌ដោយវត្តក្តី ថាជាបរិបូណ៌ដោយសីលនិងវត្តក្តី ដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកូននៃត្រកូលក្តី ដោយភាពនៃខ្លួនមានសម្បុរដ៏ល្អក្តី ដោយទ្រព្យក្តី ដោយការស្វាធ្យាយក្តី ដោយការងារក្តី ដោយសិប្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយបដិភាណក្តី ដោយវត្ថុណាមួយក្តី ជាអ្នក ( ចេញ ) អំពីត្រកូលខ្ពស់ហើយបួសក្តី ថាជាអ្នកចេញអំពីត្រកូលធំហើយបួសក្តី ( ចេញ ) អំពីត្រកូលមានភោគដ៏ច្រើនហើយបួសក្តី ថាជាអ្នកចេញអំពីត្រកូលមានភោគៈ ដ៏លើសលុបហើយបួសក្តី ថាអញជាអ្នកល្បីល្បាញមានយសជាងពួកគ្រហស្ថនិងបព្វជិតក្តី ថាជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារក្តី ថាជាអ្នកចេះព្រះសូត្រក្តី ថាជាអ្នកទ្រទ្រង់ព្រះវិន័យក្តី ថាជាធម្មកថិកក្តី ថាជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តសបទានចារិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គក្តី រមែងអួតអាង អួតអាងផ្សេងៗ ថាជាអ្នកបានបឋមជ្ឈានក្តី ថាជាអ្នកបានទុតិយជ្ឈានក្តី ថាជាអ្នកបានតតិយជ្ឈានក្តី ថាជា

អ្នកបានចតុត្ថជ្ឈានក្តី ថាជាអ្នកបានអាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណ-ញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិនិងនេវសញ្ញានាសញ្ញាយតន-សមាបត្តិក្តី ។ បុគ្គលមិនអួតអាង មិនអួតអាងផ្សេងៗយ៉ាងនេះ ។ បុគ្គលវៀរទូទៅ វៀរស្រឡះ វៀរចំពោះ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញអំពីសេចក្តីអួតអាង រមែងនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេសហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនអួតអាង ។

[ ៦៧ ] អធិប្បាយពាក្យថា មិនមានកុក្កុច្ចៈ ទ្រង់ពាក្យថា កុក្កុច្ចៈ គឺការរពឹសដៃហៅថាកុក្កុច្ចៈ ការរពឹសជើងហៅថាកុក្កុច្ចៈ ការរពឹសដៃនិងជើងក៏ហៅថាកុក្កុច្ចៈ សេចក្តីសម្គាល់ថាគួរក្នុងវត្ថុមិនគួរ សេចក្តីសម្គាល់ថាមិនគួរក្នុងវត្ថុគួរ សេចក្តីសម្គាល់ថាមានទោសក្នុងវត្ថុមិនមានទោស សេចក្តីសម្គាល់ថាមិនមានទោសក្នុងវត្ថុមានទោស សេចក្តីរង្កៀស អាការៈនៃសេចក្តីរង្កៀស ភាពនៃសេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តឯណាមានសភាពយ៉ាងនេះនេះហៅថា កុក្កុច្ចៈ ។ មួយទៀតសេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតដោយហេតុពីរ គឺភាពនៃអំពើដែលធ្វើហើយ ១ និងមិនធ្វើហើយ ១ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើងព្រោះអំពើដែលធ្វើហើយ ១ និងមិនធ្វើហើយ ១ តើដូចម្តេច ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើង ( ដោយគិត ) ថា កាយទុច្ចរិតអាត្មាអញបានធ្វើហើយ កាយសុចរិតអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស

សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើងថា វចីទុច្ចរិតអាត្មាអញបានធ្វើហើយ វចីសុចរិតអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើងថា មនោទុច្ចរិតអាត្មាអញបានធ្វើហើយ មនោសុចរិតអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើងថា បាណាតិបាត អាត្មាអញបានធ្វើហើយ ការវៀរចាកបាណាតិបាតអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើងថា អទិន្នាទានអាត្មាអញបានធ្វើហើយ ការវៀរចាកអទិន្នាទានអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្តរមែងកើតឡើងថា កាមេសុមិច្ឆាចារៈ អាត្មាអញបានធ្វើហើយ ការវៀរចាកកាមេសុមិច្ឆាចារៈ អាត្មាអញមិនបានធ្វើទេ ។ ថាមុសាវាទអាត្មាអញបានធ្វើហើយ ការវៀរចាកមុសាវាទអាត្មាអញមិនបានធ្វើទេ ។ ថាបិសុណាវាចាអាត្មាអញបានធ្វើហើយ ការវៀរចាកបិសុណាវាចាអាត្មាអញបានធ្វើទេ ។ ថាផរុសវាចាអាត្មាអញបានធ្វើហើយ ការវៀរចាកផរុសវាចាអាត្មាអញមិនបានធ្វើទេ ។ ថាសម្ផប្បលាបៈអាត្មាអញបានធ្វើហើយ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើទេ ។ ថាអភិជ្ឈា អាត្មាអញបានធ្វើហើយ អនភិជ្ឈា អាត្មាអញមិនបានធ្វើទេ ។ ថាព្យាបាទ អាត្មាអញបានធ្វើហើយ អព្យាបាទអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្ត រមែងកើតឡើងថា មិច្ឆាទិដ្ឋិ អាត្មាអញបានធ្វើហើយ

សម្មាទិដ្ឋិអាត្មាអញមិនបានធ្វើទេ ។ សេចក្ដីរង្កៀស សេចក្ដីក្ដៅក្រហាយចិត្ត សេចក្ដីប្រេះស្រាំនៃចិត្ត រមែងកើតឡើងព្រោះភាពនៃអំពើ ដែលធ្វើហើយ ១ និងមិនធ្វើហើយ ១ យ៉ាងនេះ ។ មួយទៀតសេចក្ដីរង្កៀស សេចក្ដីក្ដៅក្រហាយចិត្ត សេចក្ដីប្រេះស្រាំនៃចិត្តរមែងកើតឡើងថា អាត្មាអញជាអ្នកមិនធ្វើឲ្យពេញក្នុងសីលទាំងឡាយ ។ ថាអាត្មាអញ ជាអ្នកមានទ្វារមិនគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ។ ថាអាត្មាអញ ជាអ្នកមិនដឹងប្រមាណក្នុងភោជន ។ ថាអាត្មាអញ ជាអ្នកមិនប្រកបរឿយៗនូវការភ្ញាក់រឭក ។ ថាអាត្មាអញជាអ្នកមិនប្រកបដោយសតិនិងសម្បជញ្ញៈ ។ ថាសតិប្បដ្ឋាន ៤ អាត្មាអញមិនបានចម្រើនហើយ ។ ថាសម្មប្បធាន ៤ អាត្មាអញមិនបានចម្រើនហើយ ។ ថាឥទ្ធិបាទ ៤ អាត្មាអញមិនបានចម្រើនហើយ ។ ថាឥន្ទ្រិយ ៥ អាត្មាអញមិនបានចម្រើនហើយ ។ ថាពលៈ ៥ អាត្មាអញមិនបានចម្រើនហើយ ។ ថាពោជ្ឈង្គ ៧ អាត្មាអញមិនបានចម្រើនហើយ ។ ថាអដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញមិនបានចម្រើនហើយ ។ ថាទុក្ខអាត្មាអញមិនបានកំណត់ទេ ។ ថាសមុទយៈអាត្មាអញមិនបានលះបង់ទេ ។ ថាមគ្គអាត្មាអញមិនបានចម្រើនទេ ។ សេចក្ដីរង្កៀស សេចក្ដីក្ដៅក្រហាយចិត្ត សេចក្ដីប្រេះស្រាំនៃចិត្ត រមែងកើតឡើងថានិរោធអាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ សេចក្ដីរង្កៀសនេះបុគ្គលណាលះបង់ហើយ ផ្ដាច់ផ្ដិលហើយ រម្ងាប់ហើយ គ្របសង្កត់ហើយធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានកុក្កុច្ចៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនអួតអាង អ្នកមិនមាន

កុក្កុច្ចៈ ។

[ ៦៨ ] ពាក្យថា អ្នកពោលដោយការដឹង អ្នកមិនរាយមាយ សេចក្តីថា បញ្ញា លោកហៅថា ការដឹង បានដល់ប្រាជ្ញា សេចក្តីដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណានូវធម៌ សេចក្តីយល់ត្រូវ ។ បុគ្គលសួង់ដោយការដឹងហើយពោលនូវវាចា ទោះបីពោលច្រើន ពណ៌នាច្រើន បំភ្លឺច្រើន ថ្លែងច្រើនក៏មិនពោលវាចាដែលគេពោលអាក្រក់ និយាយអាក្រក់ ចរចាអាក្រក់ បញ្ចេញអាក្រក់ទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកពោលដោយការដឹង ។ ពាក្យថា អ្នកមិនរាយមាយ សំនួរថា សេចក្តីរាយមាយក្នុងដំណើរនោះ តើដូចម្តេច ។ សេចក្តីរាយមាយនៃចិត្ត សេចក្តីមិនស្ងប់រម្ងាប់ សេចក្តីរវើរវាយនៃចិត្ត សេចក្តីវិលនៃចិត្តឯណា នេះលោកហៅថា សេចក្តីរាយមាយ ។ សេចក្តីរាយមាយនេះ បុគ្គលណាលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើត បានដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថាជាអ្នកមិនរាយមាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលដោយការដឹងជាអ្នកមិនរាយមាយ ។

[ ៦៩ ] ពាក្យថា បុគ្គលសង្រួមវាចានោះឯងជាមុនិ សេចក្តីថា ភិក្ខុក្នុងសាសនានេះលះបង់មុសាវាទ វៀរចាកមុសាវាទ ពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលបំភ័ន្តសត្វលោក ។ លះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា គឺឮអំពីពួកជននេះមិនប្រាប់ពួកជនឯណោះដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះមិនប្រាប់

ដល់ជនពួកនេះដើម្បីបំបែកពួកជនឯណោះ ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាហើយក្តី ជាអ្នកបន្ថែមកម្លាំងឲ្យដល់ពួក ដែលព្រមព្រៀងគ្នាហើយក្តី មានសេចក្តីត្រេកអរក្នុងការព្រមព្រៀង ត្រេកអរក្នុងសេចក្តីព្រមព្រៀង មានសេចក្តីរីករាយក្នុងការព្រមព្រៀង ពោលវាចាជាទីធ្វើនូវសេចក្តីព្រមព្រៀង ។ លះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចាហើយ ក៏វាចាណាដែលជាសម្តីឥតទោស ជាសុខដល់ត្រចៀកគួរឲ្យស្រឡាញ់ ជាទីពេញហឫទ័យ ជាសម្តីរបស់អ្នកបុរី ជាទីត្រេកអរដល់ជនច្រើននាក់ ជាទីពេញចិត្តជនច្រើននាក់ ជាអ្នកពោលតែវាចាបែបនោះឯង ។ លះបង់សម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈហើយជាអ្នកពោលពាក្យក្នុងកាលគួរ ពោលតែពាក្យពិត ពោលអត្ថ ពោលធម៌ ពោលវិន័យ ពោលវាចាដែលគួរកប់ទុកក្នុងហឫទ័យ ជាវាចាមានគ្រឿងអាង មានទីបំផុត ប្រកបដោយប្រយោជន៍តាមកាលគួរ ។ បុគ្គលប្រកបដោយវចីសុចរិតទាំង ៤ តែងពោលវាចាប្រាសចាកទោស ៤ ប្រការ ។ បុគ្គលវៀរទូទៅ វៀរស្រឡះ វៀរចំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញឆ្ងាយអំពីតិរច្ឆានកថា ៣២ រមែងនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ។ ពោលនូវវត្ថុ ១០ ប្រការ ។ ពោលនូវវត្ថុ ១០ ប្រការតើដូចម្តេច ។ គឺពោលអប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំ សគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញ្ញាណទស្សនកថា ១ សតិប្បដ្ឋានកថា ១ សម្មប្បធានកថា ១ ឥទ្ធិប្បាទកថា ១ ឥន្ទ្រិយកថា ១ ពលៈកថា ១ ពោជ្ឈង្គកថា ១ មគ្គកថា

១ ផលកថា ១ និព្វានកថា ១ ។ ពាក្យថា បុគ្គលអ្នកសង្រួមវាចា គឺសង្រួម ប្រយ័ត្ន គ្រប់គ្រង បីបាច់ រក្សា រវាំង រម្ងាប់ ។ ញាណលោកហៅថា មោនៈ របស់បទថា មុនិ ។បេ។ មុនិនោះកន្លងនូវបណ្តាញ គឺសេចក្តីជាប់ចំពាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអ្នកសង្រួមវាចានោះឯងឈ្មោះថា មុនិ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលអ្នកមិនក្រោធ អ្នកមិនតក់ស្លុត អ្នកមិនអួតអាង អ្នក
មិនមានកុក្កុច្ចៈ អ្នកពោលដោយការដឹង អ្នកមិនរាយមាយ
បុគ្គលអ្នកសង្រួមវាចានោះឯង ឈ្មោះថាមុនិ ។

[ ៧០ ] បុគ្គលមិនមានសេចក្តីជាប់ចំពាក់ក្នុងវត្ថុជាអនាគត មិនសោកស្តាយចំពោះវត្ថុជាអតីត អ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ បុគ្គលនោះទិដ្ឋិទាំងឡាយនាំទៅមិនបាន ។

[ ៧១ ] ពាក្យថា បុគ្គលមិនមានសេចក្តីជាប់ចំពាក់ក្នុងវត្ថុជាអនាគត អធិប្បាយថា តណ្ហាលោកហៅថា សេចក្តីជាប់ចំពាក់ បានដល់ តម្រេក តម្រេក ខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីជាប់ចំពាក់ គឺតណ្ហានេះបុគ្គលណាលះបង់ ផ្តាច់ផ្តិល ធ្វើឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនមានសេចក្តីជាប់ចំពាក់ក្នុងវត្ថុជាអនាគតយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលមិនដល់ព្រមនូវសេចក្តីរីករាយក្នុងរូបនោះថា អាត្មាអញគប្បីមានរូបយ៉ាងនេះក្នុងអនាគតកាល មិនដល់ព្រមនូវសេចក្តីរីករាយក្នុងខន្ធទាំងនោះ

ថា អាត្មាអញគប្បីមានវេទនាយ៉ាងនេះ គប្បីមានសញ្ញាយ៉ាងនេះ គប្បីមានសង្ខារយ៉ាងនេះ គប្បីមានវិញ្ញាណយ៉ាងនេះក្នុងអនាគតកាល ឈ្មោះថា អ្នកមិនមានសេចក្ដីជាប់ចំពាក់ក្នុងវត្ថុជាអនាគតយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលមិនតាំងចិត្តដើម្បីបាននូវអាយតនៈ ដែលមិនទាន់បានថា ភ្នែករបស់អញគប្បីមានយ៉ាងនេះ រូបទាំងឡាយយ៉ាងនេះក្នុងអនាគតកាល ក៏មិនរីករាយចំពោះអាយតនៈទាំងនោះព្រោះការមិនតាំងចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះអាយតនៈទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្ដីជាប់ចំពាក់ក្នុងវត្ថុជាអនាគតយ៉ាងនេះខ្លះ ។ ត្រចៀករបស់អញគប្បីមានយ៉ាងនេះ សំឡេងទាំងឡាយយ៉ាងនេះក្នុងអនាគតកាល ។បេ។ មិនតាំងចិត្តដើម្បីបាននូវអារម្មណ៍ ដែលមិនទាន់បានថា ចិត្តរបស់អញគប្បីមានយ៉ាងនេះ ធម្មារម្មណ៍ទាំងឡាយយ៉ាងនេះក្នុងអនាគតកាល ក៏មិនរីករាយចំពោះអាយតនៈទាំងនោះ ព្រោះការមិនតាំងចិត្តជាបច្ច័យ កាលមិនរីករាយចំពោះអាយតនៈទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្ដីជាប់ចំពាក់ក្នុងវត្ថុជាអនាគតយ៉ាងនេះខ្លះ ។ មួយវិញទៀត បុគ្គលមិនបានតាំងចិត្ត ដើម្បីបាននូវអត្តភាពដែលមិនទាន់បានថា អញគប្បីបានជាទេវតា ឬជាទេវតាណាមួយ ដោយសីលឬវត្ត ឬតបៈ ឬព្រហ្មចរិយៈនេះ ក៏មិនរីករាយចំពោះអត្តភាពទាំងនោះព្រោះការមិនតាំងចិត្តជាបច្ច័យ កាលមិនរីករាយចំពោះអត្តភាពទាំងនោះ ឈ្មោះថា អ្នកមិនមានសេចក្ដីជាប់ចំពាក់ ក្នុងវត្ថុជាអនាគតយ៉ាងនេះខ្លះ ។

[ ៧២ ] ពាក្យថា មិនសោយសោកចំពោះវត្ថុជាអតីត សេចក្ដីថា មិន

សោយសោករកវត្ថុដែលប្រែប្រួលហើយ ឬមិនសោយសោកក្នុងវត្ថុដែលប្រែប្រួលហើយ គឺមិនសោយសោកថា ក្អែករបស់អញប្រែប្រួលហើយ មិនសោយសោក មិនលំបាក មិនខ្សឹកខ្សួល មិនកន្ទក់កន្ទេញគក់ទ្រូង មិនដល់នូវសេចក្តីវង្វេងថា ត្រចៀករបស់អញ ច្រមុះរបស់អញ អណ្តាតរបស់អញ កាយរបស់អញ រូបទាំងឡាយរបស់អញ សំឡេងទាំងឡាយរបស់អញ ក្លិនទាំងឡាយរបស់អញ រសទាំងឡាយរបស់អញ ផោដ្ឋព្វៈទាំងឡាយរបស់អញ ត្រកូលរបស់អញ គណៈរបស់អញ អាវាសរបស់អញ លាភរបស់អញ យសរបស់អញ សេចក្តីសរសើររបស់អញ សុខរបស់អញ ចីវររបស់អញ បិណ្ឌបាតរបស់អញ សេនាសនៈរបស់អញ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អញ មាតារបស់អញ បិតារបស់អញ បងប្អូនប្រុសរបស់អញ បងប្អូនស្រីរបស់អញ កូនប្រុសរបស់អញ កូនស្រីរបស់អញ មិត្តនិងអាមាត្យទាំងឡាយរបស់អញ ពួកញាតិរបស់អញ ពួកសាលោហិតរបស់អញ ប្រែប្រួលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនសោយសោកចំពោះវត្ថុជាអតីត ។

[ ៧៣ ] អធិប្បាយពាក្យថា អ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ ត្រង់ពាក្យថា ផស្សៈ បានដល់ ចក្ខុសម្ផស្សៈ សោតសម្ផស្សៈ ឃានសម្ផស្សៈ ជិវ្ហាសម្ផស្សៈ កាយសម្ផស្សៈ មនោសម្ផស្សៈ អធិវចនសម្ផស្សៈ បដិឃសម្ផស្សៈ សុខវេទនីយសម្ផស្សៈ ទុក្ខវេទនីយសម្ផស្សៈ អទុក្ខមសុខវេទនីយសម្ផស្សៈ កុសលផស្សៈ អកុសលផស្សៈ អព្យាកតផស្សៈ កាមាវចរផស្សៈ រូបាវចរផស្សៈ អរូបាវចរផស្សៈ សុញ្ញតផស្សៈ

អនិមិត្តផស្សៈ អប្បណិហិតផស្សៈ លោកិយផស្សៈ លោកុត្តរផស្សៈ អតីតផស្សៈ អនាគតផស្សៈ បច្ចុប្បន្នផស្សៈ ការប៉ះពាល់ សេចក្តីប៉ះពាល់ សេចក្តីប៉ះពាល់ព្រម ភាពនៃការប៉ះពាល់ព្រមឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា ផស្សៈ ។ ពាក្យថា អ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ គឺឃើញនូវចក្ខុសម្ផស្សៈដ៏ស្ងប់ស្ងាត់ចាកខ្លួនផង ចាកវត្ថុរបស់ខ្លួនផង ចាកវត្ថុដ៏ទៀងទាត់ផង ចាកវត្ថុដ៏ឋិតថេរផង ចាកវត្ថុដ៏ខ្ជាប់ខ្ជួនផង ចាកសភាវៈមិនប្រែប្រួលផង ។ ឃើញសោតសម្ផស្សៈដ៏ស្ងប់ស្ងាត់ ឃើញឃានសម្ផស្សៈដ៏ស្ងប់ស្ងាត់ ។ ឃើញជិវ្ហាសម្ផស្សៈដ៏ស្ងប់ស្ងាត់ ។ ឃើញកាយសម្ផស្សៈដ៏ស្ងប់ស្ងាត់ ។ ឃើញមនោសម្ផស្សៈដ៏ស្ងប់ស្ងាត់ ។ ឃើញអធិវចនសម្ផស្សៈដ៏ស្ងប់ស្ងាត់ ។ ឃើញបដិឃសម្ផស្សៈដ៏ស្ងប់ស្ងាត់ ។ ឃើញសុខវេទនីយសម្ផស្សៈ ។ ទុក្ខវេទនីយសម្ផស្សៈ ។ អទុក្ខមសុខវេទនីយសម្ផស្សៈ ។ កុសលផស្សៈ ។ អកុសលផស្សៈ ។ អព្យាកតផស្សៈ ។ កាមាវចរផស្សៈ ។ រូបាវចរផស្សៈ ។ អរូបាវចរផស្សៈ ។ លោកិយផស្សៈ ។ ឃើញលោកុត្តរផស្សៈដ៏ស្ងប់ស្ងាត់ចាកខ្លួនផង ចាកវត្ថុជារបស់ខ្លួនផង ចាកវត្ថុដ៏ទៀតទាត់ផង ចាកវត្ថុដ៏ឋិតថេរផង ចាកវត្ថុដ៏ខ្ជាប់ខ្ជួនផង ចាកសភាវៈមិនប្រែប្រួលផង ។ មួយទៀតឃើញអតីតផស្សៈដ៏ស្ងាប់ស្ងាត់ចាកពួកអនាគតផស្សៈផង ចាកពួកបច្ចុប្បន្ន ផស្សៈផង ។ ឃើញអនាគតផស្សៈដ៏ស្ងប់ស្ងាត់ ចាកពួកអតីតផស្សៈផង ចាកពួកបច្ចុប្បន្នផស្សៈផង ។ ឃើញបច្ចុប្បន្នផស្សៈដ៏ស្ងប់ស្ងាត់ចាកពួកអតីតផស្សៈផង ចាកអនាគតផស្សៈផង ។ មួយទៀតពួកផស្សៈណាដ៏ប្រសើរ មិនមានអាសវៈជា

លោកុត្តរប្រកបដោយសុញ្ញតៈ បុគ្គលរមែងឃើញពួកផស្សៈនោះដ៏ស្ងប់ស្ងាត់ចាករាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ឃើញពួកលោកុត្តរផស្សៈ ដ៏ស្ងប់ស្ងាត់ចាកកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ ។

[ ៧៤ ] ពាក្យថា ទិដ្ឋិទាំងឡាយនាំទៅមិនបាន គឺទិដ្ឋិទាំង ៦២ បុគ្គលនោះលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ទាំងមិនជឿ មិនត្រឡប់មកកាន់ទិដ្ឋិនោះថាមានខ្លឹម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទិដ្ឋិទាំងឡាយនាំទៅមិនបាន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> បុគ្គលមិនមានសេចក្តីជាប់ចំពាក់ក្នុងវត្ថុជាអនាគត មិនសោក
> ស្តាយចំពោះវត្ថុជាអតីត អ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈ
> ទាំងឡាយ បុគ្គលនោះទិដ្ឋិទាំងឡាយនាំទៅមិនបាន ។

[ ៧៥ ] បុគ្គលអ្នករួញចិត្ត អ្នកមិនកុហក អ្នកមិនមានសេចក្តីប្រាថ្នា អ្នកមិនមានសេចក្តីកំណាញ់ អ្នកមិនមានការឃ្នើសឃ្នង អ្នកដែលគេមិនគួរខ្ពើម រមែងមិនប្រកបក្នុងការញុះញង់ទេ ។

[ ៧៦ ] អធិប្បាយពាក្យថា អ្នករួញចិត្ត អ្នកមិនកុហក ត្រង់ពាក្យថា អ្នករួញចិត្ត សេចក្តីថា ដែលឈ្មោះថា អ្នករួញចិត្តព្រោះលះបង់រាគៈ អ្នករួញចិត្តព្រោះលះបង់ទោសៈ អ្នករួញចិត្តព្រោះលះបង់នូវមោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ ។បេ។ អ្នករួញចិត្តព្រោះលះបង់អកុសលាភិសង្ខារទាំងពួង ។ សមដូចព្រះពុទ្ធដីកានេះដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នករួញចិត្តតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះលះបង់ហើយ មានឫសគល់គាស់រំលើងហើយ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមានបែបភាព ជាធម៌លែងកើតតទៅទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នករួញចិត្តយ៉ាងនេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នករួញចិត្ត ។

[ ៧៧ ] ពាក្យថា អ្នកមិនកុហក អធិប្បាយថា កុហនវត្ថុ ៣ យ៉ាង កុហនវត្ថុខាងការសេពបច្ច័យ ១ កុហនវត្ថុខាងឥរិយាបថ ១ កុហនវត្ថុខាងការខ្សឹបជិត ១ ។

កុហនវត្ថុខាងការសេពបច្ច័យ តើដូចម្តេច ។ ពួកគហបតីក្នុងសាសនានេះរមែងនិមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះមានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ជាអ្នកមានសេចក្តីត្រូវការនូវចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ អាស្រ័យនូវសេចក្តីប្រាថ្នាដ៏លើសលុបទើបហាមឃាត់ចីវរ ហាមឃាត់បិណ្ឌបាត ហាមឃាត់សេនាសនៈ ហាមឃាត់គិលានប្បច្ចយ-

ភេសជ្ជបរិក្ខារ ។ ភិក្ខុនោះបានពោលយ៉ាងនេះថា សមណៈមានប្រយោជន៍អ្វី ដោយចីវរមានថ្លៃច្រើន ការប្រើប្រាស់ចីវរដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែរើសកំណាត់សំពត់ទាំងឡាយ អំពីព្រៃស្មសាន ឬអំពីគំនរសំរាម ឬអំពីរានផ្សា មកធ្វើជាសង្ឃាដិប្រើប្រាស់ សមណៈមានប្រយោជន៍អ្វីដោយបិណ្ឌបាតមានថ្លៃច្រើន ការចិញ្ចឹមជីវិតដ៏សមគួរដល់សមណៈនោះ គឺសមណៈត្រូវតែចិញ្ចឹមជីវិតដោយពុំនូតបាយ ដោយការដើរទៅដើម្បីសូម សមណៈមានប្រយោជន៍អ្វីដោយសេនាសនៈមានថ្លៃច្រើន ការនៅដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែជាអ្នកនៅជិតគល់ឈើ ឬនៅក្នុងព្រៃស្មសាន ឬក៏នៅក្នុងទីវាល សមណៈមានប្រយោជន៍អ្វី ដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារមានថ្លៃច្រើន ការធ្វើឱសថដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែធ្វើថ្នាំដោយមូត្រផ្អូមឬដោយចំណិតសម៉ តាំងអំពីនោះមកភិក្ខុនោះក៏ទ្រទ្រង់ចីវរដ៏សៅហ្មង បរិភោគបិណ្ឌបាតដ៏សៅហ្មង សេពសេនាសនៈដ៏សៅហ្មង សេពគិលានប្បច្ច័យភេសជ្ជបរិក្ខារដ៏សៅហ្មង ។ ពួកគហបតីដឹងភិក្ខុនោះយ៉ាងនេះថា សមណៈនេះមានសេចក្តីប្រាថ្នាតិច មានសន្តោស ស្ងប់ស្ងាត់ មិនច្របូកច្របល់ ( ដោយពួក ) ប្រារព្ធព្យាយាម ពោលធុតគុណក៏រឹងរឹតតែនិមន្តដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ ភិក្ខុនោះពោលយ៉ាងនេះថា កុលបុត្តមានសទ្ធា តែងប្រសពូនូវបុណ្យដ៏ច្រើនព្រោះធម៌ ៣ យ៉ាងមានចំពោះមុខ គឺកុលបុត្តមានសទ្ធាតែងប្រសពូនូវបុណ្យដ៏ច្រើន ព្រោះសទ្ធាមានចំពោះមុខ ១ កុលបុត្តមានសទ្ធាតែងប្រសពូនូវបុណ្យដ៏ច្រើន ព្រោះទេយ្យធម៌មាន

ចំពោះមុខ ១ កុលបុត្តមានសទ្ធា តែងប្រសព្វនូវបុណ្យដ៏ច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គលមានចំពោះមុខ ១ សទ្ធានេះរបស់ពួកអ្នកក៏មានផង ទេយ្យធម៌នេះក៏មានព្រមផង ទាំងអាត្មាក៏ជាអ្នកទទួល បើអាត្មាមិនទទួលទេពួកអ្នកនឹងជាបុគ្គលសាបសូន្យចាកបុណ្យយ៉ាងនេះ អាត្មាមិនមានសេចក្តីត្រូវការដោយទេយ្យធម៌នេះទេ ប៉ុន្តែអាត្មាទទួលដើម្បីអនុគ្រោះដល់ពួកអ្នកតែម្យ៉ាង តាំងអំពីនោះមកភិក្ខុនោះ ក៏ទទួលចីវរច្រើនផង ទទួលបិណ្ឌបាតច្រើនផង ទទួលសេនាសនៈច្រើនផង ទទួលគិលានប្បច្ច័យភេសជ្ជបរិក្ខារច្រើនផង ។ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃភិក្ខុកុហក ភាពនៃភិក្ខុកុហក ឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុខាងការសេព ( បច្ច័យ ) ។ កុហនវត្ថុខាងឥរិយាបថតើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយប្រាថ្នាសេចក្តីសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏រៀបចំទំនងដើរ រៀបចំទំនងឈរ ក៏រៀបចំទំនងអង្គុយ រៀបចំទំនងដេក ប្រុងប្រៀបហើយទើបដើរទៅ ប្រុងប្រៀបឈរ ប្រុងប្រៀបអង្គុយ ប្រុងប្រៀបសម្រេចការដេក ដើរទៅហាក់ដូចជាមានចិត្តតាំងមាំ ឈរហាក់ដូចជាមានចិត្តតាំងមាំ អង្គុយហាក់ដូចជាមានចិត្តតាំងមាំ សម្រេចការដេកហាក់ដូចជាមានចិត្តតាំងមាំ ហាក់ដូចជាចូលឈានក្នុងទីចំពោះមុខ ( នៃអ្នកផង ) ។ ការតាំងទុកខាងដើម អាការនៃការតាំងទុក ការរៀបចំឥរិយាបថ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុអ្នកធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃភិក្ខុកុហក ភាពនៃភិក្ខុ

កុហកឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុខាងឥរិយាបថ ។ កុហនវត្ថុខាងការខ្សឹបជិតតើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ប្រាថ្នាសេចក្តីសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះក៏ពោលវាចាដែលអាស្រ័យអរិយធម៌ ពោលថា សមណៈណាទ្រទ្រង់ចីវរមានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ពោលថា សមណៈណាទ្រទ្រង់បាត្រមានសភាពយ៉ាងនេះ ទ្រទ្រង់ផ្តិលជាវិការៈនៃលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់តម្រងទឹក ទ្រទ្រង់កូនសោរ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថពន្ធចង្កេះ ទ្រទ្រង់សំពត់អាយោគ សមណៈនោះមានសក្តិធំ ។ ពោលថា ឧបជ្ឈាយ៍របស់សមណៈណាមានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ។ ពោលថា អាចារ្យរបស់សមណៈណាមានសភាពយ៉ាងនេះ ពួកភិក្ខុរបស់សមណៈណាមានសភាពយ៉ាងនេះ មានឧបជ្ឈាយ៍ស្មើគ្នា មានអាចារ្យស្មើគ្នា ជាមិត្ត មិត្តឃើញព្រម ជាសម្លាញ់ សមណៈនោះមានសក្តិធំ ។ ពោលថា សមណៈណានៅក្នុងវិហារមានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ។ ពោលថា សមណៈណានៅក្នុងបន្ទាមានសភាពយ៉ាងនេះ នៅក្នុងប្រាសាទ នៅក្នុងប្រាសាទមានកំពូល នៅក្នុងគុហា នៅក្នុងទីជ្រកកោន នៅក្នុងកុដិ នៅក្នុងផ្ទះមានកំពូល នៅក្នុងប៉ម នៅក្នុងរោង នៅក្នុងថែវ នៅក្នុងរោងឆាន់ នៅក្នុងបារាំ នៅជិតគល់ឈើ សមណៈនោះមានសក្តិធំ ។ មួយទៀតសមណៈជាអ្នកស្រងូតស្រងាត់ពេក មានមុខស្រពោនក្រៃពេក ជាអ្នកកុហកក្រៃពេក រួសរាយក្រៃពេក ត្រូវគេសរសើរដោយអំណាចមាត់ ( របស់

ខ្លួន ) ថា សមណៈនេះបានវិហារសមាបត្តិទាំងឡាយ ដ៏ស្ងប់ស្ងាត់នេះ មាន សភាពយ៉ាងនេះ ពោលពាក្យប្រាកដដូច្នោះ ជាពាក្យដ៏ជ្រៅ លំបាកយល់ ដ៏ល្អិតកំបាំង ជាវាចាប្រកបដោយសុញ្ញតនិព្វាន ជាលោកុត្តរ ។ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុជាអ្នកធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃភិក្ខុកុហក ភាពនៃភិក្ខុកុហកឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុខាងការខ្សឹបជិត ។ កុហនវត្ថុទាំង ៣ ប្រការនេះ ភិក្ខុណាលះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ ភិក្ខុនោះលោកហៅថា អ្នកមិនកុហក ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នករួញចិត្ត អ្នកមិនកុហក ។

[ ៧៨ ] ពាក្យថា អ្នកមិនមានសេចក្តីប្រាថ្នា អ្នកមិនមានសេចក្តីកំណាញ់ អធិប្បាយថា តណ្ហាលោកហៅថា សេចក្តីជាប់ចំពាក់ បានដល់ សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានេះភិក្ខុណាលះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ ភិក្ខុនោះលោកហៅថា អ្នកមិនមានសេចក្តីប្រាថ្នា ។ ភិក្ខុនោះមិនប្រាថ្នារូបទាំងឡាយ មិនប្រាថ្នា មិនប៉ងមិនត្រេកអរ មិនចង់បាន មិនជាប់ចិត្តនឹងសំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព

ចក្ខុវេញ្ញេយ្យ សោតវិញ្ញេយ្យ ... 

ចក្ខុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្នទិដ្ឋធម៌ដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានសេចក្តីប្រាថ្នា ។ ពាក្យថា អ្នកមិនមានសេចក្តីកំណាញ់ សេចក្តីថា សេចក្តីកំណាញ់ ៥ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់វណ្ណៈ ១ កំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ សេចក្តីកំណាញ់រឹង សេចក្តីស្វិតស្វាញ ភាពនៃបុគ្គលមិនយកចិត្ត ( នៃបុគ្គលដទៃ ) ឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្តីកំណាញ់ ។ មួយទៀតសេចក្តីកំណាញ់ខន្ធក៏ហៅថា កំណាញ់ សេចក្តីកំណាញ់ធាតុក៏ហៅថា កំណាញ់ សេចក្តីកំណាញ់អាយតនៈក៏ហៅថា កំណាញ់ ទាំងហៅថា ការប្រកាន់ នេះលោកហៅថា សេចក្តីកំណាញ់ ។ សេចក្តីកំណាញ់នេះបុគ្គលណាលះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានសេចក្តីកំណាញ់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានសេចក្តីប្រាថ្នា អ្នកមិនមានសេចក្តីកំណាញ់ ។

[ ៧៩ ] អធិប្បាយពាក្យថា អ្នកមិនមានការឃ្មើសឃ្មង ជាអ្នកដែលគេមិនគួរខ្ពើម ត្រង់ពាក្យថា ការឃ្មើសឃ្មង បានដល់ ការឃ្មើសឃ្មង ៣ គឺការឃ្មើសឃ្មងប៉ែកខាងកាយ ១ ការឃ្មើសឃ្មងប៉ែកខាងវាចា ១ ការឃ្មើសឃ្មងប៉ែកខាងចិត្ត ១ ។ ការឃ្មើសឃ្មងប៉ែកខាងកាយតើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ទៅក្នុងសង្ឃសម្តែងការឃ្មើសឃ្មង ប៉ែកខាងកាយខ្លះ ទៅក្នុង

គណៈសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយខ្លះ សម្តែងការឃ្មើសឃ្មងប៉ែកខាងកាយក្នុងរោងឆាន់ខ្លះ សម្តែងការឃ្មើសឃ្មងប៉ែកខាងកាយក្នុងរោងភ្លើងខ្លះ សម្តែងការឃ្មើសឃ្មងប៉ែកខាងកាយក្នុងកំពង់ទឹកខ្លះ កំពុងចូលទៅកាន់ចន្លោះផ្ទះសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយខ្លះចូលទៅហើយកាន់ចន្លោះផ្ទះសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយខ្លះ ។

ភិក្ខុទៅក្នុងសង្ឃសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះទៅក្នុងសង្ឃ មិនធ្វើសេចក្តីកោតក្រែង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុទៅក្នុងសង្ឃសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយយ៉ាងនេះឯង ។ ភិក្ខុទៅក្នុងគណៈសម្តែងនូវការឃ្មើសឃ្មងប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះទៅក្នុងគណៈមិនធ្វើសេចក្តីកោតក្រែង គឺកាលពួកភិក្ខុជាថេរៈមិនពាក់ស្បែកជើងចង្ក្រម ខ្លួនពាក់ស្បែកជើងចង្ក្រម កាលពួកភិក្ខុជាថេរៈចង្ក្រមក្នុងទីចង្ក្រមដ៏ទាប ខ្លួនចង្ក្រមក្នុងទីចង្ក្រមដ៏ខ្ពស់ កាលពួកភិក្ខុជាថេរៈចង្ក្រមលើផែនដី ខ្លួនចង្ក្រមក្នុងទីចង្ក្រម ឈរប្រជ្រៀតខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុទៅក្នុងគណៈសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយយ៉ាងនេះឯង ។

ភិក្ខុសម្តែងការឃ្មើសឃ្មងប៉ែកខាងកាយក្នុងរោងឆាន់ តើដូចម្តេច ។ ភិក្ខុ

ខ្លះក្នុងសាសនានេះមិនធ្វើសេចក្តីកោតក្រែងក្នុងរោងឆាន់ គឺអង្គុយប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុថ្មីដោយអាសនៈខ្លះ ឈរប្រជ្រៀតខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុសម្តែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងរោងឆាន់យ៉ាងនេះឯង ។

ភិក្ខុសម្តែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងរោងភ្លើង តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះមិនធ្វើសេចក្តីកោតក្រែងក្នុងរោងភ្លើង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ មិនប្រាប់សិនហើយដាក់ឧសខ្លះ មិនប្រាប់សិនហើយបិទទ្វារខ្លះ ភិក្ខុសម្តែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងរោងភ្លើងយ៉ាងនេះឯង ។

ភិក្ខុសម្តែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងកំពង់ទឹក តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះមិនធ្វើសេចក្តីកោតក្រែងក្នុងកំពង់ទឹក គឺចុះទៅប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ចុះទៅខាងមុខខ្លះ ងូតប្រជ្រៀតខ្លះ ងូតខាងមុខខ្លះ ងូតខាងលើខ្លះ ឡើងប្រជ្រៀតខ្លះ ឡើងខាងមុខខ្លះ ឡើងខាងលើខ្លះ ភិក្ខុសម្តែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងកំពង់ទឹកយ៉ាងនេះឯង ។

ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នងប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះកំពុងចូលទៅកាន់ចន្លោះផ្ទះ មិនធ្វើសេចក្តីកោតក្រែង គឺដើរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ដើរខាងមុខខ្លះ កន្ទងហើយដើរខាងមុខពួកភិក្ខុជាថេរៈខ្លះ ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើស

ឃ្នងប៉ែកខាងកាយយ៉ាងនេះឯង ។

ភិក្ខុចូលទៅហើយកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នងប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះចូលទៅកាន់ចន្លោះផ្ទះ គេមិនទាន់និយាយថា សូមចូលមកលោកម្ចាស់ ក៏ចូលទៅ គេមិនទាន់និយាយថា សូមឈរវេន៍សិនលោកម្ចាស់ ក៏ឈរវេន៍ គេមិនទាន់និយាយថា សូមគង់លោកម្ចាស់ ក៏អង្គុយ ចូលទៅកាន់ទីមិនមានឱកាសខ្លះ ឈរក្នុងទីមិនមានឱកាសខ្លះ អង្គុយក្នុងទីមិនមានឱកាសខ្លះ ម្នីម្នាចូលទៅក្នុងបន្ទប់ទាំងឡាយ របស់ត្រកូលទាំងឡាយ ជាទីលាក់ពួនបិទបាំង ដែលពួកស្ត្រីក្នុងត្រកូល ដែលពួកកូនស្រីរបស់ត្រកូល ដែលពួកកូនប្រសាស្រីរបស់ត្រកូល ដែលពួកកុមារីរបស់ត្រកូលកំពុងអង្គុយនោះខ្លះ ស្ទាបអង្អែលក្បាលរបស់កុមារតូចខ្លះ ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នងប៉ែកខាងកាយយ៉ាងនេះឯង ។ នេះការឃ្នើសឃ្នងប៉ែកខាងកាយ ។

ការឃ្នើសឃ្នងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះទៅក្នុងសង្ឃសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចាខ្លះ ទៅក្នុងគណៈសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចាខ្លះ ចូលទៅក្នុងចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នងប៉ែកខាងវាចាខ្លះ ។

ភិក្ខុទៅក្នុងសង្ឃសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ទៅក្នុងសង្ឃមិនធ្វើសេចក្តីកោតក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬ ( ពួកភិក្ខុជាថេរៈ ) មិនបានអារាធនាក៏សម្តែងធម៌ វិសជ្ជនាប្រស្នា

សម្តែងបាតិមោក្ខដល់ពួកភិក្ខុដែលទៅកាន់អារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុទៅក្នុងសង្ឃសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចាយ៉ាងនេះឯង ។

ភិក្ខុទៅក្នុងគណៈសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះទៅក្នុងគណៈមិនធ្វើសេចក្តីកោតក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬ ( ភិក្ខុជាថេរៈ ) មិនបានអារាធនាក៏សម្តែងធម៌ វិសជ្ជនាប្រស្នាដល់ពួកភិក្ខុដែលទៅកាន់អារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ សម្តែងធម៌ វិសជ្ជនាប្រស្នាដល់ពួកភិក្ខុនី ពួកឧបាសក ពួកឧបាសិកាដែលទៅកាន់អារាម ឈរនិយាយវាសដៃខ្លះ ភិក្ខុទៅក្នុងគណៈសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចាយ៉ាងនេះឯង ។

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះចូលទៅកាន់ចន្លោះផ្ទះ និយាយនឹងស្ត្រី ឬនឹងកុមារី និយាយរាក់ទាក់ថា នែនាងឈ្មោះនេះ នែនាងគោត្តនេះ មានអ្វីទេ មានបបរទេ មានបាយទេ មានបង្អែមទេ អាត្មានឹងផឹកអ្វី បរិភោគអ្វី ស៊ីអ្វី មានអ្វីទេ ពួកនាងនឹងឲ្យអ្វីដល់អាត្មា ភិក្ខុចូលទៅកាន់ចន្លោះផ្ទះសម្តែងការឃ្នើសឃ្នងប៉ែកខាងវាចាយ៉ាងនេះឯង ។ នេះការឃ្នើសឃ្នងប៉ែកខាងវាចា ។

ការឃ្នើសឃ្នងប៉ែកខាងចិត្ត តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះជាអ្នកមិនមែន ( ចេញ ) អំពីត្រកូលខ្ពស់ហើយបួសទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែល ( ចេញ ) អំពីត្រកូលខ្ពស់ហើយបួស ។ មិនមែនចេញអំពីត្រកូលធំហើយបួសទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែល ( ចេញ ) អំពី

ត្រកូលធំហើយបួស ។ មិនមែន ( ចេញ ) អំពីត្រកូលមានភោគៈច្រើនហើយបួសទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែល ( ចេញ ) អំពីត្រកូលមានភោគៈច្រើនហើយបួស ។ មិនមែន ( ចេញ ) អំពីត្រកូលមានភោគៈលើសលុបហើយបួសទេ ។ មិនចេះព្រះសូត្រទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែលចេះព្រះសូត្រ ។ មិនទ្រទ្រង់ព្រះវិន័យ ។ មិនមែនជាធម្មកថិក ។ មិនប្រព្រឹត្តអារញ្ញិកធុតង្គ ។ មិនប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ។ មិនប្រព្រឹត្តបង្សុកូលិកធុតង្គ ។ មិនប្រព្រឹត្តតេចីវរិកធុតង្គ ។ មិនប្រព្រឹត្តសបទានចារិកធុតង្គ ។ មិនប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ ។ មិនប្រព្រឹត្តនេសជ្ជិកធុតង្គ ។ មិនប្រព្រឹត្តយថាសន្ថតិកធុតង្គ ។ មិនបានបឋមជ្ឈានទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គល ដែលបានបឋមជ្ឈាន ។បេ។ មិនបាននេវសញ្ញានាសញ្ញាយតនសមាបត្តិទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ នេះការឃ្មើសឃ្មង់ប៉ែកខាងចិត្ត ។ ការឃ្មើសឃ្មង ៣ នេះ បុគ្គលណាលះបង់ ផ្តាច់បង់ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង បានដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានការឃ្មើសឃ្មង ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានការឃ្មើសឃ្មង ។

[ ៨០ ] ពាក្យថា ជាអ្នកដែលគេមិនគួរខ្ពើម អធិប្បាយថា បុគ្គលដែលគេគួរខ្ពើមក៏មាន ដែលគេមិនគួរខ្ពើមក៏មាន ។ បុគ្គលដែលគេគួរខ្ពើម តើដូចម្តេច ។ បុគ្គលខ្លះក្នុងសាសនានេះជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានមារយាទ ដែលបុគ្គលគួររពឹកឃើញ ដោយសេចក្តីរង្កៀសថា មិនស្អាតមាន

អំពើបិទបាំងទុក មិនមែនជាសមណៈប្ដេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រហ្មចារីបុគ្គលប្ដេជ្ញាខ្លួនថាជាព្រហ្មចារីបុគ្គលជាអ្នកស្អុយក្នុងដោយរាគៈ ជាបុគ្គលជ្រោកជ្រាក នេះហៅថា បុគ្គលដែលគេគួរវៀរ ។ មួយទៀតបុគ្គលជាអ្នកក្រោធ ច្រើនដោយសេចក្ដីចង្អៀតចង្អល់សូម្បីគេនិយាយតិចតួចក៏រមែងចាប់ថ្នាក់ ខឹង គុំគួន តបត ធ្វើនូវសេចក្ដីក្រោធ ប្រទូស្ដ អាក់អន់ឲ្យប្រាកដ នេះហៅថា បុគ្គលដែលគេគួរវៀរ ។ មួយវិញទៀតបុគ្គលជាអ្នកក្រោធ ចងសេចក្ដីក្រោធទុក លុបគុណគេ វាយឫកស្មើ ច្រណែន កំណាញ់ អួតអាងមានមាយា រឹងរូស មើលងាយគេ មានប្រាថ្នាដ៏លាមក មានសេចក្ដីយល់ខុស ប្រកាន់តាមសេចក្ដីយល់របស់ខ្លួន ប្រកាន់មាំ ជាអ្នកលះបង់បានដោយកម្រ នេះហៅថា បុគ្គលដែលគេគួរវៀរ ។

បុគ្គលដែលគេមិនគួរវៀរ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ នេះហៅថា បុគ្គលដែលគេមិនគួរវៀរ ។ មួយទៀតភិក្ខុជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្ដីចង្អៀតចង្អល់ បើទុកជាគេនិយាយច្រើន ក៏មិនចាប់ថ្នាក់ មិនខឹង មិនគុំគួន មិនតបត មិនធ្វើនូវសេចក្ដីក្រោធ សេចក្ដីប្រទូស្ដនិងសេចក្ដីអាក់អន់ឲ្យប្រាកដ នេះហៅថា បុគ្គលដែលគេមិនគួរវៀរ ។ មួយវិញទៀតបុគ្គលជាអ្នកមិនក្រោធ មិនចងសេចក្ដីក្រោធទុក មិនលុបគុណគេ មិនវាយឫកស្មើ មិនច្រណែន មិនកំណាញ់ មិនអួតអាង មិនមានមាយា

មិនរឹងត្អឹង មិនមើលងាយគេ មិនមានសេចក្តីប្រាថ្នាដ៏លាមក មិនមានសេចក្តីយល់ខុស មិនប្រកាន់តាមសេចក្តីយល់របស់ខ្លួន មិនប្រកាន់មាំ ជាអ្នកលះបង់បានដោយងាយ នេះហៅថា បុគ្គលដែលគេមិនគួរខ្ពើម ។ អរិយបុគ្គលទាំងអស់រាប់ទាំងកល្យាណបុថុជ្ជន ឈ្មោះថា បុគ្គលដែលគេមិនគួរខ្ពើម ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនមានការឃើញសយ្ហងជាអ្នកដែលគេមិនគួរខ្ពើម ។

[ ៨១ ] ពាក្យថា បុគ្គលមិនប្រកបក្នុងការញុះញង់ ត្រង់ពាក្យថា ការញុះញង់ អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកនិយាយញុះញង់ គឺឮអំពីពួកជននេះ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះប្រាប់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះ ឬក៏ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាក្តី ថែមកម្លាំងដល់ពួកជនដែលបែកគ្នាហើយក្តី ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរហើយក្នុងពួក រីករាយក្នុងពួក ជាអ្នកនិយាយនូវពាក្យជាគ្រឿងធ្វើនូវពួក នេះលោកហៅថា ការញុះញង់ ។ មួយទៀតបុគ្គលរមែងសន្សំការញុះញង់ដោយហេតុពីរ គឺដោយសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់ ឬដោយសេចក្តីប៉ុនប៉ងដើម្បីបំបែក ។

បុគ្គលសន្សំការញុះញង់ព្រោះសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់ តើដូចម្តេច ។ បុគ្គលសន្សំការញុះញង់ ព្រោះសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់យ៉ាងនេះ ដូចនេះថា អាត្មាអញនឹងបានជាទីស្រឡាញ់នៃជននេះ នឹងបានជាទីពេញចិត្ត នឹងបានជាទីស្និទ្ធស្នាល នឹងបានជាអ្នកនៅខាងក្នុង នឹងបានជាអ្នកមានចិត្តល្អ ។

បុគ្គលមានសេចក្តីប៉ុនប៉ងដើម្បីបំបែក រមែងសន្សំការញុះញង់ តើដូច

ម្តេច ។

បុគ្គលមានសេចក្តីប៉ុនប៉ងដើម្បីបំបែក រមែងសន្សំការញុះញង់យ៉ាងនេះថា ធ្វើម្តេចឲ្យពួកជននេះផ្សេងៗពីគ្នា ទីទៃពីគ្នា ជាពួក ជាចំណែកពីរ បែកគ្នាជាពីរ ជាពីរក្រុម គប្បីបែកគ្នា មិនគប្បីប្រួបរួមគ្នា នៅជាទុក្ខមិនសប្បាយ ។

ការញុះញង់នុ៎ះដែលបុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះមិនប្រកប មិនឈម មិនជ្វាក់ មិនស្រួបចុះក្នុងការញុះញង់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងមិនប្រកបក្នុងការញុះញង់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលអ្នកក្រួញចិត្ត អ្នកមិនកុហក អ្នកមិនមានសេចក្តីប្រាថ្នា អ្នក
មិនមានសេចក្តីកំណាញ់ អ្នកមិនមានការឃ្នើសឃ្នង អ្នកដែល
គេមិនគួរខ្ពើមរមែងជាអ្នកមិនប្រកបក្នុងការញុះញង់ ។

[ ៨២ ] បុគ្គលអ្នកមិនស្រស់ស្រាយក្នុងវត្ថុជាទីត្រេកអរផង អ្នកមិនប្រកបក្នុងការមើលងាយផង អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញា វាងវៃផងរមែងជាអ្នកមិនមានជំនឿមិនប្រាសចាកតម្រេក ។

[ ៨៣ ] ពាក្យថា អ្នកមិនស្រស់ស្រាយក្នុងវត្ថុជាទីត្រេកអរ អធិប្បាយថា កាមគុណ ៥ លោកហៅថា វត្ថុជាទីត្រេកអរ ។ កាមគុណ ៥ លោកហៅថា វត្ថុជាទីត្រេកអរ តើព្រោះហេតុអ្វី ។ ( ព្រោះថា ) ពួកទេវតានិងមនុស្សច្រើនតែចង់បាន ត្រេកអរ ប្រាថ្នា ស្រឡាញ់ ក្តួចកាន់នូវកាមគុណ ៥

ហេតុនោះកាមគុណ ៥ លោកហៅថា វត្ថុជាទីត្រេកអរ ។ តណ្ហាជាទីត្រេកអរនុ៎ះដែលពួកជនណាមិនទាន់លះបង់ហើយ រូបតណ្ហារបស់ជននោះរមែងផ្សាយទៅ រសាត់ទៅ ហូរទៅ ប្រព្រឹត្តទៅតាមចក្ខុ ។ សទ្ទតណ្ហាតាមសោតៈ ។ គន្ធតណ្ហាតាមឃានៈ ។ រសតណ្ហាតាមជិវ្ហា ។ ផោដ្ឋព្វតណ្ហាតាមកាយ ។ ធម្មតណ្ហារមែងផ្សាយទៅ រសាត់ទៅ ហូរទៅ ប្រព្រឹត្តទៅតាមចិត្ត ។ តណ្ហាជាទីត្រេកអរនុ៎ះដែលពួកជនណាបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ រូបតណ្ហារបស់ពួកជននោះរមែងមិនផ្សាយទៅ មិនរសាត់ទៅ មិនហូរទៅ មិនប្រព្រឹត្តទៅតាមចក្ខុ ។ សទ្ទតណ្ហាតាមសោត ។បេ។ ធម្មតណ្ហារមែងមិនផ្សាយ មិនរសាត់ទៅ មិនហូរទៅ មិនប្រព្រឹត្តទៅតាមចិត្ត ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនស្រស់ស្រាយក្នុងវត្ថុជាទីត្រេកអរ ។

[ ៨៤ ] ពាក្យថា អ្នកមិនប្រកបក្នុងការមើលងាយ អធិប្បាយថា ចុះការមើលងាយ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះរមែងមើលងាយបុគ្គលដទៃដោយជាតិ ឬដោយគោត្ត ។បេ។ ឬក៏ដោយវត្ថុណាមួយ ។ មានះ អាការមានះ ភាពនៃមានះ ការឆ្មើងឆ្មៃ អាការឆ្មើងឆ្មៃ ចិត្តដូចទង់ជ័យ ការប្រកាន់ចិត្ត ភាពនៃចិត្តប្រាថ្នាដូចជង់ទង់ឯណាមានសភាពបែបនេះ នេះហៅថា សេចក្ដីមើលងាយ ។ សេចក្ដីមើលងាយនុ៎ះ បុគ្គលណាបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះមិនប្រកប មិនឈម មិនជាក់ មិនស្រេបចុះក្នុងសេចក្ដីមើលងាយ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនប្រកបក្នុងការមើលងាយ ។

[ ៨៥ ] ពាក្យថា អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញាវាងវៃផង អធិប្បាយថា ដែលឈ្មោះថាអ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយកាយកម្មដ៏ទន់ភ្លន់ ។ ដោយវចីកម្មដ៏ទន់ភ្លន់ ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយមនោកម្មដ៏ទន់ភ្លន់ ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយសតិប្បដ្ឋានដ៏ល្អិត ។ ដោយសម្មប្បធានដ៏ល្អិត ។ ដោយឥទ្ធិបាទដ៏ល្អិត ។ ដោយឥន្ទ្រិយ៍ដ៏ល្អិត ។ ដោយពលៈដ៏ល្អិត ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយពោជ្ឈង្គដ៏ល្អិត ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយអរិយមគ្គមានអង្គ ៨ ដ៏ល្អិត ។

[ ៨៦ ] ពាក្យថា អ្នកមានប្រាជ្ញាវាងវៃ បានដល់ បុគ្គលអ្នកមានប្រាជ្ញាវាងវៃ ៣ ពួក គឺបុគ្គលមានបរិយត្តិប្បដិភាណ ( មានប្រាជ្ញាវាងវៃព្រោះអាស្រ័យការរៀនសូត្រ ) ១ មានបរិបុច្ឆាបដិភាណ ( មានប្រាជ្ញាវាងវៃព្រោះអាស្រ័យការសាកសួរ ) ១ មានអធិគមប្បដិភាណ ( មានប្រាជ្ញាវាងវៃព្រោះអាស្រ័យការត្រាស់ដឹង ) ១ ។

បុគ្គលអ្នកមានបរិយត្តិប្បដិភាណ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះបានរៀនពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តិកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ការចេះដឹងរមែងភ្លឺច្បាស់ដល់បុគ្គលនោះព្រោះអាស្រ័យការរៀនសូត្រ ។ នេះបុគ្គលមានបរិយត្តិប្បដិភាណ ។

បុគ្គលអ្នកមានបរិបុច្ឆាបដិភាណ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ

ជាអ្នកសាកសួរ ក្នុងប្រយោជន៍របស់ខ្លួនផង ក្នុងប្រយោជន៍នៃការចេះដឹងផង ក្នុងលក្ខណៈផង ក្នុងហេតុផង ក្នុងការណ៍ គួរនិងការណ៍មិនគួរផង ។ ការចេះដឹងរមែងភ្លឺច្បាស់ដល់បុគ្គលនោះព្រោះអាស្រ័យការសាកសួរនោះ ។ នេះបុគ្គលមានបរិបុច្ឆាបដិភាណ ។

បុគ្គលមានអធិគមប្បដិភាណ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នកត្រាស់ដឹងសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ។ បុគ្គលនោះយល់អត្ថ យល់ធម៌ យល់និរុត្តិ ។ អត្ថរមែងភ្លឺច្បាស់ក្នុងសេចក្តីដែលខ្លួនដឹង ។ ធម៌រមែងភ្លឺច្បាស់ក្នុងធម៌ដែលខ្លួនដឹង ។ និរុត្តិរមែងភ្លឺច្បាស់ក្នុងនិរុត្តិដែលខ្លួនដឹង ។ ញាណក្នុងសភាវៈទាំងបីនេះឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បុគ្គលណាព្រមព្រៀង មូលមិត្ត ចូលទៅជិត អែបនែបកៀកកើយ ផ្តេកផ្តិត ប្រកបដោយបដិភាណប្បដិសម្ភិទានេះ បុគ្គលនោះលោកហៅថា អ្នកមានបដិភាណ ។ បរិយត្តិមិនមានដល់បុគ្គលណា ការសាកសួរក៏មិនមាន ការត្រាស់ដឹងក៏មិនមាន ការចេះដឹងនឹងភ្លឺច្បាស់ដល់បុគ្គលនោះដូចម្តេចបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញាវាងវៃផង ។

[ ៨៧ ] អធិប្បាយពាក្យថា រមែងជាអ្នកមិនមានជំនឿ មិនប្រាសចាកតម្រេក ត្រង់ពាក្យថា មិនមានជំនឿ សេចក្តីថា បុគ្គលរមែងមិនជឿធម៌ដែលខ្លួនដឹងដោយខ្លួនឯង ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនហើយ ( អំពីសម្នាក់ )

របស់បុគ្គលណាមួយ ទោះជាសមណៈជទៃក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ។ រមែងមិនជឿធម៌ដែលខ្លួនដឹងដោយខ្លួនឯងហើយ ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនហើយ ( អំពីសម្នាក់ ) របស់បុគ្គលណាមួយ ទោះជាសមណៈជទៃក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តីថា សង្ខារទាំងឡាយទាំងពួងមិនទៀង ។ ថាសង្ខារទាំងឡាយទាំងពួងជាទុក្ខ ។ ថាធម៌ទាំងឡាយទាំងពួងជាអនត្តា ។ ថាសង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ថាជរាមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ។ ថាការរលត់នៃសង្ខារព្រោះការរលត់អវិជ្ជា ។បេ។ ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ។ ថានេះទុក្ខ ។បេ។ ថានេះទុក្ខនិរោធគាមិនីបដិបទា ។ ថានេះអាសវៈទាំងឡាយ ។បេ។ ថានេះអាសវនិរោធគាមិនីបដិបទា ។ ថានេះធម៌ដែលត្រូវដឹង ។បេ។ ថានេះធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។ ( បុគ្គលរមែងមិនជឿ ) នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃផស្សាយតនៈទាំង ៦ នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃឧបាទានក្ខន្ធ ៥ នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃមហាភូតរូប ៤ ។ បុគ្គលរមែងមិនជឿធម៌ដែលខ្លួនដឹងដោយខ្លួនឯងហើយ ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនហើយ ( អំពីសម្នាក់ ) របស់បុគ្គលណាមួយ ទោះជាសមណៈជទៃក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តីថា ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ

មានកិរិយារលត់ទៅជាធម្មតា ។ ពិតណាស់ពាក្យនុ៎ះ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត អ្នកជឿដែរឬថា សទ្ធិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ ( ព្រះសារីបុត្តក្រាបទូលថា ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនលុះក្នុងការជឿតាមព្រះមានព្រះភាគក្នុងហេតុនុ៎ះថា សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុតដូច្នេះទេ បពិត្រព្រះអង្គដ៏ចម្រើន គុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលពួកជនណាមិនដឹង មិនឃើញ មិនយល់ មិនបានធ្វើឲ្យជាក់ច្បាស់ មិនប៉ះពាល់ដោយប្រាជ្ញាតាមពិតទេ ពួកជនទាំងនោះ គប្បីលុះក្នុងការជឿតាមពួកជនដទៃ ក្នុងហេតុនោះថា សទ្ធិ-ន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងគុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលពួកជនណាបានដឹង ឃើញ យល់ ធ្វើឲ្យជាក់ច្បាស់ ប៉ះពាល់ដោយប្រាជ្ញាហើយ ពួកជននោះជាអ្នកមិនមានសេចក្ដីសង្ស័យ មិនមានសេចក្ដីងឿងឆ្ងល់ក្នុងហេតុនោះថា សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ

ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងគុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលខ្ញុំព្រះអង្គបានដឹង ឃើញ យល់ ធ្វើឲ្យជាក់ច្បាស់ ប៉ះពាល់ដោយប្រាជ្ញាហើយ ខ្ញុំព្រះអង្គ មិនមានសេចក្តីសង្ស័យ មិនមានសេចក្តីងឿងឆ្ងល់ក្នុងហេតុនោះថា សទ្ធិន្ទ្រិយ វីរិយិ-ន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ ( ព្រះមានព្រះភាគទ្រង់សរសើរថា ) ម្នាលសារីបុត្ត ប្រពៃហើយ ប្រពៃហើយ ម្នាលសារីបុត្ត ពិតណាស់គុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលពួកជនណាមិនទាន់ដឹង មិនទាន់ឃើញ មិនទាន់យល់ មិនទាន់ធ្វើឲ្យជាក់ច្បាស់ មិនទាន់ប៉ះពាល់ដោយប្រាជ្ញាទេ ពួកជននោះគប្បីលុះក្នុងការជឿតាមជនដទៃក្នុងហេតុនោះថា សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។

ជនណាជាអ្នកមិនជឿផង ជាអ្នកដឹងនូវព្រះនិព្វានដែលបុគ្គល
មិនធ្វើផង ជាអ្នកកាត់តំណផង ជាអ្នកមានឱកាសកម្ចាត់បង់
ហើយផង ជាអ្នកខ្ជាក់ចោលនូវសេចក្តីប៉ុនប៉ងផង ជននោះឯង
ឈ្មោះថា ឧត្តមបុរស ។

ពាក្យថា មិនប្រាសចាកតម្រេក អធិប្បាយថា ពួកពាលបុថុជ្ជនទាំងអស់

រមែងត្រេកអរ សេក្ខបុគ្គល ៧ ពួក រាប់ទាំងកល្យាណបុថុជ្ជន រមែងទ្រាន់ ព្រះអរហន្តមិនត្រេក មិនទ្រាន់ ។ ព្រះអរហន្តនោះ ជាអ្នកប្រាសចាកតម្រេក ព្រោះការអស់រាគៈ ហេតុតែលោកប្រាសចាករាគៈព្រោះការអស់ទោសៈ ហេតុតែលោកប្រាសចាកទោសៈ ព្រោះការអស់មោហៈ ហេតុតែលោកប្រាសចាកមោហៈ ។ ព្រះអរហន្តនោះមានការអប់រំនៅស្រេចហើយ មានការប្រព្រឹត្តសន្សំហើយ ។បេ។ ការកើតទៀតរបស់ព្រះអរហន្តនោះមិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមានជំនឿ មិនប្រាសចាកតម្រេក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលអ្នកមិនស្រស់ស្រាយ ក្នុងវត្ថុជាទីត្រេកអរផង អ្នកមិន
ប្រកបក្នុងការមើលងាយផង អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញា
វាងវៃផងរមែងជាអ្នកមិនមានជំនឿ មិនប្រាសចាកតម្រេក ។

[ ៨៨ ] បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភផង មិនក្រោធព្រោះមិនមានលាភផង មិនអាក់អន់ព្រោះតណ្ហាផង មិនជាប់ព្រោះរសផង ។

[ ៨៩ ] ពាក្យថា បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភផង មិនក្រោធព្រោះមិនមានលាភផង អធិប្បាយថា បុគ្គលសិក្សាព្រោះលាភតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះឃើញភិក្ខុជាអ្នកមានលាភខាងចីវរ បិណ្ឌ-បាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុ

ដូចម្តេចហ្ន៎ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះជាអ្នកចេះព្រះសូត្រ លោកមានអាយុនេះ ទើបជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយដោយហេតុនោះ ។ ភិក្ខុនោះកាលខ្នះខ្នែងរកលាភក៏រៀនយកព្រះសូត្រ ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះលាភជាហេតុ ព្រោះការកើតឡើងនៃលាភ បុគ្គលសិក្សាព្រោះប្រាថ្នាលាភយ៉ាងនេះឯង ។ មួយទៀតភិក្ខុឃើញភិក្ខុជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុដូចម្តេចហ្ន៎ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះជាអ្នកទ្រទ្រង់វិន័យ ។បេ។ ជាអ្នកចេះអភិធម្ម ទើបលោកមានអាយុនេះជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយដោយហេតុនោះ ។ ភិក្ខុនោះកាលខ្នះខ្នែងរកលាភ ក៏រៀនអភិធម្មព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះលាភជាហេតុ ព្រោះការកើតឡើងនៃលាភ ។ បុគ្គលសិក្សាព្រោះប្រាថ្នាលាភយ៉ាងនេះឯង ។ មួយទៀតភិក្ខុឃើញភិក្ខុជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជ-បរិក្ខារទាំងឡាយ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុដូចម្តេចហ្ន៎ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា

លោកមានអាយុនេះជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បំសុកូលិ-កធុតង្គ តេចីវរិកធុតង្គ សបទានចារិកធុតង្គ ខលុបច្ឆាភត្តិកធុតង្គ នេសជ្ជិក-ធុតង្គ យថាសន្ថតិកធុតង្គ ទើបលោកមានអាយុនេះជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុនោះ ភិក្ខុនោះកាលខ្នះខ្នែងរកលាភ ទើបជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ។បេ។ យថាសន្ថតិកធុតង្គព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះលាភជាហេតុ ព្រោះការកើតឡើងនៃលាភ ។ បុគ្គលសិក្សាព្រោះប្រាថ្នាលាភយ៉ាងនេះឯង ។

បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះមិនមែនព្រោះហេតុនៃលាភ មិនមែនព្រោះបច្ច័យនៃលាភ មិនមែនព្រោះលាភជាហេតុ មិនមែនព្រោះការកើតឡើងនៃលាភទេ កាលមិនខ្នះខ្នែងរកលាភ ក៏រៀនព្រះសូត្រ រៀនព្រះវិន័យ រៀនព្រះអភិធម្ម ដើម្បីទូន្មានខ្លួន ដើម្បីរម្ងាប់ចិត្ត ដើម្បីរំលត់ចិត្តតែប៉ុណ្ណោះ បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភយ៉ាងនេះឯង ។ មួយទៀត ភិក្ខុមិនមែនព្រោះហេតុនៃលាភ មិនមែនព្រោះបច្ច័យនៃលាភ មិនមែនព្រោះលាភជាហេតុ មិនមែនព្រោះការកើតឡើងនៃលាភទេ កាលមិនខ្នះខ្នែងរកលាភ អាស្រ័យសេចក្តីមិនប្រាថ្នា អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីដូរផង់ អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យវត្ថុដែលមានតែម្យ៉ាងប៉ុណ្ណោះ ហើយជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បំសុកូលិក-ធុតង្គ តេចីវរិកធុតង្គ សបទានចារិកធុតង្គ ខលុបច្ឆាភត្តិកធុតង្គ នេសជ្ជិកធុតង្គ

យថាសន្តុដ្ឋិកវត្តេ បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភយ៉ាងនេះឯង ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភ ។

[ ៩០ ] ពាក្យថា បុគ្គលមិនក្រោធព្រោះមិនមានលាភផង អធិប្បាយថា បុគ្គលមិនក្រោធ ព្រោះមិនមានលាភ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះក្រោធ គុំគួន បៀតបៀន ធ្វើនូវសេចក្តីក្រោធ ការប្រទូស្ត ការអាក់អន់ឲ្យប្រាកដដោយគិតថា អាត្មាអញមិនបានត្រកូល ( ឧបដ្ឋាក ) ក្តី មិនបានពួកក្តី មិនបានអាវាសក្តី មិនបានលាភក្តី មិនបានយសក្តី មិនបានសេចក្តីសរសើរក្តី មិនបានសុខក្តី មិនបានចីវរក្តី មិនបានបិណ្ឌបាតក្តី មិនបានសេនាសនៈក្តី មិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារក្តី មិនបានអ្នកបម្រើជំងឺក្តី អាត្មាអញមិនមែនជាអ្នកល្បីឈ្មោះ ។ បុគ្គលក្រោធព្រោះមិនមានលាភយ៉ាងនេះឯង ។

បុគ្គលមិនក្រោធព្រោះមិនមានលាភ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះមិនក្រោធ មិនគុំគួន មិនថ្នាំងថ្នាក់ មិនធ្វើនូវសេចក្តីក្រោធ ការប្រទូស្ត ការអាក់អន់ឲ្យប្រាកដថា អាត្មាអញមិនបានត្រកូលក្តី មិនបានពួកក្តី មិនបានអាវាសក្តី មិនបានលាភក្តី មិនបានយសក្តី មិនបានសេចក្តីសរសើរក្តី មិនបានសុខក្តី មិនបានចីវរក្តី មិនបានបិណ្ឌបាតក្តី មិនបានសេនាសនៈក្តី មិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារក្តី មិនបានអ្នកបម្រើជំងឺក្តី អាត្មាអញមិនមែនជាអ្នកល្បីឈ្មោះ ។ បុគ្គលមិនក្រោធព្រោះមិនមានលាភយ៉ាងនេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនសិក្សាដើម្បីលាភផង មិនក្រោធព្រោះមិនមានលាភផង ។

[ ៩១ ] អធិប្បាយពាក្យថា មិនអាក់អន់ព្រោះតណ្ហាផង មិនជាប់ព្រោះរសផង ត្រង់ពាក្យថា ការអាក់អន់ មានសេចក្តីថា ការបៀតបៀន ការថ្នាំងថ្នាក់ ការខឹង ការក្រោធ ការខឹងញ៉័រ ការក្រោធខ្លាំង ការអាក់អន់ ការប្រទូស្ត ការប្រទូស្តខ្លាំងនៃចិត្ត ការគុំគួននៃចិត្ត ការប្រទូស្តក្នុងចិត្ត ការក្រេវក្រោធ អាការក្រោធ ភាពនៃចិត្តក្រោធ ការអាក់អន់ អាការអាក់អន់ ភាពនៃចិត្តអាក់អន់ ការគុំគួន អាការគុំគួន ភាពនៃចិត្តគុំគួន កំហឹង កំហឹងតបភាពនៃចិត្តកាច ការសម្រក់ទឹកភ្នែក ភាពនៃចិត្តមិនត្រេកអរឯណា នេះហៅថា ការអាក់អន់ ។ ការអាក់អន់ ភិក្ខុណាបានលះបង់ ផ្តាច់ផ្តិល ធ្វើឲ្យស្ងប់ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ភិក្ខុនោះលោកហៅថា អ្នកមិនអាក់អន់ ។ ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទ-តណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថារស គឺរសនៃឫសគល់ឬមើម រសដើម រសសំបក រសស្លឹក រសផ្កា រសផ្លែ រសជូរផ្អែម ល្វីង ហឹរ ប្រៃ ខារ ជូរអែម ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ត្រជាក់ ក្តៅ ។ ពួកសមណព្រាហ្មណ៍ខ្លះ ជាអ្នកជាប់ក្នុងរស ពួកសមណព្រាហ្មណ៍ទាំងនោះដើរស្វែងរករសដ៏ប្រសើរព្រោះចុងអណ្តាត ។ ពួកសមណព្រាហ្មណ៍នោះបានរសជូរស្វែងរករសមិនជូរ បានរសមិនជូរស្វែងរករសជូរ ។ បានរសផ្អែមស្វែងរករសមិនផ្អែម បានរសមិនផ្អែមស្វែងរករសផ្អែម ។ បានរសល្វីងស្វែងរករសមិនល្វីង បានរសមិនល្វីងស្វែងរករសល្វីង ។ បានរសហឹរស្វែងរករសមិនហឹរបានរសមិនហឹរ ស្វែងរករសហឹរ ។ បានរសប្រៃស្វែងរករសមិនប្រៃ បានរស

មិនប្រៃស្វែងរករសប្រៃ ។ បានរសខារ ស្វែងរករសមិនខារ បានរសមិនខារ ស្វែងរករសខារ ។ បានរសជូរអែមស្វែងរករសចត់ បានរសចត់ស្វែងរករសជូរអែម ។ បានរសឆ្ងាញ់ស្វែងរករសមិនឆ្ងាញ់ បានរសមិនឆ្ងាញ់ស្វែងរករសឆ្ងាញ់ ។ បានរសត្រជាក់ស្វែងរករសក្តៅ បានរសក្តៅស្វែងរករសត្រជាក់ ។ ពួកសមណព្រាហ្មណ៍នោះបានរសណាៗ មិនសន្តោសនឹងរសនោះៗ រមែងស្វែងរករសប្លែកៗ ជាអ្នកត្រេកអរ ញៀន ល្មោភ ទ្បិបទ្បប់ ជ្រុលជ្រប់ជាប់ចិត្ត ចំពាក់ លង់នៅក្នុងរសទាំងឡាយដែលជាទីពេញចិត្ត ។ តណ្ហាក្នុងរស ភិក្ខុណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ភិក្ខុនោះពិចារណាដោយឧបាយ រមែងបរិភោគអាហារដោយគិតថា អាត្មាអញបរិភោគមិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង ( បរិភោគ ) ដើម្បីតាំងនៅនៃកាយនេះ ដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យតែប៉ុណ្ណោះ អាត្មាអញកម្ចាត់បង់វេទនាចាស់ ( ឃ្លាន ) ទាំងមិនឲ្យវេទនាថ្មី ( ឆ្អែតហួស ) កើតឡើង ការត្រាច់ទៅ ( ដោយឥរិយាបថ ) ផង ការមិនមានទោសផង ការនៅជាសុខសប្បាយផង នឹងមានដល់អាត្មាអញដោយឧបាយដូចនេះ ។ បុគ្គលលាបដំបៅ ដើម្បីប្រយោជន៍ឲ្យជុះ ( សាច់ ) តែប៉ុណ្ណោះយ៉ាងណាមិញ មួយទៀតបុគ្គលលាបភ្លៅរទេះ ដើម្បីប្រយោជន៍ដល់ការផ្ទុកការៈតែប៉ុណ្ណោះយ៉ាងណាមិញ មួយវិញទៀតបុគ្គលបរិភោគអាហារ គឺសាច់កូន ដើម្បីប្រយោជន៍ដល់ការឆ្លងនូវកន្តារ

តែប៉ុណ្ណោះយ៉ាងណាមិញ ភិក្ខុពិចារណាដោយឧបាយ បរិភោគអាហារដោយគិតថា អាត្មាអញបរិភោគមិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង ( បរិភោគ ) ដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យតែប៉ុណ្ណោះ អាត្មាអញកម្ចាត់បង់វេទនាចាស់ ទាំងមិនឲ្យវេទនាថ្មីកើតឡើង ការគ្រាច់ទៅ ( ដោយឥរិយាបថ ) ផង ការមិនមានទោសផង ការនៅជាសុខសប្បាយផង នឹងមានដល់អាត្មាអញដោយឧបាយដូចនេះ ភិក្ខុរមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើតណ្ហាក្នុងរសមិនឲ្យកើតមាន ជាអ្នកចៀសវាង វៀរស្រឡះ ប្រាសចេញចាកតណ្ហាក្នុងរស មានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនអាក់អន់ព្រោះតណ្ហាផង មិនជាប់ព្រោះរសផង ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភផង មិនក្រោធព្រោះមិនមាន
លាភផង មិនអាក់អន់ព្រោះតណ្ហាផង មិនជាប់ព្រោះរសផង ។

[ ៩២ ] បុគ្គលណាជាអ្នកព្រងើយកន្តើយ មានស្មារតីគ្រប់កាល មិនប្រកាន់ថាស្មើ មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោកទាបក្នុងលោកធម៌ជាគ្រឿងដុះដាលរបស់បុគ្គលនោះមិនមានទេ ។

[ ៩៣ ] អធិប្បាយពាក្យថា ជាអ្នកព្រងើយកន្តើយ មានស្មារតីគ្រប់កាល ត្រង់ពាក្យថា ព្រងើយកន្តើយ សេចក្តីថា បុគ្គលប្រកបដោយធម្មជាតិឧបេក្ខា ឃើញរូបដោយភ្នែកហើយ ជាអ្នកមិនមានចិត្តត្រេកអរ មិនមានចិត្តអាក់អន់

ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងខ្លួន ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ ប៉ះពាល់ផ្សព្វដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកមិនមានចិត្តត្រេកអរ មិនមានចិត្តអាក់អន់ ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងខ្លួន ។ ឃើញរូបដោយភ្នែកហើយ មិនត្រូវការ មិនត្រេកអរចំពោះអារម្មណ៍ជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ។ កាយរបស់បុគ្គលនោះក៏តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសន្តាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ( ចាកអាសវៈ ) ។ ឃើញរូបដោយភ្នែក ជាអ្នកមិនស្អប់ចំពោះអារម្មណ៍ មិនជាទីពេញចិត្ត មានចិត្តមិនអាក់អន់ មានចិត្តមិនរួញរា មានចិត្តមិនគុំគួន ។ កាយរបស់បុគ្គលនោះក៏តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសន្តាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្តហើយ រមែងមិនត្រូវការ មិនត្រេកអរចំពោះអារម្មណ៍ជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ។ កាយរបស់បុគ្គលនោះក៏តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសន្តាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកមិនស្អប់ចំពោះអារម្មណ៍ មិនជាទីពេញចិត្ត មានចិត្តមិនអាក់អន់ មានចិត្តមិនរួញរា មានចិត្តមិនគុំគួន ។ កាយរបស់បុគ្គលនោះតាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសន្តាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ។ ឃើញរូបដោយភ្នែក កាយរបស់បុគ្គលនោះតាំងនៅខ្ជាប់ខ្ជួនក្នុងរូបទាំងឡាយ ជាទីពេញ

ចិត្ត ឬមិនជាទីពេញចិត្ត ចិត្តក៏ឋិតនៅខាងក្នុងសន្ដាន ឋិតនៅដោយល្អ រូបស្រឡះដោយប្រពៃ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភក្សរសដោយអណ្ដាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត កាយរបស់បុគ្គលនោះតាំងនៅខ្ជាប់ខ្ជួន ក្នុងធម៌ទាំងឡាយជាទីពេញចិត្តឬមិនជាទីពេញចិត្ត ចិត្តក៏ឋិតនៅខាងក្នុងសន្ដាន ឋិតនៅដោយល្អ រូបស្រឡះដោយប្រពៃ ។ឃើញរូបដោយភ្នែកហើយរមែងមិនត្រេកអរក្នុងវត្ថុដែលគួរត្រេកអរ មិនខឹងក្នុងវត្ថុដែលគួរខឹង មិនវង្វេងក្នុងវត្ថុដែលគួរវង្វេង មិនកម្រើកក្នុងវត្ថុដែលគួរកម្រើក មិនសៅហ្មងក្នុងវត្ថុដែលគួរសៅហ្មង មិនស្រវឹងក្នុងវត្ថុដែលគួរស្រវឹង ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភក្សរសដោយអណ្ដាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្តហើយ រមែងមិនត្រេកអរក្នុងវត្ថុដែលគួរត្រេកអរ មិនខឹងក្នុងវត្ថុដែលគួរខឹង មិនវង្វេងក្នុងវត្ថុដែលគួរវង្វេង មិនកម្រើកក្នុងវត្ថុដែលគួរកម្រើក មិនសៅហ្មងក្នុងវត្ថុដែលគួរសៅហ្មង មិនស្រវឹងក្នុងវត្ថុដែលគួរស្រវឹង ។ គ្រាន់តែឃើញរូបដែលឃើញ គ្រាន់តែឮសំឡេងដែលឮ គ្រាន់តែប៉ះពាល់ផស្សៈដែលប៉ះពាល់ គ្រាន់តែដឹងច្បាស់ធម្មារម្មណ៍ដែលដឹងច្បាស់ រមែងមិនប្រឡាក់ចំពោះរូបដែលឃើញ មិនប្រឡាក់ចំពោះសំឡេងដែលឮ មិនប្រឡាក់ចំពោះផស្សៈដែលប៉ះពាល់ មិនប្រឡាក់ចំពោះធម្មារម្មណ៍ដែលដឹង ។ មិនប្រាថ្នាចំពោះរូបដែលឃើញ មិនអាស្រ័យ មិនជាប់ចំពាក់ ជាអ្នករួចស្រឡះប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់វល់ ។ មិនប្រាថ្នាចំពោះសំឡេង

ដែលឮ ចំពោះផស្សៈដែលប៉ះពាល់ ចំពោះធម្មារម្មណ៍ដែលដឹង មិនអាស្រ័យ មិនជាប់ចំពាក់ ជាអ្នករួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាក សេចក្តីសល់វល់ ។ ភ្នែករបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តឃើញរូបដោយភ្នែក តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ ( ព្រោះ ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ត្រចៀករបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តឮសំឡេងដោយត្រចៀកតែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ ( ព្រោះ ) ព្រះអរហន្ត មានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ច្រមុះរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តធុំក្លិនដោយច្រមុះ តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ ( ព្រោះ ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ អណ្តាតរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តលិទ្ធភ្លក្សរស ដោយអណ្តាត តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ ( ព្រោះ ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ កាយរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តពាល់ត្រូវផោដ្ឋព្វៈដោយកាយ តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ ( ព្រោះ ) ព្រះអរហន្ត មានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ចិត្តរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តដឹងធម្មារម្មណ៍ដោយចិត្ត តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ ( ព្រោះ ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ភ្នែកមានរូបជាទីត្រេកអរ ត្រេកអរហើយក្នុងរូប រីករាយព្រមក្នុងរូប តែភ្នែកនោះព្រះអរហន្តបានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយទាំងព្រះអរហន្តនោះសម្តែងធម៌ដើម្បីការសង្រួមភ្នែកនោះ ។ ត្រចៀកមានសំឡេងជាទីត្រេកអរ ។ ច្រមុះ

មានក្លិនជាទីត្រេកអរ ។ អណ្តាតមានរសជាទីត្រេកអរ ត្រេកអរហើយក្នុងរស រីករាយព្រមក្នុងរស តែអណ្តាតនោះព្រះអរហន្តបានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងព្រះអរហន្តនោះសម្តែងធម៌ដើម្បីការសង្រួមអណ្តាតនោះ ។ កាយមានផស្សព្វជាទីត្រេកអរ ។ ចិត្តមានធម្មារម្មណ៍ជាទីត្រេកអរ ត្រេកអរហើយ ក្នុងធម្មារម្មណ៍ រីករាយព្រមក្នុងធម្មារម្មណ៍ តែចិត្តនោះព្រះអរហន្តបានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងព្រះអរហន្តនោះសម្តែងធម៌ដើម្បីការសង្រួម ចិត្តនោះ ។

ពួកជនរមែងនាំពាហនៈ ( មានដំរីជាដើម ) ដែលហាត់ហើយ ទៅកាន់ទីប្រជុំ ព្រះរាជារមែងឡើងគង់ពាហនៈ ដែលហាត់ហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណាអត់ធន់នឹងពាក្យ ពោលទ្រគោះ មនុស្សនោះឈ្មោះថា ជាអ្នកហាត់ហើយ ជាបុគ្គលប្រសើរផុត ។ សេះអស្សតរក្តី សេះសិន្ធពអាជានេយ្យក្តី ដំរីដ៏ប្រសើរជាកុញ្ជរជាតិក្តី ដែលគេបង្ហាត់ហើយ ឈ្មោះថាជាសត្វដ៏ប្រសើរ តែបុគ្គលអ្នកមានខ្លួនទូន្មានហើយប្រសើរជាងសត្វទាំងនោះ ។ បុគ្គលមិនគប្បីទៅកាន់ទិសដែលមិនធ្លាប់ទៅ គឺព្រះនិព្វាន ដោយយានទាំងឡាយនោះបានទេ លុះតែបុគ្គលអ្នកមានខ្លួនទូន្មានទើបទៅកាន់ទិស គឺព្រះនិព្វាន ដោយខ្លួនដែលទូន្មានហើយ ទូន្មានល្អហើយ ។ ព្រះអរហន្តទាំងឡាយរួចស្រឡះចាកភពថ្មី ដល់ហើយនូវទន្តភូមិ គឺអរហត្តផលរមែង

មិនកម្រើកក្នុងតណ្ហានិងទិដ្ឋិផ្សេងៗ ព្រះអរហន្តទាំងនោះឈ្មោះ
ថាជាអ្នកមានជ័យជំនះក្នុងលោក ។

ឥន្ទ្រិយទាំងឡាយ ដែលព្រះខីណាស្រពណាចម្រើនហើយ
ព្រះខីណាស្រពនោះឈ្មោះថា មានធម៌ចម្រើនហើយ មានខ្លួន
ទូន្មានល្អហើយ ដឹងច្បាស់នូវអារម្មណ៍ ទាំងខាងក្នុងខាងក្រៅ
ក្នុងលោកទាំងពួងផង នូវលោកនេះផង នូវលោកខាងមុខផង
រមែងរង់ចាំនូវកាលកិរិយា ( តែប៉ុណ្ណោះ )

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកព្រងើយកន្តើយ ។ ពាក្យថា ក្នុង
កាលទាំងពួង គឺគ្រប់កាល អស់កាលទាំងពួង អស់កាលជានិច្ច អស់កាល
ដ៏ទៀងទាត់ ។បេ។ ក្នុងគំនរនៃបច្ឆិមវ័យ ។ ពាក្យថា មានស្មារតី គឺមានស្មារតី
ដោយហេតុ ៤ យ៉ាង គឺបុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ
ឈ្មោះថា អ្នកមានស្មារតី ១ ក្នុងវេទនាទាំងឡាយ ១ ក្នុងចិត្ត ១ បុគ្គលចម្រើន
ធម្មានុបស្សនាសតិប្បដ្ឋានក្នុងធម៌ទាំងឡាយ ឈ្មោះថាអ្នកមានស្មារតី ១ ។បេ។
បុគ្គលនោះលោកហៅថា អ្នកមានស្មារតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នក
ព្រងើយកន្តើយ មានស្មារតីគ្រប់កាល ។

[ ៩៤ ] ពាក្យថា មិនប្រកាន់ថាស្មើក្នុងលោក គឺមិនញុំាងមានះឲ្យកើត
ឡើងដោយសារជាតិក្តី ដោយសារគោត្តក្តី ។បេ។ ដោយសារវត្ថុណាមួយក្តី
ថាអាត្មាអញជាបុគ្គលស្មើ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រកាន់ថាស្មើ
ក្នុងលោក ។

[ ៩៥ ] ពាក្យថា មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោកទាប អធិប្បាយថា បុគ្គលមិនញុំាងអតិមានះ ឲ្យកើតឡើងដោយសារជាតិក្តី ដោយសារគោត្តក្តី ។បេ។ ដោយសារវត្ថុណាមួយក្តីថាអាត្មាអញជាបុគ្គលប្រសើរ ។ មិនញុំាងមានះឲ្យកើតឡើងដោយសារជាតិក្តី ដោយសារគោត្តក្តី ។បេ។ ដោយសារវត្ថុណាមួយក្តី ថាអាត្មាអញថោកទាប ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោកទាប ។

[ ៩៦ ] អធិប្បាយពាក្យថា ធម៌ជាគ្រឿងដុះដាលរបស់បុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា របស់បុគ្គលនោះ គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថា ធម៌ជាគ្រឿងដុះដាល បានដល់ ធម៌ជាគ្រឿងដុះដាល ៧ គឺធម៌ជាគ្រឿងដុះដាលគឺរាគៈ ដុះដាលគឺទោសៈ ដុះដាលគឺមោហៈ ដុះដាលគឺមានះ ដុះដាលគឺទិដ្ឋិ ដុះដាលគឺកិលេស ដុះដាលគឺកម្ម ។ ធម៌ជាគ្រឿងដុះដាលទាំងនេះរបស់ព្រះអរហន្តមិនមាន ឥតមាន លែងមាន លោកលែងបាន គឺលោកលះបង់ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធម៌ជាគ្រឿងដុះដាល របស់បុគ្គលនោះមិនមានទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលណាជាអ្នកព្រងើយកន្តើយ មានស្មារតីគ្រប់កាលរមែង
មិនប្រកាន់ថាស្មើ មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោក
ទាបក្នុងលោក ធម៌ជាគ្រឿងដុះដាលរបស់បុគ្គលនោះមិនមាន
ទេ ។

[ ៩៧ ] និស្ស័យនៃបុគ្គលណាមិនមាន មួយទៀតតណ្ហាក្នុងភពនិងវិភពនៃបុគ្គលណាមិនមាន បុគ្គលនោះមិនអាស្រ័យព្រោះដឹងនូវធម៌ ។

[ ៩៨ ] អធិប្បាយពាក្យថា និស្ស័យនៃបុគ្គលណាមិនមាន ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា និស្ស័យ បានដល់និស្ស័យ ២ យ៉ាង គឺតណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះទិដ្ឋិនិស្ស័យ ។ តណ្ហានិស្ស័យ ព្រះអរហន្តនោះលះបង់ហើយ ទិដ្ឋិនិស្ស័យលោករលាស់ចេញហើយ និស្ស័យនៃបុគ្គលណាមិនមានឥតមាន លោកមិនបាន គឺលោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយព្រោះតណ្ហានិស្ស័យលោកលះបង់ហើយ ព្រោះទិដ្ឋិនិស្ស័យលោករលាស់ចេញហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) និស្ស័យនៃបុគ្គលណាមិនមាន ។

[ ៩៩ ] អធិប្បាយពាក្យថា បុគ្គលនោះមិនអាស្រ័យ ព្រោះដឹងនូវធម៌ ត្រង់ពាក្យថា ព្រោះដឹង គឺព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងមិនទៀង ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា ឃើញច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងជាទុក្ខ ។បេ។ ថាធម៌ទាំងឡាយទាំងពួងជាអនត្តាព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ជាធម្មតា ។ ពាក្យថា មិនអាស្រ័យ បានដល់ និស្ស័យ ២ យ៉ាង គឺ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះ

ទិដ្ឋិនិស្ស័យ ។ ព្រះអរហន្តលះបង់នូវតណ្ហានិស្ស័យ រលាស់ចេញនូវទិដ្ឋិ-និស្ស័យ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ មិនអាស្រ័យឃានៈ មិនអាស្រ័យជិវ្ហា មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស ។បេ។ មិនអាស្រ័យ មិនជាប់ មិនកៀកកើយ មិនជ្រុលជ្រប់ មិនចុះស៊ប់ គឺលោកឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់វល់ក្នុងធម៌ដែលគប្បីឃើញ ឮ ប៉ះពាល់ឬដឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះមិនអាស្រ័យព្រោះដឹងនូវធម៌ ។

[ ១០០ ] អធិប្បាយពាក្យថា តណ្ហាក្នុងភពនិងវិភពនៃបុគ្គលណាមិនមាន ត្រង់ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វ-តណ្ហា ធម្មតណ្ហា ។ ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា ក្នុងភព គឺក្នុងភវទិដ្ឋិ ។ ពាក្យថា វិភព គឺក្នុងវិភវទិដ្ឋិ ។ ពាក្យថា ក្នុងភព គឺក្នុងសស្សតទិដ្ឋិ ។ ពាក្យថា វិភព គឺក្នុងឧច្ឆេទទិដ្ឋិ ។ ពាក្យថា ក្នុងភព គឺក្នុងភពរឿយៗ ក្នុងគតិរឿយៗ ក្នុងការកើតឡើងរឿយៗ ក្នុងបដិសន្ធិរឿយៗ ក្នុងកិរិយាកើតជាអត្តភាពរឿយៗ ។ តណ្ហានៃបុគ្គលណាមិនមាន ឥតមាន លោកមិនបាន គឺលោកលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តណ្ហាក្នុងភពនិងវិភព នៃបុគ្គលណាមិនមាន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

និស្ស័យនៃបុគ្គលណាមិនមាន មួយទៀតតណ្ហាក្នុងភពនិងវិភព នៃបុគ្គលណាមិនមាន បុគ្គលនោះមិនអាស្រ័យ ព្រោះដឹងនូវធម៌ ។

[ ១០១ ] តថាគតពោលនូវបុគ្គល អ្នកមិនអាល័យក្នុងកាមទាំងឡាយនោះថាជាអ្នកស្ងប់ គន្ថៈ ( កិលេសជាគ្រឿងចាក់ស្រែះ ) នៃបុគ្គលនោះមិនមានទេ បុគ្គលនោះបានឆ្លងហើយនូវវិសត្តិកាតណ្ហា ។

[ ១០២ ] ពាក្យថា តថាគតពោលនូវបុគ្គលនោះថា ជាអ្នកស្ងប់ គឺតថាគតពោលនូវបុគ្គលនោះ សម្តែងនូវបុគ្គលនោះ និយាយនូវបុគ្គលនោះ បំភ្លឺនូវបុគ្គលនោះ បញ្ចេញនូវបុគ្គលនោះ ថាជាអ្នកស្ងប់ អ្នករម្ងាប់ អ្នកចូលទៅជិតស្ងប់ អ្នករលត់ទុក្ខ អ្នកសះស្បើយទុក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលបុគ្គលនោះថា ជាអ្នកស្ងប់ ។

[ ១០៣ ] អធិប្បាយពាក្យថា អ្នកមិនអាល័យក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់ កាម ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថា កិលេសកាម ។ ព្រះអរហន្តកំណត់ដឹងវត្ថុកាម លះបង់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេសកាម ជាអ្នកមិនអាល័យក្នុងកាមទាំងឡាយ ជាអ្នកមានកាមទៅប្រាស មានកាមលះបង់ មានកាមខ្ជាក់ចេញ មានកាមរួចស្រឡះ មានកាមបោះបង់ មានកាមរលាស់ចេញ មានរាគៈទៅប្រាស មានរាគៈលះបង់ មានរាគៈខ្ជាក់ចេញ មានរាគៈរួចស្រឡះ មានរាគៈបោះបង់ មានរាគៈរលាស់

ចេញ ជាអ្នកមិនមានប្រាថ្នា ជាអ្នករលត់ទុក្ខ ជាអ្នកត្រជាក់ ទទួលសុខ មានចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនអាល័យក្នុងកាមទាំងឡាយ ។

[ ១០៤ ] អធិប្បាយពាក្យថា គន្ថៈនៃបុគ្គលនោះមិនមានទេ ត្រង់ពាក្យថា គន្ថៈ បានដល់ គន្ថៈ ៤ យ៉ាងគឺ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ ១ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ឈ្មោះថា អភិជ្ឈាកាយគន្ថៈ ។ ការគុំគួន ការអាក់អន់ក្នុងវាទៈរបស់បុគ្គលដទៃ ឈ្មោះថា ព្យាបាទកាយគន្ថៈ ។ បុគ្គលស្ទាបអង្អែលសីលឬវត្ត ឬក៏សីលនិងវត្តរបស់ខ្លួន ឈ្មោះថា សីលព្វបរាមាសកាយគន្ថៈ ។ ទិដ្ឋិរបស់ខ្លួន ឈ្មោះថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ ពាក្យថា នៃបុគ្គលនោះ គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា គន្ថៈនៃបុគ្គលនោះមិនមានទេ បានសេចក្ដីថា គន្ថៈនៃបុគ្គលនោះមិនមាន ឥតមាន លែងមាន លោកមិនបានគឺលោកលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គន្ថៈនៃបុគ្គលនោះមិនមានទេ ។

[ ១០៥ ] ពាក្យថា បុគ្គលនោះបានឆ្លងហើយនូវវិសត្តិកាតណ្ហា អធិប្បាយថា តណ្ហាលោកហៅថា វិសត្តិកា បានដល់ តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំនួរត្រង់ពាក្យថា វិសត្តិកា ចុះវិសត្តិកាដោយអត្ថដូចម្ដេច ។ ឈ្មោះថា វិសត្តិកាព្រោះជាធម្មជាតិផ្សាយទៅកាន់អារម្មណ៍ ។ ឈ្មោះថា វិសត្តិកាព្រោះជាធម្មជាតិដ៏ទូលាយ ។ ឈ្មោះថា វិសត្តិកាព្រោះជា

ធម្មជាតិជ្រួតជ្រាប ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិមិនស្មើ ។ ឈ្មោះថា វិសត្តិកាព្រោះជាធម្មជាតិអត់ធន់ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិនាំត្រឡប់ ( ចាកអកុសលធម៌ ) ។ ឈ្មោះថា វិសត្តិកាព្រោះជាធម្មជាតិឲ្យពោលខុស ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិមានផ្លែជាពិស ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិមានគ្រឿងបរិភោគជាពិស ។ មួយទៀតតណ្ហានោះជាធម្មជាតិដ៏ទូលាយ ជ្រួតជ្រាប ផ្សាយទៅក្នុងរូប ក្នុងសំឡេង ក្នុងក្លិន ក្នុងរស ក្នុងផ្សព្វ ក្នុងត្រកូល ក្នុងពួក ក្នុងអាវាស ។បេ។ ក្នុងធម៌ទាំងឡាយដែលឃើញឮប៉ះពាល់ ឬគួរដឹង ព្រោះហេតុនោះតណ្ហាទើបឈ្មោះថា វិសត្តិកា ។ ពាក្យថា បុគ្គលនោះបានឆ្លងហើយនូវវិសត្តិកាតណ្ហា គឺបុគ្គលនោះបានឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវតណ្ហា ដែលឈ្មោះថាវិសត្តិកានេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះបានឆ្លងនូវវិសត្តិកាតណ្ហា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

តថាគតពោលនូវបុគ្គល អ្នកមិនអាល័យក្នុងកាមទាំងឡាយ
នោះថាជាអ្នកស្ងប់ គន្ថៈនៃបុគ្គលនោះមិនមានទេ បុគ្គលនោះ
បានឆ្លងហើយនូវវិសត្តិកាតណ្ហា ។

[ ១០៦ ] បុត្ត សត្វចិញ្ចឹម ស្រែនិងទីរបស់បុគ្គលនោះមិនមានទេ អត្តទិដ្ឋិក្តី និរត្តទិដ្ឋិក្តី គេរកមិនបានក្នុងបុគ្គលនោះឡើយ ។

[ ១០៧ ] អធិប្បាយពាក្យថា បុត្ត សត្វចិញ្ចឹម ស្រែនិងទីរបស់បុគ្គលនោះមិនមានទេ ត្រង់ពាក្យថា មិន គឺជាពាក្យឃាត់ ។ ពាក្យថា របស់បុគ្គល

*នោះ គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថា បុត្ត បានដល់បុត្ត ៤ ពួក គឺបុត្តកើតអំពីខ្លួន ១ បុត្តកើតក្នុងខេត្ត ១ បុត្តដែលគេឲ្យ ១ បុត្ត គឺសិស្ស ១ ។ ពាក្យថា សត្វចិញ្ចឹម គឺពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល និងសេះញី ។ ពាក្យថា ស្រែ គឺស្រែស្រូវសាលី ស្រែស្រូវធម្មតា ស្រែសណ្តែកបាយ ស្រែសណ្តែករាជមាស ស្រែស្រូវដំណើប ស្រែស្រូវស្រងែ ស្រែល្ង ។ ពាក្យថា ទី គឺទីផ្ទះ ទីជង្រុក ទីខាងមុខ ទីខាងក្រោយ ទីសួនច្បារ ទីលំនៅ ។ ពាក្យថា បុត្ត សត្វចិញ្ចឹម ស្រែនិងទីរបស់បុគ្គលនោះមិនមានទេ បានសេចក្តីថា ការហួងហែងបុត្តក្តី ការហួងហែងសត្វចិញ្ចឹមក្តី ការហួងហែងស្រែក្តី ការហួងហែងទីក្តីរបស់បុគ្គលនោះមិនមាន ឥតមាន លែងមាន បុគ្គលនោះមិនបាន គឺលោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុត្ត សត្វចិញ្ចឹម ស្រែនិងទីរបស់បុគ្គលនោះមិនមានទេ ។*

*[ ១០៨ ] អធិប្បាយពាក្យថា អត្តទិដ្ឋិក្តី និរត្តទិដ្ឋិក្តី គេរកមិនបានក្នុងបុគ្គលនោះឡើយ ត្រង់ពាក្យថា អត្តា គឺសស្សតទិដ្ឋិមិនមាន ពាក្យថា និរត្តា គឺឧច្ឆេទទិដ្ឋិមិនមាន ការប្រកាន់ថាអត្តាមិនមាន ការគប្បីដោះថានិរត្តាមិនមាន ។ ការប្រកាន់នៃបុគ្គលណាមិនមាន ការគប្បីដោះនៃបុគ្គលនោះមិនមាន ការគប្បីដោះនៃបុគ្គលណាមិនមាន ការប្រកាន់នៃបុគ្គលនោះមិនមាន ។ ព្រះអរហន្តកន្លងផុតការប្រកាន់និងការដោះ ប្រព្រឹត្តកន្លងនូវការចម្រើននិងការសាបសូន្យ ។ ព្រះអរហន្តនោះមានការនៅ ( ក្នុងអរិយវាសៈ ) នៅរួចហើយ មានការប្រព្រឹត្ត*

សន្សំហើយ ។បេ។ ភពថ្មីរបស់លោកមិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) អត្តទិដ្ឋិក្តី និរត្តទិដ្ឋិក្តីគេរកមិនបានក្នុងបុគ្គលនោះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុត្ត សត្វចិញ្ចឹម ស្រែនិងទីរបស់បុគ្គលនោះមិនមានទេ អត្តទិដ្ឋិ
ក្តី និរត្តទិដ្ឋិក្តី គេរកមិនបានក្នុងបុគ្គលនោះឡើយ ។

[ ១០៩ ] មួយទៀតសមណព្រាហ្មណ៍ទាំងឡាយជាបុថុជ្ជន គប្បីពោលដោយកិលេសណា បុគ្គលនោះមិនធ្វើកិលេសនោះឲ្យជាប្រធាន ព្រោះហេតុនោះបុគ្គលនោះមិនញាប់ញ័រក្នុងវាទៈទាំងឡាយ ។

[ ១១០ ] អធិប្បាយពាក្យថា មួយទៀតសមណព្រាហ្មណ៍ទាំងឡាយជាបុថុជ្ជន គប្បីពោលដោយកិលេសណា សំនួរត្រង់ពាក្យថា បុថុជ្ជន ចុះបុថុជ្ជនដោយអត្ថដូចម្តេច ។ ឈ្មោះថា បុថុជ្ជន ព្រោះញុំាងកិលេសក្រាស់ឲ្យកើត ។ ឈ្មោះថា បុថុជ្ជន ព្រោះមិនទាន់កម្ចាត់បង់សក្កាយទិដ្ឋិដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកយល់មុខសាស្តាទាំងឡាយដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ច្រើនរួបរឹត ។ ឈ្មោះថា បុថុជ្ជនព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗដ៏ចម្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវជំនន់ផ្សេងៗដ៏ច្រើនបន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះអន្ទះអន្ទែងដោយសេចក្តីអន្ទះអន្ទែងផ្សេងៗដ៏ចម្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវសេចក្តីក្តៅក្រហាយផ្សេងៗដ៏ច្រើនដុតហើយ ។ ឈ្មោះថា បុថុជ្ជនព្រោះជាអ្នកត្រេកអរ ចង់បាន ធ្លាក់ចុះ ងុលងប់ ជ្រុលជ្រប់ ជាប់នៅ ចំពាក់នៅ សាន់វាន់នៅក្នុងកាមគុណ

ទាំង ៥ ដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជនព្រោះត្រូវនីវរណៈទាំង ៥ ដ៏ច្រើនខ្ទប់ រាំង ហ៊ុម បិទបាំង គ្របហើយ ។ ពាក្យថា សមណៈ គឺពួកជនណាមួយ ចូលទៅរកបរិព្វាជកជាខាងក្រៅសាសនានេះ បួសជាបរិព្វាជក ។ ពាក្យថា ព្រាហ្មណ៍ គឺពួកជនណាមួយជាភោវាទិ ។ ពាក្យថា មួយទៀតសមណព្រាហ្មណ៍ ទាំងឡាយជាបុថុជ្ជនគប្បីពោលដោយកិលេសណា បានសេចក្តីថា ពួកបុថុជ្ជន គប្បីពោលដោយរាគៈណា គប្បីពោលដោយទោសៈណា គប្បីពោលដោយ មោហៈណា គប្បីពោលដោយមានះណា គប្បីពោលដោយទិដ្ឋិណា គប្បីពោល ដោយឧទ្ធច្ចៈណា គប្បីពោលដោយវិចិកិច្ឆាណា គប្បីពោលដោយអនុស័យ ណាថា ( អ្នកនេះ ) ជាអ្នកត្រេកអរ ឬថាជាអ្នកប្រទូស្ត ថាជាអ្នកវង្វេង ឬ ថាជាអ្នកជាប់ចំពាក់ ថាជាអ្នកស្ទាបអង្អែល ឬថាជាអ្នកដល់នូវសេចក្តីរាយ មាយ ថាជាអ្នកមិនដាច់ស្រេច ឬថាជាអ្នកដល់នូវកម្លាំង ។ អភិសង្ខារទាំងនោះ បុគ្គលនោះលះបង់ហើយ ព្រោះលោកលះបង់នូវអភិសង្ខារទាំងឡាយអស់ ហើយ ពួកបុថុជ្ជនគប្បីពោលនូវគតិទាំងឡាយថា ( អ្នកនេះ ) ជាអ្នកកើត ក្នុងនរក ឬថាជាអ្នកកើតក្នុងកំណើតតិរច្ឆាន ថាជាអ្នកកើតក្នុងបិត្តិវិស័យ ឬថា ជាមនុស្ស ថាជាទេវតា ឬថាជារូបព្រហ្ម ថាជាអរូបព្រហ្ម ឬថាជាសញ្ញីសត្វ ថាជាអសញ្ញីសត្វ ឬថាជានេវសញ្ញីនាសញ្ញីសត្វដោយហេតុណា ។ ពួកបុថុជ្ជន គប្បីពោល គប្បីសម្តែង គប្បីពណ៌នា គប្បីបំភ្លឺ គប្បីថ្លែងដោយហេតុណា ហេតុនោះមិនមាន បច្ច័យនោះមិនមាន ការណ៍នោះមិនមាន ហេតុនោះ ( ទ្រង់ ត្រាស់ថា ) មួយទៀត សមណព្រាហ្មណ៍ទាំងឡាយជាបុថុជ្ជន គប្បីពោល

ដោយកិលេសណា ។

[ ១១១ ] អធិប្បាយពាក្យថា បុគ្គលនោះមិនធ្វើកិលេសនោះឲ្យជាប្រធាន ត្រង់ពាក្យថា បុគ្គលនោះ គឺព្រះអរហន្តខីណាស្រព ។ ពាក្យថា ការធ្វើឲ្យជាប្រធាន បានដល់ ការធ្វើឲ្យជាប្រធានមានពីរគឺ ការធ្វើឲ្យជាប្រធានគឺតណ្ហា ១ ការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ ១ ។បេ។ នេះការធ្វើឲ្យជាប្រធាន គឺតណ្ហា ។បេ។ នេះការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា បុគ្គលនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ បុគ្គលនោះរលាស់ចោលហើយ ព្រោះលោកលះបង់នូវការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រោះលោករលាស់ចោលនូវការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោកទើបមិនប្រព្រឹត្តធ្វើតណ្ហាឬទិដ្ឋិឲ្យជាប្រធាន ជាអ្នកមិនមានទង់ជ័យគឺតណ្ហា មិនមានទង់គឺតណ្ហា មិនមានតណ្ហាជាអធិបតិ មិនមានទង់ជ័យគឺទិដ្ឋិ មិនមានទង់គឺទិដ្ឋិ មិនមានទិដ្ឋិជាអធិបតិ មិនត្រូវតណ្ហាឬទិដ្ឋិប្រព្រឹត្តហោមរោម ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះមិនធ្វើកិលេសនោះឲ្យជាប្រធាន ។

[ ១១២ ] ពាក្យថា ព្រោះហេតុនោះ ក្នុងបទថា ព្រោះហេតុនោះបុគ្គលនោះមិនញាប់ញ័រ ក្នុងវាទៈទាំងឡាយគឺ ព្រោះហេតុនោះ ព្រោះការណ៍នោះ ព្រោះទំនងនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលនោះមិនញាប់ញ័រ ឥតញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនរំជួយ មិនប្រែត្រឡប់ក្នុងវាទៈទាំងឡាយ គឺក្នុងឧបវាទៈ ក្នុងពាក្យនិន្ទា ក្នុងពាក្យតិះដៀល ក្នុងពាក្យបង្អាប់ ក្នុងពាក្យមិននាំមកនូវគុណ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ

បុគ្គលនោះមិនញាប់ញ័រក្នុងវាទៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀតសមណព្រាហ្មណ៍ទាំងឡាយជាបុថុជ្ជន គប្បីពោល
ដោយកិលេសណា បុគ្គលនោះមិនធ្វើកិលេសនោះឲ្យជាប្រធាន
ព្រោះហេតុនោះបុគ្គលនោះមិនញាប់ញ័រក្នុងវាទៈទាំងឡាយ ។

[ ១១៣ ] បុគ្គលជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តីកំណាញ់ ជាមុនិ មិនពោលក្នុងហេតុដ៏ខ្ពស់ទេ មិនពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ ។

[ ១១៤ ] ពាក្យថា ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តីកំណាញ់ អធិប្បាយថា តណ្ហាលោកហៅថា សេចក្តីប្រាថ្នា បានដល់ តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានេះបុគ្គលណាលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកប្រាសចាកសេចក្តីប្រាថ្នា ។ បុគ្គលនោះមិនប្រាថ្នាក្នុងរូប ។បេ។ មិនប្រាថ្នា មិនចំពាក់ មិនងុលងប់ មិនជ្រុលជ្រប់ក្នុងពួកធម៌ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង គឺជាអ្នកប្រាសចាកការប្រាថ្នា លះបង់ការប្រាថ្នា ខ្ជាក់ចោលការប្រាថ្នា រួចចាកការប្រាថ្នា រលាស់ចោលការប្រាថ្នា មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ ជាអ្នកត្រជាក់ សោយសុខនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ។ ពាក្យថា សេចក្តីកំណាញ់ ក្នុង

បទថា មិនមានសេចក្តីកំណាញ់ បានដល់ សេចក្តីកំណាញ់ ៥ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់វណ្ណៈ ១ កំណាញ់ធម៌ ១ សេចក្តីកំណាញ់ឯណាមានសភាពយ៉ាងនេះ ។បេ។ សេចក្តីប្រកាន់នេះលោកហៅថា សេចក្តីកំណាញ់ ។ សេចក្តីកំណាញ់នេះបុគ្គលណាបានលះបង់ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតរោលដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានសេចក្តីកំណាញ់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តីកំណាញ់ ។

[ ១១៥ ] ពាក្យថា ជាមុនិ មិនពោលក្នុងហេតុដ៏ខ្ពស់ទេ មិនពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ ត្រង់ពាក្យថា មុនិ សេចក្តីថាញាណលោកហៅថា មោនៈ ។បេ។ មុនិនោះបានកន្លងនូវបណ្តាញ ជាគ្រឿងជាប់ចំពាក់ ។ មុនិ មិនពោល មិនសម្តែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែងថា អាត្មាអញជាបុគ្គលប្រសើរ ឬថាអាត្មាអញជាបុគ្គលប្រហែលនឹងគេ ឬក៏ថាអាត្មាអញជាបុគ្គលថោកទាបជាងគេដូច្នេះឡើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិ មិនពោលក្នុងហេតុដ៏ខ្ពស់ទេ មិនពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ ។

[ ១១៦ ] ពាក្យថា កប្បៈ ក្នុងបទថា ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ បានដល់ កប្បៈ ២ គឺ កប្បៈគឺតណ្ហា ១ កប្បៈគឺទិដ្ឋិ ១ ។បេ។ នេះកប្បៈគឺតណ្ហា ។បេ។ នេះកប្បៈគឺទិដ្ឋិ ។ មុនិនោះលះបង់កប្បៈ គឺតណ្ហា រលាស់

ចោលកប្បៈគឺទិដ្ឋិហើយ ព្រោះលះបង់កប្បៈគឺតណ្ហា ព្រោះរលាស់ចោលកប្បៈគឺទិដ្ឋិទើបលោកមិនដល់ មិនចូលទៅជិតដល់ មិនចូលទៅរក មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវកប្បៈគឺតណ្ហាឬកប្បៈគឺទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមិនមានកប្បៈ ។ ពាក្យថា កប្បៈ ក្នុងបទថា ជាអ្នកមិនមានកប្បៈ បានដល់ កប្បៈ ២ គឺ កប្បៈគឺតណ្ហា ១ កប្បៈគឺទិដ្ឋិ ១ ។បេ។ នេះកប្បៈគឺតណ្ហា ។បេ។ នេះកប្បៈគឺទិដ្ឋិ ។ មុនិនោះលះបង់កប្បៈ គឺតណ្ហារលាស់ចោលកប្បៈគឺទិដ្ឋិហើយព្រោះលោកលះបង់កប្បៈគឺតណ្ហា ព្រោះលោករលាស់ចោលកប្បៈគឺទិដ្ឋិ ទើបលោកមិនឲ្យសម្រេច មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវកប្បៈគឺតណ្ហា ឬកប្បៈគឺទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តី
កំណាញ់ ជាមុនិ មិនពោលក្នុងហេតុដ៏ខ្ពស់ទេ មិនពោលក្នុង
ហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ ជាអ្នកមិនមាន
កប្បៈ មិនដល់នូវកប្បៈ ។

[ ១១៧ ] ការហួងហែងថាជារបស់ខ្លួនក្នុងលោក នៃបុគ្គលណាមិនមាន បុគ្គលណាមិនសោកស្តាយ ព្រោះវត្ថុដែលមិនមានផង មិនលុះក្នុងធម៌ទាំងឡាយផង បុគ្គលនោះឯងលោកហៅថា អ្នកស្ងប់ ។

[ ១១៨ ] ពាក្យថា ការហួងហែងថាជារបស់ខ្លួនក្នុងលោកនៃបុគ្គលណា

មិនមាន ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា ការហួងហែងថាជារបស់ខ្លួនមិនមាន សេចក្តីថា វត្ថុណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលបុគ្គលកួចកាន់ ស្ទាបអង្អែល ប្រកាន់មាំ ចុះចិត្តស៊ប់ បង្អោនទៅថា នេះរបស់អញ ឬនេះរបស់ពួកជនដទៃដូច្នេះនៃបុគ្គលណាមិនមាន ។បេ។ ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការហួងហែងថាជារបស់ខ្លួនក្នុងលោកនៃបុគ្គលណាមិនមាន ។

[ ១១៩ ] អធិប្បាយពាក្យថា មិនសោកស្តាយព្រោះវត្ថុដែលមិនមានផង គឺមិនសោកនឹងវត្ថុដែលប្រែប្រួលហើយ ឬមិនសោកក្នុងវត្ថុដែលប្រែប្រួលហើយ គឺមិនសោកថា ភ្នែករបស់អញប្រែប្រួលហើយ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងថា ត្រចៀករបស់អញ ច្រមុះរបស់អញ អណ្តាតរបស់អញ កាយរបស់អញ ចិត្តរបស់អញ រូបរបស់អញ សំឡេងរបស់អញ ក្លិនរបស់អញ រសរបស់អញ ផ្សព្វរបស់អញ ត្រកូលរបស់អញ ពួករបស់អញ អាវាសរបស់អញ លាភរបស់អញ យសរបស់អញ សេចក្តីសរសើររបស់អញ សុខរបស់អញ ចីវររបស់អញ បិណ្ឌបាតរបស់អញ សេនាសនៈរបស់អញ គិលានប្បច្ចយ-ភេសជ្ជបរិក្ខាររបស់អញ មាតារបស់អញ បិតារបស់អញ បងប្អូនប្រុសរបស់អញ បងប្អូនស្រីរបស់អញ កូនប្រុសរបស់អញ កូនស្រីរបស់អញ មិត្តរបស់អញ អាមាត្យរបស់អញ ញាតិរបស់អញ ពួកសាលោហិតរបស់អញ ប្រែប្រួលហើយដូច្នេះឡើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនសោកស្តាយ

ព្រោះវត្ថុដែលមិនមានយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលត្រូវទុក្ខវេទនាមិនជាទី ត្រេកអរប៉ះពាល់ហើយ គ្របសង្កត់ហើយ ប្រជុំព្រមហើយ ប្រកបព្រមហើយ ក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ។ បុគ្គលត្រូវរោគក្នុងភ្នែកប៉ះពាល់ហើយ គ្របសង្កត់ហើយ ប្រជុំព្រមហើយ ប្រកបព្រមហើយក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ។ បុគ្គលត្រូវរោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្ដាត រោគក្នុងកាយ រោគក្នុងក្បាល រោគត្រង់ស្លឹកត្រចៀក រោគក្នុងមាត់ រោគក្នុងធ្មេញ រោគក្អក ហឺត ឫសដូងច្រមុះ ក្ដៅក្រហាយ ស្គាំងស្គម រោគក្នុងផ្ទៃ វិលមុខ ធ្លាក់ ឈាម ចុកសៀត ចុះផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទីក្ចារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះផ្អែម ឫសដូងដុះ បូស ឫសដូងបាត អាពាធតាំងឡើងអំពីប្រមាត់ អាពាធតាំងឡើងអំពីស្លេស្ម អាពាធតាំងឡើងអំពីខ្យល់ អាពាធតាំងឡើងអំពីធាតុប្រជុំគ្នា អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្ដីព្យាយាមរបស់គេមានវាយចងជាដើម អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ ពស់តូចនិងពស់ធំពាល់ត្រូវហើយ គ្របសង្កត់ហើយ ប្រជុំព្រមហើយ ប្រកបព្រមហើយក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនសោកស្ដាយ

ព្រោះវត្ថុដែលមិនមានយ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលកាលបើវត្ថុមិនមាន មិនមានព្រម ដែលលោកមិនបាន ក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងថា អើហ្ន៎ វត្ថុនោះរបស់អញ អើហ្ន៎ វត្ថុនោះអញមិនមាន ធ្វើម្តេចហ្ន៎ វត្ថុនោះអញគប្បីមាន អើហ្ន៎ អញមិនបានវត្ថុនោះដូច្នេះឡើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនសោកស្តាយព្រោះវត្ថុដែលមិនមានយ៉ាងនេះខ្លះ ។

[ ១២០ ] ពាក្យថា មិនលុះក្នុងធម៌ទាំងឡាយផង គឺមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកដឹកនាំទៅ មិននាំចេញ មិនបន្សាត់ មិនប្រមូល ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនលុះក្នុងធម៌ទាំងឡាយ ។

[ ១២១ ] ពាក្យថា បុគ្គលនោះឯង លោកហៅថា អ្នកស្ងប់ គឺបុគ្គលនោះលោកហៅ លោកសម្តែង លោកពណ៌នា លោកបំភ្លឺ លោកថ្លែងថាជាអ្នកស្ងប់ អ្នកស្ងប់រម្ងាប់ អ្នកស្ងប់ស្ងាត់ អ្នកមានទុក្ខរលត់ អ្នកស្ងួតស្ងប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះឯងលោកហៅថា អ្នកស្ងប់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ការប្រហួងហែងថាជារបស់ខ្លួនក្នុងលោក នៃបុគ្គលណាមិនមាន

បុគ្គលណាមិនសោកស្តាយព្រោះវត្ថុដែលមិនមានផង មិនលុះ
ក្នុងធម៌ទាំងឡាយផង បុគ្គលនោះឯងលោកហៅថា អ្នកស្ងប់ ។

**ចប់បុរាភេទសុត្តនិទ្ទេសទី ១០**

# សទ្ធម្មប្បជោតិកា

# អដ្ឋកថា ខុទ្ទកនិកាយ មហានិទ្ទេស

## អដ្ឋកថា អដ្ឋកវគ្គ

## អដ្ឋកថា បុរាភេទសុត្តនិទ្ទេសទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងបុរាភេទសុត្តនិទ្ទេសទី ១០ ដូចតទៅនេះថា

[ ៥៤ ] គប្បីជ្រាបរឿងរ៉ាវដែលកើតឡើងដូចគ្នានៃសូត្រនេះថា **កថំទស្សី** ដូច្នេះជាដើមនិងសូត្រដទៃក្រៅអំពីសូត្រនេះ ៥ ទៀត គឺកលហវិវាទសូត្រ ១ ចូឡវិយូហសូត្រ ១ មហាវិយូហសូត្រ ១ តុវដកសូត្រ ១ អត្តទណ្ឌសូត្រ ១ ដោយន័យដែលពោលទុកហើយក្នុងសម្មាបរិព្វាជនីយសូត្រនោះឯង តែដោយការផ្សេងគ្នាគប្បីជ្រាបដូចតទៅនេះថា

ព្រះមានព្រះភាគ ដើម្បីសម្ដែងនូវធម៌ឲ្យជាទីសប្បាយរបស់ទេវតា ដែលជារាគចរិតក្នុងមហាសម័យនោះ ទ្រង់ឲ្យព្រះពុទ្ធនិមិត្តត្រាស់សួរបញ្ហាជាមួយព្រះអង្គហើយ ទើបបានត្រាស់សម្មាបរិព្វាជនីយសូត្រដោយប្រការណា ក្នុងមហាសម័យនេះក៏ដោយប្រការនោះដូចគ្នា ព្រះមានព្រះភាគទ្រង់ជ្រាបចិត្តរបស់ទេវតាដែលមានចិត្តកើតឡើងថា មុនពេលចុតិគួរធ្វើអ្វីហ្ន៎ ដើម្បីទ្រង់អនុគ្រោះពួកទេវតាទាំងនោះ ទើបទ្រង់នាំព្រះពុទ្ធនិមិត្តមួយអន្លើដោយភិក្ខុបរិវារ ២៥០០ អង្គមកតាមអាកាស ហើយទ្រង់ឲ្យព្រះពុទ្ធនិមិត្តទូលសួរព្រះអង្គ ទើបបានត្រាស់ព្រះសូត្រនេះ ។

ត្រាស់ដូចម្ដេច ត្រាស់ដូចតទៅនេះថា ធម្មតាព្រះពុទ្ធទាំងឡាយជាបុគ្គល

ធំក្រៃលែង ជាបុគ្គលវិសេសជាងសត្វ បណ្តារូបារម្មណ៍ដែលចែកចេញទៅដោយពណ៌ មានពណ៌ខៀវជាដើម រូបារម្មណ៍ណាមួយ ឬបណ្តាសទ្ទារម្មណ៍ជាដើម ដែលចែកចេញទៅដោយសំឡេង មានសំឡេងស្គរជាដើម អារម្មណ៍មានសទ្ទារម្មណ៍ជាដើមណាមួយ ក្នុងទីណាមួយដែលលោក ព្រមទាំងទេវលោកឃើញ បានឮ ជ្រាប ដឹងច្បាស់ ដល់ ស្វែងរក ត្រាច់តាមទៅដោយចិត្ត ដែលមិនមកកាន់គន្លង ក្នុងសំណាញ់ញាណរបស់ព្រះពុទ្ធទាំងនោះ រមែងមិនមានសមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោកព្រមទាំងទេវលោក ។បេ។ ព្រមទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេសឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ត្រាច់រង្គាត់រកអារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយដោយសារចិត្ត ដូច្នេះ ។

ព្រះមានព្រះភាគដែលមានញាណ មិនមានអ្វីរាំងក្នុងទីទាំងពួងយ៉ាងនេះ ទ្រង់បានធ្វើពួកទេវតាទាំងនោះឲ្យជា ២ ចំណែក ដោយភព្វបុគ្គលនិងអភព្វបុគ្គល ។ បុគ្គលទាំងឡាយដែលពោលដោយន័យជាដើមថា បុគ្គលណាប្រកបដោយគ្រឿងរារាំងគឺកម្ម ឈ្មោះថា អភព្វ ។ ព្រះពុទ្ធទាំងឡាយទ្រង់មិនបានសម្លឹងមើលសត្វទាំងនោះ សូម្បីនៅក្នុងទីជាមួយគ្នា ។ ចំណែកសត្វដែលផ្ទុយអំពីនេះ ឈ្មោះថា ភព្វបុគ្គល ។ ព្រះពុទ្ធទាំងឡាយយាងទៅសង្គ្រោះសត្វទាំង

នោះ សូម្បីនៅក្នុងទីឆ្ងាយ ។ ក្នុងទីប្រជុំទេវតានោះ ពួកទេវតាណាជាអកព្វ ព្រះមានព្រះភាគ ទ្រង់លះពួកទេវតាទាំងនោះ ទ្រង់ប្រមើលមើលពួកទេវតា ដែលជាភព្វ កាលទ្រង់ពិចារណាមើលហើយ ទ្រង់ធ្វើឲ្យជា ៦ ចំណែកតាមចរិត គឺពួករាគចរិតប្រមាណប៉ុណ្ណេះ ពួកទោសចរិតជាដើមប្រមាណប៉ុណ្ណេះ ។ បន្ទាប់ពីនោះទ្រង់ពិចារណាដល់នូវព្រះធម្មទេសនា ដែលជាទីសប្បាយរបស់ទេវតាទាំងនោះទើបទ្រង់កំណត់ទេសនាទុកថា តថាគតនឹងសម្តែងសម្មាបរិព្វាជនីយសូត្រ ដល់ពួកទេវតារាគចរិតនិងសម្តែងកលហវិវាទសូត្រ ដល់ពួកទេវតាទោសចរិត និងសម្តែងមហាវិយូហសូត្រ ដល់ពួកទេវតាមោហចរិត និងសម្តែងចូឡវិយូហសូត្រ ដល់ពួកទេវតាវិតក្កចរិត និងសម្តែងតុវដកសូត្រ ដល់ពួកទេវតាសទ្ធាចរិត និងសម្តែងបុរាភេទសូត្រ ដល់ពួកទេវតាពុទ្ធិចរិត ហើយទ្រង់ពិចារណាដល់បរិស័ទនោះតទៅថា បរិស័ទគប្បីដឹងដោយអត្តជ្ឈាសយៈ គឺអធ្យាស្រ័យរបស់ខ្លួន ដោយបរជ្ឈាសយៈ គឺអធ្យាស្រ័យរបស់អ្នកដទៃ ដោយអត្ថុប្បត្តិកៈ គឺហេតុដែលកើតឡើង ឬបុច្ឆាវសៈ គឺការសាកសួរហ្ន៎ ។ កាលទ្រង់ជ្រាបថា បរិស័ទគប្បីដឹងបានដោយពាក្យសួរទើបទ្រង់ត្រិះរិះថា តើមានរណាខ្លះហ្ន៎ អាចកំណត់អធ្យាស្រ័យរបស់ទេវតាទាំងឡាយ ហើយសួរបញ្ហាតាមចរិត ទ្រង់ឃើញថា បណ្តាភិក្ខុទាំង ៥០០ អង្គនោះ សូម្បីតែមួយរូបក៏មិនអាច ។ ហើយទើបទ្រង់រឭកដល់ព្រះអសីតិមហាសាវ័កនិងអគ្គសាវ័កទាំង ២ ទ្រង់ឃើញថា សូម្បីអ្នកទាំងនោះក៏មិនអាចទើបទ្រង់ត្រិះរិះបន្តថា បើព្រះបច្ចេកពុទ្ធតើអាចឬហ្ន៎ ទ្រង់ជ្រាបថា សូម្បីព្រះបច្ចេកពុទ្ធក៏មិនអាច

ទើបទ្រង់វេញកដល់សក្កទេវរាជនិងស្តេចសុយាម ជាដើមថា អង្គណាមួយគប្បីអាចហ្ន៎ បើសក្កៈនិងស្តេចសុយាមអង្គណាមួយអាច ក៏នឹងឲ្យសួរ ទ្រង់នឹងឆ្លើយដោយព្រះអង្គឯង តែអ្នកទាំងនោះមិនអាចឡើយ ។

លំដាប់នោះព្រះមានព្រះភាគទ្រង់ត្រិះរិះថា ព្រះពុទ្ធដូចគ្នានឹងតថាគតប៉ុណ្ណោះគប្បីអាច តែនៅមានព្រះពុទ្ធអង្គដទៃក្នុងទីដទៃទៀតដែរឬហ្ន៎ទើបទ្រង់ផ្សាយព្រះញាណ ដែលមិនមានទីបំផុតទៅក្នុងលោកធាតុដែលមិនមានទីបំផុតត្រួតមើលលោកមិនបានឃើញព្រះពុទ្ធអង្គដទៃឡើយ កាលដែលព្រះអង្គទ្រង់មិនបានឃើញបុគ្គលស្មើព្រះអង្គក្នុងកាលឥឡូវនេះ មិនគួរអស្ចារ្យឡើយសូម្បីតែក្នុងពេលព្រះអង្គប្រសូត ក៏ទ្រង់មិនបានឃើញបុគ្គលស្មើនឹងព្រះអង្គ តាមន័យដូចពោលហើយក្នុងអដ្ឋកថាព្រហ្មជាលសូត្រ ទើបទ្រង់បន្លឺសីហនាទដែលបុគ្គលណាមួយឲ្យប្រព្រឹត្តទៅមិនបានថា **អគ្គោហមស្មិ លោកស្ស** ដូច្នេះ កាលព្រះអង្គទ្រង់មិនឃើញបុគ្គលដទៃស្មើនឹងព្រះអង្គយ៉ាងនេះទើបទ្រង់ត្រិះរិះថា បើតថាគតសួរហើយឆ្លើយដោយខ្លួនឯង ទេវតាទាំងនោះក៏មិនអាចត្រាស់ដឹងបានកាលបើព្រះពុទ្ធអង្គដទៃសួរ កាលតថាគតឆ្លើយនឹងគួរអស្ចារ្យជាង ទេវតាទាំងឡាយក៏នឹងអាចដឹងច្បាស់បាន ព្រោះហេតុនោះ តថាគតនឹងនិម្មិតនូវព្រះពុទ្ធនិមិត្ត ហើយទ្រង់ចូលឈានមានអភិញ្ញាជាបាទ ទ្រង់ចេញហើយទ្រង់ធ្វើបរិកម្ម ដោយកាមាវចរចិត្តថា ការកាន់បាត្រនិងចីវរ ការមើលទៅមុខ ការសម្លឹងមើលឆ្វេងស្តាំ ការបត់និងការលាតសណ្តូក ចូរដូចតថាគតចុះ ហើយទ្រង់អធិដ្ឋានដោយរូបាវចរចិត្តថា ពុទ្ធនិមិត្តចូរមក ដូចកញ្ចក់ដែលជាមណ្ឌល

នៃព្រះចន្ទ ដែលផុសឡើងអំពីការបិទបាំងរបស់ក្អំយុគន្ធរ នាទិសខាងកើតចុះ ពួកទេវតាឃើញដូច្នោះក៏ពោលថា អើលោកទាំងឡាយ ព្រះចន្ទរះឡើង ១ ដួង ទៀតហើយ លុះចូលមកជិត ពួកទេវតាលះព្រះចន្ទពោលថា នុ៎ះមិនមែនព្រះចន្ទទេ គឺព្រះអាទិត្យរះឡើង លុះមកជិតទៀតក៏ពោលថា មិនមែនជាព្រះអាទិត្យ ជាទេវវិមានមួយ លុះចូលជិតមកទៀតក៏ពោលថា មិនមែនទេវវិមានជាទេវ-បុត្តមួយអង្គ លុះចូលមកជិតទៀតក៏ពោលថា មិនមែនទេវបុត្ត ជាមហាព្រហ្ម មួយអង្គ លុះចូលមកជិតទៀតក៏ពោលថា មិនមែនមហាព្រហ្មជាព្រះពុទ្ធមួយ អង្គយាងមកដូច្នេះ ។

បណ្តាពួកទេវតាទាំងនោះ ទេវតាដែលជាបុថុជ្ជនគិតគ្នាថា ការប្រជុំទេវតា នេះមានព្រះពុទ្ធមួយអង្គជាធំក្រៃលែងហើយ នេះមានពីរអង្គ តើនឹងធំក្រៃលែង យ៉ាងណាហ្ន៎ ។ ពួកទេវតាដែលជាអរិយៈគិតគ្នាថា លោកធាតុ ១ មិនមានព្រះពុទ្ធ ២ អង្គឡើយ ព្រះសាស្តាទ្រង់ពិតជានិម្មិតព្រះពុទ្ធអង្គដទៃឲ្យដូចព្រះអង្គពិត ។ លំដាប់នោះកាលពួកទេវតាកំពុងមើលនោះឯង ព្រះពុទ្ធនិមិត្តយាងមកដល់មិនថ្វាយបង្គំព្រះទសពល ធ្វើព្រងើយៗក្នុងទីចំពោះព្រះភក្ត្រហើយប្រថាប់គង់ក្នុងអាសនៈដែលនិម្មិតទុក ។ ព្រះមានព្រះភាគ មានមហាបុរិសលក្ខណៈ ៣២ សូម្បីព្រះពុទ្ធនិមិត្តក៏មាន ៣២ ដូចគ្នា ។ ព្រះមានព្រះភាគមានឆព្វណ្ណរង្សីផ្សាយចេញអំពីព្រះវរកាយ សូម្បីព្រះពុទ្ធនិមិត្តក៏ដូចគ្នា រស្មីក្នុងព្រះវរកាយរបស់ព្រះមានព្រះភាគរមែងប៉ះខ្ទប់ក្នុងព្រះវរកាយរបស់ព្រះពុទ្ធនិមិត្ត ព្រះរស្មីរបស់ព្រះពុទ្ធនិមិត្ត ក៏ប៉ះខ្ទប់ក្នុងព្រះវរកាយរបស់ព្រះមានព្រះភាគ ។ ព្រះរស្មី

ទាំងនោះ ផ្សាយចេញអំពីព្រះវរកាយរបស់ព្រះពុទ្ធទាំង ២ អង្គ រហូតដល់ភវគ្គព្រហ្ម ត្រឡប់អំពីភវគ្គព្រហ្ម មកដល់ត្រង់ទីបំផុតនៃសីសៈរបស់ទេវតា ហើយប្រតិស្ឋានត្រង់កណ្ដាប់ចក្កវាឡ ។ ល្វែងនៃចក្កវាឡទាំងមូល រុងរឿងដូចខឿនចេតិយ ដែលចងដោយជហ្វាធ្វើដោយមាស ។ ពួកទេវតាក្នុងម៉ឺនចក្កវាឡប្រជុំគ្នាក្នុងចក្កវាឡមួយ ចូលទៅឈរត្រង់ចន្លោះនៃព្រះរស្មីនៃព្រះពុទ្ធទាំង ២ ព្រះអង្គ ។

ព្រះពុទ្ធនិមិត្តគ្រាន់តែគង់ប្រថាប់ប៉ុណ្ណោះ កាលនឹងទូលសួរដល់អធិប្បញ្ញាជាដើម ទើបត្រាស់គាថាដោយន័យជាដើមថា **កថំទស្សី កថំសីលោ ឧបសន្តោតិ វុច្ចតិ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះមុន ។ ព្រះពុទ្ធនិមិត្តនោះ សួរដល់អធិប្បញ្ញាថា បុគ្គលមានការឃើញដូចម្ដេច សួរដល់អធិសីលថា មានសីលដូចម្ដេច សួរដល់អធិចិត្តថា **ឧបសន្តោតិ វុច្ចតិ** ។ បទដ៏សេសជាក់ច្បាស់ហើយ ។ ដើម្បីការជាក់ច្បាស់ក្នុងបញ្ហា ដែលព្រះពុទ្ធនិមិត្តសួរជាដើម លោកពោលទុកក្នុងគម្ពីរបេដកៈដូច្នេះថា

> បុគ្គលសាកសួររមែងចូលដល់ធម៌ដែលជាកុសល ប្រកបដោយប្រយោជន៍ រមែងមិនចុតិ មិនបដិសន្ធិ ព្រះពុទ្ធទាំងឡាយទ្រង់ពោលដល់បុគ្គលនោះថា ដូចម្ដេច ។
>
> បុគ្គលមានសង្ស័យអស់ហើយ មិនទាន់ប្រាសចាកតម្រេក មិនទាន់ជាព្រះសេក្ខ មិនទាន់ឃើញធម៌ មិនទាន់ជាព្រះវិញ្ញា-

ស្រព ទ្រទ្រង់រាងកាយទុកក្នុងភពជាទីបំផុត ព្រះពុទ្ធទាំងឡាយ ទ្រង់ពោលដល់បុគ្គលនោះ ថាដូចម្តេច ។

បុគ្គលជាអ្នកមិនដល់ព្រមដោយទុក្ខសច្ចៈមិនដល់ព្រមដោយ មគ្គសច្ចៈ និរោធសច្ចៈនឹងមានអំពីណា ជាអ្នកឆ្ងាយអំពីសមុ-ទយសច្ចៈ ព្រះពុទ្ធទាំងឡាយ ទ្រង់ពោលដល់បុគ្គលនោះថា ដូចម្តេច ។

អហេតុកសត្វមិនអាស្រ័យរូប មិនមានបច្ច័យ មិនមែន អសង្ខត មានអសង្ខតជាអារម្មណ៍ មិនមានរូប ព្រះពុទ្ធទាំង ឡាយទ្រង់ពោលដល់បុគ្គលនោះ ថាដូចម្តេច ។

គាថាទាំងនោះ គាថាទី ១ គប្បីជ្រាបថា លោកពោលសំដៅដល់ព្រះពុទ្ធ និមិត្ត គាថាទី ២ ពោលសំដៅដល់ព្រះពោធិសត្វ ដែលមានភពចុងក្រោយ គាថាទី ៣ ពោលសំដៅដល់បុគ្គលដែលតាំងនៅក្នុងអរហត្តផល គាថាទី ៤ គប្បីជ្រាបថា លោកពោលសំដៅដល់ចិត្តសមង្គី ដែលជាបុរេចរិកក្នុងការ ពិចារណាដល់ព្រះនិព្វានក្នុងអរូប ។

[ ៥៥ ] បទថា **កឹធិសេន ឧស្សន្នេន** គឺការឃើញដោយអំណាចដូច ម្តេច ។ បទថា **កឹសណ្ឋិតេន** បានដល់ ដោយការឃើញសមគ្នាដូចម្តេច ។ បទថា **កឹបការេន** បានដល់ ដោយវិធីដូចម្តេច ។ បទថា **កឹបដិភាគេន** បានដល់ ដោយអាការដូចម្តេច ។

[ ៥៦ ] បទថា **យំ បុច្ឆាមិ** បានដល់ សូមត្រាស់ព្យាករដល់បុគ្គល

ដែលខ្ញុំទូលសួរដល់ខ្ញុំ ។ បទថា **យាចាមិ** បានដល់ ទូលអង្វរឲ្យប្រាប់ ។ បទថា **អជ្ឈេសាមិ** បានដល់ សូមឲ្យត្រាស់ប្រាប់ ។ បទថា **បសាទេមិ** បានដល់ សូមញ៉ាំងសោមនស្សឲ្យកើតក្នុងសន្តានរបស់ខ្ញុំ ។ បទថា **ព្រូហិ** សេចក្តីថា ត្រាស់ដល់ពាក្យលើកជាមាតិការបស់ពាក្យអធិប្បាយ ។ បទថា **អាចិក្ខ** បានដល់ ពោលវត្ថុដែលគួរសម្តែងដោយឈ្មោះ ។ បទថា **ទេសេហិ** បានដល់ ចង្អុលឲ្យឃើញ ។ បទថា **បញ្ញាបេហិ** បានដល់ ឲ្យដឹង ។ បុគ្គលតាំងស៊ប់ដោយមានញាណជាធំលោកហៅថា **បញ្ញាបេហិ** ។ បទថា **បដ្ឋបេហិ** បានដល់ បញ្ញត្ត អធិប្បាយថា ឲ្យប្រព្រឹត្តទៅឬចូរតាំងទុកដោយមាតិកា គឺញាណ ។ បទថា **វិវរ** បានដល់ ចូរធ្វើឲ្យផ្ចារ អធិប្បាយថា បើកផ្ចារសម្តែង ។ បទថា **វិភជ** សេចក្តីថា ចង្អុលបង្ហាញដោយការចែកសម្តែង ។ បទថា **ឧត្តានីករោហិ** បានដល់ សូមធ្វើឲ្យប្រាកដ ។

ម្យ៉ាងទៀតបទថា **អាចិក្ខ** ជាមូលបទនៃបទទាំងឡាយ ៦ មានទេសនាជាដើម ។ លោកពោល ៦ បទ មានបទថា សូមសម្តែងជាដើម ដើម្បីលម្អិតនូវសេចក្តីរបស់បទថា អាចិក្ខនោះឲ្យជាក់ច្បាស់ ។ ក្នុងបទទាំងនោះ បទថា **ទេសេហិ** សេចក្តីថា សូមទ្រង់សម្តែងដោយលើកមាតិកាមុន ដោយសង្ខេបដើម្បីឧគ្ឃដិតញ្ញូបុគ្គល ។ ពិតហើយបុគ្គលដែលជាឧគ្ឃដិតញ្ញូរមែងដឹងច្បាស់ចាក់ធ្លុះនូវធម៌ ដែលព្រះអង្គត្រាស់ដោយសង្ខេប នឹងត្រាស់ដឹងជាគ្រាដំបូង ។ បទថា **បញ្ញាបេហិ** សេចក្តីថា សូមទ្រង់បញ្ញត្តដោយការពង្រីកសេចក្តីនៃបទដែលសង្ខេបដោយពិស្តារ ដោយអំណាចនៃវិបចិតញ្ញូបុគ្គល គឺដោយអំណាច

នៃបុគ្គលដែលដឹងបានដោយការត្រេកអរនៃចិត្តទាំងនោះឯង ។ បទថា **បដ្ឋបេហិ** សេចក្តីថា សូមទ្រង់ដាក់ គឺតែងតាំងដោយការត្រឡប់មកសម្តែង គឺដោយការពង្រីកសេចក្តីនៃបទដែលពង្រីកសម្តែងហើយដល់បុគ្គលនោះឯង ។

បទថា **វិវរ** សេចក្តីថា សូមទ្រង់បើកផ្ទារដោយការត្រាស់ដល់ពាក្យដែលពង្រីកហើយរឿយៗ ។ បទថា **វិភជ** សេចក្តីថា សូមទ្រង់ចែកដោយការអធិប្បាយ ចែកអត្ថតាមដែលត្រាស់ហើយរឿយៗ ។ បទថា **ឧត្តានីករោហិ** សេចក្តីថា សូមទ្រង់ធ្វើឲ្យរាក់ ដោយត្រាស់បើកផ្ទារឲ្យពិស្តារនិងដោយការចង្អុលបង្ហាញសេចក្តីដែលទ្រង់ឲ្យពិស្តារហើយ ។ ទេសនានេះដើម្បីដឹងច្បាស់ចាក់ធ្លុះរបស់នេយ្យបុគ្គលដូច្នេះឯង ។

[ ៥៨ ] ក្នុងការឆ្លើយនូវបញ្ហា ព្រះមានព្រះភាគទ្រង់មិនបានឆ្លើយអធិប្បញ្ញាជាដើមដោយសរុប កាលទ្រង់សម្តែងដល់ការស្ងប់កិលេស ដែលជាហេតុឲ្យព្រះពុទ្ធនិមិត្តត្រាស់ពាក្យថា **ឧបសន្តោតិ វុច្ចតិ** ដោយសភាវៈមានអធិប្បញ្ញាជាដើមដោយអនុលោម ដល់អធ្យាស្រ័យនៃទេវតាផ្សេងៗ ទើបត្រាស់គាថាជាដើមថា **វីតតណ្ហោ** ដូច្នេះ ។

ក្នុងគាថាទាំងនោះ គប្បីជ្រាបការសម្ពន្ធនៃគាថា ៨ ជាមួយគាថានេះថា **តំ ព្រូមិ ឧបសន្តោ** ដូច្នេះ ។ បន្ទាប់អំពីនោះគប្បីជ្រាបសម្ពន្ធនៃគាថាខាងចុងដោយបទចុងក្រោយនៃគាថាទាំងអស់នេះថា **សវេ សន្តោតិ វុច្ចតី** ដូច្នេះ ។

ការអធិប្បាយន័យទៅតាមលំដាប់បទ មានដូច្នេះថា បទថា **វីតតណ្ហោ បុរាភេទា** សេចក្តីថា ព្រះអរហន្តលះតណ្ហាបានហើយមុនរំលត់ខន្ធបរិនិព្វាន ។

បទថា **បុព្វមន្តមនិស្សិតោ** គឺបុគ្គលមិនអាស្រ័យចំណែកខាងដើម មានអតីតកាលជាដើម ។ បទថា **វេមជ្ឈេ នុបសង្ខេយ្យោ** បានដល់ ដែលបុគ្គលណាមួយរាប់មិនបានដោយន័យជាដើមថា ព្រះអរហន្តត្រេកអរហើយក្នុងកាលដែលជាបច្ចុប្បន្ន ។ បទថា **តស្ស នត្ថិ បុរេក្ខតំ** បានដល់ ព្រះអរហន្តនោះមិនមាន សូម្បីការធ្វើទុកខាងមុខក្នុងកាលដែលជាអនាគត ព្រោះមិនមានការធ្វើទុកខាងមុខ ទាំង ២ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា តថាគតហៅបុគ្គលនោះថា អ្នកស្ងប់ដូច្នេះ ។

[ ៥៩ ] បទថា **បុរា កាយស្ស ភេទា** បានដល់ មុនអំពីករជកាយបែកធ្លាយនោះឯង ។ បទថា **អត្តភាវស្ស** បានដល់ អត្តភាពទាំងអស់ ។ បទថា **កឡេវរស្ស និក្ខេបា** បានដល់ ដាក់ចុះនូវរាងកាយ គឺដាក់ចុះនូវសរីរៈ ។

បទថា **ជីវិតិន្ទ្រិយស្ស ឧបច្ឆេទា** បានដល់ មុនអំពីដាច់ជីវិតិន្ទ្រិយទាំង ២ យ៉ាង ។

[ ៦០ ] បទថា **បុព្វន្តោ វុច្ចតិ អតីតោ អទ្ធា** បានដល់ អតីតកាលគឺកាលដែលកន្លងទៅហើយលោកហៅថា ចំណែកខាងដើម ។ បទថា **អតីតំ អទ្ធានំ អារព្ភ** បានដល់ លះតណ្ហាដែលអាស្រ័យអតីតកាលបានហើយ ។

ព្រះសារីបុត្តត្រេកាលសម្ដែងដល់កត្តេករត្តិបរិយាយដទៃទៀតទើបពោលពាក្យជាដើមថា **អថវា** ដូច្នេះ ។ ក្នុងសេចក្ដីនោះបទថា **ឯវំរូបោ អហោសឹ** បានដល់ អាត្មាអញមានរូបយ៉ាងនោះ ដោយជារូបដែលគួរពេញចិត្តយ៉ាងនេះ

ថា ទោះបីខ្មៅ ក៏មានពណ៌ដូចកែវមណីពណ៌បៃតង ។ អាត្មាអញមានវេទនាយ៉ាងនេះក្នុងអតីតកាល ដោយអំណាចសុខវេទនានិងសោមនស្សវេទនាដែលជាកុសល អាត្មាអញមានសញ្ញាយ៉ាងនេះ មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះដោយអំណាចសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះឯង ។ បទថា **តត្ថ នន្ទឹ ន សមន្នានេតិ** បានដល់ ព្រះអរហន្តទាំងឡាយមិនធ្វើតណ្ហាឲ្យប្រព្រឹត្តទៅក្នុងរូបជាដើមនោះ ឬធ្វើទិដ្ឋិដែលសម្បយុត្តដោយតណ្ហានោះឲ្យប្រព្រឹត្តទៅ ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងមហាកច្ចានកត្ថេរត្ថបរិយាយ ដោយបរិយាយដទៃទៀត ទើបពោលពាក្យថា **អថវា ឥតិ មេ ចក្ខុ អហោសិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ចក្ខុ** បានដល់ ចក្ខុបសាទ ។ បទថា **រូបា** បានដល់ រូបដែលមានសមុដ្ឋាន ៤ ។ គប្បីជ្រាបអាតយនៈទាំងឡាយដ៏សេសដោយន័យនេះ ។ បទថា **វិញ្ញាណំ** បានដល់ វិញ្ញាណដែលជាទីអាស្រ័យ ។ បទថា **ន តទភិនន្ទតិ** បានដល់ មិនត្រេកអរក្នុងចក្ខុនិងរូបនោះដោយអំណាចតណ្ហានិងទិដ្ឋិ ។ បទថា **ឥតិ មេ មនោ អហោសិ ឥតិ ធម្មា** ពាក្យថា **មនោ** ជាភវង្គចិត្ត ។ បទថា **ធម្មា** បានដល់ ធម្មារម្មណ៍ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **ហសិតលបិតកីឡិតានិ** បានដល់ សើចរហូតឃើញធ្មេញ ចរចា ក្អាកក្អាយនិងលេងផ្លូវកាយជាដើម ។ បទថា **ន តទស្សាទេតិ** បានដល់ ព្រះអរហន្ត រមែងមិនត្រេកអរក្នុងការសើចជាដើមនោះ ។ បទថា **ន តំ និកាមេតិ** បានដល់ មិនធ្វើនូវការប្រាថ្នា ។ បទ

ថា **ន ច តេន វិត្តឹ អាបជ្ជតិ** បានដល់ ព្រះអរហន្តមិនដល់នូវការត្រេកអរ ដោយការសើចជាដើមនោះ ។

[ ៦១ ] ឈ្មោះថា **បច្ចុប្បន្នោ** ព្រោះអត្ថវិគ្គហថា កើតឡើងព្រោះអាស្រ័យបច្ច័យនោះៗ ។ បទថា **រត្តោតិ នុបសេវ្វយ្យា** បានដល់ ដែលបុគ្គលណាមួយរាប់មិនបានថាជាអ្នកត្រេកអរ ដោយការត្រេកអរ ។ បទតទៅក៏មានន័យនេះដូចគ្នា ។

[ ៦២ ] ក្នុងបទជាដើមថា **ឯវំ្វចោ សិយំ** គប្បីជ្រាបការប្រព្រឹត្តទៅតាមការត្រេកអរ ដែលបានដល់ការប្រព្រឹត្តទៅដោយតណ្ហានិងទិដ្ឋិ ដោយអំណាចរូបដែលប្រណីតនិងដែលគួរពេញចិត្តជាដើម ។ បទថា **ន បណិធហាតិ** បានដល់ មិនតាំងនៅដោយអំណាចនៃសេចក្ដីប្រាថ្នា ។ បទថា **អប្បណិធា-នប្បច្ចយា** បានដល់ គឺព្រោះមិនតាំងសេចក្ដីប្រាថ្នាទុក ។

[ ៦៣ ] បទថា **អសន្តាសី** បានដល់ ព្រោះការមិនបាននោះៗ ។ បទថា **អវិកត្ថី** បានដល់ មានប្រក្រតីមិនអួតអាងដោយសីលជាដើម ។ បទថា **អក្កុក្កុចោ** បានដល់ វៀរចាកការរពឹសដៃជាដើម ។ បទថា **មន្តភាណី** បានដល់ កំណត់ដោយបញ្ញាមុនហើយទើបពោល ។ បទថា **អនុទ្ធតោ** បានដល់ វៀរចាកការរាយមាយ ។ បទថា **ស វេ វាចាយតោ** បានដល់ សង្រួមក្នុងការនិយាយ ជាអ្នកពោលវាចាវៀរចាកទោស ៤ ប្រការ ។

[ ៦៤ ] បទថា **អក្កោធនោតិ យំ ហិ ខោ វុត្តំ** សេចក្ដីថា ពាក្យណាដែលព្រះមានព្រះភាគត្រាស់ថា បុគ្គលមិនក្រោធ គឺវៀរចាកសេចក្ដីក្រោធ

ព្រះសារីបុត្ត បំណងនឹងពោលពាក្យនោះ គឺសេចក្តីក្រោធមុន ទើបពោលថា **អបិច កោធោ តាវ វត្តព្វោ** ដូច្នេះ ។ បទថា **កោធោ តាវ វត្តព្វោ** បានដល់ គួរពោលសេចក្តីក្រោធមុន ។ បទថា **ទសហាការេហិ កោធោ ជាយតិ** បាន ដល់ សេចក្តីក្រោធរមែងកើតឡើងដោយហេតុ ១០ យ៉ាង ។ បទថា **អនត្ថំ មេ អចរិ** បានដល់ បុគ្គលនោះបានធ្វើនូវសេចក្តីមិនចម្រើនឲ្យដល់អញ ។ គប្បី ជ្រាបបទទាំងអស់ដោយទំនងនេះ ។ បទថា **អដ្ឋានេ វា បន កោធោ ជាយតិ** សេចក្តីថា មិនមែនជាឋានៈដែលគួរក្រោធក៏កើតសេចក្តីក្រោធព្រោះ បុគ្គលខ្លះ ភ្លៀងធ្លាក់ច្រើនក៏ក្រោធ ភ្លៀងមិនធ្លាក់ក៏ក្រោធ ព្រះអាទិត្យក្តៅក៏ ក្រោធ មិនក្តៅក៏ក្រោធ ខ្យល់បក់ក៏ក្រោធ ខ្យល់មិនបក់ក៏ក្រោធ មិនអាច បោសស្លឹកពោធិ៍ត្រង់ដើមពោធិ៍បានក៏ក្រោធ មិនអាចដណ្តប់ចីវរបាន ព្រោះ ខ្យល់ក៏ក្រោធ ជំពប់ជើងក៏ក្រោធនឹងដង្គត់ លោកពោលថា អាឃាតរមែងកើត ក្នុងទីដែលមិនមែនឋានៈសំដៅដល់សេចក្តីនេះ ។ ការផ្សេងគ្នានៃកម្មបថរមែង មានព្រោះកើតឡើងប្រារព្ធសត្វទាំងឡាយក្នុងឋានៈ ៩ យ៉ាងខាងដើមនោះ ។ តែអាឃាតក្នុងទីដែលមិនមែនជាឋានៈកើតក្នុងសង្ខារទាំងឡាយ រមែងមិនធ្វើ នូវការបែកធ្លាយនៃកម្មបថ ។ ឈ្មោះថា **ចិត្តស្ស អាឃាតោ** ព្រោះអត្ថថា ចិត្តកើតនូវអាឃាត ។ ការប្រទូស្តមានកម្លាំងច្រើនជាងនោះ ឈ្មោះថា **បដិ-ឃាតោ** ។ ឈ្មោះថា **បដិឃំ** ដោយអំណាចការបៀតបៀនឈ្មោះថា **បដិវិរោធោ** ព្រោះអត្ថថា ក្រោធតប ។ ឈ្មោះថា **កោបោ** ដោយអំណាចសេចក្តីក្រោធ ។ បទថា **បកោបោ សម្បកោបោ** លោកបន្ថែមដោយអំណាចឧបសគ្គ ។ ឈ្មោះ

ថា **ទោសោ** ដោយអំណាចការប្រទូស្ត ។ បទថា **បទោសោ សម្បទោសោ** លោកបន្ថែមដោយអំណាចឧបសគ្គ ។ ភាពដែលចិត្តឃើញខុស អាការឃើញខុស អាការប្រែប្រួលខុស ឈ្មោះថា **ចិត្តស្ស ព្យាបត្តិ** ។ ឈ្មោះថា **មនោបទោសោ** ព្រោះចិត្តកើតនូវការប្រទូស្ត ។ ឈ្មោះថា **កោធោ** ដោយអំណាចការអាក់អន់ ។ អាការដែលក្រោធឈ្មោះថា **កុជ្ឈនា** ។ ភាពជាបុគ្គលដែលក្រោធហើយឈ្មោះថា **កុជ្ឈិតត្តំ** ។ ឈ្មោះថា **ទោសោ** ព្រោះអត្ថថា ប្រទូស្ត ។ បទថា **ទុស្សនា** បានដល់ អាការៈប្រទូស្ត ។ បទថា **ទុស្សិតត្តំ** បានដល់ភាវៈដែលប្រទូស្ត ។ ការព្យាបាទឈ្មោះថា **ព្យាបត្តិ** ដោយអត្ថថា លះសភាវៈដើម ។ បទថា **ព្យាបជ្ជនា** បានដល់ អាការដែលព្យាបាទ ។ បទថា **វិរោធោ** ព្រោះអត្ថថា ខឹងក្រោធ ។ ឈ្មោះថា **បដិវិរោធោ** ព្រោះអត្ថថា ខឹងក្រោធរឿយៗ ។ ពាក្យនេះលោកពោលដោយអំណាចនៃអាការខឹងក្រោធនិងអាការខឹងក្រោធតប ។ បុគ្គលរឹងត្អឹង ជាអ្នកកាចឈ្មោះថា **ចណ្ឌោ** ។ ភាពជាអ្នកកាចឈ្មោះថា **ចណ្ឌិក្កំ** ។ ឈ្មោះថា **អស្សុរោបោ** ព្រោះអត្ថថា ជាធម្មជាតិបណ្តុះវាចាល្អមិនបាន គឺពោលល្អមិនបាន មិនល្អបរិបូណ៌នោះឯង ។ ពិតហើយក្នុងពេលក្រោធ រមែងមិនមានវាចាដែលបរិបូណ៌ ។ ពាក្យថា វាចាបរិបូណ៌នឹងមានដល់បុគ្គលណា ក៏មិនជាប្រមាណ ។ អាចារ្យមួយពួកពោលថា ឈ្មោះថា **អសុរោបោ** ព្រោះបង្ហូរនូវទឹកភ្នែក ដោយអត្ថថា ឲ្យកើតទឹកភ្នែក ។ នុ៎ះមិនសមហេតុព្រោះសូម្បីចិត្តត្រេកអរក៏កើតទឹកភ្នែកបាន ។ បទថា **អនត្តមនតា** បានដល់ ព្រោះមិនមានចិត្តត្រេកអរដោយផ្ទុយគ្នា នឹងមានចិត្ត

ត្រេកអរដូចបានពោលខាងដើម ។ ព្រោះការមិនត្រេកអរនៃចិត្តនោះរមែងមានដល់ចិត្តប៉ុណ្ណោះ មិនមានដល់សត្វ ហេតុនោះ ទើបព្រះសារីបុត្តពោលថា **ចិត្តស្ស** ។

បទថា **អធិមត្តបរិត្តតា វេទិតព្វា** បានដល់ គឺការច្រើននិងការតិច អធិប្បាយថា ការក្រោធមានកម្លាំងច្រើននិងមានកម្លាំងតិច ។ បទថា **កញ្ចិ កាលេ** បានដល់ ជួនកាល ។ បាឋៈថា **កញ្ចិ កាលំ** ក៏មាន ។ បទថា **ចិត្តាវិលករណមត្តោ ហោតិ** បានដល់ មានប្រមាណត្រឹមតែធ្វើចិត្តឲ្យល្អក់ អធិប្បាយថា ត្រឹមតែធ្វើចិត្តឲ្យសៅហ្មង ។ បាឋៈថា **ចិត្តលសករណមត្តោ** ដូច្នេះក៏មាន ។ ពាក្យនោះមិនល្អ ។ អធិប្បាយថា ត្រឹមតែធ្វើចិត្តឲ្យលំបាក ។ បទថា **ន ច តាវ មុខកុលានវិកុលានោ ហោតិ** បានដល់ មិនទាន់ធ្វើមុខជូរ មុខស្អុយ ។ បទថា **ន ច តាវ ហនុសញ្ចោបនោ ហោតិ** បានដល់ មិនទាន់ធ្វើឲ្យញ័របង្កាក៏មាន ។ បទថា **ន ច តាវ ផរុសវាចំ និច្ឆារណោ ហោតិ** បានដល់ មិនទាន់ចេញមកខាងក្រៅ ដោយការបន្លឺផរុសវាចាដោយមាត់កាត់នូវហទយៈអ្នកដទៃ ។ បទថា **ន ច តាវ ទិសាវិទិសំ អនុវិលោកនោ ហោតិ** បានដល់ មិនទាន់ឲ្យក្រឡេកមើលទិសតូចទិសធំរឿយៗ ដើម្បីរកដំបងជាដើម ដើម្បីវាយអ្នកដទៃ ។ បទថា **ន ច តាវ ទណ្ឌសត្ថបរាមសនោ ហោតិ** បានដល់ មិនដល់ថ្នាក់ចាប់ដំបងនិងសស្ត្រាដែលមានមុខតែម្ខាងជាដើម ដើម្បីប្រទូស្ត ។ បទថា **ន ច តាវ ទណ្ឌសត្ថអព្ភុក្កិរណោ ហោតិ** បានដល់ មិនដល់ថ្នាក់ចាប់ដំបងនិងសស្ត្រាប្រហារ ដូចពោលហើយ

ក៏មាន ។ បទថា **ន ច តាវ ឧណ្ហសត្ថអភិនិបាតនោ ហោតិ** បានដល់ មិនដល់ថ្នាក់គ្រវែងដំបងនិងសស្ត្រាទាំង ២ យ៉ាង ដើម្បីប្រហារអ្នកដទៃ ។ បទថា **ន ច តាវ ឆិន្នវិច្ឆិន្នការណោ ហោតិ** បានដល់ មិនធ្វើឲ្យរាងកាយអ្នកដទៃដាច់ជា ២ ចំណែក ដោយការវាយដោយដំបងនិងការកាប់ ដោយសស្ត្រាជាដើមនិងមិនធ្វើឲ្យរបួសដោយអាការច្រើនយ៉ាង ។ បាឋៈថា **ឆិន្នវិ-ច្ឆិន្នការណោ** ដូច្នេះក៏មាន ។ បទថា **ន ច តាវ សម្ភញ្ជនបលិភញ្ជនោ ហោតិ** បានដល់ មិនទាន់ធ្វើឲ្យរាងកាយដាច់ជាកំណាត់តូចធំ ។ បទថា **ន ច តាវ អង្គមង្គាបកឌ្ឍនោ ហោតិ** សេចក្តីថា មិនទាន់ធ្វើឲ្យអវយវៈតូចធំដាច់បេញទៅ ។ បទថា **ន ច តាវ ជីវិតា បនាសនោ ហោតិ** បានដល់ មិនដល់ថ្នាក់ឲ្យជីវិតិន្ទ្រិយរលត់ ។ បទថា **ន ច តាវ សព្វចាគបរិច្ចាគ-សណ្ឋិតោ ហោតិ** បានដល់ មិនទាន់ឲ្យជីវិតទាំងអស់របស់អ្នកដទៃវិនាស ឬជីវិតរបស់ខ្លួនវិនាស ។ សេចក្តីនេះលោកអធិប្បាយថា កាលណាសេចក្តីក្រោធតាំងនៅដល់ថ្នាក់សម្លាប់អ្នកដទៃ ហើយទើបសម្លាប់ខ្លួនឯង កាលនោះឈ្មោះថា ផ្តាច់បង់ជីវិតទាំងពួង ។ សមដូចព្រះមានព្រះភាគត្រាស់ ( ទុកក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា

ព្រះមានព្រះភាគត្រាស់ថា បុគ្គលកាត់បង់នូវសេចក្តីក្រោធទើបដេកជាសុខ បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបមិនសោកសៅ ម្នាលព្រាហ្មណ៍ ពួកព្រះអរិយៈ តែងសរសើរនូវការសម្លាប់សេចក្តីក្រោធ ដែលមានឫសជាពិស មានចុងដ៏ផ្អែម

ព្រោះថា បុគ្គលកាត់បង់នូវសេចក្ដីក្រោធនោះបានហើយ ទើបមិនសោកសៅ ដូច្នេះ ។

បទថា **យតោ** បានដល់ ក្នុងកាលណា ។ បទថា **បរបុគ្គលំ ឃាតេត្វា** បាដល់ ធ្វើបុគ្គលដទៃឲ្យវិនាស ។ បទថា **អត្តានំ ឃាតេតិ** បានដល់ ញុំាងខ្លួនឲ្យស្លាប់ ។ បទថា **បរមុស្សទគតោ** បានដល់ ដល់នូវការមានកម្លាំងក្រៃលែង ។ បទថា **បរមវេបុល្លប្បត្តោ** បានដល់ ដល់នូវភាពជារបស់បរិបូណ៌ក្រៃលែង ។ បទថា **កោធស្ស បហីនត្តា** បានដល់ ព្រោះលះសេចក្ដីក្រោធមានប្រការដូចពោលហើយ បានដោយអនាគាមិមគ្គ ។ បទថា **កោធវត្ថុស្ស បរិញ្ញាតត្តា** បានដល់ ព្រោះកំណត់ដឹងដើមហេតុ ដែលបានដល់វត្ថុជាទីស្រឡាញ់ វត្ថុមិនជាទីស្រឡាញ់និងវត្ថុ ដែលមិនមែនឋានៈដែលជាទីតាំង គឺជាហេតុនៃសេចក្ដីក្រោធដោយញាតបរិញ្ញានិងតីរណបរិញ្ញា ។ បទថា **កោធហេតុស្ស ឧបច្ឆិន្នត្តា** បានដល់ ព្រោះកាត់នូវចិត្តុប្បាទដែលសហគតៈដោយទោមនស្សដែលជាហេតុឲ្យសេចក្ដីក្រោធកើត ។

[ ៦៥ ] បទថា **តាសី** បានដល់ មានការខ្លាចជាប្រក្រតី ។ បទថា **ឧត្តាសី** បានដល់ មានការតក់ស្លុតក្រៃលែងជាប្រក្រតី ។ បទថា **បរិត្តាសី** បានដល់ មានការខ្លាចជាប្រក្រតីដោយជុំវិញ ។ បទថា **ភាយតិ** បានដល់ ដល់នូវការខ្លាច ។ បទថា **សន្តាសំ អាបជ្ជតិ** បានដល់ ដល់នូវការខុសប្រក្រតី ។

[ ៦៦ ] បទថា **កត្ថី ហោតិ** បានដល់ មានប្រក្រតីពោលនូវគុណ

របស់ខ្លួន ។ បទថា **វិកត្ថី** បានដល់ ជាអ្នកមានប្រក្រតីពោលគុណដោយប្រការផ្សេងៗច្រើនយ៉ាង ។ បទថា **ជាតិយា វា** បានដល់ ដល់ព្រមដោយជាតិមានភាពជាក្សត្រជាដើម ។ បទថា **គោត្តេន វា** បានដល់ ដោយគោ-តមគោត្តជាដើម ឬដោយគោត្តខ្ពង់ខ្ពស់ ។ បទថា **កោលបុត្តិយេន វា** បានដល់ ដោយភាពជាអ្នកមាននូវកូលធំ ។ បទថា **វណ្ណពោក្ខរតាយ វា** បានដល់ ដោយភាពជាអ្នកមានរាងកាយបរិបូណ៌ ដោយពណ៌សម្បុរ ។ សរីរៈលោកហៅថា **ពោក្ខរ** អធិប្បាយថា ព្រោះមានរូបស្អាតបរិបូណ៌ដោយពណ៌សម្បុរនៃសរីរៈ ។ បទថា **ធនេន វា** ជាដើម មានអត្ថងាយយល់ហើយ ។

[ ៦៧ ] បទថា **កុក្កុច្ចំ** បានដល់ ជាបទសម្តែងមាតិកានៃបទអធិប្បាយ ។ ក្នុងបទនោះ បទថា **កុក្កុច្ចំ** សេចក្តីថា ការធ្វើដែលគួរខ្ពើមឈ្មោះថា **កុក្កុច្ចំ** ភាវៈនៃការក្តៅក្រហាយក្នុងកាលជាខាងក្រោយ ឈ្មោះថា **កុក្កុច្ចំ** ។ កុក្កុច្ចនោះមានការក្តៅក្រហាយក្នុងកាលជាខាងក្រោយ ជាលក្ខណៈមានសេចក្តីសោកដល់វត្ថុដែលធ្វើហើយនិងមិនទាន់បានធ្វើ ជាកិច្ចមានការក្តៅក្រហាយ ជាបច្ចុប្បដ្ឋាន មានការធ្វើនិងការមិនធ្វើជាបទដ្ឋានគប្បីឃើញដូចភាពជាទាសៈ ។ បទថា **ហត្ថកុក្កុច្ចម្បិ** បានដល់ ធ្វើនូវភាពគួរស្អប់គឺភាពគួរខ្ពើមដោយដៃ ។ ភាវៈនៃការរពឹសដៃឈ្មោះថា **ហត្ថកុក្កុច្ច** ។ ក្នុងបាទកុក្កុច្ចជាដើមក៏មានន័យនេះដូចគ្នា ។ បទថា **អកប្បិយេ កប្បិយសញ្ញិតា** បានដល់ ទំពាស៊ីសាច់ខ្លាឃ្មុំសម្គាល់ថាជាសាច់ជ្រូក ទំពាស៊ីសាច់ខ្លាដំបងដោយសម្គាល់ថា ជាសាច់ម្រឹគបរិភោគភោជនដែលជាអកប្បិយដោយសម្គាល់ថាជាកប្បិយភោជន បរិភោគ

ក្នុងវេលាវិកាលសម្គាល់ថាជាកាល ផឹកទឹកដែលជាអកប្បិយ ដោយសម្គាល់ថាជាទឹកកប្បិយ នេះឈ្មោះថា ការសម្គាល់ក្នុងវត្ថុមិនគួរ ថាគួរ ។ បទថា **កប្បិយេ អកប្បិយសញ្ញិតា** បានដល់ ទំពាស៊ីនូវសាច់ជ្រូកដោយសម្គាល់ថាជាសាច់ខ្លាឃ្មុំ ទំពាស៊ីសាច់ម្រឹគដោយសម្គាល់ថាជាសាច់ខ្លាដំបង បរិភោគភោជនដែលជាកប្បិយដោយសម្គាល់ថាជាអកប្បិយភោជន បរិភោគក្នុងកាលដោយសម្គាល់ថាជាវេលាវិកាល ផឹកទឹកដែលជាកប្បិយដោយសម្គាល់ថាជាទឹកអកប្បិយ នេះឈ្មោះថា សម្គាល់ក្នុងវត្ថុគួរ ថាមិនគួរ ។ បទថា **អវជ្ជេ វជ្ជសញ្ញិតា** បានដល់ សម្គាល់ក្នុងវត្ថុមិនមានទោសថាមានទោស ។ បទថា **វជ្ជេ អវជ្ជសញ្ញិតា** បានដល់ សម្គាល់ក្នុងវត្ថុមានទោសថាមិនមានទោស ។ បទថា **កុក្កុច្ចាយនា** បានដល់ អាការនៃការស្តាយក្រោយ ។ បទថា **កុក្កុច្ចាយិតត្តំ** បានដល់ ភាវៈនៃបុគ្គលស្តាយក្រោយ ។ បទថា **ចេតសោ វិប្បដិសារោ** បានដល់ ចិត្តខុសប្រក្រតី ចិត្តរោលរាល ។ បទថា **មនោវិលេខោ** បានដល់ ភាពជាស្នាមគឺការប្រេះស្រាំនៃចិត្ត ។

បទថា **កតត្តា ច អកតត្តា ច** បានដល់ ព្រោះធ្វើកាយទុច្ចរិតជាដើម និងព្រោះមិនធ្វើនូវកាយសុចរិតជាដើម ។ បទថា **កតំ មេ កាយទុច្ចរិតំ** បានដល់ អាត្មាអញធ្វើនូវការប្រព្រឹត្តទុច្ចរិតផ្លូវកាយ ព្រោះការស្អុយរបស់កិលេសផ្លូវកាយ ។ បទថា **អកតំ មេ កាយសុចរិតំ** បានដល់ អាត្មាអញ មិនធ្វើការប្រព្រឹត្តសុចរិតដោយកាយ ។ ក្នុងវចីទុច្ចរិតនិងវចីសុចរិតជាដើម ក៏មានន័យនេះដូចគ្នា រហូតដល់ចុងក្រោយ គឺនិរោធ ។

[ ៦៨ ] បទថា **ចិត្តស្ស** បានដល់ មិនមែនសត្វ មិនមែនបុគ្គល ។ បទថា **ឧទ្ធច្ចំ** បានដល់ អាការរាយមាយ ។ បទថា **អវូបសមោ** បានដល់ មិនមានការស្ងប់ ។ ចិត្តញាប់ញ័រ ព្រោះហេតុនោះ ទើបឈ្មោះថា **ចេតសោ វិក្ខេបោ** ។ បទថា **ភន្តត្តំ ចិត្តស្ស** បានដល់ ភាពដែលចិត្តវិលទៅដូចយាន វិលទៅមួយអន្ទើដោយគោជាដើម ។ ក្នុងសេចក្ដីនេះ លោកពោលការអន្ទះអន្ទែងក្នុងអារម្មណ៍តែមួយនោះឯង ពិតហើយការរាយមាយ រមែងញាប់ញ័រទៅក្នុងអារម្មណ៍ ១ ការសង្ស័យរមែងញាប់ញ័រទៅក្នុងអារម្មណ៍ផ្សេងៗ ។ បទថា **ឥទំ វុច្ចតិ ឧទ្ធច្ចំ** បានដល់ នេះលោកហៅថា ភាវៈនៃការរាយមាយ ។

[ ៦៩ ] បទថា **មុសាវាទំ បហាយ** នេះ ពាក្យថា មុសា បានដល់ វចីបយោគឬកាយប្បយោគ ដែលកាច់បំបាក់នូវប្រយោជន៍របស់បុគ្គល ដែលបំណងនឹងពោលឲ្យខុស ។ ចេតនាដែលជាទីតាំងនៃកាយប្បយោគ ឬវចីបយោគរបស់អ្នកពោលដើម្បីឲ្យបុគ្គលដទៃយល់ខុស ដោយបំណងនឹងពោលឲ្យខុសឈ្មោះថា **មុសាវាទ** ។

ម្យ៉ាងទៀត បទថា **មុសា** បានដល់ រឿងដែលមិនពិត មិនប្រាកដ ។ បទថា **វាទោ** បានដល់ ការឲ្យបុគ្គលនោះដឹងនូវវត្ថុនោះដោយសេចក្ដីពិត ដោយភាពប្រាកដ ។ ម្យ៉ាងទៀតដោយលក្ខណៈចេតនា ដែលតាំងឡើងដើម្បីឲ្យបុគ្គលនោះដឹងយ៉ាងនោះរបស់អ្នកដែលបំណងឲ្យអ្នកដទៃដឹងវត្ថុ ដែលមិនពិតដោយសេចក្ដីពិត ឈ្មោះថា **មុសាវាទ** ។ នូវមុសាវាទនោះ ។ បទថា **បហាយ** បានដល់ លះនូវភាពជាអ្នកទ្រុស្តសីល ដែលបានដល់ចេតនានឹង

ពោលកុហកនោះចោល ។ បទថា **បដិវិរតោ** បានដល់ វៀរចាកភាពជាអ្នកទ្រុស្តសីលនោះតាំងអំពីពេលលះបានហើយ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងឡាយបែបនេះ សូម្បីដទៃដោយន័យនេះថា វត្ថុដែលដែលសម្តែងឲ្យដឹងដោយចិត្តរបស់បុគ្គលនោះតាមផ្លូវភ្នែកនិងផ្លូវត្រចៀកក៏មិនទាន់មាន នឹងពោលទៅថ្វីតាមផ្លូវកាយ ។

ឈ្មោះថា **សច្ចវាទី** ព្រោះអត្ថថា ពោលពិត ។ ឈ្មោះថា **សច្ចសន្ធោ** ព្រោះអត្ថថា បន្ត គឺតពាក្យសច្ចៈដោយពាក្យសច្ចៈ អធិប្បាយថា មិនពោលកុហកក្នុងចន្លោះៗ ។ ពិតហើយបុគ្គលណាជួនកាលនិយាយកុហក ជួនកាលនិយាយពិត ពាក្យសច្ចៈរបស់បុគ្គលនោះមិនតដោយភាពសច្ចៈ ព្រោះបុគ្គលនោះ និយាយ កុហកក្នុងចន្លោះ ព្រោះហេតុនោះ បុគ្គលនោះបានឈ្មោះថាមិនតាំងនៅក្នុងពាក្យសច្ចៈ ។ ចំណែកបុគ្គលនេះមិនដូច្នោះឡើយ មិននិយាយកុហក សូម្បីព្រោះហេតុនៃជីវិត រមែងតម្កល់នូវសច្ចៈទុកដោយសច្ចៈប៉ុណ្ណោះព្រោះហេតុនោះទើបឈ្មោះថា **សច្ចសន្ធោ** ។ បទថា **ថេតោ** បានដល់ មាំទាំ អធិប្បាយថា មានពាក្យសម្តីមាំទាំ ។ បុគ្គលខ្លះជាអ្នកមានពាក្យមិនមាំទាំដូចពណ៌សំពត់ជ្រលក់ល្មៀត ដូចបង្គោលដែលដោតលើគំនរអង្កាម ដូចត្រឡាចដាក់លើខ្នងសេះ ។ បុគ្គលខ្លះជាអ្នកតម្កល់នូវវាចាទុក ដូចគំនូសលើថ្មនិងដូចសសរខឿនដូច្នោះ ។ សូម្បីយកដាវកាត់ក្បាលក៏មិនពោលពាក្យបែកជា ២ បុគ្គលនេះ លោកហៅថា **ថេតោ** ។ បទថា **បច្ចយិកោ** បានដល់គប្បីជឿបាន អធិប្បាយថា មាំទាំក្នុងពាក្យសច្ចៈ ។ ពិតហើយ បុគ្គលខ្លះជឿ

*មិនបាន កាលគេពោលថា ពាក្យនេះអ្នកណាពោល ( បើមានអ្នកតបថា ) បុគ្គលនោះពោលក៏ពោលបានថា ពួកអ្នកកុំជឿពាក្យរបស់បុគ្គលនោះឡើយ ។ បុគ្គលមួយទៀតជឿបាន កាលគេពោលថា ពាក្យនេះអ្នកណាពោល ( បើមានអ្នកតបថា ) បុគ្គលនោះពោលក៏ពោលបានថា បើបុគ្គលនោះពោលកាន់យកជាប្រមាណបាន មិនចាំបាច់សាកសួររឿងនេះពិតជាយ៉ាងនោះ បុគ្គលនេះលោកហៅថា* **បច្ចយិកោ** *។ បទថា* **អវិសំវាទកោ លោកស្ស** *សេចក្តីថា មិនពោលឲ្យសត្វលោកយល់ខុស ព្រោះជាអ្នកពោលនូវពាក្យសច្ចៈនោះ ។ គប្បីជ្រាបសេចក្តីក្នុងបទជាដើមថា* **បិសុណំ វាចំ បហាយ** *ដូចតទៅនេះថា វាចាដែលបុគ្គលពោល ធ្វើឲ្យបុគ្គលដទៃស្រឡាញ់ខ្លួន ធ្វើនូវការញុះញង់ដល់អ្នកដទៃ ឈ្មោះថា* **បិសុណាវាចា** *ចំណែកវាចាដែលធ្វើនូវការគ្រោតគ្រាតឲ្យខ្លួនឯងខ្លះ ឲ្យអ្នកដទៃខ្លះ សូម្បីវាចាខ្លួនឯងក៏គ្រោតគ្រាមិនពីរោះស្តាប់ស្តាប់ហើយចិត្តមិនមានសេចក្តីសុខ ឈ្មោះថា* **ផរុសវាចា** *។ វាចាដែលជាហេតុឲ្យបុគ្គលពោលនូវពាក្យរោយរាយ មិនមានប្រយោជន៍ឈ្មោះថា* **សម្ផប្បលាប** *។ សូម្បីចេតនាណាដែលជាហេតុនៃវាចាទាំងនោះ រមែងបានឈ្មោះថា បិសុណាវាចាជាដើមដូចគ្នា ចេតនានោះឯងលោកបំណងយកក្នុងទីនេះ ។ បទថា* **ឥមេសំ ភេទាយ** *បានដល់ ស្តាប់ពាក្យក្នុងសម្នាក់ជនឯណោះហើយទៅបំបែកជនឯណោះ ។ បទថា* **ភិន្នានំ វា សន្ធាតា** *បានដល់ កាលមិត្ត ២ នាក់ឬបុគ្គលដែលរួមឧបជ្ឈាយ៍ជាមួយគ្នាជាដើមបែកគ្នាដោយហេតុណាមួយ បុគ្គលនោះចូលទៅរកបុគ្គលម្នាក់ៗ ហើយពោលពាក្យជាដើមថា ការបែកគ្នានេះមិន*

សមគួរដល់អ្នកទាំងឡាយដែលកើតក្នុងត្រកូលបែបនេះ ជាពហុស្សូតយ៉ាងនេះ ឈ្មោះថា ធ្វើនូវការផ្សះផ្សា ។ បទថា **អនុប្បទាតា** បានដល់ បន្ថែមកម្លាំងដល់អ្នករាប់អានគ្នា អធិប្បាយថា ឃើញមនុស្ស ២ នាក់ ព្រមព្រៀងគ្នាហើយ ពោលពាក្យជាដើមថា នេះសមគួរដល់ពួកអ្នក ដែលកើតក្នុងត្រកូលបែបនេះ ប្រកបដោយគុណបែបនេះហើយធ្វើឲ្យធ្ងន់ក្រៃលែង ។ ឈ្មោះថា **សមគ្គារាមោ** ព្រោះអត្ថថា បុគ្គលដែលព្រមព្រៀងគ្នា ជាទីត្រេកអររបស់បុគ្គលនោះ អធិប្បាយថា បុគ្គលដែលព្រមព្រៀងមិនមានក្នុងទីណា រមែងមិនប្រាថ្នានឹងនៅក្នុងទីនោះ ។ បាលីថា **សមគ្គរាមោ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **សមគ្គរតោ** បានដល់ ត្រេកអរក្នុងបុគ្គលដែលព្រមព្រៀងគ្នា អធិប្បាយថា មិនប្រាថ្នាលះបុគ្គលទាំងនោះ ហើយទៅក្នុងទីដទៃ ។ ឈ្មោះថា **សមគ្គនន្ទី** ព្រោះអត្ថថា ឃើញក្តី ឮក្តីនូវបុគ្គលដែលព្រមព្រៀងគ្នារមែងត្រេកអរ ។ បទថា **សមគ្គករណឹ វាចំ ភាសិតា** បានដល់ ពោលវាចាដែលធ្វើឲ្យសត្វទាំងឡាយព្រមព្រៀងគ្នាដែលសម្តែងដល់គុណរបស់សាមគ្គី មិនមែនវាចាដទៃអំពីនេះ ។ ចេតនាគ្រោតគ្រាតដោយចំណែកមួយដែលជាទីតាំងនៃកាយប្បយោគនិងវចីបយោគដែលចាក់នូវហទយៈអ្នកដទៃ ឈ្មោះថា ផរុសវាចា ។ បទថា **នេលា** សេចក្តីថា ទោស លោកហៅថា **ឯល** ឈ្មោះថា **នេលា** ព្រោះជាវាចាមិនមានទោស អធិប្បាយថា ប្រាសចាកទោសដូច **នេលា** ដែលលោកពោលទុកក្នុង ( ខុទ្ទកនិកាយឧទាន ) ថា **នេលង្គោ សេតបច្ឆាទោ** រថ គឺអត្តភាពមានអវយវៈឥតទោស មានដំបូលស ។ បទថា **កណ្ណសុខា**

បានដល់ វាចាដែលមានសេចក្ដីសុខដល់ត្រចៀក ព្រោះពីរោះដោយព្យញ្ជនៈ មិនទាស់ត្រចៀកដូចដែកស្រួចចាក់ត្រចៀកនោះឡើយ ។ ឈ្មោះថា **បេមនីយា** ព្រោះអត្ថថា មិនកើតនូវការក្រោធ ឲ្យកើតនូវការស្រឡាញ់ពេញរាងកាយ ព្រោះពីរោះដោយអត្ថ ។ ដោយបទថា **ហទយង្គមា** ព្រោះអត្ថថា ជាវាចាចូលដល់ហទយៈ គឺមិនមានអ្វីរាំង ចូលទៅកាន់ចិត្តដោយងាយ ។ ឈ្មោះថា **បោរី** ព្រោះអត្ថថា ជាពាក្យរបស់អ្នកក្រុង ព្រោះបរិបូណ៌ដោយគុណ ។ ម្យ៉ាងទៀត ឈ្មោះថា **បោរី** ព្រោះជាពាក្យកុមារល្អ ដូចនារីដែលចម្រើនក្នុងបុរី ។ ម្យ៉ាងទៀតឈ្មោះថា **បោរី** ព្រោះជាវាចារបស់អ្នកក្រុង អធិប្បាយថា ជាពាក្យរបស់អ្នកក្រុង ។ ពិតហើយអ្នកក្រុងជាអ្នកពោលសមគួរ រមែងហៅបុគ្គលដែលស្រករឪពុកថាឪពុក ស្រករបងថាបង ។ ឈ្មោះថា **ពហុជនកន្តា** ព្រោះអត្ថថា វាចាបែបនេះ រមែងជាទីពេញចិត្តរបស់ជនច្រើន ។ ឈ្មោះថា **ពហុជនមនាបា** ព្រោះអត្ថថា ជាទីពេញចិត្តរបស់ជនច្រើន ធ្វើនូវការចម្រើនឲ្យដល់ចិត្ត ដោយវាចាដែលគួរពេញចិត្ត ។ អកុសលចេតនាដែលជាហេតុនៃកាយប្បយោគនិងវចីបយោគ ដែលឲ្យដឹងការមិនមានប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** ។ ឈ្មោះថា **កាលវាទី** ព្រោះអត្ថថា ពោលត្រូវកាលដែលសមគួរ អធិប្បាយថា ពោលដោយកំណត់កាលដែលគួរពោល ។ ឈ្មោះថា **ភូតវាទី** ព្រោះអត្ថថា ពោលពិតតាមសេចក្ដីពិត ។ ឈ្មោះថា **អត្ថវាទី** ព្រោះអត្ថថា ពោលអាស្រ័យប្រយោជន៍បច្ចុប្បន្ននិងប្រយោជន៍ខាងមុខ ។ ឈ្មោះថា **ធម្មវាទី** ព្រោះអត្ថថា ពោលអាស្រ័យលោកុត្តរធម៌ ៩ ។ ឈ្មោះថា **វិនយវាទី**

ព្រោះអត្ថថា ពោលអាស្រ័យសំវរវិន័យនិងបហានវិន័យ ។

ឱកាសជាទីតាំង លោកហៅថា **និធាន** ( គោល ) គោលនៃវាចាមាន ព្រោះហេតុនោះវាចានោះឈ្មោះថា **និធានវតី** អធិប្បាយថា ពោលនូវវាចាដែលគួរចាំទុកក្នុងហឫទ័យ ។ បទថា **កាលេន** បានដល់ កាលពោលវាចាបែបនេះ ក៏មិនពោលក្នុងកាលដែលមិនគួរ ដោយគិតអញនឹងពោលវាចាដែលមានគ្រឿងអាង តែពោលក្នុងកាលដែលគួរ ។ បទថា **សាបទេសំ** សេចក្តីថា ប្រកបដោយឧបមាប្រកបដោយហេតុ ។ បទថា **បរិយន្តវតី** សេចក្តីថា កំណត់ព្រំដែនហើយ ព្រំដែនរបស់វាចាប្រាកដដោយប្រការណាក៏ពោលដោយប្រការនោះ ។ បទថា **អត្ថសញ្ហិតំ** បានដល់ បរិបូណ៌ដោយប្រយោជន៍ ដែលអ្នកចែកមិនអាច កំណត់ដោយន័យច្រើនទាំងអស់បាន ។ ម្យ៉ាងទៀត ឈ្មោះថា **អត្ថសញ្ហិតំ** ព្រោះប្រកបដោយប្រយោជន៍ដែលបុគ្គលនោះពោលដល់ អធិប្បាយថា មិនលើកពាក្យណាមួយមកហើយពោលពាក្យដទៃទៀត ។ បទថា **ចតុទ្ទោសាបគតំ វាចំ ភាសតិ** បានដល់ ពោលវាចាប្រាសចាកទោស ៤ យ៉ាង មានមុសាវាទជាដើម ។ បទថា **ទុត្តឹសាយ តិរច្ឆានកថាយ** បានដល់ ដោយពាក្យដែលទទឹងសួគ៌និងការរួចផុត ( ព្រះនិព្វាន ) ៣២ ប្រការ ។ បទថា **ទស កថាវត្ថូនិ** បានដល់ ហេតុជារឿងនៃកថាដែលអាស្រ័យវិវដ្ត ១០ ប្រការ មានភាពជាអ្នកប្រាថ្នាតិចជាដើម ។ ក្នុងបទថា **អប្បិច្ឆកថំ** នេះ ពាក្យថា **អប្បិច្ឆោ** នេះ បានដល់ វៀរសេចក្តីប្រាថ្នា មិនមានសេចក្តីប្រាថ្នា មិនមានការចង់បាន ។ សេចក្តីពិតក្នុងពាក្យថា **អប្បិច្ឆោ** នេះ ព្យញ្ជនៈមើលទៅ

ហាក់ដូចជាមានសេចក្តីប្រាថ្នានៅសេសសល់ខ្លះ តែអត្តមិនមានអ្វីនៅសេសសល់ឡើយ ព្រោះព្រះខីណាស្រពមិនមានសេចក្តីប្រាថ្នាសូម្បីតែតិចតួច ។

ម្យ៉ាងទៀតក្នុងការប្រាថ្នានេះ គប្បីជ្រាបប្រភេទដូច្នេះគឺ **អត្រិច្ឆតា** ប្រាថ្នាមិនឆ្អែត **ចាបិច្ឆតា** ប្រាថ្នាលាមក **មហិច្ឆតា** ការប្រាថ្នាច្រើន **អប្បិច្ឆតា** ការប្រាថ្នាតិច ។ ក្នុងប្រភេទនៃការប្រាថ្នាទាំងនោះ គប្បីជ្រាបដូច្នេះថា ការប្រាថ្នាលាភរបស់អ្នកដទៃ ព្រោះមិនឆ្អែតក្នុងលាភរបស់ខ្លួន ឈ្មោះថា **អត្រិច្ឆតា** ។ បុគ្គលប្រកបដោយការប្រាថ្នាច្រើននោះ សូម្បីនំឆ្អិនក្នុងភាជនៈមួយ ដែលគេដាក់បាត្ររបស់ខ្លួន ក៏ប្រាកដដូចជាមិនឆ្អិនល្អនិងដូចជាតិចតួច ។ ស្អែកឡើងគេដាក់ក្នុងបាត្ររបស់ភិក្ខុដទៃ ក៏ប្រាកដហាក់ដូចជាឆ្អិនល្អនិងដូចច្រើន ។ ការអួតក្នុងគុណ ដែលមិនមាននិងការមិនស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា **ចាបិច្ឆតា** ។ ការប្រាថ្នាលាមកនោះមកហើយដោយន័យ ( ក្នុងវិភង្គ ) ថា បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធាប្រាថ្នាថា ជនចូរដឹងនូវអញថាជាអ្នកមានសទ្ធា បុគ្គលដែលប្រកបដោយការប្រាថ្នាលាភនោះ រមែងតាំងនៅក្នុងការបោកបញ្ឆោត ។ ការអួតក្នុងគុណ ដែលមាននិងភាពជាអ្នកមិនស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា **មហិច្ឆតា** ។ សូម្បីការប្រាថ្នាច្រើននោះក៏មកហើយដោយន័យនេះថា បុគ្គលពួកខ្លះក្នុងលោកនេះជាអ្នកមានសទ្ធាប្រាថ្នាថា ជនចូរដឹងនូវអញថាជាអ្នកមានសទ្ធា ជាអ្នកមានសីលប្រាថ្នាថា ជនចូរដឹងនូវអញថា ជាអ្នកមានសីលដូច្នេះ បុគ្គលដែលប្រកបដោយការប្រាថ្នាច្រើននោះ ជាបុគ្គលឲ្យត្រេកអរបានដោយក្រ សូម្បីតែមាតាបង្កើតក៏មិនអាច

បំពេញចំណង់របស់បុគ្គលនោះបានសមដូចលោកពោលថា

គំនរភ្លើង មហាសមុទ្ទនិងបុគ្គលប្រាថ្នាច្រើន ជនទាំងឡាយឲ្យ
បច្ច័យរហូតពេញរទេះ ទាំង ៣ ប្រភេទនោះក៏មិនឆ្អែតឡើយ ។

ឯភាពជាអ្នកបិទបាំងគុណដែលមាន និងស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ការប្រាថ្នាតិច បុគ្គលដែលប្រកបដោយសេចក្តីប្រាថ្នាតិចនោះព្រោះបំណងនឹងបិទបាំងគុណដែលមានក្នុងខ្លួន ទោះបីមានសទ្ធាក៏មិនប្រាថ្នាថា សូមជនស្គាល់អាត្មាអញថាជាអ្នកមានសទ្ធា ជាអ្នកមានសីល ជាអ្នកមានវិវេក ជាពហុស្សូត ជាអ្នកប្រារព្ធព្យាយាម ជាអ្នកបរិបូណ៌ដោយសមាធិ ជាអ្នកមានបញ្ញា ជាព្រះខីណាស្រព ក៏មិនប្រាថ្នាថា ជនចូរដឹងអាត្មាអញថាជាព្រះខី-ណាស្រពដូចព្រះមជ្ឈន្តិកត្ថេរដូច្នោះ ។ ភិក្ខុអ្នកមានសេចក្តីប្រាថ្នាតិចយ៉ាងនេះ រមែងញ៉ាំងលាភដែលមិនទាន់កើតឲ្យកើតឡើង ធ្វើលាភដែលកើតឡើងហើយឲ្យឋិតថេរ ញ៉ាំងចិត្តរបស់ទាយកឲ្យត្រេកអរ មនុស្សទាំងឡាយជ្រះថ្លាហើយក្នុងវត្តរបស់ភិក្ខុនោះ រមែងឲ្យច្រើនដោយអាការដែលភិក្ខុនោះ ទទួលតែបន្តិចបន្តួច ព្រោះខ្លួនជាអ្នកមានសេចក្តីប្រាថ្នាតិច ។

នៅមានសេចក្តីប្រាថ្នាតិច ៤ យ៉ាងដទៃទៀត គឺប្រាថ្នាតិចក្នុងបច្ច័យ ១ ប្រាថ្នាតិចក្នុងធុតង្គ ១ ប្រាថ្នាតិចក្នុងបរិយត្តិ ១ ប្រាថ្នាតិចក្នុងអធិគម ១ ។ ក្នុង ៤ យ៉ាងនោះការប្រាថ្នាតិចក្នុងបច្ច័យ ៤ ឈ្មោះថា ប្រាថ្នាតិចក្នុងបច្ច័យ ។ ភិក្ខុដែលមានការប្រាថ្នាតិចក្នុងបច្ច័យនោះ រមែងដឹងកម្លាំងរបស់ទាយក ដឹងកម្លាំងរបស់ទេយ្យធម៌ ដឹងកម្លាំងរបស់ខ្លួន បើទេយ្យធម៌មានច្រើន ទាយក

បំណាងនឹងឲ្យតិច រមែងទទួលតែបន្តិចតាមកម្លាំងរបស់ទាយក ។ ទេយ្យធម៌មានតិច ទាយកបំណាងនឹងឲ្យច្រើន រមែងទទួលតែបន្តិចតាមកម្លាំងរបស់ទេយ្យធម៌ ទេយ្យធម៌ក៏មានច្រើនសូម្បីទាយកក៏បំណាងនឹងឲ្យច្រើន ដឹងកម្លាំងរបស់ខ្លួនរមែងទទួលល្មមប្រមាណប៉ុណ្ណោះ ។

ភិក្ខុមិនបំណាងនឹងឲ្យដឹងថាខ្លួនសមាទានធុតង្គ ឈ្មោះថាជាអ្នកមានសេចក្តីប្រាថ្នាតិចក្នុងធុតង្គ ។ ឯភិក្ខុណាមិនបំណាងឲ្យដឹងថាខ្លួនជាពហុស្សូត ភិក្ខុនេះឈ្មោះថាជាអ្នកមានសេចក្តីប្រាថ្នាតិចក្នុងបរិយត្តិ ។ ឯភិក្ខុណាបានជាព្រះសោ-តាបន្នជាដើមណាមួយ មិនប្រាថ្នាឲ្យដឹងថាខ្លួនជាព្រះសោតាបន្នជាដើម ភិក្ខុនេះឈ្មោះថាជាអ្នកមានសេចក្តីប្រាថ្នាតិចក្នុងអធិគម ។ ឯព្រះខីណាស្រពលះអត្រិច្ឆតា បាបិច្ឆតា មហិច្ឆតាបានហើយឈ្មោះថាជាបុគ្គលមានការប្រាថ្នាតិចព្រោះជាអ្នកប្រកបដោយសេចក្តីប្រាថ្នាតិច ដោយសេចក្តីបរិសុទ្ធ គឺមិនលោកដែលជាបដិបក្ខចំពោះការប្រាថ្នា ដោយប្រការទាំងពួង ។ ព្រះសារីបុត្ត កាលសម្តែងទោសក្នុងធម៌ទាំងនោះថា អាវុសោទាំងឡាយ ធម៌ទាំងនេះ អត្រិច្ឆតា បាបិច្ឆតា មហិច្ឆតា គួរលះ កាលពោលថា គួរប្រព្រឹត្តសមាទាន ភាពជាអ្នកប្រាថ្នាតិចបែបនេះឈ្មោះថា រមែងពោលអប្បិច្ឆកថា ។

ខ្ញុំនឹងសម្តែងអត្ថ ដែលផ្សេងគ្នាក្នុងបទជាដើមថា សន្តុដ្ឋិកថា ។ តែគប្បីជ្រាបការប្រកបដោយន័យដូចពោលហើយនោះឯង ។ បទថា **សន្តុដ្ឋិកថំ** បានដល់ កថាអាស្រ័យការសន្តោសក្នុងបច្ច័យតាមមានតាមបាន ។ សន្តោសនោះមាន ១២ យ៉ាង ។ ១២ យ៉ាងនោះតើដូចម្តេច ។ គឺសន្តោសក្នុងចីវរមាន ៣

យ៉ាង បានដល់ យថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ក្នុងបិណ្ឌបាតជាដើម ក៏ដូចគ្នា ។ នឹងពណ៌នាដល់ប្រភេទសន្តោសដូចតទៅនេះថា

ភិក្ខុក្នុងសាសនានេះ បានចីវរល្អក្តី មិនល្អក្តី ភិក្ខុនោះប្រើប្រាស់ចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃសូម្បីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។ ម្យ៉ាងទៀតភិក្ខុណា ប្រក្រតីមានកម្លាំងតិច ឬត្រូវអាពាធនិងជរាគ្របសង្កត់ ដណ្តប់ចីវរធ្ងន់តែងលំបាក ភិក្ខុនោះដោះដូរចីវរនោះជាមួយភិក្ខុដែលស្និទ្ធស្នាលហើយប្រើប្រាស់ចីវរដែលស្រាល ជាអ្នកសន្តោស នេះឈ្មោះថា យថាពលសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។ ភិក្ខុរូបដទៃបាននូវបច្ច័យប្រណីត ភិក្ខុនោះបាននូវចីវរមានតម្លៃច្រើន មានសំពត់ថ្មីជាដើម ផ្ទាំងណាមួយឬបានចីវរច្រើនផ្ទាំងហើយប្រគេនដោយគិតថា ផ្ទាំងនេះសមគួរដល់ព្រះថេរៈដែលបួសយូរ ផ្ទាំងនេះសមគួរដល់លោក ជាពហុស្សូតផ្ទាំងនេះសមគួរដល់លោក ដែលជាអ្នកមានអាពាធ ផ្ទាំងនេះសមគួរដល់ភិក្ខុដែលមានលាភតិច ដូច្នេះហើយជ្រើសរើសចីវរចាស់ៗរបស់ភិក្ខុទាំងនោះ ឬសំពត់ចាស់ៗអំពីគំនរសំរាមជាដើម យកចីវរទាំងនោះប្រើជាសង្ឃាដិ រមែងជាអ្នកសន្តោសដោយពិត នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។

ចំណែកភិក្ខុក្នុងសាសនានេះបាននូវបិណ្ឌបាតសៅហ្មងក្តី ប្រណីតក្តី ភិក្ខុនោះរមែងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះប៉ុណ្ណោះ មិនប្រាថ្នា

បិណ្ឌបាតដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោសក្នុង បិណ្ឌបាតរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត ភិក្ខុណាបាននូវបិណ្ឌបាតដែលស្លែង ឬប្រឆាំងរោគរបស់ខ្លួន ឆាន់បិណ្ឌបាតនោះហើយមិនសប្បាយ ភិក្ខុនោះប្រគេន បិណ្ឌបាតនោះដល់ភិក្ខុដែលស្និទ្ធស្នាលនឹងគ្នា ឆាន់ភោជនដែលជាទីសប្បាយ អំពីដៃរបស់ភិក្ខុនោះហើយបំពេញសមណធម៌ រមែងជាអ្នកសន្តោសនោះឯង នេះឈ្មោះថា យថាពលសន្តោសក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ ភិក្ខុដទៃបាន នូវបិណ្ឌបាតដ៏ប្រណីតច្រើន ភិក្ខុនោះប្រគេនដល់ព្រះថេរៈ ភិក្ខុជាពហុស្សូត ភិក្ខុមានលាភតិច ភិក្ខុអាពាធ ដូចប្រគេនចីវរនោះ ហើយឆាន់អាហារដែល សល់អំពីភិក្ខុទាំងនោះ ឬត្រាច់បិណ្ឌបាតហើយឆាន់អាហារដែលលាយគ្នារមែង ជាអ្នកសន្តោសដោយពិត នេះឈ្មោះថា យថាសារុប្បក្នុងបិណ្ឌបាតរបស់ភិក្ខុ នោះ ។

ម្យ៉ាងទៀតភិក្ខុក្នុងសាសនានេះបានសេនាសនៈដែលពេញចិត្តក្តី មិនពេញ ចិត្តក្តី ភិក្ខុនោះមិនកើតសោមនស្ស មិនអាក់អន់ដោយសេនាសនៈនោះ រមែង ត្រេកអរតាមមានតាមបាននោះឯង ដោយហោចសូម្បីកម្រាល ដែលធ្វើដោយ ស្មៅ នេះឈ្មោះថា យថាលាភសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ម្យ៉ាង ទៀត ភិក្ខុណាបាននូវសេនាសនៈដែលស្លែងដល់សុខភាពក្តី ធ្វើឲ្យមានជំងឺក្តី កាលនៅក្នុងសេនាសនៈណាមិនសប្បាយ ភិក្ខុនោះឲ្យសេនាសនៈនោះ ដល់ ភិក្ខុដែលពេញចិត្តគ្នា ហើយនៅក្នុងសេនាសនៈដែលជាទីសប្បាយក្នុងសម្នាក់ របស់ភិក្ខុនោះ ក៏ជាអ្នកសន្តោសនោះឯង នេះឈ្មោះថា យថាពលសន្តោស

ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ភិក្ខុរបស់ទៃមានបុណ្យច្រើន បាននូវសេនាសនៈប្រណីតច្រើន មានគុហា មណ្ឌបនិងផ្ទះកំពូលជាដើម ភិក្ខុនោះបានប្រគេនដល់ភិក្ខុដែលបួសយូរ ជាពហុស្សុត មានលាភតិច ភិក្ខុអាពាធ ដូចគ្នានឹងប្រគេនចីវរទាំងនោះហើយ សូម្បីនៅក្នុងទីណាមួយក៏រមែងជាអ្នកសន្តោសនោះឯង នេះឈ្មោះថា យថា-សារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ភិក្ខុណាសិក្សាថា ឈ្មោះថាសេនាសនៈដែលល្អពេក ជាទីតាំងនៃសេចក្តីប្រមាទ កាលភិក្ខុនោះអង្គុយក្នុងសេនាសនៈនោះរមែងត្រូវថិនមិទ្ធគ្របសង្កត់ រមែងឈានចុះកាន់ការងោកងុយ ឬវិតក្កដ៏លាមកប្រាកដដល់ភិក្ខុដែល ការងងុយងោកងក់គ្របសង្កត់ហើយភ្ញាក់ឡើង មិនទទួលសេនាសនៈបែបនោះ សូម្បីដែលដល់លំដាប់ខ្លួន ភិក្ខុនោះបដិសេធសេនាសនៈនោះហើយ សូម្បីនៅក្នុងទីវាលនិងគល់ឈើជាដើម ក៏ជាអ្នកសន្តោសនោះឯង នេះក៏ឈ្មោះថា យថាសារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀតភិក្ខុណាបាននូវភេសជ្ជៈសៅហ្មងក្តី ប្រណីតក្តី ភិក្ខុនោះបាននូវភេសជ្ជៈណា ត្រេកអរដោយភេសជ្ជៈនោះប៉ុណ្ណោះ មិនប្រាថ្នាភេសជ្ជៈដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោស ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀតភិក្ខុណាត្រូវការប្រេង តែបានទឹកអំពៅ ភិក្ខុនោះប្រគេនទឹកអំពៅនោះដល់ភិក្ខុដែលស្និទ្ធស្នាលនឹងគ្នា ហើយទទួលប្រេងអំពីដៃរបស់ភិក្ខុនោះឬស្វែងរកដទៃ សូម្បីវត្ថុទាំងនោះធ្វើភេសជ្ជៈ ក៏ជាអ្នកសន្តោស

ដូចគ្នា នេះឈ្មោះថា យថាពលសន្តោសក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ ភិក្ខុរូបដទៃមានបុណ្យច្រើន បាននូវបណីតភេសជ្ជៈមានប្រេង ទឹកឃ្មុំនិងទឹកអំពៅជាដើម ភិក្ខុនោះប្រគេនដល់ភិក្ខុដែលបួសយូរ ភិក្ខុជាពហុស្សូត ភិក្ខុអ្នកមានលាភតិច ភិក្ខុអាពាធ ដូចប្រគេនចីវរនោះ សូម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយភេសជ្ជៈណាមួយដែលភិក្ខុទាំងនោះបានហើយក៏ជាអ្នកសន្តោសដូចគ្នា ។ម្យ៉ាងទៀតភិក្ខុណាដែលមហាជនរៀបចំមធុរស ៤ យ៉ាង ទុកក្នុងភាជនៈមួយដាក់សម៉ត្រាំដោយទឹកមូត្រក្នុងភាជនៈមួយ ហើយពោលថា សូមលោកម្ចាស់ទទួលវត្ថុ ដែលលោកម្ចាស់ត្រូវការចុះ បើរោគរបស់ភិក្ខុនោះ ស្ងប់ដោយភេសជ្ជៈណាមួយក្នុងថ្នាំទាំងនោះ ហាមនូវមធុរស ៤ ដោយគិតថា ឈ្មោះថាសម៉ត្រាំដោយទឹកមូត្រ ព្រះពុទ្ធជាដើមទ្រង់សរសើរ ហើយយកសម៉ត្រាំដោយទឹកមូត្រធ្វើភេសជ្ជៈ រមែងជាអ្នកសន្តោសយ៉ាងក្រៃលែងនោះឯង នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ បណ្តាសន្តោសនីមួយៗ សន្តោស ១ មាន ៣ យ៉ាងក្នុងបច្ច័យទាំងឡាយ ។ លោកពោលថា យថាសារុប្បសន្តោស ជាសន្តោសដ៏ប្រសើរ ។ ព្រះអរហន្ត ជាអ្នកសន្តោសដោយសន្តោស ៣ យ៉ាងទាំងនេះក្នុងបច្ច័យនីមួយៗ ។

បទថា **បវិវេកកថំ** បានដល់ កថាដែលទាក់ទងនឹងវិវេក ពិតហើយវិវេកមាន ៣ យ៉ាង គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។ ក្នុងវិវេក ៣ យ៉ាងនោះ ភិក្ខុដើរតែឯង ឈរតែឯង អង្គុយឯង ដេកតែឯង ចូលទៅបិណ្ឌបាតតែឯង ត្រឡប់ពីបិណ្ឌបាតតែឯង ដើរចង្ក្រមតែឯង ត្រាច់ទៅតែឯង

នៅតែឯង នេះឈ្មោះថា កាយវិវេក ។ សមាបត្តិ ៨ ឈ្មោះថា ចិត្តវិវេក ។ និព្វាន ឈ្មោះថា ឧបធិវិវេក ។ សមដូចលោកពោលថា

កាយវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង ចិត្តវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្តីផូរផង់ក្រៃលែងផង ឧបធិវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វាន ដែលប្រាកចាកសង្ខារផង ដូច្នេះ ។

ក្នុងបទថា **សំសគ្គកាជំ** បានដល់ សំសគ្គៈមាន ៥ យ៉ាង គឺសវនសំសគ្គៈ ១ ទស្សនសំសគ្គៈ ១ សមុល្លបនសំសគ្គៈ ១ សម្ភោគ សំសគ្គៈ ១ កាយ-សំសគ្គៈ ១ ។

ក្នុងសំសគ្គៈ ៥ យ៉ាងនេះ ភិក្ខុក្នុងសាសនានេះ បានស្តាប់មកថា ត្រង់ស្រុកឬនិគមឈ្មោះនោះ មានស្រីក្មេងរូបស្អាត គួរមើល គួរស្រឡាញ់ ប្រកបដោយពណ៌សម្បុរល្អក្រៃលែងដូច្នេះ ភិក្ខុនោះ បានស្តាប់ដូច្នោះហើយ លង់ក្នុងរណ្តៅស្នេហ៍ មិនអាចប្រព្រឹត្តព្រហ្មចរិយៈបាន មិនប្រកាសភាពជាអ្នកមានកម្លាំងថយក្នុងសិក្ខា វិលមកជាហីនភេទ ព្រោះហេតុនោះ ទើបរាគៈកើតដោយវិថីនៃសោតវិញ្ញាណរបស់ភិក្ខុនោះ ជាអ្នកស្តាប់នូវសម្បត្តិ មានរូបជាដើម ដែលអ្នកដទៃប្រាប់យ៉ាងនេះ ឬស្តាប់សំឡេងសើចនិងសំឡេងចរចាដោយខ្លួនឯង ឈ្មោះថា សវនសំសគ្គៈ ។

ភិក្ខុក្នុងសាសនានេះមិនបានស្តាប់ តែឃើញឯងនូវស្រីឬស្រីវ័យក្មេង រូប

ស្អាតគួរមើល គួរស្រឡាញ់ ប្រកបដោយពណ៌សម្បុរល្អក្រៃលែង ភិក្ខុនោះឃើញនាងហើយបាក់ចិត្តស្រឡាញ់មិនអាចប្រព្រឹត្តព្រហ្មចារ្យបាន មិនប្រកាសភាពជាអ្នកមានកម្លាំងថយក្នុងសិក្ខា វិលមកជាហីនភេទ ព្រោះហេតុនោះទើបរាគៈកើតដោយវិថីនៃចក្ខុវិញ្ញាណរបស់ភិក្ខុ ដែលសម្លឹងមើលរូបដែលជាសត្រូវយ៉ាងនេះ ឈ្មោះថា ទស្សនសំសគ្គៈ ។

ម្យ៉ាងទៀតរាគៈកើតដោយការសន្ទនាប្រាស្រ័យគ្នានឹងគ្នា ឈ្មោះថា សមុល្លបនសំសគ្គៈ ។

រាគៈដែលកើតដោយការដែលភិក្ខុទទួលរបស់ភិក្ខុនី ឬភិក្ខុនីទទួលរបស់ភិក្ខុ ហើយធ្វើការបរិភោគ ឈ្មោះថា សម្ភោគសំសគ្គៈ ។

ឯរាគៈកើតដោយការចាប់ដៃជាដើម ឈ្មោះថា កាយសំសគ្គៈ ។

ព្រះអរហន្តមិនជាប់ចំពាក់នឹងបរិស័ទ ៤ ដោយសំសគ្គៈទាំង ៥ នេះ ផុតចាកការប្រកាន់និងផុតចាកការប្រឡូកប្រឡំ ពោលសរសើរគុណ នៃការមិនប្រឡូកប្រឡំ ឈ្មោះថា អសំសគ្គកថា ។

ក្នុងបទថា **វីរិយារម្ភកថំ** សេចក្តីថា ភិក្ខុណាជាអ្នកផ្គងសេចក្តីព្យាយាមទុក ជាអ្នកមានសេចក្តីព្យាយាមផ្លូវកាយនិងផ្លូវចិត្តបរិបូណ៌ មិនឲ្យកិលេសដែលកើតក្នុងពេលដើរជាប់តាម ដល់ពេលឈរមិនឲ្យកិលេសដែលកើតក្នុងពេលឈរជាប់តាម ដល់ពេលអង្គុយមិនឲ្យកិលេសដែលកើតក្នុងពេលអង្គុយជាប់តាម ដល់ពេលដេកប្រព្រឹត្តដូចចាប់ពស់វែកដោយមន្តនិងដូចជាន់កសត្រូវពោលសរសើរគុណរបស់បុគ្គលប្រារព្ធព្យាយាមដូច្នោះ ឈ្មោះថា វីរិយារម្ភ-

កថា ។

បទថា **សីលកថំ** ជាដើមនេះ ពាក្យថា **សីល** បានដល់ ចតុប្បារិសុទ្ធិសីល ។ បទថា **សមាធិ** បានដល់ សមាបត្តិ ៨ ដែលជាបាទនៃវិបស្សនា ។ បទថា **បញ្ញា** បានដល់ ញាណ ដែលជាលោកិយនិងលោកុត្តរ ។ បទថា **វិមុត្តិ** បានដល់ អរហត្តផលវិមុត្តិ ។ បទថា **វិមុត្តិញាណទស្សនំ** បានដល់ បច្ចវេក្ខណញាណ ១៩ យ៉ាង ។ កាលប្រកាសគុណនៃសីលជាដើម ឈ្មោះថា ពោលនូវសីលកថាជាដើម ។ បទថា **សតិប្បដ្ឋានកថំ** ជាដើម រហូតដល់បទចុងក្រោយថា **សង្គជាលមតិច្ច សោ មុនិ** គប្បីជ្រាបដោយទំនងដូចពោលហើយក្នុងបទមុនៗនោះឯង ។

[ ៧០ ] បទថា **និរាសត្តី** បានដល់ មិនមានតណ្ហា ។ បទថា **វិវេកទស្សី ផស្សេសុ** បានដល់ ជាអ្នកមានប្រក្រតីឃើញស្ងាត់ ក្នុងចក្ខុសម្ផស្សជាដើមដែលជាបច្ចុប្បន្ន ។ បទថា **ទិដ្ឋីសុ ច ន និយ្យតិ** បានដល់ មិនត្រូវនាំទៅក្នុងទិដ្ឋិណាមួយក្នុងបណ្ដាទិដ្ឋិ ៦២ ។

បទថា **វិបរិណាតំ វា វត្ថុំ ន សោចតិ** បានដល់ មិនដល់នូវសេចក្ដីសោកក្នុងវត្ថុណាមួយដែលលះភាវៈដើម ហើយវិនាសទៅ ។ បទថា **វិបរិណាតស្មឹ វា** បានដល់ កាលវត្ថុវិនាសទៅហើយ ។

[ ៧៣ ] បទថា **ចក្ខុសម្ផស្សោ** បានដល់ ផស្សៈដែលធ្វើចក្ខុឲ្យជាទីតាំង កើតព្រមជាមួយចក្ខុវិញ្ញាណ ឈ្មោះថា ចក្ខុសម្ផស្ស ។ ក្នុងផស្សៈដ៏សេសក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀតក្នុងបទនេះផស្សៈទាំងឡាយ ដែល

មានមុន ក៏មានចក្ខុបសាទជាដើមជាទីតាំងទាំងអស់ ។ មនោសម្ផស្ស មាន ហទយៈជាទីតាំងក៏មាន មិនមានទីតាំងក៏មាន ទាំងអស់ជាសម្ផស្សប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **អធិវចនសម្ផស្សោ** បានដល់ ជាឈ្មោះនៃសម្ផស្សនោះដោយបរិយាយ ។ ព្រោះអរូបក្ខន្ធ ៣ វិលទៅតាមខាងក្រោយឯង ធ្វើឈ្មោះរបស់សម្ផស្ស ដែលកើតព្រមជាមួយខ្លួនថា អធិវចនសម្ផស្ស ។ បទថា **បដិឃសម្ផស្សោ** បានដល់ ពោលដោយនិប្បរិយាយ ឈ្មោះថា បដិឃសម្ផស្ស គឺសម្ផស្សប្រព្រឹត្តទៅតាមបញ្ចទ្វារ ។ ឈ្មោះថា អធិវចនសម្ផស្ស គឺសម្ផស្សប្រព្រឹត្តទៅតាមមនោទ្វារ ។ បទថា **សុខវេទនីយោ សម្ផស្សោ** បានដល់ផស្សៈដែលកើតឡើងឧបការៈដល់សុខវេទនា ។ ក្នុងសម្ផស្សទាំង ២ ក្រៅអំពីនេះក៏មានន័យនេះដូចគ្នា ។

បទថា **កុសលោ ផស្សោ** បានដល់ ផស្សៈដែលកើតព្រមជាមួយកុសលចិត្ត ២១ ។ បទថា **អកុសលោ** បានដល់ ផស្សៈដែលកើតព្រមជាមួយអកុសលចិត្ត ១២ ។ បទថា **អព្យាកតោ** បានដល់ ផស្សៈដែលកើតព្រមជាមួយអព្យាកតចិត្ត ៥៦ ។ បទថា **កាមាវចរោ** បានដល់ ផស្សៈដែលកើតព្រមជាមួយកាមាវចរចិត្ត ៥៤ ។ បទថា **រូបាវចរោ** បានដល់ ផស្សៈដែលកើតព្រមជាមួយរូបាវចរចិត្ត ១៥ មានកុសលចិត្តជាដើម ។ បទថា **អរូបាវចរោ** បានដល់ ផស្សៈដែលសម្បយុត្តដោយអរូបាវចរចិត្ត ១២ ដោយអំណាចនៃកុសលចិត្តនិងអព្យាកតចិត្ត ។

បទថា **សុញ្ញតោ** បានដល់ មគ្គដែលកើតឡើងដល់អ្នកឃើញច្បាស់ដោយ

*អំណាចនៃអនត្តានុបស្សនា ឈ្មោះថា សុញ្ញតៈ ។ ផស្សៈដែលកើតព្រមជាមួយនឹងមគ្គនោះ ឈ្មោះថា សុញ្ញតផស្សៈ ។ ក្នុង ២ បទដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងបទថា* **អនិមិត្តោ** *បានដល់ មគ្គដែលកើតឡើងដល់អ្នកឃើញច្បាស់ដោយអំណាចនៃអនិច្ចានុបស្សនា ឈ្មោះថា អនិមិត្ត ។ បទថា* **អប្បណិហិតោ** *បានដល់ មគ្គដែលកើតឡើង ដល់បុគ្គលអ្នកឃើញច្បាស់ដោយអំណាចទុក្ខានុបស្សនា ឈ្មោះថា អប្បហិត ។ បទថា* **លោកិយោ** *បានដល់ វដ្ដៈ លោកហៅថា លោកៈ ព្រោះអត្ថថា វិនាស ទ្រុឌទ្រោមនិងបែកធ្លាយ ឈ្មោះថា លោកិយោ ព្រោះអត្ថថា ប្រកបនៅក្នុងលោក ព្រោះទាក់ទងក្នុងលោកនោះ គឺធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា* **លោកុត្តរោ** *បានដល់ ឈ្មោះថា លោកុត្តរ ព្រោះឆ្លងផុតចាកលោក ។ ផស្សៈដែលជាលោកុត្តរព្រោះមិនទាក់ទងក្នុងលោក ។ បទថា* **អត្ថេន វា** *បានដល់ ចាកភាពជាខ្ទួនខ្ទះ ។ បទថា* **អត្តនិយេន វា** *បានដល់ ចាកធម៌ដែលទាក់ទងដោយខ្ទួនខ្ទះ ។*

*[ ៧៥ ] បទថា* **បដិលីនោ** *បានដល់ ប្រាសចាកអកុសលធម៌នោះព្រោះលះនូវរាគៈជាដើមបាន ។ បទថា* **អកុហកោ** *បានដល់ មិនកុហកដោយវត្ថុជាគ្រឿងកុហក ៣ យ៉ាង ។ បទថា* **អបិហាលុ** *បានដល់ មានប្រក្រតីមិនចង់បាន អធិប្បាយថា វៀរចាកការប្រាថ្នានិងការចង់បាន ។ បទថា* **អមច្ឆរី** *បានដល់ វៀរចាកសេចក្តីកំណាញ់ ៥ យ៉ាង ។ បទថា* **អប្បគព្ភោ** *បានដល់ វៀរចាកភាពជាបុគ្គលភ្នាំភ្នងកាយជាដើម ។ បទថា* **អជេគុច្ឆោ** *បានដល់ មិនគួរខ្ពើស គួរស្រឡាញ់ គួរត្រេកអរ ព្រោះបរិបូណ៌ដោយសីលជាដើម ។*

បទថា **បេសុណេយ្យេ ច នោ យុតោ** បានដល់ មិនប្រកបក្នុងការស៊ិកសៀត ដែលគួរនាំចូលទៅដោយដោយអាការ ២ យ៉ាង ។

[ ៧៦ ] បទថា **រាគស្ស បហីនត្តា** បានដល់ ព្រោះលះនូវរាគកិលេសបានដោយអរហត្តមគ្គ ។ បទថា **អស្មិមានោ បហីនោ ហោតិ** បានដល់ លះនូវការតម្កើងខ្លួននិងការប្រកាន់ថាជាអញបានដោយសមុច្ឆេទ ។

[ ៧៧ ] បទថា **តីណិ កុហនវត្ថូនិ** បានដល់ ហេតុនៃការកុហក ៣ យ៉ាង ។ ក្នុងបទជាដើមថា **បច្ចយបដិសេវនសង្ខាតំ កុហនវត្ថុ** សេចក្ដីថា ដោយការដែលភិក្ខុ កាលបានទទួលនិមន្តន៍ដោយបច្ច័យមានចីវរជាដើម ទាំងមានសេចក្ដីត្រូវការបច្ច័យនោះដូចគ្នា អាស្រ័យការប្រាថ្នាលាមក ហើយបដិសេធនិងដោយការដែលដឹងថា គហបតីទាំងនោះមានសទ្ធាតាំងមាំដោយល្អក្នុងខ្លួន កាលគហបតីទាំងនោះបង្អោនបច្ច័យមានចីវរជាដើម ដែលប្រណីតមកប្រគេនទៀតដោយឧបាយនិងវិធីផ្សេងៗដោយគិតថា គួរអស្ចារ្យ លោកម្ចាស់មានសេចក្ដីប្រាថ្នាតិច មិនប្រាថ្នានឹងទទួលរបស់ណាមួយ គប្បីជាវត្ថុអញបានល្អហើយហ្ន៎ បើលោកម្ចាស់គប្បីទទួលរបស់ណាមួយ សូម្បីមានប្រមាណតិចតួច ដូច្នេះហើយសម្ដែងឲ្យដឹងថា បំណងនឹងអនុគ្រោះគហបតីប៉ុណ្ណោះ ហើយទទួលការបោកបញ្ឆោត ដែលជាហេតុឲ្យគេនាំរបស់មកប្រគេនទាំងរទេះ ចាប់តាំងអំពីកាលនោះគប្បីជ្រាបថា កុហនវត្ថុខាងការសេពបច្ច័យ ។ ម្យ៉ាងទៀត កាលភិក្ខុមានសេចក្ដីប្រាថ្នាលាមក ធ្វើឲ្យកាន់កាំងដោយឥរិយាបថ ដែលសម្ដែងនូវបំណងសរសើរ គប្បីជ្រាបថានេះគឺរឿងការបោកបញ្ឆោត អាស្រ័យឥរិ-

យាបថ ។ ម្យ៉ាងទៀតកាលភិក្ខុមានសេចក្តីប្រាថ្នាលាមក បោកបញ្ឆោតដោយឥរិយាបថដែលធ្វើប្រាថ្នានូវការសរសើរ គប្បីជ្រាបថាកុហនវត្ថុខាងឥរិយាបថ ។ ម្យ៉ាងទៀតកាលភិក្ខុមានសេចក្តីប្រាថ្នាលាមក បោកបញ្ឆោតដោយអាការនោះៗ ដោយការពោលគឺ សម្តែងដល់ការសម្រេចឧត្តរិមនុស្សធម្ម គប្បីជ្រាបថា កុហនវត្ថុខាងការខ្សឹបជិត ។

ក្នុងបទថា កុហនវត្ថុខាងការសេពបច្ច័យដូចម្តេចនេះ គប្បីជ្រាបថា ពោលយ៉ាងនេះ គឺការសេពបច្ច័យ ឈ្មោះថា ពោលគឺការសេពបច្ច័យ ។ បទថា **និមន្តេន្តិ** បានដល់ គហបតីក្នុងលោកនេះរមែងនិមន្តភិក្ខុថា សូមលោកម្ចាស់ទទួលភិក្ខាផងចុះ ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ អាចារ្យពួកខ្លះពោលថា **និម-ន្តេតិ វទន្តិ** ក៏មាន ។ ក្នុងទីបែបនោះគប្បីឃើញការកើតឡើងនៃបាឋៈថា ឲ្យនិមន្តខ្លះ និមន្តឯងខ្លះ ។ បទថា **ចីវរំ បច្ចក្ខាតិ** បានដល់ បដិសេធចីវរ ។ បទថា **ឯតំ សារុប្បំ យំ សមណោ** បានដល់ ការដែលសមណៈធ្វើនូវការទ្រទ្រង់ចីវរទុកជាការសមគួរ គឺសមរម្យ ។ បទថា **អាបណិកា វា នន្តកានិ** បានដល់ សំពត់ចាស់ៗដែលនៅល្មមប្រើបាន ដែលគេចោលត្រង់ផ្សារ ។ បទថា **ឧច្ចិនិត្វា** បានដល់ រើសយកមក ។ បទថា **ឧញ្ឆាចរិយាយ** បានដល់ ដោយការត្រាច់ទៅដើម្បីភិក្ខា ។ បទថា **បិណ្ឌិយាលោបេន** បានដល់ បាយដែលធ្វើការប្រមូលឲ្យជាពំនូតបានមក ។ បទថា **បូតិមុត្តេន វា** បានដល់ ទឹកនោមគោ ។ បទថា **ឱសធំ ការេយ្យ** បានដល់ គប្បីធ្វើភេសជ្ជកិច្ច ។ បទថា **តទុបាទាយ** បានដល់ តាំងអំពីនោះមក ។ បទថា **ធុតវាទោ** បានដល់

ជាអ្នកពោលនូវគុណនៃធុតង្គ ។ បទថា **ភិយ្យោ ភិយ្យោ និមន្តេន្តិ** បានដល់ និមន្តរឿយៗ ។ បទថា **សម្មុខីភាវា** បានដល់ ព្រោះជួបចំពោះមុខ ។ អធិប្បាយថា ព្រោះមាន ។ បទថា **បសវតិ** បានដល់ រមែងបាន ។ បុគ្គលណាមួយអាចធ្វើដោយការជួបដោយសទ្ធា ព្រោះហេតុនោះ ទើបលោកពោលថា **សទ្ធាយ សម្មុខីភាវា** ជាដើម ។ ទេយ្យធម៌និងទក្ខិណេយ្យបុគ្គលរកបានងាយ តែសទ្ធារកបានដោយក្រ ព្រោះសទ្ធារបស់បុថុជ្ជនមិនមាំទាំប្រែប្រួលគ្រប់ជំហានដោយហេតុនោះឯងអគ្គសាវកអម្បាលព្រះមហាមោគ្គល្លាន គង់មិនអាចជាអ្នកធានានូវសទ្ធារបស់បុថុជ្ជននោះបាន ទើបពោល ( ក្នុងខទាន ) ថា

ម្នាលអាវុសោ ខ្ញុំនអាត្មាធានាឲ្យអ្នកតែធម៌ ២ យ៉ាង គឺភោគៈ ១ ជីវិត ១ ឯខ្លួនអ្នកត្រូវតែជានាសទ្ធាខ្លួនឯងចុះ ដូច្នេះ ។ បទថា **ឃរំ តុម្ហេ បុញ្ចេន បរិហីនា ភាវិស្សថ** ពាក្យថា **បុញ្ចេន** ជាតតិយាវិភត្តិចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ គឺអ្នកនឹងជាបុគ្គលសាបសូន្យចាកបុណ្យ គឺបែរខ្នងដាក់បុណ្យ ។ បទថា **ភា-កុដិកា** បានដល់ ធ្វើមុខក្រញូវ ដោយការសម្តែងមុខក្រញូវ អធិប្បាយថាមានមុខជូរ ។ ឈ្មោះថា **ភាកុដិកោ** ព្រោះអត្ថថា មានមុខក្រញូវជាប្រក្រតី ។ ភាវនៃបុគ្គលមានមុខក្រញូវ ឈ្មោះថា **ភាកុដិយំ** ។ បទថា **កុហនា** បានដល់ ការធ្វើឲ្យភាន់ភាំង ។ កិរិយារបស់បុគ្គលអ្នកបោកបញ្ឆោត ឈ្មោះថា **កុហាយនា** ។ ភាវរបស់បុគ្គលអ្នកបោកបញ្ឆោត ឈ្មោះថា **កុហិតត្តំ** ។

បទថា **ឆាបិច្ឆោ** បានដល់ ប្រាថ្នានឹងសម្តែងគុណដែលមិនមាន ។ បទថា **ឥច្ឆាបកតោ** សេចក្តីថា ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ គឺប្រទូស្ត ។ បទ

ថា **សម្ភាវនាធិប្បាយោ** បានដល់ មានអធ្យាស្រ័យប្រកាន់ខ្លួនខ្លាំង ។ បទថា **គមនំ សណ្ឋបេតិ** បានដល់ រៀបចំការដើរ មានការឈានទៅមុខជាដើម អធិប្បាយថា ធ្វើនូវភាពគួរជ្រះថ្លា ។ ក្នុងបទក្រៅអំពីនេះ ក៏មានន័យនេះដូចគ្នា ។ បទថា **បណិធាយ គច្ឆតិ** បានដល់ តាំងចិត្តដើរ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សមាហិតោ វិយ គច្ឆតិ** បានដល់ ដើរដូចភិក្ខុ បានឧបចារសមាធិនិងអប្បនាសមាធិ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **អាបាថកជ្ឈាយីវ ហោតិ** បានដល់ សម្តែងភាពជាអ្នកស្ងប់ ធ្វើដូចជាចូលឈានចំពោះមុខពួកមនុស្សដែលមកជួប ។ បទថា **ឥរិយាបថស្ស** បានដល់ ឥរិយាបថ ៤ ។ បទថា **អាឋបនា** បានដល់ តាំងចិត្តទុកអំពីខាងដើម ឬតាំងចិត្តទុកដោយអើពើ ។ បទថា **ឋបនា** បានដល់ អាការនៃការតាំងទុក ។ បទថា **សណ្ឋបនា** បានដល់ ការតាក់តែង អធិប្បាយថា ធ្វើការៈឲ្យគួរជ្រះថ្លា ។ បទថា **អរិយធម្ម សន្និស្សិតំ** បានដល់ ទាក់ទងដោយលោកុត្តរ-ធម៌ ។ បទថា **កុញ្ចិកំ** បានដល់ កូនសោសម្រាប់បើក ។ បទថា **មិត្តា** បានដល់ អ្នកមានការជាប់ចំពាក់ ។ បទថា **សន្ទិដ្ឋា** បានដល់ ត្រឹមតែឃើញគ្នា ។ បទថា **សម្ភត្តា** បានដល់ ជាមិត្តស្និទ្ធស្នាលគ្នាខ្លាំង ។ បទថា **ឧទ្ទុណ្ឌោ** បានដល់ ទីសម្រាកពិសេសណាមួយ ។ បទថា **កោរជិកកោរជិកោ** បានដល់ ដែលក្លែងធ្វើមុខកញ្ចុបកញ្ចូវ អធិប្បាយថា ធ្វើមុខអាក្រក់ក្រៃលែង ។ បាឋៈថា **កោរចកកោរចកោ** ក៏មាន ។ បទថា **ភាកុដិកភាកុដិកោ** បានដល់

*មានប្រក្រតីធ្វើមុខក្រញូវពន់ពេក ។ បទថា* **កុហកកុហកោ** *បានដល់ ធ្វើឲ្យភាន់ភាំងក្រៃពេក ។ បទថា* **លបកលបកោ** *បានដល់ និយាយច្រើនពេក ។ បទថា* **មុខសម្ភារិកោ** *បានដល់ ទទួលការសរសើរមួយអន្លើដោយវត្ថុដទៃៗ ព្រោះមុខរបស់ខ្លួន ។ អាចារ្យពួកមួយពោលថា* **អប្បិតចិត្តោ** *គឺមិនស្កប់ស្កល់ចិត្ត ។ បទថា* **សន្តានំ** *បានដល់ ស្ងប់ព្រោះកិលេសស្ងប់ ។ បទថា* **សមាបត្តីនំ** *បានដល់ ធម៌ដែលគួរចូល ។ បទថា* **គម្ភីរំ** *បានដល់ ដែលមានទីតាំងដ៏ជ្រៅ ។ បទថា* **គុទ្ធរំ** *បានដល់ លំបាកនឹងឃើញបាន ។ បទថា* **និបុណំ** *បានដល់ ល្អិតសុខុម ។ បទថា* **បដិច្ចឆន្នំ** *បានដល់ អធិប្បាយឲ្យដឹងច្បាស់ ចាក់ចុះតាមអត្ថនៃបទបានលំបាក ។ បទថា* **លោកុត្តរំ** *បានដល់ សម្តែងដល់លោកុត្តរធម៌ ។ បទថា* **សុញ្ញតាបដិសញ្ញុតំ** *បានដល់ បដិសំយុត្តដោយនិព្វាន ។ម្យ៉ាងទៀត បទថា* **លោកុត្តរសុញ្ញតា បដិសញ្ញុត្តំ** *បានដល់ បដិសំយុត្តដោយនិព្វានដែលជាលោកុត្តរធម៌ ។*

*[ ៧៩ ] បទថា* **កាយិកំ ចាគត្តិយំ** *បានដល់ ប្រព្រឹត្តទៅផ្លូវកាយឈ្មោះថា* **កាយិក** *។ ការផ្តាំផ្ញើប្រព្រឹត្តទៅផ្លូវវាចានិងចិត្តក៏មានន័យដូចគ្នា ។ បទថា* **អចិត្តីការកតោ** *បានដល់ វៀរចាកការរាប់អានច្រើន ។ បទថា* **អនុចាហានានំ ចង្កមន្តានំ** *បានដល់ នៅក្នុងទីជិតភិក្ខុដែលជាថេរៈ ដែលដើរចង្ក្រមមិនពាក់ស្បែកជើង បទនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអនាទរៈ ។ បទថា* **សឧចាហនោ** *បានដល់ ពាក់ស្បែកជើងដើរចង្ក្រម ។ បទថា* **នីចេ ចង្កមេ ចង្កមន្តានំ** *បានដល់ កាលភិក្ខុជាព្រះថេរៈដើរចង្ក្រមលើផែនដី ដែលមិនបាន*

ធ្វើការកំណត់ទុក ឬដើរចង្ក្រមក្នុងទីចង្ក្រមដែលកំណត់ទុកហើយកៀរនូវខ្សាច់ធ្វើដូចកោះតែក៏នៅជាទីចង្ក្រមទៀត ។ បទថា **ឧច្ចេ ចង្កមេ ចង្កមតិ** បានដល់ដើរចង្ក្រមក្នុងទីចង្ក្រមខ្ពស់ ព័ទ្ធដោយវេទិកាឥដ្ឋ ។ បើព័ទ្ធដោយកំពែងប្រកបដោយខ្លោងទ្វារ ឬបិទបាំងទុកដោយល្អក្នុងវាំងភ្នំ វាំងព្រៃនិងវាំងគុម្ពឈើក៏រមែងគួរដើម្បីដើរក្នុងទីចង្ក្រមបែបនោះ ។ ក្នុងទីដែលមិនបិទបាំងលះឧបចារៈចេញក៏គួរ ។ បទថា **យដ្ឋិយន្តោបិ តិដ្ឋតិ** បានដល់ ឈរជិតពេក ។ បទថា **បុរតោបិ តិដ្ឋតិ** បានដល់ ឈរខាងមុខខ្លះ ។ បទថា **ឋិតកោបិ ភណតិ** បានដល់ និយាយមិនបន្ទន់ខ្លួនដូចគល់ឈើ ។ បទថា **ពាហាវិក្ខេបកោ** បានដល់ គ្រវែដៃទៅមកពោល ។ បទថា **អនុបខជ្ជ** បានដល់ ចូលទៅកាន់ទីដែលព្រះថេរៈទាំងឡាយអង្គុយ ។ បទថា **ឆវេបិ ភិក្ខុ អាសនេន បដិពាហតិ** បានដល់ មិនអង្គុយលើអាសនៈដែលដល់លំដាប់ខ្លួន ចូលទៅអង្គុយខាងមុខខ្លះ ខាងក្រោយខ្លះ ឈ្មោះថា ជ្រៀតបៀតអាសនៈ ។ បទថា **អនាបុច្ឆាបិ កដ្ឋំ បក្ខិបតិ** បានដល់ មិនប្រាប់ មិនសូមអនុញ្ញាត ហើយដាក់ឧសក្នុងភ្លើងខ្លះ ។ បទថា **ទ្វារំ បិទហតិ** បានដល់ បិទពាងភ្លើង ។ បទថា **ឱតរតិ** បានដល់ ចូលទៅកាន់កំពង់ទឹក ។ បទថា **ន្ហាយតិ** បានដល់ ជម្រះរាងកាយ ។ បទថា **ឧត្តរតិ** បានដល់ ឡើងមកកាន់ច្រាំងអំពីកំពង់ទឹក ។ បទថា **វោក្កម្មាបិ** បានដល់ ដើរហួសទៅមុខខ្លះ ។ បទថា **ឱវរកានិ** បានដល់ ផ្ទះដេកដែលគេកាត់តែងជាបន្ទប់ ។ បទថា **គុទ្ធ្លានិ** បានដល់ បិទបាំង ។ បទថា **បដិច្ឆន្នានិ** បានដល់ មានរបស់ដទៃបិទបាំងទុក ។ បទថា **អនជ្ឈិដ្ឋោ វា** បានដល់ ព្រះ

ថេរៈមិនបានប្រាប់និងមិនបានអារាធថា សូមលោកពោលធម៌ចុះ ដូច្នេះ ។

[ ៨០ ] បទថា **ចាបធម្មោ** បានដល់ មានធម៌លាមក ។ បទថា **អសុចិ-សង្កស្សរសមាចារោ** បានដល់ ឈ្មោះថា **អសុចិសង្កស្សរសមាចារោ** ព្រោះអត្ថថា មានការប្រព្រឹត្ត គឺមានការប្រកបដែលអ្នកដទៃគប្បីរឭកដោយសេចក្ដីរង្កៀសថា បុគ្គលនេះជាមនុស្សទ្រុស្តសីលដូច្នេះ ។ បទថា **សង្កស្សរសមាចារោ** សូត្រពាក្យថា **ស** ជា **ស្ស** ក៏បាន ។

បទថា **បដិច្ឆន្នកម្មន្តោ** បានដល់ មានការរំការផ្លូវកាយនិងវាចាបិទបាំង ។ បទថា **អស្សមណោ** បានដល់ មិនមែនជាសមណៈ ។ បទថា **សមណប្បដិញ្ញោ** បានដល់ ប្ដេជ្ញាឲ្យដឹងថាអាត្មាជាសមណៈ ។ បទថា **អព្រហ្មចារី** បានដល់ វៀរចាកការប្រព្រឹត្តដ៏ប្រសើរ ។ បទថា **ព្រហ្មចារិប្បដិញ្ញោ** បានដល់ មានន័យដូចគ្នាតាមដែលពោលហើយ ។ បទថា **អន្តោបូតិ** បានដល់ ដល់នូវភាពជាអ្នកស្អុយក្នុងព្រោះវៀរចាកកុសលធម៌ខាងក្នុង ។ បទថា **អវស្សុតោ** បានដល់ ទទឹកដោយរាគៈ ។ បទថា **កសម្ពុជាតោ** បានដល់ មានសភាពជាសំរាម ។

ក្នុងបទថា **អាចារគោចរសម្បន្នោ** នេះគប្បីជ្រាបសេចក្ដីតទៅនេះថា ភិក្ខុមានសេចក្ដីគោរព មានការកោតក្រែង ដល់ព្រមដោយហិរិនិងឱត្តប្បៈ ស្លៀកស្បង់រៀបរយ ដណ្ដប់រៀបរយ ឈានទៅមុខ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកឆ្វេងស្ដាំ បត់អង្គុញ លាតសណ្ដូក គួរជ្រះថ្លា មានភ្នែកដាក់ចុះ ដល់ព្រមដោយឥរិយាបថ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណ

*ក្នុងការបរិភោគ ប្រកបនូវសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭករឿយៗ ប្រកបដោយសតិសម្បជញ្ញៈ ប្រាជ្ញាតិច សន្តោស ប្រារព្ធព្យាយាម ធ្វើនូវការគោរពក្នុងអភិសមាចារិកវត្ត ច្រើនទៅដោយការកោតក្រែង នេះលោកហៅថា អាចារ ។ គប្បីជ្រាបអាចារប្រមាណប៉ុណ្ណេះ ។*

*ឯគោចរមាន ៣ យ៉ាង គឺឧបនិស្សយគោចរ ១ អារក្ខគោចរ ១ ឧបនិពន្ធគោចរ ១ ។*

*ក្នុងគោចរ ៣ យ៉ាងនោះ ឧបនិស្សយគោចរដូចម្តេច ភិក្ខុប្រកបដោយគុណគឺកថាវត្ថុ ១០ មានមិត្តល្អ ចូលទៅអាស្រ័យបុគ្គលណា រមែងបានស្តាប់រឿងដែលមិនធ្លាប់ស្តាប់ រមែងធ្វើរឿងដែលស្តាប់ហើយឲ្យជាក់ច្បាស់ ធ្វើនូវការសង្ស័យបាន ធ្វើនូវទិដ្ឋិឲ្យត្រង់ ធ្វើចិត្តឲ្យផូរផង់ តាមសិក្សានូវវត្តណារមែងចម្រើនទៅដោយសទ្ធា សីល សុតៈ ចាគៈ បញ្ញា នេះឈ្មោះថា* **ឧបនិស្សយគោចរ** ។

*អារក្ខគោចរតើដូចម្តេច ភិក្ខុក្នុងសាសនានេះ ចូលទៅក្នុងចន្លោះផ្ទះ ដើរតាមផ្លូវ មានភ្នែកដាក់ចុះ សម្លឹងមើលត្រឹមមួយជួរនឹម សង្រួមយ៉ាងល្អ ដើរទៅមិនមើលដំរី សេះ រថ អ្នកដំណើរ ស្ត្រី បុរស មិនងើយមើល មិនឱនមើល មិនសម្លឹងទិសតូចធំដើរទៅ នេះឈ្មោះថា* **អារក្ខគោចរ** ។

*ឧបនិពន្ធគោចរដូចម្តេច គឺសតិប្បដ្ឋាន ៤ ជាទីចូលទៅចងចិត្តទុកក្នុងសតិប្បដ្ឋានណា ។ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ចុះទីជាទីគោចររបស់ភិក្ខុជាដែននៃបិតារបស់*

ខ្ទួនតើដូចម្ដេច ។ គឺសតិប្បដ្ឋានទាំង ៤ នេះឯងដូច្នេះ នេះឈ្មោះថា **ឧបនិ-ពន្ធគោចរ** ។ ភិក្ខុចូលដល់ ចូលដល់ព្រម ប្រកបហើយដោយអាចារនេះនិង គោចរនេះដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបលោកហៅថា **អាចារ-គោចារសម្បន្នោ** ។ បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** បានដល់ មានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ ដែលមានប្រមាណតិចតួច ដែល មានប្រភេទជាដើមថា មិនក្លែងឲ្យត្រូវអាបត្តិ ដែលជាអកុសលចិត្តុប្បាទក្នុង សេខិយវត្ត ។ បទថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** បានដល់ កាន់ យកដោយប្រពៃ សិក្សានូវសិក្ខាបទដែលគួរសិក្សាណាមួយ ក្នុងសិក្ខាបទទាំង ឡាយ ។ ក្នុងបទថា **ចាតិមោក្ខសំវរសំវុតោ** នេះ ក្នុងទេសនាដែលជាបុគ្គ-លាធិដ្ឋានមានប្រមាណប៉ុណ្ណេះ លោកសម្ដែងដល់សីល គឺការសង្រួមក្នុង បាតិមោក្ខ ។ គប្បីជ្រាបបទទាំងពួងមានបទថា **អាចារគោចារសម្បន្នោ** ជា ដើម លោកពោលដើម្បីសម្ដែងដល់ការបដិបត្តិដែលជាហេតុឲ្យសីលរបស់អ្នក បដិបត្តិបរិបូណ៌ ។

[ ៨២ ] បទថា **សាតិយេសុ អនស្សាវី** បានដល់ វៀរចាកការស្និទ្ធ ស្នាលដោយតណ្ហាក្នុងកាមគុណទាំងឡាយ ដែលជាវត្ថុគួរត្រេកអរ ។ បទថា **សណ្ហោ** បានដល់ ប្រកបដោយកាយកម្មជាដើមដ៏ល្អិត ។ បទថា **បដិភាណវា** បានដល់ ប្រកបដោយបដិភាណក្នុងបរិយត្តិបុច្ឆា បរិបុច្ឆានិងអធិគម ។ បទ ថា **ន សទ្ធោ** បានដល់ មិនជឿបុគ្គលណាមួយ ក្នុងធម៌ដែលសម្រេចឯង ។ បទថា **ន វិរជ្ជតិ** បានដល់ មិនប្រាសចាកតម្រេកក្នុងឥឡូវនេះ ព្រោះភាពជា

អ្នកត្រេកអរទៅប្រាសហើយ ព្រោះការអស់ទៅនៃរាគៈ ។

[ ៨៣ ] បទថា **យេសំ ឯសា** បានដល់ តណ្ហាគឺ សេចក្តីប្រាថ្នាក្នុងកាមគុណដែលជាធម្មជាតគួរត្រេកអរ ដែលបុគ្គលពួកណា ។ បទថា **អប្បហីនា** បានដល់ តណ្ហាដែលសម្បយុត្តដោយការស្និទ្ធស្នាល ដែលបុគ្គលមិនទាន់លះបានដោយអរហត្តមគ្គ ។ បទថា **តេសំ ចក្ខុតោ រូបតណ្ហា សវតិ** បានដល់ តណ្ហាមានរូបជាអារម្មណ៍ សម្បយុត្តដោយជវនវិថីចិត្តដែលប្រព្រឹត្តទៅហើយតាមចក្ខុទ្វារ រមែងកើតដល់ជនទាំងនោះ ។ បទថា **បសវតិ** បានដល់ ដោយភូមិតណ្ហារមែងហូរទៅដល់ភវគ្គព្រហ្ម ដោយធម៌រមែងហូរទៅដល់គោត្រភូ ។ បទថា **សន្ទតិ** បានដល់ ហូរទៅក្រោមដូចខ្សែទឹក ។ បទថា **បវត្តតិ** បានដល់ ប្រព្រឹត្តទៅដោយកើតឡើងរឿយៗ ។ ក្នុងទ្វារដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងធម៌ចំណែកស គប្បីជ្រាបដោយន័យផ្ទុយគ្នាដែលពោលហើយ តណ្ហាឈ្មោះថា លះហើយដោយល្អដោយអរហត្តមគ្គ រូបតណ្ហារមែងមិនហូរទៅតាមចក្ខុរបស់ជនទាំងនោះ ។

[ ៨៥ ] បទថា **សណ្ហេន កាយកម្មេន សមន្នាគតោ** បានដល់ ជាអ្នកដល់ព្រមដោយកាយកម្មដែលទន់ភ្លន់ មិនគ្រោតគ្រាត ។ ក្នុងវចីកម្មជាដើមក៏មានន័យនេះដូចគ្នា ។ ក្នុងបទទាំងឡាយមានបទថា **សណ្ហេហិ សតិប្បដ្ឋានេហិ** ជាដើម សេចក្តីថា សតិប្បដ្ឋានជាដើម ជាធម៌លាយដោយលោកិយនិងលោកុត្តរ ។ បញ្ញា ៣ ពោលគឺ ប្រភេទបដិភាណដែលអាចធ្វើការសង្កេតពិនិត្យ ការធ្វើឲ្យជាក់ច្បាស់ ការកំណត់ដោយអំណាចការសាកសួរដល់អត្ថ

ដែលបានរៀនមកជាដើម និងដោយការសម្រេចលោកិយធម៌និងលោកុត្តរធម៌ មានដល់បុគ្គលណា បុគ្គលនោះឈ្មោះថា **បដិភាណវា** ។

[ ៨៦ ] បទថា **តស្ស បរិយត្តឹ និស្សាយ បដិភាយតិ** បានដល់ ញាណរបស់បុគ្គលនោះដែលបានរៀនមកស្ទាត់ជំនាញ រមែងសម្ដែងជាញាណប្រាកដចំពោះមុខ ។ បទថា **ចត្តារោ សតិប្បដ្ឋានា** សេចក្ដីថា លោកពោលពោធិបក្ខិយធម៌ ៣៧ ដោយលាយឡំគ្នា ទាំងលោកិយនិងលោកុត្តរ ។ គប្បីជ្រាបថា លោកពោលបដិសម្ភិទា ៤ ដោយលោកុត្តរ ដែលកើតអំពីមគ្គផលនិងអភិញ្ញា ៦ ដោយអំណាចជាធម៌ដែលមានក្នុងទីបំផុតនៃវិមោក្ខ ។ ក្នុងបទទាំងនោះ បទថា **ចតស្សោ** បានដល់ ប្រភេទនៃញាណ ៤ ។ ញាណ ៦ មានឥទ្ធិវិធជាដើម និងអាសវក្ខយជាខាងចុង ។ បទថា **តស្ស** បានដល់ បុគ្គល ។ គប្បីភ្ជាប់ថា **អត្ថោ បដិភាយតិ** ។ បទថា **អត្ថោ** ជាផលដែលកើតអំពីហេតុដោយសង្ខេបព្រោះបុគ្គលរមែងទៅ រមែងដល់ រមែងសម្រេចអត្ថនោះដោយស្ទុះទៅតាមហេតុ ដូច្នោះទើបលោកហៅថា **អត្ថោ** ។ តែដោយប្រភេទធម៌ទាំង ៥ នេះ គឺបច្ចុប្បន្ន ១ និព្វាន ១ អត្ថនៃភាសិត ១ វិបាក ១ កិរិយា ១ ឯណានីមួយគប្បីជ្រាបថា **អត្ថោ** ។ កាលពិចារណាដល់អត្ថនោះ ជាការដឹងច្បាស់នូវអត្ថនោះដោយប្រភេទ ។ បទថា **ធម្មោ** បានដល់ បច្ច័យដោយសង្ខេប ។ ព្រោះបច្ច័យរមែងចាត់ការ គឺឲ្យប្រព្រឹត្តទៅនិងឲ្យដល់នូវអត្ថនោះៗ ហេតុនោះទើបហៅថា **ធម្មោ** ។ តែដោយប្រភេទធម៌ ៥ នេះ គឺធម៌ដែលឲ្យកើតផលឯណានីមួយ ១ ហេតុ ១ អរិយមគ្គ ១ ភាសិតដែល

*ជាកុសល ១ អកុសល ១ គប្បីជ្រាបថា ធម៌ ។ កាលពិចារណាធម៌នោះ ជាការដឹងច្បាស់ធម៌នោះដោយប្រភេទ ការប្រើភាសាតាមសភាវៈ ការបញ្ចេញសំឡេង ការពោលឯណាក្នុងអត្ថនិងក្នុងធម៌នោះ កាលបុគ្គលនោះធ្វើសំឡេងក្នុងការប្រើភាសាតាមសភាវៈជាការនិយាយ ការពោល ការបន្លឺសំឡេងក្នុងការនិយាយ ក្នុងការពោល ក្នុងការបន្លឺសំឡេងឲ្យជាអារម្មណ៍ហើយពិចារណា ក៏ជាការដឹងច្បាស់នូវការប្រើភាសានោះ ។*

*គប្បីជ្រាបអត្ថក្នុងបទតទៅនេះថា បទថា* **អត្ថេ ញាតេ អត្ថោ បដិភាយតិ** *បានដល់ កាលអត្ថដែលមានប្រភេទដូចនាំសំឡេងរបស់បុគ្គលនោះមកពោល ហើយប្រាកដក្នុងកាលឥឡូវនេះ អត្ថដែលមានប្រភេទដូចពោលហើយក៏ជាក់ច្បាស់ដល់បុគ្គលនោះ ឈ្មោះថា ជាអ្នកប្រាជ្ញាចំពោះញាណ ។ បទថា* **ធម្មេ ញាតេ ធម្មោ បដិភាយតិ** *បានដល់ កាលធម៌មានប្រភេទដូចពោលហើយប្រាកដ ធម៌មានប្រភេទដូចពោលហើយក៏ជាក់ច្បាស់ ។ បទថា* **និរុត្តិយា ញាតាយ និរុត្តិ បដិភាយតិ** *បានដល់ កាលនិរុត្តិមានប្រភេទដូចពោលហើយប្រាកដ និរុត្តិដែលមានប្រភេទដូចពោលហើយក៏ជាក់ច្បាស់ ។ បទថា* **ឥមេសុ តីសុ ញាណេសុ ញាណំ** *បានដល់ កាលបុគ្គលធ្វើញាណទាំងអស់ក្នុងញាណ ៣ នេះ គឺអត្ថធម៌និងនិរុត្តិឲ្យជាអារម្មណ៍ ហើយពិចារណាញាណ ដែលមានប្រភេទក្នុងញាណ ៣ នោះ ឬញាណដែលមានសេចក្ដីពិស្ដារដោយគោចរកិច្ចជាដើម ក្នុងញាណទាំង ៣ នោះ ដូចពោលហើយឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បទថា* **ឥមាយ បដិភាណប្បដិសម្ភិទាយ** *បានដល់ បុគ្គលចូល*

ដល់ ដោយបញ្ញាទូលំទូលាយដូចពោលហើយ ដែលមានប្រការតាមពោលហើយនេះ ។ បទថា **សោ វុច្ចតិ បដិភាណវា** បានដល់ ពោលដោយសរុប ។ បទថា **យស្ស បរិយត្តិ នត្ថិ** សេចក្ដីថា ព្រះពុទ្ធវចនៈ ឈ្មោះថា បរិយត្តិ ពិតហើយបដិសម្ភិទា ការក្លៀវក្លា រមែងមានដល់បុគ្គលដែលរៀននូវបរិយត្តិនោះ ។ បរិយត្តិបែបនោះមិនមានដល់បុគ្គលណា ។ បទថា **បរិបុច្ឆា នត្ថិ** សេចក្ដីថា គណ្ឋិបទ បទអត្ថនិងវិនិច្ឆ័យកថា ក្នុងបាលីនិងអដ្ឋកថាជាដើម ឈ្មោះថា **បរិបុច្ឆា** ។ បដិសម្ភិទា ការក្លៀវក្លារមែងមានដល់បុគ្គលដែលពោលនូវអត្ថក្នុងបាលីដែលបានរៀនមកជាដើម ។ បទថា **អធិគម នត្ថិ** បានដល់ការសម្រេចអរហត្ត ឈ្មោះថា **អធិគមោ** ។ ពិតហើយបដិសម្ភិទា ការក្លៀវក្លា រមែងមានដល់បុគ្គលដែលសម្រេចអរហត្ត ។ សម្បត្តិ ៣ យ៉ាងដូចពោលហើយ មិនមានដល់បុគ្គលណា ។ បទថា **កឹ តស្ស បដិភាយិស្សតិ** សេចក្ដីថា ញាណដែលដល់នូវការបែកធ្លាយនឹងប្រាកដដល់បុគ្គលនោះដោយហេតុអ្វីហ្ន៎ ។

[ ៨៧ ] បទថា **សាមំ** បានដល់ ដោយខ្លួន□ងនោះឯង ។ បទថា **ស-យមភិញ្ញាតំ** បានដល់ ដឹងដោយញាណនោះដោយខ្លួនឯង ។ បទថា **អត្ត-ប្បច្ចក្ខំ ធម្មំ** បានដល់ ធម៌ដែលខ្លួនឃើញឯង ។ បទថា **ន កស្សចិ សទ្ទហាតិ** បានដល់ មិនជឿ គឺមិនប្រព្រឹត្តទៅតាមការជឿចំពោះជនដទៃព្រោះជាក់ច្បាស់ដោយខ្លួនឯង ។ លោកពោលពាក្យជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** បានដល់ ដោយអំណាចការឃើញបច្ចយាការ ១២ លោកពោលពាក្យថា **អវិជ្ជា-**

**និរោធា** ជាដើម សំដៅដល់ការត្រឡប់ទៅ នៃសង្សារវដ្ត ។ លោកពោលថា **ឥទំ ទុក្ខំ** ជាដើម ដោយឃើញអរិយសច្ច ។ លោកពោលថា **ឥមេ អាសវា** ជាដើម ដោយអំណាចការឃើញសច្ចធម៌ ដោយអំណាចកិលេស ដោយបរិយាយដទៃ ។ លោកពោលថា **ឥមេ ធម្មា អភិញ្ញេយ្យា** ជាដើម ដោយអំណាចការឃើញធម៌ដែលគួរដឹងក្រៃលែង ដែលគួរកំណត់ដឹង ដែលគួរលះ និងដែលគួរចម្រើន និងគួរធ្វើឲ្យជាក់ច្បាស់ ។ លោកពោលពាក្យថា **ឆន្នំ ផស្សាយតនានំ** ជាដើមដោយអំណាចការឃើញនូវការកើត ការរលត់ គុណ ទោសនិងឧបាយជាគ្រឿងរលាស់ចេញនៃអាយតនៈ ៦ ។ លោកពោលដោយអំណាចការឃើញជាដើមយ៉ាងនេះ គឺនៃឧបាទានក្ខន្ធ ៥ ឃើញការកើតនិងការរលត់ដោយអាការ ២៥ ឃើញការពេញចិត្តដោយអំណាចធនូរាគៈ ក្នុងខន្ធទាំងនោះ ឃើញការប្រែប្រួលនិងទោសរបស់ខន្ធទាំងនោះ ឃើញនិព្វានដែលបានដល់ការរលាស់ចេញទៅនៃមហាភូតរូប ៤ ឃើញការកើត ព្រោះអវិជ្ជាជាដើម ឃើញការរលត់ក្នុងនិរោធនូវអវិជ្ជាជាដើម គប្បីជ្រាបធម៌ទាំងនេះដោយន័យដែលពោលហើយក្នុងទីនោះៗ ។

បទថា **អមតោគធំ** ឈ្មោះថា អមតៈ ព្រោះអត្ថថា មិនមានការស្លាប់ដែលបានដល់មរណៈ ។ ឈ្មោះថា អមតៈ ព្រោះអត្ថថាជាឱសថក៏មាន ព្រោះជាបដិបក្ខចំពោះកិលេស ។ ឈ្មោះថា **អមតោគធំ** ព្រោះបង្អោនទៅក្នុងអមតៈនោះ ។ បទថា **អមតបរាយនំ** បានដល់ មានអមតៈដូចពោលហើយជាខាងមុខ ជាទីទៅ ជាផ្លូវទៅ ជាទីពឹង ព្រោះហេតុនោះទើបឈ្មោះថា **អមតបរាយនំ** ។

*បទថា* **អមតបរិយោសានំ** *បានដល់ មានអមតៈនោះជាទីបំផុត ព្រោះអស់សង្ខារវដ្តហើយ ព្រោះហេតុនោះទើបឈ្មោះថា* **អមតបរិយោសានំ** ។

*[ ៨៨ ] បទថា* **លាភកម្យា ន សិក្ខតិ** *បានដល់ មិនសិក្សាក្នុងព្រះសូត្រជាដើម ព្រោះប្រាថ្នាលាភ ។ បទថា* **អវិរុទ្ធោ ច តណ្ហាយ រសេ ច នានុគិជ្ឈតិ** *បានដល់ ជាបុគ្គលមិនមានវិរោធ ព្រោះមិនមានការក្រោធនិងមិនដល់នូវការចង់បានព្រោះតណ្ហាក្នុងរសទាំងឡាយ មានរសកើតអំពីឫសជាដើម។*

*[ ៨៩ ] បទថា* **គេធ នុ ខោ** *បានដល់ ជាបុគ្គលអ្នកធ្លាក់ចុះក្នុងការស្វែងរកនៃតណ្ហាព្រោះគិតដល់ហេតុ ដ្បិតត្រូវការនឹងបាន ។ បទថា* **លាភាភិនិព្វត្តិយា** *បានដល់ ព្រោះការកើតឡើងនៃបច្ច័យ ៤ ដោយពិសេស ។ បទថា* **លាភំ បរិចាចេន្តោ** *បានដល់ ធ្វើបច្ច័យឲ្យចម្រើនដុះដាល ។ បទថា* **អត្តទមថាយ** *បានដល់ ដើម្បីទូន្មានខ្លួនដោយបញ្ញា ដែលសម្បយុត្តដោយវិបស្សនា ។ បទថា* **អត្តសមថាយ** *បានដល់ ដើម្បីការតាំងមាំនៃខ្លួនដោយបញ្ញា ដែលសម្បយុត្តដោយសមាធិ ។ បទថា* **អត្តបរិនិព្វាបនត្ថាយ** *បានដល់ ដើម្បីឲ្យខ្លួនបរិនិព្វាន ដោយអនុបាទាបរិនិព្វានដោយញាណ ២ យ៉ាងសមដូចលោកពោល ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលអាវុសោ ព្រហ្មចរិយធម៌ដែលខ្ញុំប្រព្រឹត្តក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វានទេតើ ។ បទថា* **អប្បិច្ឆញ្ញេវ និស្សាយ** *បានដល់ ការប្រាថ្នាតិច ៤ យ៉ាង គឺការប្រាថ្នាតិចក្នុងបច្ច័យ ១ ការប្រាថ្នាតិចក្នុងអធិគម ១ ការប្រាថ្នាតិច*

ក្នុងបរិយត្តិ ១ ការប្រាថ្នាតិចក្នុងធុតង្គ ១ ។ ការផ្សេងគ្នានៃការប្រាថ្នាតិចទាំង នោះមានពិស្តារហើយខាងដើម ។ ចុះស៊ប់ដោយការប្រាថ្នាតិចនោះ ។ បទថា **សន្តុដ្ឋិញ្ញោ** បានដល់ ចុះស៊ប់ក្នុងការសន្តោស ៣ យ៉ាង ក្នុងបច្ច័យ ៤ ។ ការបែកសន្តោសទាំងនោះមានពិស្តារហើយខាងដើម ។ បទថា **សល្លេខញ្ញោ** បានដល់ ការជុសខាត់កិលេស ។ បទថា **ឥធមត្ថិតញ្ញោ** បានដល់ មានសេចក្តីត្រូវការដោយកុសលធម៌ទាំងនេះ ទើបឈ្មោះថា **ឥធមត្ថិ** ការៈនៃ **ឥធមត្ថិ** នោះ ឈ្មោះថា **ឥធមត្ថិតា** ។ អាស្រ័យគឺចូលជាមួយភាពជាបុគ្គលអ្នកមាន សេចក្តីត្រូវការដោយកុសលនោះឯង ។

បទថា **រសោ** ជាមាតិកានៃពាក្យអធិប្បាយ ។ បទថា **មូលរសោ** បានដល់ រសឯណានីមួយដែលកើតឡើងព្រោះអាស្រ័យឫស ។ ក្នុងរសដែលកើតអំពីដើមក៏មានន័យនេះឯង ។ បទថា **អម្ពិលំ** បានដល់ រសជូរ មានរសជូររបស់តក្កៈជាដើម ។ បទថា **មធុរំ** បានដល់ សប្បិនៃគោជាដើម មានរសផ្អែមដោយចំណែកមួយ ។ ប៉ុន្តែទឹកឃ្មុំផ្សំជាមួយនឹងរសចត់ទុកយូរក៏ក្លាយបាន ។ ទឹកអំពៅផ្សំជាមួយរសប្រែទុកយូរ ក៏ប្រែទៅជារសខារបាន ។ ឯសប្បិទុកយូរ សូម្បីលះពណ៌និងក្លិនក៏មិនខូចរសព្រោះហេតុនោះទើបសប្បិនោះមានរសផ្អែមដោយចំណែកមួយ ។ បទថា **តិត្តកំ** បានដល់ ស្ដឹកស្ដៅជាដើម ។ បទថា **កដុកំ** បានដល់ ខ្ញីនិងម្រេចជាដើម ។ បទថា **លោណិកំ** បានដល់ អំបិលសិន្ធវៈជាដើម ។ បទថា **ខារិកំ** បានដល់ គ្រប់ខារនិងទំពាំងជាដើម ។ បទថា **លម្ពិលំ** បានដល់ ពុទ្រា ខ្វិតនិងស្លឹកលោទជាដើម ។ បទថា **កសាវំ**

បានដល់ សម៉ជាដើម ។ រសទាំងអស់នេះលោកពោលទុកដោយជាវត្ថុក្នុងទីនេះគប្បីជ្រាបថា លោកពោលដល់រសដែលមានរសនោះៗជាវត្ថុដោយឈ្មោះមានរសជូរជាដើម ។ បទថា **សាទុ** បានដល់ រសដែលគួរពេញចិត្ត ។ បទថា **អសាទុ** បានដល់ រសដែលមិនគួរពេញចិត្ត ។ ដោយបទ ២ នេះ ក៏ឈ្មោះថាសំដៅដល់រសទាំងអស់ ។ បទថា **សីតំ** បានដល់ មានរសត្រជាក់ ។ បទថា **ឧណ្ហំ** បានដល់ មានរសក្តៅ ។ រសនេះសូម្បីផ្សេងគ្នាដោយប្រភេទមានរសដែលកើតអំពីឫសជាដើមយ៉ាងនេះ ក៏មិនផ្សេងគ្នា ដោយលក្ខណៈជាដើម ។ រសទាំងអស់នេះមានការប៉ះខ្ទប់ត្រង់អណ្តាតជាលក្ខណៈ មានការដឹងដោយជិវ្ហាវិញ្ញាណជាកិច្ច មានរសនោះឯងជាអារម្មណ៍ជាអាការប្រាកដ ។ បទថា **តេ ជិវ្ហគ្គេន រសគ្គានិ** បានដល់ សមណព្រាហ្មណ៍ទាំងនោះត្រាច់ស្វែងរករសដ៏ប្រសើរដោយចុងជិវ្ហាបសាទ ។ បទថា **បរិយេសន្តា** បានដល់ ស្វែងរក ។ បទថា **អាហិណ្ឌន្តិ** បានដល់ ត្រាច់ទៅក្នុងទីនោះៗ ។ បទថា **តេ អម្ពិលំ លភិត្វា អនម្ពិលំ បរិយេសន្តិ** បានដល់ បានរសជូរមានតក្កៈជាដើមក៏ស្វែងរករសមិនជូរ ។ ពាក្យទាំងអស់ប្រកបផ្ទាស់លំដាប់គ្នាទៅមកយ៉ាងនេះ ។

បទថា **បដិសង្ខា យោនិសោ អាហារំ អាហារេតិ** បានដល់ ដឹងដោយបញ្ញាជាគ្រឿងពិចារណា ហើយទើបឆាន់ដោយឧបាយ ។

ឥឡូវនេះដើម្បីសម្តែងឧបាយ ដែលជាឧបាយប្រាជ្ញា ទើបព្រះសារីបុត្តពោលពាក្យថា **នេវ ទវាយ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **នេវ ទវាយ** បានដល់ មិនបរិភោគដើម្បីលេង ។

ក្នុងបទនោះអ្នករបាំ អ្នកលោតជាដើម ឈ្មោះថា បរិភោគដើម្បីប្រយោជន៍ក្នុងការលេង ។ ពិតហើយការលេងដែលបានដល់ការរាំ ការច្រៀង អ្នកកំណាព្យ អ្នកលេងពាក្យស្លោករបស់អ្នកបរិភោគអាហារណា រមែងជួបនូវការសម្រេចក្រៃលែងឡើងៗ ជនទាំងនោះស្វែងរកអាហារនោះបរិភោគ ដោយមិនត្រឹមត្រូវ មិនសមគួរ ។ តែភិក្ខុនេះមិនបានឆាន់យ៉ាងនោះ ។

បទថា **ន មទាយ** បានដល់ មិនឆាន់ដើម្បីចម្រើននៃការស្រវឹង ដោយការប្រកាន់ខ្លួននិងការស្រវឹងរបស់បុរស ។ ក្នុងបទនោះព្រះរាជា មហាមាត្យរបស់ព្រះរាជា ឈ្មោះថា បរិភោគដើម្បីសេចក្តីស្រវឹង ព្រោះព្រះរាជានិងមហាមាត្យទាំងនោះ បរិភោគអាហារប្រណីត មានអាហារដែលមានរសឆ្ងាញ់ជាដើម ដើម្បីការចម្រើននៃការស្រវឹងដោយការប្រកាន់ខ្លួននិងការស្រវឹងរបស់បុរស ។ តែភិក្ខុនេះមិនដូច្នោះឡើយ ។ បទថា **ន មណ្ឌនាយ** បានដល់ មិនឆាន់ដើម្បីតាក់តែងរាងកាយ ។ ក្នុងបទនោះ ស្រ្តីដែលអាស្រ័យរូបចិញ្ចឹមជីវិតនិងអ្នករាជវាំងជាដើមរមែងផឹកសប្បិនិងទឹកអំពៅជាដើម បរិភោគអាហារល្អិតនិងទន់ដោយបំណងថា ដោយអាការយ៉ាងនេះ ថ្នាំងម្រាមដៃរបស់អញនឹងរាបស្មើ ពណ៌សម្បុរក្នុងរាងកាយនឹងផូរផង់ ។ តែភិក្ខុនេះមិនឆាន់យ៉ាងនេះទេ ។ បទថា **ន វិភូសនាយ** បានដល់ មិនឆាន់ដើម្បីឲ្យចម្រើនសាច់ក្នុងរាងកាយ ។ ក្នុងបទនោះអ្នកប្រដាល់អាជីព អ្នកបោកចំបាប់និងអ្នកប្រើកម្លាំងជាដើម រមែងឲ្យរាងកាយឆ្អែតដោយសាច់និងត្រីជាដើមដែលល្អិត ដោយសង្ឃឹមថា ដោយអាការយ៉ាងនេះសាច់របស់អញនឹងបរិបូណ៌ ដើម្បីអត់ធន់ចំពោះការដាល់តប់

ដូច្នេះ តែភិក្ខុនេះមិនមែនឆាន់ដើម្បីចម្រើនសាច់ក្នុងកាយយ៉ាងនេះឡើយ ។ បទថា **យាវទេវ** ជាការសម្តែងកំណត់ព្រំដែន នៃប្រយោជន៍ការឆាន់អាហារ ។ បទថា **ឥមស្ស កាយស្ស ឋិតិយា** បានដល់ ឆាន់ដើម្បីតាំងនៅនៃករជកាយដែលមានមហាភូតរូប ៤ នេះ អធិប្បាយថា នេះជាប្រយោជន៍ក្នុងការឆាន់នៃភិក្ខុនោះ ។ បទថា **យាបនាយ** បានដល់ ឆាន់ដើម្បីឲ្យជីវិតិន្ទ្រិយប្រព្រឹត្តទៅ ។ បទថា **វិហឹសុបរតិយា** បានដល់ សេចក្តីឃ្លានកើតឡើងព្រោះហេតុដែលមិនបរិភោគឈ្មោះថា សេចក្តីលំបាក ឆាន់ដើម្បីរម្ងាប់ គឺស្ងប់សេចក្តីលំបាកនោះ ។ បទថា **ព្រហ្មចរិយានុគ្គហាយ** បានដល់ សិក្ខា ៣ ពាក្យប្រៀនប្រដៅទាំងអស់ឈ្មោះថា ព្រហ្មចរិយៈ ឆាន់ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈនោះ ។

បទថា **ឥតិ** ជានិទស្សនៈរបស់ឧបាយ អធិប្បាយថា ដោយឧបាយនេះ ។ បទថា **បុរាណញ្ច វេទនំ បដិហង្ខាមិ** បានដល់ វេទនាដែលកើតព្រោះមិនទាន់បានបរិភោគឈ្មោះថា វេទនាចាស់ ឆាន់ដោយតាំងចិត្តថា អញនឹងកម្ចាត់វេទនាចាស់នោះចេញដូច្នេះ ។ បទថា **នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** បានដល់ វេទនាដែលកើតឡើងព្រោះហេតុឆាន់ច្រើនពេកឈ្មោះថា វេទនាថ្មី ឆាន់ដោយតាំងចិត្តថា អញនឹងមិនញ៉ាំងវេទនាថ្មីនោះឲ្យកើតឡើងដូច្នេះ ។ម្យ៉ាងទៀតវេទនាដែលកើតឡើង ព្រោះវត្ថុដែលបរិភោគជាបច្ច័យឈ្មោះថា វេទនាថ្មី ឆាន់ដើម្បីការមិនកើតឡើងនៃវេទនាថ្មីដែលមិនទាន់កើតឡើង ។ បទថា **យាត្រា ច មេ ភវិស្សតិ** បានដល់ ជីវិតរបស់អញនឹងប្រព្រឹត្តទៅបាន ។ ក្នុងបទថា **អនវជ្ជតា ច** មានវិនិច្ឆ័យថា វត្ថុមានទោសនិងវត្ថុមិនមានទោសមាន ។

ក្នុងបទនោះ ការស្វែងរកមិនប្រកបដោយធម៌ ការទទួលមិនប្រកបដោយធម៌ ការបរិភោគមិនប្រកបដោយធម៌នេះឈ្មោះថា វត្ថុមានទោស ។ ការស្វែងរកដោយធម៌ ទទួលដោយធម៌ ពិចារណាហើយបរិភោគឈ្មោះថា វត្ថុមិនមានទោស ។ ភិក្ខុរូបខ្លះធ្វើវត្ថុដែលមិនមានទោស ឲ្យជាវត្ថុដែលមានទោស ឆាន់លើសប្រមាណព្រោះគិតថា របស់ណាអញក៏បានមកហើយ មិនអាចនឹងឲ្យអាហារនោះរលួយបាន រមែងលំបាកដោយការក្អួតនិងឈឺជាដើម ។ ភិក្ខុទាំងឡាយក្នុងវិហារទាំងអស់ខ្វល់ខ្វាយក្នុងការព្យាបាលរក្សានិងស្វែងរកថ្នាំឲ្យដល់ភិក្ខុនោះ កាលត្រូវសួរថា រឿងនេះដូចម្ដេច ក៏ប្រាប់ថា ភិក្ខុរូបនោះធ្លល់ពោះជាដើម ជនទាំងឡាយរមែងនិន្ទា តិះដៀលថា ភិក្ខុរូបនេះមានប្រក្រតីយ៉ាងនេះសព្វកាល ប្រហែលជាមិនដឹងប្រមាណក្នុងផ្ទៃរបស់ខ្លួនទេដឹង ។ ភិក្ខុនេះឈ្មោះថា ធ្វើនូវវត្ថុមិនមានទោសឲ្យជាវត្ថុមានទោស ។ ភិក្ខុមិនធ្វើយ៉ាងនោះឆាន់ដោយគិតថា ការមិនមានទោសនឹងមានដល់អាត្មាអញ ។ សូម្បីក្នុងបទថា **ផាសុវិហារោ ច** ក៏មានទាំងការនៅសប្បាយនិងមានទាំងការនៅមិនសប្បាយ ។ ក្នុងបទនោះការបរិភោគរបស់ព្រាហ្មណ៍ ៥ នាក់ គឺអាហរហត្ថកៈ ១ អលំសាដកៈ ១ តត្រវដ្ដកៈ ១ កាកមាសកៈ ១ ភុត្តវមិតកៈ ១ ឈ្មោះថា ការនៅមិនសប្បាយ ។ ក្នុងព្រាហ្មណ៍ ៥ នាក់នោះព្រាហ្មណ៍ឈ្មោះថា អាហរហត្ថកៈ បរិភោគច្រើនរហូតមិនអាចក្រោកឡើងតាមធម្មតារបស់ខ្លួនបានពោលថា ជួយទាញដៃ ។ ព្រាហ្មណ៍ឈ្មោះថា អលំសាដកៈ ព្រោះភាពដែលខ្លួនមានពោះធំពេក ទោះបីក្រោកឡើងបានក៏មិនអាចស្លៀកសំពត់សាដកបាន ។ ព្រាហ្មណ៍

ឈ្មោះថា តត្រវដ្ដកៈ មិនអាចក្រោកឡើងបានបម្រះនទៀលទៅមកក្នុងទីនោះ ឯង ។ ព្រាហ្មណ៍ឈ្មោះថា កាកមាសកៈ បរិភោគរហូតដល់កដែលក្អែកអាច ចឹកស៊ីបាន ។ ព្រាហ្មណ៍ឈ្មោះថា កុត្តវមិតកៈ មិនអាចឲ្យអាហារនៅក្នុងមាត់ បានក៏ខ្ជាក់ចេញក្នុងទីនោះៗ ភិក្ខុមិនធ្វើយ៉ាងនេះ ធាន់ដោយគិតថា ការនៅ សប្បាយនឹងមានដល់អញ ។ ភាពជាបុគ្គលអ្នកមាន ផ្ទៃដែលសល់អំពីអាហារ ៤-៥ ពំនូតឈ្មោះថា នៅសប្បាយ ។ ឥរិយាបថ ៤ របស់អ្នកបរិភោគល្មម ប្រមាណហើយផឹកទឹក រមែងប្រព្រឹត្តទៅដោយសេចក្ដីសុខ ។ ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្តពោលទុក ( ក្នុងថេរគាថា ) យ៉ាងនេះថា

ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត )
ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ នៃភិក្ខុ
អ្នកមានចិត្តស្ងួនទៅរក ( ព្រះនិព្វាន ) ។

ម្យ៉ាងទៀត គប្បីប្រមូលអង្គទាំងឡាយទុកក្នុងទីនេះ ។ មិនធាន់ដើម្បីលេង ជាអង្គ ១ មិនធាន់ដើម្បីស្រវឹងជាអង្គ ១ មិនធាន់ដើម្បីតាក់តែងជាអង្គ ១ មិន ធាន់ដើម្បីប្រដាប់ជាអង្គ ១ ធាន់ដើម្បីតាំងនៅនៃកាយនេះ ដើម្បីឲ្យរាងកាយ នេះប្រព្រឹត្តទៅជាអង្គ ១ ធាន់ដើម្បីកម្ចាត់សេចក្ដីលំបាក ដើម្បីអនុគ្រោះដល់ ព្រហ្មចរិយៈជាអង្គ ១ ដោយមនសិការថា ដោយឧបាយដូច្នេះ អាត្មាអញនឹង កម្ចាត់វេទនាចាស់ នឹងមិនឲ្យវេទនាថ្មី កើតឡើងជាអង្គ ១ ការប្រព្រឹត្តទៅនឹង មានដល់អញជាអង្គ ១ ។ ក្នុងបទថា **អដ្ឋវង្គុតា ៥ ផាសុវិហារោ ៥** ជា អានិសង្សនៃការបរិភោគ ។

ព្រះមហាសិវត្ថេរពោលថា អង្គ ៤ ខាងដើមឈ្មោះថា ជាការហាម គួរប្រជុំអង្គ ៨ ខាងចុងទុកប៉ុណ្ណោះថាជាអង្គនៃការបរិភោគ ។ ក្នុងអង្គ ៨ នោះ បរិភោគដើម្បីឲ្យតាំងនៅនៃកាយនេះជាអង្គ ១ ដើម្បីឲ្យរាងកាយនេះប្រព្រឹត្តទៅជាអង្គ ១ ដើម្បីកម្ចាត់សេចក្តីលំបាកជាអង្គ ១ ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈជាអង្គ ១ ដោយមនសិការថា ដោយឧបាយនេះអញនឹងកម្ចាត់វេទនាចាស់ជាអង្គ ១ អញនឹងមិនឲ្យវេទនាថ្មីកើតឡើងជាអង្គ ១ ការប្រព្រឹត្តទៅនឹងមានដល់អញជាអង្គ ១ ការមិនមានទោសជាអង្គ ១ ការនៅសប្បាយជាអានិសង្សនៃការបរិភោគ ។ ភិក្ខុបរិភោគអាហារប្រកបដោយអង្គ ៨ យ៉ាងនេះ ។

[ ៩២ ] បទថា **ឧបេក្ខកោ** បានដល់ ជាអ្នកប្រកបដោយឆឡង្គុបេក្ខា ។ បទថា **សតោ** បានដល់ ប្រកបដោយសតិក្នុងកាយានុបស្សនាជាដើម ។

[ ៩៣ ] អ្វីឈ្មោះថា ធម៌ គឺឧបេក្ខាមានអង្គ ៦ ក្នុងបទថា **ឧបេក្ខកោតិ ឆឡង្គុបេក្ខាយ សមន្នាគតោ** នេះ ។ ញាណជាដើមឈ្មោះថា ឧបេក្ខាមានអង្គ ៦ ។ កាលពោលថា ញាណក៏បានដល់កិរិយាចិត្តញាណសម្បយុត្ត ៤ កាលពោលថា ធម៌ជាគ្រឿងនៅរឿយៗក៏បានដល់មហាចិត្ត ៨ ។ កាលពោលថា មិនមានតម្រេកនិងអាក់អន់ក៏បានដល់ចិត្ត ១០ ។ សោមនស្សរមែងមានដោយអំណាចអាសេវនៈ ។ បទថា **ចក្ខុនា រូបំ ទិស្វា** បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណដែលអាចឃើញរូប នេះជាវោហារ ឈ្មោះថា ចក្ខុគ្រាន់តែជាហេតុ ។ តែបុរាណាចារ្យទាំងឡាយពោលថា ចក្ខុរមែងមិនឃើញរូបព្រោះមិនមានចិត្តសូម្បីចិត្តក៏រមែងមិនឃើញរូបព្រោះមិនមានចក្ខុតែរមែងឃើញបាន

ដោយចិត្តដែលមានបសាទជាវត្ថុប៉ះខ្ទប់អារម្មណ៍តាមទ្វារក្នុងឋានៈដូច្នេះ ឈ្មោះថាជាការពោលដោយអង្គប្រកបដូចក្នុងប្រយោគជាដើមថា បាញ់ដោយធ្នូដូច្នេះ ព្រោះហេតុនោះអត្ថក្នុងបទនេះ ទើបមានដូច្នេះថា ឃើញរូបដោយចក្ខុវិញ្ញាណ ដូច្នេះ ។

បទថា **នេវ សុមនោ ហោតិ** បានដល់ មិនមានសោមនស្សដោយកើតលោភៈ ដោយកើតឆន្ទរាគៈ ។ បទថា **ន ទុម្មនោ** បានដល់ មិនមានចិត្តប្រទូស្តដោយកើតបដិឃៈ ។ បទថា **ឧបេក្ខកោ** បានដល់ ជាអ្នកឃើញដោយការចូលដល់ ជាអ្នកមិនធ្លាក់ទៅក្នុងចំណែក ( ណាមួយ ) ធ្វើឥរិយាបថឲ្យប្រព្រឹត្តទៅ ។ បទថា **សតោ សម្បជានោ** បានដល់ មានសតិបរិបូណ៌ដោយញាណ ។ បទថា **មនាបំ នាភិគិជ្ឈតិ** បានដល់ មិនចង់បាន មិនប្រាថ្នាអារម្មណ៍ដែលគួរប្រាថ្នា គួរជាទីត្រេកអរនៃចិត្ត ។ បទថា **នាភិហំសតិ** បានដល់ មិនគាប់ចិត្ត ។ បទថា **ន រាគំ ជនេតិ** បានដល់ មិនកើតនូវការត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នានោះ ។ បទថា **តស្ស ឋិតោវ កាយោ ហោតិ** បានដល់ កាយមានចក្ខុជាដើមរបស់ព្រះខីណាស្រពនោះ ក៏តាំងនៅគឺមិនញាប់ញ័រ ព្រោះវៀរចាកការញាប់ញ័រហើយ ។

បទថា **អមនាបំ** បានដល់ អារម្មណ៍ដែលមិនគួរប្រាថ្នា ។ បទថា **ន មង្កុ ហោតិ** បានដល់ មិនទោមនស្ស ។ បទថា **អប្បតិដ្ឋិតចិត្តោ** បានដល់ មិនមានចិត្តតាំងនៅដោយការក្រោធ ។ បទថា **អលីនមនសោ** បានដល់ មានចិត្តមិនរួញរា ។ បទថា **អព្យាបន្នចេតសោ** បានដល់ មានចិត្តវៀរចាកព្យា-

បាទ ។

បទថា **រជនីយេ ន រជ្ជតិ** បានដល់ មិនកើតរាគៈក្នុងវត្ថុជាទីតាំងនៃតម្រេក ។ បទថា **ទោសនីយេ ន ទុស្សតិ** បានដល់ មិនកើតទោសៈក្នុងវត្ថុដែលធ្វើឲ្យកើតទោសៈ ។ បទថា **មោហនីយេ ន មុយ្ហតិ** បានដល់ មិនឲ្យមោហៈកើតក្នុងវត្ថុដែលជាទីតាំងនៃមោហៈ ។ បទថា **កោបនីយេ ន កុប្បតិ** បានដល់ មិនញាប់ញ័រក្នុងវត្ថុជាទីតាំងនៃសេចក្តីក្រោធ ។ បទថា **មទនីយេ ន មជ្ជតិ** បានដល់ មិនលិចចុះក្នុងវត្ថុជាទីតាំងនៃសេចក្តីស្រវឹង ។ បទថា **កិលេសនីយេ ន កិលិស្សតិ** បានដល់ មិនចូលទៅក្តៅក្រហាយក្នុងវត្ថុ ដែលជាទីតាំងនៃការចូលទៅក្តៅក្រហាយ ។ បទថា **ទិដ្ឋេ ទិដ្ឋមត្តោ** បានដល់ ត្រឹមតែឃើញក្នុងរូបារម្មណ៍ គឺក្នុងរូបដែលឃើញហើយដោយចក្ខុវិញ្ញាណ ។ បទថា **សុតេ សុតមត្តោ** បានដល់ ត្រឹមតែបានឮក្នុងសទ្ទាយតនៈ ដោយសោតវិញ្ញាណ ។ បទថា **មុតេ មុតមត្តោ** បានដល់ ត្រឹមតែទទួលយកក្នុងវត្ថុដែលដល់ហើយ ទទួលយកដោយឃានវិញ្ញាណ ជិវ្ហាវិញ្ញាណនិងកាយ-វិញ្ញាណ ។ បទថា **វិញ្ញាតេ វិញ្ញាតមត្តោ** ប្រែថា ត្រឹមតែដឹងច្បាស់ក្នុងធម្មារម្មណ៍ដែលដឹងច្បាស់ បានដល់ ត្រឹមតែដឹងក្នុងធម្មារម្មណ៍ដែលដឹងដោយមនោវិញ្ញាណ ។ បទថា **ទិដ្ឋេ ន លិម្បតិ** បានដល់ មិនជាប់ក្នុងរូបារម្មណ៍ដែលឃើញហើយ ដោយចក្ខុវិញ្ញាណ ដោយការជាប់ដោយតណ្ហានិងទិដ្ឋិ ។ បទថា **ទិដ្ឋេ អនូបយោ** បានដល់ មិនមានតណ្ហាក្នុងរូបារម្មណ៍នោះឯង ។ បទថា **អនបាយោ** បានដល់ មិនមានចិត្តប្រទូស្ត ។ បទថា **សំវិជ្ជតិ** បាន

ដល់ ចូលទៅបាន ។ បទថា **បស្សតិ** បានដល់ សម្លឹងមើល ។ បទថា **ឆន្ទរាគោ** បានដល់ ការជាប់ចំពាក់ ។ បទថា **រូបារាមំ** មានវិគ្គហៈថា ឈ្មោះថា **រូបារាម** ព្រោះមានរូបជាទីពេញចិត្ត ។ បទថា **រូបរតំ** បានដល់ ពេញចិត្តក្នុងរូប ។ បទថា **រូបសម្មុទិតំ** បានដល់ ត្រេកត្រអាលក្នុងរូប ។

បទថា **ទន្តំ នយន្តិ សមិតឹ** បានដល់ ជនទាំងឡាយកាលទៅកណ្តាលមហាជនក្នុងសួនឬទីលានសម្រាប់លេងជាដើម រមែងទឹមគោឬសេះដែលបង្ហឹកល្អហើយត្រង់យាន ហើយនាំទៅ ។ បទថា **រាជា** សេចក្តីថា សូម្បីព្រះរាជាកាលយាងទៅកាន់ទីបែបនោះ ក៏ទ្រង់ឡើងពាហនៈដែលបង្ហឹកល្អហើយនោះឯង ។ បទថា **មនុស្សេសុ** សេចក្តីថា បុគ្គលដែលទូន្មានខ្លួនហើយ ដោយអរិយមគ្គ ៤ ជាអ្នកអស់នូវព្យសន៍ ជាបុគ្គលប្រសើរបំផុតក្នុងពួកមនុស្ស ។ បទថា **យោតិវាក្យំ** សេចក្តីថា បុគ្គលណាអត់ធន់មិនតបត មិនក្តៅក្រហាយចំពោះពាក្យពោលលុបលើបែបនោះ សូម្បីគេពោលរឿយៗ បុគ្គលបែបនេះទូន្មានខ្លួនល្អហើយ ឈ្មោះថា ជាបុគ្គលប្រសើរបំផុត ។ បទថា **អស្សតរា** បានដល់ សេះដែលកើតអំពីមេសេះបាលា ។ បទថា **អាជានីយា** បានដល់ សេះដែលអាចដឹងហេតុការណ៍ដែលសារថីទូន្មានឲ្យធ្វើបានរហ័ស ។ បទថា **សិន្ធវា** បានដល់ សេះដែលកើតក្នុងដែនសិន្ធវ ។ បទថា **មហានាគា** បានដល់ ដំរីធំជាតិកុញ្ជរ ។ បទថា **អត្តទន្តោ** សេចក្តីថា សេះអស្សតរក្តី សេះសិន្ធវក្តី ដំរីជាតិកុញ្ជរក្តីដែលគេទូន្មានហើយជាសត្វដ៏ប្រសើរ ដែលគេមិនទូន្មាន ក៏ជាសត្វមិនប្រសើរ អធិប្បាយថា តែបុគ្គលណាទូន្មានខ្លួនល្អហើយ ព្រោះទូន្មាន

ខ្លួនដោយធម៌ គឺមគ្គ ៤ ជាអ្នកអស់ព្យសន៍ បុគ្គលនេះជាបុគ្គលប្រសើរជាងនោះ គឺក្រៃលែងជាងសត្វទាំងអស់នោះ ។

បទថា **ន ហិ ឯតេហិ យានេហិ** សេចក្តីថា បុគ្គលណាមួយគប្បីទៅកាន់ទិស គឺព្រះនិព្វាន ដែលហៅថា **អគត** ព្រោះជាទិសដែលមិនធ្លាប់ទៅ ព្រោះមិនធ្លាប់ទៅ សូម្បីដោយការយល់សប្តិដោយយាន មានយានដំរីជាដើមឡើយ ដូចបុគ្គលទូន្មានខ្លួនហើយ មានខ្លួនទូន្មានដោយការទូន្មានឥន្ទ្រិយខាងដើម មានខ្លួន□ទូន្មានល្អហើយដោយអរិយមគ្គភាវនាខាងចុង ជាអ្នកអស់ព្យសន៍ មានបញ្ញារមែងទៅកាន់ទិសដែលមិនធ្លាប់ទៅនោះ គឺដល់នូវភូមិដែលទូន្មានខ្លួនហើយ ( ព្រះអរហន្ត ) ព្រោះហេតុនោះទើបការទូន្មានខ្លួននោះឯងប្រសើរ ។ បទថា **វិធាសុ ន វិកម្បន្តិ** បានដល់ មិនញាប់ញ័រ មិនយោងយោងក្នុងមានះជាដើមថា អាត្មាអញជាបុគ្គលប្រសើរជាងបុគ្គលប្រសើរ ។ បទថា **វិប្បមុត្តា បុនព្ភវា** ជាអ្នកផុតដោយល្អហើយ គឺរួចហើយតាំងនៅ ចាកការកើតរឿយៗ ដោយបដិសន្ធិក្នុងភពថ្មី ។ បទថា **ទន្តភូមឹ អនុប្បត្តា** បានដល់ សម្រេចដល់ភូមិ គឺអរហត្តផលដែលជាទីទូន្មានដោយចំណែកមួយ ហើយតាំងនៅ ។ បទថា **តេ លោកេ វិជិតាវិនោ** បានដល់ ព្រះអរហន្តទាំងនោះ ឈ្មោះថា ជាអ្នកឈ្នះហើយ ព្រោះមានជ័យជម្នះយ៉ាងវិសេសក្នុងសត្វលោក ។

ព្រោះបុគ្គលមាននូវឥន្ទ្រិយអប់រំហើយ មិនមានភ័យ មិនខុសប្រក្រតី ឈ្មោះថា ជាអ្នកទូន្មានខ្លួនហើយ ព្រោះហេតុនោះព្រះមានព្រះភាគកាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់គាថានេះថា **យស្សិន្ទ្រិយានិ** ដូច្នេះជាដើម ។

គាថានោះមានសេចក្ដីដូចតទៅនេះថា បុគ្គលណាលើកឥន្ទ្រិយ ៦ មាន ចក្ខុន្ទ្រិយជាដើមឡើងកាន់ត្រៃលក្ខណ៍ មានមិនទៀងជាដើមដោយគោចរភាវនា ហើយអប់រំឲ្យសតិនិងសម្បជញ្ញៈចូលទៅកាន់យកទុកដោយការចម្រើនភាវនា ដូចឲ្យក្លិនចូលទៅជាប់ត្រង់សំពត់ដោយការអប់ អប់រំចម្រើនឥន្ទ្រិយទាំងនោះ ដោយគោចរភាវនាក្នុងខាងក្នុងយ៉ាងណាក៏អប់រំខាងក្រៅក្នុងលោកទាំងពួងយ៉ាង នោះ ព្រោះហេតុនោះបុគ្គលជ្រាប គឺដឹងច្បាស់ចាក់ធ្លុះលោកនេះនិងលោកដទៃ គឺខន្ធលោកដែលបន្តគ្នារបស់ខ្លួននិងអ្នកដទៃយ៉ាងនេះថា ការខូចខាតឬកើតមាន ការខូចខាតនៃឥន្ទ្រិយទាំងឡាយក្នុងទីណា ចម្រើនឥន្ទ្រិយក្នុងទីនោះៗ ដោយ ការមិនសម្លឹងជាដើម ហើយបំណងនឹងស្លាប់ដូចបុគ្គលដែលទូន្មានខ្លួន ហើយ រង់ចាំកាលនៃការអស់ជីវិត មិនខ្លាចចំពោះសេចក្ដីស្លាប់ សមដូលោកពោល ទុក ( ក្នុងថេរគាថា ) ថា

ខ្ញុំមិនមានមរណៈភ័យទេ សេចក្ដីអាល័យក្នុងជីវិតក៏មិនមាន ។
អាត្មាមិនត្រេកអរនឹងសេចក្ដីស្លាប់ មិនត្រេកអរ នឹងការរស់នៅ
អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែ
អស់ថ្ងៃ ដូច្នេះ ។

បទថា **ភាវិតោ ស ទន្តោ** បានដល់ បុគ្គលនោះមានឥន្ទ្រិយអប់រំហើយ ទូន្មានខ្លួនហើយ ។

[ ៩៧ ] បទថា **និស្សយតា** បានដល់ តណ្ហានិស្ស័យនិងទិដ្ឋិនិស្ស័យ ។ បទថា **ញត្វា ធម្មំ** បានដល់ ដឹងនូវធម៌ដោយអាការទាំងឡាយ មានការមិន

ទៀតជាដើម ។ បទថា **អនិស្សិតោ** បានដល់ ដែលនិស្ស័យ ២ យ៉ាងនោះ មិនអាស្រ័យហើយយ៉ាងនេះ ។ ដោយព្រះតម្រាស់នោះ ព្រះមានព្រះភាគទ្រង់សម្តែងទុកថា ការមិនមានតណ្ហានិស្ស័យនិងទិដ្ឋិនិស្ស័យ ក្រៅអំពីការដឹងធម៌រមែងមិនមាន ។ បទថា **ភវាយ វិភវាយ វា** បានដល់ សស្សតទិដ្ឋិ ឬឧច្ឆេទទិដ្ឋិ ។ ការពន្រឹកសេចក្តីនៃគាថានេះងាយយល់ហើយ ។

[ ១០១ ] បទថា **តំ ព្រូមិ ឧបសន្តោ** បានដល់ តថាគតពោលបុគ្គលនោះ ដែលមានសភាពដូចពោលទុកហើយក្នុងគាថានីមួយៗ ថាជាអ្នកចូលទៅស្ងប់ហើយ ។ បទថា **អតរី សោ វិសត្តិកំ** បានដល់ ឆ្លងតណ្ហាធំ ដែលឈ្មោះថា **វិសត្តិកា** ព្រោះមាន ការផ្សាយទៅជាដើមនេះបានហើយ ។

[ ១០៤ ] បទថា **អត្តនោ ទិដ្ឋិយា រាគោ អភិជ្ឈា កាយគន្ថោ** បានដល់ តម្រេក ពោលគឺការត្រេកអរក្នុងទិដ្ឋិដែលខ្លួនប្រកាន់ ឈ្មោះថា អភិជ្ឈាកាយគន្ថៈ ។ បទថា **បរវាទេសុ អាឃាតោ អប្បច្ចយោ** បានដល់ សេចក្តីក្រោធនិងអាការសម្តែងនូវការមិនត្រេកអរក្នុងវាទៈ និងការលើកវាទៈរបស់អ្នកដទៃ ឈ្មោះថា ព្យាបាទកាយគន្ថៈ ។ បទថា **អត្តនោ សីលំ វា វតំ វា** បានដល់ សីលដែលបានដល់ការវៀរចាកមេថុនដែលខ្លួនប្រកាន់ ឬវត្ត មានគោវត្តជាដើម ។ បទថា **សីលព្វតំ វា** បានដល់ សីលនិងវត្តទាំង ២ នោះក្តី ។ បទថា **បរាមាសោ** បានដល់ ប្រកាន់ដោយវត្ថុដទៃជាដើមថា សេចក្តីបរិសុទ្ធរមែងមានដោយវត្ថុនេះ ។ បទថា **អត្តនោ ទិដ្ឋិ ឥទំសច្ចាភិនិវេសោ កាយគន្ថោ** បានដល់ ទិដ្ឋិដែលខ្លួនប្រកាន់ទុកដោយការប្រកាន់មិន

ជាឧបាយប្រាជ្ញាថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃជាមោឃ ឈ្មោះថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ បទថា **គន្ថា តស្ស ន វិជ្ជន្តិ** បានដល់ ទិដ្ឋិគន្ថៈទាំង ២ រមែងមិនមានដល់ព្រះខីណាស្រពនោះដោយសោតាបត្តិមគ្គ ព្យាបាទកាយគន្ថៈរមែងមិនមានដោយអនាគាមិមគ្គ អភិជ្ឈាកាយគន្ថៈរមែងមិនមានដោយអរហត្តមគ្គ ។

[ ១០៦ ] ឥឡូវនេះព្រះមានព្រះភាគ កាលទ្រង់សរសើរបុគ្គលដែលចូលទៅស្ងប់នោះ ទើបត្រាស់ពាក្យជាដើមថា **ន តស្ស បុត្តា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុត្តា** បានដល់ កូន ៤ ពួក មានកូនកើតអំពីខ្លួនជាដើម ។ ម្យ៉ាងទៀតក្នុងបទនេះគប្បីជ្រាបថា លោកពោលដល់ការកាន់យកបុត្តជាដើម ដោយឈ្មោះថាបុត្តាជាដើម ឯបុត្តទាំងនោះរមែងមិនមានដល់បុគ្គលនោះ អធិប្បាយថា ព្រោះមិនមានការប្រកាន់ទាំងនោះ ទើបបុត្តជាដើមមិនមាន ។ បទថា **អត្តា** សេចក្តីថា សស្សតទិដ្ឋិដែលប្រកាន់ថា អត្តាមានរមែងមិនមាន ។ បទថា **និរត្តា** សេចក្តីថា ឧច្ឆេទទិដ្ឋិដែលប្រកាន់ថា ដាច់សូន្យរមែងមិនមាន ។

[ ១០៨ ] បទថា **គហិតំ នត្ថិ** សេចក្តីថា វត្ថុដែលគួរប្រកាន់រមែងមិនមាន ។ បទថា **មុញ្ចិតព្វំ នត្ថិ** សេចក្តីថា វត្ថុដែលគួរដោះរមែងមិនមាន ។ បទថា **យស្ស នត្ថិ គហិតំ** បានដល់ វត្ថុដែលប្រកាន់ដោយអំណាចតណ្ហានិងទិដ្ឋិរមែងមិនមានដល់បុគ្គលណា ។ បទថា **តស្ស នត្ថិ មុញ្ចិតព្វំ** បានដល់ វត្ថុដែលត្រូវដោះ មិនមានដល់បុគ្គលនោះ ។ បទថា **គហណមុញ្ចនំ**

**សមតិក្កន្តោ** សេចក្តីថា ព្រះអរហន្ត ឈានកន្លងនូវការប្រកាន់និងការដោះហើយ ។ បទថា **វុឌ្ឍិបរិហានីតិវត្តោ** សេចក្តីថា ព្រះអរហន្តកន្លងនូវសេចក្តីចម្រើននិងសេចក្តីវិនាសហើយ ។

[ ១០៩ ] បទថា **យេន នំ វជ្ជុំ បុថុជ្ជនា អថោ សមណព្រាហ្មណា** សេចក្តីថា ពួកបុថុជ្ជនសូម្បីទេវតានិងមនុស្សទាំងអស់រួមទាំងសមណព្រាហ្មណ៍ខាងក្រៅសាសនានេះ គប្បីពោលនឹងបុគ្គលនោះថា អ្នកជាបុគ្គលតម្រេកហើយក្តី ជាអ្នកប្រទូស្តហើយក្តី ដោយទោស មានរាគៈជាដើមណា ។ បទថា **តំ តស្ស អបុរេក្ខតំ** បានដល់ ទោសមានរាគៈជាដើមនោះ ដែលបុគ្គលនោះ គឺព្រះអរហន្តមិនធ្វើឲ្យជាប្រធានហើយ ។ បទថា **តស្មា វាទេសុ នេជតិ** បានដល់ បុគ្គលនោះមិនញាប់ញ័រព្រោះហេតុនោះ គឺក្នុងពាក្យនិន្ទា ។

[ ១១២ ] បទថា **នេជតិ** នេះជាមាតិកានៃពាក្យអធិប្បាយ ។ បទថា **ន ឥញ្ជតិ** បានដល់ មិនធ្វើនូវការញាប់ញ័រ ។ បទថា **ន ចលតិ** បានដល់ មិនបង្អោនទៅ ព្រោះវាទៈនោះ ។ បទថា **ន វេធតិ** បានដល់ មិនអន្ទះអន្ទែងព្រោះមិនអាចឲ្យញាប់ញ័របាន ។ បទថា **នប្បវេធតិ** បានដល់ មិនរញ្ជួយ ។ បទថា **ន សម្បវេធតិ** បានដល់ មិនប្រែត្រឡប់ ។

[ ១១៣ ] បទថា **ន ឧស្សេសុ វទតេ** បានដល់ ធ្វើខន្ធក្នុងឋានៈដែលវិសេសទុកខាងក្នុងហើយមិនពោលមើលងាយថា អាត្មាអញជាបុគ្គលវិសេសជាងគេ ។ ក្នុងបទ ២ ក្រៅអំពីនោះ ក៏មានន័យនេះ ។ បទថា **កប្បំ នេតិ អកប្បិយោ** បានដល់ បុគ្គលនោះដែលមានលក្ខណៈយ៉ាងនេះរមែងមិនដល់

កប្បៈ ២ យ៉ាង ។ ព្រោះហេតុអ្វី ព្រោះលោកពោលទុកថាជាអ្នកមិនមានកប្បៈ គឺលះកប្បៈបានហើយ ។ ការពង្រីកសេចក្តីក្នុងគាថានេះងាយយល់ហើយ ។

[ ១១៧ ] បទថា **សកំ** បានដល់ ការប្រកាន់ថារបស់អញ ។ បទថា **អសតា ច ន សោចតិ** បានដល់ កាលវត្ថុដែលប្រកាន់ថារបស់ខ្លួនមិនមាន ដោយន័យថា មិនមានជាដើមរមែងសោកស្តាយ ។

បទថា **ធម្មេសុ ច ន គច្ឆតិ** បានដល់ មិនដល់នូវការលំអៀងដោយអំណាចឆន្ទាគតិជាដើម ក្នុងធម៌ទាំងពួង ។ បទថា **ស វេ សន្តោតិ វុច្ចតិ** បានដល់ ដែលបុគ្គលនោះមានលក្ខណៈយ៉ាងនេះ ជាបុគ្គលឧត្តមជាងហៅថាជាអ្នកស្ងប់ ។ ការពង្រីកសេចក្តីក្នុងគាថានេះមានអត្ថងាយយល់ហើយ ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្ត កាលចប់ទេសនា ទេវតាមួយសែនកោដិបានសម្រេចអរហត្ត ចំនួនព្រះសោតាបន្នជាដើមរាប់មិនបាន ។

## អដ្ឋកថា បុរាភេទនិទ្ទេសទី ១០ ចប់

# កលហវិវាទសុត្តនិទ្ទេសទី ១១

[ ១២២ ] ( ព្រះពុទ្ធនិមិត្តត្រាស់សួរថា ) ជម្លោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោកព្រមទាំងសេចក្តីកំណាញ់ មានះនិងអតិមានះ ព្រមទាំងការញុះញង់កើតអំពីណា កិលេសទាំងនោះកើតអំពីណា សូមព្រះអង្គសម្តែងសេចក្តីដែលខ្ញុំសួរនោះ ។

[ ១២៣ ] អធិប្បាយពាក្យថា ជម្លោះ វិវាទកើតអំពីណា ត្រង់ពាក្យថា ជម្លោះ សេចក្តីថាជម្លោះក្តី វិវាទក្តី ដូចគ្នាដោយអាការតែមួយ ជម្លោះណា ជម្លោះនោះឈ្មោះថា វិវាទ វិវាទណា វិវាទនោះឈ្មោះថាជម្លោះ ។ម្យ៉ាងទៀត ដោយអាការផ្សេងគ្នា វិវាទជាបុព្វភាគនៃជម្លោះលោកហៅថា វិវាទ ។ ពួកព្រះរាជាជជែកនឹងពួកព្រះរាជា ពួកខត្តិយៈជជែកនឹងពួកខត្តិយៈ ពួកព្រាហ្មណ៍ជជែកនឹងពួកព្រាហ្មណ៍ ពួកគហបតីជជែកនឹងគហបតី មាតាជជែកនឹងបុត្ត បុត្តជជែកនឹងមាតា បិតាជជែកនឹងបុត្ត បុត្តជជែកនឹងបិតា បងប្អូនប្រុសជជែកនឹងបងប្អូនប្រុស បងប្អូនស្រីជជែកនឹងបងប្អូនស្រី បងប្អូនប្រុសជជែកនឹងបងប្អូនស្រី បងប្អូនស្រីជជែកនឹងបងប្អូនប្រុស សម្លាញ់ជជែកនឹងសម្លាញ់ នេះហៅថា វិវាទ ។ ជម្លោះតើដូចម្តេច ។ ពួកគ្រហស្ថជាអ្នកខ្វល់ខ្វាយក្នុងស្វែងរកទោសតែងធ្វើជម្លោះដោយកាយវាចា ពួកបព្វជិតកាលត្រូវអាបត្តិក៏ធ្វើជម្លោះដោយកាយវាចា នេះហៅថា ជម្លោះ ។ ពាក្យថា ជម្លោះ វិវាទកើតអំពីណា គឺពុទ្ធនិម្មិតសួរមូលសួរហេតុ សួរនិទាន សួរការកើតព្រម សួរការផ្តើមកើត សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យ សួរសមុទ័យ សួរឈ្លេចឈ្លី អង្វរ អារាធនា ចោទនូវសមុទ័យនៃជម្លោះនិងវិវាទថា ជម្លោះ

វិវាទ កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ត្រាស់សួរថា ) ជម្លោះ វិវាទកើតអំពីណា ។

[ ១២៤ ] អធិប្បាយពាក្យថា សេចក្តីខ្សឹកខ្សួល សេចក្តីសោកព្រមទាំងសេចក្តីកំណាញ់ ត្រង់ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការខ្សឹកខ្សួល អាការយំ អាការខ្សឹកខ្សួល ភាពនៃការយំ ភាពនៃការខ្សឹកខ្សួល សម្តី ការពោល ការពោលផ្សេងៗ ការពោលរវើរវាយ អាការពោលរវើរវាយ ភាពនៃការពោលរវើរវាយនៃបុគ្គលដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី សេចក្តីវិនាសភោគៈប៉ះពាល់ក្តី សេចក្តីវិនាសគឺរោគប៉ះពាល់ក្តី សេចក្តីវិនាសសីលប៉ះពាល់ក្តី សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ដែលប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សោក គឺសោក អាការសោក ភាពនៃសោក ការស្ងួតខាងក្នុង ការក្រៀមក្រំខាងក្នុង ការក្តៅខាងក្នុង ការក្តួលក្តៅខាងក្នុង អាការដុតរោលចិត្ត ទោមនស្ស សរគឺសោកនៃបុគ្គលដែលត្រូវសេចក្តីវិនាសប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាស គឺរោគប៉ះពាល់ក្តី ត្រូវវិនាសសីលប៉ះពាល់ក្តី ត្រូវវិនាសទិដ្ឋិប៉ះពាល់ក្តី ដែលប្រកបដោយសេចក្តីវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់វណ្ណៈ ១ កំណាញ់ធម៌ ១ សេចក្តី

កំណាញ់ អាការនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់ ការប្រាថ្នាខុស ភាពនៃចិត្តស្វិតស្វាញ ភាពនៃចិត្តរួញ ភាពមិនយកចិត្តនៃបុគ្គលដទៃឯណា មានសភាពយ៉ាងនេះ នេះហៅថា ការកំណាញ់ ។ មួយទៀតការកំណាញ់ខន្ធ ក៏ហៅថាកំណាញ់ ការកំណាញ់ធាតុក៏ហៅថាកំណាញ់ ការកំណាញ់អាយតនៈ ក៏ហៅថាកំណាញ់ សេចក្តីប្រកាន់នេះហៅថាការកំណាញ់ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សេចក្តីខ្សឹកខ្សួល សេចក្តីសោក ព្រមទាំងសេចក្តីកំណាញ់ទាំងឡាយ ។

[ ១២៥ ] អធិប្បាយពាក្យថា មានះនិងអតិមានះ ព្រមទាំងការញុះញង់ទាំងឡាយ ត្រង់ពាក្យថា មានះ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើតដោយជាតិក្តី ដោយគោត្តក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ដោយភាពជាអ្នកមានពណ៌សម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិប្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយបដិភាណក្តី សំដៅយកវត្ថុណាមួយក្តី ។ ពាក្យថា អតិមានះ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ មើលងាយបុគ្គលដទៃ ដោយជាតិក្តី ដោយគោត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី ។ ពាក្យថា ការញុះញង់ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះជាអ្នកមានសម្តីញុះញង់ គឺឮអំពីពួកជនឯណោះហើយប្រាប់ពួកជនឯណោះដើម្បីបំបែកពួកជនឯនេះ ឬឮអំពីពួកជនឯណោះហើយប្រាប់ពួកជនឯនេះដើម្បីបំបែកពួកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាហើយផង ជាអ្នកបន្ថែមកម្លាំងដល់ពួកជនបែកបាក់គ្នាហើយផងជាអ្នកមានពួកជាទីត្រេកអរ

ត្រេកអរក្នុងពួក រីករាយក្នុងពួក ពោលវាចាដែលធ្វើឲ្យជាពួក នេះលោកហៅថា ការញុះញង់ ។ មួយទៀតជនបង្កការញុះញង់ដោយហេតុ ២ គឺដោយសេចក្ដីប្រាថ្នាឲ្យគាប់ ឬមានសេចក្ដីប្រាថ្នានឹងបំបែក ។

ជនបង្កការញុះញង់ដោយសេចក្ដីប្រាថ្នាឲ្យគាប់ តើដូចម្ដេច ។ ជនបង្កការញុះញង់ ដោយសេចក្ដីប្រាថ្នាដើម្បីឲ្យគាប់យ៉ាងនេះថា អាត្មាអញនឹងជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាអ្នកស្និទ្ធស្នាល ជាអ្នកនៅខាងក្នុង ជាអ្នកមានចិត្តល្អនៃជននេះ ។

ជនជាអ្នកមានសេចក្ដីប្រាថ្នាដើម្បីបំបែកទើបបង្កការញុះញង់ តើដូចម្ដេច ។ ជនមានសេចក្ដីប្រាថ្នាដើម្បីបំបែក ទើបបង្កការញុះញង់យ៉ាងនេះថា ធ្វើម្ដេចហ្ន៎ ជនទាំងនេះគប្បីផ្សេងៗគ្នា គប្បីប្រាសចាកគ្នាទៅជាពួក ទៅជាចំណែកពីរ ទៅជាមានអធ្យាស្រ័យពីរ ទៅជាពីរពួក គប្បីបែកគ្នា មិនគប្បីរួបរួមគ្នា គប្បីនៅជាទុក្ខ មិនសប្បាយ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) មានះនិងអតិមានះព្រមទាំងការញុះញង់ ។

[ ១២៦ ] ពាក្យថា កិលេសទាំងនោះ កើតអំពីទីណា សូមព្រះអង្គទ្រង់សំដែងសេចក្ដីដែលខ្ញុំសួរនោះ គឺពុទ្ធនិមិត្តនោះសួរមូល សួរហេតុ សួរនិទាន សួរការកើត សួរហេតុជាដែនកើតមុន សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យ សួរ សួរឈ្មោចឈ្មើ អង្វរ អារាធនា ចោទនូវសមុទ័យនៃកិលេសទាំង ៨ នេះថា កិលេសទាំង ៨ នេះ គឺជម្លោះ ១ វិវាទ ១ ការខ្សឹកខ្សួល ១ សេចក្ដីសោក ១ សេចក្ដីកំណាញ់ ១ មានះ ១ អតិមានះ ១ ការញុះញង់ ១

កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ កើតអំពីអ្វី មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) កិលេសទាំងនោះកើតអំពីណា ។ ពាក្យថា សូមព្រះអង្គទ្រង់សម្តែងសេចក្តីដែលខ្ញុំសួរនោះ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) កិលេសទាំងនោះកើតអំពីណា សូមព្រះអង្គទ្រង់សម្តែងសេចក្តីដែលខ្ញុំសួរនោះ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះត្រាស់សួរថា

ជម្លោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោកព្រមទាំងសេចក្តី
កំណាញ់ មានះនិងអតិមានះ ព្រមទាំងការញុះញង់ កើតអំពី
ណា កិលេសទាំងនោះកើតអំពីណា សូមព្រះអង្គសម្តែងសេ-
ចក្តីដែលខ្ញុំសួរនោះ ។

[ ១២៧ ] ( ព្រះមានព្រះភាគត្រាស់ថា ) ជម្លោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោកព្រមទាំងសេចក្តីកំណាញ់ មានះនិងអតិមានះព្រមទាំងការញុះញង់ កើតអំពីសភាវៈជាទីស្រឡាញ់ ( មួយទៀត ) ជម្លោះ វិវាទ ( ជាដើម ) កើតក្នុងសេចក្តីកំណាញ់ កាលបើវិវាទកើតហើយជនទាំងឡាយ ( ក៏បង្ក ) នូវការញុះញង់ ។

[ ១២៨ ] អធិប្បាយពាក្យថា ជម្លោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោក ព្រមទាំងសេចក្តីកំណាញ់ កើតអំពីសភាវៈជាទីស្រឡាញ់ ត្រង់ពាក្យថា

សភាវៈជាទីស្រឡាញ់ បានដល់ សភាវៈជាទីស្រឡាញ់ ២ គឺពួកសត្វឬពួកសង្ខារ ។

ពួកសត្វជាទីស្រឡាញ់ តើដូចម្ដេច ។ ក្នុងលោកនេះជនទាំងនោះ គឺមាតាក្ដី បិតាក្ដី បងប្អូនប្រុសក្ដី បងប្អូនស្រីក្ដី កូនប្រុសក្ដី កូនស្រីក្ដី មិត្តក្ដី អាមាត្យក្ដី ញាតិក្ដី សាលោហិតក្ដី ជាអ្នកប្រាថ្នាសេចក្ដីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្ដីសប្បាយ ប្រាថ្នាសេចក្ដីក្សេមក្សាន្តចាកយោគៈ ដល់បុគ្គលនោះ នេះពួកសត្វជាទីស្រឡាញ់ ។ ពួកសង្ខារជាទីស្រឡាញ់ តើដូចម្ដេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផោដ្ឋព្វៈជាទីគាប់ចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។

ពួកជនមានសេចក្ដីរង្កៀស ក្នុងការជណ្ដើមយកវត្ថុជាទីស្រឡាញ់ ធ្វើនូវជម្លោះក៏មាន កាលបើត្រូវគេកំពុងជណ្ដើម ធ្វើនូវជម្លោះក៏មាន កាលបើវត្ថុត្រូវគេជណ្ដើមហើយ ធ្វើនូវជម្លោះក៏មាន ។ មានសេចក្ដីរង្កៀស ក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ ធ្វើនូវជម្លោះក៏មាន កាលបើវត្ថុកំពុងប្រែប្រួល ធ្វើនូវជម្លោះក៏មាន កាលបើវត្ថុប្រែប្រួលហើយ ធ្វើនូវជម្លោះក៏មាន ។ មានសេចក្ដីរង្កៀសក្នុងការជណ្ដើមយកនូវវត្ថុជាទីស្រឡាញ់ ទាស់ទែងក៏មាន កាលបើត្រូវគេកំពុងជណ្ដើម ទាស់ទែងក៏មាន កាលបើវត្ថុត្រូវគេជណ្ដើមហើយ ទាស់ទែងក៏មាន ។ សេចក្ដីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ ទាស់ទែងក៏មាន កាលបើវត្ថុកំពុងប្រែប្រួល ទាស់ទែងក៏មាន កាលបើវត្ថុប្រែប្រួលហើយ ទាស់ទែងក៏មាន ។ មានសេចក្ដីរង្កៀសក្នុងការជណ្ដើមយកវត្ថុជាទីស្រឡាញ់

ខ្សឹកខ្សួលក៏មាន កាលបើគេកំពុងដណ្តើម ខ្សឹកខ្សួលក៏មាន កាលបើវត្ថុត្រូវគេដណ្តើមហើយ ខ្សឹកខ្សួលក៏មាន ។ មានសេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ ខ្សឹកខ្សួលក៏មាន កាលបើវត្ថុកំពុងប្រែប្រួល ខ្សឹកខ្សួលក៏មាន កាលបើវត្ថុប្រែប្រួលហើយ ខ្សឹកខ្សួលក៏មាន ។ មានសេចក្តីរង្កៀសក្នុងការដណ្តើមយកនូវវត្ថុជាទីស្រឡាញ់ សោកក៏មាន កាលបើត្រូវគេកំពុងដណ្តើម សោកក៏មាន កាលបើវត្ថុត្រូវគេដណ្តើមហើយ សោកក៏មាន ។ មានសេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ សោកក៏មាន កាលបើវត្ថុកំពុងប្រែប្រួល សោកក៏មាន កាលបើវត្ថុប្រែប្រួលហើយ សោកក៏មាន ។ ពួកជនតែងតែរក្សា គ្រប់គ្រង ហួងហែង ប្រកាន់ កំណាញ់ នូវវត្ថុជាទីស្រឡាញ់ ។

[ ១២៩ ] ពាក្យថា មានះនិងអតិមានះ ព្រមទាំងការញុះញង់ សេចក្តីថា ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងមានះឲ្យកើត អាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងអតិមានះឲ្យកើត ។

ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងមានះឲ្យកើត តើដូចម្តេច ។ ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ ហើយញុំាងមានះឲ្យកើតយ៉ាងនេះថា យើងទាំងឡាយជាអ្នកបាននូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាទីពេញចិត្ត ។

ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងអតិមានះឲ្យកើត តើដូចម្តេច ។ ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ ហើយញុំាអតិមានះឲ្យកើតយ៉ាងនេះថា យើងទាំងឡាយជាអ្នកបាននូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាទីពេញចិត្ត ឯជនទាំងនេះជាអ្នកមិនបាននូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈជា

ទីពេញចិត្តទេ ។ ពាក្យថា ការញុះញង់ គឺជនពួកខ្លះក្នុងលោកនេះជាអ្នកមានសម្តីញុះញង់ គឺឮអំពីពួកជនឯណោះហើយ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ។បេ។ ជនមានសេចក្តីប្រាថ្នាដើម្បីបំបែក បង្កនូវការញុះញង់យ៉ាងនេះ ហេតុនោះ ។បេ។ មានះនិងអតិមានះ ព្រមទាំងការញុះញង់ ។

[ ១៣០ ] ពាក្យថា ជម្លោះ វិវាទ ( ជាដើម ) កើតក្នុងសេចក្តីកំណាញ់ សេចក្តីថា កិលេសទាំង ៧ នេះគឺ ជម្លោះ ១ វិវាទ ១ ការខ្សឹកខ្សួល ១ សេចក្តីសោក ១ មានះ ១ អតិមានះ ១ ការញុះញង់ ១ ប្រកប ប្រកបសព្វគ្រប់ ប្រកបទូទៅ ប្រកបទូទៅព្រម ក្នុងសេចក្តីកំណាញ់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជម្លោះ វិវាទ ( ជាដើម ) កើតក្នុងសេចក្តីកំណាញ់ ។

[ ១៣១ ] ពាក្យថា កាលបើវិវាទកើតហើយ ជនទាំងឡាយ ( ក៏បង្ក ) នូវការញុះញង់ អធិប្បាយថា កាលវិវាទកើតហើយ កើតព្រមហើយ លេចឡើងហើយ លេចឡើងចំពោះហើយ កើតប្រាកដហើយ ជនទាំងឡាយបង្កនូវការញុះញង់ គឺឮអំពីពួកជនឯណោះហើយ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះ ហើយប្រាប់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះ ជាអ្នកបំបែកពួកជន ដែលព្រមព្រៀងគ្នាផង ជាអ្នកបន្ថែមកម្លាំងដល់ពួកជន ដែលបែកគ្នាហើយផង ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រីករាយក្នុងពួក ពោលវាចាដែលធ្វើឲ្យជាពួក នេះហៅថា ការញុះញង់ ។ មួយទៀតពួកជនបង្កការញុះញង់ដោយហេតុពីរ គឺដោយសេចក្តីប្រាថ្នាឲ្យគាប់ ឬមានសេចក្តីប្រាថ្នាដើម្បីបំបែកគេ ។

ពួកជនបង្កការញុះញង់ ដោយសេចក្តីប្រាថ្នាឲ្យគាប់ តើដូចម្តេច ។ ពួកជនបង្កការញុះញង់ ដោយសេចក្តីប្រាថ្នាឲ្យគាប់យ៉ាងនេះថា យើងទាំងឡាយនឹងជាទីស្រឡាញ់ ជាទីគាប់ចិត្ត ប្រកបដោយសេចក្តីស្និទ្ធស្នាល ជាអ្នកខាងក្នុង ជាអ្នកមានចិត្តល្អនៃជននេះ ។

ពួកជនមានសេចក្តីប្រាថ្នាដើម្បីបំបែកហើយបង្កការញុះញង់ តើដូចម្តេច ។ ពួកជនមានសេចក្តីប្រាថ្នាដើម្បីបំបែក បង្កការញុះញង់យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកជននេះគប្បីផ្សេងៗគ្នា គប្បីប្រាសចាកគ្នាទៅជាពួក ទៅជាចំណែកពីរ មានអធ្យាស្រ័យពីរ មានពួកពីរ គប្បីបែកគ្នា មិនគប្បីមកជួបគ្នា គប្បីនៅជាទុក្ខ មិនសប្បាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលបើវិវាទកើតហើយ ( ជនទាំងឡាយក៏បង្ក ) នូវការញុះញង់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជម្លោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោកព្រមទាំងសេចក្តីកំណាញ់ មានះនិងអតិមានះ ព្រមទាំងការញុះញង់ កើតអំពីសភាវៈជាទីស្រឡាញ់ ( មួយទៀត ) ជម្លោះ វិវាទ ( ជាដើម ) កើតក្នុងសេចក្តីកំណាញ់ កាលបើវិវាទកើតហើយ ( ជនទាំងឡាយក៏បង្ក ) នូវការញុះញង់ ។

[ ១៣២ ] ( ព្រះពុទ្ធនិមិត្តត្រាស់សួរថា ) អើចុះ សត្វនិងសង្ខារ ជាទីស្រឡាញ់ក្នុងលោក ( របស់ពួកជន ) ដែលត្រាច់ទៅក្នុងលោកព្រោះលោភៈ មានអ្វីជានិទាន ទាំងបំណងនិងសេចក្តីសម្រេច ដែលជាទីពឹងរបស់នរជនមាន

អ្វីជានិទាន ។

[ ១៣៣ ] ពាក្យថា សត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក មានអ្វីជានិទាន គឺព្រះពុទ្ធនិមិត្តសួរនូវមូល ។បេ។ សួរ សួរឈ្វេចឈ្វី អង្វរ អារាធនា ចោទនូវសមុទ័យ នៃសត្វនិងសង្ខារជាទីស្រឡាញ់ថា សត្វនិងសង្ខារជាទីស្រឡាញ់កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) អើចុះសត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក មានអ្វីជានិទាន ។

[ ១៣៤ ] អធិប្បាយពាក្យថា ពួកជនដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ ត្រង់ពាក្យថា ពួកជន បានដល់ ពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ ពាក្យថា ព្រោះលោភៈ បានដល់ លោភៈ អាការនៃលោភៈ ភាពនៃលោភៈ សេចក្តីត្រេកអរមានកម្លាំង អាការនៃសេចក្តីត្រេកអរមានកម្លាំង ភាពនៃសេចក្តីត្រេកអរមានកម្លាំង អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ត្រាច់ទៅ គឺត្រាច់ទៅនៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ពួកជនដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ ។

[ ១៣៥ ] ពាក្យថា បំណងនិងសេចក្តីសម្រេច មានអ្វីជានិទាន គឺព្រះពុទ្ធនិមិត្តសួរនូវមូល ។បេ។ សួរ សួរឈ្វេចឈ្វី អង្វរ អារាធនា ចោទនូវ

សមុទ័យនៃបំណងនិងសេចក្ដីសម្រេចថា បំណងនិងសេចក្ដីសម្រេច កើតអំពីណា កអំពីណា កើតព្រមអំពីណា ជុះអំពីណា ជុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) បំណងនិងសេចក្ដីសម្រេចមានអ្វីជានិទាន ។

[ ១៣៦ ] ពាក្យថា ដែលជាទីពឹងរបស់នរជន បានដល់ ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងខាងមុខ ជាទីពឹង ជាទីពំនាក់ ជាទីជ្រក ជាទីរលឹករបស់នរជន គឺថានរជនមានសេចក្ដីសម្រេច ប្រព្រឹត្តទៅខាងមុខ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ដែលជាទីពឹងរបស់នរជន ។ ហេតុនោះ ព្រះពុទ្ធនិមិត្តនោះត្រាស់សួរថា

អើចុះ សត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក ( របស់ពួកជន ) ដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ មានអ្វីជានិទាន
ទាំងបំណងនិងសេចក្ដីសម្រេចដែលជាទីពឹងរបស់នរជន មានអ្វីជានិទាន ។

[ ១៣៧ ] ( ព្រះមានព្រះភាគត្រាស់ថា ) សត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក ( របស់ពួកជន ) ដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ មានឆន្ទៈជានិទាន ទាំងបំណងនិងសេចក្ដីសម្រេចដែលជាទីពឹងរបស់នរជន ក៏មានឆន្ទៈនេះជានិទានដែរ ។

[ ១៣៨ ] អធិប្បាយពាក្យថា សត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក

មានឆន្ទៈជានិទាន ត្រង់ពាក្យថា ឆន្ទៈ បានដល់ កាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ សេចក្ដីត្រេកអរក្នុងកាម ការរីករាយក្នុងកាម បំណងក្នុងកាម ការស្រឡាញ់ក្នុងកាម សេចក្ដីក្រហល់ក្រហាយព្រោះកាម ការផល់ផប់ក្នុងកាម ការជ្រុលជ្រប់ក្នុងកាម អន្ទង់ គឺកាម ការប្រកបក្នុងកាម សេចក្ដីប្រកាន់ក្នុងកាម ការរាំងព្រោះកាមច្ឆន្ទៈ ។ មួយទៀតឆន្ទៈមាន ៥ គឺបរិយេសនច្ឆន្ទៈ ១ បដិលាភច្ឆន្ទៈ ១ បរិភោគច្ឆន្ទៈ ១ សន្និធិច្ឆន្ទៈ ១ វិសជ្ជនច្ឆន្ទៈ ១ ។

បរិយេសនច្ឆន្ទៈ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះត្រូវការគ្រប់សង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយក៏ស្វែងរករូប ស្វែងរកសំឡេង ក្លិន រស ផោដ្ឋព្វៈ នេះបរិយេសនច្ឆន្ទៈ ។

បដិលាភច្ឆន្ទៈ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្រប់សង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយក៏បានរូប បានសំឡេង ក្លិន រស ផោដ្ឋព្វៈ នេះបដិលាភច្ឆន្ទៈ ។

បរិភោគច្ឆន្ទៈ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្រប់សង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយក៏ប្រើប្រាស់រូប ប្រើប្រាស់សំឡេង ក្លិន រស ផោដ្ឋព្វៈ នេះបរិភោគច្ឆន្ទៈ ។

សន្និធិច្ឆន្ទៈ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្រប់សង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយក៏ធ្វើការសន្សំទ្រព្យ ដោយគិតថាទ្រព្យនឹងមានក្នុងកាលមានសេចក្ដីអន្តរាយ នេះសន្និធិច្ឆន្ទៈ ។

វិសជ្ជនច្ឆន្ទៈ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្រប់សង្កត់

ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយក៏ចាយទ្រព្យ ឲ្យដល់ពួកអ្នកជិះដំរី ពួកអ្នកជិះសេះ ពួកអ្នកជិះរថ ពួកខ្មាន់ធ្នូ ពួកថ្មើរជើងដោយគិតថា ជនទាំងនេះនឹងរក្សា គ្រប់គ្រង បោមរោមអាត្មាអញ នេះវិសជ្ជនច្ឆន្ទៈ ។

ពាក្យថា សត្វនិងសង្ខារជាទីស្រឡាញ់ បានដល់ ពួកសត្វឬសង្ខារជាទីស្រឡាញ់ទាំងពីរ ។បេ។ នេះពួកសត្វជាទីស្រឡាញ់ ។បេ។ នេះពួកសង្ខារជាទីស្រឡាញ់ ។ ពាក្យថា សត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក មានឆន្ទៈជានិទាន គឺសត្វនិងសង្ខារជាទីស្រឡាញ់ មានឆន្ទៈជានិទាន មានឆន្ទៈជាសមុទ័យ មានឆន្ទៈជាកំណើត មានឆន្ទៈជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) សត្វនិងសង្ខារជាទីស្រឡាញ់ក្នុងលោក មានឆន្ទៈជានិទាន ។

[ ១៣៩ ] ពាក្យថា ពួកជនណា ក្នុងបទថា ពួកជនដែលត្រាច់ទៅក្នុងលោកព្រោះលោភៈ គឺពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ ពាក្យថា ព្រោះលោភៈ បានដល់ លោភៈ អាការៈនៃលោភៈ ភាពនៃលោភៈ សេចក្តីត្រេកអរមានកម្លាំង អាការៈនៃសេចក្តីត្រេកអរមានកម្លាំង ភាពនៃសេចក្តីត្រេកអរមានកម្លាំង អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ត្រាច់ទៅ គឺត្រាច់ទៅនៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកជនដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ ។

[ ១៤០ ] ពាក្យថា បំណងនិងសេចក្តីសម្រេច មានឆន្ទៈនេះជានិទានដែរ អធិប្បាយថា តណ្ហាលោកហៅថា បំណង បានដល់ សេចក្តីត្រេកអរ

សេចក្តីត្រេកអរមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថាសេចក្តីសម្រេច សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ស្វែងរករូបក៏បានរូបឈ្មោះថាអ្នកមានរូបសម្រេចហើយ ។ ស្វែងរកសំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សេចក្តីសុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម អារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បំសុកូលិកធុតង្គ តេចីវរិកធុតង្គ សបទានចារិកធុតង្គ ខលុបច្ឆាភត្តិកធុតង្គ នេសជ្ជិកធុតង្គ យថាសន្ថតិកធុតង្គ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ក៏បាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា អ្នកមាននេវសញ្ញានាសញ្ញាយតនសមាបត្តិសម្រេចហើយ ។

> បុគ្គលភ្ជួរស្រែដោយបំណង បុគ្គលសាបព្រោះពូជ ក៏ដោយ
> បំណង ពួកឈ្មួញនាំយកទ្រព្យទៅកាន់សមុទ្រក៏ដោយបំណង
> អាត្មាអញតាំងនៅដោយបំណងណា បំណងនោះក៏សម្រេចដល់
> អាត្មាអញ ។

ការសម្រេចនៃបំណង លោកហៅថា សេចក្តីសម្រេច ។ ពាក្យថា បំណងនិងសេចក្តីសម្រេចមានធន្ទៈនេះជានិទាន គឺបំណងនិងសេចក្តីសម្រេច មានធន្ទៈនេះជានិទាន មានធន្ទៈជាសមុទ័យ មានធន្ទៈជាកំណើត មានធន្ទៈជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បំណងនិងសេចក្តីសម្រេចមានធន្ទៈ

នេះជានិទាន ។

[ ១៤១ ] ពាក្យថា ដែលជាទីពឹងរបស់នរជន គឺធម៌ទាំងឡាយណា ប្រព្រឹត្តទៅខាងមុខជាទីពឹង ជាទីពំនាក់ ជាទីជ្រកកោន ជាទីរឭករបស់នរជន គឺថានរជនមានសេចក្ដីសម្រេចប្រព្រឹត្តទៅខាងមុខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលជាទីពឹងរបស់នរជន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សត្វនិងសង្ខារ ជាទីស្រឡាញ់ក្នុងលោក ( របស់ពួកជន )
ដែលត្រាច់ទៅក្នុងលោកព្រោះលោភៈ មានឆន្ទៈជានិទានទាំង
បំណងនិងសេចក្ដីសម្រេច ដែលជាទីពឹងរបស់នរជន ក៏មាន
ឆន្ទៈជានិទានដែរ ។

[ ១៤២ ] ( ព្រះពុទ្ធនិមិត្តសួរថា ) ចុះឆន្ទៈក្នុងលោក មានអ្វីជានិទាន ទាំងវិនិច្ឆ័យទាំងឡាយនិងធម៌ទាំងឡាយណា ដែលសមណៈពោលហើយ ធម៌ទាំងនោះ គឺសេចក្ដីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្ដីសង្ស័យ ១ កើតអំពីណា ។

[ ១៤៣ ] ពាក្យថា ចុះឆន្ទៈក្នុងលោក មានអ្វីជានិទាន គឺព្រះពុទ្ធនិមិត្តសួរនូវមូល ។បេ។ សួរ សួរឈ្វេចឈ្វី អង្វរ អារាធនា ចោទនូវសមុទ័យនៃឆន្ទៈថា ឆន្ទៈកើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ចុះឆន្ទៈក្នុងលោក មានអ្វីជានិទាន ។

[ ១៤៤ ] ពាក្យថា ទាំងវិនិច្ឆ័យទាំងឡាយ កើតអំពីណា គឺព្រះពុទ្ធនិមិត្តសួរនូវមូល ។បេ។ សួរ សួរឈ្វេចឈ្វី អង្វរ អារាធនា ចោទនូវសមុ-ទ័យនៃវិនិច្ឆ័យទាំងឡាយថា វិនិច្ឆ័យទាំងឡាយកើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ទាំងវិនិច្ឆ័យទាំងឡាយ កើតអំពីណា ។

[ ១៤៥ ] អធិប្បាយពាក្យថា សេចក្ដីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្ដីសង្ស័យ ១ ត្រង់ពាក្យថា សេចក្ដីក្រោធ បានដល់ ការគុំគួននៃចិត្ត សេចក្ដីចង្អៀតចង្អល់ សេចក្ដីតានតឹង សេចក្ដីថ្នាំងថ្នាក់ ការខឹង ការខឹងខ្លាំង ការខឹងក្រៃលែង ការប្រទូស្តការប្រទូស្តខ្លាំង ការប្រទូស្តក្រៃលែង ព្យា-បាទនៃចិត្ត ការប្រទូស្តក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃការក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃការព្យាបាទ ការខឹង ការខឹងតប ការកាច ការសម្រក់ទឹកភ្នែក សេចក្ដីមិនត្រេកអរនៃចិត្ត ។ មុសាវាទ លោកហៅថា ការពោលពាក្យកុហក ។ វិចិកិច្ឆា លោកហៅថា សេចក្ដីសង្ស័យ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សេចក្ដីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្ដីសង្ស័យ ១ ។

[ ១៤៦ ] អធិប្បាយពាក្យថា ធម៌ទាំងឡាយណាដែលសមណៈពោលហើយ ត្រង់ពាក្យថា ធម៌ទាំងឡាយណា គឺធម៌ទាំងឡាយណាជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតព្រមគ្នា ច្រឡំគ្នា ប្រកបព្រមគ្នា មានការកើតឡើងតែមួយ

មានការលេតតែមួយ មានវត្ថុតែមួយ មានអារម្មណ៍តែមួយជាមួយនឹងសេចក្តីក្រោធផង ការពោលពាក្យកុហកផង សេចក្តីសង្ស័យផង ទាំងនេះលោកពោលថា ធម៌ទាំងឡាយណា ។ មួយវិញទៀតពាក្យថា ធម៌ទាំងឡាយណា គឺកិលេសទាំងឡាយមានសភាវៈដទៃ តាំងនៅដោយអាការៈដទៃ ទាំងនេះលោកពោលថា ធម៌ទាំងឡាយណា ។ ពាក្យថា ដែលសមណៈពោលហើយ គឺសមណៈមានបាបរម្ងាប់ហើយ ព្រាហ្មណ៍មានបាបបន្សាត់បង់ហើយ ភិក្ខុមានកិលេសមូលទម្លាយបង់ហើយ ជាអ្នករួចស្រឡះចាកចំណង គឺអកុសលមូលទាំងពួង ពោល ពោលដោយបការៈ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកបែក ធ្វើ ឲ្យរាក់ ប្រកាសហើយ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) និងធម៌ទាំងឡាយណាដែលសមណៈពោលហើយ ។ ហេតុនោះព្រះពុទ្ធនិមិត្តសួរថា

ចុះធន្ទៈក្នុងលោក មានអ្វីជានិទាន ទាំងវិនិច្ឆ័យទាំងឡាយនិង
ធម៌ទាំងឡាយណា ដែលសមណៈពោលហើយ ធម៌ទាំងនោះ
គឺសេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ
១ កើតអំពីណា ។

[ ១៤៧ ] ( ព្រះមានព្រះភាគត្រាស់ថា ) ជនទាំងឡាយពោលនូវធម្មជាតណា ថាឆ្ងាញ់និងមិនឆ្ងាញ់ក្នុងលោក ឆន្ទៈកើតឡើងអាស្រ័យនូវធម្មជាតនោះ ជនក្នុងលោក ឃើញនូវសេចក្តីវិនាសនិងសេចក្តីចម្រើន ក្នុងរូបទាំងឡាយហើយ ក៏ធ្វើនូវវិនិច្ឆ័យ ។

[ ១៤៨ ] ពាក្យថា ជនទាំងឡាយពោលនូវធម្មជាតណាថា ធ្លាប់និង មិនធ្លាប់ក្នុងលោក ត្រង់ពាក្យថា ធ្លាប់ បានដល់ សុខវេទនាផង វត្ថុជាទីប្រាថ្នាផង ។ ពាក្យថា មិនធ្លាប់ បានដល់ ទុក្ខវេទនាផង វត្ថុមិនជាទីប្រាថ្នាផង ។ ពាក្យថា ពោលនូវធម្មជាតណាក្នុងលោក គឺពោលនូវធម្មជាតណា សម្តែងនូវធម្មជាតណា ពណ៌នានូវធម្មជាតណា បំភ្លឺនូវធម្មជាតណា ថ្លែងនូវធម្មជាតណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងឡាយ ពោលនូវធម្មជាតណាថា ធ្លាប់និងមិនធ្លាប់ក្នុងលោក ។

[ ១៤៩ ] ឆន្ទៈកើតឡើងអាស្រ័យធម្មជាតនោះ គឺឆន្ទៈកើតមាន កើតប្រាកដ កើតឡើង កើតឡើងព្រម លេចឡើង លេចឡើងចំពោះអាស្រ័យវត្ថុធ្លាប់និងមិនធ្លាប់ អាស្រ័យសុខនិងទុក្ខ អាស្រ័យសោមនស្សនិងទោមនស្ស អាស្រ័យវត្ថុជាទីប្រាថ្នានិងមិនជាទីប្រាថ្នា អាស្រ័យសេចក្តីត្រេកអរនិងសេចក្តីថ្នាំងថ្នាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឆន្ទៈកើតឡើងអាស្រ័យនូវធម្មជាតនោះ ។

[ ១៥០ ] អធិប្បាយពាក្យថា ឃើញសេចក្តីវិនាសនិងសេចក្តីចម្រើនក្នុងរូបទាំងឡាយ ត្រង់ពាក្យថា ក្នុងរូបទាំងឡាយ បានដល់ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ។

សេចក្តីចម្រើនឡើងនៃរូបទាំងឡាយតើដូចម្តេច ។ សេចក្តីចម្រើន ការកើត ការកើតព្រម ការលេចឡើង ការលេចឡើងចំពោះការកើតប្រាជកនៃរូបទាំងឡាយឯណា នេះសេចក្តីចម្រើននៃរូបទាំងឡាយ ។

សេចក្តីវិនាសនៃរូបទាំងឡាយ តើដូចម្តេច ។ ការអស់ ការសូន្យ ការបែកធ្លាយ ការធ្លុះធ្លាយ ការមិនទៀងទាត់ ការអន្តរធាននៃរូបទាំងឡាយឯណា នេះសេចក្តីវិនាសនៃរូបទាំងឡាយ ។

ពាក្យថា ឃើញសេចក្តីវិនាសនិងចម្រើនក្នុងរូបទាំងឡាយ គឺឃើញ យល់ ថ្លឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដនូវសេចក្តីចម្រើននិងសេចក្តីវិនាសក្នុងរូបទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញសេចក្តីវិនាសនិងសេចក្តីចម្រើនក្នុងរូបទាំងឡាយ ។

[ ១៥១ ] អធិប្បាយពាក្យថា ជនក្នុងលោកធ្វើនូវវិនិច្ឆ័យ ត្រង់ពាក្យថា វិនិច្ឆ័យ បានដល់ វិនិច្ឆ័យ ២ គឺតណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ ១ ។

បុគ្គលធ្វើតណ្ហាវិនិច្ឆ័យ តើដូចម្តេច ។ ភោគៈទាំងឡាយរបស់បុគ្គលខ្លះក្នុងលោកនេះ ដែលមិនទាន់កើតឡើងក៏មិនកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ដោយហេតុដូចម្តេចហ្ន៎ ភោគៈទាំងឡាយរបស់អាត្មាអញដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយក៏ដល់នូវការអស់រលីងផង ។ម្យ៉ាងទៀតបុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញប្រកបរឿយៗនូវការប្រកបក្នុងហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺសុរានិងមេរ័យ ភោគៈទាំងឡាយដែលមិនទាន់កើតឡើងក៏មិនកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង កាលបើអាត្មាអញប្រកបរឿយៗនូវការប្រកបក្នុងការដើរលេងតាម

ប្រកក្នុងវេលាយប់ ភោគៈទាំងឡាយដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង កាលបើអាត្មាអញប្រកបរឿយៗនូវការដើរទៅកាន់ទីមហោស្រព កាលបើអាត្មាអញប្រកបរឿយៗនូវការប្រកបក្នុងហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺល្បែងភ្នាល់ កាលបើអាត្មាអញ ប្រកបរឿយៗនូវការប្រកបដោយមិត្តអាក្រក់ ភោគៈទាំងឡាយដែលមិនទាន់កើតឡើងក៏មិនកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង កាលបើអាត្មាអញប្រកបរឿយៗនូវការប្រកបក្នុងការខ្ជិលច្រអូស ភោគៈទាំងឡាយដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង ។ បុគ្គលនោះធ្វើនូវការដឹងយ៉ាងនេះហើយ ក៏មិនសេពនូវប្រធាននៃសេចក្ដីវិនាស ៦ យ៉ាងនៃភោគទាំងឡាយ ។ បុគ្គលធ្វើតណ្ហាវិនិច្ឆ័យយ៉ាងនេះខ្លះ ។ មួយទៀត ជនប្រកបដោយកសិកម្មក្ដី ពាណិជ្ជកម្មក្ដី គោរក្ខកម្មក្ដី សិល្បៈធ្នូក្ដី ភាពអ្នករាជការក្ដី សិល្បៈណាមួយក្ដី ។ បុគ្គលធ្វើតណ្ហាវិនិច្ឆ័យយ៉ាងនេះខ្លះ ។

ជនធ្វើទិដ្ឋិវិនិច្ឆ័យ តើដូចម្ដេច ។ កាលចក្ខុកើតហើយ បុគ្គលដឹងថាខ្លួនអាត្មាអញកើតហើយ ។ កាលចក្ខុវិនាសហើយ បុគ្គលក៏ដឹងថាខ្លួនអាត្មាអញវិនាសហើយ ខ្លួនអាត្មាអញទៅប្រាសហើយ ។ ជនធ្វើទិដ្ឋិវិនិច្ឆ័យយ៉ាងនេះខ្លះ ។ កាលត្រចៀក ច្រមុះ អណ្ដាត កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ កើតហើយ បុគ្គលក៏ដឹងថា ខ្លួនអាត្មាអញកើតហើយ ។ កាលផោដ្ឋព្វៈវិនាស

ហើយ បុគ្គលក៏ដឹងថា ខ្លួនអាត្មាអញវិនាសហើយ ខ្លួនអាត្មាអញទៅប្រាសហើយ ។ បុគ្គលធ្វើឲ្យកើត ឲ្យកើតព្រម ឲ្យលេចឡើង ឲ្យលេចឡើងចំពោះនូវទិដ្ឋិវិនិច្ឆ័យយ៉ាងនេះខ្លះ ។

ពាក្យថា ជន គឺសត្វ នរៈ មាណព ។បេ។ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនក្នុងលោកធ្វើនូវវិនិច្ឆ័យ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ជនទាំងឡាយពោលនូវធម្មជាតណាថា ធ្លាញ់និងមិនធ្លាញ់ក្នុងលោក ឆន្ទៈកើតឡើងអាស្រ័យនូវធម្មជាតនោះ ជនក្នុងលោកឃើញនូវសេចក្តីវិនាសនិងសេចក្តីចម្រើន ក្នុងរូបទាំងឡាយហើយ ក៏ធ្វើនូវវិនិច្ឆ័យ ។

[ ១៥២ ] កាលធម្មជាតទាំងពីរ គឺធ្លាញ់និងមិនធ្លាញ់មាន ទើបធម៌ទាំងនេះ គឺសេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១ ( ក៏កើតឡើងដែរ ) ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ ជាធម៌ដែលសមណៈជ្រាបហើយពោល ។

[ ១៥៣ ] អធិប្បាយពាក្យថា សេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១ ត្រង់ពាក្យថា សេចក្តីក្រោធ បានដល់ ការចង្អៀតចង្អល់ ការថ្នាំងថ្នាក់នៃចិត្ត ។បេ។ មុសាវាទ លោកហៅថា ការពោលពាក្យកុហក ។ វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ ។ សេចក្តីក្រោធកើតអាស្រ័យវត្ថុជា

ទីប្រាថ្នាក៏មាន ។ សេចក្ដីក្រោធកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នាក៏មាន ។ មុសា-វាទកើតអាស្រ័យវត្ថុជាទីប្រាថ្នា ក៏មាន ។ មុសាវាទកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នាក៏មាន ។ សេចក្ដីសង្ស័យកើតអាស្រ័យវត្ថុជាទីប្រាថ្នាក៏មាន ។ សេចក្ដីសង្ស័យកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នាក៏មាន ។

សេចក្ដីក្រោធកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នា តើដូចម្ដេច ។ ក្រោធកើតដោយគិតថា គេបានប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ ក្រោធកើតដោយគិតថា គេកំពុងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ ក្រោធកើតដោយគិតថា គេនឹងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ ។ ក្រោធកើតដោយគិតថា គេបានប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ កំពុងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ នឹងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់បុគ្គល ដែលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អញ ។ ក្រោធកើតដោយគិតថា គេបានប្រព្រឹត្តនូវហេតុជាប្រយោជន៍ កំពុងប្រព្រឹត្តនូវហេតុជាប្រយោជន៍ នឹងប្រព្រឹត្តនូវហេតុជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ។ ក្រោធកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នាយ៉ាងនេះឯង ។

ក្រោធកើតអាស្រ័យវត្ថុជាទីប្រាថ្នា តើដូចម្ដេច ។ កាលបុគ្គលមានសេចក្ដីរង្កៀសក្នុងការជណ្ដើមនូវវត្ថុជាទីប្រាថ្នា ក្រោធកើតក៏មាន កាលត្រូវគេកំពុងជណ្ដើម ក្រោធកើតក៏មាន កាលវត្ថុដែលត្រូវគេជណ្ដើមហើយ ក្រោធកើតក៏មាន ។ កាលបុគ្គលមានសេចក្ដីរង្កៀសក្នុងការប្រែប្រួល ចាកវត្ថុជាទីប្រាថ្នា ក្រោធកើតក៏មាន កាលវត្ថុដែលកំពុងប្រែប្រួល ក្រោធកើតក៏មាន កាលវត្ថុ

ដែលប្រែប្រួលហើយក្រោធកើតក៏មាន ក្រោធកើតអាស្រ័យវត្ថុជាទីប្រាថ្នាយ៉ាងនេះឯង ។

មុសាវាទកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នាតើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះជាប់ដោយចំណង គឺខ្នោះហើយពោលមុសាទាំងដឹងខ្លួនដើម្បីរួចចាកចំណងនោះខ្លះ ។ ជាប់ដោយចំណង គឺខ្សែខ្លះ ។ ជាប់ដោយចំណង គឺច្រវាក់ខ្លះ ។ ជាប់ដោយចំណង គឺផ្តៅខ្លះ ។ ជាប់ដោយចំណង គឺវល្លិ៍ខ្លះ ។ ជាប់ដោយចំណង គឺរបងខ្លះ ។ ជាប់ដោយចំណង គឺស្រុក និគម នគរខ្លះ ។ ជាប់ដោយចំណង គឺជនបទខ្លះ ពោលមុសាទាំងដឹងខ្លួនដើម្បីរួចចាកចំណងនោះ ។ មុសាវាទកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នាយ៉ាងនេះឯង ។

មុសាវាទកើតអាស្រ័យវត្ថុជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះនិយាយកុហកទាំងដឹងខ្លួន ព្រោះហេតុនៃរូបជាទីពេញចិត្ត ។ និយាយកុហកទាំងដឹងខ្លួន ព្រោះហេតុនៃសំឡេង ក្លិន រស ផោដ្ឋព្វៈជាទីពេញចិត្ត ព្រោះហេតុនៃចីវរ ព្រោះហេតុនៃបិណ្ឌបាត ព្រោះហេតុនៃសេនាសនៈ ព្រោះហេតុនៃគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ មុសាវាទកើតអាស្រ័យវត្ថុជាទីប្រាថ្នាយ៉ាងនេះឯង ។

សេចក្តីសង្ស័យកើតអាស្រ័យវត្ថុមិនជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលគិតថាអញនឹងរួចអំពីចក្ខុរោគឬ ឬនឹងមិនរួចអំពីចក្ខុរោគទេ អញនឹងរួចអំពីសោតរោគ ឃានរោគ ជិវ្ហារោគ កាយរោគ សីសរោគ កណ្ណរោគ មុខរោគ អញនឹងរួចអំពីទន្តរោគឬ ឬនឹងមិនរួចអំពីទន្តរោគទេ ។ សេចក្តីសង្ស័យកើតអា-

ស្រ័យវត្ថុមិនជាទីប្រាថ្នាយ៉ាងនេះឯង ។

សេចក្តីសង្ស័យកើតអាស្រ័យវត្ថុជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលគិតថា អញនឹងបានរូបទាំងឡាយជាទីពេញចិត្តឬឬនឹងមិនបានរូបទាំងឡាយជាទីពេញចិត្តទេ អញនឹងបានសំឡេងទាំងឡាយ ក្លិនទាំងឡាយ រសទាំងឡាយ ផោដ្ឋព្វៈទាំងឡាយ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារជាទីពេញចិត្ត ឬហ្ន៎ ។ សេចក្តីសង្ស័យកើតអាស្រ័យវត្ថុជាទីប្រាថ្នាយ៉ាងនេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១ ។

[ ១៥៤ ] ពាក្យថា កាលបើធម៌ទាំងពីរមានធម៌ទាំងឡាយទុំះ សេចក្តីថា កាលបើវត្ថុជាទីត្រេកអរនិងមិនជាទីត្រេកអរមាន កាលបើសុខនិងទុក្ខមាន កាលបើសោមនស្សនិងទោមនស្សមាន កាលបើវត្ថុជាទីប្រាថ្នានិងមិនជាទីប្រាថ្នាមាន កាលបើតម្រេកនិងសេចក្តីបង្អៀតបង្អល់មាន មានគ្រប់គ្រាន់ បុគ្គលបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលបើធម៌ទាំងពីរមានធម៌ទាំងឡាយទុំះ ។

[ ១៥៥ ] ពាក្យថា ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ អធិប្បាយថា ញាណឈ្មោះថា គន្លងញាណ អារម្មណ៍របស់ញាណក៏ឈ្មោះថា គន្លងញាណ ពួកធម៌កើតជាមួយនឹងញាណ ក៏ឈ្មោះថា គន្លងញាណ ។ ផ្លូវដ៏ប្រសើរឈ្មោះថាគន្លងដ៏ប្រសើរ ផ្លូវដ៏ត្រកាលឈ្មោះថាគន្លងដ៏ត្រកាល ផ្លូវដ៏ខ្ពង់ខ្ពស់ឈ្មោះថា គន្លងដ៏ខ្ពង់ខ្ពស់យ៉ាងណាមិញ ញាណក៏

ឈ្មោះថាគន្ធញាណ អារម្មណ៍របស់ញាណក៏ឈ្មោះថាគន្ធញាណ ពួកធម៌កើតជាមួយនឹងញាណក៏ឈ្មោះថាគន្ធញាណយ៉ាងនោះដែរ ។ ពាក្យថា គប្បីសិក្សា បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។

អធិសីលសិក្ខាតើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះជាអ្នកមានសីលសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យចំពោះទោសទាំងឡាយបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីល ទីតម្កល់ ទីខាងដើម ការប្រព្រឹត្ត ការប្រយ័ត្ន ការសង្រួម ប្រធាន ប្រមុខនៃការជួបប្រសព្វនូវកុសលធម៌ទាំងឡាយ នេះអធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន នេះអធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុសាសនានេះជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាដែលទៅក្នុងការកើតឡើងនិងវិនាស ជាបញ្ញាដ៏ប្រសើរ អាចទម្លុះទម្លាយ ( នូវកិលេស ) ជាគ្រឿងដល់នូវការអស់ទុក្ខដោយប្រពៃ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះទុក្ខនិរោធគាមិនីបដិបទា ដឹងច្បាស់តាមពិតថា នេះអាសវៈទាំងឡាយ ។បេ។ ដឹងច្បាស់តាមពិតថា នេះអាសវនិរោធគាមិនីបដិបទា នេះអធិប្បញ្ញាសិក្ខា ។

ពាក្យថា ជនអ្នកមានសេចក្តីសង្ស័យគប្បីសិក្សាតាមគន្ធញាណ សេចក្តី

ថា បុគ្គលអ្នកសង្ស័យ មានសេចក្តីងឿងឆ្ងល់ មានស្នាមគំនូស ( ក្នុងចិត្ត ) មានផ្លូវបែកជាពីរ មានវិចិកិច្ឆា គប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីបានញាណ ដើម្បីពាល់ត្រូវញាណ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវញាណ ។ គប្បីរំពឹងសិក្សាសិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា គប្បីឃើញសិក្សា គប្បីពិចារណាសិក្សា គប្បីតាំងចិត្តសិក្សា គប្បីចុះចិត្តស៊ប់ក្នុងសទ្ធាសិក្សា គប្បីផ្គងវិរិយៈសិក្សា គប្បីតម្កល់សតិសិក្សា គប្បីតាំងចិត្តសិក្សា គប្បីដឹងច្បាស់ដោយប្រាជ្ញាសិក្សា គប្បីដឹងធម៌ដែលគួរដឹងសិក្សា គប្បីកំណត់ធម៌ដែលគួរកំណត់សិក្សា គប្បីលះបង់ធម៌ដែលគួរលះបង់សិក្សា គប្បីចម្រើនធម៌ដែលគួរចម្រើនសិក្សា គប្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា ប្រព្រឹត្តទូទៅ ប្រព្រឹត្តដោយល្អ ប្រព្រឹត្តជឿកាន់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ ។

[ ១៥៦ ] ពាក្យថា ជាធម៌ដែលសមណៈជ្រាបហើយពោល សេចក្តីថា ធម៌ទាំងឡាយដែលព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ពោល ពោលទូទៅ ប្រាប់ សម្តែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសទុកហើយ ។ ធម៌ទាំងឡាយដែលព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ពោល ពោលទូទៅ ប្រាប់ សម្តែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសទុកហើយថា សង្ខារទាំងពួងមិនទៀង ។ ថាសង្ខារទាំងពួងជាទុក្ខ ។ ថាធម៌ទាំងពួងជាអនត្តា ។ ថាសង្ខារ

ទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ជរាមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ។ ថាការរលត់សង្ខារព្រោះការរលត់អវិជ្ជា ។បេ។ ការរលត់ជរាមរណៈព្រោះការរលត់ជាតិ ។ ថានេះជាទុក្ខ ។បេ។ នេះទុក្ខនិរោធគាមិនីបដិបទា ។ ថានេះអាសវៈ ។បេ។ នេះអាសវនិរោធគាមិនីបដិបទា ។ ថានេះពួកធម៌ដែលគួរត្រាស់ដឹង ។ ថានេះពួកធម៌ដែលគួរកំណត់ដឹង ។ ថានេះពួកធម៌ដែលគួរលះ ។ ថានេះពួកធម៌ដែលគួរចម្រើន ។ ថានេះពួកធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំងឡាយដែលព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ពោល ពោលទូទៅ ប្រាប់ សម្តែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសទុកហើយថា ( តថាគតដឹងច្បាស់ ) នូវហេតុជាទីកើតឡើងផង សេចក្តីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញនូវផស្សាយតនៈទាំង ៦ ផង បញ្ចុបាទានក្ខន្ធទាំង ៥ មហាភូតរូបទាំង ៤ វត្ថុណាមួយមានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ។ ពិតណាស់ ពាក្យនុ៎ះព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ដើម្បីត្រាស់ដឹង មិនមែនសម្តែងដើម្បីមិនឲ្យត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ប្រកបដោយហេតុ មិនមែនសម្តែងឥតហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ប្រកបដោយបាដិហារ្យ ( ធម៌ជាគ្រឿងស្រោចស្រង់ ) មិនមែនសម្តែងឥតបាដិហារ្យទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតនោះ សម្តែងធម៌ដើម្បីត្រាស់ដឹង មិនសម្តែងដើម្បីមិនត្រាស់ដឹងទេ កាលតថាគតសម្តែងធម៌ប្រកប

ដោយហេតុមិនសម្តែងឥតហេតុ កាលតថាគតសម្តែងធម៌ ប្រកបដោយបាដិ-ហារ្យមិនសម្តែងឥតបាដិហារ្យ ឱវាទបុគ្គលគួរធ្វើ អនុសាសនីក៏បុគ្គលគួរធ្វើ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរតែត្រេកអរ គួរតែរីករាយ គួរតែសោម-នស្សថា ព្រះមានព្រះភាគព្រះអង្គត្រាស់ដោយប្រពៃ ព្រះធម៌ព្រះមានព្រះភាគសម្តែងដោយប្រពៃ ព្រះសង្ឃប្រតិបត្តិហើយដោយប្រពៃ ។ កាលវេយ្យាករណ៍នេះដែលព្រះអង្គសម្តែង លោកធាតុទាំងមួយម៉ឺនក៏កម្រើកញាប់ញ័រ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាធម៌ដែលសមណៈជ្រាបហើយពោល ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

កាលធម្មជាតទាំងពីរ គឺធ្លាញ់និងមិនធ្លាញ់មាន ធម៌ទាំងនេះ គឺ
សេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១
( ក៏កើតមានដែរ ) ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សា
តាមគន្លងញាណ ជាធម៌ដែលសមណៈជ្រាបហើយពោល ។

[ ១៥៧ ] ( ព្រះពុទ្ធនិមិត្តសួរថា ) សេចក្តីត្រេកអរនិងមិនត្រេកអរមានអ្វីជាហេតុ កាលបើអ្វីមិនមានទើបធម៌ទាំងនុ៎ះមិនមាន សេចក្តីណាគឺការវិនាសនិងការចម្រើន សូមព្រះអង្គសម្តែងប្រាប់ខ្ញុំ នូវសេចក្តីនុ៎ះ ថាមានវត្ថុណាជាហេតុ ។

[ ១៥៨ ] ពាក្យថា សេចក្តីត្រេកអរនិងមិនត្រេកអរមានអ្វីជាហេតុ គឺព្រះពុទ្ធនិមិត្ត សួររកឫសគល់ ។បេ។ សួររក សួរឈ្វេចឈ្វី សូមអារាធនាចោទចំពោះហេតុជាទីកើតឡើងនៃវេទនាជាទីត្រេកអរ និងមិនជាទីត្រេកអរថា

វេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរ មានអ្វីជាហេតុ កើតអំពីណា កើតព្រមអំពីណា ផ្ដួចផ្ដើមអំពីណា កើតចំពោះឡើងអំពីណា កើតប្រាកដអំពីណា មានអ្វីជាហេតុ មានអ្វីជាដែនប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សេចក្ដីត្រេកអរនិងមិនត្រេកអរមានអ្វីជាហេតុ ។

[ ១៥៩ ] ពាក្យថា កាលបើអ្វីមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន គឺកាលបើអ្វីមិនមាន មិនមានសព្វគ្រប់ដែលបុគ្គលមិនបាន ទើបវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរមិនមាន មិនមានប្រាកដ មិនកើត មិនកើតព្រម មិនផ្ដួចផ្ដើម មិនកើតចំពោះ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) កាលបើអ្វីមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន ។

[ ១៦០ ] ពាក្យថា សេចក្ដីណា គឺការវិនាសនិងការចម្រើន អធិប្បាយថា សេចក្ដីចម្រើននៃវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរ តើដូចម្ដេច ។ សេចក្ដីចម្រើន ការដុះដាល កិរិយាកើត កិរិយាកើតព្រម កិរិយាផ្ដួចផ្ដើម កិរិយាកើតចំពោះ កិរិយាកើតប្រាកដនៃវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរឯណា នេះឈ្មោះថា សេចក្ដីចម្រើននៃវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរ ។ សេចក្ដីវិនាសនៃវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរ តើដូចម្ដេច ។ ការអស់ ការសូន្យ ការបែកធ្លាយ ការខ្ទេចខ្ទី ការមិនទៀង ការបាត់បង់ទៅ នៃវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរឯណា នេះឈ្មោះថា សេចក្ដីវិនាសនៃវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរ ។ ពាក្យថា សេចក្ដីណា គឺសេចក្ដី

ដទៃណា ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សេចក្ដីណា គឺការវិនាសនិងការចម្រើន ។

[ ១៦១ ] ពាក្យថា សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំនូវសេចក្ដីនុ៎ះថា មានវត្ថុណាជាហេតុ ត្រង់ពាក្យថា នុ៎ះ គឺខ្ញុំសួររកសេចក្ដីណា ខ្ញុំសូមសេចក្ដីណា ខ្ញុំអារាធនាសេចក្ដីណា ខ្ញុំជ្រះថ្លាសេចក្ដីណា ។ ពាក្យថា សូមសម្ដែង គឺសូមពោល ប្រាប់ សម្ដែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំនូវសេចក្ដីនុ៎ះ ។ ពាក្យថា មានវត្ថុណាជាហេតុ គឺមានវត្ថុណាជាហេតុ មានវត្ថុណាជាដែនកើត មានវត្ថុណាជាកំណើត មានវត្ថុណាជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំនូវសេចក្ដីនុ៎ះ ថាមានវត្ថុណាជាហេតុ ។ ហេតុនោះពុទ្ធនិមិត្តនោះសួរថា

> សេចក្ដីត្រេកអរនិងមិនត្រេកអរមានអ្វីជាហេតុ កាលបើអ្វីមិនមានទើបធម៌ទាំងនុ៎ះមិនមាន សេចក្ដីណា គឺការវិនាសនិងការចម្រើន សូមព្រះអង្គសម្ដែងប្រាប់ខ្ញុំ នូវសេចក្ដីនុ៎ះថា មានវត្ថុណាជាហេតុ ។

[ ១៦២ ] ( ព្រះមានព្រះភាគត្រាស់ថា ) សេចក្ដីត្រេកអរនិងមិនត្រេកអរមានផស្សៈជាហេតុ កាលបើផស្សៈមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន សេចក្ដីណា គឺការវិនាសនិងការចម្រើន តថាគតសម្ដែងទូលព្រះអង្គនូវសេចក្ដីនុ៎ះថា មានវត្ថុនេះជាហេតុ ។

[ ១៦៣ ] ពាក្យថា សេចក្តីត្រេកអរនិងសេចក្តីមិនត្រេកអរ មានផស្សៈជាហេតុ អធិប្បាយថា សុខវេទនាកើតអាស្រ័យផស្សៈជាទីតាំងនៃវេទនា ។ ព្រោះរលត់ផស្សៈជាទីតាំង នៃសុខវេទនានោះឯង សុខវេទនាដែលកើតរួចហើយ ព្រោះអាស្រ័យផស្សៈជាទីតាំងនៃសុខវេទនាកើតអំពីផស្សៈនោះ ដែលសោយរួចហើយនោះ រលត់ស្ងប់រម្ងាប់ ។ ទុក្ខវេទនាកើតឡើងព្រោះអាស្រ័យផស្សៈជាទីតាំងនៃទុក្ខវេទនា ។ ព្រោះរលត់ផស្សៈជាទីតាំង នៃទុក្ខវេទនានោះឯង ទុក្ខវេទនាដែលកើតរួចហើយ ព្រោះអាស្រ័យផស្សៈជាទីតាំងនៃទុក្ខវេទនាកើតអំពីផស្សៈមុននោះដែលសោយរួចហើយនោះរលត់ស្ងប់រម្ងាប់ ។ អទុក្ខមសុខវេទនាកើតឡើង ព្រោះអាស្រ័យផស្សៈជាទីតាំងនៃអទុក្ខមសុខវេទនា ។ ព្រោះរលត់ផស្សៈជាទីតាំង នៃអទុក្ខមសុខវេទនានោះឯង អទុក្ខមសុខវេទនាដែលកើតឡើងហើយព្រោះអាស្រ័យផស្សៈជាទីតាំងនៃអទុក្ខមសុខវេទនាកើតអំពីផស្សៈនោះដែលសោយរួចហើយនោះរលត់ស្ងប់រម្ងាប់ ។ ពាក្យថា សេចក្តីត្រេកអរនិងមិនត្រេកអរមានផស្សៈជាហេតុ បានសេចក្តីថា វេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរមានផស្សៈជាហេតុ មានផស្សៈជាទីប្រជុំកើតឡើង មានផស្សៈជាកំណើត មានផស្សៈជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីត្រេកអរនិងមិនត្រេកអរមានផស្សៈជាហេតុ ។

[ ១៦៤ ] ពាក្យថា កាលបើផស្សៈមិនមាន ធម៌ទាំងឡាយនុ៎ះក៏មិនមាន គឺកាលបើផស្សៈមិនមាន មិនមានសព្វគ្រប់ ដែលបុគ្គលមិនបានវេទនាជាទីត្រេកអរនិងមិនជាទីត្រេកអរក៏មិនមាន មិនមានប្រាកដ មិនកើត មិនកើតព្រម

មិនផ្តួចផ្តើម មិនកើតចំពោះ មិនកើតប្រាកដ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលបើផស្សៈមិនមាន ធម៌ទាំងឡាយនុ៎ះក៏មិនមាន ។

[ ១៦៥ ] ពាក្យថា សេចក្តីណា គឺការវិនាសនិងការចម្រើន សេចក្តីថា កិរិយាឃើញថាចម្រើន ក៏មានផស្សៈជាហេតុ កិរិយាឃើញថាវិនាស ក៏មានផស្សៈជាហេតុ ។ ត្រង់ពាក្យថា សេចក្តីណា គឺសេចក្តីដទៃណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីណា គឺការវិនាសនិងការចម្រើន ។

[ ១៦៦ ] អធិប្បាយពាក្យថា តថាគតសម្តែងទូលព្រះអង្គនូវសេចក្តីនុ៎ះ ថាមានវត្ថុនេះជាហេតុ ត្រង់ពាក្យថា នុ៎ះ គឺព្រះអង្គសួរសេចក្តីណា សូមសេចក្តីណា អារាធនាសេចក្តីណា ជ្រះថ្លាសេចក្តីណា ។ ពាក្យថា តថាគតសម្តែង គឺ តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតសម្តែងទូលព្រះអង្គនូវសេចក្តីនុ៎ះ ។ ពាក្យថា មានវត្ថុនេះជាហេតុ គឺមានផស្សៈនេះជាហេតុ មានផស្សៈជាទីប្រជុំកើត មានផស្សៈជាកំណើត មានផស្សៈជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតសម្តែងទូលព្រះអង្គនូវសេចក្តីនុ៎ះ ថាមានវត្ថុនេះជាហេតុ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សេចក្តីត្រេកអរនិងមិនត្រេកអរ មានផស្សៈជាហេតុ កាលបើ
ផស្សៈមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន សេចក្តីណា គឺការ
វិនាសនិងការចម្រើន តថាគតសម្តែងទូលព្រះអង្គនូវសេចក្តីនុ៎ះ
ថា មានវត្ថុនេះជាហេតុ ។

[ ១៦៧ ] ( ព្រះពុទ្ធនិមិត្តសួរថា ) ផស្សៈក្នុងលោកមានអ្វីជាហេតុ ទាំងសេចក្ដីហួងហែងកើតអំពីអ្វី កាលបើអ្វីមិនមាន ទើបសេចក្ដីប្រកាន់ថារបស់អញក៏មិនមាន កាលបើអ្វីប្រាសចេញ ទើបផស្សៈមិនពាល់ត្រូវ ។

[ ១៦៨ ] ពាក្យថា ផស្សៈក្នុងលោកមានអ្វីជាហេតុ គឺព្រះពុទ្ធនិមិត្តសួររកឫសគល់នៃផស្សៈ ។បេ។ សួរ សួរឈ្វេចឈ្វី អង្វរ អារាធនា ជ្រះថ្លានូវហេតុដែលនាំឲ្យកើតផស្សៈថា ផស្សៈមានហេតុអំពីអ្វី កើតអំពីអ្វី កើតព្រមអំពីអ្វី ផ្ដួចផ្ដើមអំពីអ្វី កើតចំពោះអំពីអ្វី កើតប្រាកដអំពីអ្វី មានអ្វីជាហេតុមានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ផស្សៈក្នុងលោកមានអ្វីជាហេតុ ។

[ ១៦៩ ] ពាក្យថា ទាំងសេចក្ដីហួងហែងកើតអំពីអ្វី គឺព្រះពុទ្ធនិមិត្តសួររកឫសគល់នៃសេចក្ដីហួងហែង ។បេ។ សួរ សួរឈ្វេចឈ្វី អង្វរ អារាធនា ជ្រះថ្លានូវហេតុដែលនាំឲ្យកើតសេចក្ដីហួងហែងថា សេចក្ដីហួងហែងកើតអំពីអ្វី កើតអំពីណា កើតព្រមអំពីអ្វី ផ្ដួចផ្ដើមអំពីអ្វី កើតចំពោះអំពីអ្វី កើតប្រាកដអំពីអ្វី មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ទាំងសេចក្ដីហួងហែងកើតអំពីអ្វី ។

[ ១៧០ ] ពាក្យថា កាលបើអ្វីមិនមានទើបសេចក្ដីប្រកាន់ថា របស់អញក៏មិនមាន គឺកាលបើអ្វីមិនមាន មិនមានសព្វគ្រប់ ដែលបុគ្គលមិនបាន ទើបសេចក្ដីប្រកាន់ថារបស់អញមិនមាន ឥតមាន លែងមាន ដែលបុគ្គលមិនបាន គឺលោកលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន

ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) កាលបើអ្វី មិនមាន ទើបសេចក្តីប្រកាន់ថារបស់អញក៏មិនមាន ។

[ ១៧១ ] ពាក្យថា កាលបើអ្វីប្រាសចេញ ទើបផស្សៈមិនពាល់ត្រូវ គឺ កាលបើអ្វីប្រាសចេញ បាត់បង់ កន្លងទៅ កន្លងផុត ប្រព្រឹត្តកន្លង ទើបផស្សៈ មិនពាល់ត្រូវ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) កាលបើអ្វីប្រាសចេញ ទើប ផស្សៈមិនពាល់ត្រូវ ។ ហេតុនោះពុទ្ធនិមិត្តនោះសួរថា

ផស្សៈក្នុងលោកមានអ្វីជាហេតុ ទាំងសេចក្តីហួងហែងកើតអំពី អ្វី កាលបើអ្វីមិនមានទើបសេចក្តីប្រកាន់ថា របស់អញក៏មិន មានកាល បើអ្វីប្រាសចេញទើបផស្សៈមិនពាល់ត្រូវ ។

[ ១៧២ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ផស្សៈ ( កើត ) ព្រោះ អាស្រ័យនាមនិងរូប សេចក្តីហួងហែងមានសេចក្តីប្រាថ្នាជាហេតុ កាលបើ សេចក្តីប្រាថ្នាមិនមាន សេចក្តីប្រកាន់ថា របស់អញក៏មិនមាន កាលបើរូប ប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ ។

[ ១៧៣ ] ពាក្យថា ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូប អធិប្បាយថា ចក្ខុវិញ្ញាណកើតព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈកើត វៀរលែងចក្ខុប្រសាទនិងរូបារម្មណ៍ ក្នុងប៉ែករូប ១ ចក្ខុ សម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម ( កើត ) ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូបយ៉ាងនេះខ្លះ ។ សោតវិញ្ញាណកើត ព្រោះអាស្រ័យ ត្រចៀកនិងសំឡេង ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ ( កើត ) វៀរលែង

សោតបសាទនិងសទ្ទារម្មណ៍ក្នុងប៉ែករូប ១ សោតសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម ( កើត ) ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូបយ៉ាងនេះខ្លះ ។ ឃានវិញ្ញាណកើត ព្រោះអាស្រ័យច្រមុះនិងក្លិន ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ ( កើត ) វៀរលែងឃានបសាទនិងគន្ធារម្មណ៍ក្នុងប៉ែករូប ១ ឃានសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម ( កើត ) ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូបយ៉ាងនេះខ្លះ ។ ជិវ្ហាវិញ្ញាណកើតព្រោះអាស្រ័យអណ្តាតនិងរស ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ ( កើត ) វៀរលែងជិវ្ហាបសាទនិងរសារម្មណ៍ក្នុងប៉ែករូប ១ ជិវ្ហាសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម ( កើត ) ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូបយ៉ាងនេះខ្លះ ។ កាយវិញ្ញាណកើត ព្រោះអាស្រ័យកាយនិងផ្សព្វ ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ ( កើត ) វៀរលែងកាយបសាទនិងផោដ្ឋព្វារម្មណ៍ក្នុងប៉ែករូប ១ កាយសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម ( កើត ) ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូបយ៉ាងនេះខ្លះ ។ មនោវិញ្ញាកើតព្រោះអាស្រ័យមនោនិងធម្មារម្មណ៍ ការប្រជុំធម៌ទាំង ៣ ទើបផស្សៈ ( កើត ) វៀរលែងវត្ថុរូបក្នុងប៉ែករូបនិងពួកធម៌មានរូបក្នុងប៉ែករូប ១ មនោសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម ( កើត ) ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូបយ៉ាងនេះខ្លះ ។

[ ១៧៤ ] ពាក្យថា សេចក្តីហួងហែងមានសេចក្តីប្រាថ្នាជាហេតុ អធិប្បាយថា តណ្ហាលោកហៅថាសេចក្តីប្រាថ្នា បានដល់ រាគៈ រាគៈខ្លាំង ។បេ។ អភិជ្ឈា

លោភៈ អកុសលមូល ។ ពាក្យថា សេចក្តីហួងហែង បានដល់ សេចក្តីហួងហែង ២ គឺសេចក្តីហួងហែងគឺតណ្ហា ១ សេចក្តីហួងហែងគឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីហួងហែងគឺតណ្ហា ។បេ។ នេះសេចក្តីហួងហែងគឺទិដ្ឋិ ។ ពាក្យថា សេចក្តីហួងហែង មានសេចក្តីប្រាថ្នាជាហេតុ បានសេចក្តីថា សេចក្តីហួងហែង មានសេចក្តីប្រាថ្នាជានិទាន មានសេចក្តីប្រាថ្នាជាហេតុ មានសេចក្តីប្រាថ្នាជាបច្ច័យ មានសេចក្តីប្រាថ្នជាអំពើ មានសេចក្តីប្រាថ្នាជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីហួងហែង មានសេចក្តីប្រាថ្នាជាហេតុ ។

[ ១៧៥ ] ពាក្យថា កាលបើសេចក្តីប្រាថ្នាមិនមាន សេចក្តីប្រកាន់ថារបស់អញក៏មិនមាន អធិប្បាយថា តណ្ហាលោកហៅថាសេចក្តីប្រាថ្នា បានដល់ រាគៈ រាគៈខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា សេចក្តីប្រកាន់ថារបស់អញ បានដល់ សេចក្តីប្រកាន់ ២ គឺសេចក្តីប្រកាន់គឺតណ្ហា ១ សេចក្តីប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីប្រកាន់គឺតណ្ហា ។បេ។ នេះសេចក្តីប្រកាន់គឺទិដ្ឋិ ។ ពាក្យថា កាលបើសេចក្តីប្រាថ្នាមិនមាន សេចក្តីប្រកាន់ថារបស់អញក៏មិនមាន សេចក្តីថា កាលបើសេចក្តីប្រាថ្នាមិនមាន មិនមានសព្វគ្រប់ បុគ្គលមិនបាន សេចក្តីប្រកាន់ថារបស់អញក៏មិនមាន ឥតមាន លែងមានបុគ្គលមិនបាន គឺលោកបានលះបង់ ផ្តាច់ផ្តិល ធ្វើឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលបើសេចក្តីប្រាថ្នាមិនមាន សេចក្តីប្រកាន់ថារបស់អញក៏មិនមាន ។

[ ១៧៦ ] អធិប្បាយពាក្យថា កាលបើរូបប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ ត្រង់ពាក្យថា រូប គឺមហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូបទាំង ៤ ។ ត្រង់ពាក្យថា កាលបើរូបប្រាសចេញ គឺរូបប្រាសចេញដោយហេតុ ៤ គឺដោយការប្រាសចេញព្រោះការដឹង ១ ដោយការប្រាសចេញព្រោះការពិចារណា ១ ដោយការប្រាសចេញព្រោះការលះ ១ ដោយការប្រាសចេញព្រោះការប្រព្រឹត្តកន្លង ១ ។

រូបប្រាសចេញដោយការប្រាសចេញព្រោះការដឹងតើដូចម្តេច ។ បុគ្គលស្គាល់រូប គឺស្គាល់ ឃើញថារូបឯណានីមួយ រូបទាំងអស់នោះជាមហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូបទាំង ៤ ដូច្នេះ រូបប្រាសចេញដោយការប្រាសចេញព្រោះការដឹងយ៉ាងនេះឯង ។

រូបប្រាសចេញដោយការប្រាសចេញ ព្រោះការពិចារណា តើដូចម្តេច ។ បុគ្គលធ្វើការដឹងយ៉ាងនេះ ហើយពិចារណានូវរូប គឺពិចារណាដោយសេចក្តីជាមិនទៀង ជាជាទុក្ខ ជារោគ ជាបូស ជាសរ ជាសេចក្តីលំបាក ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់បែកធ្លាយ ជារបស់មិនទៀង ទីពឹងមិនបាន ផ្អែកមិនបាន ទីអាងមិនបាន ជារបស់ស្អួចស្អើង ជារបស់ទទេ ជារបស់សោះសូន្យ មិនមែនជារបស់ខ្លួន ជាទោស ជាសភាវៈប្រែប្រួល មិនមានខ្លឹម ជាឫសនៃសេចក្តីលំបាក ជាអ្នកសម្លាប់ ជារបស់វិនាស ប្រកបដោយអាសវៈ ជារបស់ដែលបច្ច័យតាក់តែង ជានុយនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មាន

ព្យាធិជាធម្មតា មានសេចក្ដីស្លាប់ជាធម្មតា មានសេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីចង្អៀតចង្អល់ជាធម្មតា ប្រកបដោយសេចក្ដីសៅហ្មងជាធម្មតា ជារបស់ប្រជុំកើតឡើង ជារបស់វិនាសទៅ ជាអានិសង្ស ជាទោស ជាគ្រឿងរលាស់ចោល រូបប្រាសចេញដោយការប្រាសចេញ ព្រោះការពិចារណាយ៉ាងនេះឯង ។

រូបប្រាសចេញដោយការប្រាសចេញព្រោះការលះ តើដូចម្ដេច ។ បុគ្គលត្រិះរិះយ៉ាងនេះហើយលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវឆន្ទរាគក្នុងរូប ។ សមដូចពាក្យទុំ៎ះដែលព្រះមានព្រះភាគសម្ដែងហើយថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគឯណាក្នុងរូប អ្នកទាំងឡាយចូរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើបានយ៉ាងនេះ រូបនោះនឹងជារបស់ដែលអ្នកលះបង់ហើយ ឲ្យមានឫសគល់រលើងហើយ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនកើតទៀត មិនឲ្យមានការកើតតទៅ ។ រូបប្រាសចេញដោយការប្រាសចេញព្រោះការលះយ៉ាងនេះឯង ។

រូបប្រាសចេញដោយការប្រាសចេញព្រោះការប្រព្រឹត្តកន្លង តើដូចម្ដេច ។ រូបទាំងឡាយរបស់បុគ្គលអ្នកបានអរូបសមាបត្តិទាំង ៤ ជារូបប្រាសចេញ បាត់បង់ កន្លង ឈានកន្លង ប្រព្រឹត្តកន្លងហើយ រូបប្រាសចេញដោយការប្រាសចេញព្រោះការប្រព្រឹត្តកន្លងយ៉ាងនេះឯង ។ នេះរូបប្រាសចេញដោយហេតុទាំង ៤ ។

ពាក្យថា កាលបើរូបប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ បាន

សេចក្ដីថា កាលបើរូបប្រាសចេញ បាត់បង់ កន្លង ឈានកន្លង ប្រព្រឹត្តកន្លង ហើយ ផស្សៈទាំង ៥ គឺចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហា-សម្ផស្ស កាយសម្ផស្ស ក៏មិនពាល់ត្រូវ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាល បើរូបប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ ។ ហេតុនោះព្រះមានព្រះ ភាគត្រាស់ថា

ផស្សៈ ( កើត ) ព្រោះអាស្រ័យនាមនិងរូប សេចក្ដីហួងហែង
មានសេចក្ដីប្រាថ្នាជាហេតុ កាលបើសេចក្ដីប្រាថ្នាមិនមាន សេច
ក្ដីប្រកាន់ថារបស់អញ ក៏មិនមាន កាលបើរូបប្រាសចេញ
ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ ។

[ ១៧៧ ] ( ព្រះពុទ្ធនិមិត្តសួរថា ) បុគ្គលអ្នកព្រមព្រៀងដូចម្ដេច រូប ទើបបាត់បង់ទៅ ទាំងសុខនិងទុក្ខបាត់បង់ទៅដោយប្រការដូចម្ដេច សូមព្រះ អង្គពោលដំណើរនុ៎ះដល់ខ្ញុំ ឲ្យខ្ញុំយល់ច្បាស់ថា ( សុខនិងទុក្ខ ) បាត់បង់ទៅ ដោយប្រការយ៉ាងណា ព្រោះថាខ្ញុំមានចិត្តដូច្នេះ ។

[ ១៧៨ ] ពាក្យថា បុគ្គលអ្នកព្រមព្រៀងដូចម្ដេច រូបទើបបាត់បង់ទៅ គឺបុគ្គលអ្នកព្រមព្រៀងដូចម្ដេច ប្រតិបត្តិដូចម្ដេច សម្រេចដូចម្ដេច ប្រព្រឹត្ត ទៅដូចម្ដេច រក្សាដូចម្ដេច រស់នៅដូចម្ដេច ញុំាងអត្តភាពឲ្យរស់នៅដូចម្ដេច រូបទើបបាត់បង់ វិនាស កន្លង ឈានកន្លង ប្រព្រឹត្តកន្លងទៅបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអ្នកព្រមព្រៀងដូចម្ដេច រូបទើបបាត់បង់ទៅ ។

[ ១៧៩ ] ពាក្យថា ទាំងសុខនិងទុក្ខបាត់បង់ទៅ ដោយប្រការដូចម្ដេច

គឺសុខនិងទុក្ខបាត់បង់ទៅ វិនាស កន្លង ឈានកន្លង ប្រព្រឹត្តកន្លងទៅ ដោយប្រការដូចម្ដេច ។ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ទាំងសុខនិងទុក្ខបាត់បង់ទៅ ដោយប្រការដូចម្ដេច ។

[ ១៨០ ] ពាក្យថា សូមព្រះអង្គពោលដំណើរនុ៎ះដល់ខ្ញុំ ( សុខនិងទុក្ខ ) បាត់បង់ទៅដោយប្រការយ៉ាងណា ត្រង់ពាក្យថាដំណើរនុ៎ះ គឺខ្ញុំសួររកដំណើរណា សូមដំណើរណា អារាធនាដំណើរណា ចោទដំណើរណា ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ដំណើរនុ៎ះ ។ ពាក្យថា សូមព្រះអង្គពោលដល់ខ្ញុំ គឺសូមព្រះអង្គថ្លែង ប្រាប់ សម្ដែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសដល់ខ្ញុំ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សូមព្រះអង្គពោលដំណើរនុ៎ះដល់ខ្ញុំ ។ ពាក្យថា ( សុខនិងទុក្ខ ) បាត់បង់ទៅដោយប្រការយ៉ាងណា គឺ ( សុខនិងទុក្ខ ) បាត់បង់ វិនាស កន្លង ឈានកន្លង ប្រព្រឹត្តកន្លងទៅ ដោយប្រការយ៉ាងណា ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សូមព្រះអង្គពោលដំណើរនុ៎ះដល់ខ្ញុំ ( សុខនិងទុក្ខ ) បាត់បង់ទៅដោយប្រការយ៉ាងណា ។

[ ១៨១ ] ពាក្យថា ឲ្យខ្ញុំយល់ច្បាស់ ព្រោះថាខ្ញុំមានចិត្តដូច្នេះ ត្រង់ពាក្យថា ឲ្យខ្ញុំយល់ច្បាស់ គឺឲ្យខ្ញុំដឹង ដឹងជាក់ ដឹងច្បាស់ ដឹងប្រាកដ ចាក់ធ្លុះចំពោះ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ឲ្យខ្ញុំយល់ច្បាស់ ។ ពាក្យថា ខ្ញុំមានចិត្តដូច្នេះ គឺចិត្តរបស់ខ្ញុំបានមានហើយដូច្នេះ តម្រិះរបស់ខ្ញុំបានមានហើយដូច្នេះ វិញ្ញាណរបស់ខ្ញុំបានមានហើយដូច្នេះ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ឲ្យខ្ញុំយល់ច្បាស់ព្រោះថាខ្ញុំមានចិត្តដូច្នេះ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះពោល

ថា

បុគ្គលអ្នកព្រមព្រៀងដូចម្ដេច រូបទើបបាត់បង់ទៅ ទាំងសុខនិងទុក្ខបាត់បង់ទៅដោយប្រការដូចម្ដេច សូមព្រះអង្គពោលដំណើរនុ៎ះដល់ខ្ញុំ ឲ្យខ្ញុំយល់ច្បាស់ថា ( សុខនិងទុក្ខ ) បាត់បង់ទៅដោយប្រការយ៉ាងណា ព្រោះថាខ្ញុំមានចិត្តដូច្នេះ ។

[ ១៨២ ] ( ព្រះមានព្រះភាគត្រាស់ថា ) មិនមែនបុគ្គលមានសញ្ញាដោយសញ្ញា ( ប្រក្រតី ) ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញាវិបល្លាសទេ មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមានសញ្ញាវិនាសទេ បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាសព្រោះថាបបញ្ចសង្ខា ( ធម៌ជាគ្រឿងញុំាងសត្វឲ្យយឺតយូរ ) មានសញ្ញាជាហេតុ ។

[ ១៨៣ ] ពាក្យថា មិនមែនបុគ្គល មានសញ្ញាដោយសញ្ញា ( ប្រក្រតី ) ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញាវិបល្លាសទេ សេចក្ដីថា ពួកជនណាឋិតនៅដោយសញ្ញាប្រក្រតី ពួកជននោះលោកហៅថា អ្នកមានសញ្ញាដោយសញ្ញាប្រក្រតី ឯបុគ្គលនោះ មិនមែនឋិតនៅដោយសញ្ញាប្រក្រតីទេ ។ ពួកមនុស្សឆ្កួតនិងពួកជនណាមានចិត្តរវើរវាយ ពួកជននោះលោកហៅថា អ្នកមានសញ្ញាដោយសញ្ញាវិបល្លាស ឯបុគ្គលនោះមិនមែនឆ្កួត ទាំងមិនមែនមានចិត្តរវើរវាយទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមែនបុគ្គលមានសញ្ញាដោយសញ្ញា ( ប្រក្រតី ) ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញាវិបល្លាសទេ ។

[ ១៨៤ ] ពាក្យថា មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមាន

សញ្ញាវិនាសទេ សេចក្តីថា ពួកបុគ្គលអ្នកចូលនិរោធនិងពួកអសញ្ញសត្វឯណា ពួកបុគ្គលនោះលោកហៅថា អ្នកមិនមានសញ្ញា ឯបុគ្គលនោះមិនមែនអ្នកចូលនិរោធទាំងមិនមែនអសញ្ញសត្វទេ ។ ពួកជនណាជាអ្នកបានអរូបសមាបត្តិ ៤ ពួកជននោះលោកហៅថា អ្នកមានសញ្ញាវិនាស ឯបុគ្គលនោះមិនមែនអ្នកបានអរូបសមាបត្តិ ៤ ទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមានសញ្ញាវិនាសទេ ។

[ ១៨៥ ] ពាក្យថា បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាស អធិប្បាយថា ភិក្ខុក្នុងសាសនានេះ ព្រោះការលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន កាលបើចិត្តតម្កល់ស៊ប់ បរិសុទ្ធិ ផូរផង់ មិនមានកិលេស មានឧបក្កិលេសទៅប្រាសហើយ ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងនួន មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះជាអ្នកព្រមព្រៀង ក្នុងផ្លូវនៃអរូបសមាបត្តិ រមែងបង្អោនចិត្តទៅ ដើម្បីការបានអាកាសានញ្ចាយតនសមាបត្តិ បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ ប្រតិបត្តិយ៉ាងនេះ សម្រេចយ៉ាងនេះ ប្រព្រឹត្តយ៉ាងនេះ រក្សាយ៉ាងនេះ រស់នៅយ៉ាងនេះ ញុំាងអត្តភាពឲ្យរស់នៅយ៉ាងនេះ ដោយប្រការដូច្នេះ រូបរមែងវិនាសបាត់បង់ ឈានកន្លង ប្រព្រឹត្តកន្លងទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាស ។

[ ១៨៦ ] ពាក្យថា ព្រោះបបញ្ចសង្ខាមានសញ្ញាជាហេតុ សេចក្តីថា ធម៌ជាគ្រឿងញុំាងសត្វឲ្យយឺតយូរហ្នឹងឯងឈ្មោះថាបបញ្ចសង្ខា បានដល់ បបញ្ចសង្ខាគឺតណ្ហា បបញ្ចសង្ខាគឺទិដ្ឋិ បបញ្ចសង្ខាគឺមានះ មានសញ្ញាជាហេតុ មាន

សញ្ញាជាហេតុនាំឲ្យកើត មានសញ្ញាជាកំណើត មានសញ្ញាជាដែនកើតមុន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បបញ្ចសង្ខា មានសញ្ញាជាហេតុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មិនមែនបុគ្គលមានសញ្ញាដោយសញ្ញា ( ប្រក្រតី ) ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញាវិបល្លាសទេ មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមានសញ្ញាវិនាសទេ បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាស ព្រោះថាបបញ្ចសង្ខា មានសញ្ញាជាហេតុ ។

[ ១៨៧ ] ( ព្រះពុទ្ធនិមិត្តសួរថា ) យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ យើងខ្ញុំសូមសួរសេចក្តីដទៃ ចំពោះព្រះអង្គទៀត សូមព្រះអង្គប្រាប់សេចក្តីនោះ សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធរបស់យក្ខថា ប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះឬ ឬក៏ពោលសេចក្តីបរិសុទ្ធដទៃអំពីហេតុនេះ ។

[ ១៨៨ ] ពាក្យថា យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ គឺយើងខ្ញុំបានសួរ បានអង្វរ បានអារាធនា បានជ្រះថ្លានូវហេតុណា ។ ពាក្យថា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ គឺព្រះអង្គបានសម្តែងសម្តែងទូទៅ ប្រាប់ ទេសនា បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសទុកហើយ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ ។

[ ១៨៩ ] ពាក្យថា យើងខ្ញុំសូមសួរសេចក្ដីដទៃចំពោះព្រះអង្គទៀត សូមព្រះអង្គប្រាប់សេចក្ដីនោះ គឺយើងខ្ញុំសួរហេតុឯទៀតចំពោះព្រះអង្គ សូមហេតុឯទៀតចំពោះព្រះអង្គ អារាធនាហេតុឯទៀតចំពោះព្រះអង្គ ជ្រះថ្លាហេតុឯទៀតចំពោះព្រះអង្គ គឺសួរព្រះអង្គនូវសេចក្ដីដទៃតទៅទៀត ។ ពាក្យថា សូមព្រះអង្គប្រាប់សេចក្ដីនោះ គឺសូមព្រះអង្គពោល ប្រាប់ សម្ដែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) យើងខ្ញុំសូមសួរសេចក្ដីដទៃចំពោះព្រះអង្គទៀត សូមព្រះអង្គប្រាប់សេចក្ដីនោះ ។

[ ១៩០ ] ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ ជាបណ្ឌិតពោលនូវសេចក្ដីបរិសុទ្ធរបស់យក្ខថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណោះ ឬ សេចក្ដីថា សមណព្រាហ្មណ៍ពួកខ្លះពោល សម្ដែង និយាយ បំភ្លឺ បញ្ចេញនូវសេចក្ដីបរិសុទ្ធថាប្រសើរ ប្រសើរដោយវិសេស ប្រសើរបំផុត ជាប្រធាន ជាឧត្តម ថ្លៃថ្លា ដោយហេតុមានប្រមាណប៉ុណ្ណោះ គឺដោយអរូបសមាបត្តិ ។ ពាក្យថា របស់យក្ខ គឺរបស់សត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា នូវសេចក្ដីបរិសុទ្ធ គឺនូវសេចក្ដីស្អាត សេចក្ដីផូរផង់ដោយវិសេស សេចក្ដីម៉ត់ចត់ដោយជុំវិញ កិរិយារួច ការរួចដោយវិសេស ការរួចស្រឡះ ។ ពាក្យថា ជាបណ្ឌិតក្នុងលោកនេះ គឺពួកជនក្នុងលោកនេះ អ្នកមានវាទៈ ជាបណ្ឌិត មានវាទៈប្រកបដោយប្រាជ្ញា មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈសមតាមការណ៍

មានវាទៈសមតាមឋានៈ សមតាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធរបស់យក្ខថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះឬ ។

[ ១៩១ ] ពាក្យថា ឬក៏ពោលសេចក្តីបរិសុទ្ធដទៃ អំពីហេតុនេះ សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះកន្លង ឈានកន្លង ប្រព្រឹត្តកន្លង នូវអរូបសមាបត្តិទាំងនុ៎ះហើយពោល សម្តែង និយាយ បំភ្លឺ បញ្ចេញ នូវសេចក្តីស្អាត សេចក្តីផូរផង់ដោយវិសេស សេចក្តីម៉ត់ចត់ដោយជុំវិញ កិរិយារួច ការរួចដោយវិសេស ការរួចស្រឡះដទៃរបស់យក្ខ ជាគុណជាតិក្រៃលែងជាងហេតុនេះ គឺជាងអរូប-សមាបត្តិ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ឬក៏ពោលសេចក្តីបរិសុទ្ធដទៃអំពីហេតុនេះ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះពោលថា

យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ
យើងខ្ញុំសូមសួរសេចក្តីដទៃ ចំពោះព្រះអង្គទៀត សូមព្រះអង្គ
ប្រាប់សេចក្តីនោះ សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ ជា
បណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធរបស់យក្ខថាប្រសើរ ដោយ
ហេតុមានប្រមាណប៉ុណ្ណេះឬ ឬក៏ពោលសេចក្តីបរិសុទ្ធដទៃអំពី
ហេតុនេះ ។

[ ១៩២ ] ( ព្រះមានព្រះភាគត្រាស់ថា ) សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធ របស់យក្ខថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណព្រា-

ហ្មណ៍មួយពួកទៀត ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ តែងពោលនូវសម័យក្នុង អនុបាទិសេសៈ ។

[ ១៩៣ ] ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធ របស់យក្ខថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះ សេចក្តីថា មានសមណព្រាហ្មណ៍ពួកខ្លះ ជាសស្សតវាទ ពោល សម្តែង និយាយ បំភ្លឺ បញ្ចេញ ( នូវសេចក្តីបរិសុទ្ធ ) ថាប្រសើរ ប្រសើរដោយវិសេស ប្រសើរបំផុត ជាប្រធាន ថាឧត្តម ថ្លៃថ្លា ដោយហេតុមានប្រមាណប៉ុណ្ណេះ គឺដោយអរូបសមាបត្តិ ។ ពាក្យថា របស់យក្ខ គឺរបស់សត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា នូវសេចក្តីបរិសុទ្ធ គឺនូវសេចក្តីស្អាត សេចក្តីផូរផង់ដោយវិសេស សេចក្តីម៉ត់ចត់ដោយជុំវិញ ការរួច ការរួចដោយវិសេស ការរួចស្រឡះ ។ ពាក្យថា ជាបណ្ឌិតក្នុងលោកនេះ គឺជាអ្នកមានវាទៈជាបណ្ឌិត មានវាទៈប្រកបដោយប្រាជ្ញា មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយការណ៍ មានវាទៈសមតាមឋានៈ សមតាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធរបស់យក្ខ ថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

[ ១៩៤ ] ពាក្យថា បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណព្រា-ហ្មណ៍មួយពួកទៀត ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ ពោលនូវសម័យក្នុង

អនុបាទិសេសៈ សេចក្តីថា បណ្តាសមណព្រាហ្មណ៍ទាំងនោះឯង សមណ-ព្រាហ្មណ៍ពួកខ្លះជាឧច្ឆេទវាទ ជាអ្នកតក់ស្លុតអំពីកព ហើយត្រេកអរនូវការប្រាសចាកកព សមណព្រាហ្មណ៍ទាំងនោះ ពោលនូវសេចក្តីស្ងប់ ការស្ងប់វិសេស ការស្ងប់រម្ងាប់ ការរលត់ ការស្ងប់ឈឹងរបស់សត្វថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន កាលដែលអត្តា ( ខ្លួនឬចិត្ត ) នេះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងសូន្យ វិនាស មិនកើតទៀត ។ អត្តានោះជាសភាវៈ មិនមានឧបាទិសល់នៅ ដោយហេតុត្រឹមប៉ុណ្ណេះ ។ ពាក្យថា ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ គឺជាអ្នកមានវាទៈដ៏ឈ្លាស មានវាទៈជាបណ្ឌិត មានវាទៈប្រកបដោយប្រាជ្ញា មានវាទៈ ប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយការណ៍ មានវាទៈសមតាមឋានៈ សមតាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍មួយពួកទៀត ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ តែងពោលនូវសម័យ ក្នុងអនុបាទិសេសៈ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សមណព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ ជាបណ្ឌិត ពោលនូវ
សេចក្តីបរិសុទ្ធរបស់យក្ខថាប្រសើរ ដោយហេតុមានប្រមាណ
ប៉ុណ្ណេះ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍
មួយពួកទៀតជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ ពោលនូវសម័យ
ក្នុងអនុបាទិសេសៈ ។

[ ១៩៥ ] មុនិជាអ្នកមានប្រាជ្ញា ជាធីរៈនោះ ដឹងនូវពួកជនទាំងនុ៎ះថាជា

អ្នកអាស្រ័យ ( នូវទិដ្ឋិ ) ផង ដឹងនូវនិស្ស័យទាំងឡាយផង លុះដឹងហើយ ទើបជាអ្នករួចស្រឡះរមែងមិនដល់នូវវិវាទ មិនអន្ទោលទៅក្នុងកពតូចកពធំ ។

[ ១៩៦ ] ពាក្យថា ដឹងនូវពួកជនទាំងនុ៎ះថាជាអ្នកអាស្រ័យ ( នូវទិដ្ឋិ ) ផង ត្រង់ពាក្យថា ពួកជនទាំងនោះ គឺបុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា ជាអ្នកអាស្រ័យ គឺដឹងថាជាអ្នកអាស្រ័យសស្សតទិដ្ឋិ ដឹងថាជាអ្នកអាស្រ័យឧច្ឆេទទិដ្ឋិ ដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថាជាអ្នកអាស្រ័យសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងនូវពួកជនទាំងនុ៎ះថាជាអ្នកអាស្រ័យ ( នូវទិដ្ឋិ ) ផង ។

[ ១៩៧ ] ពាក្យថា មុនិជាអ្នកមានប្រាជ្ញានោះ ដឹងនូវនិស្ស័យទាំងឡាយ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណលោកហៅថាមោនៈ ។បេ។ មុនិនោះកន្លងនូវបណ្តាញជាគ្រឿងជាប់ចំពាក់ ។ មុនិដឹងថា បុគ្គលនេះអាស្រ័យសស្សតទិដ្ឋិ ដឹងថាបុគ្គលនេះអាស្រ័យឧច្ឆេទទិដ្ឋិ ដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថាបុគ្គលនេះអាស្រ័យសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ។ ពាក្យថា មុនិជាអ្នកមានប្រាជ្ញានោះ គឺជាបណ្ឌិតអ្នកមានប្រាជ្ញា អ្នកមានសេចក្តីត្រាស់ដឹង អ្នកមានញាណ អ្នកមានសេចក្តីឈ្វេងយល់ អ្នកមានប្រាជ្ញា ជាគ្រឿងកម្ចាត់កិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិជាអ្នកមានប្រាជ្ញានោះដឹងនូវនិស្ស័យទាំងឡាយ ។

[ ១៩៨ ] ពាក្យថា លុះដឹងហើយទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ គឺលុះដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដហើយ

ទើបជាអ្នករួច រួចស្រឡះ រួចផុត រួចស្រឡះដោយប្រពៃ ដោយអចន្តអនុបា-ទាវិមោក្ខ គឺថាលុះដឹង ស្គាល់ ថ្លឹង ពិចារណា ឃើញយល់ ធ្វើឲ្យប្រាកដថាសង្ខារទាំងពួងមិនទៀង ហើយជាអ្នករួច រួចស្រឡះ រួចផុត រួចដោយប្រពៃដោយអចន្តអនុបាទាវិមោក្ខ លុះដឹង ស្គាល់ ថ្លឹង ពិចារណា ឃើញយល់ ធ្វើឲ្យប្រាកដថាសង្ខារទាំងពួងជាទុក្ខ ថាធម៌ទាំងពួងជាអនត្តា ។បេ។ ថាវត្ថុណាមួយ មានកិរិយាកើតជាធម្មតា វត្ថុទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ហើយជាអ្នករួច រួចស្រឡះ រួចផុត រួចស្រឡះដោយប្រពៃដោយអចន្តអនុបាទាវិមោក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លុះដឹងហើយទើបជាអ្នករួចស្រឡះ ។ ពាក្យថា រមែងមិនដល់នូវវិវាទ គឺរមែងមិនធ្វើនូវកិរិយាឈ្លោះប្រកែក មិនធ្វើនូវជម្លោះ មិនធ្វើនូវសេចក្តីប្រកួតប្រកាន់ មិនធ្វើនូវវិវាទ មិនធ្វើនូវការទាស់ទែង ។ សមដូចពាក្យនុ៎ះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអគ្គិវេស្សនៈ ភិក្ខុមានចិត្តរួចស្រឡះយ៉ាងនេះហើយ រមែងមិនឈ្លោះនឹងអ្នកណាមួយ មិនទាស់ទែងនឹងអ្នកណាមួយ ពាក្យឯណាដែលគេនិយាយហើយក្នុងលោក ភិក្ខុនោះរមែងពោលតាមពាក្យនោះតែមិនប្រកាន់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លុះដឹងហើយទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ ។

[ ១៩៩ ] ពាក្យថា ជាធីរៈ មិនអន្ទោលទៅក្នុងភពតូចភពធំ ត្រង់ពាក្យថា ក្នុងភពតូចភពធំ គឺមិនអន្ទោលទៅ មិនមក មិនកាន់យក មិនស្ទាបអង្អែល មិនជាប់ចំពាក់ក្នុងកម្មភព បុនព្ភពឈ្មោះថាក្នុងភពតូចភពធំ កាមភពឈ្មោះកម្មភព កាមភពឈ្មោះបុនព្ភព រូបភពឈ្មោះកម្មភព រូបភពឈ្មោះបុនព្ភព

អរូបភពឈ្មោះកម្មភព អរូបភពឈ្មោះបុនព្ភព ក្នុងការកើតរឿយៗ ទៅរឿយៗ ការកើតឡើងរឿយៗ បដិសន្ធិរឿយៗ ការកើតឡើងចំពោះនៃអត្តភាពរឿយៗ ។ ពាក្យថា ជាធីរៈ គឺជាអ្នកប្រាជ្ញ ជាបណ្ឌិតអ្នកមានប្រាជ្ញា អ្នកមានការត្រាស់ដឹង មានញាណ មានសេចក្ដីឈ្វេងយល់ មានប្រាជ្ញាទម្លុះទម្លាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាធីរៈមិនអន្ទោលទៅក្នុងភពតូចភពធំ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនិជាអ្នកមានប្រាជ្ញា ជាធីរៈនោះដឹងនូវពួកជនទាំងនុ៎ះថា ជាអ្នកអាស្រ័យ ( នូវទិដ្ឋិ ) ផង ដឹងនូវនិស្ស័យទាំងឡាយផង លុះដឹងហើយទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ មិនអន្ទោលទៅក្នុងភពតូចភពធំ ។

## ចប់កលហវិវាទសុត្តនិទ្ទេសទី ១១ ។

# អដ្ឋកថា

## កលហវិវាទសុត្តនិទ្ទេសទី ១១

គប្បីជ្រាបវិនិច្ឆ័យក្នុងកលហវិវាទសុត្តនិទ្ទេសទី ១១ ដូចតទៅនេះថា

[ ១២២ ] បទថា **កុតោ បហូតា កលហា វិវាទា** សេចក្តីថា កិលេសទាំងនេះ គឺជម្លោះនិងវិវាទដែលជាចំណែកខាងដើមនៃជម្លោះនោះកើតអំពីណា ។ បទថា **បរិទេវសោកា សហមច្ឆរា ច** សេចក្តីថា សេចក្តីខ្សឹកខ្សួល សេចក្តីសោក សេចក្តីកំណាញ់កើតអំពីណា ។ បទថា **មានាតិមានា សហបេសុណា ច** បានដល់ មានះ អតិមានះនិងការញុះញង់ កើតមកអំពីណា ។ បទថា **តេ** បានដល់ កិលេសទាំង ៨ យ៉ាងនោះ ។ បទថា **តទិង្ឃ ព្រូហិ** បានដល់ សូមទ្រង់ត្រាស់ប្រាប់ភាពដែលខ្ញុំទូលសួរនោះចុះ ខ្ញុំសូមដឹងសេចក្តីនោះ ។ បទថា **ឥង្ឃ** ត្រឹមតែជានិបាត មានអត្ថថា សំណូមពរ ។

[ ១២៣ ] បទថា **ឯកេន អាការេន** បានដល់ ដោយហេតុដូចគ្នា ។ បទថា **អបរេន អាការេន** បានដល់ ដោយហេតុដទៃ ។ បទថា **អាគារិកា ទណ្ឌបសុតា** បានដល់ គហបតីបៀតបៀនគ្នា ។ បទថា **បព្វជិតា អាបត្តឹ អាបជ្ជន្តា** បានដល់ បព្វជិតអ្នកមិនមានផ្ទះត្រូវអាបត្តិណាមួយក្នុងអាបត្តិ ៧ កង ។ បទថា **កុតោ បហូតា** គឺកើតមកអំពីណា ។ បទថា **កុតោ ជាតា** គឺបានអត្តភាពមកអំពីណា ។ បន្ថែមឧបសគ្គទៅជា **កុតោ សញ្ជាតា** ។ បទថា **កុតោ និព្វត្តា** សេចក្តីថា ដល់លក្ខណៈកើតឡើងអំពីណា ។ បន្ថែមឧបសគ្គជា **កុតោ អភិនិព្វត្តា** ។ បទថា **កុតោ បាតុភូតា** បានដល់ ជា

របស់ប្រាកដមកអំពីណា ។ គប្បីជ្រាបសេចក្ដីក្នុងបទថា **កឹនិទានា** គឺមានអ្វីជានិទានជាដើមដូចតទៅនេះថា ឈ្មោះថា **និទានំ** ព្រោះប្រគល់ផលរបស់ខ្លួន ឈ្មោះថា **សមុទយោ** ព្រោះជាហេតុតាំងឡើងនៃផល ។ ឈ្មោះថា **ជាតិ** ព្រោះជាហេតុកើតផល ។ ឈ្មោះថា **បភវោ** ព្រោះជាដែនកើតនៃផល ។ បទថា **មូលំ បុច្ឆតិ** សេចក្ដីថា ព្រះពុទ្ធនិមិត្តទូលសួរដល់ហេតុនៃជម្លោះ ។ ពិតហើយហេតុ ឈ្មោះថា មូលព្រោះជាទីតាំង ។ ឈ្មោះថា **ហេតុ** ព្រោះអត្ថថា បញ្ជូនទៅ គឺប្រព្រឹត្តទៅដើម្បីសម្រេចផលដល់ខ្លួន ។ ឈ្មោះថា **និទានំ** ព្រោះអត្ថថា ប្រគល់ផលរបស់ខ្លួនដូចប្រាប់ថា សូមអញ្ជើញលោកទទួលផលនេះចុះ ។ ឈ្មោះថា **សម្ភវោ** ព្រោះអត្ថថា ជាហេតុកើតនៃផល ។ ឈ្មោះថា **បភវោ** ព្រោះអត្ថថា ជាដែនកើតនៃផល ។ ឈ្មោះថា **សមុដ្ឋានំ** ព្រោះអត្ថថា ជាទីកើតនៃផល ឬជាគ្រឿងកើតនៃផល ។ ឈ្មោះថា **អាហារោ** ព្រោះអត្ថថា នាំមកនូវផលរបស់ខ្លួន ។ ឈ្មោះថា **អារម្មណំ** ព្រោះអត្ថថា ញុំាងផលរបស់ខ្លួនឲ្យត្រេកអរដោយអត្ថថា មិនគប្បីហាម ។ ឈ្មោះថា **បច្ចយោ** ព្រោះអត្ថថា ជាហេតុមានមក គឺប្រព្រឹត្តទៅនៃផល ព្រោះអាស្រ័យគឺមិនរាំងវត្ថុនោះ ។ ឈ្មោះថា **សមុទយោ** ព្រោះអត្ថថា ជាហេតុតាំងឡើងនៃផល ព្រោះដូច្នោះ គប្បីជ្រាបពាក្យបរិយាយនៃបទទាំងនេះដោយប្រការដូច្នេះ ។ ព្រះសារីបុត្តត្ថេរពោលសម្ដែងទេសនាដោយន័យជាដើមថា ព្រះពុទ្ធនិមិត្តទូលសួរមូលនៃជម្លោះនិងវិវាទសំដៅដល់សេចក្ដីនោះ ។

[ ១២៧ ] បទថា **បិយប្បហូតា** បានដល់ កើតចាកវត្ថុជាទីស្រឡាញ់ ។

*បទថា* **មច្ឆេរយុត្តា កលហា វិវាទា** *សេចក្តីថា ដោយបទនេះព្រះមានព្រះភាគមិនបានសម្តែងដល់វត្ថុដែលជាទីស្រឡាញ់តែម្យ៉ាងប៉ុណ្ណោះ ថាជាបច្ច័យនៃជម្លោះនិងវិវាទ សូម្បីសេចក្តីកំណាញ់ក៏ទ្រង់សម្តែងថា ជាបច្ច័យនៃជម្លោះនិងវិវាទដូចគ្នា ។ គប្បីជ្រាបថា ធម៌ទាំងអស់នោះទ្រង់ត្រាស់ទុកក្នុងទីនេះដោយមាតិកាពោលអំពីជម្លោះនិងវិវាទ ។ វិវាទជាហេតុនៃការនិយាយញុះញង់ ដូចសេចក្តីកំណាញ់ជាហេតុ នៃជម្លោះនិងវិវាទដូច្នោះ ។ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា កាលបើវិវាទកើតឡើងហើយជនទាំងឡាយ ( ក៏បង្ក ) នូវការញុះញង់ ។ ពាក្យចន្លុះបង្ហាញអត្ថក្នុងគាថានេះងាយយល់ហើយ ។*

[ ១៣២ ] *បទថា* **បិយា សុ លោកស្មិំ កុតោនិទានា យេ វាបិ លោភា វិចរន្តិ លោកេ** *សេចក្តីថា វត្ថុជាទីស្រឡាញ់ទាំងឡាយ ពួកណាដែលលោកពោលទុកក្នុងបទនេះថា ជម្លោះកើតអំពីសភាវជាទីស្រឡាញ់ វត្ថុជាទីស្រឡាញ់ទាំងឡាយនោះក្នុងលោក មានអ្វីជាដើមហេតុ ម្យ៉ាងទៀតមិនបានពោលដល់វត្ថុជាទីស្រឡាញ់តែម្យ៉ាង សូម្បីជនពួកណាមានក្សត្រជាដើមគង់ត្រាច់ទៅត្រូវសេចក្តីលោភគ្របសង្កត់ រមែងត្រាច់ទៅព្រោះលោភជាហេតុឯសេចក្តីលោភនោះ របស់ជនទាំងនោះមានអ្វីជាហេតុ ដោយប្រការដូច្នេះព្រះពុទ្ធនិមិត្តទូលសួរប្រស្នា ២ ដោយសំណួរតែមួយ ។ ម្យ៉ាងទៀតក្នុងបទថា* **កុតោនិទានា** *នេះ គប្បីជ្រាបថា ផ្លាស់បឋមាវិភត្តិថា* **កឹនិទានា កឹហេតុកា** *ជា* **តោ** *តែក្នុងសមាសមិនមានលុប* **តោ** *នោះ ។ ម្យ៉ាងទៀតបទថា* **និទានា** *បានដល់ កើតហើយ សេចក្តីថា កើតឡើងហើយព្រោះហេតុ*

*នោះទើបលោកពោលថា* **កុតោនិទានា** *គឺកើតអំពីអ្វី កើតឡើងហើយអំពីអ្វី ។ បទថា* **អាសា ច និដ្ឋា ច** *បានដល់ ការសង្ឃឹមនិងការសម្រេចនៃការសង្ឃឹមនោះ ។ បទថា* **យេ សម្បរាយាយ នរស្ស ហោន្តិ** *គឺ* **យេ នរស្ស សម្បរាយនា ហោន្តិ** *លោកអធិប្បាយថា ជាទីទៅខាងមុខ នេះក៏ជាពាក្យសួរមួយប្រការនោះឯង ។*

[ ១៣៦ ] *បទថា* **ឥធា ហោន្តិ** *បានដល់ ជាទីពឹង ។ បទថា* **សរណា ហោន្តិ** *បានដល់ ជាទីឲ្យទុក្ខវិនាសទៅ ។ បទថា* **និដ្ឋាបរាយនោ ហោតិ** *បានដល់ ជាអ្នកមានការសម្រេចក្នុងខាងមុខ ។*

[ ១៣៧ ] *បទថា* **ឆន្ទានិទានានិ** *បានដល់ មានឆន្ទៈ មានការពេញចិត្តក្នុងកាមជាដើមជាដើមហេតុ ។ បទថា* **យេ វាបិ លោភា វិចរន្តិ** *បានដល់ ជនពួកណាមានក្សត្រជាដើមត្រាច់ទៅព្រោះសេចក្តីលោភ សូម្បីសេចក្តីលោភរបស់ជនទាំងនោះ ក៏មានឆន្ទៈជាដើមហេតុដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ឆ្លើយសេចក្តីនោះទាំង ២ រួមគ្នា ។ បទថា* **ឥតោនិទានា** *មានអធិប្បាយថា មានឆន្ទៈជាដើមហេតុនោះឯង ។ បទថា* **ឥតោនិទានា** *ព្រះមានព្រះភាគត្រាស់សំដៅដល់ឆន្ទៈ ។ មែនពិតសេចក្តីលោភជាដើម មានឆន្ទៈជាដើមហេតុ ។ម្យ៉ាងទៀតគប្បីជ្រាបការសម្រេចរបស់ពួកក្នុងបទថា* **ឥតោនិទានា** *នេះ ដោយន័យដូចពោលទុកក្នុងបទថា* **កុតោនិទានា** *នោះឯង ។ ការសម្រេចនៃសេចក្តីសង្ឃឹមលោកហៅថា* **និដ្ឋា** *ព្រោះហេតុនោះ ទើបពោលដល់ការបាននូវការសម្រេចនៃអជ្ឈាស្រ័យ ។*

[ ១៨២ ] *បទថា* **វិនិច្ឆយា** *បានដល់ តណ្ហាវិនិច្ឆ័យនិងទិដ្ឋិវិនិច្ឆ័យ ។ បទថា* **យេ ចាបិ ធម្មា សមណេន វុត្តា** *បានដល់ មួយវិញទៀតធម៌ដទៃពួកណាដែលប្រកបដោយ សេចក្តីក្រោធជាដើម ឬអកុសលធម៌ទាំងឡាយបែបនោះដែលព្រះពុទ្ធសមណៈត្រាស់ទុកហើយ ធម៌ទាំងនោះមានមកអំពីណា ។*

[ ១៨៦ ] *បទថា* **អញ្ញជាតិកា** *បានដល់ មានសភាពដទៃ ។ បទថា* **អញ្ញវិហិតកា** *បានដល់ តាំងនៅដោយអាការដទៃ ។ បទថា* **សមិតាវិនេន** *បានដល់ មានបាបរំលត់ហើយ ។ បទថា* **ពាហិតបាបធម្មេន** *បានដល់ មានធម៌ដ៏លាមកដែលខ្ទង់លះបានហើយ ។ បទថា* **ភិន្នកិលេសមូលេន** *បានដល់ កាត់ឫសគល់នៃកិលេសបានហើយតាំងនៅ ។ បទថា* **សព្វាកុសលមូលពន្ធនាបមុត្តេន** *បានដល់ ដោះនូវគ្រឿងចង គឺអកុសលមូល ១២ ហើយតាំងនៅ ។ បទថា* **វុត្តា** *បានដល់ ដែលព្រះសមណៈត្រាស់ហើយ ។ បទថា* **បវុត្តា** *បានដល់ ត្រាស់ជាផ្នែកៗ ។*

[ ១៨៧ ] *បទថា* **តម្ហបនិស្សាយ បហោតិ ឆន្ទោ** *បានដល់ ឆន្ទៈដោយអំណាចការប្រាថ្នានៅរួមគ្នានិងប្រាសចាកគ្នា រមែងមានព្រោះអាស្រ័យការត្រេកអរនិងមិនត្រេកអរ ពោលគឺទាំង ២ យ៉ាងនោះ ដែលបានដល់សុខវេទនានិងទុក្ខវេទនា ។ ដោយហេតុមានប្រមាណប៉ុណ្ណេះឈ្មោះថា ព្រះពុទ្ធសមណៈទ្រង់ឆ្លើយបញ្ហានេះថា ចុះឆន្ទៈក្នុងលោក មានអ្វីជានិទាន ។ បទថា* **រូបេសុ ទិស្វា វិភវំ ភវញ្ច** *បានដល់ ឃើញការវិនាសនិងការកើតក្នុងរូបទាំងឡាយ ។ បទថា* **វិនិច្ឆយំ កុរុតេ ជន្តុ លោកេ** *បានដល់ សត្វកើតក្នុងលោកដែល*

ប្រកបដោយការវិនាសជាដើម រមែងធ្វើនូវការវិនិច្ឆ័យដោយតណ្ហាដើម្បីឲ្យបាន លាភនិងធ្វើការវិនិច្ឆ័យ ដោយទិដ្ឋិដោយន័យជាដើមថា អត្តារបស់អញកើត ហើយដោយហេតុត្រឹមប៉ុណ្ណេះឈ្មោះថា ព្រះពុទ្ធសមណៈ ទ្រង់ឆ្លើយបញ្ហានេះ ថា ទាំងវិនិច្ឆ័យទាំងឡាយកើតអំពីណាដូច្នេះ ។

[ ១៥៩ ] បទថា **សាតាសាតំ និស្សាយ** បានដល់ ធ្វើនូវការឆ្ងាញ់ និងមិនឆ្ងាញ់ឲ្យជាឧបនិស្ស័យ ។ បទថា **ឥដ្ឋានិដ្ឋំ** បានដល់ អារម្មណ៍គួរប្រាថ្នា និងអារម្មណ៍មិនគួរប្រាថ្នា ។

[ ១៥១ ] ក្នុងគាថានេះថា **សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគំ** បទថា **សុរា** បានដល់ សុរា ៥ យ៉ាង គឺសុរាធ្វើដោយមេ្សៅ ១ សុរាធ្វើដោយនំ ១ សុរាធ្វើដោយបាយ ១ សុរាធ្វើដោយពូជនៃសុរា ១ សុរាផ្សំដោយគ្រឿងផ្សំ ១ ។ បទថា **មេរយំ** បានដល់ មេរ័យ ៥ យ៉ាង គឺមេរ័យត្រាំដោយផ្កា ១ មេរ័យ ត្រាំដោយផ្លែ ១ មេរ័យត្រាំដោយផ្កាស្រគំ ១ មេរ័យត្រាំដោយទឹកអំពៅ ១ មេរ័យ ផ្សំដោយគ្រឿងផ្សំ ១ ទាំងអស់នេះក៏ជាទឹកស្រវឹងដោយធ្វើអ្នកផឹកឲ្យស្រវឹង ។ បទថា **បមាទដ្ឋានំ** បានដល់ ជាហេតុនៃសេចក្តីប្រមាទ ។ បទនេះជាឈ្មោះ របស់ចេតនានៃអ្នកផឹកទឹកស្រវឹងនោះ ។ បទថា **អនុយោគំ** បានដល់ ប្រកប រឿយៗ ក្នុងហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះការផឹកទឹកស្រវឹង គឺសុរា និងមេរ័យនោះ គឺធ្វើរឿយៗ ព្រោះកាលអាត្មាអញប្រកបរឿយៗនូវហេតុជាទី តាំងនៃសេចក្តីប្រមាទ ភោគសម្បត្តិដែលកើតឡើងហើយ ក៏រមែងវិនាសទៅ និងដែលមិនទាន់កើតក៏មិនកើតឡើងដូច្នោះ រមែងដឹងថា ភោគសម្បត្តិរបស់

អាត្មាអញរមែងដល់សេចក្ដីវិនាស ។ ក្នុងបទទាំងពួង ក៏មានន័យយ៉ាងនេះដូចគ្នា ។ បទថា **វិកាលវិសិខាចរិយានុយោគំ** បានដល់ ប្រកបរឿយៗក្នុងការដើរច្រើនតាមច្រកល្ហកក្នុងពេលយប់ព្រលប់ គឺក្នុងពេលមិនសមគួរ ។ បទថា **សមជ្ជាភិចរណំ** បានដល់ ទៅមើលមហោស្រព ដូចជាការមើលរបាំជាដើមញយដង ។ បទថា **អាលស្សានុយោគំ** បានដល់ ខ្វល់ខ្វាយតែក្នុងភាពជាបុគ្គលខ្ជិលច្រអូស ។ បទថា **អបាយមុខានិ ន សេវតិ** បានដល់ មិនសេពទ្វារនៃសេចក្ដីវិនាសនៃភោគសម្បត្តិទាំងឡាយ ។ បទថា **កសិយា វា** បានដល់ ដោយការងារគឺការភ្ជួរខ្វះ ។ បទថា **វណិជ្ជាយ វា** បានដល់ ដោយការងារ គឺការជួញដូរដែលប្រកបដោយធម៌ខ្វះ ។ បទថា **គោរក្ខេន វា** បានដល់ ការចិញ្ចឹមគោខ្វះ ។ បទថា **ឥស្សត្ថេន វា** បានដល់ ដោយសិប្បៈធ្នូខ្វះ ។ បទថា **រាជបោរិសេន វា** បានដល់ ដោយធ្វើជាសេវករបស់ព្រះរាជាខ្វះ ។ បទថា **សិប្បញ្ញតរេន វា** បានដល់ ដោយសិប្បៈឯណានីមួយក្នុងបណ្ដាសិប្បៈមានស្នូទន្ទាំងជាដើម ។ បទថា **បដិបជ្ជតិ** បានដល់ ប្រកបការងារ ។ បទថា **ចក្ខុស្មឹ ឧប្បន្នេ ជាតានិ** បានដល់ កាលចក្ខុគឺភ្នែកកើតឡើង សត្វក៏ដឹងគឺប្រកាន់ដោយទិដ្ឋិថា អត្តារបស់អញកើតឡើងហើយ ។ បទថា **ចក្ខុស្មឹ អន្តរហិតេ** បានដល់ កាលចក្ខុនោះបាត់ទៅ ។ បទថា **អត្តា មេ អន្តរហិតោ** បានដល់ ប្រកាន់ដោយទិដ្ឋិថា អត្តារបស់អញបាត់ទៅហើយ ។ បទថា **វិគតោ មេ អត្តា** បានដល់ អត្តារបស់អាត្មាអញកន្លងទៅហើយ ។ សូម្បីក្នុងបទមានបទថា **សោតស្មឹ** ជាដើម ក៏មានន័យនេះដូចគ្នា ។

**ឯតេបិ ធម្មា ទ្វយមេវ សន្តេ** បានដល់ ធម៌ មានការក្រោធជាដើមនេះ កាលការត្រេកអរនិងការមិនត្រេកអរទាំង ២ មានក៏មានមក គឺកើតឡើង ។ ដោយហេតុមានប្រមាណប៉ុណ្ណោះក៏ឈ្មោះថា ព្រះពុទ្ធសមណៈទ្រង់ព្យាករបញ្ហាទី ៣ ហើយ ។ ព្រះពុទ្ធសមណៈ កាលទ្រង់សម្តែងដល់ឧបាយ លះសេចក្តីសង្ស័យរបស់បុគ្គល ដែលនៅមានសេចក្តីសង្ស័យ ក្នុងបញ្ហាដែលព្រះអង្គស្រាយហើយយ៉ាងនេះទើបត្រាស់ថា **កថំកថី ញាណាកថាយ សិក្ខេ** ដូច្នេះ ។ លោកអធិប្បាយថា គប្បីសិក្សាសិក្ខា ៣ ដើម្បីសម្រេចញាណ គឺញាណទស្សនៈ ។ ព្រោះហេតុអ្វី ព្រោះជាធម៌ដែលសមណៈជ្រាបហើយពោល គឺព្រោះថា ព្រះពុទ្ធសមណៈត្រាស់ដល់ធម៌ទាំងឡាយដែលទ្រង់ដឹងហើយ ការមិនដឹងក្នុងធម៌ទាំងឡាយមិនមានដល់សមណៈនោះ តែបុគ្គលដែលមានសេចក្តីសង្ស័យមិនដឹងធម៌ទាំងនោះ ព្រោះភាពដែលខ្លួនមិនមានញាណ ក៏មិនគប្បីដឹង គឺមិនមែនព្រោះទោសនៃទេសនា ព្រោះហេតុនោះទើបត្រាស់ថា ជនអ្នកមានសេចក្តីសង្ស័យគប្បីសិក្សាតាមគន្លងញាណជាធម៌ដែលសមណៈជ្រាបហើយពោល ។

បទថា **បក្ខេបពន្ធនេន វា ពន្ធោ**[១]បានដល់ ត្រូវគេចងដោយចំណង គឺគុក ។ បទថា **បរិក្ខេបពន្ធនេន** បានដល់ ត្រូវចងដោយចំណង គឺរបងជុំវិញ ។ ក្នុងបទថា **គាមពន្ធនេន** ជាដើម មានអធិប្បាយថា កាលមិនបានចេញអំពីទីនោះៗក៏ឈ្មោះថាត្រូវគេចងដោយចំណង គឺស្រុកជាដើម ។ បទថា **តស្ស ពន្ធនស្ស មោក្ខត្ថាយ** បានដល់ ដើម្បីផុតចាកចំណងដូចពោលហើយនោះ ។

---

១-បិដកខ្មែរមិនមានបទនេះ ។

[ ១៥៥ ] បទថា **ញាណម្ហិ ញាណុប្បត្តិ** បានដល់ ញាណដែលកើតឡើងមុនជាគន្លងដំណើរទៅនៃញាណដែលកើតតៗមក ព្រោះហេតុនោះសូម្បីញាណក៏ឈ្មោះថា ជាគន្លងនៃញាណ ។ បទថា **ញាណស្ស អារម្មណម្ហិ ញាណុប្បត្តិ** បានដល់ សូម្បីបច្ច័យនៃញាណ ក៏ឈ្មោះថា គន្លងនៃញាណព្រោះទាញយកអារម្មណ៍នោះហើយកើតឡើង ។ បទថា **ញាណសហភុនោបិ ធម្មា ញាណុប្បត្តិ** បានដល់ សូម្បីធម៌ទាំងឡាយដែលជាចិត្តនិងចេតសិកដ៏សេសដែលកើតរួមជាមួយញាណក៏ឈ្មោះថា គន្លងនៃញាណ ។ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលឲ្យជាក់ច្បាស់ដោយឧបមាទើបពោលថា **យថា អរិយមគ្គោ អរិយបថោ** ជាដើម ។

បទថា **កថំកថី បុគ្គលោ** បានដល់ បុគ្គលដែលមានសេចក្តីសង្ស័យ ។ បទថា **សកង្ខោ** បានដល់ មានចិត្តបែកជាពីរ ។ បទថា **សវិលេខោ** បានដល់ មានចិត្តមិនចុះស៊ប់ ។ បទថា **សទ្វេឡ្ហកោ** បានដល់ សេចក្តីងឿងឆ្ងល់ ។ បទថា **សវិចិកិច្ឆោ** បានដល់ សេចក្តីសន្ទិះ ។ បទថា **ញាណាធិគមាយ** បានដល់ ដើម្បីបានញាណ ។ បទថា **ញាណផុសនាយ** បានដល់ ដើម្បីពាក់ព្ធ័ះនូវញាណ ឬដើម្បីជួបនូវញាណ ។ បទថា **ញាណសច្ឆិកិរិយាយ** បានដល់ ដើម្បីធ្វើញាណឲ្យឃើញច្បាស់ ។

[ ១៥៦ ] បទថា **សនិទានាហំ** បានដល់ តថាគតសម្តែងធម៌មានហេតុមានបច្ច័យ ។ បទថា **សប្បាដិហារិយំ** បានដល់ នាំសត្វឲ្យផុតទុក្ខបាន ។ បទថា **នោ អប្បាដិហារិយំ** បានដល់ សម្តែងធម៌មិនធ្វើឲ្យសត្វផុតបាកទុក្ខ

ក៏មិនមែន ។

[ ១៥៧ ] បទថា **សាតំ អសាតញ្ច កុតោនិទានា** នេះព្រះមានព្រះភាគ ទ្រង់បំណងយកសុខវេទនានិងទុក្ខវេទនានោះឯងថា ការត្រេកអរនិងមិនត្រេកអរ ។ បទថា **ន ភវន្តិ ហោតេ** កែជា **ន ភវន្តិ ឯតេ** ។ បទថា **វិភវំ ភវញ្ចាបិ យមេតមត្ថំ ឯតម្មេ បព្រូហិ យតោនិទានំ** សេចក្តីថា ការមិនមាននិងការមាននៃការត្រេកអរនិងការមិនត្រេកអរនោះ មានអត្ថយ៉ាងណា ។ ក្នុងបទនេះ ធ្វើការផ្លាស់លិង្គ ។ ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយទុកថា សេចក្តីណាថា ការមិនមាននិងការមាននៃការត្រេកអរនិងការមិនត្រេកអរមាន សូមទ្រង់ត្រាស់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គថា មានវត្ថុណាជាដើមហេតុ ។ ក្នុងពាក្យនេះគប្បីជ្រាបដោយអត្ថថា ការមិនមាននិងការមាន ក៏គឺវិភវទិដ្ឋិនិងភវទិដ្ឋិ ដែលជាទីតាំងរបស់ការមិនមាន និងការមាននៃសេចក្តីត្រេកអរនិងសេចក្តីមិនត្រេកអរ ។ សេចក្តីពិតដូច្នោះ ក្នុងចំណែកនៃការឆ្លើយបញ្ហានេះនឹងពោលក្នុងនិទ្ទេសតទៅ ( ក្នុងឃ្លាប១៦៥ ) ថា ភវទិដ្ឋិក៏មានផស្សៈជាដើមហេតុ វិភវទិដ្ឋិក៏មានផស្សៈជាដើមហេតុ ។ ក្នុងនិទ្ទេសនៃគាថានេះមិនមានពាក្យដែលគួរពោល ។

[ ១៦២ ] បទថា **ឥតោនិទានំ** បានដល់ មានផស្សៈជាដើមហេតុ ។ ក្នុងគាថានេះក៏មិនមានពាក្យដែលគួរពោល ។

[ ១៦៣ ] បទថា **កិស្មឹ វិភូតេ ន ផុសន្តិ ផស្សា** បានដល់ កាលអ្វីកន្លងទៅហើយទើបផស្សៈ ៥ មានចក្ខុសម្ផស្សជាដើមមិនពាល់ត្រូវ ។ គាថា

នេះក៏មិនមានអ្វីគួរពោល ។

[ ១៧២ ] បទថា **នាមញ្ច រូបញ្ច បដិច្ច** បានដល់ ព្រោះអាស្រ័យនាមដែលប្រកបគ្នានិងអាស្រ័យរូប គឺវត្ថុដែលជាអារម្មណ៍ ។ បទថា **រូបេ វិភូតេ ន ផុសន្តិ ផស្សា** បានដល់ កាលរូបកន្លងទៅហើយទើបផស្សៈ ៥ មិនពាល់ត្រូវ ។

[ ១៧៣ ] បទថា **តិណ្ណំ សង្គតិ ផស្សោ** បានដល់ ផស្សៈរមែងកើតឡើងព្រោះប្រជុំធម៌ ៣ គឺចក្ខុ រូបនិងវិញ្ញាណ ។ បទថា **ចក្ខុញ្ច រូបា ច រូបស្មឹ** បានដល់ ចក្ខុបសាទនិងរូបារម្មណ៍ចាត់ទុកក្នុងចំណែករូប គឺផ្នែកខាងរូប ។ បទថា **ចក្ខុសម្ផស្សំ ឋបេត្វា** បានដល់ លែងនូវផស្សៈដែលកើតឡើងព្រោះប្រជុំធម៌ ៣ ប្រការ ។ បទថា **សម្បយុត្តកា ធម្មា នាមស្មឹ** បានដល់ ធម៌ដែលកើតព្រមជាមួយផស្សៈ មានវេទនាជាដើមដ៏សេស ចាត់ទុកក្នុងចំណែកនាម ។ ក្នុងបទថា **សោតញ្ច បដិច្ច** ជាដើម ក៏មានន័យដូចគ្នា ។

[ ១៧៦ ] បទថា **ចតូហិ ការណេហិ រូបំ វិភូតំ ហោតិ** បានដល់ រូបជារបស់កន្លងទៅហើយដោយហេតុ ៤ យ៉ាង ( មានប្រាសចេញដោយការដឹងជាដើម ) ។ បទថា **ញាតវិភូតេន** បានដល់ ធ្វើឲ្យប្រាកដហើយឈានកន្លង ។ បទថា **តីរណវិភូតេន** បានដល់ ពិចារណាដោយភាពជារបស់មិនទៀងជាដើម ហើយឈានកន្លង ។ បទថា **បហានវិភូតេន** បានដល់ ដោយការកន្លងទៅព្រោះលះនូវឆន្ទរាគៈ ។ បទថា **សមតិក្កមវិភូតេន** បានដល់ ដោយការឈានកន្លងដោយអំណាច ការបានអរូបសមាបត្តិ ៤ ។

[ ១៧៧ ] បទថា **កថំ សមេតស្ស** បានដល់ បដិបត្តិដូចម្តេច ។ បទថា **វិភោតិ រូបំ** បានដល់ រូបរមែងមិនមាន ឬមិនគប្បីមាន ។ បទថា **សុខំ ទុក្ខំ វា** បានដល់ ព្រះពុទ្ធនិមិត្តទូលសួរដល់រូបដែលគួរប្រាថ្នានិងមិនគួរប្រាថ្នានោះឯង ។

[ ១៨១ ] បទថា **ជានេយ្យាម** បានដល់ នឹងដឹង ។ បទថា **អាជានេយ្យាម** បានដល់ នឹងដឹងដោយពិសេស ។ បទថា **វិជានេយ្យាម** បានដល់ នឹងដឹងច្រើនយ៉ាង ។ បទថា **បដិវិជានេយ្យាម** បានដល់ នឹងដឹងដោយប្រពៃ ។ បទថា **បដិវិជ្ឈេយ្យាម** បានដល់ នឹងត្រាស់ដឹងដោយចិត្ត ។

[ ១៨២ ] បទថា **ន សញ្ញសញ្ញី** បានដល់ រូបរមែងមិនមានដល់អ្នកបដិបត្តិដោយប្រការណា បុគ្គលនោះរមែងមិនជាបុគ្គលមានសញ្ញាដោយសញ្ញាប្រក្រតីដោយប្រការនោះ ។ បទថា **ន វិសញ្ញសញ្ញី** បានដល់ ជាអ្នកមានសញ្ញាដោយសញ្ញាខុសប្រក្រតី គឺមានសញ្ញាខុសធម្មតា ឬជាមនុស្សឆ្កួត ឬជាមនុស្សមានចិត្តរាយមាយ ។ បទថា **នោបិ អសញ្ញី** បានដល់ សូម្បីវៀរចាកសញ្ញា គឺជាអ្នកចូលនិរោធឬជាសត្វមិនមានសញ្ញា ។ បទថា **ន វិភូតសញ្ញី** បានដល់ មិនជាអ្នកមានសញ្ញាឈានកន្លងហើយ ដោយន័យជាដើមថា **សព្វសោ រូបសញ្ញានំ** ព្រោះកន្លងនូវរូបសញ្ញា ដោយសព្វគ្រប់ ។ បទថា **ឯវំ សមេតស្ស វិភោតិ រូបំ** បានដល់ ពាក្យណាដែលមិនតាំងនៅក្នុងការនៃអ្នកមានសញ្ញាដោយសញ្ញាប្រក្រតីជាដើមនោះហើយពោលទុកថា ភិក្ខុនោះជាអ្នកព្រមព្រៀងក្នុងផ្លូវនៃអរូបសមាបត្តិ រមែងបង្អោនចិត្តទៅដើម្បីបានអាកាសា-

នញ្ចាយតនសមាបត្តិ[1] កាលបុគ្គលបដិបត្តិយ៉ាងនេះ គឺជាអ្នកមានការដល់ព្រម ដោយចិត្តដែលមិនមានទើបរូបមិនមាន ។ បទថា **សញ្ញានិទានា ហិ បបញ្ចសង្ខា** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងទុកថា កាលបុគ្គលបដិបត្តិហើយយ៉ាងនេះនៅមានសញ្ញាណា ធម៌ជាគ្រឿងយឺតយូរ មានតណ្ហាជាដើមដែលមានសញ្ញានោះជាដើមហេតុ ឈ្មោះថាមិនទាន់លះបានឡើយ ។

[ ១៨៤ ] បទថា **អសញ្ញិនោ វុច្ចន្តិ និរោធសមាបន្នា** បានដល់ បុគ្គលចូលនិរោធ ព្រោះរំលត់សញ្ញានិងវេទនាលោកពោលថា ជាអ្នកមិនមានសញ្ញា ព្រោះសញ្ញាមិនមាន ។ បទថា **អសញ្ញសត្តា** បានដល់ កើតក្នុងអសញ្ញីភព ព្រោះមិនមានសញ្ញាដោយប្រការទាំងពួង ។

[ ១៨៥ ] បទថា **សោ** ក្នុងបទនេះថា **សោ ឯវំ សមាហិតេ ចិត្តេ** បានដល់ ភិក្ខុនោះ ។ បទថា **ឯវំ** នេះ សម្ដែងដល់លំដាប់នៃចតុត្ថជ្ឈាន អធិប្បាយថា បាននូវចតុត្ថជ្ឈានតាមលំដាប់នេះ ។ បទថា **សមាហិតេ** បានដល់ ចិត្តជាសមាធិដោយសមាធិក្នុងចតុត្ថជ្ឈាននេះ ។ម្យ៉ាងទៀតក្នុងបទថា **បរិសុទ្ធេ** ជាដើម បានដល់ ចិត្តបរិសុទ្ធដោយសេចក្ដីបរិសុទ្ធនៃឧបេក្ខានិងសតិ ។ ឈ្មោះថា **បរិយោទាតេ** ព្រោះជាចិត្តបរិសុទ្ធនោះឯង អធិប្បាយថា ផូរផង់ ។ ឈ្មោះថា **អនង្គណោ** ព្រោះកិលេសមានរាគៈជាដើមត្រូវកម្ចាត់ចេញទៅដោយការទម្លាយបច្ច័យមានសុខវេទនាជាដើម ។ ឈ្មោះថា **វិគតូបក្កិលេសេ** ព្រោះមិនមានកិលេសនោះឯង ព្រោះថាចិត្តនឹងសៅហ្មងក៏ព្រោះកិលេស ។ ឈ្មោះ

---

១-គាថានេះ មានត្រង់ឃ្លាប ១៨៥ ។

ថា **មុទុភូតេ** ព្រោះអប់រំល្អហើយ អធិប្បាយថា ចិត្តដល់នូវការជំនាញ ។ ព្រោះចិត្តប្រព្រឹត្តទៅក្នុងអំណាចទើបហៅថា **មុទុភូតេ** ។ ឈ្មោះថា **កម្មនិយេ** ព្រោះចិត្តទន់នោះឯង លោកអធិប្បាយថា គួរដល់ការងារ សមគួរដល់ការងារ ព្រោះថា ចិត្តទន់ជាចិត្តដែលគួរដល់ការងារ ដូចមាសបរិសុទ្ធ ។ ចិត្តទាំង ២ យ៉ាងនោះជាចិត្តដែលអប់រំល្អហើយនោះឯង ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចម្រើនហើយ ទើបជាធម្មជាតគួរដល់ការងារដូចចិត្តនេះសោះឡើយដូច្នេះ ។ ចិត្តឈ្មោះថា **ឋិតេ** ព្រោះតាំងមាំក្នុងសេចក្ដីបរិសុទ្ធជាដើមនោះ ។ ឈ្មោះថា **អានេញ្ជប្បត្តេ** ព្រោះជាចិត្តតាំងមាំនោះឯង អធិប្បាយថា មិនញាប់ញ័រ មិនកម្រើក ។ម្យ៉ាងទៀតឈ្មោះថា **ឋិតេ** ព្រោះតាំងនៅក្នុងអំណាចរបស់ខ្លួន ដោយភាពជាចិត្តទន់និងគួរដល់ការងារ ។ ឈ្មោះថា **អានេញ្ជប្បត្តេ** ព្រោះសទ្ធាជាដើមកាន់យក ។ ពិតហើយចិត្តដែលសទ្ធាកាន់យករមែងមិនញាប់ញ័រ ព្រោះការមិនជឿ ។ ចិត្តដែលវីរិយៈកាន់យក រមែងមិនញាប់ញ័រព្រោះការខ្ជិលច្រអូស ។ ចិត្តដែលសតិកាន់យករមែងមិនញាប់ញ័រព្រោះសេចក្ដីប្រមាទ ។ ចិត្តដែលសមាធិកាន់យក តែងមិនញាប់ញ័រព្រោះការរាយមាយ ។ ចិត្តដែលបញ្ញាកាន់យក រមែងមិនញាប់ញ័រព្រោះអវិជ្ជា ។ ចិត្តដែលឱភាសកាន់យករមែងមិនញាប់ញ័រព្រោះការងងឹត គឺកិលេស ។ ធម៌ ៦ ប្រការនេះកាន់យករមែងមិនញាប់ញ័រ ចិត្តប្រកបដោយអង្គ ៨ ជាចិត្តគួរដល់ការនាំទៅ ដើម្បីបានអាកាសានញ្ចាយតនសមាបត្តិ ។

ន័យម្យ៉ាងទៀតឈ្មោះថា **សមាហិតេ** ព្រោះមានសមាធិក្នុងចតុត្ថជ្ឈាន ។ ឈ្មោះថា **បរិសុទ្ធេ** ព្រោះឆ្ងាយចាកនីវរណៈ ។ ឈ្មោះថា **បរិយោទាតេ** ព្រោះឈានកន្លងនូវនីវរណៈជាដើម ។ ឈ្មោះថា **អនង្គណេ** ព្រោះមិនមានការញាប់ញ័រក្នុងការប្រាថ្នាលាមក ដែលជាសត្រូវដល់ការបានឈាន ។ ពាក្យថា ការញាប់ញ័រក្នុងការប្រាថ្នា បានដល់ ការឃ្លាតទៅក្នុងសេចក្តីប្រាថ្នា មានអធិប្បាយថា ជាបច្ច័យនៃការកម្រើក មានប្រការផ្សេងៗដែលឈមចុះប្រព្រឹត្តទៅដោយអំណាចសេចក្តីប្រាថ្នា ។ ឈ្មោះថា **វិគតូបក្កិលេសេ** ព្រោះឧបក្កិលេសនៃចិត្ត មានអភិជ្ឈាជាដើមអស់ទៅ ។ គប្បីជ្រាបពាក្យទាំង ២ យ៉ាងនោះដោយទំនងដូចគ្នានឹងអនង្គណសូត្រនិងវត្ថសូត្រ ( វត្ថូបមសូត្រ ) ។ ឈ្មោះថា **មុទុភូតេ** ព្រោះដល់នូវការជំនាញ ។ ឈ្មោះថា **កម្មនិយេ** ព្រោះចូលដល់ការនៃឥទ្ធិបាទ ។ ឈ្មោះថា **ឋិតេ អានេញ្ជប្បត្តេ** ព្រោះ ចូលដល់នូវការប្រណីតដោយការបំពេញភាវនាឲ្យបរិបូណ៌ អធិប្បាយថា ចិត្តតាំងមាំដោយអាការដែលចិត្តមិនញាប់ញ័រ មិនដល់នូវការញាប់ញ័រ ។ ចិត្តប្រកបដោយអង្គ ៨ យ៉ាងនេះ ជាចិត្តគួរដល់ការនាំទៅឲ្យកើតផលជាបាទ គឺជាបទដ្ឋានដើម្បីបានអាកាសានញ្ចាយតនសមាបត្តិ ។

បទថា **អរូបមគ្គសមង្គី** បានដល់ ជាអ្នកមិនសាបសូន្យចាកធម៌ ជាផ្លូវឲ្យដល់អរូបសមាបត្តិ ។

[ ១៨៦ ] បទថា **បបញ្ចាយេវ បបញ្ចសង្ខា** បានដល់ ធម៌ជាគ្រឿងយឺតយូរមានតណ្ហាជាដើមនោះឯង ឈ្មោះថាចំណែកនៃធម៌ជាគ្រឿងយឺតយូរ ។

បទថា **ឯត្តាវតគ្គំ នុ វទន្តិ ហេកេ យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ ឧទាហុ អញ្ញម្បិ វទន្តិ ឯត្តោ** សេចក្តីថា ព្រះពុទ្ធនិមិត្តទូលសួរថា សមណព្រាហ្មណ៍ដែលជាបណ្ឌិតក្នុងលោកនេះ រមែងពោលនូវការបរិសុទ្ធរបស់សត្វដោយអរូបសមាបត្តិត្រឹមតែប៉ុណ្ណោះ ថាជាធម៌ដ៏ប្រសើរ ឬថាពោលសេចក្តីបរិសុទ្ធដទៃក្រៃលែងជាងអរូបសមាបត្តិនេះ ។

[ ១៩១ ] បទថា **ឯត្តោ អរូបសមាបត្តិតោ** បានដល់ ជាងអរូបសមាបត្តិនោះ ។

[ ១៩២ ] បទថា **ឯត្តាវតគ្គម្បិ វទន្តិ ហេកេ** បានដល់ សមណព្រាហ្មណ៍ដែលមានវាទៈថាទៀង ពួកខ្លះសម្គាល់ខ្លួនថាជាបណ្ឌិតរមែងពោលការបរិសុទ្ធដោយអរូបសមាបត្តិត្រឹមប៉ុណ្ណោះថាជាធម៌ដ៏ប្រសើរ ។ បទថា **តេសំ បុនេកេ សមយំ វទន្តិ** បានដល់ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកខ្លះមានវាទៈថាដាច់សូន្យ រមែងពោលលទ្ធិថាដាច់សូន្យ ។ បទថា **អនុបាទិសេសេ កុសលាវទានា** បានដល់ សមណព្រាហ្មណ៍អាងខ្លួនថាជាអ្នកឈ្លាសក្នុងអនុបាទិសេស ។

[ ១៩៤ ] បទថា **ភវតដ្ឋិតា** បានដល់ ខ្វាចអំពីភព ។ បទថា **វិភវំ អភិនន្ទន្តិ** បានដល់ រមែងត្រេកអរព្រោះអាស្រ័យការដាច់សូន្យ ។ បទថា **តេ សត្តស្ស សមំ** បានដល់ សមណព្រាហ្មណ៍ទាំងនោះមានវាទៈថាសូន្យ រមែងពោលដល់ការស្ងប់ គឺការមិនកើតរបស់បុគ្គល ។ បទថា **ឧបសមំ** បានដល់ ការស្ងប់ក្រៃលែង ។ បទថា **វូបសមំ** បានដល់ សន្តិ គឺការស្ងប់ ។ បទថា

**និរោធំ** បានដល់ ការមិនកើត ។ បទថា **បដិប្បស្សទ្ធំ** បានដល់ មិនកើតទៀតតទៅ ។

[ ១៩៥ ] បទថា **ឯតេ ច ញត្វា ឧបនិស្សិតា** បានដល់ ដឹងសមណព្រាហ្មណ៍ទាំងនោះជាអ្នកមានទិដ្ឋិថា អាស្រ័យសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ។ បទថា **ញត្វា មុនី និស្សយេ សោ វីមំសី** បានដល់ មុនីនោះជាអ្នកមានបញ្ញាជាគ្រឿងពិចារណា ជាបណ្ឌិត ជាព្រះពុទ្ធមុនី ដឹងដល់សមណព្រាហ្មណ៍ដែលមានទិដ្ឋិជាទីអាស្រ័យ ។ បទថា **ញត្វា វិមុត្តោ** បានដល់ ដឹងនូវធម៌ទាំងឡាយដោយភាពជាទុក្ខនិងមិនទៀងជាដើម ហើយផុតវិសេស ។ បទថា **ភវាភវាយ ន សមេតិ** បានដល់ មិនមកដល់ព្រមដោយការកើតរឿយៗ ។

[ ១៩៨ ] បទថា **អបរាមសំ** សេចក្តីថា ភិក្ខុនោះមិនបានប្រកាន់មាំ គឺមិនដល់នូវការប្រកាន់មាំ ។

## អដ្ឋកថា កលហវិវាទសុត្តនិទ្ទេសសូត្រទី ១១ ចប់

# ចូឡវិយូហាសុត្តនិទ្ទេសទី ១២

[ ២០០ ] ( ព្រះពុទ្ធនិមិត្តសួរថា ) ជនទាំងឡាយប្រកាន់ថាខ្លួនឈ្លាសវៃ ជាអ្នកជំអក់នៅក្នុងទិដ្ឋិរបស់ខ្លួនៗ រមែងប្រកាន់យក ( នូវទិដ្ឋិនោះ ) ហើយពោលផ្សេងៗថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងធម៌ បុគ្គលណាបដិសេធសេចក្តីនេះ បុគ្គលនោះឈ្មោះថា មិនមានគុណធម៌បរិបូណ៌ ។

[ ២០១ ] ពាក្យថា ជាអ្នកជំអក់នៅក្នុងទិដ្ឋិរបស់ខ្លួនៗ អធិប្បាយថា មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះកាន់យក រៀនយក ប្រកាន់ បបោសអង្អែល ជាប់ចិត្ត បណ្តាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ។ ពួកអ្នកមានផ្ទះក្តីរមែងនៅក្នុងផ្ទះ ពួកអ្នកត្រូវអាបត្តិក្តី រមែងនៅក្នុងអាបត្តិ ពួកអ្នកប្រកបដោយកិលេសក្តី រមែងនៅក្នុងកិលេសយ៉ាងណា មានសមណព្រាហ្មណ៍ពួកខ្លះជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះកាន់យក រៀនយក ប្រកាន់យក បបោសអង្អែល ជាប់ចិត្ត បណ្តាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ជាអ្នកជំអក់នៅក្នុងទិដ្ឋិរបស់ខ្លួនៗ ។

[ ២០២ ] អធិប្បាយពាក្យថា ប្រកាន់ថាខ្លួនឈ្លាសវៃរមែងប្រកាន់យក ( នូវទិដ្ឋិនោះ ) ហើយពោលផ្សេងៗ ត្រង់ពាក្យថា ប្រកាន់យក គឺកាន់យក រៀនយក ប្រកាន់យក បបោសអង្អែល ជាប់ចិត្ត ។ ពាក្យថា ពោលផ្សេងៗ គឺនិយាយផ្សេងៗ ពោលពាក្យមានប្រការផ្សេងៗ ពោលពាក្យដទៃៗ ពោលពាក្យច្រើន ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវពាក្យជាអនេក ។

ពាក្យថា ប្រកាន់ថាជាអ្នកឈ្លាសវៃ បានសេចក្តីថា មានវាទៈដ៏ឈ្លាស មានវាទៈជាបណ្ឌិត មានវាទៈជាអ្នកប្រាជ្ញ មានវាទៈប្រកបដោយញាណ មានវាទៈត្រូវតាមទំនង មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយហេតុ មានវាទៈគួរដល់ឋានៈ តាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ប្រកាន់ថាខ្លួនឈ្លាសវៃ រមែងប្រកាន់យក ( នូវទិដ្ឋិនោះ ) ហើយពោលពាក្យផ្សេងៗ ។

[ ២០៣ ] ពាក្យថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងធម៌ គឺបុគ្គលណាដឹងនូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គនេះ បុគ្គលនោះឈ្មោះថាដឹង បានដឹង បានឃើញ ចាក់ធ្លុះនូវធម៌ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងធម៌ ។

[ ២០៤ ] ពាក្យថា បុគ្គលណាបដិសេធសេចក្តីនេះ បុគ្គលនោះឈ្មោះថាមិនមានគុណធម៌បរិបូណ៌ គឺបុគ្គលណាឃាត់នូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គនេះ បុគ្គលនោះឈ្មោះថា ជាមនុស្សមិនពេញលេញ មិនគ្រប់គ្រាន់ មិនបរិបូណ៌ ជាបុគ្គលថោកទាប ហីនហោច អាប់ឱន លាមក គម្រក់ រលីបរលាប ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) បុគ្គលណាបដិសេធសេចក្តីនេះ បុគ្គលនោះឈ្មោះថា មិនមានគុណធម៌បរិបូណ៌ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះត្រាស់សួរថា

ជនទាំងឡាយប្រកាន់ថាខ្លួនឈ្លាសវៃ ជាអ្នកជំអក់នៅក្នុងទិដ្ឋិ
របស់ខ្លួនៗ រមែងប្រកាន់យក ( នូវទិដ្ឋិនោះ ) ហើយពោល

ផ្សេងៗថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថា ដឹងធម៌ បុគ្គលណាបដិសេធសេចក្តីនេះ បុគ្គលនោះឈ្មោះថា មិនមានគុណធម៌បរិបូណ៌ ។

[ ២០៥ ] ជនទាំងឡាយប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា ទាំងពោលថាជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ តើវាទៈដូចម្តេចរបស់ជនទាំងនោះជាវាទៈពិត ព្រោះថាជនទាំងនោះជាអ្នកពោលថា ខ្លួនឈ្លាសវៃទាំងអស់គ្នា ។

[ ២០៦ ] ពាក្យថា ជនទាំងឡាយប្រកាន់យ៉ាងនេះហើយរមែងទាស់ទែងគ្នា សេចក្តីថា ជនទាំងឡាយកាន់យក រៀនយក ប្រកាន់យក បបោសអង្អែលជាប់ចិត្តយ៉ាងនេះហើយរមែងទាស់ទែងគ្នា គឺធ្វើនូវជម្លោះ ធ្វើនូវសេចក្តីប្រកួតប្រកាន់ ធ្វើនូវសេចក្តីប្រកាន់ខុស ធ្វើនូវវិវាទ ធ្វើនូវការប្រណាំងប្រជែងថា អ្នកមិនចេះធម៌វិន័យនេះទេ ។បេ។ ឬបើអ្នកអាចអ្នកចូរដោះស្រាយឲ្យរួចចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងឡាយប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា ។

[ ២០៧ ] ពាក្យថា ទាំងពោលថាជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ គឺបានពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលនេះជាមនុស្សទន់ទាប ជាបុគ្គលពាលថោកទាបថោកថយ អាប់ឱន លាមក គម្រក់ ជាមនុស្សកម្សេចកម្ស៊ី មិនឈ្លាស មិនយល់ ជាអ្នកលុះក្នុងអំណាចអវិជ្ជា ជាបុគ្គលមិនមានញាណ មិនមានការ

ពិចារណាដោយញាណ អាប់ឥតប្រាជ្ញា ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ទាំងពោលថា ជាមនុស្សពាល ទន់ទាបមិនឈ្លាសវៃ ។

[ ២០៨ ] ពាក្យថា តើវាទៈដូចម្តេចរបស់ជនទាំងនេះជាវាទៈពិត គឺវាទៈដូចម្តេចរបស់សមណព្រាហ្មណ៍ទាំងនេះ ជាវាទៈពិតប្រាកដមែន ទៀងទាត់ត្រឹមត្រូវ មិនវិបរិត ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) តើវាទៈដូចម្តេចរបស់ជនទាំងនេះជាវាទៈពិត ។

[ ២០៩ ] ពាក្យថា ព្រោះថាជនទាំងនេះ ជាអ្នកពោលថាខ្លួនឈ្លាសវៃទាំងអស់គ្នា គឺសមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកពោលថា ខ្លួនជាអ្នកឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថាត្រូវតាមទំនង ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយហេតុ ពោលថាគួរដល់ឋានៈ តាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ព្រោះថាជនទាំងនេះជាអ្នកពោលថាខ្លួនឈ្លាសវៃទាំងអស់គ្នា ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះ ត្រាស់សួរថា

ជនទាំងឡាយប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា ទាំងពោលថា ជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ តើវាទៈដូចម្តេចរបស់ជនទាំងនេះ ជាវាទៈពិត ព្រោះថាជនទាំងនេះជាអ្នកពោលថាខ្លួនឈ្លាសវៃទាំងអស់គ្នា ។

[ ២១០ ] ( ព្រះមានព្រះភាគត្រាស់ថា ) បុគ្គលពាល ជាអ្នកថោកទាបមានបញ្ញាទន់អន់មិនយល់នូវធម៌របស់បុគ្គលដទៃ ជនទាំងអស់ជាមនុស្ស

ពាល មានបញ្ញាទន់អន់ ជនទាំងអស់នេះជាអ្នកជំអក់នៅក្នុងទិដ្ឋិ ។

[ ២១១ ] ពាក្យថា មិនយល់នូវធម៌របស់បុគ្គលដទៃ គឺមិនយល់តាម មិនឃើញតាម មិនដឹងតាម មិនត្រេកអរតាមនូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គរបស់បុគ្គលដទៃ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនយល់នូវធម៌របស់បុគ្គលដទៃ ។

[ ២១២ ] ពាក្យថា បុគ្គលពាល ជាអ្នកថោកទាប មានបញ្ញាទន់អន់ គឺបុគ្គលឈ្លើយ ល្ងង់ ថោកទាប ទន់អន់ ថោកថយ លាមក គម្រក់ ជាមនុស្សក្រមុំចកម្មី មានបញ្ញាថោកទាប មានបញ្ញាទន់អន់ មានបញ្ញាថោកថយ មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្តួចស្តើង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលពាល ជាអ្នកថោកទាប មានបញ្ញាទន់អន់ ។

[ ២១៣ ] ពាក្យថា ជនទាំងអស់ជាមនុស្សពាល មានបញ្ញាទន់អន់ គឺពួកសមណព្រាហ្មណ៍ទាំងអស់នេះ ជាបុគ្គលល្ងង់ ថោកទាប ទន់អន់ ថោកថយ លាមក គម្រក់ ជាមនុស្សក្រមុំចកម្មី សមណព្រាហ្មណ៍ទាំងអស់មានបញ្ញាថោកទាប មានបញ្ញាទន់អន់ មានបញ្ញាថោកថយ មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្តួចស្តើង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងអស់ជាមនុស្សពាល មានបញ្ញាថោកថយ ។

[ ២១៤ ] ពាក្យថា ជនទាំងអស់នេះ ជាអ្នកជំអក់នៅក្នុងទិដ្ឋិ គឺពួកសមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងអស់នោះកាន់ រៀន ប្រកាន់ បបោសអង្អែល ជាប់ចិត្ត បណ្តាទិដ្ឋិទាំង ៦២ នូវទិដ្ឋិ

ណាមួយហើយនៅ នៅរួម នៅជាប់ នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ។ បុគ្គលមានផ្ទះក្តីរមែងនៅក្នុងផ្ទះ បុគ្គលអ្នកត្រូវអាបត្តិក្តីរមែងនៅក្នុងអាបត្តិ បុគ្គលប្រកបដោយកិលេសក្តី រមែងនៅក្នុងកិលេសយ៉ាងណាមិញ ពួកសមណព្រាហ្មណ៍ទាំងអស់នេះជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះកាន់ រៀន ប្រកាន់ បបោសអង្អែល ជាប់ចិត្ត បណ្តាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយហើយនៅ នៅរួម នៅជាប់ នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងអស់នេះជាអ្នកជំអក់នៅក្នុងទិដ្ឋិ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលពាលជាអ្នកថោកទាប មានបញ្ញាទន់អន់រមែងមិនយល់
នូវធម៌របស់បុគ្គលដទៃ ជនទាំងអស់ជាមនុស្សពាល មាន
បញ្ញា ទន់អន់ ជនទាំងអស់នេះជាអ្នកជំអក់នៅក្នុងទិដ្ឋិ ។

[ ២១៥ ] ប្រសិនបើបុគ្គលទាំងឡាយ ជាអ្នកមានបញ្ញាឈ្លាសវៃ មានបញ្ញាបរិសុទ្ធ មានញាណដ៏ផូរផង់ ដោយទិដ្ឋិរបស់ខ្លួន បណ្តាបុគ្គលទាំងឡាយនោះ បុគ្គលណាមួយមានបញ្ញាទន់អន់ឥតមានទេ ព្រោះថាជនទាំងនោះបានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។

[ ២១៦ ] ពាក្យថា ដ៏ផូរផង់ដោយទិដ្ឋិរបស់ខ្លួន គឺផូរផង់ ស្អាត មិនសៅហ្មងដោយទិដ្ឋិរបស់ខ្លួន ដោយការគួររបស់ខ្លួន ដោយសេចក្តីគាប់ចិត្តរបស់ខ្លួន ដោយលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដ៏ផូរផង់ដោយទិដ្ឋិរបស់ខ្លួន ។

[ ២១៧ ] ពាក្យថា បុគ្គលទាំងឡាយ ជាអ្នកមានបញ្ញាឈ្លាសវៃ មាន

បញ្ញាបរិសុទ្ធល្អ គឺមានបញ្ញាស្អាត មានបញ្ញាស្អាតវិសេស មានបញ្ញាបរិ-សុទ្ធ មានបញ្ញាថ្លាស្អាត មានបញ្ញាផូរផង់ ។ ឬថាមានការឃើញស្អាត មានការឃើញស្អាតវិសេស មានការឃើញបរិសុទ្ធិ មានការឃើញហ្មត់ចត់ មានការឃើញផូរផង់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានបញ្ញាបរិសុទ្ធល្អ ។ ពាក្យថា ឈ្លាសវៃ គឺប៉ិនប្រសប់ ជាបណ្ឌិតមានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្លឺ មានបញ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឈ្លាសវៃ មានបញ្ញាបរិសុទ្ធល្អ ។ ពាក្យថា មានបញ្ញា គឺមានការដឹង ជាបណ្ឌិតមានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្លឺ មានបញ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលទាំងឡាយជាអ្នកមានបញ្ញាឈ្លាសវៃ មានបញ្ញាបរិសុទ្ធ ។

[ ២១៨ ] ពាក្យថា បណ្ដាបុគ្គលទាំងឡាយនោះ បុគ្គលណាមួយ មានបញ្ញាទន់អន់ឥតមានទេ គឺបណ្ដាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ណាមួយមានបញ្ញាថោកទាប មានបញ្ញាទន់អន់ មានបញ្ញាថោកថយ មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្ដួចស្ដើងឥតមានទេ ។ គឺថា សមណ-ព្រាហ្មណ៍ទាំងអស់ មានបញ្ញាដ៏លើសលុប មានបញ្ញាប្រសើរ មានបញ្ញាប្រសើរវិសេស មានបញ្ញាជាប្រធាន មានបញ្ញាដ៏ឧត្ដម មានបញ្ញាដ៏បវរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមួយ មានបញ្ញាទន់អន់ឥតមានទេ ។

[ ២១៩ ] ពាក្យថា ព្រោះថាជនទាំងនោះបានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ

គឺសមណព្រាហ្មណ៍ទាំងនោះ បានប្រកាន់ សមាទាន កាន់យក បបោស អង្អែល ជាប់ចិត្ត ជក់ចិត្ត ចុះចិត្តស៊ប់ ដោយប្រការដូច្នោះហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថាជនទាំងនោះ បានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ប្រសិនបើបុគ្គលទាំងឡាយ ជាអ្នកមានបញ្ញាឈ្លាសវៃ មាន
បញ្ញាបរិសុទ្ធល្អ មានញាណដ៏ផូរផង់ដោយទិដ្ឋិរបស់ខ្លួន បណ្តា
បុគ្គលទាំងឡាយនោះ បុគ្គលណាមួយ មានបញ្ញាទន់អន់ឥត
មានទេ ព្រោះថាជនទាំងនោះបានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។

[ ២២០ ] សមណព្រាហ្មណ៍ទាំងឡាយជាគូៗ បានពោលនូវគ្នានឹងគ្នាថា ពាលព្រោះទិដ្ឋិណា តថាគតមិនពោលនូវទិដ្ឋិនុ៎ះថាពិតទេ បុគ្គលទាំងឡាយបាន ធ្វើនូវទិដ្ឋិរបស់ខ្លួនៗថាពិត ព្រោះហេតុនោះបានជាជនទាំងឡាយតែងយល់នូវ បុគ្គលដទៃថាពាល ។

[ ២២១ ] អធិប្បាយពាក្យថា តថាគតមិនពោលនូវទិដ្ឋិនុ៎ះថាពិតទេ ត្រង់ ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា ទិដ្ឋិនុ៎ះ គឺទិដ្ឋិ ៦២ សេចក្តី ថា តថាគតមិនពោល មិនប្រាប់ មិនសម្តែង មិនបញ្ញត្ត មិនតាំងទុក មិនបើក មិនវែកញែក មិនធ្វើឲ្យរាក់ មិនប្រកាសនូវទិដ្ឋិនុ៎ះថាពិត ថាមែន ថាប្រាកដ ថាត្រូវ ថាមិនវិបរិតដូច្នេះទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតមិនពោល នូវទិដ្ឋិនុ៎ះ ថាពិតទេ ។

[ ២២២ ] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ ជាគូៗ បានពោលនូវ

គ្នានឹងគ្នាថា ( ពាល ) ព្រោះទិដ្ឋិណា ត្រង់ពាក្យថា ជាគូៗ បានសេចក្តីថា ជនពីរនាក់ គឺអ្នកធ្វើជម្លោះពីរនាក់ អ្នកធ្វើសេចក្តីប្រកួតប្រកាន់ពីរនាក់ អ្នកធ្វើតិរច្ឆានកថាពីរនាក់ អ្នកធ្វើវិវាទពីរនាក់ អ្នកធ្វើអធិករណ៍ពីរនាក់ អ្នកជជែកពីរនាក់ អ្នកនិយាយប៉ប៉ាច់ប៉ប៉ោចពីរនាក់ ។ ជនទាំងនោះពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះនូវគ្នានឹងគ្នាថា ពាល ថោកទាប សាបសូន្យ ថោកថយ លាមក គម្រក់ កម្សួចកម្សី ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ទាំងឡាយ ជាគូៗ បានពោលនូវគ្នានឹងគ្នា ថាពាលព្រោះទិដ្ឋិណា ។

[ ២២៣ ] ពាក្យថា បុគ្គលពាលទាំងឡាយ បានធ្វើនូវទិដ្ឋិរបស់ខ្លួនៗ ថាពិត គឺបានធ្វើនូវទិដ្ឋិរបស់ខ្លួនៗ ថាពិត ដោយពាក្យថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ បានធ្វើនូវទិដ្ឋិរបស់ខ្លួនៗ ថាពិតដោយពាក្យថា លោកមិនទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។បេ។ សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលពាលទាំងឡាយ បានធ្វើនូវទិដ្ឋិរបស់ខ្លួនៗថាពិត ។

[ ២២៤ ] ពាក្យថា ព្រោះហេតុនោះជនទាំងឡាយ តែងយល់នូវបុគ្គលដទៃថាពាល ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ទើបជនទាំងឡាយ យល់ឃើញ ក្រឡេកឃើញ សម្លឹង ពិនិត្យ រំពឹង នូវបុគ្គលដទៃថា ពាល

ថោកទាប សាបរលាប ថោកថយ លាមក គម្រក់ កម្សួចកម្សី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ជនទាំងឡាយតែងយល់នូវបុគ្គលដទៃថា ពាល ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សមណព្រាហ្មណ៍ទាំងឡាយ ជាគូៗ បានពោលនូវគ្នានឹងគ្នា
ថាពាលព្រោះទិដ្ឋិណា តថាគតមិនពោលនូវទិដ្ឋិនុ៎ះ ថាពិតទេ
បុគ្គលពាលទាំងឡាយ បានធ្វើនូវទិដ្ឋិរបស់ខ្លួនៗថាពិត ព្រោះ
ហេតុនោះបានជាជនទាំងឡាយ តែងយល់នូវបុគ្គលដទៃថា
ពាល ។

[ ២២៥ ] ( ព្រះពុទ្ធនិមិត្តសួរថា ) សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណាថាជាពាក្យទៀង ជាពាក្យពិត ចំណែកសមណព្រាហ្មណ៍ទាំងឡាយដទៃទៀតបែរជាពោលពាក្យនោះថាជាពាក្យទទេ ជាពាក្យកុហកវិញ សមណ-ព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះហើយរមែងទាស់ទែងគ្នា ព្រោះហេតុអ្វីសមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ។

[ ២២៦ ] ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណាថាជាពាក្យទៀង ជាពាក្យពិត សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះនូវធម៌ ទិដ្ឋិ បដិបទា មគ្គណា ថានេះទៀង ពិតប្រាកដ ត្រូវ មិនវិបរិត ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណាថាជាពាក្យទៀង ជាពាក្យពិត ។

[ ២២៧ ] ពាក្យថា ចំណែកសមណព្រាហ្មណ៍ទាំងឡាយដទៃទៀតបែរជាពោលពាក្យនោះ ថាជាពាក្យទទេ ជាពាក្យកុហកវិញ សេចក្តីថា សមណ-ព្រាហ្មណពួកខ្លះ ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះ នូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គនោះឯងថា នេះជាពាក្យទទេ នេះជាពាក្យកុហក នេះជាពាក្យមិនពិត នេះជាពាក្យមិនមែន នេះជាពាក្យមិនត្រូវ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ចំណែកសមណព្រាហ្មណ៍ទាំងឡាយដទៃទៀត បែរជាពោលពាក្យនោះថាជាពាក្យទទេ ជាពាក្យកុហកវិញ ។

[ ២២៨ ] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយប្រកាន់យ៉ាងនេះហើយរមែងទាស់ទែងគ្នា សេចក្តីថា សមណព្រាហ្មណ៍ទាំងឡាយ កាន់យក រៀនយក ប្រកាន់យក បបោសអង្អែល ជាប់ចិត្តយ៉ាងនេះហើយ រមែងជជែកគ្នា គឺធ្វើនូវជម្លោះ ធ្វើនូវសេចក្តីប្រកួតប្រកាន់ ធ្វើនូវសេចក្តីប្រកាន់ខុស ធ្វើនូវវិវាទ ធ្វើនូវការប្រណាំងប្រជែងថា អ្នកមិនចេះធម៌វិន័យនេះទេ ។បេ។ ឬបើអ្នកអាច អ្នកចូរដោះស្រាយឲ្យរួចចុះ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សមណព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះហើយរមែងទាស់ទែងគ្នា ។

[ ២២៩ ] ពាក្យថា ព្រោះហេតុអ្វី សមណៈទាំងឡាយមិនពោលពាក្យតែបែបមួយ សេចក្តីថា ព្រោះហេតុដូចម្តេច ព្រោះដំណើរដូចម្តេច ព្រោះហេតុអ្វី ព្រោះបច្ច័យអ្វី ព្រោះនិទានដូចម្តេច ព្រោះកិរិយាកើតឡើងដូចម្តេច ព្រោះកំណើតដូចម្តេច ព្រោះហេតុជាដែនកើតមុនដូចម្តេច សមណៈទាំងឡាយមិន

ពោលពាក្យតែបែបមួយ បែរជាពោលផ្សេងៗ ពោលនូវប្រការផ្សេងៗ ពោលដោយឡែកពីគ្នា ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយច្រើនបែបទៅវិញ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ព្រោះហេតុអ្វី សមណព្រាហ្មណ៍ទាំងឡាយមិនពោលពាក្យតែបែបមួយ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះត្រាស់សួរថា

សមណព្រាហ្មណ៍ពួកខ្លះបានពោលពាក្យណា ថាជាពាក្យទៀង
ជាពាក្យពិត សមណព្រាហ្មណ៍ទាំងឡាយដទៃទៀត បែរជា
ពោលពាក្យនោះថាជាពាក្យទទេ ជាពាក្យកុហកវិញ សមណ-
ព្រាហ្មណ៍ទាំងឡាយប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា
ព្រោះហេតុអ្វីសមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ។

[ ២៣០ ] ( ព្រះមានព្រះភាគត្រាស់ថា ) សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា សច្ចៈ ( នោះ ) មានតែមួយមិនមានជាគម្រប់ពីរទេ សមណ-ព្រាហ្មណ៍ទាំងឡាយនោះ តែងពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេងៗគ្នា ព្រោះហេតុនោះបានជាសមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ។

[ ២៣១ ] ពាក្យថា សច្ចៈ ( នោះ ) មានតែមួយ មិនមានជាគម្រប់ពីរទេ អធិប្បាយថា ទុក្ខនិរោធនិព្វាន លោកហៅថាសច្ចៈមួយ បានខាងសេចក្តីរម្ងាប់សង្ខារទាំងពួង កិរិយារលាស់ឧបធិទាំងពួង កិរិយាអស់តណ្ហា ការប្រាសចាកតម្រេក កិរិយារលត់ ព្រះនិព្វាន ។ ឬថា ដែលហៅថាសច្ចៈមួយសំដៅយកមគ្គសច្ចៈ និយ្យានសច្ចៈ ទុក្ខនិរោធគាមិនីបដិបទា មគ្គមានអង្គ ៨ ដ៏

ប្រសើរ គឺសេចក្ដីយល់ត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ សេចក្ដីរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សច្ចៈនោះមានតែមួយ មិនមានជាគម្រប់ពីរទេ ។

[ ២៣២ ] ពាក្យថា សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា ត្រង់ពាក្យថា ណា គឺនូវសច្ចៈណា ។ ពាក្យថា សត្វ គឺជាឈ្មោះរបស់សត្វ ។ សត្វកាលដឹងច្បាស់ ដឹងទូទៅ ដឹងវិសេស ដឹងជាក់ ចាក់ធ្លុះនូវសច្ចៈណា មិនគប្បីធ្វើជម្លោះ មិនគប្បីធ្វើសេចក្ដីប្រកួតប្រកាន់ មិនគប្បីធ្វើសេចក្ដីប្រកាន់ខុស មិនគប្បីធ្វើវិវាទ មិនគប្បីធ្វើការប្រណាំងប្រជែង គឺគប្បីលះបង់ គប្បីបន្ទោបង់ គប្បីធ្វើឲ្យវិនាស គប្បីដល់នូវការមិនកើតមានតទៅនូវជម្លោះ សេចក្ដីប្រកួតប្រកាន់ សេចក្ដីប្រកាន់ខុស វិវាទ សេចក្ដីប្រណាំងប្រជែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា ។

[ ២៣៣ ] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយនោះ តែងពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេងៗគ្នា សេចក្ដីថា សមណព្រាហ្មណ៍ទាំងឡាយនោះតែងសរសើរ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេងៗគ្នា គឺតែងសរសើរ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ តាមទំនើងខ្លួនឯងថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ តែងសរសើរ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយតាមទំនើងខ្លួនឯងថា លោកមិនទៀង ។បេ។ សត្វស្លាប់

ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ទាំងឡាយនោះ តែងពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេងៗគ្នា ។

[ ២៣៤ ] ពាក្យថា ព្រោះហេតុនោះទើបសមណៈទាំងឡាយមិនពោលពាក្យតែមួយ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះទើបសមណៈទាំងឡាយមិនពោលពាក្យតែមួយ គឺពោលផ្សេងៗ ពោលប្រការផ្សេងៗ ពោលដោយឡែកពីគ្នា ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយមានប្រមាណច្រើន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះទើបសមណៈទាំងឡាយ មិនពោលពាក្យតែមួយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> សត្វដឹងច្បាស់នូវសច្ចៈណាមិនគប្បីទាស់ទែងគ្នា សច្ចៈ ( នោះ )
> មានតែមួយ មិនមានជាគម្រប់ពីរទេ សមណព្រាហ្មណ៍ទាំង
> ឡាយនោះ តែងពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយ
> ផ្សេងៗគ្នា ព្រោះហេតុនោះទើបសមណៈទាំងឡាយមិនពោល
> ពាក្យតែមួយ ។

[ ២៣៥ ] ( ព្រះពុទ្ធនិមិត្តសួរថា ) ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ជាអ្នកប្រកាន់ថាឈ្លាសវៃ ពោល ពោលជជែកនូវសច្ចៈទាំងឡាយផ្សេងៗគ្នា សច្ចៈទាំងឡាយច្រើនផ្សេងៗ តើ ( សមណព្រាហ្មណ៍ទាំងនោះ ) បានឮឬ

ឬក៏សមណព្រាហ្មណ៍ទាំងនោះ រាវរកដោយសេចក្តីត្រិះរិះទេ ។

[ ២៣៦ ] ពាក្យថា ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ពោលនូវសច្ចៈទាំងឡាយផ្សេងៗគ្នា ត្រង់ពាក្យថា ព្រោះហេតុអ្វី គឺព្រោះហេតុម្តេច ព្រោះដំណើរដូចម្តេច ព្រោះហេតុដូចម្តេច ព្រោះបច្ច័យដូចម្តេច ព្រោះនិទានដូចម្តេច ទើបពួកសមណព្រាហ្មណ៍ ពោលនូវសច្ចៈទាំងឡាយផ្សេងៗ ពោលនូវសច្ចៈទាំងឡាយមានប្រការផ្សេងៗ ពោលដោយឡែកពីគ្នា ពោល ថ្លែង ពណ៌នា អធិប្បាយ នូវសច្ចៈទាំងឡាយមានប្រមាណច្រើន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ពោលនូវសច្ចៈទាំងឡាយផ្សេងៗគ្នា ។

[ ២៣៧ ] អធិប្បាយពាក្យថា ជាអ្នកប្រកាន់ថាឈ្លាសវៃ ពោល ពោលជជែក ត្រង់ពាក្យថា ពោលជជែក គឺរមែងពោលជជែក ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) ពោលជជែក ។ មួយទៀតសមណព្រាហ្មណ៍ទាំងឡាយ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយនូវទិដ្ឋិរបស់ខ្លួនៗ គឺពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ ពាក្យថា អ្នកប្រកាន់ថាឈ្លាសវៃ គឺជាអ្នកពោលថាឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាមានញាណ ពោលត្រូវទំនង ពោលប្រកបដោយលក្ខណៈ ពោលប្រកបដោយហេតុ ពោល

គួរដល់ឋានៈ តាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ជាអ្នកប្រកាន់ថា ឈ្លាសវៃពោល ពោលដដែក ។

[ ២៣៨ ] ពាក្យថា សច្ចៈទាំងឡាយច្រើនផ្សេងៗ ( តើសមណព្រាហ្មណ៍ទាំងនោះ ) បានឮឬ សេចក្តីថា សច្ចៈទាំងឡាយច្រើនផ្សេងៗ មានប្រការផ្សេងៗដទៃៗ ជាអនេក ( តើសមណព្រាហ្មណ៍ទាំងនោះ ) បានឮឬ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) សច្ចៈទាំងឡាយច្រើនផ្សេងៗ តើសមណព្រាហ្មណ៍ទាំងនោះបានឮឬ ។

[ ២៣៩ ] ពាក្យថា ឬក៏សមណព្រាហ្មណ៍ទាំងនោះវាវរកដោយសេចក្តីត្រិះរិះ សេចក្តីថា ឬក៏ ( សមណព្រាហ្មណ៍ទាំងនោះ ) ត្រូវសេចក្តីត្រិះរិះ សេចក្តីត្រិះរិះផ្សេងៗ សេចក្តីត្រិះរិះព្រម ឲ្យទៅ ឲ្យនាំទៅ ឲ្យរសាត់ ទៅឲ្យក្ដួចទៅ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ឬក៏សមណព្រាហ្មណ៍ទាំងនោះវាវរកដោយសេចក្តីត្រិះរិះ ។ មួយទៀតសមណព្រាហ្មណ៍ទាំងឡាយពោល ថ្លែងពណ៌នា ពន្យល់ អធិប្បាយ នូវប្រាជ្ញាដែលស្រាវជ្រាវ ដោយសេចក្តីត្រិះរិះដែលរិះរក ដោយការពិចារណាដោយខ្លួនឯង ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ឬក៏សមណព្រាហ្មណ៍ទាំងនោះ វាវរកដោយសេចក្តីត្រិះរិះ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះត្រាស់សួរថា

ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកាន់ថាឈ្លាស
វៃ ពោល ពោលដដែកនូវសច្ចៈទាំងឡាយផ្សេងៗគ្នា សច្ចៈ
ទាំងឡាយច្រើនផ្សេងៗ តើ (សមណព្រាហ្មណ៍ទាំងនោះ) បាន

ឮឬ ឬក៏សមណព្រាហ្មណ៍ទាំងនោះ រាវរកដោយសេចក្តីត្រិះរិះទេ ។

[ ២៤០ ] ( ព្រះមានព្រះភាគត្រាស់ថា ) សច្ចៈទាំងឡាយក្នុងលោក វៀរលែងតែសេចក្តីប្រកាន់ ថាទៀងដោយសញ្ញាចេញ មិនមែនមានច្រើនផ្សេងៗគ្នាទេ មួយវិញទៀតជនទាំងឡាយតែងតាំងនូវសេចក្តីត្រិះរិះក្នុងទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក ។

[ ២៤១ ] ពាក្យថា សច្ចៈទាំងឡាយ មិនមែនមានច្រើនផ្សេងៗគ្នាទេ គឺ សច្ចៈទាំងឡាយ មិនមែនមានច្រើនផ្សេងៗ មានប្រការផ្សេងៗ ដោយឡែកពីគ្នាច្រើនទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សច្ចៈទាំងឡាយ មិនមែនមានច្រើនផ្សេងៗគ្នាទេ ។

[ ២៤២ ] អធិប្បាយពាក្យថា ក្នុងលោកវៀរលែងតែសេចក្តីប្រកាន់ថាទៀងដោយសញ្ញាចេញ សេចក្តីថា ក្នុងលោកវៀរលែងតែសេចក្តីប្រកាន់ថាទៀងដោយសញ្ញាចេញ សច្ចៈដែលលោកថ្លែង ពណ៌នា ពន្យល់ អធិប្បាយថា មានតែមួយ គឺទុក្ខនិរោធនិព្វាន បានដល់ កិរិយារម្ងាប់នូវសង្ខារទាំងពួង កិរិយាកម្ចាត់បង់នូវឧបធិទាំងពួង កិរិយាអស់តណ្ហា កិរិយាប្រាសចាករាគៈ កិរិយារលត់ទុក្ខ ព្រះនិព្វាន ។ មួយទៀតសច្ចៈមួយ លោកពោលសំដៅយកមគ្គសច្ចៈ និយ្យានសច្ចៈ ទុក្ខនិរោធគាមិនីបដិបទា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ក្នុងលោកវៀរលែងតែសេចក្តីប្រកាន់ថាទៀតដោយសញ្ញា ។

[ ២៤៣ ] ពាក្យថា មួយទៀតជនទាំងឡាយតែងតាំងនូវសេចក្តីត្រិះរិះក្នុងទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក សេចក្តីថា ជនទាំងឡាយត្រិះរិះ ត្រិះរិះផ្សេងៗ ត្រិះរិះព្រមនូវសេចក្តីត្រិះរិះ នូវសេចក្តីត្រិះរិះផ្សេងៗ នូវសេចក្តីត្រិះរិះព្រម ហើយញុំាងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតចំពោះ លុះញុំាងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតចំពោះហើយ ក៏ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា ពាក្យរបស់ខ្ញុំជាពាក្យពិត ពាក្យរបស់អ្នកជាពាក្យកុហក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនទាំងឡាយតែងតាំងនូវសេចក្តីត្រិះរិះក្នុងទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ហើយថា

សច្ចៈទាំងឡាយក្នុងលោក វៀរលែងតែសេចក្តីប្រកាន់ថាទៀង
ដោយសញ្ញាចេញ មិនមែនមានច្រើនផ្សេងៗគ្នាទេ មួយទៀត
ជនទាំងឡាយតែងតាំងនូវសេចក្តីត្រិះរិះក្នុងទិដ្ឋិទាំងឡាយ ហើយ
ពោលនូវធម៌ជាគូ ថាពិត ថាកុហក ។

[ ២៤៤ ] បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវត្តក្តី ការប៉ះពាល់ក្តីហើយជាអ្នកឃើញនូវការមើលងាយបិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ បានពោលថា បុគ្គលពាលថោកទាប មិនឈ្លាសវៃ ។

[ ២៤៥ ] អធិប្បាយពាក្យថា បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញនូវការមើល

ឆាយ សេចក្តីថា បុគ្គលអាស្រ័យ ចូលទៅអាស្រ័យ កាន់យក បបោស អង្អែល ជាប់ចិត្តនូវការឃើញ ឬនូវសេចក្តីបរិសុទ្ធព្រោះការឃើញក្តី នូវការឮ ឬនូវសេចក្តីបរិសុទ្ធព្រោះការឮក្តី នូវសីលឬនូវសេចក្តីបរិសុទ្ធព្រោះសីលក្តី នូវវត្តឬនូវសេចក្តីបរិសុទ្ធ ព្រោះវត្តក្តី នូវការប៉ះពាល់ឬនូវសេចក្តីបរិសុទ្ធព្រោះការប៉ះពាល់ក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការឃើញក្តី ការឮក្តី សីលនិងវត្តក្តី ការប៉ះពាល់ក្តី ។ ពាក្យថា បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះហើយជាអ្នកឃើញនូវការមើលឆាយ គឺឈ្មោះថាអ្នកឃើញនូវការមើលឆាយព្រោះហេតុមិនរាប់អានខ្ទះ ។ ឬថាឈ្មោះថាអ្នកមើលឆាយព្រោះហេតុញ៉ាំងទោមនស្សឲ្យកើតខ្ទះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវត្តក្តី ការប៉ះពាល់ក្តីហើយជាអ្នកឃើញនូវការមើលឆាយ ។

[ ២៤៦ ] ពាក្យថា ឋិតនៅក្នុងវិនិច្ឆ័យហើយរីករាយ សេចក្តីថា ដែលហៅថា វិនិច្ឆ័យ បានដល់ ទិដ្ឋិ ៦២ ( បុគ្គល ) ឋិតនៅ ឋិតនៅស៊ប់ កាន់យក បបោសអង្អែល ជាប់ចិត្តក្នុងទិដ្ឋិដែលខ្លួនសម្រេចហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលឋិតនៅក្នុងវិនិច្ឆ័យ ។ ពាក្យថា រីករាយ គឺជាអ្នកត្រេកអររីករាយ រីករាយទូទៅ មានចិត្តជារបស់ខ្លួន មានសេចក្តីត្រិះរិះបរិបូណ៌ ។ ឬថា សើចបញ្ចេញធ្មេញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឋិតនៅក្នុងវិនិច្ឆ័យហើយរីករាយ ។

[ ២៤៧ ] ពាក្យថា បានពោលថា បុគ្គលពាលថោកទាប មិនឈ្លាសវៃ

គឺពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលអន់ លួង់ ថោកទាប សាបសូន្យ ថោកថយ លាមកគម្រក់ ជាមនុស្សក្រមួចកម្មី មិនឈ្លាសវៃ មិនមានប្រាជ្ញាជាគ្រឿងចាក់ធ្លុះលុះក្នុងសេចក្តីលួង់ មិនមានញាណ មិនមានប្រាជ្ញាជាគ្រឿងបំភ្លឺ ឥតបញ្ញា ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានពោលថា បុគ្គលពាល ថោកទាប មិនឈ្លាសវៃ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនិងវត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញនូវការមើលងាយឋិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ បានពោលថា បុគ្គលពាលថោកទាប មិនឈ្លាសវៃ ។

[ ២៤៨ ] បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណាហើយពោលចំពោះអាត្មាឯងថាជាបុគ្គលឈ្លាសវៃដោយអំពើនោះ បុគ្គលនោះប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃដោយខ្លួនឯង មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។

[ ២៤៩ ] ពាក្យថា បុគ្គលយល់បុគ្គលដទៃថាជាបុគ្គលពាល ដោយអំពើណា គឺបុគ្គលយល់ឃើញ មើលឃើញ ក្រឡេកឃើញ សម្លឹងឃើញ រំពឹងឃើញនូវបុគ្គលដទៃថាជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមកគម្រក់ ជាមនុស្សក្រមួចកម្មីដោយហេតុណា ដោយបច្ច័យណា ដោយដំណើរណា ដោយហេតុផ្តើមណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលយល់បុគ្គល

ដទៃថាជាបុគ្គលពាលដោយហេតុណា ។

[ ២៥០ ] ពាក្យថា ពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្លាសវៃដោយអំពើនោះ អធិប្បាយថា អត្តា លោកហៅថា អាត្មា ។ បុគ្គលនោះឯងរមែងហៅខ្លួនឯងថា អាត្មាអញជាអ្នកឈ្លាសវៃ ជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងដឹង មានញាណ មានប្រាជ្ញាជាគ្រឿងបំភ្លឺ ជាមេធាវីដោយហេតុនោះ ដោយបច្ច័យនោះ ដោយដំណើរនោះ ដោយហេតុផ្តើមនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលពោលចំពោះអាត្មាឯងថាជាបុគ្គលឈ្លាសវៃដោយអំពើនោះ ។

[ ២៥១ ] ពាក្យថា បុគ្គលនោះប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃ ដោយខ្លួនឯង គឺពោលថាឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថាត្រូវទំនង ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយហេតុ ពោលថាគួរដល់ឋានៈនូវខ្លួនដោយខ្លួនឯង តាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃ ។

[ ២៥២ ] ពាក្យថា មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ គឺមើលងាយបុគ្គលដទៃ ព្រោះហេតុមិនរាប់អានខ្លះ ។ ឬមើលងាយបុគ្គលដទៃ ព្រោះហេតុញុំាងទោមនស្សឲ្យកើតខ្លះ ។ ពាក្យថា ទាំងពោលយ៉ាងនោះដែរ គឺបុគ្គលរមែងពោលប្រកាន់នូវទិដ្ឋិនោះ ដោយប្រការដូច្នោះថា បុគ្គលនេះជាមិច្ឆាទិដ្ឋិ មានការយល់ខុសដោយប្រការដូច្នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។ ហេតុនោះព្រះមានព្រះភាគ

ត្រាស់ថា

បុគ្គលយល់បុគ្គលដទៃថាជាបុគ្គលពាលដោយអំពើណាហើយ
ពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្លាសវៃដោយអំពើនោះ
បុគ្គលនោះប្រកាន់ថា ខ្លួនជាអ្នកឈ្លាសវៃដោយខ្លួនឯង រមែង
មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។

[ ២៥៣ ] បុគ្គលនោះសម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង ជាអ្នកស្រវឹងដោយមានះ មានមានះបរិបូណ៌ អភិសេកខ្លួនដោយចិត្តខ្លួនឯង ព្រោះថា ទិដ្ឋិនោះបុគ្គលនោះសម្រេចហើយដោយប្រការដូច្នោះ ។

[ ២៥៤ ] ពាក្យថា បុគ្គលនោះសម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង អធិប្បាយថា ទិដ្ឋិ ៦២ ហៅថាទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ទិដ្ឋិ ៦២ ហេតុអ្វីក៏លោកហៅថា ទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ទិដ្ឋិទាំងអស់នោះ កន្លងនូវហេតុ កន្លងនូវលក្ខណៈ កន្លងនូវការថោកទាប ហេតុនោះទិដ្ឋិទាំង ៦២ ហៅថាទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ពួកតិរ្ថិយទាំងអស់ មានទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ហេតុអ្វីក៏ពួកតិរ្ថិយទាំងអស់ មានទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ពួកតិរ្ថិយទាំងនោះកន្លង កន្លងព្រម ប្រព្រឹត្តកន្លងនូវគ្នានឹងគ្នា ហើយញុំាងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រម ឲ្យបង្កើត ឲ្យបង្កើតចំពោះ ហេតុនោះបានជាពួកតិរ្ថិយទាំងអស់មានទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ពាក្យថា បុគ្គលនោះសម្រេច គឺសម្រេចបរិបូណ៌ មិនខ្វះខាតដោយទិដ្ឋិមានសារៈដ៏ក្រៃលែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះសម្រេចដោយទិដ្ឋិមានសារៈដ៏ក្រៃលែង ។

[ ២៥៥ ] ពាក្យថា ជាអ្នកស្រវឹងដោយមានះ មានមានះបរិបូណ៌ គឺជាអ្នកស្រវឹង ប្រមាទ ឆ្កួត ស្រវឹងលើសលុបដោយសេចក្តីប្រកាន់ទិដ្ឋិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្រវឹងដោយមានះ ។ ពាក្យថា មានមានះបរិបូណ៌ គឺមានមានះពេញលេញ មានមានះសម្រេច មានមានះមិនខ្វះខាត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្រវឹងដោយមានះមានមានះបរិបូណ៌ ។

[ ២៥៦ ] ពាក្យថា អភិសេកខ្លួនដោយចិត្តខ្លួនឯង គឺអភិសេកខ្លួនដោយចិត្តខ្លួនឯងថា អាត្មាអញជាបុគ្គលឈ្លាសវៃ ជាបណ្ឌិត មានបញ្ញា មានប្រាជ្ញាជាគ្រឿងដឹង មានញាណ មានប្រាជ្ញាជាគ្រឿងបំភ្លឺ ជាមេធាវី ហេតុនោះ ( ទ្រង់ត្រាស់ថា ) អភិសេកខ្លួនដោយចិត្តខ្លួនឯង ។

[ ២៥៧ ] ពាក្យថា ព្រោះថាទិដ្ឋិនោះ បុគ្គលនោះសម្រេចដោយប្រការដូច្នោះ គឺទិដ្ឋិនោះ បុគ្គលនោះសម្រេច សមាទាន កាន់យក បបោសអង្អែលជាប់ចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ដោយប្រការដូច្នោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថាទិដ្ឋិនោះ បុគ្គលនោះសម្រេចដោយប្រការដូច្នោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> បុគ្គលនោះ សម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង ជាអ្នក
> ស្រវឹងដោយមានះ មានមានះបរិបូណ៌ អភិសេកខ្លួនដោយចិត្ត
> ខ្លួនឯងព្រោះថាទិដ្ឋិនោះបុគ្គលនោះសម្រេចដោយប្រការដូច្នោះ ។

[ ២៥៨ ] ប្រសិនបើបុគ្គលទន់អន់ ដោយសារសម្តីរបស់បុគ្គលដទៃ ( បុគ្គលនោះ ) នឹងមានបញ្ញាថោកទាបជាមួយ ។ មួយទៀតបុគ្គលជាវេទគូ

ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ឥតមានអ្នកណាមួយ ជាបុគ្គលពាលក្នុងពួកសមណៈទេ ។

[ ២៥៩ ] ពាក្យថា ប្រសិនបើបុគ្គលទន់អន់ដោយសារសម្តីរបស់បុគ្គលដទៃ គឺប្រសិនបើបុគ្គលជាអ្នកអាប់ឱន ជាបុគ្គលពាល ថោកទាប អន់ ទន់ទាប លាមក គម្រក់ ជាមនុស្សក្រមុំចកម្មីព្រោះហេតុនៃសេចក្តីនិន្ទា ព្រោះហេតុនៃសេចក្តីតិះដៀល ព្រោះហេតុនៃសេចក្តីរិះគន់ដោយសារសម្តី ដោយសារពាក្យរបស់បុគ្គលដទៃ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រសិនបើបុគ្គលទន់អន់ដោយសារសម្តីរបស់បុគ្គលដទៃ ។

[ ២៦០ ] ពាក្យថា ( បុគ្គលនោះ ) នឹងមានបញ្ញាថោកទាបជាមួយ គឺបុគ្គលនោះឯងជាអ្នកមានបញ្ញាថោកទាប មានបញ្ញាថោកថយ មានបញ្ញាទន់ទាប មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្មួចស្មើងជាមួយនឹងបុគ្គលនោះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ នឹងជាបុគ្គលមានបញ្ញាថោកទាបជាមួយ ។

[ ២៦១ ] ពាក្យថា មួយទៀតបុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន គឺបុគ្គលជាអ្នកប្រាជា ជាបណ្ឌិត មានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្លឺ ជាមេធាវី ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀតបុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ។

[ ២៦២ ] ពាក្យថា ឥតមានអ្នកណាមួយជាបុគ្គលពាលក្នុងពួកសមណៈទេ គឺឥតមានអ្នកណាមួយជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក

គម្រក់ ជាមនុស្សក្រមេចកម្មីក្នុងពួកសមណៈទេ គឺថាទាំងអស់គ្នាសុទ្ធតែជាបុគ្គលមានបញ្ញាដ៏លើស មានបញ្ញាប្រសើរ មានបញ្ញាវិសេស មានបញ្ញាជាប្រធាន មានបញ្ញាដ៏ឧត្តម មានបញ្ញាដ៏បវរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឥតមានអ្នកណាមួយជាបុគ្គលពាលក្នុងពួកសមណៈទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ប្រសិនបើបុគ្គលទន់អន់ដោយសារសម្តីរបស់បុគ្គលដទៃ ( បុ-
គ្គលនោះ ) នឹងមានបញ្ញាថោកទាបជាមួយ មួយទៀតបុគ្គលជា
វេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ឥតមានអ្នកណាមួយជា
បុគ្គលពាលក្នុងពួកសមណៈទេ ។

[ ២៦៣ ] បុគ្គលទាំងឡាយណា សរសើរធម៌ដទៃអំពីធម៌នេះ បុគ្គលទាំងឡាយនោះឈ្មោះថា អ្នកភ្លាត់ចាកសេចក្តីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយ តែងពោលដោយច្រើនយ៉ាងនេះឯង ព្រោះថាបុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែងដោយសេចក្តីត្រេកអរនឹងទិដ្ឋិរបស់ខ្លួន ។

[ ២៦៤ ] ពាក្យថា បុគ្គលទាំងឡាយណា សរសើរធម៌ដទៃអំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថាអ្នកភ្លាត់ចាកសេចក្តីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ គឺបុគ្គលទាំងឡាយណាសរសើរធម៌ ទិដ្ឋិ បដិបទា មគ្គដទៃអំពីធម៌នេះ បុគ្គលទាំងឡាយនោះឈ្មោះថា អ្នកខុស អ្នកប្រាស អ្នកភ្លាត់ អ្នកឃ្លាតចាកផ្លូវស្អាត ផ្លូវស្អាតវិសេស ផ្លូវបរិសុទ្ធ ផ្លូវហ្មត់ចត់ ផ្លូវផូរផង់ ជាបុគ្គល

ខុស មិនពេញលេញ ព្រោះមិនមានញាណ បុគ្គលទាំងឡាយនោះ មិនបាន សម្រេច បុគ្គលទាំងឡាយនោះមិនបានបរិបូណ៌ បុគ្គលទាំងឡាយនោះជាបុគ្គល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ ជាមនុស្សក្រមេចកម្ម៉ី ហេតុ នោះ ( ទ្រង់ត្រាស់ថា ) បុគ្គលទាំងឡាយណា សរសើរធម៌ដទៃអំពីធម៌នេះ បុគ្គលទាំងឡាយនោះឈ្មោះថាអ្នកឃ្លាតចាកសេចក្ដីបរិសុទ្ធ ជាបុគ្គលមិនពេញ លេញ ។

[ ២៦៥ ] ពាក្យថា បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយ តែងពោល ដោយច្រើនយ៉ាងនេះឯង អធិប្បាយថា ទិដ្ឋិ លោកហៅថាកំពង់ ។ ពួកបុគ្គល អ្នកលុះក្នុងទិដ្ឋិ លោកហៅថា បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ ។ បុគ្គលអ្នក ប្រកបដោយទិដ្ឋិច្រើន តែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយនូវទិដ្ឋិ ដ៏ច្រើនទាំងឡាយ ដោយទិដ្ឋិមានប្រមាណច្រើន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយតែងពោលដោយច្រើនយ៉ាងនេះខ្លះ ។

[ ២៦៦ ] ពាក្យថា ព្រោះថាបុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្ដីត្រេកអរនឹងទិដ្ឋិរបស់ខ្លួន គឺ ( បុគ្គលនោះ ) ត្រេកអរ ត្រេក-អរក្រៃលែង ដោយសេចក្ដីត្រេកអរនឹងទិដ្ឋិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ ថា ) ព្រោះថាបុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែងដោយសេចក្ដីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលទាំងឡាយណា សរសើរធម៌ដទៃអំពីធម៌នេះ បុគ្គលទាំង
ឡាយនោះឈ្មោះថា អ្នកឃ្លាតចាកសេចក្ដីបរិសុទ្ធ ជាបុគ្គល

មិនពេញលេញ បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយ តែង
ពោលដោយច្រើនយ៉ាងនេះឯង ព្រោះថាបុគ្គលទាំងឡាយនោះ
ត្រេកអរក្រៃលែង ដោយសេចក្តីត្រេកអរនឹងទិដ្ឋិរបស់ខ្លួន ។

[ ២៦៧ ] បុគ្គលទាំងឡាយរមែងពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌នេះឯងដូច្នេះ មិនពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌ទាំងឡាយឯទៀតទេ ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងនៅស៊ប់ក្នុងទិដ្ឋិដ៏ច្រើនយ៉ាងនេះឯង ប្រកាន់មាំក្នុងសកាយនៈ ( ផ្លូវរបស់ខ្លួន ) នោះ ។

[ ២៦៨ ] ពាក្យថា បុគ្គលទាំងឡាយរមែងពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌នេះឯងដូច្នេះ សេចក្តីថា បុគ្គលទាំងឡាយតែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយនូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញក្នុងធម៌របស់ខ្លួននេះតែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយនូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញក្នុងធម៌នេះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ តែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយនូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញក្នុងធម៌នេះថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលទាំងឡាយ រមែងពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌នេះឯងដូច្នេះ ។

[ ២៦៩ ] ពាក្យថា មិនពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌ទាំងឡាយឯទៀតទេ សេចក្តីថា លើកទុកនូវសាស្តា នូវធម៌ដែលសាស្តាប្រាប់ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គរបស់ខ្លួនចេញហើយបោះបោល បោះបង់ បដិសេធនូវវាទៈរបស់ជនដទៃទាំងអស់ គឺពោលហើយយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា សាស្តានោះមិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសាស្តាសម្តែងល្អទេ គណៈមិនមែនប្រតិបត្តិត្រូវទេ ទិដ្ឋិមិនចម្រើនទេ បដិបទាមិនមែនសាស្តាបញ្ញត្តល្អទេ មគ្គមិនមែនជាផ្លូវស្រោចស្រង់សត្វទេ ការស្អាតក្តី ការស្អាតវិសេសក្តី ការស្អាតដោយជុំវិញក្តី ការរួចក្តី ការរួចស្រឡះក្តី ការរួចដោយជុំវិញក្តី មិនមានក្នុងលទ្ធិនេះទេ ជនទាំងឡាយស្អាតក្តី ស្អាតវិសេសក្តី ស្អាតដោយជុំវិញក្តី រួចក្តី រួចវិសេសក្តី រួចដោយជុំវិញក្តី ក្នុងលទ្ធិនេះមិនមានទេ ពួកជននេះជាអ្នកថោកទាប ថោកថយទន់ទាប លាមក គម្រក់ អាប់ឱន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌ទាំងឡាយឯទៀតទេ ។

[ ២៧០ ] ពាក្យថា ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងស៊ប់ក្នុងទិដ្ឋិដ៏ច្រើនយ៉ាងនេះឯង អធិប្បាយថា ទិដ្ឋិលោកហៅថាកំពង់ ។ ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ លោកហៅថា អ្នកមានលទ្ធិដូចជាកំពង់ ។ ( ពួកបុគ្គលនោះ ) តាំងនៅស៊ប់ តាំងនៅមាំ ជាប់ដល់ស៊ប់ ជក់ចិត្ត ចុះចិត្តស៊ប់ក្នុងទិដ្ឋិដ៏ក្រាស់ទាំងឡាយ ព្រោះទិដ្ឋិដ៏ក្រាស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងនៅស៊ប់ក្នុងទិដ្ឋិដ៏ច្រើនយ៉ាងនេះឯង ។

[ ២៧១ ] ពាក្យថា ប្រកាន់មាំក្នុងសកាយនៈនោះ គឺធម៌ឈ្មោះថាសកាយនៈ ទិដ្ឋិឈ្មោះថាសកាយនៈ បដិបទាឈ្មោះថាសកាយនៈ មគ្គឈ្មោះថាសកាយនៈ ។ ជនទាំងឡាយមានវាទៈមាំមួន មានវាទៈរឹងត្អឹង មានវាទៈដ៏មានកម្លាំង មានវាទៈខ្ជាប់ខ្ជួនក្នុងសកាយនៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រកាន់មាំក្នុងសកាយនៈនោះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលទាំងឡាយរមែងពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌នេះឯង
មិនពោលនូវសេចក្តីបរិសុទ្ធ ក្នុងធម៌ទាំងឡាយឯទៀតទេ ពួក
បុគ្គលអ្នកមានលទ្ធិ ដូចជាកំពង់ តាំងនៅស៊ប់ក្នុងទិដ្ឋិដ៏ច្រើន
យ៉ាងនេះឯង ប្រកាន់មាំក្នុងសកាយនៈនោះ ។

[ ២៧២ ] មួយទៀតបុគ្គលប្រកាន់មាំក្នុងសកាយនៈ តែងយល់នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាលក្នុងសកាយនៈនុ៎ះ បុគ្គលនោះកាលពោលនូវបុគ្គលដទៃថាពាល ថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង ។

[ ២៧៣ ] ពាក្យថា មួយទៀតបុគ្គលប្រកាន់មាំក្នុងសកាយនៈ គឺធម៌ឈ្មោះថាសកាយនៈ ទិដ្ឋិឈ្មោះថាសកាយនៈ បដិបទាឈ្មោះថាសកាយនៈ មគ្គឈ្មោះថាសកាយនៈ ។ បុគ្គលមានវាទៈមាំមួន មានវាទៈរឹងត្អឹង មានវាទៈដ៏មានកម្លាំង មានវាទៈខ្ជាប់ខ្ជួនក្នុងសកាយនៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀតបុគ្គលប្រកាន់មាំក្នុងសកាយនៈ ។

[ ២៧៤ ] ពាក្យថា តែងយល់នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាលក្នុងសកាយនៈនុ៎ះ ត្រង់ពាក្យថា នុ៎ះ គឺតែងយល់អ្នកណា ឃើញអ្នកណា មើល

អ្នកណា ក្រឡេកឃើញអ្នកណា សម្លឹងឃើញអ្នកណា រំពឹងឃើញអ្នកណា ដទៃថាជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ អាប់ឱនតាមទិដ្ឋិរបស់ខ្លួន តាមសេចក្តីគួររបស់ខ្លួន តាមសេចក្តីគាប់ចិត្តរបស់ខ្លួន តាមលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) តែងយល់នូវបុគ្គលដទៃណាមួយថាជាបុគ្គលពាលក្នុងសកាយនៈនុ៎ះ ។

[ ២៧៥ ] ពាក្យថា បុគ្គលនោះកាលពោលនូវបុគ្គលដទៃថាជាបុគ្គលពាលថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង សេចក្តីថា បុគ្គលកាលពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលនេះអាប់ឱន ពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ កម្សួចកម្សី មានធម៌មិនស្អាត មានធម៌មិនស្អាតស្អំ មានធម៌មិនបរិសុទ្ធ មានធម៌មិនផូរផង់ គប្បីនាំមក នាំមកព្រម ប្រមូលមក ប្រមូលមកព្រម ទាញមក ទាញមកព្រម ប្រកាន់ បបោសអង្អែល អាស្រ័យនូវជម្លោះ នូវសេចក្តីប្រកួតប្រកាន់ នូវសេចក្តីប្រកាន់ខុស នូវជម្លោះ នូវការប្រណាំងប្រជែងដោយខ្លួនឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះកាលពោលនូវបុគ្គលដទៃថាជាបុគ្គលពាល ថាមានធម៌មិនបរិសុទ្ធតែងនាំមកនូវជម្លោះខ្លួនឯង ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មួយទៀតបុគ្គលប្រកាន់មាំក្នុងសកាយនៈ តែងយល់នូវបុគ្គល
ដទៃណាមួយ ថាជាបុគ្គលពាលក្នុងសកាយនៈនុ៎ះ បុគ្គលនោះ
កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គលពាល ថាមានធម៌មិន

បរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង ។

[ ២៧៦ ] ជននោះតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ រមែងដល់នូវការទាស់ទែងក្នុងលោកតទៅ ជនលះបង់នូវវិនិច្ឆ័យទាំងពួងរមែងមិនធ្វើនូវជម្លោះក្នុងលោក ។

[ ២៧៧ ] ពាក្យថា ជនតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ សេចក្តីថា ទិដ្ឋិ ៦២ លោកហៅថាវិនិច្ឆ័យ ជនតាំងនៅ តាំងនៅស៊ប់ប្រកាន់ បបោសអង្អែល អាស្រ័យក្នុងទិដ្ឋិដែលខ្លួនសម្រេចហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនតាំងនៅក្នុងវិនិច្ឆ័យ ។ ពាក្យថា ប្រមាណយកដោយខ្លួនឯងហើយ គឺប្រមាណយក ស្មានយកដោយខ្លួនឯង គឺប្រមាណយក ស្មានយកដោយខ្លួនឯងថា សាស្តានេះជាសព្វញ្ញូ ប្រមាណយក ស្មានយកដោយខ្លួនឯងថា ធម៌នេះដែលសាស្តាសម្តែងល្អហើយ ពួកនេះប្រតិបត្តិត្រូវ ទិដ្ឋិនេះចម្រើន បដិបទានេះសាស្តាបញ្ញត្តល្អហើយ មគ្គនេះជាទីស្រោចស្រង់សត្វ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ ។

[ ២៧៨ ] ពាក្យថា ជននោះរមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ សេចក្តីថា អនាគត លោកហៅថាតទៅ ។ ជនតាំងទុកនូវវាទៈរបស់ខ្លួនតទៅហើយដល់ ចូលដល់ ចូលទៅជិត កាន់យក បបោសអង្អែល អាស្រ័យនូវជម្លោះ នូវការប្រកួតប្រកាន់ នូវការប្រកាន់ខុស នូវការទាស់ទែង នូវការប្រណាំងប្រជែងដោយខ្លួនឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជននោះរមែង

ដល់នូវការទាស់ទែងក្នុងលោកតទៅយ៉ាងនេះខ្លះ ។ មួយទៀត ( បុគ្គលនោះ ) តែងធ្វើជម្លោះ ធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីប្រកាន់ខុស ធ្វើការទាស់ទែង ធ្វើការប្រណាំងប្រជែងជាមួយទីងវាទៈ នៃជនដទៃតទៅថា អ្នកមិនចេះធម្មវិន័យនេះទេ ។បេ។ ឬបើអ្នកអាច អ្នកចូរដោះស្រាយចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជននោះរមែងដល់នូវការទាស់ទែងក្នុងលោកតទៅយ៉ាងនេះខ្លះ ។

[ ២៧៩ ] ពាក្យថា ជនលះបង់នូវវិនិច្ឆ័យទាំងពួង សេចក្តីថា ទិដ្ឋិ ៦២ លោកហៅថាវិនិច្ឆ័យ ។ ជនលះបង់ លះលែង លះចោល កម្ចាត់បង់ កម្ចាត់បង់ស្រឡះ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅទៀត នូវទិដ្ឋិដែលខ្វះនវិនិច្ឆ័យទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនលះបង់នូវវិនិច្ឆ័យទាំងពួង ។

[ ២៨០ ] ពាក្យថា ជនរមែងមិនធ្វើជម្លោះក្នុងលោក សេចក្តីថា រមែងមិនធ្វើជម្លោះ មិនធ្វើសេចក្តីប្រកួតប្រកាន់ មិនធ្វើសេចក្តីប្រកាន់ខុស មិនធ្វើសេចក្តីទាស់ទែង មិនធ្វើនូវសេចក្តីប្រណាំងប្រជែង ។ សមដូចព្រះតម្រាស់នេះដែលព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តផុតស្រឡះយ៉ាងនេះហើយ រមែងមិនពោលប្រកាន់ជាមួយបុគ្គលណាមួយ មិនជជែកជាមួយបុគ្គលណាមួយ និយាយតែពាក្យណាដែលគេនិយាយក្នុងលោកនោះតែមិនប្រកាន់ ។ ពាក្យថា ជន បានដល់សត្វ នរៈ មាណព បុរស បុគ្គល ជនមានជីវិត ជនមានជាតិ ជនអ្នកកើត ជនទៅដោយឥន្ទ្រិយ ជនអ្នកកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវ-

លោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនរមែងមិនធ្វើនូវជម្លោះក្នុងលោក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ជននោះតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ
រមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ ជនលះបង់នូវ
វិនិច្ឆ័យទាំងពួង រមែងមិនធ្វើនូវជម្លោះក្នុងលោក ។

## ចប់ ចូឡវិយូហសុត្តនិទ្ទេសទី ១២

## អដ្ឋកថា
## ចូឡវិយូហាសុត្តនិទ្ទេស ទី ១២

គប្បីជ្រាបវិនិច្ឆ័យក្នុងចូឡវិយូហាសុត្តនិទ្ទេសទី ១២ ដូចតទៅនេះថា

[ ២០០ ] បទថា **សកំ សកំ ទិដ្ឋិបរិព្វសានា** សេចក្តីថា ក្នុងមហាសម័យនោះឯង ព្រះមានព្រះភាគដើម្បីទ្រង់ប្រកាសសេចក្តីនោះ ដល់ទេវតាទាំងឡាយពួកខ្លះ ដែលមានចិត្តកើតឡើងថា សមណព្រាហ្មណ៍ដែលប្រកាន់នូវទិដ្ឋិទាំងអស់នេះថា អញជាអ្នកត្រឹមត្រូវ សមណព្រាហ្មណ៍ទាំងនេះប្រកាន់ថាខ្លួនត្រឹមត្រូវ តាំងនៅក្នុងទិដ្ឋិរបស់ខ្លួនប៉ុណ្ណោះឬហ្ន៎ ឬថាប្រកាន់ទិដ្ឋិដទៃផងដែរ ទើបទ្រង់ឲ្យព្រះពុទ្ធនិមិត្តទូលសួរព្រះអង្គដោយន័យមុននោះឯង ហើយត្រាស់ព្រះសូត្រនេះ ។ ក្នុងសូត្រនោះ គាថា ២ ខាងដើមជាពាក្យសួរ ។

ក្នុងគាថាទាំងនោះ បទថា **សកំ សកំ ទិដ្ឋិបរិព្វសានា** បានដល់ សមណព្រាហ្មណ៍ទាំងឡាយនៅក្នុងទិដ្ឋិរបស់ខ្លួន ។ បទថា **វិគ្គយ្ហ នានា កុសលា វទន្តិ** បានដល់ ប្រកាន់ទិដ្ឋិនោះយ៉ាងខ្ជាំងក្លា ប្តេជ្ញាថា ខ្ញុំជាអ្នកឈ្លាសក្នុងទិដ្ឋិនោះ ជាអ្នកនិយាយច្រើន មិននិយាយតែម្តង ។ បទថា **យោ ឯវំ ជានាតិ ស វេទិ ធម្មំ ឥទំ បដិក្កោសមកេវលី សោ** សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះពោលសំដៅដល់ទិដ្ឋិនោះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថា ដឹងធម៌ តែបុគ្គលណាជំទាស់នូវធម៌នេះ បុគ្គលនោះឈ្មោះថា ជាមនុស្សអាក្រក់ ។

[ ២០២ ] បទថា **នានា វទន្តិ** បានដល់ និយាយហេតុផ្សេងៗគ្នា ។

បទថា **វិវិធំ វទន្តិ** បានដល់ និយាយច្រើនយ៉ាង ។ បទថា **អញ្ញោញ្ញំ វទន្តិ** បានដល់ មិនពោលតែម្យ៉ាង ពោលអាងត្រង់នោះ ពោលអាងត្រង់នេះ ។

[ ២០៤ ] បទថា **អកោវិលី សោ** បានដល់ បុគ្គលនោះមិនឈ្លាស ។ បទថា **អសមត្តោ** បានដល់ មិនបរិបូណ៌ ។ បទថា **អបរិបុណ្ណោ** បានដល់ មិនពេញ ។

[ ២០៥ ] បទថា **ពាលោ** បានដល់ មនុស្សអាក្រក់ ។ បទថា **អកុសលោ** បានដល់ មិនឈ្លាស ។

តអំពីនេះទៅជាគាថាឆ្លើយ ៣ គាថា ។ គាថាទាំងនោះ រួមសេចក្ដីដែលពោលទុកដោយអត្ថខាងដើមនិងអត្ថខាងចុងទើបសូត្រនេះបានឈ្មោះថា **ចូឡ-វិយូហសូត្រ** ព្រោះមានសេចក្ដីតិចជាងសូត្រតទៅ ដោយការរួបរួមនោះ ។

[ ២១០ ] ក្នុងគាថាទាំងនោះគប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ មុនសិន ។ បទថា **បរស្ស ចេ ធម្មំ** បានដល់ ទិដ្ឋិរបស់អ្នកដទៃ ។ បទថា **សព្វេវិមេ ពាលា** អធិប្បាយថា កាលបើយ៉ាងនេះទើបសមណព្រាហ្មណ៍ទាំងអស់នោះជាបុគ្គលពាល ព្រោះហេតុអ្វី ព្រោះថា ជនទាំងអស់នេះមានការជំអក់នៅក្នុងទិដ្ឋិ ។

[ ២១៥ ] បទថា **សន្ទិដ្ឋិយា ចេវ ន វីវទាតា សំសុទ្ធបញ្ញា កុសលា មុតីមា** សេចក្ដីថា បើសមណព្រាហ្មណ៍ជាអ្នកមិនផូរផង់ មិនបរិសុទ្ធិ សៅហ្មងនឹងមានបញ្ញាបរិសុទ្ធ ឈ្លាស មានការដឹង ព្រោះទិដ្ឋិរបស់ខ្លួន ។ម្យ៉ាងទៀតបាឋថា **សន្ទិដ្ឋិយាចេវទាតា** ។ បទនេះមានអធិប្បាយថា បើបុគ្គលជា

អ្នកផូរផង់ មានបញ្ញាបរិសុទ្ធល្អ ជាអ្នកឈ្លាស មានការដឹង ព្រោះទិដ្ឋិរបស់ខ្លួនសោត ។ បទថា **ន តេសំ កោចិ** សេចក្ដីថា កាលបើដូច្នោះ បណ្ដាសមណព្រាហ្មណ៍ពួកនោះ នឹងមិនជាបុគ្គលមានបញ្ញាថោកថយ សូម្បីតែម្នាក់ ព្រោះហេតុអ្វី ព្រោះថា ជនទាំងនោះបានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។

[ ២២០ ] គប្បីជ្រាបសេចក្ដីសង្ខេបនៃគាថាថា **ន វាហមេតំ** ដូច្នេះថា បុគ្គលជាគូ គឺជន ២ នាក់ ពោលប្រារព្ធទិដ្ឋិណា ដល់គ្នានឹងគ្នាថា ជាពាលតថាគតមិនពោលទិដ្ឋិនោះ ថាពិត គឺជារបស់ពិត ព្រោះហេតុអ្វី ព្រោះសមណព្រាហ្មណ៍ទាំងអស់នោះបានធ្វើទិដ្ឋិរបស់ខ្លួនថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃជាមោឃៈ ព្រោះហេតុនោះបានជាជនទាំងឡាយ តែងយល់នូវបុគ្គលដទៃថាពាល ។ ក្នុងសេចក្ដីនេះមានបាឋៈ ២ យ៉ាងគឺ **តថិយំ តថេវំ** ។

[ ២២១ ] បទថា **តច្ឆំ** បានដល់ មិនទទេ ។ បទថា **តថំ** បានដល់ មិនវិបរិត ។ បទថា **ភូតំ** បានដល់ មាន ។ បទថា **យាថាវំ** បានដល់ មានព្រម ។ បទថា **អវិបរីតំ** បានដល់ មិនខុសសង្កេត ។

[ ២២៥ ] ក្នុងគាថាដែលជាពាក្យសួរថា **យមាហុ** បានដល់ សមណព្រាហ្មណ៍ពួកខ្លះ ពោលទិដ្ឋិសច្ចណាថាពិត ។

[ ២៣០ ] ក្នុងគាថាដែលជាពាក្យឆ្លើយថា **ឯកំ ហិ សច្ចំ** បានដល់ សច្ចៈមានមួយ គឺនិរោធឬមគ្គ ។ បទថា **យស្មឹ បជា នោ វិវទេ បជានំ** បានដល់ ពួកសត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីវិវាទគ្នា នឹងពួកសត្វដែលដឹងច្បាស់ ។ បទថា **សយំ ថុនន្តិ** បានដល់ ពោលដោយខ្លួនឯង ។

*[ ២៣៥ ] គប្បីជ្រាបក្នុងគាថាដែលជាពាក្យសួរថា* **កស្មា នុ** *ដូចតទៅនេះថា*

*បទថា* **បវាទិយាសេ** *បានដល់ ពោលអួតអាង ។ បទថា* **តេ តក្កមនុស្សរន្តិ** *បានដល់ សមណព្រាហ្មណ៍ទាំងនោះពោលឯង ឬទៅតាមការត្រិះរិះរបស់ខ្លួនឯង ។*

*[ ២៣៩ ] បទថា* **តក្កបរិយាហដំ** *បានដល់ ប្រមូលយកដោយការត្រិះរិះ ។ បទថា* **វីមំសានុចរិតំ** *បានដល់ គិតដោយបញ្ញាដែលចូលទៅប្រាកដដល់ខ្លួន ។ បទថា* **សយំ បដិភាណំ** *បានដល់ ដឹងដោយខ្លួនឯង ។*

*[ ២៤០ ] គប្បីជ្រាបសេចក្តីក្នុងគាថាដែលជាពាក្យតបថា* **ន ហេវ** *ដូចតទៅនេះថា*

*បទថា* **អញ្ញត្រ សញ្ញាយ និច្ចានិ** *បានដល់ វៀរចាកការប្រកាន់ថាទៀងត្រឹមតែសញ្ញា ។ បទថា* **តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា** *បានដល់ ត្រឹមតែធ្វើការត្រិះរិះជានិច្ចរបស់ខ្លួន ឲ្យកើតនូវទិដ្ឋិទាំងឡាយ ។*

*[ ២៤៣ ] ព្រោះពួកសមណព្រាហ្មណ៍ ញុំាងនូវការត្រិះរិះក្នុងទិដ្ឋិទាំងឡាយឲ្យកើត ញុំាងទិដ្ឋិឲ្យកើតដូច្នោះ ទើបព្រះសារីបុត្តពោលពាក្យថា ញុំាងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រមជាដើម ។ បទថា* **ជនេន្តិ** *បានដល់ ញុំាងទិដ្ឋិឲ្យកើតក្រៃលែងឡើង ឈ្មោះថា* **ជនេន្តិ** *។ បទថា* **សញ្ជនេន្តិ** *ជាដើមលោកពោលបន្ថែមបទឧបសគ្គ ។ បទថា* **មយ្ហំ សច្ចំ** *បានដល់ ពាក្យពោលរបស់ខ្ញុំពិត ។*

[ ២៤៤ ] ឥឡូវនេះព្រះមានព្រះភាគ ក្នុងកាលសច្ចៈដទៃមិនមានយ៉ាងនេះដើម្បីសម្តែងដល់ការបដិបត្តិខុសរបស់ពួកសមណព្រាហ្មណ៍ ដែលមានទិដ្ឋិរឮកដល់ត្រឹមតែការត្រិះរិះ ទើបត្រាស់គាថា **ទិដ្ឋេ សុតេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ទិដ្ឋេ** អធិប្បាយថា រូបដែលបានឃើញជាសេចក្តីបរិសុទ្ធ ព្រោះការឃើញ ។ ក្នុងសំឡេងដែលបានឮជាដើមក៏មានន័យនេះ ។ បទថា **ឯតេ ច និស្សាយ វិមានទស្សី** សេចក្តីថា អាស្រ័យធម៌ គឺទិដ្ឋិទាំងនេះហើយ ឃើញនូវការមិនរាប់អាន គឺការមិនគួរគោរព ពោលគឺការមិនមានសេចក្តីបរិសុទ្ធ ។ បទថា **វិនិច្ឆយេ ឋត្វា បហស្សមានោ ពាលោ បរោ អកុសលោតិ ចាហ** សេចក្តីថា ជាអ្នកឃើញនូវការមិនគួររាប់អានយ៉ាងនេះតាំងនៅក្នុងទិដ្ឋិដែលវិនិច្ឆ័យនោះ ជាអ្នកត្រេកអរ ជាអ្នករីករាយ ពោលយ៉ាងនេះថា អ្នកដទៃអាក្រក់និងល្ងង់ ។

[ ២៤៥ ] បទថា **ន សម្មានេតីតិបិ វិមានទស្សី** បានដល់ មិនធ្វើនូវការរាប់អានច្រើន ព្រោះហេតុនោះទើបឈ្មោះថា អ្នកឃើញនូវការមើលងាយ គឺមិនសម្តែងនូវការរាប់អានខ្លះ គឺឃើញនូវការគួររាប់អានយ៉ាងច្រើន ក៏មិនមែន ។ បទថា **តោមនស្សំ ជនេតីតិបិ** សេចក្តីថា ជាប់ស្អិតនូវការអាស្រ័យព្រោះទិដ្ឋិមុន ហើយបាននូវទោមនស្សខាងក្រោយ ទើបញុំាងសោមនស្សឲ្យកើតក្នុងវេលាដែលតាំងនៅក្នុងទិដ្ឋិវិនិច្ឆ័យ ។

[ ២៤៦ ] បទថា **វិនិច្ឆិតទិដ្ឋិយា ឋត្វា** បានដល់ តាំងនៅក្នុងទិដ្ឋិដែលសម្រេចនូវការឃើញកាន់យកហើយ ។

[ ២៤៨ ] កាលបើដូច្នោះ ទើបមានគាថាថា **យេនេវ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សយមត្តនា** បានដល់ ខ្លួនឯងនោះឯង ។ បទថា **វិមានេតិ** បានដល់ តិះដៀល ។ បទថា **តមេវ ចាហុ** បានដល់ ពោលពាក្យនោះ ទិដ្ឋិនោះ ឬបុគ្គលនោះ ។

[ ២៥៣ ] គប្បីជ្រាបសេចក្តីនៃគាថាថា **អតិសារទិដ្ឋិយា** ដូច្នេះជាដើម ដូចតទៅនេះថា មេលទ្ធិនោះសម្បូរ បរិបូណ៌ ប៉ោងដោយការប៉ោងដែលជាអតិសារៈទិដ្ឋិដែលកន្លងសារៈ ដែលជាលក្ខណៈនោះយ៉ាងនេះនិងសម្បូរ បរិ-បូណ៌ដោយទិដ្ឋិមានះនោះទើបមានការប្រកាន់ខ្លួនពេញទំហឹងយ៉ាងនេះថា អាត្មាអញសម្បូរ អភិសេកខ្លួនឯងដោយចិត្តថា អាត្មាអញជាបណ្ឌិត ព្រោះអ្វី ព្រោះថា ទិដ្ឋិនោះ បុគ្គលសម្រេចហើយដោយប្រការដូច្នោះ ។

[ ២៥៤ ] បទថា **សញ្ញា តា ទិដ្ឋិយោ លក្ខណាតិក្កន្តា** បានដល់ ទិដ្ឋិទាំង ៦២ នោះ ឈានកន្លងនូវលក្ខណៈ ច្លងនូវលក្ខណៈ ។ បទថា **អធោមោ** បានដល់ មិនខ្វះខាត ។

[ ២៥៨ ] គប្បីក្លាប់សេចក្តីនិងអត្ថនៃគាថាថា **បរស្ស ចេ** ដូច្នេះ ។ មានអ្វីក្រៃលែងជាងនេះទៀត មានដូច្នេះគឺ មេលទ្ធិនោះតាំងនៅក្នុងការសម្រេចចិត្តហើយត្រេកអរ ពោលថា អ្នកដទៃជាពាល មិនឈ្លាស បើបុគ្គលនោះត្រូវពោលទោស រមែងជាបុគ្គលអាក្រក់ ព្រោះពាក្យរបស់អ្នកដទៃសោត ។ បទថា **តុមោ សហា ហោតិ និហីនបញ្ញោ** បានដល់ បុគ្គលនោះរមែងជាអ្នកមានបញ្ញាថោកថយ មួយអន្លើដោយបុគ្គលនោះ ព្រោះថា សូម្បីបុគ្គលនោះក៏

ត្រូវពាលនឹងបុគ្គលនោះ ថាជាពាល ។ បើដូច្នោះពាក្យនៃបុគ្គលនោះយកជាប្រមាណមិនបាន ។ តែបើបុគ្គលនោះជាវេទគូ ជាអ្នកប្រាជ្ញបានខ្លួនឯងសោតកាលបើយ៉ាងនោះ ឥតមានអ្នកណាមួយជាបុគ្គលត្រូវពាលក្នុងពួកសមណៈទេព្រោះថា បុគ្គលទាំងអស់នោះជាបណ្ឌិតតាមសេចក្តីប្រាជ្ញារបស់ខ្លួន ។

[ ២៥៩ ] បទថា **វាចាយ** បានដល់ ព្រោះការពោល ។ បទថា **វចនេន** បានដល់ ព្រោះភាសិត ។ បទថា **និន្ទិតការណា** បានដល់ ព្រោះហេតុនៃការនិន្ទា ។ បទថា **គរហិតការណា** បានដល់ ព្រោះហេតុនៃការមើលងាយ ។ បទថា **ឧបវទិតការណា** បានដល់ ព្រោះហេតុនៃការពោលបៀតបៀន ។

[ ២៦៣ ] គប្បីជ្រាបការភ្ជាប់សេចក្តីនិងអត្ថនៃគាថាថា **អញ្ញំ ឥតោ** ដូចតទៅនេះថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯង ឥតមានអ្នកណាមួយជាបុគ្គលពាល ក្នុងពួកសមណៈទេ បុគ្គលណាមួយគប្បីមានពាក្យសួរថា ព្រោះហេតុអ្វី ក្នុងសេចក្តីនោះសូមឆ្លើយថា ព្រោះបុគ្គលទាំងឡាយណាសរសើរធម៌ដទៃអំពីធម៌នេះ បុគ្គលទាំងឡាយនោះឈ្មោះថា អ្នកភ្លាត់ចាកសេចក្តីបរិសុទ្ធ ជាបុគ្គលមិនពេញលេញ បុគ្គលអ្នកមានទិដ្ឋិដូចជាកំពង់ទាំងឡាយចំនួនច្រើន គឺជនពួកណារមែងសរសើរទិដ្ឋិដទៃចាកទិដ្ឋិនេះ ជនទាំងនោះរមែងពោលដោយច្រើនយ៉ាងនេះឯង មានពាក្យអធិប្បាយថា ព្រោះតិរ្ថិយទាំងឡាយជាច្រើនរមែងពោលយ៉ាងនេះថា ជនពួកណាសរសើរទិដ្ឋិដទៃចាកទិដ្ឋិនេះ ជនទាំងនោះរមែងជាអ្នកភ្លាំងភ្លាត់ គឺភ្លាត់ចាកផ្លូវនៃសេចក្តីបរិសុទ្ធិ និងជាអ្នកមិនបរិបូណ៌ បើសួរថា ព្រោះហេតុអ្វី ទើប

ពោលយ៉ាងនេះ ឆ្លើយថា ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្តីត្រេកអរនឹងទិដ្ឋិរបស់ខ្លួន មានពាក្យអធិប្បាយថា ព្រោះពួកតិរ្ថិយរមែងត្រេកអរក្រៃលែងដោយរាគៈក្នុងទិដ្ឋិរបស់ខ្លួន ។

[ ២៦៤ ] បទថា **តេ សុទ្ធិមគ្គំ** បានដល់ អញ្ញតិរ្ថិយទាំងនោះ រមែងខុសក្លាំងក្លាត់ឃ្លាតនូវផ្លូវដែលមិនសៅហ្មង ។ បទថា **វិសុទ្ធិមគ្គំ** បានដល់ ផ្លូវដែលមិនមានទោស ។ បទថា **បរិសុទ្ធិមគ្គំ** បានដល់ ផ្លូវនៃធម៌ស ។ បទថា **វោទាតមគ្គំ** បានដល់ ផ្លូវផូរផង់ ។ បទថា **បរិយោទាតមគ្គំ** បានដល់ ផ្លូវមានពន្លឺ ។ បទថា **វិរទ្ធា** បានដល់ ក្លាត់ចាកផ្លូវដែលពោល ហើយតាំងនៅ ។ បទថា **អបរទ្ធា** បានដល់ ក្លាំងក្លាត់ទៅ ហើយតាំងនៅ ។ បទថា **ខលិតា** បានដល់ វិនាស ។ បទថា **គលិតា** បានដល់ ក្លាត់ធ្លាក់ចាកទីនោះ ។ បទថា **អញ្ញាយ** បានដល់ ចាកការត្រាស់ដឹង ។ បទថា **អបរទ្ធា** បានដល់ ដល់នូវបរាជ័យ ។ម្យ៉ាងទៀតបាឋៈថា **ញាយាបរទ្ធា** ដូច្នេះក៏មានសេចក្តីថា ក្លាត់ចាកផ្លូវដែលគួរដឹង ។ ពួកតិរ្ថិយត្រេកអរក្រៃលែងយ៉ាងនេះ ។

[ ២៦៧ ] គប្បីជ្រាបគាថាថា **ឥធេវ សុទ្ធឹ** ដូចតទៅនេះថា

ក្នុងបទទាំងនោះ បទថា **សកាយនេ** បានដល់ ក្នុងផ្លូវរបស់ខ្លួន ។ បទថា **ទឡ្ហំនេ វទានា** បានដល់ ពោលសង្កត់ឲ្យធ្ងន់ ។

[ ២៧១ ] បទថា **ថិរវាទា** បានដល់ ពោលសម្រេចនូវការឃើញ ។ បទថា **ពលិកវាទា** បានដល់ ពោលមាំទាំ ។ បទថា **អវដ្ឋិតវាទា** បានដល់ ពោលដោយការផ្តោតចិត្ត ។

[ ២៧២ ] បណ្ដាតិរ្ថិយដែលពោលអះអាងយ៉ាងនេះ តិរ្ថិយណាមួយតែង យល់នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាលក្នុងសកាយនៈនុ៎ះ ព្រោះហេតុនោះតិរ្ថិយដែលពោលអះអាងថា នេះប៉ុណ្ណោះពិត ក្នុងការប្រព្រឹត្តរបស់ខ្លួន ដោយសង្ខេបបានដល់ សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ដោយពិស្ដារបានដល់ នត្ថិ-កទិដ្ឋិ អហេតុកទិដ្ឋិ អកិរិយទិដ្ឋិជាដើម គប្បីឃើញបុគ្គលដទៃដោយធម៌រួមគ្នាក្នុងទិដ្ឋិនេះថា ជាបុគ្គលពាល តិរ្ថិយទាំងអស់ក៏ជាបណ្ឌិត ជាអ្នកបដិបត្តិប្រពៃតាមការយល់ឃើញរបស់បុគ្គលនោះមិនមែនឬ កាលបើយ៉ាងនេះ បុគ្គលនោះកាលពោលនូវបុគ្គលដទៃថាពាល ថាមានធម៌មិនបរិសុទ្ធតែងនាំមកនូវជម្លោះខ្លួនឯងព្រោះមេទិដ្ឋិនោះ កាលពោលដល់បុគ្គលដទៃថាជាពាល មានធម៌មិនបរិសុទ្ធ ពោលអ្នកដទៃថា បុគ្គលនេះជាពាលនិងមានធម៌មិនបរិសុទ្ធ គប្បីនាំមកនូវជម្លោះដោយខ្លួនឯង ព្រោះហេតុអ្វី ព្រោះមេលទ្ធិទាំងអស់ក៏ជាបណ្ឌិតដូចគ្នានិងជាអ្នកបដិបត្តិប្រពៃដូចគ្នាតាមការយល់ឃើញ របស់មេលទ្ធិនោះ ។

[ ២៧៦ ] ក្នុងបទទាំងអស់គប្បីជ្រាបយ៉ាងនេះថា បទថា **វិនិច្ឆយេ ឋត្វា សយំ បមាយ ឧទ្ធំ ស លោកស្មឹ វិវាទមេតិ** សេចក្ដីថា មេទិដ្ឋិនោះតាំងនៅក្នុងទិដ្ឋិដែលខ្លួនយល់ថាត្រឹមត្រូវ រាប់អានឯងហើយរមែងបន្តនូវវិវាទក្រៃ-លែងឡើង ។ បុគ្គលដែលកើតមក កាលដឹងទោសក្នុងទិដ្ឋិដែលខ្លួនវិនិច្ឆ័យយ៉ាងនេះហើយ លះបង់នូវទិដ្ឋិដែលខ្លួនវិនិច្ឆ័យទាំងពួងហើយ ដោយអរិយមគ្គរមែងមិនធ្វើនូវជម្លោះក្នុងលោក ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូលគឺអរហត្ត ។

[ ២៧៧ ] បទថា **សយំ បមាយ** បានដល់ រាប់អានដោយខ្លួនឯង ។ បទថា **បមិនិត្វា** បានដល់ ធ្វើនូវការគិតគ្នេរ ។ បាឋៈថា **បរិនេត្វា** ដូច្នេះក៏មាន បទនោះមិនល្អ ។

[ ២៧៨ ] បទថា **ឲត្តុំ វាទេន សទ្ធឹ** បានដល់ ជាមួយបុគ្គលដែលពោលសង្កត់សង្កិនខ្លួន ។

កាលចប់ទេសនាបុគ្គលត្រាស់ដឹងធម៌ ដូចគ្នាតាមដែលពោលហើយក្នុងបុរាភេទសូត្រនោះឯង ។

**អដ្ឋកថាចូឡវិយូហសុត្តនិទ្ទេសទី ១២ ចប់**

# មហាវិយូហសុត្តនិទ្ទេសទី ១៣

[ ២៨១ ] ( ព្រះពុទ្ធនិមិត្តត្រាស់សួរថា ) ពួកសមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ឋិតែងសម្តែងថា ពាក្យនេះឯងជាពាក្យពិត តើសមណព្រាហ្មណ៍ទាំងអស់នោះនឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ឬក៏បានពាក្យសរសើរក្នុងហេតុនោះដែរ ។

[ ២៨២ ] អធិប្បាយពាក្យថា ពួកសមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ឋិ ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងមូល មិនសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយនេះ ជាពាក្យអស់រលីង ។ ពាក្យថា ត្រាំនៅក្នុងទិដ្ឋិ សេចក្តីថា មានសមណព្រាហ្មណ៍ពួកមួយជាអ្នកលុះក្នុងទិដ្ឋិ សមណ-ព្រាហ្មណ៍ទាំងនោះកាន់ កួចកាន់ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតបណ្តាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅទូទៅ នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ។ ពួកជនអ្នកគ្រប់គ្រងផ្ទះក្តីរមែងនៅក្នុងផ្ទះ ពួកភិក្ខុអ្នកត្រូវអាបត្តិក្តីរមែងនៅក្នុងអាបត្តិ ពួកជនមានកិលេសក្តីតែងនៅក្នុងកិលេស យ៉ាងណាមិញ មានសមណព្រាហ្មណ៍ពួកមួយជាអ្នកលុះក្នុងទិដ្ឋិក៏យ៉ាងនោះដែរ សមណព្រាហ្មណ៍ទាំងនោះកាន់ កួចកាន់ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតបណ្តាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅទូទៅ នៅត្រាំក្នុងទិដ្ឋិរបស់ខ្លួនៗ ។ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ពួកសមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ឋិ ។

[ ២៨៣ ] ពាក្យថា តែងសម្តែងថា ពាក្យនេះឯងជាពាក្យពិត គឺតែងពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែងថាលោកទៀង ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ តែងពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែងថាលោកមិនទៀង ។បេ។

សត្វស្លាប់ទៅកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) តែងសម្តែងថា ពាក្យនេះឯងជាពាក្យពិត ។

[ ២៨៤ ] ពាក្យថា តើសមណព្រាហ្មណ៍ទាំងអស់នោះនឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ សេចក្តីថា តើសមណព្រាហ្មណ៍ទាំងអស់នោះនឹងនាំមកនូវនិន្ទា នាំមកនូវពាក្យតិះដៀល នាំមកនូវការសរសើរតែម្យ៉ាង គឺសមណព្រាហ្មណ៍ទាំងអស់នោះជាអ្នកត្រូវគេនិន្ទា ត្រូវគេតិះដៀល ត្រូវគេមិនសរសើរតែម្យ៉ាងឬ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ។

[ ២៨៥ ] ពាក្យថា ឬក៏បាននូវពាក្យសរសើរក្នុងហេតុនោះដែរ សេចក្តីថា ឬក៏បាន បានចំពោះ បានប្រាកដ តែងបាននូវពាក្យសរសើរ ពាក្យស្ញើចកិត្តិសព្ទ ពាក្យនាំមកនូវសេចក្តីសរសើរក្នុងហេតុនោះ គឺក្នុងទិដ្ឋិរបស់ខ្លួនក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួននោះដែរ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ឬក៏បាននូវពាក្យសរសើរក្នុងហេតុនោះដែរ ។ ហេតុនោះព្រះពុទ្ធនិមិត្តត្រាស់សួរថា

> ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ តែងសម្តែងថា
> ពាក្យនេះឯង ជាពាក្យពិត តើសមណព្រាហ្មណ៍ទាំងអស់នោះ
> នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ឬក៏បាននូវពាក្យសរសើរក្នុង
> ហេតុនោះដែរ ។

[ ២៨៦ ] ( ព្រះមានព្រះភាគត្រាស់ថា ) ផល គឺសេចក្តីសរសើរទុំមាន បន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ តថាគតពោលនូវផលនៃវិវាទថាមាន ២ ប្រការ បុគ្គលកាលឃើញទោសនេះហើយឃើញច្បាស់នូវព្រះនិព្វានជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត រមែងមិនទាស់ទែងទេ ។

[ ២៨៧ ] អធិប្បាយពាក្យថា ផលគឺសេចក្តីសរសើរទុំ មានបន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ ត្រង់ពាក្យថា ផលគឺសេចក្តីសរសើរទុំ មានបន្តិចបន្តួចទេ គឺផលទុំមានប្រមាណតិច ផលទុំអន់ថយ ផលទុំថោក ផលទុំលាមក ផលទុំអាក្រក់ ផលទុំស្តួចស្តើង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ផលទុំមានបន្តិចបន្តួច ។ ពាក្យថា មិនអាចដើម្បីរម្ងាប់បានទេ គឺមិនអាចដើម្បីរម្ងាប់រាគៈ ដើម្បីរម្ងាប់ទោសៈ ដើម្បីរម្ងាប់មោហៈ ដើម្បីរម្ងាប់កោធៈ ដើម្បីរម្ងាប់ ដើម្បីស្ងប់ស្ងាត់ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីគ្របសង្កត់នូវឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ផលគឺសេចក្តីសរសើរទុំ មានបន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ ។

[ ២៨៨ ] ពាក្យថា តថាគតពោលនូវផលនៃវិវាទ ថាមាន ២ ប្រការ គឺតថាគតពណ៌នា ប្រាប់ សំដែង បញ្ញត្ត ផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា ជម្លោះព្រោះទិដ្ឋិ ការប្រកាន់ព្រោះទិដ្ឋិ ការទាស់ទែងព្រោះទិដ្ឋិ ការវិវាទព្រោះ

ទិដ្ឋិ ការបែកខ្ញែកព្រោះទិដ្ឋិ រមែងមានផល ២ ប្រការ គឺការឈ្នះនិងការចាញ់ លាភនិងឥតលាភ យសនិងឥតយស និន្ទានិងសរសើរ សុខនិងទុក្ខ សោមនស្សនិងទោមនស្ស អារម្មណ៍ជាទីប្រាថ្នានិងមិនជាទីប្រាថ្នា សេចក្តីអាណិតនិងការថ្នាំងថ្នាក់ ធូរចិត្តនិងតឹងចិត្ត ការត្រេកអរនិងក្រេវក្រោធ ម្យ៉ាងទៀត អំពើនោះ ជាអំពើប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតសត្វតិរច្ឆាន ប្រព្រឹត្តទៅដើម្បីប្រេតវិស័យ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលនូវផលនៃវិវាទ ថាមាន ២ ប្រការ ។

[ ២៨៩ ] អធិប្បាយពាក្យថា បុគ្គលកាលឃើញទោសនេះហើយ រមែងមិនទាស់ទែងទេ ត្រង់ពាក្យថា ឃើញទោសនេះ គឺឃើញ ជួប ថ្លឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ នូវទោសក្នុងជម្លោះព្រោះទិដ្ឋិ ក្នុងការប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងការវិវាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកព្រោះទិដ្ឋិនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញនូវទោសនេះ ។ ពាក្យថា រមែងមិនទាស់ទែងទេ គឺរមែងមិនធ្វើនូវជម្លោះ មិនធ្វើនូវការប្រកាន់ មិនធ្វើនូវការទាស់ទែង មិនធ្វើនូវការវិវាទ មិនធ្វើនូវការបែកខ្ញែក គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ដល់នូវការមិនកើតមាននូវជម្លោះ នូវការប្រកាន់ នូវការទាស់ទែង នូវវិវាទនិងការបែកខ្ញែក ជាអ្នកធ្ងាយ វៀរបង់ ចៀសវាង ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញចាកជម្លោះ ចាកការប្រកាន់ ចាកការទាស់ទែង ចាកវិវាទនិងការបែកខ្ញែក តែងនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលកាលឃើញទោសនេះហើយ រមែងមិន

ទាស់ទែងទេ ។

[ ២៩០ ] ពាក្យថា ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត អធិប្បាយថា អមតនិព្វាន ហៅថាភូមិមិនមានវិវាទ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ទុក្ខ និព្វាន ។ បុគ្គលកាលឃើញ ប្រទះ រមិលមើល សម្លឹងមើល ពិនិត្យមើល នូវភូមិមិនមានវិវាទនោះ ថាជាទីក្សេមក្សាន្ត ជាទីពំនាក់ ជាទីជ្រកកោន ជាទីរឭក ជាទីមិនមានភ័យ ជាទីទៀងទាត់ ជាទីមិនស្លាប់ ជាទីមិនមានកិលេសជាគ្រឿងចាក់ស្រែះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ផល គឺសេចក្តីសរសើរនុ៎ះមានបន្តិចបន្តួច មិនអាចដើម្បីរម្ងាប់
បានទេ តថាគតពោលនូវផលនៃវិវាទថាមាន ២ ប្រការ បុគ្គល
កាលឃើញទោសនេះហើយ ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិ
មិនមានវិវាទ ជាទីក្សេមក្សាន្ត រមែងមិនទាស់ទែងទេ ។

[ ២៩១ ] សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជនអ្នកប្រាជ្ញរមែងមិនប្រកាន់នូវសម្មតិទាំងអស់នុ៎ះទេ (ព្រោះ) លោកមិនមានធម៌ជាគ្រឿងប្រកាន់ មិនធ្វើសេចក្តីចូលចិត្តក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ធ្វើម្តេចនឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។

[ ២៩២ ] អធិប្បាយពាក្យថា សម្មតិទាំងឡាយណាមួយដែលកើតអំពី

បុថុជ្ជន ត្រង់ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងមូលមិនសេសសល់ ឥតសេសសល់ ពាក្យថាណាមួយនេះ ជាពាក្យអស់រលីង ។ ពាក្យថា សម្មតិទាំងឡាយ គឺទិដ្ឋិ ៦២ លោកហៅថាសម្មតិទាំងឡាយ ។ ពាក្យថាកើតអំពីបុថុជ្ជន គឺសម្មតិទាំងនោះកើតអំពីបុថុជ្ជនទាំងឡាយ ហេតុនោះទើបឈ្មោះថា កើតអំពីបុថុជ្ជន ។ ឬថាសម្មតិទាំងនោះកើតហើយអំពីជនផ្សេងៗ ដ៏ច្រើន ហេតុនោះទើបឈ្មោះថា កើតអំពីបុថុជ្ជន ហេតុនោះ ( ទ្រង់ត្រាស់ថា ) សម្មតិទាំងឡាយណាមួយ កើតអំពីបុថុជ្ជន ។

[ ២៩៣ ] ពាក្យថា អ្នកប្រាជ្ញរមែងមិនប្រកាន់ នូវសម្មតិទាំងអស់នុ៎ះទេ គឺអ្នកប្រាជ្ញ ជាអ្នកដល់នូវវិជ្ជា មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងកម្ចាត់កិលេស មិនដល់ មិនចូលទៅជិត មិនចូលទៅរក មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវសម្មតិគឺទិដ្ឋិទាំងអស់នុ៎ះទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញរមែងមិនប្រកាន់ នូវសម្មតិទាំងអស់នុ៎ះទេ ។

[ ២៩៤ ] អធិប្បាយពាក្យថា លោកមិនមានធម៌ជាគ្រឿងប្រកាន់ ធ្វើម្ដេចនឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ត្រង់ពាក្យថា ធម៌ជាគ្រឿងប្រកាន់ បានដល់ធម៌ជាគ្រឿងប្រកាន់ ២ យ៉ាង គឺធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ១ ធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ។បេ។ នេះធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ ។ បុគ្គលនោះលះបង់ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា រលាស់ចោលធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ បុគ្គលមិនមានធម៌ជាគ្រឿងប្រកាន់ព្រោះលះបង់ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ព្រោះរលាស់ចោលធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ គប្បី

ចូលទៅជិត ចូលទៅរក ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត នូវរូបថាជារបស់អញ ដូចម្តេចកើត ។ គប្បីចូលទៅជិត ចូលទៅរក ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតនូវវេទនាដូចម្តេចកើត នូវសញ្ញាដូចម្តេចកើត នូវសង្ខារដូចម្តេចកើត នូវវិញ្ញាណដូចម្តេចកើត នូវគតិដូចម្តេចកើត នូវឧបបត្តិដូចម្តេចកើត នូវបដិសន្ធិដូចម្តេចកើត នូវភពដូចម្តេចកើត នូវសង្សារដូចម្តេចកើត នូវវដ្តៈដូចម្តេចកើត ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកមិនមានធម៌ជាគ្រឿងប្រកាន់ ធ្វើម្តេចនឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។

[ ២៩៥ ] ពាក្យថា មិនធ្វើនូវសេចក្តីចូលចិត្តក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ គឺមិនធ្វើសេចក្តីចូលចិត្ត មិនធ្វើសេចក្តីពេញចិត្ត មិនធ្វើសេចក្តីស្រឡាញ់ មិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលូតលាស់ មិនឲ្យដុះដាលឡើងនូវតម្រេកក្នុងអារម្មណ៍ដែលឃើញ ឬក្នុងសេចក្តីបរិសុទ្ធព្រោះឃើញ ក្នុងអារម្មណ៍ដែលឮ ឬក្នុងសេចក្តីបរិសុទ្ធព្រោះឮ ក្នុងអារម្មណ៍ដែលប៉ះពាល់ ឬក្នុងសេចក្តីបរិសុទ្ធព្រោះប៉ះពាល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនធ្វើនូវសេចក្តីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សម្មតិទាំងឡាយណាមួយដែលកើតអំពីបុថុជ្ជន អ្នកប្រាជ្ញរមែង
មិនប្រកាន់នូវសម្មតិទាំងអស់នុ៎ះទេ ( ព្រោះ ) លោកមិនមាន
ធម៌ជាគ្រឿងប្រកាន់ មិនធ្វើសេចក្តីចូលចិត្តក្នុងអារម្មណ៍ដែល
ខ្លួនឃើញហើយ ឮហើយទេ ធ្វើម្តេចនឹងដល់នូវធម៌ជាគ្រឿង

ប្រការ ។

[ ២៩៦ ] សមណព្រាហ្មណ៍ទាំងឡាយ ( ណា ) ជាអ្នកប្រកាន់ថាសីលឧត្តម ប្រកាន់ស្អិតនូវវត្ត បានពោលនូវសេចក្ដីបរិសុទ្ធ ដោយការសង្រួមថា យើងសិក្សានូវសេចក្ដីបរិសុទ្ធ របស់គ្រូនោះក្នុងទិដ្ឋិនេះតែម្យ៉ាង ( សមណ-ព្រាហ្មណ៍ទាំងនោះ ) ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃរមែងជាអ្នកចូលទៅរកភព ។

[ ២៩៧ ] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ ( ណា ) ជាអ្នកប្រកាន់ថាសីលឧត្តម បានពោលនូវសេចក្ដីបរិសុទ្ធ ដោយការសង្រួម សេចក្ដីថា មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកពោលថាសីលឧត្តម សមណព្រាហ្មណ៍ទាំងនោះពោល និយាយ សម្ដែង ពណ៌នា បំភ្លឺ ថ្លែងនូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះ ដោយគុណត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរវាំង ត្រឹមតែការមិនប្រព្រឹត្តកន្លង ។ ( តួយ៉ាងដូច ) សមណមុណ្ឌិកាបុត្ត បានពោលយ៉ាងនេះថា ម្នាលជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ ថាជាអ្នកមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ដល់នូវគុណដែលគួរដល់ដ៏ខ្ពង់ខ្ពស់ ជាសមណៈដែលគេផ្ចាញ់មិនបាន ចុះធម៌ ៤ តើដូចម្ដេច ម្នាលជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើបាបកម្មដោយកាយ ១ មិនពោលពាក្យអាក្រក់ ១ មិនត្រិះរិះនូវតម្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិតអាក្រក់ ១ ម្នាលជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ នេះឯងថា ជាអ្នកមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ដល់នូវគុណដែលគួរដល់ដ៏ខ្ពង់ខ្ពស់ ជាសមណៈដែលគេផ្ចាញ់មិនបាន ។ មាន

សមណព្រាហ្មណ៍ពួកមួយ ជាអ្នកពោលថាសីលឧត្តម សមណព្រាហ្មណ៍ទាំងនោះពោល និយាយ សំដែង ពណ៌នា បំភ្លឺ ថ្លែងនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះ ដោយគុណត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរវាំង ត្រឹមតែការមិនប្រព្រឹត្តកន្លងយ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រកាន់ថាសីលឧត្តម បានពោលនូវសេចក្តីបរិសុទ្ធដោយការសង្រួម ។

[ ២៩៨ ] ពាក្យថា ប្រកាន់ស្អិតនូវវត្ត ត្រង់ពាក្យថា វត្ត គឺកាន់យក សមាទាន អើពើ ទទួល ស្ទាបអង្អែល ប្រកាន់ស្អិតហើយតាំងមាំ តម្កល់ស៊ប់ ជាប់ស្អិត ចូលទៅរក ចុះចិត្តស៊ប់ ឱនទៅរកនូវវត្តដំរី វត្តសេះ វត្តគោ វត្តពពែ វត្តឆ្កែ វត្តក្អែក វត្តវាសុទេព វត្តបុណ្ណកទ្ធ វត្តមណិកទ្ធ វត្តភ្លើង វត្តនាគ វត្តគ្រុឌ វត្តយក្ខ វត្តអសុរ វត្តគន្ធព្វ វត្តមហារាជ វត្តព្រះចន្ទ្រ វត្តព្រះអាទិត្យ វត្តព្រះឥន្ទ្រ វត្តព្រះព្រហ្ម វត្តទេវតា វត្តទិស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រកាន់ស្អិតនូវវត្ត ។

[ ២៩៩ ] អធិប្បាយពាក្យថា យើងសិក្សានូវសេចក្តីបរិសុទ្ធ របស់គ្រូនោះ ក្នុងទិដ្ឋិនេះតែម្យ៉ាង ត្រង់ពាក្យថា ក្នុងទិដ្ឋិនេះ គឺយើងសិក្សា ប្រព្រឹត្តទូទៅ ប្រព្រឹត្តព្រម សមាទាន ប្រព្រឹត្តក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីគាប់ចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) យើងសិក្សាក្នុងទិដ្ឋិនេះតែម្យ៉ាង ។ ពាក្យថា នូវសេចក្តីបរិសុទ្ធរបស់គ្រូនោះ គឺនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះរបស់

គ្រូនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) យើងសិក្សានូវសេចក្តីបរិសុទ្ធ របស់គ្រូនោះក្នុងទិដ្ឋិនេះតែម្យ៉ាង ។

[ ៣០០ ] អធិប្បាយពាក្យថា ( សមណព្រាហ្មណ៍ទាំងនោះ ) ជាអ្នកប្រកាន់ថា ខ្លួនឈ្លាសវៃ រមែងជាអ្នកចូលទៅរកភព ត្រង់ពាក្យថា ជាអ្នកចូលទៅរកភព គឺជាអ្នកចូលទៅជិតកាន់ភព ចូលទៅរកភព ចុះស៊ប់ក្នុងភព ឱនទៅរកភព ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកចូលទៅរកភព ។ ពាក្យថា ប្រកាន់ថាខ្លួនឈ្លាសវៃ គឺជាអ្នកពោលថាឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថាប្រកបដោយហេតុ ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយការណ៍ ពោលថាប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកចូលទៅរកភពប្រកាន់ថាឈ្លាសវៃ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> សមណព្រាហ្មណ៍ទាំងឡាយ ( ណា ) ជាអ្នកប្រកាន់ថាសីល
> ឧត្តម ប្រកាន់ស្អិតនូវវត្ត បានពោលនូវសេចក្តីបរិសុទ្ធដោយ
> ការសង្រួមថា យើងសិក្សានូវសេចក្តីបរិសុទ្ធរបស់គ្រូនោះ ក្នុង
> ទិដ្ឋិនេះតែម្យ៉ាង ( សមណព្រាហ្មណ៍ទាំងនោះ ) ជាអ្នកប្រកាន់
> ថា ខ្លួនឈ្លាសវៃ រមែងជាអ្នកចូលទៅរកភព ។

[ ៣០១ ] បើបុគ្គលណាឃ្លាតចាកសីលនិងវត្តហើយ បុគ្គលនោះរមែងញាប់ញ័រ ព្រោះភ្លាត់ចាកកម្ម បុគ្គលនោះឯងតែងចង់បានផង ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធ ដូចបុគ្គលឃ្លាតចាកផ្ទះហើយសាបសូន្យចាកពួក ។

[ ៣០២ ] ពាក្យថា បើបុគ្គលណាឃ្លាតចាកសីលនិងវត្តហើយ អធិប្បាយថា បុគ្គលឃ្លាតចាកសីលនិងវត្តដោយហេតុ ២ ប្រការគឺ ឃ្លាតដោយការលះបង់ព្រោះបុគ្គលដទៃ ឬកាលមិនសម្រេចហើយឃ្លាត ។

បុគ្គលឃ្លាតដោយការលះបង់ព្រោះបុគ្គលដទៃ តើដូចម្តេច ។ បុគ្គលដទៃឲ្យលះបង់ថា សាស្តានោះមិនមែនជាសព្វញ្ញូទេ ធម៌មិនមែនព្រះសាស្តាសំដែងដោយប្រពៃទេ គណៈមិនមែនប្រតិបត្តិដោយប្រពៃទេ ទិដ្ឋិមិនមែនល្អទេ បដិបទាមិនមែនសាស្តានោះ បញ្ញត្តដោយប្រពៃទេ មគ្គមិនមែនជាទីស្រោចស្រង់សត្វទេ សេចក្តីស្អាតក្តី ការស្អាតវិសេសក្តី ការរួចក្តី ការរួចដោយវិសេសក្តី ការរួចស្រឡះក្តី មិនមានក្នុងលទ្ធិនុ៎ះទេ ជនទាំងឡាយស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះក្នុងលទ្ធិនុ៎ះមិនមានទេ ជនទាំងឡាយនោះជាអ្នកថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់តិចតួច បុគ្គលដទៃឲ្យលះបង់យ៉ាងនេះឯង ។ បុគ្គលនោះកាលត្រូវគេឲ្យលះបង់យ៉ាងនេះ ក៏ឃ្លាតចាកសាស្តា ឃ្លាតចាកធម៌ដែលសាស្តាពោល ឃ្លាតចាកគណៈ ឃ្លាតចាកទិដ្ឋិ ឃ្លាតចាកបដិបទា ឃ្លាតចាកមគ្គ បុគ្គលឃ្លាតដោយការលះបង់ ព្រោះបុគ្គលដទៃយ៉ាងនេះ ។

បុគ្គលកាលមិនសម្រេចហើយឃ្លាត តើដូចម្តេច ។ បុគ្គលកាលមិនញុំាងសីលឲ្យសម្រេច ឈ្មោះថាឃ្លាតចាកសីល មិនញុំាងវត្តឲ្យសម្រេចឈ្មោះថាឃ្លាតចាកវត្ត មិនញុំាងសីលនិងវត្តឲ្យសម្រេចឈ្មោះថាឃ្លាតចាកសីលនិងវត្ត បុគ្គលកាលមិនសម្រេចហើយឃ្លាតយ៉ាងនេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា )

បើបុគ្គលណាឃ្លាតចាកសីលនិងវត្តហើយ ។

[ ៣០៣ ] អធិប្បាយពាក្យថា បុគ្គលនោះរមែងញាប់ញ័រ ព្រោះភ្លាត់ចាកកម្ម ត្រង់ពាក្យថា បុគ្គលនោះរមែងញាប់ញ័រ គឺបុគ្គលនោះរមែងញាប់ញ័រ ញាប់ញ័រខ្លាំង ញាប់ញ័រចំប្រប់ថា សីលក្តី វត្តក្តី សីលនិងវត្តក្តី អាត្មាអញខុសហើយ អាត្មាអញប្រាសចេញហើយ អាត្មាអញភ្លាំងភ្លាត់ហើយ អាត្មាអញឃ្លៀងឃ្លាតហើយ អាត្មាអញប្រាសចាកអរហត្តផលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះរមែងញាប់ញ័រ ។ ពាក្យថា ព្រោះភ្លាត់ចាកកម្ម គឺបុគ្គលនោះរមែងញាប់ញ័រ ញាប់ញ័រខ្លាំង ញាប់ញ័រចំប្រប់ថា បុញ្ញាភិសង្ខារក្តី អបុញ្ញាភិសង្ខារក្តី អានេញ្ជាភិសង្ខារក្តី អាត្មាអញខុសហើយ អាត្មាអញប្រាសចេញហើយ អាត្មាអញភ្លាំងភ្លាត់ហើយ អាត្មាអញឃ្លៀងឃ្លាតហើយ អាត្មាអញប្រាសចាកអរហត្តផលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះរមែងញាប់ញ័រ ព្រោះភ្លាត់ចាកកម្ម ។

[ ៣០៤ ] ពាក្យថា បុគ្គលនោះឯងតែងចង់បានផង ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធ ត្រង់ពាក្យថា បុគ្គលនោះចង់បាន គឺចង់បានសីល ចង់បានវត្ត ចង់បាន ចង់បានខ្លាំង ចង់បានណាស់នូវសីលនិងវត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះរមែងចង់បាន ។ ពាក្យថា ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធ គឺប្រាថ្នានូវសេចក្តីបរិសុទ្ធនៃសីល ប្រាថ្នានូវសេចក្តីបរិសុទ្ធនៃវត្ត ប្រាថ្នា ស្រឡាញ់ ចង់បានណាស់ នូវសេចក្តីបរិសុទ្ធនៃសីលនិងវត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះឯងតែងចង់បានផង ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធ ។

[ ៣០៥ ] ពាក្យថា ( ដូច ) បុគ្គលឃ្លាតចាកផ្ទះ ហើយសាបសូន្យចាកពួក សេចក្តីថា បុរសចេញអំពីផ្ទះនៅជាមួយនឹងពួក ឃ្លាតពួកហើយរមែងទៅតាមពួកនោះ ឬត្រឡប់មកកាន់ផ្ទះខ្លួនវិញយ៉ាងណា បុគ្គលអ្នកលុះក្នុងទិដ្ឋិនោះរមែងប្រកាន់សាស្តានោះ ឬប្រកាន់សាស្តាដទៃ ប្រកាន់ធម៌ដែលសាស្តាពោលហើយនោះ ឬប្រកាន់ធម៌ដទៃដែលសាស្តាពោលហើយ ប្រកាន់គណៈនោះ ឬប្រកាន់គណៈដទៃ ប្រកាន់ទិដ្ឋិនោះ ឬប្រកាន់ទិដ្ឋិដទៃ ប្រកាន់បដិបទានោះ ឬប្រកាន់បដិបទាដទៃ ប្រកាន់មគ្គនោះ ឬប្រកាន់ ស្ទាបអង្អែល ប្រកាន់ ស្អិតនូវមគ្គដទៃក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ( ដូច ) បុគ្គលឃ្លាតចាកផ្ទះ ហើយសាបសូន្យចាកពួក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលណាឃ្លាតចាកសីលនិងវត្តហើយ បុគ្គលនោះឯងរមែង
ញាប់ញ័រ ព្រោះភ្លាត់ចាកកម្ម បុគ្គលនោះរមែងចង់បានផង
ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធ ដូចបុគ្គលឃ្លាតចាកផ្ទះហើយសាប
សូន្យចាកពួក ។

[ ៣០៦ ] បុគ្គលលះបង់នូវសីលនិងវត្តទាំងអស់ផង នូវកម្មដែលមានទោសនិងមិនមានទោសនុ៎ះផង មិនប្រាថ្នានូវសេចក្តីបរិសុទ្ធនិងសេចក្តីមិនបរិសុទ្ធផង គប្បីប្រព្រឹត្តវៀរ មិនប្រកាន់នូវសេចក្តីស្ងប់ ។

[ ៣០៧ ] ពាក្យថា បុគ្គលលះបង់នូវសីលនិងវត្តទាំងអស់ គឺបុគ្គលលះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាសដល់ការមិនកើតមាននូវសេចក្តីបរិសុទ្ធនៃសីលទាំងអស់ លះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាសដល់ការមិនកើត

មានទូវសេចក្ដីបរិសុទ្ធនៃវត្តទាំងអស់ លះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាសដល់ការមិនកើតមាន នូវសេចក្ដីបរិសុទ្ធនៃសីលនិងវត្តទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលលះបង់នូវសីលនិងវត្តទាំងអស់ ។

[ ៣០៨ ] ពាក្យថា នូវកម្មដែលមានទោសនិងមិនមានទោសទុំះផង សេចក្ដីថា អំពើខ្មៅឲ្យផលខ្មៅ លោកហៅថាកម្មមានទោស ។ អំពើសឲ្យផលសលោកហៅថាកម្មមិនមានទោស ។ ( បុគ្គល ) លះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាសដល់ការមិនកើតមាន នូវកម្មមានទោសផង កម្មមិនមានទោសផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) នូវកម្មដែលមានទោសនិងមិនមានទោសទុំះផង ។

[ ៣០៩ ] ពាក្យថា មិនប្រាថ្នាសេចក្ដីបរិសុទ្ធនិងសេចក្ដីមិនបរិសុទ្ធ អធិប្បាយថា ពួកបុថុជ្ជនតែងប្រាថ្នាសេចក្ដីមិនបរិសុទ្ធ ប្រាថ្នាអកុសលធម៌ ប្រាថ្នាសេចក្ដីបរិសុទ្ធ ប្រាថ្នាកាមគុណ ៥ ប្រាថ្នាសេចក្ដីមិនបរិសុទ្ធ ប្រាថ្នាអកុសលធម៌ ប្រាថ្នាកាមគុណ ៥ ប្រាថ្នាសេចក្ដីបរិសុទ្ធ ប្រាថ្នាទិដ្ឋិ ៦២ ប្រាថ្នាសេចក្ដីមិនបរិសុទ្ធ ប្រាថ្នាអកុសលធម៌ ប្រាថ្នាកាមគុណ ៥ ប្រាថ្នាទិដ្ឋិ ៦២ ប្រាថ្នាសេចក្ដីបរិសុទ្ធ ប្រាថ្នាកុសលធម៌ក្នុងត្រៃធាតុ ប្រាថ្នាសេចក្ដីមិនបរិសុទ្ធ ប្រាថ្នាអកុសលធម៌ ប្រាថ្នាកាមគុណ ៥ ប្រាថ្នាទិដ្ឋិ ៦២ ប្រាថ្នាកុសលធម៌ក្នុងត្រៃធាតុ ប្រាថ្នាសេចក្ដីបរិសុទ្ធ ឯកល្យាណបុថុជ្ជនប្រាថ្នាការយានចុះកាន់និយាមៈ សេក្ខបុគ្គលប្រាថ្នាអរហត្តជាធម៌ប្រសើរ ។ កាលបើដល់ព្រះអរហត្តហើយ ព្រះអរហន្តមិនប្រាថ្នាអកុសលធម៌ មិនប្រាថ្នាកាមគុណ ៥ មិនប្រាថ្នាទិដ្ឋិ ៦២ មិនប្រាថ្នាកុសលធម៌ក្នុងត្រៃធាតុ មិនប្រាថ្នាការយានចុះកាន់និយាមៈ

មិនប្រាថ្នា ព្រះអរហត្តជាធម៌ដ៏ប្រសើរ ។ ព្រះអរហន្តកាលកន្លងសេចក្ដីប្រាថ្នា ឈ្មោះថា កន្លងផុតសេចក្ដីចម្រើននិងសេចក្ដីសាបសូន្យ ។ ព្រះអរហន្តនោះ មានអរិយវាសនៅរួចហើយ មានការប្រព្រឹត្តសន្សំហើយ ។បេ។ ភពថ្មីនៃព្រះ អរហន្តនោះមិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រាថ្នានូវសេចក្ដីបរិសុទ្ធ និងសេចក្ដីមិនបរិសុទ្ធ ។

[ ៣១០ ] អធិប្បាយពាក្យថា គប្បីប្រព្រឹត្តវៀរ មិនប្រកាន់សេចក្ដីស្ងប់ ត្រង់ពាក្យថា វៀរ គឺវៀរទូទៅ វៀរស្រឡះ វៀរចំពោះ ឃ្លាតចេញ រលាស់ចេញរួចស្រឡះប្រកបប្រាសចាកសេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធរមែងនៅដោយ ចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) វៀរ ។ ពាក្យថា គប្បីប្រព្រឹត្ត គឺគប្បីត្រាច់ទៅ គប្បីត្រាច់ទៅផ្សេងៗ គប្បីញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ គប្បីញុំាងការប្រព្រឹត្តឥរិយាបថឲ្យកើត គប្បីរក្សាឥរិយាបថ គប្បីបំពេញឥរិយាបថ គប្បីបង្គ្រប់ឥរិយាបថ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីប្រព្រឹត្តវៀរ ។ ពាក្យថា មិនប្រកាន់សេចក្ដីស្ងប់ សេចក្ដីថា ទិដ្ឋិ ៦២ លោកហៅថាសេចក្ដីស្ងប់ ។ បុគ្គលមិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវសេចក្ដីស្ងប់ គឺទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីប្រព្រឹត្តវៀរ មិនប្រកាន់សេចក្ដីស្ងប់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលលះបង់នូវសីលនិងវត្តទាំងអស់ផង នូវកម្មដែលមាន
ទោសនិងមិនមានទោសនុ៎ះផង មិនប្រាថ្នា សេចក្ដីបរិសុទ្ធនិង
សេចក្ដីមិនបរិសុទ្ធផង គប្បីប្រព្រឹត្តវៀរ មិនប្រកាន់សេចក្ដី

ស្ងប់ ។

[ ៣១១ ] ពួកសមណព្រាហ្មណ៍ ជាឧទ្ធំសភាវៈ មានតណ្ហាមិនទាន់ទៅប្រាសក្នុងភពតូចភពធំទាំងឡាយ អាស្រ័យនូវសេចក្តីខ្ពើម ( បាប ) នោះ ឬអាស្រ័យនូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយរមែងពោលសេចក្តីបរិសុទ្ធ ។

[ ៣១២ ] ពាក្យថា អាស្រ័យសេចក្តីខ្ពើម ( បាប ) នោះ គឺមានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកមានវាទៈថាខ្ពើមបាបដោយតបៈ ជាអ្នកមានការខ្ពើមបាបដោយតបៈជាខ្លឹម អាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរកចុះចិត្តស៊ប់ ឱនទៅរកនូវការខ្ពើមបាបដោយតប ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាស្រ័យសេចក្តីខ្ពើម ( បាប ) នោះ ។

[ ៣១៣ ] ពាក្យថា នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ គឺអាស្រ័យ ចូលទៅអាស្រ័យ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត នូវអារម្មណ៍ដែលខ្លួនឃើញហើយ ឬនូវសេចក្តីបរិសុទ្ធ ព្រោះឃើញនូវអារម្មណ៍ដែលឮហើយ ឬនូវសេចក្តីបរិសុទ្ធ ព្រោះឮនូវអារម្មណ៍ដែលប៉ះពាល់ហើយ ឬនូវសេចក្តីបរិសុទ្ធព្រោះប៉ះពាល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នូវអារម្មណ៍ដែលខ្លួនឃើញហើយ ឮ ឬប៉ះពាល់ហើយ ។

[ ៣១៤ ] ពាក្យថា ជាឧទ្ធំសភាវៈ រមែងពោលសេចក្តីបរិសុទ្ធ គឺមានសមណព្រាហ្មណ៍ពួកមួយជាឧទ្ធំសភាវៈ ។ សមណព្រាហ្មណ៍ជាឧទ្ធំសភាវៈតើដូចម្តេច ។ សមណព្រាហ្មណ៍ណាជាពួកប្រកាន់អច្ចន្តសុទ្ធិ ប្រកាន់សង្សារ

សុទ្ធិ ជាអកិរិយទិដ្ឋិ ជាសស្សតវាទ សមណព្រាហ្មណ៍ទាំងនេះ ឈ្មោះថា ឧទ្ធំសភាវាទ ។ សមណព្រាហ្មណ៍ទាំងនោះតែងសរសើរ ពោលសម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ រួចវិសេស រួចស្រឡះ ព្រោះសង្សារ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាឧទ្ធំសភាវាទ រមែងពោលសេចក្តីបរិសុទ្ធ ។

[ ៣១៥ ] ពាក្យថា មានតណ្ហាមិនទាន់ទៅប្រាសក្នុងភពតូចភពធំទាំងឡាយ ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ក្នុងភពតូចភពធំទាំងឡាយ គឺក្នុងកម្មភព បុនព្ភព ឈ្មោះថា ភពតូចភពធំ គឺថាក្នុងកាមភពឈ្មោះកម្មភព ក្នុងកាមភពឈ្មោះបុនព្ភព ក្នុងរូបភពឈ្មោះកម្មភព ក្នុងរូបភពឈ្មោះបុនព្ភព ក្នុងអរូបភពឈ្មោះកម្មភព ក្នុងអរូបភពឈ្មោះបុនព្ភព ក្នុងការកើតរឿយៗ ក្នុងការទៅរឿយៗ ក្នុងឧបបត្តិរឿយៗ ក្នុងបដិសន្ធិរឿយៗ ក្នុងការកើតចំពោះនៃអត្តភាពរឿយៗ ។ ពាក្យថា មានតណ្ហាមិនទាន់ទៅប្រាស គឺមិនទាន់ប្រាសចាកតណ្ហា មិនទាន់ឃ្លាតចេញចាកតណ្ហា មិនទាន់លះតណ្ហា មិនទាន់ខ្ជាក់ចោលតណ្ហា មិនទាន់រួចចាកតណ្ហា មិនទាន់លះបង់តណ្ហា មិនទាន់រលាស់ចោលតណ្ហា ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានតណ្ហាមិនទាន់ទៅប្រាស ក្នុងភពតូចភពធំទាំងឡាយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ពួកសមណព្រាហ្មណ៍ ជាឧទ្ធំសភាវាទ មានតណ្ហាមិនទាន់ទៅ
ប្រាស ក្នុងភពតូចភពធំទាំងឡាយ អាស្រ័យនូវសេចក្តីខ្ពើម

( បាប ) នោះ ឬអាស្រ័យនូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬ ប៉ះពាល់ហើយរមែងពោលសេចក្ដីបរិសុទ្ធ ។

[ ៣១៦ ] ការជាប់ចិត្តទាំងឡាយនៃបុគ្គលកាលប្រាថ្នាក្ដី ការញាប់ញ័រក្នុងធម៌ទាំងឡាយដែលខ្លួនកំណត់ហើយក្ដី ការច្យុតនិងការកើតក្ដីនៃបុគ្គលណាមិនមានក្នុងលោកនេះ បុគ្គលនោះគប្បីញាប់ញ័រដោយកិលេសដូចម្ដេចកើត គប្បីជាប់ចិត្តក្នុងហេតុដូចម្ដេចកើត ។

[ ៣១៧ ] ពាក្យថា ការជាប់ចិត្តទាំងឡាយនៃបុគ្គលកាលប្រាថ្នា សេចក្ដីថា តណ្ហាលោកហៅសេចក្ដីប្រាថ្នា បានដល់ តម្រេក តម្រេកមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា កាលប្រាថ្នា គឺកាលត្រូវការ កាលចង់បាន កាលត្រេកអរ កាលស្រឡាញ់ កាលជាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលប្រាថ្នា ។ ពាក្យថា ការជាប់ចិត្តទាំងឡាយ សេចក្ដីថា តណ្ហាលោកហៅថាការជាប់ចិត្ត បានដល់ តម្រេក តម្រេកមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការជាប់ចិត្តទាំងឡាយនៃបុគ្គលកាលប្រាថ្នា ។

[ ៣១៨ ] ពាក្យថា ការញាប់ញ័រក្នុងធម៌ទាំងឡាយដែលខ្លួនកំណត់ទុកហើយក្ដី ពាក្យថា ការកំណត់ បានដល់ ការកំណត់ ២ គឺការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះការកំណត់គឺទិដ្ឋិ ។ ជនទាំងឡាយមានសេចក្ដីរង្កៀស ក្នុងការដណ្ដើមយកនូវវត្ថុ រមែងញាប់ញ័រក៏មាន កាលវត្ថុដែលគេកំពុងដណ្ដើមរមែងញាប់ញ័រក៏មាន កាលវត្ថុ

ត្រូវគេជណ្តើមហើយរមែងញាប់ញ័រក៏មាន ជនទាំងឡាយមានសេចក្តីរង្កៀស ក្នុងការប្រែប្រួលនៃវត្ថុរមែងញាប់ញ័រក៏មាន កាលវត្ថុកំពុងប្រែប្រួល រមែងញាប់ញ័រក៏មាន កាលវត្ថុប្រែប្រួលហើយរមែងញាប់ញ័រ ញាប់ញ័រខ្លាំង ញាប់ញ័រចំប្រប់ក៏មាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការញាប់ញ័រក្នុងធម៌ទាំងឡាយដែលខ្លួនកំណត់ហើយក្តី ។

[ ៣១៩ ] ពាក្យថា ការច្យុតិនិងការកើតនៃបុគ្គលណាមិនមានក្នុងលោកនេះ ត្រង់ពាក្យថា នៃបុគ្គលណា សេចក្តីថា ការមក ការទៅ ការទៅនិងការមក មរណកាល ដំណើរ ភពតូចភពធំ ការច្យុតិ ការឧបបត្តិ ការកើតនិងការបែកធ្លាយ ជាតិ ជរា មរណៈ នៃព្រះអរហន្តខីណាស្រពមិនមាន គ្មាន ឥតមានសោះ មិនកើតមាន គឺលោកលះបង់ហើយ ផ្តាច់បង់ហើយ រម្ងាប់ហើយ គ្រប់សង្កត់ហើយ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការច្យុតិនិងការកើត នៃបុគ្គលណាមិនមានក្នុងលោកនេះ ។

[ ៣២០ ] ពាក្យថា បុគ្គលនោះគប្បីញាប់ញ័រដោយកិលេសដូចម្តេចកើត គប្បីជាប់ចិត្តក្នុងហេតុ ដូចម្តេចកើត អធិប្បាយថា បុគ្គលនោះគប្បីញាប់ញ័រដោយរាគៈដូចម្តេច គប្បីញាប់ញ័រដោយទោសៈដូចម្តេច គប្បីញាប់ញ័រដោយមោហៈដូចម្តេច គប្បីញាប់ញ័រដោយមានះដូចម្តេច គប្បីញាប់ញ័រដោយទិដ្ឋិដូចម្តេច គប្បីញាប់ញ័រដោយឧទ្ធច្ចៈដូចម្តេច គប្បីញាប់ញ័រដោយវិចិកិច្ឆាដូចម្តេច គប្បីញាប់ញ័រដោយអនុស័យដូចម្តេចកើត ថាបុគ្គលនោះជាអ្នកត្រេកអរ

ក្តី ថាជាអ្នកប្រទូស្តក្តី ថាជាអ្នកវង្វេងក្តី ថាជាអ្នកជាប់ចំពាក់ក្តី ថាជាអ្នកស្ទាប អង្អែលក្តី ថាជាអ្នកដល់នូវការវាយមាយក្តី ថាជាអ្នកដល់នូវសេចក្តីមិនដាច់ស្រេចក្តី ថាជាអ្នកដល់នូវកម្លាំងក្តី ។ អភិសង្ខារទាំងឡាយនោះ បុគ្គលនោះលះបង់ហើយ ព្រោះលះបង់អភិសង្ខាររួចហើយ លោកគប្បីញាប់ញ័រដោយហេតុដូចម្តេចព្រោះគតិថា អាត្មាអញកើតក្នុងនរកក្តី ថាកើតក្នុងកំណើតតិរច្ឆានក្តី ថាកើតក្នុងប្រេតវិស័យក្តី ថាកើតជាមនុស្សក្តី ថាកើតជាទេវតាក្តី ថាកើតជារូបព្រហ្មក្តី ថាកើតជាអរូបព្រហ្មក្តី ថាកើតជាសញ្ញីព្រហ្មក្តី ថាកើតជាអសញ្ញីព្រហ្មក្តី ថាកើតជានេវសញ្ញីនាសញ្ញីព្រហ្មក្តី ។ បុគ្គលនោះ គប្បីញាប់ញ័រ គប្បីញាប់ញ័រខ្លាំង គប្បីញាប់ញ័រចំប្រប់ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យនោះមិនមាន ការណ៍នោះមិនមាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះគប្បីញាប់ញ័រដោយកិលេសដូចម្តេច ។ ពាក្យថា គប្បីជាប់ចិត្តក្នុងហេតុដូចម្តេចកើត គឺគប្បីជាប់ចិត្ត គប្បីជាប់ចិត្តខ្លាំង គប្បីជាប់ចិត្តចំពោះក្នុងហេតុដូចម្តេចកើត ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះគប្បីញាប់ញ័រដោយកិលេសដូចម្តេចកើត គប្បីជាប់ចិត្តក្នុងហេតុដូចម្តេចកើត ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> ការជាប់ចិត្តទាំងឡាយនៃបុគ្គលកាលប្រាថ្នាក្តី ការញាប់ញ័រក្នុង
> ធម៌ទាំងឡាយដែលខ្លួនកំណត់ហើយក្តី ការច្យុតិនិងការកើតក្តី
> នៃបុគ្គលណាមិនមានក្នុងលោកនេះ បុគ្គលនោះគប្បីញាប់ញ័រ
> ដោយកិលេស ដូចម្តេចកើត គប្បីជាប់ចិត្ត ក្នុងហេតុដូចម្តេច

កើត ។

[ ៣២១ ] សមណព្រាហ្មណ៍ពួកមួយបានពោលធម៌ណាថាឧត្តម ចំណែកសមណព្រាហ្មណ៍ពួកដទៃ បានពោលធម៌នោះឯងថា ថោកទាប ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះតើពាក្យណាជាពាក្យពិត ព្រោះថាសមណព្រាហ្មណ៍ទាំងនេះជាអ្នកប្រកាន់ថា ឈ្លាសវៃទាំងអស់គ្នា ។

[ ៣២២ ] ពាក្យថា សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌ណាថាឧត្តម គឺសមណព្រាហ្មណ៍ពួកមួយ បានពោលយ៉ាងនេះ សម្តែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះនូវធម៌ គឺទិដ្ឋិ បដិបទា មគ្គណា ថានេះជាធម៌ដ៏ឧត្តម ខ្ពង់ខ្ពស់ ប្រសើរ ប្រសើរបំផុត ជាប្រធាន ថ្លៃថ្លា ប្រសើរក្រៃលែង ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌ណាថាឧត្តម ។

[ ៣២៣ ] ពាក្យថា ចំណែកសមណព្រាហ្មណ៍ពួកដទៃ បានពោលធម៌នោះឯងថាថោកទាប គឺសមណព្រាហ្មណ៍ពួកមួយបានពោលយ៉ាងនេះ សម្តែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះនូវធម៌ គឺទិដ្ឋិ បដិបទា មគ្គនោះឯងថាធម៌នេះថោកទាប ធម៌នេះថោកទាបពេក ធម៌នេះទន់ទាប ធម៌នេះលាមក ធម៌នេះអាក្រក់ ធម៌នេះស្តួចស្តើង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំណែកសមណព្រាហ្មណ៍ពួកដទៃ បានពោលធម៌នោះឯងថាថោកទាប ។

[ ៣២៤ ] ពាក្យថា ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើពាក្យណាជាពាក្យពិត គឺពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើពាក្យណាជាពាក្យពិត

ទៀនទាត់ មិនឃ្លៀនឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើពាក្យណាជាពាក្យពិត ។

[ ៣២៥ ] ពាក្យថា ព្រោះថាសមណព្រាហ្មណ៍ទាំងនេះប្រកាន់ថា ឈ្លាសវៃទាំងអស់គ្នា គឺសមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកមានវាទៈថាឈ្លាសវៃ មានវាទៈថាជាបណ្ឌិត មានវាទៈថាជាអ្នកប្រាជ្ញ មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយការណ៍ មានវាទៈប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថាសមណព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់ថាឈ្លាសវៃទាំងអស់គ្នា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សមណព្រាហ្មណ៍ពួកមួយបានពោលធម៌ណាថាឧត្តម ចំណែក
សមណព្រាហ្មណ៍ពួកដទៃបានពោលធម៌នោះឯង ថាថោកទាប
ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះតើពាក្យណាជាពាក្យពិត
ព្រោះថាសមណព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់ថាឈ្លាសវៃ
ទាំងអស់គ្នា ។

[ ៣២៦ ] សមណព្រាហ្មណ៍ទាំងឡាយបានពោលធម៌របស់ខ្លួន ថាបរិបូណ៌ បានពោលធម៌របស់ជនដទៃ ថាថោកថយ ( សមណព្រាហ្មណ៍ទាំងឡាយ ) ប្រកាន់យ៉ាងនេះរមែងទាស់ទែងគ្នា បានពោលនូវសម្មតិរបស់ខ្លួនៗថាពិត ។

[ ៣២៧ ] ពាក្យថា សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌របស់ខ្លួន ថាបរិបូណ៌ គឺសមណព្រាហ្មណ៍ពួកមួយ បានពោលយ៉ាងនេះ សម្តែងយ៉ាង

នេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះនូវធម៌ គឺទិដ្ឋិ បដិបទា មគ្គ របស់ខ្លួនថា ធម៌នេះពេញលេញ បរិបូណ៌ មិនថោកថយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ពួកមួយបានពោលធម៌របស់ខ្លួនថា បរិបូណ៌ ។

[ ៣២៨ ] ពាក្យថា បានពោលធម៌របស់ជនដទៃថាថោកថយ គឺសមណ-ព្រាហ្មណ៍ពួកមួយបានពោលយ៉ាងនេះ សម្តែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះនូវធម៌ គឺទិដ្ឋិ បដិបទា មគ្គរបស់ជនដទៃថា នេះថោកទាប នេះថោកទាបពេក នេះទន់ទាប នេះលាមក នេះអាក្រក់ នេះស្តួចស្តើង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានពោលធម៌របស់ជនដទៃថា ថោកទាប ។

[ ៣២៩ ] ពាក្យថា ប្រកាន់យ៉ាងនេះរមែងទាស់ទែងគ្នា គឺកាន់យក ប្រកាន់ស្ទាបអង្អែល ប្រកាន់ស្អិតយ៉ាងនេះ រមែងទាស់ទែងគ្នា គឺធ្វើនូវជម្លោះ ធ្វើនូវការប្រកាន់ ធ្វើនូវការទាស់ទែង ធ្វើនូវការវិវាទ ធ្វើនូវការបែកខ្ញែកគ្នាថា អ្នកមិនយល់ធម៌វិន័យនេះទេ ។បេ។ បើអ្នកអាចចូរអ្នកដោះចុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រកាន់យ៉ាងនេះរមែងទាស់ទែងគ្នា ។

[ ៣៣០ ] ពាក្យថា បានពោលនូវសម្មតិរបស់ខ្លួនៗ ថាពិត គឺថាលោកទៀង ។បេ។ សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានពោលនូវសម្មតិរបស់ខ្លួនៗថាពិត ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

( សមណព្រាហ្មណ៍ទាំងឡាយ ) បានពោលធម៌របស់ខ្លួនថា
បរិបូណ៌ បានពោលធម៌របស់ជនដទៃថាថោកថយ ( សមណ-

ព្រាហ្មណ៍ទាំងឡាយ ) ប្រកាន់យ៉ាងនេះរមែងទាស់ទែងគ្នា បាន ពោលនូវសម្មតិរបស់ខ្លួនៗថាពិត ។

[ ៣៣១ ] ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃបន្ទុះបង្អាប់ មិនមានបុគ្គលណាមួយវិសេសក្នុងធម៌ទាំងឡាយទេ ព្រោះថាបុគ្គលច្រើននាក់ ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន តែងពោលធម៌របស់ជនដទៃជាថោកទាប ។

[ ៣៣២ ] ពាក្យថា ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃបន្ទុះបង្អាប់ គឺប្រសិនបើបុគ្គលជាអ្នកផ្តេសផ្តាស ពាល ថោកថយ ថោកទាប ទន់ទាប លាមក អាក្រក់ ស្តួចស្តើង ព្រោះហេតុតែបុគ្គលដទៃបន្ទុះបង្អាប់ ព្រោះហេតុតែបុគ្គលដទៃនិន្ទា ព្រោះហេតុតែបុគ្គលដទៃតិះដៀល ព្រោះហេតុតែបុគ្គលដទៃជេរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃបន្ទុះបង្អាប់ ។

[ ៣៣៣ ] ពាក្យថា មិនមានបុគ្គលណាមួយវិសេស ក្នុងធម៌ទាំងឡាយ គឺមិនមានបុគ្គលណាមួយ ថ្លៃថ្នូរ ប្រសើរ វិសេស ជាប្រធាន ដ៏ឧត្តម ប្រសើរក្រៃលែង ក្នុងធម៌ទាំងឡាយទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមានបុគ្គលណាមួយវិសេសក្នុងធម៌ទាំងឡាយ ។

[ ៣៣៤ ] ពាក្យថា ព្រោះថាបុគ្គលច្រើននាក់ តែងពោលធម៌របស់ជនដទៃថា ថោកទាប គឺបុគ្គលច្រើននាក់ ពោលត្មះ និន្ទា តិះដៀលនូវធម៌របស់ជនច្រើននាក់ ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ ស្តួចស្តើង

ក៏មាន បុគ្គលច្រើននាក់ពោលត្មះ និន្ទា តិះដៀល នូវធម៌របស់ជនម្នាក់ថា ថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ ស្អួចស្អើងក៏មាន បុគ្គលម្នាក់ពោលត្មះ និន្ទា តិះដៀល នូវធម៌របស់ជនច្រើននាក់ ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ ស្អួចស្អើងក៏មាន បុគ្គលម្នាក់ពោលត្មះ និន្ទា តិះដៀលនូវធម៌របស់ជនម្នាក់ ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ ស្អួចស្អើងក៏មាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថាបុគ្គលច្រើននាក់តែងពោលធម៌របស់ជនដទៃ ថាថោកទាប ។

[ ៣៣៥ ] ពាក្យថា ជាអ្នកមានវាទៈដ៏មាំ ក្នុងផ្លូវរបស់ខ្លួន គឺធម៌ឈ្មោះថាផ្លូវរបស់ខ្លួន ទិដ្ឋិឈ្មោះថាផ្លូវរបស់ខ្លួន បដិបទាឈ្មោះថាផ្លូវរបស់ខ្លួន មគ្គឈ្មោះថាផ្លូវរបស់ខ្លួន ។ ជាអ្នកមានវាទៈដ៏មាំ មានវាទៈទៀងទាត់ មានវាទៈដ៏មានកម្លាំង មានវាទៈតាំងនៅស៊ប់ក្នុងផ្លូវរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃបន្ទះ-
បន្អាប់ មិនមានបុគ្គលណាមួយវិសេស ក្នុងធម៌ទាំងឡាយទេ
ព្រោះថាបុគ្គលច្រើននាក់ ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន
តែងពោលធម៌របស់ជនដទៃ ថាថោកទាប ។

[ ៣៣៦ ] ការបូជាធម៌របស់ខ្លួនជាការមានពិត ព្រោះថាតិរ្ថិយទាំងឡាយតែងសរសើរផ្លូវទាំងឡាយរបស់ខ្លួនបើវាទៈទាំងអស់គប្បីជាវាទៈពិតម្ល៉េះសម

សេចក្ដីបរិសុទ្ធនៃជនទាំងឡាយនោះមានប្រាកដ ។

[ ៣៣៧ ] អធិប្បាយពាក្យថា ការបូជាធម៌របស់ខ្លួនជាការមានពិត សំណួរថា ចុះការបូជាធម៌របស់ខ្លួនតើដូចម្ដេច ។ បុគ្គលធ្វើសក្ការៈ ធ្វើសេចក្ដី គោរព រាប់អាន បូជានូវសាស្ដារបស់ខ្លួនថា សាស្ដានេះជាសព្វញ្ញូ នេះឈ្មោះថា ការបូជាធម៌របស់ខ្លួន ។ ធ្វើសក្ការៈ ធ្វើសេចក្ដីគោរព រាប់អាន បូជានូវធម៌របស់ខ្លួន ដែលសាស្ដានោះពោលហើយ នូវគណៈរបស់ខ្លួន នូវទិដ្ឋិរបស់ខ្លួន នូវបដិបទារបស់ខ្លួន នូវមគ្គរបស់ខ្លួនថា មគ្គនេះជាទីស្រោចស្រង់ នេះឈ្មោះថា ការបូជាធម៌របស់ខ្លួន ។ ពាក្យថា ការបូជាធម៌របស់ខ្លួន ជាការមានពិត បានសេចក្ដីថា ការបូជាធម៌របស់ខ្លួនដោយប្រការដូច្នោះ ជាការបូជាមិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការបូជាធម៌របស់ខ្លួនជាការមានពិត ។

[ ៣៣៨ ] ពាក្យថា ព្រោះថាជនទាំងឡាយ តែងសរសើរនូវផ្លូវរបស់ខ្លួនទាំងឡាយ សេចក្ដីថា ធម៌ឈ្មោះថាផ្លូវរបស់ខ្លួន ទិដ្ឋិឈ្មោះថាផ្លូវរបស់ខ្លួន បដិបទាឈ្មោះថាផ្លូវរបស់ខ្លួន មគ្គឈ្មោះថាផ្លូវរបស់ខ្លួន ។ ជនទាំងឡាយតែងសរសើរ ស្ញើច កោត ពណ៌នានូវផ្លូវរបស់ខ្លួនទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថាជនទាំងឡាយ តែងសរសើរនូវផ្លូវរបស់ខ្លួន ។

[ ៣៣៩ ] ពាក្យថា បើវាទៈទាំងអស់គប្បីជាវាទៈពិត គឺបើវាទៈទាំងអស់ជាវាទៈពិត មិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើវាទៈទាំងអស់គប្បីជាវាទៈពិត ។

[ ៣៤០ ] ពាក្យថា ម៉្លេះសមសេចក្ដីបរិសុទ្ធនៃជនទាំងឡាយនោះ ( មាន ) ប្រាកដ គឺសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះនៃសមណព្រាហ្មណ៍ទាំងនោះ ( មាន ) ប្រាកដ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ម៉្លេះសមសេចក្ដីបរិសុទ្ធនៃជនទាំងឡាយនោះ ( មាន ) ប្រាកដ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ការបូជាធម៌របស់ខ្លួនជាការមានពិត ព្រោះថាតិរ្ថិយទាំងឡាយ
តែងសរសើរផ្លូវទាំងឡាយរបស់ខ្លួន បើវាទៈទាំងអស់គប្បីជា
វាទៈពិត ម៉្លេះសមសេចក្ដីបរិសុទ្ធនៃជនទាំងឡាយនោះ ( មាន )
ប្រាកដ ។

[ ៣៤១ ] ព្រាហ្មណ៍មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ ទាំងមិនមានការពិចារណាក្នុងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ព្រោះដំណើរនោះ ( ព្រាហ្មណ៍នោះ ) កន្លងផុតនូវវិវាទទាំងឡាយ មិនឃើញធម៌ដទៃ ថាប្រសើរសោះ ។

[ ៣៤២ ] អធិប្បាយពាក្យថា ព្រាហ្មណ៍មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ ត្រង់ពាក្យថា មិនមាន គឺជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ បានដល់បុគ្គលដ៏ប្រសើរ ព្រោះបន្សាត់បង់នូវធម៌ទាំង ៧ ។បេ។ ជាអ្នកមិនអាស្រ័យតណ្ហា ជាបុគ្គលនឹងនួន បុគ្គលនោះលោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ សេចក្ដីថា ភាពនៃញាណដែលបុគ្គលដទៃគប្បីណែនាំនៃព្រាហ្មណ៍មិនមាន គឺថាព្រាហ្មណ៍មិនមាន

បុគ្គលដទៃគួរណែនាំ មិនគប្បីជឿបុគ្គលដទៃ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់នឹងបុគ្គលដទៃ ជាអ្នកមិនវង្វេង ដឹងខ្លួន មានស្មារតី តែងដឹង តែងឃើញ ។ ភាពនៃញាណដែលបុគ្គលដទៃគប្បីណែនាំ នៃព្រាហ្មណ៍មិនមាន គឺថាព្រាហ្មណ៍មិនមានបុគ្គលដទៃគួរណែនាំ មិនគប្បីជឿបុគ្គលដទៃ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់នឹងបុគ្គលដទៃ ជាអ្នកមិនវង្វេង ដឹងខ្លួន មានស្មារតី តែងដឹង តែងឃើញថាសង្ខារទាំងពួងមិនទៀង ។ ថាសង្ខារទាំងពួងជាទុក្ខ ។បេ។ ភាពនៃញាណ ដែលបុគ្គលដទៃគប្បីណែនាំនៃព្រាហ្មណ៍មិនមាន គឺថាព្រាហ្មណ៍មិនមានបុគ្គលដទៃគួរណែនាំ មិនគប្បីជឿបុគ្គលដទៃ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់នឹងបុគ្គលដទៃ ជាអ្នកមិនវង្វេង ដឹងខ្លួន មានស្មារតី តែងដឹង តែងឃើញថារបស់ណាមួយមានការកើតឡើងជាធម្មតា របស់ទាំងអស់នោះតែងរលត់ទៅវិញជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍មិនមានញាណ ដែលបុគ្គលដទៃគប្បីណែនាំ ។

[ ៣៨៣ ] អធិប្បាយពាក្យថា ទាំងមិនមានការពិចារណាក្នុងធម៌ទាំងឡាយហើយកាន់យកព្រមទេ ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ពិចារណា គឺការពិនិត្យ ពិចារណា ជ្រើសរើស ថ្លឹង ត្រិះរិះ សម្តែងឲ្យច្បាស់ ធ្វើឲ្យប្រាកដ ហើយកាន់យកដោយប៉ែក កាន់យកដោយចំណែក កាន់យកថាប្រសើរ កាន់យកដោយអំណាចអវយវៈ កាន់យកដោយគំនរ កាន់យកដោយការប្រមូល គឺប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត ចុះចិត្តស៊ប់ បង្អោន

ទៅថានេះទៀងពិត មិនឃៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួលដូច្នេះ រមែងមិនមាន មិនមានព្រម មិនកើតមាន គឺលោកលះបង់ហើយ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងមិនមានការពិចារណា ក្នុងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ។

[ ៣៨៤ ] ពាក្យថា ព្រោះដំណើរនោះ ( ព្រាហ្មណ៍នោះ ) កន្លងផុត នូវវិវាទទាំងឡាយ ត្រង់ពាក្យថា ព្រោះដំណើរនោះ គឺព្រោះហេតុនោះ ព្រោះ ការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ព្រាហ្មណ៍ នោះកន្លងផុត កន្លងបង់ ឆ្លងផុត ឆ្លងស្រឡះនូវជម្លោះព្រោះទិដ្ឋិ នូវការប្រកាន់ ព្រោះទិដ្ឋិ នូវការទាស់ទែងព្រោះទិដ្ឋិ នូវការវិវាទព្រោះទិដ្ឋិ នូវការបែកខ្ញែកគ្នា ព្រោះទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះដំណើរនោះ ព្រាហ្មណ៍នោះ កន្លងផុតនូវវិវាទទាំងឡាយ ។

[ ៣៨៥ ] ពាក្យថា មិនឃើញធម៌ដទៃថាប្រសើរសោះ គឺមិនឃើញ មិន ប្រទះ មិនរមិលមើល មិនសម្លឹងមើល មិនពិចារណាឃើញនូវសាស្តាដទៃ នូវធម៌ដែលសាស្តាពោលហើយ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គធម៌ជា កំពូល ប្រសើរ វិសេស ជាប្រធាន ឧត្តម ប្រសើរក្រៃលែង ព្រោះវៀរចាក សតិប្បដ្ឋាន វៀរចាកសម្មប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាក ពលៈ វៀរចាកពោជ្ឈង្គ វៀរចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ ថា ) មិនឃើញធម៌ដទៃថាប្រសើរ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ ទាំងមិនមានការពិចារណា ក្នុងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ព្រោះដំណើរនោះ ( ព្រាហ្មណ៍នោះ ) កន្លងផុតនូវវិវាទទាំងឡាយ មិនឃើញធម៌ដទៃថាប្រសើរសោះ ។

[ ៣៨៦ ] សមណព្រាហ្មណ៍ពួកមួយយល់នូវសេចក្តីបរិសុទ្ធ ព្រោះការឃើញថា អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះ ពិតដូច្នោះមែន បើសមណព្រាហ្មណ៍ម្នាក់ឃើញ ( នូវសេចក្តីពិត ) ប្រយោជន៍អ្វីដោយការឃើញនោះរបស់សមណព្រាហ្មណ៍ម្នាក់នោះសមណព្រាហ្មណ៍ទាំងឡាយកន្លងចោលនូវសេចក្តីបរិសុទ្ធ រមែងពោលដោយហេតុដទៃ ។

[ ៣៨៧ ] អធិប្បាយពាក្យថា អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះពិតដូច្នោះមែន ត្រង់ពាក្យថា អាត្មាអញដឹង គឺអាត្មាអញដឹងដោយបរចិត្តញ្ញាណ ឬដឹងដោយបុព្វេនិវាសានុស្សតិញ្ញាណ ។ ពាក្យថា អាត្មាអញឃើញ គឺអាត្មាអញឃើញដោយមំសចក្ខុ ឬឃើញដោយទិព្វចក្ខុ ។ ពាក្យថា ដំណើរនេះពិតដូច្នោះមែន គឺដំណើរនេះពិត មិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះពិតដូច្នោះមែន ។

[ ៣៨៨ ] ពាក្យថា សមណព្រាហ្មណ៍ពួកមួយ យល់នូវសេចក្តីបរិសុទ្ធដោយការឃើញ សេចក្តីថា សមណព្រាហ្មណ៍ពួកមួយ យល់នូវការស្អាតស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះដោយការឃើញ ។ គឺ

ថាសមណព្រាហ្មណ៍ពួកមួយ យល់នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះដោយការឃើញថាលោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ សមណព្រាហ្មណ៍ពួកមួយ យល់នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះដោយការឃើញថាលោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ពួកមួយ យល់នូវសេចក្តីបរិសុទ្ធដោយការឃើញ ។

[ ៣៤៩ ] អធិប្បាយពាក្យថា បើសមណព្រាហ្មណ៍ម្នាក់ឃើញ ( នូវសេចក្តីពិត ) ប្រយោជន៍អ្វីដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់នោះ ត្រង់ពាក្យថា បើសមណព្រាហ្មណ៍ម្នាក់ឃើញ គឺឃើញដោយបរចិត្តញ្ញាណ ឬឃើញដោយបុព្វេនិវាសានុស្សតិញ្ញាណ ឃើញដោយមំសចក្ខុ ឬឃើញដោយទិព្វចក្ខុ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើសមណព្រាហ្មណ៍ម្នាក់ឃើញ ( នូវសេចក្តីពិត ) ។ ពាក្យថា ប្រយោជន៍អ្វី ដោយការឃើញនោះរបស់សមណព្រាហ្មណ៍ម្នាក់នោះ គឺប្រយោជន៍អ្វី ដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់នោះ គឺថាការកំណត់ទុក្ខមានដូចម្តេចកើត ការលះបង់សមុទ័យមិនមាន ការចម្រើនមគ្គមិនមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន ការលះបង់រាគៈដោយសមុច្ឆេទមិនមាន ការលះបង់ទោសៈដោយសមុច្ឆេទមិនមាន ការលះបង់មោហៈដោយសមុច្ឆេទមិនមាន ការលះបង់កិលេសទាំងឡាយដោយសមុច្ឆេទមិនមាន ការផ្តាច់ផ្តិលសង្សារវដ្តក៏មិនមាន ហេតុនោះ ( ទ្រង់

ត្រាស់ថា ) បើសមណព្រាហ្មណ៍ម្នាក់ឃើញ ( នូវសេចក្ដីពិត ) ប្រយោជន៍អ្វីដោយការឃើញនោះរបស់សមណព្រាហ្មណ៍ម្នាក់នោះ ។

[ ៣៥០ ] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ កន្លងចោលនូវសេចក្ដីបរិសុទ្ធ រមែងពោលដោយហេតុដទៃ សេចក្ដីថា សមណព្រាហ្មណ៍ទាំងនោះ កន្លង រំលង កន្លងចោលនូវមគ្គដ៏ស្អាត មគ្គស្អាតវិសេស មគ្គបរិសុទ្ធិ មគ្គផូរផង់ មគ្គផូរផង់ក្រៃលែងដោយទិដ្ឋិ គឺវៀរចាកសតិប្បដ្ឋាន វៀរចាកសម្ម-ប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គ វៀរចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហើយពោល សម្ដែង ពណ៌នា បំភ្លឺ ថ្លែងនូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កន្លងចោលនូវសេចក្ដីបរិសុទ្ធ រមែងពោលដោយហេតុដទៃយ៉ាងនេះខ្លះ ។ម្យ៉ាងទៀតព្រះពុទ្ធទាំងឡាយក្ដី សាវ័ករបស់ព្រះពុទ្ធទាំងឡាយក្ដី ព្រះបច្ចេកពុទ្ធទាំងឡាយក្ដី កន្លង រំលង កន្លងចោលនូវមគ្គមិនស្អាត មគ្គមិនស្អាតវិសេស មគ្គមិនបរិសុទ្ធ មគ្គមិនផូរផង់ មគ្គមិនផូរផង់ក្រៃលែងនៃទិដ្ឋិរបស់សមណព្រាហ្មណ៍ទាំងនោះ ហើយពោល សម្ដែង ពណ៌នា បំភ្លឺ ថ្លែងនូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សមណព្រាហ្មណ៍ទាំងឡាយកន្លងចោល រមែងពោលនូវសេចក្ដីបរិសុទ្ធដោយហេតុដទៃយ៉ាងនេះខ្លះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សមណព្រាហ្មណ៍ពួកមួយ យល់នូវសេចក្តីបរិសុទ្ធ ព្រោះការ
ឃើញថា អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះពិត
ដូច្នោះមែន បើសមណព្រាហ្មណ៍ម្នាក់ឃើញ ( នូវសេចក្តីពិត )
ប្រយោជន៍អ្វីដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់
នោះ សមណព្រាហ្មណ៍ទាំងឡាយ កន្លងចោលនូវសេចក្តីបរិ-
សុទ្ធ រមែងពោលដោយហេតុដទៃ ។

[ ៣៥១ ] នរជនកាលឃើញតែងឃើញនាមរូប លុះឃើញហើយរមែង
ដឹងនូវនាមរូបនោះឯង បុគ្គលឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន
ចំណែកអ្នកឈ្លាសទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធ ដោយការឃើញ
នោះទេ ។

[ ៣៥២ ] អធិប្បាយពាក្យថា នរជនកាលឃើញតែងឃើញនាមរូប ត្រង់
ពាក្យថា នរជនកាលឃើញ គឺកាលឃើញដោយបរចិត្តញ្ញាណក្តី ឃើញដោយ
បុព្វេនិវាសានុស្សតិញ្ញាណក្តី ឃើញដោយមំសចក្ខុក្តី ឃើញដោយទិព្វចក្ខុក្តី
គឺតែងឃើញនូវនាមរូបនោះឯង ថាទៀង ថាសុខ ថាខ្លួន តែមិនឃើញនូវការ
កើតឬការរលត់ អានិសង្សឬទោស ឬក៏ការរលាស់ចោលនូវធម៌ទាំងនោះទេ
ហេតុនោះ ( ទ្រង់ត្រាស់ថា ) នរជនកាលឃើញ តែងឃើញនាមរូប ។

[ ៣៥៣ ] ពាក្យថា លុះឃើញហើយ តែងដឹងនូវនាមរូបនុ៎ះឯង ត្រង់
ពាក្យថា គឺលុះឃើញហើយ គឺលុះឃើញហើយ ដោយបរចិត្តញ្ញាណក្តី លុះ
ឃើញហើយ ដោយបុព្វេនិវាសានុស្សតិញ្ញាណក្តី លុះឃើញហើយ ដោយមំស

ចក្ខុក្តី លុះឃើញហើយ ដោយទិព្វចក្ខុក្តី លុះឃើញហើយនូវនាមរូបនោះឯង តែងដឹងថាទៀង ថាសុខ ថាខ្លួន តែមិនដឹងនូវការកើតឬការរលត់ អានិសង្ស ឬទោស ឬក៏ការរលាស់ចោល នូវធម៌ទាំងនោះទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លុះឃើញហើយ តែងដឹងនូវនាមរូបនោះឯង ។

[ ៣៥៤ ] ពាក្យថា បុគ្គលឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន គឺឃើញកាមច្រើនក្តី នាមរូបតិចក្តី ថាទៀង ថាសុខ ថាខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន ។

[ ៣៥៥ ] អធិប្បាយពាក្យថា ចំណែកជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធ ដោយការឃើញនោះទេ ត្រង់ពាក្យថា ជនអ្នកឈ្លាស គឺជនណាជាអ្នកឈ្លាសក្នុងខន្ធ អ្នកឈ្លាសក្នុងធាតុ អ្នកឈ្លាសក្នុងអាយតនៈ អ្នកឈ្លាសក្នុងបដិច្ចសមុប្បាទ អ្នកឈ្លាសក្នុងសតិប្បដ្ឋាន អ្នកឈ្លាសក្នុងសម្មប្បធាន អ្នកឈ្លាសក្នុងឥទ្ធិបាទ អ្នកឈ្លាសក្នុងឥន្ទ្រិយ អ្នកឈ្លាសក្នុងពលៈ អ្នកឈ្លាសក្នុងពោជ្ឈង្គៈ អ្នកឈ្លាសក្នុងមគ្គ អ្នកឈ្លាសក្នុងផល អ្នកឈ្លាសក្នុងព្រះនិព្វាន ជនអ្នកឈ្លាសទាំងនោះ រមែងមិនពោល មិនសម្តែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួចរួចវិសេស រួចស្រឡះ ដោយការឃើញនាមរូប ដោយបរចិត្តញាណក្តី ដោយបុព្វេនិវាសានុស្សតិញ្ញាណក្តី ដោយមំសចក្ខុក្តី ដោយទិព្វចក្ខុក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចំណែកជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធ ដោយការឃើញនោះទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

នវជនកាលឃើញ តែងឃើញនាមរូប លុះឃើញហើយរមែង
ដឹងនូវនាមរូបនោះឯង បុគ្គលឃើញកាមច្រើនក៏មាន ឃើញ
នាមរូបតិចក៏មាន ចំណែកជនអ្នកឈ្លាសទាំងឡាយ មិនពោល
នូវសេចក្តីបរិសុទ្ធដោយការឃើញនោះទេ ។

[ ៣៥៦ ] បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន បុគ្គលនោះអាស្រ័យសភាវៈណាជាអ្នកពោលថាល្អ ពោលថាបរិសុទ្ធិក្នុងសភាវៈនោះ ឃើញថាពិតក្នុងសភាវៈនោះ ។

[ ៣៥៧ ] ពាក្យថា បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ គឺជាអ្នកមានវាទៈតាំងនៅមាំថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ ជាអ្នកមានវាទៈតាំងនៅមាំថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ ពាក្យថា ដែលគេមិនអាចទូន្មានបានងាយ គឺបុគ្គលអ្នកមានវាទៈតាំងនៅមាំ គេទូន្មានបានដោយក្រ ឲ្យដឹងបានដោយក្រ ឲ្យយល់បានដោយក្រ ឲ្យឃើញបានដោយក្រ ឲ្យជ្រះថ្លាបានដោយក្រ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំដែលគេមិនអាចទូន្មានបានងាយ ។

[ ៣៥៨ ] ពាក្យថា អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន គឺប្រព្រឹត្តធ្វើឲ្យជាប្រមុខ ធ្វើឲ្យជាប្រធាននូវទិដ្ឋិដែលតែងតាំងហើយ តាក់តែងហើយ

តម្កល់ទុកហើយ គឺថាជាអ្នកមានទិដ្ឋិជាទង់ជ័យ មានទិដ្ឋិជាទង់ មានទិដ្ឋិជាអធិបតី ត្រូវទិដ្ឋិរួបរឹត ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកធ្វើនូវទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន ។

[ ៣៥៩ ] អធិប្បាយពាក្យថា អាស្រ័យនូវសភាវៈណា ជាអ្នកពោលថាល្អក្នុងសភាវៈនោះ ត្រង់ពាក្យថា អាស្រ័យនូវសភាវៈណា គឺអាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរក ជ្រុលជ្រប់ ឱនទៅរកនូវសាស្តា នូវធម៌ដែលសាស្តាពោលហើយ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាស្រ័យនូវសភាវៈណា ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីចូលចិត្តរបស់ខ្លួន ក្នុងការពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកពោលថាល្អ គឺជាអ្នកពោលថាល្អ ពោលថាស្អាត ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលប្រកបដោយញាណ ពោលប្រកបដោយហេតុ ពោលប្រកបដោយលក្ខណៈ ពោលប្រកបដោយការណ៍ ពោលប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាស្រ័យនូវសភាវៈណា ជាអ្នកពោលថាល្អក្នុងសភាវៈនោះ ។

[ ៣៦០ ] អធិប្បាយពាក្យថា បុគ្គលនោះជាអ្នកពោលថាបរិសុទ្ធិ ឃើញថាពិតក្នុងសភាវៈនោះ ត្រង់ពាក្យថា ជាអ្នកពោលថាបរិសុទ្ធិ គឺជាអ្នកពោលថាស្អាត ពោលថាស្អាតវិសេស ពោលថាបរិសុទ្ធិ ពោលថាផូរផង់ ពោលថាផូរផង់ក្រៃលែង ។ ឬថាជាអ្នកឃើញថាស្អាត ឃើញថាស្អាតវិសេស ឃើញថាបរិសុទ្ធិ ឃើញថាផូរផង់ ឃើញថាផូរផង់ក្រៃលែង ហេតុនោះ ( ទ្រង់ត្រាស់

ថា ) ពោលថាបរិសុទ្ធិ ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការចូលចិត្តរបស់ខ្លួន ក្នុងការពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា បុគ្គលនោះឃើញថាពិត គឺឃើញ មើលឃើញ យល់ចាក់ធ្លុះថាពិត មិនឃៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះជាអ្នកពោលថាបរិសុទ្ធិ ឃើញថាពិតក្នុងសភាវៈនោះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានឆាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន បុគ្គលនោះអាស្រ័យសភាវៈណាជាអ្នកពោលថាល្អ ពោលថាបរិសុទ្ធិក្នុងសភាវៈនោះ ឃើញថាពិតក្នុងសភាវៈនោះ ។

[ ៣៦១ ] ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណព្រោះព្រាហ្មណ៍នោះ ដឹងសម្មតិទាំងឡាយដែលកើតអំពីបុថុជ្ជន លោកព្រងើយកន្តើយនឹងទិដ្ឋិ ដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។

[ ៣៦២ ] អធិប្បាយពាក្យថា ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ ត្រង់ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់នូវធម៌ទាំង ៧ ។បេ។ ជាអ្នកមិនអាស្រ័យតណ្ហា ជាបុគ្គលនឹងនួន បុគ្គលនោះលោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ការកំណត់ បានដល់ ការកំណត់ ២ ការកំណត់ គឺតណ្ហា ១ ការ

កំណត់ គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះការកំណត់គឺទិដ្ឋិ ។ ញាណលោកហៅថា ការពិចារណា បានដល់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ពាក្យថា ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ គឺព្រាហ្មណ៍ពិចារណាហើយ ដឹងហើយ ថ្លឹងហើយ ត្រិះរិះហើយ ធ្វើឲ្យច្បាស់ហើយ ធ្វើឲ្យប្រាកដហើយ ថាសង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ ។បេ។ ពិចារណាហើយ ដឹងហើយ ថ្លឹងហើយ ត្រិះរិះហើយ ធ្វើឲ្យច្បាស់ហើយ ធ្វើឲ្យប្រាកដហើយថា របស់ណាមួយមានកិរិយាកើតឡើងជាធម្មតា របស់ទាំងអស់នោះមានសេចក្តីរលត់ទៅវិញជាធម្មតា រមែងមិនដល់ មិនចូលទៅជិត មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវការកំណត់គឺតណ្ហាក្តី នូវការកំណត់គឺទិដ្ឋិក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ ។

[ ៣៦៣ ] ពាក្យថា មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ សេចក្តីថាទិដ្ឋិ ៦២ បុគ្គលនោះបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន ក្ដួចយកទៅមិនបាន មិនមកមិនត្រឡប់មកកាន់ទិដ្ឋិនោះថា មានខ្លឹម ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនលុះក្នុងទិដ្ឋិ ។ ពាក្យថា ទាំងមិនមានផៅពង្សដោយញាណ គឺមិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវផៅពង្ស គឺតណ្ហាក្តី នូវផៅពង្ស គឺទិដ្ឋិក្តី ដោយសមាបត្តិញាណ ៨ ក្តី ដោយអភិញ្ញាញាណ ៥ ក្តី ដោយមិច្ឆា-

ញាណក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្ស ដោយញាណ ។

[ ៣៦៤ ] អធិប្បាយពាក្យថា ព្រាហ្មណ៍នោះដឹងសម្មតិទាំងឡាយដែល កើតអំពីបុថុជ្ជន ត្រង់ពាក្យថា ដឹង គឺដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដហើយ ថាសង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ ។បេ។ ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដហើយថា របស់ណាមួយមាន កិរិយាកើតឡើងជាធម្មតា របស់ទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះដឹង ។ ទិដ្ឋិ ៦២ លោកហៅ ថាសម្មតិ ។ ពាក្យថា ដែលកើតអំពីបុថុជ្ជន គឺសម្មតិទាំងនោះកើតអំពីបុថុជ្ជន ទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលកើតអំពីបុថុជ្ជន ។ ម្យ៉ាងទៀត សម្មតិទាំងនោះកើតអំពីជនផ្សេងៗ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលកើត អំពីបុថុជ្ជន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះដឹងថា សម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន ។

[ ៣៦៥ ] ពាក្យថា រមែងព្រងើយកន្តើយនិងទិដ្ឋិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ គឺជនទាំងឡាយដទៃ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតដោយ អំណាចតណ្ហា ដោយអំណាចទិដ្ឋិ ព្រះអរហន្តព្រងើយកន្តើយ មិនប្រកាន់ មិន ស្ទាបអង្អែល មិនប្រកាន់ស្អិត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រងើយកន្តើយ នឹងទិដ្ឋិ ដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការគំណត់ មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ ព្រោះព្រាហ្មណ៍នោះដឹងសម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន លោកព្រងើយកន្តើយនឹងទិដ្ឋិ ដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។

[ ៣៦៦ ] មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ កាលវិវាទទាំងឡាយកើតឡើងហើយ លោកជាអ្នកមិនលុះក្នុងពួក កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយ ជាអ្នកមិនប្រកាន់នូវលទ្ធិ ដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។

[ ៣៦៧ ] អធិប្បាយពាក្យថា មុនិក្នុងលោកនេះលះបង់នូវគន្ថៈទាំងឡាយ ត្រង់ពាក្យថា គន្ថៈ បានដល់ គន្ថៈ ៤ គឺអភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ហៅថាអភិជ្ឈាកាយគន្ថៈ ។ ការគុំគួន ការអាក់អន់ក្នុងវាទៈរបស់បុគ្គលដទៃ ហៅថាព្យាបាទកាយគន្ថៈ ។ បុគ្គលស្ទាបអង្អែលសីលឬវត្ត ឬក៏សីលវត្តរបស់ខ្លួន ហៅថាសីលព្វតបរាមាសកាយគន្ថៈ ។ សេចក្តីយល់ឃើញរបស់ខ្លួន ហៅថាឥទំសច្ចាភិនិវេសកាយគន្ថៈ ។ ពាក្យថា លះបង់ គឺបោះបង់ ឬលះបោលនូវគន្ថៈទាំងឡាយ ។ ឬថាស្រាយ ឬត្រដោះចេញ នូវគន្ថៈទាំងឡាយដែលចាក់ស្រែះ ក្រង ធ្វាក់ ពាក់ព័ន្ធ ពាក់មាំ ជាប់ ជំពាក់ ចងមាំ ចងជាប់ ។ ជនទាំងឡាយរុះរើ ធ្វើឲ្យខ្ទេចខ្ទីនូវវត្ថុ រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តីយ៉ាងណាមិញ មុនិបោះបង់ ឬលះបោលនូវគន្ថៈទាំងឡាយ ឬថាស្រាយ ឬ

ត្រដោះចេញនូវគន្ថៈទាំងឡាយដែលចាក់ស្រេះ ក្រង ច្នាក់ ពាក់ព័ន្ធ ជាប់មាំ ជាប់ជំពាក់ ចងមាំ ចងជាប់យ៉ាងនោះដែរ ។ ពាក្យថា មុនិ សេចក្តីថា ញាណ បញ្ញា ការដឹងច្បាស់ លោកហៅថាមោនៈ ។បេ។ មុនិនោះកន្លងនូវសំណាញ់ គឺកិលេសជាគ្រឿងចំពាក់ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។បេ។ ក្នុងមនុស្សលោកនេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិក្នុងលោកនេះលះបង់នូវគន្ថៈទាំងឡាយ ។

[ ៣៦៨ ] ពាក្យថា កាលវិវាទទាំងឡាយ ( កើតហើយ ) លោកជាអ្នកមិនលុះក្នុងពួក គឺកាលវិវាទទាំងឡាយកើតព្រមហើយ លេចឡើង លេចឡើងចំពោះ កើតប្រាកដ កាលដល់នូវឆន្ទាគតិ ដល់នូវទោសាគតិ ដល់នូវមោហាគតិ ដល់នូវភយាគតិ លោកក៏មិនដល់នូវឆន្ទាគតិ មិនដល់នូវទោសាគតិ មិនដល់នូវមោហាគតិ មិនដល់នូវភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺមិនត្រូវធម៌ជាពួកឲ្យទៅ នាំទៅ បន្សាត់ទៅ កួចយកទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលវិវាទទាំងឡាយ ( កើតហើយ ) លោកជាអ្នកមិនលុះក្នុងពួក ។

[ ៣៦៩ ] អធិប្បាយពាក្យថា កាលបើពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ត្រង់ពាក្យថា ជាអ្នកស្ងប់ គឺជាអ្នកស្ងប់ព្រោះស្ងប់រាគៈ ជាអ្នកស្ងប់ព្រោះស្ងប់ទោសៈ ជាអ្នកស្ងប់ព្រោះស្ងប់មោហៈ ។បេ។ ជា

អ្នកស្ងប់ រម្ងាប់ ស្ងប់ស្ងៀម រលត់ ស្ងប់រម្ងាប់ ព្រោះស្ងប់ រម្ងាប់ ស្ងប់ស្ងៀម រលាយ រលត់ ទៅប្រាស ស្ងប់រម្ងាប់នូវអកុសលាភិសង្ខារទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់ ។ ពាក្យថា កាលពួកជនមិនស្ងប់ គឺកាលពួកជនមិនស្ងប់ មិនរម្ងាប់ មិនស្ងប់ស្ងៀម មិនរលត់ មិនស្ងប់រម្ងាប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ។ ពាក្យថា លោកជាអ្នកព្រងើយកន្តើយ សេចក្តីថា ព្រះអរហន្តប្រកបដោយឆឡង្គុបេក្ខា ឃើញរូបដោយភ្នែក ជាអ្នកមានចិត្តមិនរីករាយ មានចិត្តមិនអាក់អន់ នៅព្រងើយ មានសតិសម្បជញ្ញៈ ។ ឮសំឡេងដោយត្រចៀក ។បេ។ ជាអ្នកអប់រំទូន្មានខ្លួនល្អ រង់ចាំតែមរណកាល ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ។

[ ៣៧០ ] ពាក្យថា ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃកំពុងប្រកាន់ គឺជនដទៃរមែងប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ព្រះអរហន្តតែងព្រងើយ មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមិនប្រកាន់នូវលទ្ធិដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ កាលវិវាទទាំងឡាយ ( កើតហើយ ) លោកជាអ្នកមិនលុះក្នុងពួក កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ជាអ្នក

មិនប្រកាន់នូវលទ្ធិដែលជនទាំងឡាយដទៃកំពុងប្រកាន់ ។

[ ៣៧១ ] អ្នកប្រាជ្ញនោះ លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី មិនដល់នូវឆន្ទាគតិ ជាអ្នកមិនមានវាទៈតាំងមាំ រួចស្រឡះចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ។

[ ៣៧២ ] ពាក្យថា លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាអតីត លោកហៅថា អាសវៈខាងដើម កិលេសណាប្រារព្ធសង្ខារទាំងឡាយជាអតីត ហើយកើតឡើង ( អ្នកប្រាជ្ញ ) លះបង់ លះចោល លះស្រឡះ លះផ្តាច់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេសទាំងនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់អាសវៈខាងដើម ។ ពាក្យថា មិនធ្វើអាសវៈថ្មី សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាបច្ចុប្បន្ន លោកហៅថា អាសវៈថ្មី ។ លោកមិនធ្វើឆន្ទៈ មិនធ្វើសេចក្តីស្រឡាញ់ មិនធ្វើតម្រេក មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ ព្រោះប្រារព្ធសង្ខារជាបច្ចុប្បន្ន ហេតុនោះ ( ទ្រង់ត្រាស់ថា ) លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី ។

[ ៣៧៣ ] អធិប្បាយពាក្យថា មិនដល់នូវឆន្ទាគតិ មិនមានវាទៈតាំងមាំ ត្រង់ពាក្យថា មិនដល់នូវឆន្ទាគតិ គឺមិនដល់នូវឆន្ទាគតិ មិនដល់នូវទោសាគតិ មិនដល់នូវមោហាគតិ មិនដល់នូវភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះ

ដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកឲ្យទៅ នាំទៅ បន្សាត់ទៅ កួចយកទៅទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនដល់នូវឆន្ទាគតិ ។ ពាក្យថា ជាអ្នកមិនមានវាទៈតាំងមាំ គឺជាអ្នកមិនមានវាទៈតាំងមាំថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ថាលោកមិនទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។បេ។ ជាអ្នកមិនមានវាទៈតាំងមាំថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមិនដល់នូវឆន្ទាគតិ មិនមានវាទៈតាំងមាំ ។

[ ៣៧៤ ] អ្នកប្រាជ្ញនោះ រួចស្រឡះចាកទិដ្ឋិទាំងឡាយ គឺទិដ្ឋិ ៦២ អ្នកប្រាជ្ញនោះលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ អ្នកប្រាជ្ញនោះរួចស្រឡះ ប្រាសចាកទិដ្ឋិទាំងឡាយ មានចិត្តប្រាសចាកដែន គឺកិលេស ។ ពាក្យថា អ្នកប្រាជ្ញ គឺអ្នកប្រាជ្ញបណ្ឌិត អ្នកមានប្រាជ្ញា មានកិរិយាដឹង មានញាណ មានប្រាជ្ញាច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញនោះរួចស្រឡះចាកទិដ្ឋិទាំងឡាយ ។

[ ៣៧៥ ] អធិប្បាយពាក្យថា ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ត្រង់ពាក្យថា ប្រឡាក់ បានដល់ការប្រឡាក់ ២ គឺការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។បេ។ នេះការប្រឡាក់គឺតណ្ហា ។បេ។ នេះការប្រឡាក់គឺទិដ្ឋិ ។ បុគ្គលនោះលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺ

ទិដ្ឋិ បុគ្គលនោះជាអ្នកមិនប្រឡាក់ ព្រោះលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ រមែងមិនប្រឡាក់ក្នុងអបាយលោក មិនប្រឡាក់ក្នុងមនុស្សលោក មិនប្រឡាក់ក្នុងទេវលោក មិនប្រឡាក់ក្នុងខន្ធលោក មិនប្រឡាក់ក្នុងធាតុលោក មិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅប្រឡាក់ក្នុងអាយតនលោក ជាអ្នកមិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅជិតប្រឡាក់ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ មិនប្រកប សម្រេចនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រឡាក់ក្នុងលោក ។ ពាក្យថា ជាអ្នកមិនតិះដៀលខ្លួនឯង សេចក្តីថា បុគ្គលរមែងតិះដៀលខ្លួនឯងដោយហេតុ ២ គឺអំពើដែលខ្លួនធ្វើហើយ ១ មិនធ្វើហើយ ១ ។ តិះដៀលខ្លួនឯងព្រោះអំពើដែលខ្លួនធ្វើហើយនិងមិនធ្វើហើយ តើដូចម្តេច ។ តិះដៀលខ្លួនឯងថា កាយទុច្ចរិតអញធ្វើហើយ កាយសុចរិតអញមិនបានធ្វើ តិះដៀលខ្លួនឯងថា វចីទុច្ចរិតអញធ្វើហើយ មនោទុច្ចរិតអញធ្វើហើយ បាណាតិបាតអញធ្វើហើយ ។បេ។ មិច្ឆាទិដ្ឋិអញធ្វើហើយ សម្មាទិដ្ឋិអញមិនបានធ្វើ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយនិងមិនធ្វើហើយ យ៉ាងនេះឯង ។ មួយ៉ាងទៀតតិះដៀលខ្លួនឯងថា អញមិនបានបំពេញក្នុងសីលទាំងឡាយ តិះដៀលខ្លួនឯងថា អញមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ថាអញមិនដឹងប្រមាណក្នុងភោជន ថាអញមិនប្រកបរឿយៗនូវការភ្ញាក់រឭក ថាអញមិនប្រកបដោយសតិនិងសម្បជញ្ញៈ ថាសតិប្បដ្ឋានទាំង ៤ អញមិនបានចម្រើន ថាសម្មប្បធាន ៤ អញមិនបានចម្រើន ថាឥទ្ធិបាទ ៤ អញមិនបានចម្រើន ថាឥន្ទ្រិយ ៥ អញ

មិនបានចម្រើន ជាពលៈ ៥ អញមិនបានចម្រើន ជាពោជ្ឈង្គ ៧ អញមិនបានចម្រើន ជាអដ្ឋង្គិកមគ្គដ៏ប្រសើរ អញមិនបានចម្រើន ជាទុក្ខអញមិនបានកំណត់ដឹង ជាទុក្ខសមុទ័យអញមិនបានលះបង់ ជាមគ្គអញមិនបានចម្រើន ជានិរោធអញមិនបានធ្វើឲ្យជាក់ច្បាស់ ។ តិះដៀលខ្លួនឯងព្រោះអំពើដែលខ្លួនធ្វើនិងមិនធ្វើហើយយ៉ាងនេះឯង ។ មិនធ្វើ មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះនូវអំពើដែលគួរតិះដៀលខ្លួនយ៉ាងនេះឈ្មោះថាជាអ្នកមិនតិះដៀលខ្លួនឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមិនតិះដៀលខ្លួនរមែងមិនប្រឡាក់ក្នុងលោក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

អ្នកប្រាជ្ញនោះលះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី មិន
ដល់នូវឆន្ទាគតិ ជាអ្នកមិនមានវាទៈតាំងមាំ រួចស្រឡះចាកទិដ្ឋិ
ទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ។

[ ៣៧៦ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) បុគ្គលនោះធ្វើសេនាណាមួយដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយឲ្យវិនាសក្នុងធម៌ទាំងពួង បុគ្គលនោះមានភារៈដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ។

[ ៣៧៧ ] ពាក្យថា បុគ្គលនោះធ្វើសេនាណាមួយដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយឲ្យវិនាសក្នុងធម៌ទាំងពួង អធិប្បាយថា មារសេនា លោកហៅថា សេនា ។ កាយទុច្ចរិតជាមារសេនា វចីទុច្ចរិតជាមារសេនា មនោទុច្ចរិតជាមារសេនា រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា

មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង ការអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ជាមារសេនា ។ សមដូចជាព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា

កាមទាំងឡាយជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរគេហៅថាសេនាទី ២ សេចក្តីស្រេកឃ្លានជាសេនាទី ៣ របស់អ្នក តណ្ហាគេហៅថាសេនាទី ៤ ថីនមិទ្ធៈជាសេនាទី ៥ របស់អ្នក សេចក្តីខ្លាចគេហៅថាសេនាទី ៦ វិចិកិច្ឆាជាសេនាទី ៧ របស់អ្នក ការលុបគុណគេ ការរឹងរូសជាសេនាទី ៨ របស់អ្នក លាភៈ សេចក្តីសរសើរ សក្ការៈ យសដែលបុគ្គលបានខុសហើយក្តី បុគ្គលលើកខ្លួនក្តី បុគ្គលបង្អាប់អ្នកដទៃក្តី ម្នាលមារ នុ៎ះជាសេនារបស់អ្នកដែលនាំមកនូវធម៌ខ្មៅ បុគ្គលមិនក្លៀវក្លាមិនឈ្នះនូវសេនានោះទេ បុគ្គលលុះឈ្នះនូវសេនានោះ ទើបបានសុខ ។

មារសេនាទាំងអស់ផង កិលេសជាទីទំនាស់ទាំងអស់ផងដែលបុគ្គលផ្ចាញ់ហើយ ទាំងធ្វើឲ្យចាញ់ហើយ បំបាត់បង់ រំលត់រំលាយ ក្នុងទីកំបាំងមុខដោយអរិយមគ្គ ៤ ក្នុងកាលណា ក្នុងកាលនោះ បុគ្គលនោះលោកហៅថា អ្នកធ្វើសេនាឲ្យវិនាស ។ បុគ្គលនោះជាអ្នកធ្វើសេនាឲ្យវិនាសក្នុងធម៌ដែលខ្លួនឃើញ ជាអ្នកធ្វើសេនាឲ្យវិនាស ក្នុងធម៌ដែលខ្លួនឮ ដែលប៉ះពាល់ ដែលដឹងច្បាស់

ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះជាអ្នកធ្វើសេនាណាមួយ ទាំងពួងដែល ខ្លួនឃើញ ឮ ឬប៉ះពាល់ហើយឲ្យវិនាសក្នុងធម៌ទាំងពួង ។

[ ៣៧៨ ] អធិប្បាយពាក្យថា បុគ្គលនោះមានភារៈដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ត្រង់ពាក្យថា ភារៈ បានដល់ភារៈ ៣ គឺខន្ធភារៈ ១ កិលេស ភារៈ ១ អភិសង្ខារភារៈ ១ ខន្ធភារៈ តើដូចម្ដេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណអំពីបដិសន្ធិ នេះខន្ធភារៈ ។ កិលេសភារៈ តើដូចម្ដេច ។ រាគៈ ទោសៈ មោហៈ ។បេ។ អកុសលាភិសង្ខារទាំងអស់ នេះកិលេសភារៈ ។ អភិសង្ខារភារៈ តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះអភិសង្ខារ-ភារៈ ។ ខន្ធភារៈ កិលេសភារៈនិងអភិសង្ខារភារៈ បុគ្គលលះបង់ហើយ ផ្ដាច់ បង់ឫសគល់ហើយ ធ្វើមិនឲ្យមានទីនៅ ដូចជាទីនៅនៃដើមត្នោត ដល់នូវការ មិនមាន មានការមិនកើតតទៅទៀតជាធម្មតាក្នុងកាលណា ( ក្នុងកាលនោះ ) បុគ្គលនោះលោកហៅថា អ្នកមានភារៈដាក់ចុះហើយ ជាអ្នកមានភារៈធ្លាក់ចុះ ទម្លាក់ភារៈចោល ជម្រុះភារៈចេញ ដាក់ភារៈចេញ មានភារៈស្ងប់រម្ងាប់ហើយ ។ ពាក្យថា ជាមុនិ សេចក្ដីថា ញាណ លោកហៅថាមោនៈ បានដល់ បញ្ញា ការដឹងច្បាស់ ការសន្សំ ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ព្រម ការចូលទៅកំណត់ ការកំណត់ចំពោះ ភាពជាអ្នកប្រាជ្ញ ភាពជាអ្នកឈ្លាស ភាពជាអ្នកមានប្រាជ្ញាល្អិត ភាពជាអ្នកចេះចែករំលែក ការគិត ការពិចារណា ប្រាជ្ញាដូចផែនដី ប្រាជ្ញាអាចកម្ចាត់បង់កិលេស ប្រាជ្ញាជាគ្រឿងត្រួតត្រា ការ ឃើញច្បាស់ ការដឹងព្រម បញ្ញាដូចជាជន្ទួញ បញ្ញាជាធំ បញ្ញាជាកម្លាំង បញ្ញា

ជាសស្ត្រាវុធ បញ្ញាដូចប្រាសាទ បញ្ញាជាពន្លឺ បញ្ញាជារស្មី បញ្ញាជាគ្រឿងបំភ្លឺ បញ្ញាជាកែវ ការមិនវង្វេង ការសន្សំធម៌ ការយល់ត្រូវ បុគ្គលអ្នកប្រកបដោយញាណនោះ ឈ្មោះថាមុនិ ជាអ្នកដល់នូវមោនៈ ។ មោនេយ្យៈមាន ៣ គឺកាយមោនេយ្យៈ ១ វចីមោនេយ្យៈ ១ មនោមោនេយ្យៈ ១ ។

កាយមោនេយ្យៈ តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ ប្រការឈ្មោះជាកាយមោនេយ្យៈ ។ កាយសុចរិត ៣ ប្រការ ឈ្មោះថាកាយមោនេយ្យៈ ។ ញាណមានកាយជាអារម្មណ៍ ឈ្មោះថាកាយមោនេយ្យៈ ការកំណត់ដឹងកាយឈ្មោះថាកាយមោនេយ្យៈ ។ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថាកាយមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងកាយ ឈ្មោះថាកាយមោនេយ្យៈ ។ ចតុត្ថជ្ឈានសមាបត្តិ ជាគ្រឿងរលត់កាយសង្ខារ ឈ្មោះថាកាយមោនេយ្យៈ ។ នេះកាយមោនេយ្យៈ ។

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះវចីទុច្ចរិត ៤ ប្រការ ឈ្មោះថាវចីមោនេយ្យៈ ។ វចីសុចរិត ៤ ប្រការ ឈ្មោះថាវចីមោនេយ្យៈ ។ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថាវចីមោនេយ្យៈ ។ ការកំណត់ដឹងដោយវាចា ឈ្មោះថាវចីមោនេយ្យៈ ។ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថាវចីមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថាវចីមោនេយ្យៈ ។ ទុតិយជ្ឈាន សមាបត្តិជាគ្រឿងរលត់វចីសង្ខារ ឈ្មោះថាវចីមោនេយ្យៈ ។ នេះវចីមោនេយ្យៈ ។

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ ប្រការ ឈ្មោះថាមនោមោនេយ្យៈ ។ មនោសុចរិត ៣ ប្រការ ឈ្មោះថាមនោមោនេយ្យៈ ។

ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថាមនោមោនេយ្យៈ ។ ការកំណត់ដោយចិត្ត ឈ្មោះថាមនោមោនេយ្យៈ ។ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថាមនោ-មោនេយ្យៈ ។ ការលះឆន្ទរាគក្នុងចិត្ត ឈ្មោះថាមនោមោនេយ្យៈ ។ សញ្ញាវេទ-យិតនិរោធសមាបត្តិ ជាគ្រឿងរលត់ចិត្តសង្ខារ ឈ្មោះថាមនោមោនេយ្យៈ ។ នេះមនោមោនេយ្យៈ ។

បណ្ឌិតទាំងឡាយពោលនូវអ្នកប្រាជ្ញផ្លូវកាយ អ្នកប្រាជ្ញផ្លូវវាចា អ្នកប្រាជ្ញផ្លូវចិត្ត អ្នកប្រាជ្ញមិនមានអាសវៈដែលបរិបូណ៌ដោយមោនេយ្យធម៌ ថាជាអ្នកលះបង់នូវបាបទាំងពួង ។ បណ្ឌិតទាំងឡាយពោលនូវអ្នកប្រាជ្ញផ្លូវកាយ អ្នកប្រាជ្ញផ្លូវវាចា អ្នកប្រាជ្ញផ្លូវចិត្ត អ្នកប្រាជ្ញមិនមានអាសវៈ ដែលបរិបូណ៌ដោយមោនេ-យ្យធម៌ ថាជាអ្នកលាងបាប ។

មុនិប្រកបដោយមោនេយ្យធម៌ទាំងនេះមាន ៦ ពួក គឺអាគារមុនិ អនា-គារមុនិ សេក្ខមុនិ អសេក្ខមុនិ បច្ចេកមុនិ មុនិមុនិ ។ ពួកអាគារមុនិ តើដូចម្តេច ។ ពួកគ្រហស្ថណាបានឃើញនូវបទ គឺព្រះនិព្វាន បានដឹងច្បាស់នូវសា-សនា ពួកនេះឈ្មោះអាគារមុនិ ។ ពួកអនាគារមុនិ តើដូចម្តេច ។ ពួកបព្វជិតណាបានឃើញនូវបទ គឺព្រះនិព្វាន បានដឹងច្បាស់នូវសាសនា ពួកនេះឈ្មោះអនាគារមុនិ ។ សេក្ខបុគ្គល ៧ ពួក ឈ្មោះសេក្ខមុនិ ។ ពួកព្រះអរហន្តឈ្មោះអសេក្ខមុនិ ។ ពួកព្រះបច្ចេកពុទ្ធ ឈ្មោះបច្ចេកមុនិ ។ ព្រះតថាគតទាំងឡាយជាអរហន្តសម្មាសម្ពុទ្ធ ឈ្មោះមុនិមុនិ ។

បុគ្គលមានសភាពជាអ្នកវង្វេង មិនមានការចេះដឹង មិនមែនឈ្មោះថាមុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណាជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ ហើយវៀរបង់នូវបាបទាំងឡាយ ដូចបុគ្គលផ្គងនូវជញ្ជីង ( ហើយថ្លឹង ) បុគ្គលនោះឈ្មោះថា មុនិ បុគ្គលនោះឈ្មោះថាមុនិ ដោយហេតុនោះ បុគ្គលណាដឹងនូវប្រយោជន៍ទាំងពីរក្នុងលោក បុគ្គលនោះ ទើបតថាគតហៅថា មុនិដោយហេតុនោះ បុគ្គលណា ដឹងធម៌របស់ពួកអសប្បុរសផង របស់ពួកសប្បុរសផង ទាំងខាងក្នុងទាំងខាងក្រៅ ក្នុងលោកទាំងអស់ ជាបុគ្គលដែលទេវតានិងមនុស្សទាំងឡាយបូជាហើយ បានកន្លងនូវសំណាញ់ គឺកិលេស ជាគ្រឿងជំពាក់ បុគ្គលនោះឈ្មោះថាមុនិ ។

ពាក្យថា រូបស្រឡះ គឺចិត្តរបស់មុនិរូប រូបវិសេស រូបស្រឡះចាករាគៈចិត្ត ( រូបស្រឡះ ) ចាកទោសៈ ចិត្តរូប រូបវិសេស រូបស្រឡះចាកមោហៈ ។បេ។ ចិត្តរូប រូបវិសេស រូបស្រឡះចាកអកុសលាភិសង្ខារទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះមានការៈដាក់ចុះហើយ ជាមុនិរូបស្រឡះហើយ ។

[ ៣៧៩ ] អធិប្បាយពាក្យថា ព្រះមានព្រះភាគ ( ទ្រង់ត្រាស់ថា ) ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ត្រង់ពាក្យថា ការកំណត់ បានដល់ ការកំណត់ ២ គឺការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះការកំណត់គឺទិដ្ឋិ ។ បុគ្គលនោះ

លះបង់នូវការកំណត់គឺតណ្ហា វលាស់ចោលនូវការកំណត់គឺទិដ្ឋិព្រោះបានលះបង់ការកំណត់គឺតណ្ហា វលាស់ចោលការកំណត់គឺទិដ្ឋិ បុគ្គលនោះមិនកំណត់ មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះនូវការកំណត់គឺតណ្ហា ឬការកំណត់គឺទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមានការកំណត់ ។ ពាក្យថា ជាអ្នកមិនត្រេកអរ សេចក្ដីថា ពាលបុថុជ្ជនទាំងអស់រមែងត្រេកអរ សេក្ខបុគ្គលទាំង ៧ ពួក រាប់យកកល្យាណបុថុជ្ជនផងរមែងត្រេកអរទូទៅ ត្រេកអរចំពោះ ដើម្បីដល់នូវគុណដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ឯព្រះអរហន្តជាអ្នកឆ្ងាយ វៀរបង់ វៀរចំពោះ ឃ្លាតចេញ វលាស់ចោល រួចស្រឡះ មិនប្រកប មានចិត្តប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនមានការកំណត់ មិនត្រេកអរ ។ ពាក្យថា មិនមានសេចក្ដីប្រាថ្នា សេចក្ដីថា តណ្ហា លោកហៅថាសេចក្ដីប្រាថ្នា បានដល់សេចក្ដីត្រេកអរ សេចក្ដីត្រេកអរដ៏មានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្ដីប្រាថ្នានុ៎ះ បុគ្គលណាលះបង់ហើយ ផ្ដាច់ផ្ដិលហើយ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានសេចក្ដីប្រាថ្នា ។ ពាក្យថា ព្រះមានព្រះភាគជាពាក្យពោលដោយគោរព ។ម្យ៉ាងទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់រាគៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ទោសៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់មោហៈ ។

ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់មានះ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ទិដ្ឋិ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ នូវចម្រូង ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់នូវកិលេស ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចែករំលែកញែកនូវធម្មរតនៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ធ្វើទីបំផុតនៃភពទាំងឡាយ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចម្រើនព្រះកាយ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចម្រើនសីល ចម្រើនចិត្ត ចម្រើនបញ្ញា ។ មួយទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់គប់រកនូវសេនាសនៈទាំងឡាយដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាកមនុស្សសមគួរដល់ការពួនសម្ងំ ។ មួយទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ។ មួយទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០

អានាបានស្សតិសមាធិ អសុភសមាបត្តិ ។ មួយទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយវិញទៀតឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថាព្រះមានព្រះភាគនេះ មិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ ព្រះនាមថា ព្រះមានព្រះភាគនេះរបស់ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ ការបញ្ញត្តថាមានព្រះភាគនេះ ( កើត ) អំពីការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគ ( ត្រាស់ថា ) មិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ព្រះមានព្រះភាគ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះធ្វើសេនាណា
មួយដែលឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង
បុគ្គលនោះមានភារៈដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ជា
អ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ។

**ចប់មហាវិយូហសុត្តនិទ្ទេសទី ១៣**

# អដ្ឋកថា

# មហាវិយូហសុត្តនិទ្ទេសទី ១៣

គប្បីជ្រាបអត្ថក្នុងមហាវិយូហសុត្តនិទ្ទេសទី ១៣ ដូចតទៅនេះថា

[ ២៨១ ] ក្នុងបទនេះថា **យេកេចិមេ ទិដ្ឋិបរិព្វសានា** ព្រះមានព្រះភាគទ្រង់ឲ្យព្រះពុទ្ធនិមិត្តទូលសួរព្រះអង្គ ហើយទើបត្រាស់ដោយន័យមុននោះឯង ដើម្បីទ្រង់ធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ ដល់ទេវតាពួកខ្លះដែលមានគំនិតកើតឡើងថា សមណព្រាហ្មណ៍ទាំងនេះមានកាប្រកាន់ក្នុងទិដ្ឋិ រមែងបានទទួលនិន្ទាតែម្យ៉ាងឬ ឬថារមែងបានទទួលនូវការសរសើរ អំពីសម្នាក់របស់អ្នកប្រាជ្ញផងដែរ ។

ក្នុងបទទាំងនោះ បទថា **អន្វានយន្តិ** សេចក្ដីថា រមែងត្រូវនាំមកក្នុងកាលខាងក្រោយ រមែងនាំមករឿយៗ ។

[ ២៨៤ ] បទថា **និន្ទមេវ អន្វេន្តិ** បានដល់ រមែងចូលដល់ការតិះដៀល ។

[ ២៨៦ ] ឥឡូវនេះព្រោះពួកមេលទ្ធិទាំងឡាយសូម្បីពោលថានេះប៉ុណ្ណោះពិត រមែងបានទទួលនូវការសរសើរក្នុងកាលខ្លះ ក្នុងទីខ្លះ នៃផលរបស់វាទៈ គឺការសរសើរនោះ ជារបស់តិច មិនអាចស្ងប់កិលេស មានរាគៈជាដើមបាន នឹងពោលថ្វីដល់ផលទី ២ គឺផលនៃការនិន្ទា ព្រោះហេតុនោះព្រះមានព្រះភាគកាលទ្រង់សម្ដែងសេចក្ដីនោះ ទើបត្រាស់គាថាឆ្លើយនេះមុន ផល គឺសេចក្ដីសរសើរនុ៎ះមានបន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ តថាគតពោលនូវផលនៃវិវាទថាមាន ២ ប្រការជាដើម ។

ក្នុងបទទាំងនោះ បទថា **ឯតេ វិវាទស្ស ផលានិ** បានដល់ និន្ទានិងសរសើរ ឬការឈ្នះនិងការចាញ់ជាដើម ដែលមានចំណែកស្មើគ្នាជាមួយនិន្ទានិងសរសើរនោះ ។ បទថា **ឯតម្បិ ទិស្វា** បានដល់ ឃើញទោសក្នុងផលនៃវិវាទនោះថា និន្ទាជាវត្ថុមិនគួរប្រាថ្នាឡើយ ជារបស់តិចមិនគ្រប់គ្រាន់ដើម្បីស្ងប់កិលេសបានទេ ។ បទថា **ខេមាភិបស្សំ អវិវាទភូមឹ** បានដល់ ឃើញនូវភូមិនៃការមិនវិវាទ គឺនិព្វានថាជាធម្មជាតក្សេម ។

[ ២៨៧ ] បទថា **អប្បកំ** បានដល់ បន្តិចបន្តួច ។ បទថា **បរិត្តកំ** បានដល់ តិច ។ បទថា **ឱមកំ** បានដល់ ទាប ។ បទថា **លាមកំ** បានដល់ មិនល្អ ។ បទថា **សមាយ** បានដល់ ដើម្បីការស្ងប់កិលេសមានរាគៈជាដើម ។ បទថា **ឧបសមាយ** បានដល់ ដើម្បីស្ងប់ក្រៃលែងឡើង ។ បទថា **វូបសមាយ** បានដល់ ដើម្បីឲ្យលិចចុះវិនាសទៅ ។ បទថា **និព្វានាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់អមតមហានិព្វាន ។ បទថា **បដិនិស្សគ្គាយ** បានដល់ ដើម្បីលះកិលេសទាំងឡាយដោយមគ្គ ។ បទថា **បដិប្បស្សទ្ធិយា** បានដល់ មិនល្មមដើម្បីឲ្យកើតសេចក្ដីរម្ងាប់ដោយផល ។

[ ២៩១ ] កាលមិនវិវាទយ៉ាងនេះ គប្បីជ្រាបគាថាថា **យា កាចិមា** ជាដើមដូចតទៅនេះថា

ក្នុងបទទាំងនោះ បទថា **សម្មុតិយោ** បានដល់ ទិដ្ឋិទាំងឡាយ ។ បទថា **បុថុជ្ជា** បានដល់ ជារបស់កើតអំពីបុថុជ្ជន ។ បទថា **សោ ឧបយំ កិមេយ្យ** សេចក្ដីថា បុគ្គលនោះគប្បីចូលដល់ធម៌ណាមួយ ក្នុងបណ្ដារូបជាដើម ដែល

គួរចូលដល់ដោយអត្ថថា គប្បីចូលដល់ដូចម្តេច ឬគប្បីចូលដល់ដោយហេតុដូចម្តេច ។ បទថា **ទិដ្ឋេ សុតេ ខន្តិមកុព្វមានោ** បានដល់ មិនធ្វើនូវការពេញចិត្តក្នុងរូបដែលឃើញនិងក្នុងសំឡេងដែលឮ ថាជាហេតុឲ្យបរិសុទ្ធិទាំងឡាយ ។

[ ២៩២ ] បទថា **បុថុជ្ជនេហិ ជនិតា សេ** បានដល់ ដែលបុថុជ្ជជនឲ្យកើតឡើង ។ បទថា **តា សម្មុតិយោ** បានដល់ ទិដ្ឋិទាំងនោះ ។ បទថា **បុ-ថុនានាជនេហិ ជនិតា សេ** បានដល់ ដែលមេលទ្ធិផ្សេងៗជាច្រើនឲ្យកើត ។

[ ២៩៣ ] បទថា **នេតិ** កាត់បទជា **ន ឯតិ** ។ បទថា **ន ឧបេតិ** បានដល់ មិនចូលទៅជិត ។ បទថា **ន ឧបគច្ឆតិ** បានដល់ វិលត្រឡប់ ។ បទថា **នាភិនិវិសតិ** បានដល់ មិនចូលទៅតាំងមាំ ។

[ ២៩៦ ] គប្បីជ្រាបគាថាថា **សីលុត្តមា** ជាដើមដូចតទៅនេះថា

គាថានោះមានសេចក្តីដូច្នេះថា សមណព្រាហ្មណ៍ពួកខ្លះ គឺពួកដែលឈ្មោះថាសីលុត្តមា ដែលសម្គាល់នូវសីលប៉ុណ្ណោះ ថាជារបស់ឧត្តម ពោលសេចក្តីបរិសុទ្ធដោយការសង្រួមទើបសមាទានវត្ត មានវត្តដ៏រីជាដើម ហើយចូលទៅតាំងនៅ សមណព្រាហ្មណ៍ទាំងនោះត្រិះរិះថា ការបរិសុទ្ធរបស់សាស្តា គប្បីមានក្នុងទិដ្ឋិនេះប៉ុណ្ណោះ ទើបជាបុគ្គលត្រូវនាំចូលដល់ភព លិចចុះក្នុងភពពោលអាង ។ ម្យ៉ាងទៀតសមណព្រាហ្មណ៍ទាំងនោះ ដែលពោលអាងថាខ្លួនជាអ្នកឈ្លាស គឺមានវាទៈយ៉ាងនេះថា យើងជាអ្នកឈ្លាស ។

[ ៣០១ ] បើសមណព្រាហ្មណ៍ដែលសម្គាល់ថា សីលឧត្តមយ៉ាងនេះ អ្នកណាក៏ដោយដែលបដិបត្តិយ៉ាងនោះ គប្បីជ្រាបគាថាថា **សចេ ចុតោ** ជាដើម

ដូចតទៅនេះថា

គាថានោះមានសេចក្ដីដូចតទៅនេះថា បើបុគ្គលជាអ្នកឃ្លាតចាកសីលនិងវត្ត ដោយការវិនិច្ឆ័យអំពីបុគ្គលដទៃ ឬមិនសម្រេចទើបជាអ្នកឃ្លាត បុគ្គលនោះភ្លាត់ចាកកម្ម គឺសីលនិងវត្តនោះឬកម្ម មានបុញ្ញាភិសង្ខារជាដើម ហើយរមែងញាប់ញ័រ គឺញាប់ញ័រដល់កត ។ ម្យ៉ាងទៀតរមែងរវើរវាយ កន្ទក់កន្ទេញនិងប្រាថ្នាដល់ការបរិសុទ្ធព្រោះសីលនិងវត្តនោះ ។ សួរថា ដូចអ្វី ឆ្លើយថា ដូចបុគ្គលឃ្លាតចាកផ្ទះ ហើយសាបសូន្យចាកពួកដូច្នោះ អធិប្បាយថា បុគ្គលដែលចេញចាកផ្ទះភ្លាត់ចាកពួក រមែងប្រាថ្នាផ្ទះនោះ ឬពួកនោះយ៉ាងណា ។

[ ៣០២ ] បទថា **បរិវិច្ឆិន្នណាយ វា** បានដល់ ត្រូវអ្នកដទៃឃាត់ ។

បទថា **អនភិសម្ភុណន្តោ វា** បានដល់ មិនញុំាងការបដិបត្តិនោះឲ្យបរិបូណ៌បាន ។

[ ៣០៣ ] បទថា **អញ្ញាយ អបរទ្ធោ** បានដល់ សាបសូន្យចាកនិព្វាន ឬចាកមគ្គ ។

[ ៣០៥ ] បទថា **តំ វា សត្ថំ អនុពន្ធតិ** បានដល់ ជាប់តាមពួកនោះទៅអំពីខាងក្រោយក្នុងទីគ្រប់អន្លើ ។

[ ៣០៦ ] គប្បីជ្រាបគាថាថា **សីលព្វតំ វាបិ បហាយ សព្វំ** ដែលជាហេតុញាប់ញ័រនៃសមណព្រាហ្មណ៍ខាងក្រៅសាសនាដែលប្រកាន់ថា សីលឧត្តមដូច្នេះជាដើម ដូចតទៅនេះថា

បទថា **សាវជ្ជានវជ្ជំ** បានដល់ អកុសលទាំងអស់និងកុសលដែលជា

លោកិយ ។ បទថា **ឯតំ សុទ្ធឹ អសុទ្ធិន្តិ អបត្ថយានោ** បានដល់ មិនប្រាថ្នានូវការបរិសុទ្ធ ដែលបានដល់កាមគុណ ៥ ជាដើម និងការមិនបរិសុទ្ធដែលបានដល់អកុសលជាដើម ។ បទថា **វិរតោ ចរេ** បានដល់ ជាអ្នកវៀរហើយចាកសេចក្តីបរិសុទ្ធនិងសេចក្តីមិនបរិសុទ្ធ គប្បីបដិបត្តិ ។ បទថា **សន្តិមនុគ្គហាយ** បានដល់ មិនកាន់យកនូវទិដ្ឋិ ។

[ ៣០៨ ] បទថា **កណ្ហំ កណ្ហវិបាកំ** បានដល់ អកុសលកម្មឲ្យផលជាអកុសលវិបាក ។ បទថា **សុក្កំ សុក្កវិបាកំ** បានដល់ លោកិយកុសលឲ្យផលសដូចគ្នានឹងខ្លួន ។

[ ៣០៩ ] បទថា **និយាមាវក្កន្តិ** បានដល់ ការចូលកាន់មគ្គ ។ បទថា **សេក្ខា** បានដល់ ព្រះសេក្ខៈ ៧ ពួក ។ បទថា **អគ្គធម្មំ** សេចក្តីថា ធម៌ជាន់ខ្ពស់ បានដល់អរហត្តផល ។

[ ៣១១ ] ព្រះមានព្រះភាគកាលទ្រង់សម្តែង ដល់សមណព្រាហ្មណ៍ខាងក្រៅសាសនានេះដែលប្រកាន់ថា សីលឧត្តម ជាអ្នកមានវាទៈថា បរិសុទ្ធិបានដោយការសង្រួមយ៉ាងនេះ និងការចង្អៀតចង្អល់របស់សមណព្រាហ្មណ៍ទាំងនោះនិងការបដិបត្តិរបស់ព្រះអរហន្ត ដែលលះសីលនិងវត្តហើយ ឥឡូវនេះកាលទ្រង់សម្តែង ពួកសមណព្រាហ្មណ៍ខាងក្រៅដែលមានវាទៈថា បរិសុទ្ធិដោយប្រការដទៃ ទើបត្រាស់គាថានេះថា **តមូបនិស្សាយ** ដូច្នេះជាដើម ។

គាថានោះមានសេចក្តីដូចតទៅនេះថា មានសមណព្រាហ្មណ៍ពួកដទៃអាស្រ័យតបៈដទៃទៀតដែលគួរខ្ពើមនោះឬអាស្រ័យវត្ថុណានីមួយ បណ្តាការ

បរិសុទ្ធព្រោះរូបដែលឃើញជាដើម ឬជាអ្នកពោលការបរិសុទ្ធក្នុងសង្សារខាង មុខដោយអកិរិយទិដ្ឋិ មានតណ្ហាមិនទាន់ទៅប្រាស ក្នុងភពតូចភពធំទាំងឡាយ អាស្រ័យនូវសេចក្តីខ្ពើម ( បាប ) នោះ ឬអាស្រ័យនូវអារម្មណ៍ដែលខ្លួនឃើញ ៗ ឬប៉ះពាល់ហើយរមែងពោលសេចក្តីបរិសុទ្ធ គឺរមែងពោល រមែងប្រាប់ ។

[ ៣១២ ] បទថា **តមោជិគុច្ឆវាទា** បានដល់ សមណព្រាហ្មណ៍ទាំង ឡាយដែលមានវាទៈខ្ពើមចំពោះបាប ដោយតបៈ មានការធ្វើកាយឲ្យលំបាកជា ដើម ។ បទថា **តមោជិគុច្ឆសារា** បានដល់ មានការខ្ពើមដោយតបៈនោះជា សារៈ ។

[ ៣១៤ ] បទថា **ឧទ្ធំសរាវាទា** បានដល់ ពោលនូវការបរិសុទ្ធដោយ សង្សារ ។

[ ៣១៦ ] គប្បីអធិប្បាយថា កាលសមណព្រាហ្មណ៍ទាំងនោះ ដែលមិន ទាន់ប្រាសចាកតណ្ហា កន្ទក់កន្ទេញដល់សេចក្តីបរិសុទ្ធយ៉ាងនេះ សូម្បីបុគ្គល ណាសម្គាល់ខ្លួនថា ដល់ការបរិសុទ្ធហើយ កាលបុគ្គលនោះនៅប្រាថ្នាវត្ថុនោះៗ ក្នុងភពតូចភពធំព្រោះមិនប្រាសចាកតណ្ហា រមែងមានរបស់ពេញចិត្តរឿយៗ នោះឯង ។ ពិតហើយតណ្ហាដែលបុគ្គលសេពជាអចិណ្ណ រមែងបន្ថែមនូវចំណង់ ក្រៃលែងឡើង មិនត្រឹមតែរបស់ពេញចិត្តតែម្យ៉ាង សូម្បីការញាប់ញ័ររមែង មាន ព្រោះវត្ថុទាំងឡាយដែលកំណត់ហើយ ។ លោកអធិប្បាយថា សូម្បីការ ញាប់ញ័រក៏រមែងមាន ព្រោះវត្ថុដែលបុគ្គលនោះកំណត់ទុកដោយតណ្ហានិងទិដ្ឋិ ។ គប្បីភ្ជាប់សេចក្តីនៃគាថានេះថា ចុតិនិងការកើតក្តី នៃបុគ្គលណាមិនមានក្នុង

លោកនេះ ព្រោះប្រាសចាកតណ្ហាហើយក្នុងភពតូចនិងភពធំ បុគ្គលនោះគប្បីញាប់ញ័រដោយកិលេសដូចម្តេចកើត គប្បីជាប់ចិត្តក្នុងហេតុដូចម្តេចកើត ។

[ ៣១៩ ] បទថា **អាគមនំ** បានដល់ មកទៀត ។ បទថា **គមនំ** បានដល់ ទៅក្នុងភពដទៃអំពីភពនេះ ។ បទថា **គមនាគមនំ** បានដល់ ទៅអំពីភពនេះហើយត្រឡប់មកទៀត ។ បទថា **កាលំ** បានដល់ មរណៈ ។ បទថា **គតិ** បានដល់ គួរទៅតាមគតិដោយអំណាចនៃការទៅ ។

[ ៣២១ ] បទថា **យមាហុ ធម្មំ** នេះ ជាគាថាសួរ ។

[ ៣២៦ ] ព្រោះវាទៈពិតក្នុងវាទៈទាំងនេះ សូម្បីតែមួយមិនមាន ដ្បិតថាសមណព្រាហ្មណ៍ទាំងនោះ ពោលដោយហេតុត្រឹមតែទិដ្ឋិតែម្យ៉ាង ហេតុនោះឥឡូវនេះព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់គាថាឆ្លើយនេះថា **សកំ ហិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សម្មុតី** បានដល់ ទិដ្ឋិ ។

[ ៣២៧ ] បទថា **អធោមំ** បានដល់ មិនខ្វះ ។

[ ៣៣១ ] កាលសមណព្រាហ្មណ៍ទាំងនេះ ពោលធម៌របស់ខ្លួនថាជាធម៌បរិបូណ៌ ពោលធម៌របស់អ្នកដទៃថាអាក្រក់យ៉ាងនេះ ទើបមានគាថាថា **បរស្ស ចេ វម្ភយិតេន ហីនោ** គឺបុគ្គលណាមួយតិះដៀលសោតជាដើម ។ ពាក្យនោះមានសេចក្តីដូចតទៅនេះថា បើបុគ្គលគប្បីជាបុគ្គលអាក្រក់ ព្រោះហេតុដែលអ្នកដទៃតិះដៀលសោត មិនមានបុគ្គលណាវិសេសក្នុងធម៌ទាំងឡាយទេ ព្រោះហេតុអ្វី ព្រោះថា បុគ្គលច្រើនទាក់ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន

តែងពោលធម៌របស់ជនដទៃ ថាថោកទាប គឺជាអ្នកពោលមាំទាំក្នុងធម៌របស់ខ្លួនប៉ុណ្ណោះ ។

[ ៣៣២ ] បទថា **វម្ភយិតការណា** បានដល់ ព្រោះត្រូវកម្ចាត់ ។ បទថា **គរហិតការណា** បានដល់ ព្រោះហេតុដែលខ្លួនធ្វើនូវអំពើលាមក ។ បទថា **ឧបវទិតការណា** បានដល់ ព្រោះហេតុអ្នកដទៃជេរ ។

[ ៣៣៥ ] បទថា **សកាយនំ** បានដល់ ផ្លូវប្រព្រឹត្តរបស់ខ្លួន ។ ពាក្យដែលគួរពោលក្រៃលែងជាងនេះមានដូចតទៅនេះថា

[ ៣៣៦ ] គប្បីជ្រាបគាថាថា **សធម្មបូជា** ដូចតទៅនេះថា ក្នុងគាថានោះមានសេចក្តីដូចតទៅនេះថា ពួកតិត្ថិយទាំងនោះសរសើរធម៌ជាផ្លូវប្រព្រឹត្តរបស់ខ្លួនដោយប្រការណា សូម្បីការបូជាធម៌របស់ពួកជនទាំងនោះ រមែងប្រព្រឹត្តទៅដោយប្រការនោះ ព្រោះពួកបុគ្គលទាំងនោះ រមែងធ្វើសក្ការក្នុងសាស្តាជាដើមយ៉ាងក្រៃលែង បើជនទាំងនោះគប្បីកាន់យកជាប្រមាណក្នុងសេចក្តីនោះបាន កាលបើដូច្នោះវាទៈទាំងពួងនោះឯងក៏គប្បីជារបស់ពិត ព្រោះអ្វី ព្រោះការបរិសុទ្ធរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ជារបស់ចំពោះខ្លួនប៉ុណ្ណោះ ។ សេចក្តីបរិសុទ្ធនោះរមែងមិនសម្រេចក្នុងបុគ្គលដទៃ សូម្បីដោយបរមត្ថ ក៏មិនមាន ។ ព្រោះសេចក្តីនោះត្រឹមតែជាការប្រកាន់ដោយទិដ្ឋិរបស់សមណព្រាហ្មណ៍ទាំងនោះដែលដឹងបានដោយការចង្អុលបង្ហាញអំពីអ្នកដទៃ ។ បទថា **បច្ចត្តមេវ** បានដល់ ចំពោះខ្លួនប៉ុណ្ណោះ ។

[ ៣៤១ ]ម្យ៉ាងទៀតដោយផ្ទុយគ្នា បុគ្គលណា ឈ្មោះថាជាព្រាហ្មណ៍

ព្រោះបន្សាត់បាបបានហើយទើបមានគាថាថា **ន ព្រាហ្មណស្ស បរនេយ្យមត្ថិ** គាថានោះមានសេចក្តីដូចតទៅនេះថា ញាណដែលបុគ្គលដទៃគប្បីនែនាំរមែងមិនមានដល់ព្រាហ្មណ៍ ព្រោះជាអ្នកឃើញប្រពៃហើយដោយន័យជាដើមថា សង្ខារទាំងឡាយមិនទៀង សូម្បីការសម្រេចចិត្តហើយប្រកាន់មាំក្នុងធម៌ គឺទិដ្ឋិទាំងឡាយថា វត្ថុនេះប៉ុណ្ណោះពិត ក៏មិនមានដល់ព្រាហ្មណ៍ ព្រោះហេតុនោះទើបព្រាហ្មណ៍នោះឈានកន្លងហើយនូវជម្លោះដោយទិដ្ឋិ ព្រោះព្រាហ្មណ៍នោះរមែងមិនឃើញធម៌ដទៃដោយភាពជាធម៌ប្រសើរក្រៅអំពីសតិប្បដ្ឋានជាដើម ។

[ ៣៤២ ] បទថា **ន បរនេយ្យោ** បានដល់ ព្រាហ្មណ៍ជាអ្នកមិនត្រូវឲ្យបុគ្គលដទៃណែនាំ គឺឲ្យដឹង ។ បទថា **ន បរប្បត្តិយោ ន បរបច្ចយោ** បានដល់ មិនជឿអ្នកដទៃ ។ បទថា **ន បរបដិពទ្ធគូ** បានដល់ មិនប្រព្រឹត្តទៅទាក់ទងដោយអ្នកដទៃ ។

[ ៣៤៦ ] គប្បីជ្រាបការភ្ជាប់អត្ថនៃគាថាថា **ជានាមិ** ដូចតទៅនេះថា បុគ្គលជាព្រាហ្មណ៍ដោយបរមត្ថយ៉ាងនេះ រមែងមិនឃើញធម៌ដទៃ ដោយភាពជាធម៌ប្រសើរ ចំណែកតិត្ថិយពួកដទៃ ដឹងដោយបរចិត្តញាណជាដើមខ្លះពោលយ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះពិតដូច្នោះមែន ដូច្នេះខ្លះ ឈ្មោះថារមែងជឿការបរិសុទ្ធដោយទិដ្ឋិ ព្រោះហេតុអ្វី ព្រោះបណ្តាសមណព្រាហ្មណ៍ទាំងនោះ បើសមណព្រាហ្មណ៍មួយបានឃើញហើយ ។ សមណព្រាហ្មណ៍ណា បានឃើញអត្ថតាមសេចក្តីពិត ដោយបរចិត្តញាណជាដើមនោះ សមណព្រាហ្មណ៍អ្នកឃើញនោះនឹងមានប្រយោជន៍អ្វី ដោយការ

ឃើញនោះ គឺនឹងធ្វើអ្វីបាន នឹងកំណត់ដឹងទុក្ខឲ្យសម្រេចបានដូចម្តេច ឬថានឹងបានប្រយោជន៍ណាមួយ ក្នុងបណ្តាការលះហេតុនៃទុក្ខជាដើមនោះ ដោយការឃើញនោះរបស់បុគ្គលនោះ ព្រោះពួកតិត្ថិយទាំងនោះ កន្លងអរិយមគ្គដោយប្រការទាំងពួង រមែងពោលសេចក្តីបរិសុទ្ធដោយទស្សនៈដទៃ ឬព្រះពុទ្ធជាដើម ទ្រង់ឈានកន្លងតិត្ថិយទាំងនោះ ទ្រង់រមែងពោលសេចក្តីបរិសុទ្ធដោយទស្សនៈដទៃនោះឯង ។

[ ៣៥១ ] គប្បីជ្រាបការភ្ជាប់អត្ថនៃគាថាថា **បស្សំ នរោ** ដូច្នេះជាដើម ដូចតទៅនេះថា អ្វីដែលពោលក្រៅលែងជាងនេះ មានដូចតទៅនេះថា នរជនណាបានឃើញដោយបរចិត្តញ្ញាណជាដើម នរជននោះកាលឃើញ ក៏ឃើញនាមរូបមិនដទៃអំពីនោះ ឬឃើញហើយ ក៏ស្គាល់នាមរូបទាំងនោះប៉ុណ្ណោះដោយភាពជារបស់ទៀង ឬដោយភាពជាសុខ មិនឃើញយ៉ាងដទៃ នរជននោះកាលឃើញយ៉ាងនេះ ឃើញនាមរូបច្រើនខ្លះ តិចខ្លះដោយពិត ដោយភាពជារបស់ទៀងនិងដោយភាពសុខ កាលបើយ៉ាងនោះ គឺចំណែកអ្នកឈ្លាសទាំងឡាយមិនពោលនូវសេចក្តីបរិសុទ្ធដោយការឃើញនោះទេ គឺដោយការឃើញបែបនោះរបស់បុគ្គលនោះឡើយ ។

[ ៣៥៦ ] គប្បីជ្រាបការភ្ជាប់អត្ថរបស់គាថាថា **និវិស្សវាទី** ជាដើមដូចតទៅនេះថា

កាលសេចក្តីបរិសុទ្ធមិនមានដោយការឃើញនោះនរជនណាពោលដោយការប្រកាន់មាំយ៉ាងនេះថា ខ្ញុំដឹង ខ្ញុំឃើញសេចក្តីបរិសុទ្ធនោះពិត ឬអាស្រ័យ

ទិដ្ឋិនោះ ជឿសេចក្តីបរិសុទ្ធដោយទិដ្ឋិ ពោលដោយការប្រកាន់មាំយ៉ាងនេះថា នេះប៉ុណ្ណោះពិត នរជននោះដែលគេមិនអាចទូន្មានបានងាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន គឺតាក់តែងហើយទុកខាងមុខ នរជននោះអាស្រ័យសភាវៈណាជាអ្នកពោលថាល្អ ពោលថាបរិសុទ្ធិក្នុងសភាវៈនោះ សម្គាល់ខ្លួនថា អាត្មាអញជាបុគ្គលមានវាទៈបរិសុទ្ធ ឬមានទិដ្ឋិបរិសុទ្ធដូច្នេះ ឃើញថាពិតក្នុងសភាវៈនោះ គឺបានឃើញការមិនវិបរិតក្នុងទិដ្ឋិរបស់ខ្លួននោះ អធិប្បាយថា ទិដ្ឋិនោះប្រព្រឹត្តទៅយ៉ាងណា បានឃើញទិដ្ឋិនោះប្រព្រឹត្តទៅយ៉ាងនោះ មិនប្រាថ្នានឹងឃើញដោយប្រការដទៃ ។

[ ៣៥៧ ] បទថា **និវិស្សវាទី** បានដល់ ប្រកាន់មាំ ពោល ។ បទថា **ទុព្វិនយោ** បានដល់ លំបាកនឹងទូន្មានបាន ។ បទថា **ទុប្បញ្ញាបយោ** បានដល់ លំបាកនឹងឲ្យដឹង គឺឲ្យបានដោយចិត្ត ។ បទថា **ទុន្និជ្ឈាបយោ** បានដល់ លំបាកនឹងឲ្យយល់រឿយៗដើម្បីពិចារណាហើយកាន់យកដោយចិត្តបាន ។ បទថា **ទុប្បេក្ខាបយោ** បានដល់ លំបាកនឹងឲ្យឃើញបាន ។ បទថា **ទុប្បសាទយោ** បានដល់ លំបាកនឹងឲ្យចិត្តកើតសេចក្តីជ្រះថ្លាបាន ។

[ ៣៦០ ] បទថា **អបស្សិ** បានដល់ សម្រេចបដិវេធដោយញាណ ។ បទថា **បដិវិជ្ឈិ** បានដល់ សម្រេចនូវការត្រាស់ដឹងដោយចិត្ត ។ គប្បីជ្រាបសេចក្តីក្នុងគាថាទាំងឡាយ ដែលលើកនូវទិដ្ឋិជាគ្រឿង កំណត់ទុកខាងមុខដូចតទៅនេះថា

[ ៣៦១ ] គប្បីជ្រាបគាថាថា **ន ព្រាហ្មណោ កប្បមុបេតិ សង្ខំ** ជា

ដើមដូចតទៅនេះថា ។ ក្នុងបទទាំងនោះ បទថា **សង្ខំ** សេចក្ដីថា ជ្រាបហើយ គឺដឹងហើយ ។ បទថា **ឆបិ ញាណាពន្ធុ** បានដល់ មិនធ្វើតណ្ហា ឬទិដ្ឋិជាគ្រឿងចងដោយសមាបត្តិញាណជាដើម ។ ក្នុងបទនោះមានវិគ្គហៈថា ឈ្មោះថា **ឆបិ ញាណាពន្ធុ** ព្រោះវិគ្គហថា មិនមានតណ្ហានិងទិដ្ឋិជាគ្រឿងចង ដែលធ្វើហើយដោយញាណ ។ បទថា **សម្មុតិយោ** បានដល់ សម្មុតិ គឺទិដ្ឋិ ។ បទថា **បុថុជ្ជា** បានដល់ មានបុថុជ្ជនជាដែនកើត ។ បទថា **ឧគ្គហាណន្តិ មញ្ញេ** បានដល់ សមណព្រាហ្មណ៍ពួកដទៃរមែងប្រកាន់មាំ អធិប្បាយថា សមណ-ព្រាហ្មណ៍ពួកដទៃរមែងប្រកាន់មាំទិដ្ឋិទាំងនោះ ។ បទថា **ឧបេក្ខតី** បានដល់ មិនធ្លាក់ទៅក្នុងចំណែកនៃការសម្លឹងមើលតាំងអំពីកើត ។

[ ៣៦៦ ] អ្វីដែលពោលក្រៃលែងជាងនេះ មានដូចតទៅនេះថា

គប្បីជ្រាបគាថាថា **វិសជ្ជ គន្ថានិ** ជាដើមដូចតទៅនេះថា ក្នុងបទទាំងនោះ បទថា **អនុគ្គហោ** បានដល់ វៀរចាកការប្រកាន់មាំ ។ ឈ្មោះថា **អនុគ្គហោ** ព្រោះអត្ថថា មិនមានការប្រកាន់មាំ ឬព្រោះអត្ថថា មិនប្រកាន់មាំ ។

[ ៣៦៧ ] បទថា **គន្ថេ វោស្សជ្ជិត្វា វា** បានដល់ លះបង់នូវកិលេសជាគ្រឿងរួបរឹតទាំងឡាយ មានអភិជ្ឈាជាដើម ។ បទថា **វិសជ្ជ** បានដល់ លះហើយដោយមិនប្រកាន់មាំទៀត ។ បទថា **គធិតេ** បានដល់ គ្រឿងចង ។ បទថា **គន្ថិតេ** បានដល់ ចងទុកដូចចងនឹងអំបោះ ។ បទថា **ពន្ធេ** បានដល់ ចងទុកយ៉ាងល្អ ។ បទថា **វិពន្ធេ** បានដល់ ជាប់ចំពាក់ច្រើនយ៉ាង ។ បទថា **បលិពុទ្ធេ** បានដល់ ចងជាប់គ្នាដោយជុំវិញ ។ បទថា **ពន្ធនេ** បានដល់ ចង

ទុកដោយកិលេស ។ បទថា **ឆោជយិត្វា** បានដល់ ស្រាយហើយ ។ បទថា **សច្ចំ វិសជ្ជំ ករោន្តិ** បានដល់ ធ្វើឲ្យជារបស់ប្រើការលែងបាន ។ បទថា **វិកោបេន្តិ** បានដល់ ធ្វើឲ្យបែកជាចម្រៀកៗ ។

[ ៣៧១ ] អ្វីដែលគួរពោលក្រៃលែងជាងនេះ មានដូចតទៅនេះថា

គប្បីជ្រាបគាថាថា **បុព្វាសវេ** ជាដើម ដូចតទៅនេះថា ក្នុងបទទាំងនោះ បទថា **បុព្វាសវេ** បានដល់ កិលេសដែលកើតឡើងប្រារព្ធរូបក្នុងអតីតជាដើម ។ បទថា **នវេ** បានដល់ កិលេសដែលកើតឡើងប្រារព្ធរូបក្នុងបច្ចុប្បន្នជាដើម ។ បទថា **ន ឆន្ទគូ** បានដល់ មិនទៅដោយអំណាចឆន្ទាគតិជាដើម ។ បទថា **អនត្តគរហី** បានដល់ មិនតិះដៀលខ្លួន ដោយការធ្វើនិងមិនធ្វើ ។

[ ៣៧៦ ] គប្បីជ្រាបគាថាថា **ស សព្វធម្មេសុ** ដូចតទៅនេះថា

ក្នុងបទទាំងនោះ បទថា **សព្វធម្មេសុ** បានដល់ ក្នុងធម៌ គឺទិដ្ឋិ ៦២ ដែលមានប្រភេទយ៉ាងនេះថា **យំ កិញ្ចិ ទិដ្ឋំ វា** ។ បទថា **បន្នភារោ** បានដល់ មានភារៈ ត្រូវដាក់ចុះហើយ ។ បុគ្គលរមែងមិនកំណត់ ព្រោះហេតុនោះទើបឈ្មោះថា **ន កប្បិយោ** ។ អធិប្បាយថា មិនធ្វើនូវការកំណត់ទាំង ២ យ៉ាង ។ បទថា **នូបរតោ** បានដល់ មិនមានការព្រមព្រៀងដែលចូលទៅត្រេកអរដូចបុថុជ្ជន កល្យាណជននិងព្រះសេក្ខ ។ បទថា **ន បត្ថិយោ** បានដល់ មិនមានតណ្ហា ។ ពិតហើយតណ្ហាឈ្មោះថា **បត្ថិយា** ព្រោះធ្វើឲ្យប្រាថ្នា ។ ឈ្មោះថា **ន បត្ថិយោ** ព្រោះសេចក្តីប្រាថ្នាមិនមានដល់បុគ្គលនោះ ។ បទមុននិងបទក្រោយបន្ទាប់អំពីនេះ មានអត្ថងាយយល់ទាំងអស់ហើយ ព្រោះមានន័យដូច

ពោលហើយក្នុងបាលីនោះៗ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនា ដោយធម៌ជាកំពូល គឺអរហត្ត ។

កាលចប់ទេសនាមានបុគ្គលសម្រេចធម៌ ដូចគ្នានឹងពោលហើយក្នុងបុរាភេទសូត្រនោះឯង ។

## អដ្ឋកថា មហាវិយូហសុត្តនិទ្ទេសទី ១៣ ចប់

# សុត្តន្តបិដក
# ខុទ្ទកនិកាយ មហានិទ្ទេស
# តតិយភាគ
## តុវដកសុត្តនិទ្ទេសទី ១៤

[ ១ ] ( ព្រះពុទ្ធនិមិត្តពោលថា ) ខ្ញុំសូមសួរនូវវិវេកផង សន្តិបទផង ចំពោះព្រះអង្គ ជាអាទិច្ចពន្ធុ ទ្រង់ស្វែងរកគុណដ៏ធំ ភិក្ខុឃើញដូចម្តេចហើយ ញុំាងកិលេសឲ្យរលត់ ទើបមិនប្រកាន់នូវរបស់អ្វីក្នុងលោក ។

[ ២ ] អធិប្បាយពាក្យថា ខ្ញុំសូមសួរចំពោះព្រះអង្គ ជាអាទិច្ចពន្ធុ ត្រង់ពាក្យថា សួរ បានដល់ ការសួរ ៣ គឺការសួរជាគ្រឿងបំភ្លឺនូវធម៌ដែលមិនទាន់ឃើញ ការសួរជាគ្រឿងប្រៀបធៀបនូវធម៌ ដែលឃើញហើយ ការសួរជាគ្រឿងកាត់សេចក្តីសង្ស័យ ។

ការសួរជាគ្រឿងបំភ្លឺនូវធម៌ ដែលមិនទាន់ឃើញ តើដូចម្តេច ។ លក្ខណៈដែលបុគ្គលមិនដឹង មិនឃើញ មិនថ្លឹង មិនត្រិះរិះ មិនប្រាកដ មិនជាក់ច្បាស់តាមប្រក្រតី បុគ្គលសួរនូវប្រស្នា ដើម្បីការដឹង ការឃើញ ការថ្លឹង ការត្រិះរិះ ដើម្បីជាក់ច្បាស់នូវលក្ខណៈនោះ នេះការសួរជាគ្រឿងបំភ្លឺនូវធម៌ដែលមិនទាន់ឃើញហើយ ។

ការសួរជាគ្រឿងប្រៀបធៀបនូវធម៌ ដែលឃើញហើយ តើដូចម្តេច ។ លក្ខណៈដែលបុគ្គលដឹង ឃើញ ថ្លឹង ត្រិះរិះ ប្រាកដ ជាក់ច្បាស់ហើយដោយប្រក្រតី បុគ្គលសួរប្រស្នា ដើម្បីប្រយោជន៍ដល់ការប្រៀបធៀប ជាមួយនឹង

បណ្ឌិតទាំងឡាយដទៃ នេះការសួរជាគ្រឿងប្រៀបធៀបនូវធម៌ ដែលឃើញហើយ ។

ការសួរជាគ្រឿងកាត់សេចក្តីសង្ស័យ តើដូចម្តេច ។ បុគ្គលនៅក្នុងការសង្ស័យ នៅក្នុងសេចក្តីងឿងឆ្ងល់ ដោយប្រក្រតីបែកទៅជាពីរថា យ៉ាងនេះឬហ្ន៎ មិនមែនយ៉ាងនេះឬហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ បុគ្គលនោះក៏សួរប្រស្នា ដើម្បីប្រយោជន៍ ដល់ការកាត់សេចក្តីងឿងឆ្ងល់នេះ ការសួរជាគ្រឿងកាត់សេចក្តីងឿងឆ្ងល់ ។ នេះការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួររបស់មនុស្ស ការសួររបស់អមនុស្ស ការសួររបស់និម្មិត ។

ការសួររបស់មនុស្ស តើដូចម្តេច ។ មនុស្សទាំងឡាយចូលទៅសួរប្រស្នានឹងព្រះពុទ្ធមានព្រះភាគ គឺពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកវេស្សៈសួរ ពួកសុទ្ទៈសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះការសួររបស់មនុស្ស ។

ការសួររបស់អមនុស្ស តើដូចម្តេច ។ ពួកអមនុស្ស ចូលទៅសួរប្រស្នានឹងព្រះពុទ្ធមានព្រះភាគ គឺពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្សសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទ្រសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះការសួររបស់អមនុស្ស ។

ការសួររបស់និម្មិត តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់និម្មិតរូបណា

ដែលសម្រេចដោយព្រះទ័យ មានអវយវៈតូចធំគ្រប់ មានឥន្ទ្រិយមិនខ្វះខាត រូបនិម្មិតនោះចូលទៅសួរប្រស្នានឹងព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ដោះស្រាយ នេះការសួររបស់និម្មិត ។ នេះការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍ខ្លួន ការសួរប្រយោជន៍បុគ្គលដទៃ ការសួរប្រយោជន៍ទាំងពីរ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍បច្ចុប្បន្ន ការសួរប្រយោជន៍លោកខាងមុខ ការសួរប្រយោជន៍ដ៏ក្រៃលែង ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍មិនមានទោស ការសួរប្រយោជន៍មិនមានកិលេស ការសួរប្រយោជន៍ដ៏ផូរផង់ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រារព្ធធម៌ជាអតីត ការសួរប្រារព្ធធម៌ជាអនាគត ការសួរប្រារព្ធធម៌ជាបច្ចុប្បន្ន ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ខាងក្នុង ការសួរធម៌ខាងក្រៅ ការសួរធម៌ទាំងខាងក្នុងទាំងខាងក្រៅ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ជាកុសល ការសួរធម៌ជាអកុសល ការសួរធម៌ជាអព្យាកតៈ ។

ការសួរ ៣ ដទៃទៀត គឺការសួរខន្ធ ការសួរធាតុ ការសួរអាយតនៈ ។

ការសួរ ៣ ដទៃទៀត គឺការសួរសតិប្បដ្ឋាន ការសួរសម្មប្បធាន ការសួរឥទ្ធិបាទ ។

ការសួរ ៣ ដទៃទៀត គឺការសួរឥន្ទ្រិយ ការសួរពលៈ ការសួរពោជ្ឈង្គ ។

ការសួរ ៣ ដទៃទៀត គឺការសួរមគ្គ ការសួរផល ការសួរព្រះនិព្វាន ។

ពាក្យថា ខ្ញុំសូមសួរចំពោះព្រះអង្គ គឺខ្ញុំសូមសួរព្រះអង្គ សូមអង្វរព្រះអង្គ អារាធនាព្រះអង្គ ចោទព្រះអង្គ សូមព្រះអង្គទ្រង់សម្តែងធម៌នោះដល់ខ្ញុំ ហេតុនោះ ( ត្រាស់សួរថា ) ខ្ញុំសូមសួរចំពោះព្រះអង្គ ។

ពាក្យថា អាទិច្ចពន្ធុ សេចក្តីថា សុរិយៈ លោកហៅថាអាទិច្ចៈ ។ សុរិយៈ ជាគោតមៈ ដោយគោត្ត ព្រះមានព្រះភាគ ជាគោតមៈ ដោយគោត្ត ។ ព្រះមានព្រះភាគ ជាព្រះញាតិព្រះអាទិត្យ ដោយគោត្ត ជាវង្សត្រកូលដោយគោត្ត ហេតុនោះព្រះពុទ្ធទើបជាអាទិច្ចពន្ធុ ហេតុនោះទ្រង់ត្រាស់ថា ខ្ញុំសូមសួរចំពោះព្រះអង្គជាអាទិច្ចពន្ធុ ។

[ ៣ ] អធិប្បាយពាក្យថា នូវវិវេកផង សន្តិបទផង ចំពោះព្រះអង្គដែលទ្រង់ស្វែងរកគុណដ៏ធំ ត្រង់ពាក្យថា វិវេក បានដល់ វិវេក ៣ គឺកាយវិវេក ចិត្តវិវេក ឧបធិវិវេក ។

កាយវិវេក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះគប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះ គុហាភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ទាំងជាអ្នកស្ងប់ស្ងាត់ដោយកាយ គឺភិក្ខុនោះដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង ដេកម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានទីចង្រ្កមម្នាក់ឯង ត្រាច់ទៅ សម្រេចនៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យទៅម្នាក់ឯង នេះកាយវិវេក ។

ចិត្តវិវេក តើដូចម្តេច ។ ភិក្ខុចូលបឋមជ្ឈានចិត្តស្ងប់ស្ងាត់ចាកនីវរណធម៌

ទាំងឡាយ ចូលទុតិយជ្ឈានចិត្តស្ងប់ស្ងាត់ចាកវិតក្កនិងវិចារៈ ចូលតតិយជ្ឈាន ចិត្តស្ងប់ស្ងាត់ចាកបីតិ ចូលចតុត្ថជ្ឈានចិត្តស្ងប់ស្ងាត់ចាកសុខនិងទុក្ខ ចូលអាកាសានញ្ចាយតនៈចិត្ត ស្ងប់ស្ងាត់ចាករូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ចូលវិញ្ញាណញ្ចាយតនៈចិត្ត ស្ងប់ស្ងាត់ចាកអាកាសានញ្ចាយតនសញ្ញា ចូលអាកិញ្ចញ្ញាយតនៈចិត្ត ស្ងប់ស្ងាត់ចាកវិញ្ញាណញ្ចាយតនសញ្ញា ចូលនេវសញ្ញានាសញ្ញាយតនៈចិត្ត ស្ងប់ស្ងាត់ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់សោតាបន្នបុគ្គលរមែងស្ងប់ស្ងាត់ចាកសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ទាំងចាកកិលេសទាំងឡាយដែលតាំងនៅជាមួយនឹងកិលេសទាំងនោះ ចិត្តរបស់សកទាគាមិបុគ្គលរមែងស្ងប់ស្ងាត់ ចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាត ទាំងចាកកិលេសទាំងឡាយដែលតាំងនៅជាមួយនឹងកិលេសទាំងឡាយនោះ ចិត្តរបស់អនាគាមិបុគ្គល រមែងស្ងប់ស្ងាត់ចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនដ៏ល្អិត ចាកកាមរាគានុស័យ បដិឃានុស័យដ៏ល្អិត ទាំងចាកកិលេសទាំងឡាយដែលតាំងនៅជាមួយនឹងកិលេសទាំងនោះ ចិត្តរបស់ព្រះអរហន្តរមែងស្ងប់ស្ងាត់ចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចាកកិលេសទាំងឡាយដែលតាំងនៅជាមួយនឹងកិលេសទាំងនោះ ទាំងចាកនិមិត្តទាំងអស់ជាខាងក្រៅ នេះចិត្តវិវេក ។

ឧបធិវិវេក តើដូចម្តេច ។ កិលេសទាំងឡាយផង ខន្ធទាំងឡាយផង អ-

ភិសង្ខារទាំងឡាយផង លោកហៅថា ឧបធិ ។ អមតនិព្វាន លោកហៅថា ឧបធិវិវេក បានដល់ ការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់កិលេស និព្វាន នេះឧបធិវិវេក ។

កាយវិវេក ( មាន ) ដល់បុគ្គលទាំងឡាយ ដែលមានកាយគេចចេញ ( ចាកពួក ) ត្រេកអរក្នុងការចេញចាកកាម ចិត្តវិវេក ( មាន ) ដល់បុគ្គលទាំងឡាយអ្នកមានចិត្តបរិសុទ្ធ ដល់នូវការផូរផង់ក្រៃលែង ឯឧបធិវិវេក ( មាន ) ដល់បុគ្គលមិនមានឧបធិសម្រេចព្រះនិព្វានដែលប្រាសចាកសង្ខារ ។

ពាក្យថា សន្តិ សេចក្តីថា សន្តិក្តី សន្តិបទក្តី ដោយអាការតែមួយទេ សន្តិបទនោះឯង ឈ្មោះថា អមតនិព្វាន បានដល់ការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ទុក្ខ និព្វាន សមដូចពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា នេះបទស្ងប់រម្ងាប់ នេះបទដ៏ឧត្តម គឺការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ទុក្ខ និព្វាន ។ មយ៉ាងទៀត ដោយអាការដទៃ ធម៌ទាំងឡាយណា ប្រព្រឹត្តទៅដើម្បីបាននូវការស្ងប់រម្ងាប់ ដើម្បីពាល់ត្រូវនូវការស្ងប់រម្ងាប់ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវការស្ងប់រម្ងាប់ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ធម៌ទាំងនេះ លោកហៅថា សន្តិបទ តាណបទ ( បទគឺទីពឹង ) លេណបទ ( បទគឺទីជ្រកកោន ) សរណបទ ( បទគឺជាទីរឭក ) អភយបទ ( បទគឺមិនមានភ័យ ) អច្ចុតបទ ( បទគឺមិនឃ្លាត )

អមតបទ ( បទគឺមិនស្លាប់ ) និព្វានបទ ( បទគឺនិព្វាន ) ។

ពាក្យថា ទ្រង់ស្វែងរកគុណធំ គឺព្រះមានព្រះភាគស្វែងរកគុណធំ ។ ព្រះមានព្រះភាគស្វែង ស្វែងរក ស្ទះស្វែងរកនូវសីលក្ខន្ធធំ ហេតុនោះឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។ ស្វែង ស្វែងរក ស្ទះស្វែងរកនូវសមាធិក្ខន្ធធំ បញ្ញាខន្ធធំ វិមុត្តិក្ខន្ធធំ វិមុត្តិញាណទស្សនក្ខន្ធធំ ហេតុនោះឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។ ស្វែង ស្វែងរក ស្ទះស្វែងរកនូវការកម្ចាត់បង់នូវគំនរងងឹតធំ ទំលាយបង់នូវវិបល្លាសធំ ដកចោលនូវសរគឺតណ្ហាធំ ទំលុះទំលាយនូវសន្ទុះគឺទិដ្ឋិធំ បន្សាត់បង់នូវមានះដូចជាទង់ធំ រម្ងាប់បង់នូវអភិសង្ខារធំ រលាស់ចោលនូវឱឃៈធំ ដាក់ចុះនូវភារៈធំ ផ្តាច់បង់នូវសង្សារវដ្តធំ រំលត់នូវសេចក្តីអន្ទះអន្ទែងធំ គ្របសង្កត់នូវសេចក្តីក្តៅក្រហាយធំ លើកឡើងនូវទង់ជ័យគឺធម៌ធំ ហេតុនោះឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។ ស្វែង ស្វែងរក ស្ទះស្វែងរកនូវសតិប្បដ្ឋានធំ សម្មប្បធានធំ ឥទ្ធិបាទធំ ឥន្ទ្រិយធំ ពលៈធំ ពោជ្ឈង្គធំ អដ្ឋង្គិកមគ្គដ៏ប្រសើរធំ អមតនិព្វាន ប្រយោជន៍ដ៏ក្រៃលែងធំ ហេតុនោះឈ្មោះថា ទ្រង់ស្វែងរកគុណធំ ។ ម្យ៉ាងទៀតព្រះមានព្រះភាគ គឺជាបុគ្គលដែលពួកសត្វមានសក្តិធំ ស្វែង ស្វែងរក ស្ទះស្វែងរកថា ព្រះពុទ្ធ ( គង់នៅ ) ក្នុងទីណា ព្រះមានព្រះភាគក្នុងទីណា ព្រះមានព្រះភាគជាទេវតាធំជាងទេវតាក្នុងទីណា ព្រះមានព្រះភាគ ជានរៈប្រសើរក្នុងទីណា ហេតុនោះឈ្មោះថា ស្វែងរកគុណធំ ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) នូវវិវេកផង សន្តិបទផង ចំពោះព្រះអង្គស្វែងរកគុណធំ ។

[ ៤ ] ពាក្យថា ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេសឲ្យរលត់ គឺភិក្ខុឃើញ មើល ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដដូចម្តេច ទើបញុំាងរាគៈរបស់ខ្លួនឲ្យរលត់ ញុំាងទោសៈឲ្យរលត់ ញុំាងមោហៈឲ្យរលត់ ញុំាងកោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ឲ្យរលត់ ឲ្យស្ងប់ ឲ្យរម្ងាប់ ឲ្យស្ងប់ស្ងៀម ឲ្យរម្ងាប់ចំពោះ ។ ពាក្យថា ភិក្ខុ គឺភិក្ខុជាល្បាណបុថុជ្ជនក្តី ភិក្ខុជាសេក្ខៈក្តី ហេតុនោះ ( ត្រាស់សួរថា ) ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេសឲ្យរលត់ ។

[ ៥ ] ពាក្យថា មិនប្រកាន់របស់អ្វី ក្នុងលោក គឺមិនប្រកាន់ មិនកាន់យក មិនស្ទាបអង្អែលដោយឧបាទានទាំងបួន ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា របស់អ្វីមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណនីមួយ ហេតុនោះ ( ត្រាស់សួរថា ) មិនប្រកាន់របស់អ្វី ក្នុងលោក ។ ហេតុនោះ ព្រះពុទ្ធនិមិត្តនោះ ( ត្រាស់សួរថា )

ខ្ញុំសូមសួរវិវេកផង សន្តិបទផង ចំពោះព្រះអង្គជាអាទិច្ចពន្ធុ
ទ្រង់ស្វែងរកគុណធំ ភិក្ខុឃើញដូចម្តេច ហើយញុំាងកិលេស
ឲ្យរលត់ ទើបមិនប្រកាន់នូវរបស់អ្វីក្នុងលោក ។

[ ៦ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសញ្ញានិងអស្មិមានះទាំងពួងដោយការយល់ តណ្ហាទាំងឡាយណាមួយជាខាងក្នុង បុគ្គលគប្បីមានសតិសព្វកាល សិក្សាដើម្បីបន្ទោបង់តណ្ហាទាំងនោះ ។

[ ៧ ] ពាក្យថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសញ្ញានិងអស្មិមានះទាំងពួងដោយការយល់ អធិប្បាយថា កិលេសជាគ្រឿងយឺតយូរ ឈ្មោះបបញ្ចសញ្ញា បានដល់ តណ្ហាបបញ្ចសញ្ញានិងទិដ្ឋិ-បបញ្ចសញ្ញា ។

ឫសគល់នៃតណ្ហាបបញ្ចសញ្ញា តើដូចម្តេច ។ គឺអវិជ្ជាជាឫសគល់ អយោ-និសោមនសិការជាឫសគល់ អស្មិមានះជាឫសគល់ អហិរិកជាឫសគល់ អនោត្តប្បជាឫសគល់ ឧទ្ធច្ចជាឫសគល់ នេះឫសគល់នៃតណ្ហាបបញ្ចសញ្ញា ។

ឫសគល់នៃទិដ្ឋិបបញ្ចសញ្ញា តើដូចម្តេច ។ គឺអវិជ្ជាជាឫសគល់ អយោ-និសោមនសិការជាឫសគល់ អស្មិមានះជាឫសគល់ អហិរិកជាឫសគល់ អនោត្តប្បជាឫសគល់ ឧទ្ធច្ចជាឫសគល់ នេះឫសគល់នៃទិដ្ឋិបបញ្ចសញ្ញា ។

ពាក្យថា ព្រះមានព្រះភាគ គឺជាពាក្យពោលដោយគោរព ។ ម្យ៉ាងទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវរាគៈ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវទោសៈ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវមោហៈ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវមានះ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវទិដ្ឋិ ។ ឈ្មោះថា មានព្រះភាគ

ព្រោះហេតុបំបាក់បង់នូវចំរូង ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុបំបាក់បង់នូវកិលេស ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុទ្រង់ចែករំលែកញែកនូវធម្មរតនៈ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុធ្វើនូវទីបំផុតនៃភពទាំងឡាយ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុចម្រើនព្រះកាយ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុចម្រើនសីល ព្រោះហេតុចម្រើនចិត្ត ព្រោះហេតុចម្រើនបញ្ញា ។ មួយទៀត ឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់គប់រកនូវសេនាសនទាំងឡាយដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាកមនុស្សសមគួរដល់ការពួនសម្ងំ ។ ឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ មួយទៀតឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀតឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀតឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃវិមោក្ខធម៌ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀតឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ អសុភសមាបត្តិ ។ មួយទៀតឈ្មោះថាមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥

ពលៈ ៥ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយទៀតឈ្មោះថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថា មានព្រះភាគនេះមិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ នេះជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ មានព្រះភាគបញ្ញត្តិថា មានព្រះភាគនុ៎ះ កើតដោយការធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបានចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់នៃពោធិព្រឹក្ស ។

ក្នុងពាក្យថា បុគ្គលគប្បីរំលត់អស្មិមានះទាំងពួងដោយការយល់ សេចក្តីថា បញ្ញា លោកហៅថាការយល់ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ពាក្យថា អស្មិមានះ គឺការប្រកាន់ថា អញមានក្នុងរូប សេចក្តីពេញចិត្តថាអញមានការដេកត្រាំរឿយៗ ថាអញមានសេចក្តីប្រកាន់ ថាអញមានក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ សេចក្តីពេញចិត្តថាអញមានការដេកត្រាំរឿយៗ ថាអញមាន ។ ពាក្យថា ព្រះមានព្រះភាគត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសង្ខានិងអស្មិមានះទាំងពួងដោយការយល់ បានសេចក្តីថា បុគ្គលគប្បីរំលត់ គប្បីចូលទៅរំលត់ គប្បីរំលត់មិនសល់ គប្បីរម្ងាប់ គប្បីឲ្យវិនាស គប្បីឲ្យស្ងប់រម្ងាប់ នូវឫសគល់នៃបបញ្ចសង្ខានិងអស្មិមានះផងទាំងពួងដោយការយល់ ហេតុនោះ ( ទ្រង់ត្រាស់

ថា ) ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់នៃបបញ្ចសញ្ញា និងអស្មិមានះទាំងពួងដោយការយល់ ។

[ ៨ ] អធិប្បាយពាក្យថា តណ្ហាទាំងឡាយណាមួយ ជាខាងក្នុង ត្រង់ពាក្យថា ណាមួយ គឺសព្វទាំងអស់ គ្រប់ទាំងអស់ ឥតសេសសល់ មិនមានសេសសល់ ពាក្យថា ណាមួយនុ៎ះ ជាពាក្យអស់រលីង ពាក្យថា តណ្ហា បានដល់ រូបតណ្ហា ។ល។ ធម្មតណ្ហា ។ ពាក្យថា ជាខាងក្នុង គឺតណ្ហានោះរមែងតាំងឡើងខាងក្នុង ហេតុនោះឈ្មោះថាខាងក្នុង ។ម្យ៉ាងទៀតចិត្តលោកហៅថា ខាងក្នុង បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធ ។ តណ្ហានោះទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នាប្រកបព្រមដោយចិត្ត ដោយមនៈ មានការកើតក្នុងទីជាមួយគ្នា មានការរលត់ក្នុងទីជាមួយគ្នា មានវត្ថុតែមួយ មានអារម្មណ៍តែមួយ ដូច្នេះទើបឈ្មោះថា ខាងក្នុង ហេតុនោះ ( ទ្រង់ត្រាស់ថា ) តណ្ហាទាំងឡាយណាមួយ ជាខាងក្នុង ។

[ ៩ ] អធិប្បាយពាក្យថា បុគ្គលគប្បីមានសតិសព្វកាល សិក្សាដើម្បីបន្ទោបង់តណ្ហាទាំងនោះ ត្រង់ពាក្យថា សព្វកាល គឺសព្វកាល គ្រប់កាល អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀង អស់កាលមិនដាច់ អស់កាលរឿយៗ មិនរោយរាយ ថែមហើយថែមទៀត ជាប់តគ្នា មិនមានចន្លោះ ដូចជារលកទឹកទង្គិចគ្នា ប៉ះពាល់គ្នា អស់បុរេភត្ត បច្ឆាភត្ត អស់បឋមយាម មជ្ឈិមយាម បច្ឆិមយាម អស់កាឡបក្ខ ជុណ្ហបក្ខ អស់រដូវ

ភ្លៀង រដូវរងា រដូវក្តៅ អស់ចំណែកបឋមវ័យ អស់ចំណែកមជ្ឈិមវ័យ អស់ចំណែកបច្ឆិមវ័យ ។ ពាក្យថា មានសតិ គឺមានសតិដោយហេតុ ៤ យ៉ាង គឺ ចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា មានសតិ ( ចម្រើន ) វេទនាសុវេទនានុបស្សនាសតិប្បដ្ឋាន ឈ្មោះថាមានសតិ ( ចម្រើន ) ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋាន ឈ្មោះថាមានសតិ ( ចម្រើន ) ធម្មេសុធម្មានុបស្សនាសតិប្បដ្ឋាន ឈ្មោះថាមានសតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺមានសតិ ព្រោះវៀរបង់នូវភាពមិនមានសតិ មានសតិព្រោះធ្វើនូវធម៌ទាំងឡាយ ដែលគួរធ្វើដោយសតិ មានសតិព្រោះកម្ចាត់បង់នូវធម៌ទាំងឡាយជាសត្រូវដល់សតិ មានសតិព្រោះមិនភ្លេចធម៌ទាំងឡាយ ជានិមិត្តរបស់សតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺមានសតិព្រោះប្រកបដោយសតិ មានសតិព្រោះស្ទាត់ដោយសតិ មានសតិព្រោះជំនាញដោយសតិ មានសតិព្រោះមិនបោះបង់សតិ ។ មានសតិដោយហេតុ ៤ ដទៃទៀត គឺមានសតិព្រោះមានសតិមិនដាច់ មានសតិព្រោះមានសតិជាប់ត មានសតិព្រោះមានសតិរឿយៗ មានសតិ ព្រោះប្រកបដោយធម៌ជាប់តៗគ្នា មានសតិព្រោះពុទ្ធានុស្សតិ មានសតិ ព្រោះធម្មានុស្សតិ មានសតិព្រោះសង្ឃានុស្សតិ មានសតិព្រោះសីលានុស្សតិ មានសតិព្រោះចាគានុស្សតិ មានសតិព្រោះទេវតានុស្សតិ មានសតិ ព្រោះអានាបានស្សតិ មានសតិព្រោះមរណស្សតិ មានសតិព្រោះកាយគតាសតិ មានសតិព្រោះឧបសមានុស្សតិ ។ សតិណាការរឭករឿយៗ រឭកចំពោះ ធម្មជាតិជាគ្រឿងរឭក ការរឭក ការចាំបាន ការមិនភ្លេច សេចក្តីមិនវង្វេង

ធម្មជាតិជាគ្រឿងរឭក សតិន្ទ្រិយ សតិពលៈ សម្មាសតិ សតិសម្ពោជ្ឈង្គ ជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង នេះលោកហៅថា សតិ ។ បុគ្គលណាជាអ្នកចូលទៅជិត ប្រកបចូលទៅជិត ប្រកបព្រមចូលទៅរក ចូលទៅរកព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយសតិនេះ បុគ្គលនោះលោកហៅថា មានសតិ ។

ពាក្យថា សិក្ខា បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មានសីល សង្រួមល្អក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីលជាទីពឹង សីលជាខាងដើម ការប្រព្រឹត្ត ការសង្រួម ការរវាំង ជាប្រធាន ជាប្រមុខ ដើម្បីបានកុសលធម៌ទាំងឡាយ នេះអធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កនិងវិចារៈ ចូលទុតិយជ្ឈាន ជាធម្មជាតិកើតក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ ។ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួល

សុខដោយនាមកាយផង ព្រះអរិយទាំងឡាយ តែងសរសើរបុគ្គលដែលបាន តតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជា គ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏ចូលតតិយជ្ឈាននោះ ព្រោះ លះបង់សុខផង ព្រោះលះបង់ទុក្ខផង ព្រោះវិនាសទៅនៃសោមនស្សនិងទោ-មនស្សក្នុងកាលមុន ចូលចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសេចក្តីបរិសុទ្ធ ដោយឧបេក្ខានិងសតិ នេះអធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ប្រព្រឹត្តទៅក្នុងសេចក្តីចម្រើននិងការវិនាស ជាប្រាជ្ញាដ៏ ប្រសើរ ជាគ្រឿងទំលុះទំលាយ ជាដំណើរទៅដើម្បីការអស់ទុក្ខដោយប្រពៃ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះការឲ្យកើត ទុក្ខ ដឹងច្បាស់តាមពិតថា នេះការរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅដើម្បីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា ទាំងនេះជាអាសវៈ ដឹង ច្បាស់តាមពិតថា នេះការឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះការរលត់ អាសវៈ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅដើម្បីការរលត់អាសវៈ នេះអធិប្បញ្ញាសិក្ខា ។

ពាក្យថា បុគ្គលគប្បីមានសតិសព្វកាល សិក្សាដើម្បីបន្ទោបង់តណ្ហាទាំង នោះ បានសេចក្តីថា គប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បី សិក្សាអធិប្បញ្ញាផង ដើម្បីនាំចេញ ដើម្បីនាំចេញចំពោះ ដើម្បីលះបង់ ដើម្បី រម្ងាប់ ដើម្បីលាស់ចោល ដើម្បីគ្រប់សង្កត់នូវតណ្ហាទាំងនោះ គប្បីទឹកសិក្សា

សិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា គប្បីឃើញសិក្សា គប្បីពិចារណាសិក្សា គប្បីអធិដ្ឋានចិត្តសិក្សា គប្បីជឿដោយសទ្ធាសិក្សា គប្បីផ្គងព្យាយាមសិក្សា គប្បីតាំងទុកនូវសតិសិក្សា គប្បីតំកល់ចិត្តសិក្សា គប្បីដឹងច្បាស់ដោយបញ្ញាសិក្សា គប្បីដឹងចំពោះនូវអភិញ្ញេយ្យធម៌សិក្សា គប្បីកំណត់ដឹងនូវបរិញ្ញេយ្យធម៌សិក្សា គប្បីលះបង់នូវបហាតព្វធម៌សិក្សា គប្បីចម្រើនភាវេតព្វធម៌សិក្សា គប្បីធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌សិក្សា ប្រព្រឹត្តទូទៅ ប្រព្រឹត្តទូទៅព្រម ប្រព្រឹត្តសមាទាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលគប្បីមានសតិសព្វកាលសិក្សា ដើម្បីបន្ទោបង់តណ្ហាទាំងនោះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលគប្បីរំលត់ឫសគល់ នៃបបញ្ចសង្ខានិងអស្មិមានះទាំងពួងដោយការយល់ តណ្ហាទាំងឡាយណាមួយ ជាខាងក្នុង បុគ្គលគប្បីមានសតិសព្វកាលសិក្សា ដើម្បីបន្ទោបង់នូវតណ្ហាទាំងនោះ ។

[ ១០ ] បុគ្គលគប្បីដឹងនូវធម៌ណាមួយ ជាខាងក្នុងឬខាងក្រៅ មិនគប្បីធ្វើនូវកម្លាំងដោយធម៌នោះ ការរលត់នោះពួកសប្បុរសមិនបានពោលហើយ ។

[ ១១ ] ពាក្យថា បុគ្គលគប្បីដឹងនូវធម៌ណាមួយជាខាងក្នុង អធិប្បាយថា បុគ្គលគប្បីដឹងគុណណាមួយរបស់ខ្លួន ក្នុងកុសលធម៌ក្តី ក្នុងអព្យាកតធម៌ក្តី ។ គុណរបស់ខ្លួន តើដូចម្តេច ។ បុគ្គល ( ចេញ ) អំពីត្រកូលខ្ពស់ហើយបួសក្តី អំពីត្រកូលធំហើយបួសក្តី អំពីត្រកូលមានភោគៈច្រើនហើយបួសក្តី អំពីត្រកូលមានភោគៈដ៏លើសលុបហើយបួសក្តី ( ដឹង ) ជាអាត្មាអញ ជាអ្នក

ល្បីល្បាញ មានយសជាងពួកគ្រហស្ថនិងបព្វជិតក្តី ( ដឹង ) ថាអញជាអ្នកបាន ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារក្តី ថាជាអ្នកទ្រទ្រង់ព្រះសូត្រក្តី ជាអ្នកទ្រទ្រង់វិន័យក្តី ជាធម្មកថិកក្តី ជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គក្តី ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គក្តី ជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គក្តី ជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គក្តី ជាអ្នកប្រព្រឹត្តសបទានចារិកធុតង្គក្តី ជាអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គក្តី ជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គក្តី ជាអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គក្តី បានបឋមជ្ឈានក្តី បានទុតិយជ្ឈានក្តី បានតតិយជ្ឈានក្តី បានចតុត្ថជ្ឈានក្តី បានអាកាសានញ្ចាយតនសមាបត្តិក្តី បានវិញ្ញាណញ្ចាយតនសមាបត្តិក្តី បានអាកិញ្ចញ្ញាយតនសមាបត្តិក្តី បាននេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ទាំងនេះហៅថា គុណរបស់ខ្លួន ។ បុគ្គលគប្បីដឹង គប្បីដឹងទូទៅ គប្បីដឹងផ្សេងៗ គប្បីដឹងចំពោះ គប្បីចាក់ធ្លុះនូវគុណណាមួយរបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីដឹងនូវធម៌ណាមួយ ជាខាងក្នុង ។ ពាក្យថា ខាងក្រៅ គឺគុណទាំងនោះ គប្បីមានដល់ឧបជ្ឈាយ៍ឬអាចារ្យ ហេតុនោះ ( ទ្រង់ត្រាស់ ) ថា ជាខាងក្នុងឬខាងក្រៅ ។

[ ១២ ] ពាក្យថា បុគ្គលមិនគប្បីធ្វើនូវកម្លាំង ដោយធម៌នោះ គឺមិនគប្បីធ្វើនូវកម្លាំង មិនគប្បីធ្វើនូវសេចក្តីរឹងត្អឹង មិនគប្បីធ្វើនូវសេចក្តីប្រកាន់ មិនគប្បីធ្វើនូវការប៉ោងឡើងមិនគប្បីធ្វើនូវការក្រអឺតក្រអោងដោយគុណរបស់ខ្លួនផង ដោយគុណរបស់បុគ្គលដទៃផង មិនគប្បីញុំាងសេចក្តីប្រកាន់ឲ្យកើតដោយគុណនោះ មិនគប្បីរឹងរូស រឹងរូសក្រៃលែង មានក្បាលងើបឡើងដោយ

គុណនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើនូវកម្លាំងដោយធម៌នោះ ។

[ ១៣ ] ពាក្យថា សេចក្ដីរលត់នោះ ពួកសប្បុរសមិនពោលហើយ គឺសេចក្ដីរលត់នោះពួកអ្នកស្ងប់ អ្នករម្ងាប់ សប្បុរស គឺព្រះពុទ្ធ សាវករបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធទាំងឡាយ មិនពោល មិនពោលសព្វគ្រប់ មិនប្រាប់ មិនសម្ដែង មិនបញ្ញត្ត មិនតាំងទុក មិនបើក មិនចែក មិនធ្វើឲ្យរាក់ មិនប្រកាសហើយ ហេតុនោះទ្រង់ត្រាស់ថា សេចក្ដីរលត់នោះ ពួកសប្បុរសមិនពោលហើយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលគប្បីដឹងនូវធម៌ណាមួយជាខាងក្នុងឬខាងក្រៅ បុគ្គលមិនគប្បីធ្វើនូវកម្លាំងដោយធម៌នោះ សេចក្ដីរលត់នោះពួកសប្បុរសមិនពោលហើយ ។

[ ១៤ ] បុគ្គលមិនគប្បីសម្គាល់ថាប្រសើរជាង ថាថោកទាបជាង ឬថាស្មើគ្នាដោយគុណនោះឡើយ បុគ្គលបើត្រូវអាការទាំងឡាយ មានសភាពជាអនេកគ្របសង្កត់ហើយ មិនគប្បីតាំងខ្លួនទេ ។

[ ១៥ ] ពាក្យថា មិនគប្បីសម្គាល់ថាប្រសើរជាងដោយគុណនោះ គឺមិនគប្បីញ៉ាំងមានះឲ្យកើតថា អញជាអ្នកប្រសើរជូច្នេះ ដោយជាតិក្ដី គោត្តក្ដី ភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្ដី ភាពនៃខ្លួនមានសម្បុរល្អក្ដី ទ្រព្យក្ដី ការស្វាធ្យាយក្ដី ការងារក្ដី សិល្បៈក្ដី ថ្នាក់នៃវិជ្ជាក្ដី សុតៈក្ដី បដិភាណក្ដី វត្ថុណាមួយក្ដី ហេតុនោះទ្រង់ត្រាស់ថា មិនគប្បីសម្គាល់ថាប្រសើរជាង ដោយគុណនោះ ។

[ ១៦ ] ពាក្យថា ថោកទាបជាង ឬថាស្មើគ្នា គឺបុគ្គលមិនគប្បីញ៉ាំងសេចក្តីប្រកាន់ទាប ឲ្យកើតឡើងថា អញជាអ្នកថោកទាបដូច្នេះ ដោយជាតិក្តី គោត្តក្តី ។បេ។ វត្ថុណាមួយក្តី មិនគប្បីញ៉ាំងសេចក្តីប្រកាន់ឲ្យកើតឡើងថាអញជាអ្នកស្មើគ្នាដូច្នេះ ដោយជាតិក្តី គោត្តក្តី ភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ភាពនៃខ្លួនមានសម្បុរល្អក្តី ទ្រព្យក្តី ការស្វាធ្យាយក្តី ការងារក្តី សិល្បៈក្តី ថ្នាក់នៃវិជ្ជាក្តី សុតៈក្តី បដិភាណក្តី វត្ថុណាមួយក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ថោកទាបជាង ឬថាស្មើគ្នា ។

[ ១៧ ] ពាក្យថា បុគ្គលបើត្រូវអាការៈទាំងឡាយមានសភាពជាអនេកគ្របសង្កត់ហើយ គឺអាការៈមានប្រការជាអនេកគ្របសង្កត់ បៀតបៀន រួបរឹតចោមរោមហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលបើត្រូវអាការៈទាំងឡាយមានសភាពជាអនេកគ្របសង្កត់ហើយ ។

[ ១៨ ] ពាក្យថា មិនគប្បីតាំងខ្លួន សេចក្តីថា អត្តា លោកហៅថា ខ្លួន បុគ្គលមិនគប្បីតាំង តែងតាំង ដល់នូវការតែងតាំងខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីតាំងខ្លួន ព្រោះហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនគប្បីសម្គាល់ថាប្រសើរជាង ថាថោកទាបជាង ឬថា
ស្មើគ្នាដោយគុណនោះឡើយ បុគ្គលបើត្រូវអាការៈទាំងឡាយ
មានសភាពជាអនេកគ្របសង្កត់ហើយ មិនគប្បីតាំងខ្លួនទេ ។

[ ១៩ ] ភិក្ខុគប្បីរម្ងាប់កិលេសខាងក្នុងតែម្យ៉ាង មិនគប្បីស្វែងរកនូវការស្ងប់ដោយឧបាយដទៃទេ ភិក្ខុរម្ងាប់កិលេសខាងក្នុង អត្តាមិនមានឬនិរត្តានឹង

មានពីណា ។

[ ២០ ] ពាក្យថា គប្បីរម្ងាប់កិលេសខាងក្នុងតែម្យ៉ាង គឺគប្បីរម្ងាប់រាគៈ គប្បីរម្ងាប់ទោសៈ គប្បីរម្ងាប់មោហៈខាងក្នុង គប្បីរម្ងាប់ គប្បីចូលទៅរម្ងាប់ គប្បីឲ្យស្ងប់ គប្បីឲ្យរលត់ គប្បីឲ្យរម្ងាប់ចំពោះនូវកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈនិងកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីរម្ងាប់កិលេសខាងក្នុងតែម្យ៉ាង ។

[ ២១ ] ពាក្យថា ភិក្ខុមិនគប្បីស្វែងរកនូវការរម្ងាប់ដោយឧបាយដទៃទេ គឺភិក្ខុមិនគប្បីស្វែងរក មិនគប្បីគន់រក មិនគប្បីគន់រករឿយៗនូវការស្ងប់ ការចូលទៅជិតស្ងប់ ការរម្ងាប់ ការរលត់ ការស្ងប់រម្ងាប់ដោយផ្លូវដទៃ ផ្លូវមិនបរិសុទ្ធ បដិបទាខុស ផ្លូវមិនមែនជាទីស្រោចស្រង់សត្វ វៀរចាកសតិប្បដ្ឋាន វៀរចាកសម្មប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គ វៀរចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីស្វែងរកនូវការរម្ងាប់ដោយឧបាយដទៃទេ ។

[ ២២ ] ពាក្យថា ភិក្ខុរម្ងាប់កិលេសខាងក្នុងហើយ គឺរម្ងាប់រាគៈ រម្ងាប់ទោសៈ ខាងក្នុង ។បេ។ រម្ងាប់ ចូលទៅរម្ងាប់ ស្ងប់ រលត់ ឲ្យស្ងប់រម្ងាប់ នូវអកុសលាភិសង្ខារទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុរម្ងាប់កិលេស

ខាងក្នុងហើយ ។

[ ២៣ ] អធិប្បាយពាក្យថា អត្តាមិនមានឬថានិរត្តា ( នឹងមាន ) អំពីណា ត្រង់ពាក្យថា មិនមាន គឺជាពាក្យហាមឃាត់ ។

ពាក្យថា អត្តា គឺសស្សតទិដ្ឋិមិនមាន ពាក្យថា និរត្តា គឺឧច្ឆេទទិដ្ឋិមិនមាន ។ ការប្រកាន់ថា អត្តាមិនមាន ការគប្បីលែងថា និរត្តាមិនមាន ។ ការប្រកាន់នៃបុគ្គលណាមិនមាន ការគប្បីលែងនៃបុគ្គលនោះមិនមាន ។ ការគប្បីលែងនៃបុគ្គលណាមាន ការប្រកាន់នៃបុគ្គលនោះក៏មាន ។ ព្រះអរហន្តកន្លងនូវការប្រកាន់និងការលែង គឺប្រព្រឹត្តកន្លងនូវសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ។ ព្រះអរហន្តនោះមានការនៅ ( ក្នុងអរិយវាសៈ ) នៅរួចហើយ មានការប្រព្រឹត្តសន្សំហើយ ។បេ។ កពថ្មីនៃលោកមិនមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា ) អត្តាមិនមានឬថានិរត្តា ( នឹងមាន ) អំពីណា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ហើយថា

ភិក្ខុគប្បីរម្ងាប់កិលេសខាងក្នុងតែម្យ៉ាង មិនគប្បីស្វែងរកនូវការរម្ងាប់ដោយឧបាយដទៃទេ ភិក្ខុរម្ងាប់កិលេស ខាងក្នុងហើយ អត្តាមិនមានទេ ឬថានិរត្តានឹងមានអំពីណា ។

[ ២៤ ] រលកមិនកើតត្រង់ទីពាក់កណ្តាល នៃសមុទ្ទ ( សមុទ្ទនោះ ) តាំងនៅនឹងយ៉ាងណាមិញ ភិក្ខុគប្បីតាំងនៅនឹងនួន មិនញាប់ញ័រយ៉ាងនោះឯង មិនគប្បីធ្វើនូវការប៉ោងឡើងក្នុងហេតុនីមួយ ។

[ ២៥ ] ពាក្យថា រលកមិនកើតត្រង់ទីពាក់កណ្តាលនៃសមុទ្ទ ( សមុទ្ទនោះ )

តាំងនៅនឹងយ៉ាងណាមិញ អធិប្បាយថា សមុទ្ទមានជំរៅទៅខាងក្រោមប្រាំបី ម៉ឺនបួនពាន់យោជន៍ ទឹកខាងក្រោមបួនម៉ឺនយោជន៍ កម្រើកដោយហ្វូងត្រីនិង អណ្ដើក ទឹកខាងលើបួនម៉ឺនយោជន៍ កម្រើកដោយខ្យល់ ទឹកត្រង់កណ្ដាលបួន ពាន់យោជន៍មិនកម្រើក មិនរង្គើ មិនញ័រ មិនរញ្ជួយ មិនរញ្ជួយខ្លាំង មិន វិល ជាសមុទ្ទមិនកម្រើក មិនរំជួល មិនកក្រើក មិនកករ មិនផុល ជាសមុទ្ទ ស្ងប់ស្ងាត់ រលកក្នុងទីនោះមិនកើតឡើង តាំងនៅនឹងយ៉ាងណាមិញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រលកមិនកើតឡើងត្រង់ទីពាក់កណ្ដាលសមុទ្ទ តាំងនៅនឹង យ៉ាងណាមិញ ( ភិក្ខុតាំងនៅនឹង ) យ៉ាងនេះឯង ។ម្យ៉ាងទៀតសីទន្ដរសមុទ្ទ ក្នុងចន្លោះភ្នំទាំង ៧ ទឹកក្នុងសមុទ្ទនោះមិនកម្រើក មិនរង្គើ មិនញ័រ មិនរញ្ជួយ មិនរញ្ជួយខ្លាំង មិនវិល ជាសមុទ្ទមិនកម្រើក មិនរំជួល មិនកម្រើក មិនកករ មិនផុល ជាសមុទ្ទស្ងប់ស្ងាត់ រលកមិនកើតក្នុងសមុទ្ទនោះ សមុទ្ទតាំងនៅនឹង ហេតុនោះ ( ទ្រង់ត្រាស់ថា ) រលកមិនកើតឡើងត្រង់ទីពាក់កណ្ដាលនៃសមុទ្ទ ( សមុទ្ទនោះ ) តាំងនៅនឹងយ៉ាងណាមិញ ( ភិក្ខុតាំងនៅនឹង ) យ៉ាងនេះឯង ។

[ ២៦ ] អធិប្បាយពាក្យថា ភិក្ខុគប្បីតាំងនៅនឹងនួន មិនញាប់ញ័រយ៉ាង នោះឯង ត្រង់ពាក្យថា យ៉ាងនោះ គឺជាពាក្យញុំាងសេចក្ដីឧបមា ឲ្យសម្រេច ពាក្យថា តាំងនៅនឹងនួន គឺមិនកម្រើក មិនកក្រើកព្រោះលាភ មិនកម្រើក ព្រោះឥតលាភ មិនកម្រើកព្រោះយស មិនកម្រើកព្រោះឥតយស មិនកម្រើក ព្រោះសេចក្ដីសរសើរ មិនកម្រើកព្រោះនិន្ទា មិនកម្រើកព្រោះសេចក្ដីសុខ មិនកម្រើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ មិនញាប់ញ័រខ្លាំង មិនញាប់ញ័រ

ព្រមសូម្បីព្រោះទុក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តាំងនៅនឹងយ៉ាងនោះឯង ។ ពាក្យថា មិនញាប់ញ័រ សេចក្តីថា តណ្ហា ហៅថាការញាប់ញ័របានខាងតម្រេក តម្រេកខ្លាំង ។ល។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាជាគ្រឿងញាប់ញ័រនោះ បុគ្គលណាលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះ លោកហៅថាជាអ្នកមិនញាប់ញ័រ ។ បុគ្គលអ្នកមិនញាប់ញ័រព្រោះលះបង់តណ្ហាជាគ្រឿងញាប់ញ័រ ។ បុគ្គលនោះរមែងមិនញាប់ញ័រសូម្បីព្រោះលាភ មិនញាប់ញ័រសូម្បីព្រោះឥតលាភ មិនញាប់ញ័រសូម្បីព្រោះយស មិនញាប់ញ័រសូម្បីព្រោះឥតយស មិនញាប់ញ័រសូម្បីព្រោះសេចក្តីសរសើរ មិនញាប់ញ័រសូម្បីព្រោះនិន្ទា មិនញាប់ញ័រសូម្បីព្រោះសុខ មិនញាប់ញ័រ មិនឃ្លេងឃ្លោង មិនរន្ធត់ មិនរន្ធត់ខ្លាំង មិនត្រឡប់រន្ធត់ព្រមសូម្បីព្រោះទុក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុ គប្បីតាំងនៅនឹងនួន មិនញាប់ញ័រយ៉ាងនោះឯង ។

[ ២៧ ] អធិប្បាយពាក្យថា មិនគប្បីធ្វើនូវការប៉ោងឡើងក្នុងហេតុនីមួយ ត្រង់ពាក្យថា ការប៉ោងឡើង បានដល់ ការប៉ោងឡើង ៧ គឺការប៉ោងឡើងគឺរាគៈ ការប៉ោងឡើងគឺទោសៈ ការប៉ោងឡើងគឺមោហៈ ការប៉ោងឡើងគឺមានះ ការប៉ោងឡើងគឺទិដ្ឋិ ការប៉ោងឡើងគឺកិលេស ការប៉ោងឡើងគឺកម្ម ។ ភិក្ខុមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើត មិនគប្បីបង្កើតចំពោះនូវការប៉ោងឡើងនោះ ។ ពាក្យថា ក្នុងហេតុនីមួយ គឺក្នុងហេតុនីមួយអ្វីៗ ណាៗ ខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ហេតុនោះ ( ទ្រង់

ត្រាស់ថា ) មិនគប្បីធ្វើនូវការប្រឹងឡើងក្នុងហេតុនីមួយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ហើយថា

រលកមិនកើតត្រង់ទីពាក់កណ្តាល នៃសមុទ្រ ( សមុទ្រនោះ )
តាំងនៅនឹងយ៉ាងណាមិញ ភិក្ខុគប្បីតាំងនៅនឹងនួន មិនញាប់
ញ័រយ៉ាងនោះឯង មិនគប្បីធ្វើនូវការប្រឹងឡើងក្នុងហេតុនីមួយ ។

[ ២៨ ] ( ព្រះពុទ្ធនិមិត្តត្រាស់ថា ) ព្រះអង្គមានចក្ខុបើកហើយ បានសម្តែងធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ជាគ្រឿងនាំចេញនូវអន្តរាយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គសម្តែងនូវបដិបទា បាតិមោក្ខនិងសមាធិ ។

[ ២៩ ] អធិប្បាយពាក្យថា ព្រះអង្គមានចក្ខុបើកហើយ បានសម្តែង ត្រង់ពាក្យថា បានសម្តែង គឺបានសម្តែងប្រាប់ ពន្យល់ បញ្ញត្ត តែងតាំង បើក បែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ ( ទ្រង់ត្រាស់ ) ថា បានសម្តែង ។ ពាក្យថា មានចក្ខុបើកហើយ គឺព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយចក្ខុ ៥ គឺមានចក្ខុបើក ដោយមំសចក្ខុ ១ មានចក្ខុបើក ដោយទិព្វចក្ខុ ១ មានចក្ខុបើក ដោយបញ្ញាចក្ខុ ១ មានចក្ខុបើក ដោយពុទ្ធចក្ខុ ១ មានចក្ខុបើក ដោយសមន្តចក្ខុ ១ ។

ព្រះមានព្រះភាគមានចក្ខុបើក ដោយមំសចក្ខុ តើដូចម្តេច ។ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគមានសម្បុរ ៥ គឺសម្បុរខៀវ ១ សម្បុរលឿង ១ សម្បុរក្រហម ១ សម្បុរខ្មៅ ១ សម្បុរស ១ ។ រោមព្រះនេត្របិតនៅត្រង់ទីណា ទីនោះមានសម្បុរខៀវ ខៀវល្អ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កា

ត្របកភ្នែក ។ ទីក្រៅអំពីនោះមានសម្បុរលឿង លឿងល្អ ដូចសម្បុរមាស គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាកណ្ណិការ ។ រណ្តៅព្រះនេត្រទាំងពីរខាងរបស់ព្រះមានព្រះភាគមានសម្បុរក្រហម ក្រហមល្អ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងអណ្តើកមាស ។ ត្រង់កណ្តាលមានសម្បុរខ្មៅ ខ្មៅល្អ មិនមានសៅហ្មង យ៉ាងស្និទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្លែផ្គាំ ។ ក្រៅអំពីនោះមានសម្បុរស សល្អ សស្រស់ សសុទ្ធ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាយព្រឹក ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ ទាំងយប់ទាំងថ្ងៃ ដោយព្រះមំសចក្ខុតាមប្រក្រតីនោះដែលរាប់ចូលក្នុងអត្តភាពកើតអំពីសុចរិតកម្មក្នុងកាលមុន ។ ទោះបីងងឹតប្រកបដោយអង្គ ៤ គឺព្រះអាទិត្យអស្តង្គត ១ ថ្ងៃឧបោសថខាងកាឡបក្ខ ១ ដងព្រៃដែលញឹក ១ អាកាសមេឃដ៏ធំតាំងឡើង ១ ព្រះមានព្រះភាគ ទ្រង់ទតឃើញជុំវិញចម្ងាយ ១ យោជន៍ក្នុងទីងងឹតប្រកបដោយអង្គ ៤ សូម្បីមានសភាពយ៉ាងនេះ ។ មិនមានជញ្ជាំង សន្ទះទ្វារ កំពែង ភ្នំ គុម្ពឈើ វល្លិ៍ ជាគ្រឿងរាំងដើម្បីឃើញរូបទាំងឡាយទេ ។ បើទុកជាគេដាក់គ្រាប់ល្ងមួយគ្រាប់ក្នុងរទេះពេញ ដោយល្ងធ្វើឲ្យជាគ្រឿងចំណាំ ក៏នៅតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ងនោះបានវិញដដែល ។ ព្រះមំសចក្ខុជាប្រក្រតីរបស់ព្រះមានព្រះភាគបរិសុទ្ធិយ៉ាងនេះ ។ ព្រះមានព្រះភាគឈ្មោះថា មានចក្ខុបើកហើយដោយមំសចក្ខុយ៉ាងនេះឯង ។

ព្រះមានព្រះភាគ មានចក្ខុបើកហើយ ដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វបរិសុទ្ធិកន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ទត

ឃើញពួកសត្វ កំពុងច្យុត កំពុងកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទានអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្យ៉ាងទៀត ពួកសត្វដ៏ចម្រើននេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀល នូវពួកព្រះអរិយៈជាសម្មាទិដ្ឋិ សមាទានអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះលុះបែកធ្លាយរាងកាយស្លាប់ទៅក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រះមានព្រះភាគទ្រង់មានចក្ខុដូចជាទិព្វ បរិសុទ្ធិកន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ឃើញពួកសត្វដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ទ្រង់ជ្រាបនូវពួកសត្វ ដែលអន្ទោលទៅតាមកម្មយ៉ាងនេះ ។ មួយទៀតកាលបើព្រះមានព្រះភាគប្រាថ្នានឹងឃើញ គប្បីឃើញលោកធាតុមួយខ្លះ ឃើញលោកធាតុពីរខ្លះ ឃើញលោកធាតុបីខ្លះ ឃើញលោកធាតុបួនខ្លះ ឃើញលោកធាតុ ៥ ខ្លះ ឃើញលោកធាតុ ១០ ខ្លះ ឃើញលោកធាតុ ២០ ខ្លះ ឃើញលោកធាតុ ៣០ ខ្លះ ឃើញលោកធាតុ ៤០ ខ្លះ ឃើញលោកធាតុ ៥០ ខ្លះ ឃើញលោកធាតុយ៉ាងតូច ១ ពាន់ខ្លះ ឃើញលោកធាតុជាកណ្តាល មួយពាន់ពីរដាន់ខ្លះ ទតឃើញលោកធាតុមួយពាន់បី

ជាន់ខ្ពស់ ឈ្មោះថាទតឃើញមហាសហស្សលោកធាតុខ្ពស់ ។ មួយទៀតបើព្រះមានព្រះភាគទ្រង់ប្រាថ្នាត្រឹមណា គប្បីទតឃើញត្រឹមណោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគបរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគ ឈ្មោះថាមានចក្ខុបើកហើយដោយចក្ខុដូចជាទិព្វយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមុត មានប្រាជ្ញាទំលុះទំលាយនូវកិលេស ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា បែកព្រះញាណ ទ្រង់បានបដិសម្ភិទា ទ្រង់ដល់នូវសេចក្តីក្លៀវក្លា ៤ យ៉ាង ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសដ៏ប្រសើរ ជាបុរសដូចសីហៈ ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរសអាចនាំទៅនូវធុរៈ ជាអនន្តញ្ញាណ មានតេជៈជាអនន្ត មានយសជាអនន្ត ទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានធនជាន ដឹកនាំ ទូន្មានប្រៀនប្រដៅ ពន្យល់ ធ្វើសត្វឲ្យពិនិត្យ សម្លឹង ធ្វើសត្វឲ្យជ្រះថ្លា ។ ព្រោះថា ព្រះមានព្រះភាគនោះទ្រង់ញុំាងមគ្គដែលមិនទាន់កើតឡើងឲ្យកើតឡើង ទ្រង់ញុំាងមគ្គដែលមិនទាន់កើតសព្វគ្រប់ឲ្យកើតសព្វគ្រប់ ទ្រង់ប្រាប់ផ្លូវដែលមិនទាន់បានប្រាប់ ទ្រង់យល់ផ្លូវ ទ្រង់ជ្រាបច្បាស់នូវផ្លូវ ទ្រង់វាងវៃក្នុងផ្លូវ ។ ឯពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវមកតាមក្រោយ ។ ព្រោះថា ព្រះមានព្រះភាគនោះទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ ទ្រង់មានចក្ខុ មានធម៌ មានញាណ មានភាពដ៏ប្រសើរ ទ្រង់ពោលសម្តែង បង្អោននូវប្រយោជន៍ ទ្រង់ប្រទានអមតធម៌ ជា

ម្ចាស់នៃធម៌ ជាព្រះតថាគត ។ ហេតុណាមួយដែលព្រះមានព្រះភាគនោះមិនជ្រាប មិនឃើញ មិនជ្រាបច្បាស់ មិនធ្វើឲ្យជាក់ច្បាស់ មិនប៉ះពាល់ដោយបញ្ញាមិនមាន ។ ធម៌ទាំងពួងរាប់ទាំងអតីត អនាគតនិងបច្ចុប្បន្នរមែងមកកាន់គន្លងចំមុខព្រះញាណ នៃព្រះពុទ្ធមានព្រះភាគដោយអាការៈគ្រប់យ៉ាង ។ ឈ្មោះថា វត្ថុណាមួយដែលត្រូវយល់ត្រូវដឹង គឺប្រយោជន៍ខ្លួនក្តី ប្រយោជន៍ជនដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់ក្តី ប្រយោជន៍កំបាំងក្តី ប្រយោជន៍ដែលត្រូវនាំចេញក្តី ប្រយោជន៍ដែលបាននាំចេញស្រាប់ហើយក្តី ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ផូរផង់ក្តី ប្រយោជន៍យ៉ាងសំខាន់ក្តី ទាំងអស់នោះរមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃពុទ្ធ-ញ្ញាណ ។ ព្រះពុទ្ធមានព្រះភាគ មានព្រះញាណមិនទើសទាល់ក្នុងអតីត មានព្រះញាណមិនទើសទាល់ក្នុងអនាគតក្នុងបច្ចុប្បន្ន ។ កាយកម្មទាំងអស់ប្រ-ព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ មនោកម្មទាំងអស់ប្រព្រឹត្តទៅតាមព្រះញាណ របស់ព្រះពុទ្ធមានព្រះភាគ ។ ហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណាហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុតហេតុដែលត្រូវដឹង ក៏មានញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង ហេតុដែលត្រូវដឹងក៏មិនប្រព្រឹត្តកន្លងព្រះញាណ ធម៌ទាំងនោះរមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ បាតស្មុគទាំងពីរដែលស្និទ្ធគ្នាល្អ បាត

ស្នុកខាងក្រោម មិនប្រព្រឹត្តហួសបាតស្នុកខាងលើ បាតស្នុកខាងលើមិនប្រព្រឹត្ត ហួសបាតស្នុកខាងក្រោម រមែងតាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នាយ៉ាងណា ហេតុដែលត្រូវដឹងផង ព្រះញាណផងរបស់ព្រះពុទ្ធមានព្រះភាគតាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នាយ៉ាងនោះដែរ គឺហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ។ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹងក៏មានព្រះញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង គន្លងដែលត្រូវដឹងមិនប្រព្រឹត្តកន្លងព្រះញាណ ធម៌ទាំងនោះរមែងតាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ។ ធម៌ទាំងអស់ជាប់ដោយការនឹក ជាប់ដោយការប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទ នៃព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគប្រព្រឹត្តទៅក្នុងសត្វទាំងពួង ។ ព្រះមានព្រះភាគទ្រង់ជ្រាបអាសយៈ ជ្រាបអនុសយៈ ជ្រាបចរិត ជ្រាបនូវការបង្អោនទៅនៃសត្វទាំងពួង ជ្រាបពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយក្រ ជាសត្វមានភព្វនិងឥតភព្វ ។ លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សសាមញ្ញ រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញ្ញាណ ហ្វូងត្រីនិងអណ្តើកណាមួយ ដោយហោចទៅរាប់យកត្រីឈ្មោះ តិមិតិមង្គលៈ

ប្រព្រឹត្តទៅក្នុងខាងក្នុងនៃមហាសមុទ្ទយ៉ាងណា លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សសាម័ញ្ញ ប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញ្ញាណយ៉ាងនោះដែរ ។ ហ្វូងបក្សីណាមួយដោយហោចទៅរាប់យកគ្រុឌឈ្មោះវេនតេយ្យ ប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាសយ៉ាងណា ពួកជនណាមានបញ្ញាស្មើនឹងព្រះសារីបុត្ត សូម្បីជនទាំងនោះ ប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញ្ញាណយ៉ាងនោះដែរ ។ ព្រះពុទ្ធញ្ញាណរមែងផ្សាយគ្របបញ្ញានៃពួកទេវតានិងមនុស្សហើយឋិតនៅ ។ ពួកជនណាមួយជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ជាអ្នកមានប្រាជ្ញាល្អិត មានបរប្បវាទធ្វើហើយ មានភាពដូចជាខ្នាន់ធ្នូ អ្នកបាញ់រោមកន្ទុយ ហាក់ដូចជាទំលុះទំលាយ នូវទិដ្ឋិទាំងឡាយដោយប្រាជ្ញា ជនទាំងនោះតាក់តែងរឿយៗនូវប្រស្នា ហើយចូលទៅសួរព្រះតថាគត ។ ប្រស្នាទាំងនោះលុះព្រះមានព្រះភាគទ្រង់បានសម្តែង បានដោះហើយក៏ទៅជាប្រស្នាដែលព្រះអង្គទ្រង់សម្តែងចេញនូវហេតុនិងជាប្រស្នាដែលព្រះអង្គទ្រង់បញ្ឈប់ទុក ។ ជនទាំងនោះនាំគ្នាចុះចូលព្រះមានព្រះភាគ ។ លំដាប់នោះព្រះមានព្រះភាគ ទ្រង់រុងរឿងក្រៃពេកក្នុងប្រជុំនោះដោយប្រាជ្ញា ។ ព្រះមានព្រះភាគឈ្មោះថា មានចក្ខុបើកហើយដោយបញ្ញាចក្ខុយ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ បានទតឃើញពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា

មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយក្រ ទាំងសត្វពួកខ្លះជាអ្នកឃើញទោសក្នុងបរលោកថា គួរខ្លាច ។ ដូចជលជាតិពួកខ្លះ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តី ក្នុងត្រពាំងព្រលឹតក្តី ត្រពាំងឈូកក្រហមក្តី ត្រពាំងឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក លូតតាមទឹក លិចចុះខាងក្នុងដែលទឹកចិញ្ចឹមហើយ ផ្កាជលជាតិពួកខ្លះ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅស្មើនឹងទឹក ជលជាតិពួកខ្លះ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅផុតអំពីទឹក មិនទទឹកដោយទឹកយ៉ាងណា ព្រះមានព្រះភាគទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ បានទតឃើញពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយក្រ ទាំងសត្វពួកខ្លះជាអ្នកឃើញទោសក្នុងបរលោកថា គួរខ្លាចក៏យ៉ាងនោះដែរ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគទ្រង់សម្តែងអសុភកថាចំពោះបុគ្គលជារាគចរិត ព្រះមានព្រះភាគទ្រង់ត្រាស់ប្រាប់មេត្តាភាវនា ចំពោះបុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគទ្រង់ញុំាងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងឧទ្ទេស ( ការរៀនបាលី ) ក្នុងបរិបុច្ឆា ( ការរៀនអដ្ឋកថា ) ក្នុងការស្តាប់ធម៌តាមកាល ក្នុងការសាកសួរធម៌តាមកាល ក្នុងការនៅរួមជាមួយនឹងគ្រូ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់

អានាបានស្សតិចំពោះបុគ្គលជាវិតក្កចរិត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់និមិត្តគួរជ្រះថ្លា គឺការត្រាស់ដឹងប្រពៃនៃព្រះពុទ្ធ ការទ្រទ្រង់ល្អនៃធម៌ ការប្រតិបត្តិប្រពៃនៃព្រះសង្ឃនិងសីលទាំងឡាយសម្រាប់ខ្លួន ចំពោះបុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគទ្រង់ត្រាស់ប្រាប់នូវវិបស្សនានិមិត្ត គឺអាការមិនទៀង អាការជាទុក្ខ អាការមិនមែនខ្លួនចំពោះបុគ្គលជាញាណចរិត ។

បុគ្គលឋិតនៅលើកំពូលភ្នំថ្ម គប្បីឃើញប្រជុំជនក្នុងទីជុំវិញបាន
យ៉ាងណា បពិត្រព្រះសុមេធៈ ទ្រង់មានសមន្តចក្ខុ ព្រះអង្គជា
បុគ្គលប្រាសចាកសេចក្ដីសោក សូមឡើងកាន់ប្រាសាទ គឺធម៌
ហើយទតមើលប្រជុំជនដែលខ្វល់ដោយសេចក្ដីសោកត្រូវជាតិ
និងជរាគ្របសង្កត់យ៉ាងនោះដែរ ។

ព្រះមានព្រះភាគឈ្មោះថា មានចក្ខុបើកហើយ ដោយពុទ្ធចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុបើកហើយ ដោយសមន្តចក្ខុ តើដូចម្ដេច ។ ព្រះសព្វញ្ញុតញ្ញាណ ហៅថាសមន្តចក្ខុ ។ ព្រះមានព្រះភាគទ្រង់ប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយសព្វញ្ញុតញ្ញាណ ។

ហេតុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគនោះ ទ្រង់មិន
ឃើញឬថាមិនជ្រាប មិនយល់ មិនមានទេ ហេតុណាដែល
ត្រូវដឹង ព្រះមានព្រះភាគទ្រង់ជ្រាបនូវហេតុ ( នោះ ) ទាំងអស់
ព្រោះហេតុនោះ ព្រះតថាគតទើបឈ្មោះថា សមន្តចក្ខុ ។

ព្រះមានព្រះភាគទ្រង់ឈ្មោះថា មានចក្ខុបើកហើយដោយសមន្តចក្ខុយ៉ាងនេះឯង ហេតុនោះទ្រង់ត្រាស់ថា មានចក្ខុបើកហើយ បានសម្តែង ។

[ ៣០ ] អធិប្បាយពាក្យថា ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ជាគ្រឿងនាំចេញនូវអន្តរាយ ត្រង់ពាក្យថា ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង គឺមិនជឿតាមគេថាយ៉ាងនេះៗ មិនមែនដោយឮថាដូច្នេះៗ មិនមែនដោយឮតៗគ្នា មិនមែនដោយការផ្ទៀងផ្ទាត់នឹងក្បួន មិនមែនដោយហេតុនៃសេចក្ដីត្រិះរិះ មិនមែនដោយហេតុនៃការស្ទើរស្ទាន់ មិនមែនដោយសេចក្ដីត្រិះរិះនូវអាការៈ មិនមែនដោយហេតុដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្តទេ គឺព្រះអង្គជ្រាបដោយព្រះអង្គឯងពិត ជាធម៌ជាក់ច្បាស់ចំពោះព្រះអង្គ ហេតុនោះ (ទ្រង់ត្រាស់ថា) ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ។ ពាក្យថា ជាគ្រឿងនាំចេញនូវអន្តរាយ ត្រង់ពាក្យថា អន្តរាយ បានដល់ អន្តរាយពីរ គឺអន្តរាយច្បាស់លាស់ ១ អន្តរាយកំបាំង ១ ។

អន្តរាយច្បាស់លាស់ តើដូចម្តេច ។ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ពួកចោរ ឬពួកមាណពធ្វើចោរកម្មក្តី មិនទាន់ធ្វើចោរកម្មក្តី រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគគុម្ពត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឫសដូងច្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុកផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទីខ្វាដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះផ្អែមមាត់ ឫសដូងដុះ បូស

ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំធាតុបួន អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្ដីព្យាយាមរបស់គេមានវាយចងជាដើម អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ ទាំងនេះលោកហៅថា អន្តរាយច្បាស់លាស់ ។

អន្តរាយកំបាំង តើដូចម្ដេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ ការក្រោធ ការចងក្រោធទុក ការលុបគុណ ការវាយឫកស្មើ ការច្រណែន ការកំណាញ់ ការលាក់ទោសខ្លួន ការអួតអាង ការរឹងរូស ការប្រណាំងវាសនា ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ទាំងនេះលោកហៅថា អន្តរាយកំបាំង ។

អធិប្បាយពាក្យថា អន្តរាយ ចុះឈ្មោះថាអន្តរាយដោយអត្ថថា ដូចម្ដេច ។ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈគ្របសង្កត់ ។ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ ។ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះ ។

ចុះឈ្មោះថាអន្តរាយ ព្រោះជាសភាវៈគ្របសង្កត់ តើដូចម្ដេច ។ អន្តរាយ

ទាំងនោះតែងសង្កត់សង្កិន គ្របសង្កត់ ជិះជាន់ ស្រាំពន្ទិច រួបរឹត ញាំញីនូវបុគ្គលនោះ ។ ឈ្មោះថា អន្តរាយព្រោះជាសការៈគ្របសង្កត់ យ៉ាងនេះ ។

ចុះឈ្មោះថា អន្តរាយព្រោះជាសការៈប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ តើដូចម្តេច ។ អន្តរាយទាំងនោះតែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដើម្បីអន្តរាយកុសលធម៌ទាំងឡាយ ។ តែងប្រព្រឹត្តទៅដើម្បីសាបសូន្យ ដើម្បីអន្តរាយកុសលធម៌ទាំងឡាយ តើដូចម្តេច ។ តែងប្រព្រឹត្តទៅដើម្បីសាបសូន្យ ដើម្បីអន្តរាយដល់កុសលធម៌ទាំងនេះ គឺសេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិជាអនុលោម សេចក្តីប្រតិបត្តិមិនជាសត្រូវ សេចក្តីប្រតិបត្តិជាប្រយោជន៍សមគួរ សេចក្តីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ការធ្វើឲ្យពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវការភ្ញាក់រឭក ការមានស្មារតីដឹងខ្លួន ការប្រកបរឿយៗនូវការចម្រើនសតិប្បដ្ឋាន ៤ ការប្រកបរឿយៗនូវការចម្រើនសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ឈ្មោះថា អន្តរាយ ព្រោះជាសការៈប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យយ៉ាងនេះ ។

ចុះឈ្មោះថា អន្តរាយ ព្រោះជាសការៈអាស្រ័យនៅក្នុងអត្តភាពនោះ តើដូចម្តេច ។ ធម៌អកុសលដ៏លាមកទាំងនោះ ជាអន្តរាយ អាស្រ័យក្នុងអត្តភាព កើតឡើងក្នុងអត្តភាពនោះ ។ ពួកសត្វអាស្រ័យនឹងរូងដេកក្នុងរូង ពួកសត្វអាស្រ័យនឹងទឹកដេកក្នុងទឹក ពួកសត្វអាស្រ័យនឹងព្រៃដេកក្នុងព្រៃ ពួកសត្វ

អាស្រ័យនឹងដើមឈើដេកលើដើមឈើយ៉ាងណាមិញ ធម៌អកុសលដ៏លាមក ទាំងនោះជាអន្តរាយ អាស្រ័យក្នុងអត្តភាព កើតឡើងក្នុងអត្តភាពនោះក៏យ៉ាង នោះដែរ ហេតុនោះឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះយ៉ាងនេះឯង ។

សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងថា ម្នាល ភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស នៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលបុគ្គលត្រិះរិះដោយសេចក្ដីរឭក ជាទីតាំងនៃសញ្ញោជនៈ កើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយភ្នែក ធម៌ អកុសលដ៏លាមកទាំងនោះ រមែងនៅក្នុងខាងក្នុង រមែងជាប់តាមភិក្ខុនោះព្រោះ ហេតុនោះ ( ភិក្ខុនោះតថាគត ) ហៅថា អ្នកនៅរួមនឹងសិស្ស ធម៌អកុសល ដ៏លាមកទាំងនោះ រមែងគ្របសង្កត់ភិក្ខុនោះ ព្រោះហេតុនោះ ( ភិក្ខុនោះ តថាគត ) ហៅថា អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ មួយទៀតធម៌ ទាំងឡាយជាអកុសលដ៏លាមក ដែលបុគ្គលត្រិះរិះដោយសេចក្ដីរឭក ជាទីតាំង នៃសញ្ញោជនៈកើតឡើងដល់ភិក្ខុព្រោះឮសំឡេងដោយត្រចៀក ហិតក្លិនដោយ ច្រមុះ ជញ្ជក់រសដោយអណ្ដាត ប៉ះពាល់ផ្សព្វដោយកាយ ដឹងធម៌ដោយចិត្ត ធម៌អកុសលដ៏លាមកទាំងនោះ រមែងនៅខាងក្នុង រមែងជាប់តាមភិក្ខុនោះ ព្រោះហេតុនោះ ( ភិក្ខុនោះតថាគត ) ហៅថា អ្នកនៅរួមនឹងសិស្ស ធម៌អកុសល

ដ៏លាមកទាំងនោះរមែងគ្របសង្កត់ភិក្ខុនោះ ព្រោះហេតុនោះ ( ភិក្ខុនោះតថាគត ) ហៅថា អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យរមែងនៅជាទុក្ខ មិនសប្បាយយ៉ាងនេះឯង ។ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះ យ៉ាងនេះឯង ។

មួយទៀតព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ នេះ ជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ធម៌ ៣ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯងជាមន្ទិលខាងក្នុង ជាបច្ចាមិត្តខាងក្នុង ជាសត្រូវខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាខ្មាំងខាងក្នុង ។

លោភៈឲ្យកើតវិនាស លោភៈជាគ្រឿងញ៉ាំងចិត្ត ឲ្យកម្រើក
ភ័យកើតឡើងខាងក្នុង តែជនមិនដឹងនូវភ័យនោះ ។ ជនល្មោភ
រមែងមិនដឹងនូវអត្ថ ជនល្មោភរមែងមិនឃើញនូវធម៌ លោភៈ
គ្របសង្កត់ជន ក្នុងកាលណា សេចក្តីងងឹតងងល់ រមែងកើត

ក្នុងកាលនោះ ទោសៈឲ្យកើតវិនាស ទោសៈជាគ្រឿងញុំាង ចិត្តឲ្យកម្រើក ភ័យរមែងកើតខាងក្នុង តែជនមិនដឹងនូវភ័យ នោះ ជនក្រោធរមែងមិនដឹងអត្ថ ជនក្រោធរមែងមិនឃើញធម៌ សេចក្ដីក្រោធគ្របសង្កត់ជន ក្នុងកាលណា ការងងឹតងងល់ រមែងកើតក្នុងកាលនោះ មោហៈឲ្យកើតវិនាស មោហៈជាគ្រឿង ញុំាងចិត្តឲ្យកម្រើក ភ័យរមែងកើតខាងក្នុង តែជនមិនដឹងនូវ ភ័យនោះ ជនវង្វេងរមែងមិនដឹងអត្ថ ជនវង្វេងរមែងមិនឃើញ ធម៌ មោហៈគ្របសង្កត់ជនក្នុងកាលណា ការងងឹតងងល់រមែង កើតក្នុងកាលនោះ ។

ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះយ៉ាងនេះ ឯង ។

មួយវិញទៀត ព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគត្រាស់ហើយថា បពិត្រ មហារាជ ធម៌របស់បុរស ៣ កាលកើតឡើងខាងក្នុង រមែងកើតឡើងដើម្បី មិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ធម៌ ៣ តើដូចម្ដេច បពិត្រមហារាជ លោភៈ ជាធម៌របស់បុរស កាលកើតខាងក្នុងរមែងកើតដើម្បី មិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហារាជ ទោសៈ ជាធម៌របស់បុរស កាលកើតខាងក្នុងរមែងកើតដើម្បីមិនជាប្រយោជន៍ ដើម្បី ទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ បពិត្រមហារាជ មោហៈ ជាធម៌របស់បុរស កាលកើតឡើងខាងក្នុង រមែងកើតដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បី

កិរិយានៅមិនសប្បាយ បពិត្រមហារាជ ធម៌របស់បុរស ៣ នេះឯង កាលកើតឡើងខាងក្នុង រមែងកើតដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ ដើម្បីកិរិយានៅមិនសប្បាយ ។

លោភៈ ទោសៈ មោហៈ កើតចេញអំពីខ្លួន រមែងសម្លាប់
បុរសដែលមានចិត្តអាក្រក់ ដូចផ្លែឫស្សីសម្លាប់ដើមឫស្សី ។

ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះយ៉ាងនេះឯង ។

ន័យមួយទៀតព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគត្រាស់ហើយថា

រាគៈនិងទោសៈមានអត្តភាពនេះជាហេតុ សេចក្តីមិនត្រេកអរ
តម្រេក កិរិយាព្រឺរោមកើតអំពីអត្តភាពនេះ សេចក្តីត្រិះរិះក្នុង
ចិត្តក៏កើតឡើងអំពីអត្តភាពនេះ ដូចពួកក្មេងតូចលែងក្អែក ។

ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យនៅក្នុងអត្តភាពនោះយ៉ាងនេះឯង ។

ពាក្យថា ជាគ្រឿងនាំចេញនូវអន្តរាយ គឺជាគ្រឿងនាំចេញអន្តរាយ ជាគ្រឿងលះបង់អន្តរាយ ជាគ្រឿងរម្ងាប់អន្តរាយ ជាគ្រឿងរលាស់ចោលអន្តរាយ ជាគ្រឿងរម្ងាប់អន្តរាយ គឺអមតនិព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ធម៌ដែលព្រះអង្គជ្រាបដោយព្រះអង្គឯង ជាគ្រឿងនាំចេញនូវអន្តរាយ ។

[ ៣១ ] ពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គសម្តែងនូវបដិបទា សេចក្តីថា សូមព្រះអង្គសម្តែងនូវបដិបទា គឺសម្តែង ប្រាប់ ពោល បញ្ញត្ត

តែងតាំង បើក បែក ធ្វើឲ្យងាយ ប្រកាសនូវសម្មាបដិបទាអនុលោមបដិបទា បដិបទាមិនជាសត្រូវ បដិបទាជាប្រយោជន៍ដ៏សមគួរ ការប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវការភ្ញាក់រឭក ការមានស្មារតីដឹងខ្លួន សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ និព្វាននិងបដិបទាជាដំណើរទៅកាន់និព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) សូមព្រះអង្គសម្តែងនូវបដិបទា ។ ពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន គឺព្រះពុទ្ធនិមិត្តនោះត្រាស់ហៅព្រះពុទ្ធមានព្រះភាគ ។ មួយទៀតព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើក បែក ធ្វើឲ្យងាយ ប្រកាសហើយនូវធម៌ណា ធម៌ទាំងអស់នោះជាធម៌ល្អ ជាធម៌ចម្រើនជាធម៌គួររាប់រក ជាធម៌មិនមានទោស ជាធម៌ដែលបុគ្គលគួរសេព ហេតុនោះ ( ទ្រង់ត្រាស់ថា ) បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះអង្គសម្តែងនូវបដិបទា ។

[ ៣២ ] អធិប្បាយពាក្យថា បាតិមោក្ខនិងសមាធិ ត្រង់ពាក្យថា បាតិ-មោក្ខ គឺសីល ទីតាំង ទីខាងដើម សេចក្តីប្រព្រឹត្ត សេចក្តីសង្រួម សេចក្តីរវាំង ប្រធាន ប្រមុខនៃការបាននូវធម៌ទាំងឡាយជាកុសល ។ ពាក្យថា សមាធិបានដល់ ការតាំងនៅ ការតាំងនៅព្រម ការតាំងនៅស៊ប់នៃចិត្ត ការមិនកន្ទួរភាការមិនរាយមាយ ភាពនៃចិត្តមិនកន្ទួរភា សេចក្តីស្ងប់ឥន្ទ្រិយ គឺសមាធិ កម្លាំងគឺសមាធិ ការតាំងចិត្តដោយប្រពៃ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បាតិមោក្ខនិងសមាធិ ។ ហេតុនោះព្រះពុទ្ធនិមិត្តនោះត្រាស់ថា

ព្រះអង្គមានចក្ខុបើកហើយ បានសំដែងធម៌ដែលព្រះអង្គជ្រាប ដោយព្រះអង្គឯង ជាគ្រឿងនាំចេញនូវអន្តរាយ បពិត្រព្រះអង្គ ដ៏ចម្រើន សូមព្រះអង្គសំដែងនូវបដិបទា បាតិមោក្ខនិងសមាធិ ។

[ ៣៣ ] ( ព្រះមានព្រះភាគត្រាស់តបថា ) បុគ្គលមិនគប្បីឡេះឡោះ ដោយភ្នែក គប្បីរាំងត្រចៀកចាកគាមកថា មិនគប្បីជាប់ចំពាក់ក្នុងរសផង មិនគប្បីប្រកាន់វត្ថុណាមួយក្នុងលោកផង ។

[ ៣៤ ] អធិប្បាយពាក្យថា បុគ្គលមិនគប្បីឡេះឡោះដោយភ្នែក សំណួរថា បុគ្គលអ្នកឡេះឡោះដោយភ្នែក តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នក ឡេះឡោះដោយភ្នែក ប្រកបដោយសេចក្តីឡេះឡោះដោយភ្នែក គិតថា អាត្មា អញគួរឃើញអារម្មណ៍ដែលមិនធ្លាប់ឃើញ គួររំលងចោលអារម្មណ៍ ដែល ឃើញហើយ ប្រកបរឿយៗនូវការត្រាច់ទៅឆ្ងាយៗនិងការត្រាច់ទៅមិនឈប់ ឈរ គឺចេញអំពីអារាមទៅអារាម អំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពីក្រុងទៅក្រុង អំពីដែនទៅដែន អំពីជនបទទៅជនបទ ដើម្បីឃើញរូប ជាអ្នកឡេះឡោះដោយភ្នែកយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលខ្លះ ចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ ជាអ្នកដើរមិនសង្រួមតែងក្រឡេកមើល ដំរី ក្រឡេកមើលសេះ ក្រឡេកមើលរថ ក្រឡេកមើលពលថ្មើរជើង ក្រឡេក មើលពួកស្រី ក្រឡេកមើលពួកបុរស ក្រឡេកមើលពួកក្មេងប្រុស ក្រឡេក មើលពួកក្មេងស្រី ក្រឡេកមើលរានផ្សារ ក្រឡេកមើលមុខផ្ទះ ក្រឡេកមើល លើ ក្រឡេកមើលក្រោម ដើរសម្លឹងទិសតូចទិសធំ ជាអ្នកឡេះឡោះដោយ

ក្អែកយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលខ្លះឃើញរូបដោយភ្នែកហើយជាអ្នកប្រកាន់និមិត្ត ជាអ្នកប្រកាន់អនុព្យញ្ជនៈ ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមភិក្ខុអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ជាអ្នកឡេះឡោះដោយភ្នែកយ៉ាងនេះខ្លះ ។ ដូចជាសមណព្រាហ្មណ៍ពួកមួយដ៏ចម្រើនបរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវការស្តាប់និងមើលល្បែងដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺរាំ ច្រៀង ប្រគំមហោស្រព ចម្បាំងមហាភារតនិងរាមកេរ្តិ៍ជាដើម គង រគាំង ស្គរមានជ្រុងបួន គូរគំនូររូប របាំ ល្បែងដំដែក ល្បែងរ៉ាវ ការលាងឆ្អឹង ប្រជល់ដំរី ប្រខាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់ពពែ ប្រជល់កែះ ប្រជល់មាន់ ប្រជល់ចាប ល្បែងគុណដំបង ប្រដាល់ ចំបាប់ ចម្បាំង ទីសម្រាប់រៀបពល ទីនៅកងទ័ព ការមើលកងទ័ព ជាអ្នកឡេះឡោះដោយភ្នែកយ៉ាងនេះខ្លះ ។

ភិក្ខុជាអ្នកមិនឡេះឡោះដោយភ្នែក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ក៏ដើរសង្រួម មិនក្រឡេកមើលដំរី មិនក្រឡេកមើលសេះ មិនក្រឡេកមើលរថ មិនក្រឡេកមើលពលថ្មើរជើង មិនក្រឡេកមើលពួកស្រី មិនក្រឡេកមើលពួកបុរស មិនក្រឡេកមើលពួកក្មេងប្រុស មិនក្រឡេកមើលពួកក្មេងស្រី មិនក្រឡេកមើលរានផ្សារ មិនក្រឡេកមើលមុខផ្ទះ មិនក្រឡេកមើលលើ មិនក្រឡេកមើលក្រោម មិនដើរសម្លឹងទិសតូចឬទិសធំ

ជាអ្នកមិនឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញនូវរូបដោយភ្នែកហើយជាអ្នកមិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្សគប្បីជាប់តាមភិក្ខុអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ជាអ្នកមិនឡេះឡោះដោយភ្នែក យ៉ាងនេះខ្លះ ។ ដូចជាសមណព្រាហ្មណ៍ ដ៏ចម្រើនពួកខ្លះបរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះមិនប្រកបរឿយៗនូវការស្តាប់និងការមើលល្បែងដែលជាសត្រូវមានសភាពយ៉ាងនេះ គឺល្បែងរាំ ច្រៀង ប្រគំមហោស្រព ចម្បាំងមហាភារតនិងរាមកេរ្តិ៍ជាដើម ។បេ។ ការមើលកងព័ទ ជាអ្នកវៀរស្រឡះចាកការប្រកបរឿយៗនូវការស្តាប់និងការមើលល្បែងដែលជាសត្រូវ មានសភាពយ៉ាងនេះ ជាអ្នកមិនឡេះឡោះដោយភ្នែកយ៉ាងនេះខ្លះ ។

ពាក្យថា បុគ្គលមិនគប្បីឡេះឡោះដោយភ្នែក បានសេចក្តីថា បុគ្គលគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់នូវការឡេះឡោះដោយភ្នែក ហើយជាអ្នកឆ្ងាយ វៀរចេញ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល ផុតស្រឡះ ប្រកបប្រាសចាកការឡេះឡោះដោយភ្នែក សម្រេចនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនគប្បីឡេះឡោះដោយភ្នែក ។

[ ៣៥ ] ពាក្យថា គប្បីរារាំងត្រចៀកចាកគាមកថា សេចក្តីថា តិរច្ឆានកថា

៣២ លោកហៅថាគាមកថា ។ តិរច្ឆានកថានោះ តើដូចម្ដេច ។ គឺនិយាយអំពីព្រះរាជា និយាយអំពីចោរ និយាយអំពីអាមាត្យធំ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីយាន និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីបុរស និយាយអំពីយោធាដែលក្លៀវក្លា និយាយអំពីច្រក និយាយអំពីកំពង់ទឹក និយាយអំពីញាតិដែលចែកឋានទៅកាន់បរលោកហើយ និយាយអំពីពាក្យដែលឥតប្រយោជន៍មានសភាពផ្សេងៗ និយាយអំពីលោក និយាយអំពីសមុទ្ទ និយាយអំពីសេចក្ដីចម្រើននិងមិនចម្រើន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ចាកគាមកថា ។ ពាក្យថា គប្បីរាំងត្រចៀក គឺគប្បីរាំង ហាមឃាត់ ខាំងខា រក្សា គ្រប់គ្រង បិទ ផ្ដាច់បង់នូវត្រចៀកចាកគាមកថា ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីរាំងត្រចៀកចាកគាមកថា ។

[ ៣៦ ] អធិប្បាយពាក្យថា មិនគប្បីជាប់ជំពាក់ក្នុងរស ត្រង់ពាក្យថា រស គឺរសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ រសជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ ជូរផ្អែម ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ត្រជាក់ ក្ដៅ ។ សមណព្រាហ្មណ៍ពួកមួយ ជាប់ជំពាក់ក្នុងរស ។ សមណព្រាហ្មណ៍ទាំងនោះតែងត្រាច់ស្វែងរករសដ៏ប្រសើរដោយចុងនៃអណ្ដាត ។ សមណព្រាហ្មណ៍ទាំងនោះបានរសជូរស្វែងរករសមិនជូរ បានរសមិនជូរហើយស្វែងរករសជូរ ។បេ។ បានរស

ត្រជាក់ ហើយស្វែងរករសក្តៅ បានរសក្តៅ ហើយស្វែងរកនូវរសត្រជាក់ ។ សមណព្រាហ្មណ៍ទាំងនោះបានរបស់ណាៗ មិនសន្តោសនឹងរបស់នោះៗ ស្វែងរករសឯទៀតៗ ជាអ្នកត្រេកអរ ជាប់ជំពាក់ ល្មោភ ជក់ជាប់ ញាំម ជាប់ស្អិត មានអាការជាប់ស្អិត ញៀនក្នុងរសទាំងឡាយជាទីគាប់ចិត្ត ។ បុគ្គលណាបាន លះបង់ បានផ្តាច់ផ្តិលនូវចំណង់ក្នុងរសទុំះ ។បេ។ ដុតដោយភ្លើងគឺញាណ ហើយ បុគ្គលនោះពិចារណាដោយត្រូវទំនងហើយ បរិភោគអាហារមិនដើម្បី លេង មិនដើម្បីស្រវឹង មិនដើម្បីប្រដាប់ មិនដើម្បីស្អិតស្អាង គ្រាន់តែដើម្បី ឋិតនៅនៃកាយនេះ ដើម្បីឲ្យកាយប្រព្រឹត្តទៅ ដើម្បីបំបាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយៈ ។បេ។ ការនៅសប្បាយផង ។ បុគ្គលលាបដំបៅ គ្រាន់តែប្រយោជន៍ឲ្យដុះសាច់យ៉ាងណា មួយទៀតបុគ្គលលាបភ្លៅរទេះ គ្រាន់ តែប្រយោជន៍ដល់ការដឹកនាំនូវភារៈយ៉ាងណា មួយទៀតបុគ្គលបរិភោគសាច់ កូនគ្រាន់តែប្រយោជន៍ដល់ការឆ្លងឲ្យផុតផ្លូវដាច់ស្រយាលយ៉ាងណា ភិក្ខុពិចា-រណាដោយត្រូវទំនងហើយបរិភោគអាហារ មិនដើម្បីលេង ។បេ។ សេចក្តីមិន មានទោសផង ការនៅសប្បាយផងក៏យ៉ាងនោះដែរ ។ បុគ្គលលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការបាត់បង់នូវចំណង់ក្នុងរសដូច្នេះ ជាអ្នកឆ្ងាយវៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ មិនប្រកបដោយចំណង់ ក្នុងរស សម្រេចនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីជាប់ចំពាក់ក្នុងរស ។

[ ៣៧ ] អធិប្បាយពាក្យថា មិនគប្បីប្រកាន់វត្ថុណាមួយក្នុងលោក ត្រង់

ពាក្យថា ប្រកាន់ បានដល់ សេចក្ដីប្រកាន់ពីរ គឺសេចក្ដីប្រកាន់ គឺតណ្ហា ១ សេចក្ដីប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះសេចក្ដីប្រកាន់គឺតណ្ហា ។បេ។ នេះសេចក្ដីប្រកាន់គឺទិដ្ឋិ ។ បុគ្គលលះបង់សេចក្ដីប្រកាន់ គឺតណ្ហា រលាស់ចោលសេចក្ដីប្រកាន់គឺទិដ្ឋិ មិនគប្បីប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវចក្ខុ មិនគប្បីប្រកាន់ មិនកាន់យក មិនស្ទាបអង្អែល មិនប្រកាន់ស្អិតនូវត្រចៀក ច្រមុះ អណ្ដាត កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វ ត្រកូល ពួកអាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុ-វោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ននិងធម៌ដែលខ្លួនឃើញ ឮ ប៉ះពាល់ឬគប្បីដឹង ។ ពាក្យថា វត្ថុណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាមួយ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។បេ។ ក្នុងអាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីប្រកាន់វត្ថុណាមួយក្នុងលោក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> បុគ្គលមិនគួរឡេះឡោះដោយភ្នែក គប្បីរាំងត្រចៀក ចាក
> គាមកថា មិនគប្បីជាប់ចំពាក់ក្នុងរសផង មិនគប្បីប្រកាន់វត្ថុ
> ណាមួយក្នុងលោកផង ។

[ ៣៨ ] ភិក្ខុត្រូវផស្សៈប៉ះពាល់ហើយក្នុងកាលណា ក្នុងកាលនោះមិនគប្បីធ្វើនូវការទួញយំក្នុងទីណាមួយទេ មួយទៀតមិនគប្បីប្រាថ្នាភព មិនគប្បី

ញាប់ញ័រក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយឡើយ ។

[ ៣៩ ] ពាក្យថា ភិក្ខុត្រូវផស្សៈប៉ះពាល់ហើយក្នុងកាលណា អធិប្បាយថា ភិក្ខុត្រូវផស្សៈ គឺរោគប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ប្រកបព្រម គឺត្រូវរោគភ្នែកប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ប្រកបព្រម ត្រូវរោគត្រចៀក រោគ ច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគគុម្ពត្រចៀក រោគមាត់ រោគធ្មេញ ក្អកហឺត ឬសដូងច្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់កម រោគកើតក្នុងទីខ្វាដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះផ្អែមមាត់ ឬសដូងដុះ បូស ឬសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីប្រជុំធាតុបួន អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្តីព្យាយាម ( របស់គេមានវាយចងជាដើម ) អាពាធកើតអំពីផលកម្មត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃនិងពស់តូច ពស់ធំ ប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ប្រកបព្រម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្រូវផស្សៈប៉ះពាល់ហើយក្នុងកាលណា ។

[ ៤០ ] ពាក្យថា ភិក្ខុមិនគប្បីធ្វើនូវការទួញយំក្នុងទីណាមួយ គឺភិក្ខុមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើត មិនគប្បីបង្កើតចំពោះនូវការយំ យំរៀបរាប់ អាការនៃការយំ អាការនៃការយំរៀបរាប់ ភាពនៃការយំ ភាពនៃការយំរៀបរាប់ ការរៀបរាប់ដោយវាចា ការរៀបរាប់ផ្សេងៗ

ការបរបា អាការនៃការបរបា ភាពនៃការបរបា ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងកន្លែងណាមួយ ក្នុងទីណាៗ ក្នុងទីខ្លះដែលជាខាងក្នុងក្តី ខាងក្រៅក្តី ទាំងខាងក្នុងខាងក្រៅក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីធ្វើនូវការទួញយំក្នុងទីណាមួយទេ ។

[ ៤១ ] ពាក្យថា មួយទៀតមិនគប្បីប្រាថ្នាភព គឺមិនគប្បីប្រាថ្នាកាមភព មិនគប្បីប្រាថ្នារូបភព មិនគប្បីប្រាថ្នា មិនគប្បីប៉ុនប៉ង មិនគប្បីចង់បានអរូបភព ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀតមិនគប្បីប្រាថ្នាភព ។

[ ៤២ ] អធិប្បាយពាក្យថា មិនគប្បីញាប់ញ័រក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយឡើយ ត្រង់ពាក្យថា អារម្មណ៍ដែលគួរខ្លាច គឺភ័យក្តី ការខ្លាចក្តី បើដោយអាការៈតែមួយទេ គឺមានន័យដូចគ្នា ។ សមដូចព្រះពុទ្ធដីកានេះដែលព្រះមានព្រះភាគត្រាស់ហើយថា ការខ្លាច ការញញើតនោះតែងមកដោយពិត ។ អារម្មណ៍ខាងក្រៅដែលលោកពោលហើយ គឺសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី គោ ក្របី ដំរី ពស់ ខ្ទួយ ក្អែប ឬថាពួកចោរ ឬពួកមាណពមានការងារធ្វើហើយក្តី មានការមិនទាន់ធ្វើហើយក្តី ។ មួយទៀត បើដោយអាការៈដទៃវិញ ការខ្លាច អាការខ្លាច ការញាប់ញ័រជាខាងក្នុង មានចិត្តជាសមុដ្ឋាន ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលខ្លួនឯង ភ័យអំពីអ្នកដទៃតិះដៀល ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលក ភ័យអំពីក្រពើ ភ័យអំពីអន្ទង់ ភ័យអំពី

ត្រីសាហាវ ភ័យអំពីការចិញ្ចឹមជីវិត ភ័យអំពីគេមិនសរសើរ ភ័យអំពីសេចក្តីត្រេកអរក្នុងបរិស័ទ អាការខ្លាច ការញាប់ញ័រ ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត លោកហៅថា ភ័យ ។ ពាក្យថា មិនគប្បីញាប់ញ័រក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយ បានសេចក្តីថា ភិក្ខុឃើញក្តី ឮក្តីនូវអារម្មណ៍ដែលគួរខ្លាចទាំងឡាយហើយមិនគប្បីរន្ធត់ មិនគប្បីរន្ធត់ខ្លាំង មិនគប្បីញាប់ញ័រ មិនគប្បីតក់ស្លុត មិនគប្បីស្ទន់ មិនគប្បីស្ទន់ស្ទោ មិនគប្បីខ្លាច មិនគប្បីដល់នូវសេចក្តីតក់ស្លុត ជាបុគ្គលមិនរន្ធត់ មិនញាប់ញ័រ មិនតក់ស្លុត មិនរត់ លះបង់ភ័យដែលគួរខ្លាច ប្រាសចាកការព្រឺរោម ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីញាប់ញ័រក្នុងអារម្មណ៍ដែលគួរខ្លាចទាំងឡាយឡើយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុត្រូវផស្សៈប៉ះពាល់ហើយក្នុងកាលណា ក្នុងកាលនោះមិន
គប្បីធ្វើនូវការទួញយំ ក្នុងទីណាមួយទេ មួយទៀតមិនគប្បី
ប្រាថ្នាភព មិនគប្បីញាប់ញ័រក្នុងអារម្មណ៍ ដែលគួរខ្លាចទាំង
ឡាយឡើយ ។

[ ៤៣ ] ភិក្ខុបានបាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី មិនគប្បីធ្វើនូវការសន្សំទុកទេ មួយទៀតកាលបើមិនបានវត្ថុទាំងនោះ ក៏មិនគប្បីតក់ស្លុតឡើយ ។

[ ៤៤ ] អធិប្បាយពាក្យថា បាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី ត្រង់ពាក្យថា បាយ គឺបាយ នំ សដូវ ត្រី សាច់ ។ ពាក្យថា ទឹក គឺទឹក ៨ យ៉ាង គឺទឹកស្វាយ ទឹកព្រីង ទឹកចេកមានគ្រាប់ ទឹកចេកឥតគ្រាប់ ទឹកស្រគំ ទឹកចាន់

ទឹកក្រអៅឈូក ទឹកម៉ាក់ប្រាង ។ ទឹក ៨ យ៉ាងដទៃទៀត គឺទឹកសង្ស៊ូវ ទឹកពុទ្រាតូច ទឹកពុទ្រាធំ ទឹកដោះថ្លា ទឹកគីប្រេង ទឹកបបរ ទឹកដោះស្រស់ ទឹករស ( ស្លឹកឈើជាដើម ) ។ ពាក្យថា បង្អែម គឺបង្អែមដែលធ្វើអំពីមេព្រា បង្អែមនំ បង្អែមមើមឈើ បង្អែមសម្បកឈើ បង្អែមស្លឹកឈើ បង្អែមផ្កាឈើ បង្អែមផ្លែឈើ ។ ពាក្យថា សំពត់ បានដល់ សំពត់ ៦ យ៉ាង គឺសំពត់សម្បកឈើ ១ សំពត់អំបោះ ១ សំពត់សូត្រ ១ សំពត់រោមសត្វ ១ សំពត់សម្បកធ្មៃ ១ សំពត់ដែលធ្វើដោយវត្ថុទាំងនោះលាយចម្រុះគ្នា ១ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី ។

[ ៤៥ ] អធិប្បាយពាក្យថា បានហើយ មិនគប្បីធ្វើនូវការសន្សំទុកទេ ត្រង់ពាក្យថា បាន គឺបាន បានហើយ យកមកហើយ បានស៊ប់ហើយ បានចំពោះហើយ មិនមែន ( បាន ) ដោយការកុហក គឺញ៉ាំងសត្វលោកឲ្យភាន់ភាំង មិនមែនដោយការពោលពាក្យរាក់ទាក់ មិនមែនដោយការធ្វើនិមិត្ត គឺពោលបញ្ចិតបញ្ចៀង មិនមែនដោយការកិនកម្ទេចនូវគុណទេ មិនមែនដោយការស្វែងរកលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែនដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹកឈើ មិនមែនដោយការឲ្យផ្កាឈើ មិនមែនដោយការឲ្យផ្លែឈើ មិនមែនដោយការឲ្យលំអិតសម្រាប់ងូត មិនមែនដោយការឲ្យអំលិតសម្រាប់លាប មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្ទន់ មិនមែនដោយការឲ្យទឹកសម្រាប់លុបមុខ មិនមែនដោយការពោលលើកតម្កើងអ្នកដទៃ មិនមែនដោយការពោលពាក្យមិនពិត ដូចសម្ល

សណ្តែកបាយ មិនមែនដោយការថ្នាក់ថ្នម ( នូវកូនត្រកូល ) មិនមែនដោយការចូលទៅអង្គុយលើតាំងក្នុងផ្ទះយ៉ាងរហ័ស មិនមែនដោយវត្ថុវិជ្ជា ( ការចេះទាយនូវទីភូមិស្ថាន ) មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយអង្គវិជ្ជា ( ការចេះទាយអវយវៈ ) មិនមែនដោយនក្ខត្តវិជ្ជា ( ការចេះទាយនក្ខត្តឫក្ស ) មិនមែនដោយការទៅធ្វើទូនជាទូត មិនមែនដោយការទៅធ្វើទូន ជាអ្នកនាំដំណឹងដែលគេផ្តាំមិនមែនដោយការធ្វើជាអ្នកបំរើគេដោយស្មងមិនមែនដោយវេជ្ជកម្ម មិនមែនដោយនវកម្ម មិនមែនដោយការឲ្យដុំបាយដោយដុំបាយ មិនមែនដោយការឲ្យទៅឲ្យមក គឺបាន បានហើយ យកមកហើយ បានសិបហើយ បានចំពោះហើយដោយធម៌ដ៏ស្មើ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានហើយ ។ ពាក្យថា មិនគប្បីធ្វើនូវការសន្សំទេ គឺមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើត មិនគប្បីបង្កើតចំពោះនូវការសន្សំបាយ ការសន្សំទឹក ការសន្សំសំពត់ ការសន្សំយាន ការសន្សំទីដេក ការសន្សំគ្រឿងក្រអូប ការសន្សំអាមិសៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានហើយមិនគប្បីធ្វើនូវការសន្សំទេ ។

[ ៤៦ ] ពាក្យថា កាលបើមិនបានវត្ថុទាំងនោះទេក៏មិនគប្បីតក់ស្លុត គឺមិនគប្បីតក់ស្លុត មិនគប្បីរន្ធត់ មិនគប្បីញាប់ញ័រ មិនគប្បីខ្លាច មិនគប្បីដល់នូវការតក់ស្លុត ជាអ្នកមិនភ័យ មិនរន្ធត់ មិនតក់ស្លុត មិនរត់ ជាអ្នកមានការភ័យដែលគួរខ្លាចលះបង់ហើយ ប្រាសចាកការព្រឺរោមដោយគិតថា អញមិនបានបាយក្តី មិនបានទឹកក្តី មិនបានសំពត់ក្តី មិនបានត្រកូលក្តី មិនបានគណៈក្តី មិនបានអាវាសក្តី មិនបានលាភក្តី មិនបានយសក្តី មិនបានសេចក្តីសរសើរ

ក្តី មិនបានសុខក្តី មិនបានចីវរក្តី មិនបានបិណ្ឌបាតក្តី មិនបានសេនាសនៈក្តី មិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារក្តី មិនបានបុគ្គលអ្នកបម្រើជំងឺក្តី ( ព្រោះ ) អញជាអ្នកមិនល្បីល្បាញ ហេតុនោះ ( ទ្រង់ត្រាស់ ) ថា កាលបើមិនបាននូវវត្ថុទាំងនោះមិនគប្បីតក់ស្លុតឡើយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុបានបាយក្តី ទឹកក្តី បង្អែមក្តី សំពត់ក្តី មិនគប្បីធ្វើនូវការ
សន្សំទុកទេ មួយទៀតកាលបើមិនបានវត្ថុទាំងនោះ ក៏មិនគប្បី
តក់ស្លុតឡើយ ។

[ ៤៧ ] ភិក្ខុជាអ្នកមានឈានមិនគប្បីឡេះឡោះដោយជើងទេ គប្បីវៀរចាកកុក្កុច្ច ( ការពើសឬការរង្កៀស ) មិនគប្បីប្រហែសទេ មួយទៀតគប្បីនៅក្នុងទីអង្គុយឬទីដេក ដែលមិនមានសំឡេង ។

[ ៤៨ ] អធិប្បាយពាក្យថា ភិក្ខុជាអ្នកមានឈាន មិនគប្បីឡេះឡោះដោយជើង ត្រង់ពាក្យថា ជាអ្នកមានឈាន គឺជាអ្នកមានឈានដោយបឋមជ្ឈានក្តី មានឈានដោយទុតិយជ្ឈានក្តី មានឈានដោយតតិយជ្ឈានក្តី មានឈានដោយចតុត្ថជ្ឈានក្តី មានឈានដោយឈានដែលប្រកបដោយវិតក្កៈនិងវិចារៈក្តី មានឈានដោយឈានដែលមិនមានវិតក្កៈមានត្រឹមតែវិចារៈក្តី មានឈានដោយឈានដែលមិនមានវិតក្កៈមិនមានវិចារៈក្តី មានឈានដោយឈានដែលប្រកបដោយបីតិក្តី មានឈានដោយឈានដែលមិនមានបីតិក្តី មានឈានដោយឈាន ដែលប្រកបដោយបីតិក្តី មានឈានដោយឈានប្រកបដោយសេចក្តីសប្បាយក្តី មានឈានដោយឈានប្រកបដោយសុខក្តី មានឈាន

ដោយឈានប្រកបដោយឧបេក្ខាក្តី មានឈានដោយសុញ្ញតជ្ឈានក្តី មានឈានដោយអនិមិត្តជ្ឈានក្តី មានឈានដោយអប្បណិហិតជ្ឈានក្តី មានឈានដោយលោកិយជ្ឈានក្តី មានឈានដោយលោកុត្តរជ្ឈានក្តី ជាអ្នកត្រេកអរក្នុងឈាន ជាអ្នកប្រកបរឿយៗ នូវចិត្តមានអារម្មណ៍តែមួយ ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមានឈាន ។ ត្រង់ពាក្យថា ជាអ្នកមិនគប្បីរពឹសដោយជើង ( មានពាក្យបុច្ឆាថា ) ជាអ្នកមិនរពឹសដោយជើង តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នករពឹសដោយជើង ប្រកបដោយការរពឹសដោយជើងគឺជាអ្នកប្រកបរឿយៗនូវការត្រាច់ទៅឆ្ងាយៗនិងការត្រាច់ទៅមិនឈប់ឈរ គឺចេញអំពីអារាមទៅអារាម អំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពីនគរទៅនគរ អំពីដែនទៅដែន អំពីជនបទទៅជនបទ បុគ្គលជាអ្នករពឹសដោយជើង យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុជាអ្នកប្រកបដោយការរពឹសដោយជើង ខាងក្នុងអារាមនៃសង្ឃ មិនមែនព្រោះហេតុតែប្រយោជន៍ មិនមែនព្រោះហេតុតែធ្វើ ( នូវកិច្ចរបស់សង្ឃ ) ជាអ្នកមានចិត្តរវើរវាយ មានចិត្តមិនស្ងប់រម្ងាប់ ចេញអំពីបរិវេណទៅបរិវេណ អំពីវិហារទៅវិហារ អំពីអឌ្ឍយោគទៅអឌ្ឍយោគ អំពីប្រាសាទទៅប្រាសាទ អំពីប្រាសាទត្រងិលទៅប្រាសាទត្រងិល អំពីគុហាទៅគុហា អំពីលេណៈ ( ទីជ្រកកោន ) ទៅលេណៈ អំពីកុដិទៅកុដិ អំពីផ្ទះកំពូលទៅផ្ទះកំពូល អំពីបញ្ចាទៅបញ្ចា អំពីរោងទៅរោង អំពីទីជ្រកអាស្រ័យទៅទីជ្រកអាស្រ័យ អំពីឃ្លាំងទៅឃ្លាំង អំពីឧបដ្ឋានសាលាទៅឧបដ្ឋានសាលា អំពីរោងមូលទៅរោងមូល អំពី

គល់ឈើទៅគល់ឈើ ឬក៏ពួកភិក្ខុអង្គុយក្នុងទីណាក៏ទៅក្នុងទីនោះ ។ បើក្នុងទីនោះភិក្ខុ ១ រូប មានភិក្ខុជាគម្រប់ពីររូប ឬភិក្ខុ ២ រូប មានភិក្ខុជាគម្រប់បីរូប ឬក៏ភិក្ខុ ៣ រូប មានភិក្ខុជាគម្រប់ ៤ រូប ក្នុងទីនោះ ភិក្ខុនោះតែងចរចានូវពាក្យឥតប្រយោជន៍ច្រើន គឺពោលអំពីព្រះរាជា ពោលអំពីចោរ ពោលអំពីមហាមាត្យ ពោលអំពីសេនា ពោលអំពីភ័យ ពោលអំពីចម្បាំង ពោលអំពីបាយ ពោលអំពីទឹក ពោលអំពីសំពត់ ពោលអំពីយាន ពោលអំពីដំណេក ពោលអំពីផ្កាកម្រង ពោលអំពីគ្រឿងក្រអូប ពោលអំពីញាតិ ពោលអំពីស្រុក ពោលអំពីនិគម ពោលអំពីក្រុង ពោលអំពីជនបទ ពោលអំពីស្រី ពោលអំពីប្រុស ពោលអំពីអ្នកក្លៀវក្លា ពោលអំពីច្រក ពោលអំពីកំពង់ទឹក ពោលអំពីបុរសដែលចែកឋានទៅកាន់បរលោកក្នុងកាលមុន ពោលវាចាមានសភាពផ្សេងៗ ពោលអំពីរឿងលោក ពោលអំពីសមុទ្ទ ឬពោលអំពីសេចក្តីចម្រើននិងវិនាសជាដូច្នោះ ភិក្ខុជាអ្នករពឹសដោយជើងយ៉ាងនេះខ្លះ ។ ពាក្យថា ជាអ្នកមិនគប្បីរពឹសដោយជើង បានសេចក្តីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានការរពឹសដោយជើង ជាអ្នកថ្វាយ វៀរ វៀរចំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ មិនប្រកបដោយការរពឹសដោយជើងហើយសម្រេចនៅប្រព្រឹត្ត ប្រព្រឹត្តព្រម ទៅប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ដោយចិត្តដែលប្រាសចាកដែន គឺកិលេស ។ បុគ្គលនោះ គប្បីជាអ្នកមានទីពួនសម្ងំជាទីត្រេកអរ ត្រេកអរតែក្នុងទីពួនសម្ងំ ប្រកបរឿយៗនូវការរម្ងាប់ចិត្តខាងក្នុង មានឈានមិនបានឃ្លាតចេញ ប្រកបដោយវិបស្សនា ចម្រើនសុញ្ញាគារដ្ឋាន

មានឈានត្រេកអរក្នុងឈាន ប្រកបរឿយៗនូវចិត្តមានអារម្មណ៍តែមួយ ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមានឈាន មិនគប្បីរពឹសដោយជើង ។

[ ៤៩ ] អធិប្បាយពាក្យថា គប្បីវៀរចាកកុក្កុច្ចៈ មិនគប្បីប្រហែសទេ ត្រង់ពាក្យថា កុក្កុច្ចៈ គឺការរពឹសដៃ ហៅថាកុក្កុច្ចៈ ការរពឹសជើង ហៅថាកុក្កុច្ចៈ ការរពឹសដៃនិងជើង ហៅថាកុក្កុច្ចៈ សេចក្តីសម្គាល់ក្នុងរបស់គួរថាជារបស់មិនគួរ សេចក្តីសម្គាល់ក្នុងរបស់មិនគួរថាជារបស់គួរ សេចក្តីសម្គាល់ក្នុងរបស់មិនមានទោសថាជារបស់មានទោស សេចក្តីសម្គាល់ក្នុងរបស់មានទោសថាជារបស់មិនមានទោស កុក្កុច្ចៈ អាការនៃកុក្កុច្ច ភាពនៃកុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្តឯណាមានសភាពយ៉ាងនេះ នេះហៅថា កុក្កុច្ចៈ ។ម្យ៉ាងទៀតកុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្តរមែងកើតដោយហេតុ ២ គឺភាពនៃអំពើដែលខ្លួនធ្វើហើយ ឬមិនបានធ្វើ ។ កុក្កុច្ចៈ ការក្តៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្ត រមែងកើតឡើងព្រោះអំពើដែលធ្វើហើយឬមិនបានធ្វើ តើដូចម្តេច ។ កុក្កុច្ចៈ ការក្តៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្តកើតឡើងថា កាយទុច្ចរិតអញបានធ្វើហើយ កាយសុចរិតអញមិនបានធ្វើទេ ។ កុក្កុច្ចៈ ។បេ។ ការស្ដាកស្ដាមនៃចិត្តកើតឡើងថា វចីទុច្ចរិតអញបានធ្វើហើយ មនោទុច្ចរិតអញបានធ្វើហើយ បាណាតិបាតអញបានធ្វើហើយ ការវៀរចាកបាណាតិបាតអញមិនបានធ្វើទេ ។ កុក្កុច្ចៈ ការក្តៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្តកើតឡើងថា អទិន្នាទានអញធ្វើហើយ កាមេសុមិច្ឆាចារ

អញធ្វើហើយ មុសាវាទអញធ្វើហើយ បិសុណាវាចាអញធ្វើហើយ ផរុសវាចាអញធ្វើហើយ សម្ផប្បលាបអញធ្វើហើយ អភិជ្ឈាអញធ្វើហើយ ព្យាបាទអញធ្វើហើយ មិច្ឆាទិដ្ឋិអញធ្វើហើយ សម្មាទិដ្ឋិអញមិនបានធ្វើទេ ។ កុក្កុច្ចៈ ការក្ដៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្តរមែងកើតឡើង ព្រោះអំពើដែលធ្វើហើយ ឬមិនបានធ្វើយ៉ាងនេះឯង ។ មួយទៀតកុក្កុច្ចៈ ការក្ដៅក្រហាយនៃចិត្ត ការស្ដាកស្ដាមនៃចិត្ត រមែងកើតឡើងថា អញជាអ្នកមិនបានធ្វើនូវការបំពេញក្នុងសីល ថាអញជាអ្នកមិនបានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ថាអញជាអ្នកមិនដឹងប្រមាណក្នុងភោជន ថាអញជាអ្នកមិនប្រកបនូវការភ្ញាក់រឭក ថាអញជាអ្នកមិនប្រកបដោយសតិសម្បជញ្ញ ថាសតិប្បដ្ឋាន ៤ អញមិនបានចម្រើន ថាសម្មប្បធាន ៤ អញមិនបានចម្រើន ថាឥទ្ធិបាទ ៤ អញមិនបានចម្រើន ថាឥន្ទ្រិយ ៥ អញមិនបានចម្រើន ថាពលៈ ៥ អញមិនបានចម្រើន ថាពោជ្ឈង្គ ៧ អញមិនបានចម្រើន ថាអដ្ឋង្គិកមគ្គដ៏ប្រសើរអញមិនបានចម្រើន ថាទុក្ខអញមិនបានកំណត់ដឹង ថាសមុទយៈអញមិនបានលះបង់ ថាមគ្គអញមិនបានចម្រើន ថានិរោធអញមិនបានធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា គប្បីវៀរចាកកុក្កុច្ចៈ គឺគប្បីឆ្ងាយ វៀរ វៀរចំពោះចាកកុក្កុច្ចៈ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានកុក្កុច្ចៈ គឺថាគប្បីជាបុគ្គលឆ្ងាយ វៀរ វៀរចំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះមិនប្រកបដោយកុក្កុច្ចៈ គប្បីសម្រេចនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីវៀរចាកកុក្កុច្ចៈ ។ ពាក្យថា មិនគប្បីប្រហែស គឺគប្បីជាអ្នកធ្វើដោយគោរព ធ្វើរឿយៗ

ធ្វើមិនដាច់ ប្រព្រឹត្តមិនរួញរា មិនដាក់ឆន្ទៈ មិនដាក់ធុរៈ មិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ។ គឺបានខាងការពេញចិត្ត ការព្យាយាម ការឧស្សាហ៍ ការប្រឹងប្រែង កម្លាំង ការមិនប្រែត្រឡប់វិញ សតិសម្បជញ្ញៈ ការព្យាយាមជាគ្រឿងដុតកំដៅកិលេស ការតាំងព្យាយាម អធិដ្ឋាន ការប្រកបរឿយៗនិងការមិនប្រហែសក្នុងកុសលធម៌ទាំងឡាយថា កាលណាអញនឹងបំពេញសីលក្ខន្ធដែលមិនទាន់បំពេញហើយ ឬថែទាំសីលក្ខន្ធដែលពេញហើយដោយប្រាជ្ញាក្នុងសីលក្ខន្ធនោះ ។ មួយទៀតបានខាងការពេញចិត្ត ការព្យាយាម ការឧស្សាហ៍ ការប្រឹងប្រែង កម្លាំង ការមិនប្រែត្រឡប់វិញ សតិសម្បជញ្ញៈ សេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស ការតាំងព្យាយាម អធិដ្ឋាន ការប្រកបរឿយៗនិងសេចក្តីមិនប្រហែស ក្នុងកុសលធម៌ទាំងឡាយថា កាលណាអញនឹងបំពេញសមាធិក្ខន្ធ បញ្ញាក្ខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញក្តី កាលណា អញគប្បីកំណត់ដឹងទុក្ខ ដែលមិនទាន់កំណត់ដឹងក្តី នឹងលះបង់កិលេសដែលមិនទាន់លះបង់ក្តី នឹងចម្រើនមគ្គដែលមិនទាន់ចម្រើនក្តី នឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីវៀរចាកកុក្កុច្ចៈ មិនគប្បីប្រហែសទេ ។

[ ៥០ ] អធិប្បាយពាក្យថា មួយទៀតគប្បីនៅក្នុងទីអង្គុយ ឬទីដេកដែលមិនមានសំឡេង ត្រង់ពាក្យថា មួយទៀត គឺជាបទតភ្ជាប់ ។បេ។ ភិក្ខុអង្គុយក្នុងទីណា គឺគ្រែ តាំង ពូក កន្ទេល កំណាត់ស្បែក កម្រាលស្មៅ កម្រាលស្លឹក កម្រាលចំបើង ទីនោះលោកហៅថា ទីអង្គុយ ។ សេនាសនៈ វិហារ

អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រងិល គុហា លោកហៅថា ទីដេក ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀតក្នុងទីអង្គុយ ឬទីដេក ។ ពាក្យថា គប្បីនៅក្នុងទីដែលមិនមានសំឡេង បានសេចក្តីថា គប្បីត្រាច់ទៅ គប្បីនៅ គប្បីទៅ គប្បីប្រព្រឹត្ត គប្បីរក្សា គប្បីយាត្រា គប្បីឲ្យយាត្រាទៅក្នុងសេនាសនៈដែលមិនមានសំឡេង មិនមានការគឹកកង ប្រាសចាកខ្យល់កាយនៃជន ជាទីស្ងប់ស្ងាត់ចាកមនុស្ស ជាទីដ៏សមគួរដល់ការពួនសម្ងំ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីនៅក្នុងទីអង្គុយ ឬទីដេកដែលមិនមានសំឡេង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុជាអ្នកមានឈាន មិនគប្បីរពឹសដោយជើង គប្បីវៀរចាក
កុក្កុច្ចៈ ( ការរពឹសឬរង្កៀស ) មិនគប្បីប្រហែសទេ ម្យ៉ាងទៀត
គប្បីនៅក្នុងទីអង្គុយ ឬទីដេកដែលមិនមានសំឡេង ។

[ ៥១ ] ភិក្ខុមានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ គប្បីគប់រកនូវការភ្ញាក់រឭក គប្បីលះបង់នូវសេចក្តីខ្ជិលប្រអូស មាយា ការសើច ការលេង មេថុនធម្មព្រមទាំងការស្អិតស្អាងចេញ ។

[ ៥២ ] ពាក្យថា មិនគប្បីធ្វើការដេកលក់ឲ្យច្រើន គឺធ្វើយប់នឹងថ្ងៃឲ្យមាន ៦ ចំណែក គប្បីភ្ញាក់រឭក ៥ ចំណែក គប្បីដេក ១ ចំណែក ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ ។

[ ៥៣ ] ពាក្យថា ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស គប្បីគប់រកការភ្ញាក់រឭក អធិប្បាយថា ភិក្ខុក្នុងសាសនានេះ គប្បីដុសខាត់ចិត្តចាក

ពួកធម៌ជាគ្រឿងរារាំង ដោយការចង្រ្កម ដោយកិរិយាអង្គុយ អស់វេលាថ្ងៃ គប្បីជុសខាត់ចិត្ត ចាកពួកធម៌ជាគ្រឿងរារាំង ដោយការចង្រ្កម ដោយកិរិយាអង្គុយ អស់បឋមយាមនៃរាត្រី គប្បីសម្រេចសីហសេយ្យាស ដោយចំហៀងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី យកជើងតម្រួតលើជើង ជាអ្នកមានស្មារតីដឹងខ្លួន ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា ក្រោកឡើងហើយជុសខាត់ចិត្ត ចាកពួកធម៌ជាគ្រឿងរារាំង ដោយការចង្រ្កម ដោយកិរិយាអង្គុយ អស់បច្ឆិមយាមនៃរាត្រី ។ ពាក្យថា គប្បីគប់រកការភ្ញាក់រឭក គឺគប្បីគប់រក គប្បីគប់រកព្រម គប្បីសេពចំពោះនូវការភ្ញាក់រឭក ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីគប់រកការភ្ញាក់រឭក ។ ពាក្យថា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស សេចក្តីថា ការព្យាយាម លោកហៅថា ការព្យាយាមជាគ្រឿងដុតកម្តៅកិលេស បានដល់ការព្យាយាមតឹងតែងដែលប្រព្រឹត្តទៅក្នុងចិត្ត ការខ្នះខ្នែង ការសង្វាត ការស្ទុះស្ទា ការព្យាយាម ការឧស្សាហ៍ ការប្រឹងប្រែង កម្លាំងចិត្ត ការព្យាយាមដ៏មាំ ការប្រឹងប្រែងមិនធូរថយ ការមិនដាក់ឆន្ទៈចោល ការមិនដាក់ធុរៈចោល ការផ្គងនូវធុរៈ សេចក្តីព្យាយាម ការព្យាយាមជាធំ ព្យាយាមជាកម្លាំង ព្យាយាមដោយប្រពៃ បុគ្គលនោះព្រមព្រៀង មូលមិត្ត ចូលទៅជិត អែបនែប កៀកកើយ ផ្តេកផ្តិត ប្រកបដោយការព្យាយាមជាគ្រឿងដុតកំដៅកិលេសនេះ ទើបលោកហៅថា អ្នកមានព្យាយាមជាគ្រឿងដុតកំដៅកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមានព្យាយាមជាគ្រឿងដុតកំដៅកិលេស គប្បីគប់រកការភ្ញាក់រឭក ។

[ ៥៤ ] អធិប្បាយពាក្យថា គប្បីលះបង់នូវសេចក្ដីខ្ជិលច្រអូស មាយា ការសើច ការលេង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ត្រង់ពាក្យថា សេចក្ដីខ្ជិលច្រអូស គឺសេចក្ដីខ្ជិលច្រអូស អាការនៃការខ្ជិលច្រអូស ភាពនៃការខ្ជិលច្រអូស ភាពនៃចិត្តខ្ជិលច្រអូស សេចក្ដីខ្ជិល អាការខ្ជិល ភាពនៃសេចក្ដីខ្ជិលណានេះ លោកហៅថា សេចក្ដីខ្ជិលច្រអូស ។ ពាក្យថា មាយា គឺការប្រព្រឹត្តប្រកបដោយការបញ្ឆោត លោកហៅថា មាយា ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងសេចក្ដីប្រាថ្នាដ៏លាមក ព្រោះហេតុនៃការបិទបាំងទុច្ចរិតនោះ តែងប្រាថ្នាថាឥអ្នកផងកុំដឹងអញត្រិះរិះ ថាអ្នកផងកុំដឹងអញពោលនូវវាចា ថាអ្នកផងកុំស្គាល់អញប្រឹងប្រែងដោយកាយ ថាអ្នកផងកុំដឹងអញ ។ មាយា ភាពនៃមាយា ការបំភ្លេច ការបញ្ឆោត ការបំភាន់ ការរោយរាយ ការនាំចេញ ការរក្សាពុត ការលាក់ពុត ការលាក់លៀម ការបិទបាំង ការគ្របបិទបាំង អំពើដ៏ជ្រៅ អំពើដ៏កំបាំង ការគ្របជិតស្និត កិរិយាអាក្រក់ឯណា មានសភាពយ៉ាងនេះ នេះលោកហៅថា មាយា ។ ពាក្យថា ការសើច គឺបុគ្គលខ្លះក្នុងលោកនេះសើចបង្ហាញធ្មេញហួសប្រមាណ ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ការសើចបញ្ចេញធ្មេញហួសប្រមាណឯណា នេះជាអំពើរបស់ក្មេងក្នុងអរិយវិន័យ ។

ពាក្យថាការលេង បានដល់ការលេង ២ គឺការលេងប្រកបដោយកាយ ១ ការលេងប្រកបដោយវាចា ១ ។ ការលេងប្រកបដោយកាយ តើដូចម្ដេច ។

ជនទាំងឡាយ លេងជីវខ្លះ លេងសេះខ្លះ លេងរថខ្លះ លេងធ្នូខ្លះ លេងបាស្កា មានក្រឡាប្រាំបីខ្លះ លេងបាស្កាមានក្រឡាដប់ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងវាងផ្លូវដែលគូរវាងខ្លះ លេងផ្ទាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងដោយបាចស្វាករលាស់ទឹកល័ខជាដើមឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងប៉ិស្វឹកខ្លះ លេងនង្គ័លតូចខ្លះ លេងជាំដូងខ្លះ លេងកង្ហារខ្លះ លេងគ្រឿងវាល់ដីដោយស្លឹកខ្លះ លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងឲ្យទាយអក្សរខ្លះ លេងទាយចិត្ត ( ស្តេចចង់ ) ខ្លះ លេងធ្វើត្រាប់គេខ្លះ នេះហៅថា ការលេងប្រកបដោយកាយ ។

ការលេងប្រកបដោយវាចា តើដូចម្តេច ។ ការធ្វើឲ្យដូចជាស្គរ ដោយសំឡេងមាត់ ការធ្វើត្រាប់ស្គរដោយមាត់ ការធ្វើសំឡេងដោយមាត់ដូចជាស្គរដែលគេវាយហើយ ការធ្វើសំឡេងដោយអណ្តាតទល់បបូរមាត់ ការបញ្ចេញសំឡេងដូចស្គរដោយមាត់ ការធ្វើឲ្យដូចជាស្គរតូច ដោយមាត់ ការនិយាយពន្យល់ឲ្យអ្នករាំ ការស្រែកហ៊ោ ការច្រៀង អំពើសើចលេង នេះហៅថា ការលេងប្រកបដោយវាចា ។

ឈ្មោះថា មេថុនធម្ម បានដល់ ធម៌អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់អ្នកខូច ធម៌អាក្រក់ មានទឹកជាទីបំផុត ធម៌កំបាំង ការជួបជុំរបស់បុគ្គល ១ គូៗ ។ ព្រោះហេតុអ្វី ទើបលោកហៅថា មេថុនធម្ម ។ ធម៌របស់បុគ្គល ២ នាក់ដែលត្រេកអរ ត្រេកអរក្រៃពេក មានចិត្តទទឹកដោយរាគៈ មានកិលេសរួបរឹត មានចិត្តដែលកិលេសគ្របសង្កត់ ធម៌របស់បុគ្គល ២ នាក់ស្មើគ្នា ព្រោះ

ហេតុនោះលោកហៅថា មេថុនធម្ម ។ ពួកជនអ្នកធ្វើជម្លោះ ២ នាក់ អ្នកធ្វើការប្រកាន់ ២ នាក់ អ្នកធ្វើវិវាទកថា ២ នាក់ អ្នកធ្វើការជជែក ២ នាក់ អ្នកធ្វើអធិករណ៍ ២ នាក់ អ្នកនិយាយ ២ នាក់ អ្នកចរចា ២ នាក់ លោកហៅថា អ្នកធ្វើធម៌ជាគូយ៉ាងណា ធម៌របស់បុគ្គល ២ នាក់ ដែលត្រេកអរ ត្រេកអរក្រៃពេក មានចិត្តទទឹកដោយរាគៈ មានកិលេសរួបរឹត មានចិត្តដែលកិលេសគ្របសង្កត់ ជាធម៌របស់បុគ្គល ២ នាក់ស្មើគ្នា ព្រោះហេតុនោះ លោកហៅថា មេថុធម្មយ៉ាងនោះដែរ ។

ពាក្យថា ការស្អិតស្អាង បានដល់ ការស្អិតស្អាង ២ គឺការស្អិតស្អាងរបស់គ្រហស្ថ ១ ការស្អិតស្អាងរបស់បព្វជិត ១ ។

ការស្អិតស្អាងរបស់គ្រហស្ថ តើដូចម្តេច ។ សក់ ពុកមាត់ ពុកចង្កា ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប គ្រឿងអាភរណៈ គ្រឿងប្រដាប់សំពត់ គ្រឿងស្អិតស្អាង ឈ្នួតក្បាល គ្រឿងអប់ ការប្រេបាច់រឹត ការផ្ងូតទឹក ការគក់ប្របាច់ កញ្ចក់ គ្រឿងបន្តក់ កម្រងផ្កានិងគ្រឿងលាប គ្រឿងលំអិតសម្រាប់ប្រោះមុខ វត្ថុសម្រាប់លាបមុខ គ្រឿងប្រដាប់ដៃ ចំណងក្ជួងសក់ ដំបង បំពង់ថ្នាំហិត ព្រះខ័ន ឆត្រ ស្បែកជើងដ៏វិចិត្រ មកុដ ឬក្បាំងមុខ ស្មៀតសក់ កែវមណី ផ្លិតធ្វើពីរោមកន្ទុយសត្វនិងសំពត់សទាំងវែងទាំងខ្លី នេះហៅថា ការស្អិតស្អាងរបស់គ្រហស្ថ ។

ការស្អិតស្អាងរបស់បព្វជិត តើដូចម្តេច ។ ការប្រដាប់ចីវរ ការប្រដាប់បាត្រ ការប្រដាប់ ការស្អិតស្អាង ការលេង ការលេងដោយប្រការៈ ការជាប់

ចិត្ត ភាពនៃការជាប់ចិត្ត ការធ្វើនូវគ្រឿងប្រដាប់ ភាពនៃការធ្វើនូវគ្រឿងប្រដាប់នូវកាយស្អុយនេះក្តី នូវបរិក្ខារទាំងឡាយជាខាងក្រៅក្តី នេះហៅថា ការស្អិតស្អាងរបស់បព្វជិត ។

ពាក្យថា គប្បីលះបង់នូវសេចក្តីខិលប្រអូស មាយា ការសើច ការលេងមេថុនធម្ម ព្រមទាំងការស្អិតស្អាង បានសេចក្តីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវសេចក្តីខិលប្រអូសផង មាយាផង ការសើចផង ការលេងផង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ព្រមទាំងបរិវារ ព្រមទាំងគ្រឿងប្រោះព្រំ ព្រមទាំងបរិក្ខារ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីលះបង់នូវសេចក្តីខិលប្រអូស មាយា ការសើច ការលេង មេថុនធម្ម ព្រមទាំងការស្អិតស្អាង ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមានព្យាយាម ជាគ្រឿងដុតកំដៅកិលេស មិនគប្បីធ្វើការ
ដេកលក់ឲ្យច្រើនទេ គប្បីគប់រកនូវការភ្ញាក់រឭក គប្បីលះបង់
នូវសេចក្តីខិលប្រអូស មាយា ការសើច ការលេង មេថុនធម្ម
ព្រមទាំងការស្អិតស្អាង ។

[ ៥៥ ] ភិក្ខុអ្នករាប់អាន ( ព្រះរតនត្រ័យ ) មិនគប្បីគប់នូវអំពើធ្មប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង មិនគប្បីសេពនូវមន្តសម្រាប់ទាយសំរែកសត្វផង ថ្នាំសម្រាប់ធ្វើកកិឲ្យតាំងនៅផង ការរក្សារោគផង ។

[ ៥៦ ] ពាក្យថា ភិក្ខុមិនគប្បីគប់នូវអំពើធ្មប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង អធិប្បាយថា ពួកគ្រូធ្មប់តែងប្រកបអំពើធ្មប់ កាលបើទី

ក្រុងគេបិទហើយឬសង្គ្រាមទល់គ្នាហើយ ក៏ញុំាងចង្រៃឲ្យកើត ញុំាងឧបទ្រព ឲ្យកើត ញុំាងរោគឲ្យកើត ធ្វើឲ្យបុក ធ្វើឲ្យបុកសៀត ធ្វើឲ្យគ្រុនក្ដៅ ធ្វើឲ្យ ចុះឈាមចំពោះពួកបច្ចាមិត្តជាសត្រូវពួកគ្រូធ្មប់តែងប្រកបអំពើធ្មប់យ៉ាងនេះ ។ ពួកគ្រូទាយសុបិន តែងទាយសុបិនថា បុគ្គលណាយល់សប្តិក្នុងវេលាព្រឹក ព្រហាមវិបាករមែងមានយ៉ាងនេះ បុគ្គលណាយល់សប្តិក្នុងវេលាថ្ងៃត្រង់វិបាក រមែងមានយ៉ាងនេះ បុគ្គលណាយល់សប្តិក្នុងវេលាថ្ងៃរសៀលវិបាករមែងមាន យ៉ាងនេះ បុគ្គលណាយល់សប្តិក្នុងបឋមយាម ក្នុងមជ្ឈិមយាម ក្នុងបច្ឆិមយាម បុគ្គលណាដេកដោយចំហៀងខាងស្ដាំ បុគ្គលណាដេកដោយចំហៀងខាងឆ្វេង បុគ្គលណាដេកផ្ងារ បុគ្គលណាដេកផ្កាប់ បុគ្គលណាយល់សប្តិឃើញព្រះចន្ទ បុគ្គលណាយល់សប្តិឃើញព្រះអាទិត្យ បុគ្គលណាយល់សប្តិឃើញមហា- សមុទ្រ បុគ្គលណាយល់សប្តិឃើញស្ដេចភ្នំឈ្មោះសិនេរុ បុគ្គលណាយល់សប្តិ ឃើញដំរី បុគ្គលណាយល់សប្តិឃើញសេះ បុគ្គលណាយល់សប្តិឃើញរថ បុគ្គលណាយល់សប្តិឃើញពលថ្មើរជើង បុគ្គលណាយល់សប្តិឃើញសេនា- ព្យូហៈ បុគ្គលណាយល់សប្តិឃើញសួនជាទីត្រេកអរ បុគ្គលណាយល់សប្តិ ឃើញព្រៃជាទីត្រេកអរ បុគ្គលណាយល់សប្តិឃើញភូមិ ជាទីត្រេកអរ បុគ្គល ណា យល់សប្តិឃើញស្រះឈូកជាទីត្រេកអរ វិបាករមែងមានយ៉ាងនេះ ពួក គ្រូទាយសុបិនតែងទាយសុបិនយ៉ាងនេះ ។ ពួកគ្រូទាយលក្ខណៈ តែងទាយ លក្ខណៈ គឺលក្ខណៈកែវមណី លក្ខណៈដំបង ឬឈើច្រត់ លក្ខណៈសំពត់ លក្ខណៈដាវ លក្ខណៈព្រួញ លក្ខណៈធ្នូ លក្ខណៈអាវុធ លក្ខណៈស្រី

លក្ខណៈប្រុស លក្ខណៈក្មេងស្រី លក្ខណៈក្មេងប្រុស លក្ខណៈខ្ញុំស្រី លក្ខណៈខ្ញុំប្រុស លក្ខណៈដំរី លក្ខណៈសេះ លក្ខណៈក្របី លក្ខណៈគោឧសភ លក្ខណៈពពែ លក្ខណៈកែះ លក្ខណៈមាន់ លក្ខណៈចាបឬក្រួច លក្ខណៈទន្សោង លក្ខណៈគ្រឿងប្រដាប់ផ្ទះ ឬកំពូលផ្ទះ លក្ខណៈអណ្តើក លក្ខណៈម្រឹគ ពួកគ្រូទាយលក្ខណៈតែងទាយលក្ខណៈយ៉ាងនេះ ។ ពួកគ្រូទាយនក្ខត្តឫក្សតែងទាយថា នក្ខត្តឫក្ស ២៨ ការចូលកាន់ផ្ទះត្រូវធ្វើដោយនក្ខត្តឫក្សនេះ មកុដគេត្រូវចងដោយនក្ខត្តឫក្សនេះ ការដណ្តឹងកូនគេ ត្រូវធ្វើដោយនក្ខត្តឫក្សនេះ ការនាំពូជ ( ដើម្បីសាបព្រោះ ) ត្រូវធ្វើដោយនក្ខត្តឫក្សនេះ ការគ្រប់គ្រងផ្ទះត្រូវធ្វើដោយនក្ខត្តឫក្សនេះ ពួកគ្រូទាយនក្ខត្តឫក្ស រមែងទាយនក្ខត្តឫក្សយ៉ាងនេះ ។ ពាក្យថា ភិក្ខុមិនគប្បីគប់ នូវអំពើធ្មប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង បានសេចក្តីថា មិនគប្បីគប់ មិនគប្បីប្រព្រឹត្ត មិនគប្បីប្រព្រឹត្តព្រម មិនគប្បីប្រព្រឹត្តសមាទាន ឬមិនគប្បីកាន់យក មិនគប្បីរៀន មិនគប្បីទ្រទ្រង់ មិនគប្បីចងចាំ មិនគប្បីកំណត់ មិនគប្បីប្រកបនូវអំពើធ្មប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីគប់នូវអំពើធ្មប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង ។

[ ៥៧ ] ពាក្យថា ភិក្ខុអ្នកកាប់អាន ( ព្រះរតនត្រ័យ ) មិនគប្បីសេពនូវមន្តសម្រាប់ទាយសំរែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង អធិប្បាយថា សំរែកម្រឹគ លោកហៅថា សំរែកសត្វ ។ ពួកគ្រូទាយសំរែកម្រឹគរមែងទាយសំរែកម្រឹគ រមែងដឹងនូវសំរែកស្រែករបស់

ពួកសត្វស្លាបឬពួកសត្វចតុប្បាទ ពួកគ្រូទាយសម្រែកម្រឹគរមែងទាយសម្រែកម្រឹគយ៉ាងនេះ ។ ពួកគ្រូពេទ្យធ្វើគភ៌រមែងញុំាងគភ៌ឲ្យតាំងនៅបាន ។ គភ៌មិនតាំងនៅដោយហេតុ ២ គឺដោយពួកជន្តុវ ឬដោយខ្យល់កម្រើក ។ ពួកគ្រូពេទ្យតែងឲ្យឱសថដើម្បីការពារពួកជន្តុវ ឬខ្យល់កម្រើក ពួកគ្រូពេទ្យធ្វើគភ៌រមែងញុំាងគភ៌ឲ្យតាំងនៅដោយវិធីយ៉ាងនេះ ។ ពាក្យថា ការរក្សារោគ បានដល់ការរក្សា ៥ គឺវេជ្ជកម្មខាងស្លាក ១ វេជ្ជកម្មខាងវះ ១ វេជ្ជកម្មខាងការរក្សាកាយ ១ វេជ្ជកម្មខាងភូត ១ វេជ្ជកម្មខាងកុមារ ១ ។ ពាក្យថា អ្នករាប់អាន ( ព្រះរតនត្រ័យ ) គឺអ្នករាប់អានព្រះពុទ្ធ រាប់អានព្រះធម៌ រាប់អានព្រះសង្ឃ បុគ្គលនោះរាប់អានព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏លើកតម្កើងបុគ្គលនោះ ។ សមដូចព្រះពុទ្ធដីកានេះដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាជាអ្នកកុហក រឹងរូស ពោលអែបអប មានកិលេសដូចស្នែង មានមានះខ្ពស់ឡើង មានចិត្តមិនតាំងមាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះមិនឈ្មោះថា អ្នករាប់អានតថាគតផង ភិក្ខុទាំងនោះឈ្មោះថាជាអ្នកប្រាសចាកធម្មវិន័យនេះផង ភិក្ខុទាំងនោះមិនដល់នូវសេចក្តីចម្រើនលូតលាស់ធំទូលាយក្នុងធម្មវិន័យនេះផង ម្នាលភិក្ខុទាំងឡាយ ឯពួកភិក្ខុណាជាអ្នកមិនកុហក មិនពោលអែបអប ជាអ្នកប្រាជ្ញ មិនរឹងរូស មានចិត្តតាំងមាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឈ្មោះថា រាប់អានតថាគតផង ភិក្ខុទាំងនោះឈ្មោះថា មិនប្រាសចាកធម្មវិន័យនេះផង ភិក្ខុទាំងនោះរមែងដល់នូវសេចក្តីចម្រើនលូតលាស់ ធំទូលាយក្នុងធម្មវិន័យនេះផង ។

ពួកភិក្ខុណាជាអ្នកកុហក រឹងរូស ពោលពាក្យអែបអប មានកិលេសដូចស្នែង មានមានះខ្ពស់ឡើង មានចិត្តមិនតាំងមាំ ភិក្ខុទាំងនោះរមែងមិនលូតលាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ទុកហើយ ឯពួកភិក្ខុណា ជាអ្នកមិនកុហក មិនពោលអែបអប ជាអ្នកប្រាជ្ញ មិនរឹងរូស មានចិត្តតាំងមាំ ភិក្ខុទាំងនោះរមែងលូតលាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធត្រាស់ទុកហើយ ។

ពាក្យថា ភិក្ខុអ្នករាប់អាន ( ព្រះរតនត្រ័យ ) មិនគប្បីសេពនូវមន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង បានសេចក្តីថា បុគ្គលអ្នករាប់អានព្រះរតនត្រ័យ មិនគប្បីសេព មិនគប្បីរាប់រក មិនគប្បីសេពចំពោះ មិនគប្បីប្រព្រឹត្ត មិនគប្បីអើពើ មិនគប្បីប្រព្រឹត្តសមាទាន ឬមិនគប្បីកាន់យក មិនគប្បីរៀន មិនគប្បីទ្រទ្រង់ មិនគប្បីចងចាំ មិនគប្បីកំណត់ មិនគប្បីប្រកបនូវមន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុអ្នករាប់អាន ( ព្រះរតនត្រ័យ ) មិនគប្បីសេពនូវមន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុអ្នករាប់អាន ( ព្រះរតនត្រ័យ ) មិនគប្បីគប់នូវអំពើធ្មប់ផង សុបិនផង លក្ខណៈផង នក្ខត្តឫក្សផង មិនគប្បីសេពនូវ

មន្ត សម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សាពោគផង ។

[ ៥៨ ] ភិក្ខុមិនគប្បីញាប់ញ័រដោយនិន្ទា បើត្រូវគេសរសើរហើយ មិនគប្បីឡើងជំនោរ គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយផង ការក្រោធផង ការញុះញង់ផង ។

[ ៥៩ ] ពាក្យថា ភិក្ខុមិនគប្បីញាប់ញ័រដោយនិន្ទា អធិប្បាយថា បុគ្គលពួកខ្លះក្នុងលោកនេះ និន្ទាភិក្ខុ គឺនិន្ទា តិះដៀល ត្មះ ដោយជាតិខ្លះ គោត្តខ្លះ ភាពនៃខ្លួនជាកូនមានត្រកូលខ្លះ ភាពនៃខ្លួនមានពណ៌សម្បុរល្អខ្លះ ទ្រព្យខ្លះ ការរៀនមន្តខ្លះ ការងារខ្លះ សិប្បៈខ្លះ ថ្នាក់នៃវិជ្ជាខ្លះ ការចេះដឹងខ្លះ ការវាងវៃខ្លះ វត្ថុណាមួយខ្លះ ។ ភិក្ខុត្រូវគេនិន្ទា តិះដៀល ពោលទោសហើយ មិនគប្បីញាប់ញ័រ មិនគប្បីញាប់ញ័រខ្លាំង មិនគប្បីញ័រចំប្រប់ មិនគប្បីតក់ស្លុត មិនគប្បីតក់ស្លុតខ្លាំង មិនគប្បីស្ទន់ស្ទោ មិនគប្បីខ្លាច មិនគប្បីដល់នូវការតក់ស្លុត ជាអ្នកមិនភ័យ ជាអ្នកមិនរន្ធត់ ជាអ្នកមិនតក់ស្លុត ជាអ្នកមិនរត់ ជាអ្នកលះបង់ភ័យដែលគួរខ្លាចហើយ ប្រាសចាកការព្រឺរោមដោយនិន្ទា ដំនៀលពាក្យត្មះ ការបង្អាប់កេរ្តិ៍ ការនាំមកនូវទោស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីញាប់ញ័រដោយនិន្ទា ។

[ ៦០ ] ពាក្យថា បើត្រូវគេសរសើរហើយ មិនគប្បីឡើងជំនោរ អធិប្បាយថា បុគ្គលពួកខ្លះក្នុងលោកនេះសរសើរភិក្ខុ គឺសរសើរ ស្ញើច តម្កើងពណ៌នាដោយជាតិខ្លះ ។បេ។ វត្ថុណាមួយខ្លះ ។ ភិក្ខុត្រូវគេសរសើរ ស្ញើច

តម្កើង ពណ៌នា មិនគប្បីធ្វើនូវការឡើងជំនោរ មិនគប្បីធ្វើការខ្ពស់ឡើង មិនគប្បីធ្វើមានះ មិនគប្បីធ្វើការរឹងត្អឹងព្រោះការសរសើរ ស្ញើច តម្កើង ការនាំមកនូវគុណ មិនត្រូវរឹងត្អឹង រឹងរូស មានក្បាលងើបព្រោះដំណើរនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើត្រូវគេសរសើរហើយ មិនគប្បីឡើងជំនោរ ។

[ ៦១ ] អធិប្បាយពាក្យថា គប្បីបន្ទោបង់លោភៈព្រមទាំងមច្ឆរិយៈផងការក្រោធផង កាញុះញង់ផង ត្រង់ពាក្យថា លោភៈ បានដល់ ការជាប់ចិត្ត អាការនៃការជាប់ចិត្ត ភាពនៃការជាប់ចិត្ត តម្រេកមានកម្លាំង អាការនៃតម្រេកមានកម្លាំង ភាពនៃតម្រេកមានកម្លាំង អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា កំណាញ់ បានដល់ កំណាញ់ ៥ គឺកំណាញ់អាវាស ១ ។បេ។ សេចក្តីប្រកាន់ លោកហៅថាកំណាញ់ ។ ពាក្យថា ក្រោធ បានដល់ សេចក្តីគុំគួន សេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង សេចក្តីថ្នាំងថ្នាក់នៃចិត្ត ការខឹង ការខឹងខ្លាំង ការខឹងក្រៃលែង សេចក្តីប្រទូស្ត សេចក្តីប្រទូស្តខ្លាំង សេចក្តីប្រទូស្តក្រៃលែង ការប្រែប្រួលនៃចិត្ត ការប្រទូស្តក្នុងចិត្ត សេចក្តីក្រោធ អាការក្រោធ ភាពនៃក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃការព្យាបាទ ការខុស ការអាក់អន់ ភាពកាច ការចេញទឹកភ្នែក សេចក្តីមិនត្រេកអរនៃចិត្ត ។ ពាក្យថា ការញុះញង់ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានវាចាញុះញង់ គឺឮអំពីពួកជនឯណោះហើយប្រាប់ពួកជនឯណោះ ដើម្បីការបំបែកពួកជនឯនេះ ឬឮអំពីពួកជនឯណោះហើយប្រាប់ពួកជនឯនេះ ដើម្បីការបំបែកពួកជនឯណោះ ជាអ្នក

បំបែកពួកជន ដែលព្រមព្រៀងគ្នាហើយផង ជាអ្នកបន្ថែមកម្លាំងដល់ពួកជន ដែលបែកគ្នាហើយផង ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រីករាយក្នុងពួក ជាអ្នកពោលនូវវាចាធ្វើឲ្យជាពួក នេះលោកហៅថា កាញុះញង់ ។ មួយទៀត បុគ្គលបង្កការញុះញង់ដោយហេតុ ២ គឺដោយសេចក្ដីប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន ឬជាអ្នកប៉ុនប៉ងឲ្យគេបែកគ្នា ។ បុគ្គលបង្កការញុះញង់ ដោយប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន តើដូចម្ដេច ។ បុគ្គលបង្កការញុះញង់ដោយប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន យ៉ាងនេះថា អញនឹងបានជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីស្និទ្ធស្នាល ជាអ្នកខាងក្នុង ជាមិត្តសម្លាញ់នៃជននេះ ។ បុគ្គលប៉ុនប៉ងឲ្យគេបែកគ្នា ហើយបង្កការញុះញង់ តើដូចម្ដេច ។ បុគ្គលប៉ុនប៉ងឲ្យគេបែកគ្នា ហើយបង្កការញុះញង់យ៉ាងនេះថា ធ្វើដូចម្ដេចជនទាំងអម្បាលនេះគប្បីផ្សេងគ្នា គប្បីព្រាត់ប្រាសគ្នា គប្បីជាពួក គប្បីជាចំណែកពីរ គប្បីបែកជាពីរ គប្បីបែកជាពីរពួក គប្បីបែកគ្នា មិនគប្បីមកជួបគ្នា គប្បីនៅជាទុក្ខ មិនសប្បាយ ។ ពាក្យថា គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង ការក្រោធផង ការញុះញង់ផង បានសេចក្ដីថា គប្បីបន្ទោបង់ លះបង់ បោះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវលោភៈផង មច្ឆរិយៈផង ការក្រោធផង ការញុះញង់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង ការក្រោធផង ការញុះញង់ផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីញាប់ញ័រដោយនិន្ទា បើត្រូវគេសរសើរហើយ មិន
គប្បីឡើងជំនោរ គប្បីបន្ទោបង់លោភៈ ព្រមទាំងមច្ឆរិយៈផង

ការក្រោធផង ការញុះញង់ផង ។

[ ៦២ ] ភិក្ខុមិនគប្បីតាំងនៅក្នុងការទិញនិងការលក់ មិនគប្បីធ្វើនូវការឲ្យគេតិះដៀលក្នុងទីណាមួយ មិនគប្បីជាប់ក្នុងស្រុក មិនគប្បីពោលរាក់ទាក់នឹងជនព្រោះប្រាថ្នាលាភទេ ។

[ ៦៣ ] ពាក្យថា ភិក្ខុមិនគប្បីតាំងនៅក្នុងការទិញនិងការលក់ អធិប្បាយថា ការទិញនិងការលក់ទាំងឡាយណាដែលព្រះមានព្រះភាគទ្រង់ឃាត់ហាមក្នុងវិន័យ ការទិញនិងការលក់ទាំងនោះ លោកមិនបំណងយកក្នុងសេចក្តីនេះទេ ។ ភិក្ខុតាំងនៅក្នុងការទិញនិងការលក់ តើដូចម្តេច ។ ភិក្ខុធ្វើរបស់បន្ទំក្តី ប្រាថ្នាចំណេញក្តី នូវបាត្រចីវរ ឬបរិក្ខារដទៃណាមួយ ជាមួយនឹងសហធម្មិកទាំង ៥ ឈ្មោះថា តាំងនៅក្នុងការទិញនិងការលក់យ៉ាងនេះ ។ ភិក្ខុមិនតាំងនៅក្នុងការទិញនិងការលក់ តើដូចម្តេច ។ ភិក្ខុមិនធ្វើរបស់បន្ទំក្តី មិនប្រាថ្នាចំណេញក្តី នូវបាត្រចីវរ ឬបរិក្ខារដទៃណាមួយ ជាមួយនឹងសហធម្មិកទាំង ៥ ឈ្មោះថា មិនតាំងនៅក្នុងការទិញនិងការលក់យ៉ាងនេះ ។ ពាក្យថា មិនគប្បីតាំងនៅក្នុងការទិញនិងការលក់ បានសេចក្តីថា មិនតាំងនៅ មិនតាំងនៅព្រមក្នុងការទិញនិងការលក់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវការទិញ និងការលក់ គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញចាកការទិញនិងការលក់ គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីតាំងនៅក្នុងការទិញនិងការលក់ ។

[ ៦៤ ] ពាក្យថា មិនគប្បីធ្វើនូវការឲ្យគេតិះដៀលក្នុងទីណាមួយ អធិប្បាយថា ពួកកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល តើដូចម្តេច ។ មានសមណ-ព្រាហ្មណ៍ពួកមួយ មានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តរបស់បុគ្គលដទៃ សមណ-ព្រាហ្មណ៍ទាំងនោះឃើញអំពីចម្ងាយខ្លះ មិនឃើញក្នុងទីជិតខ្លះ ដឹងចិត្តដោយចិត្តខ្លះ ។ មានពួកទេវតាខ្លះ មានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តរបស់បុគ្គលដទៃ ទេវតាទាំងនោះឃើញអំពីចម្ងាយខ្លះ មិនប្រាកដក្នុងទីជិតខ្លះ ដឹងច្បាស់នូវចិត្តដោយចិត្តខ្លះ ។ ជនទាំង ២ ពួកនោះរមែងឲ្យគេតិះដៀល ដោយកិលេសគ្រោតគ្រាតខ្លះ ដោយកិលេសជាកណ្តាលខ្លះ ដោយកិលេសដ៏ល្អិតខ្លះ ។ ពួកកិលេសគ្រោតគ្រាត តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ទាំងនេះហៅថា កិលេសគ្រោតគ្រាត ។ ពួកកិលេសជាកណ្តាល តើដូចម្តេច ។ កាមវិតក្កព្យាបាទវិតក្ក វិហឹសាវិតក្ក ទាំងនេះហៅថាកិលេសជាកណ្តាល ។ ពួកកិលេសដ៏ល្អិត តើដូចម្តេច ។ ការត្រិះរិះចំពោះញាតិ ការត្រិះរិះចំពោះជនបទ ការត្រិះ-រិះចំពោះការមិនចង់ស្លាប់ ការត្រិះរិះប្រកបដោយសេចក្តីអាណិតចំពោះជនដទៃ ការត្រិះរិះ ប្រកបដោយលាភសក្ការនិងសេចក្តីសរសើរ ការត្រិះរិះប្រកបដោយការ មិនឲ្យគេមើលងាយ ទាំងនេះហៅថា កិលេសដ៏ល្អិត ។ ជនទាំង ២ ពួកនោះរមែងឲ្យគេតិះដៀលដោយពួកកិលេសគ្រោតគ្រាតខ្លះ ដោយពួកកិលេសជាកណ្តាលខ្លះ ដោយពួកកិលេសដ៏ល្អិតខ្លះ ។ ភិក្ខុមិនគប្បីធ្វើនូវការឲ្យគេតិះដៀល គឺមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីឲ្យលូតលាស់ មិនគប្បីឲ្យដុះដាល នូវពួកកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល

គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវកិលេស ជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកពួកកិលេសជាគ្រឿងធ្វើនូវការឲ្យគេតិះដៀល ហើយនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ។ ពាក្យថា ក្នុងទីណាមួយ គឺក្នុងទីដូចម្តេច ក្នុងទីណា ក្នុងទីនីមួយ ទោះជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងខាងក្រៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើនូវការឲ្យគេតិះដៀលក្នុងទីណាមួយ ។

[ ៦៥ ] ពាក្យថា មិនគប្បីជាប់ក្នុងស្រុក អធិប្បាយថា ភិក្ខុជាប់ក្នុងស្រុក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ នៅប្រឡូកប្រឡំដោយពួកគ្រហស្ថក្នុងស្រុក គឺជាអ្នកត្រេកត្រអាលជាមួយ មានសេចក្តីសោកជាមួយ កាលពួកគ្រហស្ថដល់នូវសុខ ក៏ដល់នូវសុខ កាលពួកគ្រហស្ថដល់នូវទុក្ខ ក៏ដល់នូវទុក្ខ កាលបើករណីយកិច្ចកើតឡើង ក៏ដល់នូវការខ្វល់ខ្វាយចំពោះខ្លួនឯង ភិក្ខុជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុស្លៀកក្នុងវេលាព្រឹកព្រហាម ហើយកាន់យកបាត្រនិងចីវរ ចូលទៅក្នុងស្រុក ឬនិគម ដើម្បីបិណ្ឌបាតដោយកាយដែលមិនបានរក្សា ដោយវាចាដែលមិនបានរក្សា ដោយចិត្តដែលមិនបានរក្សា ដោយស្មារតីដែលមិនបានតម្កល់មាំ ដោយឥន្ទ្រិយដែលមិនបានសង្រួម ភិក្ខុនោះជាប់ក្នុងអារម្មណ៍នោះៗ ក្តួចកាន់ក្នុងអារម្មណ៍នោះៗ ចំពាក់ក្នុងអារម្មណ៍នោះៗ ដល់នូវវិនាសក្នុងអារម្មណ៍នោះៗ ភិក្ខុជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ។ ភិក្ខុមិនជាប់ក្នុងស្រុក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មិននៅប្រឡូកប្រឡំ

ដោយពួកគ្រហស្ថ ក្នុងស្រុក គឺជាអ្នកមិនត្រេកអរជាមួយ មិនសោកជាមួយ កាលពួកគ្រហស្ថដល់នូវសុខក៏មិនដល់នូវសុខ (ជាមួយ) កាលបើពួកគ្រហស្ថដល់នូវទុក្ខ ក៏មិនដល់នូវទុក្ខ ( ជាមួយ ) កាលបើករណីយកិច្ចកើតឡើង ក៏មិនដល់នូវការខ្វល់ខ្វាយដោយខ្លួនឯង ភិក្ខុមិនជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុស្លៀកក្នុងវេលាព្រឹកព្រហាម ហើយកាន់យកនូវបាត្រនិងចីវរ ចូលទៅស្រុកឬនិគម ដើម្បីបិណ្ឌបាតដោយកាយដែលរក្សាហើយ ដោយវាចាដែលរក្សាហើយ ដោយចិត្តដែលរក្សាហើយ ដោយស្មារតីដែលតម្កល់មាំហើយ ដោយឥន្ទ្រិយដែលសង្រួមហើយ ភិក្ខុនោះមិនជាប់ក្នុងអារម្មណ៍នោះៗ មិនក្ដួចកាន់ក្នុងអារម្មណ៍នោះៗ មិនចំពាក់ក្នុងអារម្មណ៍នោះៗ មិនដល់នូវការវិនាសក្នុងអារម្មណ៍នោះៗ ភិក្ខុមិនជាប់ក្នុងស្រុក យ៉ាងនេះខ្លះ ។ ពាក្យថា មិនគប្បីជាប់ក្នុងស្រុក បានសេចក្ដីថា មិនគប្បីជាប់ មិនគប្បីក្ដួចកាន់ មិនគប្បីចំពាក់ មិនគប្បីកង្វល់ក្នុងស្រុក ជាអ្នកមិនជាប់ចិត្ត មិនធ្លាក់ចុះ មិនជ្រុលជ្រប់ មិនផ្ទុងផ្ទប់ ប្រាសចាកការជាប់ចំពាក់ ឃ្លាតចាកការជាប់ចំពាក់ លះបង់ការជាប់ចំពាក់ ។បេ។ គប្បីនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីជាប់ក្នុងស្រុក ។

[ ៦៦ ] ពាក្យថា មិនគប្បីពោលរាក់ទាក់នឹងជន ព្រោះប្រាថ្នាលាភ អធិប្បាយថា ការរាក់ទាក់ តើដូចម្ដេច ។ ការហៅរក ការពោលរាក់ទាក់ ការពោលស្រស់ស្រាយ ការពោលស្រុះស្រួល ការពោលរួសរាយ ការលួងលោម ការបន្ទន់ចិត្តគ្រហស្ថ ការលើកបញ្ជោរ ការលើកតម្កើង ការពោល

ពាក្យជាទីស្រឡាញ់រឿយៗ ការបន្ទោបន្ទន់កាយ ការពោលពាក្យដូចសម្ល សណ្ដែកបាយ ការថ្នាក់ថ្នមកូនរបស់គ្រហស្ថ ការពោលពាក្យដូចស៊ុំខ្នងជនដទៃ ទៅរកពួកជនដទៃណា នៃភិក្ខុអ្នកអាស្រ័យលាភៈសក្ការៈ និងសេចក្ដីសរសើរ មានប្រាថ្នាដ៏លាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ ជាអ្នកសម្លឹងអាមិស អ្នកធ្ងន់ក្នុងលោកធម៌ ឬការពោលពាក្យផ្អែមល្ហែម ការពោលពាក្យទន់ ការពោលពាក្យប្រកបដោយមេត្តា ការពោលពាក្យមិនអាក្រក់ណា ចំពោះជនទាំងនោះ នេះលោកហៅថា ការពោលរាក់ទាក់ ។ មួយទៀត ភិក្ខុពោលរាក់ទាក់នឹងជន ដោយហេតុ ២ គឺភិក្ខុដាក់ខ្លួនឲ្យទាប លើកបុគ្គលដទៃឲ្យខ្ពស់ ពោលរាក់ទាក់នឹងជនឬលើកខ្លួនឯងឲ្យខ្ពស់ដាក់បុគ្គលដទៃឲ្យទាប ពោលរាក់ទាក់នឹងជន ។

ភិក្ខុដាក់ខ្លួនឲ្យទាបលើកបុគ្គលដទៃឲ្យខ្ពស់ ពោលរាក់ទាក់នឹងជន តើដូចម្ដេច ។ ភិក្ខុពោលថា អ្នកទាំងឡាយ មានឧបការៈច្រើនដល់អាត្មា អាត្មាអាស្រ័យនឹងពួកអ្នកទើបបានចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ឯពួកជនដទៃណាសម្គាល់ដើម្បីឲ្យ ឬដើម្បីធ្វើដល់អាត្មា ពួកជននោះក៏អាស្រ័យអ្នកទាំងឡាយ យល់អ្នកទាំងឡាយ មួយទៀតឈ្មោះដើមណាដែលមាតាបិតាឲ្យ ឈ្មោះរបស់អាត្មានោះបាត់ទៅហើយ អាត្មាដែលបានឋានៈជាជីតុនអាមាត្យឯណោះ ជាជីតុនឧបាសិកាឯណោះ ក៏ដោយសារអ្នកទាំងឡាយ ភិក្ខុដាក់ខ្លួនឲ្យទាប លើកបុគ្គលដទៃឲ្យខ្ពស់ ពោលរាក់ទាក់នឹងជន យ៉ាងនេះឯង ។

ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ដាក់បុគ្គលដទៃឲ្យទាប ពោលរាក់ទាក់នឹងជន តើ

ដូចម្តេច ។ ភិក្ខុពោលថា អាត្មាមានឧបការៈច្រើនដល់អ្នកទាំងឡាយ អ្នកទាំងឡាយអាស្រ័យនឹងអាត្មាទើបដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេ-សុមិច្ឆាចារៈ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកសុរានិងមេរ័យ អាត្មាឲ្យឧទ្ទេស ឲ្យបរិបុច្ឆា ប្រាប់ឧបោសថ អធិដ្ឋាននូវនវកម្មដល់អ្នកទាំងឡាយ ម្យ៉ាងទៀតអ្នកទាំងឡាយ មិនសមបើបោះបង់អាត្មាចោលទៅធ្វើសក្ការៈ ធ្វើគោរពរាប់អានបូជាបុគ្គលដទៃវិញសោះ ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ ដាក់បុគ្គលដទៃឲ្យទាប ពោលរាក់ទាក់នឹងជនដទៃ យ៉ាងនេះឯង ។ ពាក្យថា មិនគប្បីពោលរាក់ទាក់នឹងជនព្រោះប្រាថ្នាលាភ បានសេចក្តីថា ភិក្ខុបង្អាប់នូវលាភ មិនរាក់ទាក់នឹងជនព្រោះហេតុតែលាភ ព្រោះការណ៍នៃលាភ ព្រោះការកើតនៃលាភ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាសឲ្យដល់នូវការមិនកើតមាននូវការពោលរាក់ទាក់ គប្បីជាអ្នកធ្វាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការរាក់ទាក់ នៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីពោលរាក់ទាក់នឹងជនព្រោះប្រាថ្នាលាភ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ភិក្ខុមិនគប្បីតាំងនៅក្នុងការទិញនិងការលក់ មិនគប្បីធ្វើនូវការ
> ឲ្យគេតិះដៀលក្នុងទីណាមួយ មិនគប្បីជាប់ក្នុងស្រុក មិនគប្បី
> ពោលរាក់ទាក់នឹងជនព្រោះប្រាថ្នាលាភទេ ។

[ ៦៧ ] ភិក្ខុមិនគប្បីជាអ្នកអួតអាង មិនគប្បីពោលវាចាកៀវគរ មិនគប្បីសិក្សានូវអំពើឃ្នើសឃ្នង មិនគប្បីពោលពាក្យផ្ទួញផ្តាល់ ។

[ ៦៨ ] ពាក្យថា ភិក្ខុមិនគប្បីជាអ្នកអួតអាង សេចក្តីថា ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកអួតអាង ជាអ្នកពោលអំនួត ភិក្ខុនោះអួតអាង គឺអួតអាង ពោលអំនួតថា ខ្ញុំជាអ្នកបរិបូណ៌ដោយសីល ឬថាជាអ្នកបរិបូណ៌ដោយវត្ត ឬក៏ថាជាអ្នកបរិបូណ៌ដោយសីលនិងវត្ត ដោយជាតិ ដោយគោត្ត ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូល ដោយភាពនៃខ្លួនមានសម្បុរល្អ ដោយទ្រព្យ ដោយការរៀន ដោយការងារ ដោយសិប្បៈ ដោយថ្នាក់នៃវិជ្ជា ដោយការចេះដឹង ដោយបដិភាណឬដោយវត្ថុណាមួយ ថាជាអ្នកចេញអំពីត្រកូលខ្ពស់ហើយបួស ឬថាជាអ្នកចេញ អំពីត្រកូលមានភោគៈច្រើនហើយបួស ថាជាអ្នកចេញអំពីត្រកូលមានភោគៈដ៏លើសលុបហើយបួស ថាជាអ្នកចេះព្រះសូត្រ ថាជាអ្នកទ្រទ្រង់វិន័យ ថាជាធម្មកថិក ថាជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ។បេ។ ឬថាជាអ្នកបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ ភិក្ខុមិនគប្បីពោលអួត គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវការពោលអួត គឺជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញចាកការពោលអួត គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេសយ៉ាងនេះឯង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីជាអ្នកអួតអាង ។

[ ៦៩ ] ពាក្យថា មិនគប្បីពោលនូវវាចាកៀវគរ សំណួរថា ចុះវាចាកៀវគរ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ពោលវាចាកៀវគរចីវរ ពោល

វាចាកៀរគរបិណ្ឌបាត ពោលវាចាកៀរគរសេនាសនៈ ពោលវាចាកៀរគរគិលានប្បច្ចយភេសជ្ជបរិក្ខារ នេះលោកហៅថា វាចាកៀរគរ ។ មួយទៀតភិក្ខុពោលពាក្យពិតខ្លះ ពោលពាក្យកុហកខ្លះ ពោលពាក្យញុះញង់ខ្លះ ពោលពាក្យមិនញុះញង់ខ្លះ ពោលពាក្យអាក្រក់ខ្លះ ពោលពាក្យមិនអាក្រក់ខ្លះ ពោលសម្ផប្បលាបៈខ្លះ ពោលពាក្យមិនមែនជាសម្ផប្បលាបៈខ្លះ ពោលវាចាដោយប្រាជ្ញាខ្លះ ព្រោះហេតុចីវរ ព្រោះហេតុបិណ្ឌបាត ព្រោះហេតុសេនាសនៈ ព្រោះហេតុគិលានប្បច្ចយភេសជ្ជបរិក្ខារ នេះលោកហៅថា វាចាកៀរគរ ។ មួយទៀតភិក្ខុមានចិត្តជ្រះថ្លា សម្ដែងធម៌ដល់ពួកជនដទៃ ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ពួកជនគប្បីស្ដាប់ធម៌របស់អញ លុះស្ដាប់ហើយគប្បីជ្រះថ្លានឹងធម៌ លុះជ្រះថ្លាហើយគប្បីធ្វើអាការជ្រះថ្លាដល់អញ នេះលោកហៅថា វាចាកៀរគរ ។ ពាក្យថា មិនគប្បីពោលវាចាកៀរគរ បានសេចក្ដីថា មិនគប្បីពោល មិនគប្បីសម្ដែង មិនគប្បីពណ៌នា មិនគប្បីបំភ្លឺ មិនគប្បីថ្លែងនូវវាចាកៀរគរ ដោយហោចទៅរាប់យកធម្មទេសនាវាចាផង គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវវាចាកៀរគរ គប្បីជាអ្នកថ្វាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកវាចាកៀរគរ គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីពោលវាចាកៀរគរ ។

[ ៧០ ] អធិប្បាយពាក្យថា មិនគប្បីសិក្សានូវអំពើឃ្មើសឃ្មង ត្រង់ពាក្យថា អំពើឃ្មើសឃ្មង បានដល់ អំពើឃ្មើសឃ្មង ៣ គឺអំពើឃ្មើសឃ្មងប្រកប

ដោយកាយ ១ អំពើឃ្នើសឃ្នងប្រកបដោយវាចា ១ អំពើឃ្នើសឃ្នងប្រកបដោយចិត្ត ១ ។

អំពើឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងសង្ឃ សម្តែងការឃ្នើសឃ្នង ប្រកបដោយកាយក៏មាន នៅក្នុងគណៈ សម្តែងការឃ្នើសឃ្នងប្រកបដោយកាយក៏មាន សម្តែងការឃ្នើសឃ្នងប្រកបដោយកាយក្នុងរោងឆាន់ក៏មាន សម្តែងការឃ្នើសឃ្នងប្រកបដោយកាយក្នុងរោងភ្លើងក៏មាន សម្តែងការឃ្នើសឃ្នងប្រកបដោយកាយក្នុងកំពង់ទឹកក៏មាន កំពុងចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នង ប្រកបដោយកាយក៏មាន ចូលទៅកាន់ចន្លោះផ្ទះហើយសម្តែងការឃ្នើសឃ្នងប្រកបដោយកាយក៏មាន ។

ភិក្ខុនៅក្នុងសង្ឃ សម្តែងការឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងសង្ឃ មិនធ្វើសេចក្តីកោតក្រែង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុនៅក្នុងសង្ឃ សម្តែងការឃ្នើសឃ្នង ប្រកបដោយកាយយ៉ាងនេះ ។

ភិក្ខុនៅក្នុងគណៈ សម្តែងការឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងគណៈមិនធ្វើសេចក្តីកោតក្រែង គឺកាលពួកភិក្ខុជាថេរៈមិនពាក់ស្បែកជើងចង្រ្កម ខ្លួនពាក់ស្បែកជើងចង្រ្កម កាលពួកភិក្ខុជាថេរៈចង្រ្កមក្នុងទីចង្រ្កមទាប ខ្លួនចង្រ្កមលើទីចង្រ្កមខ្ពស់ កាលពួកភិក្ខុជាថេរៈចង្រ្កមលើផែនដី ខ្លួនចង្រ្កមលើទីចង្រ្កម ឈរប្រជ្រៀតខ្លះ អង្គុយប្រជ្រៀតខ្លះ

ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុនៅក្នុងគណៈសម្តែងការឃ្នើសឃ្នងប្រកបដោយកាយយ៉ាងនេះ ។

ភិក្ខុសម្តែងការឃ្នើសឃ្នងប្រកបដោយកាយក្នុងរោងឆាន់ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះមិនធ្វើសេចក្តីកោតក្រែងក្នុងរោងឆាន់គឺអង្គុយប្រជ្រៀតពួកភិក្ខុជាថេរៈ ឃាត់ពួកភិក្ខុថ្មីដោយអាសនៈខ្លះ ឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយនឹងពួកភិក្ខុជាថេរៈខ្លះ និយាយវាសដៃខ្លះ ភិក្ខុសម្តែងការឃ្នើសឃ្នង ប្រកបដោយកាយក្នុងរោងឆាន់យ៉ាងនេះ ។

ភិក្ខុសម្តែងការឃ្នើសឃ្នងប្រកបដោយកាយក្នុងរោងភ្លើង តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មិនធ្វើសេចក្តីកោតក្រែងក្នុងរោងភ្លើង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ មិនប្រាប់សិនហើយដាក់ឧសខ្លះ មិនប្រាប់សិនហើយបិទទ្វារខ្លះ ភិក្ខុសម្តែងការឃ្នើសឃ្នង ប្រកបដោយកាយក្នុងរោងភ្លើងយ៉ាងនេះ ។

ភិក្ខុសម្តែងការឃ្នើសឃ្នងប្រកបដោយកាយក្នុងកំពង់ទឹក តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះមិនធ្វើសេចក្តីកោតក្រែងក្នុងកំពង់ទឹក គឺចុះទៅប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ចុះខាងមុខខ្លះ ងូតប្រជ្រៀតខ្លះ ងូតខាងមុខខ្លះ ងូតខាងលើខ្លះ ឡើងប្រជ្រៀតខ្លះ ឡើងខាងមុខខ្លះ ឡើងខាងលើខ្លះ ភិក្ខុសម្តែងការឃ្នើសឃ្នង

ប្រកបដោយកាយ ក្នុងកំពង់ទឹកយ៉ាងនេះ ។

ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នង ប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះកំពុងចូលទៅកាន់ចន្លោះផ្ទះ មិនធ្វើសេចក្តីកោតក្រែង គឺដើរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ដើរខាងមុខខ្លះ ដើរហួសទៅពីមុខពួកភិក្ខុជាថេរៈខ្លះ ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សម្តែងការឃ្នើសឃ្នងប្រកបដោយកាយយ៉ាងនេះ ។

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសម្តែងការឃ្នើសឃ្នងប្រកបដោយកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះហើយ គេមិនទាន់និយាយថា លោកម្ចាស់សូមចូលមកក៏ចូលមក គេមិនទាន់និយាយថា លោកម្ចាស់សូមឈរវង់ក៏នៅឈរ គេមិនទាន់និយាយថា លោកម្ចាស់សូមគង់ ក៏អង្គុយ ចូលទៅកាន់ទីមិនមែនឱកាសខ្លះ ឈរក្នុងទីមិនមែនឱកាសខ្លះ អង្គុយក្នុងទីមិនមែនឱកាសខ្លះ ម្នីម្នាចូលទៅក្នុងបន្ទប់ទាំងឡាយ របស់ត្រកូលទាំងឡាយ ជាទីដែលគេពួនផង បិទបាំងផង ជាទីដែលពួកស្រីក្នុងត្រកូល ពួកកូនស្រីរបស់ត្រកូល ពួកកូនប្រសាស្រីរបស់ត្រកូល ពួកកុមារីរបស់ត្រកូលអង្គុយខ្លះ ស្ទាបអង្អែលក្បាលរបស់កុមារតូចខ្លះ ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសម្តែងការឃ្នើសឃ្នងប្រកបដោយកាយយ៉ាងនេះ ។ នេះឈ្មោះថា អំពីឃ្នើសឃ្នងប្រកបដោយកាយ ។

អំពីឃ្នើសឃ្នងប្រកបដោយវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះនៅក្នុងសង្ឃសម្តែងកាឃ្នើសឃ្នងប្រកបដោយវាចាក៏មាន នៅក្នុងគណៈសម្តែង

កាឃ្មើសឃ្មង ប្រកបដោយវាចាក៏មាន ចូលទៅចន្លោះផ្ទះ ហើយសម្តែងការឃ្មើសឃ្មងប្រកបដោយវាចាក៏មាន ។

ភិក្ខុនៅក្នុងសង្ឃសម្តែងការឃ្មើសឃ្មង ប្រកបដោយវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសននេះ នៅក្នុងសង្ឃមិនធ្វើសេចក្តីកោតក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬពួកភិក្ខុជាថេរៈមិនបានអារាធនា ក៏សម្តែងធម៌ ធ្លើយប្រស្នាសម្តែងបាតិមោក្ខ ដល់ពួកភិក្ខុនៅក្នុងអារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុនៅក្នុងសង្ឃសម្តែងកាឃ្មើសឃ្មងប្រកបដោយវាចាយ៉ាងនេះ ។

ភិក្ខុនៅក្នុងគណៈ សម្តែងកាឃ្មើសឃ្មងប្រកបដោយវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ នៅក្នុងគណៈមិនធ្វើសេចក្តីកោតក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬពួកភិក្ខុជាថេរៈមិនបានអារាធនា ក៏សម្តែងធម៌ ធ្លើយប្រស្នាដល់ពួកភិក្ខុនៅក្នុងអារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ សម្តែងធម៌ ធ្លើយប្រស្នាដល់ពួកភិក្ខុនី ពួកឧបាសក ពួកឧបាសិកា ដែលនៅក្នុងអារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុនៅក្នុងគណៈសម្តែងកាឃ្មើសឃ្មងប្រកបដោយវាចាយ៉ាងនេះ ។

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ហើយសម្តែងកាឃ្មើសឃ្មង ប្រកបដោយវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះហើយនិយាយនឹងស្រីឬនឹងកុមារី និយាយមម៉េះមម៉ោះថា នែនាងឈ្មោះនេះ នែនាងគោត្តនេះ មានអ្វីទេ មានបបរទេ មានបាយទេ មានបង្អែមទេ ពួកយើងនឹងផឹកអ្វី បរិភោគអ្វី ស៊ីអ្វី មានអ្វីទេ ពួកនាងនឹងឲ្យអ្វីដល់អាត្មា ភិក្ខុចូលទៅកាន់ចន្លោះផ្ទះហើយ

សម្តែងការឃ្មើសឃ្មងប្រកបដោយវាចាយ៉ាងនេះ ។ នេះឈ្មោះថា អំពើឃ្មើសឃ្មងប្រកបដោយវាចា ។

អំពើឃ្មើសឃ្មងប្រកបដោយចិត្ត តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះជាអ្នកមិនចេញអំពីត្រកូលខ្ពស់ហើយបួសទេ តែតាំងចិត្តធ្វើខ្លួន ឲ្យប្រហែលនឹងបុគ្គល ដែលចេញអំពីត្រកូលខ្ពស់ហើយបួស ជាអ្នកមិនចេញអំពីត្រកូលធំហើយបួស ជាអ្នកមិនចេញអំពីត្រកូលមានភោគៈច្រើនហើយបួស ជាអ្នកមិនចេញអំពីត្រកូលមានភោគៈដ៏លើសលុប ហើយបួសទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គលដែលចេញអំពីត្រកូលមានភោគៈលើសលុប ហើយបួស ជាអ្នកមិនចេះព្រះសូត្រទេតែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គលដែលចេះព្រះសូត្រ ជាអ្នកមិនទ្រទ្រង់ព្រះវិន័យ មិនមែនជាធម្មកថិក មិនប្រព្រឹត្តអារញ្ញិកធុតង្គ មិនប្រព្រឹត្តបិណ្ឌបាតិកធុតង្គ មិនប្រព្រឹត្តបំសុកូលិកធុតង្គ មិនប្រព្រឹត្តតេចីវរិកធុតង្គ មិនប្រព្រឹត្តសបទានចារិកធុតង្គ មិនប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ មិនប្រព្រឹត្តនេសជ្ជិកធុតង្គ មិនប្រព្រឹត្តយថាសន្ថតិកធុតង្គទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គល ដែលប្រព្រឹត្តយថាសន្ថតិកធុតង្គ ជាអ្នកមិនបានបឋមជ្ឈានទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គល ដែលបានបឋមជ្ឈានជាអ្នកមិនបានទុតិយជ្ឈាន មិនបានតតិជ្ឈាន មិនបានចតុត្ថជ្ឈាន មិនបានអាកាសានញ្ចាយតនសមាបត្តិ មិនបានវិញ្ញាណញ្ចាយតនសមាបត្តិ មិនបានអាកិញ្ចញ្ញាយតនសមាបត្តិ មិនបាននេវសញ្ញានាសញ្ញាយតនសមាបត្តិទេ តែតាំងចិត្តធ្វើខ្លួនឲ្យប្រហែលនឹងបុគ្គល ដែលបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ នេះ

ឈ្មោះថា អំពើឃ្នើសឃ្នងប្រកបដោយចិត្ត ។ ពាក្យថា មិនគប្បីសិក្សានូវអំពើឃ្នើសឃ្នង បានសេចក្ដីថា មិនគប្បីសិក្សា មិនគប្បីប្រព្រឹត្ត មិនគប្បីប្រព្រឹត្តព្រម មិនគប្បីប្រព្រឹត្ត សមាទាននូវអំពើឃ្នើសឃ្នង គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាននូវអំពើឃ្នើសឃ្នង គប្បីជាអ្នកឆ្ងាយវៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកអំពើឃ្នើសឃ្នង គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីសិក្សានូវអំពើឃ្នើសឃ្នង ។

[ ៧១ ] ពាក្យថា មិនគប្បីពោលពាក្យផ្ចួញផ្ចាល់ សំណួរថា ពាក្យផ្ចួញផ្ចាល់តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកធ្វើនូវពាក្យពោលមានភាពយ៉ាងនេះថា អ្នកមិនយល់ធម៌វិន័យនេះទេ ។បេ។ ឬថាបើអ្នកអាច ចូរដោះចុះ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលមោឃរាជ កាលបើពាក្យផ្ចួញផ្ចាល់មាន សម្ដីច្រើនក៏កើតប្រាកដ កាលបើពាក្យច្រើនមានហើយ សេចក្ដីពាយមាយក៏កើតប្រាកដ កាលបើបុគ្គលមានចិត្តពាយមាយហើយ សេចក្ដីមិនសង្រួមក៏កើតប្រាកដ កាលបើបុគ្គលមិនសង្រួមហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។ ពាក្យថា មិនគប្បីពោលនូវពាក្យផ្ចួញផ្ចាល់ គឺមិនគប្បីពោល មិនគប្បីពណ៌នា មិនគប្បីបំភ្លឺ មិនគប្បីថ្លែងនូវពាក្យផ្ចួញផ្ចាល់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាននូវពាក្យផ្ចួញផ្ចាល់ គប្បីជាអ្នកឆ្ងាយវៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញចាកពាក្យផ្ចួញផ្ចាល់ គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ

( ទ្រង់ត្រាស់ថា ) មិនគប្បីពោលនូវពាក្យផ្ចូញផ្ចាល់ ។ ព្រោះហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីជាអ្នកអួតអាង មិនគប្បីពោលនូវវាចាកៀកគរ មិនគប្បីសិក្សានូវអំពីឃ្នើសឃ្នង មិនគប្បីពោលពាក្យផ្ចូញផ្ចាល់ ។

[ ៧២ ] បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក គប្បីជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្តឡើយ ។

[ ៧៣ ] ពាក្យថា បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក អធិប្បាយថា មុសាវាទ លោកហៅថា ការពោលពាក្យកុហក ។ បុគ្គលខ្លះក្នុងលោកនេះទៅកាន់រោងជាទីប្រជុំ ទៅកាន់បរិស័ទ ។បេ។ ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួន ព្រោះហេតុតែអាមិសតិចតួច នេះលោកហៅថា ការពោលពាក្យកុហក ។ ម្យ៉ាងទៀត មុសាវាទរមែងមានដោយអាការៈ ៣ គឺមុសាវាទរបស់បុគ្គលនោះក្នុងកាលមុនថាអញនឹងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលកំពុងពោលថាអញកំពុងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គល ដែលពោលហើយថាអញពោលពាក្យកុហកហើយ ១ មុសាវាទ រមែងមានដោយអាការៈ ៣ នេះ ។ មួយទៀត មុសាវាទរមែងមានដោយអាការៈ ៤ ដោយអាការៈ ៥ ដោយអាការៈ ៦ ដោយអាការៈ ៧ ដោយអាការៈ ៨ មុសាវាទរបស់បុគ្គលនោះក្នុងកាលមុនថាអញនឹងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គលដែលកំពុងពោលថាអញកំពុងពោលពាក្យកុហក ១ មុសាវាទរបស់បុគ្គល ដែលពោល

ហើយថាអញពោលពាក្យកុហកហើយ ១ ( មុសាវាទរបស់បុគ្គល ) ព្រោះបិទបាំងសេចក្តីយល់ ១ ព្រោះបិទបាំងសេចក្តីចូលចិត្ត ១ ព្រោះបិទបាំងសេចក្តីគាប់ចិត្ត ១ ព្រោះបិទបាំងសេចក្តីសម្គាល់ ១ ព្រោះបិទបាំងការកើត ១ មុសាវាទរមែងមានដោយអាការៈ ៨ នេះ ។ ពាក្យថា បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក បានសេចក្តីថា គប្បីវៀរចាកការពោលពាក្យកុហក គប្បីលះបង់បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមានបែបភាព នូវការពោលពាក្យកុហក គប្បីជាអ្នកថ្វាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការពោលពាក្យកុហក គប្បីនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក ។

[ ៧៤ ] អធិប្បាយពាក្យថា គប្បីជាអ្នកដឹងខ្លួនមិនធ្វើនូវការពោលពាក្យអួតទាំងឡាយ សំណួរថា ភាពនៃការពោលអួត តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នកពោលអួត ពោលអួតគ្រប់យ៉ាង បានខាងការពោលអួត ភាពនៃការពោលអួត សេចក្តីពោលអួត សម្តីគ្រោតគ្រាត សម្តីគគ្រើម ការអួតខ្លាំង សេចក្តីអួតខ្លាំង ក្នុងដំណើរនោះនេះលោកហៅថា ភាពនៃការអួត ។ ពាក្យថា គប្បីជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ បានសេចក្តីថា ជាអ្នកដឹងខ្លួន មិនគប្បីធ្វើ មិនគប្បីបង្កើត មិនគប្បីបង្កើតព្រម មិនគប្បីបញ្ចេញ មិនគប្បីបញ្ចេញចំពោះនូវការពោលអួត គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាននូវការពោលអួត គប្បីជាអ្នកថ្វាយ វៀរ វៀរស្រឡះ ឃ្លាត

ចេញ វលាស់ចោល រួចស្រឡះ ប្រាសចេញចាកការពោលអួត គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីជាអ្នកដឹងខ្លួនមិនធ្វើនូវការពោលអួតទាំងឡាយ ។

[ ៧៥ ] អធិប្បាយពាក្យថា ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្ត ត្រង់ពាក្យថា ទាំង គឺជាពាក្យតំណនៃបទ ។បេ។ ពាក្យថា ទាំងនេះ គឺជាលំដាប់លំដោយនៃបទ ។ បុគ្គលខ្លះក្នុងលោកនេះកាលចិញ្ចឹមជីវិតដ៏សៅហ្មង មើលងាយបុគ្គលដទៃដែលចិញ្ចឹមជីវិតដ៏ឧត្តមថា បុគ្គលនេះចិញ្ចឹមជីវិតដោយវត្ថុច្រើនអ្វីម៉្លេះ បរិភោគវត្ថុគ្រប់មុខ គឺពូជដែលកើតអំពីមើម ពូជដែលកើតអំពីដើម ពូជដែលកើតអំពីថ្នាំង ពូជដែលកើតអំពីត្រួយ ពូជដែលកើតអំពីគ្រាប់ ជាគម្រប់ ៥ មិនធ្វើសេចក្តីព្យាយាមដ៏ស្មើដោយកាំទ្រនិងចុងនៃក្តក ។ ព្រោះការចិញ្ចឹមជីវិតដ៏សៅហ្មងនោះ បុគ្គលនោះមើលងាយបុគ្គលដទៃដែលចិញ្ចឹមជីវិតដ៏ឧត្តម បុគ្គលខ្លះក្នុងលោកនេះ ចិញ្ចឹមជីវិតដ៏ឧត្តម មើលងាយបុគ្គលដទៃដែលចិញ្ចឹមជីវិតដ៏សៅហ្មងថា បុគ្គលនេះមានបុណ្យតិច មានស័ក្តិតិចអ្វីម៉្លេះ មិនធ្លាប់បាននូវចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ ព្រោះការចិញ្ចឹមជីវិត ដ៏ឧត្តមនោះ បុគ្គលនោះមើលងាយបុគ្គលដទៃដែលចិញ្ចឹមជីវិតដ៏សៅហ្មង ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកបរិបូរដោយបញ្ញា បុគ្គលនោះត្រូវគេសួរហើយក៏ឆ្លើយប្រស្នា ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អញជាអ្នកបរិបូរដោយបញ្ញា ឯពួកបុគ្គលឯទៀតនេះមិនបរិបូរដោយបញ្ញាទេ ។ ព្រោះការបរិបូរដោយ

បញ្ញានោះ បុគ្គលនោះមើលងាយបុគ្គលដទៃ ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នកបរិបូរដោយសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូរដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អញជាអ្នកបរិបូរដោយសីល ឯពួកភិក្ខុឯទៀតនេះទ្រុស្តសីល មានធម៌អាក្រក់ ។ ព្រោះការបរិបូរដោយសីលនោះ បុគ្គលនោះមើលងាយបុគ្គលដទៃ ។ បុគ្គលខ្លះក្នុងសាសនានេះបរិបូរដោយវត្ត គឺជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប្រព្រឹត្តបំសុកូលិកធុតង្គ ប្រព្រឹត្តតេចីវរិកធុតង្គ ប្រព្រឹត្តសបទានចារិកធុតង្គ ប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ ប្រព្រឹត្តនេសជ្ជិកធុតង្គ ប្រព្រឹត្តយថាសន្ថតិកធុតង្គ ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អញជាអ្នកបរិបូរដោយវត្ត ឯពួកភិក្ខុឯទៀតនេះ មិនបរិបូរដោយវត្តទេ ។ ព្រោះការបរិបូរដោយវត្តនោះ បុគ្គលនោះមើលងាយបុគ្គលដទៃ ។ ពាក្យថា ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្ត បានសេចក្តីថា មិនគប្បីមើលងាយ មិនគប្បីបន្អាប់បុគ្គលដទៃ ដោយការចិញ្ចឹមជីវិតដ៏សៅហ្មង ដោយការចិញ្ចឹមជីវិតដ៏ឧត្តម ដោយការបរិបូរដោយបញ្ញា ដោយការបរិបូរដោយសីល ដោយការបរិបូរដោយវត្ត មិនគប្បីបង្កើតមានះដោយហេតុនោះ មិនគប្បីជាអ្នករឹងរូស រឹងត្អឹង មានក្បាលងើបឡើងដោយហេតុនោះឡើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្ត ។ ហេតុនោះ

ព្រះមានព្រះភាគត្រាស់ថា

បុគ្គលគប្បីវៀរចាកការពោលពាក្យកុហក គប្បីជាអ្នកដឹងខ្លួន មិនធ្វើនូវការពោលអួតទាំងឡាយ ទាំងមិនគប្បីមើលងាយនូវបុគ្គលដទៃដោយការចិញ្ចឹមជីវិត ដោយបញ្ញា ដោយសីលនិងវត្តឡើយ ។

[ ៧៦ ] បុគ្គលត្រូវគេប្រទូស្តហើយ បើឮនូវសំដីច្រើនរបស់សមណៈទាំងឡាយ ឬរបស់ជនមានមាត់ពាក្យច្រើនទាំងឡាយហើយ មិនត្រូវពោលតបនឹងជនទាំងនោះដោយពាក្យអាក្រក់ទេ ព្រោះថាជនជាអ្នកស្ងប់ រមែងមិនធ្វើនូវសត្រូវតបឡើយ ។

[ ៧៧ ] អធិប្បាយពាក្យថា បុគ្គលត្រូវគេប្រទូស្តហើយ បើឮនូវសម្តីច្រើនរបស់សមណៈទាំងឡាយ ឬរបស់ជនមានមាត់ពាក្យច្រើនទាំងឡាយហើយ ត្រង់ពាក្យថា ត្រូវគេប្រទូស្តហើយ គឺត្រូវគេប្រទូស្ត ជេរ កោសរូស ប្រទេចតិះដៀល បន្តុះបង្អាប់ហើយ ។ ពាក្យថា របស់សមណៈទាំងឡាយ គឺពួកជនណាមួយក្រៅអំពីសាសនានេះ នៅក្នុងពួកបរិព្វាជក ប្រកបក្នុងពួកបរិព្វាជក ។ ពាក្យថា របស់ជនមានមាត់ពាក្យច្រើនទាំងឡាយ គឺពួកក្សត្រិយ៍ផង ព្រាហ្មណ៍ផង វេស្សៈផង សុទ្ទៈផង គ្រហស្ថផង បព្វជិតផង ទេវតាផង មនុស្សផង ។ ពួកជននោះគប្បីជេរ គប្បីផ្តាសា គប្បីខឹង គប្បីខឹងខ្លាំង គប្បីបៀតបៀន គប្បីបៀតបៀនខ្លាំង គប្បីធ្វើទុក្ខបុកម្នេញ គប្បីធ្វើទុក្ខខ្លាំង គប្បីធ្វើនូវការបៀតបៀនដោយពាក្យដ៏ច្រើនដែលមិនជាទីប្រាថ្នា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត ។

បើឮ ស្តាប់ ចាប់បាន ចាំបាន កំណត់បាននូវសម្តីច្រើនរបស់ពួកជនទោះដែលមិនជាទីប្រាថ្នា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលត្រូវគេប្រទូស្តហើយ បើឮសម្តីច្រើនរបស់សមណៈទាំងឡាយ ឬរបស់ជនមានមាត់ពាក្យច្រើនទាំងឡាយ ។

[ ៧៨ ] អធិប្បាយពាក្យថា មិនត្រូវពោលតបនឹងជនទាំងនោះដោយពាក្យអាក្រក់ ត្រង់ពាក្យថា ដោយពាក្យអាក្រក់ គឺដោយពាក្យរឹងរូស ។ ពាក្យថា មិនត្រូវពោលតប សេចក្តីថា មិនគប្បីពោលតប គឺមិនគប្បីជេរតបនឹងជនដែលជេរ មិនគប្បីខឹងតបនឹងជនដែលខឹង មិនគប្បីប្រកួតតបនឹងជនដែលប្រកួត មិនគប្បីធ្វើជម្លោះ មិនគប្បីធ្វើសេចក្តីប្រកួត មិនគប្បីធ្វើនូវការទាស់ទែង មិនគប្បីធ្វើនូវវិវាទ មិនគប្បីធ្វើនូវសេចក្តីបែកខ្ញែកគ្នាទេ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាពនូវជម្លោះ ការប្រកួត សេចក្តីទាស់ទែង វិវាទ ការបែកខ្ញែកគ្នា គប្បីជាអ្នកឆ្ងាយ វៀរ វៀរស្រឡះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញ ចាកការជម្លោះ សេចក្តីប្រកួត ការទាស់ទែង វិវាទ ការបែកខ្ញែកគ្នា គប្បីនៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនត្រូវពោលតបនឹងជននោះដោយពាក្យអាក្រក់ទេ ។

[ ៧៩ ] ពាក្យថា ព្រោះថាជនអ្នកស្ងប់ រមែងមិនធ្វើសត្រូវតបឡើយ ត្រង់ពាក្យថា ជនអ្នកស្ងប់ គឺឈ្មោះថាអ្នកស្ងប់ ព្រោះស្ងប់រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ ។បេ។ ឈ្មោះថា អ្នកស្ងប់ អ្នកចូលទៅជិតស្ងប់ អ្នកស្ងប់វិសេស អ្នករលត់ អ្នករម្ងាប់ ព្រោះស្ងប់រម្ងាប់ រម្ងាប់វិសេស ផុត រំលត់

ឃ្លាតចេញ រម្ងាប់នូវអកុសលាភិសង្ខារទាំងអស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនអ្នកស្ងប់ ។ ពាក្យថា ព្រោះថាជនអ្នកស្ងប់ រមែងមិនធ្វើសត្រូវតបឡើយ បានសេចក្តីថា ជនអ្នកស្ងប់មិនធ្វើ មិនបង្កើត មិនបង្កើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះនូវសត្រូវតប នូវចំបាប់តប នូវចម្បូងតប នូវបដិប័ក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះថា ជនអ្នកស្ងប់មិនធ្វើនូវសត្រូវតបឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលត្រូវគេប្រទូស្តហើយ បើឮនូវសម្តីច្រើនរបស់សមណៈ
ទាំងឡាយ ឬរបស់ជនមានមាត់ពាក្យច្រើនទាំងឡាយហើយ
មិនត្រូវពោលតបនឹងជនទាំងនោះដោយពាក្យអាក្រក់ទេ ព្រោះ
ថា ជនអ្នកស្ងប់រមែងមិនធ្វើនូវសត្រូវតបឡើយ ។

[ ៨០ ] ភិក្ខុដឹងធម៌នេះហើយគប្បីពិនិត្យ មានស្មារតី សិក្សាសព្វកាល ដឹងនូវការរលត់ថា ជាការស្ងប់ហើយ មិនគប្បីប្រហែសក្នុងសាសនានៃព្រះគោតម ។

[ ៨១ ] អធិប្បាយពាក្យថា ដឹងធម៌នេះហើយ ត្រង់ពាក្យថា ធម៌នេះ គឺធម៌ដែលតថាគតប្រាប់ សំដែង បញ្ញត្ត តាំង បើក ចែក ធ្វើឲ្យរាក់ ប្រកាសហើយ ។ ពាក្យថា ដឹងធម៌ គឺដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងធម៌នេះ យ៉ាងនេះខ្លះ ។ម្យ៉ាងទៀត យល់ ដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដហើយនូវធម៌ដ៏ស្មើផង ធម៌មិនស្មើផង ធម៌ជាផ្លូវផង ធម៌មិនមែនជាផ្លូវផង ធម៌មានទោសផង ធម៌

មិនមានទោសផង ធម៌ថោកទាបផង ធម៌ខ្ពង់ខ្ពស់ផង ធម៌ខ្មៅផង ធម៌សផង ធម៌ដែលអ្នកចេះដឹងតិះដៀលផង ធម៌ដែលអ្នកចេះដឹងសរសើរផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងធម៌នេះ យ៉ាងនេះខ្វះ ។ ឬថាយល់ ដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដហើយនូវធម៌ គឺសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិប្បទា ធម្មានុធម្មប្បដិបទា ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវសេចក្ដីភ្ញាក់រឭក សតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ និព្វាននិងនិព្វានគាមិនីបដិបទា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងធម៌នេះយ៉ាងនេះខ្វះ ។

[ ៨២ ] អធិប្បាយពាក្យថា ភិក្ខុគប្បីពិនិត្យ មានស្មារតីសិក្សាសព្វកាល ត្រង់ពាក្យថា ពិនិត្យ គឺពិនិត្យ ពិចារណា ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងអស់មិនទៀង ។បេ។ ពិនិត្យ ពិចារណា ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថារបស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីពិនិត្យ ។ ពាក្យថា សព្វកាល គឺសព្វកាល សព្វគ្រាក្នុងកាលទាំងពួង ។បេ។ ក្នុងគំនរនៃវ័យជាបច្ឆិម ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺភិក្ខុចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ។បេ។ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា គប្បីសិក្សា បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា

អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។បេ។ នេះអធិប្បញ្ញាសិក្ខា ។ គប្បីនឹកសិក្សានូវសិក្ខាទាំង ៣ នេះ ។បេ។ គប្បីសិក្សា គប្បីប្រព្រឹត្ត គប្បីប្រព្រឹត្តស្មើ គប្បីប្រព្រឹត្តសមាទាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុគប្បីពិនិត្យ មានស្មារតីសិក្សាសព្វកាល ។

[ ៨៣ ] ពាក្យថា ដឹងនូវការរលត់ថាជាការស្ងប់ គឺដឹងនូវការរលត់រាគៈថាជាការស្ងប់ ដឹង ស្គាល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដនូវការរលត់ទោសៈ មោហៈ ។បេ។ អកុសលាភិសង្ខារទាំងអស់ថាជាការស្ងប់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដឹងនូវការរលត់ថាជាការស្ងប់ ។

[ ៨៤ ] ពាក្យថា មិនគប្បីប្រហែសក្នុងសាសនានៃព្រះគោតម គឺក្នុងសាសនារបស់ព្រះគោតម ក្នុងសាសនារបស់ព្រះពុទ្ធ ក្នុងសាសនារបស់ព្រះជិនស្រី ក្នុងសាសនារបស់ព្រះតថាគត ក្នុងសាសនារបស់ព្រះពុទ្ធជាទេវតា ក្នុងសាសនារបស់ព្រះអរហន្ត ។ ពាក្យថា មិនគប្បីប្រហែស គឺគប្បីជាអ្នកធ្វើដោយសេចក្តីគោរព ធ្វើមិនដាច់ ធ្វើមិនឈប់ មិនប្រព្រឹត្តរួញរា មិនដាក់ឆន្ទៈ មិនដាក់ធុរៈ មិនធ្វេសប្រហែស ក្នុងធម៌ជាកុសលទាំងឡាយថា កាលណាអញគប្បីញុំាងសីលក្ខន្ធដែលមិនទាន់ពេញលេញឲ្យពេញលេញបាន ។បេ។ ឬគប្បីញុំាងសមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញឲ្យពេញបាន ឬកាលណាអញគប្បីកំណត់ដឹងនូវទុក្ខដែលមិនទាន់កំណត់ដឹង ឬគប្បីលះបង់កិលេសទាំងឡាយដែលមិនទាន់លះបង់ ឬគប្បីចម្រើនមគ្គដែលមិនទាន់ចម្រើន ឬគប្បីធ្វើឲ្យជាក់ច្បាស់នូវនិរោធដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់

គឺបានដល់ឆន្ទៈ ការព្យាយាម ការឧស្សាហ៍ ការព្យាយាមដ៏មាំ កម្លាំងចិត្ត ការមិនត្រឡប់វិញ សតិនិងសម្បជញ្ញៈ ការព្យាយាមជាគ្រឿងដុតកំដៅកិលេស ការតម្កល់ព្យាយាម ការអធិដ្ឋាន ការប្រកបរឿយៗនិងការមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីប្រហែសក្នុងសាសនានៃព្រះគោតម ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុដឹងធម៌នេះហើយ គប្បីពិនិត្យ មានស្មារតី សិក្សាសព្វកាល
ដឹងនូវការរលត់ ថាជាការស្ងប់ហើយ មិនគប្បីប្រហែសក្នុង
សាសនានៃព្រះគោតម ។

[ ៨៥ ] ព្រះមានព្រះភាគត្រាស់ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់គ្របសង្កត់ ( នូវអារម្មណ៍ ) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយការជឿស្តាប់បុគ្គលដទៃ ព្រោះហេតុនោះបុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយៗសព្វកាលក្នុងសាសនានៃព្រះមានព្រះភាគនោះ ។

[ ៨៦ ] ពាក្យថា ព្រះមានព្រះភាគអង្គនោះ ទ្រង់គ្របសង្កត់ ( នូវអារម្មណ៍ ) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ គឺឈ្មោះថា ទ្រង់គ្របសង្កត់ ( អារម្មណ៍ ) ព្រោះទ្រង់គ្របសង្កត់រូប គ្របសង្កត់សំឡេង គ្របសង្កត់ក្លិន គ្របសង្កត់រស គ្របសង្កត់ផោដ្ឋព្វ គ្របសង្កត់ធម្មារម្មណ៍ ព្រះអង្គមិនត្រូវពួកកិលេសណាមួយ គ្របសង្កត់បានទេព្រោះថា ទ្រង់គ្របសង្កត់នូវអកុសលធម៌ទាំងឡាយដ៏លាមក ជាធម៌ប្រកបដោយសេចក្តីសៅហ្មង ប្រកបដោយភពថ្មី

ទៀត មានសេចក្តីក្រវល់ក្រវាយ មានសេចក្តីទុក្ខជាវិបាក ជាបច្ច័យនៃជាតិ ជរានិងមរណៈតទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះមានព្រះភាគនោះទ្រង់គ្របសង្កត់ ( នូវអារម្មណ៍ ) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ ។

[ ៨៧ ] ពាក្យថា បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយការជឿស្តាប់បុគ្គលដទៃ ត្រង់ពាក្យថា ធម៌ជាក់ច្បាស់ គឺបានឃើញ បានយល់ បានប្រទះ បានចាក់ធ្លុះនូវធម៌ដោយខ្លួនឯង ដែលត្រាស់ដឹងដោយខ្លួនឯង ជាក់ច្បាស់ចំពោះខ្លួន មិនមែនដោយជឿ ស្តាប់បុគ្គលដទៃ មិនមែនដោយឮថាដូច្នេះៗ មិនមែនតាមទំនៀម មិនមែនដោយការផ្ទេរផ្ទាំនឹងក្បួន មិនមែនដោយហេតុនៃការត្រិះរិះ មិនមែនដោយហេតុនៃការគ្នេរគ្នាន់ មិនមែនដោយកាជញ្ជឹងនូវអាការៈ មិនមែនដោយការយល់ ការពិនិត្យនិងការចូលចិត្តឡើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយការជឿ ស្តាប់បុគ្គលដទៃ ។

[ ៨៨ ] ពាក្យថា ព្រោះហេតុនោះ ក្នុងសាសនានៃព្រះមានព្រះភាគនោះ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុនោះ ព្រោះរឿងនោះ ព្រោះដើមចមនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។ ពាក្យថា ក្នុងសាសនានៃព្រះមានព្រះភាគនោះ គឺក្នុងសាសនារបស់ព្រះមានព្រះភាគ ក្នុងសាសនារបស់ព្រះគោតម ក្នុងសាសនារបស់ព្រះពុទ្ធ ក្នុងសាសនារបស់ព្រះជិនស្រី ក្នុងសាសនារបស់ព្រះតថាគត ក្នុងសាសនារបស់ព្រះពុទ្ធជាទេវតា ក្នុងសាសនារបស់ព្រះអរហន្តនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះហេតុនោះ ក្នុងសាសនានៃព្រះមានព្រះភាគនោះ ។

[ ៨៩ ] អធិប្បាយពាក្យថា ព្រះមានព្រះភាគត្រាស់ថា បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយៗ សព្វកាល ត្រង់ពាក្យថា គប្បីមិនប្រហែស គឺគប្បីជាអ្នកធ្វើដោយគោរព ។បេ។ មិនប្រហែសក្នុងកុសលទាំងឡាយ ។ ពាក្យថា សព្វកាល គឺសព្វកាល សព្វគ្រា ។បេ។ ក្នុងគំនរនៃវ័យជាបច្ឆិម ។ ពាក្យថា ថ្វាយបង្គំ គឺថ្វាយបង្គំដោយកាយ ថ្វាយបង្គំដោយវាចា ថ្វាយបង្គំដោយចិត្ត ថ្វាយបង្គំដោយអនុលោមប្បដិបត្តិ ថ្វាយបង្គំ ធ្វើសក្ការៈ ធ្វើគោរពរាប់អាន បូជា កោតក្រែង ដោយធម្មានុធម្មប្បដិបត្តិ ។ ពាក្យថា គប្បីសិក្សារឿយៗ បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។បេ។ នេះអធិប្បញ្ញាសិក្ខា ។ គប្បីនឹកសិក្សាសិក្ខា ៣ នេះ ។បេ។ គប្បីធ្វើឲ្យជាក់ច្បាស់ សិក្សា ប្រព្រឹត្ត ប្រព្រឹត្តស្មើ ប្រព្រឹត្តសមាទានទូវនិរោធដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តថា មានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រះមានព្រះភាកត្រាស់ថា បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សារឿយៗសព្វកាល ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះមានព្រះភាគត្រាស់ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់គ្របសង្កត់ ( នូវអារម្មណ៍ ) ព្រះអង្គមិនមានអ្វីគ្របសង្កត់បានទេ<br>
បានឃើញធម៌ជាក់ច្បាស់ មិនមែនដោយជឿ ស្តាប់បុគ្គលដទៃ<br>
ព្រោះហេតុនោះ បុគ្គលគប្បីមិនប្រហែស ថ្វាយបង្គំ សិក្សា<br>
រឿយៗសព្វកាលក្នុងសាសនានៃព្រះមានព្រះភាគនោះ ។

**ចប់ តុវដកសុត្តនិទ្ទេសទី ១**

# អដ្ឋកថា

## តុវដកសុត្តនិទ្ទេសទី ១៤

គប្បីជ្រាបអត្ថក្នុងតុវដកសុត្តនិទ្ទេសទី ១៤ ដូចតទៅនេះថា

[ ១ ] បទថា **បុច្ឆាមិ តំ** នេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនោះដល់ទេវតាទាំងឡាយពួកខ្លះដែលមានចិត្តកើតឡើងថា ការបដិបត្តិដើម្បីសម្រេចអរហត្តដូចម្តេចហ្ន៎ ទើបទ្រង់ឲ្យព្រះពុទ្ធនិមិត្ត ត្រាស់សួរព្រះអង្គដោយន័យមុននោះឯង ហើយត្រាស់តបក្នុងមហាសម័យនោះឯង ។

គប្បីជ្រាបអត្ថក្នុងគាថា ដែលជាសំណួរនោះមុន ។ លោកចែកពាក្យសួរដោយអំណាចអទិដ្ឋជោតនាបុច្ឆាជាដើម ទុកក្នុងបទនេះថា **បុច្ឆាមិ** ដូច្នេះ ។ បទថា **អាទិច្ចពន្ធុ** បានដល់ ជាផៅពង្សនៃព្រះអាទិត្យ ។ បទថា **វិវេកំ សន្តិបទញ្ច** បានដល់ ជាអ្នកស្ងាត់ផង ជាអ្នកប្រព្រឹត្តទៅកាន់ការស្ងប់ផង ។ បទថា **កថំ ទិស្វា** បានដល់ ភិក្ខុឃើញដូចម្តេច លោកអធិប្បាយថា ជាអ្នកមានការឃើញ ប្រព្រឹត្តទៅហើយដូចម្តេច ។

[ ២ ] បទថា **តិស្សោ បុច្ឆា** ជាការកំណត់ចំនួន ។

ពាក្យសួរដើម្បីធ្វើវត្ថុដែលមិនទាន់ឃើញ មិនចាក់ធ្លុះឲ្យប្រាកដ ឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។ ពាក្យសួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយដោយញាណចក្ខុ ឈ្មោះថា **ទិដ្ឋសំសន្ទនាបុច្ឆា** ។ ពាក្យសួរដើម្បីកាត់សេចក្តីសង្ស័យ ឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** ។ បទថា **បកតិយា លក្ខណំ អញ្ញាតំ** បានដល់ លក្ខណៈដែលពិតនៃធម៌ទាំងឡាយដែលមិនទាន់ដឹងដោយប្រក្រតី ។ បទ

ថា **អទិដ្ឋំ** បានដល់ ជាវត្ថុដែលមិនទាន់ឃើញហើយ ។ បាឋថា **ន ទិដ្ឋំ** ដូច្នេះក៏មាន ។ បទថា **អតុលិតំ** បានដល់ មិនប្រៀបធៀបមើល ដូចធៀបដោយជញ្ជីង ។

បទថា **អតីរិតំ** បានដល់ មិនពិចារណាដោយការត្រិះរិះ ។ បទថា **អវិភូតំ** បានដល់ មិនប្រាកដ ។ បទថា **អវិភាវិតំ** បានដល់ មិនចម្រើនដោយបញ្ញា ។ បទថា **តស្ស ញាណាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការដឹងនូវលក្ខណៈរបស់ធម៌នោះ ។ បទថា **ទស្សនាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការឃើញ ។

បទថា **តុលនាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការប្រៀបធៀប ។ បទថា **តីរណាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការពិចារណា ។ បទថា **វិភាវនាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យភ្លឺច្បាស់ ។ បទថា **អញ្ញេហិ បណ្ឌិតេហិ** បានដល់ ដោយបុគ្គលដល់ព្រមដោយការដឹងពួកដទៃ ។ បទថា **សំសយ បក្ខន្តា** បានដល់ ចូលទៅកាន់ភាពសន្ទិះ ។ បទថា **មនុស្សបុច្ឆា** បានដល់ ពាក្យសួររបស់មនុស្សទាំងឡាយ ។ បទថា **អមនុស្សបុច្ឆា** បានដល់ ពាក្យសួររបស់អមនុស្ស មាននាគនិងគ្រុឌជាដើម ។ បទថា **គហដ្ឋា** បានដល់ គ្រហស្ថដ៏សេស ។

បទថា **បព្វជិតា** លោកពោលដោយភេទ ។ បទថា **នាគា** បានដល់ នាគមាន **សុដស្សនាគ** ជាដើម ។ បទថា **សុបណ្ណា** គប្បីជ្រាបដោយគេស្គាល់ទូទៅថាជាគ្រុឌ ។ បទថា **យក្ខា** គប្បីជ្រាបដោយ គេស្គាល់ទូទៅថាជាយក្ខ ។ បទថា **អសុរា** បានដល់ អសុរទាំងឡាយ មានបហារាទអសុរជាដើម ។ បទ

ថា **គន្ធព្វា** បានដល់ ពួកគន្ធព្វ មានកូនគន្ធព្វ ឈ្មោះបញ្ចសិខៈជាដើម ។ បទថា **មហារាជានោ** បានដល់ មហារាជទាំង ៤ ។ បទថា **អហីនិន្ទ្រិយំ** បានដល់ មានឥន្ទ្រិយមិនខ្វះខាត ដោយអំណាចនៃសណ្ឋាន ។ បទថា **សោ និម្មិតោ** បានដល់ ព្រះពុទ្ធនោះ ដែលព្រះមានព្រះភាគទ្រង់និម្មិត ។ បទថា **ប៉ាធានត្ថបុច្ឆា** បានដល់ សួរធម៌ដែលវិសេស ។ បទថា **អតីតបុច្ឆា** បានដល់ ការសួរប្រារព្ធធម៌ដែលជាអតីត ។ សូម្បីក្នុងធម៌ដែលជាអនាគតជាដើម ក៏មានន័យនេះដូចគ្នា ។

បទថា **កុសលបុច្ឆា** បានដល់ ការសួរធម៌ដែលមិនមានទោស ។ បទថា **អកុសលបុច្ឆា** បានដល់ ការសួរធម៌ដែលមានទោស ។ បទថា **អព្យាកតបុច្ឆា** បានដល់ ការសួរដល់ធម៌ដែលផ្សេងអំពីធម៌ទាំង ២ នោះ ។

បទថា **អជ្ឈេសាមិ តំ** បានដល់ ខ្ញុំសូមអង្វរព្រះអង្គ ។ បទថា **កថយស្សុ មេ** បានដល់ សូមទ្រង់ត្រាស់ប្រាប់នូវធម៌នោះដល់ខ្ញុំ ។ បទថា **គោត្តញាតកោ** បានដល់ ជាញាតិដោយគោត្ត ។ បទថា **គោត្តពន្ធុ** បានដល់ ជាមនុស្សខាងក្នុងគោត្ត ។

[ ៣ ] បទថា **ឯកេនាការេន** បានដល់ ដោយចំណែកមួយ ។ បទថា **សន្តិបទំ** បានដល់ និព្វានបទ ពោលគឺសន្តិ ។ បទថា **យេ ធម្មា សន្តាធិគមាយ** បានដល់ ធម៌ពួកណាមានសតិប្បដ្ឋានជាដើម ប្រព្រឹត្តទៅដើម្បីបាននូវព្រះនិព្វាន ។ បទថា **សន្តិផុសនាយ** បានដល់ ដើម្បីពាល់ត្រូវ នូវនិព្វាន ដោយការពាល់ត្រូវ គឺញាណ ។ បទថា **សច្ឆិកិរិយាយ** បានដល់ ដើម្បីធ្វើ

ឲ្យប្រេចក្ស ។

បទថា **មហាន្តំ សីលក្ខន្ធំ** បានដល់ គំនរសីលធំ ។ សូម្បីក្នុងសមាធិក្ខន្ធជាដើមក៏មានន័យនេះដូចគ្នា ។ សីលក្ខន្ធជាដើមជាលោកិយផង លោកុត្តរផង ។ វិមុត្តិញ្ញាណទស្សនៈ ជាលោកិយតែម្យ៉ាង ។ បទថា **តមោកាយស្ស បទាលនំ** បានដល់ ការកម្ចាត់គំនរអវិជ្ជា ។ បទថា **វិបល្លាសស្ស ភេទនំ** បានដល់ ការទម្លាយវិបល្លាស ៤ យ៉ាង ។ បទថា **តណ្ហាសល្លស្ស អព្ពុហនំ** បានដល់ ដកនូវព្រួញ គឺតណ្ហា ។ បទថា **អភិសង្ខារស្ស វូបសមំ** បានដល់ ការរំលត់អភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ។ បទថា **ភារស្ស និក្ខេបនំ** បានដល់ ដាក់នូវភារៈ គឺបញ្ចក្ខន្ធ ។ បទថា **សំសារវដ្ដស្ស ឧបច្ឆេទំ** បានដល់ កាត់នូវការប្រព្រឹត្តទៅនៃសង្សារវដ្ដ ។ បទថា **សន្តាបស្ស និព្វាបនំ** បានដល់ រំលត់នូវការក្ដៅ គឺកិលេស ។ បទថា **បរិឡាហស្ស បដិប្បស្សទ្ធិំ** បានដល់ ស្ងប់នូវការក្ដៅក្រហាយ គឺកិលេស ។ បទថា **ទេវទេវោ** បានដល់ ព្រះពុទ្ធជាទេវតាក្រៃលែងជាងទេវតាទាំងឡាយ ។

[ ៦ ] លំដាប់នោះព្រះមានព្រះភាគព្រោះកាលទ្រង់ឃើញទើបទ្រង់កម្ចាត់នូវកិលេសទាំងឡាយបានដោយប្រការណា កាលទ្រង់ឃើញ ដោយប្រការនោះហើយ ទ្រង់ឃើញការប្រព្រឹត្តទៅយ៉ាងនោះទើបទ្រង់រំលត់ដោយឥតសេសសល់ ( នូវកិលេស ) ហេតុនោះកាលទ្រង់ធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ ទើបទ្រង់ដឹកនាំទេវបរិស័ទនោះ ក្នុងការលះកិលេសដោយប្រការផ្សេងៗ ទ្រង់ផ្ដើមត្រាស់គាថា ៥ មានពាក្យថា **ម្លំ បបញ្ចសង្ខាយ** ដូច្នេះជាដើម ។

ក្នុងគាថាទាំងនោះ គប្បីជ្រាបដោយសង្ខេបនៃគាថាដើម ជាមុនសិន ។ បទថា **បបញ្ច** ក្នុងបទថា **បបញ្ចសង្ខា** បានដល់ តណ្ហាដែលរាប់ថាជាគ្រឿងយឺតយូរ ។ គ្រឿងយឺតយូរនោះឯង ឈ្មោះថា **បបញ្ចសង្ខា** ។ កិលេសទាំងឡាយ មានអវិជ្ជាជាដើមជាឫសគល់ នៃបបញ្ចសង្ខានោះ ។ ភិក្ខុគប្បីកម្ចាត់កិលេសទាំងពួងដែលប្រព្រឹត្តទៅ គឺកិលេសដែលជាឫសគល់នៃចំណែករបស់ធម៌ ជាគ្រឿងយឺតយូរនិងអស្មិមានះដោយបញ្ញា ។ ឯតណ្ហាដែលមានខាងក្នុងណាមួយគប្បីកើតឡើង ។ ភិក្ខុគប្បីជាអ្នកមានសតិសិក្សា គឺគប្បីជាអ្នកមានសតិតាំងមាំសិក្សាក្នុងកាលសព្វកាលដើម្បីកំចាត់ គឺដើម្បីលះតណ្ហាទាំងនោះ ។

[ ៨ ] បទថា **អជ្ឈត្តសមុដ្ឋានា វា** បានដល់ តណ្ហាកើតឡើងក្នុងចិត្ត ។

[ ៩ ] បទថា **បុរេភត្តំ** បានដល់ មុនអាហារពេលថ្ងៃ ។ បទថា **បុរេភត្តំ** ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ ប្រែថា អស់កាលមុនភត្ត ។ តែដោយអត្ថជាសត្តមីវិភត្តិ ប្រែថា ក្នុងកាលមុនភត្ត ។ ក្នុងកាលក្រោយភត្តជាដើមក៏ន័យនេះដូចគ្នា ។ បទថា **បច្ឆាភត្តំ** បានដល់ ក្រោយអាហារពេលថ្ងៃ ។ បទថា **បុរិមយាមំ** បានដល់ ចំណែកដំបូងនៃរាត្រី ។ បទថា **មជ្ឈិមយាមំ** បានដល់ ចំណែកទី ២ នៃរាត្រី ។ បទថា **បច្ឆិមយាមំ** បានដល់ ចំណែកទី ៣ នៃរាត្រី ។ បទថា **កាឡេ** បានដល់ ខាងរនោច ។ បទថា **ជុណ្ហេ** បានដល់ ខាងខ្នើត ។ បទថា **វស្សេ** បានដល់ ក្នុងរដូវវស្សា ៤ ខែ ។ បទថា **ហេមន្តេ** បានដល់ ក្នុងរដូវរងា ៤ ខែ ។ បទថា **គិម្ហេ** បានដល់ ក្នុងរដូវប្រាំង ៤ ខែ ។ បទថា **បុរិមេ វយោខន្ធេ** បានដល់ ក្នុងចំណែករបស់វ័យ

*ដំបូង បានដល់ ក្នុងបឋមវ័យ ។ ក្នុងវ័យ ៣ នោះ សម្រាប់បុគ្គលមានអាយុ ១០០ ឆ្នាំជាកំណត់ ក្នុងវ័យនីមួយៗមាន ៣៣ ឆ្នាំ ៤ ខែ ។*

*[ ១០ ] ព្រះមានព្រះភាគកាលទ្រង់សម្តែងទេសនាប្រកបដោយត្រៃសិក្ខា ក្នុងគាថាដំបូងយ៉ាងនេះដោយធម៌ដ៏កំពូល គឺអរហត្តហើយ ដើម្បីទ្រង់សម្តែងដោយការលះនូវការប្រកាន់ខ្លួនទៀត ទើបត្រាស់គាថាថា* **យន្តិញ្ចិ** *ដូច្នេះជាដើម ។*

*ក្នុងគាថានោះ បទថា* **យន្តិញ្ចិ ធម្មមភិជញ្ញា អជ្ឈត្តំ** *បានដល់ គប្បីដឹងគុណធម៌របស់ខ្លួន មានភាពជាអ្នកមានត្រកូលខ្ពស់ជាដើមឯណានីមួយ ។ បទថា* **អថវាបិ ពហិទ្ធា** *បានដល់ គប្បីដឹងគុណរបស់អាចារ្យនិងឧបជ្ឈាយ៍ខាងក្រៅ ។ បទថា* **ន តេន ថាមំ កុព្វេថ** *បានដល់ មិនគប្បីធ្វើមានះដោយគុណធម៌នោះ ។*

*[ ១៣ ] បទថា* **សតានំ** *បានដល់ អ្នកមានគុណធម៌ គឺសេចក្តីស្ងប់ ។ បទថា* **សន្តានំ** *បានដល់ ជាអ្នករំលត់មានះបានហើយ ។ បទថា* **ន វុត្តា** *បានដល់ មិនប្រាប់ ។ បទថា* **នប្បវុត្តា** *បានដល់ មិនដោះស្រាយ ។*

*[ ១៤ ] ឥឡូវនេះព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់វិធីមិនធ្វើការប្រកាន់ខ្លួន ទើបត្រាស់គាថាថា* **សេយ្យោ ន តេន** *ដូច្នេះជាដើម ។ បទនោះមានសេចក្តីដូចតទៅនេះថា ភិក្ខុមិនគប្បីសម្គាល់ថា អាត្មាអញល្អជាងគេ អាត្មាអញអន់ជាងគេ ឬអាត្មាអញស្មើគេដោយមានះនោះ ភិក្ខុដល់ព្រមដោយគុណធម៌ជាច្រើន មានភាពជាអ្នកមានត្រកូលខ្ពស់ជាដើមនោះ មិនគប្បី*

*កំណត់ខ្លួន តាំងនៅដោយន័យជាដើមថា អញបួសហើយចាកត្រកូលខ្ពស់ ។*

*[ ១៩ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយការលះមានះយ៉ាងនេះ ឥឡូវនេះដើម្បីទ្រង់សម្តែងដោយការស្ងប់កិលេសទាំងពួង ទើបត្រាស់គាថាថា* **អជ្ឈត្តមេវ** *ដូច្នេះជាដើម ។*

*ក្នុងគាថានោះ បទថា* **អជ្ឈត្តមេវ ឧបសមេ** *បានដល់ គប្បីស្ងប់កិលេសទាំងអស់ មានរាគៈជាដើមក្នុងខ្លួននោះឯង ។ បទថា* **ន អញ្ញតោ ភិក្ខុ សន្តិមេសេយ្យ** *បានដល់ មិនគប្បីស្វែងរកសេចក្តីស្ងប់ដោយឧបាយដទៃក្រៅអំពីសតិប្បដ្ឋានជាដើម ។ បទថា* **កុតោ និរត្តា វា** *សេចក្តីថា ការមិនមានខ្លួន រមែងមិនមានអំពីទីណាឡើយ ។*

*[ ២១ ] បទថា* **ន ឃសេយ្យ** *បានដល់ មិនគប្បីស្វែងរកដោយសីលនិងវត្តជាដើម ។ បទថា* **ន គវេសេយ្យ** *បានដល់ មិនគប្បីសម្លឹងមើល ។ បទថា* **ន បរិយេសេយ្យ** *បានដល់ មិនគប្បីឃើញរឿយៗ ។*

*[ ២៤ ] ឥឡូវនេះព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពជាតាទិបុគ្គលរបស់ព្រះខីណាស្រព ដែលជាអ្នកស្ងប់ហើយក្នុងខាងក្នុង ទើបត្រាស់គាថាថា* **មជ្ឈេ យថា** *ដូច្នេះជាដើម ។*

*បទនោះមានសេចក្តីដូច្នេះថា រលករមែងកើតត្រង់កណ្តាលប្រមាណ ៤ ពាន់យោជន៍ គឺនៅចន្លោះកណ្តាលចំណែកខាងលើនិងចំណែកខាងក្រោមនៃមហាសមុទ្ទ ឬក្នុងកណ្តាលសមុទ្ទដែលតាំងនៅក្នុងចន្លោះភ្នំ ( សមុទ្ទសីទន្តរ ) សមុទ្ទនោះស្ងប់មិនញាប់ញ័រយ៉ាងណា ភិក្ខុដែលជាព្រះខីណាស្រព គប្បីជា*

អ្នកឈប់ មិនមានការញាប់ញ័រ ក្នុងលាភជាដើមក៏យ៉ាងនោះ ភិក្ខុបែបនោះ មិនគប្បីធ្វើកិលេសជាគ្រឿងខ្ពស់ឡើង មានរាគៈជាដើមក្នុងទីណាមួយឡើយ ។

[ ២៥ ] បទថា **ឧព្ភេធេន** បានដល់ ដោយចំណែកខាងក្រោម ។ បទថា **គម្ភីរោ** បានដល់ មហាសមុទ្ទជម្រៅប្រមាណ ៨៤០០០ យោជន៍ រាប់អំពីខាងលើទឹកចុះទៅក្រោម ។ បាឋៈថា **ឧព្ភេធោ** ដូច្នេះក៏មាន ។ បាឋៈនោះមិនល្អ ។ បទថា **ហេដ្ឋា** បានដល់ ទឹកខាងក្នុង ។ បទថា **ឧបរិ** បានដល់ ទឹកខាងលើ ។ បទថា **មជ្ឈេ** បានដល់ រវាងកណ្តាល ។ បទថា **ឆ កម្បតិ** បានដល់ មិនញាប់ញ័រចាកទីតាំង ។ បទថា **ឆ វិកម្បតិ** បានដល់ មិនកួចទៅកួចមក ។ បទថា **ឆ ចលតិ** បានដល់ នឹង ។ បទថា **ឆ វេធតិ** បានដល់ មិនរញ្ជួយ ។ បទថា **ឆ បវេធតិ** បានដល់ មិនបោកទៅបោកមក ។ បទថា **ឆ សម្បវេធតិ** បានដល់ មិនវិលទៅមក ។ បទថា **អនេរិតោ** បានដល់ ជាសមុទ្ទមិនញាប់ញ័រ ។ បទថា **អឃដ្ដិតោ** បានដល់ មិនកម្រើក ។ បទថា **អចលិតោ** បានដល់ មិនរំជើបរំជួល ។ បទថា **អលុឡិតោ** បានដល់ មិនត្រូវបៀតបៀនឲ្យល្អក់ ។ បទថា **តត្រ ឩមិ នោ ជាយតិ** បានដល់ រលកមិនកើតក្នុងទីនោះ ។ បទថា **សត្តន្នំ បព្វតានំ អន្តរិកាសុ** បានដល់ សមុទ្ទសីទន្តរមានក្នុងចន្លោះភ្នំទាំង ៧ មានភ្នំយុគន្ធរជាដើម ។ បទថា **សីទន្តរា** បានដល់ ឈ្មោះថាសីទា ព្រោះដោយហោចសូម្បីសំឡីធ្លាក់ទៅក្នុងសមុទ្ទនោះក៏លិច ។ បទថា **អន្តរា** បានដល់ ឈ្មោះថា អន្តរៈ ព្រោះកើតក្នុងចន្លោះភ្នំ ។ បាឋៈថា **អន្តរសីទា** ក៏មាន ។

[ ២៥ ] ឥឡូវនេះព្រះពុទ្ធនិមិត្តកាលទ្រង់អនុមោទនាព្រះធម្មទេសនាដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយធម៌ជាកំពូល គឺព្រះអរហត្តឲ្យក្រៃលែង កាលត្រាស់សួរបដិបទាខាងដើមរបស់ព្រះអរហត្តនោះ ទើបត្រាស់ព្រះគាថាថា **អកិត្តយិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អកិត្តយិ** បានដល់ ត្រាស់ប្រាប់ ។ បទថា **វិវដចក្ខុ** បានដល់ ប្រកបដោយចក្ខុ ៥ ភ្លឺថ្លាមិនមានគ្រឿងរាំង ។ បទថា **សក្ខិធម្មំ** បានដល់ នូវធម៌ដែលប្រចក្សដល់ព្រះអង្គដែលទ្រង់បានដឹងក្រៃលែងដោយព្រះអង្គឯងហើយដើម្បីប្រកាស ។

បទថា **បរិស្សយវិនយំ** បានដល់ ដើម្បីកម្ចាត់អន្តរាយ ។ បទថា **បដិបទំ វទេហិ** បានដល់ សូមទ្រង់ត្រាស់ប្រាប់បដិបទា ក្នុងឥឡូវនេះចុះ ។ បទថា **ភទ្ទន្តេ** សេចក្តីថា ព្រះពុទ្ធនិមិត្ត ទ្រង់ហៅព្រះមានព្រះភាគថា សូមសេចក្តីចម្រើនមានដល់ទ្រង់ចុះ ។ ម្យ៉ាងទៀតលោកអធិប្បាយថា សូមទ្រង់ឆ្លើយនូវបដិបទាដែលចម្រើនល្អដល់ខ្ញុំចុះ ។ បទថា **ចាតិមោក្ខំ អថវាបិ សមាធឹ** បានដល់ ព្រះពុទ្ធនិមិត្តត្រាស់សួរញែកបដិបទានោះឯង ។ ត្រាស់សួរមគ្គដោយបទថា **បដិបទំ** ។ ត្រាស់សួរសីលនិងសមាធិ ដោយបទក្រៅអំពីនេះ ។

[ ២៩ ] បទថា **មំសចក្ខុនាបិ** បានដល់ ដោយមំសចក្ខុដែលប្រព្រឹត្តទៅដោយចំណែក ប្រកបរបស់ភ្នែក ។ បទថា **ទិព្វចក្ខុនាបិ** បានដល់ ចក្ខុឈ្មោះថា **ទិព្វ** ព្រោះដូចគ្នានឹងរបស់ទិព្វ ។ ពិតហើយទេវតាទាំងឡាយ មានបសាទចក្ខុជាទិព្វដែលកើតឡើងព្រោះសុចរិតកម្ម មិនលាយឡំដោយប្រមាត់

ស្នេស្នេទិនឈាមជាដើម អាចទទួលអារម្មណ៍ក្នុងទីឆ្ងាយបាន ព្រោះផុតចាក វត្ថុសៅហ្មង ។ ញាណចក្ខុនេះដែលកើតដោយកម្លាំងនៃការបំពេញព្យាយាម ក៏ដូចគ្នានោះឯង ព្រោះហេតុនោះទើបឈ្មោះថា **ទិព្វ** ព្រោះដូចគ្នានឹងរបស់ទិព្វ ឈ្មោះថា **ទិព្វ** ព្រោះបានមកដោយអំណាចទិព្វវិហារធម៌និងព្រោះខ្លួនអាស្រ័យ ទិព្វវិហារធម៌ខ្លះ ឈ្មោះថា **ទិព្វ** ព្រោះរុងរឿងច្រើនដោយកំណត់អាលោកសញ្ញា ខ្លះ ឈ្មោះថា **ទិព្វ** ព្រោះមានគតិធំដោយការឃើញរូបដែលនៅខាងក្រៅកំពែង ជាដើមខ្លះ ទាំងអស់នោះគប្បីជ្រាបតាមគន្លងនៃសព្ទសាស្ត្រ ។ ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ឃើញ ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ដូចចក្ខុ ព្រោះធ្វើកិច្ចនៃចក្ខុ ខ្លះ ឈ្មោះថា ទិព្វចក្ខុ ព្រោះជាទិព្វផង ជាចក្ខុផង ។ ព្រះមានព្រះភាគមាន ចក្ខុក្លឺថ្លាដោយទិព្វចក្ខុនោះ ។

ឥឡូវនេះព្រះសារីបុត្តត្ថេរ ដើម្បីពោលចក្ខុ ៥ យ៉ាង ដោយពិស្តារទើប ពោលពាក្យថា **កថំ ភគវា មំសចក្ខុនា វិវដចក្ខុ** ដូច្នេះជាដើម ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **មំសចក្ខុម្ហិ ភគវតោ បញ្ច វណ្ណា សំ-វិជ្ជន្តិ** បានដល់ ពណ៌ ៥ ក្នុងចក្ខុដែលប្រព្រឹត្តទៅដោយចំណែក ប្រកបរបស់ ភ្នែក រមែងរកបានចំពោះព្រះមានព្រះភាគសម្ពុទ្ធ ។ បទថា **នីលោ ច វណ្ណោ** បានដល់ ពណ៌ផ្កាត្រកៀត ។ បទថា **បីតកោ ច វណ្ណោ** បានដល់ ពណ៌ ផ្កាកណិការ ។ បទថា **លោហិតកោ ច វណ្ណោ** បានដល់ ពណ៌ដូចអណ្តើក មាស ។ បទថា **កណ្ហោ ច វណ្ណោ** បានដល់ ពណ៌ដូចផ្កាអញ្ចន ។ បទថា **ឱទាតោ ច វណ្ណោ** បានដល់ មានពណ៌ដូចផ្កាយព្រឹក ។ បទថា **យត្ថ ច**

**អក្ខិលោមានិ បតិដ្ឋិតានិ** បានដល់ រោមព្រះនេត្រទាំងឡាយ ដុះឡើងក្នុងទីណា ។ បទថា **នីលំ** ក្នុងបទថា **តំ នីលំ ហោតិ សុនីលំ** លោកពោលដោយសរុប ។ បទថា **សុនីលំ** បានដល់ ខៀវស្លុទ្ធៗមិនមានពណ៌ដទៃ ។ បទថា **ទស្សនិកំ** បានដល់ ឲ្យកើតភាពគួរសរសើរ ។ បទថា **ទស្សនេយ្យំ** បានដល់ គួរមើល ។ បទថា **ឧមាបុប្ផសមានំ** បានដល់ ដូចគ្នានឹងផ្កាចង្កុលណី ។ បទថា **តស្ស បរតោ** បានដល់ ខាងក្រៅដោយជុំវិញរោមព្រះនេត្រនោះ ។ បទថា **បីតកំ** លោកពោលដោយសរុប ។ បទថា **សុបីតកំ** បានដល់ លឿងស្លុទ្ធៗមិនមានពណ៌ដទៃ ។ បទថា **ឧភយតោ ច អក្ខិកូដានិ** បានដល់ ខាងចុងព្រះនេត្រទាំងសងខាង ។ បទថា **លោហិតកានិ** លោកពោលដោយសរុប ។ បទថា **សុលោហិតកានិ** បានដល់ ក្រហមស្លុទ្ធៗមិនប្រាកដឱកាស ។ បទថា **មជ្ឈេ កណ្ហំ** សេចក្តីថា ខ្មៅដូចគ្នានឹងផ្កាអញ្ចនតាំងនៅកណ្តាលព្រះនេត្រ ។ បទថា **សុកណ្ហំ** បានដល់ ខ្មៅស្លុទ្ធៗមិនមានពណ៌ដទៃ ។ បទថា **អលូខំ** បានដល់ មានសិរី ។ បទថា **សិនិទ្ធំ** បានដល់ ប្រណីត ។ បទថា **ភទ្ទារិដ្ឋកសមានំ** បានដល់ ដូចគ្នានឹងផ្លែសម៉ខ្មៅ ដែលយកសម្បកចេញហើយ ។ បាលីថា **អទ្ទារិដ្ឋកសមានំ** ដូច្នេះក៏មាន អធិប្បាយសេចក្តីបាលីនោះថា ដូចគ្នានឹងក្អែកដែលមានខ្លួនសើម ។ បទថា **ឱទាតំ** លោកពោលដោយសរុប ។ បទថា **សុឱទាតំ** បានដល់ សស្លុទ្ធៗដូចគ្នានឹងមណ្ឌលនៃប្រាក់មិនមានពណ៌ដទៃ ។ លោកសម្តែងភាពជាពណ៌សក្រៃលែងដោយបទ ២ ថា **សេតំ បណ្ឌរំ** ។ បទថា **ទាកតិកេន មំសចក្ខុនា** បានដល់ មំសចក្ខុជាប្រក្រតី ។

បទថា **អត្តភាវបរិយាបន្នេន** បានដល់ អាស្រ័យនៅក្នុងអត្តភាព ។ បទថា **បុរិមសុចរិតកម្មាភិនិព្វត្តេន** បានដល់ កើតឡើងព្រោះកម្មមានកាយសុចរិតជាដើម ក្នុងអត្តភាពដែលកើតហើយនោះៗ ក្នុងភពមុន ។ បទថា **សមន្តា យោជនំ បស្សតិ** បានដល់ ទ្រង់ឃើញរូបដែលនៅខាងក្នុងជញ្ជាំងជាដើមក្នុងទីមួយយោជន៍ គឺប្រមាណ ៤ គាវុតដោយជុំវិញ វៀរចាកគ្រឿងរាំងដោយមំសចក្ខុប្រក្រតី ។ បទថា **ទិវា ចេវ រត្តឹ** បានដល់ ទាំងពេលថ្ងៃ ទាំងពេលយប់ ។ បទថា **ចតុរង្គសមន្នាគតោ** បានដល់ សេចក្តីងងឹតប្រកបដោយអង្គ ៤ វៀរចាកពន្លឺ ។ បទថា **សុរិយោ ច អត្ថង្គមិតោ** បានដល់ ព្រះអាទិត្យដែលកំពុងបញ្ចេញពន្លឺលិចទៅ ។ បទថា **កាឡបក្ខោ ច ឧបោសថោ** បានដល់ ក្នុងថ្ងៃឧបោសថខាងរនោច ១៤ រោច ។ បទថា **តិព្វោ ច វនសណ្ឌោ** បានដល់ ដូរព្រៃដែលក្រាស់ ។ បទថា **មហា ច អកាលមេឃោ អព្ភុដ្ឋិតោ** បានដល់ ផ្ទៃពពកខ្មៅធំតាំងឡើង ។ បទថា **កុដ្ដោ វា** បានដល់ ជញ្ជាំងកដោយឥដ្ឋ ។ បទថា **កវាដំ វា** បានដល់ សន្ទះទ្វារសន្ទះបង្អួចក្តី ។ បទថា **បាការោ វា** បានដល់ កំពែងដីឥដ្ឋជាដើមក្តី ។ បទថា **បព្វតោ វា** បានដល់ ភ្នំមានភ្នំដីជាដើមក្តី ។ បទថា **គច្ឆំ វា** បានដល់ គុម្ពឈើខ្ចីក្តី ។ បទថា **លតា វា** បានដល់ វល្លិប្រេងជាដើមក្តី ។ បទថា **អាវរណំ រូបានំ ទស្សនាយ** បានដល់ ជាគ្រឿងរាំងនូវការឃើញរូបារម្មណ៍ទាំងឡាយ ។ បទថា **ឯកញ្ចេ តិលផលំ និមិត្តំ កត្វា** បានដល់ យកគ្រាប់ល្ងមួយធ្វើជាសញ្ញា ។ បទថា **តិលវាហេ បក្ខិបេយ្យ** បានដល់ ដាក់ក្នុងគំនរល្ងក្នុងរទេះ ។ តែ

អាចារ្យពួកខ្លះពោលថា ២ រទេះ ១ កុម្ភៈឈ្មោះថា **វាហា** ។ បទថា **តញ្ចោវ តិលផលំ ឧទ្ធរេយ្យ** បានដល់ ទ្រង់ចាប់យកគ្រាប់ល្ងដែលធ្វើគ្រឿងសម្គាល់នោះយកមកបាន ។

បទថា **ទិព្វេន ចក្ខុនា** នេះបានពោលអធិប្បាយទុកហើយ ។ បទថា **វិសុទ្ធេន** សេចក្ដីថា ឈ្មោះថា **វិសុទ្ធ** ព្រោះហេតុនៃសេចក្ដីបរិសុទ្ធនៃទិដ្ឋិដោយការឃើញចុតិនិងបដិសន្ធិ ។ ពិតហើយ បុគ្គលណាឃើញត្រឹមតែចុតិមិនឃើញបដិសន្ធិ បុគ្គលនោះរមែងកាន់យកនូវឧច្ឆេទទិដ្ឋិ ។ បុគ្គលណាឃើញបដិសន្ធិតែម្យ៉ាងមិនឃើញចុតិ បុគ្គលនោះរមែងកាន់យកនូវសស្សតទិដ្ឋិព្រោះប្រាកដសត្វកើតថ្មី ។ ឯបុគ្គលណាឃើញទាំង ២ យ៉ាងនោះព្រោះបុគ្គលនោះឈានកន្លងទិដ្ឋិ ២ យ៉ាងនោះ ដូច្នោះទើបការឃើញរបស់បុគ្គលនោះ ជាហេតុនៃទិដ្ឋិវិសុទ្ធិ ។ ឯពុទ្ធបុត្តទាំងឡាយរមែងឃើញទាំង ២ យ៉ាងនោះ ដោយហេតុនោះទើបលោកពោលថា ឈ្មោះថាបរិសុទ្ធិ ព្រោះជាហេតុនៃការបរិសុទ្ធនៃទិដ្ឋិ ។ ឈ្មោះថា កន្លងផុតចក្ខុជារបស់មនុស្ស ព្រោះឃើញរូបកន្លងព្រំដែនរបស់មនុស្ស ។ម្យ៉ាងទៀតគប្បីជ្រាបថា ឈ្មោះថាកន្លងផុតចក្ខុជារបស់មនុស្សព្រោះកន្លងនូវមំសចក្ខុដែលជារបស់មនុស្ស ។ បទថា **អតិក្កន្តមានុសកេន សត្តេ បស្សតិ** បានដល់ ទ្រង់សម្លឹងមើលពួកសត្វដូចមនុស្សទាំងឡាយមើលដោយភ្នែកសាច់ដូច្នោះ ។ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សនោះ ។ ក្នុងបទថា **ចវមានេ ឧបបជ្ជមានេ** នេះគប្បីជ្រាបសេចក្ដីដូច្នេះថា ក្នុងខណៈចុតិក្ដី ខណៈបដិសន្ធិក្ដី មិនអាចឃើញបានដោយទិព្វចក្ខុ ។ សត្វពួកណាជិតនឹងចុតិ នឹងចុតិក្នុងកាលឥឡូវនេះ សត្វទាំងនោះលោកបំណងយកថា ឈ្មោះ

*ថាកំពុងចុតិ ។ ឯសត្វពួកណាបដិសន្ធិទើបនឹងកើត សត្វទាំងនោះលោកបំណង យកថាកំពុងបដិសន្ធិ ។ លោកសម្ដែងទុកថា ព្រះមានព្រះភាគទ្រង់ឃើញសត្វ ទាំងនោះដែលកំពុងចុតិនិងកំពុងបដិសន្ធិ ។ បទថា* **ហីនេ** *បានដល់ ថោកទាប ព្រោះប្រកបដោយផលដែលកើតអំពីមោហៈ ។ បទថា* **បណីតេ** *ផ្ទុយគ្នានឹង* **ហីនេ** *នោះ ។ បទថា* **សុវណ្ណេ** *បានដល់ មានពណ៌សម្បុរគួរប្រាថ្នា គួរ ស្រឡាញ់ គួរពេញចិត្តព្រោះប្រកបដោយផលដែលកើតអំពីអទោសៈ ។ បទ ថា* **ទុព្វណ្ណេ** *ផ្ទុយគ្នានឹង* **សុវណ្ណេ** *នោះ គឺមានរូបស្អាតនិងរូបមិនស្អាត ។ បទថា* **សុគតេ** *បានដល់ កើតក្នុងទីដែលល្អឬស្ដុកស្ដម្ភមានទ្រព្យច្រើនព្រោះ ប្រកបដោយផលដែលកើតអំពីអលោភៈ ។ បទថា* **ទុគ្គតេ** *បានដល់ កើត ក្នុងទីដែលអាក្រក់ឬក្រីក្រ មានបាយនិងទឹកតិច ព្រោះប្រកបដោយផលដែល កើតអំពីលោភៈ ។ បទថា* **យថាកម្មូបគេ** *បានដល់ ចូលដល់កម្មដែលខ្លួន សន្សំទុក ។*

*ក្នុងបទទាំងនោះ លោកពោលដល់កិច្ចរបស់ទិព្វចក្ខុ ដោយបទជាដើមថា* **ចវមានេ** *ដែលមានក្នុងបទមុន ។ តែដោយបទនេះលោកពោលដល់កិច្ចគឺការ ដឹងពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ។*

*លំដាប់នៃការកើតឡើងនៃញាណនោះ មានដូចតទៅនេះថា ភិក្ខុក្នុងធម្ម- វិន័យនេះចម្រើនអាលោកសញ្ញា មានមុខឆ្ពោះទៅកាន់នរកខាងក្រោម ឃើញ ពួកសត្វនរកកំពុងសោយមហាទុក្ខ ។ ការឃើញនោះជាកិច្ចរបស់ទិព្វចក្ខុនោះ ឯង ។ ភិក្ខុនោះធ្វើទុកក្នុងចិត្តយ៉ាងនេះថា សត្វទាំងនេះធ្វើនូវកម្មអ្វីហ្ន៎ទើបសោយ*

ទុក្ខនេះដូច្នេះ ។ លំដាប់នោះញាណដែលមានកម្មនោះជាអារម្មណ៍ ក៏កើតឡើង ដល់ភិក្ខុនោះថាព្រោះធ្វើកម្មយ៉ាងនេះ ។ម្យ៉ាងទៀតភិក្ខុចម្រើនអាលោកសញ្ញា មានមុខឆ្ពោះទៅកាន់ទេវលោកខាងលើ ឃើញពួកសត្វ ក្នុងនន្ទនវនឧទ្យាន មិស្សកវននិងបារុសកវនជាដើម សោយនូវមហាសម្បត្តិ។ ការឃើញបែបនោះ ជាកិច្ចរបស់ទិព្វចក្ខុនោះឯង ។ ភិក្ខុនោះធ្វើទុកក្នុងចិត្តយ៉ាងនេះថា សត្វទាំងនេះ ធ្វើកម្មអ្វីហ្ន៎ ទើបសោយនូវសម្បត្តិនេះដូច្នេះ ។ លំដាប់នោះញាណដែលមាន កម្មនោះជាអារម្មណ៍ក៏កើតឡើងដល់ភិក្ខុនោះថា ព្រោះធ្វើកម្មយ៉ាងនេះ ។ នេះ ឈ្មោះថា **យថាកម្មូបគញ្ញាណ** ។ ញាណនេះមិនមានបរិកម្មដោយឡែក ឡើយ ។ ញាណនេះយ៉ាងណា សូម្បីអនាគតំសញ្ញាណក៏យ៉ាងនោះ ញាណ ទាំងនេះមានទិព្វចក្ខុជាបាទ រមែងសម្រេចព្រមនឹងទិព្វចក្ខុនោះឯង ។ បទថា **ឥមេ** ក្នុងបទជាដើមថា **ឥមេ វត ភោន្តោ** ជាពាក្យសម្តែងដល់ការឃើញ ដោយទិព្វចក្ខុ ។ បទថា **វត** ជានិបាត ចុះក្នុងអត្ថថា សោយសោក ។ បទ ថា **ភោន្តោ** គឺ **ភវន្តោ** ( បុគ្គលចម្រើន ) ឈ្មោះថា **ទុច្ចរិត** ព្រោះអត្ថថា ប្រព្រឹត្តអាក្រក់ ឬប្រព្រឹត្តប្រទូស្ត ព្រោះមានចិត្តស្អុយដោយកិលេស ។ ឈ្មោះ ថា **កាយទុច្ចរិត** ព្រោះអត្ថថា ប្រព្រឹត្តអាក្រក់ផ្លូវកាយឬប្រព្រឹត្តអាក្រក់កើត អំពីកាយ ។ ក្នុងបទក្រៅអំពីនេះក៏មានន័យនេះដូចគ្នា ។ បទថា **សមន្នាគតា** បានដល់ ជាអ្នកដល់ព្រម ។

បទថា **អរិយានំ ឧបវាទកា** បានដល់ ជាអ្នកបំណាងភាពមិនមែនជា ប្រយោជន៍ ចំពោះព្រះអរិយៈដែលជាព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះ

សាវកពុទ្ធ ដោយហោចសូម្បីព្រះសោតាបន្នដែលជាគ្រហស្ថ ហើយពោលតិះដៀលដោយអន្តិមវត្ថុឬដោយកម្ចាត់គុណ លោកអធិប្បាយថា ជាអ្នកជេរ ជាអ្នកតិះដៀល ។ បណ្តា ២ យ៉ាងនោះគប្បីជ្រាបថា កាលពោលថា ភិក្ខុទាំងនេះមិនមានសមណធម៌ ភិក្ខុទាំងនេះមិនមែនសមណៈ ឈ្មោះថា ពោលតិះដៀលដោយអន្តិមវត្ថុ ។ កាលពោលថា ភិក្ខុទាំងនេះមិនមានឈាន មិនមានវិមោក្ខ មិនមានមគ្គ មិនមានផលដូច្នេះ ឈ្មោះថាតិះដៀលដោយកម្ចាត់គុណ ។ម្យ៉ាងទៀតបុគ្គលនោះគប្បីពោលដោយដឹងក្តី មិនដឹងក្តី សូម្បីទាំង ២ យ៉ាងក៏ឈ្មោះថាតិះដៀលព្រះអរិយៈដូចគ្នា ។ កម្មនោះជាកម្មធ្ងន់ហាក់ដូចអនន្តរិយ-កម្ម ហាមទាំងសួគ៌ ហាមទាំងមគ្គតែនៅកែបាន ព្រោះហេតុនោះបុគ្គលណាតិះដៀលព្រះអរិយៈ បុគ្គលនោះគួរទៅ បើខ្លួនជាធំជាងគួរអង្គុយប្រហោងហើយពោលខមាទោសថា ខ្ញុំបានពោលពាក្យនេះៗនឹងលោក សូមលោកអត់ទោសឲ្យដល់ខ្ញុំផងចុះដូច្នេះតែបើខ្លួនខ្ចីជាងគប្បីថ្វាយបង្គំហើយអង្គុយប្រហោងផ្គងអញ្ជលី ហើយពោលសូមខមាទោសថា ខ្ញុំបានពោលពាក្យនេះៗនឹងលោក សូមលោកអត់ទោសឲ្យដល់ខ្ញុំផងចុះដូច្នេះ ។ បើលោកមិនអត់ទោសឲ្យ ចៀសចេញទៅកាន់ទីដទៃ គួរទៅឯង ឬបញ្ជូនសទ្ធិវិហារិកជាដើមទៅឲ្យលោកអត់ទោសឲ្យ បើមិនអាចទៅបានឬមិនអាចបញ្ជូនទៅបាន ក៏ទៅរកភិក្ខុដែលនៅក្នុងវិហារនោះ បើភិក្ខុទាំងនោះខ្ចីជាងគប្បីអង្គុយប្រហោង បើចាស់ជាងគួរបដិបត្តិតាមន័យដែលពោលហើយក្នុងភិក្ខុដែលជាធំនោះឯង ហើយពោលសូមខមា-ទោសថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំបានពោលពាក្យនេះៗនឹងលោកម្ចាស់ឈ្មោះ

នោះ សូមលោកម្ចាស់ឈ្មោះនោះអត់ទោសឲ្យដល់ខ្ញុំផងចុះដូច្នេះ ។ កាលមិនសូមខមាទោសចំពោះមុខ ក៏គួរធ្វើវត្តនេះនោះឯង ។ បើលោកជាភិក្ខុត្រាច់ទៅម្នាក់ឯង ទីលំនៅ ទីទៅរបស់លោកមិនប្រាកដ គប្បីទៅរកភិក្ខុឈ្លាសមួយរូបហើយពោលថា លោកដ៏ចម្រើន ខ្ញុំបានពោលពាក្យនេះៗ នឹងលោកម្ចាស់ឈ្មោះនោះ កាលខ្ញុំនឹកដល់ពាក្យនោះក៏មានសេចក្តីក្តៅក្រហាយ ខ្ញុំធ្វើដូចម្តេចល្អ ។ ភិក្ខុអ្នកឈ្លាសរូបនោះក៏នឹងពោលថា លោកកុំគិតច្រើនថ្វីឡើយ ព្រះថេរៈរមែងអត់ទោសឲ្យដល់លោក សូមលោកស្ងប់ចិត្តចុះ ខ្លួនឯងគប្បីផ្គងអញ្ជលីតម្រង់ទៅកាន់ទិស ដែលព្រះអរិយៈនោះទៅហើយពោលថា សូមលោកម្ចាស់អត់ទោសឲ្យចុះដូច្នេះ ។ បើព្រះអរិយៈនោះបរិនិព្វានទៅហើយ គួរទៅកាន់ទីតម្កល់គ្រែដែលលោកបរិនិព្វាន ( ឬ ) ទៅកាន់ឈាបនដ្ឋានហើយសូមខមាទោស ។ កាលធ្វើយ៉ាងនេះហើយទើបជាការមិនហាមសួគ៌ មិនហាមមគ្គ រមែងជាប្រក្រតីដូចមុននោះឯង ។

បទថា **មិច្ឆាទិដ្ឋិកា** បានដល់ មានការយល់ឃើញវិបរិត ។ បទថា **មិច្ឆាទិដ្ឋិកម្មសមាទានា** បានដល់ បុគ្គលណាដឹកនាំអ្នកដទៃក្នុងកាយកម្មជាដើមដែលជាមូលនៃមិច្ឆាទិដ្ឋិ បុគ្គលនោះឈ្មោះថាជាអ្នកកាន់យកនូវការធ្វើផ្សេងៗច្រើនយ៉ាង ដោយអំណាចមិច្ឆាទិដ្ឋិ ។ម្យ៉ាងទៀតក្នុងសេចក្តីនេះ កាលការតិះដៀលព្រះអរិយៈ សង្គ្រោះហើយដោយការកាន់យកថា ជាវចីទុច្ចរិតនិងដោយកាលមិច្ឆាទិដ្ឋិ សង្គ្រោះហើយដោយការកាន់យកថាជាមនោទុច្ចរិត ពាក្យ២នេះដែលពោលដដែលទៀត គប្បីជ្រាបថា ដើម្បីសម្តែងការមានទោសច្រើន ។

*ព្រោះបុគ្គលតិះដៀលព្រះអរិយៈជាអ្នកមានទោសច្រើនហាក់ដូចអនន្តរិយកម្ម ។ សេចក្តីនេះព្រះមានព្រះភាគ ក៏បានត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលសារីបុត្ត ភិក្ខុបរិបូរណ៍ដោយសីលហើយ បរិបូរណ៍ដោយសមាធិហើយ បរិបូរណ៍ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯងយ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុ ( នៃការមិនលះបង់នូវវាចាជាដើមរបស់បុគ្គលនោះ ) ថា មានឧបមេយ្យប្រហែលគ្នាយ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេនឹងធ្លាក់ទៅ រងទុក្ខក្នុងនរកដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះឯង ។ មិនមានធម៌ដទៃដែលមានទោសច្រើន ជាងមិច្ឆាទិដ្ឋិឡើយ ដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃសូម្បីតែធម៌ ១ ដែលមានទោសធំយ៉ាងនេះដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយមានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង ។ បទថា* **កាយស្ស ភេទា** *បានដល់ លះបង់ឧបាទិន្នកខន្ធ ។ បទថា* **បរំ មរណា** *បានដល់ កាន់យកខន្ធដែលនឹងកើតបន្ទាប់អំពីខន្ធនោះ ។ម្យ៉ាងទៀតបទថា* **កាយស្ស ភេទា** *បានដល់ ការដាច់នៃជីវិតិន្ទ្រិយ ។ បទថា* **បរំ មរណា** *បានដល់ ខាងមុខអំពីចុតិចិត្ត ។ បទថា* **អបាយំ** *ជាដើម ជាវេវចនៈរបស់នរកទាំងអស់នោះឯង ។ ពិតហើយនរកឈ្មោះថា អបាយ ព្រោះប្រាសចាកសេចក្តីចម្រើនដែលសន្មតជាបុណ្យដែលជាហេតុនៃស្ថានសួគ៌និងនិព្វាន ឬព្រោះមិនមានសេចក្តីចម្រើន*

នៃសេចក្តីសុខទាំងឡាយ ។ នរកឈ្មោះថា ទុគ្គតិ ព្រោះជាទីនៅអាស្រ័យរបស់ទុក្ខ ។ មា្យ៉ាងទៀតនរកឈ្មោះថា ទុគ្គតិ ព្រោះជាទីទៅដែលកើតដោយកម្មអាក្រក់ ច្រើនទៅដោយទោស ។ នរកឈ្មោះថា វិនិបាត ព្រោះជាទីដែលសត្វអ្នកធ្វើកម្មអាក្រក់ ប្រាសចាកអំណាច ឬឈ្មោះថា វិនិបាត ព្រោះជាទីដែលអវយវៈតូចធំវិនាសទៅ ។ ឈ្មោះថា នរក ព្រោះជាទីមិនមានសេចក្តីចម្រើនដែលសន្មតថា ជាការពេញចិត្ត ។ មា្យ៉ាងទៀតលោកសម្តែងកំណើតតិរច្ឆានដោយអបាយសព្ទ ។ ពិតហើយកំណើតតិរច្ឆានឈ្មោះថា អបាយ ព្រោះប្រាសចាកសុគតិ ( តែ ) មិនឈ្មោះថា ទុគ្គតិ ព្រោះអាចជាទីកើតនៃនាគរាជជាដើមដែលមានសក្តិធំ ។ លោកសម្តែងបិត្តិវិស័យ ដោយទុគ្គតិសព្ទ ។ ពិតហើយបិត្តិវិស័យឈ្មោះថា អបាយនិងទុគ្គតិ ព្រោះប្រាសចាកសុគតិនិងព្រោះជាគតិរបស់ទុក្ខតែមិនឈ្មោះថា វិនិបាត ព្រោះមិនធ្លាក់ទៅដូចអសុរកាយ ។ លោកសម្តែងអសុរកាយដោយ **វិនិបាត** សព្ទ ។ ពិតហើយអសុរកាយនោះលោកហៅថា អបាយនិងទុគ្គតិ តាមដែលពោលទុកហើយនិងលោកហៅថា វិនិបាត ព្រោះធ្លាក់ទៅទាំងរាងកាយ ។ លោកសម្តែងនរកមានច្រើនយ៉ាង មានអវីចិជាដើមដោយ **និរយ** សព្ទ ។ បទថា **ឧបបន្នា** បានដល់ ចូលទៅដល់ហើយអធិប្បាយថា កើតឡើងក្នុងទីនោះ ។ គប្បីជ្រាបធម៌ចំណែកសដោយផ្ទុយគ្នាតាមដែលពោលហើយ ។ តែការផ្សេងគ្នាមានដូចតទៅនេះថា ក្នុងបទនោះសូម្បីមនុស្សគតិលោក ក៏សង្គ្រោះដោយ **សុគតិ** សព្ទ ។ ទេវគតិប៉ុណ្ណោះ លោកសង្គ្រោះដោយ **សគ្គ** សព្ទ ។ បណ្តាបទទាំងនោះឈ្មោះថា សុគតិ ព្រោះជា

*គតិល្អ ។ ឈ្មោះថា សគ្គៈ ព្រោះប្រសើរទៅដោយអារម្មណ៍ មានរូបជាដើម ។ ទាំងអស់នោះឈ្មោះថា **លោក** ព្រោះអត្ថថា បែកធ្លាយ ។ នេះជាអធិប្បាយនៃពាក្យដោយប្រការដូច្នេះ ។ បទទាំងពួងថា **ឥតិ ធិញ្ញ ន ចក្ខុនា** ជាដើមជាពាក្យសរុប ។ សេចក្ដីសង្ខេបក្នុងបទនេះថា ព្រះមានព្រះភាគ ទ្រង់ឃើញដោយទិព្វចក្ខុ ដោយប្រការដូច្នេះឯង ។ ទិព្វចក្ខុញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ ដោយអំណាចនៃបរិត្តារម្មណ៍ បច្ចុប្បន្នារម្មណ៍ អជ្ឈត្តារម្មណ៍និងពហិទ្ធារម្មណ៍ ។ យថាកម្មូបគញ្ញាណរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អតីតារម្មណ៍ អជ្ឈត្តារម្មណ៍និងពហិទ្ធារម្មណ៍ ។ អនាគតំសញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណារម្មណ៍ មគ្គារម្មណ៍ អនាគតារម្មណ៍ អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍ និងនវត្តព្វារម្មណ៍ ។*

*បទថា **អាកង្ខមានោ ច ភគវា** បានដល់ ព្រះមានព្រះភាគទ្រង់ប្រាថ្នា ។ បទថា **ឯកម្បិ លោកធាតុំ បស្សេយ្យ** បានដល់ ទ្រង់ឃើញចក្កវាឡមួយ ។ ក្នុងបទថា **សហស្សិម្បិ ចូឡនិកំ** គប្បីជ្រាបដូចតទៅនេះថា លោកធាតុឈ្មោះថាមួយពាន់ ជាចំណែកតូចក្នុងអនាគតដ្ឋាន ( មជ្ឈិមនិកាយមូលបណ្ណាសក ) ថា*

> *ព្រះអង្គត្រាស់ថា ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយឲ្យភ្លឺបានត្រឹមណា លោក គឺចក្កវាឡទាំងមួយពាន់ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នក ប្រព្រឹត្តទៅបាន*

តែត្រឹមចក្កវាឡមួយពាន់ទុំះ ។

បទថា **ចូឡនិកំ** បានដល់ តូច ។ ក្នុងបទថា **ទ្វិសហស្សិម្បិ មជ្ឈិមិកំ លោកធាតុំ** គប្បីជ្រាបសេចក្ដីដូចតទៅនេះថា មួយពាន់ចក្កវាឡ គុណនឹងមួយពាន់រួមជាប្រមាណចក្កវាឡមួយលាន ឈ្មោះថា ទ្វិសហស្សីលោកធាតុជាចំណែកកណ្ដាល ។ ដោយលោកធាតុប្រមាណប៉ុណ្ណោះលោកសម្ដែងដល់ជាតិខេត្តរបស់ព្រះពុទ្ធទាំងឡាយ ។ ពិតហើយទីប្រមាណប៉ុណ្ណោះរមែងញាប់ញ័រក្នុងថ្ងៃដែលព្រះពោធិសត្វទាំងឡាយ ចុតិចាកទេវលោក ក្នុងភពចុងក្រោយហើយបដិសន្ធិក្នុងផ្ទៃរបស់មាតា ក្នុងថ្ងៃប្រសូតចាកផ្ទៃ ក្នុងថ្ងៃយាងចេញបួសក្នុងថ្ងៃត្រាស់ដឹង ក្នុងថ្ងៃសម្ដែងធម្មចក្កប្បវត្តនសូត្រ ក្នុងថ្ងៃដាក់អាយុ-សង្ខារនិងក្នុងថ្ងៃបរិនិព្វាន ។ បទថា **តិសហស្សិម្បិ មហាសហស្សិម្បិ លោកធាតុំ** សេចក្ដីថា ឈ្មោះថា តិសហស្សីលោកធាតុព្រោះជាទី ៣ តាំងអំពីសហស្សី ( ទី១ ) ។ ឈ្មោះថា មហាសហស្សីលោកធាតុ ព្រោះអត្ថថាគុណដោយពាន់ចំនួនធំ ដោយគុណសហស្សីទី ១ មួយពាន់ដង ជាលោកធាតុថ្នាក់កណ្ដាល ហើយគុណលោកធាតុថ្នាក់កណ្ដាលមួយពាន់ដង រួមជាមហា-សហស្សីដោយព្រំដែនមានប្រមាណប៉ុណ្ណោះ លោកសម្ដែងដល់លោកធាតុមានប្រមាណមួយពាន់លាន ។ តែព្រះគណកបុត្តទិស្សត្ថេរ ពោលទុកយ៉ាងនេះថានោះមិនមែនប្រមាណរបស់តិសហស្សីមហាសហស្សីលោកធាតុ ព្រោះប្រមាណនេះជាការភ្លាំងភ្លាត់ក្នុងការស្វាធ្យាយ ជាការខុសគ្គងនៃវាចារបស់អាចារ្យទាំងឡាយ ពិតណាស់ទីមានប្រមាណមួយលានកោដិឈ្មោះថា តិសហស្សីមហា-

សហស្សី ។ ដោយព្រំដែនមានប្រមាណប៉ុណ្ណោះ ឈ្មោះថា លោកសម្តែងដល់អាណាខេត្តរបស់ព្រះមានព្រះភាគ ។ ពិតណាស់អានុភាពរបស់អាដានាដិយបរិត្ត ឥសិគិលិបរិត្ត ធជគ្គបរិត្ត ពោជ្ឈង្គបរិត្ត ខន្ធបរិត្ត មោរបរិត្ត មេត្តបរិត្ត និងរតនបរិត្តរមែងផ្សាយទៅក្នុងរវាងនេះ ។

បទថា **យាវតា វា បន អាកង្ខេយ្យ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ត្រូវការប៉ុនណា ។ ដោយបទនេះឈ្មោះថា លោកសម្តែងដល់វិសយខេត្ត ពិតណាស់ការកំណត់ប្រមាណនៃវិសយខេត្តរបស់ព្រះមានព្រះភាគទាំងឡាយ មិនមាន ។ ព្រះសង្គីតិកាចារ្យនាំឧបមាក្នុងការមិនមានវិសយខេត្តនេះមកដូចតទៅនេះថា

បើបុគ្គលណាមួយ យកគ្រាប់ស្ពៃមកដាក់ឲ្យពេញក្នុងមួយសែនកោដិចក្កវាឡកម្ពស់ដល់ព្រហ្មលោក ហើយយកគ្រាប់ស្ពៃមួយដាក់ក្នុងចក្កវាឡមួយក្នុងទិសខាងកើត គ្រាប់ស្ពៃទាំងនោះទោះបីអស់ទៅ ចំណែកនៃចក្កវាឡទាំងឡាយក្នុងទិសខាងកើតមិនទាន់អស់ឡើយ ។ ក្នុងទិសខាងត្បូងជាដើមក៏មានន័យដូចគ្នា ។ ឈ្មោះថា ការមិនមែនវិស័យរបស់ព្រះពុទ្ធទាំងឡាយ ក្នុងវិសយខេត្តនោះរមែងមិនមាន ។ បទថា **តាវតកំ បស្សេយ្យ** បានដល់ គប្បីទតបានត្រឹមនោះ ។ ទិព្វចក្ខុកថាក៏ចប់ហើយដោយបទថា ទិព្វចក្ខុរបស់ព្រះមានព្រះភាគបរិសុទ្ធិយ៉ាងនេះ ។

បទថា **កថំ ភគវា បញ្ញាចក្ខុនាបិ វិវដចក្ខុ** បានដល់ មានចក្ខុដោយបញ្ញាចក្ខុដែលរបស់ណាមួយមិនបិទបាំងហើយដោយប្រការណា ។

បទថា **មហាបញ្ញោ បុថុបញ្ញោ** រហូតដល់បទថា **តត្ថ អតិរោចតិ យថិទំ បញ្ញាយ** មានសេចក្តីបានពោលកន្លងមកហើយនោះឯង ។ បទថា **ពុទ្ធចក្ខុនា** បានដល់ ដោយឥន្ទ្រិយបរោបរិយត្តិញាណនិងអាសយានុសយញាណ ។ ឈ្មោះរបស់ញាណទាំង ២ នេះ ក៏គឺ **ពុទ្ធចក្ខុ** ។ ឈ្មោះរបស់សព្វញ្ញុតញ្ញាណក៏គឺ **សមន្តចក្ខុ** ។ ឈ្មោះរបស់មគ្គញ្ញាណ ៣ ក៏គឺ **ធម្មចក្ខុ** ។ បទថា **លោកំ វោលោកេន្តោ អទ្ទស សត្តេ** បានដល់ ទ្រង់បានឃើញសត្វទាំងឡាយ ។ គប្បីជ្រាបសេចក្តីក្នុងបទថា **អប្បរជក្ខេ** ជាដើមដូចតទៅនេះថា ធូលី មានរាគៈជាដើមក្នុងបញ្ញាចក្ខុដោយន័យដែលពោលហើយរបស់សត្វពួកណាមានតិច សត្វទាំងនោះឈ្មោះថា មានធូលីក្នុងភ្នែកតិច ។ ធូលី មានរាគៈជាដើម របស់សត្វទាំងនោះមានច្រើន សត្វទាំងនោះឈ្មោះថា មានធូលីច្រើនក្នុងភ្នែក ។ ឥន្ទ្រិយ មានសទ្ធាជាដើមរបស់សត្វពួកណាចាស់ក្លា សត្វទាំងនោះឈ្មោះថា មានឥន្ទ្រិយក្លៀវក្លា ។ ឥន្ទ្រិយទាំងនោះរបស់សត្វពួកណាទន់ សត្វទាំងនោះឈ្មោះថា មានឥន្ទ្រិយទន់ ។ អាការទាំងឡាយមានសទ្ធាជាដើមរបស់សត្វពួកណាល្អ សត្វទាំងនោះឈ្មោះថា មានអាការល្អ ។ សត្វពួកណាកំណត់ហេតុដែលពោលហើយ អាចដឹងបានដោយងាយ សត្វនោះឈ្មោះថា ឲ្យដឹងបានងាយ ។ សត្វពួកណាឃើញបរលោកនិងវជ្ជៈ ដោយភាពជាភ័យ សត្វទាំងនោះឈ្មោះថា ជាអ្នកឃើញទោសក្នុងបរលោក ជាគួរខ្លាច ។ បទថា **ឧប្បលិនិយំ** បានដល់ ក្នុងពួកឈូកខៀវ ។ សូម្បីបទក្រៅអំពីនេះក៏មានន័យដូចគ្នា ។ បទថា **អន្តោនិមុគ្គពោសិនី** បានដល់ ផ្កាឈូកពួកណាលិច

ក្នុងទឹកត្រូវទឹកចិញ្ចឹមទុក ។ បទថា **ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ** បានដល់ តាំងឡើងផុតទឹក ។ ក្នុងផ្កាឈូកទាំងនោះផ្កាឈូកណាផុសឡើងផុតទឹក ផ្កាឈូកនោះរង់ចាំពន្លឺព្រះអាទិត្យ ក៏នឹងរីកក្នុងថ្ងៃនេះ ។ ផ្កាឈូកណាតាំងនៅស្មើទឹក ផ្កាឈូកនោះនឹងរីកក្នុងថ្ងៃស្អែក ផ្កាឈូកណាមិនទាន់ផុតចាកទឹក លិចក្នុងទឹកត្រូវទឹកចិញ្ចឹមទុក ផ្កាឈូកនោះនឹងរីកក្នុងថ្ងៃទី ៣ នោះឯង ។ ម្យ៉ាងទៀតផ្កាឈូកដែលមិនទាន់ផុតទឹកពួកដទៃ ឈ្មោះថា ជាផ្កាឈូកមានរោគក៏មាន ផ្កាឈូកណានឹងមិនរីកក៏នឹងជាអាហាររបស់ត្រីនិងអណ្តើកប៉ុណ្ណោះ ផ្កាឈូកនោះលោកសម្តែងទុកថា មិនបានលើកឡើងកាន់បាលី តែគួរនាំមកសម្តែងទុក ។

លោកសម្តែងដល់បុគ្គល ៤ ពួក គឺឧគ្ឃដិតញ្ញូ វិបចិតញ្ញូ នេយ្យ បទបរម ដូចផ្កាឈូក ៤ ប្រភេទដូច្នោះ ។ បុគ្គលណាដឹងធម៌ក្នុងវេលាដែលលោកលើកមកពោល បុគ្គលនេះលោកហៅថា **ឧគ្ឃដិតញ្ញូ** ។

បុគ្គលណា កាលលោកពង្រីកដោយពិស្តារនៃភាសិត ដែលលើកឡើងពោលដោយសង្ខេប ទើបដឹងនូវធម៌ បុគ្គលនេះលោកហៅថា **វិបចិតញ្ញូ** ។

បុគ្គលណាទន្ទេញ សាកសួរ ដាក់ចិត្តដោយឧបាយ សេពគប់ អន្ទយជិតកល្យាណមិត្ត ទើបដឹងនូវធម៌ បុគ្គលនេះលោកហៅថា **នេយ្យ** ។

បុគ្គលណាសូម្បីស្តាប់ច្រើន ទន្ទេញពោលច្រើន ទ្រទ្រង់ទុកច្រើន ស្វាធ្យាយច្រើន ក៏មិនដឹងធម៌ក្នុងជាតិនោះ បុគ្គលនេះលោកហៅថា **បទបរម** ។

ក្នុងបុគ្គលទាំងនោះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលក្នុងលោកធាតុមួយម៉ឺន ដូចគ្នានឹងផ្កាឈូកជាដើម ទ្រង់បានឃើញដោយអាការទាំងពួងយ៉ាង

នេះថា ឧគ្ឃដិតញ្ញូនីងវីកក្នុងថ្ងៃនេះ វិបចិតញ្ញូនឹងរីកក្នុងថ្ងៃស្អែកនេះ ។ ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ នឹងសម្រេចប្រយោជន៍ក្នុងអត្តភាពនេះ ដល់បុគ្គល ៣ ពួកនិងបានជាវាសនាក្នុងអនាគត ដល់បុគ្គលដែលជាបទបរម ។

គប្បីជ្រាបអត្ថក្នុងបទថា **រាគចរិតោ** ជាដើម ដូចតទៅនេះថា ឈ្មោះថា **រាគចរិត** ព្រោះមានការប្រព្រឹត្តក្នុងអារម្មណ៍ដោយតម្រេក ។ ឈ្មោះថា **ទោសចរិត** ព្រោះមានការប្រព្រឹត្តក្នុងអារម្មណ៍ដោយការប្រទូស្ត ។ ឈ្មោះថា **មោហចរិត** ព្រោះមានការប្រព្រឹត្តក្នុងអារម្មណ៍ដោយការវង្វេង ។ ឈ្មោះថា **វិតក្កចរិត** ព្រោះមានការប្រព្រឹត្តក្នុងអារម្មណ៍ដោយវិតក្កដោយការត្រិះរិះ ។ ឈ្មោះថា **សទ្ធាចរិត** ព្រោះមានការប្រព្រឹត្តក្នុងអារម្មណ៍ដោយឱកប្បនសទ្ធា ។ ឈ្មោះថា **ញាណចរិត** ព្រោះមានការប្រព្រឹត្តជាការដឹង ប្រព្រឹត្តព្រមនឹងការដឹង ប្រព្រឹត្តព្រោះការដឹង ឬប្រព្រឹត្តដើម្បីការដឹង ។ បទថា **រាគចរិតស្ស** បានដល់ ដល់បុគ្គលដែលមានរាគៈក្រាស់ រាគៈខ្លាំង ។ សូម្បីបទដទៃក៏មានន័យដូចគ្នា ។

បទថា **អសុភកថំ កថេតិ** សេចក្តី ទ្រង់ត្រាស់កថាបដិសំយុត្ត ដោយអសុភ ១០ មានឧទ្ធុមាតកៈជាដើម ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយនវកនិបាត ) ថា ចម្រើនអសុភដើម្បីលះរាគៈ ដូច្នេះ ។ បទថា **មេត្តាភាវនំ អាចិក្ខតិ** បានដល់ ទ្រង់ត្រាស់នូវមេត្តាភាវនាដែលចាប់ចិត្ត ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយនវកនិបាត ) ថា ចម្រើនមេត្តាដើម្បីលះព្យាបាទ ដូច្នេះ ។

បទថា **ឧទ្ទេសេ** បានដល់ ក្នុងការស្វាធ្យាយ ។ បទថា **បរិបុច្ឆាយ** បានដល់ ក្នុងការពោលអត្ថ ។ បទថា **កាលេន ធម្មស្សវនេ** បានដល់ ក្នុងការស្តាប់បរិយត្តិធម៌ឲ្យក្រៃលែង ក្នុងកាលដែលសមគួរ ។ បទថា **ធម្មសាកច្ឆាយ** បានដល់ ក្នុងការសន្ទនាជាមួយនឹងអ្នកដទៃ ។ បទថា **គរុសំវាសេ** បានដល់ ក្នុងការចូលទៅជិតគ្រូ ។ បទថា **និវេសេតិ** បានដល់ ឲ្យតាំងនៅក្នុងសម្នាក់នៃអាចារ្យ ។ បទថា **អានាបានស្សតឹ អាចិក្ខតិ** បានដល់ ត្រាស់ប្រាប់នូវកម្មដ្ឋាន ដែលសម្បយុត្តដោយអានាបានស្សតិ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយនវកនិបាត ) ថា ចម្រើនអានាបានស្សតិដើម្បីផ្តាច់ផ្តិលនូវវិតក្កដូច្នេះ ។ បទថា **ចាសាទនីយំ និមិត្តំ អាចិក្ខតិ** បានដល់ ត្រាស់ប្រាប់ព្រះសូត្រដែលឲ្យកើតនូវសេចក្តីជ្រះថ្លាមានចូឡវេទល្លសូត្រនិងមហាវេទល្លសូត្រជាដើម ។ បទថា **ពុទ្ធសុពោធឹ** បានដល់ ការត្រាស់ដឹងជាព្រះពុទ្ធរបស់ព្រះពុទ្ធមានព្រះភាគ ។ បទថា **ធម្មសុធម្មតំ** បានដល់ ភាពដែលលោកុត្តរធម៌ ៩ យ៉ាង ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ។ បទថា **សង្ឃសុបដិបត្តឹ** បានដល់ ភាពជាអ្នកបដិបត្តិល្អ មានការបដិបត្តិប្រពៃរបស់ព្រះអរិយសង្ឃ ៨ ពួក ។

បទថា **សីលានិ ច អត្តនោ** បានដល់ ទ្រង់ប្រាប់សីលដែលមានរបស់ខ្លួន ។ បទថា **វិបស្សនានិមិត្តំ** បានដល់ ទ្រង់ប្រាប់នូវធម៌ដែលបដិសំយុត្តដោយការកើតនិងការរលត់ជាដើម ។ បទថា **អនិច្ចាការំ** បានដល់ អាការមានហើយត្រឡប់ជាមិនមាន ។ បទថា **ទុក្ខាការំ** បានដល់ អាការបៀតបៀន

ដោយការកើតនិងការរលត់ ។ បទថា **អនត្ថាការំ** បានដល់ អាការមិនប្រព្រឹត្ត ទៅក្នុងអំណាច ។

បទថា **សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ** បានដល់ បុរសឈរនៅលើ កំពូលភ្នំថ្មតាន់ ។ កាលឈរលើកំពូលភ្នំនោះក៏មិនមានកិច្ចដែលនឹងឡើងដើម ឈើដើម្បីមើលឡើយ ។ បទថា **តថូបមំ** បានដល់ ប្រៀបដោយភ្នំថ្មដែល មានចំណែកដូចគ្នានោះ ។ ក្នុងបទនេះមានសេចក្តីសង្ខេបដូចតទៅនេះថា

បុរសមានចក្ខុឈរលើកំពូលភ្នំថ្ម គប្បីឃើញពួកជនដោយជុំវិញយ៉ាងណា បពិត្រព្រះមានព្រះភាគ ទ្រង់មានបញ្ញាល្អ មានសមន្តចក្ខុ ដោយសព្វញ្ញុត- ញ្ញាណ គឺមានបញ្ញាស្អាត ទ្រង់មានសោកទៅប្រាសហើយដោយព្រះអង្គឯង ទ្រង់ឡើងកាន់ប្រាសាទ ដែលសម្រេចដោយធម៌ សម្រេចដោយបញ្ញា សូម ទ្រង់ពិចារណា ត្រិះរិះដល់ពួកជន ដែលដល់ព្រមដោយសេចក្តីសោកនិងត្រូវ ជាតិ ជរាគ្របសង្កត់ហើយយ៉ាងនោះ ។ សេចក្តីនេះមានពាក្យអធិប្បាយដូច តទៅនេះថា ដូចជនទាំងឡាយធ្វើនូវផែនដីធំដោយជុំវិញជើងភ្នំ ហើយសង់ខ្ទម ត្រង់ផ្ទៃដីដែលសមគួរដល់ការសាបព្រោះក្នុងទីនោះ គប្បីបង្កាត់ភ្លើងក្នុងពេល យប់ គប្បីមានការងងឹតប្រកបដោយអង្គ ៤ ពេលនោះបុរសអ្នកមានភ្នែកល្អ ឈរលើកំពូលភ្នំនោះសម្លឹងមើលផែនដី ផែនដីមិនប្រាកដ ភ្លឺស្រែមិនប្រាកដ ខ្ទមមិនប្រាកដ មនុស្សដែលដេកក្នុងខ្ទមមិនប្រាកដ ប្រាកដត្រឹមតែអណ្តាតភ្លើង ក្នុងខ្ទមយ៉ាងណា កាលព្រះតថាគតទ្រង់ឡើងកាន់ធម្មប្រាសាទ ទ្រង់ប្រមើល មើលសត្វសត្វពួកណាមិនធ្វើសេចក្តីល្អទុក សត្វទាំងនោះសូម្បីអង្គុយក្បែរព្រះ

ជានុខាងស្តាំក្នុងវិហារតែមួយ ក៏មិនមកកាន់គន្លងនៃពុទ្ធចក្ខុ ដូចព្រួញដែលបាញ់ទៅក្នុងពេលយប់ដូច្នោះ ឯសត្វណាធ្វើសេចក្តីល្អទុក ជាវេនេយ្យបុគ្គលសត្វទាំងនោះ សូម្បីនៅឆ្ងាយអំពីព្រះតថាគត ក៏រមែងមកកាន់គន្លងពុទ្ធចក្ខុសត្វទាំងនោះដូចភ្លើងនិងដូចភ្នំហិមពាន្ត ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងធម្មបទ ) ថា

> ពួកសប្បុរសតែងប្រាកដក្នុងទីឆ្ងាយដូចភ្នំហិមពាន្តដូច្នោះ ពួក
> អសប្បុរស ( ទុកជាឋិតនៅ ) ក្នុងទីជិត ក៏រមែងមិនប្រាកដ
> ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ដូច្នេះ ។

គប្បីជ្រាបសេចក្តីក្នុងបទថា **សព្វញ្ញុតញ្ញាណំ** ដូចតទៅនេះថា

ឈ្មោះថា **សព្វញ្ញូ** ព្រោះដឹងទូទៅដល់វត្ថុទាំងពួង ដែលជាគន្លងនៃធម៌ដែលគួរដឹង ៥ ប្រការ ។ ពិតហើយធម៌ទាំងពួង មានប្រភេទជាសង្ខតធម៌និងអសង្ខតធម៌ជាដើម ឈ្មោះថាជាគន្លងនៃធម៌ដែលគួរដឹង ៥ ប្រការ គឺសង្ខារ ១ វិការ ១ លក្ខណៈ ១ និព្វាន ១ បញ្ញត្តិ ១ ។ ភាពនៃសព្វញ្ញូ ឈ្មោះថា **សព្វញ្ញុតា** ។ សព្វញ្ញុតានោះឯងគឺ **ញាណំ** គួរនឹងពោលថា **សព្វញ្ញុតាញាណំ** លោកក៏ពោលថា **សព្វញ្ញុតញ្ញាណំ** ។ បទថា **សព្វញ្ញូ** បានដល់ ដែលដឹងវត្ថុទាំងពួងមាន ៥ យ៉ាង គឺ **កមសព្វញ្ញូ** ដឹងវត្ថុទាំងពួងតាមលំដាប់ ១ **សកឹសព្វញ្ញូ** ដឹងវត្ថុទាំងពួងម្តងម្កាល ១ **សតតសព្វញ្ញូ** ដឹងវត្ថុទាំងពួងរឿយៗ ១ **សត្តិសព្វញ្ញូ** ដឹងវត្ថុទាំងពួងតាមសមត្ថភាព ១ **ញាតសព្វញ្ញូ** ដឹងវត្ថុទាំងពួងដែលប្រាកដ ១ ។ ក្នុងសព្វញ្ញូ ៥ យ៉ាងនោះ ព្រោះមិនមានកាលដែលដឹង

វត្ថុទាំងពួងតាមលំដាប់ទើបមិនឈ្មោះថា **កមសព្វញ្ញូ** ។ ព្រោះមិនមានការទាញយកអារម្មណ៍ទាំងពួងម្ដងម្កាល ទើបមិនឈ្មោះថា **សកឹសព្វញ្ញូ** ។ ព្រោះមានចិត្ត មានអារម្មណ៍ពិតប្រាកដក្នុងចក្ខុវិញ្ញាណជាដើម ព្រោះជំទាស់នឹងភវង្គចិត្ត និងព្រោះមិនមានការប្រែកបទើបមិនឈ្មោះថា **សតតសព្វញ្ញូ** ។ ព្រោះអាចដឹងនូវវត្ថុទាំងពួងដោយមានសេសសល់ គប្បីជាសត្តិសព្វញ្ញូ ឬព្រោះដឹងច្បាស់នូវធម៌ទាំងពួង គប្បីជាញាតសព្វញ្ញូ ។ ការដឹងវត្ថុទាំងពួងមិនមានក្នុងសត្តិ-សព្វញ្ញូដោយប្រការដូច្នេះ ។ សូម្បីសត្តិសព្វញ្ញូនោះក៏មិនត្រូវ ព្រោះលោកពោលទុកថា វត្ថុណាមួយក្នុងត្រៃលោកធាតុនេះ ដែលព្រះមានព្រះភាគទ្រង់មិនឃើញ រមែងមិនមាន ។បេ។ ព្រោះហេតុនោះ ទើបព្រះតថាគតឈ្មោះថាជាអ្នកមានសមន្តចក្ខុ ។ ញាតសព្វញ្ញូនោះឯងត្រឹមត្រូវ ។ កាលបើយ៉ាងនេះសព្វញ្ញូរមែងមានដោយកិច្ចដោយមិនវង្វេង ដោយសម្រេចអំពីការណៈដោយអាស្រ័យអាវជ្ជនៈ ។ បទថា **តេន ញាណេន** បានដល់ ដោយញាណដែលដឹងវត្ថុទាំងពួងនោះ ។

ដើម្បីឲ្យដឹងភាពជាសព្វញ្ញូដោយបរិយាយដទៃទៀត ទើបព្រះសារីបុត្តត្ថេរពោលគាថាថា **ន តស្ស** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ** សេចក្ដីថា របស់ណាមួយក្នុងត្រៃលោកធាតុនេះដែលបញ្ញាចក្ខុរបស់ព្រះតថាគតនោះមិនឃើញក្នុងកាលបច្ចុប្បន្ននេះ សូម្បីប្រមាណតិចតួចរមែងមិនមាន គឺរមែងមិនប្រាកដ ។ បទថា **អត្ថិ** នេះ ជាបទអាខ្យាត ប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ។ ដោយបទនេះ

*លោកសម្តែងភាពដែលធម៌ទាំងពួង ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាល ដែលព្រះតថាគតដឹងហើយ ។ ក្នុងគាថានេះប្រកប* **ឆ** *អក្ខរៈចូលទៅដើម្បីងាយស្រួលក្នុងការចងគាថា ។* **អថោ** *សព្ទក្នុងបទថា* **អថោ វិញ្ញាតំ** *នេះ ជានិបាត ចុះក្នុងការប្រព្រឹត្តទៅនៃវាចាតទៅ ។ បទថា* **អវិញ្ញាតំ** *មានបាឋៈដ៏សេសថា ធម្មជាតណាមួយដែលជាអតីតកាល ឈ្មោះថាដែលព្រះពុទ្ធញាណមិនដឹងច្បាស់មិនមាន ។ ក្នុងការកាន់យក* **អត្ថិ** *សព្ទ ដែលជា* **អត្យ** *សព្ទសូម្បីវៀរបាឋៈដ៏សេសក៏គួរដូចគ្នា ។ ដោយបទនេះ លោកសម្តែងដល់ភាពដែលធម៌ទាំងពួងដែលជាអតីតកាល ដែលព្រះតថាគតទ្រង់ដឹងហើយ ។ បទថា* **អជានិតព្វំ** *បានដល់ ធម្មជាតដែលអាចនឹងមិនដឹងដែលជាអនាគតកាលនឹងមិនមាន ឬរមែងមិនមាន ។ ដោយបទនេះ លោកសម្តែងដល់ភាពដែលធម៌ទាំងពួងជាអនាគតកាល ដែលព្រះតថាគតដឹង ។* **អ** *អក្ខរៈក្នុងបទថា* **អជានិតព្វំ** *នេះ ត្រឹមតែជាវិសេសនៈនៃកិរិយាដឹងនោះឯង ។*

*ក្នុងបទថា* **សព្វំ អភិញ្ញាសិ យទត្ថិ ញេយ្យំ** *នេះ គប្បីជ្រាបដូច្នេះថា នឹងមានធម្មជាតណាមួយឯណាដែលគួរដឹង គឺគួរជ្រាប ដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ ឬផុតចាកកាលទៅហើយ ព្រះតថាគតទ្រង់ជ្រាបហើយ គឺទ្រង់ដឹង ទ្រង់ចាក់ធ្លុះនូវធម្មជាតទាំងអស់នោះដោយព្រះសព្វញ្ញុតញ្ញាណដ៏ក្រៃលែង ។ ក្នុងបទនេះគប្បីឃើញថា* **អត្ថិ** *សព្ទជា* **អត្យ** *សព្ទក្នុងការកាន់យកកាលទាំង ៣ និងផុតចាកកាលដោយ* **អត្ថិ** *សព្ទ ។ បទថា* **តថាគតោ តេន សមន្តចក្ខុ** *បានដល់ ឈ្មោះថា* **សមន្តចក្ខុ** *ព្រោះមានញាណចក្ខុដែលប្រព្រឹត្តទៅ*

ហើយដោយជុំវិញ គឺដោយប្រការទាំងពួងព្រោះសម្តែងដោយមិនសេសសល់ ដោយកាល ដោយឱកាស ។ លោកអធិប្បាយទុកថា ព្រោះហេតុតាមដែលពោលហើយនោះ ទើបព្រះតថាគតជាព្រះសព្វញ្ញូ មានសមន្តចក្ខុ ។ ព្រះសព្វញ្ញុតញ្ញាណ សម្រេចហើយដោយទេសនា ដែលជាបុគ្គលាធិដ្ឋានដោយគាថានេះ ។

[ ៣០ ] បទថា **ន ឥតិហិតិហំ** បានដល់ មិនមែនដោយត្រូវជឿចំពោះបុគ្គលដទៃថា បានឮមកថា ធម៌នេះដូច្នេះ បានឮមកថា ធម៌នេះដូច្នេះ ។ បទថា **ន ឥតិកិរាយ** បានដល់ មិនមែនដោយបានឮតៗគ្នាមកថា បានឮថានេះយ៉ាងនេះ ។ បទថា **ន បរម្បរាយ** បានដល់ មិនមែនដោយពាក្យពោលបន្តៗគ្នាមក ។ បទថា **ន បិដកសម្បទាយ** បានដល់ មិនមែនដោយអាងថានេះសមនឹងតម្រាបិដករបស់យើង ។ បទថា **ន តក្កហេតុ** បានដល់ មិនមែនដោយការដៅស្មាន ។ បទថា **ន អាការបរិវិតក្កេន** បានដល់ មិនមែនត្រិះរិះតាមហេតុយ៉ាងនេះថា ហេតុការណ៍នេះល្អ ។ បទថា **ន ទិដ្ឋិនិជ្ឈា-នក្ខន្តិយា**បានដល់មិនមែនយល់ថា នេះសមនឹងទិដ្ឋិដែលយើងសម្លឹងហើយគាប់ចិត្តហើយកាន់យក ។

[ ៣២ ] គប្បីជ្រាបសេចក្តីក្នុងបទថា **អជ្ឈត្តំ សមាធឹ** នេះ ដូចតទៅនេះថា បទថា **សមាធឹ** បានដល់ ឈ្មោះថា សមាធិព្រោះចិត្តជាកុសលមានអារម្មណ៍តែ ១ ។ ឈ្មោះថា **សមាធិ** ដោយអត្ថថាដូចម្តេច ដោយអត្ថថាតាំងចិត្តមាំ ។ ឈ្មោះថា ការតាំងចិត្តមាំនេះដូចម្តេច គឺការតាំងចិត្តនិងចេតសិក

ទុកក្នុងអារម្មណ៍ ១ ដោយស្មើនិងដោយប្រពៃ ។ លោកអធិប្បាយថា ការតាំងទុក ព្រោះហេតុនោះចិត្តនិងចេតសិកទាំងឡាយ មិនរាយមាយ មិនរីករវរ តាំងនៅក្នុងអារម្មណ៍ ១ ដោយអានុភាពនៃធម៌ណាដោយស្មើនិងដោយប្រពៃ នេះគប្បីជ្រាបថា ការតាំងចិត្តមាំ ។

លោកពោលដល់សមាធិនោះជាគាថាព័ន្ធថា

សមាធិនោះមានការមិនរាយមាយជាលក្ខណៈ មានការកម្ចាត់
នូវការរាយមាយជាកិច្ច មានការមិនញាប់ញ័រជាអាការប្រាកដ
មានសេចក្តីសុខជាបទដ្ឋាន ។

សមាធិឈ្មោះថា **ឋិតិ** ព្រោះតាំងនៅក្នុងអារម្មណ៍ដោយការមិនល្អក់កករ មិនញាប់ញ័រ ។ ២ បទក្រោយលោកចុះឧបសគ្គ ។ ឈ្មោះថា **សណ្ឋិតិ** ព្រោះរួបរួមសម្បយុត្តធម៌ទុកក្នុងអារម្មណ៍ ។ ឈ្មោះថា **អវដ្ឋិតិ** ព្រោះមិនចូលទៅគោងអារម្មណ៍តាំងនៅ ។ ពិតហើយ ក្នុងចំណែកកុសលធម៌មាន ៤ យ៉ាង គឺសទ្ធា សតិ សមាធិនិងបញ្ញា រមែងឈមចុះក្នុងអារម្មណ៍ ។ ដោយហេតុនោះឯង ទើបសទ្ធាលោកពោលថា ចុះស៊ប់ ។ សតិលោកពោលថា មិនអណ្តែតអណ្តូង សមាធិលោកពោលថា តាំងចុះស៊ប់ បញ្ញាលោកពោលថា ឈមចុះ ឯខាងអកុសលធម៌មាន ៣ យ៉ាង គឺតណ្ហា ទិដ្ឋិនិងអវិជ្ជា រមែងឈមចុះក្នុងអារម្មណ៍ ។ ដោយហេតុនោះទើបធម៌ទាំងនោះ លោកពោលថាជាឱឃៈ ។ ម្យ៉ាងទៀតក្នុងចំណែកអកុសលនេះ ចិត្តមានអារម្មណ៍តែមួយបានតែមិនមានកម្លាំងដូចកាលបុគ្គលយកទឹកស្រោចក្នុងទីដែលកើតធូលី ហើយលាង

ឲ្យរលោង ធូលីបាត់ទៅមួយជួរខណៈ កាលស្ងួតហើយធូលីក៏ប្រាកដដូចដើម យ៉ាងណា ការដែលចិត្តមានអារម្មណ៍ ១ ក្នុងចំណែកអកុសលក៏មិនមានកម្លាំង យ៉ាងនោះដូចគ្នា ។ ឈ្មោះថា **អវិសាហារោ** ព្រោះជាបដិបក្ខចំពោះការស្រុះទៅ ដែលប្រព្រឹត្តទៅហើយដោយអំណាចការរាយមាយនិងសេចក្តីសង្ស័យ ។ ចិត្តស្រុះទៅដោយអំណាចនៃការរាយមាយនិងសេចក្តីសង្ស័យនោះឯង ឈ្មោះថា **វិក្ខេប** ។ តែរាយមាយយ៉ាងនោះមិនមាន ព្រោះហេតុនោះទើបឈ្មោះថា **អវិក្ខេប** ។ ចិត្ត ឈ្មោះថាស្រុះទៅ គឺស្រុះទៅក្នុងទីផ្សេងៗ ដោយអំណាចការរាយមាយនិងសេចក្តីសង្ស័យ ។ តែភាពជាអ្នកមានចិត្តដែលបុគ្គលណាមួយឲ្យរាយមាយមិនបានយ៉ាងនេះ ឈ្មោះថា **អវិសាហដមានសតា** ។ បទថា **សមថោ** សមថមាន ៣ យ៉ាង គឺចិត្តសមថៈ ១ អធិករណសមថៈ ១ សព្វសង្ខារសមថៈ ១ ក្នុងសមថៈ ៣ យ៉ាងនោះឈ្មោះថា ចិត្តសមថៈ ព្រោះចិត្តមានអារម្មណ៍មួយក្នុងសមាបត្តិ ៨ ព្រោះចិត្តញាប់ញ័រ ចិត្តក្តៅក្រហាយស្ងប់រម្ងាប់ព្រោះអាស្រ័យសមថៈនោះ ហេតុនោះទើបសមថៈនោះហៅថា **ចិត្តសមថ** ។

ឈ្មោះថា អធិករណសមថៈ មាន ៧ យ៉ាង មានសម្មុខាវិន័យជាដើម អធិករណ៍ទាំងឡាយនោះៗស្ងប់រម្ងាប់ព្រោះអាស្រ័យសមថៈនោះ ព្រោះហេតុនោះទើបសមថៈនោះហៅថា **អធិករណសមថ** ។

តែព្រោះសង្ខារទាំងពួងស្ងប់រម្ងាប់ព្រោះអាស្រ័យនិព្វានដូច្នោះ ទើបនិព្វាននោះហៅថា **សព្វសង្ខារសមថ** ក្នុងសេចក្តីនេះលោកបំណាងយកចិត្តសមថៈ ។

ឈ្មោះថា **សមាធិន្ទ្រិយំ** ព្រោះធ្វើនូវភាពជាធំក្នុងលក្ខណៈនៃសមាធិ ។ ឈ្មោះថា **សមាធិពលំ** ព្រោះមិនញាប់ញ័រក្នុងឧទ្ធច្ចៈ ។ បទថា **សម្មាសមាធិ** បានដល់ សមាធិដែលពិត សមាធិដែលនាំសត្វចេញទៅ ។

[ ៣៣ ] លំដាប់នោះព្រោះឥន្ទ្រិយសំវរៈជាការរក្សាសីល ឬព្រោះទេសនានេះដែលព្រះអង្គទ្រង់សម្តែងតាមលំដាប់នេះ ជាទីសប្បាយរបស់ទេវតាទាំងឡាយ ហេតុនោះព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិបទា ផ្តើមតាំងអំពីឥន្ទ្រិយសំវរៈទៅទើបទ្រង់ប្រារព្ធពាក្យជាដើមថា **ចក្ខូហិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ចក្ខូហិ នេវ លោលស្ស** បានដល់ មិនគប្បីជាអ្នកឡេះឡោះដោយចក្ខុទាំងឡាយ ដោយអំណាចមើលរូបដែលមិនធ្លាប់មើលជាដើម ។ បទថា **គាមកថាយ អាវរយេ សោតំ** បានដល់ គប្បីរាំងត្រចៀកចាកតិរច្ឆានកថា ។

[ ៣៤ ] បទថា **ចក្ខុលោលិយេន** បានដល់ ដោយភាពជាអ្នកឡេះឡោះដោយចក្ខុ ដោយអំណាចលោភៈដែលកើតឡើងហើយក្នុងចក្ខុទ្វារ ។ បទថា **អទិដ្ឋំ ទក្ខិតព្វំ** បានដល់ រូបារម្មណ៍ដែលមិនធ្លាប់មើល គួរមើល ។ បទថា **ទិដ្ឋំ សមតិក្កមិតព្វំ** បានដល់ រូបារម្មណ៍ដែលធ្លាប់ឃើញហើយគួរឆ្លងទៅ ។ បទថា **អារាមេន អារាមំ** បានដល់ អំពីសួន មានសួនផ្កាជាដើម ទៅកាន់សួនផ្លែឈើឬសួនផ្កា ។ បទថា **ទីឃចារិកំ** បានដល់ ត្រាច់ទៅយូរ ។ បទថា **អនវដ្ឋិតចារិកំ** បានដល់ ត្រាច់ទៅដោយមិនសម្រេចចិត្ត ។ បទថា **អ-នុយុត្តោ ហោតិ រូបទស្សនាយ** បានដល់ ជាអ្នកខ្វល់ខ្វាយរឿយៗដើម្បី

មើលរូបារម្មណ៍ ។ បទថា **អន្តរឃរំ បវិដ្ឋោ** បានដល់ ចូលទៅដល់ខាងក្នុងធរណីទ្វារ ។ បទថា **វីថិ បដិបន្នោ** បានដល់ ឈានទៅវាំងផ្លូវ ។ បទថា **ឃរមុខានិ ឱលោកេន្តោ** បានដល់ សម្លឹងតាមទ្វារផ្ទះ ។ បទថា **ឧទ្ធំ ឱលោកេន្តោ** បានដល់ ងើបមុខសម្លឹងមើលខាងលើ ។ បទថា **ចក្ខុនា រូបំ ទិស្វា** បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណដែលអាចឃើញរូបដែលបានរាប់ហាថា **ចក្ខុ** ដោយអំណាចជាហេតុ ។ តែបុរាណាចារ្យពោលទុកថា

ចក្ខុមិនឃើញរូប ព្រោះមិនមានចិត្តចិត្តមិនឃើញរូប ព្រោះមិនមានចក្ខុ រមែងឃើញដោយចិត្តដែលមានបសាទចក្ខុ ប៉ះខ្ទប់អារម្មណ៍តាមទ្វារ ។

កថាបែបនេះឈ្មោះថា សសម្ភារកថា ដូចក្នុងប្រយោគជាដើមថា បាញ់ដោយធ្នូ ព្រោះហេតុនោះទើបអត្ថក្នុងសេចក្តីនេះ មានដូច្នេះថា ឃើញរូបដោយចក្ខុវិញ្ញាណ ។ បទថា **និមិត្តគ្គាហី** បានដល់ កាន់យកនិមិត្តថាស្រីនិងប្រុស ឬនិមិត្តដែលជាទីតាំងនៃកិលេសមានសុភនិមិត្តជាដើម ដោយអំណាចឆន្ទរាគៈ គឺរមែងមិនតាំងនៅត្រឹមតែការឃើញប៉ុណ្ណោះទេ ។ បទថា **អនុព្យញ្ជនគ្គាហី** បានដល់ កាន់យកអាការមានដៃ ជើង សើច ពោល ក្រឡេកមើលជាដើម ដែលហៅថា **អនុព្យញ្ជនៈ** ឲ្យប្រាកដ ដោយជាហេតុឲ្យកិលេសទាំងឡាយប្រាកដ ។ គប្បីជ្រាបក្នុងបទថា **យត្វាធិករណមេនំ** ជាដើមដូចតទៅនេះថា ធម៌ទាំងឡាយមានអភិជ្ឈាជាដើមទាំងនេះ គប្បីគ្របសង្កត់ ជាប់តាមបុគ្គលនោះដែលមិនសង្រួមចក្ខុន្ទ្រិយដោយទ្វារគឺសតិជាអ្នកមិនបិទនូវចក្ខុទ្វារ តាំង-

នៅ ព្រោះហេតុណា គឺព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រិយណា ។ បទថា **តស្ស សំវរាយ ន បដិបជ្ជតិ** បានដល់ រមែងមិនបដិបត្តិ ដើម្បីបិទនូវចក្ខុន្ទ្រិយនោះដោយទ្វារ គឺសតិ ។ លោកពោលថាភិក្ខុយ៉ាងនេះឈ្មោះថាមិនរក្សានូវចក្ខុន្ទ្រិយ មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយ ។ ក្នុងបទនោះ ការសង្រួម ឬមិនសង្រួម រមែងមិនមានក្នុងចក្ខុន្ទ្រិយដោយពិត ព្រោះសតិ ឬការវង្វេងរមែងមិនកើតឡើង ព្រោះអាស្រ័យចក្ខុបសាទ ម្យ៉ាងទៀត កាលណារូបារម្មណ៍មកកាន់គន្លងចក្ខុ កាលនោះ កាលភវង្គចិត្តកើតឡើងហើយរលត់ទៅ ២ ដង កិរិយាមនោធាតុញុំាងអាវជ្ជនកិច្ចឲ្យសម្រេច កើតឡើងហើយរលត់ទៅ ។ បន្ទាប់អំពីនោះ ចក្ខុវិញ្ញាណធ្វើនូវកិច្ចឃើញ ។ បន្ទាប់អំពីនោះវិបាកមនោធាតុធ្វើកិច្ចទទួល បន្ទាប់អំពីនោះវិបាកអហេតុកមនោវិញ្ញាណ-ធាតុធ្វើកិច្ចពិចារណា បន្ទាប់អំពីនោះកិរិយាអហេតុកមនោវិញ្ញាណធាតុ ញុំាងនូវវោដ្ឋព្វនកិច្ចឲ្យសម្រេចកើតឡើង ហើយរលត់ទៅ ក្នុងលំដាប់នោះជវនចិត្តរមែងស្ទុះទៅ ។

ការមិនសង្រួម ឬការសង្រួម រមែងមិនមានក្នុងសម័យនៃភវង្គចិត្តនោះ រមែងមិនមានក្នុងសម័យណាមួយបណ្ដាអាវជ្ជនចិត្តជាដើម តែក្នុងខណៈជវនចិត្ត បើភាពជាអ្នកទ្រុស្តសីល ភាពជាអ្នកវង្វេង ការមិនដឹង ការមិនអត់ធន់ ឬការខ្ជិលច្រអូសកើតឡើង ការមិនសង្រួមរមែងមាន ។ ភិក្ខុកាលបើរស់នៅយ៉ាងនេះ លោកហៅថា ជាអ្នកមិនសង្រួមក្នុងចក្ខុន្ទ្រិយ ។ ព្រោះហេតុអ្វី ព្រោះកាលមិនមានការសង្រួមក្នុងចក្ខុន្ទ្រិយ សូម្បីទ្វារក៏ឈ្មោះថាមិនគ្រប់គ្រង

សូម្បីភវង្គចិត្ត សូម្បីវិថីចិត្តមានអាវជ្ជនៈជាដើម ក៏ឈ្មោះថាមិនគ្រប់គ្រង ។ សេចក្ដីនេះដូចម្ដេច ដូចទ្វារ ៤ ក្នុងនគរមិនបិទ សូម្បីបិទទ្វារផ្ទះ ទ្វារបន្ទប់ជាដើមខាងក្នុងនគរក្ដី ទោះជាដូច្នោះ ក៏មិនឈ្មោះថារក្សាទ្រព្យទាំងអស់ខាងក្នុងនគរនោះឯង ព្រោះចោរទាំងឡាយចូលទៅតាមទ្វារនគរ គប្បីធ្វើតាមសេចក្ដីត្រូវការយ៉ាងណា កាលភាពជាបុគ្គលទ្រុស្តសីលជាដើមកើតឡើងក្នុងជវនចិត្ត កាលមិនមានការសង្រួមនោះ សូម្បីទ្វារក៏មិនជាការគ្រប់គ្រង ភវង្គចិត្ត វិថីចិត្ត មានអាវជ្ជនៈជាដើម ក៏ឈ្មោះថាមិនជាការគ្រប់គ្រងនោះឯង ។

បទថា **សទ្ធាទេយ្យានិ** បានដល់ ដែលគេជឿកម្មផលរបស់កម្ម លោកនេះនិងលោកខាងមុខហើយប្រគេន អធិប្បាយថា មិនបានប្រគេនដោយអាការយ៉ាងនេះថា ភិក្ខុនេះជាញាតិ ជាមិត្តរបស់អញ ឬនឹងតបស្នងនូវវត្ថុនេះ ឬភិក្ខុនេះធ្លាប់ធ្វើវត្ថុនេះដូច្នេះ ។ ការប្រគេនយ៉ាងនេះមិនឈ្មោះថា ប្រគេនដោយសទ្ធាឡើយ ។ ម្យ៉ាងទៀតបទថា **ភោជនានិ** នេះ ត្រឹមតែជាមាតិកាទេសនាតែដោយអត្ថ លោកពោលពាក្យទាំងអស់នេះថា ភិក្ខុបរិភោគភោជន ជណ្ដប់ចីវរ សេពសេនាសនៈ បរិភោគគិលានប្បច្ច័យភេសជ្ជបរិក្ខារដែលគេប្រគេនដោយសទ្ធា ។ បទថា **សេយ្យថីទំ** ត្រឹមតែជានិបាត សេចក្ដីថា នុ៎ះដូចម្ដេច ។ ការរាំឯណានីមួយ ឈ្មោះថា **នច្ចំ** ។ ភិក្ខុដើរទៅក្នុងស្រុក ក៏មិនគួរសម្លឹងមើល ។ ការច្រៀងឯណានីមួយ ឈ្មោះថា **គីតំ** ។ ការប្រគំឯណានីមួយ ឈ្មោះថា **វាទិតំ** ។ ការរាំជាដើម ឈ្មោះថា **បេក្ខំ** ។ ការនិទានរឿងភារតៈនិងរាមាយណៈ ( រាមកេរ្តិ៍ ) ជាដើម ឈ្មោះថា **អក្ខានំ** ។ ភិក្ខុមិនគួរទៅក្នុង

ទីដែលគេនិទានទោះ ។ បទថា **ចាណិស្សរំ** បានដល់ គង ។ អាចារ្យមួយពួកពោលថា ភ្លេងទះដៃ ។ បទថា **វេតឡំ** បានដល់ គ្រឿងវាយដែលក្រាស់ ។ អាចារ្យពួកមួយពោលថា ការរាយមន្តលើសាកសពរបស់អ្នកស្លាប់ ។ បទថា **កុម្ភថូនំ** បានដល់ ការវាយលើឧបករណ៍វាង ៤ ជ្រុង ។ អាចារ្យពួកមួយពោលថា លេងវាយដោយសម្លេងក្រឡ ។ បទថា **សោភនគរកំ** បានដល់ ដេរជាសទៅដោយអ្នករបាំ អធិប្បាយថា នគរស្អាត គឺមានអ្នកធ្វើឲ្យវិចិត្រដោយការឈ្លាសវៃ ។ បទថា **ចណ្ឌាលំ** បានដល់ ល្បែងដុំដែក ( លេងឃ្លី ) អាចារ្យពួកខ្លះពោលថា ការលេងបោកសរសៃថ្មៃ របស់មនុស្សចណ្ឌាល ។ បទថា **វំសំ** បានដល់ លើកឫស្សីឡើងហើយលេង ( រាំវ ) ។ បទថា **ធោវនំ** បានដល់ ល្បែងលាងឆ្អឹង បានឮថា ក្នុងជនបទខ្លះកាលញាតិស្លាប់គេមិនដុត គេជីករណ្តៅកប់ ។ ញាតិដឹងពេលដែលសាកសពនោះរលួយ ទើបជីកយកមក ហើយលាងឆ្អឹង យកគ្រឿងក្រអូបលាបរក្សាទុក ។ កាលដល់ថ្ងៃនក្ខត្តឫក្ស ពួកញាតិតម្កល់ឆ្អឹងទុកក្នុងទីមួយ តម្កល់សុរាជាដើមក្នុងទីមួយហើយនាំគ្នាយំរៀបរាប់ ផឹកសុរា ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយទសកនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ ក្នុងទក្ខិណជនបទ តែងមានពិធីលាងឆ្អឹង ជាចម្មតា បាយក្តី ទឹកក្តី បង្អែមក្តី ចម្អាបក្តី វត្ថុដែលគប្បីលិទ្ធក្តី ទឹកដែលគប្បីផឹកក្តី ការរាំក្តី ច្រៀងក្តី ប្រគំក្តីតែងមានក្នុងពិធីលាងឆ្អឹងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពិធីលាងឆ្អឹងនុ៎ះ

មានមែន តថាគតមិនពោលថា ពិធីលាងធ្មេញនោះ មិនមានទេ ដូច្នេះ ។

តែអាចារ្យពួកមួយពោលថា ការលាងធ្មេញដោយការបោកបញ្ឆោត ឈ្មោះ ធោវនៈ ។ ក្នុងការជល់ដំរីជាដើម ភិក្ខុមិនគួរប្រយុទ្ធដោយដំរីជាដើម មិនគួរឲ្យដំរីជល់គ្នា មិនគួរមើលដំរីជល់គ្នា ។ បទថា **និព្ពុទ្ធំ** បានដល់ ការប្រយុទ្ធដោយបោកចំបាប់គ្នា ។ បទថា **ឧយ្យោធិកំ** បានដល់ ទីដែលគេច្បាំងគ្នា ។ បទថា **ពលគ្គំ** បានដល់ ទីកន្លែងរាប់មនុស្ស ( ត្រួតពល ) ។ បទថា **សេនាព្យូហំ** បានដល់ បន្ទាយទាហាន គឺទីសម្រាករបស់អ្នកចម្បាំង មានកងទ័ពរទេះជាដើម ។ បទថា **អនីកទស្សនំ** បានដល់ មើលកងទ័ពដែលលោកពោលទុកដោយន័យថា ដំរីបី ហៅថាសេនាដំរីយ៉ាងតិចបំផុតជាដើម ។ បទថា **ន និមិត្តគ្គាហី ហោតិ** បានដល់ មិនកាន់យកនិមិត្តដូចពោលហើយដោយអំណាចឆន្ទរាគៈ ។ បទដ៏សេសគប្បីជ្រាបដោយន័យផ្ទុយគ្នា តាមដែលពោលហើយ ។ ម្យ៉ាងទៀតលោកពោលហើយខាងដើមថា កាលភាពជាអ្នកទ្រុស្តសីលកើតឡើងហើយក្នុងជវនចិត្ត កាលមិនមានការសង្រួម សូម្បីទ្វារក៏មិនជាការគ្រប់គ្រង ភវង្គចិត្ត វិថីចិត្តមានអាវជ្ជនៈជាដើម ក៏មិនឈ្មោះថាគ្រប់គ្រងយ៉ាងណា ក្នុងទីនេះក៏យ៉ាងនោះ កាលសីលជាដើមកើតឡើងហើយក្នុងជវនចិត្តនោះ សូម្បីទ្វារក៏ឈ្មោះថា គ្រប់គ្រងបាន ភវង្គចិត្ត វិថីចិត្តមានអាវជ្ជនៈជាដើម ក៏ឈ្មោះថាគ្រប់គ្រងបាន សេចក្តីនេះដូចម្តេច ដូចកាលបិទទ្វារនគរហើយខាងក្នុងផ្ទះជាដើម ទោះបីមិនបានបិទ ក៏ទ្រព្យទាំងអស់ខាងក្នុង

នគរ ឈ្មោះថារក្សាល្អហើយ គ្រប់គ្រងល្អហើយនោះឯង កាលទ្វារនគរបិទហើយ ចោរទាំងឡាយក៏ចូលទៅមិនបានយ៉ាងណា កាលសីលជាដើមកើតហើយក្នុងជវនចិត្ត សូម្បីទ្វារក៏ឈ្មោះថាគ្រប់គ្រងបាន ភវង្គចិត្ត វិថីចិត្តមានអាវជ្ជនៈជាដើម ក៏ឈ្មោះថាគ្រប់គ្រងបានយ៉ាងនោះឯង ព្រោះហេតុនោះការសង្រួម សូម្បីកើតឡើងក្នុងខណៈនៃជវនចិត្ត លោកក៏ពោលថាជាការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បន្ទាប់អំពីនោះទាំងខាងក្រោយទាំងខាងមុខ គប្បីជ្រាបដោយបរិយាយតាមដែលពោលហើយ ។ បទថា **វិសូកទស្សនា** បានដល់ ការមើលវត្ថុដែលជាការលេង ។

[ ៣៥ ] បទថា **គាមកថា** បានដល់ ពាក្យពោលរបស់ពួកអ្នកស្រុក ។ បទថា **ពត្តឹស** គឺ **ទ្វត្តឹស** ។ វាចាដែលជាគ្រឿងរាំងផ្លូវទៅកាន់ឋានសួគ៌និងផ្លូវទៅកាន់ព្រះនិព្វាន ឈ្មោះថា តិរច្ឆានកថា ព្រោះជាវាចាដែលមិននាំសត្វចេញទៅ ( អំពីវដ្ដ ) ។ ក្នុងគាមកថាទាំងនោះវាចាដែលប្រារព្ធព្រះរាជាប្រព្រឹត្តទៅដោយន័យជាដើមថា ព្រះបាទមហាសម្មតរាជ ព្រះបាទមន្ធាតុរាជ ព្រះបាទធម្មាសោករាជមានអានុភាពយ៉ាងនេះៗ ឈ្មោះថា រាជកថា ។ ក្នុងចោរកថាជាដើមក៏ន័យនេះ ។ ក្នុងគាមកថាទាំងនេះវាចាអាស្រ័យផ្ទះ ដោយន័យជាដើមថា ព្រះរាជាអង្គនោះ មានរូបគួរឲ្យសរសើរដូច្នេះជា តិរច្ឆានកថា ។ តែវាចាដែលប្រព្រឹត្តទៅយ៉ាងនេះថា ព្រះរាជាអង្គនោះមានអានុភាពច្រើនដល់ម៉្លោះ ក៏គង់សោយទិវង្គត ឈ្មោះថា តាំងនៅក្នុងភាពជាកម្មដ្ឋាន ។ សូម្បីក្នុងពួកចោរវាចាអាស្រ័យផ្ទះថា អស្ចារ្យហ្ន៎ ចោរក្លាហានទាំងឡាយអាស្រ័យការធ្វើរបស់

ពួកចោរថា មូលទេពមានអានុភាពច្រើនយ៉ាងនេះ មេឃមាលាមានអានុភាពច្រើនយ៉ាងនេះ ឈ្មោះថា តិរច្ឆានកថា ។ ក្នុងការច្បាំងពាក្យពោលដោយការពេញចិត្តក្នុងរឿងការតយុទ្ធជាដើមថា បុគ្គលឈ្មោះនោះត្រូវបុគ្គលឈ្មោះនោះសម្លាប់យ៉ាងនេះ ត្រូវចាក់យ៉ាងនេះ ក៏ឈ្មោះថា តិរច្ឆានកថា ។

ឯវាចាដែលប្រព្រឹត្តទៅយ៉ាងនេះថា បុគ្គលនោះក៏គង់ស្លាប់ដូច្នេះជាកម្មដ្ឋានក្នុងទីទាំងពួង ។

ម្យ៉ាងទៀតក្នុងអាហារមានបាយជាដើម មិនគួរពោលដោយការពេញចិត្តក្នុងកាមថា ខ្ញុំទំពា ស៊ី ផឹក បរិភោគអាហារមានពណ៌ មានក្លិន មានរសដល់ព្រម ដោយផស្សៈយ៉ាងនេះដូច្នេះ ។ តែគួរធ្វើឲ្យប្រកបដោយប្រយោជន៍ហើយពោលថា កាលមុនខ្ញុំបានប្រគេនបាយ ទឹក សំពត់ ទីដេក ផ្កា គ្រឿងក្រអូបដែលបរិបូណ៌ដោយពណ៌ជាដើមយ៉ាងនេះដល់លោកអ្នកមានសីលទាំងឡាយ ខ្ញុំបានធ្វើការបូជាព្រះចេតិយដូច្នេះ ។ ក្នុងញាតិកថាជាដើម ក៏មិនគួរពោលដោយពេញចិត្តថា ញាតិរបស់ខ្ញុំជាអ្នកក្លាហានមានសមត្ថភាព ឬពោលថា កាលមុនខ្ញុំបានត្រាច់ទៅដោយយានដ៏វិចិត្រយ៉ាងនេះដូច្នេះ ។ តែគួរពោលធ្វើឲ្យប្រកបដោយប្រយោជន៍ថា ញាតិទាំងឡាយរបស់ខ្ញុំ ក៏ស្លាប់ហើយ ឬពោលថា កាលមុនខ្ញុំបានប្រគេនស្បែកជើងយ៉ាងនេះដល់សង្ឃ ។

ក្នុងគាមកថាជាដើមក៏មិនគួរពោលដោយការពេញចិត្តយ៉ាងនេះថា មនុស្សដែលនៅក្នុងស្រុកនោះជាអ្នកក្លាហាន មានសមត្ថភាព មានជំហរឹងប៉ឹង ក្រីក្ររកស៊ីងាយ រកស៊ីលំបាកដូច្នេះ ។ គួរពោលធ្វើឲ្យប្រកបដោយប្រយោជន៍ថា

មនុស្សទាំងនោះមានសទ្ធា ជ្រះថ្លាឬបុគ្គលនោះបានស្លាប់ហើយ ។ ក្នុងនិគមកថា នគរកថា ជនបទកថាក៏ន័យនេះដូចគ្នា ។ ឥត្ថីកថា ក៏មិនគួរពោលដោយការពេញចិត្តទាក់ទងនឹងពណ៌សម្បុររូបរាងជាដើម គួរពោលយ៉ាងនេះប៉ុណ្ណោះថា ស្រីដែលមានសទ្ធាបានស្លាប់ហើយ ។ សូរកថា ក៏មិនគួរពោលដោយការពេញចិត្តថា អ្នកចម្បាំងឈ្មោះនន្ទិមិត្ត ជាអ្នកក្លាហាន គួរពោលយ៉ាងនេះថា អ្នកចម្បាំងដែលមានសទ្ធាជ្រះថ្លា បានស្លាប់ហើយដូច្នេះ ។ សូម្បីវិសិខាកថា ក៏មិនគួរពោលដោយការពេញចិត្តថា ច្រកនោះរាបស្មើ ច្រកនោះមិនរាបស្មើ ។ អ្នករស់នៅត្រង់ច្រកនោះជាមនុស្សក្លាហាន មានសមត្ថភាព ។ គួរពោលប៉ុណ្ណោះថា អ្នករស់នៅត្រង់ច្រកនោះ មានសទ្ធាជ្រះថ្លា តែក៏ស្លាប់ហើយ ។

បទថា **កុម្ភដ្ឋានកថា** បានដល់ វាចាដែលទាក់ទងដោយកំពង់ទឹក លោកពោលថា **ឧទកតិត្ថកថា** ក៏មាន បានដល់ កុម្ភទាសីកថា មិនគួរពោលដោយការពេញចិត្តថា នាងកុម្ភទាសីនោះគួរជ្រះថ្លា ជាស្រីឈ្លាសក្នុងការរាំ ក្នុងការច្រៀង ។ គួរពោលដោយន័យជាដើមថា នាងកុម្ភទាសីនោះជាស្រីមានសទ្ធាជ្រះថ្លា ។ បទថា **បុព្វបេតកថា** បានដល់ ពោលដល់ញាតិដែលស្លាប់ទៅហើយ ក្នុងបទនោះ គប្បីជ្រាបវិនិច្ឆ័យដូចគ្នានឹងពោលដល់ញាតិដែលកំពុងរស់នៅ ។ បទថា **នានត្តកថា** បានដល់ ការពោលឥតប្រយោជន៍ រឿងផ្សេងៗដ៏សេស ផុតចាកកថាមុននិងកថាក្រោយ ។ បទថា **លោកក្ខាយិកា** បានដល់ ពោលឲ្យសត្វលោកវង្វេងជឿយ៉ាងនេះថា លោកនេះអ្នកណាសាង អ្នកនោះសាង ក្អែកមានពណ៌សព្រោះឆ្អឹងស កុកក្រកមានពណ៌ក្រហមព្រោះ

ឈាមក្រហម ។ បទថា **សមុទ្ទក្ខាយិកា** ការពោលរឿងសមុទ្ទឥតប្រយោជន៍យ៉ាងនេះថា ព្រោះហេតុអ្វីទើបឈ្មោះថាសមុទ្ទ ឈ្មោះថាសាគរ ព្រោះទេវតាប្រចាំសាគរជីក ឈ្មោះថាសមុទ្ទ ព្រោះប្រកាសឲ្យដឹងឯងដោយម្រាមមេដៃថា សាគរយើងជាអ្នកជីក ។ បទថា **ភវោ** បានដល់ សេចក្ដីចម្រើន ។ បទថា **អភវោ** បានដល់ សេចក្ដីវិនាស ។ ការពោលដល់ហេតុឥតប្រយោជន៍ធម្មតាៗថា ការចម្រើនយ៉ាងនេះ ការវិនាសយ៉ាងនេះ ឈ្មោះថា **ឥតិភវាភវកថា** ។ បទថា **អាវរេយ្យ** បានដល់ គប្បីធ្វើនូវការការពារ ។ បទថា **និវារេយ្យ** បានដល់ គប្បីរាំងចាកអារម្មណ៍ ។ បទថា **សំវរេយ្យ** បានដល់ គប្បីការពារ ធ្វើមិនឲ្យមានសេសសល់ដោយប្រពៃ ។ បទថា **រក្ខេយ្យ** បានដល់ ធ្វើការរក្សា ។ បទថា **គោបេយ្យ** បានដល់ គ្រប់គ្រងជានិច្ច ។ បទថា **បិទហេយ្យ** បានដល់ ធ្វើការបិទ ។ បទថា **បច្ឆិន្ទេយ្យ** បានដល់ កាត់ក្រសែ គឺតណ្ហា ។

[ ៣៦ ] បទថា **តេន តេន ន តុស្សន្តិ** បានដល់ មិនពេញចិត្តដោយរស មានរសជូរជាដើមនោះៗ ។ បទថា **អបរាបរំ បរិយេសន្តិ** បានដល់ រមែងស្វែងរករសក្រៃលែងឡើង ។

[ ៣៨ ] បទថា **ផស្សេន** បានដល់ ផស្សៈ គឺរោគ ។ បទថា **ភវញ្ច នាភិជប្បេយ្យ** បានដល់ មិនគប្បីប្រាថ្នាភព មានកាមភពជាដើម ដើម្បីបន្ទោបង់នូវផស្សៈនោះ ។ បទថា **ភេរវេសុ ច ន សម្បវេធេយ្យ** បានដល់ មិនគប្បីញាប់ញ័រព្រោះការតក់ស្លុត មានរាជសីហ៍និងខ្លាធំជាដើម ដែលជា

បច្ច័យនៃផស្សៈនោះ ឬមិនគប្បីញាប់ញ័រក្នុងអារម្មណ៍ ដែលជាវិស័យនៃយានិន្ទ្រិយនិងមនិន្ទ្រិយដ៏សេស ។ ដោយប្រការដូច្នេះឈ្មោះថា លោកពោលដល់ការសង្រួមឥន្ទ្រិយដោយបរិបូណ៌ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវការសង្រួមឥន្ទ្រិយដោយបទមុនហើយ ដោយបទនេះ ទើបទ្រង់សម្តែងថា ភិក្ខុនៅក្នុងព្រៃ បានឃើញ ឬបានឮវត្ថុដែលគួរខ្លាចមិនគប្បីញាប់ញ័រដូច្នេះ ។

[ ៤២ ] បទថា **ឃកេេឆាការេឆ** បានដល់ ដោយហេតុដូចគ្នា ។ បទថា **ភយម្បិ ភេរវម្បិ តញ្ញេវ** បានដល់ ភ័យក្តី ការខ្លាចក្តីទាំងតូចទាំងធំ ក៏ជានិមិត្តនៃការតក់ស្លុតដូចគ្នា ។ ដើម្បីសម្តែងសេចក្តីនោះ ទើបលោកពោលពាក្យជាដើមថា **វុត្តញ្ហេតំ** ដូច្នេះ ។ បទថា **ភយំ** បានដល់ ការខ្លាចកើតឡើងព្រោះរាជសីហ៍ជាដើមនោះជាហេតុ ។ បទថា **ភយានកំ** បានដល់ ការសម្តែងដល់អាការៈ ។ បទថា **ឆម្ភិតត្តំ** បានដល់ មានកាយញាប់ញ័រដោយអំណាចការខ្លាច ។ បទថា **លោមហំសោ** បានដល់ ព្រឺរោម គឺមានចុងរោមបះឡើង ។ ព្រះសារីបុត្តកាលសម្តែងភ័យដោយកិច្ច ដោយបទទាំង ២ នេះហើយសម្តែងទោសដោយសភាវៈទៀតថា ការតក់ស្លុត ការភ័យខ្លាចនៃចិត្ត ។ បទថា **ឧព្វេគោ** បានដល់ ការខ្លាច ។ បទថា **ឧត្រាសោ** បានដល់ ការកម្រើកនៃចិត្ត ។ បទថា **ជាតិភយំ** បានដល់ ភ័យកើតឡើងព្រោះអាស្រ័យជាតិ ។ ក្នុងបទដ៏សេសក៏មានន័យដូចគ្នា ។ ភ័យកើតអំពីព្រះរាជា ឈ្មោះថា **រាជភយំ** ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **អត្តានុវាទភយំ** បានដល់ ភ័យកើតអំពីការតិះដៀលខ្លួនឯងដែលធ្វើកម្មអាក្រក់ ។ បទថា **បរា–**

**ឆុវាទភយំ** បានដល់ ភ័យកើតអំពីការតិះដៀលរបស់អ្នកដទៃ ។

បទថា **ឧណ្ណភយំ** សេចក្តីថា សម្រាប់គ្រហស្ថ បានដល់ អាជ្ញាដែលព្រះរាជាត្រាស់ឲ្យដាក់ សម្រាប់បព្វជិត បានដល់ ភ័យដែលកើតព្រោះអាស្រ័យអាជ្ញាខាងព្រះវិន័យ ។ បទថា **ទុគ្គតិភយំ** បានដល់ ភ័យកើតឡើងព្រោះអាស្រ័យអបាយ ៤ ។ បទថា **ឧមិភយំ** បានដល់ ភ័យកើតដល់អ្នកចុះទឹកក្នុងសមុទ្ទ ។ បានឮថា ក្នុងសមុទ្ទមានរលកឈ្មោះថា **មហិន្ទ** ផុសឡើងប្រមាណ ៦០ យោជន៍ រលកឈ្មោះថា **អគ្គា** ផុសឡើង ៥០ យោជន៍ រលកឈ្មោះថា **រោហិណី** ផុសឡើងប្រមាណ ៤០ យោជន៍ ភ័យកើតព្រោះអាស្រ័យរលកបែបនេះ ឈ្មោះថា **ឧមិភយំ** ។ ភ័យកើតអំពីក្រពើ ឈ្មោះថា **កុម្ភីលភយំ** ។ ភ័យកើតអំពីទឹកក្ដួច ឈ្មោះថា **អាវដ្ដភយំ** ។ ត្រីកាចហៅថា **សុសុកា** ភ័យកើតអំពីត្រីកាចនោះ ឈ្មោះថា **សុសុកាភយំ** ។ បទថា **អាជីវកភយំ** បានដល់ ភ័យកើតអំពីការចិញ្ចឹមជីវិត ។ បទថា **អសិលោកភយំ** បានដល់ ភ័យកើតអំពីសេចក្តីតិះដៀល ។

[ ៤៣ ] បទថា **លទ្ធា ច សន្និធី កយិរា** បានដល់ ភិក្ខុបានយ៉ាងណាមួយ បណ្ដាបាយជាដើមទាំងនោះដោយធម៌ហើយមិនគួរគិតថា ភិក្ខុដែលនៅព្រៃបានវត្ថុដោយកម្រ ហើយធ្វើការសន្សំ ។

[ ៤៤ ] បទថា **ឱទនោ** បានដល់ បាយដែលកើតអំពីអង្ករបស់ស្រូវនិងអនុលោមដោយស្រូវ ៧ យ៉ាងគឺ ស្រូវសាលី ១ ស្រូវខ្សាយ ១ ស្រូវដំណើប ១ ស្រងែ ១ ប្លាំ ១ ស្គួយ ១ ស្មៅគែលលក ១ ។ បទថា

**កុម្មាសោ** បានដល់ នំដែលកើតអំពីអង្ករដំណើប ។ បទថា **សត្តុ** បានដល់ សដូវដែលធ្វើដោយស្រូវសាលីជាដើម ។ សត្វដែលកើតក្នុងទឹកឈ្មោះថាត្រី ។ បទថា **មំសំ** មានន័យជាក់ច្បាស់ហើយ ។ បទថា **អម្ពបានំ** បានដល់ ទឹកដែលធ្វើអំពីផ្លែស្វាយខ្ចីឬស្វាយទុំ ។ ក្នុងទឹកដែលធ្វើអំពីផ្លែស្វាយនោះ កាលធ្វើដោយផ្លែស្វាយខ្ចី គួរធ្វើដោយដំផ្លែស្វាយខ្ចី ហើយត្រាំទឹកហាលថ្ងៃ ត្រងលាយជាមួយទឹកឃ្មុំ ស្ករក្រាមនិងកប្បិរជាដើមដែលទទួលប្រគេនក្នុងថ្ងៃនោះ ។ បទថា **ជម្ពុបានំ** បានដល់ ទឹកដែលធ្វើអំពីផ្លែព្រីង ។ បទថា **ចោចបានំ** បានដល់ ទឹកដែលធ្វើដោយផ្លែចេកមានគ្រាប់ ។ បទថា **មោចបានំ** បានដល់ ទឹកដែលធ្វើដោយផ្លែចេកមិនមានគ្រាប់ ។ បទថា **មធុកបានំ** បានដល់ ទឹកធ្វើអំពីផ្លែស្រគំ ។ ម្យ៉ាងទៀតទឹកផ្លែស្រគំនោះ គួរលាយដោយទឹក បើយកទឹកដែលកើតក្នុងផ្លែសុទ្ធៗ មិនគួរ ។ បទថា **មុទ្ទិកបានំ** បានដល់ ទឹកដែលប្របាច់ផ្លែចាន់ក្នុងទឹក ធ្វើដូចទឹកផ្លែស្វាយ ។ បទថា **សាលូកបានំ** បានដល់ ទឹកដែលប្របាច់ក្រអៅឈូក មានឈូកក្រហមនិងឈូកខៀវជាដើម ។ បទថា **ផារុសកបានំ** បានដល់ ទឹកដែលធ្វើអំពីមាក់ប្រាង ប្របាច់ដូចគ្នានឹងទឹកផ្លែស្វាយ ។

បទថា **កោសម្ពបានំ** បានដល់ ទឹកដែលធ្វើដោយផ្លែសង្ក្រ័រ ។ បទថា **កោលបានំ** បានដល់ ទឹកដែលធ្វើដោយផ្លែពុទ្រាតូច ។ បទថា **ពទរបានំ** បានដល់ ទឹកផ្លែពុទ្រាធំដូចគ្នានឹងទឹកផ្លែស្វាយដែរ ។ ទឹកបាន ១១ យ៉ាងនេះ ត្រជាក់ក្តី ចម្អិនដោយកម្តៅព្រះអាទិត្យក្តីក៏គួរ ។ បទថា **ឃតបានំ** បានដល់

សប្បិ ។ បទថា **តេលចានំ** បានដល់ ប្រេងល្ងជាដើម ។ បទថា **បយោចានំ** បានដល់ ទឹក ។ បទថា **យាគុចានំ** បានដល់ ទឹកបបរ ដែលមានរសជូរជាដើម ។ បទថា **រសចានំ** បានដល់ ទឹកបានដែលធ្វើដោយរស មានរសបន្លែត្រាំជាដើម ។ បទថា **បិដ្ឋខជ្ជកំ** បានដល់ របស់គួរទំពាដែលធ្វើដោយម្សៅ មានម្សៅនៃធញ្ញជាតិ ៧ យ៉ាងនិងអបរណ្ណជាតិដែលអនុលោមតាមធញ្ញជាតិ ដូចជា ម្សៅខ្នុរ ម្សៅខ្នុរសម្ល ម្សៅម្កាក់ ម្សៅគ្រាប់ស្ពៃ ម្សៅវល្លិទឹកដោះជាដើម ។ សូម្បី **បូវខជ្ជក** ជាដើម ក៏ធ្វើដោយម្សៅទាំងនេះដូចគ្នា ។ បទថា **មូលខជ្ជកំ** បានដល់ របស់ទំពាដែលធ្វើដោយឈើ មានមើមត្រាវ មើមរាជព្រឹក្ស មើមជំឡូងជាដើម ។ បទថា **តចខជ្ជកំ** បានដល់ របស់ទំពាដែលធ្វើដោយសម្បកឈើ មានសម្បកអំពៅជាដើម ។ បទថា **បត្តខជ្ជកំ** បានដល់ របស់ទំពាដែលធ្វើដោយស្លឹកឈើ មានស្លឹកស្ពៅ ស្លឹកព្រះក្រុង[១]ស្លឹកបដោលៈ និងស្លឹកអញ្ចន់ខៀវជាដើម ។ បទថា **បុប្ផខជ្ជកំ** បានដល់ របស់ទំពាដែលធ្វើដោយផ្កាឈើមានផ្កាត្រាវ ផ្ការាជព្រឹក្ស ផ្កាជលា ផ្កាម្រុំ ផ្កាឧប្បល ផ្កាឈូកជាដើម ។ បទថា **ផលខជ្ជកំ** បានដល់ របស់ទំពាដែលធ្វើអំពីផ្លែឈើ មានខ្នុរ ខ្នុរសម្ល ដូង ម្កាក់ អម្ពិល ក្រូចព្រៃ ខ្វិត ឃ្លោក ត្រឡាច ទន្លាប់ ត្រសក់ត្រប់ ចេកមានគ្រាប់ ចេកមិនមានគ្រាប់ជាដើម ។

[ ៤៥ ] បទថា **ន កុហាណាយ** បានដល់ មិនមែនបានដោយការបំភាន់ ។

---

១-ព្រះក្រុងជាវល្លិម្យ៉ាង ដើមតូចៗ ស្លឹករាងមូលកំប៉ោះៗ គេយកស្លឹកវាមកប្រឡាក់ជាមួយទឹកកំបោរ ត្រងឲ្យស្អាតដាក់ក្នុងភាជនៈ វានឹងកកមានរសជាតល្វីងយឆ្ងាញ់ពិសា ។

- ៤៦៣ -



បទថា **ន លបនាយ** សេចក្តីថា មិនមែនដោយការនិយាយទាក់ដោយបច្ច័យ មិនមែនឃើញពួកមនុស្សមកវិហារ ហើយនិយាយកោសយ៉ាងនេះថា ពួកអ្នកមកដើម្បីអ្វី មកនិមន្តភិក្ខុឬ បើដូច្នោះពួកអ្នកត្រឡប់ទៅមុនចុះ អាត្មាយកបាត្រហើយនឹងទៅតាមក្រោយ ។ ម្យ៉ាងទៀតមិនមែនណែនាំខ្លួន ហើយពោលកោសយ៉ាងនេះថា អាត្មាឈ្មោះតិស្សៈ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងអាត្មា មហាមាត្យរបស់ព្រះរាជាអង្គនោះៗក៏ជ្រះថ្លាក្នុងអាត្មាដូច្នេះ ។ បទថា **ន នេមិត្តិកតាយ** បានដល់ មិនមែនបានដោយការធ្វើនិមិត្តដោយកាយ ឬវាចាណាមួយដល់អ្នកដទៃឲ្យកើតនូវការដឹង ហើយឲ្យបច្ច័យ ។ បទថា **ន និប្បេសិកតាយ** បានដល់ សម្តែងកិរិយាមានការជេរអ្នកដទៃជាដើមលោកហៅថា ការកម្ចាត់គុណអ្នកដទៃ ព្រោះកម្ចាត់ គឺគ្របសង្កត់នូវគុណរបស់អ្នកដទៃដោយសភាពមិនល្អដូចបោសដោយចម្រៀកឫស្សីតូចៗ ។ ម្យ៉ាងទៀតព្រោះការជាន់ឈ្លីគុណរបស់អ្នកដទៃឲ្យខ្ទេចខ្ទី ហើយស្វែងរកលាភ ដូចបុកគន្ធជាតិ ហើយរកក្លិនក្រអូបដូច្នោះ មិនមែនបានដោយកម្ចាត់គុណអ្នកដទៃបែបនោះ ។ បទថា **និជិគីសនតា** ក្នុងបទថា **ន លាភេន លាភំ និជិគីសនតាយ** បានដល់ ការស្វែងរក ។ ការស្វែងរកលាភដោយលាភ រមែងមានដោយការនាំលាភដែលបានហើយអំពីទីដទៃ ទៅដោះដូរក្នុងទីដទៃ មិនមែនបានដោយការស្វែងរកលាភបែបនេះ ។ បទថា **ន ទារុទានេន** បានដល់ មិនមែនបានដោយការឲ្យឈើ ដែលជាហេតុជាបច្ច័យ ។ ពិតណាស់មិនគួរឲ្យឈើក្នុងវិហារ ឬនាំមកពីទីដទៃ ហើយរក្សាគ្រប់គ្រងដល់ឧបដ្ឋាកទាំងឡាយ ដោយគិតថាឧបដ្ឋាកទាំងនេះ នឹងឲ្យបច្ច័យ

ដល់អញដោយអាការយ៉ាងនេះ ព្រោះកាលភិក្ខុសម្រេចជីវិតយ៉ាងនេះ ឈ្មោះថា រស់នៅដោយមិច្ឆាជីវៈ គឺការស្វែងរកដែលមិនសមគួរ ។ ភិក្ខុនោះរមែងបានទទួលនូវការតិះដៀល ក្នុងបច្ចុប្បន្ននិងត្រូវលិចចុះក្នុងអបាយ ក្នុងកពខាងមុខ ។ ភិក្ខុឲ្យឈើដែលជាចំណែករបស់ខ្លួន ដើម្បីសង្គ្រោះត្រកូលរមែងត្រូវអាបត្តិទុក្កដ ឈ្មោះថា **កុលទូសក** ឲ្យរបស់អ្នកដទៃដោយថេយ្យចិត្ត ត្រូវកាត់ជាភណ្ឌទេយ្យ គឺត្រូវសង ។ ក្នុងរបស់សង្ឃក៏មានន័យនេះដូចគ្នា ។ តែបើឲ្យរបស់នោះព្រោះខ្លួនជាអ្នកមានអំណាច រមែងត្រូវអាបត្តិត្រង់លះគរុភណ្ឌ ។ សួរថា ឈើយ៉ាងណាជាគរុភណ្ឌ ឈើយ៉ាងណាមិនជាគរុភណ្ឌ ឆ្លើយថា ឈើដែលមិនបានដាំក្នុងកាលមុនកើតឯងក្នុងអារាមសង្ឃកំណត់ខេត្តទុក នោះឯងជាគរុភណ្ឌ ក្រៅអំពីនោះទៅមិនមែនជាគរុភណ្ឌ ។ ឈើក្នុងទីដែលដាំ ក៏ជាគរុភណ្ឌទាំងអស់ មិនមានប្រមាណសូម្បីប៉ុនជន្លដែកចារក៏ជាគរុភណ្ឌ ។

ក្នុងបទទាំងឡាយ មានបទថា **ន វេឡុទានេន** ជាដើម ពាក្យថា មិនមែនបានដោយការឲ្យឫស្សី បានដល់ មិនមែនបានមកដោយការឲ្យឫស្សីជាហេតុជាបច្ច័យឡើយដោយន័យដែលពោលហើយក្នុងបទនេះថា **ន ទារុទានេន** ដូច្នេះ ។ ម្យ៉ាងទៀត ឫស្សីមានប្រមាណប៉ុននាឡិប្រេង ដោយប្រមាណជាគរុភណ្ឌ តូចជាងនោះមិនជាគរុភណ្ឌ ។ មនុស្សទាំងឡាយទៅវិហារសុំឫស្សី ភិក្ខុឲ្យមិនបានព្រោះជារបស់សង្ឃ មនុស្សទាំងឡាយអង្វរឬទទូចរឿយៗ ភិក្ខុទាំងឡាយគួរពោលថា ពួកលោកធ្វើទណ្ឌកម្ម ( ការងារឲ្យសង្ឃ ) ហើយកាន់យកចុះ ។ បើធ្វើយ៉ាងនេះឈ្មោះថា មិនបានឲ្យឫស្សី ។ បើមនុស្សទាំង

ឡាយនោះប្រគេនកាំបិតនិងពូថៅជាដើម ឬរបស់ទំពា របស់ឆាន់ ក៏មិនគួរទទួលតែលោកពោលទុកក្នុងអដ្ឋកថាវិន័យថា ពួកមនុស្សត្រូវភ្លើងឆេះផ្ទះ បើកាន់យកទៅមិនគួរហាម ។ បើខ្ទួតកើតត្រង់គុម្ពឫស្សីរបស់សង្ឃ បើមិនគោះខ្ទួតនោះចេញ ឫស្សីនឹងវិនាស គួរធ្វើដូចម្តេច គួរប្រាប់ពួកមនុស្សក្នុងពេលចេញបិណ្ឌបាត ។ បើពួកមនុស្សមិនប្រាថ្នានឹងគោះឲ្យគួរពោលថា ពួកអ្នកនឹងបានចំណែកស្មើៗគ្នា បើពួកមនុស្សមិនប្រាថ្នានោះឯងគួរប្រាប់ថា ពួកអ្នកនឹងបាន ២ ចំណែក សូម្បីយ៉ាងនេះពួកមនុស្សក៏នៅតែមិនប្រាថ្នាទៀត គួរពោលថា មិនមានប្រយោជន៍ដែលនឹងឲ្យវិនាស បើពួកអ្នកមានពេល ពួកអ្នកនឹងធ្វើទណ្ឌកម្ម ចូរគោះហើយយកទៅចុះ ។ បើធ្វើដូចពោលមកនេះឈ្មោះថា មិនបានឲ្យឫស្សី កាលគុម្ពឫស្សីត្រូវភ្លើងឆេះ ឬគុម្ពឫស្សីត្រូវទឹកកួចទៅ ក៏មានន័យដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យស្លឹកឈើព្រោះជាគរុភណ្ឌដូចតទៅនេះថា ក្នុងទីណាគេលក់ដូរស្លឹកឈើ បុគ្គលត្រូវការក្លិនជាដើម យកទៅដើម្បីអប់ក្លិនជាដើម ក្នុងទីដែលរកបានដោយក្រប៉ែបនោះស្លឹកឈើជាគរុភណ្ឌ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងស្លឹកចារនិងស្លឹកត្នោត ប្រើជាគ្រឿងប្រដាប់ត្រចៀកជាដើមមុន ។ ក្នុងស្លឹកត្នោត ក៏គួរពោលទុកក្នុងទីនេះដូចគ្នា ។ ព្រោះស្លឹកត្នោតក្នុងព្រៃត្នោតដែលកើតឯង ក៏ជាគរុភណ្ឌក្នុងទីដែលសង្ឃកំណត់ទុកដូចគ្នា ។ ក្រៅអំពីនោះទៅមិនជាគរុភណ្ឌឡើយ ។ ស្លឹកត្នោតដែលដាំទាំងអសក៏ជាគរុភណ្ឌ ។ ស្លឹករីតទទេប្រមាណ ៨ ធ្នាប់យ៉ាងតូច ក៏ជាប្រមាណគរុភណ្ឌនោះ សូម្បីស្មៅក៏

គួរនាំមក ពោលក្នុងទីនេះដូចគ្នា ក្នុងទីណាមិនមានស្មៅ មនុស្សទាំងឡាយក៏យកចំបើងនិងស្លឹកដូងបិទបាំងក្នុងទីនោះៗ ព្រោះហេតុនោះសូម្បីចំបើងនិងស្លឹកដូងទាំងនោះ ក៏សង្គ្រោះចូលដោយស្មៅបានដូចគ្នា ។ ដោយហេតុនេះបណ្តាស្មៅយាប្លងនិងចំបើងជាដើម ស្មៅឯណានីមួយ ប្រមាណមួយក្តាប់និងបណ្តាស្លឹកដូងជាដើម សូម្បីតែមួយធាងដែលគេប្រគេនដល់សង្ឃក្តី កើតឯងក្នុងទីនោះក្តី ស្មៅដែលកើតក្នុងដីរបស់សង្ឃក្រៅវត្តក្តី ស្មៅដែលសង្ឃរក្សាគ្រប់គ្រងហើយក្តីរមែងជាគរុភណ្ឌ ។ ម្យ៉ាងទៀតកាលសង្ឃធ្វើសង្ឃកម្មនិងចេតិយកម្មស្រេចហើយ ទោះឲ្យស្មៅដែលសល់ជាដើមនោះក្នុងបុគ្គលិកកម្ម ( ចំណែកបុគ្គល ) ក៏គួរ សូម្បីក្នុងឈើនិងឫស្សីដែលលោកពោលហើយខាងដើម ក៏មានន័យដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យផ្កាដូចតទៅនេះថា

ផ្ការមែងជាគរុភណ្ឌ ក្នុងទីដែលកំណត់ទុកយ៉ាងនេះថា ចូរលះផ្កាក្នុងដើមឈើប្រមាណប៉ុណ្ណេះហើយបង្អោនទៅដើម្បីបបរនិងភត្តក្នុងដើមឈើប្រមាណប៉ុណ្ណេះចូរបង្អោនទៅក្នុងការជួសជុលសេនាសនៈ ។ បើសាមណេរទាំងឡាយបេះផ្កាហើយធ្វើឲ្យជាគំនរ ភិក្ខុអ្នកចែកផ្កាប្រកបដោយអង្គ ៥ រាប់ចំនួនសង្ឃហើយធ្វើឲ្យជាចំណែកៗ ។ ភិក្ខុនោះ រមែងមិនចាំបាច់ប្រាប់សង្ឃក្នុងទីប្រជុំហើយឲ្យ ឯភិក្ខុដែលមិនទាន់បានទទួលសម្មតិគួរប្រាប់មុនហើយសឹមឲ្យ ភិក្ខុឲ្យផ្កាដល់បុគ្គលណាបាន ឲ្យដល់បុគ្គលណាមិនបាន ភិក្ខុទៅផ្ទះមាតាបិតា ហៅមាតាបិតាចេញអំពីផ្ទះ ហើយពោលថា សូមញោមយកផ្កាទៅបូជាព្រះដូច្នេះរមែងឲ្យបាន ដើម្បីយកទៅប្រដាប់សិរលិង្គរមែងមិនបាន ។ ម្យ៉ាងទៀតមិនគួរ

នាំទៅឲ្យញាតិដ៏សេស គួរហៅមកហើយសឹមឲ្យ ដើម្បីយកទៅបូជាព្រះ ។ កាលជនដ៏សេសទៅកាន់ទីបូជាព្រមគ្នា ភិក្ខុដែលមិនប្រាថ្នាការតបស្នង គួរឲ្យបាន ។ បើធ្វើដូចពោលមកនេះឈ្មោះថា មិនបានឲ្យនូវផ្កា ។

ផ្កាជាច្រើនក្នុងវិហាររីក ភិក្ខុត្រាច់បិណ្ឌបាតឃើញមនុស្សទាំងឡាយ គប្បីពោលថា ពួកអ្នកចូរបូជាផ្កាជាច្រើនក្នុងវិហារចុះ ត្រឹមតែពោលមិនមានទោស តែមិនគួរពោលដោយគិតថា ពួកមនុស្សនឹងកាន់យករបស់ទំពា របស់បរិភោគមកប្រគេន ។ បើភិក្ខុគិតហើយពោល មិនគួរឆាន់របស់ទំពារបស់បរិភោគ ។ ពួកមនុស្សសួរតាមធម្មតារបស់ខ្លួនថា ផ្កាក្នុងវិហារនៅមានឬ ហើយពោលបន្តថា ក្នុងថ្ងៃឈ្មោះនោះ ពួកខ្ញុំនឹងមកវិហារ លោកម្ចាស់ទាំងឡាយ កុំឲ្យសាមណេរបេះផ្កាឡើយ ។ ភិក្ខុភ្លេចប្រាប់សាមណេរៗក៏នាំគ្នាបេះផ្កា ពួកមនុស្សចូលទៅរកភិក្ខុពោលថា ក្នុងថ្ងៃនោះពួកខ្ញុំពិតលោកម្ចាស់ទាំងឡាយថា កុំឲ្យសាមណេរបេះផ្កា ហេតុអ្វីលោកម្ចាស់មិនឃាត់ ។ គួរពោលថា អាត្មាភ្លេចទៅហើយ ផ្កាគ្រាន់តែបេះប៉ុណ្ណោះមិនបានធ្វើនូវការបូជាឡើយ មិនគួរពោលថា ពួកអ្នកយកទៅបូជាចុះ ។ បើភិក្ខុពោលមិនគួរឆាន់អាហារ ។ ភិក្ខុមួយរូបទៀតប្រាប់ដល់សាមណេរទាំងឡាយថា អ្នកស្រុកនោះពោលថា ពួកលោកកុំបេះផ្កា សូម្បីមនុស្សទាំងឡាយនាំអាហារមកប្រគេនដល់លោក ហើយពោលថា ពួកមនុស្សរបស់ពួកខ្ញុំមិនច្រើន សូមលោកម្ចាស់ឲ្យសាមណេរទាំងឡាយបេះផ្កាជាមួយពួកខ្ញុំចុះ គួរពោលថា ឧបាសកពួកសាមណេរបានកិច្ចការហើយ ពួកដែលមិនទៅបិណ្ឌបាតនឹងដឹងដោយខ្លួនឯងដូច្នេះ បានន័យត្រឹមប៉ុណ្ណេះ ហើយ

ធ្វើសាមណេរដែលជាបុត្ត ឬជាបងប្អូនប្រុសឲ្យបេះនូវផ្កា មិនមានទោស បើធ្វើដូចពោលមកនេះឈ្មោះថា មិនបានឲ្យផ្កា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យផ្លែឈើ ដូចតទៅនេះថា ផ្លែឈើដែលកំណត់ទុកដូចផ្កាក៏ជាគរុភណ្ឌ កាលមានផលាផលច្រើនក្នុងវិហារ ពួកមនុស្សមិនមានការសប្បាយ គឺឈឺ នាំគ្នាមកសូម ភិក្ខុមិនហ៊ានឲ្យព្រោះជារបស់សង្ឃ ពួកមនុស្សក្តៅក្រហាយនាំគ្នាជេរប្រទេច គួរធ្វើដូចម្តេចក្នុងរឿងនោះ ។ គួរកំណត់ផ្លែឈើ ឬដើមឈើ ហើយធ្វើកតិកាថា ក្នុងដើមឈើនោះៗកាន់យកផ្លែឈើបានប្រមាណប៉ុណ្ណេះ ឬក្នុងដើមឈើប្រមាណប៉ុណ្ណេះកាន់យកផ្លែមិនបាន មិនគប្បីហាម ។ ពួកចោរឬឥស្សរជនកាន់យកដោយកម្លាំង មិនគួរហាមព្រោះជនទាំងនោះក្រោធហើយសូម្បីវិហារទាំងមូលក៏នឹងវិនាសតែគួរពោលដល់ទោស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យនូវគ្រឿងផ្ងូតដូចតទៅនេះថា លម្អិតដែលប្រើសម្រាប់ផ្ងូតទឹកបុកហើយមិនជាគរុភណ្ឌ សម្បកឈើដែលនៅលើដើមឈើជាគរុភណ្ឌ តែលម្អិតសម្រាប់ប្រើជ្រលក់គួរដល់ភិក្ខុមិនមានជំងឺ ។ លម្អិតគ្រប់យ៉ាងរមែងគួរដល់ភិក្ខុអ្នកមានជំងឺទាំងអស់ ។

ការឲ្យលម្អិតដើមប្រេសជាដើម មានន័យដូចពោលហើយ ក្នុងបទថា **ឧចុណ្ណទានេន** មិនមែនបានដោយការឲ្យលម្អិត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យដីស្អិតដូចតទៅនេះថា ក្នុងទីណារកដីស្អិតបានដោយកម្រ ដីស្អិតក្នុងទីនោះឯងជាគរុភណ្ឌ ។ ដីស្អិតនោះដោយហោចមានប្រមាណប៉ុនដុំស្ករអំពៅទម្ងន់ ៣០ បលៈ តូចជាងនោះមិនជាគរុភណ្ឌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យឈើស្ទន់ ដូចតទៅនេះថា ឈើស្ទន់ដែលមិនបានកាត់ជាគរុភណ្ឌ សង្ឃប្រគល់ភារៈដែលធ្វើឈើស្ទន់ ដល់សាមណេរពួកណា សាមណេរពួកនោះឲ្យចំពោះដល់អាចារ្យនិងឧបជ្ឈាយ៍របស់ខ្លួនមិនបាន ។ ម្យ៉ាងទៀតសាមណេរពួកណា បានទទួលកំណត់ទុកថា គប្បីនាំឈើស្ទន់មកប្រមាណប៉ុណ្ណេះ សាមណេរទាំងនោះ ទោះឲ្យឈើស្ទន់ចំណែកដែលលើសដល់អាចារ្យនិងឧបជ្ឈាយ៍ ក៏បាន ។ ភិក្ខុមួយរូបមិនគួរកាន់យកឈើស្ទន់មកអំពីរោងរក្សាឈើស្ទន់ គួរកាន់យក ១ កំណាត់ប៉ុណ្ណោះរាល់ៗថ្ងៃ ។ ភិក្ខុមួយរូបដែលគេចចេញទៅតែឯង រាប់ភិក្ខុសង្ឃហើយ គួរកាន់យកឈើស្ទន់ដែលដល់លំដាប់ខ្លួនប៉ុណ្ណោះ ។ កាលភិក្ខុអាគន្តុកកំពុងមកក្នុងចន្លោះ ឬមកហើយលាទៅ គប្បីនាំឈើស្ទន់មកទុកក្នុងទី ដែលអាគន្តុកភិក្ខុនោះអាចចាប់យកទៅបាន ។ បទថា **ន មុខោទកគណ្ឌុសកេន** បានដល់ មិនមែនបានដោយការឲ្យទឹកលុបមុខ ។

ក្នុងបទថា **ន ចាដុកម្យតាយ** ជាដើមមានវិនិច្ឆ័យដូចតទៅនេះថា វាចាដែលដាក់ខ្លួនទុកក្នុងទីទាប ដូចជាទាសៈ ហើយសរសើរពាក្យដែលអ្នកដទៃពោល សូម្បីភ្ញាំងភ្ញាត់ដោយបំណងឲ្យគេស្រឡាញ់ខ្លួន ហៅថា **ចាដុកម្យតា-យ** ។ បទថា **មុគ្គសូបតាយ** បានដល់ ឈ្មោះថា ពាក្យឡេះឡោះព្រោះវាចានោះដូចសម្លស្លណ្តែកបាយ ព្រោះហេតុនោះពាក្យថា **មុគ្គសូបតាយ** នេះជាឈ្មោះនៃការសម្រេចជីវិតរស់នៅបាន ដោយវាចាឡេះឡោះ ក្នុងបុគ្គលដែលរស់នៅបានដោយវាចាឡេះឡោះ មានវាចាឡេះឡោះច្រើន មានពាក្យពិតតិច

ដូចសម្ផសំណេ្តកបាយ សំណេ្តកបាយដោយច្រើនផ្អិន តិចតួចតៅដូច្នោះ ឬឈ្មោះថា អ្នកពោលវាចាឡេះឡោះ មិនមានការប្រឌិតរឿង មិនមានដូចសម្ផសំណេ្តកបាយ មិនជាសម្ផ រមែងមិនមាន ។ បុគ្គលពោលពាក្យឡេះឡោះ រមែងតាំងនៅក្នុងផ្លូវដែលខ្លួនប្រាថ្នាហើយ ដូចផ្លូវដែលបែកជា ៤ ដូច្នោះ ។ ដោយហេតុនោះភាពដែលបុគ្គលនោះពោលកុហកលោកហៅថា **មុគ្គសូបតា** ។ បទថា **ន ចារិភដ្យតាយ** បានដល់ មិនមែនបានដោយភាពជាអ្នកបម្រើ ។ ការងាររបស់អ្នកបម្រើ ឈ្មោះថា **ចារិភដ្យ** ។ ភាពនៃ **ចារិភដ្យ** ឈ្មោះថា **ចារិភដ្យតា** ។ បទនេះជាឈ្មោះនៃការលេងឲ្យរបស់ក្មេង ដោយការធ្វើគ្រឿងប្រដាប់ជាដើម ។ បទថា **ន បីឋមទ្ទិកតាយ** បានដល់ មិនមែនប្រើបានដោយភាពជាអ្នកប្រញាប់ប្រញាល់ចូលទៅកាន់ផ្ទះ ហើយអង្គុយលើគ្រែ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ន វត្ថុវិជ្ជាយ** ដូច្នេះជាដើមដូចតទៅនេះថា តម្រាដឹងដល់ការស្តុកស្តម្ភនិងមិនស្តុកស្តម្ភ របស់ស្រុកនិគមនិងនគរជាដើម ឈ្មោះថា **វត្ថុវិជ្ជា** ។ វិជ្ជាដ៏សេសមានតម្រាពោលអំពីលក្ខណៈនិងតម្រាទាយយល់សប្តិជាដើម ដែលរារាំងនូវផ្លូវសួគ៌និងផ្លូវទៅកាន់ការរួចផុត ព្រោះមិននាំសត្វចេញទៅអំពីទុក្ខបាន ឈ្មោះថា **តិរច្ឆានវិជ្ជា** ។ ការដឹងលក្ខណៈមានបុណ្យ មិនមានបុណ្យរបស់ស្ត្រីនិងបុរស ឈ្មោះថា **អង្គវិជ្ជា** ។ តម្រាដឹងការប្រកបរបស់នក្ខត្តឫក្សទាំងឡាយ ឈ្មោះថា **នក្ខត្តវិជ្ជា** ។

បទថា **ន ទូតគមនេន** បានដល់ មិនមែនទៅធ្វើជាទូតកម្ម ។ បទថា **ន បហិណគមនេន** បានដល់ មិនមែនដោយការទទួលដំណឹងរបស់គ្រហស្ថ

ហើយចេញអំពីផ្ទះបញ្ជូនទៅកាន់ផ្ទះ ។ បទថា **ន ជង្ឃបេសនិយេន** បានដល់ មិនមែនបានដោយការនាំដំណឹងនិងតបដំណឹង របស់គ្រហស្ថនោះៗ ក្នុងចន្លោះស្រុកនិងក្នុងចន្លោះតំបន់ជាដើម ។ ឈ្មោះថា **ជង្ឃបេសនិយំ** នេះសមគួរដោយការទទួលដំណឹងរបស់មាតាបិតារបស់ខ្លួននិងរបស់អ្នក ដែលបម្រើមាតាបិតារបស់ភិក្ខុនោះ ហើយបញ្ជូនទៅឲ្យក្នុងទីណាមួយ ។ ការនាំដំណឹងរបស់ជាងឈើដែលធ្វើការងារដល់ចេតិយក្តី ដល់សង្ឃក្តី ដល់ខ្លួនក្តី គួរ ។ មនុស្សទាំងឡាយពោលថា ខ្ញុំនឹងឲ្យទាន ខ្ញុំនឹងធ្វើការបូជា សូមលោកម្ចាស់ប្រាប់ដល់ភិក្ខុសង្ឃដូច្នេះ ប្រគេនបិណ្ឌបាត ថ្នាំឬចីវរ ដោយពោលថា សូមលោកម្ចាស់ប្រគេនដល់ភិក្ខុរូបនោះ ប្រគល់ផ្កា គ្រឿងក្រអូប គ្រឿងលាបជាដើមឬទង់ជ័យទង់ផ្កាលាជាដើមឲ្យដោយពោលថា សូមលោកម្ចាស់ធ្វើនូវការបូជាដូច្នេះ នាំវត្ថុទាំងអស់នេះទៅក៏គួរ មិនឈ្មោះថាជាអ្នកនាំដំណឹងឡើយ ។ កាលភិក្ខុនាំដំណឹងខាងក្រៅអំពីទីនេះ ត្រូវអាបត្តិទុក្កដគ្រប់ៗជំហាន ។

បទថា **ន វេជ្ជកម្មេន** បានដល់ មិនមែនបានដោយភាពជាពេទ្យផ្សំថ្នាំព្យាបាលរាងកាយជាដើម តែគួរផ្សំថ្នាំដល់សហធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ។ ព្រោះមិនផ្សំថ្នាំដល់សហធម្មិកទាំងនោះ បុគ្គលដែលមានសីល សទ្ធានិងបញ្ញាស្មើគ្នា ជាអ្នកប្រកបហើយក្នុងត្រៃសិក្ខាមិនបាន បើផ្សំថ្នាំដល់បុគ្គលទាំង ៥ គឺមាតាបិតា អ្នកបម្រើមាតាបិតា ខ្លួនឯង វេយ្យាវច្ចៈនិងបព្វជ្ជាបេក្ខៈក៏គួរ ។ កាលភិក្ខុផ្សំថ្នាំឲ្យដល់ជន ១០ ពួក គឺបងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី ប្អូនស្រីរបស់មាតា បងស្រីរបស់មាតាបិតា

ប្អូនប្រុសរបស់បិតា បងប្រុសរបស់មាតាបិតា ប្អូនស្រីរបស់បិតា ប្អូនប្រុសរបស់មាតា[១]គួរកាន់យកកេសជ្ជៈ ដែលជារបស់ជនទាំងនោះផង់ឲ្យតែម្យ៉ាង ។ បើមិនគ្រប់គ្រាន់គួរឲ្យរបស់ខ្លួន ធ្វើឲ្យជារបស់ខ្ចី ។ កាលកិក្ខុឲ្យនាំបច្ច័យ ៤ របស់ជនទាំងនោះមក បន្តមកតាំងអំពីកូនរហូតដល់ ៧ ជួរត្រកូល ឈ្មោះថា មិនជាការធ្វើវិញ្ញត្តិ កាលកិក្ខុផ្សំថ្នាំឲ្យដល់ជនទាំងនោះ ក៏មិនចាត់ជាវេជ្ជកម្មឬមិនជាអាបត្តិ ព្រោះទ្រុសត្រកូល ។ បទថា **ន បិណ្ឌបដិបិណ្ឌកេន** នេះ គួរឲ្យដុំបាយដល់អ្នកណា មិនគួរឲ្យដល់អ្នកណា ។ គួរឲ្យដល់មាតាបិតា អ្នកបម្រើមាតាបិតា វេយ្យាវច្ចករនិងបព្វជ្ជាបេក្ខៈ ចោរដែលមកប្រឈមមុខនិងឥស្សរជន ។ សូម្បីឲ្យដល់ជនទាំងនេះ ហើយត្រឡប់បានក្នុងកាលខាងក្រោយ ក៏មិនជាការឲ្យដុំបាយតបស្នងដុំបាយ ។

បទថា **ន នានានុប្បទានេន** បានដល់ មិនមែនបានដោយការតបស្នងដល់បុគ្គលដែលឲ្យដល់ខ្លួន ។ បទថា **ធម្មេន** បានដល់ កើតឡើងដោយធម៌ ។ បទថា **សមេន** បានដល់ ដោយកាយទុច្ចរិតជាដើម ។ បទថា **លទ្ធា** បានដល់ បានហើយផ្លូវកាយ ។ បទថា **លភិត្វា** បានដល់ ដល់ហើយផ្លូវចិត្ត ។ បទថា **អធិគន្ត្វា** បានដល់ សម្រេចហើយ ។ បទថា **វិន្ទិត្វា** បានដល់ ជួបប្រទះហើយដោយញាណ ។ បទថា **បដិលភិត្វា** បានដល់ បានរឿយៗ ។

---

១-ក្នុងបុគ្គលទី ១០ បាលីអដ្ឋកថាថា មាតុច្ឆា ប្រែថា ប្អូនស្រីរបស់មាតា ឯក្នុងអដ្ឋកថាព្រះវិន័យ ត្រង់អធិប្បាយតតិយបារាជិកជា បិតុលា ទេ ដែលប្រែថា ប្អូនប្រុសរបស់មាតា ឃើញថាត្រូវជាង បណ្ឌិតគប្បីជ្រាប ។

ក្នុងបទថា **អន្តសន្និធិ** នេះ គប្បីជ្រាបកថា ២ យ៉ាងគឺ ដោយផ្លូវវិន័យ និងផ្លូវនៃការជុសខាត់កិលេសដូចតទៅនេះថា គប្បីជ្រាបតាមផ្លូវព្រះវិន័យមុន បាយឯណានីមួយ ដែលបានទទួលក្នុងថ្ងៃនេះ ក្នុងថ្ងៃដទៃរាប់ថាជារបស់ដែលសន្សំហើយត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បាយនោះ ។ តែបើឲ្យបាយដែលខ្លួនបានដល់សាមណេរទាំងឡាយ ហើយរក្សាបាយដែលសាមណេរទាំងនោះបានទុកឆាន់ក្នុងថ្ងៃទី ២ ក៏គួរ តែមិនជាការជុសខាត់កិលេស ។ ក្នុងការសន្សំទឹកផឹកក៏មានន័យដូចគ្នា ។ ឈ្មោះថា **បាន** ក្នុងបទនេះបាន ៨ យ៉ាង មានទឹកបានធ្វើដោយផ្លែស្វាយជាដើមនិងទឹកបាន ដែលអនុលោមចូលគ្នាបានជាមួយទឹកបានទាំងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វត្ថសន្និធិ** ជាដើមដូចតទៅនេះថា សំពត់ដែលមិនបានអធិដ្ឋាននិងមិនបានវិកប្ប ចាត់ជាសន្និធិនិងធ្វើសល្លេខបដិបត្តិឲ្យកម្រើកនេះពោលដោយត្រង់ តែបើពោលដោយអម ភិក្ខុគួរជាអ្នកសន្តោសក្នុងចីវរ ។ ក្នុងចីវរ ៣ បានផ្ទាំងទី ៤ មកគួរឲ្យដល់ភិក្ខុដទៃ បើមិនអាចឲ្យដល់ភិក្ខុរូបណាមួយបាន បំណងនឹងឲ្យដល់រូបណា រូបនោះទៅដើម្បីរៀន ឬដើម្បីសាកសួរ គួរឲ្យក្នុងពេលដែលលោកត្រឡប់មក ។ មិនឲ្យមិនគួរ ។ ម្យ៉ាងទៀតកាលចីវរមិនគ្រប់គ្រាន់ តែនៅមានការសង្ឃឹមថានឹងបានបន្ថែមទៀត ទោះរក្សាទុកអស់កាលដែលព្រះមានព្រះភាគអនុញ្ញាតក៏គួរ កាលមិនមានម្ជុល អំបោះនិងភិក្ខុដែលជួយធ្វើចីវរ សូម្បីបន្តអំពីនោះ ក៏គួរធ្វើវិនយកម្មរក្សាទុក តែមិនគួររក្សាទុកដោយគិតថា កាលចីវរចាស់ អញនឹងបានចីវរបែបនេះអំពី

ណាទៀតហ្ន៎ ។ ទាំងជាការសន្សំ ទាំងញុំាងសល្លេខប្បដិបត្តិឲ្យកម្រើក ។

គប្បីជ្រាបអធិប្បាយក្នុងការសន្សំយានដូចតទៅនេះថា ឈ្មោះថា **យាន** បានដល់ រ រថ រទេះ រថទ្រទ្រង់គ្រឿង អង្រឹងស្នែង គ្រែស្នែង ។ នុ៎ះមិនមែនជាយានរបស់បព្វជិត តែស្បែកជើងចាត់ជាយាន ។ ស្បែកជើង ២ គូយ៉ាងឧក្រិដ្ឋគួរដល់ភិក្ខុមួយរូប គឺមួយគូសម្រាប់ទៅព្រៃ មួយគូសម្រាប់ជើងដែលលាងហើយ បើបានគូទី ៣ គួរឲ្យដល់ភិក្ខុរូបដទៃ ។ មិនគួររក្សាទុកដោយគិតថា កាលស្បែកជើងចាស់ អញនឹងបានស្បែកជើងដទៃអំពីណាទៀត ទាំងជាការសន្សំ និងទាំងញុំាងសល្លេខប្បដិបត្តិឲ្យកម្រើក ។

គប្បីជ្រាបអធិប្បាយក្នុងការសន្សំទីដេក ដូចតទៅនេះថា បទថា **សយនំ** បានដល់ គ្រែ ។ គ្រែ ២ យ៉ាងឧក្រិដ្ឋ រមែងគួរដល់ភិក្ខុមួយរូប គឺក្នុងបន្ទប់ ១ ក្នុងទីសម្រាកពេលថ្ងៃ ១ ។ បើបានច្រើនជាងនោះ គួរឲ្យដល់ភិក្ខុដទៃឬដល់គណៈ មិនឲ្យមិនគួរ ជាការសន្សំផងនិងញុំាងសល្លេខប្បដិបត្តិឲ្យកម្រើកផង ។

គប្បីជ្រាបអធិប្បាយក្នុងការសន្សំគ្រឿងក្រអូបដូចតទៅនេះថា កាលមានអាពាធដោយរោគបូស រមាស់ដែលជាទោសដល់ស្បែកជាដើម គ្រឿងក្រអូបរមែងគួរដល់ភិក្ខុ កាលរោគស្ងប់ដោយគ្រឿងក្រអូបនោះ គួរឲ្យដល់ភិក្ខុអាពាធរូបដទៃ ឬនាំយកទៅប្រោះផ្ទះត្រង់ទ្វារ ។ មិនគួររក្សាទុកដោយគិតថា ដើម្បីប្រើក្នុងកាលមានរោគទៀត ជាការសន្សំផង ញុំាងសល្លេខប្បដិបត្តិឲ្យកម្រើកផង ។

គប្បីជ្រាបបទថា **អាមិសំ** ជាដើម គឺរបស់ក្រៅអំពីដែលពោលហើយ

ដូចជាភិក្ខុរបខ្វះក្នុងធម្មវិន័យនេះឲ្យនាំមកនូវល្ង អង្ករ សណ្តែកបាយ សណ្តែករាជមាស ដូង អំបិល ត្រី សាច់ងៀត សប្បិ ប្រេង ភាជនដីជាដើម មករក្សាទុកដោយគិតថា របស់ទាំងនេះនឹងមានប្រយោជន៍ក្នុងកាលនោះៗ ភិក្ខុនោះក្នុងរដូវភ្លៀងឲ្យសាមណេរដាំបបរអំពីព្រឹកហើយឆាន់ បញ្ជូនសាមណេរទៅថា សាមណេរការចូលទៅស្រុក ក្នុងខណៈមានភ្លៀងធ្លាក់ខ្លាំងលំបាក ចូរអ្នកទៅកាន់ត្រកូលនោះប្រាប់ថា ខ្ញុំមកអង្គុយក្នុងវិហារហើយ អ្នកចូរនាំទឹកដោះជូរជាដើម មកអំពីត្រកូលនោះដូច្នេះ ។ កាលភិក្ខុទាំងឡាយសួរថា ហេតុអ្វីលោកមិនចូលទៅកាន់ស្រុក ភិក្ខុនោះឆ្លើយថា ឥឡូវនេះស្រុកនោះចូលទៅលំបាក ភិក្ខុទាំងនោះពោលថា មិនជាការថ្មីឡើយ លោកនៅចុះ ពួកខ្ញុំនឹងរកភិក្ខាមកឯង ហើយនាំគ្នាទៅ ។ លំដាប់នោះសាមណេរនាំទឹកដោះជូរជាដើមមកនាំចូលទៅប្រគេនព្រមទាំងកត្តនិងម្ហូប កាលភិក្ខុឆាន់អាហារនោះឯង ពួកឧបដ្ឋាកក៏បញ្ជូនកត្តមកប្រគេន ។ បន្ទាប់អំពីនោះភិក្ខុនោះក៏ឆាន់យ៉ាងឆ្ងាញ់ ។ បន្ទាប់មកភិក្ខុទាំងឡាយទទួលបិណ្ឌបាតហើយត្រឡប់មក ភិក្ខុនោះក៏នៅតែឆាន់ឲ្យឆ្អែតស្កប់ស្កល់នោះឯង សូម្បី ៤ ខែកន្លងទៅ ភិក្ខុនេះលោកហៅថា មានជីវិតនៅដូចកុដុម្ពិកៈក្បាលត្រងោល មិនមែននៅដូចសមណៈ ។ ភិក្ខុបែបនេះឈ្មោះថា ជាអ្នកសន្សំអាមិស ។ តែក្នុងលំនៅរបស់ភិក្ខុ គួររក្សាអាមិសមានប្រមាណប៉ុណ្ណេះ គឺអង្ករមួយនាឡិ ស្ករអំពៅ ១ ដុំ សប្បិប្រមាណ ៤ ចំណែកដើម្បីជាប្រយោជន៍ ដល់ចោរដែលមកដល់ខុសកាល ។ ព្រោះចោរទាំងនោះកាលមិនបានបដិសណ្ឋារៈដោយអាមិស ក៏នឹងសម្លាប់ចោល ព្រោះហេតុនោះ

បើមិនមានអាមិសប៉ុណ្ណោះ ក៏គួររកមករក្សាទុក ។ ម្យ៉ាងទៀត ក្នុងពេលមានជំងឺ នឹងបាន់អាមិសដែលជាកប្បិយដោយខ្លួនឯងក៏គួរ ។ ម្យ៉ាងទៀតសូម្បីរក្សាអាមិសច្រើនក្នុងកប្បិយកុដិ ក៏មិនជាការសន្សំ ។

[ ៤៧ ] បទថា **ឈាយី ន បាទលោលស្ស** សេចក្តីថា ភិក្ខុគប្បីជាអ្នកត្រេកអរក្នុងឈាននិងមិនគប្បីជាអ្នកឡេះឡោះព្រោះជើង ។ បទថា **វិរមេ កុក្កុច្ចា នប្បមជ្ជេយ្យ** បានដល់ គប្បីបន្ទោបង់នូវការថ្កាំថ្កងមានថ្កាំថ្កងដៃជាដើម និងមិនគប្បីប្រមាទក្នុងរឿងនេះ ដោយការធ្វើ ដោយគោរពជាដើម ។

[ ៤៨ ] បទថា **ឯកគ្គមនុយុត្តោ** បានដល់ ខ្វល់ខ្វាយក្នុងភាពជាអ្នកមានអារម្មណ៍តែ ១ ។ បទថា **បរមត្ថគរុកោ** បានដល់ ធ្ងន់ក្នុងប្រយោជន៍ដ៏ឧត្តម ។ បាឋៈថា **សកត្ថគរុកោ** ក៏មាន ។ គប្បីជ្រាបបទថា **បដិសល្លានារាមោ** ដូចតទៅនេះថា ការពេញចិត្តឈ្មោះថា **អារាម** ។ ភិក្ខុដែលនាំចិត្តចេញចាកអារម្មណ៍នោះៗ ហើយពេញចិត្តក្នុងការពួនសម្ងំក្នុងភាពមានអារម្មណ៍តែមួយ ឈ្មោះថា **បដិសល្លានារាមោ** ។ បទថា **អស្ស** គឺ **ភវេយ្យ** ។ ភិក្ខុត្រេកអរហើយក្នុងការពួនសម្ងំនោះឈ្មោះថា **បដិសល្លានរតោ** ។ លោកសម្តែងដល់ ភាពជាអ្នកបរិបូណ៌ក្នុងសីលទាំងឡាយ ដោយបទទាំងនេះ ។ សេចក្តីនោះព្រោះហេតុអ្វី ព្រោះភាពមានអារម្មណ៍តែមួយ រមែងមិនសម្រេចដល់ភិក្ខុដែលមានសីលវិបត្តិ ។ បទថា **អជ្ឈត្តំ ចេតោសមថមនុយុត្តោ** បានដល់ ខ្វល់ខ្វាយក្នុងការស្ងប់ចិត្ត របស់ខ្លួន ។ ក្នុងទីនេះ បទថា **អជ្ឈត្តំ** ក្តី **អត្តនោ** ក្តី មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ បទថា **អជ្ឈត្តំ**

នេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ប្រែថា ក្នុងខាងក្នុងសម្រេចរូប ដោយការប្រកបដោយឧបសគ្គនេះថា **អនុ** ។ បទថា **អនិរាកតជ្ឈានោ** បាន ដល់ មិននាំឈានចេញទៅខាងក្រៅ ឬមិនញុំាងឈានឲ្យវិនាស ។ ឈ្មោះ ថា **និរាករណំ** នេះមានអត្ថថា ការនាំចេញ ការធ្វើឲ្យវិនាស ។ ម្យ៉ាងទៀត គប្បីឃើញការប្រើពាក្យក្នុងប្រយោគជាដើមថា បុគ្គលគួរធ្វើការរឹងត្អឹងឲ្យជ្រះ ស្រឡះ ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា **វិបស្សនាយ សមន្នាគតោ** បានដល់ ប្រកបដោយអនុបស្សនា ៧ យ៉ាង ។

អនុបស្សនា ៧ គឺអនិច្ចានុបស្សនា ១ ទុក្ខានុបស្សនា ១ អនត្តានុបស្សនា ១ និព្វិទានុបស្សនា ១ វិរាគានុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គា នុបស្សនា ១ អនុវិបស្សនាទាំងនោះ ពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **ព្រូហេតា សុញ្ញាគារានំ** បានដល់ ចម្រើននូវសុញ្ញាគារ ។ ក្នុងបទនេះ គប្បីជ្រាបថា ភិក្ខុរៀនកម្មដ្ឋាន ទាំងសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋានហើយ ចូលទៅអង្គុយត្រង់សុញ្ញាគារអស់យប់និងថ្ងៃឈ្មោះថា ចម្រើននូវសុញ្ញាគារ ។ សូម្បីបំពេញក្នុងប្រាសាទដែលមានជាន់មួយជាដើម ក៏គប្បីឃើញថាចម្រើននូវ សុញ្ញាគារ ។

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សក្កច្ចការី** ជាដើម ដូចតទៅនេះ ថា គប្បីជាអ្នកធ្វើដោយការអើពើដោយអំណាចធ្វើដោយគោរព ចំពោះបុគ្គល ឬចំពោះទេយ្យធម៌ដើម្បីបំពេញកុសលធម៌ មានទានជាដើម ។ បទថា **អស្ស** គឺកវេយ្យ ។ ការជាប់តឈ្មោះថា **សាតច្ចំ** ។ ឈ្មោះថា **សាតច្ចការី** ព្រោះ

ភាពជាអ្នកធ្វើជាប់ត ។ ឈ្មោះថា **អដ្ឋិតការី** ព្រោះភាពជាអ្នកធ្វើជាប់តមិនមានចន្លោះ បុគ្គលណាឲ្យទាន ធ្វើនូវការបូជា ស្តាប់ធម៌ឬបំពេញសមណធម៌មួយថ្ងៃ អស់កាលយូរទើបធ្វើទៀត មិនប្រព្រឹត្តទៅជាប់តគ្នា បុគ្គលនោះលោកហៅថា **ឋិតការី** ដូចបង្កួយរត់ទៅបានបន្តិច ហើយឈប់បន្តិច មិនរត់តទៅដូច្នោះ ចំណែកបុគ្គលណាមិនធ្វើយ៉ាងនោះ បុគ្គលនោះឈ្មោះថា **អដ្ឋិតការី** ។ បទថា **អនោលីនវុត្តិកោ** បានដល់ មានការប្រព្រឹត្តធូរថយក៏មិនមែន ព្រោះមានការពង្រីកចេញទៅ បានដល់ ធ្វើជាប់តគ្នាទៅ ។ បទថា **អនិក្ខិត្តច្ឆន្ទោ** បានដល់ ឈ្មោះថា មិនដាក់ឆន្ទៈ ព្រោះភាពជាអ្នកមិនលះបង់ឆន្ទៈក្នុងការធ្វើសេចក្តីព្យាយាមដើម្បីធ្វើកុសល ។ បទថា **អនិក្ខិត្តធុរោ** បានដល់ មិនដាក់ចុះនូវធុរៈក្នុងការធ្វើសេចក្តីព្យាយាម អធិប្បាយថា មិនមានចិត្តរាថយ ។

បទថា **អប្បដិវានី** បានដល់ មិនត្រឡប់ ។ បទថា **អធិដ្ឋានំ** បានដល់ មានការតាំងចិត្តមាំក្នុងការធ្វើកុសល ។ បទថា **អនុយោគោ** បានដល់ ការប្រកបរឿយៗ ។ បទថា **អប្បមាទោ** បានដល់ ការមិននៅប្រាសចាកសតិ ។

[ ៥១ ] បទថា **តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ** បានដល់ សេចក្តីខ្ជិលច្រអូស ការបោកបញ្ឆោត ការសើច ការលេងផ្លូវកាយនិងផ្លូវវាចា ។ បទថា **សវិភូសំ** បានដល់ ជាមួយនឹងគ្រឿងប្រដាប់ ។

[ ៥២ ] បទថា **រត្តិន្ទិវំ ឆកោដ្ឋាសំ ករិត្វា** បានដល់ គប្បីចែកឲ្យជា ៦ ចំណែក ពេលយប់ ៣ ចំណែក គឺបឋមយាម មជ្ឈិមយាមនិងបច្ឆិមយាម ពេលថ្ងៃក៏ដូចគ្នា ។ បទថា **បញ្ចកោដ្ឋាសំ ជាគរេយ្យ** បានដល់ គប្បីលះ

យាមកណ្ដាលក្នុងរាត្រី[១]ហើយមិនដេកលក់ក្នុងចំណែក ៥ ដ៏សេស ។ បទថា **ឯកកោដ្ឋាសំ និបជ្ជេយ្យ** បានដល់ មានសតិសម្បជញ្ញៈ ដេកលក់ក្នុងមជ្ឈិមយាមមួយចំណែក ។

[ ៥៣ ] បទថា **ឥធ ភិក្ខុ ទិវសំ** បានដល់ ចែកពេលថ្ងៃជា ៣ ចំណែក គឺពេលព្រឹក ពេលថ្ងៃត្រង់និងពេលល្ងាច ។ បទថា **ចង្កមេន និសជ្ជាយ** បានដល់ បរិហារដោយឥរិយាបថទាំង ២ នេះអស់ថ្ងៃទាំងមូលដោយហាមចិត្តចាកធម៌ជាគ្រឿងរាំងចិត្ត គឺនីវរណៈ ៥ ឬចាកអកុសលធម៌ទាំងពួង ។ បទថា **ចិត្តំ បរិសោធេយ្យ** បានដល់ គប្បីជម្រះចិត្តឲ្យបរិសុទ្ធិចាកធម៌ទាំងនោះ ។ ក្នុងទីនេះមិនបានកំណត់ការឈរក៏ពិតតែក៏គួរកំណត់យកការឈរ ដែលបន្ថែមក្នុងការដើរចង្ក្រមនិងការអង្គុយនោះឯង ។ បទថា **បឋមំ យាមំ** បានដល់ក្នុងបឋមយាមទាំងមូល ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **សេយ្យំ** ដូចតទៅនេះថា ការដេកមាន ៤ យ៉ាង គឺកាមភោគីសេយ្យា ១ បេតសេយ្យា ១ សីហសេយ្យា ១ តថាគតសេយ្យា ១ ។

ក្នុងការដេក ៤ យ៉ាងនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយពួកអ្នកបរិភោគកាមច្រើនតែដេកផ្អៀងទៅខាងឆ្វេង នេះឈ្មោះថា **កាមភោគីសេយ្យា** ។ ពិតហើយបុគ្គលបរិភោគកាមទាំងនោះ រមែងមិនដេកផ្អៀងទៅខាងស្ដាំ ។ ម្នាលភិក្ខុទាំងឡាយប្រេតច្រើនតែដេកផ្ងារ នេះឈ្មោះថា **បេត-**

១-ដេកក្នុងមជ្ឈិមយាម ។

**សេយ្យា** ។ ពិតហើយព្រោះប្រេតមានសាច់និងឈាមតិច ប្រេតគ្របដណ្តប់ដោយគ្រោងឆ្អឹងទើបមិនអាចដេកផ្អៀងបានត្រូវដេកផ្ងារ ។ ម្នាលភិក្ខុទាំងឡាយសីហមិគរាជសម្រេចការដេកដោយខាងៗស្តាំ ។បេ។ រមែងត្រេកអរដោយការមិនភ្លាំងភ្លាត់និងឃ្លៀងឃ្លាតនៃកាយនេះ នេះឈ្មោះថា **សីហសេយ្យា** ។ ពិតហើយសីហមិគរាជ ព្រោះមានអំណាចខ្ពស់ រមែងដាក់ជើងមុខទាំង ២ មួយកន្លែង ដាក់ជើងក្រោយទាំង ២ មួយកន្លែង ស៊កកន្ទុយទុកក្នុងចន្លោះភ្លៅកំណត់ឱកាសដែលជើងមុខ ជើងក្រោយនិងកន្ទុយតាំងនៅ ហើយដាក់ក្បាលលើទីបំផុតជើងមុខទាំង ២ សូម្បីដេកលក់អស់ថ្ងៃ កាលភ្ញាក់ឡើងក៏ភ្ញាក់ដោយមិនតក់ស្លុត ងើបក្បាល សង្កេតឱកាសដែលជើងមុខតាំងនៅជាដើម បើទីណាមួយឃ្លាតទៅ តាំងនៅមិនរៀបរយ សីហមិគរាជទោមនស្សថា នេះមិនសមគួរដល់បុគ្គលដែលមានភាពក្លាហានដោយកំណើត ទើបដេកបន្តក្នុងទីនោះមិនចេញទៅស្វែងរកអាហារ តែកាលមិនឃ្លៀងឃ្លាតតាំងនៅរៀបរយ សីហៈក៏ត្រេកអរថា នេះសមគួរដល់អ្នកមានជាតិក្លាហានដោយកំណើត ទើបក្រោកពត់កាយ តាមបែបសីហៈ រលាស់រោមត្រង់ក បន្លឺសីហនាទ ៣ ដងហើយទើបចេញទៅរកអាហារ ។ ឯការដេកដោយចតុត្ថជ្ឈាន ហៅថា **តថាគត-សេយ្យា** ។ ក្នុងសេយ្យា ៤ យ៉ាងនោះ ក្នុងទីនេះសំដៅយកសីហសេយ្យា ព្រោះសេយ្យានេះ ឈ្មោះថាជាសេយ្យាដ៏ឧត្តម ព្រោះជាឥរិយាបថដែលមានអំណាចខ្ពស់ ។

បទថា **ចាគេ ចាគំ** បានដល់ ជើងឆ្វេងដាក់លើជើងស្តាំ ។ បទថា **អច្ចា-**

**ឆាយ** បានដល់ ដាក់ជើងឲ្យហួសគ្នាបន្តិច ព្រោះកាលកជើងប៉ះកជើង ជង្គង់ប៉ះជង្គង់វេទនាកើតឡើងរឿយៗ ចិត្តមិនជាឯកគ្គតាដេកមិនសប្បាយ ។ កាលដាក់ជើងហួសគ្នាបន្តិច មិនបៀតបៀនគ្នា វេទនារមែងមិនកើត ចិត្តមាន អារម្មណ៍ ១ ដេកសប្បាយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ចាទេ ចាទំ** ។ បទថា **សតោ សម្បជានោ** បានដល់ ជាអ្នកប្រកបដោយ សតិនិងសម្បជញ្ញៈ ។ ដោយបទនេះពោលដល់សតិសម្បជញ្ញៈ ដែលកំណត់ ល្អហើយ ។ បទថា **ឧដ្ឋានសញ្ញំ មនសិករិត្វា** បានដល់ តាំងឧដ្ឋានសញ្ញា កំណត់ពេលភ្ញាក់ទុកក្នុងចិត្តថា អញនឹងភ្ញាក់ក្នុងពេលនោះដូច្នេះ ។ ពិតហើយ ភិក្ខុដែលធ្វើយ៉ាងនេះហើយដេកនឹងភ្ញាក់ក្នុងកាលដែលកំណត់ទុកដោយពិត ។

គប្បីជ្រាបអធិប្បាយក្នុងនិទ្ទេសនៃវីរិយិន្ទ្រិយដូចតទៅនេះថា

បទថា **ចេតសិកោ** នេះ លោកពោលដើម្បីសម្តែង ដោយកំណត់យក សេចក្តីព្យាយាមប្រព្រឹត្តទៅផ្លូវចិត្ត ។ ព្រោះសេចក្តីព្យាយាមនេះក្នុងព្រះសូត្រ ទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមណាប្រព្រឹត្តទៅក្នុងកាយ សេចក្តីព្យាយាមនោះជាវីរិយសម្ពោជ្ឈង្គ ១ សេចក្តីព្យាយាមណា ប្រព្រឹត្តទៅ ក្នុងចិត្ត សេចក្តីព្យាយាមនោះជាវីរិយសម្ពោជ្ឈង្គ ១ ព្រោះថាវីរិយសម្ពោជ្ឈង្គ នេះ រមែងមកកាន់ឧទ្ទេសដោយប្រការដូច្នេះជាដើម លោកពោលថា **ចេត-សិកោ** ក៏ដើម្បីសម្តែងថា សេចក្តីព្យាយាមប្រព្រឹត្តទៅផ្លូវកាយមិនមាន មាន តែប្រព្រឹត្តទៅផ្លូវចិត្តប៉ុណ្ណោះ ដូចកាយវិញ្ញាណ សូម្បីពោលថាប្រព្រឹត្តទៅផ្លូវ កាយ ព្រោះកើតឡើងដល់បុគ្គលអ្នកចង្ក្រមជាដើម ។ បទថា **វីរិយារម្ភោ**

បានដល់ ការប្រារព្ធ គឺវិរិយៈ ។

ពិតហើយ **អារម្ភ** សព្ទនេះ មកហើយក្នុងអត្ថមិនមែនតិច គឺក្នុងកម្ម ក្នុងអាបត្តិ ក្នុងកិរិយា ក្នុងវិរិយៈ ក្នុងការបៀតបៀន ក្នុងការប្រទូស្ត ។

អារម្ភៈ មកក្នុងសេចក្តីថា កម្ម ក្នុងគាថានេះថា

**យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភបច្ចយា**
**អារម្ភានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។**

ទុក្ខនីមួយទាំងអស់តែងកើតឡើងព្រោះសង្ខារជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ទៅនៃសង្ខារទាំងឡាយ ។

អារម្ភៈ មកក្នុងសេចក្តីថា អាបត្តិ ដូចក្នុងប្រយោគជាដើមថា **អារភតិ ច វិប្បដិសារី ច ហោតិ** គឺបុគ្គលខ្លះប្រព្រឹត្តល្មើស ( ត្រូវអាបត្តិ ) ផង មាន សេចក្តីក្តៅក្រហាយផង ។

អារម្ភៈ មកក្នុងអត្ថថា កិរិយា មានឧបករណ៍ក្នុងការបូជាយញ្ញជាដើមដូចក្នុងប្រយោគជាដើមថា **មហាយញ្ញា មហារម្ភា ន តេ ហោន្តិ មហប្ផលា** ( មហាយញ្ញទាំងឡាយ ) មានការរវល់ច្រើន យញ្ញទាំងនោះមិនមែនមានផលច្រើនទេ ។

អារម្ភៈមកក្នុងអត្ថថា វិរិយៈ ដូចក្នុងប្រយោគជាដើមថា **អារភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ** អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ។

អារម្ភៈ មកក្នុងអត្ថថា ការបៀតបៀន ដូចក្នុងប្រយោគជាដើមថា **សមណំ**

**គោតមំ ឧទ្ទិស្ស ចាណំ អារភន្តិ** ពួកជន តែងសម្លាប់សត្វចំពោះព្រះសមណគោតម ។

អារម្ភៈ មកក្នុងអត្ថថា ការប្រទូស្ត មានការកាត់និងការទម្លាយជាដើមដូចក្នុងប្រយោគជាដើមថា **ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ** ភិក្ខុវៀរស្រឡះចាកការធ្វើពីជគាមនិងភូតគាមឲ្យវិនាស ។ ក្នុងទីនេះលោកបំណងយកវីរិយៈប៉ុណ្ណោះ ។ ដូចលោកពោលថា បទថា **វីរិយារម្ភោ** បានដល់ប្រារព្ធ គឺវីរិយៈ ។

ពិតហើយ សេចក្តីព្យាយាម លោកហៅថា **អារម្ភ** ដោយអំណាចនៃសេចក្តីព្យាយាម ។ បទថា **វីរិយារម្ភោ** នេះ ជាបទសម្តែងដល់សភាវៈនៃសេចក្តីព្យាយាមនោះ ។ ឈ្មោះថា **និក្កមោ** ព្រោះចេញទៅអំពីការខ្ជិលប្រអូស ។ ឈ្មោះថា **បរក្កមោ** ព្រោះការឈានទៅកាន់ឋានៈដទៃៗ ។ ឈ្មោះថា **ឧយ្យាមោ** ព្រោះឈានឡើងទៅ ។ ឈ្មោះថា **វាយាមោ** ព្រោះការប្រឹងប្រែង ។ ឈ្មោះថា **ឧស្សាហោ** ព្រោះការខ្នះខ្នែង ។ ឈ្មោះថា **ឧស្សោឡ្ហី** ព្រោះការខ្នះខ្នែងដ៏ខ្ពង់ខ្ពស់ ។ ឈ្មោះថា **ថាមោ** ព្រោះតាំងនៅក្នុងការមាំមួន ។ ឈ្មោះថា **ធិតិ** ព្រោះទ្រទ្រង់នូវការបន្តនៃកុសលទុកដោយអំណាចការទ្រទ្រង់ចិត្តនិងចេតសិកទុកបានឬដោយអំណាចការប្រព្រឹត្តទៅដោយមិនកាត់ផ្តាច់ ។

ន័យម្យ៉ាងទៀត បទថា **និក្កមោ** នេះ ដើម្បីបន្ទោបង់កាមទាំងឡាយ ។ បទថា **បរក្កមោ** នេះ ដើម្បីកាត់ការជាប់ជំពាក់ ។ បទថា **ឧយ្យាមោ** នេះ ដើម្បីដកឱឃៈ ។ បទថា **វាយាមោ** នេះដើម្បីទៅដល់ត្រើយ ។ បទថា

**ឧស្សាហោ** នេះ ដើម្បីទៅខាងមុខ ។ បទថា **ឧស្សោឡ្ហី** នេះ ដើម្បីការក្រៃលែងឡើងទៅ ។ បទថា **ថាមោ** នេះ ដើម្បីដកនូវកិលេស ដែលដូចគ្នានឹងវន្ទុកដែក ។ បទថា **ធិតិ** នេះ ដើម្បីមិនឈប់បង្អង់ ។

បទថា **អសិថិលបរក្កមតា** បានដល់ ដោយអំណាចការឈានទៅមិនរួញរា ក្នុងកាលដែលប្រព្រឹត្តទៅយ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ** ស្បែក សរសៃ ឆ្អឹង សូមឲ្យសល់នៅចុះ អធិប្បាយថា ឈានទៅខាងមុខ យ៉ាងស្វាហាប់ យ៉ាងមាំទាំ ។ ម្យ៉ាងទៀត ព្រោះសេចក្តីព្យាយាមនេះមិនដាក់នូវឆន្ទៈ មិនដាក់ធុរៈ មិនធ្វេងទៅ មិនលះបង់ នាំមកនូវភាពជាបុគ្គលមិនធូរថយក្នុងទីដែលធ្វើកុសលកម្ម ព្រោះហេតុនោះទើបលោកពោលថា **អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា** ដូចជនទាំងឡាយពោលថា ពួកអ្នកចូរចាំចាប់គោ ដែលនាំទំនិញទៅក្នុងទីដែលជន់ដោយទឹកក្បែរឆ្នេរស្ទឹងគង្គា គោនោះសូម្បីលុតជង្គង់ត្រង់ផែនដី ក៏គង់នាំទំនិញទៅបាន មិនឲ្យទំនិញធ្លាក់ចុះត្រង់ផែនដីយ៉ាងណា សេចក្តីព្យាយាមរមែងមិនដាក់ធុរៈ ផ្គងទុកក្នុងទីដែលធ្វើកុសលកម្មក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបព្រះសារីបុត្តពោលថា **ធុរសម្បគ្គាហោ** ដូច្នេះ ។ ឈ្មោះថា **វីរិយិន្ទ្រិយំ** ព្រោះធ្វើនូវភាពជាធំក្នុងលក្ខណៈផ្គងទុក ។ ឈ្មោះថា **វីរិយពលំ** ព្រោះមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ។ ឈ្មោះថា **សម្មាវាយាមោ** ព្រោះព្យាយាមក្នុងកុសលដែលនាំសត្វចេញចាកទុក្ខបានពិតប្រាកដ ។

[ ៥៤ ] បទថា **តន្ទិ** បានដល់ ការខ្ជិលច្រអូស ។ បទថា **តន្ទិយនា**

*បានដល់ អាការខ្ជិលច្រអូស ។ បទថា* **តន្ទិមនកតា** *បានដល់ ភាពជាអ្នកមានចិត្តត្រូវសេចក្តីខ្ជិលច្រអូសគ្របសង្កត់ ។ ភាពនៃការខ្ជិលច្រអូស ឈ្មោះថា* **អាលស្យំ** *។ អាការនៃភាពខ្ជិលច្រអូស ឈ្មោះថា* **អាលស្យាយនា** *។ ភាពជាបុគ្គលខ្ជិលច្រអូស ឈ្មោះថា* **អាលស្យាយិតត្តំ** *។ ដោយបទទាំងអស់នេះ លោកពោលដល់ភាពជាអ្នកខ្ជិលច្រអូសផ្លូវកាយ ដោយអំណាចកិលេស ។*

*បទថា* **វញ្ចនិកា ចរិយា** *បានដល់ កិរិយាបោកបញ្ឆោត ។ បទថា* **មា មំ ជញ្ញាតិ វាចំ ភាសតិ** *បានដល់ ភិក្ខុទាំងដឹងកន្លងនូវបញ្ញត្ត ធ្វើកម្មធ្ងន់តែពោលធ្វើហាក់ដូចជាស្ងប់ថា ខ្ញុំមិនមានការល្មើសឡើយ ។ បទថា* **កាយេន បរក្កមតិ** *បានដល់ ធ្វើនូវការបិទបាំងផ្លូវកាយដោយគិតថា បុគ្គលណាមួយកុំបីដឹងបាបកម្មដែលអញធ្វើនេះឡើយ ។ ឈ្មោះថា* **មាយា** *ព្រោះបញ្ឆោតឲ្យវង្វេងតាមផ្លូវភ្នែកដោយបិទបាំងទោសដែលមាន ។ ភាវនៃអ្នកបោកបញ្ឆោតឈ្មោះថា* **មាយាវិតា** *។ ឈ្មោះថា* **អច្ចសរា** *ព្រោះជាហេតុសត្វកន្លងដោយការធ្វើហើយបិទបាំងអំពើអាក្រក់ទុកទៀត ។ ឈ្មោះថា* **វញ្ចនា** *ព្រោះលាក់បាំងនូវសេចក្តីពិតដោយឲ្យឃើញយ៉ាងដទៃ ដោយវាចានិងកិរិយា ។ ឈ្មោះថា* **និកតិ** *ព្រោះជាហេតុឲ្យសត្វបិទបាំងនូវកំហុស អធិប្បាយថា ធ្វើខុស ។ ឈ្មោះថា* **និកិរណា** *ព្រោះបោះនូវកំហុសដោយពោលថា ខ្ញុំមិនបានធ្វើយ៉ាងនេះ ។ ឈ្មោះថា* **បរិហរណា** *ព្រោះចៀសវាងនូវកំហុស ដោយពោលថា មិនបានធ្វើយ៉ាងនេះ ។ ឈ្មោះថា* **គូហនា** *ព្រោះសង្រួមកាយជាដើម ។*

ឈ្មោះថា **បរិគូហនា** ព្រោះការលាក់ចំណែកខ្លះអំពីប្រការទាំងពួង ។ ឈ្មោះថា **ឆាទនា** ព្រោះបិទបាំងនូវអំពើអាក្រក់ដោយកាយកម្មនិងវចីកម្ម ដូចបិទបាំងលាមកដោយស្មៅជូច្នោះ ។ ឈ្មោះថា **បរិច្ឆាទនា** ព្រោះបិទបាំងចំណែកខ្លះអំពីប្រការទាំងពួង ។ ឈ្មោះថា **អនុត្តានីកម្មំ** ព្រោះមិនសម្តែងដើម្បីបើកផ្ចារ ។ ឈ្មោះថា **អនាវិកម្មំ** ព្រោះមិនសម្តែងឲ្យប្រាកដ ។ ឈ្មោះថា **វោច្ឆាទនា** ព្រោះគ្របកំហុសទុកយ៉ាងល្អ ។ ឈ្មោះថា **បាបកិរិយា** ព្រោះធ្វើអាក្រក់ជាថ្មីទៀត ដោយបិទបាំងនូវអំពើអាក្រក់ដែលធ្វើមកហើយ ។ បទថា **អយំ វុច្ចតិ** បានដល់ នេះហៅថា ការបញ្ឆោតដែលមានលក្ខណៈបិទបាំងនូវអំពើអាក្រក់ដែលធ្វើមកហើយ ដែលជាហេតុឲ្យបុគ្គល អ្នកប្រកបដូចផេះបិទបាំងរងើកភ្លើង ដូចជន្លត់បិទបាំងដោយទឹក ដូចសស្ត្រាបិទបាំងដោយសំពត់ចាស់ដែលគេយកមករុំ ។ បទថា **អតិវេលំ ឧន្នាមិសកំ ហាសតិ** បានដល់ បើកធ្មេញបង្ហាញដល់អ្នកដទៃហួសប្រមាណ ញុំាងការរីករាយឲ្យកើតហើយសើច ។

បទថា **កាយិកា ច ខិឌ្ឌា** បានដល់ ការលេងដែលប្រព្រឹត្តទៅតាមផ្លូវកាយ ។ សូម្បីផ្លូវវាចា ក៏មានន័យនេះដូចគ្នា ។ បទថា **ហត្ថីហិបិ កីឡន្តិ** បានដល់ លេងដោយការលេងមានការអង្គុយជាដើមលើខ្នង ឲ្យរត់ ឲ្យលោតទៅខាងមុខដោយឲ្យដំរីលេង ។ ក្នុងសេះនិងរថក៏មានន័យនេះឯង ។ បទថា **អដ្ឋបទេបិ កីឡន្តិ** បានដល់ ឈ្មោះថា **អដ្ឋបទំ** ព្រោះមួយជួរៗមាន ៨ ក្រឡា ។ ក្នុងជួរ ៨ នោះ ។ សូម្បីក្នុង បទថា **ទសបទេបិ** ក៏មានន័យដូច

គ្នា ។ បទថា **អាកាសេបិ** បានដល់ លេងអុកដូចលេងបាស្កាក្រឡា ៨ នោះឯង ។ បទថា **បរិហារបថេបិ** បានដល់ គូសខ្សែលើផែនដី ធ្វើឲ្យជាចន្លោះ ហើយលេងនាំវត្ថុ ដែលគប្បីនាំទៅ ក្នុងចន្លោះនោះ ។ បទថា **សន្តិកាយបិ កីឡន្តិ** បានដល់ លេងបាស្កាកម្រើកខ្លះ គឺយកកូនបាស្កា ឬដុំក្រួសតាំងទុករួមគ្នា ហើយយកក្រចកក្តិះចេញនិងក្តិះចូល ដោយមិនឲ្យកម្រើក បើដុំក្រួសណាមួយក្នុងទីនោះកម្រើកនឹងចាញ់ ។

បទថា **ខលិកាយ** បានដល់ លេងបោះអន្ទាក់លើក្តារក្តាល់ ។ បទថា **ឃដិកាយ** បានដល់ លេងដោយយកដំបងវែងវាយដំបងខ្លីហៅថា **ឃដិកា** លេងដោយការលេងនោះ ។ បទថា **សលាកហត្ថេន** បានដល់ យកស្លាកជ្រលក់ដោយល័ខ ជ្រលក់ដោយទឹកក្រហមឬម្សៅសើម ហើយរលាស់ស្លាកនោះលើផែនដីឬជញ្ជាំង មើលថាជារូបអ្វីហើយលេង សម្តែងឲ្យឃើញជារូបដំរីនិងសេះ ជាដើម ។ បទថា **អក្ខេន** បានដល់ លេងអន្គុញ់ ។ បទថា **បង្គចីរេន** បានដល់ ទងស្លឹកឈើ ហៅថា **បង្គចីរំ** លេងផ្លុំស្លឹកឈើនោះ ។ បទថា **វង្កកេន** បានដល់ នង្គ័លតូចសម្រាប់ក្មេងអ្នកស្រុកលេង ។ បទថា **មោក្ខចិកាយ** បានដល់ លេងដាំដូង លោកអធិប្បាយថា លេងត្រឡប់ក្បាលចុះក្រោម ដោយលោតទទួលកំណាត់ឈើក្នុងអាកាស ឬដាក់ក្បាលលើផែនដី ។ បទថា **ចិង្គុលកេន** បានដល់ លេងគ្រឿងវិលដោយខ្យល់ដែលធ្វើដោយស្លឹកត្នោតជាដើមហៅថា **ចិង្គុលកំ** លេងចិង្គុលកៈនោះ ។ បទថា **បត្តាឡ្ហកេន** បានដល់ នាឡិស្លឹកឈើ ហៅថា **បត្តាឡ្ហក** លេងវាល់ខ្សាច់ជាដើមដោយ

នាឡិស្លឹកឈើនោះ ។ បទថា **វង្កកេន** បានដល់ រទេះតូច ។ បទថា **ធនុកេន** បានដល់ ធ្នូតូច ។ បទថា **អក្ខរិកាយ** បានដល់ លេងសរសេរអក្សរលើអាកាស ឬលើខ្នងហើយទាយ ហៅថា **អក្ខរិកា** ។ បទថា **មនេសិកាយ** បានដល់ លេងឲ្យដឹងនូវការគិតផ្លូវចិត្តហៅថា **មនេសិកា** ។ បទថា **យថាវជ្ជេន** បានដល់ លេងត្រាប់ទោសរបស់មនុស្សភ្នែកខ្វាក់ មនុស្សខ្វិន មនុស្សខ្ទកជាដើម ហៅថា **យថាវជ្ជំ** ។

បទថា **មុខភេរិកំ** បានដល់ ធ្វើសំឡេងតាមមាត់ឲ្យឮដូចស្គរ ។ បទថា **មុខាឡម្ពរំ** បានដល់ លេងធ្វើត្រាប់ស្គរដោយមាត់ ។ បទថា **មុខឌិណ្ឌិមកំ** បានដល់ លេងរោទ៍ស្គរដោយមាត់ ។ បទថា **មុខវលិមកំ** បានដល់ ធ្វើសំឡេងដោយប្រើបបូរមាត់និងអណ្តាត ។ បាឋៈថា **មុខតលិកំ** ដូច្នេះក៏មាន ។ បទថា **មុខភេរុឡកំ** បានដល់ ផ្ទុំជាស្គរតាមមាត់ ( ក្តក់ ) ។ បទថា **ឆាជកំ** បានដល់ សម្តែងល្ខោន ។ បាឋៈថា **ឆជ្ជកំ** ក៏មាន ។ បទថា **លាបំ** បានដល់ ធ្វើសំឡេងបង្អក ។ បទថា **គីតំ** បានដល់ ច្រៀង ។ បទថា **ឆវកម្មំ** បានដល់ លេងសើច ។ បទថា **អយំ វាចសិកា ខិឌ្ឌា** បានដល់ ឈ្មោះថា **អយំ វាចសិកា ខិឌ្ឌា** ព្រោះកើតហើយក្នុងវចីទ្វារ ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **កេសា ច មស្សុ ច** ជាដើម ដូចតទៅនេះថា ការយកកន្ត្រៃកាត់សក់មិនឲ្យសេសសល់ដោយអន្ទើៗ ការកោរពុកមាត់ឲ្យដូចជាចង្កូម ការធ្វើផ្កាឲ្យមានទងតែមួយជាដើម ការប្រោះព្រំគ្រឿងក្រអូប មានគ្រឿងក្រអូបកើតអំពីឫសជាដើម ការលាបស្រឡាបស្បែក ការ

តាក់តែងគ្រឿងប្រដាប់ត្រង់កជាដើម ការតាក់តែងគ្រឿងប្រដាប់ ត្រង់ក្បាល ការដណ្ដប់សំពត់ដ៏វិចិត្របិទបាំងសរីរៈ ការប្រដាប់សង្វារ ។ បាឋៈថា **បាសធំ** ដូច្នេះក៏មាន ។ ការទ្រទ្រង់សំពត់ឈ្នួត ពោលគឺសំពត់ជួតក្បាល ឈ្មោះថា **វេឋធំ** ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **ឧច្ឆាទនំ** ដូចតទៅនេះថា ក្លិនកាយរបស់ទារកដែលកើតអំពីគភ៌មាតានឹងអស់ទៅក្នុងកាលអាយុប្រមាណ ១២ ឆ្នាំ ។ ដើម្បីកម្ចាត់ក្លិនកាយរបស់ទារក មាតាបិតាអប់ដោយលម្អិតរមៀតជាដើម ។ ការអប់យ៉ាងនេះមិនគួរ ។ តែមាតាបិតាឲ្យទារកមានបុណ្យ ដេកលើភ្លៅទាំង ២ ហើយលាបដោយប្រេងរឹត ដើម្បីឲ្យចំណែកផ្សេង មានដៃ ជើង ភ្លៅនិងផ្ចិតជាដើមបរិបូណ៌ល្អ ការគក់ប្របាច់យ៉ាងនេះ ក៏មិនគួរ ។ បទថា **ផ្លាបធំ** បានដល់ ឲ្យទារកទាំងនោះងូតដោយគ្រឿងក្រអូបជាដើម ។ បទថា **សម្ពាហធំ** បានដល់ យកដំបងជាដើមវាយត្រង់ដៃនិងជើង ឲ្យដៃជាដើមធំដូចអ្នកប្រដាល់ ។ បទថា **អាធាសំ** បានដល់ ការឆ្លុះកញ្ចក់ណាមួយ មិនគួរ ។ បទថា **អញ្ជនំ** បានដល់ បន្តក់ភ្នែកដើម្បីតាក់តែង ។ បទថា **មាលា** បានដល់ផ្កាជាកម្រងក្ដី មិនជាកម្រងក្ដី ។ បទថា **វិលេបនំ** បានដល់ ធ្វើការលាបស្បែកឯណានីមួយ ។ បទថា **មុខចុណ្ណកំ មុខលេបំ** សេចក្ដីថា ជនទាំងឡាយដើម្បីយកមុនជាដើមត្រង់មុខចេញទើបប្រើជ័រដីស្អិត កាលឈាមចេញដោយជ័រដីស្អិតនោះក៏ប្រើប្រេងរបស់គ្រាប់ស្ពៃជាដើម កាលប្រេងគ្រាប់ស្ពៃនោះកាត់នូវមុនដែលជាទោសហើយ ក៏ប្រើប្រេងល្ង កាលឈាមឈប់ហូរដោយប្រេង

ល្អក៏ប្រើប្រេងរមៀត កាលពណ៌សម្បុរកើតដោយប្រេងរមៀតនោះ ក៏លាបមុខដោយគ្រឿងលាបមុខ ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **ហត្ថពន្ធំ** ជាដើមដូចតទៅនេះថា ជនទាំងឡាយចងសំបកខ្យងដ៏វិចិត្រត្រង់ដៃជាដើមត្រាច់ទៅ គ្រឿងប្រដាប់ដៃទាំងអស់នោះឬគ្រឿងប្រដាប់ដៃដទៃ មិនគួរ ។ ជនមួយពួកទៀតចងកំប៉ោយត្រាច់ទៅ ហើយលម្អកំប៉ោយនោះដោយកម្រងមាស កម្រងកែវមុក្តា ។ ទាំងអស់នោះមិនគួរ ។ ជនដទៃមួយពួកទៀតកាន់ឈើច្រត់ប្រវែង ៤ ហត្ថ ឬឈើច្រត់ប្រដាប់ដទៃត្រាច់ទៅ ។ម្យ៉ាងទៀតជនទាំងឡាយ ស្ពាយបំពង់ថ្នាំវិចិត្រទៅដោយរូបស្រីនិងប្រុសជាដើម យ៉ាងល្អត្រង់ស្មាខាងឆ្វេង ។ ជនមួយពួកទៀត ស្ពាយដាវយ៉ាងមុតមានស្រោមវិចិត្រមិនមែនតិច បាំងឆត្រវិចិត្រទៅដោយក្បាច់ធ្មេញមករ ដេរដោយអំបោះមានពណ៌ ៥ ពាក់ស្បែកជើងដែលរចនា ដោយអន្ទាំកន្ទុយក្ងោកជាដើម វិចិត្រដោយមាសនិងប្រាក់ជាដើម ។ បុគ្គលខ្លះរុំសាយសក់វែងប្រមាណ ១ ហត្ថ ទទឹង ៤ ធ្នាប់ ពាក់ក្បាំងមុខត្រង់ថ្ងាសដូចផ្លេកបន្ទោរវាសអំពីមេឃ ប្រើផ្លិតចាមរីនិងផ្លិតវាលវីជនី ទាំងអស់នោះមិនគួរ ។

បទថា **ឥមស្ស វា បូតិកាយស្ស** បានដល់ សរីរៈដែលសម្រេចដោយមហាភូតរូប ៤ នេះ ។ បទថា **កេឡនា** បានដល់ ការលេងសប្បាយ ។ បទថា **បរិកេឡនា** បានដល់ លេងបានគ្រប់ចំណែក ដោយប្រការទាំងពួង ។ បទថា **គេធិតតា** បានដល់ ការប្រាថ្នា ។ បទថា **គេធិតត្តំ** បានដល់ ការពេញចិត្ត ការប្រាថ្នា ។ បទថា **ចបលនា** បានដល់ ការធ្វើនូវការប្រដាប់

តាក់តែង ។ បទថា **ចាបល្យំ** បានដល់ ភាវៈនៃការប្រដាប់ ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **សាភរណំ** ជាដើមដូចតទៅនេះថា រួមគ្នានឹងគ្រឿងប្រដាប់ ឈ្មោះថា **សាភរណំ** ។ ប្រព្រឹត្តទៅរួមគ្នានឹងបរិវារ គឺការលាបស្បែក ឈ្មោះថា **សបរិវារំ** ។ រួមនឹងរបស់ប្រើ ឈ្មោះថា **សបរិភណ្ឌំ** ។ រួមនឹងបរិក្ខារ ឈ្មោះថា **សបរិក្ខារំ** ។

[ ៥៥ ] បទថា **អាថព្វណំ** បានដល់ ការប្រកបមន្តធ្វើអថ័ន ។ បទថា **សុបិនំ** បានដល់ តម្រាទាយសុបិន្ត ។ បទថា **លក្ខណំ** បានដល់ ការទាយលក្ខណៈមានការទាយលក្ខណៈកែវមណីជាដើម ។ បទថា **នោ វិទហេ** បានដល់ មិនគប្បីធ្វើ ។ បទថា **វិរុតញ្ច** បានដល់ សំឡេងយំរបស់សត្វ មានម្រឹគជាដើម ។

[ ៥៦ ] បទថា **អាថព្វណិកា** បានដល់ ដែលដឹងមន្ត ដើម្បីសម្លាប់អ្នកដទៃ ។ បទថា **អាថព្វណំ បយោជេន្តិ** មានអធិប្បាយថា បានឮថា ពួកអ្នកប្រកបអថ័នបរិភោគរបស់មិនប្រែអស់ ៧ ថ្ងៃ ក្រាលស្បូវក្លាំងដេកលើផែនដីប្រព្រឹត្តតបៈក្នុងថ្ងៃទី ៧ ចូលកាន់ព្រៃស្មសានឈរថ្វាយអំពីផ្លូវ ៧ ជំហាន គ្រវីដៃរាយវិជ្ជា ។ ពេលនោះការងាររបស់ពួកគេក៏សម្រេច ។ ព្រះសារីបុត្តត្ថេរពោលថា ប្រកបអាថព្វណៈសំដៅដល់វត្ថុនេះឯង ។ ក្នុងបទទាំងនោះ បទថា **បយោជេន្តិ** បានដល់ ជាអ្នកខ្វល់ខ្វាយ ។ បទថា **ឧគរេ វា រុទ្ធេ** បានដល់ កាលនគរត្រូវបិទដោយជុំវិញ ។ បទថា **សង្គាមេ វា បច្ចុបដ្ឋិតេ** បានដល់ កាលសង្គ្រាមតាំងឡើងប្រកៀកគ្នា ។ បទថា **បច្ចត្ថិកេសុ បច្ចាមិត្តេសុ** បាន

ដល់ ក្នុងបុគ្គលដែលមានពៀរនៅម្ខាងមួយចំណែក ។ បទថា **ឡិតី ឧប្បាទេន្តិ** បានដល់ ធ្វើនូវការញាប់ញ័រនៃកាយនិងការរំដើបរំជួល ឲ្យកើតឡើងដល់សត្រូវ ។ បទថា **ឧបទ្ទវំ** បានដល់ ការបៀតបៀនផ្លូវកាយ ។ បទថា **រោគំ** បានដល់ ព្យាធិ ។ បទថា **បជ្ជរកំ** បានដល់ រោគគ្រុនក្ដៅ ។ បទថា **សុលំ** បានដល់ រោគចុក ។ បទថា **វិសូចិកំ** បានដល់ រោគចុកសៀត ។ បទថា **បក្ខន្ទិកំ** បានដល់ រោគចុះឈាម ។ បទថា **ករោន្តិ** បានដល់ ធ្វើឲ្យកើតឡើង ។

បទថា **សុបិនបាឋកា** បានដល់ ពួកអ្នកទាយយល់សប្ដិ ។ បទថា **អាទិសន្តិ** បានដល់ រមែងព្យាករ ។ ក្នុងបទថា **យោ បុព្វណ្ហសមយំ សុបិនំ បស្សតិ** ជាដើម ជាទុតិយាវិភត្តិចុះក្នុងអច្ចន្តសំយោគ ( រហូត ) អធិប្បាយថា ក្នុងពេលព្រឹក ។ បទថា **ឯវំ វិបាកោ ហោតិ** បានដល់ នឹងមានផលបែបនេះ ដោយជាផលដែលគួរប្រាថ្នានិងមិនគួរប្រាថ្នា ។ បទថា **អវកុជ្ជនិបន្នោ** បានដល់ ដេកផ្កាប់មុខយល់សប្ដិ ពួកអ្នកទាយយល់សប្ដិ ទាយយល់សប្ដិយ៉ាងនេះ ។

មយ៉ាងទៀតបុគ្គលយល់សប្ដិ រមែងយល់សប្ដិដោយហេតុ ៤ ប្រការ គឺ ធាតុក្ខោភៈ គឺធាតុកម្រើក ១ អនុភូតបុព្វៈ គឺអារម្មណ៍ធ្លាប់សេពមកអំពីមុន ១ ទេវតោបសំហារៈ គឺទេវតាបណ្ដាល ១ បុព្វនិមិត្ត គឺប្រផ្នូលប្រាប់ហេតុឲ្យដឹងមុន ១ ។

ក្នុងការយល់សប្ដិ ៤ ប្រការនោះ បុគ្គលមានធាតុកម្រើក ព្រោះប្រមាត់

ជាដើមកម្រើកជាបច្ច័យ ឈ្មោះថា យល់សប្តិដោយធាតុកម្រើក កាលយល់សប្តិរមែងយល់សប្តិច្រើនយ៉ាង ។ បុគ្គលយល់សប្តិដោយធ្លាប់សេពអារម្មណ៍មកអំពីមុន រមែងឃើញអារម្មណ៍ដែលធ្លាប់សេពមកហើយ ក្នុងកាលមុន ។ បុគ្គលយល់សប្តិ ដោយទេវតាបណ្តាលចិត្ត រមែងឃើញអារម្មណ៍ទាំងឡាយដោយអានុភាពរបស់ទេវតាទាំងឡាយ ។ បុគ្គលយល់សប្តិ ដោយបុព្វនិមិត្ត រមែងយល់សប្តិឃើញប្រផ្នូល ប្រាប់ហេតុជាមុននៃវត្ថុដែលជាប្រយោជន៍ ឬវត្ថុដែលមិនជាប្រយោជន៍ ដែលប្រាថ្នានឹងឲ្យកើតដោយបុណ្យនិងបាប ។ ក្នុងការយល់សប្តិទាំងនេះ យល់សប្តិដែលធាតុកម្រើកនិងដោយអារម្មណ៍ធ្លាប់សេពមកអំពីមុន មិនពិតប្រាកដឡើយ យល់សប្តិដោយទេវតាបណ្តាលចិត្តពិតខ្លះ មិនពិតខ្លះ ។ ព្រោះទេវតាក្រោធបំណងនឹងឲ្យដល់នូវការវិនាសដោយឧបាយ ក៏សម្តែងធ្វើឲ្យវិបរិត ( ខុសការពិត ) យល់សប្តិដោយបុព្វនិមិត្តយល់សប្តិនោះពិតដោយចំណែកមួយ ។

ប្រភេទនៃការយល់សប្តិ រមែងមានដោយប្រភេទនៃការទាក់ទងគ្នា របស់មូលហេតុ ៤ យ៉ាងនេះ បុថុជ្ជននិងសេក្ខៈរមែងយល់សប្តិ ៤ យ៉ាងនេះព្រោះមិនទាន់លះវិបល្លាសបាន ។ ព្រះអសេក្ខៈមិនយល់សប្តិ ព្រោះលះវិបល្លាសបានហើយ ។ កាលយល់សប្តិតើដេកលក់យល់សប្តិ ឬភ្ញាក់យល់សប្តិ ឬមិនលក់មិនភ្ញាក់យល់សប្តិ ។ ក្នុងសេចក្តីនេះបើដេកលក់យល់សប្តិខុសផ្លូវអភិធម្មពិត ព្រោះថាបុគ្គលយល់សប្តិដោយចិត្តចូលកាន់ភវង្គ ភវង្គចិត្តនោះមិនមានអារម្មណ៍ មានរូបនិមិត្តជាដើម ឬមិនសម្បយុត្តដោយកិលេស មានរាគៈជា

ដើមឡើយ ។ កាលយល់សប្តិចិត្តបែបនេះរមែងកើតឡើង ។ បើភ្ញាក់យល់សប្តិ មិនត្រូវតាមផ្លូវវិន័យ ព្រោះថាការភ្ញាក់យល់សប្តិ រមែងយល់សប្តិដោយចិត្ត ដែលជាអព្វោហារិក ។ ឈ្មោះថា មិនត្រូវអាបត្តិ ព្រោះធ្វើការល្មើសដោយ ចិត្តជាអព្វោហារិក តែមិនជាអាបត្តិដោយចំណែកមួយប៉ុណ្ណោះព្រោះការល្មើស ដែលអ្នកយល់សប្តិធ្វើហើយ ។ បើមិនដេកលក់មិនភ្ញាក់ យល់សប្តិ បុគ្គល ណាមួយក៏មិនយល់សប្តិ កាលបើយ៉ាងនេះការយល់សប្តិក៏មិនមាន មិនមែន មិនមានការយល់សប្តិ ។ ព្រោះហេតុអ្វី ព្រោះបុគ្គលដេកលក់ដូចគ្នានឹងស្វា ដេកលក់រមែងយល់សប្តិបាន ។ ដូចព្រះនាគសេនពោលទុកថា មហាបពិត្រ បុគ្គលដេកលក់ដូចគ្នានឹងស្វាដេកលក់នោះឯង ទើបយល់សប្តិ ។

ពាក្យថា បុគ្គលដេកលក់ដូចគ្នានឹងស្វាដេកលក់ គឺប្រកបហើយដោយការ ដេកលក់របស់ស្វា ។ ការដេកលក់ណាផ្លាស់ប្តូររហ័ស ព្រោះលាយដោយចិត្ត ជាកុសលជាដើមរឿយៗ ដូចការដេកលក់របស់ស្វាផ្លាស់ទៅបានរហ័ស ការ ចេញចាកភវង្គចិត្តរឿយៗ រមែងមានក្នុងការប្រព្រឹត្តទៅរបស់ការដេកលក់ណា បុគ្គលប្រកបដោយការដេកលក់នោះ រមែងយល់សប្តិដោយហេតុនោះ ទើប ការយល់សប្តិនេះជាកុសលខ្លះ អកុសលខ្លះ អព្យាកតខ្លះ ។ ក្នុងការយល់ សប្តិនោះ កាលបុគ្គលយល់សប្តិថា ធ្វើការថ្វាយបង្គំព្រះចេតិយ ស្តាប់ធម៌ សម្តែងធម៌ជាដើម គប្បីជ្រាបថាជាកុសល កាលបុគ្គលយល់សប្តិថា ធ្វើ បាណាតិបាតជាដើម គប្បីជ្រាបថាជាអកុសល ការយល់សប្តិក្រៅអំពី ២ យ៉ាងនោះជាអព្យាកត ក្នុងខណៈនៃអាវជ្ជនៈនិងតទារម្មណ ។ ការយល់សប្តិ

នោះមិនអាចឲ្យបដិសន្ធិបាន ព្រោះមានកម្លាំងតិច តែក្នុងបវត្តិកាលការយល់សប្តិដែលជាកុសល ឬអកុសលដទៃ មកបន្ថែមកម្លាំងរមែងឲ្យវិបាកបាន ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **មណិលក្ខណំ** ជាដើមដូចតទៅនេះថា ពួកអ្នកទាយលក្ខណៈរមែងទាយលក្ខណៈរបស់កែវមណីជាដើម ដោយពណ៌សណ្ឋានជាដើមយ៉ាងនេះថា កែវមណីយ៉ាងនេះប្រសើរ យ៉ាងនេះមិនប្រសើរ រមែងជាហេតុ រមែងមិនជាហេតុនៃការមិនមានរោគនិងភាពជាធំជាដើម ដល់ម្ចាស់ទ្រព្យ ។ ក្នុងលក្ខណៈទាំងនោះ បទថា **អាវុធលក្ខណំ** បានដល់ អាវុធដ៏សេសវៀរដាវជាដើម ។ សូម្បីលក្ខណៈស្ត្រីជាដើម ក៏គប្បីជ្រាបដោយអំណាចសេចក្តីចម្រើននិងសេចក្តីវិនាសរបស់ត្រកូល ដែលស្រីនិងបុរសជាដើមរស់នៅ ។ ឯក្នុងលក្ខណៈពពែជាដើម គួរជ្រាបការផ្សេងគ្នា គឺសាច់ពពែមានលក្ខណៈយ៉ាងនេះជាដើមគួរបរិភោគ យ៉ាងនេះមិនគួរបរិភោគ ។

ក្នុងបទថា **គោធាយ លក្ខណេ ចិត្តកម្មបិឡន្ធន** ជាដើមគប្បីជ្រាបការផ្សេងគ្នាដូច្នេះថា កាលទន្សងបែបនេះមានវត្ថុនេះរមែងមាន ។ លក្ខណៈជញ្ជាំគប្បីជ្រាបដោយអំណាច នៃជញ្ជាំប្រដាប់ខ្ទះ ជញ្ជាំផ្ទះខ្ទះ ។ សូម្បីលក្ខណៈអណ្តើក ក៏ដូចគ្នានឹងលក្ខណៈទន្សងនោះឯង ។ លក្ខណៈម្រឹគ លោកពោលសង្គ្រោះយកម្រឹគគ្រប់ប្រភេទដោយអំណាចលក្ខណៈនៃសត្វជើង ៤ ទាំងអស់ ។ បទថា **ឯវំ លក្ខណាទាបកា លក្ខណំ អាទិសន្តិ** បានដល់ អ្នកពោលតាមតម្រាទាយលក្ខណៈ រមែងទាយគឺរមែងប្រាប់លក្ខណៈយ៉ាងនេះ ។

បទថា **នក្ខត្តានិ** បានដល់ ឫក្ស ២៨ យ៉ាង មានកត្តិកាឫក្សជាដើម ។

*បទថា* **អមិណា ឆក្ខត្តេន យរប្បវេសោ កាតព្វោ** *បានដល់ ការងាររមង្គល ឡើងផ្ទះថ្មីគួរធ្វើដោយឫក្សនេះ ។ បទថា* **មក្កុដំ ពន្ធិតព្វំ** *បានដល់ ការងារមង្គលគ្រឿងប្រដាប់ ។ បទថា* **វាវេយ្យំ** *បានដល់ ពួកអ្នកមើលឫក្ស ប្រាប់ការធ្វើអាវាហមង្គលថា លោកទាំងឡាយ ចូរនាំកូនស្រីមកអំពីត្រកូលនោះមកឲ្យដល់កូនកំលោះដោយឫក្សឈ្មោះនោះនិងប្រាប់ការធ្វើការវិវាហមង្គលថា ចូរពួកលោកឲ្យកូនស្រីនេះដល់កូនកំលោះឈ្មោះនោះដោយឫក្សនោះ សេចក្តីចម្រើនទើងមានដល់ជនទាំង ២ ដោយប្រការដូច្នេះ ហើយទាយថា គប្បីធ្វើអាវាហមង្គលនិងវិវាហមង្គល គឺការរៀបការ ។ បទថា* **ពីជនីហារោ** *បានដល់ ការនាំនូវពូជចេញទៅខាងក្រៅដើម្បីព្រោះ ។ បាលីថា* **និហារោ** *ក៏មាន ។*

*[ ៥៧ ] បទថា* **មិគចក្កំ** *នេះ ជាឈ្មោះរួមសត្វគ្រប់ប្រភេទ លោកពោលដោយអំណាចការដឹងសំឡេងយំ របស់បក្សីនិងសំឡេងយំរបស់សត្វជើង ៤ គ្រប់ប្រភេទ ។ បទថា* **មិគវាក្កចាឋកា** *បានដល់ អ្នកទាយសំឡេងរបស់បក្សីនិងសត្វជើង ៤ ។ បទថា* **មិគវាក្កំ អានិសន្តិ** *បានដល់ ស្តាប់សំឡេងសត្វទាំងនោះហើយទាយ ។ បទថា* **រុតំ** *បានដល់ សំឡេង ។ បាលីថា* **រុធំ** *ក៏មាន ។ បទថា* **វស្សិតំ** *បានដល់ វាចា ។ បទថា* **គព្ភករណីយា** *បានដល់ ផ្សំថ្នាំឲ្យតាំងគភ៌ ដោយការឲ្យថ្នាំដើម្បីកុំឲ្យគភ៌ដែលតាំងហើយធ្លាក់ចុះ ។ ពិតហើយ គភ៌រមែងធ្លាក់ចុះដោយហេតុ ៣ ប្រការ គឺដោយខ្យល់ ១ ដោយសត្វល្អិតទាំងឡាយ ១ ដោយកម្ម ១ ។ ក្នុងហេតុ ៣ ប្រការនោះកាលធ្លាក់ចុះដោយខ្យល់ ក៏ឲ្យថ្នាំត្រជាក់ដើម្បីកែខ្យល់ ។ កាលធ្លាក់ចុះដោយសត្វ*

ល្អិតក៏ធ្វើការការពារសត្វល្អិតទាំងឡាយ តែបើធ្លាក់ចុះដោយកម្មសូម្បីព្រះពុទ្ធទាំងឡាយក៏មិនអាចរារាំងបាន ព្រោះហេតុនោះទើបក្នុងទីនេះមិនកាន់យកការធ្លាក់ដោយកម្មនោះ ។ បទថា **សាលាកិយំ** បានដល់ ព្យាបាលដោយការប្រើវត្ថុជាបន្ទះៗ ។ បទថា **សល្លកត្តិយំ** បានដល់ ព្យាបាលដោយកម្ម គឺការវះកាត់ ។ បទថា **កាយតិកិច្ឆំ** បានដល់ ប្រកបថ្នាំដោយឫសឈើជាដើមហើយព្យាបាលផ្លូវកាយ ។ បទថា **ភូតិយំ** បានដល់ ព្យាបាលតាមផ្លូវព្រាយបិសាច ។ បទថា **កោមារភច្ចំ** បានដល់ ព្យាបាលកុមារ ។

បទថា **កុហា** បានដល់ ធ្វើឲ្យវង្វេង ។ បទថា **ថទ្ធា** បានដល់ មានរាងកាយរឹងដូចអង្កត់ឧស ។ បទថា **លបា** បានដល់ ពោលទាក់ទងដោយបច្ច័យ ។ បទថា **សិង្គី** បានដល់ ចូលចិត្តប្រដាប់តាក់តែងជាប្រក្រតី ។ បទថា **ឧន្នឡា** បានដល់ មានមានះលើកឡើងដូចដើមបបុស ។ បទថា **អសមាហិតា** បានដល់ វៀរចាកឧបចារសមាធិនិងអប្បនាសមាធិ ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **ន គណ្ហេយ្យ** ជាដើម ដូចតទៅនេះថា គឺមិនគប្បីទទួលយកដោយឧទ្ទេស ។ ឈ្មោះថា **ន ឧគ្គណ្ហេយ្យ** ដោយការស្វាធ្យាយ ។ ឈ្មោះថា **ន ធារេយ្យ** ដោយការតាំងទុកក្នុងចិត្ត ។ ឈ្មោះថា **ន ឧបធារេយ្យ** ដោយការតាំងទុកក្បែរ ។ ឈ្មោះថា **ន ឧបលក្ខេយ្យ** ដោយការសាកសួរ ។ ឈ្មោះថា **នប្បយោជេយ្យ** ដោយការប្រាប់ដល់អ្នកដទៃ ។

[ ៥៨ ] បទថា **បេសុណិយំ** គឺ **បេសុញ្ញំ** ។ ពាក្យពន្យល់ដ៏សេសមានអត្ថដូចពោលទុកហើយ ។

[ ៦២ ] បទថា **កយវិក្កយេ** បានដល់ មិនគួរតាំងនៅដោយការបោកបញ្ឆោតឬក៏ដោយប្រាថ្នាចំណេញជាមួយសហធម្មិកទាំង ៥ ។ បទថា **ឧបវាទំ ភិក្ខុ ន ករេយ្យ** បានដល់ មិនឲ្យកើតនូវកិលេសជាគ្រឿងធ្វើនូវការតិះដៀល មិនគប្បីញុំាងនូវពាក្យតិះដៀលសមណៈនិងព្រាហ្មណ៍ដទៃ ឲ្យកើតក្នុងខ្លួន ។ បទថា **គាមេ ច នាភិសជ្ជេយ្យ** បានដល់ មិនគប្បីទាក់ទងដោយការប្រឡូកប្រឡំជាមួយគ្រហស្ថជាដើមក្នុងស្រុក ។ បទថា **លាភកម្យា ជនំ ន លបយេយ្យ** បានដល់ មិនគប្បីពោលរាក់ទាក់នឹងជន ព្រោះការចង់បានលាភ ។

[ ៦៣ ] បទថា **យេ កយវិក្កយា វិរយេ បដិក្ខិត្តា** បានដល់ ការទិញនិងការលក់ពួកណាដែលព្រះមានព្រះភាគ ទ្រង់ហាមក្នុងកយវិក្កយសិក្ខាបទដោយការឲ្យនិងការទទួលថា មិនគួរ ។

ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងការទិញនិងការលក់ ដែលបំណងក្នុងទីនេះទើបពោលពាក្យថា **បញ្ចន្នំ សទ្ធឹ បត្តំ វា ចីវរំ វា** ដូច្នេះជាដើម ក្នុងបទទាំងនោះ បទថា **បញ្ចន្នំ សទ្ធឹ** បានដល់ ជាមួយសហធម្មិក ៥ ពួក ។ សហធម្មិក ៥ ពួក បានដល់ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរនិងសាមណេរី ។ បទថា **វញ្ចនិយំ វា** បានដល់ ការបោកបញ្ឆោតដោយសម្តែងថា សមគួរ ។ បទថា **ឩនយំ វា បត្ថយន្តោ** បានដល់ ត្រូវការឲ្យបម្រើនឡើង ។ បទថា **បរិវត្តេតិ** បានដល់ ធ្វើនូវការដោះដូរ ។

[ ៦៤ ] បទថា **ឥទ្ធិមន្តោ** បានដល់ មានអំណាចឲ្យកើតការសម្រេច ។ បទថា **ទិព្វចក្ខុកា** បានដល់ មានញាណចក្ខុដូចគ្នានឹងទិព្វ ។ម្យ៉ាងទៀតបាន

នូវញាណចក្ខុដោយធម៌ជាគ្រឿងនៅអាស្រ័យ ដែលជាទិព្វព្រហ្មវិហារធម៌ ។ បទថា **បរចិត្តវិទុនោ** បានដល់ ដឹងចិត្តរបស់អ្នកដទៃដោយចិត្តរបស់ខ្លួន ។ បទថា **តេ ទូរតោបិ បស្សន្តិ** បានដល់ ឃើញ គឺសម្លឹងឃើញដល់ចក្កវាឡ ១ យោជន៍ខ្លះ ១០០ យោជន៍ខ្លះ ១០០០ យោជន៍ ១០០០០០ យោជន៍ ចក្កវាឡ ១ ខ្លះ ២ ខ្លះ ៣ ខ្លះ ៤ ខ្លះ ៥ ខ្លះ ១០ ខ្លះ ២០ ខ្លះ ៤០ ខ្លះ ១០០០ ចក្រវាលខ្លះ ក្រៃលែងជាងនោះខ្លះ ។ បទថា **អាសន្នាបិ ន ទិស្សន្តិ** បានដល់ ឈរជិតខ្លះ អង្គុយជិតខ្លះ រមែងមិនប្រាកដ ។ បទថា **ចេតសាបិ ចិត្តំ បជានន្តិ** បានដល់ ដឹងចិត្តអ្នកដទៃដោយចិត្តរបស់ខ្លួន ។ បទថា **ទេវតាបិ ខោ សន្តិ ឥទ្ធិមន្តិនិយោ** បានដល់ ទេវតាដែលមានអំណាច ឲ្យនូវសេចក្ដីសម្រេចមានយ៉ាងនេះ ។ បទថា **បរចិត្តវិទុនិយោ** បានដល់ ដឹងចិត្តរបស់អ្នកដទៃ ។

បទថា **ឱឡារិកេហិ វា កិលេសេហិ** បានដល់ ដោយវត្ថុឲ្យកើតការក្ដៅក្រហាយ មានកាយទុច្ចរិតជាដើម ។ បទថា **មជ្ឈិមេហិ វា** បានដល់ ដោយកាមវិតក្កជាដើម ។ បទថា **សុខុមេហិ វា** បានដល់ ដោយវិតក្កទាំងឡាយមានញាតិវិតក្កជាដើម ។ គប្បីជ្រាបកាយទុច្ចរិតជាដើម ដោយកម្មបថ គប្បីជ្រាបកាមវិតក្កជាដើមដោយអំណាចកិលេស ដែលមានវដ្ដៈជាមូល ។

គប្បីជ្រាបអធិប្បាយក្នុងបទថា **ញាតិវិតក្ក** ជាដើមដូចតទៅនេះថា វិតក្កកើតឡើងព្រោះប្រារព្ធញាតិទាំងឡាយដោយសេចក្ដីស្រឡាញ់ អាស្រ័យកាមគុណ ៥ យ៉ាងនេះថា ញាតិទាំងឡាយរបស់អាត្មាអញ មានការនៅសប្បាយ

មានសម្បត្តិដូច្នេះ ឈ្មោះថា វិតក្កដល់ញាតិ ។ តែវិតក្កប្រព្រឹត្តទៅយ៉ាងនេះថា ញាតិទាំងឡាយមានសទ្ធាជ្រះថ្លា បានដល់នូវការអស់ទៅ ជ្រះថ្លាហើយដូច្នេះ មិនឈ្មោះថា **ញាតិវិតក្ក** ។ តែវិតក្កប្រព្រឹត្តទៅយ៉ាងនេះថា ញាតិទាំងឡាយមានសទ្ធាជ្រះថ្លា បានដល់នូវការអស់ទៅ សូន្យទៅហើយ មិនឈ្មោះថា ញាតិវិតក្កទេ ។ ការត្រិះរិះកើតឡើងដោយសេចក្ដីស្រឡាញ់ អាស្រ័យផ្ទះនៃបុគ្គលអ្នកមានចិត្តត្រេកអរថា ជនបទរបស់ខ្ញុំមានកិច្ចារកបានងាយ មានស្រូវបរិបូណ៌ ឈ្មោះថា ជនបទវិតក្កា ។ វិតក្កប្រព្រឹត្តទៅយ៉ាងនេះថា មនុស្សទាំងឡាយក្នុងជនបទរបស់ខ្ញុំ មានសទ្ធាជ្រះថ្លា ដល់នូវការអស់ទៅ សាបសូន្យទៅហើយ មិនឈ្មោះថា ជនបទវិតក្កទេ ។ ការត្រិះរិះដល់ការមិនស្លាប់ ឬការត្រិះរិះដល់ទេវតាដែលមិនស្លាប់ ឈ្មោះថា អមរវិតក្កា ។ សេចក្ដីនេះខ្លួននឹងជាបុគ្គលមានសេចក្ដីសុខក្នុងភពខាងមុខ ព្រោះធ្វើទុក្ករ មានការព្យាយាមអង្គុយប្រហោងជាដើម ។ បទថា **អមរោ** បានដល់ ការត្រិះរិះប្រកបដោយការធ្វើទុក្កកិរិយានោះរបស់អ្នកធ្វើទុក្កកិរិយា ឈ្មោះថា អមរវិតក្កា ។ ចំណែកមេលទ្ធិត្រូវគេសួរថា សូមលោកប្រាប់ដល់សស្សតទិដ្ឋិជាដើម រមែងដល់នូវការលំបាកចិត្តថា ខ្ញុំមិនដឹងថាយ៉ាងនេះក៏មិនមែន មិនដឹងថាយ៉ាងនោះក៏មិនមែន ខ្ញុំមិនដឹងថាយ៉ាងដទៃក៏មិនមែន ខ្ញុំមិនដឹងថាមិនមានក៏មិនមែន ខ្ញុំមិនដឹងថាមិនមែនមិនមានក៏មិនមែន ការត្រិះរិះរបស់មេលទ្ធិនោះជាការត្រិះរិះប្រកបដោយទិដ្ឋិ ។ ទេវតាឈ្មោះអមរ ព្រោះមិនស្លាប់ ព្រោះមិនមានសណ្ឋាន សូម្បីក្នុងចំណែកមួយ ដូចត្រីឈ្មោះអមរ ( អន្ទង់ ) បុគ្គលណាមួយ មិនអាចចាប់ក្នុងទឹកយក

មកសម្លាប់បាន ហែលទៅក្នុងទីផ្សេងៗចាប់មិនបានដូច្នោះ សូម្បីទាំង ២ នោះ លោកពោលបញ្ចូលតែមួយថា **អមរាវិតក្កោ** ។

បទថា **បរានុទ្ទយតាបដិសញ្ញុត្តោ** បានដល់ ប្រកបដោយសេចក្តីស្រឡាញ់ អាស្រ័យផ្ទះ ដូចគ្នានឹងភាពជាអ្នកករុណាអ្នកដទៃ គឺកាលឧបដ្ឋាកត្រេកអរនិងសោយសោក ភិក្ខុក៏ត្រេកអរនិងសោយសោកទ្វេដង ជាមួយឧបដ្ឋាកទាំងនោះ កាលឧបដ្ឋាកទាំងនោះមានសេចក្តីសុខ ភិក្ខុក៏មានសេចក្តីសុខទ្វេដង កាលឧបដ្ឋាកទាំងនោះមានសេចក្តីទុក្ខ ភិក្ខុក៏មានសេចក្តីទុក្ខទ្វេដង កាលកិច្ចដែលត្រូវធ្វើកើតឡើង ភិក្ខុខ្វល់ខ្វាយដោយខ្លួនឯង កាលធ្វើកិច្ចនោះឲ្យសម្រេច រមែងកន្លងបញ្ញត្ត ញុំាងសល្លេខបដិបត្តិឲ្យកម្រើក ។ វិតក្កៈណា អាស្រ័យផ្ទះ ព្រោះនៅជាប់ជំពាក់នឹងគ្នាឬព្រោះខ្វល់ខ្វាយដល់គ្នានឹងគ្នា នេះឈ្មោះថា **បរា–នុទ្ទយតាបដិសញ្ញុត្តោ** ។ បទថា **លាភសក្ការសិលោកបដិសញ្ញុត្តោ** បានដល់ ប្រកបដោយអំណាចការធ្វើឲ្យជាអារម្មណ៍ដោយលាភ មានចីវរជាដើម ដោយសក្ការៈនិងដោយកេរ្តិ៍ឈ្មោះ ។ បទថា **អនវញ្ញត្តិបដិសញ្ញុត្តោ** បានដល់ វិតក្កដែលកើតជាមួយសេចក្តីប្រាថ្នា មិនចង់ឲ្យបុគ្គលណាមួយមើលងាយយ៉ាងនេះថា ធ្វើម្តេចហ្ន៎ អ្នកដទៃកុំបីមើលងាយអញ កុំបីពោលកំហែងអញ ។ វិតក្កកើតឡើងអាស្រ័យផ្ទះ គឺកាមគុណ ៥ ក្នុងកាលចិត្តកើងឡើងថា អ្នកដទៃកុំបីមើលងាយអញឡើយដូច្នេះ ឈ្មោះថា **អនវញ្ញត្តិបដិសញ្ញុត្តោ** ។

[ ៦៥ ] បទថា **តត្រ តត្រ សជ្ជតិ** បានដល់ ជាប់ក្នុងអារម្មណ៍នោះៗ ។ បទថា **តត្រ តត្រ គណ្ហាតិ** បានដល់ ចូលទៅកាន់អារម្មណ៍ដូចពោលហើយ

បទថា **ពជ្ឈតិ** បានដល់ រមែងពាក់ព័ន្ធ រមែងជួចគ្នាតែមួយ ដោយអារម្មណ៍នោះៗ ។ បទថា **អនយព្យសនំ** បានដល់ សេចក្ដីមិនចម្រើននិងសេចក្ដីវិនាសក្នុងទីនោះៗ ។ បទថា **អាបជ្ជតិ** បានដល់ រមែងសម្រេច ។

[ ៦៦ ] បទថា **អាមិសចក្ខុស្ស** បានដល់ ជាអ្នកឡេះឡោះដោយអាមិសមានចីវរជាដើម ។ បទថា **លោកធម្មគរុកស្ស** បានដល់ លះនូវលោកុត្តរធម៌ ពោលធ្ងន់តែក្នុងលោកធម៌ មានរូបជាដើមប៉ុណ្ណោះ ។ បទថា **អាលបនា** បានដល់ ឃើញមនុស្សទាំងឡាយមកកាន់វិហារ ពោលពាក្យរាក់ទាក់យ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកមកដើម្បីអ្វី មកនិមន្តភិក្ខុឬ បើដូច្នោះចូរពួកអ្នកទៅមុនចុះ អាត្មានឹងទៅតាមក្រោយ ។

ម្យ៉ាងទៀតនាំខ្លួនចូលទៅហើយ ពោលរាក់ទាក់ណែនាំខ្លួនយ៉ាងនេះថា អាត្មាឈ្មោះតិស្សៈ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងអាត្មា អាមាត្យធំឈ្មោះនោះរបស់ព្រះរាជា ក៏ជ្រះថ្លាក្នុងអាត្មាដូច្នេះ ឈ្មោះថា **អាលបនា** ។ បទថា **លបនា** បានដល់ កាលសួរហើយ ក៏ពោលរាក់ទាក់ដូចបានពោលហើយនោះឯង ។

បទថា **សល្លបនា** បានដល់ ការដែលភិក្ខុអាស្រ័យការខ្លាចក្រែងក្នុងការនឿយណាយរបស់គហបតីទាំងឡាយ បានឱកាសហើយពោលរាក់ទាក់យ៉ាងស្រស់ស្រាយ ។ បទថា **ឧល្លបនា** បានដល់ ពោលរាក់ទាក់លើកឲ្យខ្ពស់យ៉ាងនេះថា អ្នកជាមហាកុដុម្ពិកៈ ជាអ្នកឲ្យទានច្រើន ជាមហាទានបតី ។ បទថា **សមុល្លបនា** បានដល់ ពោលរាក់ទាក់លើកឲ្យខ្ពស់គ្រប់ចំណែក ។ បទថា **ឧន្នហនា** បានដល់ ភិក្ខុពោលលើកឲ្យខ្ពស់យ៉ាងនេះថា ឧបាសកទាំងឡាយ

កាលមុនក្តី កាលបែបនេះពួកអ្នកឲ្យទានដើមវដូវកាល ព្រោះហេតុអ្វីទើប ឥឡូវនេះមិនឲ្យហ្ន៎ រហូតពួកឧបាសកពោលពាក្យជាដើមថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងប្រគេន តែពួកខ្ញុំមិនទាន់បានឱកាស អធិប្បាយថា និយាយចង ។ ម្យ៉ាងទៀតភិក្ខុឃើញអ្នកស្រុកកាន់អំពៅ សួរថា ឧបាសកយកអំពៅមកអំពី ណា ជននោះឆ្លើយថា ខ្ញុំយកមកអំពីចម្ការអំពៅ ក៏សួរថា អំពៅត្រង់ចម្ការ នោះមានរសឆ្ងាញ់ល្អឬហ្ន៎ ជននោះឆ្លើយថា លោកម្ចាស់ឆាន់ហើយនឹងដឹង ក៏ពោលថា ឧបាសក ការពោលថាពួកអ្នកចូរប្រគេនអំពៅដល់ភិក្ខុ រមែងមិន គួរ ការនិយាយចងបុគ្គលយ៉ាងនេះក៏ឈ្មោះថា **ឧល្លបនា** ។ ការពោលចង រឿយៗគ្រប់ចំណែក ឈ្មោះថា **សមុល្លបនា** ។ បទថា **ឧក្កាចនា** បានដល់ ការពោលអួតអាងយ៉ាងនេះថា ត្រកូលនោះស្គាល់អាត្មាល្អ បើទេយ្យធម៌កើត ឡើងក្នុងត្រកូលនេះក៏នឹងឲ្យដល់អាត្មាពិតប្រាកដ អធិប្បាយថា ការនិយាយ អួត ។ ការពោលអួតរឿយៗគ្រប់ចំណែក ឈ្មោះថា **សមុក្កាចនា** ។

បទថា **អនុប្បិយភាណិតា** បានដល់ ការនិយាយដោយពាក្យគួរ ស្រឡាញ់រឿយៗ ដោយអំណាចបបច្ច័យ ។ បទថា **សណ្ហវាចតា** បានដល់ ការពោលទន់ភ្លន់ ។ បទថា **សខិលវាចតា** បានដល់ ការពោលសំឡេងថ្នមៗ ឬពោលសំឡេងទន់ ។ បទថា **សិថិលវាចតា** បានដល់ និយាយដាក់ឲ្យធូន់ ។ បទថា **អផរុសវាចតា** បានដល់ ពោលពីរោះ ។ បទថា **បុរាណំ មាតា-បេត្តិកំ** បានដល់ ឈ្មោះដែលកើតឡើងក្នុងកាលមុន ជារបស់មាតាបិតាដាក់ ឲ្យ ។ បទថា **អន្តរហិតំ** បានដល់ ឈ្មោះនោះបិទបាំងទុក គឺជារឿងខាងក្រៅ ។

បទថា **ញាយាមិ** បានដល់ ខ្ញុំជាអ្នកប្រាកដ ។ បទថា **អសុកស្ស កុលូប-កោ** បានដល់ ជាអ្នកចូលដល់ត្រកូលរបស់អាមាត្យនោះ ។ បទថា **អសុកាយ** បានដល់ របស់ឧបាសិកានោះ ។ បទថា **មំ ឧស្សុង្ហិត្វា** បានដល់ ចោលខ្ញុំហើយ ។

[ ៦៧ ] បទថា **បយុត្តំ** បានដល់ ទាក់ទងដោយចីវរជាដើម ឬប្រាថ្នាប្រយោជន៍នោះ ។ អធិប្បាយសេចក្តីនៃគាថាទាំងអស់នេះ មានន័យដូចពោលហើយខាងដើមនោះឯង ។

[ ៧២ ] បទថា **មោសវជ្ជេ ន និយ្យេថ** បានដល់ គប្បីចេញចាកមុសាវាទ ។ បទថា **ជីវិតេន** បានដល់ ដោយការរស់នៅ ។

[ ៧៤ ] បទថា **សឋោ** បានដល់ មិនពោលតាមធម៌ ដោយការសម្តែងគុណដែលមិនមាន ។ ជាអ្នកអួតអាងគ្រប់ចំណែក ឈ្មោះថា **បរិសឋោ** ។ បទថា **យំ តត្ថ** បានដល់ ក្នុងបុគ្គលនោះឯណា ។ បទថា **សឋំ** បានដល់ បោកបញ្ឆោតសម្តែងគុណដែលមិនមាន ។ បទថា **សឋតា** បានដល់ អាការអួតអាង ។ បទថា **សាឋេយ្យំ** បានដល់ ភាវៈនៃការអួតអាង ។ បទថា **កក្ករតា** បានដល់ ភាពជាបុគ្គលគ្រោតគ្រាត មិនសមទីងប៉ះពាល់ ដូចការគគ្រិះរបស់ដើមឈូកដូច្នោះ ។ បទថា **កក្ករិយំ** ក៏ជាវេវចនៈនៃបទថា **កក្ករតា** នោះឯង ។ លោកពោលការបោកបញ្ឆោតយ៉ាងខ្លាំងក្លា ដូចកប់ទុកដោយបទ ២ ថា **បរិក្ខត្តតា បរិក្ខត្តិយំ** តែអាចារ្យពួកខ្លះពណ៌នាសេចក្តីនេះថា បទថា **កក្ករតា** បានដល់ ពោលលើកតម្កើង ។ បទថា **កក្ករិយំ** បានដល់

កិរិយាដែលលើកសរសើរ ។ បទថា **បរិក្ខត្តតា** បានដល់ អាការតាក់តែង ។ បទថា **បរិក្ខត្តិយំ** បានដល់ កិរិយាតាក់តែង ។ បទថា **ឥធំ វុច្ចតិ** បានដល់ បុគ្គលណាមួយក៏មិនអាចដឹងខាងមុខ ឬខាងក្រោយរបស់បុគ្គល ដែលប្រកបដោយធម៌ណា ធម៌នេះលោកហៅថា ភាពជាអ្នកអួតដែលមានលក្ខណៈប្រកាសគុណដែលមិនមានរបស់ខ្លួន ដូចជ្រូកយក្ខដែលលោកពោលទុកយ៉ាងនេះថា

ខាងឆ្វេងជាជ្រូក ខាងស្តាំជាពពែនិងម្រឹគ សំឡេងជាចៀម
ស្នែងជាគោចាស់[១] ។

[ ៧៥ ] បទថា **អតិមញ្ញតិ** បានដល់ កន្លងល្មើស ។ បទថា **កឹ បនាយំ ពហុលាជីវោ** បានដល់ ភិក្ខុនេះ ហេតុអ្វីទើបមានការរស់នៅយ៉ាងប្រសើរ ។ បទថា **សព្ពំ សំភក្ខេតិ** បានដល់ ឆាន់នូវពូជគ្រប់យ៉ាង ដែលបានហើយ ។ បទថា **អប្បបុញ្ញោ** បានដល់ មានបុណ្យតិច ។ បទថា **អប្បេសក្ខោ** បានដល់ មិនមានបរិវារ ។ បទថា **បញ្ញាសម្បន្នោ** បានដល់ដល់ព្រមដោយបញ្ញាបរិបូណ៌ ។ បទថា **បញ្ហំ វិសជ្ជេតិ** បានដល់ ពោលឆ្លើយនូវបញ្ហាបាន ចម្លើលបង្ហាញបាន ។

[ ៧៦ ] បទថា **សុត្វា រុសិតោ ពហុំ វាចំ សមណានំ វា បុថុជនានំ** បានដល់ ត្រូវអ្នកដទៃប្រទូស្ត ត្រូវបៀតបៀន បានស្តាប់វាចាដែលមិនគួរប្រាថ្នា

---

១-យក្ខនិម្មិតកាយចំហៀងខាងឆ្វេងជាជ្រូក ចំហៀងខាងស្តាំជាពពែ ជាដើម ដើម្បីនាយស្រួលបញ្ឆោតស៊ីសត្វនោះៗ ។

សម្បីច្រើនរបស់សមណៈទាំងនោះ ឬរបស់បុថុជ្ជនពួកដទៃ មានពួកក្សត្រជាដើម ។ បទថា **ន បដិវជ្ជា** បានដល់ មិនគប្បីឆ្លើយឆ្លង ព្រោះអ្វី ព្រោះថាជនអ្នកស្ងប់រមែងមិនធ្វើនូវសត្រូវតបឡើយ ។

[ ៧៨ ] បទថា **កក្កុឡេន** បានដល់ ដោយពាក្យគ្រោតគ្រាត ។

[ ៧៩ ] បទថា **សន្តោ** បានដល់ រំលត់កិលេសបានហើយ ។ បទថា **បដិសេនី** បានដល់ សត្រូវដែលជាគូបដិបក្ខ ។ បទថា **បដិមល្លំ** បានដល់ ចម្បាំងតប ។ បទថា **បដិកណ្ដកំ** បានដល់ ចង្រៀរ ។ បទថា **បដិបក្ខំ** បានដល់ ជាបដិបក្ខដោយកិលេស អធិប្បាយថា មិនធ្វើនូវការជាប់ជំពាក់ដោយអំណាចកិលេស ។

[ ៨០ ] បទថា **ឯតញ្ច ធម្មមញ្ញាយ** បានដល់ ដឹងធម៌តាមដែលពោលហើយទាំងអស់នោះ ។ បទថា **វិចិនំ** កែជា **វិចិន្តោ** ។ បទថា **សន្តីតិ និព្វុតី ញត្វា** បានដល់ ដឹងនូវការរំលត់រាគៈជាដើមថាជាការស្ងប់ ។

[ ៨១ ] បទថា **សមញ្ច** បានដល់ កាយសុចរិតជាដើម ។ បទថា **វិសមញ្ច** បានដល់ កាយទុច្ចរិតជាដើម ។ បទថា **បថញ្ច** បានដល់ កុសលកម្មបថ ១០ ។ បទថា **វិបថញ្ច** បានដល់ អកុសលកម្មបថ ១០ ។ បទថា **សាវជ្ជញ្ច** បានដល់ អកុសល ។ បទថា **អនវជ្ជញ្ច** បានដល់ កុសល ។ បទថា **ហីនបណីតកណ្ហសុក្កវិញ្ញូគរហិតប្បសត្ថំ** នេះ ក៏ជាកុសលនិងអកុសលនោះឯង ។ ក្នុងធម៌ជាកុសលនិងអកុសលទាំងនោះ កាយសុចរិតជាដើមឈ្មោះថា **សមំ** ព្រោះធ្វើឲ្យស្មើ ។ កាយទុច្ចរិតជាដើមឈ្មោះថា **វិសមំ**

ព្រោះធ្វើឲ្យមិនស្មើ ។ កុសលកម្មបថ ១០ ឈ្មោះថា **បថំ** ព្រោះជាផ្លូវទៅកាន់សុគតិ ។ អកុសលកម្មបថ ១០ ឈ្មោះថា **វិបថំ** ព្រោះជាបដិបក្ខចំពោះការទៅសុគតិ ព្រោះជាផ្លូវទៅអបាយ ។ អកុសលឈ្មោះថា **សាវជ្ជំ** ព្រោះប្រព្រឹត្តទៅដោយទោស ។ កុសលឈ្មោះថា **អនវជ្ជំ** ព្រោះអស់ទោសហើយ ។ ម្យ៉ាងទៀតគប្បីជ្រាបថា ឈ្មោះថា **ហីនំ** ព្រោះប្រកបដោយមោហៈខ្លះ មោហៈនិងទោសៈខ្លះ មោហៈនិងលោភៈខ្លះ ។ ឈ្មោះថា **បណីតំ** ព្រោះប្រកបដោយអលោភៈ អទោសៈនិងអមោហៈ ។ ឈ្មោះថា **កណ្ហំ** ព្រោះមានវិបាកខ្មៅ ។ ឈ្មោះថា **សុក្កំ** ព្រោះមានវិបាកស ។ ឈ្មោះថា **វិញ្ញូគរហិតំ** ព្រោះវិញ្ញូជនមានព្រះពុទ្ធជាដើមទ្រង់តិះដៀល ។ ឈ្មោះថា **វិញ្ញូបសត្ថំ** ព្រោះវិញ្ញូជនទាំងនោះសរសើរហើយ ។

[ ៨៥ ] បើសួរថាព្រោះហេតុអ្វីភិក្ខុមិនគប្បីប្រមាទ គប្បីជ្រាបគាថាថា **អភិភូ ហិ សោ** ដូច្នេះជាដើម ជាពាក្យឆ្លើយ ។

ក្នុងបទនោះ បទថា **អភិភូ** បានដល់ ជាអ្នកគ្របសង្កត់រូបជាដើម ។ បទថា **អនភិភូតោ** បានដល់ មិនត្រូវរូបជាដើមនោះគ្របសង្កត់ ។ បទថា **សក្ខិធម្មំ អនីតិហមទស្សី** បានដល់ បានឃើញធម៌ជាក់ច្បាស់ហើយ ដោយមិនជឿចំពោះអ្នកដទៃ ។ បទថា **សទា នមស្សមប្បមត្តោ** បានដល់ នមស្ការសិក្សាសិក្ខា ៣ ។

[ ៨៦ ] បទថា **កេហិចិ កិលេសេហិ** បានដល់ កិលេសដែលធ្វើឲ្យក្តៅក្រហាយ មានរាគៈជាដើមណាមួយ ។ បទថា **អភិភូ ហិ សោ** បានដល់

គ្របសង្កត់កិលេសទាំងនោះបានហើយ ។ បទដ៏សេសក្នុងទីទាំងពួង ជាក់ច្បាស់ហើយ ។

ក្នុងទីនេះគប្បីជ្រាបការសង្រួមឥន្ទ្រិយ ដោយបទជាដើមថា គប្បីជ្រាបបច្ចយបដិសេវនសីល គឺសីលក្នុងការសេពបច្ច័យ មានការសន្សំជាគោល ដោយបទជាដើមថា នៃស្រូវឬនៃទឹកទាំងឡាយ ។ គប្បីជ្រាបបាតិមោក្ខសំវរសីលដោយបទជាដើមថា **ចក្ខូហិនេវលោលោ** តែម្យ៉ាងប៉ុណ្ណោះ ។ គប្បីជ្រាបបច្ចយបដិសេវនសីល មានការសន្សំជាគោលធំ មានពាក្យថា **អន្នានមថោ បានានំ** ជាដើម ។ គប្បីជ្រាបបាតិមោក្ខសំវរសីល ដោយពាក្យថា **មេថុន-មោសវជ្ជបេសុណិយា** ជាដើម ។ គប្បីជ្រាបអាជីវបារិសុទ្ធិសីលដោយពាក្យថា **អាថព្វណំ សុបិនំ លក្ខណំ** ជាដើម ។ គប្បីជ្រាបសមាធិ ដោយបទនេះថា **ឈាយី ន បាទលោលស្ស** ។ គប្បីជ្រាបបញ្ញា ដោយពាក្យនេះថា **វិចិនំ ភិក្ខុ** ។ គប្បីជ្រាបត្រៃសិក្ខាដោយសង្ខេបដោយបទនេះថា **សទា សតោ សិក្ខេ** ។ ព្រះមានព្រះភាគ ត្រាស់ការសង្គ្រោះនិងការបន្ទោបង់ ដែលជាឲ្យឧបការដល់សីល សមាធិ បញ្ញាដោយពាក្យថា **អថ អាសនេសុ សយនេ-សុ អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យ និទ្ទំ ន ពហុលីករេយ្យ** ជាដើម ។ ព្រះមានព្រះភាគកាលត្រាស់បដិបទាដ៏បរិបូណ៌ ដល់ព្រះពុទ្ធនិមិត្តយ៉ាងនេះហើយ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺព្រះអរហត្ត ។

កាលចប់ទេសនាសត្វដែលសម្រេចធម៌ ដូចគ្នាតាមដែលពោលទុកហើយក្នុងបុរាភេទសូត្រនោះឯង ។

**អដ្ឋកថា តុវដកសុត្តនិទ្ទេសទី ១៤ ចប់**

# អត្តទណ្ឌសុត្តនិទ្ទេសទី ១៥

[ ៩០ ] ( ព្រះមានព្រះភាគត្រាស់ថា ) ភ័យកើតអំពីអាជ្ញារបស់ខ្លួន អ្នកទាំងឡាយ ចូរមើលជនអ្នកឈ្លោះគ្នា តថាគតនឹងសម្តែងសំវេគធម៌តាមដែលតថាគតធ្លាប់សំវេគហើយ ។

[ ៩១ ] អធិប្បាយពាក្យថា ភ័យកើតអំពីអាជ្ញារបស់ខ្លួន ត្រង់ពាក្យថា អាជ្ញា បានដល់ អាជ្ញា ៣ គឺអាជ្ញាដោយកាយ អាជ្ញាដោយវាចា អាជ្ញាដោយចិត្ត ។ កាយទុច្ចរិត ៣ ប្រការឈ្មោះថា អាជ្ញាដោយកាយ វចីទុច្ចរិត ៤ ប្រការឈ្មោះថា អាជ្ញាដោយវាចា មនោទុច្ចរិត ៣ ប្រការឈ្មោះថា អាជ្ញាដោយចិត្ត ។ ពាក្យថា ភ័យ បានដល់ ភ័យ ២ ប្រការ គឺទិដ្ឋធម្មិកភ័យ ១ សម្ប-រាយិកភ័យ ១ ។

ទិដ្ឋធម្មិកភ័យ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់នូវតំណ ( នៃផ្ទះ ) ខ្លះ ប្លន់ធំខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយខ្លះ ឈរស្កាត់ប្រកផ្លូវខ្លះ គប់រកកិរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ ពួករាជបុរសចាប់បុគ្គលនោះថ្វាយព្រះរាជាទូលថា បពិត្រព្រះសម្មតិទេព បុគ្គលនេះជាចោរ ប្រព្រឹត្តអាក្រក់ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យនឹងទណ្ឌកម្មណា ចំពោះចោរនេះ សូមទ្រង់ដាក់នូវទណ្ឌកម្មនោះចុះ ។ ព្រះរាជាក៏គម្រាមចោរនោះ ។ ចោរនោះទទួលទុក្ខទោមនស្សព្រោះការគម្រាមជាបច្ច័យ ក៏មាន ។ ភ័យទុក្ខទោមនស្សនុ៎ះ កើតមកពីណាដល់ចោរនោះ ។ ភ័យទុក្ខទោមនស្សកើតឡើង ចម្រើនឡើង ដុះដាលឡើង

លូតលាស់ឡើង កើតប្រាកដឡើងអំពីអាជ្ញារបស់ខ្លួន ។ ព្រះរាជាមិនពេញព្រះទ័យ ដោយអំពើសូម្បីត្រឹមប៉ុណ្ណោះ ។ ព្រះរាជាត្រាស់បង្គាប់ ឲ្យចងចោរនោះដោយចំណងគឺខ្នោះក្តី ដោយចំណងគឺខ្សែក្តី ដោយចំណងគឺច្រវាក់ក្តី ដោយចំណងគឺផ្តៅក្តី ដោយចំណងគឺវល្លិក្តី ដោយចំណងគឺគុកក្តី ដោយចំណងគឺរបងក្តី ដោយចំណងគឺស្រុកក្តី ដោយចំណងគឺនគរក្តី ដោយចំណងគឺដែនក្តី ដោយចំណងគឺជនបទក្តី ដោយហោចទៅព្រះរាជាក៏រមែងធ្វើ ( នូវចោរនោះ ) ឲ្យស្តាប់បង្គាប់ថាជាអ្នកមិនត្រូវបានចៀសចេញ ទៅអំពីទីនេះទេ ។ ចោរនោះទទួលរងទុក្ខទោមនស្ស ព្រោះចំណងជាបច្ច័យក៏មាន ។ ភ័យទុក្ខទោមនស្សបែបនុ៎ះកើតមកពីណាដល់ចោរនោះ ។ ភ័យទុក្ខទោមនស្សកើតឡើង ចម្រើនឡើង ដុះដាលឡើង លូតលាស់ឡើង កើតប្រាកដឡើងអំពីអាជ្ញារបស់ខ្លួន ។ ព្រះរាជាមិនពេញព្រះទ័យដោយអំពើសូម្បីត្រឹមប៉ុណ្ណោះ ។ ព្រះរាជាញ៉ាំងចោរនោះឲ្យនាំទ្រព្យមួយរយក្តី មួយពាន់ក្តី មួយម៉ឺនក្តី មកថ្វាយព្រះអង្គ ។ ចោរនោះទទួលរងទុក្ខទោមនស្ស ព្រោះការវិនាសទ្រព្យជាបច្ច័យក៏មាន ។ ភ័យទុក្ខទោមនស្សនុ៎ះ កើតមកពីណាដល់ចោរនោះ ។ ភ័យទុក្ខទោមនស្សកើតឡើង ចម្រើនឡើង ដុះដាលឡើង លូតលាល់ឡើង កើតប្រាកដឡើងអំពីអាជ្ញារបស់ខ្លួន ។ ព្រះរាជាមិនពេញព្រះទ័យ ដោយអំពើសូម្បីត្រឹមប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ត្រាស់បង្គាប់រាជបុរសឲ្យធ្វើចោរនោះ ដោយកម្មករណ៍ផ្សេងៗ គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹក

ត្រចៀកទាំងច្រមុះខ្លះ ធ្វើនូវរិលង្គថាលកកម្ម ( អំពើដែលពោះរលាក្បាលធ្វើឲ្យដូចជាថ្នាំងជ្រក់ ) ខ្លះ ធ្វើនូវសង្ខមុណ្ឌកកម្ម ( អំពើដែលគេបកស្បែកក្បាលឲ្យរលីងដូចស័ង្ខ ) ខ្លះ ធ្វើនូវរាហុមុខកម្ម ( អំពើដែលថ្ពក់ហែកមាត់ឲ្យដូចជាមាត់រាហូ ) ខ្លះ ធ្វើនូវជោតិមាលិកកម្ម ( អំពើដែលរុំខ្លួនដុត ) ខ្លះ ធ្វើនូវហត្ថប្បជ្ជោតិកកម្ម ( អំពើដែលរុំដៃដុត ) ខ្លះ ធ្វើនូវឯរកវត្តិកកម្ម ( អំពើដែលពន្លាត់ស្បែកកជល់កជើង ) ខ្លះ ធ្វើនូវចីរកវាសិកកម្ម ( អំពើដែលបកស្បែកធ្វើឲ្យដូចជាស្លៀកសម្បកឈើ ) ខ្លះ ធ្វើនូវឯណេយ្យកកម្ម ( អំពើដែលដាក់កងត្រង់ជើងដោតឲ្យឈរហើយដុត ) ខ្លះ ធ្វើនូវពលិសមំសិកកម្ម ( អំពើដែលខ្វាសាច់ដោយសន្ទូច ) ខ្លះ ធ្វើនូវកហាបណកកម្ម ( អំពើដែលពោះសរីរៈប្រមាណប៉ុនៗកហាបណៈ ) ខ្លះ ធ្វើនូវខារាបតច្ឆិកកម្ម ( អំពើដែលយកទឹកផ្សារស្រោច ) ខ្លះ ធ្វើនូវបលិឃបរិវត្តិកកម្ម ( អំពើដែលឲ្យដេកផ្អៀងហើយដោតទម្លុះប្រហោងត្រចៀកទៅក្នុងផែនដីបង្វិលដូចជាជើងគុល ) ខ្លះ ធ្វើនូវបលាលបីឋកកម្ម ( អំពើដែលគេកិនឆ្អឹងឲ្យខ្ទេចហើយយកសក់យួរឡើងធ្វើឲ្យដូចជាកណ្តាប់ចំបើង ) ខ្លះ ស្រោចដោយប្រេងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ។ ចោរនោះទទួលរងទុក្ខទោមនស្ស ព្រោះហេតុនៃកម្មការណ៍ជាបច្ច័យក៏មាន ។ ភ័យទុក្ខទោមនស្សបែបនុ៎ះ កើតមកពីណាដល់ចោរនោះ ។ ភ័យទុក្ខទោមនស្សកើតឡើង ចម្រើនឡើង ដុះដាលឡើង លូតលាស់ឡើង កើតប្រាកដឡើងអំពីអាជ្ញារបស់ខ្លួន ។ ព្រះរាជាជាធំ ( អាចធ្វើ ) នូវអាជ្ញាទាំង ៤ យ៉ាងនេះឯង ។ ចោរនោះលុះ

បែកធ្លាយរាងកាយស្លាប់ទៅក៏កើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះកម្មរបស់ខ្លួន ។ នាយនិរយបាលទាំងឡាយ ក៏ធ្វើនូវកម្មករណ៍ឈ្មោះចំណង ៥ ប្រការចំពោះសត្វនោះ គឺបោះដែកគោលដ៏ក្តៅត្រង់ដៃ ( ម្ខាង ) បោះដែកគោលដ៏ក្តៅត្រង់ដៃទីពីរ បោះដែកគោលដ៏ក្តៅត្រង់ជើង ( ម្ខាង ) បោះដែកគោលដ៏ក្តៅត្រង់ជើងទីពីរ បោះដែកគោលដ៏ក្តៅត្រង់ពាក់កណ្តាលដើមទ្រូង ។ សត្វនោះក៏ទទួលរងនូវវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លាចផ្សារក្នុងនរកនោះ បាបកម្មនោះមិនទាន់អស់ដរាបណា សត្វនោះក៏មិនធ្វើកាលកិរិយាដរាបនោះ ។ ភ័យទុក្ខទោមនស្សទុំ កើតមកពីណាដល់ចោរនោះ ។ ភ័យទុក្ខទោមនស្សកើតចម្រើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ។ នាយនិរយបាលទាំងឡាយផ្តេកសត្វនោះ ហើយចាំងដោយដឹងទាំងឡាយ ។ សត្វនោះក៏ទទួលរងវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លាចផ្សាក្នុងនរកនោះ បាបកម្មនោះមិនទាន់អស់ដរាបណា សត្វនោះក៏មិនធ្វើកាលកិរិយាដរាបនោះ ។ នាយនិរយបាលទាំងឡាយចាប់សត្វនោះឲ្យមានជើងឡើងលើ ឲ្យមានក្បាលចុះក្រោមហើយក៏កាប់ដោយកាំបិតព្រាទាំងឡាយ ។ នាយនិរយបាលទាំងឡាយ ទឹមសត្វនោះក្នុងរថហើយក៏បរទៅខ្លះ បរមកវិញខ្លះ លើផែនដីដ៏ក្តៅដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ ។បេ។ នាយនិរយបាលទាំងឡាយ ឲ្យសត្វនោះឡើងទៅលើភ្នំរងើកភ្លើងដ៏ធំដែលភ្លើងកំពុងឆេះទ្រលោមសន្ធោសន្ធៅខ្លះ ឲ្យចុះខ្លះ ។បេ។ នាយនិរយបាលទាំងឡាយចាប់សត្វនោះឲ្យមានជើងឡើងលើ ឲ្យមានក្បាលចុះក្រោមហើយ បោះចុះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅដែលភ្លើងកំពុងឆេះទ្រលោមសន្ធោសសន្ធៅ ។ សត្វនោះ

ត្រូវកម្មស្ងោរខ្ទោលឡើង ដូចពពុះទឹកក្នុងខ្ទះនោះ ។ សត្វនោះត្រូវកម្មស្ងោរខ្ទោលឡើងដូចពពុះទឹកក្នុងខ្ទះនោះ ក៏អណ្តែតឡើងលើម្តងទៅក្រោមម្តង ទៅខាងទទឹងម្តង ។ សត្វនោះទទួលវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា ក្នុងនរកនោះ បាបកម្មនោះមិនទាន់អស់ដរាបណា សត្វនោះក៏មិនធ្វើកាលកិរិយាដរាបនោះ ។ ភ័យទុក្ខទោមនស្សទ្រុំះ កើតមកពីណាជល់ចោរនោះ ។ ភ័យទុក្ខទោមនស្សកើតចម្រើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ។ នាយនិរយបាលទាំងឡាយចាប់បោះសត្វនោះទៅក្នុងមហានរក ។ ឯមហានរកនោះសោតមានជ្រុង ៤ មានទ្វារ ៤ ដែលចម្មតាចែកតាក់តែងដោយចំណែកព័ទ្ធដោយកំពែងដែក គ្របដោយដែក ។ ទីនៃមហានរកនោះដែកសុទ្ធដែលរុងរឿងប្រកបដោយកំដៅ ផ្សាយទៅអស់មួយរយយោជន៍ ដោយជុំវិញឋិតនៅសព្វកាល ។ មហានរកទាំងនោះក្តៅដ៏ពន្លឹកអស់កាលជានិច្ច មានអណ្តាតភ្លើងដែលបុគ្គលចូលទៅបានដោយក្រ មានសភាពគួរជាទីព្រឺរោម តក់ស្លុត ជាទុក្ខគួរខ្លាច ។ គំនរអណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងកើត ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្មផ្ជប់ទៅនឹងជញ្ជាំងខាងលិច ។ គំនរអណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងលិច ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្មផ្ជប់ទៅនឹងជញ្ជាំងខាងកើត ។ គំនរអណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងជើង ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្មផ្ជប់ទៅនឹងជញ្ជាំងខាងត្បូង ។ គំនរ អណ្តាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងត្បូងឆាបឆេះសត្វទាំងឡាយដែលមានបាបកម្មផ្ជប់ទៅនឹងជញ្ជាំងខាងជើង ។ គំនរអណ្តាតភ្លើងគួរខ្លាចតាំង

ឡើងអំពីខាងក្រោម ធាបឆេះសត្វទាំងឡាយដែលមានបាបកម្មផ្ទប់ទៅទីង ដំបូល ។ គំនរអណ្តាតភ្លើងដ៏គួរខ្លាច តាំងឡើងអំពីដំបូល ធាបឆេះសត្វទាំង ឡាយដែលមានបាបកម្មផ្ទប់មកទីងផែនដី ។ អំបែងដែកកំពុងឆេះក្តៅសព្វ រុង រឿងយ៉ាងណា នរកអវិចី ( ក៏ប្រាកដ ) ដល់សត្វដែលតាំងនៅអំពីខាងក្រោម ខាងលើ អំពីខាងក៏យ៉ាងនោះដែរ ។ សត្វទាំងឡាយជាអ្នកលោភធំ ធ្វើអំពើ អាក្រក់ច្រើនយ៉ាង មានអំពើបាបតែមួយយ៉ាង រមែងឆេះតែមិនស្លាប់ក្នុងនរក នោះ ។កាយនៃសត្វទាំងឡាយដែលអាស្រ័យនៅក្នុងនរកនោះប្រាកដស្មើដោយ ភ្លើង អ្នកចូរមើលភាពនៃកម្មដ៏មាំមួនចុះ សត្វទាំងនោះមិនទៅជាផេះ មិនទៅជា ធ្យូង ។ សត្វនរកទាំងឡាយរមែងស្ទុះទៅទិសខាងកើត ស្ទុះអំពីទិសនោះមក ទិសខាងលិចខ្លះ ស្ទុះទៅទិសខាងជើង ស្ទុះអំពីទិសនោះមកទិសខាងត្បូងខ្លះ ។ សត្វនរកទាំងនោះស្ទុះទៅទិសណាៗទ្វារក្នុងទិសនោះៗក៏បិទជិតឯង សត្វនរក ទាំងនោះសុទ្ធតែមានសេចក្តីប្រាថ្នា ដើម្បីចេញស្វែងរកនូវការរួចចេញ ។ ប៉ុន្តែ សត្វនរកទាំងនោះ មិនបានចេញអំពីនរកនោះ ព្រោះកម្មជាបច្ច័យ បាបកម្ម របស់សត្វទាំងនោះមានច្រើនយ៉ាង ដែលខ្លួនធ្វើហើយជាកម្មឲ្យផលមិនទាន់ អស់ ។

ភ័យទុក្ខទោមនស្សនុ៎ះ កើតមកអំពីណា ដល់សត្វនោះ ។ ភ័យទុក្ខទោ-មនស្សកើតចម្រើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ។ ទុក្ខក្នុងនរកណា ទុក្ខក្នុងកំណើតតិរច្ឆានណា ទុក្ខក្នុងបិត្តិវិស័យណា ទុក្ខក្នុង មនុស្សណា ទុក្ខទាំងនោះ កើតអំពីណា ចម្រើនអំពីណា ដុះដាលអំពីណា

លូតលាស់អំពីណា កើតប្រាកដឡើងអំពីណា ។ ទុក្ខទាំងនោះកើតចម្រើន ដុះដាល លូតលាស់ កើតប្រាកដ អំពីអាជ្ញារបស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភ័យកើតអំពីអាជ្ញារបស់ខ្លួន ។

[ ៩២ ] ពាក្យថា អ្នកទាំងឡាយ ចូរមើលជនអ្នកឈ្លោះគ្នា ត្រង់ពាក្យថា ជន បានដល់ក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា អ្នកឈ្លោះគ្នា គឺអ្នកទាំងឡាយ ចូរមើល ចូរឃើញ ចូរក្រឡេកមើល ចូរពិនិត្យមើល ចូរពិចារណាមើលនូវជនអ្នកឈ្លោះគ្នា ជនអ្នកប្រកែកគ្នា ជនខុសនឹងគ្នា ជនប្រកាន់ខុសនឹងគ្នា ជនដែលបៀតបៀនគ្នា ជនដែលតបតគ្នា ជនដែលគុំកួនគ្នា ជនដែលគុំកួនចំពោះគ្នា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកទាំងឡាយ ចូរមើលជនអ្នកឈ្លោះគ្នា ។

[ ៩៣ ] ពាក្យថា តថាគតនឹងសម្ដែងសំវេគធម៌ គឺតថាគតនឹងសម្ដែង នឹងបង្ហាញ ប្រាប់ ពន្យល់ បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសនូវសំវេគធម៌ សេចក្ដីរន្ធត់ តក់ស្លុត ភ័យ លំបាក ចង្អៀតចង្អល់ ឧបទ្រពចង្រៃ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតនឹងសម្ដែងសំវេគធម៌ ។

[ ៩៤ ] ពាក្យថា តាមដែលតថាគតធ្លាប់សង្វេគហើយ គឺតថាគតសង្វេគរន្ធត់ ដល់នូវការសង្វេគហើយ ដោយខ្លួនឯងយ៉ាងណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) តាមដែលតថាគតសង្វេគហើយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភ័យកើតអំពីអាជ្ញារបស់ខ្លួន អ្នកទាំងឡាយ ចូរមើលជនអ្នក

ឈ្មោះថា តថាគតនឹងសម្តែងសំវេគធម៌ តាមដែលតថាគត
សំវេគហើយ ។

[ ៩៥ ] ភ័យចូលមកកាន់តថាគត ព្រោះឃើញប្រជាជនកំពុងញាប់ញ័រ ដូចពួកត្រីក្នុងទីមានទឹកតិច ព្រោះឃើញពួកជនដែលទាស់ទែងគ្នីគ្នា ។

[ ៩៦ ] អធិប្បាពាក្យថា ព្រោះឃើញប្រជាជនកំពុងញាប់ញ័រ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះរបស់សត្វ ។ ប្រជាជនកំពុងញាប់ញ័រដោយ ការញាប់ញ័រព្រោះតណ្ហា កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះទិដ្ឋិ កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះកិលេស កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះទុច្ចរិត កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះយោគ កំពុងញាប់ញ័រដោយការញាប់ញ័រព្រោះវិបាក កំពុងញាប់ញ័រដោយរាគៈដែលត្រេកអរហើយ កំពុងញាប់ញ័រដោយទោសៈដែលប្រទុស្តហើយ កំពុងញាប់ញ័រដោយមោហៈដែលវង្វេងហើយ កំពុងញាប់ញ័រដោយមានះដែលជាប់ចំពាក់ហើយ កំពុងញាប់ញ័រដោយទិដ្ឋដែលស្ទាបអង្អែលហើយកំពុងញាប់ញ័រដោយឧទ្ធច្ចៈដែលរាយមាយហើយ កំពុងញាប់ញ័រដោយវិចិកិច្ឆាដែលមិនចូលចិត្តហើយ កំពុងញាប់ញ័រដោយអនុសយៈដែលដល់ហើយនូវកម្លាំង កំពុងញាប់ញ័រដោយលាភ កំពុងញាប់ញ័រដោយការមិនមានលាភ កំពុងញាប់ញ័រដោយយស កំពុងញាប់ញ័រដោយការមិនមានយស កំពុងញាប់ញ័រដោយសេចក្តីសរសើរ កំពុងញាប់ញ័រដោយនិន្ទា កំពុងញាប់ញ័រដោយសុខ កំពុងញាប់ញ័រដោយទុក្ខ កំពុងញាប់ញ័រដោយជាតិ កំពុងញាប់ញ័រដោយជរា កំពុងញាប់ញ័រដោយព្យាធិ កំពុង

ញាប់ញ័រដោយមរណៈ កំពុងញាប់ញ័រដោយសោក ខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ កំពុងញាប់ញ័រដោយទុក្ខក្នុងនរក កំពុងញាប់ញ័រ ដោយទុក្ខក្នុងកំណើតតិរច្ឆាន កំពុងញាប់ញ័រដោយទុក្ខក្នុងបិត្តិវិស័យ កំពុងញាប់ញ័រដោយទុក្ខជារបស់មនុស្ស ដោយទុក្ខមានការចុះកាន់គភ៌ជាមូល ដោយទុក្ខមានការឋិតនៅក្នុងគភ៌ជាមូល ដោយទុក្ខមានការចេញចាកគភ៌ជាមូល ដោយទុក្ខមានការជាប់ចំពាក់នៃសត្វដែលកើតហើយ ដោយទុក្ខដែលទាក់ទងអំពីបុគ្គលដទៃនៃសត្វដែលកើតហើយ ដោយទុក្ខគឺការព្យាយាមរបស់ខ្លួន ដោយទុក្ខគឺការព្យាយាមរបស់បុគ្គលដទៃ ដោយទុក្ខទុក្ខ ដោយទុក្ខគឺសង្ខារ ដោយទុក្ខព្រោះការប្រែប្រួល ដោយទុក្ខគឺរោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្ដាត រោគកាយ រោគក្បាល រោគត្រង់ស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឫសដូងច្រមុះ ក្ដៅក្រហាយ ស្គាំងស្គម រោគក្នុងផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគក្នុងទីទ្វារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ទឹកមូត្រផ្អែម ឫសដូចដុះ បូស ឫសដូងបាត អាពាធតាំងឡើងអំពីប្រមាត់ អាពាធតាំងឡើងអំពីស្លេស្ម អាពាធតាំងឡើងអំពីខ្យល់ អាពាធតាំងឡើងអំពីការប្រជុំធាតុ អាពាធកើតអំពីផ្លាស់រដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើគ្នា អាពាធកើតអំពីការព្យាយាមខ្លាំង អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ គម្លាន សម្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់ កំពុងញាប់ញ័រខ្លាំង អន្ទះអន្ទែង អន្ទះសា រន្ធត់ ចំប្រប់ខ្លាំង ដោយទុក្ខ

ព្រោះមរណៈមាតា ដោយទុក្ខព្រោះមរណៈបិតា ដោយទុក្ខព្រោះមរណៈបងប្អូនប្រុស ដោយទុក្ខព្រោះមរណៈបងប្អូនស្រី ដោយទុក្ខព្រោះមរណៈបុត្ត ដោយទុក្ខព្រោះមរណៈធីតា ដោយទុក្ខព្រោះមរណៈញាតិ ដោយទុក្ខព្រោះវិនាសភោគៈ ដោយទុក្ខព្រោះវិនាសគឺរោគ ដោយទុក្ខព្រោះវិនាសសីល ដោយទុក្ខព្រោះវិនាសគឺទិដ្ឋិ ។ ពាក្យថា ព្រោះឃើញ គឺព្រោះឃើញ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះឃើញប្រជាជនកំពុងញាប់ញ័រ ។

[ ៩៧ ] ពាក្យថា ដូចពួកត្រីក្នុងទីមានទឹកតិច សេចក្តីថា ត្រីក្នុងទីមានទឹកតិច មានទឹកស្ងួចស្តើង មានទឹករីងទៅ ត្រូវក្អែកក្តី ខ្លែងក្តី កុកក្តី ឆាបឆក់ចឹកស៊ីក៏រមែងញាប់ញ័រ ញាប់ញ័រខ្លាំង អន្ទះអន្ទែង អន្ទះសា ចំប្រប់ខ្លាំងយ៉ាងណាមិញ ពួកប្រជាជនក៏រមែងញាប់ញ័រដោយការញាប់ញ័រព្រោះតណ្ហា ។បេ។ ញាប់ញ័រ ញាប់ញ័រខ្លាំង អន្ទះអន្ទែង អន្ទះសា រន្ធត់ ចំប្រប់ខ្លាំងដោយទុក្ខព្រោះវិនាសគឺទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដូចពួកត្រីក្នុងទីមានទឹកតិច ។

[ ៩៨ ] ពាក្យថា ទាស់ទែងគ្នា សេចក្តីថា ពួកសត្វខឹង ខឹងតប បៀតបៀនតប គុំកួន គុំកួនតបនូវគ្នានឹងគ្នា គឺពួកព្រះរាជាទាស់ទែងនឹងពួកព្រះរាជាខ្លះ ពួកក្សត្រទាស់ទែងនឹងពួកក្សត្រខ្លះ ពួកព្រាហ្មណ៍ទាស់ទែងនឹងពួកព្រាហ្មណ៍ខ្លះ ពួកគហបតីទាស់ទែងនឹងពួកពួកគហបតីខ្លះ មាតាទាស់ទែងនឹងបុត្តខ្លះ បុត្តទាស់ទែងនឹងមាតាខ្លះ បិតាទាស់ទែងនឹងបុត្តខ្លះ បុត្តទាស់ទែងនឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសខ្លះ បងប្អូនស្រីទាស់ទែងនឹងបង

ប្អូនស្រីខ្លះ បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីខ្លះ បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសខ្លះ សម្លាញ់ទាស់ទែងនឹងសម្លាញ់ខ្លះ ។ ពួកជនទាំងនោះដល់នូវជំលោះ ប្រកែក ទាស់ទែងក្នុងទីនោះ ហើយប្រហារនូវគ្នានឹងគ្នាដោយដៃខ្លះ ប្រហារដោយដុំដីខ្លះ ប្រហារដោយដំបងខ្លះ ប្រហារដោយគ្រឿងសស្ត្រាវុធខ្លះ ។ ពួកជនទាំងនោះក្នុងទីនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខជិតស្លាប់ខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាស់ទែងគ្នា ។

[ ៩៩ ] ពាក្យថា ភ័យចូលមកកាន់តថាគតព្រោះឃើញ ត្រង់ពាក្យថា ព្រោះឃើញ សេចក្តីថា ភ័យ សេចក្តីលំបាក ការចង្រៀតចង្អល់ ឧបទ្រពចង្រៃរមែងចូលមក ( កាន់តថាគត ) ព្រោះឃើញ យល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភ័យចូលមកកាន់តថាគតព្រោះឃើញ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> ភ័យចូលមកកាន់តថាគត ព្រោះឃើញប្រជាជនកំពុងញាប់ញ័រ
> ដូចពួកត្រីក្នុងទីមានទឹកតិច ព្រោះឃើញពួកជនដែលទាស់ទែង
> គ្នីគ្នា ។

[១០០] លោកមិនមានខ្លឹមដោយជុំវិញ សង្ខារក្នុងទិសទាំងអស់ញាប់ញ័រ តថាគតកាលប្រាថ្នាសេចក្តីចម្រើនដើម្បីខ្លួន មិនបានឃើញ ( នូវទីណាមួយដែលទុក្ខ ) មិនញាំញីឡើយ ។

[ ១០១ ] អធិប្បាពាក្យថា លោកមិនមានខ្លឹមដោយជុំវិញ ( ដូចតទៅនេះ ) និរយលោក តិរច្ឆានយោនិលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក

ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកមុខ ព្រមទាំងព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ និរយលោកមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម គឺចាកខ្ទឹមគឺខ្ទឹមទៀងក្តី ចាកខ្ទឹមគឺខ្ទឹមសុខក្តី ចាកខ្ទឹមគឺខ្ទឹមខ្លួនក្តី ចាកសភាវៈទៀងក្តី ចាកការឋិតថេរក្តី ចាកការមាំមួនក្តី ចាកសភាវៈមិនប្រែប្រួលក្តី ។ តិរច្ឆានយោនិលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកមុខ ព្រមទាំងព្រហ្មលោក ព្រមទាំងទេវលោក ជាសភាវៈមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម គឺចាកខ្ទឹមគឺខ្ទឹមទៀងក្តី ចាកខ្ទឹមគឺខ្ទឹមសុខក្តី ចាកខ្ទឹមគឺខ្ទឹមខ្លួនក្តី ចាកសភាវៈទៀងក្តី ចាកការឋិតថេរក្តី ចាកការមាំមួនក្តី ចាកសភាវៈមិនប្រែប្រួលក្តី ។ ដើមបបុសមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ដើមល្ហុងមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ដើមល្វាមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ដើមកន្ទាំងបាយសមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ដើមរលួសបាយមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ដុំពពុះទឹកមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ក្រពេញទឹកមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ថ្ងៃបណ្តើរកូនមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា ដើមចេកមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា រស្មីមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹមយ៉ាងណា និរយលោកមិនមានខ្ទឹម ឥតខ្ទឹម ប្រាសចាកខ្ទឹម គឺចាកខ្ទឹមគឺខ្ទឹមទៀងក្តី ចាកខ្ទឹមគឺខ្ទឹមសុខក្តី ចាកខ្ទឹមគឺខ្ទឹមខ្លួនក្តី ចាកសភាវៈទៀងក្តី ចាកការឋិតថេរក្តី ចាកការមាំមួនក្តី ចាក

សភាវៈមិនប្រែប្រួលក្តី តិរច្ឆានយោនិលោក បិត្តិវិសយលោក មនុស្ស-លោក ។បេ។ ព្រមទាំងទេវលោក មិនមានខ្ទីម ឥតខ្ទីម ប្រាសចាកខ្ទីម គឺចាកខ្ទីមគឺខ្ទីមទៀងក្តី ចាកខ្ទីមគឺខ្ទីមសុខក្តី ចាកខ្ទីមគឺខ្ទីមខ្លួនក្តី ចាកសភាវៈទៀងក្តី ចាកការឋិតថេរក្តី ចាកការមាំមួនក្តី ចាកសភាវៈមិនប្រែប្រួលក្តី ក៏យ៉ាងនោះដែរ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកមិនមានខ្ទីមដោយជុំវិញ ។

[ ១០២ ] ពាក្យថា សង្ខារក្នុងទិសទាំងអស់ញាប់ញ័រ អធិប្បាយថា ពួកសង្ខារណា ក្នុងទិសខាងកើត សង្ខារទាំងនោះឯងរំកើប ញាប់ញ័រ កក្រើក ខ្ទាំងខ្ទប់ជាប់តាមដោយជាតិ ព្រោះសភាពសង្ខារនោះមិនទៀង គឺត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈញាំញី ជាសង្ខារតាំងនៅក្នុងកងទុក្ខ ពុំមានទីពំនាក់ ពុំមានទីជ្រកកោន ពុំមានទីពឹង ពុំមានទីពំនាក់ឡើយ ។ ពួកសង្ខារណាក្នុងទិសខាងលិច ពួកសង្ខារណាក្នុងទិសខាងជើង ពួកសង្ខារណាក្នុងទិសខាងត្បូង ពួកសង្ខារណាក្នុងទិសអាគ្នេយ៍ ពួកសង្ខារណាក្នុងទិសពាយ័ព្យ ពួកសង្ខារណាក្នុងទិសឦសាន ពួកសង្ខារណាក្នុងទិសនិរតី ពួកសង្ខារណាក្នុងទិសខាងក្រោម ពួកសង្ខារណាក្នុងទិសខាងលើ ពួកសង្ខារណាក្នុងទិសទាំង ១០ សង្ខារទាំងនោះឯងរំកើប ញាប់ញ័រ កក្រើក ខ្ទាំងខ្ទប់ ជាប់តាមដោយជាតិ ព្រោះសភាពសង្ខារនោះមិនទៀង គឺត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈញាំញី ជាសង្ខារតាំងនៅក្នុងទុក្ខ ពុំមានទីពំនាក់ ពុំមានទីជ្រកកោន ពុំមានទីពឹង ពុំមានទីពំនាក់ឡើយ ។ សមដូចពាក្យនុ៎ះ ដែលព្រះមានព្រះភាគត្រាស់ថា

វិមានទាំងឡាយរុងរឿងខាំងក្នុងទិសក៏មែនពិតហើយ (តែ) បុគ្គល អ្នកមានប្រាជ្ញាល្អ ឃើញទោសដែលឲ្យញាប់ញ័រក្នុងរូប សព្វកាល ព្រោះហេតុនោះទើបមិនត្រេកអរក្នុងរូប ។

លោកត្រូវមច្ចុគ្របសង្កត់ ត្រូវជរាចោមរោម ត្រូវសរ គឺតណ្ហាមុត ប្រកបដោយផ្សែង គឺសេចក្តីប្រាថ្នាគ្រប់កាល លោកទាំងមូលត្រូវភ្លើងឆេះ លោកទាំងមូលប្រាលរន្ទាល លោកទាំងមូលសន្ធោសន្ធៅ លោកទាំងមូលរំភើប ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) សង្ខារក្នុងទិសទាំងអស់ញាប់ញ័រ ។

[ ១០៣ ] ពាក្យថា កាលប្រាថ្នាសេចក្តីចម្រើន ដើម្បីខ្លួន គឺកាលចង់បាន ត្រេកអរ ប្រាថ្នា ស្រឡាញ់ ក្ងួចកាន់ ចំពោះសេចក្តីចម្រើន ទីពំនាក់ ទីជ្រកកោន ទីពឹង ដំណើរ ការប្រព្រឹត្តទៅមុខដើម្បីខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលប្រាថ្នាសេចក្តីចម្រើនដើម្បីខ្លួន ។

[ ១០៤ ] ពាក្យថា តថាគតមិនឃើញ ( នូវទីណាមួយដែលទុក្ខ ) មិនញាំញី គឺមិនបានឃើញទីដែលទុក្ខមិនស្រោចចុះ បានឃើញតែទីដែលទុក្ខស្រោចចុះតែម្យ៉ាង ។ សេចក្តីចម្រើនទាំងពួង ត្រូវជរាញាំញី ភាពនៃការមិនមានរោគទាំងពួងត្រូវព្យាធិញាំញី ជីវិតទាំងពួងត្រូវមរណៈញាំញី លាភទាំងពួងត្រូវអលាភញាំញី យសទាំងពួងត្រូវអយសញាំញី សេចក្តីសរសើរទាំងពួងត្រូវនិន្ទាញាំញី សុខទាំងពួងត្រូវទុក្ខញាំញី ។

ពួកធម៌ទាំងនុ៎ះ គឺលាភ អលាភ យស អយស និន្ទា បសំសា

សុខនិងទុក្ខជាសភាពមិនទៀង មិនឋិតថេរ មានការប្រែប្រួល
ជាធម្មតាក្នុងពួកមនុស្ស ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតមិនឃើញ ( នូវទីណាមួយ ) ដែលទុក្ខមិនញាំញីឡើយ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

លោកមិនមានខ្លឹមដោយជុំវិញ សង្ខារក្នុងទិសទាំងអស់ញាប់
ញ័រ តថាគតកាលប្រាថ្នាសេចក្ដីចម្រើនដើម្បីខ្លួន មិនបានឃើញ
( នូវទីណាមួយដែលទុក្ខ ) មិនញាំញីឡើយ ។

[ ១០៥ ] សេចក្ដីមិនត្រេកអរកើតមានដល់តថាគត ព្រោះឃើញសត្វទាំងឡាយដែលទាស់ចិត្តក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ទាំងតថាគតបានឃើញសរក្នុងពួកសត្វនុ៎ះ ជាសរអាស្រ័យនៅក្នុងហឫទ័យដែលគេកម្រឃើញបាន ។

[ ១០៦ ] អធិប្បាយពាក្យថា ដែលទាស់ចិត្តក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ត្រង់ពាក្យថា ក្នុងកាលជាទីសាបសូន្យតែម្យ៉ាង សេចក្ដីថា ជរាញាំងភាពក្មេងទាំងពួងឲ្យសាបសូន្យ ព្យាធិញាំងភាពមិនមានរោគទាំងពួង ឲ្យសាបសូន្យ មរណៈញាំងជីវិតទាំងពួងឲ្យសាបសូន្យ អលាភញាំងលាភទាំងពួងឲ្យសាបសូន្យ អយសញាំងយសទាំងពួងឲ្យសាបសូន្យ និន្ទាញាំងសេចក្ដីសរសើរទាំងពួងឲ្យសាបសូន្យ ទុក្ខញាំងសុខទាំងពួងឲ្យសាបសូន្យ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ។ ពាក្យថា ទាស់ចិត្ត សេចក្ដីថា សត្វទាំងឡាយអ្នកប្រាថ្នាភាពក្មេង ថ្នាំងថ្នាក់នឹងជរា សត្វទាំងឡាយអ្នកប្រាថ្នាភាពមិនមានរោគ ថ្នាំងថ្នាក់នឹងព្យាធិ សត្វទាំងឡាយអ្នកប្រាថ្នាជីវិត ថ្នាំងថ្នាក់

នឹងមរណៈ សត្វទាំងឡាយអ្នកប្រាថ្នាលាភ ថ្នាំងថ្នាក់នឹងអលាភ សត្វទាំងឡាយអ្នកប្រាថ្នាយស ថ្នាំងថ្នាក់នឹងអយស សត្វទាំងឡាយអ្នកប្រាថ្នាសេចក្តីសរសើរ ថ្នាំងថ្នាក់នឹងនិន្ទា សត្វទាំងឡាយអ្នកប្រាថ្នាសុខ ទាស់ថ្នាំងថ្នាក់ ខ្នាំងខ្នាស់ ខ្នាំងខ្នាស់ចំពោះ ចង្អៀតចង្អល់ តានតឹងចិត្តដោយសារទុក្ខ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាស់ចិត្តក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ។

[ ១០៧ ] ពាក្យថា សេចក្តីមិនត្រេកអរកើតមានដល់តថាគត ព្រោះឃើញ ត្រង់ពាក្យថា ព្រោះឃើញ គឺព្រោះជួប យល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ព្រោះឃើញ ។ ពាក្យថា សេចក្តីមិនត្រេកអរ ( កើតមាន ) ដល់តថាគត គឺសេចក្តីមិនត្រេកអរណា សេចក្តីមិនរីករាយណា សេចក្តីមិនស្រស់ស្រាយណា សេចក្តីអផ្សុកណា សេចក្តីតក់ស្លុតណា មានហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីមិនត្រេកអរកើតមានដល់តថាគត ព្រោះឃើញ ។

[ ១០៨ ] ពាក្យថា ទាំងតថាគតបានឃើញសរក្នុងពួកសត្វនុ៎ះ ត្រង់ពាក្យថា ទាំង គឺជាបទតភ្ជាប់ ។បេ។ ពាក្យថា ទាំងនុ៎ះ ជាលំដាប់នៃបទ ។ ពាក្យថា នុ៎ះ បានដល់ ក្នុងពួកសត្វ ។ ពាក្យថា សរ បានដល់ សរ ៧ សរគឺរាគៈ សរគឺទោសៈ សរគឺមោហៈ សរគឺមានះ សរគឺទិដ្ឋិ សរគឺសោក សរគឺសង្ស័យ ។ ពាក្យថា បានឃើញ គឺបានប្រទះ យល់ ឃើញ ចាក់ធ្លុះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងតថាគតបានឃើញសរ ក្នុងពួកសត្វនុ៎ះ ។

[ ១០៩ ] អធិប្បាយពាក្យថា ជាសរអាស្រ័យនៅក្នុងហឫទ័យដែលគេ

កម្រឃើញបាន ត្រង់ពាក្យថា ដែលគេកម្រឃើញបាន គឺជួបប្រទះបានដោយក្រ យល់បានដោយក្រ ឃើញបានដោយក្រ ត្រាស់ដឹងបានដោយក្រ ឈ្វេងយល់បានដោយក្រ ចាក់ធ្លុះបានដោយក្រ ។ ពាក្យថា ជាសរអាស្រ័យនៅក្នុងហឫទ័យ សេចក្ដីថា ចិត្តលោកហៅថា ហឫទ័យ បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោ-វិញ្ញាណធាតុ ដែលកើតអំពីមនៈនោះ ។ ពាក្យថា ជាសរអាស្រ័យនៅក្នុងហឫទ័យ បានសេចក្ដីថា អាស្រ័យនៅក្នុងហឫទ័យ អាស្រ័យនូវចិត្ត អាស្រ័យនៅព្រមក្នុងចិត្ត ប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នានឹងចិត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាសរអាស្រ័យនៅក្នុងហឫទ័យ ដែលគេកម្រឃើញបាន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> សេចក្ដីមិនត្រេកអរកើតមានដល់តថាគត ព្រោះឃើញសត្វទាំងឡាយ ដែលទាស់ចិត្តក្នុងកាលជាទីសាបសូន្យតែម្យ៉ាង ទាំងតថាគតបានឃើញសរក្នុងពួកសត្វនុ៎ះ ជាសរអាស្រ័យនៅក្នុងហឫទ័យដែលគេកម្រឃើញបាន ។

[ ១១០ ] បុគ្គលដែលត្រូវសរណាមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅ មិនលិចចុះ ។

[ ១១១ ] អធិប្បាយពាក្យថា បុគ្គលដែលត្រូវសរណាមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង ត្រង់ពាក្យថា សរ បានដល់ សរ ៧ សរគឺរាគៈ សរ

គឺទោសៈ សរគឺមោហៈ សរគឺមានះ សរគឺទិដ្ឋិ សរគឺសេចក្តីសោក សរគឺសេចក្តីសង្ស័យ ។

សរគឺរាគៈ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង សេចក្តីស្រើបស្រាល សេចក្តីត្រេកត្រអាល សេចក្តីរីករាយ តម្រេកដែលប្រកបដោយសេចក្តីរីករាយ តម្រេកខ្លាំងនៃចិត្ត ។បេ។ អភិជ្ឈា លោភៈ អកុសលមូលឯណា នេះសរគឺរាគៈ ។

សរគឺទោសៈ តើដូចម្តេច ។ គំនុំកើតឡើងថា គេបានប្រព្រឹត្តនូវសេចក្តីវិនាសដល់អាត្មាអញ គំនុំកើតឡើងថា គេកំពុងប្រព្រឹត្តនូវសេចក្តីវិនាសដល់អាត្មាអញ គំនុំកើតឡើងថាគេនឹងប្រព្រឹត្តនូវសេចក្តីវិនាសដល់អាត្មាអញ ។បេ។ ភាពនៃចិត្តកាច ការញ៉ាំងទឹកភ្នែកឲ្យស្រក់ ភាពនៃចិត្តមិនត្រេកអរ នេះសរគឺទោសៈ ។

សរគឺមោហៈ តើដូចម្តេច ។ ការមិនដឹងទុក្ខ ។បេ។ ការមិនដឹងនូវសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ការមិនដឹងទីបំផុតខាងដើម ការមិនដឹងទីបំផុតខាងចុង ការមិនដឹងទីបំផុតខាងដើមនិងទីបំផុតខាងចុង ការមិនដឹងក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យគ្នានឹងគ្នា ព្រោះរបស់នេះជាបច្ច័យ ការមិនឃើញ ការមិនយល់ច្បាស់ ការមិនភ្ញាក់រឭក ការមិនត្រាស់ដឹង ការមិនចាក់ធ្លុះ ការមិនកាន់យកស៊ប់ ការមិនស្ទង់ចុះស៊ប់ ការសម្លឹងមើលមិនស្មើ ការមិនពិចារណា អំពើមិនជាក់ច្បាស់ ការមិនថ្លូរថ្លង់ ភាពនៃសេចក្តីល្ងង់ខ្លៅ សេចក្តីវង្វេង សេចក្តីវង្វេងខ្លាំង សេចក្តីវង្វេងជ្រប់ អវិជ្ជា អន្លង់គឺអវិជ្ជា

យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានគឺអវិជ្ជា គន្លឹះគឺអវិជ្ជា មោហៈ អកុសលមូលឯណា មានសភាពយ៉ាងនេះ នេះសរគឺមោហៈ ។

សរគឺមានះ តើដូចម្តេច ។ សេចក្តីប្រកាន់ថា អាត្មាអញជាបុគ្គលប្រសើរ ការប្រកាន់ថា អាត្មាអញជាបុគ្គលស្មើ ការប្រកាន់ថា អាត្មាអញជាបុគ្គលថោកទាប សេចក្តីប្រកាន់ ការប្រកាន់ ភាពនៃសេចក្តីប្រកាន់ ការឆ្មើងឆ្មៃ ការក្រអឺតក្រអោង សភាពដូចទង់ ការប្រកាន់ចិត្ត ភាពនៃចិត្តប្រាថ្នាដូចទង់ឯណា មានសភាពយ៉ាងនេះ នេះសរគឺមានះ ។

សរគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិមានវត្ថុ ២០ មិច្ឆាទិដ្ឋិមានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិមានវត្ថុ ១០ ទិដ្ឋិដំណើរគឺទិដ្ឋិ ការប្រកាន់គឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ គ្រឿងញាប់ញ័រគឺទិដ្ឋិ សំយោជនៈគឺទិដ្ឋិ ការកាន់យក ការកាន់មាំ ការប្រកាន់ ការស្ទាបអង្អែល ផ្លូវអាក្រក់ គន្លងខុស ភាពនៃសេចក្តីខុស លំនៅដូចជាកំពង់ ការប្រកាន់ក្នុងការស្វែងរកខុស ការប្រកាន់ក្លាត់ ការប្រកាន់ឃ្លៀងឃ្លាត ការប្រកាន់ខុស ការប្រកាន់ក្នុងវត្ថុមិនពិត ថាជាវត្ថុពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន មានសភាពយ៉ាងនេះ នេះសរគឺទិដ្ឋិ ។

សរគឺសេចក្តីសោក តើដូចម្តេច ។ ការសោក អាការសោក ភាពនៃការសោក ការស្ងួតស្ងប់ក្នុង ការស្រពោនក្នុង ការក្តៅក្នុង ការក្តៅរោលរាលខាងក្នុង ការសញ្ជប់សញ្ជឹងនៃចិត្ត ការតូចចិត្តរបស់បុគ្គលដែលត្រូវវិនាសចាកញាតិប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាសគឺរោគប៉ះពាល់ក្តី ត្រូវវិនាសចាកសីលប៉ះពាល់ក្តី ត្រូវវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយវិនាស

ណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី នេះសរគឺសេចក្តីសោក ។

សរគឺសេចក្តីសង្ស័យ តើដូចម្តេច ។ សេចក្តីសង្ស័យក្នុងទុក្ខ សេចក្តីសង្ស័យក្នុងទុក្ខសមុទ័យ សេចក្តីសង្ស័យក្នុងទុក្ខនិរោធ សេចក្តីសង្ស័យក្នុងទុក្ខនិរោធគាមិនីបដិបទា សេចក្តីសង្ស័យក្នុងទីបំផុតខាងដើម សេចក្តីសង្ស័យក្នុងទីបំផុតខាងចុង សេចក្តីសង្ស័យ ក្នុងទីបំផុតខាងដើមនិងទីបំផុតខាងចុង សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យគ្នានឹងគ្នា ព្រោះរបស់នេះជាបច្ច័យ សេចក្តីសង្ស័យ អាការសង្ស័យ ភាពនៃសេចក្តីសង្ស័យ ការប្រាសចាកសេចក្តីយល់ ការងឿងឆ្ងល់ ផ្លូវបែកជាពីរ ការអល់អែក ការកាន់យកនូវចំណែកច្រើនយ៉ាង ការស្ទាក់ស្ទើរ ការអង្អឹអង្អែ ការមិនចុះចិត្តស៊ប់ ភាពនៃចិត្តច្រួលច្រាល់ ការសាំញុំនៃចិត្តឯណា មានសភាពយ៉ាងនេះ នេះសរគឺសេចក្តីសង្ស័យ ។

[ ១១២ ] ពាក្យថា បុគ្គលត្រូវសរណាមុតហើយរមែងស្ទុះទៅកាន់ទិសទាំងពួង អធិប្បាយថា បុគ្គលត្រូវសរគឺរាគៈមុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ញាំញីទន្ទ្រានហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់នូវតំណ ( នៃផ្ទះ ) ខ្លះ ប្លន់ធំខ្លះ ធ្វើការប្លន់ក្នុងផ្ទះមួយខ្លះ ឈរស្ទាក់ប្រកផ្លូវខ្លះ គប់រកកិរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ បុគ្គលដែលត្រូវសរ គឺរាគៈមុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គល

ដែលត្រូវសេរ គឺរាគៈ មុត ធ្នុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ កាលស្វែងរកភោគៈទាំងឡាយ រមែងស្ទុះទៅកាន់មហាសមុទ្រដោយនាវា ត្រូវត្រជាក់បៀតបៀន ត្រូវកម្ដៅបៀតបៀន លំបាកដោយសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ ពស់តូចនិងពស់ធំ ត្រូវសេចក្ដីស្រេកឃ្លានបៀតបៀន ក៏ទៅកាន់ដែនឈ្មោះគុម្ពៈ ទៅកាន់ស្រុកតក្កោលៈ ទៅកាន់ស្រុកតក្កសិលា ទៅកាន់ស្រុកកាលមុខៈ ទៅកាន់ស្រុកមរណបារៈ ទៅកាន់ស្រុកវេសុង្គៈ ទៅកាន់ស្រុកវេរាបថៈ ទៅកាន់ស្រុកជវៈ ទៅកាន់ស្រុកតម្ពលិង្គៈ ទៅកាន់ស្រុកវង្គៈ ទៅកាន់ស្រុកឯឡវទ្ធនៈ ទៅកាន់ស្រុកសុវណ្ណកូដៈ ទៅកាន់ស្រុកសុវណ្ណភូមិ ទៅកាន់ស្រុកតម្ពបណ្ណិ ទៅកាន់ស្រុកសុប្បារៈ ទៅកាន់ស្រុកភរុកៈ ទៅកាន់ស្រុកសុរដ្ឋៈ ទៅកាន់ស្រុកអង្គណេកៈ ទៅកាន់ស្រុកគង្គណៈ ទៅកាន់ស្រុកបរមគង្គណៈ ទៅកាន់ស្រុកយោនៈ ទៅកាន់ស្រុកបិនកៈ ទៅកាន់អល្លសណ្ឌៈ ទៅកាន់មរុកន្តារៈ ទៅកាន់ជណ្ណុបថ ទៅកាន់អជបថ ទៅកាន់មេណ្ឌបថ ទៅកាន់សង្កុបថ ទៅកាន់ឆត្តបថ ទៅកាន់វំសបថ ទៅកាន់សកុណបថ ទៅកាន់មូសិកាបថ ទៅកាន់ទរិបថ ទៅកាន់វេត្តាចារៈ ។ កាលស្វែងរកមិនបានរមែងទទួលទុក្ខទោមនស្ស មានការមិនបានជាមូលខ្វះ កាលស្វែងរកក៏រកបាន លុះបានហើយ ក៏ទទួលទុក្ខទោមនស្ស មានការរក្សាជាមូលថា ធ្វើម្ដេចហ្ន៎ ព្រះរាជាមិនគប្បីយកភោគៈទាំងឡាយ ចោរទាំងឡាយមិន គប្បីលួចយកភោគៈទាំងឡាយរបស់អាត្មាអញ ភ្លើងមិនគប្បីឆេះ ទឹកមិនគប្បីបន្សាត់ ទាយាទទាំងឡាយមិនជាទីស្រឡាញ់មិនគប្បីនាំយកទៅបានដូច្នេះខ្វះ ។ បុគ្គលនោះ កាលរក្សាគ្រប់គ្រង

យ៉ាងនេះ ភោគៈទាំងនោះក៏គង់វិនាសទៅ ។ បុគ្គលនោះក៏ទទួលទុក្ខទោមនស្ស មានការព្រាត់ប្រាស់ជាមូលខ្លះ ។ បុគ្គលដែលត្រូវសរ គឺរាគៈមុត ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្អុះទៅ រត់ទៅ រលេះរលាំងទៅ អន្ទោលទៅយ៉ាងនេះខ្លះ ។ បុគ្គលដែលត្រូវសរ គឺទោសៈ សរគឺមោហៈ សរគឺមានះ មុត ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយរមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់នូវតំណខ្លះ ប្លន់ធំខ្លះ ធ្វើការប្លន់ក្នុងផ្ទះមួយខ្លះ ឈរស្កាត់ប្រកផ្លូវខ្លះ គប់រកកិរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ បុគ្គលដែលត្រូវសរ គឺមានះ មុត ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយរមែងស្អុះទៅ រត់ទៅ រលេះ រលាំងទៅ អន្ទោលទៅយ៉ាងនេះឯង ។

បុគ្គលដែលត្រូវសរ គឺទិដ្ឋិមុត ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងទៅជាអចេលក៍ ( គ្មានសំពត់ ) លះបង់មារយាទ ស៊ីលិទ្ធដៃ ( និងជម្រះឧច្ចារដោយម្រាមដៃ ) ជាអ្នកមិនទទួលភត្តដែលមានគេហៅរកថា លោកដ៏ចម្រើនចូរមក ជាអ្នកមិនទទួលភត្តដែលមានគេឃាត់ថា លោកដ៏ចម្រើនចូរឈប់ មិនទទួលភត្តដែលមានគេនាំមកមុន មិនទទួលភត្តដែលមានគេធ្វើចំពោះ មិនត្រេកអរនឹងកិច្ចនិមន្ត ។ អចេលក៍នោះ មិនទទួលភត្តដែលឃើញគេដោះអំពីមាត់ឆ្នាំង មិនទទួលភត្តដែលឃើញគេដោះអំពីមាត់កញ្ជើ មិនទទួលភត្តនៅចន្លោះធរណីទ្វារ មិនទទួលភត្តនៅចន្លោះកំណាត់ឈើ មិនទទួលភត្ត

នៅចន្លោះអង្រែ មិនទទួលភត្តរបស់មនុស្សពីរនាក់កំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្តរបស់ស្ត្រីកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីកំពុងនៅរួមនឹងបុរស មិនទទួលភត្តដែលគេអង្គាសមក ( មិនទទួលភត្ត ) ក្នុងទីដែលមានឆ្កែចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកមេរ័យ មិនផឹកទឹកថ្នាំ ដែលត្រាំដោយស្រូវទាំងពួង ។ អចេលនៈនោះ ជាអ្នកទទួលភត្តតែក្នុងផ្ទះមួយ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្លះ ទទួលភត្តតែក្នុងផ្ទះពីរ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្លះ ។បេ។ ទទួលភត្តតែក្នុងផ្ទះ ៧ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ១ ភាជន៍តូចខ្លះ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ២ ភាជន៍តូចខ្លះ ។បេ។ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ៧ ភាជន៍តូចខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ។បេ។ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ អចេលក៍ប្រកបដោយសេចក្ដីព្យាយាម ក្នុងការផ្លាស់ប្ដូរនូវការបរិភោគភត្ត រំលងកន្លះខែខ្លះ មានសភាពយ៉ាងនេះដូច្នេះឯង ។ បុគ្គលដែលត្រូវសរ គឺទិដ្ឋិមុត ជ្ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅ យ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលដែលត្រូវសរ គឺទិដ្ឋិ មុត ជ្ជុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ បុគ្គលនោះជាអ្នកមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានចំនៀរស្បែកជាអាហារខ្លះ មានស្នែឬសារាយជាអាហារខ្លះ មានបាយក្ដាំងជាអាហារ

ខ្លះ មានមេម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមនិងផ្លែឈើក្នុងព្រៃជាអាហារ បរិភោគតែផ្លែឈើដែលជ្រុះឯងខ្លះ ។ បុគ្គលនោះទ្រទ្រង់សំពត់សំបកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំបកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាខ្លះ ទ្រទ្រង់សំពត់បង្សុកូលខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់ស្បូវក្រងខ្លះ ទ្រទ្រង់សំពត់ត្បាញដោយសំបកក្របៅខ្លះ ទ្រទ្រង់ចំរៀកក្តារជាសំពត់ខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុកសក់និងពុកមាត់ខ្លះ ជាអ្នកប្រកបរឿយៗនូវការព្យាយាមក្នុងការទុកសក់នឹងពុកមាត់ ជាអ្នកឈរងើយឡើងលើ ហាមឃាត់អាសនៈខ្លះ អង្គុយប្រហោងប្រព្រឹត្តកាន់វត្ត ក្នុងការព្យាយាម អង្គុយប្រហោងខ្លះ ដេកលើបន្លាខ្លះ សម្រេចការដេកលើបន្លាខ្លះ សម្រេចការដេកលើចម្រៀកក្តារខ្លះ សម្រេចការដេកលើផែនដីទួលខ្លះ ប្រព្រឹត្តដេកផ្អៀងតែម្ខាងខ្លះ ទ្រទ្រង់ក្អែលខ្លះ ប្រព្រឹត្តនៅក្នុងទីវាលខ្លះ ប្រព្រឹត្តនៅក្នុងទីតាមតែប្រទះខ្លះ ជាអ្នកស៊ីលាមកខ្លះ ប្រកបក្នុងការបរិភោគលាមកខ្លះ មិនផឹកទឹកត្រជាក់ប្រកបក្នុងការបរិភោគនូវភត្ត មិនបាច់ផឹកទឹកត្រជាក់ខ្លះ ប្រកបរឿយៗ នូវព្យាយាមក្នុងការចុះត្រាំទឹកជាគំរប់ ៣ ដង នឹងពេលល្ងាចខ្លះ បុគ្គលជាអ្នកប្រកបរឿយៗនូវព្យាយាមក្នុងការផ្អើរកម្តៅកាយច្រើនប្រការ មានសភាពយ៉ាងនេះដូច្នេះឯង ។ បុគ្គលដែលត្រូវសរ គឺទិដ្ឋិ មុត ជ្ចុះ ពាល់ត្រូវ គ្របសង្កត់ញាំញី ទន្ទ្រានហើយរមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅយ៉ាង

នេះខ្ទះ ។

បុគ្គលដែលត្រូវសេចក្តីសោក មុត ធុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយរមែងស្តាយស្រណោះ លំបាក ខ្សឹកខ្សួល គក់ទ្រូងដល់នូវសេចក្តីវង្វេង ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ហើយថា ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ មាតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ ស្ត្រីនោះទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃមាតានោះ ហើយក៏ដើរចេញអំពីច្រក ចូលទៅច្រក ចេញអំពីផ្លូវត្រឡែងកែងចូលទៅផ្លូវត្រឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយបានឃើញមាតារបស់ខ្ញុំដែរឬ អ្នកទាំងឡាយ បានឃើញមាតារបស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ បិតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ បងប្អូនប្រុសបានធ្វើមរណកាលហើយ បងប្អូនស្រី បានធ្វើមរណកាលហើយ បុត្តបានធ្វើមរណកាលហើយ ធីតាបានធ្វើមរណកាលហើយ ស្វាមីបានធ្វើមរណកាលហើយ ។ ស្ត្រីនោះ ក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃស្វាមីនោះ ហើយក៏ដើរចេញអំពីច្រក ចូលទៅកាន់ច្រក ចេញអំពីផ្លូវត្រឡែងកែងចូលទៅកាន់ផ្លូវត្រឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយបានឃើញស្វាមីរបស់ខ្ញុំដែរឬ អ្នកទាំងឡាយបានឃើញស្វាមីរបស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ មាតារបស់បុរសម្នាក់ក្នុងក្រុងសាវត្ថីនេះឯងបានធ្វើមរណកាលហើយ ។ បុរសនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ព្រោះកាលកិរិយានៃមាតានោះ ហើយក៏ដើរ

ចេញអំពីច្រក ចូលទៅកាន់ច្រក ចេញអំពីផ្លូវត្រឡែងកែង ចូលទៅកាន់ផ្លូវត្រឡែងកែងហើយពោលយ៉ាងនេះថា អ្នកទាំងឡាយ បានឃើញមាតារបស់ខ្ញុំដែរឬ អ្នកទាំងឡាយ បានឃើញមាតារបស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ហេតុធ្លាប់មានមកហើយ បិតារបស់បុរសម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលហើយ បងប្អូនប្រុសបានធ្វើមរណកាលហើយ បងប្អូនស្រីបានធ្វើមរណកាលហើយ បុត្តបានធ្វើមរណកាលហើយ ធីតាបានធ្វើមរណកាលហើយ ភរិយាបានធ្វើមរណកាលហើយ ។ បុរសនោះ ក៏ទៅជាឆ្កួត មានចិត្តរវើរវាយព្រោះកាលកិរិយានៃភរិយានោះ ហើយដើរចេញអំពីច្រកចូលទៅកាន់ច្រក ចេញអំពីផ្លូវត្រឡែងកែងចូលទៅកាន់ផ្លូវត្រឡែងកែង ហើយពោលយ៉ាងនេះថា អ្នកទាំងឡាយ បានឃើញភរិយារបស់ខ្ញុំដែរឬ អ្នកទាំងឡាយ បានឃើញភរិយារបស់ខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ហេតុធ្លាប់មានមកហើយ ស្ត្រីម្នាក់ក្នុងក្រុងសាវត្ថីនេះឯង បានទៅកាន់ត្រកូលញាតិ ។ ពួកជនជាញាតិទាំងនោះមានប្រាថ្នាផ្ដាច់ស្វាមីរបស់ស្ត្រីនោះ ហើយឲ្យដល់បុរសឯទៀត ។ តែស្ត្រីនោះមិនចង់បានបុរសនោះទេ ។ គ្រានោះស្ត្រីនោះបានពោលពាក្យនេះនឹងស្វាមីថា ម្នាលអយ្យបុត្ត ពួកជនជាញាតិទាំងនេះ មានប្រាថ្នាផ្ដាច់អ្នក ហើយឲ្យខ្ញុំដល់បុរសឯទៀត យើងទាំងពីរនាក់នឹងស្លាប់ ។ គ្រានោះបុរសនោះកាត់ស្ត្រីនោះជាពីរកំណាត់ហើយសម្លាប់ខ្លួនឯងថា យើងទាំងពីរនាក់នឹងបានជួបគ្នាក្នុងបរលោក ។ បុគ្គលដែលត្រូវសរគឺសោក មុត ផ្ទះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយរមែងស្តុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅយ៉ាង

នេះ ។

បុគ្គលដែលត្រូវសរ គឺសេចក្តីសង្ស័យ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយ ជាអ្នកស្ទុះទៅកាន់សេចក្តីសង្ស័យ ស្ទុះទៅកាន់សេចក្តីយល់ខុស ជាអ្នកយល់បែកជាពីរថា ក្នុងអតីតកាលអាត្មាអញបានកើតឬហ្ន៎ ក្នុងអតីតកាលអាត្មាអញមិនបានកើតទេឬហ្ន៎ ក្នុងអតីតកាល អាត្មាអញបានកើតដូចម្តេចហ្ន៎ ក្នុងអតីតកាលអាត្មាអញបានកើតដោយប្រការដូចម្តេចហ្ន៎ ក្នុងអតីតកាលអាត្មាអញមានសភាពដូចម្តេច បានកើតដូចម្តេចហ្ន៎ ក្នុងអនាគត-កាល អាត្មាអញនឹងមានឬហ្ន៎ ក្នុងអនាគតកាលអាត្មាអញនឹងមិនមានទេឬហ្ន៎ ក្នុងអនាគតកាលអាត្មាអញនឹងមិនមានដូចម្តេចហ្ន៎ ក្នុងអនាគតកាលអាត្មាអញនឹងមានដោយប្រការដូចម្តេចហ្ន៎ ក្នុងអនាគតកាល អាត្មាអញមានសភាពដូចម្តេច នឹងមានទៀតដូចម្តេចហ្ន៎ ។ បុគ្គលអ្នកមានសេចក្តីសង្ស័យក្នុងសន្តានក្នុងបច្ចុប្បន្នឥឡូវនេះថា អាត្មាអញមានឬហ្ន៎ អាត្មាអញមិនមានទេឬហ្ន៎ អាត្មាអញមានដូចម្តេចហ្ន៎ អាត្មាអញមានដោយប្រការដូចម្តេចហ្ន៎ សត្វមកអំពីទីណា សត្វនោះនឹងទៅក្នុងទីណា ។ បុគ្គលដែលត្រូវសរ គឺសេចក្តីសង្ស័យ មុត ធ្លុះ ពាល់ត្រូវ គ្របសង្កត់ ញាំញី ទន្ទ្រានហើយរមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅ អន្ទោលទៅយ៉ាងនេះ ។ បុគ្គលបង្កើតសរទាំងនោះ កាលបើបង្កើតសរទាំងនោះរមែងស្ទុះទៅក្នុងបុរត្ថិមទិស ស្ទុះទៅក្នុងបច្ឆិមទិស ស្ទុះទៅក្នុងឧត្តរទិស ស្ទុះទៅក្នុងទក្ខិណទិស ដោយអំណាចនៃការបង្កើតសរ ។ ការបង្កើតសរទាំងនោះបើបុគ្គលមិនបានលះបង់ហើយ បុគ្គលក៏រមែងស្ទុះទៅក្នុងគតិ ស្ទុះទៅក្នុង

នរក ស្ទុះទៅក្នុងកំណើតតិរច្ឆាន ស្ទុះទៅក្នុងបិត្តិវិស័យ ស្ទុះទៅក្នុងមនុស្ស-លោក ស្ទុះទៅក្នុងទេវលោក ព្រោះការបង្កើតសរដែលខ្លួនមិនទាន់លះបង់បាន រមែងស្ទុះទៅ រត់ទៅ រលះរលាំងទៅអន្ទោលទៅអំពីគតិកាន់គតិ អំពីកំណើតកាន់កំណើត អំពីបដិសន្ធិកាន់បដិសន្ធិ អំពីភពកាន់ភព អំពីសង្សារកាន់សង្សារ អំពីវដ្តៈកាន់វដ្តៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដែលត្រូវសរណាមុតហើយ រមែងស្ទុះទៅកាន់ទិសទាំងពួង ។

[ ១១៣ ] ពាក្យថា បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅ មិនលិចចុះ សេចក្តីថា បុគ្គលដក កើច ទាញ កន្ត្រាក់ គាស់ រំលើង លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានទូវសរគឺរាគៈ សរគឺទោសៈ សរគឺមោហៈ សរគឺមានះ សរគឺទិដ្ឋិ សរគឺសោកៈ សរគឺសេចក្តីសង្ស័យនោះឯងបាន ទើបមិនស្ទុះទៅក្នុងបុរត្ថិមទិស មិនស្ទុះទៅក្នុងបច្ឆិមទិស មិនស្ទុះទៅក្នុងឧត្តរទិស មិនស្ទុះទៅក្នុងទក្ខិណទិសទេ ។ ការបង្កើតសរទាំងនោះ បើបុគ្គលលះបង់បានហើយ បុគ្គលក៏រមែងមិនស្ទុះទៅក្នុងគតិ មិនស្ទុះទៅក្នុងនរក មិនស្ទុះទៅក្នុងកំណើតតិរច្ឆាន មិនស្ទុះទៅក្នុងបិត្តិវិស័យ មិនស្ទុះទៅក្នុងមនុស្សលោក មិនស្ទុះទៅក្នុងទេវលោក ព្រោះការបង្កើតសរដែលបុគ្គលលះបង់បានហើយ គឺបុគ្គលមិនស្ទុះអំពីគតិកាន់គតិ មិនស្ទុះអំពីកំណើតកាន់កំណើត មិនស្ទុះអំពីបដិសន្ធិកាន់បដិសន្ធិ មិនស្ទុះអំពីភពកាន់ភព មិនស្ទុះអំពីសង្សារកាន់សង្សារ មិនស្ទុះ រត់ រលះរលាំង អន្ទោលអំពីវដ្តៈកាន់វដ្តៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដកសរនោះហើយទើបមិនស្ទុះទៅ ។ ពាក្យថា មិនលិចចុះ គឺ

មិនលិចចុះក្នុងអន្លង់គឺកាម មិនលិចចុះក្នុងអន្លង់គឺភព មិនលិចចុះក្នុងអន្លង់គឺទិដ្ឋិ មិនលិចចុះ មិនជ្រមុជ មិនសំយុងចុះ មិនធ្លាក់ចុះ មិនឈមចុះ ក្នុងអន្លង់គឺអវិជ្ជា ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលដកសរនោះហើយ ទើបមិនស្ទុះទៅ មិនលិចចុះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា

បុគ្គលដែលត្រូវសរណាមួយមុតហើយ រមែងស្ទុះទៅកាន់ទិស
ទាំងពួង បុគ្គលដកសរនោះហើយទើបមិនស្ទុះទៅ មិនលិចចុះ ។

[ ១១៤ ] ( ព្រះមានព្រះភាគត្រាស់ថា អារម្មណ៍ទាំងឡាយណាក្នុងលោកដែលសត្វជាប់ចំពាក់ ) ការសិក្សាក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន បុគ្គលមិនគប្បីខ្វល់ខ្វាយ ក្នុងគ្រឿងចំពាក់ទាំងនោះទេ គប្បីយល់ច្បាស់នូវកាមទាំងឡាយដោយសព្វគ្រប់ ហើយគប្បីសិក្សានូវព្រះនិព្វានដើម្បីខ្លួន ។

[ ១១៥ ] អធិប្បាយពាក្យថា អារម្មណ៍ទាំងឡាយណាក្នុងលោកដែលសត្វជាប់ចំពាក់ ការសិក្សាក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន ត្រង់ពាក្យថា ការសិក្សា បានដល់ ការសិក្សាខាងដំរី ការសិក្សាខាងសេះ ការសិក្សាខាងបររថ ការសិក្សាខាងធ្នូ វេជ្ជកម្មដោយស្លាក វេជ្ជកម្មដោយការវះកាត់ វេជ្ជកម្មដោយការរក្សាកាយ វេជ្ជកម្មខាងខ្មោច វេជ្ជកម្មខាងការរក្សាក្មេង ។ ពាក្យថា គេតែងរៀន គឺគេតែងរៀន សម្តែង និយាយ បំភ្លឺ បញ្ចេញ ។ ឬគេតែងរៀនកាន់ទន្ទេញ ទ្រទ្រង់ ចងចាំ កំណត់ ដើម្បីបាននូវអារម្មណ៍ដែលជាប់ចំពាក់ ។ កាមគុណ ៥ គឺរូបទាំងឡាយដែលដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ត្រេកអរពេញចិត្ត ស្រឡាញ់ ប្រកបដោយកាមដែលគួរត្រេកអរ លោកហៅថា គ្រឿង

ជាប់ចំពាក់ ។ កាមគុណ ៥ លោកហៅថា គ្រឿងជាប់ចំពាក់ តើហេតុដូចម្តេច ។ ( ព្រោះថា ) ទេវតានិងមនុស្សទាំងឡាយ ច្រើនតែប្រាថ្នា ត្រេកអរ ស្រឡាញ់ ចូលចិត្តនូវកាមគុណ ៥ ហេតុនោះកាមគុណ ៥ លោកហៅថា គ្រឿងជាប់ចំពាក់ ។ ពាក្យថា ក្នុងលោក គឺក្នុងមនុស្សលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) អារម្មណ៍ទាំងឡាយណា ក្នុងលោកដែលសត្វជាប់ចំពាក់ ការសិក្សាក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន ។

[ ១១៦ ] ពាក្យថា បុគ្គលមិនគប្បីខ្វល់ខ្វាយក្នុងគ្រឿងចំពាក់ទាំងនោះ សេចក្តីថា បុគ្គលមិនគប្បីខ្វល់ខ្វាយក្នុងការសិក្សាទាំងនោះ ឬក្នុងកាមគុណ ៥ ទាំងនោះ មិនគប្បីបង្អោនទៅកាន់កាមគុណនោះ មិនគប្បីទោរទន់ទៅរកកាមគុណនោះ មិនគប្បីឈមទៅរកកាមគុណនោះ មិនគប្បីចុះស៊ប់ក្នុងកាមគុណនោះ មិនគប្បីយកកាមគុណនោះជាធំ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនគប្បីខ្វល់ខ្វាយក្នុងគ្រឿងចំពាក់ទាំងនោះទេ ។

[ ១១៧ ] ពាក្យថា គប្បីយល់ច្បាស់នូវកាមទាំងឡាយដោយសព្វគ្រប់ ត្រង់ពាក្យថា យល់ច្បាស់ គឺយល់ច្បាស់ យល់ច្បាស់ថា សង្ខារទាំងឡាយទាំងពួងមិនទៀង យល់ច្បាស់ថា សង្ខារទាំងឡាយទាំងពួងជាទុក្ខ ។បេ។ យល់ច្បាស់ថា ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា ដោយសព្វគ្រប់ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសេសសល់ ពាក្យថា សព្វគ្រប់ នុ៎ះ ជាពាក្យអស់រលីង ។ ពាក្យថា កាម បើតាមឧទានបានដល់កាម ២ គឺ

វត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថា កិលេសកាម ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីយល់ច្បាស់នូវកាមទាំងឡាយ ដោយសព្វគ្រប់ ។

[ ១១៨ ] អធិប្បាយពាក្យថា គប្បីសិក្សានូវព្រះនិព្វាន ដើម្បីខ្លួន ត្រង់ពាក្យថា សិក្សា បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។បេ។ នេះអធិប្បញ្ញាសិក្ខា ។ ពាក្យថា ព្រះនិព្វានដើម្បីខ្លួន សេចក្តីថា បុគ្គលគប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីរំលត់រាគៈ ដើម្បីរំលត់ទោសៈ ដើម្បីរំលត់មោហៈរបស់ខ្លួន ។បេ។ ដើម្បីរម្ងាប់ ដើម្បីស្ងប់ ដើម្បីស្ងប់រម្ងាប់ ដើម្បីរំលត់ ដើម្បីរលាស់ចេញ ដើម្បីលះបង់ ដើម្បីកម្ចាត់បង់នូវអភិសង្ខារជាអកុសលទាំងពួង ។ បុគ្គលគប្បីពិចារណាសិក្សានូវសិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា ។បេ។ គប្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ សិក្សា ប្រព្រឹត្តដោយអើពើ ប្រព្រឹត្តដោយត្រឹមត្រូវ ប្រព្រឹត្តជឿកាន់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីសិក្សានូវព្រះនិព្វានដើម្បីខ្លួន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

( អារម្មណ៍ទាំងឡាយណា ក្នុងលោកដែលសត្វជាប់ចំពាក់ )
ការសិក្សាក្នុងអារម្មណ៍ទាំងនោះ គេតែងរៀន បុគ្គលមិនគប្បី
ខ្វល់ខ្វាយក្នុងគ្រឿងចំពាក់ទាំងនោះទេ គប្បីយល់ច្បាស់នូវកាម
ទាំងឡាយដោយសព្វគ្រប់ហើយសិក្សានូវព្រះនិព្វានដើម្បីខ្លួន ។

[ ១១៩ ] មុនិគប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្មើសឃ្មង មិនមានមាយា

មានពាក្យញុះញង់លះបង់ហើយ ជាអ្នកមិនក្រោធ រមែងឆ្លងផុតលោភៈដ៏លាមកនិងសេចក្តីកំណាញ់បាន ។

[ ១២០ ] អធិប្បាយពាក្យថា គប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្នើសឃ្នង ត្រង់ពាក្យថា គប្បីជាអ្នកមានសច្ចៈ គឺគួរជាអ្នកប្រកបដោយសច្ចវាចាគួរប្រកបដោយសម្មាទិដ្ឋិ គួរប្រកបដោយមគ្គដ៏ប្រសើរមានអង្គ ៨ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីជាអ្នកមានសច្ចៈ ។ ពាក្យថា ជាអ្នកមិនឃ្នើសឃ្នង បានដល់ការឃ្នើសឃ្នង ៣ គឺការឃ្នើសឃ្នងដោយកាយ ១ ការឃ្នើសឃ្នងដោយវាចា ១ ការឃ្នើសឃ្នងដោយចិត្ត ១ ។បេ។ នេះការឃ្នើសឃ្នងដោយចិត្ត ។ ការឃ្នើសឃ្នង ៣ នេះ បុគ្គលណាបានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនឃ្នើសឃ្នង ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្នើសឃ្នង ។

[ ១២១ ] ពាក្យថា មិនមានមាយា មានពាក្យញុះញង់លះបង់ហើយ អធិប្បាយថា ការប្រព្រឹត្តជាគ្រឿងបញ្ឆោត លោកហៅថា មាយា ។ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងប្រាថ្នាដ៏លាមក ព្រោះហេតុនៃការបិទបាំងនូវអំពើទុច្ចរិតនោះ រមែងប្រាថ្នាថា សូមកុំឲ្យអ្នកផងដឹងនូវអញ រមែងត្រិះរិះថា សូមកុំឲ្យអ្នកផងដឹងនូវអញ ពោលវាចាថា សូមកុំឲ្យអ្នកផងដឹងនូវអញ ប្រឹងប្រែងដោយកាយថា សូមកុំឲ្យអ្នកផងដឹងនូវអញ មាយា ភាពនៃបុគ្គលមានកល

លាក់ពុត ការប្រព្រឹត្តឈ្លានពាន ការបញ្ឆោត ការលាក់កំទួច ការលួចគំនិត ការវាសវាង ការគេចកែ ការលាក់លៀម ការកែកាញ់ ការបិទបាំង ការបិទទុកដោយជុំវិញ អំពើមិនផ្ងារ អំពើមិនច្បាស់ ការបិទជិតស្លុង កិរិយាដ៏លាមកណា មានសភាពយ៉ាងនេះ នេះលោកហៅថា មាយា ។ មាយានុ៎ះ បុគ្គលណាបានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានមាយា ។ ពាក្យថា មានពាក្យញុះញង់លះបង់ហើយ ត្រង់ពាក្យថា ញុះញង់ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលពាក្យញុះញង់ ។បេ។ បុគ្គលមានសេចក្តីប៉ុនប៉ងដើម្បីបំបែក រមែងនាំមកនូវពាក្យញុះញង់យ៉ាងនេះឯង ។ ពាក្យញុះញង់នុ៎ះ បុគ្គលណាបានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមានពាក្យញុះញង់លះបង់ហើយ គឺមានពាក្យញុះញង់ប្រាសចេញហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនមានមាយា មានពាក្យញុះញង់លះបង់ហើយ ។

[ ១២២ ] អធិប្បាយពាក្យថា មុនិ ជាអ្នកមិនក្រោធ រមែងឆ្លងផុតលោកៈដ៏លាមកនិងសេចក្តីកំណាញ់បាន ត្រង់ពាក្យថា ជាអ្នកមិនក្រោធ លោកបានពោលហើយក៏ពិតមែនហើយ ។ តែខ្ញុំគួរពោលពីសេចក្តីក្រោធ ជាមុនសិន ។ សេចក្តីក្រោធ រមែងកើតឡើងដោយអាការ ១០ យ៉ាង ។បេ។ សេចក្តីក្រោធនុ៎ះ បុគ្គលណាបានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិន

ក្រោធ ។ បុគ្គលឈ្មោះថា អ្នកមិនក្រោធព្រោះលះបង់ក្រោធ ឈ្មោះថា អ្នកមិនក្រោធព្រោះកំណត់ដឹងវត្ថុក្រោធ ឈ្មោះថា អ្នកមិនក្រោធព្រោះផ្តាច់ផ្តិលហេតុក្រោធ ពាក្យថា លោភៈ បានដល់ សេចក្តីជាប់ចំពាក់ អាការជាទីជាប់ចំពាក់ ភាពនៃចិត្តជាប់ចំពាក់ ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីកំណាញ់ លោកពោលសំដៅមច្ឆរិយៈ ៥ គឺអាវាសមច្ឆរិយៈ ។បេ។ ការប្រកាន់ស្អិត លោកហៅថា សេចក្តីកំណាញ់ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈបានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ មុនិនោះកន្លងនូវបណ្តាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា មុនិ ជាអ្នកមិនក្រោធរមែងឆ្លងផុតលោភៈដ៏លាមកនិងសេចក្តីកំណាញ់បាន បានសេចក្តីថា មុនិបានឆ្លងឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង លោតរំលងនូវលោភៈដ៏លាមកនិងសេចក្តីកំណាញ់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិ ជាអ្នកមិនក្រោធរមែងឆ្លងផុតលោភៈដ៏លាមកនិងសេចក្តីកំណាញ់បាន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនិគប្បីជាអ្នកមានសច្ចៈ ជាអ្នកមិនឃ្លើសឃ្លង មិនមានមាយា
មានពាក្យញុះញង់លះបង់ហើយ ជាអ្នកមិនក្រោធ រមែងឆ្លង
ផុតលោភដ៏លាមកនិងសេចក្តីកំណាញ់បាន ។

[ ១២៣ ] ជនមានចិត្តស្ទុងទៅកាន់ព្រះនិព្វាន គប្បីគ្របសង្កត់នូវការដេកលក់ នូវការខ្ជិល នូវការរួញរា មិនគប្បីនៅរួមដោយសេចក្តីប្រហែស មិនគប្បីតាំងនៅក្នុងការមើលងាយឡើយ ។

[ ១២៤ ] អធិប្បាយពាក្យថា គប្បីគ្របសង្កត់នូវការដេកលក់ នូវការខ្ជិល នូវការរួញរា ត្រង់ពាក្យថា ការដេកលក់ បានខាងភាពនៃកាយឈឺចាប់ ភាពនៃកាយមិនគួរដល់ការងារ ការទន់ទោរចុះ ការងោកងក់ ការងុយស្រឡេតខាងក្នុងសន្ដាន ការងុយងក់ ការលក់ ការញ័រគ្របក្ដែក អាការជាទីលក់ ភាពនៃចិត្តលក់ស៊ប់ ។ ពាក្យថា ការខ្ជិល បានដល់ សេចក្ដីខ្ជិល អាការកម្ជិល ភាពនៃចិត្តខ្ជិល សេចក្ដីប្រអូស អាការប្រអូស ភាពនៃចិត្តប្រអូស ។ ពាក្យថា ការរួញរា បានខាងភាពនៃចិត្តឈឺចាប់ ភាពនៃចិត្តមិនគួរដល់ការងារ អាការជាទីធុញថប់ ការរួញថយ ការកៀចក្រាញ អាការជាទីកៀចក្រាញ ភាពនៃចិត្តកៀចក្រាញ ការរួញ អាការជាទីរួញ ភាពនៃចិត្តរួញ ។ ពាក្យថា គប្បីគ្របសង្កត់នូវការដេកលក់ នូវការខ្ជិល នូវការរួញរា បានសេចក្ដីថា គប្បីសង្កត់ គប្បីគ្របសង្កត់ គប្បីបង្ក្រប គប្បីសង្កត់សង្កិន គប្បីរួបរឹត គប្បីញាំញីនូវការដេកលក់ ១ ការខ្ជិល ១ ការរួញរា ១ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីគ្របសង្កត់នូវការដេកលក់ នូវការខ្ជិលនិងការរួញរា ។

[ ១២៥ ] អធិប្បាយពាក្យថា មិនគប្បីនៅរួមដោយសេចក្ដីប្រហែស ឯសេចក្ដីប្រហែស ខ្ញុំត្រូវពោលដូចតទៅនេះ ។ ការបណ្ដោយចិត្ត ការឲ្យកម្លាំងដល់ការបណ្ដោយចិត្តទៅក្នុងកាយទុច្ចរិតក្ដី ក្នុងវចីទុច្ចរិតក្ដី ក្នុងមនោទុច្ចរិតក្ដី ក្នុងកាមគុណ ៥ ក្ដី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចោលនូវសេចក្ដីប្រាថ្នា ការដាក់ចោលនូវធុរៈ ការមិនសេព ការមិនចម្រើន ការធ្វើមិនឲ្យច្រើន ការមិនតាំងទុក ការ

មិនប្រកបរឿយៗ ការធ្វេសក្នុងការចម្រើននូវកុសលធម៌ ការប្រហែស អាការជាទីធ្វេស ភាពនៃចិត្តធ្វេសណាមានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្ដីប្រហែស ។ ពាក្យថា មិនគប្បីនៅរួមដោយសេចក្ដីប្រហែស បានសេចក្ដីថា មិនគប្បីនៅរួម មិនគប្បីនៅអាស្រ័យ មិនគប្បីនៅជិតដោយការប្រហែស គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវការប្រហែស គឺគប្បីជាបុគ្គលចៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកការប្រហែស គប្បីជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីនៅរួមដោយសេចក្ដីប្រហែស ។

[ ១២៦ ] អធិប្បាយពាក្យថា មិនគប្បីតាំងនៅក្នុងការមើលងាយ ត្រង់ពាក្យថា ការមើលងាយ សេចក្ដីថា បុគ្គលខ្លះក្នុងលោកនេះ រមែងមើលងាយអ្នកឯទៀតដោយជាតិក្ដី ដោយគោត្តក្ដី ។បេ។ ដោយវត្ថុដ៏វិសេសណាមួយក្ដី ។ សេចក្ដីប្រកាន់ អាការប្រកាន់ ភាពនៃចិត្តប្រកាន់ ការធ្មើងធ្មៃ អាការធ្មើងធ្មៃ ចិត្តដូចទង់ជ័យ ការប្រកាន់ខ្លាំង ភាពនៃចិត្តប្រាថ្នាដូចទង់ណា មានសភាពយ៉ាងនេះ នេះលោកហៅថា ការមើលងាយ ។ ពាក្យថា មិនគប្បីតាំងនៅក្នុងការមើលងាយ គឺមិនគប្បីឋិតនៅ មិនគប្បីតាំងនៅក្នុងការមើលងាយ បានសេចក្ដីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវការមើលងាយ គឺគួរចៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកការមើលងាយ គប្បីជាអ្នកមានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីតាំងនៅក្នុងការមើល

ឆាយ ។

[ ១២៧ ] ពាក្យថា ជនមានចិត្តស្ទុងទៅកាន់ព្រះនិព្វាន អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះកាលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម តំកល់ទុកទឹកដែលបុគ្គលគប្បីផឹកនិងភោជនដែលបុគ្គលគប្បីបរិភោគ បោសប្រាសទីបរិវេណ ថ្វាយបង្គំព្រះចេតិយ រៀបចំគ្រឿងក្រអូបនិងកម្រងផ្កា ថ្វាយព្រះចេតិយ ធ្វើប្រទក្សិណព្រះចេតិយ កសាងអភិសង្ខារជាកុសលណាមួយដែលប្រព្រឹត្តទៅក្នុងត្រៃធាតុ មិនមែនព្រោះហេតុគតិ មិនមែនព្រោះហេតុការកើត មិនមែនព្រោះហេតុបដិសន្ធិ មិនមែនព្រោះហេតុភព មិនមែនព្រោះហេតុសំសារ មិនមែនព្រោះហេតុវដ្តៈទេ រមែងជាអ្នកមានបំណងដើម្បីប្រាសចាកយោគ ជាអ្នកឱនទៅកាន់ព្រះនិព្វាន ឈមទៅកាន់ព្រះនិព្វាន ទោរទន់ទៅកាន់ព្រះនិព្វាន កសាងកុសលទាំងអស់នោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនមានចិត្តស្ទុងទៅកាន់ព្រះនិព្វាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលញ៉ាំងចិត្តឲ្យងាកចេញចាកសង្ខារធាតុទាំងពួង ហើយប្រមូលចិត្តដើម្បីអមតធាតុ ( ព្រះនិព្វាន ) ថា គុណជាតនុ៎ះស្ងប់ គុណជាតនុ៎ះប្រសើរ គឺការរម្ងាប់សង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនមានចិត្តស្ទុងទៅកាន់ព្រះនិព្វានយ៉ាងនេះខ្លះ ។

បណ្ឌិតទាំងឡាយ ឲ្យទានមិនមែនព្រោះហេតុសុខនៃឧបធិដើម្បី
កពថ្មីទេ បណ្ឌិតទាំងនោះឲ្យទានដើម្បីការអស់ឧបធិ មិនដើម្បី
កពថ្មីដោយពិត ។ បណ្ឌិតទាំងឡាយ ចម្រើនឈាន មិនមែន

ព្រោះហេតុសុខនៃឧបធិដើម្បីភពថ្មីទេ បណ្ឌិតទាំងនោះចម្រើនឈានដើម្បីការអស់ឧបធិ មិនដើម្បីភពថ្មីដោយពិត ។ បណ្ឌិតទាំងឡាយ មានចិត្តត្រេកអរស៊ប់ចំពោះការរលត់ទុក្ខ ទើបឲ្យទាន មានចិត្តទន់ទោរទៅកាន់ព្រះនិព្វាននោះ មានចិត្តចុះស៊ប់ទៅកាន់ព្រះនិព្វាននោះ បណ្ឌិតទាំងនោះ មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ ដូចស្ទឹងទាំងឡាយដែលហូរទៅកាន់ទីកណ្ដាលនៃសាគរ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជនមានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ជនមានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន គប្បីគ្របសង្កត់នូវការដេកលក់ នូវការខ្ជិល នូវការរួញរា មិនគប្បីនៅរួមដោយសេចក្ដីប្រហែស មិនគប្បីតាំងនៅក្នុងការមើលងាយឡើយ ។

[ ១២៨ ] បុគ្គលគប្បីគេចចេញចាកពាក្យកុហក មិនគប្បីធ្វើសេចក្ដីស្នេហាក្នុងរូប គប្បីស្គាល់មានះ ទាំងគប្បីប្រព្រឹត្តវៀរស្រឡះចាកសាហសាចរិយា[១]

[ ១២៩ ] ពាក្យថា គប្បីគេចចេញចាកពាក្យកុហក អធិប្បាយថា មុសាវាទលោកហៅថា ពាក្យកុហក ។ បុគ្គលខ្លះក្នុងលោកនេះនៅក្នុងទីប្រជុំក្ដី នៅក្នុងបរិស័ទក្ដី នៅក្នុងកណ្ដាលញាតិក្ដី នៅក្នុងកណ្ដាលពួកក្ដី នៅក្នុងកណ្ដាល

---

១-ការប្រព្រឹត្តសាហ័ស គឺការប្រព្រឹត្តហ័សដោយកម្លាំងរាគៈ ទោសៈ មោហៈជាដើម ហៅថា សាហសាចរិយា ។

រាជត្រកូលក្តីដែលគេនាំយកទៅសួរជាសាក្សីថា នែបុរសដ៏ចម្រើន អ្នកចូរមក អ្នកដឹងហេតុណា ចូរអ្នកប្រាប់ហេតុនោះ បុគ្គលនោះមិនដឹងនិយាយថា ខ្ញុំដឹងក្តី ដឹងនិយាយថា ខ្ញុំមិនដឹងក្តី មិនឃើញនិយាយថា ខ្ញុំឃើញក្តី ឃើញនិយាយថា ខ្ញុំមិនឃើញក្តី ជាអ្នកពោលវាចាកុហកទាំងដឹងខ្លួន ព្រោះហេតុខ្លួនខ្លះ ព្រោះហេតុបុគ្គលដទៃខ្លះ ព្រោះហេតុអាមិសៈបន្តិចបន្តួចខ្លះ នេះហៅថា ពាក្យកុហក ។ មួយទៀតមុសាវាទដោយអាការបី ដោយអាការៈបួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ។បេ។ នេះមុសាវាទដោយអាការៈប្រាំបី ។ ពាក្យថា គប្បីគេចចេញចាកពាក្យកុហក បានសេចក្តីថា មិនគប្បីបណ្តោយ មិនគប្បីបន្សាត់ មិនគប្បីបង្ហើរដោយពាក្យកុហក គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវពាក្យកុហក គប្បីជាអ្នកចៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកពាក្យកុហក ជាអ្នកមានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីគេចចេញចាកពាក្យកុហក ។

[ ១៣០ ] ពាក្យថា មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប ត្រង់ពាក្យថា រូប បានដល់ មហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូប ៤ ។ ពាក្យថា មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប គឺមិនគប្បីធ្វើស្នេហា មិនគប្បីធ្វើសេចក្តីពេញចិត្ត មិនគប្បីធ្វើសេចក្តីស្រឡាញ់ មិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យដុះដាល មិនគប្បីឲ្យលូតលាស់ មិនគប្បីឲ្យកើតឡើងនូវតម្រេកក្នុងរូប ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប ។

[ ១៣១ ] អធិប្បាយពាក្យថា គប្បីស្គាល់មានះ ត្រង់ពាក្យថា មានះ សេចក្តីថា មានះដោយចំណែក ១ បានដល់ ការក្រអឺតក្រអោងនៃចិត្ត ។ មានះដោយចំណែក ២ គឺមានះដោយការលើកខ្លួនឯង ១ មានះដោយការបង្អាប់អ្នកដទៃ ១ ។ មានះដោយចំណែក ៣ គឺមានះថាអញជាបុគ្គលប្រសើរ ១ មានះថាអញជាបុគ្គលស្មើ ១ មានះថាអញជាបុគ្គលថោកទាប ១ ។ មានះដោយចំណែក ៤ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះលាភ ១ ញុំាងមានះឲ្យកើត ព្រោះយស ១ ញុំាងមានឲ្យកើតព្រោះសេចក្តីសរសើរ ១ ញុំាងមានះឲ្យកើតព្រោះសុខ ១ ។ មានះដោយចំណែក ៥ គឺបុគ្គលញុំាងមានះឲ្យកើតថា អញបានរូបជាទីពេញចិត្ត ញុំាងមានះឲ្យកើតថាអញបានសំឡេង ក្លិន រស ផ្សព្វជាទីពេញចិត្ត ។ មានះដោយចំណែក ៦ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះចក្ខុសម្បទ ញុំាងមានះឲ្យកើតព្រោះសោតសម្បទ ឃានសម្បទ ជិវ្ហាសម្បទ កាយសម្បទ មនោសម្បទ ។ មានះដោយចំណែក ៧ គឺមានះ អតិមានះ មានាតិមានះ ឱមានះ អធិមានះ អស្មិមានះ មិច្ឆាមានះ ។ មានះដោយចំណែក ៨ គឺបុគ្គលញុំាងមានះឲ្យកើតព្រោះលាភ ញុំាងឱមានះឲ្យកើតព្រោះអលាភ ញុំាងមានះឲ្យកើតព្រោះយស ញុំាងឱមានះឲ្យកើតព្រោះអយស ញុំាងមានះឲ្យកើត ព្រោះបសំសា ញុំាងឱមានះឲ្យកើតព្រោះនិន្ទា ញុំាងមានះឲ្យកើតព្រោះសុខ ញុំាងឱមានះឲ្យកើតព្រោះទុក្ខ ។ មានះដោយចំណែក ៩ គឺមានះថា អញប្រសើរជាងបុគ្គលប្រសើរ មានះថាអញស្មើនឹងបុគ្គលប្រសើរ មានះថាអញថោកទាបជាងបុគ្គលប្រសើរ មានះថាអញប្រសើរជាងបុគ្គលអ្នកស្មើ មានះថាអញស្មើនឹងបុគ្គល

អ្នកស្មើ មានះថាអញថោកទាបជាងបុគ្គលអ្នកស្មើ មានះថាអញប្រសើរជាងបុគ្គលអ្នកថោកទាប មានះថាអញស្មើនឹងបុគ្គលអ្នកថោកទាប មានះថាអញថោកទាបជាងបុគ្គលអ្នកថោកទាប ។ មានះដោយចំណែក ១០ គឺបុគ្គលខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើតដោយជាតិក្តី គោត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី សេចក្តីប្រកាន់ អាការជាទីប្រកាន់ ភាពនៃចិត្តប្រកាន់ ការផ្ទើងផ្ទៃ អាការផ្ទើងផ្ទៃ ចិត្តដូចទង់ ការប្រកាន់ខ្លាំង ភាពនៃចិត្តប្រាថ្នាដូចទង់ ឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា មានះ ។

ពាក្យថា គប្បីស្គាល់មានះ គឺគប្បីស្គាល់មានះដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តិរណបរិញ្ញា ១ បហានបរិញ្ញា ១ ។ ញាតបរិញ្ញា តើដូចម្តេច ។ បុគ្គលស្គាល់មានះថា មានះនេះដោយចំណែក ១ គឺការផ្ទើងផ្ទៃនៃចិត្ត មានះនេះដោយចំណែក ២ គឺមានះដោយការលើកខ្លួនឯង មានះដោយការបន្តុះបង្អាប់អ្នកដទៃ ។បេ។ មានះនេះដោយចំណែក ១០ គឺបុគ្គលខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើតដោយជាតិក្តី គោត្តក្តី ។បេ។ ដោយវត្ថុណាមួយក្តី បុគ្គលដឹងឃើញដូច្នេះ នេះញាតបរិញ្ញា ។ តិរណបរិញ្ញា តើដូចម្តេច ។ បុគ្គលដឹងយ៉ាងនេះហើយពិចារណានូវមានះដោយសេចក្តីថា មិនទៀង ជាទុក្ខ ។បេ។ ពិចារណានូវមានះដោយសេចក្តីថា មិនជាទីរលាស់ចេញ នេះតិរណបរិញ្ញា ។ បហានបរិញ្ញា តើដូចម្តេច ។ បុគ្គលពិចារណាយ៉ាងនេះហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវមានះ នេះបហានបរិញ្ញា ។ ពាក្យថា គប្បីស្គាល់មានះ គឺគប្បីស្គាល់មានះដោយបរិញ្ញា ៣ នេះឯង ហេតុនោះ ( ទ្រង់ត្រាស់

ថា ) គប្បីស្គាល់មានះ ។

[ ១៣២ ] ពាក្យថា ទាំងគប្បីប្រព្រឹត្តវៀរស្រឡះចាកសាហសាចរិយា សំណួរថា សាហសាចរិយា តើដូចម្តេច ។ ការប្រព្រឹត្តដោយតម្រេករបស់បុគ្គលដែលត្រេកអរឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយកំហឹងរបស់បុគ្គលដែលខឹងឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយល្ងង់ខ្លៅរបស់បុគ្គលដែលល្ងង់ ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយមានះរបស់បុគ្គលដែលប្រកាន់មាំឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយទិដ្ឋិរបស់បុគ្គលដែលស្ទាបអង្អែលឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយឧទ្ធច្ចរបស់បុគ្គលដែលដល់នូវសេចក្តីរាយមាយ ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយវិចិកិច្ឆារបស់បុគ្គល អ្នកដល់នូវសេចក្តីមិនដាច់ស្រេច ឈ្មោះថា សាហសាចរិយា ការប្រព្រឹត្តដោយអនុស័យរបស់បុគ្គលដែលដល់នូវកម្លាំង ឈ្មោះថា សាហសាចរិយា នេះសាហសាចរិយា ។ ពាក្យថា គប្បីប្រព្រឹត្តវៀរស្រឡះចាកសាហសាចរិយា គឺគប្បីចៀសវាង គេចចេញ វៀរចេញ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញ ចាកសាហសាចរិយា គប្បីនៅត្រាច់ទៅ ទៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា យាត្រាទៅ ដោយចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីប្រព្រឹត្តវៀរស្រឡះចាកសាហសាចរិយា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលគប្បីគេចចេញចាកពាក្យកុហក មិនគប្បីធ្វើសេចក្តីស្នេហា
ក្នុងរូប គប្បីស្គាល់មានះ ទាំងគប្បីប្រព្រឹត្តវៀរស្រឡះ ចាក

សាហសាចរិយា ។

[ ១៣៣ ] បុគ្គលមិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ ( ខន្ធចាស់ ) មិនគប្បីធ្វើសេចក្តីពេញចិត្តក្នុងនវក្ខន្ធ ( ខន្ធថ្មី ) មិនគប្បីសោកស្តាយ ចំពោះវត្ថុកាលវិនាស មិនគប្បីជាអ្នកអាស្រ័យសភាវៈជាគ្រឿងទាញមក ។

[ ១៣៤ ] ពាក្យថា មិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ សេចកក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអតីតលោកហៅថា បុរាណក្ខន្ធ ។ បុគ្គលមិនគប្បីត្រេកអរ មិនគប្បីសរសើរ មិនគប្បីជ្រុលជ្រប់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវការត្រេកអរ ការសរសើរ ការជ្រុលជ្រប់ ការប្រកាន់ ការស្ទាបអង្អែល ការជាប់ចំពាក់ចំពោះសង្ខារជាអតីត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ ។

[ ១៣៥ ] ពាក្យថា មិនគប្បីធ្វើសេចក្តីពេញចិត្តក្នុងនវក្ខន្ធ សេចកក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្នលោកហៅថា នវក្ខន្ធ ។ បុគ្គលមិនគប្បីធ្វើសេចក្តីពេញចិត្ត មិនគប្បីធ្វើសេចក្តីប្រាថ្នា មិនគប្បីធ្វើសេចក្តីស្រឡាញ់ គឺមិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យលូតលាស់ មិនគប្បីឲ្យដុះដាល មិនគប្បីឲ្យកើតនូវតម្រេកចំពោះសង្ខារជាបច្ចុប្បន្ន ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើសេចក្តីពេញចិត្តក្នុងនវក្ខន្ធ ។

[ ១៣៦ ] ពាក្យថា មិនគប្បីសោកស្តាយ ចំពោះវត្ថុកាលវិនាស គឺមិន

គប្បីសោកស្តាយ មិនគប្បីលំបាក មិនគប្បីស្ទាបអង្អែល មិនគប្បីខ្សឹកខ្សួល មិនគប្បីគក់ទ្រូង មិនគប្បីដល់នូវសេចក្តីវង្វេង ចំពោះវត្ថុកាលវិនាស ខូចខាត សាបសូន្យ បាត់បង់ ព្រាត់ប្រាស អន្តរធាន គឺមិនគប្បីសោកស្តាយ មិនគប្បីលំបាក មិនគប្បីស្ទាបអង្អែល មិនគប្បីខ្សឹកខ្សួល មិនគប្បីគក់ទ្រូង មិនគប្បីដល់នូវសេចក្តីវង្វេង ចំពោះចក្ខុកាលវិនាស ខូចខាត សាបសូន្យ បាត់បង់ ព្រាត់ប្រាស អន្តរធាន ចំពោះសោតៈ ឃានៈ ជិវ្ហា កាយ រូប សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ត្រកូល គណៈ អាវាស លាភ យស បសំសា សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាលវិនាសខូចខាត សាបសូន្យ បាត់បង់ ព្រាត់ប្រាស អន្តរធាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីសោកស្តាយចំពោះវត្ថុកាលវិនាស ។

[ ១៣៧ ] ពាក្យថា មិនគប្បីជាអ្នកអាស្រ័យសភាវៈជាគ្រឿងទាញមក អធិប្បាយថា តណ្ហា លោកហៅថា សភាវៈជាគ្រឿងទាញមក បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាលោកហៅថា សភាវៈជាគ្រឿងទាញមក តើដូចម្តេច ។ បុគ្គលតែងទាញមក ប្រមូលមក កាន់យក ស្ទាបអង្អែល ជាប់ចំពាក់ចំពោះរូប បុគ្គលតែងទាញមក ប្រមូលមក កាន់យក ស្ទាបអង្អែល ជាប់ចំពាក់ចំពោះវេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សំសារវដ្តៈ ដោយតណ្ហាណា ព្រោះហេតុនោះ តណ្ហានោះ លោកហៅថា ជាគ្រឿងទាញមក ។ ពាក្យថា មិនគប្បីជាអ្នកអាស្រ័យសភាវៈជាគ្រឿងទាញមកគឺមិនគប្បីជាអ្នកអាស្រ័យនូវតណ្ហាគឺគប្បី

លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានទូវតណ្ហា បុគ្គលគប្បីចៀសវាង គេចចេញ វៀរស្រឡះ រត់ចេញ រលាស់ចេញ រួចចេញ ប្រាសចេញចាកតណ្ហា ជាអ្នកមានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីអាស្រ័យសភាវជាគ្រឿងទាញមក ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនគប្បីត្រេកអរចំពោះបុរាណក្ខន្ធ ( ខន្ធចាស់ ) មិនគប្បីធ្វើសេចក្តីពេញចិត្តក្នុងនវក្ខន្ធ ( ខន្ធថ្មី ) មិនគប្បីសោកស្តាយចំពោះវត្ថុកាលវិនាស មិនគប្បីអាស្រ័យសភាវៈ ជាគ្រឿងទាញមក ។

[ ១៣៨ ] តថាគតពោលថា សេចក្តីប្រាថ្នាជាអន្លង់ធំ ពោលថា តណ្ហាជាអាចម ជាបំណង ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រថា កាមជាភក់ ដែលសត្វកន្លងបានដោយក្រ ។

[ ១៣៩ ] ពាក្យថា តថាគតពោលថា សេចក្តីប្រាថ្នាជាអន្លង់ធំ សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាលោកហៅថា អន្លង់ធំ បានខាងរាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា តថាគតពោលថា សេចក្តីប្រាថ្នាជាអន្លង់ធំ បានសេចក្តីថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសនូវសេចក្តីប្រាថ្នា ថាជាអន្លង់ធំ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលថា សេចក្តីប្រាថ្នាជាអន្លង់ធំ ។

[ ១៤០ ] ពាក្យថា តថាគតពោលថា តណ្ហាជាអាចម ជាបំណាង សេចក្តីថា តណ្ហា លោកហៅថា អាចម បានដល់រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាលោកហៅថា បំណាង បានដល់រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា តថាគតពោលថា តណ្ហាជាអាចម ជាបំណាង បានសេចក្តីថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសនូវតណ្ហា ថាដូចជាអាចម ថាជាបំណាង ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតពោលថា តណ្ហាជាអាចម ជាបំណាង ។

[ ១៤១ ] ពាក្យថា ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រ សេចក្តីថា តណ្ហា លោកហៅថា អារម្មណ៍ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា លោកហៅថា គ្រឿងញាប់ញ័រ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រ ។

[ ១៤២ ] ពាក្យថា កាមជាភក់ ដែលសត្វកន្លងបានដោយក្រ សេចក្តីថា កាមដូចជាភក់ កាមដូចជាល្បាប់ សេចក្តីសៅហ្មងគឺកាម គ្រឿងស្អិតគឺកាម សេចក្តីកង្វល់គឺកាម ដែលសត្វឆ្លងបានដោយក្រ កន្លងបានដោយក្រ រំលងបានដោយក្រ ឆ្លងឡើងបានដោយក្រ ឈានកន្លងបានដោយក្រ ប្រព្រឹត្តកន្លងបានដោយក្រ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាមជាភក់ ដែលសត្វកន្លងបានដោយក្រ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតពោលថា សេចក្តីប្រាថ្នាជាអន្ទង់ធំ ពោលថា តណ្ហា ជាអាចម ជាបំណង ជាអារម្មណ៍ ជាគ្រឿងញាប់ញ័រ ថា កាមជាភក់ដែលសត្វកន្លងបានដោយក្រ ។

[ ១៤៣ ] មុនិមិនឃ្លាតចាកសច្ចៈ ជាព្រាហ្មណ៍ឋិតនៅលើទីទួល មុនិនោះលះបង់វត្ថុទាំងពួង មុនិនោះឯងតថាគតហៅថា អ្នកស្ងប់ ។

[ ១៤៤ ] ពាក្យថា មុនិ មិនឃ្លាតចាកសច្ចៈ គឺមិនឃ្លាតចាកសច្ចវាចា មិនឃ្លាតចាកសម្មាទិដ្ឋិ មិនឃ្លាតចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ពាក្យថា មុនិ សេចក្តីថា ញាណលោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។បេ។ មុនិនោះកន្លងនូវបណ្តាញ ជាគ្រឿងចំពាក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិ មិនឃ្លាតចាកសច្ចៈ ។

[ ១៤៥ ] ពាក្យថា ជាព្រាហ្មណ៍ ឋិតនៅលើទីទួល សេចក្តីថា អមតនិព្វាន លោកហៅថា ទីទួល បានខាង ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ព្រាហ្មណ៍ គឺឈ្មោះថាព្រាហ្មណ៍ ព្រោះលះធម៌ ៧ ។បេ។ ជាអ្នកមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) ប្រកបដោយតាទិគុណ បុគ្គលនោះលោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ជាព្រាហ្មណ៍ឋិតនៅលើទីទួល បានសេចក្តីថា ព្រាហ្មណ៍ឋិតនៅលើទីទួល គឺឋិតនៅលើកោះ ឋិតនៅលើទីពំនាក់ ឋិតនៅលើទីពួន ឋិតនៅលើទីពឹង ឋិតនៅលើទីមិនមានភ័យ ឋិតនៅលើទីមិនច្យុត ឋិតនៅលើទីមិនស្លាប់ ឋិតនៅលើទីមិនមានវានៈ ( ព្រះនិព្វាន ) ហេតុនោះ

( ទ្រង់ត្រាស់ថា ) ជាព្រាហ្មណ៍ឋិតនៅលើទីទួល ។

[ ១៤៦ ] ពាក្យថា មុនិនោះលះបង់វត្ថុទាំងពួង អធិប្បាយថា វត្ថុទាំងពួង លោកពោលសំដៅអាយតនៈ ១២ គឺចក្ខុ ១ រូប ១ ។បេ។ ចិត្ត ១ ធម៌ ១ ។ ឆន្ទរាគៈក្នុងអាយតនៈទាំងឡាយ ទាំងខាងក្នុងនិងខាងក្រៅ មុនិនោះបានលះបង់ ផ្តាច់បង់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាទៅក្នុងកាលណា វត្ថុទាំងពួង ឈ្មោះថា មុនិនោះបានលះចោល ខ្ជាក់ចេញ រួចស្រឡះ លះបង់ រលាស់ចោល ដោយហេតុមានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ។ តណ្ហា ១ ទិដ្ឋិ ១ មានះ ១ មុនិនោះបានលះបង់ ផ្តាច់បង់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាទៅ ក្នុងកាលណា វត្ថុទាំងពួង ឈ្មោះថា មុនិនោះលះចោល ខ្ជាក់ចេញ រួចស្រឡះ លះបង់ រលាស់ចោលដោយហេតុមានប្រមាណប៉ុណ្ណោះក្នុងកាលនោះ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអនេញ្ជាភិសង្ខារ មុនិនោះបានលះបង់ ផ្តាច់បង់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាទៅ ក្នុងកាលណា វត្ថុទាំងពួង ឈ្មោះថា មុនិនោះបានលះចោល ខ្ជាក់ចេញ រួចស្រឡះ លះបង់ រលាស់ចោល ដោយហេតុមានប្រមាណប៉ុណ្ណោះក្នុងកាលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិនោះលះបង់វត្ថុទាំងពួង ។

[ ១៤៧ ] ពាក្យថា មុនិនោះឯង តថាគតហៅថា អ្នកស្ងប់ គឺមុនិនោះ

តថាគតពោល សម្តែង និយាយ បំភ្លឺ បញ្ចេញ ថាជាអ្នកស្ងប់ រម្ងាប់ ស្ងប់ រម្ងាប់ រលត់ សះស្បើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិនោះ តថាគត ហៅថា អ្នកស្ងប់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនិមិនឃ្លាតចាកសច្ចៈ ជាព្រាហ្មណ៍ឋិតនៅលើទីទួល មុនិនោះ

លះបង់វត្ថុទាំងពួង មុនិនោះឯងតថាគតហៅថា អ្នកស្ងប់ ។

[ ១៤៨ ] មុនិនោះ ឈ្មោះថាអ្នកដឹង មុនិនោះ ឈ្មោះថាអ្នកដល់នូវវេទ ឈ្មោះថាមិនអាស្រ័យធម៌ព្រោះដឹង មុនិនោះ ឈ្មោះថារស់នៅក្នុងលោកដោយប្រពៃ តែងមិនស្រឡាញ់ចំពោះបុគ្គលណាមួយក្នុងលោកនេះ ។

[ ១៤៩ ] អធិប្បាយពាក្យថា មុនិនោះ ឈ្មោះថាអ្នកដឹង មុនិនោះ ឈ្មោះថា អ្នកដល់នូវវេទ ត្រង់ពាក្យថា អ្នកដឹង គឺអ្នកចេះដឹង អ្នកតាំងនៅក្នុងវិជ្ជា មានញាណ មានប្រាជ្ញា មានប្រាជ្ញាឈ្វេងយល់ មានប្រាជ្ញាធ្លុះធ្លាយ ។ ពាក្យថា អ្នកដល់នូវវេទ សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។បេ។ មុនិនោះជាអ្នកប្រាសចាករាគៈក្នុងវេទនាទាំងពួង កន្លងវេទទាំងពួង ឈ្មោះថា អ្នកដល់នូវវេទ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិនោះ ឈ្មោះថាអ្នកដឹង មុនិនោះ ឈ្មោះថាអ្នកដល់នូវវេទ ។

[ ១៥០ ] ពាក្យថា ឈ្មោះថាមិនអាស្រ័យធម៌ ព្រោះដឹង គឺព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងមិនទៀង ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង ជាទុក្ខ ។បេ។ ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា

ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មិនអាស្រ័យ បានដល់ និស្ស័យ ២ គឺតណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះទិដ្ឋិនិស្ស័យ ។ មុនិលះបង់តណ្ហានិស្ស័យ រលាស់ចេញនូវទិដ្ឋិនិស្ស័យ មិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ មិនអាស្រ័យឃានៈ ។បេ។ មិនអាស្រ័យធម៌ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង មិនក្រាញនៅ មិនចូលទៅជិត មិនជ្រុលជ្រប់ មិនចុះស៊ប់ គឺជាអ្នករត់ចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឈ្មោះថា មិនអាស្រ័យធម៌ ព្រោះដឹង ។

[ ១៥១ ] ពាក្យថា មុនិនោះ ឈ្មោះថារស់នៅក្នុងលោក ដោយប្រពៃ អធិប្បាយថា ឆន្ទរាគក្នុងអាយតនៈ ទាំងខាងក្នុងខាងក្រៅ មុនិនោះបានលះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាតទៅក្នុងកាលណា មុនិនោះ ឈ្មោះថាត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅក្នុងលោក ដោយប្រពៃ ដោយហេតុមានប្រមាណប៉ុណ្ណេះក្នុងកាលនោះ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារនិងអនេញ្ជាភិសង្ខារ មុនិនោះបាន លះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាវៈមិនមាន មិនឲ្យមានការកើតជាធម្មតាតទៅក្នុងកាលណា មុនិនោះឈ្មោះថាត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅក្នុងលោកដោយប្រពៃ ដោយ

ហេតុមានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះ ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មុនិនោះ ឈ្មោះថារស់នៅក្នុងលោកដោយប្រពៃ ។

[ ១៥២ ] ពាក្យថា តែងមិនស្រឡាញ់ ចំពោះបុគ្គលណាមួយក្នុងលោកនេះ សេចក្ដីថា តណ្ហា លោកហៅថា សេចក្ដីស្រឡាញ់ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្ដីស្រឡាញ់ គឺតណ្ហានុ៎ះ មុនិណាបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ មុនិនោះ មិនស្រឡាញ់ចំពោះបុគ្គលណាមួយទោះជាក្សត្រក្ដី ព្រាហ្មណ៍ក្ដី វេស្សៈក្ដី សុទ្ទៈក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ទេវតាក្ដី មនុស្សក្ដី ហេតុនោះ ( ទ្រង់ត្រាស់ថា ) តែងមិនស្រឡាញ់ចំពោះបុគ្គលណាមួយក្នុងលោកនេះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> មុនិនោះ ឈ្មោះថាអ្នកដឹង មុនិនោះ ឈ្មោះថាអ្នកដល់នូវវេទ
> ឈ្មោះថាមិនអាស្រ័យធម៌ ព្រោះដឹង មុនិនោះ ឈ្មោះថារស់
> នៅក្នុងលោកដោយប្រពៃ តែងមិនស្រឡាញ់ចំពោះបុគ្គលណា
> មួយក្នុងលោកនេះ ។

[ ១៥៣ ] បុគ្គលណាបានឆ្លងនូវកាមផង នូវគ្រឿងចំពាក់ ដែលសត្វឆ្លងបានដោយក្រក្នុងលោកផង បុគ្គលនោះ រមែងមិនសោកស្ដាយ មិនសញ្ជប់សញ្ជឹង ( ព្រោះ ) ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានចំណង ។

[ ១៥៤ ] អធិប្បាយពាក្យថា បុគ្គលណា បានឆ្លងនូវកាមផង នូវគ្រឿងចំពាក់ ដែលសត្វឆ្លងបានដោយក្រក្នុងលោកផង ត្រង់ពាក្យថា បុគ្គលណា គឺ

ជនណា បែបណា ប្រកបយ៉ាងណា មានបែបផែនយ៉ាងណា មានប្រការយ៉ាងណា ដល់នូវឋានៈយ៉ាងណា ប្រកបដោយធម៌ណា ទោះជាក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សក្តី សុទ្ទៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះហៅថា វត្ថុកាម ។បេ។ នេះហៅថាកិលេសកាម ។ ពាក្យថា គ្រឿងចំពាក់ បានដល់ គ្រឿងចំពាក់ ៧ គឺគ្រឿងចំពាក់ គឺរាគៈ ១ គ្រឿងចំពាក់គឺទោសៈ ១ គ្រឿងចំពាក់គឺមោហៈ ១ គ្រឿងចំពាក់គឺមានះ ១ គ្រឿងចំពាក់គឺទិដ្ឋិ ១ គ្រឿងចំពាក់ គឺកិលេស ១ គ្រឿងចំពាក់គឺទុច្ចរិត ១ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ដែលសត្វឆ្លងបានដោយក្រ សេចក្តីថា បុគ្គលណាបានឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវកាមនិងគ្រឿងចំពាក់ ដែលសត្វឆ្លងបានដោយក្រ លោតរំលងបានដោយក្រ ឆ្លងចេញបានដោយក្រ ឆ្លងកាត់បានដោយក្រ ឈានកន្លងបានដោយក្រ ប្រព្រឹត្តកន្លងបានដោយក្រក្នុងលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលណាបានឆ្លងនូវកាមផង នូវគ្រឿងចំពាក់ដែលសត្វឆ្លងបានដោយក្រក្នុងលោកផង ។

[ ១៥៥ ] ពាក្យថា បុគ្គលនោះ រមែងមិនសោកស្តាយ មិនសញ្ជប់សញ្ជឹង អធិប្បាយថា បុគ្គលនោះរមែងមិនសោកស្តាយរកវត្ថុដែលត្រូវប្រែប្រួល ឬកាលវត្ថុប្រែប្រួលហើយ មិនសោកស្តាយ គឺមិនសោកស្តាយថា ចក្ខុរបស់អញប្រែប្រួលហើយ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង

មិនដល់នូវសេចក្ដីវង្វេងថា សោតៈរបស់អញ ឃានៈរបស់អញ ជិវ្ហារបស់អញ កាយរបស់អញ រូបរបស់អញ សំឡេងរបស់អញ ក្លិនរបស់អញ រសរបស់អញ ផ្សព្វរបស់អញ ត្រកូលរបស់អញ ពួករបស់អញ អាវាសរបស់អញ លាភរបស់អញ យសរបស់អញ សេចក្ដីសរសើររបស់អញ សុខរបស់អញ ចីវររបស់អញ បិណ្ឌបាតរបស់អញ សេនាសនៈរបស់អញ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អញ មាតារបស់អញ បិតារបស់អញ បងប្អូនប្រុសរបស់អញ បងប្អូនស្រីរបស់អញ បុត្តរបស់អញ ធីតារបស់អញ មិត្តរបស់អញ អាមាត្យរបស់អញ ញាតិសាលោហិតរបស់អញប្រែប្រួលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងមិនសោកស្ដាយ ។ ពាក្យថា មិនសញ្ជប់សញ្ជឹង គឺមិនទ្រមឹងទ្រមើយ មិនស្រពោនស្រពាប់ មិនទង្គឹះ មិនជ្រប់ មិនស្ងួលស្ងប់ ។ ឬថា មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនឧបបត្តិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ រមែងមិនសោកស្ដាយ មិនសញ្ជប់សញ្ជឹង ។

[ ១៥៦ ] ពាក្យថា ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានចំណង សេចក្ដីថា តណ្ហា លោកហៅថា ខ្សែ បានដល់ រាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា ឈ្មោះថាខ្សែទុំ៎ះ បុគ្គលណាបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមានខ្សែដាច់ហើយ ។ ពាក្យថា ជាអ្នកមិនមានចំណង សេចក្ដីថា ចំណង ៧ ចំណង គឺរាគៈ ១ ចំណងគឺទោសៈ ១ ចំណងគឺមោហៈ ១ ចំណងគឺមានះ ១ ចំណងគឺទិដ្ឋិ ១ ចំណង

គឺកិលេស ១ ចំណងគឺទុច្ចរិត ១ ។ ចំណងទាំងនុ៎ះ បុគ្គលណា បានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានចំណង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមានខ្សែដាច់ហើយ ជាអ្នកមិនមានចំណង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណាបានឆ្លងនូវកាមផង នូវគ្រឿងចំពាក់ ដែលសត្វឆ្លង
បានដោយក្រក្នុងលោកផង បុគ្គលនោះរមែងមិនសោកស្ដាយ
មិនសញ្ជប់សញ្ជឹង ( ព្រោះ ) ជាអ្នកមានខ្សែដាច់ហើយ ជា
អ្នកមិនមានចំណង ។

[ ១៥៧ ] កិលេសជាតណា ( ដែលកើត ) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះឲ្យរីងស្ងួត កិលេសជាតជាគ្រឿងកង្វល់ កុំមានដល់អ្នកក្នុងកាលជាខាងក្រោយឡើយ បើអ្នកមិនកាន់យកក្នុងខន្ធជាកណ្ដាលទេ អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។

[ ១៥៨ ] ពាក្យថា កិលេសជាតណា ( ដែលកើត ) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះឲ្យរីងស្ងួត អធិប្បាយថា កិលេសទាំងឡាយណា គប្បីកើតឡើង ព្រោះប្រារព្ធនូវសង្ខារជាអតីត អ្នកចូរញុំាងកិលេសទាំងនោះឲ្យស្ងួត ឲ្យរីង ឲ្យក្រៀម គឺចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកិលេសទាំងនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសជាតណា ( ដែលកើត ) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះ ឲ្យរីងស្ងួតយ៉ាង

នេះខ្លះ ។ មួយទៀត កម្មាភិសង្ខារណាមានផលមិនទាន់ចាស់ ជាអតីត អ្នកចូរញុំាងកម្មាភិសង្ខារទាំងនោះឲ្យស្ងួត ឲ្យរីង ឲ្យក្រៀម គឺចូរធ្វើមិនឲ្យជាពូជ ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកម្មាភិសង្ខារនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសជាតណា ( ដែលកើត ) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះឲ្យរីងស្ងួត យ៉ាងនេះខ្លះ ។

[ ១៥៩ ] ពាក្យថា កិលេសជាតជាគ្រឿងកង្វល់ ចូរកុំមានដល់អ្នកក្នុងកាលជាខាងក្រោយឡើយ សេចក្ដីថា អនាគត លោកហៅថា កាលខាងក្រោយ ។ គ្រឿងកង្វល់ទាំងឡាយណា គប្បីកើតឡើងព្រោះប្រារព្ធនូវសង្ខារជាអនាគត គ្រឿងកង្វល់ទាំងនេះគឺ កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត កុំមានដល់អ្នកឡើយ ទាំងអ្នកកុំធ្វើឲ្យប្រាកដ កុំញុំាងគ្រឿងកង្វល់ឲ្យកើតឡើង កុំឲ្យដុះដាល កុំឲ្យលូតលាស់ កុំឲ្យកើតឡើងចំពោះ គឺចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវគ្រឿងកង្វល់ទាំងនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កិលេសជាតជាគ្រឿងកង្វល់ ចូរកុំមានដល់អ្នកក្នុងកាលជាខាងក្រោយឡើយ ។

[ ១៦០ ] ពាក្យថា បើអ្នកមិនកាន់យកក្នុងខន្ធជាកណ្ដាល សេចក្ដីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាបច្ចុប្បន្នហៅថា ខន្ធជាកណ្ដាល ។ បើអ្នកមិនកាន់ មិនស្ទួយ មិនចាប់ មិនពាល់ មិនត្រេកអរ មិនស្រស់ស្រាយ មិនជ្រុលជ្រប់ ចំពោះសង្ខារជាបច្ចុប្បន្ន ដោយអំណាចតណ្ហានិងទិដ្ឋិទេ គឺថា

បើអ្នកលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានទូវសេចក្តីត្រេកអរ សេចក្តីស្រស់ស្រាយ សេចក្តីជ្រុលជ្រប់ សេចក្តីប្រកាន់ ការស្ទាបអង្អែល ការជាប់ចំពាក់ទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បើអ្នកមានកាន់យកក្នុងខន្ធជាកណ្តាល ។

[ ១៦១ ] ពាក្យថា អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ គឺអ្នកនឹងជាបុគ្គលស្ងប់ព្រោះស្ងប់រាគៈ ជាបុគ្គលស្ងប់ព្រោះស្ងប់ទោសៈ ។បេ។ នឹងជាអ្នកស្ងប់ អ្នករម្ងាប់ អ្នកស្ងប់រម្ងាប់ អ្នករលត់ទុក្ខ អ្នកសះស្បើយទុក្ខ ព្រោះស្ងប់ ព្រោះរម្ងាប់ ព្រោះស្ងប់រម្ងាប់ ព្រោះផុត ព្រោះរលត់ទុក្ខ ព្រោះប្រាសទៅ ព្រោះទ្រុឌទ្រោមទៅនៃអភិសង្ខារជាអកុសលទាំងពួង ហើយនឹងត្រាច់ទៅ នៅ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កិលេសជាតណា ( ដែលកើត ) ក្នុងកាលមុន អ្នកចូរញុំាង
កិលេសជាតនោះឲ្យរីងស្ងួត កិលេសជាតជាគ្រឿងកង្វល់ កុំ
មានដល់អ្នកក្នុងកាលជាខាងក្រោយឡើយ បើអ្នកមិនកាន់យក
ក្នុងខន្ធជាកណ្តាលទេ អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។

[ ១៦២ ] សេចក្តីប្រកាន់ក្នុងនាមនិងរូប ដោយសព្វគ្រប់នៃបុគ្គលណា មិនមានទេ បុគ្គលនោះរមែងមិនសោកព្រោះសត្វនិងសង្ខារដែលមិនមាន បុគ្គលនោះឯង រមែងមិនសាបសូន្យក្នុងលោកឡើយ ។

[ ១៦៣ ] អធិប្បាយពាក្យថា សេចក្តីប្រកាន់ក្នុងនាមនិងរូប ដោយសព្វ

គ្រប់នៃបុគ្គលណាមិនមានទេ ត្រង់ពាក្យថា ដោយសព្វគ្រប់ គឺគ្រប់ទាំងអស់ សព្វទាំងអស់ ឥតសេសសល់ មិនមានសេសសល់ ពាក្យថា ដោយសព្វគ្រប់ទុំះ គឺជាពាក្យប្រមូល ។ ពាក្យថា នាម បានដល់ អរូបក្ខន្ធ ៤ ។ ពាក្យថា រូប បានដល់ មហាភូរូប ៤ និងឧបាទាយរូបរបស់មហាភូតរូប ៤ ។ ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា សេចក្តីប្រកាន់ បានខាងសេចក្តីប្រកាន់ ២ សេចក្តីប្រកាន់ គឺតណ្ហា ១ សេចក្តីប្រកាន់ គឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីប្រកាន់គឺតណ្ហា ។បេ។ នេះសេចក្តីប្រកាន់គឺទិដ្ឋិ ។ ពាក្យថា ការប្រកាន់ក្នុងនាមនិងរូប ដោយសព្វគ្រប់នៃបុគ្គលណាមិនមានទេ បានសេចក្តីថា សេចក្តីប្រកាន់ក្នុងនាមនិងរូបដោយសព្វគ្រប់នៃបុគ្គលណា មិនមាន ឥតមាន មិនបាន គឺបុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេចក្តីប្រកាន់ក្នុងនាមនិងរូប ដោយសព្វគ្រប់នៃបុគ្គលណា មិនមានទេ ។

[ ១៦៤ ] ពាក្យថា បុគ្គលនោះរមែងមិនសោក ព្រោះសត្វនិងសង្ខារដែលមិនមាន អធិប្បាយថា បុគ្គលរមែងមិនសោករកវត្ថុដែលត្រូវប្រែប្រួល ឬកាលវត្ថុប្រែប្រួលហើយមិនសោក គឺមិនសោកថា ចក្ខុរបស់អញប្រែប្រួលហើយ មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេងថា សោតៈរបស់អញ ឃានៈរបស់អញ ជិវ្ហារបស់អញ កាយរបស់អញ រូបរបស់អញ សំឡេងរបស់អញ ក្លិនរបស់អញ រសរបស់អញ ផស្សព្វរបស់អញ

ត្រកូលរបស់អញ ពួករបស់អញ អាវាសរបស់អញ លាភរបស់អញ ។បេ។ ញាតិសាលោហិតរបស់អញប្រែប្រួលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលរមែងមិនសោក ព្រោះសត្វនិងសង្ខារដែលមិនមានយ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលដែលត្រូវទុក្ខវេទនា មិនជាទីត្រេកអរពាល់ត្រូវ គ្របសង្កត់ រួបរឹតទន្រ្ទានហើយរមែងមិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ រមែងមិនសោក ព្រោះសត្វនិងសង្ខារដែលមិនមាន យ៉ាងនេះខ្លះ ។ មួយទៀតបុគ្គលដែលត្រូវចក្ខុរោគពាល់ត្រូវ គ្របសង្កត់ ។បេ។ ត្រូវសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃនិងពស់ពាល់ត្រូវ គ្របសង្កត់ រួបរឹត ទន្រ្ទានហើយ រមែងមិនសោកមិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេង ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលរមែងមិនសោក ព្រោះសត្វនិងសង្ខារដែលមិនមាន យ៉ាងនេះខ្លះ ។ មួយវិញទៀត កាលសត្វនិងសង្ខារមិនមាន ឥតមាន ដែលមិនបានបុគ្គលក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេងថា ឱហ្ន៎ វត្ថុនោះមានដល់អញហើយ ឱហ្ន៎ វត្ថុនោះមិនមានដល់អញទេ ឱហ្ន៎ សូមឲ្យវត្ថុនោះមានដល់អញ ឱហ្ន៎ អញមិនបានវត្ថុនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលរមែងមិនសោក ព្រោះសត្វនិងសង្ខារដែលមិនមាន យ៉ាងនេះខ្លះ ។

[ ១៦៥ ] ពាក្យថា បុគ្គលនោះឯង រមែងមិនសាបសូន្យក្នុងលោក អធិប្បាយថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាមួយ ដែលគួរកាន់យក

គួរស្អាបអង្អែល គួរជាប់ចំពាក់ គួរជ្រុលជ្រប់ គួរចុះស៊ប់ថានេះរបស់អញ ក្តី ថានេះរបស់បុគ្គលដទៃក្តីនៃបុគ្គលណាមាន ឯសេចក្តីសាបសូន្យនៃបុគ្គល នោះក៏មាន ។ សមដូចភាសិតទុំះថា

ព្រះអង្គសាបសូន្យចាករថ សេះ កែវមណីនិងកុណ្ឌល សាប សូន្យចាកបុត្តនិងភរិយាដូច្នោះដែរ កាលភោគៈទាំងអស់ ព្រះ អង្គ មិនបានសេពសោយហើយ ហេតុអ្វីទើបព្រះអង្គមិនក្តៅ ក្រហាយក្នុងកាលដែលគួរសោក ។ ភោគៈទាំងឡាយ លះបង់ សត្វមុនក៏មាន សត្វលះបង់ភោគៈទាំងនោះ មុនជាងទៅទៀត ក៏មាន បពិត្រព្រះអង្គ អ្នកមានប្រាថ្នាកាម ពួកជនអ្នកមាន ភោគៈ មិនមានអ្វីជារបស់ខ្លួនទេ ហេតុនោះ ទើបខ្ញុំមិនសោក ក្នុងកាលដែលគួរសោក ។ ព្រះចន្ទរមែងរះឡើង រួចពេញវង់ ហើយអស់ទៅវិញ ព្រះអាទិត្យអស្តង្គតទៅ លោកធម៌ទាំង ៨ ខ្ញុំដឹងច្បាស់ហើយ ហេតុនោះទើបខ្ញុំមិនសោក ក្នុងកាលដែល គួរសោក ។

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាមួយដែលគួរកាន់យក គួរស្អាប អង្អែល គួរជាប់ចំពាក់ គួរជ្រុលជ្រប់ គួរចុះស៊ប់ថានេះរបស់អញក្តី ថានេះ របស់បុគ្គលដទៃក្តី នៃបុគ្គលណា មិនមានទេ សេចក្តីសាបសូន្យនៃបុគ្គលនោះ ក៏មិនមាន ។ សមដូចភាសិតទុំះថា បពិត្រសមណៈ លោកត្រេកអរឬ ម្នាល អ្នកមានអាយុ យើងត្រេកអរព្រោះបានអ្វី បពិត្រសមណៈ បើដូច្នោះ លោក

សោកឬ ម្នាលអ្នកមានអាយុ យើងសាបសូន្យអ្វីហើយ បពិត្រសមណៈ បើដូច្នោះ លោកមិនត្រេកអរ មិនសោកឬ ម្នាលអ្នកមានអាយុ យ៉ាងហ្នឹងហើយ ។

យូរណាស់ហើយ យើងទើបឃើញព្រាហ្មណ៍ ដែលមានទុក្ខ
រលត់ហើយ ដែលមិនមានសេចក្តីត្រេកអរ ដែលមិនមាន
សេចក្តីតានតឹង ជាកិក្ខុឆ្លងតណ្ហាដែលផ្សាយទៅកាន់អារម្មណ៍
ផ្សេងៗក្នុងលោក ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះឯង រមែងមិនសាបសូន្យក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សេចក្តីប្រកាន់ក្នុងនាមនិងរូបដោយសព្វគ្រប់នៃបុគ្គលណា មិន
មានទេ បុគ្គលនោះរមែងមិនសោក ព្រោះសត្វនិងសង្ខារដែល
មិនមាន បុគ្គលនោះឯង រមែងមិនសាបសូន្យក្នុងលោក ។

[ ១៦៦ ] ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណាមិនមានទេ បុគ្គលនោះកាលមិនបានសេចក្តីប្រកាន់ រមែងមិនសោកថា អញមិនមានរបស់នេះដូច្នេះឡើយ ។

[ ១៦៧ ] អធិប្បាយពាក្យថា ខន្ធនីមួយដែលគួរប្រកាន់ថានេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមានទេ ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាមួយដែលគួរកាន់ គួរស្ទាបអង្អែល គួរជាប់ចំពាក់ គួរជ្រុលជ្រប់ គួរចុះស៊ប់ថានេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន មិនមាន

ព្រម ដែលមិនបាន គឺបុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើង ដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខន្ធនីមួយដែលគួរប្រកាន់ថានេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមានយ៉ាងនេះខ្លះ ។ ពាក្យនេះព្រះមានព្រះភាគក៏បានត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ កាយនេះមិនមែនរបស់អ្នកទាំងឡាយទេ ទាំងមិនមែនរបស់អ្នកដទៃទេ ម្នាលភិក្ខុទាំងឡាយ កម្មនេះជារបស់ចាស់ដែលគេតាក់តែងហើយ ដែលចិត្តសន្សំហើយ ជាទីតាំងនៃវេទនា អ្នកទាំងឡាយត្រូវឃើញ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះអរិយសាវកអ្នកចេះដឹងរមែងកំណត់ទុកក្នុងចិត្តដោយឧបាយ ចំពោះបដិច្ចសមុប្បាទធម៌ ដោយល្អថា កាលបើនេះមាននេះក៏មាន នេះកើតឡើងព្រោះនេះកើត កាលបើនេះមិនមាន នេះក៏មិនមាន នេះរលត់ព្រោះនេះរលត់ គឺថាសង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ។បេ។ ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ការរលត់សង្ខារព្រោះការរលត់រលាយអស់អវិជ្ជាមិនមានសេសសល់ ។បេ។ ការរលត់កងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ។ ខន្ធនីមួយ ( ដែលគួរប្រកាន់ថា ) នេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណាមិនមានយ៉ាងនេះខ្លះ ។ ពាក្យនេះព្រះមានព្រះភាគ ក៏បានត្រាស់ហើយថា

ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សម្លឹងមើលនូវ
លោក ថាជារបស់សូន្យចុះ បុគ្គលដកអត្តានុទិដ្ឋិហើយ គប្បី

ធ្វើងមច្ចុបានដោយវិធីយ៉ាងនេះ មច្ចុរាជ រមែងមិនជួបប្រទះនូវ
បុគ្គលដែលសម្លឹងមើលលោកយ៉ាងនោះ ។

ខន្ធទីមួយ ( ដែលគួរប្រកាន់ថា ) នេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមានយ៉ាងនេះខ្វះ ។

មួយទៀត ពាក្យនេះព្រះមានព្រះភាគត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា មិនមែនជារបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នូវធម្មជាតនោះចេញ ធម្មជាតនោះ ដែលអ្នកទាំងឡាយលះបង់បានហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលដ៏វែង ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតដូចម្តេច មិនមែនរបស់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះរូបនោះចេញ រូបនោះដែលអ្នកទាំងឡាយលះហើយនឹងមានប្រយោជន៍ មានសេចក្តីសុខអស់កាលវែង វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់នាមខន្ធនោះចេញ នាមខន្ធនោះ ដែលអ្នកទាំងឡាយលះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលវែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច ស្មៅ ឈើ មែកឈើ ស្លឹកឈើណា មាននៅក្នុងវត្តជេតពននេះ អ្នកផងគប្បីនាំយកចេញ ឬដុត ឬក៏ធ្វើនូវស្មៅជាដើមនោះឲ្យសមគួរដល់បច្ច័យ ចុះអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះដែរឬទេថា អ្នកផងនាំយក ឬដុត ឬក៏ធ្វើនូវយើងទាំងឡាយ ឲ្យសមគួរដល់បច្ច័យ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះ មិនដូច្នោះទេ ។ ដំណើរនុ៎ះ

ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្លួនក្តី វត្ថុជារបស់ខ្លួនក្តី ទុំះមិនមែន ជារបស់យើងខ្ញុំទេ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះមែនហើយ វត្ថុណាមិន មែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់វត្ថុនោះចេញ វត្ថុនោះ ដែលអ្នកទាំងឡាយលះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខអស់ កាលវែង ។ ម្នាលភិក្ខុទាំងឡាយ វត្ថុអ្វីមិនមែនរបស់អ្នកទាំងឡាយ ម្នាល ភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់ រូបនោះចេញ រូបនោះដែលអ្នកទាំងឡាយលះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខអស់កាលវែង ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែន របស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់នាមខន្ធនោះចេញ នាមខន្ធ នោះដែលអ្នកទាំងឡាយលះបង់ហើយ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលដ៏វែង ។ ខន្ធនីមួយ ( ដែលគួរប្រកាន់ថា ) នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមាន យ៉ាងនេះខ្វះ ។ មួយទៀតមាន ភាសិតនេះថា

បពិត្រអ្នកជាធំ បុគ្គលកាលឃើញ នូវការកើតឡើង នៃការ ប្រព្រឹត្តទៅសុទ្ធ នូវតំណនៃសង្ខារសុទ្ធ ភ័យរមែងមិនមានដោយ ពិត បុគ្គលឃើញដោយបញ្ញានូវសត្វលោក ទុកស្មើដោយស្មៅ និងកំណាត់ឈើក្នុងកាលណា ក្នុងកាលនោះរមែងមិនប្រាថ្នានូវ វត្ថុដទៃបន្តិចបន្តួច ក្រៅអំពីមិនបដិសន្ធិ ។

វជិរាភិក្ខុនី បានពោលពាក្យទុំះនឹងមារមានចិត្តបាបថា

ម្នាលមារអ្នកជឿនូវអ្វីហ្ន៎ថាជាសត្វ ទិដ្ឋិរបស់អ្នកដូច្នោះឬ នេះ ជាគំនរនៃសង្ខារសុទ្ធ សត្វក្នុងគំនរនេះ បុគ្គលរកមិនបានទេ ពាក្យថារថដូច្នេះ រមែងកើតមាន ព្រោះគ្រឿងផ្សំនៃអវយវៈ យ៉ាងណាមិញ កាលបើខន្ធទាំងឡាយមានសេចក្តីសន្មតថាសត្វ ក៏រមែងមានយ៉ាងនោះដែរ ពិតណាស់ ទុក្ខហ្នឹងឯងរមែងកើត ឡើង ទុក្ខរមែងឋិតនៅផង រលត់ទៅផង មិនមានធម្មជាតណា មួយក្រៅអំពីទុក្ខកើតឡើង មិនមានធម្មជាតដទៃ ក្រៅអំពីទុក្ខ រលត់ទៅ ។

ខន្ធនីមួយ ( ដែលគួរប្រកាន់ ) ថានេះរបស់អញ ឬថានេះរបស់បុគ្គល ដទៃនៃបុគ្គលណាមិនមាន យ៉ាងនេះខ្វះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្វែងរករូបរហូតដល់គតិរបស់រូប ស្វែងរកវេទនា សញ្ញា សង្ខារ វិញ្ញាណ រហូតដល់គតិរបស់វិញ្ញាណ កាលបើភិក្ខុនោះស្វែង រករូបរហូតដល់គតិរបស់រូប ស្វែងរកវេទនា សញ្ញា សង្ខារ វិញ្ញាណ រហូត ដល់គតិរបស់វិញ្ញាណ យ៉ាងនេះហើយ ( សេចក្តីប្រកាន់ ) ណាថា អញ ដូច្នេះក្តី ថារបស់អញដូច្នេះក្តី ( ថាអញ ) មានដូច្នេះក្តីរបស់ភិក្ខុណា ( សេចក្តី ប្រកាន់ ) នោះ របស់ភិក្ខុនោះ មិនមានទេ ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថានេះរបស់បុគ្គលដទៃ នៃបុគ្គល ណា មិនមានយ៉ាងនេះខ្វះ ។

ព្រះអានន្ទមានអាយុ ក្រាបទូលសួរដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា

បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលព្រះអង្គពោលថា លោកសូន្យ លោកសូន្យ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលព្រះអង្គពោលថា លោកសូន្យ តើដោយហេតុដូចម្ដេច ។ ម្នាលអានន្ទ ធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ព្រោះហេតុណា ហេតុនោះបានជាតថាគតពោលថា លោកសូន្យ ។ ម្នាលអានន្ទ ធម្មជាតដូចម្ដេចដែលសូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ចក្ខុហ្នឹងឯងសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន រូបទាំងឡាយសូន្យ ចក្ខុ-វិញ្ញាណសូន្យ ចក្ខុសម្ផស្សសូន្យ សុខក្ដី ទុក្ខក្ដី អទុក្ខមសុខក្ដីណាដែលបុគ្គលដឹងហើយ រមែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតមានសុខជាដើមនោះឯងជារបស់សូន្យ សោតៈសូន្យ សទ្ទៈសូន្យ ឃានៈសូន្យ គន្ធៈសូន្យ ជិវ្ហាសូន្យ រសទាំងឡាយសូន្យ កាយសូន្យ ផោដ្ឋព្វៈទាំងឡាយសូន្យ មនៈសូន្យ ធម្មៈសូន្យ មនោវិញ្ញាណសូន្យ មនោសម្ផស្សសូន្យ សុខក្ដី ទុក្ខក្ដី អទុក្ខមសុខក្ដីណា ដែលបុគ្គលដឹងហើយ រមែងកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតមានសុខជាដើមនោះឯង ជារបស់សូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ធម្មជាតដែលសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួនព្រោះហេតុណា ហេតុនោះតថាគតពោលថា លោកសូន្យ ។ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ខន្ធនីមួយដែលគួរប្រកាន់ថា នេះរបស់អញ ឬថា នេះរបស់បុគ្គលដទៃ នៃបុគ្គលណា មិនមានយ៉ាងនេះខ្លះ ។

[ ១៦៨ ] ពាក្យថា បុគ្គលនោះកាលមិនបានសេចក្ដីប្រកាន់ ត្រង់ពាក្យថា សេចក្ដីប្រកាន់ បានដល់ សេចក្ដីប្រកាន់ ២ សេចក្ដីប្រកាន់គឺតណ្ហា ១ សេចក្ដី

ប្រកាន់ គឺទិដ្ឋិ ១ ។បេ។ នេះសេចក្តីប្រកាន់ គឺតណ្ហា ។បេ។ នេះសេចក្តីប្រកាន់ គឺទិដ្ឋិ ។ បុគ្គលកាលលះបង់សេចក្តីប្រកាន់ គឺតណ្ហា រលាស់ចោលសេចក្តីប្រកាន់គឺទិដ្ឋិហើយមិនចួប មិនប្រទះ មិនបាន មិនបានចំពោះនូវសេចក្តីប្រកាន់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះកាលមិនបាននូវសេចក្តីប្រកាន់ ។

[ ១៦៩ ] ពាក្យថា រមែងមិនសោកថា អញមិនមានរបស់នេះ គឺបុគ្គលមិនសោករករបស់ដែលត្រូវប្រែប្រួលឬកាលវត្ថុដែលប្រែប្រួលហើយមិនសោក គឺមិនសោកថា ចក្ខុរបស់អញប្រែប្រួល សោតៈរបស់អញ ។បេ។ មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង មិនដល់នូវការវង្វេងថា ញាតិសាលោហិតរបស់អញ ប្រែប្រួលហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលមិនសោកថា អញមិនមានរបស់នេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ខន្ធនីមួយ ( ដែលគួរប្រកាន់ថា ) នេះរបស់អញ ឬថានេះរបស់
បុគ្គលដទៃនៃបុគ្គលណា មិនមានទេ បុគ្គលនោះកាលមិនបាន
សេចក្តីប្រកាន់រមែងមិនសោកថា អញមិនមានរបស់នេះដូច្នេះ
ឡើយ ។

[ ១៧០ ] តថាគតដែលត្រូវគេសួរ អំពីពួកបុគ្គលអ្នកមិនញាប់ញ័រហើយ នឹងពោលនូវអានិសង្ស ( នៃពួកបុគ្គល ) នោះ គឺបុគ្គលអ្នកមិនមានសេចក្តីប្រណែន អ្នកមិនប្រាថ្នា អ្នកមិនមានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ។

[ ១៧១ ] អធិប្បាយពាក្យថា បុគ្គលអ្នកមិនមានសេចក្តីប្រណែន អ្នកមិន

ប្រាថ្នា សំណួរថា សេចក្តីប្រណៃនតើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នកប្រណៃនរមែងប្រណៃន ឈ្នានីស ចងនូវសេចក្តីប្រណៃន ទុកក្នុងលាភសក្ការៈ ការគោរព ការរាប់អាន ការថ្វាយបង្គំ ការបូជារបស់បុគ្គលដទៃ សេចក្តីប្រណៃន អំពើនៃសេចក្តីប្រណៃន សេចក្តីឫស្យា អាការនៃឫស្យា ភាពនៃសេចក្តីឫស្យា សេចក្តីឈ្នានីស អាការនៃឈ្នានីស ភាពនៃសេចក្តីឈ្នានីស ឯណាមានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្តីប្រណៃន ។ សេចក្តីប្រណៃននុ៎ះបុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានសេចក្តីប្រណៃន ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានសេចក្តីប្រណៃន ។ ពាក្យថា អ្នកមិនប្រាថ្នា សេចក្តីថា តណ្ហាលោកហៅថា សេចក្តីប្រាថ្នា បានខាងរាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានុ៎ះ បុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនប្រាថ្នា ។ បុគ្គលនោះមិនប្រាថ្នាក្នុងរូប ។បេ។ មិនប្រាថ្នា មិនចង់បាន មិនល្មោភ មិនជ្រុលជ្រប់ក្នុងអារម្មណ៍ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង គឺជាអ្នកអស់ចំណង់ គ្មានចំណង់ លះបង់ចំណង់ ខ្ជាក់ចោលចំណង់ មានចំណង់រួចស្រឡះ មានចំណង់វិនាស មានចំណង់រលាស់ចេញជាអ្នកអស់តម្រេក គ្មានតម្រេក លះបង់តម្រេក ខ្ជាក់ចោលតម្រេក មានតម្រេករួចស្រឡះ មានតម្រេកវិនាស មានតម្រេករលាស់ចេញ ជាអ្នកមិន

ឃ្លាន រលត់ចំណង់ មានចិត្តត្រជាក់ទទួលសុខ មានខ្លួនដ៏ប្រសើរ សម្រាន្តនៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានសេចក្តីប្រណីន អ្នកមិនប្រាថ្នា ។

[ ១៧២ ] ពាក្យថា អ្នកមិនមានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងអារម្មណ៍ទាំងពួង អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីញាប់ញ័រ បានខាងរាគៈ រាគៈមានកម្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា ជាគ្រឿងញាប់ញ័រនុ៎ះ បុគ្គលណាបានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានការញាប់ញ័រ ។ បុគ្គលនោះ ឈ្មោះថា អ្នកមិនមានការញាប់ញ័រ ព្រោះលះតណ្ហាជាគ្រឿងញាប់ញ័រហើយ រមែងមិនញាប់ញ័រក្នុងលាភខ្លះ មិនញាប់ញ័រក្នុងអលាភខ្លះ មិនញាប់ញ័រក្នុងយសខ្លះ មិនញាប់ញ័រក្នុងអយសខ្លះ មិនញាប់ញ័រក្នុងបសំសាខ្លះ មិនញាប់ញ័រក្នុងនិន្ទាខ្លះ មិនញាប់ញ័រក្នុងសុខខ្លះ មិនញាប់ញ័រ មិនកំរើក មិនរំភើប មិនរន្ធត់ មិនស្ទន់ស្ទោ ក្នុងទុក្ខខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានការញាប់ញ័រ ។ ពាក្យថា អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង សេចក្តីថា ធម៌ទាំងពួងលោកពោលសំដៅអាយតនៈ ១២ គឺចក្ខុ ១ រូប ១ ។បេ។ មនៈ ១ ធម្មៈ ១ ។ កាលណាឆន្ទរាគៈក្នុងអាយតនៈទាំងខាងក្នុងខាងក្រៅ បុគ្គលបានលះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវភាពមិនមាន មិនឲ្យមានការកើតតទៅជាធម្មតា បុគ្គលនោះលោកហៅថា អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង អ្នកនឹងធឹងក្នុងធម៌ទាំងពួង អ្នកកណ្តាលក្នុងធម៌ទាំងពួង អ្នកព្រងើយកន្តើយក្នុង

ធម៌ទាំងពួង ក្នុងកាលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ។

[ ១៧៣ ] ពាក្យថា តថាគតដែលត្រូវគេសួរ អំពីពួកបុគ្គលអ្នកមិនញាប់ញ័រ នឹងពោលនូវអានិសង្ស ( នៃពួកបុគ្គល ) នោះ គឺតថាគតដែលត្រូវគេសួរ គេដេញដោល គេសូម គេអារាធនា គេជ្រះថ្លា អំពីពួកបុគ្គលអ្នកមិនញាប់ញ័រ នឹងពោល នឹងសម្តែង នឹងប្រាប់ ។បេ។ នឹងប្រកាសនូវអានិសង្ស ៤ នេះថា បុគ្គលនោះជាអ្នកមិនមានសេចក្តីប្រណែន ១ អ្នកមិនប្រាថ្នា ១ អ្នកមិនមានការញាប់ញ័រ ១ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ១ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតដែលត្រូវគេសួរ អំពីពួកបុគ្គលអ្នកមិនញាប់ញ័រ នឹងពោលនូវអានិសង្ស ( នៃពួកបុគ្គល ) នោះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> តថាគតដែលត្រូវគេសួរ អំពីពួកបុគ្គលអ្នកមិនញាប់ញ័រ នឹងពោលនូវអានិសង្ស ( នៃពួកបុគ្គល ) នោះ គឺបុគ្គលអ្នកមិនមានសេចក្តីប្រណែន អ្នកមិនប្រាថ្នា អ្នកមិនមានការញាប់ញ័រ អ្នកមានចិត្តស្មើក្នុងធម៌ទាំងពួង ។

[ ១៧៤ ] ការតាក់តែងណាមួយនៃបុគ្គលអ្នកមិនមានការញាប់ញ័រ អ្នកដឹងច្បាស់មិនមានទេ បុគ្គលនោះវៀរចាកការផ្តើមផ្សេងៗ រមែងឃើញសេចក្តីក្សេមក្នុងទីទាំងពួង ។

[ ១៧៥ ] ពាក្យថា អ្នកមិនមានការញាប់ញ័រ អ្នកដឹងច្បាស់ សេចក្តីថា តណ្ហា លោកហៅថា ការញាប់ញ័រ បានខាងរាគៈ រាគៈមានកម្លាំង ។បេ។

អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាជាគ្រឿងញាប់ញ័រនុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានការញាប់ញ័រ ។ បុគ្គលឈ្មោះថា អ្នកមិនមានការញាប់ញ័រនោះ ព្រោះលះតណ្ហាជាគ្រឿងញាប់ញ័រហើយ រមែងមិនញាប់ញ័រក្នុងលាភខ្លះ មិនញាប់ញ័រក្នុងអលាភខ្លះ មិនញាប់ញ័រក្នុងយសខ្លះ មិនញាប់ញ័រក្នុងអយសខ្លះ មិនញាប់ញ័រក្នុងបសំសាខ្លះ មិនញាប់ញ័រក្នុងនិន្ទាខ្លះ មិនញាប់ញ័រក្នុងសុខខ្លះ មិនញាប់ញ័រ មិនកំរើក មិនរំភើប មិនរន្ធត់ មិនស្ទន់ស្ទោក្នុងទុក្ខខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានការញាប់ញ័រ ។ ពាក្យថា អ្នកដឹងច្បាស់ គឺអ្នកដឹង ដឹងទូទៅ ដឹងច្បាស់ ដឹងចំពោះ យល់ច្បាស់ថា សង្ខារទាំងពួងមិនទៀង អ្នកដឹង ដឹងទូទៅ ដឹងច្បាស់ ដឹងចំពោះ យល់ច្បាស់ថា សង្ខារទាំងពួងជាទុក្ខ ។បេ។ អ្នកដឹង ដឹងទូទៅ ដឹងច្បាស់ ដឹងចំពោះ យល់ច្បាស់ថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះមានការរលត់ទៅវិញជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកមិនមានការញាប់ញ័រ អ្នកដឹងច្បាស់ ។

[ ១៧៦ ] ពាក្យថា ការតាក់តែងណានីមួយ មិនមាន សេចក្តីថា ការតាក់តែងទាំងឡាយ លោកពោលសំដៅយក បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ បុគ្គលលះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាពមិនមាន មិនឲ្យមានការកើតតទៅជាធម្មតា ក្នុងកាលណា ការតាក់តែង

ទាំងឡាយនៃបុគ្គល មិនមាន ឥតមាន ដែលមិនបាន គឺលោកបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ ដោយហេតុប៉ុណ្ណេះ ក្នុងកាលនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការតាក់តែងណាទីមួយមិនមាន ។

[ ១៧៧ ] ពាក្យថា បុគ្គលនោះវៀរចាកការផ្ដើមផ្សេងៗ សេចក្ដីថា បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ លោកហៅថា ការផ្ដើមផ្សេងៗ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ បុគ្គលលះបង់ ផ្ដាច់ឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ដល់នូវភាពមិនមាន មិនឲ្យមានការកើតតទៅជាធម្មតា ក្នុងកាលណា បុគ្គលជាអ្នកចៀសវាង គេចចេញ វៀរស្រឡះផ្សេងៗ រត់ចេញ រលាស់ចេញ រួចស្រឡះ ប្រកបប្រាសចាកការផ្ដើមផ្សេងៗ មានចិត្តប្រាសចាកសេចក្ដីសល់វល់ ដោយហេតុប៉ុណ្ណេះក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា ) បុគ្គលនោះវៀរចាកការតាក់តែងផ្សេងៗ ។

[ ១៧៨ ] ពាក្យថា រមែងឃើញសេចក្ដីក្សេមក្នុងទីទាំងពួង សេចក្ដីថា រាគៈជាគ្រឿងធ្វើនូវភ័យ ទោសៈ ជាគ្រឿងធ្វើនូវភ័យ មោហៈ ជាគ្រឿងធ្វើនូវភ័យ ។បេ។ កិលេសទាំងឡាយជាគ្រឿងធ្វើនូវភ័យ ។ ព្រោះរាគៈជាគ្រឿងធ្វើនូវភ័យលោកលះបង់ហើយ ។បេ។ ព្រោះកិលេសជាគ្រឿងធ្វើនូវភ័យ លោកលះបង់ហើយ ទើបឈ្មោះថា ឃើញសេចក្ដីក្សេមក្នុងទីទាំងពួង គឺឃើញហេតុមិនមានភ័យក្នុងទីទាំងពួង ឃើញវត្ថុមិនមានចង្រៃក្នុងទីទាំងពួង ឃើញវត្ថុមិនមានឧបទ្រពក្នុងទីទាំងពួង ឃើញការមិនមានឧបសគ្គក្នុងទីទាំងពួង ឃើញ

គុណដ៏ស្ងប់រម្ងាប់ក្នុងទីទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) រមែងឃើញសេចក្ដីក្សេមក្នុងទីទាំងពួង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ការតាក់តែងណានីមួយនៃបុគ្គលអ្នកមិនមានការញាប់ញ័រ អ្នកដឹងច្បាស់មិនមានទេ បុគ្គលនោះវៀរចាកការផ្ដើមផ្សេងៗរមែងឃើញសេចក្ដីក្សេមក្នុងទីទាំងពួង ។

[ ១៧៩ ] មុនិ មិននិយាយក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏ថោកទាបទេ មិននិយាយក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ ( ព្រោះ ) លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ មិនប្រកាន់ មិនលះបង់ ( ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ ) ។

[ ១៨០ ] ពាក្យថា មុនិ មិននិយាយក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏ថោកទាបទេ មិននិយាយក្នុងហេតុ ដ៏ខ្ពង់ខ្ពស់ទេ សេចក្ដីថា ញាណលោកហៅថា មោនៈ បានដល់ ប្រាជ្ញា ការដឹងសព្វ ។បេ។ មុនិនោះកន្លងនូវបណ្ដាញជាគ្រឿងជាប់ចំពាក់ ។បេ។ មុនិរមែងមិននិយាយ មិនសម្ដែង មិនពោល មិនបំភ្លឺ មិនបញ្ចេញថាអញជាបុគ្គលប្រសើរ ឬថាអញជាបុគ្គលស្មើ ឬក៏ថា អញជាបុគ្គលថោកទាបដូច្នេះឡើយ ហេតុនោះទ្រង់ត្រាស់ថា មុនិមិននិយាយក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏ថោកទាបទេ មិននិយាយក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ ។

[ ១៨១ ] អធិប្បាយពាក្យថា លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ត្រង់ពាក្យថា ជាអ្នកស្ងប់ គឺជាអ្នកស្ងប់ ព្រោះស្ងប់រាគៈ ជាអ្នកស្ងប់ អ្នក

រម្ងាប់ អ្នកស្ងប់រម្ងាប់ អ្នករលត់ទុក្ខ អ្នកសះស្បើយទុក្ខ ព្រោះស្ងប់ទោសៈ មោហៈ ។បេ។ ព្រោះស្ងប់ ព្រោះរម្ងាប់ ព្រោះធុះធ្លាយ ព្រោះរលត់ ព្រោះប្រាសចេញ ព្រោះសះស្បើយនូវអភិសង្ខារជាអកុសលទាំងពួង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកស្ងប់ ។ ពាក្យថា ប្រាសចាកកំណាញ់ សេចក្តីថា កំណាញ់ ៥ គឺកំណាញ់អាវាស ។បេ។ ការប្រកាន់ នេះលោកហៅថា ការកំណាញ់ ។ ការកំណាញ់នោះបុគ្គលណាលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើង គឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមានកំណាញ់ទៅប្រាស មានកំណាញ់ឃ្លាតចេញ មានកំណាញ់លះបង់ មានកំណាញ់ខ្ជាក់ចោល មានកំណាញ់រួចចេញ មានកំណាញ់បន្សាត់ចេញ មានកំណាញ់រលាស់ចេញហើយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ ។

[ ១៨២ ] អធិប្បាយពាក្យថា មិនប្រកាន់ មិនលះបោល ព្រះមានព្រះភាគត្រាស់ដូច្នេះ ត្រង់ពាក្យថា មិនប្រកាន់ គឺមិនប្រកាន់ មិនក្តួចកាន់ មិនទង់ទាញទុក មិនកាន់យក មិនស្អាបអង្អែល មិនជាប់ចំពាក់ចំពោះរូប មិនប្រកាន់ មិនក្តួចកាន់ មិនទង់ទាញទុក មិនស្អាបអង្អែល មិនជាប់ចំពាក់ចំពោះវេទនា សញ្ញា សង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្តៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនប្រកាន់ ។ ពាក្យថា មិនរលាស់ចោល គឺមិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនឲ្យដល់ការមិនមាននូវរូប មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនឲ្យដល់ការមិនមាននូវវេទនា សញ្ញា សង្ខារ

វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្តៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនលះបង់ចោល ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

មុនិមិននិយាយក្នុងហេតុដ៏ស្មើទេ មិននិយាយក្នុងហេតុដ៏ថោកទាបទេ មិននិយាយក្នុងហេតុដ៏ខ្ពង់ខ្ពស់ទេ ( ព្រោះ ) លោកជាអ្នកស្ងប់ ប្រាសចាកកំណាញ់ មិនប្រកាន់ មិនលះបង់ចោល ( ព្រះមានព្រះភាគត្រាស់ដូច្នេះ ) ។

## ចប់ អត្តទណ្ឌសុត្តនិទ្ទេសទី ១៥

# អដ្ឋកថា

## អត្តទណ្ឌសុត្តនិទ្ទេសទី ១៥

គប្បីជ្រាបវិនិច្ឆ័យក្នុងអត្តទណ្ឌសុត្តនិទ្ទេសទី ១៥ ដូចតទៅនេះថា

[ ៩០ ] គប្បីជ្រាបអត្ថក្នុងគាថាទី ១ មានពាក្យផ្ដើមថា **អត្តទណ្ឌា ភយំ ជាតំ** ដូច្នេះ ។

ភ័យណារបស់សត្វលោកកើតហើយក្នុងលោកបច្ចុប្បន្នឬក្នុងសម្បរាយភព ភ័យទាំងអស់ កើតអំពីអាជ្ញារបស់ខ្លួន គឺកើតព្រោះហេតុប្រព្រឹត្តអាក្រក់របស់ខ្លួន កាលបើដូច្នេះពួកអ្នកចូរមើលជនដែលទាស់ទែងគ្នា គឺចូរមើលជនដែលជាស្ដេចសក្យៈជាដើមនេះ ទាស់ទែងនូវគ្នានឹងគ្នា ។ ព្រះមានព្រះភាគ កាលទ្រង់អប់រំជនដែលប្រទូស្ត អ្នកបដិបត្តិខុសចំពោះគ្នានោះយ៉ាងនេះហើយ ដើម្បីឲ្យជននោះកើតនូវសេចក្ដីសង្វេគ ដោយការសម្ដែងដល់ការបដិបត្តិប្រពៃរបស់ព្រះអង្គទើបត្រាស់ថា តថាគតនឹងសម្ដែងសំវេគធម៌ តាមដែលតថាគតធ្លាប់សំវេគហើយ អធិប្បាយថា កាលមុនតថាគតជាពោធិសត្វ ។

[ ៩១ ] បទថា **តយោ** គឺការកំណត់ចំនួន ។ បទថា **ទណ្ឌា** បានដល់ទុច្ចរិត ។ បទថា **កាយទណ្ឌោ** បានដល់ កាយទុច្ចរិត ។ ក្នុងអាជ្ញាតាមផ្លូវវាចាជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **តិវិធំ កាយទុច្ចរិតំ** បានដល់ការប្រព្រឹត្តអាក្រក់ប្រព្រឹត្តទៅតាមផ្លូវកាយ មានបាណាតិបាតជាដើម ឬទុច្ចរិត ៣ ដែលបានឈ្មោះថា ប្រព្រឹត្តអាក្រក់ ព្រោះស្អុយដោយកិលេស ។ បទថា **ចតុព្វិធំ** បានដល់ វចីទុច្ចរិត ៤ មានមុសាវាទជាដើម ។ បទថា **តិវិធំ** បាន

ដល់ មនោទុច្ចរិត ៣ យ៉ាង មានអភិជ្ឈាជាដើម ។ បទថា **ទិដ្ឋធម្មិកំ** បាន ដល់ ភ័យដែលបានទទួលក្នុងបច្ចុប្បន្ននេះ គឺក្នុងអត្តភាពនេះ ។ បទថា **សម្ប-រាយិកំ** បានដល់ ភ័យដែលបានទទួលក្នុងអត្តភាព ដែលមិនទាន់មកដល់ ។ បទថា **អាគុចារី** បានដល់ ជាអ្នកប្រព្រឹត្តអាក្រក់ គឺប្រព្រឹត្តខុស ។ បទថា **តមេនំ រាជា បរិភាសតិ** បានដល់ ព្រះរាជាទ្រង់បរិភាសបុគ្គលដែលធ្វើអាក្រក់ឲ្យកើតនូវការខ្លាច ។ បទថា **ទុក្ខំ ទោមនស្សំ បដិសំវេទេតិ** បានដល់ សោយទុក្ខផ្លូវកាយ ទោមនស្សផ្លូវចិត្ត ។ បទថា **ឯតំ ភយំ ទុក្ខំ ទោមនស្សំ** បានដល់ ភ័យ ទុក្ខនិងទោមនស្សបែបនោះ ។ បទថា **កុតោ តស្ស** បានដល់ ភ័យរបស់ចោរនោះកើតមកអំពីណា ។ បទថា **អត្តទណ្ឌតោ ជាតំ** បានដល់ កើតអំពីទុច្ចរិតដែលខ្លួនធ្វើ ។

បទថា **អន្តមសោ** បានដល់ ដោយហោច ។ បទថា **សវចនីយម្បិ ករោតិ ន តេ លព្ភា ឥតោ បក្កមិតុំ** បានដល់ ទ្រង់ធ្វើការខាខាំងថា ចោរនោះ វានឹងទៅអំពីទីនេះ គឺអំពីស្រុកជាដើមនេះមិនបាន ហាមចេញទៅខាងក្រៅ ។ បទថា **ធនជានិប្បច្ចយាបិ** បានដល់ ព្រោះហេតុនៃការសាបសូន្យទ្រព្យ ។ ព្រះរាជាទ្រង់ត្រាស់ឲ្យធ្វើកម្មករណៈផ្សេងៗដល់បុគ្គលនោះ ។ បទថា **កសា-ហិបិ តាឡេតិ** បានដល់ ឲ្យវាយដោយរំពាត់មានជង់ខ្លះ ។ បទថា **វេត្តេហិបិ តាឡេតិ** បានដល់ ឲ្យវាយដោយផ្តៅមានបន្លាខ្លះ ។ បទថា **អឌ្ឍទណ្ឌកេហិ** ជាដើម មានន័យដូចពោលហើយ ខាងដើមនោះឯង ។ បទថា **សុនខេហិបិ ខាទាបេតិ** បានដល់ ឲ្យឆ្កែដែលគេបង្អត់អាហារ ២-៣ ថ្ងៃខាំស៊ី ។ សុនខ

ទាំងនោះត្រឹមតែមួយសន្ទុះប៉ុណ្ណោះ ក៏ខាំស៊ីសល់តែរាងឆ្អឹង ។ បទថា **ស្វលេ ឧត្តាសេតិ** បានដល់ ប្រើលំពែងចាក់លើកឡើង ។ បទថា **រាជា ឥមេសំ ចតុន្នំ ឋណ្ឌានំ ឥស្សរោ** បានដល់ ព្រះរាជា អាចដាក់នូវអាជ្ញាទាំង ៤ យ៉ាងនេះ ។ បទថា **សកេន កម្មេន** បានដល់ ព្រោះកម្មដែលខ្លួនធ្វើ ។ ក្នុងបទថា **តមេនំ និរយបាលា** នេះ ព្រះថេរៈពួកខ្លះពោលថា ពួកនាយនិរយ-បាលមិនមាន កម្មដែលដូចរូបយន្តនោះឯងដាក់ទោស ។ ពាក្យនោះត្រូវបដិ-សេធទុកក្នុងព្រះអភិធម្ម ដោយន័យជាដើមថា ពួកនិរយបាលក្នុងស្ថាននរកមានដែរឬ ។ អើ ។ ចុះពួកអ្នកធ្វើកម្ម ( ធ្វើទោស ) មានដែរឬ ។ ពួកនិរយបាលក្នុងនរកមានដូចក្នុងមនុស្សលោក ដែលមានពួកអ្នកដាក់ទោស ។ បទថា **តត្តំ អយោខិលំ** បានដល់ ពួកនិរយបាលឲ្យសត្វនរកដែលមានរាងកាយ ៣ គាវុត ដេកផ្ងារលើផែនដីដែកដែលឆេះសន្ធោសន្ធៅ ហើយយកដែកគោលប្រមាណប៉ុនដើមត្នោត ទម្លុះត្រង់ដៃស្តាំ ត្រង់ដៃឆ្វេងជាដើមក៏ដូចគ្នា ។ ពួកនិរយបាលឲ្យសត្វនរកដេកផ្កាប់មុខខ្លះ ផ្អៀងឆ្វេងខ្លះ ផ្អៀងស្តាំខ្លះ ដេកផ្ងារខ្លះ ដាក់នូវកម្មការណ៍នោះ ។

បទថា **សំវេសេត្វា** បានដល់ ឲ្យសរីរៈប្រមាណ ៣ គាវុត ដេកលើផែនដីដែកដែលឆេះប្រាល ។ បទថា **កុឋារីហិ** បានដល់ យកដឹងធំដែលមានមុខប៉ុនដំបូលផ្ទះ ពន្លះ ។ ឈាមហូរដូចទឹកហូរ អណ្តាតភ្លើងឆេះឡើងអំពីផែនដីដែករហូតដល់ទីដែលពន្លះកើតមហាទុក្ខ ។ម្យ៉ាងទៀតកាលពន្លះដោយសរសៃបន្ទាត់ ៨ ជ្រុងខ្លះ ៦ ជ្រុងខ្លះ ដូចចាំងឈើ ។ បទថា **វាសីហិ** បានដល់

ដោយកាំបិតព្រា ប្រមាណប៉ុនចង្អេរធំ ។ បទថា **រថេ យោជេត្វា** បានដល់ ទឹមត្រង់រថដែលមានភ្លើងឆេះទូទៅទាំងនឹម ទាំងខ្សែ ទាំងទ្រពង កង់ ទូកនិង ជន្ទញ ។ បទថា **មហន្តំ** បានដល់ ភ្នំរងើកភ្លើងធំប្រមាណប៉ុនផ្ទះកំពូល ។ បទថា **អារោបេន្តិ** បានដល់ យកដំបងដែកដែលមានភ្លើងឆេះរន្ទាល វាយ បង្ខំឲ្យឡើងភ្នំរងើកភ្លើង ។ បទថា **សកិម្បិ ឧទ្ធំ** បានដល់ ទៅខាងលើ ខាង ក្រោមនិងខាងទទឹង ដូចអង្ករដែលគេដាក់ក្នុងឆ្នាំងដែលមានទឹកពុះខ្ទោល ។ បទថា **មហានិរយេ** បានដល់ ក្នុងអវីចិមហានរក ។

បទថា **ចតុក្កណ្ណោ** បានដល់ ដូចគ្នានឹងប្រអប់ ៤ ជ្រុង ។ បទថា **វិភត្តោ** បានដល់ ចែកដោយទ្វារ ៤ ។ បទថា **ភាគសោ មិតោ** បានដល់ ចែក ចេញដោយចំណែកនៃទ្វារនិងផ្លូវ ។ បទថា **បរិយន្តោ** បានដល់ ព័ទ្ធជុំវិញ ។ បទថា **អយសា** បានដល់ មានបន្ទះដែកកម្រាស់ប្រមាណ ៩ យោជន៍គ្រប ខាងលើ ។ បទថា **សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ** បានដល់ ផ្សាយ ទៅ តាំងនៅ បុគ្គលកាលឈរសម្លឹងមើលក្នុងទី ១០០ យោជន៍ដោយជុំវិញ ភ្នែកទាំង ២ នឹងលៀនចេញ ដូចគូនៃកូនឃ្លី ។ បទថា **កទរិយា តបនា** បានដល់ មហានរក ៨ រណ្ដៅនិងឧស្សទនរកទាំងអស់នោះ ជាទីស្រើប ដុត រោលសត្វជានិច្ចព្រោះហេតុនោះទើបឈ្មោះថា **កទរិយា តបនា** ។ មហានរក ឈ្មោះថា **ឃោរា** ព្រោះឲ្យកើតទុក្ខគួរស្បើម ។ ឈ្មោះថា **អច្ចិមន្តោ** ព្រោះ មានអណ្ដាតភ្លើង តាំងនៅអស់កប្ប ។ ឈ្មោះថា **ទុរាសទា** ព្រោះធ្វើបាន លំបាកដើម្បីនឹងចូលទៅជិត ដើម្បីប៉ះពាល់ ។ ឈ្មោះថា **លោមហំសនរូបា**

ព្រោះត្រឹមតែឃើញឬត្រឹមតែបានឮក៏ព្រឺរោម ព្រឺស្បែក ។ ឈ្មោះថា **ភិស្មា** ព្រោះគួរស្ញើប ។ ឈ្មោះថា **បដិភយា** ព្រោះឲ្យកើតការខ្លាច ។ ឈ្មោះថា **ទុខា** ព្រោះមិនមានសេចក្ដីសុខ ។

គប្បីជ្រាបសេចក្ដីសង្ខេបនៃគាថាមានពាក្យផ្ដើមថា **បុរត្ថិមាយ ច ភិត្តិយា** រហូតដល់ចប់គាថាថា **ឯវំ អវីចិនិរយោ** ដូចតទៅនេះថា មហានរក ឈ្មោះ អវីចិ ព្រោះអត្ថថា ចន្លោះរបស់អណ្ដាតភ្លើង ឬចន្លោះរបស់សត្វ ឬចន្លោះនៃសេចក្ដីទុក្ខរបស់សត្វក្នុងនរកនោះមិនមាន ព្រោះថាក្នុងអវីចិនោះអណ្ដាតភ្លើងតាំងឡើងអំពីជញ្ជាំងទិសខាងកើតជាដើម ហើយដុតបុគ្គលដែលមានបាបកម្មផ្ទប់គ្នានឹងជញ្ជាំងទិសខាងលិចជាដើម ។ អណ្ដាតភ្លើងទម្លុះជញ្ជាំងនោះទៅខាងមុខ ១០០ យោជន៍ ។ អណ្ដាតភ្លើងឆេះអំពីខាងក្រោម ទល់គ្នានឹងដំបូលខាងលើ អណ្ដាតភ្លើងដែលឆេះដំបូលខាងលើ បាញ់មកទល់គ្នានឹងបាតខាងក្រោមក្នុងអវីចិនេះ ឈ្មោះថា មិនមានចន្លោះនៃអណ្ដាតភ្លើងយ៉ាងនេះ ។ ទី ១០០ យោជន៍ក្នុងអវីចិនោះ ពេញទៅដោយសត្វនរកមិនមានចន្លោះ ដូចនាឡិដែលពេញដោយម្សៅ ដែលធ្វើដោយវល្លិទឹកដោះ ។ សត្វនរកដែលឆេះក្នុងនរកក្នុងឥរិយាបថ ៤ មិនមានប្រមាណ ។ សត្វនរកមិនបៀតបៀនគ្នា ឆេះក្នុងទីរៀងៗខ្លួនប៉ុណ្ណោះក្នុងអវីចិនរកនេះឈ្មោះថា មិនមានចន្លោះនៃសត្វនរកយ៉ាងនេះ ។ តំណក់ទឹកឃ្មុំ ៦ តំណក់ ដាក់លើចុងអណ្ដាត រមែងជាអព្វោហារិក ព្រោះតំណក់ទឹកទន់ដែង តំណក់ទី ៧ មានកម្លាំងតាមដុតឆេះអស់យ៉ាងណា ឧបេក្ខា-អកុសលវិបាក ៦ ដ៏សេស រមែងជាអព្វោហារិក ព្រោះអកុសលវិបាកដែល

ជាទុក្ខវេទនា មានកម្លាំងតាមដុតអស់ក្នុងនរកនោះក៏យ៉ាងនោះ ។ ទុក្ខប៉ុណ្ណោះប្រាកដមិនមានចន្លោះ ។ ក្នុងនរកអវីចិនេះ ឈ្មោះថាមិនមានចន្លោះនៃទុក្ខយ៉ាងនេះ ។ ឈ្មោះថា **និរយោ** ព្រោះអត្ថថា ប្រាសចាកសេចក្តីត្រេកអរ ។

បទថា **តត្ថ សត្តា មហាលុទ្ទា** បានដល់ សត្វដែលកើតក្នុងនរកអវីចិនោះ មានកម្មគ្រោតគ្រាតច្រើន ។ បទថា **មហាកិព្វិសការិនោ** បានដល់ ធ្វើកម្មអាក្រក់ច្រើន ។ បទថា **អច្ចន្តបាបកម្មន្តា** បានដល់ មានបាបកម្មដោយចំណែកមួយ ។ បទថា **បច្ចន្តិ ន ច មិយ្យរេ** បានដល់ ឆេះក្នុងរវាងអណ្តាតភ្លើង តែមិនស្លាប់ ។ បទថា **ជាតវេទសមោ កាយោ** បានដល់ រាងកាយរបស់សត្វនរកទាំងនោះ ដូចគ្នានឹងភ្លើង ។ បទថា **តេសំ និរយវាសិនំ** បានដល់ សត្វដែលនៅក្នុងនរកទាំងនោះ ជាអ្នកមានបាបកម្ម ។ បទថា **បស្ស កម្មានំ ទឡ្ហត្តំ** បានដល់ ចូរមើលនូវភាពជាថាវរៈនៃបាបកម្ម ។ បទថា **ន ភស្មា ហោតិ នបិ មសិ** បានដល់ សូម្បីផេះក៏មិនមាន ធ្យូងក៏មិនមាន ។ បទថា **បុរត្ថិមេន** សេចក្តីថា ដរាបណាទ្វារមិនទាន់បិទ សត្វនរកក៏ស្ទុះទៅរកទ្វារនោះដរាបនោះ ។ ស្បែកជាដើមរបស់សត្វនរក ទាំងនោះតែងឆេះត្រង់ទ្វារនោះ កាលសត្វនរកទាំងនោះទៅដល់ជិតទ្វារ ទ្វារនោះក៏បិទ ទ្វារទិសខាងលិចក៏ប្រាកដដូចមិនបានបិទ ។ ក្នុងបទទាំងអស់ក៏មានន័យនេះឯង ។ បទថា **អភិ-និក្ខមិតាសា តេ** បានដល់ សត្វនរកទាំងនោះមានការទន្ទឹង ដើម្បីនឹងចេញអំពីនរកទើបឈ្មោះថា **និក្ខមិតាសា** ។ បទថា **មោក្ខគវេសិនោ** បានដល់ ស្វែងរក គឺស្វែងរកឧបាយចេញ ។ បទថា **ន តេ តតោ និក្ខមិតុំ លភន្តិ**

**កម្មបច្ចយា** បានដល់ សត្វទាំងនោះទៅមិនដល់ទ្វារចេញអំពីនរក ព្រោះបាបកម្មជាបច្ច័យ ។ បទថា **តេសញ្ច ទាបកម្មន្តំ អវិបក្កំ កតំ ពហុំ** បានដល់ កម្មលាមកគ្រោតគ្រាតដែលមិនទាន់ឲ្យផល មិនទាន់អស់ដែលសត្វទាំងនោះធ្វើហើយ សន្សំទុកហើយមានច្រើនប្រការ នៅមិនទាន់ឲ្យផល ។

[ ៩៣ ] បទថា **សំវេគំ** បានដល់ សេចក្តីតក់ស្លុត ។ បទថា **ឧព្វេគំ** បានដល់ ចេញចាកឋានដែលខ្លួនតាំងនៅ ។ បទថា **ឧត្រាសំ** បានដល់ ការលំបាកចិត្ត មិនសម្រេចចិត្ត ។ បទថា **ភយំ** បានដល់ ចិត្តតក់ស្លុត ។ បទថា **បីឡនំ** បានដល់ ការខ្ទាំងខ្ទប់ ។ បទថា **ឃដ្ដនំ** បានដល់ ការបៀតបៀន ។ បទថា **ឧបទ្ទវំ** បានដល់ ចង្រៃ ។ បទថា **ឧបសគ្គំ** បានដល់ ការរារាំង ។

[ ៩៥ ] ឥឡូវនេះព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ប្រការដែលព្រះអង្គទ្រង់សង្វេគមកហើយ ទើបត្រាស់ព្រះតម្រាស់ថា **ផន្ទមានំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ផន្ទមានំ** បានដល់ អន្ទះអន្ទែងដោយតណ្ហាជាដើម ។ បទថា **អប្បោទកេ** បានដល់ ក្នុងទីដែលមានទឹកតិច ។ បទថា **អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា** បានដល់ ឃើញសត្វផ្សេងៗប្រទូសរ៉ាយគ្នានឹងសត្វដទៃៗ ។ បទថា **មំ ភយមាវិសិ** បានដល់ ភ័យចូលមកដល់តថាគតហើយ ។

[ ៩៦ ] បទថា **កិលេសផន្ទនាយ ផន្ទមានំ** បានដល់ ញាប់ញ័រព្រោះ

ការញាប់ញ័រដោយកិលេសមានរាគៈជាដើម ។ បទថា **បយោគោ** បានដល់ កាយបយោគ វចីបយោគនិងមនោបយោគ ។

[ ៩៨ ] បទថា **វិរុទ្ធា** បានដល់ ទឹងក្រោធដល់គ្នានឹងគ្នា ។ បទថា **បដិវិរុទ្ធា** បានដល់ ប្រឈមមុខឈ្លោះគ្នាឬប្រទូស្តគ្នាយ៉ាងខ្លាំងក្លា ។ បទថា **អាហតា** បានដល់ ប្រហារគ្នាដោយសេចក្តីក្រោធ ។ បទថា **បច្ចាហតា** បានដល់ វាយតប់ប្រយុទ្ធគ្នា ។ បទថា **អាឃាតិតា** បានដល់ ការខ្ញាំងខ្ញប់ដល់គ្នានឹងគ្នា ។ បទថា **បច្ចាឃាតិតា** បានដល់ ការខ្ញាំងខ្ញប់ដល់គ្នានឹងគ្នា យ៉ាងខ្លាំងក្លា ។ បទថា **បាណីហិបិ ឧបក្កមន្តិ** បានដល់ ប្រទូស្តគ្នាដោយដៃខ្លះ ។

[ ១០០ ] បទថា **សមន្តមសារោ លោកោ** បានដល់ លោកទាំងអស់ ចាប់អំពីនរកជាដើមមកមិនមានខ្លឹមសារ គឺវៀរចាកនិច្ចសារជាដើម ។ បទថា **ទិសា សព្វា សមេរិតា** បានដល់ សង្ខារទាំងឡាយ ក្នុងទិសទាំងពួងញាប់ញ័រហើយ ព្រោះការមិនទៀង ។ បទថា **ឥច្ឆំ ភវនមត្តនោ** បានដល់ កាលប្រាថ្នាទីជ្រកកោនដើម្បីខ្លួន ។ បទថា **នាទ្ទសាសឹ អនោសិតំ** បានដល់ មិនបានឃើញទីណាមួយដែលមិនត្រូវគ្របសង្កត់ដោយជរាជាដើម ។

[ ១០១ ] បទថា **អសារោ** បានដល់ មិនជាខ្លឹមសារឬវៀរចាកខ្លឹមសារ ។ បទថា **និស្សារោ** បានដល់ វៀរចាកខ្លឹមសារ ដោយប្រការទាំងពួង ។ បទថា **សារាបគតោ** បានដល់ ប្រាសចាកខ្លឹមសារ ។ បទថា **និច្ចសារសារេន វា** បានដល់ ខ្លឹមសារដែលរាប់ថាជាខ្លឹមសាររហូតទៅ ។ សូម្បី ២ បទតទៅក៏មានន័យនេះដូចគ្នា ។

[ ១០២ ] បទថា **យេ បុរត្ថិមាយ ទិសាយ សង្ខារា** បានដល់ សង្ខារទាំងឡាយដែលរួមគ្នាធ្វើឡើង ដោយបច្ច័យក្នុងទិសខាងកើត ។ បទថា **តេបិ ឃរិតា** បានដល់ សង្ខារទាំងនោះក៏ញាប់ញ័រ ។ បទថា **សមេរិតា** បានដល់ ញាប់ញ័រក្រៃលែង ។ បទថា **ចលិតា** បានដល់ ទៅកាន់ការញាប់ញ័រ ។ បទថា **ឃដ្ដិតា** បានដល់ ត្រូវការកើត ការរលត់បៀតបៀន ។ បទថា **អនិច្ចតាយ** បានដល់ ព្រោះមានហើយត្រឡប់ជាមិនមាន ។ បទថា **ជាតិយា អនុគតា** បានដល់ ដែលការកើតចូលទៅជាប់តាម ។ បទថា **ជរាយ អនុសដា** បានដល់ ត្រូវបៀតបៀនព្រោះការចាស់ ។ បទថា **ព្យាធិនា អភិភូតា** បានដល់ ត្រូវព្យាធិដែលកើតឡើង ព្រោះការប្រែប្រួលនៃធាតុគ្របសង្កត់ ។ បទថា **មរណេន អព្ភាហតា** បានដល់ ត្រូវមរណៈអូសទាញកម្ចាត់ ។ បទថា **អតាណា** បានដល់ វៀរចាកការរក្សា ។ បទថា **អលេណា** បានដល់ វៀរចាកទីពួនសម្ងំ ។ បទថា **អសរណា** មានវិគ្គហៈថា ឈ្មោះថា **អសរណា** ព្រោះអត្ថថា ទីពឹងរបស់ពួកសត្វនោះមិនមាន ។ បទថា **អសរណីភូតា** បានដល់ ឈ្មោះថា **អសរណីភូតា** ព្រោះអត្ថថា មិនធ្វើកិច្ចដើម្បីជាទីពឹងឯង ។

[ ១០៣ ] បទថា **អត្ថនោ ភវនំ** ជាពាក្យលើកឡើង ដើម្បីពន្រើកសេចក្ដី ។ បទថា **តាណំ** បានដល់ ទីរក្សា ។ បទថា **លេណំ** បានដល់ ទីពួន ។ បទថា **សរណំ** បានដល់ ទីញ៉ាំងទុក្ខឲ្យវិនាសទៅ ។ បទថា **គតី** បានដល់ ទីអាស្រ័យ ។ បទថា **បរាយនំ** បានដល់ ទីពឹងខាងមុខ ឈ្មោះថា **បរាយនំ** ។

[ ១០៨ ] បទថា **អជ្ឈោសិតំយេវអទ្ទសំ** បានដល់ បានឃើញទីទាំងពួង ត្រូវជរាជាដើមញាំញី ។ បទថា **សត្តំ យោព្វញ្ញំ** បានដល់ ការនៃភាពជាកំលោះក្រមុំ ឈ្មោះថា **យោព្វញ្ញំ** ភាពជាកំលោះក្រមុំទាំងពួងរបស់សត្វដែលនៅមានចិត្ត ។ បទថា **ជរាយ ឱសិតំ** បានដល់ ត្រូវជរាគឺការចាស់ញាំញីគ្របសង្កត់ ។ ក្នុងបទទាំងពួងក៏មានន័យយ៉ាងនេះ ។

[ ១០៩ ] បទថា **ឱសានេត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ** បានដល់ បានឃើញនូវទីបំផុតដែលតាំងនៅមិនបាន ដែលវិនាសនូវភាពជាកំលោះក្រមុំជាដើម គឺបានឃើញសត្វទាំងឡាយដែលត្រូវទាស់ចិត្តដោយជរាជាដើម ដែលមានចិត្តត្រូវញាំញី ទើបតថាគតមានការមិនត្រេកអរ ។ បទថា **អថេត្ថ សល្លំ** បានដល់ សរមានរាគៈជាដើម ក្នុងសត្វទាំងឡាយនេះ ។ បទថា **ហទយស្សិតំ** បានដល់ អាស្រ័យចិត្ត ។

[ ១០៦ ] បទថា **យោព្វញ្ញំ ជរា ឋោសាបេតិ** បានដល់ ជរាឲ្យនៅមិនបាន ឲ្យវិនាសទៅ ។ ក្នុងបទទាំងពួង ក៏មានន័យយ៉ាងនេះ ។

[ ១១០ ] បើសួរថា ព្រួញមានអានុភាពដូចម្តេច គប្បីជ្រាបតាមគាថាថា **យេន សល្លេន ឱតិណ្ណោ** ដូច្នេះជាដើម ។

បទថា **ទិសា សព្វា វិធាវតិ** បានដល់ សត្វរមែងស្ទុះទៅកាន់ទិសដែលជាទុច្ចរិតខ្លះ ទិសមានទិសខាងកើតជាដើមខ្លះ ទិសដែលជាគតិខ្លះ ។ បទថា **តមេវ សល្លំ អព្វុយ្ហ ន ធាវតិ ន សីទតិ** បានដល់ ព្រោះដកនូវព្រួញនោះចោល រមែងមិនស្ទុះទៅកាន់ទិសនោះនិងមិនលិចចុះក្នុងឱឃៈ ៤ ។

[ ១១១ ] គប្បីជ្រាបសេចក្ដីក្នុងបទថា **អញ្ញាណំ** ជាដើម ដូចតទៅថា ឈ្មោះថា **អនស្សទ្ធំ** ព្រោះជាបដិបក្ខចំពោះ **ឧស្សទ្ធំ** ។ ឈ្មោះថា **អនភិ-សមយោ** ព្រោះអត្ថថា ជាអ្នកបែរមុខទៅមិនចូលដល់ មិនប្រកបក្នុងធម៌ ។ ឈ្មោះថា **អនុពោធោ** ព្រោះអត្ថថា ដឹងធម៌តាមដែលមានពិត ។ ឈ្មោះថា **អននុពោធោ** ព្រោះផ្ទុយគ្នានឹង **នុពោធោ** នោះ ។ ឈ្មោះថា **អសម្ពោធោ** ព្រោះអត្ថថា មិនត្រាស់ដឹងប្រកបដោយព្រះត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ។ ឈ្មោះថា **អសម្ពោធោ** ព្រោះអត្ថថា ដឹងនូវការមិនស្ងប់និងការមិនសមគួរក៏មាន ។ ឈ្មោះថា **អប្បដិវេធោ** ព្រោះអត្ថថា មិនចាក់ធ្លុះអរិយសច្ច ៤ ។ ឈ្មោះថា **អសង្គាហណា** ព្រោះអត្ថថា មិនកាន់យកធម៌ឯណានីមួយក្នុងរូបជាដើម ដោយភាពជាសាមញ្ញលក្ខណៈ មានការមិនទៀងជាដើម ។ ឈ្មោះថា **អបរិយោគាហណា** ព្រោះអត្ថថា មិនឈមចុះកាន់ធម៌នោះ នោះឯង ។ ឈ្មោះថា **អសមបេក្ខណា** ព្រោះអត្ថថា មិនសម្លឹងដោយស្មើ ។ ឈ្មោះថា **អបច្ចវេក្ខណា** ព្រោះអត្ថថា មិនពិចារណាចំពោះនូវសភាវៈ របស់ធម៌ទាំងឡាយ ។ ឈ្មោះថា **អបច្ចក្ខកម្មំ** ព្រោះអត្ថថា មិនមានកម្ម សូម្បីតែមួយដែលប្រចក្សដល់សភាវនោះ ព្រោះប្រព្រឹត្តវិបរិតក្នុងកុសលកម្មនិងអកុសល-កម្ម ឬព្រោះមិនមានការកាន់យកតាមសេចក្ដីពិត ឬអត្ថថា មិនមានការធ្វើកម្មណាមួយឲ្យប្រចក្សឯង ។ ឈ្មោះថា **ទុម្មេជ្ឈំ** ព្រោះអត្ថថា កាលមោហៈមិនទាន់កើតឡើង ចិត្តសន្តានណាគប្បីជាសភាវៈផូរផង់ ស្អាតបរិសុទ្ធិ ចិត្តសន្តានដែលជាសេចក្ដីផូរផង់នោះ ត្រូវមោហៈនេះប្រទូស្ត ។ ភាពជាពាល ឈ្មោះថា

**ពាល្យំ** ។ ឈ្មោះថា **មោហោ** ព្រោះអត្ថថា វង្វេង ។ ការវង្វេងមានកម្លាំងខ្លាំងឡើង ឈ្មោះថា **បមោហោ** ។ ឈ្មោះថា **សម្មោហោ** ព្រោះអត្ថថា វង្វេងដោយជុំវិញ ។ ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា មិនដឹងព្រោះជាបដិបក្ខចំពោះវិជ្ជា ។ បទថា **ឱឃ** និង **យោគ** ទាំង ២ នេះ មានសេចក្តីបានពោលទុកហើយ ។ ឈ្មោះថា **អនុសយោ** ព្រោះអត្ថថា ដេកត្រាំ ដោយការមានកម្លាំង ។ ឈ្មោះថា **បរិយុដ្ឋានំ** ព្រោះអត្ថថា លិចលង់ គ្របសង្កត់ចិត្ត ។ ឈ្មោះថា **លង្គី** ព្រោះអត្ថថា មិនអាចបែរមុខទៅកាន់ប្រយោជន៍បាន ព្រោះមិនមានការកាន់យកនូវប្រយោជន៍ រមែងជាប់ស្អិតដោយពិត អធិប្បាយថា រមែងទៅលំបាក ។ ម្យ៉ាងទៀត ឈ្មោះថា **លង្គី** ព្រោះកម្ចាត់បានលំបាក ។ មោហៈនេះឈ្មោះថា **លង្គី** ព្រោះដូចគន្លឹះ ពោលគឺទុកជាំដែលដកចេញបានលំបាក ។ បទដ៏សេសមានអត្ថងាយយល់ហើយ ។

គប្បីជ្រាបសេចក្តីក្នុងបទថា **យា ឯវរូបា កង្ខា** ជាដើមដូចតទៅនេះថា ឈ្មោះថា **កង្ខា** ដោយអំណាចនៃការសង្ស័យ ។ ឈ្មោះថា **កង្ខាយនា** ព្រោះអត្ថថា ដើរទៅកាន់ការសង្ស័យ ។ សេចក្តីសង្ស័យក្រៃលែងជាងសេចក្តីសង្ស័យក្នុងកាលមុន ឈ្មោះថា **កង្ខាយនា** ។ ម្យ៉ាងទៀតលោកពោលបទនេះ ដោយអំណាចនៃអាការៈ ។ ចិត្តដែលពោរពេញ ដោយសេចក្តីសង្ស័យ ឈ្មោះថា **កង្ខាយិតំ** ព្រោះទាក់ទង ដោយការសង្ស័យ ។ ភាពនៃសេចក្តីសង្ស័យនោះ ឈ្មោះថា **កង្ខាយិតត្តំ** ។ ការមិនមាន ការឃើញ ឈ្មោះថា **វិមតិ** ។ បទថា **វិចិកិច្ឆា** សេចក្តីថា ប្រាសចាកការពិចារណា ។ ម្យ៉ាងទៀត

*ឈ្មោះថា* **វិចិកិច្ឆា** *ព្រោះអត្ថថា ជាហេតុពិចារណាសភាវធម៌ បានដោយលំបាក ។ វិចិកិច្ឆានោះមានការសង្ស័យជាលក្ខណៈ មានការញាប់ញ័រជាកិច្ច មានការសម្រេចចិត្តមិនបានជាអាការប្រាកដ ឬមានការកាន់យកច្រើនចំណែកជាអាការប្រាកដ មានអយោនិសោមនសិការៈជាហេតុជិត ។ គប្បីឃើញថាការស្ងប់សង្ស័យ ជាធម៌ធ្វើអន្តរាយដល់ការបដិបត្តិ ។*

*បទថា* **ទ្វេឡ្ហកំ** *ព្រោះអត្ថថា ឈមទៅ ២ ចំណែក ដោយការញាប់ញ័រ ។ ឈ្មោះថា* **ទ្វេធាបថោ** *ព្រោះអត្ថថា ដូចផ្លូវបែកជា ២ ដោយហាមការបដិបត្តិ ។ ឈ្មោះថា* **សំសយោ** *ព្រោះអត្ថថា ជឿគ្រប់យ៉ាង ព្រោះមិនអាចតាំងនៅបានក្នុងអាការៈមួយ ដោយការប្រព្រឹត្តទៅថា នេះទៀង ឬមិនទៀង ដូច្នេះជាដើម ។ ឈ្មោះថា* **អនេកំសគ្គាហោ** *ព្រោះអត្ថថា មិនសម្រេចចិត្តដោយមិនអាចកាន់យកចំណែកមួយបាន ។ ឈ្មោះថា* **អាសប្បនា** *ព្រោះអត្ថថា មិនអាចសម្រេចចិត្ត ទើបថយចាកអារម្មណ៍ ។ ឈ្មោះថា* **បរិសប្បនា** *ព្រោះអត្ថថា មិនអាចឈានចុះ ទើបរារែកដោយជុំវិញ ។ ឈ្មោះថា* **អបរិយោគាហណា** *ព្រោះអត្ថថា មិនអាចកំណត់យកបាន ។ ឈ្មោះថា* **ថម្ភិតត្តំ ចិត្តស្ស** *ព្រោះអត្ថថា មិនអាចប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយការប្រាកដក្នុងចិត្តបាន អធិប្បាយថា ភាពដែលចិត្តរឹងត្អឹង ។ ពិតហើយសេចក្តីសង្ស័យកើតឡើងហើយ រមែងធ្វើឲ្យចិត្តរឹងត្អឹង ។ម្យ៉ាងទៀត ព្រោះសេចក្តីសង្ស័យនោះកាលកើតឡើងទាញយកអារម្មណ៍ទុក ហាក់ដូចជាគូសទុកក្នុងចិត្ត ហេតុនោះទើបពោលថា* **មនោវិលេខោ** *គឺការសាំញាំនៃចិត្ត ។*

[ ១១២ ] បទថា **រិត្តោ** បានដល់ ត្រូវបាញ់ដោយព្រួញ ។ បទថា **ផុដ្ឋោ** បានដល់ ប៉ះពាល់ ។ បទថា **បរេតោ** បានដល់ គ្របសង្កត់ ។ បទថា **ធាវតិ** បានដល់ ស្ទុះទៅខាងមុខ ។ បទថា **វិធាវតិ** បានដល់ ទៅដោយវិធីផ្សេងៗ ។ បទថា **សន្ធាវតិ** បានដល់ ស្ទុះទៅដោយកម្លាំង ។ បទថា **សំសរតិ** បានដល់ ត្រាច់ទៅក្នុងទីផ្សេងៗ ។ បទថា **អចេលកោ** បានដល់ អ្នកមិនស្លៀកសំពត់ ។ បទថា **មុត្តាចារោ** បានដល់ លះបង់អាចារៈ មិនប្រព្រឹត្តតាមកុលបុត្តក្នុងលោកក្នុងការបន្ទោបង់ឧច្ចារៈជាដើម ឈរបន្ទោបង់ឧច្ចារបស្សាវៈ ឈរទំពាអាហារ ។ បទថា **ហត្ថាបលេខនោ** បានដល់ កាលដុំបាយក្នុងដៃអស់ ក៏លិឍដៃ ឬបន្ទោបង់ឧច្ចារៈហើយកាន់យកថាដៃជាឈើជម្រះ ក៏យកដៃជូត ។ បានឮថា ពួកអចេលក៏ទាំងនោះ បញ្ញត្តឈើជម្រះថាជាសត្វ ។ ឈ្មោះថា **ន ឯហិភទន្តិកោ** ព្រោះអត្ថថា កាលគេពោលថា សូមមកទទួលអាហារចុះ ក៏មិនមក ។ ឈ្មោះថា **ន តិដ្ឋភទន្តិកោ** ព្រោះអត្ថថា កាលគេពោលថា បើដូច្នោះសូមឈប់សិន ក៏មិនឈប់ ។ បានឮថា បុគ្គលត្រូវសរតីទិដ្ឋិចាក់ដោតនោះមិនធ្វើទាំង ២ យ៉ាង ដោយគិតថានឹងជាការធ្វើតាមពាក្យ របស់បុគ្គលដទៃ ។

បទថា **អភិហដំ** បានដល់ មិនទទួលភិក្ខាដែលគេបែងទុកមុន ហើយទើបនាំមកឲ្យ ។ បទថា **ឧទ្ទិស្ស កតំ** បានដល់ ភិក្ខាដែលប្រាប់យ៉ាងនេះថា អាហារនេះធ្វើចំពោះលោក ។ បទថា **ន និមន្តនំ** បានដល់ មិនត្រេកអរ មិនទទួលភិក្ខាដែលគេនិមន្តយ៉ាងនេះថា និមន្តចូលទៅកាន់ត្រកូល វិថីឬស្រុកនោះចុះ ។

*បទថា* **ន កុម្ភិមុខា** *បានដល់ មិនទទួលភិក្ខាដែលគេដួសអំពីឆ្នាំងឲ្យ ។ បទថា* **ន កឡោបិមុខា** *សេចក្តីថា ឆ្នាំងបាយឬកញ្ជ្រែង ឈ្មោះថា* **កឡោបិ** *រមែងមិនទទួលភិក្ខាអំពីឆ្នាំងបាយនោះ ព្រោះហេតុអ្វី ព្រោះគិតថាឆ្នាំងបាយទាំងឡាយ រមែងបាននូវការប៉ះខ្ទប់ដោយវែក ព្រោះអាស្រ័យអញ ។ បទថា* **ន ឯឡកមន្តរំ** *បានដល់ មិនទទួលភិក្ខាដែលបុគ្គលឈរកន្លងធរណីទ្វារឲ្យ ព្រោះហេតុអ្វី ព្រោះគិតថា ធរណីទ្វារនេះព្រោះអាស្រ័យអញ ទើបត្រូវឈរកន្លង ។ ក្នុងការឈរចន្លោះកំណាត់ឈើនិងអង្រែជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា* **ទ្វិន្នំ** *បានដល់ មិនទទួលភិក្ខា កាលមនុស្ស ២ នាក់កំពុងបរិភោគអាហារ មនុស្សម្នាក់ក្រោកឡើងមកប្រគេន ព្រោះហេតុអ្វី ព្រោះគិតថា រំខានដល់ការបរិភោគអាហារ ។ម្យ៉ាងទៀតគប្បីជ្រាបសេចក្តីក្នុងបទជាដើមថា* **ន គព្ភិនិយា** *ដូចតទៅនេះថា រមែងមិនទទួល ដោយគិតថា ទារកក្នុងផ្ទៃរបស់ស្រីមានគភ៌រមែងលំបាក ។ កាលទារកកំពុងបៅដោះនឹងរំខានដល់ការបៅដោះបាន ។ នឹងរំខានដល់ការត្រេកអររបស់ស្ត្រីដែលនៅជាមួយបុរស ។ បទថា* **ន សំកិត្តីសុ** *បានដល់ មិនទទួលភិក្ខាដែលគេរៃអង្គាសគ្នា ហើយធ្វើទុក ។ បានឮថា ក្នុងសម័យទុរ្ភិក្ស ពួកសាវករបស់អចេលក៍ ក៏បបួលគ្នានាំអង្ករជាដើមមកដាំបាយ ដើម្បីជាប្រយោជន៍ដល់ពួកអចេលក៍ ។ អចេលក៍ដែលឧក្រិដ្ឋ មិនទទួលអាហារអំពីទីនោះ ។ បទថា* **ន យត្ថ សា** *បានដល់មិនទទួលភិក្ខាដែលគេមិនឲ្យដល់សុនខ ក្នុងទីដែលសុនខរង់ចាំ ដោយគិតថាអញនឹងបានដុំបាយហើយនាំមកឲ្យ ព្រោះហេតុអ្វី ព្រោះអន្តរាយដល់ដុំបាយ*

របស់សុនខនោះ ។

បទថា **សណ្ឌសណ្ឌចារិនី** បានដល់ ដែលមានរុយកំពុងរោមជាក្រុមៗ ព្រោះបើមនុស្សទាំងឡាយ ឃើញអចេលក៍ហើយគិតថា អញនឹងឲ្យភិក្ខាដល់អចេលក៍នេះ ទើបចូលទៅកាន់ផ្ទះបាយ កាលមនុស្សចូលទៅរុយដែលទុំលើមាត់ឆ្នាំងបាយជាដើម ក៏នឹងស្ទុះហើរជាក្រុមៗ គេចទៅ ទើបមិនទទួលភិក្ខាដែលនាំមកអំពីទីដែលមានរុយរោមនោះ ព្រោះហេតុអ្វី ព្រោះអចេលក៍គិតថា អាស្រ័យអញ ទើបអន្តរាយដល់អាហាររបស់រុយទាំងឡាយ ។ បទថា **ថុសោទកំ** បានដល់ ថ្នាំត្រាំធ្វើដោយគ្រឿងផ្សំ គឺស្រាវគ្រប់ប្រភេទ ។ បណ្ដាវត្ថុទាំងនេះ ការផឹកសុរាប៉ុណ្ណោះមានទោស តែអចេលក៍នេះមានការសម្គាល់ក្នុងវត្ថុគ្រប់ប្រភេទថា មានទោស ។ បទថា **ឯកាគារិកោ** បានដល់ បានភិក្ខាក្នុងផ្ទះមួយខ្នងប៉ុណ្ណោះ ក៏ត្រឡប់ ។ បទថា **ឯកាលោបិកោ** បានដល់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយបាយមួយពំនូតប៉ុណ្ណោះ ។ សូម្បីក្នុងបទថា **ទ្វាគារិកោ** ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **ឯកិស្សាបិ ទត្តិយា** បានដល់ ក្នុងភាជន៍មួយ ។ ភាជន៍តូចៗប្រើដាក់ភិក្ខាមានរសដ៏ប្រសើរ ឈ្មោះថា **ទត្តិ** ។ បទថា **ឯកាហិកំ** បានដល់ រំលងមួយថ្ងៃ ។ បទថា **អឌ្ឍមាសិកំ** បានដល់ រំលងកន្លះខែខ្លះ ។ បទថា **បរិយាយភត្តភោជនំ** បានដល់ បរិភោគអាហារដែលវិលមកដល់តាមវារៈ ។ បរិភោគអាហារដែលមកដល់តាមវារៈយ៉ាងនេះ គឺរំលង ១ ថ្ងៃខ្លះ ២ ថ្ងៃខ្លះ ៧ ថ្ងៃខ្លះ កន្លះខែខ្លះ ។ បទថា **សាកភក្ខា** ជាដើម មានន័យដូចបានពោលហើយនោះឯង ។

បទថា **ឧព្ភដ្ឋកោ** បានដល់ ឈរត្រង់ ។ បទថា **ឧក្កុដិកប្បធានមនុយុត្តោ** បានដល់ ព្យាយាមអង្គុយច្រហោង កាលដើរក៏ដើរច្រហោង លោតទៅ ។ បទថា **កណ្ដកាបស្សយិកោ** បានដល់ ដោតបន្លាដែកឬបន្លាធម្មជាតិលើកផែនដី ក្រាលកម្រាលស្បែកលើនោះ ធ្វើនៅការឈរនិងការចង្ក្រមជាដើម ។ បទថា **សេយ្យំ** សូម្បីដេកក៏សម្រេចការដេកលើបន្លានោះឯង ។ បទថា **ផលកសេយ្យំ** បានដល់ ដេកលើបន្ទះក្ដារ ។ បទថា **ថណ្ឌិលសេយ្យំ** បានដល់ ដេកលើទួលខ្ពស់ ។ បទថា **ឯកបស្សយិកោ** បានដល់ ដេកផ្អៀងម្ខាងប៉ុណ្ណោះ ។ បទថា **រជោជល្លធរោ** បានដល់ យកខ្លាញ់លាបរាងកាយហើយឈរក្នុងទីដែលហុយទៅដោយធូលី បន្ទាប់អំពីនោះធូលី រមែងជាប់រាងកាយរបស់អចេលក៍នោះ អចេលក៍នោះរមែងទ្រទ្រង់នូវធូលីនោះទុក ។ បទថា **យថាសន្ថតិកោ** បានដល់ ពេញចិត្តក្នុងអាសនៈដែលបាន ហើយអង្គុយលើអាសនៈដែលបាននោះជាប្រក្រតី ។ ក្នុងបទថា **វេកដិកោ** ឧច្ចារៈ ហៅថា **វិកដំ** បរិភោគឧច្ចារៈនោះ ។ បទថា **អបានកោ** បានដល់ មិនផឹកទឹកត្រជាក់ ។ ឈ្មោះថា **សាយតតិយកំ** ព្រោះអត្ថថា មានពេលល្ងាចជាគម្រប់ ៣ គឺរមែងប្រកបការខ្វល់ខ្វាយ ក្នុងការចុះងូតទឹក ដោយតាំងចិត្តថាអញនឹងបន្សាត់បាបមួយថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់និងល្ងាច ។

បទថា **តេ សត្តេ អភិសង្ខរោតិ** បានដល់ ញុំាងព្រួញ ៧ មានរាគៈជាដើមនោះឲ្យកើត ។ បទថា **អភិសង្ខរោន្តោ** បានដល់ កាលឲ្យកើត ។ បទថា **សល្លាភិសង្ខារវសេន** បានដល់ ព្រោះហេតុឲ្យកូនសរកើតឡើង ។

បទថា **បុរត្ថិមំ ទិសំ ធាវតិ** បានដល់ ស្ទុះទៅកាន់ទិសខាងកើត ។ បទថា **តេ សល្លាភិសង្ខារានំ អប្បហីនា** បានដល់ លះនូវការប្រកបកូនសរ មានរាគៈជាដើមនោះមិនបាន ។ បទថា **សល្លាភិសង្ខារានំ អប្បហីនត្តា** បានដល់ ព្រោះលះការប្រកបនូវកូនសរមិនបាន ។ បទថា **គតិយា ធាវតិ** បានដល់ ស្ទុះទៅក្នុងគតិ ។ បទថា **គតិយា គតឹ** បានដល់ ចេញអំពីគតិទៅកាន់គតិ ។

[ ១១៣ ] បទថា **ន សីទតិ** បានដល់ មិនលិចចុះ ។ បទថា **ន សំសីទតិ** បានដល់ មិនលិចចុះដោយជុំវិញ ។ បទថា **ន ឱសីទតិ** បានដល់ មិនសំយុងចុះ ។ បទថា **ន អវសីទតិ** បានដល់ មិនធ្លាក់ចុះ ។ បទថា **ន អវគច្ឆតិ** បានដល់ មិនធ្លាក់ទៅក្រោម ។

[ ១១៤ ] កាលសត្វទាំងឡាយត្រូវព្រួញ មានអានុភាពជំមុតហើយយ៉ាងនេះ គប្បីជ្រាបគាថានេះថា **តត្ថ សិក្ខានុគយន្តិ យានិ លោកេ គធិតានិ** ដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយដូច្នេះថា ជនទាំងឡាយរមែងពោលដល់ ឬរមែងរៀននូវនិមិត្តនោះ គឺសិក្សាមិនមែនតិច មានសិប្បដំរីជាដើម ដែលជានិមិត្តក្នុងកាមគុណដែលលោកពោលថា ជាទីពាក់ព័ន្ធព្រោះធ្វើវិគ្គហៈថា ជនទាំងឡាយ រមែងពាក់ព័ន្ធដោយកាមគុណ ៥ ក្នុងលោក ឬព្រោះពាក់ព័ន្ធក្នុងកាលយូរ អ្នកទាំងឡាយចូរមើលចុះ សត្វលោកនេះជាអ្នកខ្វល់ខ្វាយដរាបណា កុលបុត្តជាបណ្ឌិតមិនគប្បីបង្អោនទៅក្នុងការពាក់ព័ន្ធទាំងនោះ ឬក្នុងការសិក្សាទាំងនោះក្នុងកាលណាដឹងច្បាស់នូវកាមទាំងឡាយ ដោយ

ប្រការទាំងពួងហើយ ដោយការឃើញដោយភាពជារបស់មិនទៀង ជាដើម ដោយពិត គប្បីសិក្សានូវការរំលត់របស់ខ្លួនប៉ុណ្ណោះ ។

[ ១១៧ ] បទថា **បដិវិជ្ឈត្វា** បានដល់ ចេញឬចាក់ធ្លុះដោយញាណ ។

[ ១១៩ ] ឥឡូវនេះព្រះមានព្រះភាគ កាលទ្រង់សម្ដែងដល់វត្ថុដែលគួរសិក្សា ដើម្បីការរំលត់ ទើបត្រាស់ពាក្យថា **សច្ចោ សិយា** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សច្ចោ** បានដល់ ប្រកបដោយវាចាសច្ច ញាណសច្ចនិងមគ្គសច្ច ។ បទថា **រិត្តបេសុណោ** បានដល់ លះនូវពាក្យញុះញង់ ។ បទថា **វេវិច្ឆំ** បានដល់ សេចក្ដីកំណាញ់ ។

[ ១២៣ ] បទថា **និទ្ទំ តន្ទឹ សហេ ថីនំ** បានដល់ គប្បីគ្របសង្កត់ធម៌ ៣ យ៉ាងនេះ គឺការងោកងុយ ១ ការខ្ជិលច្រអូសផ្លូវកាយ ១ ការខ្ជិលច្រអូសផ្លូវចិត្ត ១ ។ បទថា **និព្វានមានសោ** បានដល់ ជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ។

[ ១២៤ ] បទថា **កាយស្ស អកល្យតា** បានដល់ ការដែលទាមកាយគឺខន្ធ ៣ អាពាធ ។ អាពាធលោកហៅថា **អកល្លកោ** ។ ក្នុងវិន័យលោកក៏ពោលទុកថា **នាហំ ភន្តេ អកល្លកោ** បពិត្រលោកម្ចាស់ ខ្ញុំមិនឈឺទេ ។ បទថា **អកម្មញ្ញតា** បានដល់ អាការមិនគួរដល់ការងារ ពោលគឺភាពដែលកាយឈឺថ្កាត់ ។ ឈ្មោះថា **ឱនាហោ** ព្រោះអត្ថថា លំបាកកាយ ដូចពពកគ្របអាកាសដូច្នោះ ។ អាការដែលគ្របគ្រប់ចំណែកឈ្មោះថា **បរិយោនាហោ** ។ ឈ្មោះថា **អន្តោសមោរោធោ** ព្រោះអត្ថថា ងងុយស្រឡេតខាងក្នុង ។ ឈ្មោះ

ថា **មិទ្ធំ** ព្រោះអត្ថថា កម្ចាត់ អធិប្បាយថា បៀតបៀន ព្រោះមិនគួរដល់ការងារ ។ ឈ្មោះថា **សុប្បំ** ព្រោះអត្ថថា ជាហេតុលក់ ។ ឈ្មោះថា **ចបលាយិកា** ព្រោះអត្ថថា ធ្វើឲ្យត្របកភ្នែកញ័រជាដើម ។ បទថា **សុបនា សុបិតត្តំ** បានដល់ ជាពាក្យសម្តែងសភាវាការ ។ បទថា **ឱលីយនា** បានដល់ អាការដែលរួញរា ។ បទទី ២ បន្ថែមនូវឧបសគ្គ ។ បទថា **លីនំ** បានដល់ រួញត្រឡប់ដោយការមិនលាចេញទៅ ។ ២ បទទៀតក្រៅអំពីនេះសម្តែងដល់សភាវនិងអាការ ។ បទថា **ឋិនំ** បានដល់ តាំងនៅជាដុំព្រោះមិនផ្សាយចេញទៅដូចដុំសប្បិ ។ បទថា **ឋិយនា** ជាពាក្យសម្តែងអាការ ។ ការដែលរួញរាឈ្មោះថា **ឋិយិតត្តំ** អធិប្បាយថា ត្រូវចងទុកដោយអំណាចមិនផ្សាយចេញទៅ ។

[ ១២៧ ] បទថា **សព្វសង្ខារធាតុយា** បានដល់ ដែលមានចិត្តបង្អោនទៅក្នុងនិព្វាន ញ៉ាំងចិត្តឲ្យត្រឡប់ចាកសង្ខារធាតុដែលប្រព្រឹត្តទៅក្នុងភូមិទាំងឡាយ ៣ ។ បទថា **ចិត្តំ បដិវាបេត្វា** បានដល់ ញ៉ាំងចិត្តឲ្យវិលត្រឡប់ ។ បទថា **ឯតំ សន្តំ** បានដល់ និព្វាននេះឈ្មោះថាស្ងប់ព្រោះស្ងប់ចាកកិលេស ។ ឈ្មោះថា **បណីតំ** ព្រោះអត្ថថា មិនក្តៅក្រហាយ ។

បទថា **ឧបធិសុខស្ស ហេតុ** សេចក្តីថា បណ្ឌិតទាំងឡាយ មិនឲ្យទានព្រោះហេតុនៃកាមសុខដែលជារបស់មិនល្អ ។ បទថា **កាមញ្ច តេ ឧបធិបរិក្ខយាយ** បានដល់ បណ្ឌិតទាំងនោះឲ្យទានដើម្បីការអស់ទៅនៃកាម ដើម្បីការអស់កាមតែម្យ៉ាង ។ បទថា **អបុនព្ភវាយ** បានដល់ ដើម្បីនិព្វាន ។ បទ

*ថា* **ឈានានិ ភាវេន្តិ** *បានដល់ ញ៉ាំងបឋមជ្ឈានជាដើមឲ្យចម្រើន ។ បទថា* **បុនព្ភវាយ** *បានដល់ ព្រោះហេតុនៃភពថ្មី ។ បណ្ឌិតទាំងនោះ ជាអ្នកប្រាថ្នាចំពោះនិព្វានទើបឲ្យទាន ។*

*[ ១២៨ ] បទថា* **សាហសា** *បានដល់ ព្រោះហេតុរួសរាន់ មានការប្រព្រឹត្តត្រេកអរជាដើម របស់អ្នកមានតម្រេក ។*

*[ ១៣៣ ] បទថា* **បុរាណំ នាភិនន្ទេយ្យ** *បានដល់ មិនគប្បីពេញចិត្តក្នុងរូបជាដើម ក្នុងអតីត ។ បទថា* **នវេ** *បានដល់ ក្នុងបច្ចុប្បន្ន ។ បទថា* **ហីយមានេ** *បានដល់ វិនាស ។ បទថា* **អាកាសំ ន សិតោ សិយា** *បានដល់ មិនគប្បីជាអ្នកអាស្រ័យតណ្ហា ។ ពិតហើយ តណ្ហា លោកហៅថា* **អាកាសោ** *ព្រោះទាក់ទងដោយរូបជាដើម ។*

*[ ១៣៦ ] បទថា* **វេមានេ** *បានដល់ មិនរស់នៅ ។ បទថា* **វិគច្ឆមានេ** *បានដល់ ប្រាសទៅ ។*

*[ ១៣៧ ] មានបាឋៈ ២ យ៉ាង គឺ* **អាកាសតិ អាកស្សតិ** *។*

*[ ១៣៨ ] បើសួរថាព្រោះហេតុអ្វីទើបមិនជាបុគ្គលអាស្រ័យកិលេសដែលជាគ្រឿងជាប់ចំពាក់ គប្បីជ្រាបគាថានេះថា* **គេធំ ព្រូមិ** *ដូច្នេះ ជាដើម ។*

*គប្បីជ្រាបអត្ថនៃគាថានោះដូចតទៅនេះថា ព្រោះតថាគតពោលតណ្ហា គឺការជាប់ចំពាក់នេះថាជាការជាប់ចិត្ត ព្រោះជាប់ចិត្តក្នុងរូបជាដើម អធិប្បាយថា តថាគតហៅថា ការជាប់ចិត្ត ។ សួរថា មានអ្វីក្រៃលែងជាងនេះទៀត ឆ្លើយថា តថាគតពោលតណ្ហាថាជាអន្លង់ធំ ព្រោះអត្ថថា លិចលង់ ពោល*

ថាជាអាចម ព្រោះអត្ថថា លេបត្របាក់ ពោលថាជាបំណង ព្រោះវង្វេងចាំខ្សែប ថានេះរបស់អញ ពោលថាជាអារម្មណ៍ ព្រោះអត្ថថា លែងបានលំបាកនិង ពោលថាជាគ្រឿងញាប់ញ័រ ព្រោះអត្ថថា ធ្វើនូវការញាប់ញ័រនិងពោលថាកាម ជាភក់ ជាសភាវៈកន្ទងបានលំបាក ព្រោះអត្ថថា ជាកង្វល់នៃលោកនិងព្រោះ អត្ថថា ឆ្លងផុតបានដោយក្រ ។

[ ១៤០ ] បទថា **អាចមំ** ឈ្មោះថា **អាចម** ព្រោះអត្ថថា លេបត្របាក់ គឺមកតាំងអំពីបដិសន្ធិ ។ បទនេះជាឈ្មោះនៃតណ្ហាដែលឲ្យបដិសន្ធិក្នុងភពថ្មី ដែលមានវដ្តៈជាមូល ។ បទថា **ជប្បនំ** នេះ ជាឈ្មោះរបស់តណ្ហាដែលជា ការប្រាថ្នា ។

[ ១៤១ ] បទថា **អារម្មណាម្បិ វុច្ចតិ តណ្ហា** បានដល់ តណ្ហាដែល កើតឡើងក្នុងអារម្មណ៍មានរូបជាដើម លោកពោលថាជាអារម្មណ៍ ព្រោះមិន អាចលែងទៅបាន ។

[ ១៤២ ] បទថា **កាមបង្កោ** បានដល់ ឈ្មោះថា **បង្កោ** ព្រោះអត្ថថា លិចចុះ ។ បទថា **កទ្ទមោ** សេចក្តីថា ឈ្មោះថា **កទ្ទមោ** ព្រោះអត្ថថា ជាប់ នៅ ។ ឈ្មោះថា **កិលេសោ** ព្រោះអត្ថថា ដុតកោល ។ ឈ្មោះថា **បលិបោ** ព្រោះអត្ថថា ឲ្យជាប់ស្អិតដូចជ័រស្អិត ។ ឈ្មោះថា **បលិពោធោ** ព្រោះអត្ថថា រាំងហើយទ្រទ្រង់ទុក នរជនមិនបានអាស្រ័យកិលេស ជាគ្រឿងជាប់ចំពាក់ ដែលសម្តែងដោយការជាប់ចិត្តជាដើមនេះ ដោយប្រការដូច្នេះ ។

[ ១៤៣ ] គប្បីជ្រាបគាថានេះថា **សច្ចា អវោក្កម្មំ** ជាដើមដូចតទៅនេះ

ថា គាថានោះមានសេចក្តីដូច្នេះថា បុគ្គលដល់នូវការរាប់ថាជា **មុនិ** ព្រោះបដិបត្តិដើម្បីភាពជាមុនី មិនឈានកន្លងនូវសច្ចៈ ៣ យ៉ាង ដែលពោលទុកហើយ ក្នុងកាលមុន ឈ្មោះថា **ព្រាហ្មណោ** ព្រោះតាំងនៅលើគោក គឺព្រះនិព្វាន ។ បុគ្គលនោះឯងតថាគតពោលថា ជាអ្នកស្ងប់ ព្រោះលះបង់បាននូវអាយតនៈទាំងពួង ។ ក្នុងនិទ្ទេស មិនមានពាក្យដែលគួរពោល ។ មានអ្វីក្រៃលែងជាងនេះទៀតដូច្នេះ ។

[ ១៤៨ ] គប្បីជ្រាបគាថាជាដើមថា **ស វេ វិទ្វា** ដូចតទៅនេះថា

ក្នុងបទទាំងនោះ បទថា **ញត្វា ធម្មំ** បានដល់ ដឹងនូវសង្ខតធម៌ ដោយន័យថាមិនទៀងជាដើម ។ បទថា **សម្មា សោ លោកេ ឥរិយានោ** បានដល់ បុគ្គលនោះនៅក្នុងលោកដោយប្រពៃ ព្រោះលះកិលេសធ្វើឲ្យនៅដោយមិនប្រពៃ ។

[ ១៥៣ ] កាលរស់នៅយ៉ាងនេះ គប្បីជ្រាបគាថាថា **យោធ កាមេ** ជាដើមដូចតទៅនេះថា ក្នុងបទទាំងនោះ បទថា **សង្គំ** បានដល់ បុគ្គលណាឆ្លងផុតនូវគ្រឿងជាប់ចំពាក់ ៧ យ៉ាងបាន ។ បទថា **នាជ្ឈេតិ** បានដល់ មិនសម្ងំ ។

[ ១៥៧ ] ព្រោះហេតុនោះបណ្តាអ្នកទាំងឡាយ តថាគតពោលដល់បុគ្គលដែលប្រាថ្នាដើម្បីភាពជាយ៉ាងនោះ ។

គប្បីជ្រាបគាថាជាដើមថា **យំ បុព្វេ** ដូចតទៅនេះថា ក្នុងបទទាំងនោះបទថា **បុព្វេ** បានដល់ កិលេសជាតិដែលមានការកើតឡើងជាធម្មតាព្រោះប្រារព្ធ

ដល់សង្ខារក្នុងអតីតនិងកម្មក្នុងអតីត ។ បទថា **បច្ឆា តេ មាហុ កិញ្ចនំ** បានដល់ កិលេសជាគ្រឿងកង្វល់មានរាគៈជាដើម មានការកើតឡើងជាធម្មតា ព្រោះប្រារព្ធសង្ខារក្នុងអនាគត កុំបីមានដល់អ្នក ។ បទថា **មជ្ឈេ ចេ នោ គហិស្សសិ** បានដល់ បើអ្នកមិនប្រកាន់ធម៌មានរូបជាដើមក្នុងបច្ចុប្បន្នសោត អ្នកនឹងជាបុគ្គល ស្ងប់ត្រាច់ទៅ ។

[ ១៥៨ ] បទថា **អតីតំ ករោហិ** សេចក្តីថា ចូរអ្នកធ្វើឲ្យអស់នូវពូជ ដោយមគ្គញ្ញាណ ។

[ ១៥៩ ] បទថា **រាគកិញ្ចនំ** សេចក្តីថា ការកង្វល់ គឺរាគៈ ។ ក្នុង បទថា **ទោសកិញ្ចនំ** ជាដើម ក៏ន័យនេះដូចគ្នា ។

[ ១៦២ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសម្រេចអរហត្តយ៉ាង នេះហើយ ឥឡូវនេះបានត្រាស់គាថាទាំងឡាយបន្តអំពីនេះដោយទ្រង់សរសើរ អរហត្តតទៅ ។ ក្នុងបទទាំងនោះគប្បីជ្រាបសេចក្តីនៃគាថាជាដើមថា **សព្វសោ** ដូចតទៅនេះថា បទថា **មមាយិតំ** បានដល់ ធ្វើនូវការប្រកាន់ថាជាខ្លួនរបស់ អញ ឬប្រកាន់ថា នេះជារបស់អញ ។ បទថា **អសតា ច ន សោចតិ** បានដល់ មិនសោក ព្រោះមិនមានការត្រេកអរនិងព្រោះមិនមានហេតុ ។ បទ ថា **ន ជីយតិ** បានដល់ មិនជួបនូវការវិនាស ។

[ ១៦៤ ] បទថា **អហុ វត មេ** បានដល់ នាមរូបរបស់អាត្មាអញមាន ហើយហ្ន៎ ។ បទថា **តំ វត មេ នត្ថិ** បានដល់ នាមរូបដែលមានហើយក្នុង អតីត ឥឡូវនេះមិនមានដល់អញឡើយ ។ បទថា **សិយា វត មេ** បានដល់

*អញមិនបានទាមរូបដែលនឹងមានដល់អញហ្ន៎ ឥឡូវនេះអញមិនសម្រេចដោយចំណែកមួយ ។ មានអ្វីក្រៃលែងជាងនោះទៀត ។*

*[ ១៦៦ ] គប្បីជ្រាបគាថាជាដើមថា* **យស្ស នត្ថិ** *ដូចតទៅនេះថា*

*ក្នុងបទទាំងនោះ បទថា* **កិញ្ចនំ** *បានដល់ ធម្មជាតិ មានរូបជាដើមណាមួយ ។*

*[ ១៦៧ ] បទថា* **អភិសង្ខតំ** *បានដល់ ដែលកម្មគ្របដណ្ដប់ហើយ ។ បទថា* **អភិសញ្ចេតយិតំ** *បានដល់ ដែលចិត្តធ្វើឲ្យជាគំនរហើយ ។ បទថា* **អវិជ្ជាយ ត្វេវ** *កាត់បទជា* **អវិជ្ជាយ តុ ឯវ** *។ បទថា* **អសេសវិរាគនិរោធា** *បានដល់ រលត់មិនសេសសល់ដោយមគ្គ បានដល់ខ្ចាក់ចេញនូវរាគៈ ។*

*បទថា* **សុញ្ញតោ លោកំ អវេក្ខស្សុ** *បានដល់ អ្នកចូរមើលលោកដោយភាពជារបស់សូន្យ ដោយអាការ ២ យ៉ាង គឺដោយការកំណត់ ការប្រព្រឹត្តទៅក្នុងអំណាច ១ ដោយចូលទៅពិចារណាសង្ខារដោយភាពជារបស់ទទេ ១ ។ បទថា* **អត្តានុទិដ្ឋឹ ឩហច្ច** *បានដល់ ដកនូវសក្កាយទិដ្ឋិ ។ បទថា* **ឯវំ មច្ចុតរោ សិយា** *បានដល់ គប្បីជាអ្នកឆ្លងនូវមរណៈបាន ដោយអាការយ៉ាងនេះ ។ បទថា* **ឯវំ លោកំ អវេក្ខន្តំ** *បានដល់ ដែលពិចារណាឃើញនូវខន្ធលោកយ៉ាងនេះ ។ បទថា* **មច្ចុរាជា ន បស្សតិ** *បានដល់ មច្ចុរាជមើលមិនឃើញ គឺសម្លឹងមិនឃើញ ។ បទថា* **ឆាត្តំ បត្ថយតេ កិញ្ចិ** *បានដល់ មិនប្រាថ្នា មិនត្រូវការអ្វីដទៃ សូម្បីមានប្រមាណតិចតួច ។ បទថា* **អញ្ញត្រ អប្បដិសន្ធិយា** *បានដល់ ក្រៅអំពីព្រះនិព្វាន ។ អាចារ្យទាំងឡាយ*

សូធ្យធ្វើជាពាក្យតែ ១ ថា **អញ្ញត្រប្បដិសង្ខិយា** ។ មានអ្វីក្រៃលែងជាងនេះទៀត ។

[ ១៧០ ] គប្បីជ្រាបគាថាជាដើមថា **អនិដ្ឋុរី** ដូចតទៅនេះថា ក្នុងបទទាំងនោះ បទថា **អនិដ្ឋុរី** បានដល់ មិនប្រណែន ។ អាចារ្យពួកខ្លះសូធ្យថា **អនិដ្ឋូរី** ក៏មាន ។ បទថា **សព្វធិ សមោ** បានដល់ ជាអ្នកស្មើក្នុងវត្ថុទាំងពួង អធិប្បាយថា ជាអ្នកព្រងើយ ។ លោកអធិប្បាយទុកដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា បុគ្គលណាមិនសោយសោកថា វត្ថុនេះមិនមានដល់អញ អញត្រូវសួរដល់បុគ្គលដែលមិនញាប់ញ័រនោះ ក៏ប្រាប់អានិសង្ស ៤ ក្នុងបុគ្គលនោះថា បុគ្គលជាអ្នកមិនប្រណែន មិនតាមជាប់ចិត្ត មិនញាប់ញ័រ ជាអ្នកស្មើក្នុងអាយតនៈទាំងពួង ។

[ ១៧១ ] បទថា **និដ្ឋុរិយោ** បានដល់ ជាអ្នកប្រណែន ។ ភាវៈនៃបុគ្គលប្រណែន ឈ្មោះថា **និដ្ឋុរិយំ** អធិប្បាយថា ស្មោះទឹកមាត់ថា គុណសូម្បីមានប្រមាណតិចតួចក៏មិនមានព្រោះអាស្រ័យភាពជាអ្នកប្រណែននោះ ។ បទថា **និដ្ឋុរិយកម្មំ** បានដល់ ការធ្វើនូវភាពជាអ្នកប្រណែន ។ ពិតហើយគ្រហស្ថអាស្រ័យគ្រហស្ថ ឬភិក្ខុអាស្រ័យភិក្ខុ កាលក្រោធដោយហេតុត្រឹមបន្តិចបន្តួចប៉ុណ្ណោះ អាស្រ័យសេចក្តីប្រណែននោះ ក៏ពោលថាមិនមានគុណសូម្បីបន្តិចបន្តួច ទើបធ្វើនូវការប្រណែន ដូចស្តោះទឹកមាត់ ហើយយកជើងជាន់ឈ្លីដូច្នោះ ការធ្វើរបស់បុគ្គលនោះហៅថា **និដ្ឋុរិយកម្មំ** ។ បទថា **ឥស្សា** ជាពាក្យសម្តែងសភាវ ។ បទ ២ បន្ទាប់អំពីនោះជាការសម្តែងអាការៈ ។ បទ

៣ ក្រៅអំពីនោះជាបទពោលដោយអម ។ មួយវិញទៀត សេចក្តីប្រណែននោះ ដោយលក្ខណៈជាដើម មានការប្រណែននូវសម្បត្តិអ្នកដទៃជាលក្ខណៈ មានការមិនត្រេកអរ ក្នុងសម្បត្តិរបស់បុគ្គលដទៃនោះជាកិច្ច មានការបែរមុខចេញអំពីសម្បត្តិអ្នកដទៃនោះជាអាការប្រាកដ មានសម្បត្តិអ្នកដទៃជាហេតុជិត ។

[ ១៧២ ] បទថា **លាភេបិ ច នញ្ញតិ** បានដល់ មិនញាប់ញ័រ ព្រោះការបានបច្ច័យ ។ បទថា **អលាភេបិ** បានដល់ ក្នុងការមិនបានបច្ច័យទាំងឡាយ ។ មានអ្វីក្រៃលែងជាងនេះទៀត ។

[ ១៧៤ ] គប្បីជ្រាបគាថាជាដើមថា **អនេជស្ស** ដូចតទៅនេះថា ក្នុងបទទាំងនោះ បទថា **និសង្ខតិ** បានដល់ សង្ខារណាមួយ បណ្តាអភិសង្ខារមានបុញ្ញាភិសង្ខារជាដើម ព្រោះអភិសង្ខារនោះដែលបុញ្ញកម្មតាក់តែង ឬរមែងតាក់តែង ហេតុនោះទើបហៅថា **និសង្ខតិ** ។ បទថា **វិយារម្ភា** បានដល់ អភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ច្រើនយ៉ាង ។ បទថា **ខេមំ បស្សតិ សព្វធិ** បានដល់ រមែងឃើញការមិនមានភ័យនោះឯង ក្នុងទីទាំងពួង ។ បទថា **អារម្ភា** បានដល់ ការព្យាយាមធ្វើកម្មគ្រាដំបូង ។ បទថា **វិយារម្ភា** គឺឈ្មោះថា **វិយារម្ភ** ដោយអំណាចព្យាយាមច្រើនយ៉ាង ក្រៃលែងឡើងៗ ។ ពាក្យនេះជាឈ្មោះនៃកម្មដែលញុំាងបដិសន្ធិឲ្យកើតក្នុងភព ៣ ព្រោះហេតុនោះវៀរហើយចាកវិយារម្ភៈ ។

[ ១៧៩ ] បុគ្គលកាលឃើញយ៉ាងនេះ គប្បីជ្រាបគាថាជាដើមថា **ន សមេសុ** ដូចតទៅនេះថា ក្នុងបទទាំងនោះ បទថា **ន សមេសុ** បានដល់ មុនី

មិនពោលដល់ខ្លួនក្នុងបុគ្គលដែលស្មើខ្លួន ដោយអំណាចមានះថា អាត្មាអញជាអ្នកស្មើនឹងគេជាដើម ។ ក្នុងមនុស្សដែលទាបជាងនិងក្នុងមនុស្សដែលខ្ពស់ជាងក៏មិនពោល ។ បទថា **ឆាទេតិ ន និរស្សតិ** បានដល់ មិនប្រកាន់ មិនលះបង់នូវធម៌ណាមួយ ក្នុងរូបជាដើម ។ បទដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ហើយ ព្រោះមានន័យដូចពោលទុកហើយក្នុងទីនោះៗ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺអរហត្តដោយប្រការដូច្នេះ ។

## អដ្ឋកថា អត្តទណ្ឌសុត្តនិទ្ទេសទី ១៥ ចប់

# សារីបុត្តសុត្តនិទ្ទេសទី ១៦

[ ១៨៣ ] ( ព្រះសារីបុត្តមានអាយុ ពោលដូច្នេះថា ) ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ ទាំងមិនបានឮ ( អំពីសម្នាក់ ) អ្នកណាមួយទេ ព្រះសាស្តាមានព្រះសូរសៀងដ៏ពីរោះយ៉ាងនេះ ទ្រង់ចុះចាកឋានតុសិតមកកាន់ពួក ។

[ ១៨៤ ] ពាក្យថា ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ គឺក្នុងកាលមុនអំពីកាលនេះ ព្រះមានព្រះភាគអង្គនោះ ខ្ញុំមិនធ្លាប់ឃើញ ដោយចក្ខុនេះ ដោយអត្តភាពនេះទេ ។ កាលដែលព្រះមានព្រះភាគ គង់ចាំវស្សាលើថ្មបណ្ឌុកម្ពល ក្រោមម្លប់បារិច្ឆត្តព្រឹក្ស នាឋានតាវត្តិង្ស មានពួកទេវតាហែហម ទ្រង់យាងចុះកាន់ក្រុងសង្កស្ស តាមជណ្តើរកែវត្រង់កណ្តាល ខ្ញុំមិនបានឃើញក្នុងកាលមុន វៀរលែងនូវការឃើញនេះ ។ ហេតុនោះ ( លោកពោលថា ) ក្នុងកាលមុនអំពីកាលនេះ ខ្ញុំមិនបានឃើញ ។

[ ១៨៥ ] ពាក្យថា ព្រះសារីបុត្តមានអាយុ ( ពោល ) ថាដូច្នេះ ត្រង់ពាក្យថា ដូច្នេះជាពាក្យតបទ ភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះនុ៎ះ គឺជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនុ៎ះ ជាពាក្យប្រកបដោយសេចក្តីគោរព កោតក្រែង ។ ពាក្យថា សារីបុត្ត គឺជាឈ្មោះ ជាការរាប់ ជាពាក្យសម្គាល់ ជាបញ្ញត្តិ ជាពាក្យហៅ ជានាម ជានាមកម្ម ជានាមបញ្ញត្តិ ជាសម្តី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាសរបស់ព្រះថេរៈនោះ ហេតុនោះ ( លោកពោលថា ) ព្រះសារីបុត្តមានអាយុពោលដូច្នេះ ។

[ ១៨៦ ] ពាក្យថា ទាំងមិនបានឮ អំពីសម្នាក់អ្នកណាមួយទេ ត្រង់ពាក្យថា មិន ជាពាក្យហាមឃាត់ ។ ពាក្យថា ទាំង ជាពាក្យតបទ ភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ទាំងនុ៎ះ គឺជាលំដាប់បទ ។ ពាក្យថា អ្នកណាមួយ គឺអ្នកណាមួយ ទោះក្សត្រក្ដី ព្រាហ្មណ៍ក្ដី វេស្សៈក្ដី សុទ្ទៈក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ទេវតាក្ដី មនុស្សក្ដី ហេតុនោះ ( លោកពោលថា ) ទាំងមិនបានឮ អំពីសម្នាក់អ្នកណាមួយទេ ។

[ ១៨៧ ] ពាក្យថា ព្រះសាស្ដា មានព្រះសូរសៀងពីរោះយ៉ាងនេះ អធិប្បាយថា ព្រះអង្គមានព្រះសូរសៀងពីរោះ សូរសៀងទន់ផ្អែម សូរសៀងគួរជាទីស្រឡាញ់ សូរសៀងជាទីគាប់ចិត្ត សូរសៀងពីរោះ ដូចសំឡេងសត្វករវិកយ៉ាងនេះ ។ ព្រះសូរសៀងដែលផ្សាយចេញចាកព្រះឱស្ឋ របស់ព្រះមានព្រះភាគនោះ ប្រកបដោយអង្គ ៨ គឺក្បោះក្បាយ ១ គប្បីដឹងបានដោយងាយ ១ ទន់ពីរោះ ១ ស្រួលស្ដាប់ ១ មូល ១ មិនបែកព្រែក ១ ក្រអួន ១ លាន់រំពង ១ ។ កាលណាព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងបរិស័ទឲ្យដឹង ដោយព្រះសូរសៀង ព្រះសូរសៀងព្រះមានព្រះភាគអង្គនោះ មិនខ្ចាយចេញទៅខាងក្រៅអំពីបរិស័ទ ។ ព្រះមានព្រះភាគអង្គនោះ មានព្រះសូរសៀងដូចជាសំឡេងព្រហ្ម មានព្រះសូរសៀងដូចជាសំឡេងសត្វករវិក ហេតុនោះ លោកពោលថា ព្រះមានព្រះភាគ មានព្រះសូរសៀងពីរោះយ៉ាងនេះ ។ ពាក្យថា ព្រះសាស្ដា គឺព្រះមានព្រះភាគ ជាអ្នកនាំពួក ។ នាយពួក ញុំាងពួកទាំងឡាយឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺចោរ ឲ្យឆ្លងផ្លូវលំបាកគឺម្រឹគសាហាវ ឲ្យ

ឆ្លងផ្លូវលំបាកគឺការអត់ឃ្លាន ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញ ឲ្យឆ្លងផុតផ្លូវលំបាក គឺការមិនមានទឹក ឲ្យបានដល់ទីក្សេមយ៉ាងណាមិញ ព្រះមានព្រះភាគជាអ្នកនាំពួក តែងញុំាងពួកសត្វឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺជាតិ ឲ្យឆ្លងផ្លូវលំបាកគឺជរា ឲ្យឆ្លងផ្លូវលំបាកគឺព្យាធិ ឲ្យឆ្លងផ្លូវលំបាកគឺមរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ឲ្យឆ្លងផ្លូវលំបាកគឺរាគៈ ឲ្យឆ្លងផ្លូវលំបាកគឺទោសៈ មោហៈ មានះ ទិដ្ឋិ កិលេស ទុច្ចរិត ឲ្យឆ្លងសេចក្ដីសាំញុំាគឺរាគៈ ឲ្យឆ្លងសេចក្ដីសាំញុំាគឺទោសៈ មោហៈ មានះ ទិដ្ឋិ ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លង ចេញ ឲ្យឆ្លងផុតនូវសេចក្ដីសាំញុំា គឺកិលេស ឲ្យដល់ទីក្សេម គឺអមតនិព្វានក៏យ៉ាងនោះដែរ ហេតុនោះព្រះមានព្រះភាគជាអ្នកនាំពួកយ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគទ្រង់ទូន្មាន ណែនាំ ប្រៀនប្រដៅឲ្យស្គាល់ ឲ្យបាក់ចុះ ឲ្យសម្លឹងមើល ឲ្យជ្រះថ្លា ហេតុនោះ ព្រះមានព្រះភាគជាអ្នកនាំពួកយ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ធ្វើមគ្គដែលមិនទាន់កើតឲ្យកើតឡើង ទ្រង់ធ្វើមគ្គដែលមិនទាន់កើតឲ្យកើតព្រម ទ្រង់ប្រាប់មគ្គដែលមិនទាន់បានប្រាប់ជាអ្នកដឹងនូវមគ្គ ជ្រាបច្បាស់នូវមគ្គ ឈ្លាសក្នុងមគ្គ ។ ឯពួកសាវកឥឡូវនេះ ជាអ្នកដើរតាមមគ្គ ជាអ្នកប្រកបតាមក្រោយ ហេតុនោះព្រះមានព្រះភាគឈ្មោះថា ជាអ្នកនាំពួក យ៉ាងនេះខ្លះ ហេតុនោះ ( លោកពោលថា ) ព្រះសាស្ដាមានព្រះសួរសៀងពីរោះ យ៉ាងនេះឯង ។

[ ១៨៨ ] ពាក្យថា ចុះចាកឋានតុសិតមកកាន់ពួក អធិប្បាយថា ព្រះមានព្រះភាគ ចុះចាកកាយតុសិត ស្ដេចមកកាន់ផ្ទៃមាតា ទាំងមានស្មារតីដឹង

ច្បាស់ ហេតុនោះ ( លោកពោលថា ) ព្រះសាស្តាចុះចាកឋានតុសិត មក កាន់ពួក យ៉ាងនេះខ្លះ ។ មួយទៀត ពួកទេវតាលោកហៅថា តុសិត ។ ពួកទេវតាទាំងនោះ ជាអ្នកត្រេកអរ ត្រេកអរព្រម ពេញចិត្ត រីករាយ មានបីតិនិងសោមនស្ស ព្រះសាស្តាចុះចាកឋានតុសិតទេវលោក មកកាន់ពួក ហេតុនោះ ( លោកពោលថា ) ចុះចាកឋានតុសិត មកកាន់ពួក យ៉ាងនេះខ្លះ ។ មួយវិញទៀតព្រះអរហន្តទាំងឡាយ លោកហៅថា តុសិត ។ ព្រះអរហន្តទាំងនោះជាអ្នកត្រេកអរ ត្រេកអរព្រម ពេញចិត្ត រីករាយ មានបីតិនិងសោមនស្ស ព្រះមានព្រះភាគស្តេចមកកាន់ពួកព្រះអរហន្តទាំងឡាយ ហេតុនោះ ( លោកពោលថា ) ចុះចាកឋានតុសិត មកកាន់ពួកយ៉ាងនេះខ្លះ ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះមានពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះជាអាចារ្យនៃពួក ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះជាសាស្តានៃពួក ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះទ្រង់រក្សាពួក ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះទ្រង់ទូន្មានពួក ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះទ្រង់ប្រៀនប្រដៅពួក ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់អង់អាចចូលទៅរកពួក ។ ព្រះមានព្រះភាគឈ្មោះថា មានពួក ព្រោះពួក តែងស្តាប់ដោយគោរព ( នូវពាក្យ ) នៃព្រះមានព្រះភាគនោះ ផ្ទៀងសោតៈស្តាប់ តម្កល់ទុកនូវចិត្តដើម្បីដឹង ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក ព្រោះទ្រង់ញុំាងពួក ឲ្យក្រោកចេញអំពីអកុសលធម៌ ហើយឲ្យតាំងនៅក្នុងកុសលធម៌ ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក របស់ពួកនៃភិក្ខុ ។

ព្រះមានព្រះភាគ ឈ្មោះថា មានពួក របស់ពួកនៃភិក្ខុនី ។ ព្រះមានព្រះភាគ ឈ្មោះថា មានពួក របស់ពួកនៃឧបាសក ។ ព្រះមានព្រះភាគឈ្មោះថា មានពួក របស់ពួកនៃឧបាសិកា ។ ព្រះមានព្រះភាគឈ្មោះថា មានពួក របស់ពួកនៃព្រះរាជា ។ ព្រះមានព្រះភាគឈ្មោះថា មានពួក របស់ពួកនៃក្សត្រ របស់ពួកនៃព្រាហ្មណ៍ របស់ពួកនៃវេស្សៈ របស់ពួកនៃសុទ្ទៈ របស់ពួកនៃទេវតា របស់ពួកនៃព្រហ្ម ។ ព្រះមានព្រះភាគ មានសង្ឃ មានគណៈ ជាគណាចារ្យ បានស្ដេចមកចូលទៅជិត ចូលទៅជិតព្រម បានដល់នូវសន្តស្សនគរ ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគ ចុះចាកឋានតុសិតមកកាន់ពួក ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

( ព្រះសារីបុត្តមានអាយុ ពោលដូច្នេះថា ) ក្នុងកាលមុនអំពី
កាលនេះ ខ្ញុំមិនបានឃើញ ទាំងមិនបានឮ ( អំពីសម្នាក់ )
អ្នកណាមួយទេ ព្រះសាស្ដា មានព្រះសូរសៀងពីរោះយ៉ាងនេះ
ទ្រង់ចុះចាកឋានតុសិត មកកាន់ពួក ។

[ ១៨៩ ] ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ប្រាកដដល់លោក ព្រមទាំងទេវលោក ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួងតែមួយអង្គឯង បានដល់នូវសេចក្ដីត្រេកអរ ។

[ ១៩០ ] ពាក្យថា ដល់លោកព្រមទាំងទេវលោក គឺដល់លោក ព្រមទាំងទេវលោក ព្រមទាំងមារលោក ព្រមទាំងព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស

ហេតុនោះ ( លោកពោលថា ) ដល់លោក ព្រមទាំងទេវលោក ។

[ ១៩១ ] ពាក្យថា ទ្រង់មានចក្ខុប្រាកដ អធិប្បាយថា ពួកទេវតាឃើញព្រះមានព្រះភាគកាលគង់លើថ្មបណ្ឌុកម្ពល ក្រោមម្លប់បារិច្ឆត្តកព្រឹក្ស នាឋានតាវត្តិង្ស ទ្រង់សម្ដែងធម៌យ៉ាងណា ពួកមនុស្ស ក៏រមែងឃើញយ៉ាងនោះ ។ មនុស្សទាំងឡាយឃើញយ៉ាងណា ពួកទេវតាឃើញយ៉ាងនោះ ។ ព្រះមានព្រះភាគប្រាកដដល់ពួកទេវតាយ៉ាងណា ប្រាកដដល់ពួកមនុស្សយ៉ាងនោះ ។ ព្រះមានព្រះភាគ ប្រាកដដល់ពួកមនុស្សយ៉ាងណា ប្រាកដដល់ពួកទេវតាយ៉ាងនោះ ហេតុនោះ ( លោកពោលថា ) មានចក្ខុប្រាកដយ៉ាងនេះខ្លះ ។ មួយទៀតពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំង ដែលមានចិត្តមិនទាន់ទូន្មានទេ ប្រាកដដោយភេទនៃអ្នកមានចិត្តទូន្មាន មានចិត្តមិនទាន់រម្ងាប់ទេ ប្រាកដដោយភេទនៃអ្នកមានចិត្តរម្ងាប់ មានចិត្តមិនទាន់ស្ងប់ស្ងាត់ទេ ប្រាកដដោយភេទនៃអ្នកមានចិត្តស្ងប់ស្ងាត់ មិនទាន់មានទុក្ខរលត់ទេ ប្រាកដដោយភេទនៃអ្នកមានទុក្ខរលត់យ៉ាងណាមិញ ។

ពួកសមណព្រាហ្មណ៍ ដែលមានបរិវារហែហម មិនមានសេចក្ដី
បរិសុទ្ធខាងក្នុង មានលម្អខាងក្រៅ ត្រាច់ទៅក្នុងលោក ដូច
ជាកុណ្ឌលដែលធ្វើអំពីដីស្អិត មានសភាពដ៏សមគួរ ឬដូចជា
មាសកៈទង់ដែង ដែលក្រឡែមាស ( យ៉ាងណាមិញ ) ។

ចំណែកព្រះមានព្រះភាគមិនប្រាកដយ៉ាងនោះទេ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះទ័យទូន្មានហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តទូន្មាន ទ្រង់មានព្រះទ័យ

រម្ងាប់ហើយ ប្រាកដដោយភេទនៃអ្នកមានចិត្តរម្ងាប់ ទ្រង់មានព្រះទ័យស្ងប់រម្ងាប់ហើយប្រាកដដោយភេទនៃអ្នកមានចិត្តស្ងប់រម្ងាប់ ទ្រង់មានទុក្ខរលត់ហើយប្រាកដដោយភេទនៃអ្នកមានទុក្ខរលត់ហើយ ដោយពិត ប្រាកដ ទៀងទាត់មិនប្រែប្រួល មិនវិបរិត ពិតមែន ។ មួយទៀតព្រះពុទ្ធទាំងឡាយមានព្រះភាគមានព្រះឥរិយាបថមិនបានញាប់ញ័រ សឹងបរិបូណ៌ដោយសេចក្ដីប្រាថ្នា ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគ មានចក្ខុប្រាកដ យ៉ាងនេះខ្លះ ។ មួយទៀត ព្រះមានព្រះភាគ ព្រះអង្គមានកិត្តិសព្ទដ៏បរិសុទ្ធ មានកិត្តិសព្ទនិងសេចក្ដីសសើរដ៏ពោរពេញ ក្នុងភពនៃនាគផង ក្នុងភពនៃគ្រុឌផង ក្នុងភពនៃយក្ខផង ក្នុងភពនៃអសុរផង ក្នុងភពនៃគន្ធព្វផង ក្នុងភពនៃមហារាជផង ក្នុងភពនៃព្រះឥន្ទផង ក្នុងភពនៃព្រហ្មផង គឺថាព្រះអង្គមានកិត្តិសព្ទនិងសេចក្ដីសរសើរ ប្រាកដបែបនេះផង ប្រាកដបែបនោះផង លើសលុបជាងនោះផង ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគ មានចក្ខុប្រាកដ យ៉ាងនេះខ្លះ ។ មួយទៀតព្រះមានព្រះភាគ ព្រះអង្គប្រកបដោយកម្លាំង ១០ តែងប្រាកដជាក់ច្បាស់ដោយវេសារជ្ជញាណ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ តេជះ ១ ពលៈ ១ គុណ ១ វីរិយៈ ១ បញ្ញា ១ ។

> សប្បុរសទាំងឡាយ រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមវន្ត
> អសប្បុរសទាំងឡាយ មិនប្រាកដក្នុងទីឆ្ងាយនោះបានទេដូចជា
> សរដែលគេបាញ់ទៅក្នុងពេលយប់ ។

ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគមានចក្ខុប្រាកដយ៉ាងនេះខ្លះ ។

ពាក្យថា ទ្រង់មានចក្ខុ សេចក្តីថា ព្រះមានព្រះភាគ មានចក្ខុដោយចក្ខុ ៥ គឺមានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ ១ មានចក្ខុដោយសមន្តចក្ខុ ១ ។

ព្រះមានព្រះភាគមានចក្ខុដោយមំសចក្ខុ តើដូចម្តេច ។ ក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគមានសម្បុរ ៥ គឺសម្បុរខៀវ ១ សម្បុរលឿង ១ សម្បុរក្រហម ១ សម្បុរខ្មៅ ១ សម្បុរស ១ ។ រោមព្រះនេត្ររបស់ព្រះមានព្រះភាគ តាំងនៅត្រង់ទីណា ទីនោះមានសម្បុរខៀវ ខៀវស្រងាត់ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាត្រកៀត ។ ទីក្រៅអំពីនោះ មានសម្បុរលឿង លឿងទុំ ដូចសម្បុរមាស គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងផ្កាកណ្ណិការ ។ រណ្តៅព្រះនេត្រទាំង ២ ខាងរបស់ព្រះមានព្រះភាគ មានសម្បុរក្រហម ក្រហមឆ្អៅ គួរជ្រះថ្លា គួររមិលមើល ស្រដៀងនឹងអណ្តើកមាស ។ ត្រង់កណ្តាលមានសម្បុរខ្មៅ ខ្មៅស្រិល មិនមានសៅហ្មង យ៉ាងស្និទ្ធ គួរជ្រះថ្លា គួររមិលមើលស្រដៀងនឹងផ្លែផ្គាំ ។ ក្រៅអំពីនោះ មានសម្បុរស សសុទ្ធ សក្បុស សត្រសុស គួរជ្រះថ្លា គួររមិលមើលស្រដៀងនឹងផ្កាយព្រឹក ។ ព្រះមានព្រះភាគទ្រង់ទតឃើញជុំវិញ ចម្ងាយមួយយោជន៍ ទាំងយប់ទាំងថ្ងៃដោយព្រះមំសចក្ខុតាមប្រក្រតីនោះដែលកើតអំពីសុចរិតកម្មក្នុងកាលមុន រាប់ទាំងអត្តភាពផង ។ ទោះបីងងឹត ប្រកបដោយអង្គ ៤ គឺព្រះអាទិត្យអស្តង្គត ១ ថ្ងៃឧបោសថជាចំណែកខាងរនោច ១ ដងព្រៃជិតស្ទុប ១ ភ្លៀងធំខុសកាលតាំងឡើង ១ ព្រះមានព្រះភាគទ្រង់ទតឃើញជុំវិញ ចម្ងាយមួយយោជន៍ក្នុងទីងងឹតប្រកបដោយ

*អង្គ ៤ សូម្បីមានសភាពយ៉ាងនេះ ។ ព្រះអង្គមិនមានជញ្ជាំងឬសន្ទះទ្វារ កំផែង ឬភ្នំ គុម្ពឈើឬវល្លិ ជាគ្រឿងរាំងនូវកិរិយាឃើញរូបទាំងឡាយទេ ។ បើទុក ជាគេដាក់គ្រាប់ល្ង ១ គ្រាប់ក្នុងរទេះពេញ ដោយល្ងធ្វើឲ្យជាគ្រឿងចំណាំ ក៏ នៅតែព្រះមានព្រះភាគ ទ្រង់រើសយកគ្រាប់ល្ងនោះបានវិញដដែល ។ ព្រះ មំសចក្ខុជាប្រក្រតីរបស់ព្រះមានព្រះភាគបរិសុទ្ធយ៉ាងនេះឯង ។ ព្រះមានព្រះ ភាគមានចក្ខុដោយមំសចក្ខុយ៉ាងនេះ ។*

*ព្រះមានព្រះភាគ មានចក្ខុដោយទិព្វចក្ខុ តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងផុតចក្ខុរបស់មនុស្ស ទ្រង់ទតឃើញ ពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាប ឧត្ដម មានវណ្ណៈល្អ មាន វណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ដឹងច្បាស់នូវពួកសត្វដែល អន្ទោលទៅតាមកម្មថា អើហ្ន៎ ពួកសត្វដ៏ចម្រើនទាំងនេះ ប្រកបដោយកាយ ទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ កាន់យកអំពើនៃមិច្ឆាទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅហើយ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្យ៉ាងទៀតពួកសត្វ ដ៏ចម្រើននេះប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយ មនោសុចរិត មិនតិះដៀលព្រះអរិយៈ ជាសម្មាទិដ្ឋិ កាន់យកអំពើនៃសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រះមានព្រះភាគទ្រង់មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងផុត ចក្ខុរបស់មនុស្ស ទ្រង់ឃើញពួកសត្វដែលកំពុងច្យុត កំពុងកើត ជាសត្វថោក*

ទាប ឧត្តម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានដំណើរល្អ មានដំណើរអាក្រក់ ទ្រង់ជ្រាបនូវពួកសត្វដែលអន្ទោលទៅតាមកម្មយ៉ាងនេះ ។ មួយទៀត ព្រះមានព្រះភាគ កាលបើចង់ឃើញ គប្បីឃើញលោកធាតុ ១ ខ្វះ ឃើញលោកធាតុ ២ ខ្វះ ឃើញលោកធាតុ ៣ ខ្វះ ឃើញលោកធាតុ ៤ ខ្វះ ឃើញលោកធាតុ ៥ ខ្វះ ឃើញលោកធាតុ ១០ ខ្វះ ឃើញលោកធាតុ ២០ ខ្វះ ឃើញលោកធាតុ ៣០ ខ្វះ ឃើញលោកធាតុ ៤០ ខ្វះ ឃើញលោកធាតុ ៥០ ខ្វះ ឃើញលោកធាតុតូច ១០០០ ខ្វះ ឃើញលោកធាតុជាកណ្តាល ១ ពាន់ ២ ជាន់ខ្វះ ( មួយលាន ) ឃើញលោកធាតុ ១ ពាន់ ៣ ជាន់ខ្វះ ( ១០០ កោដិ ) ឃើញលោកធាតុច្រើនពាន់ខ្វះ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រាថ្នាត្រឹមណា គប្បីទតឃើញត្រឹមនោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគបរិសុទ្ធិយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់មានចក្ខុដោយទិព្វចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ មានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញារីករាយ មានបញ្ញារហ័ស មានបញ្ញាក្លាហាន មានបញ្ញាទម្លាយបង់នូវកិលេស ឈ្លាសក្នុងប្រភេទនៃបញ្ញា មានញាណបែកធ្លាយ បានសម្រេចបដិសម្ភិទា បានសម្រេចចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសដ៏ប្រសើរ ជាសីហបុរស ជានាគបុរស ជាអាជញ្ញបុរស ជាបុរសអ្នកនាំនូវធុរៈ មានញាណមិនមានទីបំផុត មានតេជះមិនមានទីបំផុត មានយសមិនមានទីបំផុត ស្តុកស្តម្ភ មាំមួន មានទ្រព្យ ទ្រង់ទូន្មាន ណែនាំ ប្រៀនប្រដៅ ឲ្យស្គាល់ ឲ្យចាក់ធ្លុះ ឲ្យប្រាថ្នា ឲ្យជ្រះថ្លា ។

ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ទ្រង់ញុំាងមគ្គដែលមិនទាន់កើតឡើងព្រម ឲ្យកើតឡើងព្រម ទ្រង់ប្រាប់មគ្គដែលមិនទាន់បានប្រាប់ ជាអ្នកដឹងនូវមគ្គ ជ្រាបច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គ ។ ឯពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ មកតាមក្រោយ ។ ព្រោះថា ព្រះមានព្រះភាគនោះទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ ទ្រង់មានចក្ខុ មានធម៌ មានញាណ មានភាពដ៏ប្រសើរ ទ្រង់ពោល សម្ដែង បង្អោននូវប្រយោជន៍ ជាអ្នកឲ្យនូវព្រះនិព្វាន ជាម្ចាស់ហេតុធម៌ ជាព្រះតថាគត ។ ហេតុណាមួយដែលព្រះមានព្រះភាគនោះមិនជ្រាប មិនឃើញ មិនជាក់ច្បាស់ មិនធ្វើឲ្យប្រាកដ មិនពាល់ត្រូវដោយបញ្ញាមិនដែលមានទេ ។ ធម៌ទាំងអស់រាប់ទាំងអតីត អនាគត បច្ចុប្បន្ន រមែងមកកាន់គន្លងចំពោះមុខព្រះញាណនៃព្រះពុទ្ធដ៏មានព្រះភាគ ដោយអាការទាំងពួង ។ ឈ្មោះថា វត្ថុណាមួយ ដែលត្រូវយល់ ត្រូវដឹង ប្រយោជន៍ខ្លួនក្ដី ប្រយោជន៍អ្នកដទៃក្ដី ប្រយោជន៍ទាំង ២ ក្ដី ប្រយោជន៍ជាបច្ចុប្បន្នក្ដី ប្រយោជន៍ក្នុងលោកខាងមុខក្ដី ប្រយោជន៍រាក់ក្ដី ប្រយោជន៍ជ្រៅក្ដី ប្រយោជន៍លាក់ក្ដី ប្រយោជន៍កំបាំងក្ដី ប្រយោជន៍ដែលត្រូវណែនាំក្ដី ប្រយោជន៍ដែលបាននាំចេញស្រាប់ហើយក្ដី ប្រយោជន៍មិនមានទោសក្ដី ប្រយោជន៍មិនមានកិលេសក្ដី ប្រយោជន៍ដ៏ផូរផង់ក្ដី ព្រយោជន៍ដ៏សំខាន់ក្ដី ទាំងអស់នោះរមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃពុទ្ធញ្ញាណ ។ ព្រះពុទ្ធមានព្រះភាគ មានព្រះញាណមិនទើសទាក់ក្នុងអតីត មានព្រះញាណមិនទើសទាក់ក្នុងអនាគត មានព្រះញាណមិន

ទើសទាក់ក្នុងបច្ចុប្បន្ន ។ កាយកម្មទាំងអស់ ប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ មនោកម្មទាំងអស់ប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ។ ហេតុដែលត្រូវដឹងមានត្រឹមណា ព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹង ក៏មានញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង គន្លងដែលត្រូវដឹងប្រព្រឹត្តកន្លងព្រះញាណក៏មិនមាន ធម៌ទាំងនោះ រមែងស្ថិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ផ្ទៃស្មុគទាំង ២ ដែលស្និទ្ធគ្នាល្អ ផ្ទៃស្មុគខាងក្រោម មិនប្រព្រឹត្តហួសផ្ទៃស្មុគខាងលើ ផ្ទៃស្មុគខាងលើមិនហួសផ្ទៃស្មុគខាងក្រោម ផ្ទៃស្មុគទាំង ២ រមែងឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងណាមិញ ហេតុដែលត្រូវដឹងផង ព្រះញាណផង របស់ព្រះពុទ្ធមានព្រះភាគ តាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងនោះឯង គឺហេតុដែលត្រូវមានត្រឹមណាព្រះញាណក៏មានត្រឹមនោះ ព្រះញាណមានត្រឹមណា ហេតុដែលត្រូវដឹងក៏មានត្រឹមនោះ ព្រះញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹង ក៏មានព្រះញាណជាទីបំផុត ព្រះញាណមិនប្រព្រឹត្តកន្លងហេតុដែលត្រូវដឹង គន្លងដែលត្រូវដឹងប្រព្រឹត្តកន្លងព្រះញាណក៏មិនមាន ធម៌ទាំងនោះ រមែងតាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ។ ធម៌ទាំងពួងជាប់ដោយការពិចារណា ជាប់ដោយសេចក្តីប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទនៃព្រះពុទ្ធមានព្រះភាគ ។ ព្រះញាណរបស់ព្រះពុទ្ធ

មានព្រះភាគ ប្រព្រឹត្តទៅក្នុងពួកសត្វទាំងពួង ។ ព្រះមានព្រះភាគទ្រង់ជ្រាប អធ្យាស្រ័យ ជ្រាបអនុស័យ ជ្រាបចរិត ជ្រាបនូវអធិមុត្តិនៃសត្វទាំងពួង ជ្រាបច្បាស់នូវសត្វទាំងឡាយដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ឲ្យដឹងបានដោយងាយ ឲ្យដឹងបានដោយកម្រ ជាសត្វគួរនិងមិនគួរត្រាស់ដឹង ។ លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅក្នុងពុទ្ធញាណ ។ ហ្វូងត្រីនិងអណ្តើកណាទីមួយ ដោយហោចទៅរាប់តាំងពីត្រីឈ្មោះតិមិនិងត្រីឈ្មោះតិមិង្គល ប្រព្រឹត្តទៅក្នុងខាងក្នុងមហាសមុទ្រយ៉ាងណា លោកព្រមទាំងទេវលោក ព្រមទាំងមារ ព្រមទាំងព្រហ្ម ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ក៏ប្រព្រឹត្តទៅខាងក្នុងពុទ្ធញាណក៏យ៉ាងនោះឯង ពួកបក្សីណាមួយដោយហោចទៅរាប់តាំងពីគ្រុឌ ឈ្មោះវេនតេយ្យ ប្រព្រឹត្តទៅក្នុងប្រទេសនៃអាកាសយ៉ាងណា ពួកជនណាមានបញ្ញាស្មើនឹងព្រះសារីបុត្ត សូម្បីជនទាំងនោះក៏ប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញាណយ៉ាងនោះឯង ។ ពុទ្ធញាណផ្សាយគ្របនូវបញ្ញានៃទេវតានិងមនុស្សទាំងឡាយ ហើយឋិតនៅ ។ ពួកជនណាមួយជាខត្តិយ-បណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ជាបណ្ឌិតមានប្រាជ្ញាល្អិត មានបរប្បវាទធ្វើហើយ មានសភាពដូចជាខ្នាន់ធ្នូអ្នកបាញ់រោមកន្ទុយ អាចទម្លាយនូវទិដ្ឋិទាំងឡាយដោយប្រាជ្ញាបាន ពួកជនទាំងនោះក៏តាក់

តែងរៀបចំនូវបញ្ហា ហើយចូលទៅសួរព្រះតថាគត ។ បញ្ហាទាំងនោះព្រះមានព្រះភាគទ្រង់សម្តែងទាំងដោះស្រាយហើយ ជាប្រស្នាដែលព្រះមានព្រះភាគគួរសម្តែងចេញនូវហេតុ ទាំងជាប្រស្នាដែលព្រះអង្គគួរបញ្ឈប់ទុក ។ ជនទាំងនោះនាំគ្នាចុះចូលព្រះមានព្រះភាគ ។ គ្រានោះព្រះមានព្រះភាគទ្រង់រុងរឿងក្នុងទីប្រជុំនោះដោយបញ្ញា ព្រះមានព្រះភាគមានចក្ខុដោយបញ្ញាចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ បានឃើញនូវសត្វទាំងឡាយមានធូលីស្រាលស្តើងក្នុងភ្នែក មានធូលីក្រាស់ក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វឲ្យដឹងបានដោយងាយឲ្យដឹងបានដោយកម្រ នូវសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោក ថាគួរខ្លាច ។ ដូចជលជាតិពួកខ្លះ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តីក្នុងត្រពាំងព្រលឹតក្តី ក្នុងត្រពាំងឈូកក្រហមក្តី ក្នុងត្រពាំងឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក លូតតាមទឹក លិចចុះខាងក្នុងដែលទឹកចិញ្ចឹមហើយ ផ្កាជលជាតិពួកខ្លះ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅស្មើនឹងទឹក ជលជាតិពួកខ្លះ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅផុតពីទឹក មិនទទឹកដោយទឹកយ៉ាងណា ព្រះមានព្រះភាគទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុទ្រង់ទតឃើញនូវសត្វទាំងឡាយដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វឲ្យដឹងបានដោយ

ឆាយ ឲ្យដឹងបានដោយកម្រ នូវសត្វពួកខ្លះ ជាអ្នកឃើញទោសក្នុងបរលោក ថា គួរខ្លាច ក៏យ៉ាងនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះ ជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធា ចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគទ្រង់សម្តែងអសុភកថាដល់បុគ្គល ជារាគចរិត ។ ព្រះមានព្រះភាគទ្រង់ប្រាប់មេត្តាភាវនាដល់បុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងឧទ្ទេស ( ការ រៀនបាលី ) ក្នុងបរិបុច្ឆា ( ការរៀនអដ្ឋកថា ) ក្នុងការស្តាប់ធម៌តាមកាល ក្នុងការសន្ទនាគ្នាទៅវិញទៅមកនូវធម៌តាមកាល ក្នុងការនៅជាមួយនឹងគ្រូ ។ ព្រះមានព្រះភាគទ្រង់ប្រាប់អានាបានស្សតិ ដល់បុគ្គលជាវិតក្កចរិត ។ ព្រះមាន ព្រះភាគទ្រង់ប្រាប់និមិត្តដែលគួរជ្រះថ្លា គឺការត្រាស់ដឹងដ៏ប្រពៃនៃព្រះពុទ្ធ ការទ្រ ទ្រង់ល្អនៃព្រះធម៌ សេចក្តីប្រតិបត្តិល្អនៃព្រះសង្ឃនិងសីលទាំងឡាយសម្រាប់ ខ្លួន ដល់បុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគទ្រង់ប្រាប់នូវវិបស្សនានិមិត្ត គឺអាការមិនទៀង អាការជាទុក្ខ អាការមិនមែនខ្លួនដល់បុគ្គលជាញាណចរិត ។

បុគ្គលឈរលើកំពូលភ្នំថ្មគប្បីឃើញប្រជុំជនដោយជុំវិញយ៉ាង
ណាមិញ បពិត្រព្រះអង្គមានប្រាជ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គ
មានសេចក្តីសោក ទៅប្រាសហើយ សូមទ្រង់យាងឡើងកាន់
ប្រាសាទ គឺធម៌ ហើយទតមើលប្រជុំជន ដែលខ្វល់ដោយ
សេចក្តីសោក ត្រូវជាតិនិងជរាគ្របសង្កត់ ក៏យ៉ាងនោះឯង ។

ព្រះមានព្រះភាគ មានចក្ខុដោយពុទ្ធចក្ខុយ៉ាងនេះ ។

ព្រះមានព្រះភាគ មានចក្ខុដោយសមន្តចក្ខុ តើដូចម្តេច ។ ព្រះសព្វញ្ញុ-តញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគទ្រង់ចូល ចូលព្រម ទៅជិត ជិតព្រម ដល់ ដល់ព្រម ប្រកបដោយសព្វញ្ញុតញ្ញាណ ។

ហេតុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគនោះ ទ្រង់

មិនឃើញឬថាមិនទ្រង់ជ្រាប មិនគួរជ្រាបមិនមានទេ ហេតុណា

ដែលត្រូវដឹង ព្រះមានព្រះភាគ ទ្រង់ជ្រាបហេតុនោះទាំងអស់

ព្រោះហេតុនោះ ព្រះតថាគតទើបឈ្មោះថា សមន្តចក្ខុ ។

ព្រះមានព្រះភាគ មានចក្ខុដោយសមន្តចក្ខុយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគ មានចក្ខុប្រាកដ ។

[ ១៩២ ] ពាក្យថា កម្ចាត់នូវងងឹតទាំងពួង គឺទ្រង់បន្សាត់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យដល់នូវការៈមិនមានបែបភាព នូវងងឹតគឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹតគឺកិលេស ងងឹតគឺទុច្ចរិត គ្រឿងធ្វើឲ្យងងឹត គ្រឿងធ្វើមិនឲ្យមានបញ្ញាចក្ខុ គ្រឿងធ្វើមិនឲ្យមានញាណជាគ្រឿងរលត់បញ្ញា ជាចំណែកនៃការបៀតបៀនដែលមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ហេតុនោះ ( លោកពោលថា ) កម្ចាត់បង់នូវងងឹតទាំងពួង ។

[ ១៩៣ ] ពាក្យថា ដល់នូវការត្រេកអរតែមួយព្រះអង្គឯង អធិប្បាយថា ព្រះមានព្រះភាគមួយព្រះអង្គឯងដោយចំណែកបព្វជ្ជា មួយព្រះអង្គឯង ដោយសេចក្តីថា មិនមានបុគ្គលជាទី ២ មួយព្រះអង្គឯង ដោយអត្ថថាលះបង់តណ្ហា

មួយព្រះអង្គឯងព្រោះព្រះអង្គប្រាសចាករាគៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាកទោសដោយចំណែកមួយ មួយព្រះអង្គឯងព្រោះព្រះអង្គប្រាសចាកមោហៈដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គមិនមានកិលេសដោយចំណែកមួយ មួយព្រះអង្គឯង ព្រោះព្រះអង្គយាងទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង មួយព្រះអង្គឯង ព្រោះព្រះអង្គតែម្នាក់ឯងទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ ហេតុនោះ ( លោកពោល ) តែមួយព្រះអង្គឯង ។

ព្រះមានព្រះភាគមួយព្រះអង្គឯង ដោយចំណែកបព្វជ្ជានោះ តើដូចម្ដេច ។ ព្រះមានព្រះភាគ កាលនៅជាកំលោះនៅឡើយមានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យកំពុងចម្រើន គឺបឋមវ័យ កាលដែលព្រះមាតាបិតា ទ្រង់មិនពេញព្រះទ័យ ( នឹងការទ្រង់ផ្នួស ) ដែលមានព្រះភក្ត្រជោកទៅដោយទឹកព្រះនេត្រទ្រង់ព្រះកន្សែងសោយសោកហើយ ទ្រង់ក៏លះបង់ពួកញាតិ កាត់យសបលិ-ពោធទាំងអស់ កាត់បុត្តទារបលិពោធ កាត់ញាតិបលិពោធ កាត់មិត្តាមច្ចប-លិពោធ កាត់សន្និធិបលិពោធ ហើយកោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពមិនមានការកង្វល់ត្រាច់ទៅ ប្រព្រឹត្តនៅ ចរទៅ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅមួយអង្គឯង ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯងដោយចំណែកបព្វជ្ជាយ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯងដោយសេចក្ដីថា មិនមានបុគ្គលជាទី ២

តើដូចម្តេច ។ ព្រះមានព្រះភាគនោះ កាលទ្រង់ព្រះផ្នួសហើយយ៉ាងនេះ តែមួយព្រះអង្គ ទ្រង់អាស្រ័យសេនាសនៈស្ងាត់ដែលតាំងនៅក្នុងព្រៃតូចធំ មានសំឡេងតិច មានគឹកកងតិច ប្រាសចាកសម្ពីមនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស គួរជាទីលាក់ខ្លួនពួនសម្ងំបាន ព្រះមានព្រះភាគអង្គនោះយាងទៅមួយអង្គឯង ឈរមួយអង្គឯង គង់នៅមួយអង្គឯង សម្រេចការផ្ទំមួយអង្គឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតមួយអង្គឯង ចៀសចេញទៅមួយអង្គឯង គង់នៅក្នុងទីស្ងាត់មួយអង្គឯង អធិដ្ឋានទីចង្ក្រមមួយអង្គឯង ត្រាច់ទៅ ប្រព្រឹត្តនៅ ចរទៅ ប្រព្រឹត្តទៅ រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅមួយព្រះអង្គឯង ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯងដោយសេចក្តីថា មិនមានបុគ្គលជាទី ២ យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ដោយសេចក្តីថា លះបង់តណ្ហានោះ តើដូចម្តេច ។ ព្រះមានព្រះភាគអង្គនោះ មួយព្រះអង្គឯង មិនមានបុគ្គលជាទី ២ យ៉ាងនេះហើយ ព្រះអង្គមិនមានសេចក្តីប្រហែស មានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានព្រះទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា តាំងទុកនូវមហាបធាន កម្ចាត់បង់នូវមារដែលមិនលែងជនឲ្យរួច ព្រមទាំងសេនាជាផៅពង្សនៃអ្នកប្រហែស ហើយលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវតណ្ហាដែលជាបណ្តាញ ជាគ្រឿងហូរទៅជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ។

បុរសដែលមានតណ្ហាជាទី ២ រមែងអន្ទោលទៅអស់កាលជា

យូរអង្វែង មិនប្រព្រឹត្តកន្លងនូវសង្សារវដ្ដ ជាភាពមានប្រការ
យ៉ាងនេះ ជាភាពមានប្រការដទៃ ភិក្ខុដឹងនូវទោសនោះហើយ
គប្បីជាអ្នកប្រាសចាកតណ្ហា មិនមានការប្រកាន់ មានស្មារតី
វៀរនូវតណ្ហាដែលជាដែនកើតទុក្ខ ។

ព្រះមានព្រះភាគ ឈ្មោះថា មួយព្រះអង្គឯង ដោយសេចក្តីថា លះបង់តណ្ហា យ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គប្រាសចាករាគៈដោយចំណែកមួយ តើដូចម្តេច ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះប្រាសចាករាគៈដោយចំណែកមួយ ព្រោះលះបង់រាគៈហើយ ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះប្រាសចាកទោសៈដោយចំណែកមួយ ព្រោះលះបង់ទោសៈហើយ ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះប្រាសចាកមោហៈដោយចំណែកមួយ ព្រោះលះបង់មោហៈហើយ ។ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះមិនមានកិលេសដោយចំណែកមួយ ព្រោះលះបង់នូវកិលេសទាំងឡាយហើយ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះស្តេចទៅកាន់ផ□ជាទីទៅ□ន បុគ្គលម្នាក់ឯង តើដូចម្តេច ។ ដែលហៅថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯងនោះ សំដៅយកសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។

ព្រះមានព្រះភាគមានប្រក្រតីឃើញនូវទីបំផុត នៃធម៌ជាគ្រឿង

អស់ទៅនៃជាតិ មានសេចក្ដីអនុគ្រោះដោយប្រយោជន៍ ទ្រង់ជ្រាបច្បាស់នូវផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ជនទាំងឡាយក្នុងកាលមុនបានឆ្លងហើយតាមផ្លូវនោះ ជនទាំងឡាយបម្រុងនឹងឆ្លង ជនទាំងឡាយកំពុងឆ្លងនូវឱឃៈ ( ក៏ឆ្លងតាមផ្លូវនោះ ) ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះស្ដេចទៅកាន់ផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯងយ៉ាងនេះ ។

ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គតែម្នាក់ឯង ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិតើដូចម្ដេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ វីមង្សា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គ ៤ លោកហៅថាពោធិ ដោយសារពោធិញ្ញាណនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដឹងថា សង្ខារទាំងពួងមិនទៀង ត្រាស់ដឹងថា សង្ខារទាំងឡាយពួងជាទុក្ខ ត្រាស់ដឹងថា ធម៌ទាំងពួងជាអនត្តា ត្រាស់ដឹងថា សង្ខារទាំងពួងមានអវិជ្ជាជាបច្ច័យ ។បេ។ ត្រាស់ដឹងថា ជរាមរណៈមានជាតិជាបច្ច័យ ត្រាស់ដឹងថា សេចក្ដីរលត់នៃសង្ខារ ព្រោះរលត់អវិជ្ជា ។បេ។ ត្រាស់ដឹងថា ការរលត់នៃជរាមរណៈព្រោះរលត់ជាតិ ត្រាស់ដឹងថា នេះទុក្ខ ត្រាស់ដឹងថា នេះទុក្ខសមុទយៈ ត្រាស់ដឹងថា នេះទុក្ខនិរោធ ត្រាស់ដឹងថា នេះទុក្ខនិរោធគាមិនីបដិបទា ត្រាស់ដឹងថា នេះអាសវៈ ត្រាស់ដឹងថា នេះអាសវសមុទយៈ ត្រាស់ដឹងថា នេះអាសវៈនិរោធ ត្រាស់ដឹងថា នេះអាសវៈនិរោធគាមិនីបដិបទា ត្រាស់ដឹងថា ធម៌ទាំងនេះគប្បីដឹង ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវកំណត់ ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវលះបង់

ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវចម្រើន ត្រាស់ដឹងថា ធម៌ទាំងនេះត្រូវធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងនូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្ដីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃផស្សាយតនៈ ៦ ត្រាស់ដឹងនូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្ដីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃឧបាទានក្ខន្ធ ៥ ត្រាស់ដឹងនូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្ដីអស់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នៃមហាភូតរូប ៤ ត្រាស់ដឹងថា ធម្មជាតិណាមួយមានការកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ។ មួយទៀតធម្មជាតិណាមួយ ដែលព្រះមានព្រះភាគគប្បីជ្រាប គប្បីជ្រាបចំពោះ គប្បីជ្រាបព្រម គប្បីត្រាស់ដឹង គប្បីពាល់ត្រូវ គប្បីធ្វើឲ្យជាក់ច្បាស់ ព្រះមានព្រះភាគក៏ទ្រង់ជ្រាប ជ្រាបតាមលំដាប់ ជ្រាបចំពោះ ជ្រាបព្រមជ្រាបដោយប្រពៃ ត្រាស់ដឹងបានចំពោះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់នូវធម្មជាតិទាំងអស់នោះដោយពោធិញ្ញាណនោះ ព្រះមានព្រះភាគ មួយព្រះអង្គឯង ព្រោះព្រះអង្គតែមួយព្រះអង្គឯង ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិយ៉ាងនេះ ។

ពាក្យថា សេចក្ដីត្រេកអរ ក្នុងបទថា បានដល់នូវសេចក្ដីត្រេកអរ មានសេចក្ដីថា ព្រះមានព្រះភាគ ដល់ សម្រេច ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់នូវសេចក្ដីត្រេកអរក្នុងនេក្ខម្មៈ នូវសេចក្ដីត្រេកអរក្នុងបវិវេក នូវសេចក្ដីត្រេកអរក្នុងការស្ងប់រម្ងាប់ នូវសេចក្ដីត្រេកអរក្នុងសម្ពោធិ ហេតុនោះ ( លោកពោលថា ) បានដល់នូវសេចក្ដីត្រេកអរមួយព្រះអង្គឯង ។ ហេតុនោះ ព្រះសារី

បុគ្គលត្រូវពោលថា

ព្រះមានព្រះភាគ មានចក្ខុប្រាកដដល់លោក ព្រមទាំងទេវលោក ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួង តែមួយអង្គឯង បានដល់នូវសេចក្តីត្រេកអរ ។

[ ១៩៤ ] ខ្ញុំមកនឹងសួរប្រស្នា ដើម្បីពួកជនអ្នកជាប់ច្រើននាក់ ក្នុងទីនេះ ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ទ្រង់នឹងធឹង ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ។

[ ១៩៥ ] អធិប្បាយថា ពាក្យថា ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ជាតាទិបុគ្គល ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ជាសយម្ភូ ឥតមានគ្រូអាចារ្យ បានត្រាស់ដឹងសច្ចៈ ដោយព្រះអង្គឯងក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនផង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងសច្ចៈនោះផង ទ្រង់ដល់នូវភាវៈស្ទាត់ក្នុងពលទាំងឡាយផង ។ សំណួរត្រង់ពាក្យថា ព្រះពុទ្ធ ចុះព្រះនាមថាព្រះពុទ្ធ ដោយអត្ថថាដូចម្តេច ។ ព្រះនាមថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះហេតុព្រះអង្គញ៉ាំងពួកសត្វ ឲ្យត្រាស់ដឹង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះទ្រង់ត្រាស់ដឹងនូវធម៌ទាំងអស់ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះទ្រង់ឃើញច្បាស់នូវធម៌ទាំងអស់ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះការរាប់ថាជាព្រះខីណាស្រព ។ ព្រះនាមថា ព្រះពុទ្ធ ព្រោះការរាប់ថាមិនមានឧបក្កិ-

លេស ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គប្រាសចាករាគៈ ដោយចំណែក មួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គប្រាសចាកទោសៈដោយចំណែក មួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គប្រាសចាកមោហៈ ដោយចំណែក មួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គមិនមានកិលេសដោយចំណែកមួយ ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គយាងទៅកាន់ផ្លូវជាទីទៅ តែមួយអង្គឯង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ តែមួយអង្គ ឯង ។ ព្រះនាមថាព្រះពុទ្ធ ព្រោះព្រះអង្គកម្ចាត់បង់នូវសេចក្តីមិនដឹង ព្រោះព្រះ អង្គបាននូវសេចក្តីត្រាស់ដឹង ។ ព្រះនាមថាព្រះពុទ្ធនោះ ព្រះមាតាមិនបានថ្វាយ ព្រះបិតាមិនបានថ្វាយ បងប្អូនប្រុសមិនបានថ្វាយ បងប្អូនស្រីមិនបានថ្វាយ ពួកមិត្តនិងអាមាត្យមិនបានថ្វាយ ពួកញាតិសាលោហិត មិនបានថ្វាយ ពួក សមណព្រាហ្មណ៍មិនបានថ្វាយ ពួកទេវតាមិនបានថ្វាយ ព្រះនាមថាព្រះពុទ្ធ នោះ ជាព្រះនាមមានក្នុងទីបំផុត នៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មាន ជោគ ការបញ្ញត្តិថា ព្រះពុទ្ធនេះ ( កើត ) ដោយការធ្វើឲ្យជាក់ច្បាស់ព្រម ដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ(លោក ពោលថា ) ចំពោះព្រះពុទ្ធនោះ ។

[ ១៩៦ ] ពាក្យថា ព្រះអង្គមិនអាស្រ័យ អធិប្បាយថា គ្រឿងអាស្រ័យ មាន ២ គ្រឿងអាស្រ័យគឺតណ្ហា ១ គ្រឿងអាស្រ័យគឺទិដ្ឋិ ១ ។

គ្រឿងអាស្រ័យគឺតណ្ហា តើដូចម្តេច ។ បុគ្គលប្រកាន់វត្ថុដែលខ្លួនធ្វើឲ្យ ជាសីមា ធ្វើឲ្យជាព្រំ ធ្វើឲ្យជាប្រទល់ដែន ធ្វើឲ្យជាទីបំផុត កាន់កាប់ ប្រកាន់

ដោយចំណែកតណ្ហាទាំងអម្បាលម៉ានថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណោះរបស់អញ អម្បាលម៉ាននេះរបស់អញ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ កម្រាល គ្រឿងដណ្តប់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែចម្ការ ប្រាក់ មាស ស្រុកនិគម រាជធានី ដែនជនបទ ឃ្លាំងនិងជង្រុករបស់អញសូម្បីការប្រកាន់នូវផែនដីធំទាំងមូលដោយអំណាចតណ្ហា ការប្រែប្រួលនៃតណ្ហា ១០៨ ទាំងអម្បាលម៉ាន នេះគ្រឿងអាស្រ័យ គឺតណ្ហា ។

គ្រឿងអាស្រ័យគឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ធម្មជាតិជំទាស់គឺទិដ្ឋិ ធម្មជាតិញាក់ញ័រគឺទិដ្ឋិ ។ គ្រឿងចងក្រៀកគឺទិដ្ឋិ កំណាន់ កំណាន់ស៊ុបសួន ការប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវគួរខ្ពើម ផ្លូវខុស សភាពខុស ទីដូចជាកំពង់ កំណាន់ដោយការស្វះស្វែងរកផ្សេងៗ កំណាន់ផ្ទុយ កំណាន់ប្រែប្រួល កំណាន់ខុស កំណាន់ថា មែនក្នុងវត្ថុដែលមិនមែន ទិដ្ឋិ ៦២ ទាំងអម្បាលម៉ាន នេះគ្រឿងអាស្រ័យ គឺទិដ្ឋិ ។

ព្រះពុទ្ធមានព្រះភាគ លះបង់គ្រឿងអាស្រ័យ គឺតណ្ហា រលាស់ចោលគ្រឿងអាស្រ័យគឺទិដ្ឋិហើយ ។ ព្រោះលះបង់គ្រឿងអាស្រ័យគឺតណ្ហា រលាស់ចោលគ្រឿងអាស្រ័យគឺទិដ្ឋិ ព្រះមានព្រះភាគមិនអាស្រ័យចក្ខុ មិនអាស្រ័យសោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត មិនអាស្រ័យ មិនស្អិត មិនចូលទៅជិត មិនជក់ចិត្ត មិនចុះចិត្ត ស្ទុះចេញ ខ្ជាតចេញ ឃ្លាតចេញ ប្រាសចេញ ចាករូប

សំឡេង ក្លិន រស ផោដ្ឋព្វ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវ-សញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ជាអតីត អនាគត បច្ចុប្បន្ន ធម៌ទាំងឡាយដែលខ្ញុំឃើញ ឮ ប៉ះពាល់ឬគប្បីដឹង មានព្រះទ័យសម្រេច សម្រាន្តនៅ ហេតុនោះ ( លោកពោលថា ) ព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ។

[ ១៩៧ ] ពាក្យថា ទ្រង់នឹងធឹង អធិប្បាយថា ព្រះមានព្រះភាគទ្រង់នឹងធឹងដោយអាការ ៥ យ៉ាង គឺទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ១ ទ្រង់នឹងធឹង ព្រោះព្រះអង្គបានលះ ១ ទ្រង់នឹងធឹង ព្រោះព្រះអង្គបានឆ្លង ១ ទ្រង់នឹងធឹងព្រោះព្រះអង្គបានរួច ១ ទ្រង់នឹងធឹងព្រោះការសម្តែងចេញនូវគុណនោះ ១ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹងក្នុងលាភផង ទ្រង់នឹងធឹងក្នុងការមិនមានលាភផង ទ្រង់នឹងធឹងក្នុងយសផង ទ្រង់នឹងធឹងក្នុងការមិនមានយសផង ទ្រង់នឹងធឹងក្នុងសេចក្តីសរសើរផង ទ្រង់នឹងធឹងក្នុងនិន្ទាផង ទ្រង់នឹងធឹងក្នុងសុខផង ទ្រង់នឹងធឹងក្នុងទុក្ខផង ។ បើពួកជនគប្បីលាបព្រះពាហាម្ខាង ដោយគ្រឿងក្រអូប គប្បីប្រាស់ព្រះពាហាម្ខាង ដោយកាំបិតព្រា ។ តម្រេកក្នុងការលាប ដោយគ្រឿងក្រអូបឯណោះមិនមាន សេចក្តីថ្នាំងថ្នាក់ក្នុងការប្រាស់ដោយកាំបិតព្រា

ឯណោះមិនមាន ។ ព្រះមានព្រះភាគ លះស្រឡះនូវសេចក្តីស្រឡាញ់ស្អិត និងសេចក្តីថ្នាំងថ្នាក់ កន្លងផុតនូវសេចក្តីកាន់ជើងនិងសេចក្តីផ្ចាញ់ផ្ចាល់ កន្លងផុតស្រឡះនូវសេចក្តីត្រូវចិត្តនិងសេចក្តីខុសចិត្ត ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹងក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹងព្រោះព្រះអង្គបានលះ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់បានលះ ខ្ជាក់ លែង កម្ចាត់ លះបង់រាគៈ ។ ទ្រង់បានលះ ខ្ជាក់ លែង កម្ចាត់ លះបង់ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ ការអន្ទះអន្ទែងទាំងអស់ ការក្តៅក្រហាយទាំងអស់ អភិសង្ខារជាអកុសលទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹងព្រោះព្រះអង្គបានលះយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹងព្រោះទ្រង់បានឆ្លង តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់បានឆ្លងកាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លង ឆ្លងផុត ឆ្លងរួច កន្លង កន្លងដោយប្រពៃ រំលងនូវផ្លូវសង្សារទាំងអស់ ។ ព្រះអង្គគង់នៅក្នុងអរិយវាសប្រព្រឹត្តចរណៈដើរហួសផ្លូវឆ្ងាយ គឺសង្សារ ដល់នូវទិស គឺ ( ព្រះនិព្វាន ) ដល់នូវទីបំផុត ( អនុបាទិសេសនិព្វាន ) រក្សាព្រហ្មចរិយៈ ដល់នូវទិដ្ឋិដ៏ឧត្តម ចម្រើនមគ្គ លះបង់កិលេស ចាក់ធ្លុះព្រះអរហត្តផលដែលមិនកម្រើក ធ្វើឲ្យច្បាស់លាស់នូវនិរោធ ។ ព្រះអង្គកំណត់ដឹងទុក្ខ លះបង់សមុទយៈ ចម្រើនមគ្គ ធ្វើឲ្យច្បាស់លាស់នូវនិរោធ ត្រាស់ដឹង

ធម៌ដែលត្រូវត្រាស់ដឹង កំណត់ធម៌ដែលត្រូវកំណត់ដឹង លះបង់ធម៌ដែលត្រូវលះបង់ ចម្រើនធម៌ដែលត្រូវចម្រើន ធ្វើឲ្យច្បាស់លាស់នូវធម៌ដែលត្រូវធ្វើឲ្យច្បាស់លាស់ ។ ព្រះអង្គដកគន្លឹះទ្វារគឺអវិជ្ជា កម្ចាត់ស្នាមភ្លោះគឺកម្មាភិសង្ខារ ដកសសរខឿនគឺតណ្ហា មិនមានសន្ទះទ្វារគឺឱរម្ភាគិយសំយោជនៈ ជាបុគ្គលបរិសុទ្ធ ទម្លាក់ទង់ជ័យគឺមានះហើយដាក់ភារៈគឺខន្ធជាដើម ប្រាសចាកយោគៈនិងកិលេស លះស្រឡះនូវអង្គ ៥ គឺនីវរណៈប្រកបអង្គ ៦ គឺឧបេក្ខា មានការឃុំគ្រងយ៉ាងឯកគឺសតិ មានអបស្សេនធម៌ ៤ បន្ទោបង់បច្ចេកសច្ចៈ មានការស្វែងរកគ្រប់យ៉ាង លះចោលហើយដោយប្រពៃ មានសង្កប្បៈមិនល្អក់ រម្ងាប់កាយសង្ខារ មានចិត្តរួចស្រឡះដោយល្អ មានបញ្ញារួចស្រឡះដោយល្អ មានគុណដ៏បរិបូណ៌ អប់រំព្រហ្មចរិយៈ ជាបុរសដ៏ខ្ពង់ខ្ពស់ ជាបុរសដ៏ក្រៃលែង ដល់ហើយនូវកិរិយាបាននូវអមតៈ ។ ព្រះអង្គឈប់កពូន ឈប់កម្ចាត់កម្ចាយ ឈ្មោះថាទ្រង់នឹងនួនព្រោះកម្ចាត់កម្ចាយ ( កិលេស ) ព្រះអង្គឈប់លះបង់ ឈប់ប្រកាន់មាំ ឈ្មោះថាទ្រង់នឹងនួនព្រោះលះបង់ ព្រះអង្គឈប់ចាក់ស្រែះ ឈប់ក្រអឺតក្រអោង ឈ្មោះថាទ្រង់នឹងនួនព្រោះមិនចាក់ស្រែះ ព្រោះឈប់រំលត់ ឈប់បង្កាត់ ឈ្មោះថាទ្រង់នឹងនួន ព្រោះរំលត់ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខសីលក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខសមាធិក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខបញ្ញាខន្ធ ឈ្មោះថាទ្រង់នឹងនួនព្រោះប្រកបដោយអសេក្ខវិមុត្តិក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះប្រកបដោយអសេក្ខវិមុត្តិញាណទស្សនក្ខន្ធ ឈ្មោះថាទ្រង់នឹងនួន ព្រោះ

ដឹងអរិយសច្ច ឈ្មោះថាទ្រង់នឹងនួនព្រោះកន្ទង ( តណ្ហាជាគ្រឿងញាប់ញ័រ ) យ៉ាងនេះឈ្មោះថាទ្រង់នឹងនួនព្រោះរំលត់ភ្លើង គឺកិលេស ឈ្មោះថាទ្រង់នឹងនួនព្រោះមិនមានការត្រឡប់វិញ ឈ្មោះថាទ្រង់នឹងនួនព្រោះចាប់កំពូល ( គឺជម្នះ ) បាន ឈ្មោះថាទ្រង់នឹងនួនព្រោះការសេពចំពោះនូវការរួច ឈ្មោះថាទ្រង់នឹងនួនព្រោះមេត្តាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួនព្រោះករុណាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួនព្រោះមុទិតាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួនព្រោះឧបេក្ខាដ៏បរិសុទ្ធ ឈ្មោះថាទ្រង់នឹងនួនព្រោះបរិសុទ្ធិយ៉ាងដាច់ខាត ឈ្មោះថាទ្រង់នឹងនួន ព្រោះបរិសុទ្ធិ មិនមានតណ្ហា ទិដ្ឋិ មានះ ឈ្មោះថាទ្រង់នឹងនួនព្រោះទ្រង់រួចស្រឡះ ( ចាកកិលេស ) ឈ្មោះថាទ្រង់នឹងនួនព្រោះជាអ្នកសន្តោស ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតខន្ធ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតធាតុ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតអាយតនៈ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតគតិ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតឧបបត្តិ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតបដិសន្ធិ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតភព ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតសង្សារ ឈ្មោះថាទ្រង់នឹងនួនក្នុងទីបំផុតវដ្តៈ ឈ្មោះថាទ្រង់នឹងនួនក្នុងភពចុងបង្អស់ ឈ្មោះថាទ្រង់នឹងនួនក្នុងសរីរៈចុងបង្អស់ គឺទ្រទ្រង់នូវសរីរចុងបង្អស់ រើចេញនូវដំណើរទៅកាន់ភពថ្មី ។

នេះជាភពចុងបង្អស់របស់ព្រះអង្គ នេះជាសរីរៈក្រោយបង្អស់
របស់ព្រះអង្គ ព្រះអង្គមិនមានជាតិ មរណៈ សង្សារនិងភពថ្មី
ទៀតទេ ។

ព្រះមានព្រះភាគទ្រង់នឹងធឹង ព្រោះបានចូងផុតយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះបានរូប តើដូចម្ដេច ។ ព្រះហឫទ័យរបស់ព្រះមានព្រះភាគរូប រូបស្រឡះ រូបផុតចាករាគៈ ។ ព្រះហឫទ័យរូប រូបស្រឡះ រូបផុតចាកទោសៈ ។ ព្រះហឫទ័យរូប រូបស្រឡះ រូបផុតចាកមោហៈ ។ ព្រះហឫទ័យរូប រូបស្រឡះ រូបផុតចាកកោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីអន្ទះអន្ទែងទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹងព្រោះបានរូបយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់នឹងធឹងព្រោះការសម្ដែងចេញនូវគុណនោះ តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់នឹងធឹង ព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើសីលមានទ្រង់ក៏មានសីល ទ្រង់នឹងធឹងព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើសទ្ធាមានទ្រង់ក៏មានសទ្ធា ទ្រង់នឹងធឹងព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើវីរិយៈមានទ្រង់ក៏មានវីរិយៈ ទ្រង់នឹងធឹង ព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើសតិមានទ្រង់ក៏មានសតិ ទ្រង់នឹងធឹង ព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើសមាធិមាន ទ្រង់ក៏តាំងព្រះហឫទ័យខ្ជាប់ ។ ទ្រង់នឹងធឹងព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើបញ្ញាមានទ្រង់ក៏មានបញ្ញា ទ្រង់នឹងធឹងព្រោះការសម្ដែងចេញនូវគុណនោះថា កាលបើវិជ្ជាមាន ទ្រង់ក៏មានត្រៃវិជ្ជា ទ្រង់នឹងធឹង ព្រោះការសម្ដែងចេញនូវ

គុណនោះថា កាលបើអភិញ្ញាមានទ្រង់ក៏មានអភិញ្ញា ៦ ទ្រង់នឹងជឹងព្រោះការសម្តែងចេញនូវគុណនោះថា កាលបើពលមានទ្រង់ក៏មានពល ១០ ។ ព្រះមានព្រះភាគទ្រង់នឹងជឹង ព្រោះការសម្តែងចេញនូវគុណនោះយ៉ាងនេះ ហេតុនោះ ( លោកពោលថា ) ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ទ្រង់នឹងជឹង ។

[ ១៩៨ ] អធិប្បាយពាក្យថា ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ត្រង់ពាក្យថា មិនកុហក សេចក្តីថា វត្ថុនៃការកុហកមាន ៣ គឺវត្ថុនៃការកុហក ចំណែកខាងការសេពបច្ច័យ ១ វត្ថុនៃការកុហក ចំណែកខាងឥរិយាបថ ១ វត្ថុនៃការកុហកចំណែកខាងការពោលក្នុងទីជិត ១ ។

វត្ថុនៃការកុហកចំណែកខាងការសេពបច្ច័យ តើដូចម្តេច ។ ពួកគហបតីក្នុងសាសនានេះ និមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ។ ភិក្ខុនោះមានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានសេចក្តីត្រូវការ អាស្រ័យសេចក្តីប្រាថ្នានូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារដ៏លើសលុប ហើយហាមឃាត់ចីវរ ហាមឃាត់បិណ្ឌបាត ហាមឃាត់សេនាសនៈ ហាមឃាត់គិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះបាននិយាយយ៉ាងនេះថា ស្រមណ៍មានប្រយោជន៍អ្វី ដោយចីវរមានថ្លៃច្រើន ឯការសមគួរនោះ ស្រមណ៍ត្រូវតែរើសសំពត់ ដែលមិនមានជាយទាំងឡាយអំពីព្រៃស្មសានឬអំពីគំនរសំរាម ឬក៏ដែលធ្លាក់ក្នុងចន្លោះផ្សារ យកមកធ្វើសង្ឃាដិប្រើប្រាស់ ស្រមណ៍មានប្រយោជន៍អ្វីដោយបិណ្ឌបាតមានថ្លៃច្រើន

ឯការសមគួរនោះ ស្រមណ៍ត្រូវតែចិញ្ចឹមជីវិតដោយពំនូតបាយដែលធ្វើឲ្យទៅជាដុំ ដោយការដើរទៅស្វែងរក ស្រមណ៍មានប្រយោជន៍អ្វីដោយសេនាសនៈមានថ្លៃច្រើន ឯការសមគួរនោះ ស្រមណ៍ត្រូវតែជាអ្នកនៅជិតដើមឈើ ឬនៅក្នុងព្រៃស្មសាន ពុំនោះសោតនៅក្នុងទីវាល ស្រមណ៍មានប្រយោជន៍អ្វីដោយគិលានប្បច្ចយភេសជ្ជបរិក្ខារមានថ្លៃច្រើន ឯការសមគួរនោះ ស្រមណ៍ត្រូវតែធ្វើថ្នាំដោយទឹកមូត្រស្អុយ ដោយចំណិតផ្លែសម៉ តាំងអំពីកាលនោះ ក៏ប្រើប្រាស់ចីវរសៅហ្មង បរិភោគបិណ្ឌបាតសៅហ្មង សេពសេនាសនៈសៅហ្មង សេពសោយគិលានប្បច្ចយភេសជ្ជបរិក្ខារ ដ៏សៅហ្មង ។ ពួកគហបតីដឹងភិក្ខុនោះយ៉ាងនេះថា ស្រមណ៍នេះមានសេចក្ដីប្រាថ្នាតិច ជាអ្នកសន្ដោស ស្ងប់ស្ងាត់ មិនប្របូកប្របល់ ផ្គងព្យាយាម ពោលធុតគុណ ដូច្នេះហើយក៏រឹងរឹតតែនិមន្តដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះបាននិយាយយ៉ាងនេះថា កុលបុត្តមានសទ្ធា បានបុណ្យច្រើន ព្រោះវត្ថុ ៣ ប្រការមានក្នុងទីចំពោះមុខ គឺកុលបុត្តមានសទ្ធាបានបុណ្យច្រើន ព្រោះសទ្ធាមានក្នុងទីចំពោះមុខ ១ កុលបុត្តមានសទ្ធាបានបុណ្យច្រើនព្រោះទេយ្យធម៌មានក្នុងទីចំពោះមុខ ១ កុលបុត្តមានសទ្ធាបានបុណ្យច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គលមានក្នុងទីចំពោះមុខ ១ សទ្ធារបស់ពួកអ្នកក៏មាន ទេយ្យធម៌ក៏មានព្រម អាត្មាក៏ជាអ្នកទទួល បើអាត្មានឹងមិនទទួល កាលបើយ៉ាងនេះ ពួកអ្នក មុខជាឃ្លាតឆ្ងាយចាកបុណ្យមិនខាន អាត្មាមិនមានសេចក្ដីត្រូវការដោយវត្ថុនេះទេ ប៉ុន្តែអាត្មាទទួលដើម្បីអនុគ្រោះដល់ពួកអ្នកទេតើ តាំងពីនោះ

មកភិក្ខុនោះទទួលចីវរក៏ច្រើន ទទួលបិណ្ឌបាតក៏ច្រើន ទទួលសេនាសនៈក៏ច្រើន ទទួលគិលានប្បច្ចយភេសជ្ជបរិក្ខារក៏ច្រើន ។ ការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការបំភាន់ អាការនៃការបំភាន់ ភាពនៃការបំភាន់ សភាពយ៉ាងនេះឯណា នេះលោកហៅថា វត្ថុនៃការកុហកចំណែកខាងការសេពបច្ច័យ ។

វត្ថុនៃការកុហកចំណែកខាងឥរិយាបថ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះមានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ប្រាថ្នាការសរសើរ ( គិត ) ថា អ្នកផងនឹងសរសើរអាត្មាអញយ៉ាងនេះហើយរៀបចំដំណើរ រៀបចំការឈរ រៀបចំការអង្គុយ រៀបចំការដេក ប្រុងចិត្តហើយទើបដើរ ប្រុងចិត្តហើយទើបឈរ ប្រុងចិត្តហើយទើបអង្គុយ ប្រុងចិត្តហើយទើបសម្រេចនូវការដេក ដើរធ្វើហាក់ដូចជាចូលកាន់សមាធិ ឈរធ្វើហាក់ដូចជាចូលកាន់សមាធិ អង្គុយធ្វើហាក់ដូចជាចូលកាន់សមាធិ សម្រេចការដេកធ្វើហាក់ដូចជាចូលកាន់សមាធិ ជាបុគ្គលហាក់ដូចជាចូលឈានក្នុងគន្លងចក្ខុ ( នៃអ្នកផង ) ។ កិរិយាផ្គូផ្គង កិរិយាតម្កល់ កិរិយារៀបចំនូវឥរិយាបថ កិរិយាធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន កិរិយាបំភាន់ អាការនៃការបំភាន់ ភាពនៃការបំភាន់ មានសភាពយ៉ាងនេះឯណា នេះលោកហៅថា វត្ថុនៃការកុហកចំណែកខាងឥរិយាបថ ។

វត្ថុនៃការកុហកចំណែកខាងការពោលក្នុងទីជិត តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ប្រាថ្នា

ការសរសើរ ( គិត ) ថា អ្នកផងទាំងសរសើរអាត្មាយ៉ាងនេះ ហើយពោលវាចាដែលអាស្រ័យព្រមនូវអរិយធម៌ គឺពោលថាស្រមណ៍ណាទ្រទ្រង់ចីវរមានសភាពយ៉ាងនេះ ស្រមណ៍នោះមានសក្តិធំ ពោលថាស្រមណ៍ណាទ្រទ្រង់បាត្រ ទ្រទ្រង់ផ្តិលលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់សំពត់តម្រងទឹក ទ្រទ្រង់កូនសោ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថុពន្ធចង្កេះ ទ្រទ្រង់សំពត់អាយោគ មានសភាពយ៉ាងនេះ ស្រមណ៍នោះមានសក្តិធំ ។ ពោលថាស្រមណ៍ណា មានឧបជ្ឈាយ៍បែបនេះ ស្រមណ៍នោះមានសក្តិធំ ។ ពោលថាស្រមណ៍ណា មានអាចារ្យ មានឧបជ្ឈាយ៍ស្មើគ្នា មានអាចារ្យស្មើគ្នា មានពួកមិត្ត មានពួកគៀនយ៉ាងជិតដិត យ៉ាងស្គាល់ស្មើរបែបនេះ ស្រមណ៍នោះមានសក្តិធំ ។ ពោលថាស្រមណ៍ណា នៅក្នុងវិហារបែបនេះ ស្រមណ៍នោះមានសក្តិធំ ។ ពោលថាស្រមណ៍ណានៅក្នុងបន្ទា នៅក្នុងប្រាសាទ នៅក្នុងផ្ទះមានជំបូលរលីង នៅក្នុងរូងភ្នំ នៅក្នុងទីសម្រាប់ជ្រកកោន នៅក្នុងកុដិ នៅក្នុងផ្ទះមានកំពូល នៅក្នុងប៉មនៅក្នុងផ្ទះមូល នៅក្នុងថែវ នៅក្នុងរោងឆាន់ នៅក្នុងបារាំ នៅក្នុងម្លប់ឈើបែបនេះ ស្រមណ៍នោះមានសក្តិធំ ។ មួយទៀតភិក្ខុធ្វើមុខស្រងូតស្រងាត់ ធ្វើមុខស្រពោនស្រពាប់ បំភាន់បំភាំង និយាយរាក់ទាក់ ត្រូវគេសរសើរដោយអំណាចមាត់ហើយក៏ពោលសម្តីដ៏ជ្រៅ កំបាំង ល្អិត ដ៏បិទបាំង ប្រកបព្រមដោយព្រះនិព្វាន ដែលជាលោកុត្តរធម៌ ប្រាកដដូចនោះថា ស្រមណ៍នេះជាអ្នកបានវិហារសមាបត្តិទាំងឡាយ ដ៏រម្ងាប់មានសភាពយ៉ាងនេះ ។ កិរិយាធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន កិរិយាបំភាន់ អាការនៃការបំភាន់ ភាព

នៃការបំភាន់ មានសភាពយ៉ាងនេះឯណា នេះលោកហៅថា វត្ថុនៃការកុហក ចំណែកខាងការពោលក្នុងទីជិត ។

វត្ថុនៃការកុហកទាំង ៣ នេះ ព្រះពុទ្ធមានជោគបានលះបង់ ក្បិលក្រំបែល រំលត់រំលាយ រំសាយរំសោះ ធ្វើមិនគួរឲ្យកើត បានដុតដោយភ្លើង គឺញាណហើយ ហេតុនោះ ព្រះពុទ្ធឈ្មោះថា ព្រះអង្គមិនកុហក ហេតុនោះ ( លោកពោលថា ) ព្រះអង្គមិនកុហក ។

[ ១៩៩ ] អធិប្បាយថា ពាក្យថា ព្រះអង្គជាមេពួក ទ្រង់យាងមក ត្រង់ពាក្យថា ព្រះអង្គជាមេពួក គឺព្រះមានព្រះភាគជាមេពួក ។ ព្រះមានព្រះភាគឈ្មោះថាមេពួក ព្រោះជាអាចារ្យរបស់ពួក ។ ឈ្មោះថាមេពួក ព្រោះជាគ្រូរបស់ពួក ។ ឈ្មោះថាមេពួក ព្រោះគ្រប់គ្រងពួក ។ ឈ្មោះថាមេពួក ព្រោះទូន្មានពួក ។ ឈ្មោះថាមេពួក ព្រោះប្រដែប្រដៅពួក ។ ឈ្មោះថាមេពួក ព្រោះក្លៀវក្លាចូលទៅកាន់ពួក ។ ឈ្មោះថាមេពួក ព្រោះពួកប្រាថ្នាដើម្បីស្តាប់ ផ្ទៀងសោតៈ តម្កល់ចិត្តដើម្បីដឹង ( ព្រះពុទ្ធដីកា ) របស់ព្រះអង្គ ។ ឈ្មោះថាមេពួក ព្រោះញុំាងពួកឲ្យចេញចាកអកុសល ហើយឲ្យតាំងនៅមាំក្នុងកុសល ។ ឈ្មោះថា មេពួករបស់ពួកភិក្ខុ ។ ឈ្មោះថា មេពួករបស់ពួកភិក្ខុនី ។ ឈ្មោះថាមេពួករបស់ពួកឧបាសក ។ ឈ្មោះថា មេពួករបស់ពួកឧបាសិកា ។ ឈ្មោះថាមេពួករបស់ពួកព្រះរាជា ។ ឈ្មោះថា មេពួករបស់ពួកក្សត្រ ។ ឈ្មោះថាមេពួករបស់ពួកព្រាហ្មណ៍ ។ ឈ្មោះថា មេពួករបស់ពួកវេស្សៈ ។ ឈ្មោះថាមេពួករបស់ពួកសុទ្ទៈ ។ ឈ្មោះថាមេពួករបស់ពួកព្រហ្ម ។ ឈ្មោះថា មេពួក

របស់ពួកទេវតា ។ ទ្រង់មានក្រុម មានពួក ជាអាចារ្យរបស់ពួកយាងមកហើយ ចូលមកជិតហើយ ចូលមកជិតព្រមហើយ ដល់ព្រមហើយនូវសង្កស្សនគរ ហេតុនោះ ( លោកពោលថា ) ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ។

[ ២០០ ] ពាក្យថា ដើម្បីពួកជនអ្នកជាប់ច្រើននាក់ក្នុងទីនេះ ត្រង់ពាក្យថា ច្រើននាក់ គឺដើម្បីពួកក្សត្រ ពួកព្រាហ្មណ៍ ពួកវេស្សៈ ពួកសុទ្ទៈ ពួកគ្រហស្ថ ពួកបព្វជិត ពួកទេវតា ពួកមនុស្សច្រើននាក់ ។ ពាក្យថា ដើម្បីពួកជនអ្នកជាប់ គឺដើម្បីពួកជនអ្នកជាប់ អ្នកប្រព្រឹត្តជាប់ អ្នកបម្រើ គឺដើម្បីពួកសិស្ស ហេតុនោះ ( លោកពោលថា ) ដើម្បីពួកជនអ្នកជាប់ដ៏ច្រើននាក់ក្នុងទីនេះ ។

[ ២០១ ] ពាក្យថា ខ្ញុំមកនឹងសួរប្រស្នា គឺខ្ញុំជាបុគ្គលមកហើយដោយត្រូវការប្រស្នា ខ្ញុំជាបុគ្គលចង់សួរប្រស្នា ទើបមក ជាបុគ្គលចង់ស្តាប់ប្រស្នាទើបមក ហេតុនោះ ( លោកពោលថា ) ខ្ញុំមកនឹងសួរប្រស្នាយ៉ាងនេះខ្លះ ។ មួយទៀតកិរិយាមក កិរិយាឈានទៅមុខ កិរិយាឈានចូលទៅជិត កិរិយាអង្គុយជិត នៃពួកជនដែលមានសេចក្តីត្រូវការដោយប្រស្នា នៃពួកជនអ្នកសួរប្រស្នា នៃពួកជនអ្នកចង់ស្តាប់ប្រស្នា ហេតុនោះ ( លោកពោលថា ) ខ្ញុំមកនឹងសួរប្រស្នាយ៉ាងនេះខ្លះ ។ មួយវិញទៀត ព្រះអង្គមានការមកដោយប្រស្នា ព្រះអង្គជាបុគ្គលអាចដើម្បីឲ្យខ្ញុំព្រះអង្គសួរ ដើម្បីសម្តែង ដើម្បីឆ្លើយ នេះជាភារៈរបស់ព្រះអង្គអ្នកសម្តែង ហេតុនោះ ( លោកពោលថា ) ខ្ញុំមកនឹងសួរ

ប្រស្នាយ៉ាងនេះខ្លះ ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ខ្ញុំមកនឹងសួរប្រស្នា ដើម្បីពួកជនអ្នកជាប់ច្រើននាក់ ក្នុងទីនេះ ចំពោះព្រះពុទ្ធអង្គនោះ ព្រះអង្គមិនអាស្រ័យ ទ្រង់នឹងធឹង ព្រះអង្គមិនកុហក ព្រះអង្គជាមេពួក ទ្រង់យាងមក ។

[ ២០២ ] ភិក្ខុខ្ពើមរអើមតែងគប់អាសនៈទទេ គឺគល់ឈើឬព្រៃស្មសាន ឬក្នុងរូងភ្នំទាំងឡាយ ។

[ ២០៣ ] អធិប្បាយពាក្យថា ភិក្ខុខ្ពើមរអើម ត្រង់ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬជាសេក្ខៈ ហេតុនោះ ( លោកពោលថា ) ភិក្ខុ ។ ពាក្យថា ខ្ពើមរអើម គឺខ្ពើមរអើមជាតិ ខ្ពើមរអើមជរា ព្យាធិ មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ សេចក្តីតូចចិត្ត សេចក្តីសង្រេងសង្រៃ ខ្ពើមរអើម ព្រួយចិត្ត អៀន ឆ្អើមទុក្ខដែលកើតក្នុងនរក ទុក្ខដែលកើតក្នុងកំណើតតិរច្ឆាន ទុក្ខដែលកើតក្នុងបិត្តិវិស័យ ទុក្ខដែលកើតក្នុងមនុស្ស ទុក្ខមានកិរិយាចូលកាន់គភ៌ជាដើមចម ទុក្ខមានកិរិយាស្ថិតនៅក្នុងគភ៌ជាដើមចម ទុក្ខមានកិរិយាចេញចាកគភ៌ជាដើមចម ទុក្ខដែលចូលទៅចងក្រៀកនូវសត្វដែលកើតហើយ ទុក្ខដែលជាប់តអំពីអ្នកដទៃនៃសត្វដែលកើតហើយ ទុក្ខដោយសេចក្តីព្យាយាមរបស់ខ្លួន ទុក្ខដោយសេចក្តីព្យាយាមរបស់គេ ទុក្ខដោយសេចក្តីលំបាក ទុក្ខដោយសង្ខារ ទុក្ខដោយការប្រែក្លាយ ទុក្ខដោយរោគភ្នែក ទុក្ខដោយរោគត្រចៀក ទុក្ខរោគដោយច្រមុះ ទុក្ខដោយរោគអណ្តាត ទុក្ខដោយរោគកាយ ទុក្ខដោយរោគក្បាល ទុក្ខដោយរោគត្រចៀក ទុក្ខដោយរោគមាត់

ទុក្ខដោយរោគធ្មេញ ក្អក ហឺត រោគប្រមុះ ក្តៅក្នុង គ្រាំគ្រា ឃ្លង់ ពក រោគក្នុងពោះ សន្លប់ សន្ធំ ចុះឈាម ចុកសៀត ចុះរាគរូស ស្រែង របេង ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតត្រង់កន្ទែងដែលខ្វារដោយក្រចក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះ ទឹកមូត្រផ្អែម ឫសដូងដុះ រលកកែវ ឫស ដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីសេម្ហ អាពាធកើតអំពីខ្យល់ អាពាធកើត អំពីប្រជុំខ្យល់ប្រមាត់និងស្លេស្ម អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតដោយការផ្លាស់ប្តូរ ឥរិយាបថមិនស្មើគ្នា អាពាធកើតដោយការ ព្យាយាម ( មានវាយនិងចងជាដើម ) អាពាធកើតដោយវិបាកនៃកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ជុះ នោម ទុក្ខ គឺសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅ ថ្ងៃនិងសត្វលូន ទុក្ខព្រោះមាតាស្លាប់ ទុក្ខព្រោះបិតាស្លាប់ ទុក្ខព្រោះបងប្អូន ប្រុសស្លាប់ ទុក្ខព្រោះបងប្អូនស្រីស្លាប់ ទុក្ខព្រោះកូនប្រុសស្លាប់ ទុក្ខព្រោះ កូនស្រីស្លាប់ ទុក្ខព្រោះវិនាសញាតិ ព្រោះវិនាសភោគៈ ព្រោះវិនាសគឺរោគ ព្រោះវិនាសសីល ព្រោះវិនាសទិដ្ឋិ ហេតុនោះ ( លោកពោលថា ) ភិក្ខុខ្ពឹម រអើម ។

[ ២០៤ ] ពាក្យថា តែងគប់អាសនៈទទេ សេចក្តីថា គេអង្គុយលើទីណា ទីនោះលោកហៅថា អាសនៈ គឺគ្រែ តាំង ពូក កន្ទេល កំណាត់ស្បែក កម្រាលស្មៅ កម្រាលស្លឹកឈើខ្ទិ កម្រាលស្លឹកឈើទុំ ។ អាសនៈនោះទទេ ស្ងាត់ ស្ងាត់សូន្យ ចាកការឃើញរូបមិនជាទីសប្បាយ ទទេ ស្ងាត់ ស្ងាត់សូន្យ ចាកការឮសំឡេងមិនជាទីសប្បាយ ។បេ។ ទទេ ស្ងាត់ ស្ងាត់សូន្យចាកកាម

គុណ ៥ មិនជាទីសប្បាយ ។ គប់ គប់ព្រម សេព សេពដោយអស់ជើង សេពព្រម សេពស៊ប់នូវអាសនៈនោះ ហេតុនោះ ( លោកពោលថា ) គប់អាសនៈទទេ ។

[ ២០៥ ] ពាក្យថា គល់ឈើ ឬព្រៃស្មសាន សេចក្តីថា គល់ឈើហ្នឹងឯងឈ្មោះថាគល់ឈើ ព្រៃស្មសានហ្នឹងឯងឈ្មោះថាព្រៃស្មសាន ហេតុនោះ ( លោកពោលថា ) គល់ឈើ ឬព្រៃស្មសាន ។

[ ២០៦ ] ពាក្យថា ឬក្នុងរូងភ្នំទាំងឡាយ សេចក្តីថា ភ្នំទាំងឡាយហ្នឹងឯងឈ្មោះថាភ្នំ ប្រកទាំងឡាយហ្នឹងឯង ឈ្មោះថាប្រកភ្នំ រូងភ្នំទាំងឡាយហ្នឹងឯងឈ្មោះថារូងភ្នំ ផ្ទៃភ្នំរបស់ភ្នំទាំងឡាយឈ្មោះថាចន្លោះភ្នំទាំងឡាយ ហេតុនោះ ( លោកពោលថា ) ឬក្នុងរូងភ្នំទាំងឡាយ ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ភិក្ខុខ្ជីមរអើមតែងគប់អាសនៈទទេ គឺគល់ឈើ ឬព្រៃស្មសាន
ឬក្នុងរូងភ្នំទាំងឡាយ ។

[ ២០៧ ] ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈខ្ពស់និងទាបនោះ ជាពួកសត្វដែលភិក្ខុមិនគប្បីរន្ធត់ក្នុងសយនាសនៈ មិនមានសំឡេងគឹកកង ។

[ ២០៨ ] ពាក្យថា ខ្ពស់និងទាប ក្នុងបទថា ក្នុងសយនៈខ្ពស់និងទាប គឺខ្ពស់និងទាប ថោកនិងថ្លៃ ល្អនិងអាក្រក់ ។ ពាក្យថា ក្នុងសយនៈ សេចក្តីថា សេនាសនៈលោកហៅថា សយនៈ គឺវិហារ បញ្ញា ប្រាសាទ ផ្ទះមានដំបូលរលីង រូងភ្នំ ហេតុនោះ ( លោកពោលថា ) ក្នុងសយនៈខ្ពស់និងទាប ។

[ ២០៩ ] ពាក្យថា ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈនោះ ត្រង់ពាក្យថា ស្រែក គឺស្រែកសន្ធាប់ បន្លឺ ធ្វើសំឡេង ។ មួយទៀតមានប៉ុន្មានប៉ុន្មាន មានប្រមាណប៉ុន្មាន មានកំណត់ប៉ុន្មាន ច្រើនប៉ុន្មាន ។

ពាក្យថា ពួកសត្វគួរខ្លាច គឺពួកសីហៈ ខ្លាធំ ខ្លាដំបង ខាឃ្មុំ ខ្លារខិន ឆ្កែព្រៃ គោ ក្របី ដំរី ពស់ ខ្យួយ ក្អែប ពួកចោរ ឬពួកមាណពមានការងារធ្វើហើយក្តី មានការងារមិនទាន់ធ្វើហើយក្តី ហេតុនោះ ( លោកពោលថា ) ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈនោះ ។

[ ២១០ ] ពាក្យថា ជាពួកសត្វ ដែលភិក្ខុមិនគប្បីរន្ធត់ ត្រង់ពាក្យថា ដែលភិក្ខុ បានសេចក្តីថា ភិក្ខុមិនគប្បីរន្ធត់ មិនគប្បីញាប់ញ័រ មិនគប្បីញាប់ញ័រព្រម មិនគប្បីតក់ស្លុត មិនគប្បីស្ញូន់ស្ញោ មិនគប្បីឡើងឡង់ មិនគប្បីខ្លាច មិនគប្បីដល់នូវការស្ញប់ស្ញែង គប្បីជាបុគ្គលមិនខ្លាច មិនរន្ធត់ មិនស្ញូន់ មិនរត់ លះបង់សេចក្តីខ្លាចនិងសេចក្តីចំប្រប់ ប្រាសចាកសេចក្តីព្រឺព្រួចនៃរោម ព្រោះពួកសត្វគួរខ្លាច គឺព្រោះឃើញឬព្រោះឮនូវពួកសត្វគួរខ្លាច ហេតុនោះ ( លោកពោលថា ) ជាពួកសត្វដែលភិក្ខុមិនគប្បីរន្ធត់ ។

[ ២១១ ] ពាក្យថា ក្នុងសយនាសនៈ មិនមានសំឡេងគឹកកង គឺក្នុងសេនាសនៈមិនមានសំឡេង មិនមានសំឡេងគឹកកង ប្រាសចាកខ្យល់កាយរបស់ជន គួរដល់សេចក្តីស្ងាត់របស់មនុស្ស គួរដល់សេចក្តីសម្ងំ ហេតុនោះ ( លោកពោលថា ) ក្នុងសយនាសនៈមិនមានសំឡេងគឹកកង ។ ហេតុនោះព្រះសារីបុត្តត្ថេរពោលថា

ពួកសត្វគួរខ្លាច ស្រែកក្នុងសយនៈខ្ពស់និងទាបនោះ ជាពួកសត្វដែលភិក្ខុមិនគប្បីរន្ធត់ ក្នុងសយនាសនៈ មិនមានសំឡេងតឹកកង ។

[ ២១២ ] ភិក្ខុគប្បីគ្របសង្កត់ពួកបរិស្សយ ( អន្តរាយ ) ណា ក្នុងសយនាសនៈទីបំផុត បរិស្សយ ( ទាំងនោះ ) ក្នុងលោករបស់ភិក្ខុ ទៅកាន់ទិសដែលមិនដែលទៅ តើមានប៉ុន្មាន ។

[ ២១៣ ] អធិប្បាយថា ពាក្យថា បរិស្សយទាំងឡាយក្នុងលោក តើមានប៉ុន្មាន ត្រង់ពាក្យថា តើមានប៉ុន្មាន គឺមានប៉ុន្មាន មានប្រមាណប៉ុន្មាន មានកំណត់ប៉ុន្មាន ច្រើនប៉ុន្មាន ។ ពាក្យថា បរិស្សយទាំងឡាយ គឺបរិស្សយមាន ២ គឺបាកដបរិស្សយ ( អន្តរាយប្រាកដ ) ១ បដិច្ឆន្នបរិស្សយ ( អន្តរាយកំបាំង ) ១ ។

ពួកបាកដបរិស្សយ តើដូចម្តេច ។ ពួកសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ឆ្កែព្រៃ គោ ក្របី ដំរី ពស់ ខ្យ ក្អែប ពួកចោរ ឬមាណពមានការងារធ្វើហើយក្តី មានការងារមិនទាន់ធ្វើហើយក្តី រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត រោគប្រមុះ រោគក្តៅក្នុង រោគគ្រាំគ្រា រោគក្នុងពោះ សន្ទប់ សន្និ បុះឈាម បុកសៀត រាករូស ឃ្លង់ ពក ស្រែង របេងឆ្កួតជ្រូក ដំនួចពិស រមាស់ កម រោគកើតត្រង់កន្ទែងដែលខ្វារដោយក្រចកឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះ ទឹកមូត្រផ្អែម ឫសដូងដុះ រលកកែវ ឫស

ដូងបាត ពួកអាពាធកើតអំពីប្រមាត់ ពួកអាពាធកើតអំពីស្លេស្ម ពួកអាពាធកើតអំពីខ្យល់ ពួកអាពាធកើតដោយការប្រជុំ ( ខ្យល់ប្រមាត់និងស្លេស្ម ) ពួកអាពាធកើតអំពីការប្រែប្រួលរដូវ ពួកអាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើ ពួកអាពាធកើតដោយការព្យាយាមរបស់អ្នកដទៃ ពួកអាពាធកើតដោយវិបាកនៃកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃនិងសត្វលូន ទាំងនេះលោកហៅថា ពួកបាកដបរិស្សយៈដូច្នេះខ្លះ ។ ពួកបដិច្ឆន្នបរិស្សយៈ តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ទាំងនេះលោកហៅថា ពួកបដិច្ឆន្នបរិស្សយៈ ។

សំណួរត្រង់ពាក្យថា បរិស្សយៈ ចុះបរិស្សយៈ តើដោយសេចក្តីដូចម្តេច ។ បរិស្សយៈ ព្រោះហេតុគ្របសង្កត់ ។ បរិស្សយៈ ព្រោះហេតុប្រព្រឹត្តទៅព្រមដើម្បីសេចក្តីសាបសូន្យ ។ បរិស្សយៈព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ ។

បរិស្សយៈ ព្រោះហេតុគ្របសង្កត់ តើដូចម្តេច ។ បរិស្សយៈទាំងនោះរមែងសង្កត់ គ្របសង្កត់ បង្ក្រប រួបរឹត ក្តោបញាំញីបុគ្គលនោះ ។ បរិស្សយៈព្រោះហេតុគ្របសង្កត់យ៉ាងនេះ ។

បរិស្សយៈ ព្រោះហេតុប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ តើដូចម្តេច ។ បរិស្សយៈទាំងនោះ រមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ ដើម្បីអន្តរាយនៃកុសលធម៌ទាំងឡាយ ។ ពួកកុសលធម៌ តើដូចម្តេច ។ ( ពួកបរិស្សយៈ ) រមែងប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យ ដើម្បីអន្តរាយនៃកុសលធម៌ទាំងនេះ គឺសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា កិរិយាធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយ កិរិយាគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ កិរិយាដឹងប្រមាណក្នុងភោជន កិរិយាប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក កិរិយាប្រកបរឿយៗក្នុងការនានូវសតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ កិរិយាប្រកបរឿយៗក្នុងការនានូវសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ បរិស្សយៈ ព្រោះហេតុប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីសាបសូន្យយ៉ាងនេះ ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ តើដូចម្តេច ។ ពួកអកុសលធម៌ដ៏អាក្រក់នេះអាស្រ័យព្រមនូវអត្តភាព កើតក្នុងអត្តភាពនោះ ។ ពួកសត្វអាស្រ័យរូងដេកក្នុងរូង ពួកសត្វអាស្រ័យទឹកដេកក្នុងទឹក ពួកសត្វអាស្រ័យព្រៃដេកក្នុងព្រៃ ពួកសត្វអាស្រ័យដើមឈើ ដេកលើដើមឈើយ៉ាងណាមិញ ពួកអកុសលធម៌ដ៏អាក្រក់នេះ អាស្រ័យព្រមនូវអត្តភាព កើតក្នុងអត្តភាពនោះ យ៉ាងនោះដែរ បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះយ៉ាងនេះដូច្នេះខ្លះ ។

សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខមិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យ រមែងនៅជាទុក្ខមិនសប្បាយ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ដ៏អាក្រក់ជាតម្រិះដោយអំណាចកិរិយាអន្ទោលទៅ (ក្នុងអារម្មណ៍ផ្សេងៗ) ជាគ្រឿងទំនុកបម្រុងរបស់សំយោជនៈ កើតដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ពួកអកុសលធម៌ដ៏អាក្រក់នោះ នៅជាប់ជិតជាមខាងក្នុងនៃភិក្ខុនោះ ហេតុនោះតថាគតហៅភិក្ខុនោះថា អ្នកនៅរួមនឹងសិស្ស ពួកអកុសលធម៌ដ៏អាក្រក់នោះ ត្រួតត្រានូវភិក្ខុនោះ ហេតុនោះតថាគតហៅ ភិក្ខុនោះថា អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃនៅមានទៀត ពួកអកុសលធម៌ដ៏អាក្រក់ ជាតម្រិះកើតដោយអំណាចកិរិយាអន្ទោលទៅ ជាគ្រឿងទំនុកបម្រុងនៃសំយោជនៈ កើតដល់ភិក្ខុព្រោះឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ក្រេបជញ្ជក់រសដោយអណ្ដាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ពួកអកុសលធម៌ដ៏អាក្រក់នោះ រមែងនៅជាប់ជិតជាមខាងក្នុងភិក្ខុនោះ ហេតុនោះតថាគតហៅភិក្ខុនោះថា អ្នកនៅរួមនឹងសិស្ស ពួកអកុសលធម៌ដ៏អាក្រក់នោះត្រួតត្រាភិក្ខុនោះ ហេតុនោះតថាគតហៅភិក្ខុនោះថា អ្នកនៅរួមនឹងអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមនឹងសិស្ស អ្នកនៅរួមនឹងអាចារ្យជាទុក្ខ មិនសប្បាយយ៉ាងនេះឯង ។ បរិស្សយៈព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។

មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ពួកមន្ទិលខាងក្នុង ពួកខ្មាំងខាងក្នុង ពួកអ្នកមានពៀរខាងក្នុង ពួកអ្នកសម្លាប់ខាងក្នុង ពួកបច្ចាមិត្តខាងក្នុង នេះមាន ៣ ចុះមាន ៣ គឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកមានពៀរខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈជាមន្ទិលខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកមានពៀរខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ មោហៈជាមន្ទិលខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកមានពៀរខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាបច្ចាមិត្តខាងក្នុង ម្នាលភិក្ខុទាំងឡាយ ពួកមន្ទិលខាងក្នុង ពួកខ្មាំង ខាងក្នុង ពួកអ្នកមានពៀរខាងក្នុង ពួកបច្ចាមិត្តខាងក្នុង មាន ៣ យ៉ាងនេះឯង ។

លោភៈឲ្យកើតវិនាស លោភៈបណ្តាលឲ្យចិត្តកម្រើក ភ័យកើតហើយក្នុងខាងក្នុង អ្នកផងមិនដឹងនូវភ័យនោះ ជនល្មោភរមែងមិនស្គាល់ផល ជនល្មោភរមែងមិនឃើញហេតុ ងងឹតឈឹងតែងមានក្នុងកាលដែលលោភៈគ្របសង្កត់នរៈ ទោសៈឲ្យកើតវិនាស ទោសៈបណ្តាលឲ្យចិត្តកម្រើក ភ័យកើតហើយក្នុងខាងក្នុង អ្នកផងមិនដឹងនូវភ័យនោះ ជនខឹងរមែងមិនស្គាល់ផល ជនខឹងរមែងមិនឃើញហេតុ ងងឹតឈឹងតែងមានក្នុងកាលដែលកោធៈគ្របសង្កត់នរៈ មោហៈឲ្យកើតវិនាស មោហៈបណ្តាលឲ្យចិត្តកម្រើក ភ័យកើតហើយក្នុងខាងក្នុង អ្នកផង

មិនដឹងនូវភ័យនោះ ជនរនៀងនរមែងមិនស្គាល់ផល ជនរនៀង
រមែងមិនឃើញហេតុ ងងឹតឈឹងតែងមានក្នុងកាល ដែល
មោហៈគ្របសង្កត់នរៈ ។

បរិស្សយៈព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្វះ ។

មួយវិញទៀត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា បពិត្រ មហារាជ ពួកធម៌ ៣ កាលដែលកើតខាងក្នុងនៃបុរស ក៏កើតដើម្បីមិនឲ្យមាន សេចក្តីចម្រើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល ពួកធម៌ ៣ គឺអ្វីខ្វះ បពិត្រ មហារាជ លោភៈជាធម៌កាលដែលកើតឡើងក្នុងសន្តាននៃបុរស ក៏កើតឡើង ដើម្បីមិនឲ្យមានសេចក្តីចម្រើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល បពិត្រ មហារាជ ទោសៈជាធម៌កាលដែលកើតឡើងក្នុងសន្តាននៃបុរស ក៏កើតឡើង ដើម្បីមិនឲ្យមានសេចក្តីចម្រើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល បពិត្រ មហារាជ មោហៈជាធម៌កាលដែលកើតឡើងក្នុងសន្តាននៃបុរស ក៏កើតឡើង ដើម្បីមិនឲ្យមានសេចក្តីចម្រើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល បពិត្រ មហារាជ ពួកធម៌ ៣ នេះឯងកាលដែលកើតឡើងក្នុងសន្តាននៃបុរស ក៏កើត ឡើង ដើម្បីមិនឲ្យមានសេចក្តីចម្រើន ដើម្បីឲ្យលំបាក ដើម្បីឲ្យនៅមិនស្រួល។

លោភៈ ទោសៈនិងមោហៈ កកើតអំពីចិត្តតែងបៀតបៀនបុរស
ដែលមានចិត្តអាក្រក់ ដូចដើមឫស្សីស្លាប់ដោយសារផ្លែរបស់
ខ្លួន ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះយ៉ាងនេះខ្វះ ។

មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា

រាគៈនិងទោសៈ មានអត្តភាពនេះជាដើមទង សេចក្ដីអផ្សុក
សេចក្ដីត្រេកអរនិងសេចក្ដីព្រឺព្រួចរោម កើតអំពីអត្តភាពនេះ
សេចក្ដីជញ្ជឹង ក្នុងចិត្តទាំងឡាយ តាំងឡើងអំពីអត្តភាពនេះ
ហើយលែង ( នូវចិត្ត ) ដូចពួកក្មេងតូចលែងក្អែក ។

បរិស្សយៈ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។ ពាក្យថា ក្នុងលោក គឺក្នុងមនុស្សលោក ហេតុនោះ ( លោកពោលថា ) បរិស្សយៈទាំងឡាយ ក្នុងលោកមានប៉ុន្មាន ។

[ ២១៤ ] ពាក្យថា ទៅកាន់ទិសដែលមិនដែលទៅ សេចក្ដីថា អមត និព្វានលោកហៅថា ទិសដែលមិនដែលទៅ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលនូវឧបធិទាំងពួង ការអស់តណ្ហា ការរសាយ ការរលត់ ព្រះនិព្វាន ។ ទិសដែលមិនដែលទៅ មិនធ្លាប់ទៅដោយកាលដ៏អង្វែងនេះ ។ បុគ្គលប្ដូមនូវភាជន៍ប្រេងដែលពេញស្មើ មិនហៀរហូរយ៉ាងណា បុគ្គលកាល ប្រាថ្នានូវទិសដែលមិនធ្លាប់ទៅ ត្រូវឃុំគ្រងចិត្តរបស់ខ្លួន យ៉ាងនោះ ។ កាល ដល់ កាលទៅ កាលឈានទៅ កាន់ទិសដែលមិនធ្លាប់ទៅ ហេតុនោះ ( លោក ពោលថា ) ទៅកាន់ទិសដែលមិនដែលទៅ ។

[ ២១៥ ] ពាក្យថា ភិក្ខុគប្បីគ្របសង្កត់ ពួកបរិស្សយៈណា គឺគប្បី គ្របសង្កត់ គប្បីគ្រប គប្បីសង្រ្គប គប្បីបង្រ្គប គប្បីញាំញីនូវពួកបរិស្សយៈ ណា ហេតុនោះ ( លោកពោលថា ) ភិក្ខុគប្បីគ្របសង្កត់ពួកបរិស្សយៈ

ណា ។

[ ២១៦ ] ពាក្យថា ក្នុងសយនាសនៈទីបំផុត គឺក្នុងសេនាសនៈទីបំផុត ខាងចុង ខាងចុងបង្អស់ គឺទីបំផុតភូមិក្តី ទីបំផុតព្រៃក្តី ទីបំផុតទឹកក្តី ទីបំផុតទន្លេក្តី បានដល់ទីដែលគេមិនភ្ជួរ មិនសាបព្រោះ មិនមែនជាឧបចារៈរបស់ពួកមនុស្ស កន្លងនូវទីបំផុតនៃជន ហេតុនោះ ( លោកពោលថា ) ក្នុងសយនាសនៈទីបំផុត ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ភិក្ខុគប្បីគ្របសង្កត់ពួកបរិស្សយៈណា ក្នុងសយនាសនៈទីបំផុត បរិស្សយៈទាំងនោះក្នុងលោក របស់ភិក្ខុទៅកាន់ទិសដែលមិនដែលទៅ តើមានប៉ុន្មាន ។

[ ២១៧ ] ភិក្ខុមានចិត្តបញ្ជូនទៅហើយនោះ ត្រូវមានសម្តីដូចម្តេច ភិក្ខុនោះ ត្រូវមានគោចរដូចម្តេចក្នុងសាសនានេះ ត្រូវមានសីលនិងវត្តដូចម្តេច ។

[ ២១៨ ] ពាក្យថា ត្រូវមានសម្តីដូចម្តេច គឺព្រះសារីបុត្តត្ថេរ សួរនូវវចីបារិសុទ្ធិថា ភិក្ខុគប្បីប្រកបដោយសម្តីប្រាកដដូចម្តេច មានទ្រង់ទ្រាយដូចម្តេច មានបែបដូចម្តេច មានយ៉ាងដូចម្តេច ។

វចីបារិសុទ្ធិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះលះបង់មុសាវាទ ជាអ្នកវៀរស្រឡះចាកមុសាវាទ ពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលបំភាន់សត្វលោក លះបង់បិសុណាវាចា ជាអ្នកវៀរស្រឡះចាកបិសុណាវាចា គឺឮអំពីពួកជននេះមិនប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះមិនប្រាប់ដល់ពួកជននេះដើម្បី

បំបែកពួកជនឯណោះ ជាអ្នកបង្រួបបង្រួមពួកជនដែលបែកគ្នាហើយ ជាអ្នកឲ្យកម្លាំងដល់ពួកជនដែលស្រុះស្រួលគ្នាហើយ មានសេចក្តីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងការព្រមព្រៀង ពោលវាចាដែលធ្វើឲ្យព្រមព្រៀងគ្នាដោយប្រការដូច្នេះ លះបង់ផរុសវាចា ជាអ្នកវៀរស្រឡះចាកផរុសវាចា វាចាណាដែលជាសម្តីឥតមានទោស ស្រួលដល់ត្រចៀក គួរឲ្យស្រឡាញ់ពេញហឫទ័យ ជាសម្តីរបស់អ្នកក្រុង ជាទីត្រេកអរដល់ជនច្រើននាក់ ពេញចិត្តដល់ជនច្រើននាក់ តែងពោលតែវាចាបែបនោះឯង លះបង់សម្ផប្បលាបៈ ជាអ្នកវៀរស្រឡះចាកសម្ផប្បលាបៈ ពោលក្នុងកាលគួរ ពោលពាក្យពិត ពោលអត្ថ ពោលធម៌ ពោលវិន័យ ពោលពាក្យជាទីតម្កល់ទុកក្នុងហឫទ័យតាមកាល ប្រកបដោយគ្រឿងអាង មានគ្រឿងកំណត់ប្រកបដោយប្រយោជន៍ ប្រកបដោយវចីសុចរិត ៤ ពោលវាចា ប្រាសចាកទោស ៤ គប្បីជាអ្នកតម វៀរ វៀរស្រឡះចេញ ខ្ជាត ឃ្លាត ប្រាសចេញចាកតិរច្ឆានកថា ៣២ នៅដោយចិត្តដែលធ្វើឲ្យប្រាសចាកដែន ពោលកថាវត្ថុ ១០ គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា សតិប្បដ្ឋានកថា សម្មប្បធានកថា ឥទ្ធិបាទកថា ឥន្ទ្រិយកថា ពលកថា ពោជ្ឈង្គកថា មគ្គកថា ផលកថា និព្វានកថា ជាអ្នកប្រុងប្រយ័ត្ន រវាំង គ្របគ្រង ឃុំគ្រងរក្សា សង្រួមដោយវាចានេះវចីបារិសុទ្ធិ ។ គប្បីជាអ្នកប្រកបដោយវចីបារិសុទ្ធិប្រាកដដូច្នេះ ហេតុនោះ ( លោកពោលថា ) ត្រូវមានសម្តីដូចម្តេច ។

*[ ២១៩ ] ពាក្យថា ភិក្ខុនោះត្រូវមានគោចរដូចម្ដេច ក្នុងសាសនានេះ គឺព្រះសារីបុត្តត្ថេរ សួរគោចរថា ( ភិក្ខុនោះ ) គប្បីជាអ្នកប្រកបដោយគោចរប្រាកដដូចម្ដេច មានទ្រង់ទ្រាយដូចម្ដេច មានបែបដូចម្ដេច មានយ៉ាងដូចម្ដេច ។ អគោចរក៏មាន គោចរក៏មាន ។*

*អគោចរ តើដូចម្ដេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកត្រាច់ទៅកាន់ផ្ទះស្ត្រីពេស្យា ជាអ្នកត្រាច់ទៅកាន់ផ្ទះស្ត្រីមេម៉ាយ ជាអ្នកត្រាច់ទៅកាន់ផ្ទះស្ត្រីក្រមុំចាស់ ជាអ្នកត្រាច់ទៅកាន់សម្នាក់មនុស្សខ្ទើយ ជាអ្នកត្រាច់ទៅកាន់សម្នាក់ភិក្ខុនី ជាអ្នកត្រាច់ទៅកាន់រោងស្រា នៅប្រឡូកប្រឡល់នឹងពួកព្រះរាជា ពួកមហាមាត្យរបស់ព្រះរាជានិងពួកតិរ្ថិយ និងពួកសាវកនៃតិរ្ថិយ និងការប្រឡូកប្រឡល់ដោយគ្រហស្ថ មិនត្រូវទំនង សេពគប់ ចូលទៅអង្គុយជិតពួកត្រកូលមិនមានជំនឿ មិនជ្រះថ្លា មិនមែនជាអណ្ដូង ជាអ្នកជេរជំលាប ប្រាថ្នាការមិនចម្រើន ប្រាថ្នាការមិនជាប្រយោជន៍ ប្រាថ្នាការមិនស្រួល ប្រាថ្នាការមិនក្សេមចាកយោគៈដើម្បីពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នេះហៅថា អគោចរ ។ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់ មិនសង្រួម ដើរទៅក្រឡេកមើលដំរី មើលសេះ មើលរថ មើលពលថ្មើរជើង មើលពួកស្ត្រី មើលពួកប្រុស មើលពួកក្មេងប្រុស មើលពួកក្មេងស្រី មើលចន្លោះផ្សារ មើលទ្វារផ្ទះ មើលលើ មើលក្រោម មៀងមើលទិសនិងទិសតូចៗ ដើរទៅ នេះក៏ហៅថា អគោចរដែរ ។ មួយទៀត ភិក្ខុឃើញរូបដោយចក្ខុ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏អាក្រក់ គឺអភិជ្ឈានិងទោមនស្ស*

គប្បីជិតជាមជាប់តាមភិក្ខុនេះព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រិយណា ។បេ។ មិនសង្រួមមនិន្ទ្រិយ មិនប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយ នេះក៏ហៅថា អគោចរដែរ ។ ពុំនោះសោត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ គឺរាំ ច្រៀង ប្រគំ មហោស្រព និយាយរឿង គង រគាំង ស្គរមានជ្រុង ៤ រូបគំនូរ ល្បែងដំដែក ល្បែងរ៉ាវ ល្បែងលាងឆ្អឹង ប្រជល់ដំរី ប្រខាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់ពពែ ប្រជល់កែះ ប្រជល់មាន់ ប្រជល់ចាប ល្បែងគុណដំបង ប្រដាល់ ចំបាប់ ទីសម្រាប់ច្បាំងគ្នា ទីសម្រាប់រៀបពលលំនៅកងទ័ព ទីសម្រាប់មើលសេនាប្រកបដោយអង្គ ៤ ជាអ្នកប្រកបរឿយៗនូវការមើលល្បែងដែលជាសត្រូវដល់កុសលធម៌មានសភាពយ៉ាងនេះដូច្នេះៗខ្លះ នេះក៏ហៅថា អគោចរដែរ ។ សូម្បីតែកាមគុណទាំង ៥ ក៏ឈ្មោះថា អគោចរ ។ សមដូចព្រះតម្រាស់នេះដែលព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំប្រព្រឹត្តក្នុងអគោចរដែលជាវិស័យនៃសត្រូវ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ប្រព្រឹត្តក្នុងអគោចរ ដែលជាវិស័យនៃសត្រូវ មារនឹងបានចន្លោះ មារនឹងបានអារម្មណ៍ ម្នាលភិក្ខុទាំងឡាយ អគោចររបស់ភិក្ខុដែលជាវិស័យនៃសត្រូវគឺអ្វី គឺកាមគុណទាំង ៥ កាមគុណទាំង ៥ តើដូចម្តេចខ្លះ គឺរូបទាំងឡាយដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទី

ប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល សំឡេងទាំងឡាយដែលគប្បីដឹងច្បាស់ដោយត្រចៀក ក្លិនទាំងឡាយដែលគប្បីដឹងច្បាស់ដោយច្រមុះ រសទាំងឡាយដែលគប្បីដឹងច្បាស់ដោយអណ្ដាត ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាមគួរឲ្យត្រេកត្រអាល ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អគោចររបស់ភិក្ខុដែលជាវិស័យនៃសត្រូវ ។ នេះក៏លោកហៅថា អគោចរដែរ ។

គោចរ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនត្រាច់ទៅកាន់សម្នាក់ស្ត្រីពេស្យា មិនត្រាច់ទៅកាន់សម្នាក់ស្ត្រីមេម៉ាយ មិនត្រាច់ទៅកាន់សម្នាក់ស្ត្រីក្រមុំចាស់ មិនត្រាច់ទៅកាន់សម្នាក់មនុស្សខ្ទើយ មិនត្រាច់ទៅកាន់សម្នាក់ភិក្ខុនី មិនត្រាច់ទៅកាន់រោងស្រា មិននៅច្របូកច្របល់នឹងពួកព្រះរាជានិងពួកមហាមាត្យរបស់ព្រះរាជានិងពួកតិរ្ថិយ និងពួកសាវកតិរ្ថិយ និងការច្របូកច្របល់ដោយគ្រហស្ថមិនត្រូវទំនង សេពគប់ ចូលទៅអង្គុយជិតនឹងពួកត្រកូលដែលមានជំនឿជ្រះថ្លា ជាអណ្ដូងចិញ្ចែងចិញ្ចាច ដោយកាសាវភស្ត្រ សាយកាយដោយខ្យល់ឥសី ប្រាថ្នាសេចក្ដីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្ដីស្រួល ប្រាថ្នាសេចក្ដីក្សេមចាកយោគៈ ដើម្បីពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា នេះហៅថា គោចរ ។ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរតាមថ្នល់សន្រ្ទួមដើរទៅ មិនក្រឡេកមើលដំរី មិនមើលសេះ មិនមើលរថ មិនមើល

ពលថ្មើរជើង ។បេ។ មិនមៀងមើលទិសនិងទិសតៀង ដើរទៅ នេះក៏ហៅថា គោចរដែរ ។ មួយវិញទៀត ភិក្ខុឃើញរូបដោយចក្ខុ ជាអ្នកមិនកាន់យកនូវនិមិត្ត ។បេ។ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ នេះហៅថា គោចរដែរ ។ ពុំនោះសោតដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ មិនប្រកបរឿយៗ នូវការមើលល្បែងដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ គឺល្បែងរាំ ច្រៀង ប្រគំ ។បេ។ ទីសម្រាប់មើលសេនាប្រកបដោយអង្គ ៤ ជាអ្នកវៀរស្រឡះ ចាកកិរិយាប្រកបរឿយៗ នូវការមើលល្បែងដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះឯង នេះក៏ហៅថា គោចរដែរ ។ សូម្បីសតិប្បដ្ឋានទាំង ៤ ក៏ឈ្មោះថា គោចរដែរ ។ សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តក្នុងគោចរ ដែលជាវិស័យរបស់បិតាខ្លួន ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ប្រព្រឹត្តក្នុងគោចរ ដែលជាវិស័យរបស់បិតាខ្លួន មារនឹងមិនបានចន្លោះ មារនឹងមិនបានអារម្មណ៍ ម្នាលភិក្ខុទាំងឡាយ គោចរដែលជាវិស័យរបស់បិតាខ្លួនគឺអ្វី គឺសតិប្បដ្ឋាន ៤ ចុះសតិប្បដ្ឋាន ៤ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមដុតកម្តៅកិលេស ដឹងខ្លួន មានស្មារតីកម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ( ជាអ្នកឃើញរឿយៗនូវវេទនា ) ក្នុងវេទនាទាំងឡាយ ( ជាអ្នកឃើញរឿយៗនូវចិត្ត ) ក្នុងចិត្ត ជាអ្នកឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយ

មានព្យាយាមដុតកម្តៅកិលេស ដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា គោចរដែលជាវិស័យរបស់បិតាខ្លួន ។ នេះក៏លោកហៅថា គោចរដែរ ។ ភិក្ខុគប្បីជាអ្នកប្រកបដោយគោចរប្រាកដដូច្នេះ ហេតុនោះ ( លោកសួរថា ) ភិក្ខុនោះមានគោចរដូចម្តេច ក្នុងសាសនានេះ ។

[ ២២០ ] ពាក្យថា ត្រូវមានសីលនិងវត្តដូចម្តេច គឺព្រះសារីបុត្តត្ថេរសួរសីលព្វតបារិសុទ្ធិថា គប្បីជាអ្នកប្រកបដោយសីលនិងវត្តប្រាកដដូចម្តេច មានទ្រង់ទ្រាយដូចម្តេច មានបែបដូចម្តេច មានយ៉ាងដូចម្តេច ។

សីលព្វតបារិសុទ្ធិ តើដូចម្តេច ។ សីលផង វត្តផងក៏មាន វត្តមិនមែនសីលក៏មាន ។

សីលផង វត្តផង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារនិងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ ត្រឹមតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សេចក្តីរវាំង សេចក្តីសង្រួម សេចក្តីមិនប្រព្រឹត្តល្មើសណាក្នុងសិក្ខាបទទាំងនោះ នេះសីល ។ ការសមាទានណា ការសមាទាននោះជាវត្ត ។ ឈ្មោះថា សីល ដោយសេចក្តីថា សង្រួម ឈ្មោះថា វត្ត ដោយសេចក្តីថា សមាទាន ។ នេះលោកហៅថា សីលផង វត្តផង ។

វត្តមិនមែនសីល តើដូចម្តេច ។ ធុតង្គ ៨ គឺអារញ្ញិកង្គៈ បិណ្ឌបាតិកង្គៈ បំសុកូលិកង្គៈ តេចីវរិកង្គៈ សពទានចារិកង្គៈ ខលុបច្ឆាភត្តិកង្គៈ នេសជ្ជិកង្គៈ

យថាសន្ថតិកង្គៈ នេះលោកហៅថា វត្តមិនមែនសីល ។ វីរិយសមាទានក៏លោកហៅថាឲ្យវត្តមិនមែនសីល ។ ភិក្ខុផ្គង តម្កល់ចិត្តថា ស្បែក សរសៃនិងឆ្អឹងចូរសល់នៅតាមប្រាថ្នាចុះ សាច់និងឈាមចូររីងស្ងួតក្នុងសរីរៈចុះ គុណជាតិណាដែលគេគប្បីសម្រេចដោយកម្លាំងកាយនៃបុរស ដោយកម្លាំងប្រាជ្ញានៃបុរស ដោយការព្យាយាមនៃបុរស ដោយសេចក្តីប្រឹងប្រែងនៃបុរស ការមិនទាន់សម្រេចនូវគុណជាតិនោះទេ នឹងមិនឈប់ព្យាយាមឡើយ វីរិយសមាទានមានសភាពយ៉ាងនេះលោកហៅថា វត្តមិនមែនសីល ។ ភិក្ខុផ្គងតម្កល់ចិត្តថា អាត្មាអញនឹងមិនបរិភោគ នឹងមិនផឹក នឹងមិនចេញអំពីវត្ត នឹងមិនទម្រេតបើព្រួញគឺតណ្ហា អាត្មាអញដកមិនទាន់រួចទេ វីរិយសមាទាន មានសភាពយ៉ាងនេះលោកហៅថា វត្តមិនមែនសីល ។ ភិក្ខុផ្គងតាំងចិត្តថា ចិត្តរបស់អាត្មាអញមិនទាន់រួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់មាំដរាបណា អាត្មាអញនឹងមិនទម្លាយភ្នែនចេញដរាបនោះ វីរិយសមាទានមានសភាពយ៉ាងនេះ លោកហៅថា វត្តមិនមែនសីល ។ ភិក្ខុផ្គងតម្កល់ចិត្តថា ចិត្តរបស់អាត្មាអញ បើមិនទាន់រួចស្រឡះចាកអាសវៈព្រោះមិនប្រកាន់មាំដរាបណា អាត្មាអញនឹងមិនក្រោកចាកអាសនៈនេះ មិនចុះអំពីទីចង្ក្រម មិនចេញអំពីវត្ត មិនចេញអំពីអឌ្ឍយោគ មិនចេញអំពីប្រាសាទ មិនចេញអំពីប្រាសាទត្រងិល មិនចេញអំពីគុហា មិនចេញអំពីទីពួន មិនចេញអំពីកុដិ មិនចេញអំពីផ្ទះកំពូល មិនចេញអំពីប៉ម មិនចេញអំពីរោង មិនចេញអំពីទីអាស្រ័យ មិនចេញអំពីរោងឆាន់ មិនចេញអំពីមណ្ឌប មិនចេញអំពីគល់ឈើដរាបនោះ វីរិយសមាទានមានសភាពយ៉ាង

នេះ លោកហៅថា វត្តមិនមែនសីល ។ ភិក្ខុផ្គងតម្កល់ចិត្តថា ក្នុងបុព្វណ្ហ-សម័យនេះឯង អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវអរិយធម៌ឲ្យទាល់តែបាន វីរិយសមាទាន មានសភាព យ៉ាងនេះ លោកហៅថា វត្តមិនមែនសីល ។ ភិក្ខុផ្គងតម្កល់ចិត្តថា ក្នុងវេលា ថ្ងៃត្រង់នេះឯង ក្នុងវេលាថ្ងៃរសៀល ក្នុងវេលាមុនបាយ ក្នុងវេលាក្រោយបាយ ក្នុងយាមដើមដំបូង ក្នុងយាមកណ្តាល ក្នុងយាមខាងក្រោយ ក្នុងកាលខាង រនោច ក្នុងកាលខាងខ្នើត ក្នុងរដូវភ្លៀង ក្នុងរដូវត្រជាក់ ក្នុងរដូវក្តៅ ក្នុង វ័យខាងដំបូង ក្នុងវ័យខាងកណ្តាលនេះ ក្នុងវ័យខាងខាងក្រោយ អាត្មា អញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ ច្បាស់នូវអរិយធម៌ឲ្យទាល់តែបាន វីរិយសមាទានមានសភាពយ៉ាងនេះ លោក ហៅថា វត្តមិនមែនសីល ។ នេះសីលពូតបារិសុទ្ធិ ។ ភិក្ខុគប្បីជាអ្នកប្រកប ដោយសីលពូតបារិសុទ្ធិប្រាកដដូច្នេះ ហេតុនោះ ( លោកសួរថា ) ត្រូវមាន សីលនិងវត្តដូចម្តេច ។

[ ២២១ ] អធិប្បាយពាក្យថា ភិក្ខុមានចិត្តបញ្ជូនទៅ ត្រង់ពាក្យថា មាន ចិត្តបញ្ជូនទៅ គឺមានសេចក្តីព្យាយាមតឹងតែង មានកម្លាំងចិត្ត មានសេចក្តី ប្រឹងប្រែងដ៏មុតមាំ មានឆន្ទៈមិនដាក់ចុះ មានធុរៈមិនដាក់ចុះ ក្នុងកុសលធម៌ ទាំងឡាយ ។ មួយទៀត មានចិត្តបញ្ជូនទៅ បានដល់ខ្លួននៃបុគ្គលដែលបញ្ជូន ចិត្តទៅក្នុងប្រយោជន៍ខ្លួនផង ក្នុងធម៌គួរដឹងផង ក្នុងលក្ខណៈផង ក្នុងហេតុផង ក្នុងហេតុគួរ ឬមិនគួរផង ។ មានចិត្តបញ្ជូនទៅថា សង្ខារទាំងពួងមិនទៀង ។

មានចិត្តបញ្ជូនទៅថា សង្ខារទាំងពួងជាទុក្ខ ។ មានចិត្តបញ្ជូនទៅថា ធម៌ទាំងពួងមិនមែនខ្លួន ។ មានចិត្តបញ្ជូនទៅថា សង្ខារ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ មានចិត្តបញ្ជូនទៅថា ជរាមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ។ មានចិត្តបញ្ជូនទៅថា ការរលត់សង្ខារ ព្រោះរលត់អវិជ្ជា ។បេ។ មានចិត្តបញ្ជូនទៅថា ការរលត់ជរាមរណៈ ព្រោះរលត់ជាតិ ។ មានចិត្តបញ្ជូនទៅថា នេះទុក្ខ ។បេ។ មានចិត្តបញ្ជូនទៅថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ មានចិត្តបញ្ជូនទៅថា នេះអាសវៈ ។បេ។ មានចិត្តបញ្ជូនទៅថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់អាសវៈ ។ មានចិត្តបញ្ជូនទៅថា ធម៌ទាំងឡាយនេះគួរដឹងច្បាស់ ។បេ។ មានចិត្តបញ្ជូនទៅថាធម៌នេះគួរធ្វើឲ្យជាក់ច្បាស់ ។ មានចិត្តស្ទុងទៅកាន់ការកើត ការរលត់ អានិសង្ស ទោសនិងការលាស់ចេញនៃផស្សាយតនៈ ៦ ។ មានចិត្តស្ទុង ទៅកាន់ការកើត ការវិនាស អានិសង្ស ទោសនិងការលាស់ចេញនៃឧបាទានក្ខន្ធទាំង ៥ ផង នៃមហាភូតរូបទាំង ៤ ផង ។ មានចិត្តបញ្ជូនទៅថា របស់ណាមានការកើតជាធម្មតា របស់ទាំងអស់នោះមានការរលត់ជាធម្មតា ។ ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ហេតុនោះ ( លោកសួរថា ) ភិក្ខុមានចិត្តបញ្ជូនទៅ ។ ហេតុនោះព្រះសារីបុត្តពោលថា

> ភិក្ខុមានចិត្តបញ្ជូនទៅហើយនោះត្រូវមានសម្តីដូចម្តេច ភិក្ខុនោះ
> ត្រូវមានគោចរដូចម្តេច ក្នុងសាសនានេះ ត្រូវមានសីលនិងវត្ត
> ដូចម្តេច ។

[ ២២២ ] ភិក្ខុនោះសមាទានសិក្ខាដូចម្តេច មានចិត្តខ្ពស់ឯក មានប្រាជ្ញា មានស្មារតី ( ដូចម្តេច ) ទើបកម្ចាត់បង់មន្ទិលរបស់ខ្លួនបាន ដូចជាងលោហៈ ដេញមន្ទិលប្រាក់ ។

[ ២២៣ ] ពាក្យថា ភិក្ខុនោះ សមាទានសិក្ខាដូចម្តេច គឺភិក្ខុនោះកាន់ សមាទាន កាន់យក កួចកាន់ បបោសអង្អែល ប្រកាន់ស្អិតនូវសិក្ខាដូចម្តេច ហេតុនោះ ( លោកសួរថា ) ភិក្ខុនោះសមាទានសិក្ខាដូចម្តេច ។ ពាក្យថា មានចិត្តខ្ពស់ឯក មានប្រាជ្ញា មានស្មារតី ត្រង់ពាក្យថា មានចិត្តខ្ពស់ឯក គឺមានចិត្តមានអារម្មណ៍តែមួយ មានចិត្តមិនរវើរវាយ មានចិត្តមិនរសេមរសាម ហេតុនោះ ( លោកសួរថា ) មានចិត្តខ្ពស់ឯក ។ ពាក្យថា មានប្រាជ្ញា គឺមានប្រាជ្ញាចាស់ ជាបណ្ឌិត មានប្រាជ្ញា មានការដឹង មានញាណ មានការភ្លឺច្បាស់ មានប្រាជ្ញាកម្ចាត់បង់កិលេស ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺមានស្មារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវកាយក្នុងកាយ មានស្មារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ មានស្មារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវចិត្តក្នុងចិត្ត មានស្មារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ។ ភិក្ខុនោះហៅថា អ្នកមានស្មារតី ។ ត្រង់ពាក្យថា ភិក្ខុនោះសមាទានសិក្ខា ដូចម្តេច គឺលោកសួរ អធិសីលសិក្ខា ។ ត្រង់ពាក្យថា មានចិត្តខ្ពស់ឯក គឺលោកសួរ អធិចិត្តសិក្ខា ។ ត្រង់ពាក្យថា មានប្រាជ្ញា គឺលោកសួរអធិប្បញ្ញាសិក្ខា ។ ត្រង់ពាក្យថា មានស្មារតី គឺលោកសួរសតិបារិសុទ្ធិ ហេតុនោះ ( លោកសួរថា )

ភិក្ខុនោះមានចិត្តខ្ពស់ឯក មានប្រាជ្ញា មានស្មារតី សមាទានសិក្ខាដូចម្តេច ។

[ ២២៤ ] ពាក្យថា ទើបកម្ចាត់បង់មន្ទិលរបស់ខ្លួនបាន ដូចជាងលោហៈដែលដេញមន្ទិលប្រាក់ អធិប្បាយថា ជាងមាស លោកហៅថា ជាងលោហៈ ។ ជាតរូប លោកហៅថា ប្រាក់ ។ ជាងមាសកម្ចាត់ ដុសខាត់ ដេញមន្ទិលប្រាក់ដ៏គ្រោតគ្រាតផង កម្ចាត់ ដុសខាត់ ដេញមន្ទិលធុនកណ្តាលផង កម្ចាត់ ដុសខាត់ ដេញមន្ទិលធុនល្អិតផង មានឧបមាយ៉ាងណា ភិក្ខុកម្ចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវកិលេសគ្រោតគ្រាតរបស់ខ្លួនផង កម្ចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវកិលេសជាកណ្តាលផង កម្ចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវកិលេសដ៏ល្អិតផង ក៏មានឧបមេយ្យយ៉ាងនោះឯង ។ មួយទៀត ភិក្ខុកម្ចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវមន្ទិលគឺរាគៈ មន្ទិលគឺទោសៈ មន្ទិលគឺមោហៈ មន្ទិលគឺមានះ មន្ទិលគឺទិដ្ឋិ មន្ទិលគឺកិលេស មន្ទិលគឺទុច្ចរិតរបស់ខ្លួនជាកិលេស ជាតិធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណជាគ្រឿង ធ្វើឲ្យរលត់បញ្ញា ជាកិលេសជាតិប្រព្រឹត្តទៅក្នុងពួកធម៌ធ្វើឲ្យចង្អៀតចង្អល់ចិត្ត ប្រព្រឹត្តទៅក្នុងទីមិនមែនជាព្រះនិព្វាន ។ មួយទៀត ភិក្ខុកម្ចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវមិច្ឆាទិដ្ឋិ ដោយសម្មាទិដ្ឋិ កម្ចាត់ ដុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវមិច្ឆាសង្កប្ប ដោយសម្មាសង្កប្ប នូវ

មិច្ឆាវាចា ដោយសម្មាវាចា នូវមិច្ឆាកម្មន្តៈដោយសម្មាកម្មន្តៈ នូវមិច្ឆាអាជីវៈ ដោយសម្មាអាជីវៈ នូវមិច្ឆាវាយាមៈដោយសម្មាវាយាមៈ នូវមិច្ឆាសតិដោយ សម្មាសតិ នូវមិច្ឆាសមាធិដោយសម្មាសមាធិ នូវមិច្ឆាញាណ ដោយសម្មា-ញាណ នូវមិច្ឆាវិមុត្តិដោយសម្មាវិមុត្តិ ។ មួយវិញទៀត ភិក្ខុកម្ចាត់ ជុសខាត់ ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវកិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីក្រហល់ក្រហាយទាំងអស់ អភិសង្ខារជាអកុសលទាំងអស់ ដោយអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ ( លោកសួរថា ) ទើបកម្ចាត់បង់មន្ទិលរបស់ខ្លួនបាន ដូចជាងលោហៈដេញមន្ទិលប្រាក់ ។ ហេតុនោះ ព្រះសារីបុត្តត្ថេរពោលថា

ភិក្ខុនោះសមាទានសិក្ខាដូចម្តេច មានចិត្តខ្ពស់ឯក មានប្រាជ្ញា
មានស្មារតី ( ដូចម្តេច ) ទើបកម្ចាត់បង់មន្ទិលរបស់ខ្លួនបាន
ដូចជាងលោហៈដេញមន្ទិលប្រាក់ ។

[ ២២៥ ] ( ព្រះមានព្រះភាគត្រាស់តបថា ម្នាលសារីបុត្ត ) ការសប្បាយណា របស់ភិក្ខុកាលខ្ពើមរអើមសេពទីអង្គុយ ទីដេកដ៏ស្ងាត់ មានបំណងនូវសម្ពោធិញ្ញាណតាមលំដាប់ធម៌ តថាគតនឹងប្រាប់ការសប្បាយនោះ ដល់អ្នកតាមទំនងដែលតថាគតដឹង ។

[ ២២៦ ] អធិប្បាយពាក្យថា ការសប្បាយណារបស់ភិក្ខុកាលខ្ពើមរអើម ត្រង់ពាក្យថា កាលខ្ពើមរអើម គឺខ្ពើមរអើមព្រោះជាតិ ព្រោះជរា ព្រោះព្យាធិ

ព្រោះមរណៈ ព្រោះសោក ព្រោះសេចក្តីខ្សឹកខ្សួល ព្រោះទុក្ខ ព្រោះតូចចិត្ត ព្រោះសេចក្តីតានតឹង ។បេ។ ខ្ពើមរអើម ជិនឆ្អន់ នឿយណាយ ព្រោះទុក្ខគឺវិនាសទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) កាលខ្ពើមរអើម ពាក្យថា ការសប្បាយណា សេចក្តីថា ការសប្បាយ ការនៅសប្បាយណា តថាគតនឹងសម្តែងនូវការនៅសប្បាយនោះ ។ ការនៅសប្បាយ តើដូចម្តេច ។ ការប្រតិបត្តិដោយប្រពៃ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនជាសត្រូវ ការប្រតិបត្តិតាមលំដាប់ប្រយោជន៍ ការប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ភាពជាអ្នកបំពេញក្នុងសីល ភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវការភ្ញាក់រឭក សតិសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ និព្វាននិងបដិបទា ជាដំណើរទៅកាន់ព្រះនិព្វាន នេះឈ្មោះថា ការនៅសប្បាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ការសប្បាយណារបស់ភិក្ខុកាលខ្ពើមរអើម ។

[ ២២៧ ] ពាក្យថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត គឺទ្រង់ហៅព្រះថេរៈនោះតាមនាម ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យនិយាយដោយគោរព ។ មួយទៀតព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បោលនូវរាគៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បោលទោសៈ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បោលមោហៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បោលមានះ ។ ព្រះនាមថា ព្រះមានព្រះភាគព្រោះហេតុទ្រង់បំបាក់បោលទិដ្ឋិ ។ ព្រះនាមថាព្រះមានព្រះ

ភាគ ព្រោះហេតុទ្រង់បំបាក់ចោលកិលេសដូចបទ□ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ចោលកិលេស ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះ ហេតុទ្រង់ចែករំលែក បំបែកនូវធម្មរតនៈ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះអង្គធ្វើនូវទីបំផុតនៃភព ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គមានកាយអប់រំហើយ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុព្រះអង្គមានសីលអប់រំហើយ ព្រោះព្រះអង្គមានព្រះទ័យអប់រំហើយ ព្រោះព្រះអង្គមានប្រាជ្ញាអប់រំហើយ ។ មួយទៀតព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុព្រះ មានបុណ្យទ្រង់គប់រកព្រៃតូចនិងព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ មានសំឡេងតិច មានសូរកង់រំពងតិច ប្រាសចាកខ្យល់ដែលកើត (អំពីសរីរៈមនុស្ស) ជាទីគួរដល់ការកំបាំងអំពីមនុស្ស សមគួរដល់ការពួនសម្ងំ ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគចីវរ បិណ្ឌបាត សេនាសនៈនិងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យនៃអ្នកជំងឺ ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរសធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀត ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបាន-

ស្សតិសមាធិ អសុកសមាបត្តិ ។ មួយទៀតព្រះនាមថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានបុណ្យទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុ ព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថា ព្រះមានព្រះភាគនេះមិន មែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្ត អាមាត្យថ្វាយ មិនមែនពួកញាតិ សាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយ ព្រះនាមថាព្រះមានព្រះភាគនេះ មានក្នុងទីបំផុតនៃវិមោក្ខ របស់ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ការបញ្ញត្តថាព្រះមានព្រះភាគនេះ កើតដោយការធ្វើ ឲ្យជាក់ច្បាស់ព្រមទាំងការបាន ចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ព្រោះហេតុនោះ ( លោកពោលថា ) ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត ។

[ ២២៨ ] ពាក្យថា សេពនូវទីអង្គុយ ទីដេកដ៏ស្ងាត់ អធិប្បាយថា គេអង្គុយលើទីណា ទីនោះលោកហៅថា ទីអង្គុយ គឺគ្រែ តាំង ពូក កន្ទេល ចម្មខ័ណ្ឌ កម្រាលស្មៅ កម្រាលស្លឹក កម្រាលចំបើង ។ ទីសេនាសនៈ គឺវិហារ អឌ្ឍយោគ ប្រាសាទ ប្រាសាទត្រងិល គុហា លោកហៅថា ទីដេក ។ ទីដេកទីអង្គុយដ៏ស្ងាត់ ស្ងាត់ឈឹង ស្ងាត់ជ្រងំ ចាកការឃើញរូប មិនជាទីសប្បាយ ចាកការឮសំឡេង មិនជាទីសប្បាយ ។បេ។ ដ៏ស្ងាត់ ស្ងាត់ឈឹង

ស្ងាត់ជ្រងំ ចាកកាមគុណ ៥ មិនជាទីសប្បាយ ។ កាលគប់ គប់រក សមគប់ គប់ស្និទ្ធ នូវទីដេកទីអង្គុយដ៏ស្ងាត់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេពនូវទីអង្គុយ ទីដេកដ៏ស្ងាត់ ។

[ ២២៩ ] ពាក្យថា មានបំណងនូវសម្ពោធិញ្ញាណ តាមលំដាប់ធម៌ សេចក្តីថា ការដឹង បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា សម្ពោធិ ។ មានបំណងដើម្បីត្រាស់ដឹង មានបំណងដើម្បីត្រាស់ដឹងតាម មានបំណងដើម្បីត្រាស់ដឹងចំពោះ មានបំណងដើម្បីត្រាស់ដឹងព្រម មានបំណងដើម្បីបាន មានបំណងដើម្បីពាល់ត្រូវ មានបំណងដើម្បីធ្វើឲ្យជាក់ច្បាស់នូវសម្ពោធិញ្ញាណនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានបំណងដើម្បីសម្ពោធិញ្ញាណ ។ សំណួរត្រង់ពាក្យថា តាមលំដាប់ធម៌ ចុះតាមលំដាប់ធម៌នៃពោធិញ្ញាណ តើដូចម្តេច ។ ការប្រតិបត្តិដោយប្រពៃ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនជាសត្រូវ ការប្រតិបត្តិតាមលំដាប់ប្រយោជន៍ ការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ភាពជាអ្នកបំពេញក្នុងសីល ភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវសេចក្តីភ្ញាក់រឭក សតិសម្បជញ្ញៈ ធម៌ទាំងនេះ លោកហៅថា តាមលំដាប់ធម៌នៃពោធិញ្ញាណ ។ មួយទៀត វិបស្សនាក្នុងចំណែកខាងដើមនៃមគ្គ ៤ នេះលោកហៅថា តាមលំដាប់ធម៌នៃពោធិញ្ញាណ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មានបំណងនូវពោធិញ្ញាណ តាមលំដាប់ធម៌ ។

[ ២៣០ ] អធិប្បាយពាក្យថា តថាគតនឹងប្រាប់ការសប្បាយនោះ ដល់

អ្នកតាមទំនង ដែលតថាគតដឹង ត្រង់ពាក្យថា ការសប្បាយនោះ គឺធម៌ជាលំដាប់នៃពោធិញ្ញាណ ។ ពាក្យថា តថាគតនឹងប្រាប់ គឺតថាគតនឹងពោលប្រាប់ ចង្អុល បង្ហាញ សម្តែង ធ្វើឲ្យដឹងច្បាស់ តាំងផ្តើមបើក បែក ធ្វើឲ្យរាក់ ប្រកាស ។ ពាក្យថា តាមទំនងដែលតថាគតដឹង គឺតថាគតកាលដឹង យល់ ចូលចិត្ត ដឹង ប្រាកដ ចាក់ធ្លុះយ៉ាងណា នឹងសម្តែងនូវធម៌នោះ យ៉ាងនោះ ដោយខ្លួនឯង ជាធម៌ដឹងចំពោះខ្លួនឯង ប្រាកដចំពោះខ្លួន មិនមែនដោយយល់ថា យ៉ាងនេះយ៉ាងនោះទេ មិនមែនតាមឮថាដូច្នេះ មិនមែនឮតៗគ្នាមកទេ មិនមែនដោយការប្រកាន់តាមក្បួន មិនមែនដោយការប្រកាន់តាមត្រិះរិះ មិនមែនដោយការប្រកាន់តាមន័យ មិនមែនត្រិះរិះដោយអាការៈ មិនមែនដោយការពិចារណាតាមការគួរដោយទិដ្ឋិទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតនឹងប្រាប់ការសប្បាយនោះដល់អ្នក តាមទំនងដែលតថាគតដឹង ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

> ( ព្រះមានព្រះភាគត្រាស់តបថា ម្នាលសារីបុត្ត ) ការសប្បាយ
> ណា របស់ភិក្ខុកាលខ្ពើមរអើមសេពទីអង្គុយ ទីដេកដ៏ស្ងាត់
> មានបំណងនូវសម្ពោធិញ្ញាណតាមលំដាប់ធម៌តថាគតនឹងប្រាប់
> ការសប្បាយនោះដល់អ្នកតាម ទំនងដែលតថាគតដឹង ។

[ ២៣១ ] ភិក្ខុជាធីរៈ មានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ មិនគប្បីខ្លាចចំពោះភ័យ ៥ យ៉ាង គឺរបោម មមាច ពស់ សម្ផស្សរបស់មនុស្ស និងសត្វចតុប្បាទ ។

[ ២៣២ ] ពាក្យថា ធីរៈ ក្នុងបទថា ធីរៈមិនគប្បីខ្លាចចំពោះភ័យ ៥ យ៉ាង បានដល់ ធីរៈ បណ្ឌិត អ្នកមានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានការភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងកម្ចាត់បង់នូវកិលេស ។ ភិក្ខុជាធីរៈមិនគប្បីខ្លាច មិនគប្បីតក់ស្លុត មិនគប្បីរន្ធត់ មិនគប្បីស្ញុំស្ញែង មិនគប្បីដល់នូវសេចក្ដីតក់ស្លុត មិនគប្បីជាអ្នកស្ញុំ មិនញាប់ញ័រ មិនតក់ស្លុត មិនរត់ចេញ លះបង់នូវសេចក្ដីខ្លាចនិងសេចក្ដីភ្ញាក់ ជាអ្នកប្រាសចាកសេចក្ដីព្រឺរោមចំពោះភ័យ ៥ យ៉ាង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុជាធីរៈ មិនគប្បីខ្លាចចំពោះភ័យ ៥ យ៉ាង ។

[ ២៣៣ ] អធិប្បាយពាក្យថា ភិក្ខុមានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ ត្រង់ពាក្យថា ភិក្ខុ បានដល់ ភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ។ ពាក្យថា មានស្មារតី បានដល់ ភិក្ខុមានស្មារតីដោយហេតុ ៤ គឺ មានស្មារតី ចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវកាយក្នុងកាយ មានស្មារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវវេទនាក្នុងវេទនា មានស្មារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវចិត្តក្នុងចិត្ត មានសារតីចម្រើនសតិប្បដ្ឋាន ជាគ្រឿងពិចារណានូវធម៌ក្នុងធម៌ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្តធម៌ ប្រកបដោយទីបំផុតជុំវិញ បានដល់ ទីបំផុតជុំវិញ ៤ គឺទីបំផុតជុំវិញដោយការសង្រួមសីល ១ ទីបំផុតជុំវិញដោយការសង្រួមឥន្ទ្រិយ ១ ទីបំផុតជុំវិញដោយការដឹងប្រមាណក្នុងភោជន ១ ទីបំផុតជុំវិញដោយការប្រកបរឿយៗនូវការភ្ញាក់រឭក ១ ។

ទីបំផុតជុំវិញដោយការសង្រួមសីល តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរសីល បរិបូណ៌ដោយអាចារនិង គោចរ ឃើញភ័យក្នុងទោសមានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខា-បទទាំងឡាយ ពិចារណាឃើញច្បាស់ នូវភាពស្អុយក្នុងខាងក្នុង ប្រព្រឹត្តក្នុង ទីបំផុតជុំវិញដោយការសង្រួមសីលក្នុងខាងក្នុង មិនទម្លាយនូវខេត្តដែន ( នៃ សីល ) នេះទីបំផុតជុំវិញ ដោយការសង្រួមសីល ។

ទីបំផុតជុំវិញដោយការសង្រួមឥន្ទ្រិយ តើដូចម្តេច ។ ភិក្ខុក្នុងសាសនា នេះ ឃើញរូបដោយភ្នែក ជាអ្នកមិនកួចកាន់នូវនិមិត្ត មិនកួចកាន់នូវអនុព្យ-ញ្ជនៈ ធម៌ជាអកុសល ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជិតជាមតាម បុគ្គលមិនសង្រួមនូវចក្ខុន្ទ្រិយ ព្រោះការមិនសង្រួមចក្ខុន្ទ្រិយណាជាហេតុ ប្រ-តិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធរសដោយអណ្តាត ប៉ះពាល់ សម្ផស្សដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនកួចកាន់ នូវនិមិត្ត មិនកួចកាន់នូវអនុព្យញ្ជនៈ ធម៌ជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស មិនជិតជាមតាមបុគ្គលមិនសង្រួមមនិន្ទ្រិយ ព្រោះការមិនសង្រួមមនិន្ទ្រិយណា ជាហេតុ ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួម ក្នុងមនិន្ទ្រិយ ពិចារណានូវអាទិត្តបរិយាយសូត្រ ប្រព្រឹត្តក្នុងទីបំផុតជុំវិញ ដោយការសង្រួមឥន្ទ្រិយខាងក្នុង មិនទម្លាយខេត្តដែន នេះទីបំផុតជុំវិញដោយ ការសង្រួមឥន្ទ្រិយ ។

ទីបំផុតជុំវិញ ដោយការដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយបរិភោគអាហារថា អាត្មាអញមិនបរិភោគដើម្បីការលេង មិនដើម្បីការស្រវឹង មិនដើម្បីការតាក់តែង មិនដើម្បីការផូរផង់គ្រាន់តែដើម្បីការតាំងនៅនៃកាយនេះ ដើម្បីការញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ នឹងកម្ចាត់បង់នូវវេទនាចាស់ផង នឹងមិនញ៉ាំងវេទនាថ្មីឲ្យកើតឡើងផង កិរិយាប្រព្រឹត្តទៅ ( នៃឥរិយាបថទាំង ៤ ) ផង សេចក្តីមិនមានទោសផង ការនៅសប្បាយផងនឹងមានដល់អាត្មាអញដូច្នេះ ភិក្ខុពិចារណានូវអាហារឧបមាដោយប្រេងសម្រាប់លាបភ្លៅរទេះនិងសំពត់សម្រាប់រុំដំបៅ និងសាច់កូន ប្រព្រឹត្តក្នុងទីបំផុតជុំវិញដោយការដឹងប្រមាណក្នុងភោជនខាងក្នុង មិនទម្លាយនូវខេត្តដែននេះទីបំផុតជុំវិញដោយការដឹងប្រមាណក្នុងភោជន ។

ទីបំផុតជុំវិញដោយការប្រកបរឿយៗនូវការភ្ញាក់រឭក តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញ៉ាំងចិត្តឲ្យបរិសុទ្ធិចាកធម៌ជាគ្រឿងរារាំង ដោយការចង្ក្រមដោយការអង្គុយ អស់វេលាថ្ងៃ ញ៉ាំងចិត្តឲ្យបរិសុទ្ធិ ចាកធម៌ជាគ្រឿងរារាំងដោយការចង្ក្រម ដោយការអង្គុយអស់បឋមយាមនៃរាត្រី សម្រេចសីហសេយ្យាដោយខាងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី យកជើងតម្រួតលើជើង មានស្មារតីដឹងខ្លួន ធ្វើទុកក្នុងចិត្តនូវសញ្ញាថា នឹងក្រោកហើយក្រោកក្នុងបច្ឆិមយាមនៃរាត្រី ញ៉ាំងចិត្តឲ្យបរិសុទ្ធិចាកធម៌ជាគ្រឿងរារាំង ដោយការចង្ក្រម ដោយការអង្គុយ ពិចារណានូវការនៅតាមកត្តករត្តសូត្រ ប្រព្រឹត្តក្នុងទីបំផុតជុំវិញ

ដោយការប្រកបរឿយៗនូវការភ្ញាក់រឭកខាងក្នុង មិនទម្លាយនូវខេត្តដែន នេះទីបំផុតជុំវិញដោយការប្រកបរឿយៗនូវការភ្ញាក់រឭក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ ។

[ ២៣៤ ] ពាក្យថា របោម មមាច ពស់ សេចក្តីថា រុយក្រហមលោកហៅថា របោម ។ ពួករុយទាំងអស់ លោកហៅថា មមាច ។ ព្រោះអ្វីបានជាពួករុយទាំងអស់លោកហៅថា មមាច ។ ពួករុយទាំងនោះ តែងហើរធ្មៀលធ្វាត់ទៅខាំ ព្រោះហេតុនោះ ពួករុយទាំងអស់ លោកហៅថា មមាច ។ ពស់ទាំងឡាយ លោកហៅថា ពស់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) របោម មមាច ពស់ ។

[ ២៣៥ ] ពាក្យថា សម្ផស្សរបស់មនុស្សនិងសត្វចតុប្បាទ សេចក្តីថា ពួកចោរក្តី មាណពមានការងារធ្វើហើយក្តី មានការងារធ្វើមិនទាន់ហើយក្តី លោកហៅថា សម្ផស្សរបស់មនុស្ស ។ ពួកជនទាំងនោះគប្បីសួរប្រស្នាចំពោះភិក្ខុក្តី លើកវាទៈក្តី ជេរក្តី ប្រទេចក្តី ខឹងក្តី ក្រេវក្រោធក្តី បៀតបៀនក្តី បៀតបៀនផ្សេងៗក្តី គ្របសង្កត់ក្តី ជិះជាន់ក្តី ប្រហារក្តី ប្រហារមាំក្តី ធ្វើនូវការបៀតបៀនមាំក្តី ។ ការបៀតបៀនអំពីមនុស្សណានីមួយ ( ការបៀតបៀននោះ ) ឈ្មោះថា សម្ផស្សរបស់មនុស្ស ។ ពាក្យថា សត្វចតុប្បាទ គឺ សត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ឆ្កែព្រៃ គោ ក្របី ដំរី ។ សត្វទាំងនោះគប្បីញាំញី ខាំស៊ី បៀតបៀន បៀតបៀនផ្សេងៗ គ្របសង្កត់ ជិះជាន់ ប្រហារ ប្រហារមាំ ធ្វើការប្រហារមាំចំពោះភិក្ខុ ។ ការបៀតបៀនមាំអំពីសត្វចតុប្បាទ

ភ័យអំពីសត្វចតុប្បាទណាទីមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) សម្ពស្សរបស់មនុស្សនិងសត្វចតុប្បាទ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុជាធីរៈ មានស្មារតី ប្រព្រឹត្តធម៌ប្រកបដោយទីបំផុតជុំវិញ
មិនគប្បីខ្លាចចំពោះភ័យ ៥ យ៉ាង គឺរបោម មមាច ពស់
សម្ពស្សរបស់មនុស្សនិងសត្វចតុប្បាទ ។

[ ២៣៦ ] ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើន របស់ពួកអ្នកកាន់ធម៌ដទៃនោះ មិនគប្បីតក់ស្លុតទេ មួយទៀតភិក្ខុទាំងឡាយ អ្នកស្វែងរកកុសលធម៌ គប្បីគ្របសង្កត់អន្តរាយទាំងឡាយដទៃបាន ។

[ ២៣៧ ] ពាក្យថា ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើន របស់ពួកអ្នកកាន់ធម៌ដទៃនោះ មិនគប្បីតក់ស្លុតទេ អធិប្បាយថា ជនទាំងឡាយណាទីមួយ មិនជ្រះថ្លាក្នុងព្រះពុទ្ធ មិនជ្រះថ្លាក្នុងព្រះធម៌ មិនជ្រះថ្លាក្នុងព្រះសង្ឃ លើកតែសហធម្មិកបុគ្គល ៧ ពួកចេញ លោកហៅថា ពួកអ្នកកាន់ធម៌ដទៃ ។ ពួកជននោះគប្បីសួរប្រស្នានឹងភិក្ខុ ឬលើកវាទៈជេរប្រទេច ខឹងក្រេវក្រោធ បៀតបៀនបៀតបៀនផ្សេងៗ គ្របសង្កត់ ជិះជាន់ ប្រហារ ប្រហារខ្លាំង ធ្វើនូវការបៀតបៀនខ្លាំង ភិក្ខុឃើញក្តី ឮក្តី នូវហេតុគួរខ្លាចដ៏ច្រើនរបស់ជននោះ មិនគប្បីញាប់ញ័រ មិនគប្បីរន្ធត់ មិនគប្បីសស្ទើតសស្ទក់ មិនគប្បីតក់ស្លុត មិនគប្បីស□ន្ទត់ មិនគប្បីរំភើប មិនគប្បីញ័រចំប្រប់ មិនគប្បីខ្លាច មិនគប្បីដល់នូវការតក់ស្លុត គប្បីជាអ្នកមិនខ្លាច មិនញាប់ញ័រ មិនតក់ស្លុត មិនរត់ចេញ លះបង់នូវសេចក្តីខ្លាចនិងការភ្ញ័ក មានការព្រឺរោមទៅប្រាសហើយ ហេតុនោះ (ទ្រង់

ត្រាស់ថា ) ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើនរបស់ពួកអ្នកកាន់ធម៌ដទៃនោះ មិនគប្បីតក់ស្លុតទេ ។

[ ២៣៨ ] ពាក្យថា មួយទៀត ភិក្ខុទាំងឡាយអ្នកស្វែងរកកុសលធម៌ គប្បីគ្របសង្កត់អន្តរាយទាំងឡាយដទៃបាន សេចក្តីថា មួយទៀត សេចក្តីអន្តរាយទាំងឡាយដទៃ ដែលគួរគ្របសង្កត់ ជិះជាន់ សង្កត់សង្កិន បំផ្លាញ ញាំញីក៏មាន ។ ពាក្យថា សេចក្តីអន្តរាយ បានដល់ សេចក្តីអន្តរាយ ២ គឺ អន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។បេ។ ឈ្មោះថា អន្តរាយព្រោះជាសភាពអាស្រ័យក្នុងសរីរៈនោះយ៉ាងនេះខ្លះ ។ ពាក្យថា អ្នកស្វែងរកកុលធម៌ គឺភិក្ខុអ្នកស្វែងរក ស្វះស្វែងរក ប្រមើលរកនូវការប្រតិបត្តិល្អ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិដ៏សមគួរដល់អត្ថ ។បេ។ នូវមគ្គដ៏ប្រសើរមានអង្គ ៨ ព្រះនិព្វាន ការប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វានគប្បីគ្របសង្កត់ ជិះជាន់ សង្កត់សង្កិន បំផ្លាញ ញាំញីនូវសេចក្តីអន្តរាយទាំងឡាយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀតភិក្ខុទាំងឡាយ អ្នកស្វែងរកកុសលធម៌គប្បីគ្របសង្កត់អន្តរាយទាំងឡាយដទៃបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុឃើញហេតុគួរខ្លាចដ៏ច្រើន របស់ពួកអ្នកកាន់ធម៌ដទៃនោះ
មិនគប្បីតក់ស្លុតទេ មួយទៀតភិក្ខុទាំងឡាយ អ្នកស្វែងរក
កុសលធម៌ គប្បីគ្របសង្កត់អន្តរាយទាំងឡាយដទៃបាន ។

[ ២៣៩ ] ភិក្ខុត្រូវសម្ផស្សជំងឺឬគម្លានពាល់ត្រូវហើយ គប្បីទ្រាំអត់ចំពោះត្រជាក់និងក្តៅ ភិក្ខុនោះដែលអាការដ៏ច្រើននោះពាល់ត្រូវហើយ មិន

គប្បីជាអ្នកធ្វើឱកាស គប្បីធ្វើព្យាយាមប្រឹងប្រែង ឲ្យនៅតែម៉ឺងម៉ាត់ ។

[ ២៨០ ] ពាក្យថា ភិក្ខុត្រូវសម្ផស្សជំងឺ ( ឬ ) គម្លានពាល់ត្រូវហើយ សេចក្ដីថា សម្ផស្សនៃរោគ លោកហៅថា សម្ផស្សជំងឺ ។ ភិក្ខុត្រូវសម្ផស្សនៃរោគពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម គឺថាត្រូវរោគភ្នែកពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ត្រូវរោគត្រចៀក រោគច្រមុះ រោគអណ្ដាត រោគកាយ ។បេ។ ត្រូវសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃនិងពស់ពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ។ សេចក្ដីឃ្លាន លោកហៅថា គម្លាន ។ ភិក្ខុត្រូវគម្លានពាល់ត្រូវគ្របសង្កត់ ស្រោចចុះ ប្រកបព្រម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្រូវសម្ផស្សរោគពាល់ត្រូវហើយ ។

[ ២៨១ ] ពាក្យថា គប្បីទ្រាំអត់ចំពោះត្រជាក់និងក្ដៅ ត្រង់ពាក្យថា ត្រជាក់ បានដល់ ត្រជាក់ដោយហេតុ ២ គឺត្រជាក់ដោយអំណាច ធាតុខាងក្នុងកម្រើក ១ ត្រជាក់ដោយអំណាចរដូវខាងក្រៅ ១ ។ ពាក្យថា ក្ដៅ បានដល់ ការក្ដៅដោយហេតុ ២ គឺក្ដៅដោយអំណាចធាតុខាងក្នុងកម្រើក ១ ក្ដៅដោយអំណាចរដូវខាងក្រៅ ១ ។ ពាក្យថា គប្បីទ្រាំអត់ចំពោះត្រជាក់និងក្ដៅ បានសេចក្ដីថា ភិក្ខុគប្បីជាអ្នកអត់ធន់ចំពោះត្រជាក់ ក្ដៅ សេចក្ដីឃ្លាន សេចក្ដីស្រេក សម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ ពស់ ចំពោះគន្លងពាក្យដែលគេពោលអាក្រក់មកអាក្រក់ គប្បីជាអ្នកប្រកបដោយជាតិ ជាអ្នកអត់ធន់វេទនា ប្រព្រឹត្តទៅក្នុងសរីរៈដែលកើតហើយ ជាទុក្ខខ្លាំងខ្លា ខ្លោចផ្សា ក្ដៅផ្សា មិនស្រួល មិនជាទីគាប់ចិត្តដែលអាចនាំយកជីវិតបាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុគប្បី

អត់សង្កត់ចំពោះត្រជាក់និងក្តៅ ។

[ ២៤២ ] អធិប្បាយពាក្យថា ភិក្ខុនោះ ដែលអាការដ៏ច្រើននោះពាល់ត្រូវហើយ មិនគប្បីជាអ្នកធ្វើឱកាស ត្រង់ពាក្យថា ភិក្ខុនោះដែលអាការនោះ គឺភិក្ខុនោះជាអ្នកត្រូវសម្ផស្សជំងឺផង គម្លានផង ត្រជាក់ផង ក្តៅផង ពាល់ត្រូវគ្របសង្កត់ ស្រោចចុះ ប្រកបព្រម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះដែលអាការនោះពាល់ត្រូវហើយ ។ ពាក្យថា ដោយច្រើន គឺត្រូវអាការច្រើនយ៉ាងពាល់ត្រូវ គ្របសង្កត់ ស្រោចចុះ ប្រកបព្រម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះដែលអាការដ៏ច្រើននោះពាល់ត្រូវហើយ ។ ពាក្យថា មិនគប្បីជាអ្នកធ្វើឱកាស គឺឈ្មោះថាមិនធ្វើឱកាស ព្រោះមិនធ្វើឱកាសដល់វិញ្ញាណដែលប្រកបដោយអភិសង្ខារក៏មាន ឬឈ្មោះថាមិនធ្វើឱកាស ព្រោះមិនធ្វើឱកាសដល់កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតក៏មាន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះដែលអាការដ៏ច្រើននោះពាល់ត្រូវហើយ មិនគប្បីជាអ្នកធ្វើឱកាស ។

[ ២៤៣ ] ពាក្យថា គប្បីធ្វើព្យាយាមប្រឹងប្រែងឲ្យនៅតែម៉ឺងម៉ាត់ សេចក្តីថា ការព្យាយាមតឹងតែង ការសង្វាត ការប្រឹងប្រែង ការឧហាត ការព្យាយាម ការឧស្សាហ៍ ការខ្មីឃ្មាត ការមិនបន្ធូរបន្ថយកម្លាំងកាយ ការតាំងមាំ ការប្រឹងប្រែងមិនធូរថយ ការមិនដាក់ចុះនូវសេក្តីប្រាថ្នា ការមិនដាក់ធុរៈ ការផ្គងធុរៈ ការព្យាយាម ការព្យាយាមជាធំ ការព្យាយាមជាកម្លាំង ការព្យាយាមត្រូវដែលប្រព្រឹត្តទៅក្នុងចិត្តឯណានោះ លោកហៅថា ការព្យាយាមប្រឹងប្រែង ។ ភិក្ខុគប្បីធ្វើព្យាយាមប្រឹងប្រែងឲ្យម៉ឺងម៉ាត់ គឺគប្បីជាអ្នកសមាទានដ៏មាំទាំ ជាអ្នក

សមាទានដ៏មុតមាំ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុគប្បីធ្វើព្យាយាមប្រឹងប្រែងឲ្យម៉ឺងម៉ាត់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុត្រូវសម្ផស្សជំងឺឬគម្លានពាល់ត្រូវហើយគប្បីទ្រាំអត់ចំពោះត្រជាក់និងក្តៅ ភិក្ខុនោះដែលអាការដ៏ច្រើននោះពាល់ត្រូវហើយមិនគប្បីជាអ្នកធ្វើឱកាស គប្បីធ្វើព្យាយាមប្រឹងប្រែងឲ្យនៅតែម៉ឺងម៉ាត់ ។

[ ២៤៤ ] ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក គប្បីផ្សព្វផ្សាយមេត្តាចំពោះពួកសត្វ ដែលមានសន្តានតក់ស្លុតនិងមានសន្តានរឹងប៉ឹង ភិក្ខុបើដឹងសេចក្តីល្អក់ចិត្តក្នុងកាលណាគប្បីបន្ទោបង់នូវសេចក្តីល្អក់ចិត្តនោះ ( ដោយគិតថា ) នេះបក្ខពួករបស់ខ្មៅក្នុងកាលនោះ ។

[ ២៤៥ ] អធិប្បាយពាក្យថា ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក ត្រង់ពាក្យថា មិនគប្បីធ្វើការលួច សេចក្តីថា ភិក្ខុក្នុងសាសនានេះ គប្បីជាអ្នកលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មានខ្លួនជាអ្នកមិនលួច មានសភាពដ៏ស្អាត ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគប្បីធ្វើការលួច ។ ពាក្យថា មិនគប្បីពោលកុហក គឺភិក្ខុក្នុងសាសនានេះ គប្បីជាអ្នកលះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ជាអ្នកពោលតែពាក្យពិតតពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលបំភាន់សត្វលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក ។

[ ២៤៦ ] អធិប្បាយពាក្យថា គប្បីផ្សព្វផ្សាយមេត្តាចំពោះពួកសត្វដែលមានសន្តានតក់ស្លុត និងមានសន្តានរឹងប៉ឹង ត្រង់ពាក្យថា មេត្តា បានដល់សេចក្តីរាប់អាន អាការនៃសេចក្តីរាប់អាន ភាពនៃសេចក្តីរាប់អាន សេចក្តីអាណិត អាការនៃសេចក្តីអាណិត ភាពនៃសេចក្តីអាណិត ការស្វែងរកប្រយោជន៍ សេចក្តីអនុគ្រោះ ការមិនព្យាបាទ ការមិនចងពៀរ ការមិនប្រទូស្ត កុសលមូលចំពោះពួកសត្វ ។ ពួកសត្វដែលមិនទាន់លះបង់សេចក្តីតក់ស្លុត គឺតណ្ហាផង ពួកសត្វដែលមិនលះបង់សេចក្តីភ័យដ៏ពន្លឹកផង ឈ្មោះថាពួកសត្វមានសន្តានតក់ស្លុត ព្រោះហេតុអ្វីទើបលោកហៅថា ពួកសត្វមានសន្តានតក់ស្លុត ។ ព្រោះថា ពួកសត្វនោះតែងតក់ស្លុត រន្ធត់ ញាប់ញ័រ ភិតភ័យ ដល់នូវសេចក្តីតក់ស្លុត ហេតុនោះទើបលោកហៅថា ពួកសត្វមានសន្តានតក់ស្លុត ពួកសត្វដែលលះបង់សេចក្តីតក់ស្លុត គឺតណ្ហាផង ពួកសត្វដែលលះបង់សេចក្តីភ័យដ៏ពន្លឹកផង ឈ្មោះថាពួកសត្វមានសន្តានរឹងប៉ឹង ។ ព្រោះហេតុអ្វីទើបលោកហៅថា ពួកសត្វមានសន្តានរឹងប៉ឹង ។ ( ព្រោះថា ) ពួកសត្វទាំងនោះរមែងមិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនខ្លាច មិនដល់នូវការតក់ស្លុត ហេតុនោះ ទើបលោកហៅថា ពួកសត្វមានសន្តានរឹងប៉ឹង ។ ពាក្យថា គប្បីផ្សព្វផ្សាយមេត្តា ចំពោះពួកសត្វដែលមានសន្តានតក់ស្លុតនិងមានសន្តានរឹងប៉ឹង បានសេចក្តីថា គប្បីប៉ះពាល់ គប្បីផ្សាយមេត្តាចំពោះសត្វមានសន្តានតក់ស្លុតនិងមានសន្តានរឹងប៉ឹង គឺថាគប្បីផ្សាយទៅដោយចិត្តដែលប្រព្រឹត្តទៅក្នុងមេត្តាដ៏ទូលាយ ជាសភាពធំ មិនមានប្រមាណ មិនមានពៀរ មិនមាន

ព្យាបាទ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីផ្សព្វផ្សាយមេត្តាចំពោះពួកសត្វដែលមានសន្តានតក់ស្លុតនិងសន្តានរឹងប៉ឹង ។

[ ២៤៧ ] ពាក្យថា ភិក្ខុបើដឹងនូវសេចក្តីល្អក់ចិត្តក្នុងកាលណា ត្រង់ពាក្យថា ក្នុងកាលណា គឺក្នុងវេលាណា ។ ពាក្យថា ចិត្ត បានដល់ ចិត្ត មនោ មានសៈ ហទយៈ បណ្ឌរ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។ ចិត្តតែងល្អក់ វឹកវរ រំភើប ខ្វាំងខ្វប់ ញាប់ញ័រ ភ្ញាក់ផ្អើល មិនស្ងប់ ព្រោះកាយទុច្ចរិត ចិត្តតែងល្អក់ វឹកវរ រំភើប ខ្វាំងខ្វប់ ញាប់ញ័រ ភ្ញាក់ផ្អើល មិនស្ងប់ ព្រោះវចីទុច្ចរិត មនោទុច្ចរិត រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង កម្តៅទាំងពួង អភិសង្ខារជាអកុសលទាំងពួង ។ ពាក្យថា ភិក្ខុបើដឹងសេចក្តីល្អក់ចិត្តក្នុងកាលណា គឺគប្បីដឹង គប្បីយល់ គប្បីចូលចិត្ត គប្បីដឹងច្បាស់ គប្បីចាក់ធ្លុះនូវភាពនៃចិត្តល្អក់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីដឹងសេចក្តីល្អក់ចិត្តក្នុងកាលណា ។

[ ២៤៨ ] ពាក្យថា គប្បីបន្ទោបង់នូវសេចក្តីល្អក់ចិត្តនោះ ( ដោយគិត ) ថា នេះបក្ខពួករបស់ខ្មៅ ត្រង់ពាក្យថា ខ្មៅ គឺមារឈ្មោះថាខ្មៅ អធិបតី អ្នកដល់នូវទីបំផុត អ្នកមិនឲ្យរួច ផៅពង្សអ្នកប្រមាទ ។ ពាក្យថា គប្បីបន្ទោបង់នូវសេចក្តីល្អក់ចិត្តនោះ ( ដោយគិត ) ថា នេះបក្ខពួករបស់ខ្មៅ សេចក្តីថា

ភិក្ខុគប្បីលះបង់បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវភាពមិនមាន ដោយគិតថា នេះជាបក្ខពួករបស់ខ្មៅ ជាពួករបស់មារ ជាអន្ទាក់របស់មារ ជាសន្ទូចរបស់មារ ជានុយរបស់មារ ជាវិស័យរបស់មារ ជាតបៈទីបំផុតរបស់មារ ជាគោចររបស់មារ ជាចំណងរបស់មារ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីបន្ទោបង់នូវសេចក្តីល្អក់ចិត្តនោះ ( ដោយគិត ) ថា នេះបក្ខពួករបស់ខ្មៅយ៉ាងនេះខ្លះ ។ មួយវិញទៀត ភិក្ខុគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវភាពមិនមាន ( ដោយគិត ) ថា នេះបក្ខពួករបស់ខ្មៅ ជាពួករបស់មារ ជាពួកអកុសល ជាកិលេសចម្រើនតែទុក្ខ ជាផលនៃទុក្ខ ជាកិលេសប្រកបក្នុងការប្រព្រឹត្តទៅក្នុងនរក ប្រកបក្នុងការប្រព្រឹត្តទៅក្នុងសត្វតិរច្ឆាន ប្រកបក្នុងការប្រព្រឹត្តទៅក្នុងបិត្តិវិស័យ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីបន្ទោបង់នូវសេចក្តីល្អក់ចិត្តនោះ ( ដោយគិត ) ថា នេះបក្ខពួករបស់ខ្មៅ យ៉ាងនេះខ្លះ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលកុហក គប្បីផ្សព្វផ្សាយ
មេត្តាចំពោះពួកសត្វដែលមានសន្តានតក់ស្លុត និងមានសន្តាន
រឹងប៉ឹង ភិក្ខុបើដឹងសេចក្តីល្អក់ចិត្តក្នុងកាលណា គប្បីបន្ទោបង់
នូវសេចក្តីល្អក់ចិត្តនោះ ( ដោយគិត ) ថា នេះបក្ខពួករបស់
ខ្មៅក្នុងកាលនោះ ។

[ ២៤៩ ] ភិក្ខុមិនគប្បីលុះអំណាចក្រោធនិងការមើលងាយ ទាំងគប្បីគាស់ឫសនៃកិលេសទាំងនោះចេញ មួយទៀតគប្បីគ្របសង្កត់ឲ្យមាំនូវសភាវៈជាទី

ស្រឡាញ់ ឬមិនជាទីស្រឡាញ់ ។

[ ២៥០ ] ពាក្យថា ភិក្ខុមិនគប្បីលុះអំណាចក្រោធ និងការមើលងាយ ត្រង់ពាក្យថា ក្រោធ បានដល់ ការអាឃាត ការគំនុំរបស់ចិត្ត ។បេ។ ភាពជាអ្នកកាច ការចេញទឹកភ្នែក ការអាក់អន់ចិត្ត ។ ពាក្យថា ការមើលងាយ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ មើលងាយបុគ្គលដទៃដោយជាតិក៏មាន ដោយគោត្តក៏មាន ។បេ។ ដោយវត្ថុណាមួយក៏មាន ។ ពាក្យថា មិនគប្បីលុះអំណាចក្រោធនិងការមើលងាយ បានសេចក្តីថា មិនគប្បីលុះអំណាចក្រោធផង ការមើលងាយផង គប្បីលះបង់ បន្ទោបង់ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវសេចក្តីក្រោធផង នូវការមើលងាយផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមិនគប្បីលុះអំណាចក្រោធនិងការមើលងាយ ។

[ ២៥១ ] សំណួរត្រង់ពាក្យថា ទាំងគប្បីគាស់ឫសនៃកិលេសទាំងនោះចេញ តើឫសក្រោធដូចម្តេច ។ អវិជ្ជាជាឫស អយោនិសោមនសិការៈជាឫស អស្មិមានះជាឫស អហិរិកៈជាឫស អនោត្តប្បៈជាឫស ឧទ្ធច្ចៈជាឫស នេះឫសនៃក្រោធ ។ ឫសនៃការមើលងាយ តើដូចម្តេច ។ អវិជ្ជាជាឫស អយោនិ-សោមនសិការៈជាឫស អស្មិមានះជាឫស អហិរិកៈជាឫស អនោត្តប្បៈជាឫស ឧទ្ធច្ចៈជាឫស នេះឫសនៃការមើលងាយ ។ ពាក្យថា គប្បីគាស់ឫសនៃកិលេសទាំងនោះចេញ បានសេចក្តីថា គប្បីគាស់រំលើង រើចោល ផ្តាច់ចោល ផ្តាច់ផ្តិល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវភាពមិនមាន នូវឫសនៃក្រោធផង នៃការមើលងាយផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) ទាំងគប្បីគាស់ឫសនៃ

កិលេសទាំងនោះចេញ ។

[ ២៥២ ] អធិប្បាយពាក្យថា មួយទៀតគប្បីគ្របសង្កត់ឲ្យមាំនូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ត្រង់ពាក្យថា មួយទៀត គឺជាពាក្យតបទ ជាពាក្យជាប់ដោយបទ បំពេញបទ រួបរួមអក្ខរៈ សម្រួលព្យញ្ជនៈ ពាក្យថា មួយទៀត នេះជាលំដាប់បទ ។ ពាក្យថា សភាវៈជាទីស្រឡាញ់ បានដល់របស់ជាទីស្រឡាញ់ ២ គឺពួកសត្វ ឬពួកសង្ខារ ។ ពួកសត្វជាទីស្រឡាញ់តើដូចម្តេច សត្វទាំងនោះឯណាក្នុងលោកនេះ មានប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាសេចក្តីក្សេមចាកយោគៈ គឺជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី កូនប្រុសក្តី កូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តីរបស់ជននោះ នេះពួកសត្វជាទីស្រឡាញ់ ។ ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបទាំងឡាយជាទីពេញចិត្ត សំឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផ្សព្វជាទីពេញចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។ ពាក្យថា មិនជាទីស្រឡាញ់ បានដល់ សភាវៈមិនជាទីស្រឡាញ់ ២ គឺពួកសត្វ ១ ឬពួកសង្ខារ ១ ។ ពួកសត្វមិនជាទីស្រឡាញ់តើដូចម្តេច ។ ពួកសត្វណាក្នុងលោកនេះ ប្រាថ្នាការមិនចម្រើន ប្រាថ្នាការឥតប្រយោជន៍ ប្រាថ្នាការមិនសប្បាយ ប្រាថ្នាការមិនក្សេមចាកយោគៈ ប្រាថ្នាដើម្បីផ្តាច់ផ្តិលចាកជីវិតរបស់ជននោះ នេះពួកសត្វមិនជាទីស្រឡាញ់ ។ ពួកសង្ខារមិនជាទីស្រឡាញ់ តើដូចម្តេច ។ រូបទាំងឡាយមិនជាទីពេញចិត្ត សំឡេង ក្លិន រស ផ្សព្វ មិនជាទីពេញចិត្ត នេះពួកសង្ខារមិនជាទីស្រឡាញ់ ។ ពាក្យ

ថា ឲ្យមាំ ជាពាក្យដោយចំណែកមួយ ជាពាក្យមិនឲ្យសង្ស័យ ជាពាក្យមិនឲ្យសន្ទិះ ជាពាក្យមិនបែកជា ២ ជាពាក្យមិនមានហឫទ័យពីរ ជាពាក្យប្រកបដាច់ស្រេច ជាពាក្យមិនខុស ពាក្យថាឲ្យមាំនេះ ជាពាក្យមានកំណត់ ។ ពាក្យថា មួយទៀតគប្បីគ្របសង្កត់នូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ បានសេចក្ដីថា គប្បីគ្របសង្កត់ គប្បីសង្កត់ គ្របនូវសភាវៈជាទីស្រឡាញ់និងមិនជាទីស្រឡាញ់នូវអារម្មណ៍ដ៏ត្រេកអរ ស្រឡាញ់និងមិនត្រេកអរ នូវសុខនិងទុក្ខ នូវសោមនស្សនិងទោមនស្ស នូវអារម្មណ៍ជាទីប្រាថ្នានិងមិនជាទីប្រាថ្នា ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀតគប្បីគ្របសង្កត់នូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមិនគប្បីលុះអំណាចក្រោធនិងការមើលងាយ ទាំងគប្បីគាស់ឫសនៃកិលេសទាំងនោះចេញ មួយទៀតគប្បីគ្របសង្កត់ឲ្យមាំនូវសភាវៈជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ ។

[ ២៥៣ ] ភិក្ខុមានបីតិដ៏ល្អ គប្បីធ្វើបញ្ញាឲ្យជាប្រធាន ហើយសង្កត់សង្កិននូវអន្តរាយទាំងនោះ គប្បីគ្របសង្កត់នូវសេចក្ដីអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ ។

[ ២៥៤ ] អធិប្បាយពាក្យថា ភិក្ខុមានបីតីដ៏ល្អ គប្បីធ្វើបញ្ញាឲ្យជាប្រធាន ត្រង់ពាក្យថា បញ្ញា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ការពិច័យ ការពិច័យដោយវិសេស ការពិចារណាធម៌ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្ដីយល់ឃើញត្រូវ ។ ពាក្យថា ធ្វើបញ្ញាឲ្យជាប្រធាន សេចក្ដីថា បុគ្គល

ខ្វះក្នុងលោកនេះ ប្រព្រឹត្តធ្វើបញ្ញាឲ្យជាប្រធាន មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ជាអ្នកច្រើនដោយការពិចារណា ជាអ្នកច្រើនដោយការជ្រើសរើស ច្រើនដោយការឈ្វេងយល់ ច្រើនដោយការស្វែងរកនៅដោយការដឹងប្រាកដ ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះធ្ងន់ដោយប្រាជ្ញានោះ បង្អោនទៅដោយប្រាជ្ញានោះ ទោរទៅដោយប្រាជ្ញានោះបន្ទន់ទៅដោយប្រាជ្ញានោះ មានចិត្តចុះស៊ុបក្នុងប្រាជ្ញានោះ មានប្រាជ្ញានោះជាអធិបតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុធ្វើប្រាជ្ញាឲ្យជាប្រធានយ៉ាងនេះខ្វះ ។ ន័យមួយទៀត ភិក្ខុកំពុងដើរក្តីក៏ដឹងច្បាស់ថាអញដើរ កំពុងឈរក្តីក៏ដឹងច្បាស់ថាអញឈរ កំពុងអង្គុយក្តី ក៏ដឹងច្បាស់ថាអញអង្គុយ កំពុងដេកក្តី ក៏ដឹងច្បាស់ថាអញដេក ឬកាយរបស់ភិក្ខុនោះជាអត្តភាពតាំងនៅដោយប្រការណាៗក៏ដឹងច្បាស់កាយនោះ ដោយប្រការនោះៗ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុធ្វើបញ្ញាឲ្យជាប្រធានយ៉ាងនេះខ្វះ ។ ន័យមួយវិញទៀត ភិក្ខុតែងធ្វើនូវការដឹងខ្លួន ក្នុងការឈានទៅមុខ ឈានថយក្រោយ តែងធ្វើនូវការដឹងខ្លួនក្នុងការរមិលមើលទៅមុខ រមិលមើលផ្សេងៗ តែងធ្វើនូវការដឹងខ្លួនក្នុងការបត់ដៃចូលលាដៃចេញ តែងធ្វើនូវការដឹងខ្លួនក្នុងការទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ តែងធ្វើនូវការដឹងខ្លួនក្នុងការស៊ី ផឹក ទំពាស៊ី លិទ្ធភក្សរ តែងធ្វើនូវការដឹងខ្លួនក្នុងការធ្វើឧច្ចារៈ បស្សាវៈ តែងធ្វើនូវការដឹងខ្លួនក្នុងការដើរ ឈរ អង្គុយ ដេកលក់ភ្ញាក់រឭក និយាយ ស្ងៀម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុធ្វើប្រាជ្ញាឲ្យជាប្រធានយ៉ាងនេះខ្វះ ។ ពាក្យថា មានបីតិដ៏ល្អ សេចក្តីថា បីតិ បាមោជ្ជ កើត

ឡើងដោយអំណាចពុទ្ធានុស្សតិឈ្មោះថា បីតិដ៏ល្អ បីតិ បាមោជ្ជ កើតឡើង ដោយអំណាចធម្មានុស្សតិ ដោយអំណាចសង្ឃានុស្សតិ ដោយអំណាចសីលា-នុស្សតិ ដោយអំណាចចាគានុស្សតិ ដោយអំណាចទេវតានុស្សតិ ដោយអំណាចអានាបានស្សតិ ដោយអំណាចមរណានុស្សតិ ដោយអំណាចកាយគតាសតិ ដោយអំណាចឧបសមានុស្សតិ ឈ្មោះថាបីតិដ៏ល្អ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមានបីតិដ៏ល្អ ធ្វើបាជ្ជាឲ្យជាប្រធាន ។

[ ២៥៥ ] ពាក្យថា អន្តរាយ ក្នុងបទថា គប្បីសង្កត់សង្កិនអន្តរាយទាំងនោះ បានដល់ អន្តរាយ ២ គឺអន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។បេ។ ទាំងនេះហៅថា អន្តរាយប្រាកដ ។បេ។ ទាំងនេះហៅថា អន្តរាយកំបាំង ។បេ។ ឈ្មោះថា អន្តរាយ ព្រោះជាសភាវៈអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះខ្លះ ។ ពាក្យថា គប្បីគ្របសង្កត់អន្តរាយទាំងនោះ គឺគប្បីអត់សង្កត់ គ្របសង្កត់ សង្កត់សង្កិន រួបរឹត ញាំញីនូវអន្តរាយទាំងនោះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីគ្របសង្កត់អន្តរាយទាំងនោះ ។

[ ២៥៦ ] ពាក្យថា គប្បីគ្របសង្កត់សេចក្តីអផ្សុកក្នុងសេនាសនៈដ៏ស្ងាត់ ត្រង់ពាក្យថា សេចក្តីអផ្សុក បានដល់ សេចក្តីមិនត្រេកអរ អាការនៃសេចក្តីមិនត្រេកអរ សេចក្តីមិនរីករាយ អាការនៃសេចក្តីមិនរីករាយ អាការនៃសេចក្តីអផ្សុក សេចក្តីរសាប់រសល់ ។ ពាក្យថា ក្នុងសេនាសនៈដ៏ស្ងាត់ គឺគប្បីអត់ធន់ គ្របសង្កត់ រួបរឹត ក្រសោប ញាំញីនូវសេចក្តីអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ ឬក្នុងធម៌ជាអធិកុសលណាមួយ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បី

គ្របសង្កត់នូវសេចក្តីអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ ។

[ ២៥៧ ] ពាក្យថា គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ គឺគប្បីអត់សង្កត់ គ្របសង្កត់ រួបរឹត ក្រសោប ញាំញី នូវធម៌ដែលគេគប្បីខ្សឹកខ្សួល ៤ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមានបីតិដ៏ល្អ គប្បីធ្វើបញ្ញាឲ្យជាប្រធានហើយសង្កត់សង្កិននូវអន្តរាយទាំងនោះ គប្បីគ្របសង្កត់សេចក្តីអផ្សុកក្នុងសេ-នាសនៈដ៏ស្ងាត់ គប្បីគ្របសង្កត់នូវបរិទេវធម៌ ៤ ។

[ ២៥៨ ] អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគក្នុងទីណា ឱហ្ន៎ អាត្មាអញដេកមិនស្រួលសោះក្នុងថ្ងៃនេះ អាត្មាអញនឹងដេកក្នុងទីណា ភិក្ខុជាសេក្ខៈជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ គប្បីកម្ចាត់បង់នូវវិតក្ក ដែលគប្បីទួញយំទាំងនេះចេញ ។

[ ២៥៩ ] ពាក្យថា អាត្មាអញនឹងបរិភោគអ្វី ក្នុងបទថា អាត្មាអញនឹងបរិភោគអ្វីឬនឹងបរិភោគក្នុងទីណា គឺអាត្មាអញនឹងបរិភោគអ្វី បាយឬនំកុម្មាសសដូវឬត្រី ឬក៏សាច់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាត្មាអញនឹងបរិភោគអ្វី ។ ពាក្យថា ឬនឹងបរិភោគក្នុងទីណា គឺអាត្មាអញនឹងបរិភោគ ក្នុងទីណា ក្នុងខត្តិយត្រកូលឬព្រាហ្មណត្រកូល វេស្សត្រកូលឬសុទ្ទត្រកូល ហេតុនោះ ( ទ្រង់ត្រាស់ថា ) អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគក្នុងទីណា ។

[ ២៦០ ] ពាក្យថា ឱហ្ន៎ អាត្មាអញដេកមិនស្រួលសោះ ក្នុងថ្ងៃនេះ

អាត្មាអញនឹងដេកក្នុងទីណា គឺយប់នេះ អាត្មាអញដេកមិនស្រួលហើយ លើបន្ទះក្ដារឬលើកន្ទេល លើចម្ងខ័ណ្ឌឬលើកម្រាលស្មៅ លើកម្រាលស្លឹក ឬលើកម្រាលចំបើង លុះដល់យប់មកទៀត តើអាត្មាអញនឹងដេកឲ្យស្រួលក្នុងទីណា លើគ្រែឬលើតាំង លើពូកឬលើខ្នើយ ក្នុងវិហារឬក្នុងអឌ្ឍយោគ ក្នុងប្រាសាទ ឬក្នុងប្រាសាទត្រងិល ឬក៏ក្នុងគុហា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឱហ្ន៍ អាត្មាអញដេកមិនស្រួលសោះក្នុងថ្ងៃនេះ អាត្មាអញនឹងដេកក្នុងទីណា ។

[ ២៦១ ] ពាក្យថា នូវវិតក្កទាំងនេះ ក្នុងបទថា នូវវិតក្កដែលគប្បីទូញយំទាំងនេះ គឺនូវវិតក្ក ប្រកបដោយបិណ្ឌបាតពីរ នូវវិតក្កប្រកបដោយសេនាសនៈពីរ ដែលគប្បីទូញយំ ទូញយំទូទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) នូវវិតក្កដែលគប្បីទូញយំទាំងនេះ ។

[ ២៦២ ] អធិប្បាយពាក្យថា ភិក្ខុជាសេក្ខៈ ជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ គប្បីកម្ចាត់បង់ សំណួរត្រង់ពាក្យថា សេក្ខៈ ចុះព្រោះហេតុអ្វីភិក្ខុលោកហៅថា សេក្ខៈ ។ ឈ្មោះថា សេក្ខៈ ព្រោះហេតុលោកសិក្សា ។ ចុះសិក្សាអ្វី ។ សិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ។ អធិសីលសិក្ខា តើដូចម្ដេច ។បេ។ នេះហៅថា អធិប្បញ្ញាសិក្ខា ។ ភិក្ខុកាលរំពឹងត្រៃសិក្ខាទាំងនេះ ឈ្មោះថាសិក្សា កាលដឹង ឈ្មោះថាសិក្សា កាលឃើញ ឈ្មោះថាសិក្សា កាលពិចារណា ឈ្មោះថាសិក្សា កាលតាំងចិត្តឈ្មោះថាសិក្សា កាលចុះចិត្តស៊ុបដោយសទ្ធា ឈ្មោះថាសិក្សា កាលផ្គងព្យាយាម ឈ្មោះថាសិក្សា កាលតម្កល់ស្មារតី ឈ្មោះថាសិក្សា កាលតម្កល់

ចិត្តមាំ ឈ្មោះថាសិក្សា កាលដឹងច្បាស់ដោយប្រាជ្ញា ឈ្មោះថាសិក្សា កាលដឹងច្បាស់នូវធម៌ដែលគួរដឹង ឈ្មោះថាសិក្សា កាលកំណត់ដឹងធម៌ដែលគួរដឹង ឈ្មោះថាសិក្សា កាលលះបង់ធម៌ដែលគួរលះបង់ ឈ្មោះថាសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាសិក្សា កាលចម្រើនធម៌ដែលគួរចម្រើន ឈ្មោះថាសិក្សា ជាប្រព្រឹត្ត ជាប្រព្រឹត្តព្រម ជាសមាទានជាសិក្សា ។ ព្រោះហេតុនោះទើបលោកហៅថា សេក្ខៈ ។ សេក្ខបុគ្គលគប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីកម្ចាត់បង់ បន្ទោបង់ លះបង់ រម្ងាប់ លះចោល ឲ្យស្ងប់រម្ងាប់ គឺជាកាលរំពឹងគប្បីសិក្សានូវសិក្ខាទាំង ៣ នេះ កាលដឹង ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ គប្បីសិក្សា គប្បីប្រព្រឹត្ត គប្បីប្រព្រឹត្តព្រម គប្បីសមាទានប្រព្រឹត្ត ហេតុនោះ ( ទ្រង់ត្រាស់ថា ) សេក្ខៈគប្បីកម្ចាត់បង់ ។

[ ២៦៣ ] សំណួរត្រង់ពាក្យថា ជាអ្នកត្រាច់ទៅ ដោយការមិនអាឡោះអាល័យ ចុះភិក្ខុជាអ្នកត្រាច់ទៅដោយការអាឡោះអាល័យ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកប្រកបដោយការកន្ទ្វល់ ព្រោះត្រកូល ដោយការកន្ទ្វល់ព្រោះពួក ដោយការកន្ទ្វល់ ព្រោះអាវាស ដោយការកន្ទ្វល់ព្រោះចីវរ ដោយការកន្ទ្វល់ព្រោះបិណ្ឌបាត ដោយការកន្ទ្វល់ព្រោះសេនាសនៈ ជាអ្នកប្រកបដោយការកន្ទ្វល់ព្រោះថ្នាំជាគ្រឿងកែរោគ ដែលជាបរិក្ខារសម្រាប់ជីវិត ភិក្ខុជាអ្នកត្រាច់ទៅដោយការអាឡោះអាល័យយ៉ាងនេះ ។ ភិក្ខុជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះជាអ្នកមិន

ប្រកបដោយការកន្វល់ព្រោះត្រកូល ជាអ្នកមិនប្រកបដោយការកន្វល់ ព្រោះពួក អាវាស ចីវរ បិណ្ឌបាត សេនាសនៈនិងថ្នាំជាបច្ច័យគ្រឿងកែរោគដែលជាបរិក្ខារសម្រាប់ជីវិត ភិក្ខុជាអ្នកត្រាច់ទៅដោយការមិនអាឡោះអាល័យយ៉ាងនេះ ។

បុគ្គលពួកខ្លះ ( ចេញហើយ ) អំពីដែនវជ្ជីទៅកាន់ដែនមគធៈ
ទៅកាន់ដែនកោសល ពួកភិក្ខុនៅក្នុងដែនមគធៈ ជាអ្នកត្រាច់
ទៅប្រាសចាកពួក ឥតមានអាឡោះអាល័យ ការត្រាច់ទៅជា
ការប្រពៃ ការប្រព្រឹត្តល្អជាការប្រពៃ ការនៅដោយមិនអាឡោះ
អាល័យសព្វកាល ជាការប្រពៃ ការសោកសួរអត្ថនិងការងារ
របស់ជនអ្នកប្រសប់នោះ ជាកិច្ចទូទៅរបស់បុគ្គលអ្នកមិនមាន
កន្វល់ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុជាសេក្ខៈ ជាអ្នកត្រាច់ទៅដោយការមិនមានអាឡោះអាល័យ គប្បីកម្ចាត់បង់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាត្មាអញនឹងបរិភោគអ្វី ឬនឹងបរិភោគក្នុងទីណា ឱហ្ន៎ អាត្មា
អញដេកមិនស្រួលសោះ ក្នុងថ្ងៃនេះ អាត្មានឹងដេកក្នុងទីណា
ភិក្ខុជាសេក្ខៈ ជាអ្នកត្រាច់ទៅ ដោយការមិនអាឡោះអាល័យ
គប្បីកម្ចាត់បង់នូវវិតក្កដែលគប្បីទូញយំទាំងនេះចេញ ។

[ ២៦៤ ] ភិក្ខុនោះក្នុងសាសនានេះ បានម្ហូបចំណីនិងគ្រឿងស្លៀកដណ្ដប់ក្នុងកាលដ៏គួរហើយ គប្បីដឹងប្រមាណដើម្បីសន្ដោស ភិក្ខុនោះជាអ្នកគ្រប់គ្រង

ក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក សូម្បីត្រូវគេកោសរូស ក៏មិនគប្បីពោលពាក្យទ្រគោះទេ ។

[ ២៦៥ ] អធិប្បាយពាក្យថា បានម្ហូបចំណីនិងគ្រឿងស្លៀកដណ្តប់ក្នុងកាលដ៏គួរ ត្រង់ពាក្យថា ម្ហូបចំណី បានដល់ បាយ នំកុម្មាស សដូវ ត្រី សាច់ ។ ពាក្យថា គ្រឿងស្លៀកដណ្តប់ បានដល់ ចីវរ ៦ យ៉ាង គឺចីវរដែលធ្វើដោយសម្បកឈើ ធ្វើដោយកប្បាស ធ្វើដោយសូត្រ ធ្វើដោយរោមសត្វ ធ្វើដោយសម្បកធ្មៃ ធ្វើលាយដោយវត្ថុ ៥ យ៉ាងខាងដើម ។ ពាក្យថា បានម្ហូបចំណីនិងគ្រឿងស្លៀកដណ្តប់ ក្នុងកាលដ៏គួរ បានសេចក្តីថា ភិក្ខុបានចីវរ បានបិណ្ឌបាត មិនមែនដោយកុហក មិនមែនដោយការរួសរាយ មិនមែនដោយការធ្វើនិមិត្ត មិនមែនដោយការកិនបំបាក់ មិនមែនដោយការស្វែងរកលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែនដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹក មិនមែនដោយការឲ្យផ្កា មិនមែនដោយការផ្លែ មិនមែនដោយការគ្រឿងកក់ មិនមែនដោយការឲ្យគ្រឿងលម្អិត មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្ទន់ មិនមែនដោយការឲ្យទឹកលុបមុខ មិនមែនដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន មិនមែនដោយភាព ជាអ្នកពោលពាក្យដូចសម្លសណ្តែកបាយ មិនមែនដោយភាពជាអ្នកបម្រើត្រកូល មិនមែនដោយភាពជាអ្នករលះរលាំងចូលទៅកាន់ផ្ទះ ហើយអង្គុយលើតាំង មិនមែនដោយវិជ្ជាទាយភូមិឋាន មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយវិជ្ជាទាយអវយវៈ មិនមែនដោយវិជ្ជាទាយនក្ខត្តឫក្ស មិនមែនដោយដំណើរជាទូត មិនមែនដោយ

ដំណើរដែលគេបញ្ជូនទៅ មិនមែនដោយការបម្រើដោយស្មុង មិនមែនដោយវេជ្ជកម្ម មិនមែនដោយឲ្យជុំបាយ មិនមែនដោយឲ្យទៅឲ្យមក គឺបានបានហើយបានចំពោះ បានចំពោះហើយ ដោយធម៌ដ៏ស្មើ ហេតុនោះ ( ទ្រង់ត្រាស់ថា ) បានម្ហូបចំណីនិងគ្រឿងស្លៀកដណ្តប់ក្នុងកាលដ៏គួរ ។

[ ២៦៦ ] អធិប្បាយពាក្យថា ភិក្ខុនោះក្នុងសាសនានេះ គប្បីដឹងប្រមាណដើម្បីសន្តោស ត្រង់ពាក្យថា ភិក្ខុនោះគប្បីដឹងប្រមាណ សេចក្តីថា ភិក្ខុដឹងប្រមាណដោយហេតុ ២ គឺដោយការទទួល ឬដោយការបរិភោគ ។

ភិក្ខុដឹងប្រមាណដោយការទទួល តើដូចម្តេច ។ ទោះវត្ថុតិចដែលទាយកឲ្យភិក្ខុទទួល ដើម្បីអាណិតត្រកូល ដើម្បីតាមរក្សាត្រកូល ដើម្បីអនុគ្រោះត្រកូល ទោះវត្ថុច្រើនដែលទាយកឲ្យ ភិក្ខុទទួលចីវរល្មមតែរក្សាកាយ ទទួលបិណ្ឌបាតល្មមតែរក្សាផ្ទៃ ភិក្ខុដឹងប្រមាណដោយការទទួលយ៉ាងនេះ ។

ភិក្ខុដឹងប្រមាណដោយការបរិភោគ តើដូចម្តេច ។ ភិក្ខុពិចារណាដោយឧបាយ ហើយប្រើប្រាស់ចីវរគ្រាន់តែដើម្បីការពារត្រជាក់ ដើម្បីការពារកម្តៅ ដើម្បីការពារសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃនិងពស់ទាំងឡាយ គ្រាន់តែដើម្បីបិទបាំងអវយវៈដែលធ្វើសេចក្តីខ្មាសឲ្យកម្រើក ភិក្ខុពិចារណាដោយឧបាយហើយបរិភោគបិណ្ឌបាតថា អាត្មាអញ ( បរិភោគ ) ដើម្បីការលេងក៏ទេ ដើម្បីការស្រវឹងក៏ទេ ដើម្បីការប្រដាប់ក៏ទេ ដើម្បីការផូរផង់ក៏ទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់សេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយៈ អាត្មាអញនឹងកម្ចាត់បង់នូវវេទនា

ចាស់ផង នឹងញុំាងវេទនាថ្មីមិនឲ្យកើតឡើងផង ការប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ផង សេចក្តីមិនមានទោសផង ការនៅសប្បាយផង នឹងមានដល់អាត្មាអញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។ ភិក្ខុពិចារណាដោយឧបាយ ហើយសេពសេនាសនៈ គ្រាន់តែដើម្បីការពារត្រជាក់ ដើម្បីការពារកម្តៅ ដើម្បីការពារសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃនិងពស់ទាំងឡាយ គ្រាន់តែដើម្បីបន្ទោបង់នូវអន្តរាយ គឺរដូវ និងការត្រេកអរក្នុងការសម្ងំនៅ ភិក្ខុពិចារណាដោយឧបាយ ហើយសេពនូវថ្នាំជាគ្រឿងកែរោគដែលជាបរិក្ខាររបស់ជីវិត គ្រាន់តែដើម្បីកម្ចាត់បង់វេទនាទាំងឡាយដែលបៀតបៀនផ្សេងៗដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។ ភិក្ខុដឹងប្រមាណដោយការបរិភោគយ៉ាងនេះ ។ ពាក្យថា ភិក្ខុនោះគប្បីដឹងប្រមាណ គឺគប្បីដឹងយល់ ដឹងច្បាស់ ដឹងចំពោះ ចាក់ធ្លុះចំពោះនូវប្រមាណដោយហេតុ ២ នេះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះគប្បីដឹងប្រមាណ ។

[ ២៦៧ ] ពាក្យថា ក្នុងសាសនានេះដើម្បីសន្តោស សេចក្តីថា ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរតាមមានតាមបាន ទាំងជាអ្នកសរសើរគុណសន្តោសដោយចីវរតាមមានតាមបាន តែងមិនដល់នូវអនេសនៈ ជាកម្មមិនសមគួរព្រោះហេតុនៃចីវរ មិនបានចីវរក៏មិនអន្ទះសា បានចីវរហើយក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រក្រតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ហើយបរិភោគ មួយទៀតមិនលើកតម្កើងខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែសន្តោសដោយចីវរតាមមានតាមបាននោះ ភិក្ខុណាឈ្លាសវៃ

មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតីក្នុងចីវរសន្តោសនោះ ភិក្ខុនេះលោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថា ប្រសើរដែលមានមកតាំងអំពីដើម ។ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយបិណ្ឌបាតតាមមានតាមបាន ទាំងជាអ្នកសរសើរគុណ សន្តោសដោយបិណ្ឌបាតតាមមានតាមបាន តែងមិនដល់នូវអនេសនៈ ជាកម្មមិនសមគួរ ព្រោះហេតុនៃបិណ្ឌបាត មិនបានបិណ្ឌបាតក៏មិនអន្ទះសា បានបិណ្ឌបាតហើយក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រក្រតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ហើយបរិភោគ មួយទៀត មិនលើកតម្កើងខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែសន្តោសដោយបិណ្ឌបាតតាមមានតាមបាននោះ ភិក្ខុណាឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតីក្នុងបិណ្ឌបាតសន្តោសនោះ ភិក្ខុនេះលោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថាប្រសើរដែលមានមកតាំងអំពីដើម ។ មួយទៀត ភិក្ខុជាអ្នកសន្តោស ដោយសេនាសនៈតាមមានតាមបាន ទាំងជាអ្នកសរសើរគុណសន្តោសដោយសេនាសនៈតាមមានតាមបាន តែងមិនដល់នូវអនេសនៈ ជាកម្មមិនសមគួរ ព្រោះហេតុនៃសេនាសនៈ មិនបានសេនាសនៈក៏មិនអន្ទះសា បានសេនាសនៈហើយក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រក្រតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ ហើយបរិភោគ មួយទៀតមិនលើកតម្កើងខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែសន្តោសដោយសេនាសនៈតាមមានតាមបាននោះ ភិក្ខុណាឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតីក្នុងសេនាសនៈសន្តោសនោះ ភិក្ខុនេះលោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស

ជាវង្សគេស្គាល់ថា ប្រសើរដែលមានមកតាំងអំពីដើម ។ មួយវិញទៀត ភិក្ខុជាអ្នកសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ទាំងជាអ្នកសរសើរគុណសន្តោស ដោយគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបាន តែងមិនដល់នូវអនេសនៈ ជាកម្មមិនសមគួរ ព្រោះហេតុគិលានប្បច្ចយភេសជ្ជបរិក្ខារ មិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារក៏មិនអន្ទះសា បានគិលានប្បច្ចយភេសជ្ជបរិក្ខារហើយក៏មិនជាប់ចំពាក់ មិនជ្រប់ មិនងប់ មានប្រក្រតីឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួន ហើយបរិភោគ មួយទៀតមិនលើកតម្កើងខ្លួន មិនបង្អាប់ជនដទៃ ព្រោះសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបាននោះ ភិក្ខុណាឈ្លាសវៃ មិនខ្ជិល មានការដឹងខ្លួន ប្រុងស្មារតីក្នុងគិលានប្បច្ចយភេសជ្ជបរិក្ខារសន្តោសនោះ ភិក្ខុនេះលោកហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាវង្សគេស្គាល់ថាប្រសើរ ដែលមានមកតាំងអំពីដើម ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះ ក្នុងសាសនានេះគប្បីស្គាល់ប្រមាណ ដើម្បីសន្តោស ។

[ ២៦៨ ] អធិប្បាយពាក្យថា ភិក្ខុនោះជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក ត្រង់ពាក្យថា ភិក្ខុនោះជាអ្នកគ្រប់គ្រងក្នុងបច្ច័យទាំង ៤ នោះ គឺជាអ្នកគ្រប់គ្រង បីបាច់ រក្សា សង្រួម ក្នុងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេជ្ជបរិក្ខារ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះ ជាអ្នកគ្រប់គ្រងក្នុងបច្ច័យទាំង ៤ នោះយ៉ាងនេះក៏មាន ។ មួយទៀត ភិក្ខុជាអ្នកគ្រប់គ្រង បីបាច់ រក្សា សង្រួម ក្នុងអាយតនៈទាំងឡាយ

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះ ជាអ្នកគ្រប់គ្រងអាយតនៈទាំងនោះ យ៉ាងនេះ ក៏មាន ។ ពាក្យថា ជាអ្នកប្រុងប្រយ័ត្នហើយត្រាច់ទៅក្នុងស្រុក គឺ ជាអ្នកប្រយ័ត្ន ប្រុងប្រៀប រៀបចំ គ្រប់គ្រង បីបាច់ រក្សា សង្រួមក្នុងស្រុក ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះ ជាអ្នកគ្រប់គ្រងក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក ។

[ ២៦៩ ] ពាក្យថា សូម្បីត្រូវគេកោសរូសក៏មិនគប្បីពោលពាក្យទ្រគោះ គឺត្រូវគេកោសរូស ជេរ ប្រទេច ខ្ទាំងខ្ទប់ តិះដៀល បន្អាប់បន្អោន ក៏មិនគប្បី និយាយតនឹងគេ ដែលនិយាយដោយពាក្យទ្រគោះអាក្រក់ មិនគប្បីជេរតនឹង គេដែលជេរ មិនគប្បីខឹងតនឹងគេដែលខឹង មិនគប្បីបង្កហេតុនឹងគេដែលបង្ក ហេតុ មិនគប្បីធ្វើជម្លោះ មិនគប្បីធ្វើកាបង្កហេតុ មិនគប្បីធ្វើការប្រកួតប្រកាន់ មិនគប្បីធ្វើវិវាទ មិនគប្បីធ្វើការប្រកែប្រកាន់ គឺគប្បីលះបង់ បន្ទោបង់ ធ្វើឲ្យ វិនាស ធ្វើឲ្យបាត់បង់នូវជម្លោះ ការបង្កហេតុ ការប្រកួតប្រកាន់ វិវាទនឹងការ ប្រកែប្រកាន់ គប្បីជាបុគ្គលវៀរឆ្ងាយ វៀរស្រឡះ វៀរផុត ចេញទៅ រលាស់ ចេញ ផុតស្រឡះ ប្រាសចេញ ចាកជម្លោះ ការបង្កហេតុ ការប្រកួតប្រកាន់ វិវាទនឹងការប្រកែប្រកាន់ ហើយនៅដោយចិត្តដែលធ្វើឲ្យប្រាសចាកដែន ហេតុ នោះ ( ទ្រង់ត្រាស់ថា ) សូម្បីត្រូវគេកោសរូសក៏មិនគប្បីពោលពាក្យទ្រគោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុនោះក្នុងសាសនានេះ បានម្ហូបចំណីនិងគ្រឿងស្លៀកដណ្តប់
ក្នុងកាលដ៏គួរហើយគប្បីដឹងប្រមាណដើម្បីសន្តោស ភិក្ខុនោះ

ជាអ្នកគ្រប់គ្រង ក្នុងបច្ច័យទាំង ៤ នោះ ជាអ្នកប្រុងប្រយ័ត្ន ហើយត្រាច់ទៅក្នុងស្រុក សូម្បីត្រូវគេគោសរូស ក៏មិនគប្បីពោលពាក្យទ្រគោះទេ ។

[ ២៧០ ] ភិក្ខុគប្បីមានភ្នែកសម្លឹងចុះក្រោម មិនគប្បីរលោភរលាំ ដោយជើង គប្បីប្រកបរឿយៗក្នុងឈាន ទាំងជាអ្នកភ្ញាក់រឭកច្រើន គប្បីប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ គប្បីផ្តាច់បង់នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីអាស្រ័យនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង ។

[ ២៧១ ] អធិប្បាយពាក្យថា ភិក្ខុគប្បីមានភ្នែកសម្លឹងចុះក្រោម គប្បីមិនរលោភរលាំដោយជើង សំណួរថា ភិក្ខុមានភ្នែកក្រឡេកមើល តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកឡេះឡោះដោយភ្នែក ប្រកបដោយការឡេះឡោះដោយភ្នែក គិតថាអាត្មាអញគួរឃើញរបស់ដែលមិនទាន់ឃើញ គួររំលងរបស់ដែលឃើញហើយ ប្រកបរឿយៗនូវការត្រាច់ទៅឆ្ងាយ ត្រាច់ទៅមិនឈប់ឈរ អំពីសួនច្បារទៅសួនច្បារ អំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពីនគរទៅនគរ អំពីដែនទៅដែន អំពីជនបទទៅជនបទដើម្បីមើលរូប ភិក្ខុមានភ្នែកក្រឡេកមើលយ៉ាងនេះក៏មាន ។ មួយទៀតភិក្ខុចូលទៅចន្លោះផ្ទះ ដើរតាមថ្នល់ទៅមិនសង្រួម ក្រឡេកមើលដំរី មើលសេះ មើលរថ មើលពលថ្មើរជើង មើលពួកស្រី មើលពួកប្រុស មើលពួកក្មេងប្រុស មើលពួកក្មេងស្រី មើលចន្លោះរានផ្សារ មើលមុខផ្ទះ មើលលើ មើលក្រោម សម្លឹងមើលទិសតូចនិងទិសធំ ភិក្ខុមានភ្នែកក្រឡេកមើលយ៉ាងនេះក៏មាន ។ មួយ

ទៀត ភិក្ខុបានឃើញរូបដោយភ្នែក ហើយជាអ្នកកាន់យកនិមិត្ត កាន់យកអនុព្យញ្ជនៈធម៌ទាំងឡាយ ជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្សគប្បីជាប់តាមនូវភិក្ខុ អ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែការមិនសង្រួមចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ភិក្ខុមានភ្នែកក្រឡេកមើល យ៉ាងនេះក៏មាន ។ មួយវិញទៀតដូចជាសមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ បរិភោគភោជនដែលគេឲ្យដោយសទ្ធា តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវការស្ដាប់និងការមើលល្បែងជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ គឺល្បែងរាំ ច្រៀង ប្រគំ មហោស្រព ចម្បាំងស្ដេចការតៈនិងព្រះរាមជាដើម គង រគាំង ស្គរមានជ្រុងបួន រូបគំនូរ ល្បែងដុំដែក ល្បែងរ៉ាវ ល្បែងលាងឆ្អឹង ប្រជល់ដំរី ប្រខាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់ពពែ ប្រជល់កែះ ប្រជល់មាន់ ប្រជល់ចាប ល្បែងគុណដំបង ប្រដាល់ ចំបាប់ ទីសម្រាប់ច្បាំងគ្នា ទីសម្រាប់រៀបពល ទីលំនៅកងទ័ពសេនាព្យូហ៍ ទីមើលកងទ័ព ដូចនេះខ្លះ ភិក្ខុមានភ្នែកក្រឡេកមើលយ៉ាងនេះក៏មាន ។ ភិក្ខុមានភ្នែកមិនក្រឡេកមើល តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនរឡេះរឡោះដោយភ្នែក ជាអ្នកមិនប្រកបដោយការរឡេះរឡោះដោយភ្នែក ដោយគិតថា អាត្មាអញត្រូវឃើញរបស់ដែលមិនទាន់ឃើញ ត្រូវរំលងរបស់ដែលឃើញហើយ មិនប្រកបរឿយៗនូវការត្រាច់ទៅឆ្ងាយ ត្រាច់ទៅមិនឈប់ឈរ អំពីសួនច្បារទៅសួនច្បារអំពីឧទ្យានទៅឧទ្យាន អំពីស្រុកទៅស្រុក អំពីនិគមទៅនិគម អំពី

ក្រុងទៅក្រុង អំពីដែនទៅដែន អំពីជនបទទៅជនបទ ដើម្បីមើលរូបទេ ភិក្ខុមានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុចូលទៅចន្លោះផ្ទះដើរតាមថ្នល់ទៅ សង្រួម មិនក្រឡេកមើលនូវដំរី ។បេ។ មិនសម្លឹងមើលទិសតូចនិងទិសធំដើរទៅ ភិក្ខុមានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញរូបដោយភ្នែក មិនកាន់យកនូវនិមិត្ត ។បេ។ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ភិក្ខុមានភ្នែកមិនក្រឡេកមើលយ៉ាងនេះខ្លះ ។ មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ ។បេ។ ទីមើលកងទ័ពដូចនេះខ្លះ ភិក្ខុនោះជាអ្នកវៀរស្រឡះចាកកិរិយាប្រកបរឿយៗនូវការស្តាប់និងការមើលល្បែងដែលជាសត្រូវមានសភាពយ៉ាងនេះ ភិក្ខុមានភ្នែកមិនក្រឡេកមើល យ៉ាងនេះខ្លះ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុគប្បីមានភ្នែកសម្លឹងចុះក្រោម ។

[ ២៧២ ] អធិប្បាយពាក្យថា មិនគប្បីរលោភរលាំដោយជើង សំណួរថា ភិក្ខុអ្នករលោភរលាំដោយជើង តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះជាអ្នករលោភរលាំដោយជើង ប្រកបដោយការរលោភរលាំដោយជើង ប្រកបរឿយៗនូវការត្រាច់ទៅឆ្ងាយ ត្រាច់ទៅមិនឈប់ឈរ អំពីសួនច្បារទៅសួនច្បារ ។បេ។ ដើម្បីកិរិយាឃើញរូប ភិក្ខុអ្នករលោភរលាំដោយជើង យ៉ាងនេះក៏មាន ។ មួយទៀតភិក្ខុ ជាអ្នករលោភរលាំដោយជើង ប្រកបដោយការរលោភរលាំដោយជើងខាងក្នុងសង្ឃារាម ជាអ្នកមានចិត្តអណ្តែតអណ្តូង មានចិត្តមិនស្ងប់ ទៅអំពីបរិវេណ កាន់បរិវេណ មិនមែនព្រោះហេតុនៃអត្ថ មិនមែនព្រោះហេតុនៃ

ការណ៍ ។បេ។ ពោលនូវកថា អំពីសេចក្ដីចម្រើននិងវិនាសដូច្នេះខ្លះ ដូច្នោះខ្លះ ភិក្ខុអ្នករលោភរលាំដោយជើងយ៉ាងនេះក៏មាន ។ ពាក្យថា មិនគប្បីរលោភរលាំដោយជើង បានសេចក្ដីថា គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់នូវការរលោភរលាំដោយជើង គប្បីជាអ្នកវៀរចា្ងយ វៀរចេញ វៀរស្រឡះ ចេញទៅ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ ចាកការរលោភរលាំដោយជើងសម្រាន្ត នៅដោយចិត្តដែលធ្វើឲ្យប្រាសចាកដែន ជាអ្នកមានការត្រេកអរក្នុងការពួនសម្ងំ ជាអ្នកត្រេកអរក្នុងការពួនសម្ងំ ជាអ្នកប្រកបនូវសេចក្ដីស្ងប់ចិត្តរបស់ខ្លួន មានឈានមិនសាបសូន្យប្រកបដោយវិបស្សនា ជាអ្នកចម្រើននូវការនៅក្នុងផ្ទះស្ងាត់ មានឈាន ត្រេកអរក្នុងឈាន ប្រកបនូវការនៅម្នាក់ឯងធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុគប្បីមានភ្នែកសម្លឹងចុះក្រោម មិនគប្បីរលោភរលាំដោយជើង ។

[ ២៧៣ ] អធិប្បាយពាក្យថា គប្បីប្រកបរឿយៗក្នុងឈាន ទាំងជាអ្នកភ្ញាក់រឭកច្រើន ត្រង់ពាក្យថា ប្រកបរឿយៗក្នុងឈាន គឺប្រកបរឿយៗ ក្នុងឈានដោយហេតុ ២ គឺប្រកបលែលកផ្សេផ្សំ ប្រកបព្រមដើម្បីញុំាងបឋមជ្ឈាន ដែលមិនទាន់កើតឲ្យកើតឡើង ឬប្រកបលែលកផ្សេផ្សំ ប្រកបព្រមដើម្បីញុំាងទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានដែលមិនទាន់កើតឲ្យកើតឡើង ហេតុនោះ ឈ្មោះថា ប្រកបរឿយៗក្នុងឈាន យ៉ាងនេះក៏មាន ។ មួយទៀតភិក្ខុគប់រកដោយច្រើន ចម្រើន ធ្វើឲ្យច្រើននូវបឋមជ្ឈានដែលកើតឡើងហើយ ឬគប់រកដោយច្រើន ចម្រើន ធ្វើឲ្យច្រើននូវទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន

ដែលកើតហើយ ហេតុនោះ ឈ្មោះថា ប្រកបរឿយៗក្នុងឈាន យ៉ាងនេះក៏មាន ។ ពាក្យថា ទាំងជាអ្នកភ្ញាក់រឭកច្រើន គឺភិក្ខុក្នុងសាសនានេះញុំាងចិត្តឲ្យស្អាតចាកធម៌ ជាគ្រឿងរារាំងដោយការចង្ក្រម ដោយការអង្គុយអស់វេលាថ្ងៃ ញុំាងចិត្តឲ្យស្អាតចាកធម៌ជាគ្រឿងរារាំង ដោយការចង្ក្រម ដោយការអង្គុយអស់បឋមយាមនៃរាត្រី សម្រេចសីហសេយ្យា ដោយបង្អៀងខាងស្តាំ ដាក់តម្រួតជើងម្ខាងលើជើងម្ខាង មានសតិ មានសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវសញ្ញាថា នឹងក្រោកអស់មជ្ឈិមយាមនៃរាត្រី ញុំាងចិត្តឲ្យស្អាត ចាកធម៌ជាគ្រឿងរារាំង ដោយការចង្ក្រម ដោយការអង្គុយ អស់បច្ឆិមយាមនៃរាត្រី ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីប្រកបរឿយៗ ក្នុងឈាន ទាំងជាអ្នកភ្ញាក់រឭកច្រើន ។

[ ២៧៤ ] ពាក្យថា គប្បីប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ ត្រង់ពាក្យថា ឧបេក្ខា បានដល់ ការតាំងចិត្តជាកណ្តាល ការព្រងើយ ការសម្ងំផ្ទះ ការមានចិត្តស្មើ ការមានចិត្តស្ងប់ ការមានចិត្តជាកណ្តាលក្នុងចតុត្ថជ្ឈាន ។ ពាក្យថា ជាអ្នកមានចិត្តតាំងមាំ គឺការតាំងនៅ ការឋិតនៅ ការឋិតនៅនឹង ការមិនកន្ទះរា ការមិនរវើរវាយ ការមិនរសាប់រសល់ ការស្ងប់នៃចិត្ត សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ។ ពាក្យថា គួរប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ បានសេចក្តីថា គួរប្រារព្ធឧបេក្ខាក្នុងចតុត្ថជ្ឈាន ហើយជាអ្នកមានចិត្តមូលក្នុងអារម្មណ៍តែមួយ មានចិត្តមិនរាយមាយ មានចិត្តមិនរសាប់រសល់ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ ។

[ ២៧៥ ] អធិប្បាយពាក្យថា គប្បីផ្តាច់បង់នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីអាស្រ័យនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង ត្រង់ពាក្យថា សេចក្តីត្រិះរិះបានដល់ សេចក្តីត្រិះរិះ ៩ គឺការត្រិះរិះកាម ការត្រិះរិះព្យាបាទ ការត្រិះរិះវិហឹសា ការត្រិះរិះញាតិ ការត្រិះរិះជនបទ ការត្រិះរិះទេវតា ការត្រិះរិះប្រកបដោយការអាណិតជនដទៃ ការត្រិះរិះប្រកបដោយលាភសក្ការៈនិងសេចក្តីសរសើរ ការត្រិះរិះប្រកបដោយសេចក្តីមិនឲ្យគេមើលងាយ នេះលោកហៅថា សេចក្តីត្រិះរិះទាំងប្រាំបួន ។ កាមសញ្ញាជាទីអាស្រ័យនៃកាមវិតក្ក ព្យាបាទសញ្ញា ជាទីអាស្រ័យនៃព្យាបាទវិតក្ក វិហឹសាសញ្ញាជាទីអាស្រ័យនៃវិហឹសាវិតក្ក ។ មួយទៀត អវិជ្ជា ជាទីអាស្រ័យ អយោនិសោមនសិការ ជាទីអាស្រ័យ អស្មិមានះជាទីអាស្រ័យ អនោត្តប្បៈ ជាទីអាស្រ័យ ឧទ្ធច្ច ជាទីអាស្រ័យ នៃវិតក្ក គឺសេចក្តីត្រិះរិះ ។ ពាក្យថា កុក្កុច្ច គឺកុក្កុច្ចបានដល់ការរពឹសដៃក៏មាន កុក្កុច្ចបានដល់ការរពឹសជើង ក៏មាន កុក្កុច្ចៈបានដល់ការរពឹសទាំងដៃទាំងជើង ក៏មាន សេចក្តីសម្គាល់ថាគួរក្នុងរបស់ដែលមិនគួរ សេចក្តីសម្គាល់ថាមិនគួរក្នុងរបស់ដែលគួរ សេចក្តីសម្គាល់ថាមានទោសក្នុងរបស់ដែលមិនមានទោស សេចក្តីសម្គាល់ថាមិនមានទោសក្នុងរបស់ដែលមានទោស សេចក្តីសង្ស័យ អាការនៃសេចក្តីសង្ស័យ ភាពនៃសេចក្តីសង្ស័យ សេចក្តីក្តៅក្រហាយនៃចិត្ត សភាវៈជាគំនូសនៃចិត្តឯណា មានសភាពយ៉ាងនេះ នេះលោកហៅថា កុក្កុច្ចៈ ។ មួយទៀត កុក្កុច្ចៈសេចក្តីក្តៅប្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើង ដោយហេតុ ២ គឺភាពដែលបានធ្វើ ១ ភាពដែលមិនបានធ្វើ ១ ។

កុក្កុច្ចៈ គឺសេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើង ដោយភាពដែលបានធ្វើនិងភាពដែលមិនបានធ្វើ តើដូចម្តេច ។ កុក្កុច្ចៈសេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើង ដោយគិតថា កាយទុច្ចរិតអាត្មាអញបានធ្វើ កាយសុចរិតអាត្មាអញមិនបានធ្វើទេ ។ វចីទុច្ចរិតអាត្មាអញបានធ្វើ ។ មនោទុច្ចរិតអាត្មាអញបានធ្វើ ។ កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើង ដោយគិតថា បាណាតិបាតអាត្មាអញបានធ្វើ ចេតនាជាហេតុវៀរចាកបាណាតិបាតអាត្មាអញមិនបានធ្វើទេ ។ អទិន្នាទាន អាត្មាអញបានធ្វើ ។ កាមេសុមិច្ឆាចារ អាត្មាអញបានធ្វើ ។ មុសាវាទ អាត្មាអញបានធ្វើ ។ បិសុណាវាចា អាត្មាអញបានធ្វើ ។ ផរុសវាចា អាត្មាអញបានធ្វើ ។ សម្ផប្បលាបៈ អាត្មាអញបានធ្វើ ។ អភិជ្ឈា អាត្មាអញបានធ្វើ ។ ព្យាបាទ អាត្មាអញបានធ្វើ ។ កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើងដោយគិតថា មិច្ឆាទិដ្ឋិ អាត្មាអញបានធ្វើ សម្មាទិដ្ឋិ អាត្មាអញមិនបានធ្វើទេ ។ កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើង ដោយភាពដែលបានធ្វើនិងភាពដែលមិនបានធ្វើ យ៉ាងនេះ ។ មួយវិញទៀត កុក្កុច្ចៈ សេចក្តីក្តៅក្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើង ដោយគិតថា អាត្មាអញជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ ជាអាត្មាអញ ជាអ្នកមិនមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ។ ជាអាត្មាអញជាអ្នកមិនស្គាល់ប្រមាណក្នុងភោជន ។ ជាអាត្មាអញជាអ្នកមិនប្រកបរឿយៗ នូវការភ្ញាករឭក ។ ជាអាត្មាអញ ជាអ្នកមិនប្រកបដោយសតិនិងសម្បជញ្ញៈ ។ ជាអាត្មាអញមិនបានចម្រើនសតិប្បដ្ឋាន ៤ ។ ជា

អាត្មាអញមិនបានចម្រើនសម្មប្បធាន ៤ ។ ថាអាត្មាអញមិនបានចម្រើនឥទ្ធិបាទ ៤ ។ ថាអាត្មាអញមិនបានចម្រើនឥន្ទ្រិយ ៥ ។ ថាអាត្មាអញមិនបានចម្រើនពលៈ ៥ ។ ថាអាត្មាអញមិនបានចម្រើនពោជ្ឈង្គ ៧ ។ ថាអាត្មាអញមិនបានចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ថាអាត្មាអញមិនបានកំណត់ដឹងនូវទុក្ខ ។ ថាអាត្មាអញមិនបានលះបង់ទុក្ខសមុទ័យ ។ ថាអាត្មាអញ មិនបានចម្រើនមគ្គ ។ កុក្កុច្ចៈ គឺសេចក្តីក្តៅប្រហាយនៃចិត្ត គំនូសនៃចិត្តកើតឡើងដោយគិតថា អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់នូវនិរោធទេ ។ ពាក្យថា គប្បីផ្តាច់បង់នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីតាំងនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង បានសេចក្តីថា គប្បីផ្តាច់បង់ គាស់ផ្តាច់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់នូវការត្រិះរិះផង នូវសភាវៈជាទីអាស្រ័យនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីផ្តាច់បង់នូវសេចក្តីត្រិះរិះផង នូវធម៌ជាទីតាំងនៃសេចក្តីត្រិះរិះផង នូវកុក្កុច្ចៈផង ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ភិក្ខុគប្បីមានភ្នែកសម្លឹងចុះក្រោម មិនគប្បីរលោភលាំដោយ
ជើងគប្បីប្រកបរឿយៗក្នុងឈាន ទាំងជាអ្នកភ្ញាក់រឭកច្រើនគប្បី
ប្រារព្ធឧបេក្ខា ហើយជាអ្នកមានចិត្តតាំងមាំ គប្បីផ្តាច់បង់នូវ
សេចក្តីត្រិះរិះផង នូវធម៌ជាទីអាស្រ័យនៃសេចក្តីត្រិះរិះផង នូវ
កុក្កុច្ចៈផង ។

[ ២៧៦ ] បុគ្គលដែលគេដាស់តឿនដោយវាចាហើយ គួរជាអ្នកមានស្មារតី ត្រេកអរចំពោះ គួរទម្លាយចោលនូវសេចក្តីរឹងត្អឹងចំពោះពួកសព្រហ្ម-

ចារី គួរបញ្ចេញវាចាជាកុសលកុំឲ្យហួសកម្រិត មិនគួរគិតគូរអំពីវាទធម៌របស់អ្នកផងទេ ។

[ ២៧៧ ] អធិប្បាយពាក្យថា បុគ្គលដែលគេដាស់តឿន ដោយវាចាហើយ គួរជាអ្នកមានស្មារតី ត្រេកអរចំពោះ ត្រង់ពាក្យថា ដែលគេដាស់តឿន សេចក្តីថា ឧបជ្ឈាយ៍ក្តី អាចារ្យក្តី ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នាក្តី ភិក្ខុមានអាចារ្យស្មើគ្នាក្តី មិត្តក្តី ជនដែលធ្លាប់ឃើញគ្នាក្តី ជនដែលធ្លាប់គប់រកគ្នាក្តី សម្លាញ់ក្តី ដាស់តឿនថា នៃលោកមានអាយុ អំពើរបស់លោកនេះ មិនគួរទេ អំពើរបស់លោកនេះ មិនសមល្មមទេ អំពើរបស់លោកនេះ មិនសមគួរទេ អំពើរបស់លោកនេះ មិនមែនតាំងនៅក្នុងសីលទេដូច្នេះ បុគ្គលគួរប្រុងស្មារតី ហើយត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ប្រាថ្នា រួសរាយ ប៉ុនប៉ង ស្រឡាញ់ជាប់ចិត្ត នឹងការដាស់តឿននោះ ។ ដូចស្ត្រីឬបុរសដែលនៅក្មេង ជាក្រមុំកំលោះ មានជាតិជាអ្នកប្រដាប់កាយ មានក្បាលកក់ហើយ បានកម្រងផ្កាឧប្បលក្តី កម្រងផ្កាម្លិះក្តី កម្រងផ្ការំដួលក្តី ហើយទទួលយកដោយដៃទាំងពីរ ប្រដាប់លើក្បាលដែលជាអវយវៈដ៏ឧត្តម រួចត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ប្រាថ្នា រួសរាយ ប៉ុនប៉ង ស្រឡាញ់ជាប់ចិត្ត យ៉ាងណា បុគ្គលគួរប្រុងស្មារតី ហើយត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ប្រាថ្នា រួសរាយ ប៉ុនប៉ង ស្រឡាញ់ ជាប់ចិត្តនូវការដាស់តឿននោះ ក៏យ៉ាងនោះដែរ ។

បុគ្គលបើឃើញនូវអ្នកប្រាជ្ញណា ដែលមានប្រកតីបង្ហាញទោស

ដែលឧស្សាហ៍ពោលផ្ចញ់ផ្ចាល់ ដូចជនអ្នកបង្ហាញកំណប់ទ្រព្យ គួរតែគប់រកនូវបណ្ឌិត ប្រាកដដូច្នោះ កាលបើបុគ្គលគប់រកបណ្ឌិតប្រាកដដូច្នោះ សេចក្ដីល្អរមែងកើតមាន មិនមែនជាការអាក្រក់ទេ ជនគួរទូន្មានគេ គួរប្រៀនប្រដៅគេ ទាំងគួរជួយរាំងចាកអសប្បុរស ដ្បិតថាជនអ្នកទូន្មានគេនោះ រមែងជាទីស្រឡាញ់នៃពួកសប្បុរស តែមិនជាទីស្រឡាញ់នៃពួកអសប្បុរសទេ ។

ហេតុនោះ ( ទ្រង់ត្រាស់ថា ) ដែលគេដាស់តឿនដោយវាចាហើយ គួរជាអ្នកត្រេកអរចំពោះ ។

[ ២៧៨ ] ពាក្យថា គួររំលាយបោល នូវសេចក្ដីរឹងត្អឹង ចំពោះពួកសព្រហ្មចារី សេចក្ដីថា បុគ្គលមានសង្ឃកម្មជាមួយគ្នា មានឧទ្ទេសជាមួយគ្នា មានការសិក្សាស្មើគ្នា ឈ្មោះថា សព្រហ្មចារី ។ ពាក្យថា គួរទម្លាយបោលនូវសេចក្ដីរឹងត្អឹង ចំពោះពួកសព្រហ្មចារី គឺគួរទម្លាយបោលនូវភាពនៃចិត្តចង្អៀតចង្អល់ ភាពនៃចិត្តរឹងត្អឹង ចំពោះពួកសព្រហ្មចារី គួរទម្លាយបោលនូវការរឹងត្អឹងនៃចិត្ត ៥ ផង គួរទម្លាយបោលនូវការរឹងត្អឹងនៃចិត្ត ៣ ផង គួរទម្លាយបោល បំបែកបោល កំទេចបោលនូវការរឹងត្អឹងដោយរាគៈ ការរឹងត្អឹងដោយទោសៈ ការរឹងត្អឹងដោយមោហៈ ព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) គួរទម្លាយបោលនូវសេចក្ដីរឹងត្អឹងចំពោះពួកសព្រហ្មចារី ។

[ ២៧៩ ] ពាក្យថា គួរបញ្ចេញវាចាជាកុសល កុំឲ្យហួសកម្រិត គឺគួរ

បញ្ចេញវាចាដែលផុសផុលឡើងអំពីប្រាជ្ញា គឺថាគួរបញ្ចេញ គួរបរិយា គួរស្រដីនូវវាចាដែលប្រកបដោយអត្ថ ប្រកបដោយធម៌ តាមកាលគួរ ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត អាស្រ័យប្រយោជន៍ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គួរបញ្ចេញវាចាជាកុសល ។ ពាក្យថា កម្រិត ក្នុងបទថា គួរបញ្ចេញវាចា កុំឲ្យហួសកម្រិត បានដល់ កម្រិត ២ គឺកម្រិតកាល ១ កម្រិតសីល ១ ។

កម្រិតកាល តើដូចម្តេច ។ បុគ្គលមិនគួរពោលវាចាឲ្យហួសកាល មិនគួរពោលវាចាឲ្យហួសកម្រិត មិនគួរពោលវាចាឲ្យកន្លងហួសកាលនិងកម្រិត មិនគួរពោលវាចាដែលមិនទាន់ដល់កាល មិនគួរពោលវាចាដែលមិនទាន់ដល់កម្រិត មិនគួរពោលវាចាដែលមិនទាន់ដល់កាលនិងកម្រិត ។

ជនណាកាលបើមិនទាន់ដល់កាលគួរទេ ហើយពោលឲ្យហួស
កម្រិត ជននោះរមែងដេកជាទុក្ខ ដូចកូនតាវ៉ៅដែលក្អែករក្សា
យ៉ាងនោះឯង ។

នេះ កម្រិតកាល ។

កម្រិតសីល តើដូចម្តេច ។ បុគ្គលត្រេកត្រអាលហើយ មិនគួរពោលវាចាប្រទូស្តហើយ មិនគួរពោលវាចាវង្វេងហើយ មិនគួរពោលវាចា មិនគួរពោលពាក្យកុហក មិនគួរពោលពាក្យញុះញង់ មិនគួរពោលពាក្យទ្រគោះ មិនគួរពោល មិនគួរនិយាយ មិនគួរបរិយា មិនគួរពណ៌នា មិនគួរស្រដីនូវពាក្យឥតប្រយោជន៍នេះកម្រិតសីលព្រោះហេតុនោះ ( ទ្រង់ត្រាស់ថា ) គួរបញ្ចេញវាចា

ជាកុសល កុំឲ្យហួសកម្រិត ។

[ ២៨០ ] ពាក្យថា មិនគួរគិតគូរអំពីវាទធម៌របស់អ្នកផង ត្រង់ពាក្យថា អ្នកផង បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សូទ្រ គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ បុគ្គលមិនគួរគិតគូរ មិនគួរញុំាងចេតនា ឲ្យកើតឡើង មិនគួរញុំាងសេចក្តីត្រិះរិះក្នុងចិត្តឲ្យកើតឡើង មិនគួរញុំាងការធ្វើទុកក្នុងចិត្តឲ្យកើតឡើង អំពីវាទៈ ការពោលបង្អាប់ ការនិន្ទា ការបន្តុះបង្អាប់ ការតិះដៀល ការនាំទោសរបស់ជន ព្រោះសីលវិបត្តិក្តី ព្រោះអាចារវិបត្តិក្តី ព្រោះទិដ្ឋិវិបត្តិក្តី ព្រោះអាជីវវិបត្តិក្តី ហេតុនោះ ( ទ្រង់ត្រាស់ថា ) មិនគួរគិតគូរអំពីវាទធម៌របស់អ្នកផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> បុគ្គលដែលគេដាស់តឿនដោយវាចាហើយ គួរជាអ្នកមានស្មារតី
> ត្រេកអរចំពោះ គួរទម្លាយចោលនូវសេចក្តីរឹងត្អឹង ចំពោះពួក
> សព្រហ្មចារី គួរបញ្ចេញវាចាជាកុសលកុំឲ្យហួសកម្រិត មិន
> គួរគិតគូរអំពីវាទធម៌របស់អ្នកផងទេ ។

[ ២៨១ ] មួយទៀត ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញនូវធូលីទាំងឡាយណា ធូលី ( ទាំងនោះ ) មាន ៥ ក្នុងលោក គួរសង្កត់សង្កិនតម្រេកក្នុងរូប សំឡេង រស ក្លិននិងផស្សៈទាំងឡាយ ។

[ ២៨២ ] ពាក្យថា មួយទៀត ធូលី ( ទាំងនោះ ) មាន ៥ ក្នុងលោក ត្រង់ពាក្យថា មួយទៀត គឺជាពាក្យតបទ ជាពាក្យជាប់ជំពាក់ដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា មួយទៀត

ធុលីជាលំដាប់នៃបទ ។ តម្រេកក្នុងរូប ១ តម្រេកក្នុងសំឡេង ១ តម្រេកក្នុងក្លិន ១ តម្រេកក្នុងរស ១ តម្រេកក្នុងផ្សព្វ ១ ឈ្មោះថា ធូលី ៥ ។ មួយទៀត

ធូលី គឺរាគៈ មិនមែនសំដៅយកលំអងទេ ពាក្យថា ធូលីទុំ
ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីទុំ
ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាស
ចាកធូលី ។ ធូលីគឺទោសៈ មិនមែនសំដៅយកលំអងទេ ពាក្យ
ថា ធូលីទុំជាឈ្មោះនៃទោសៈ បណ្ឌិតទាំងនោះ រមែងលះបង់
នូវធូលីទុំ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ
ដែលប្រាសចាកធូលី ។ ធូលី គឺមោហៈ មិនមែនសំដៅយក
លំអងទេ ពាក្យថា ធូលីទុំជាឈ្មោះនៃមោហៈ បណ្ឌិតទាំង
នោះ រមែងលះបង់នូវធូលីទុំ ហើយសម្រាកសម្រាន្តនៅក្នុង
សាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធ-លោក ធាតុលោក អាយតនលោក ហេតុនោះ ( ទ្រង់ត្រាស់ថា ) មួយទៀត ធូលី ( ទាំងនោះ ) មាន ៥ ក្នុងលោក ។

[ ២៨៣ ] អធិប្បាយពាក្យថា ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញនូវធូលីទាំងឡាយណា ត្រង់ពាក្យថា នូវធូលីទាំងឡាយណា គឺនូវតម្រេកក្នុងរូប តម្រេកក្នុងសំឡេង តម្រេកក្នុងក្លិន តម្រេកក្នុងរស តម្រេកក្នុងផ្សព្វ ។ ពាក្យថា មានស្មារតី សេចក្តីថា ការរឭក ការរឭករឿយៗ ការរឭកចំពោះ

ការនឹកឃើញ ការភ្នកឃើញ ការចាំទុក ការមិនភាន់ច្រឡំ ការមិនភ្លេច សតិ ឥន្ទ្រិយគឺសតិ កម្លាំងគឺសតិ ការរឭកប្រពៃ សម្មាសតិ គឺសតិផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯងឯណា នេះលោកហៅថា ស្មារតី ។ ភិក្ខុណាប្រកបប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម បរិបូណ៌ដោយស្មារតីនេះ ។ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា គួរសិក្សាបានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ អធិ-សីលសិក្ខា តើដូចម្ដេច ។បេ។ នេះអធិប្បញ្ញាសិក្ខា ។ ពាក្យថា ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញនូវធូលីទាំងឡាយណា បានសេចក្ដីថា បុគ្គលអ្នកមានស្មារតី គួរសិក្សាអធិសីលផង គួរសិក្សាអធិចិត្តផង គួរសិក្សាអធិប្បញ្ញាផង គប្បីនឹករំពឹងសិក្សា គប្បីដឹងសិក្សា ។បេ។ គប្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើ ឲ្យជាក់ច្បាស់សិក្សា គប្បីប្រព្រឹត្ត ប្រព្រឹត្តដោយប្រពៃ ប្រព្រឹត្តសមាទាននូវសិក្សាទាំង ៣ នេះ ដើម្បីកិរិយានាំចេញ ការបន្ទោបង់ ការលះបង់ ការរម្ងាប់ ការរលាស់ចេញ ការកម្ចាត់បង់នូវតម្រេកក្នុងរូប តម្រេកក្នុងសំឡេង តម្រេកក្នុងក្លិន តម្រេកក្នុងរស តម្រេកក្នុងផ្សព្វ ឯណា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញនូវធូលីទាំងឡាយណា ។

[ ២៨៤ ] ពាក្យថា គួរសង្កត់សង្កិននូវតម្រេកក្នុងរូប សំឡេង រស ក្លិន និងផស្សៈទាំងឡាយ គឺគួរសង្កត់សង្កិន គ្របសង្កត់ រឹបជាន់ ស្រំពន្លិច ជាន់កំទេច ញាំញីនូវតម្រេក ក្នុងរូប សំឡេង ក្លិន រស ផ្សព្វទាំងឡាយ ហេតុ

នោះ ( ទ្រង់ត្រាស់ថា ) គួរសង្កត់សង្កិនទូវតម្រេកក្នុងរូប សំឡេង រស ក្លិន និងផស្សៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀត ភិក្ខុមានស្មារតី គួរសិក្សាដើម្បីកិរិយានាំចេញនូវ
ធូលីទាំងឡាយណា ធូលី ( ទាំងនោះ ) មាន ៥ ក្នុងលោក គួរ
សង្កត់សង្កិត ម្រេកក្នុងរូប សំឡេង រស ក្លិននិងផស្សៈទាំង
ឡាយ ។

[ ២៨៥ ] ព្រះមានព្រះភាគត្រាស់ថា ភិក្ខុមានស្មារតី មានចិត្តផុតស្រឡះល្អ គប្បីបន្ទោបង់នូវសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ទាំងនុ៎ះចេញ ភិក្ខុនោះកាលពិចារណាធម៌ ដោយប្រពៃតាមកាលគួរ ភិក្ខុនោះនឹងជាអ្នកមានចិត្តខ្ពស់ឯកកម្ចាត់បង់នូវងងឹតបាន ។

[ ២៨៦ ] ពាក្យថា គប្បីបន្ទោបង់នូវសេចកក្តីប្រាថ្នាក្នុងអារម្មណ៍ ទាំងនុ៎ះចេញ ត្រង់ពាក្យថា ក្នុងអារម្មណ៍ទាំងនុ៎ះ គឺក្នុងរូប សំឡេង ក្លិន រស និងផ្សព្វ ។ ពាក្យថា សេចក្តីប្រាថ្នា បានដល់ សេចក្តីប្រាថ្នាគឺកាម តម្រេកគឺកាម សេចក្តីរីករាយគឺកាម បំណង់គឺកាម ស្នេហាគឺកាម ការក្តៅក្រហាយគឺកាម ការជ្រប់គឺកាម ការលិចលង់គឺកាម ឱឃៈគឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាមឆន្ទៈ ក្នុងកាមទាំងឡាយ ។ ពាក្យថា គប្បីបន្ទោបង់នូវសេចក្តីប្រាថ្នាក្នុងអារម្មណ៍ទាំងនុ៎ះចេញ គឺគប្បីនាំចេញ កម្ចាត់បង់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់នូវសេចក្តីប្រាថ្នាក្នុងអារម្មណ៍ទាំងនុ៎ះចេញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) គប្បីបន្ទោបង់នូវសេចកក្តីប្រាថ្នា

ក្នុងអារម្មណ៍ទាំងនុ៎ះចេញ ។

[ ២៨៧ ] អធិប្បាយពាក្យថា ភិក្ខុជាអ្នកមានស្មារតីមានចិត្តផុតស្រឡះល្អ ត្រង់ពាក្យថា ភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ។ ពាក្យថា ជាអ្នកមានស្មារតី សេចក្តីថា ការរឭក ការរឭករឿយៗ ។បេ។ ការរឭកដោយប្រពៃ សម្មោជ្ឈង្គ គឺសតិ ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង នេះលោកហៅថា ស្មារតី ។ ភិក្ខុប្រកបដោយស្មារតីនេះ ។បេ។ ភិក្ខុនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុជាអ្នកមានស្មារតី ។ ពាក្យថា មានចិត្តផុតស្រឡះល្អ សេចក្តីថា ចិត្តរបស់ភិក្ខុចូលបឋមជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អចាកនីវរណៈទាំងឡាយ ចិត្តរបស់ភិក្ខុចូលទុតិយជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកវិតក្កៈនិងវិចារៈទាំងឡាយ ចិត្តរបស់ភិក្ខុចូលតតិយជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកបីតិ ចិត្តរបស់ភិក្ខុចូលចតុត្ថជ្ឈាន ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អចាកសុខនិងទុក្ខទាំងឡាយ ចិត្តរបស់ភិក្ខុចូលអាកាសានញ្ចាយតនៈ ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាករូបសញ្ញា ចាកបដិឃសញ្ញា ចាកនានត្តសញ្ញា ចិត្តរបស់ភិក្ខុចូលវិញ្ញាណញ្ចាយតនៈ ជាចិត្ត ( ផុត ) ចាកអាកាសានញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុចូលអាកិញ្ចញ្ញាយតនៈជាចិត្ត ( ផុត ) ចាកវិញ្ញាណញ្ចាយតនសញ្ញា ចិត្តរបស់ភិក្ខុចូលនេវសញ្ញានាសញ្ញាយតនៈ ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាកអាកិញ្ចញ្ញាយតនសញ្ញា ចិត្តរបស់ភិក្ខុជាសោតាបន្នជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អចាកសក្កាយទិដ្ឋិ វិចិកិច្ឆា

សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យនិងកិលេសទាំងឡាយដែលនៅជាមួយនឹងសំយោជនៈនោះ ចិត្តរបស់ភិក្ខុដែលជាសកទាគាមិ ជាចិត្តផុតផុតស្រឡះ ផុតស្រឡះល្អ ចាកកាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាតនិងកិលេសទាំងឡាយ ដែលតាំងនៅជាមួយសំយោជនៈនោះ ចិត្តរបស់ភិក្ខុជាអនាគាមិ ជាចិត្តផុត ផុត ស្រឡះ ផុតស្រឡះល្អ ចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យដ៏ល្អិតនិងកិលេសទាំងឡាយ ដែលតាំងនៅជាមួយអនុស័យនោះ ចិត្តរបស់ភិក្ខុជាអរហន្ត ជាចិត្តផុត ផុតស្រឡះ ផុតស្រឡះល្អ ចាករូបរាគៈ អរូបរាគៈ មានៈឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យនិងកិលេសទាំងឡាយដែលតាំងនៅជាមួយអនុស័យនោះនិងនិមិត្តទាំងពួង ពួដ៏ខាងក្រៅ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុជាអ្នកមានស្មារតី មានចិត្តផុតស្រឡះល្អ ។

[ ២៨៨ ] អធិប្បាយពាក្យថា ភិក្ខុនោះកាលពិចារណាធម៌ដោយប្រពៃតាមកាលគួរ ត្រង់ពាក្យថា តាមកាលគួរ គឺកាលបើចិត្តរាយមាយនេះជាកាលគួរដល់សមថៈ កាលបើចិត្តតាំងមាំនេះជាកាលគួរដល់វិបស្សនា ។

ព្រះយោគី ជាអ្នកឈ្លាសវៃក្នុងកាល តែងផ្គងចិត្តក្នុងកាលគួរ
មួយទៀត តែងសង្កត់សង្កិនចិត្តក្នុងកាលដទៃ តែងពន្រើក
ពន្រាយចិត្តក្នុងកាលគួរ តែងតាំងចិត្តឲ្យមាំក្នុងកាលគួរ តែង
ព្រងើយកន្តើយក្នុងកាលគួរ ការគួរផ្គង ( ចិត្ត ) ក្នុងកាលដូច
ម្តេច ការគួរសង្កត់សង្កិន ( ចិត្ត ) ក្នុងកាលដូចម្តេច កាល

ជាទីពន្រឹកពន្រាយ ( ចិត្ត ) ក្នុងកាលដូចម្តេច កាលជាទីធ្វើនូវសមថៈតើដូចម្តេច ព្រះមានព្រះភាគ សម្តែងនូវកាលគួរដល់ការព្រងើយនៃចិត្តរបស់ព្រះយោគី ដោយប្រការដូចម្តេច ការគួរផ្គងក្នុងកាលចិត្តរួញរា ការគួរសង្កត់សង្កិន ក្នុងកាលចិត្តរាយមាយ ព្រះយោគីគួរពន្រឹកពន្រាយចិត្ត ដែលគ្មានសេចក្តីរីករាយ ក្នុងខណៈនោះឯង កាលណាចិត្តរីករាយ មិនរួញរា មិនរវើរវាយ កាលនោះជាកាលគួរដល់សមថៈ ព្រះយោគីគួរធ្វើចិត្តឲ្យរីករាយខាងក្នុង កាលណាចិត្តតាំងមាំដោយឧបាយទុំះយ៉ាងនេះ កាលនោះព្រះយោគីគួរធ្វើចិត្តដែលតាំងមាំ ឲ្យព្រងើយកន្តើយដោយប្រាជ្ញា អ្នកប្រាជ្ញជាអ្នកដឹងកាល ស្គាល់កាល ឈ្លាសវៃក្នុងកាល គួរកំណត់នូវនិមិត្តនៃចិត្តសព្វកាលយ៉ាងនេះ ។

ពាក្យថា ភិក្ខុនោះ កាលពិចារណាធម៌ដោយប្រពៃ តាមកាលគួរ បានសេចក្តីថា ពិចារណាធម៌ដោយប្រពៃថា សង្ខារទាំងពួងមិនទៀង ពិចារណាធម៌ដោយប្រពៃថា សង្ខារទាំងពួងជាទុក្ខ ពិចារណាធម៌ដោយប្រពៃថា ធម៌ទាំងពួងមិនមែនខ្លួន ។បេ។ ពិចារណាធម៌ដោយប្រពៃថា ធម្មជាតណាមួយ មានកិរិយាកើតជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ជាធម្មតា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ភិក្ខុនោះ កាលពិចារណាធម៌ដោយប្រពៃ ។

[ ២៨៩ ] អធិប្បាយពាក្យថា ព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះនឹង

ជាអ្នកមានចិត្តខ្ពស់ឯក កម្ចាត់បង់នូវងងឹត ត្រង់ពាក្យថា ជាអ្នកមានចិត្តខ្ពស់ឯក គឺមានចិត្តប្រសើរតែមួយ មានចិត្តមិនរាយមាយ មានចិត្តមិនកន្ទុះរា ហេតុនោះ ( ទ្រង់ត្រាស់ថា ) ជាអ្នកមានចិត្តខ្ពស់ឯក ។ ពាក្យថា ភិក្ខុនោះនឹងកម្ចាត់បង់នូវងងឹត គឺនឹងសម្លាប់ កម្ចាត់បង់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យបាត់បង់នូវងងឹតគឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹតគឺកិលេស ងងឹតគឺទុច្ចរិត ធម្មជាតជាគ្រឿងធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើឲ្យរលត់ប្រាជ្ញា ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ពាក្យថា ព្រះមានព្រះភាគ គឺជាពាក្យពោលដោយគោរព ។ មួយទៀតព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់រាគៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់ទោសៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះទ្រង់កាច់បង់មោហៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់មានះ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់ទិដ្ឋិ ។ ព្រះនាមថា មានព្រះភាគ ព្រោះទ្រង់កាច់បង់បន្លាគឺកាមគុណ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់កាច់បង់កិលេស ព្រះនាមថា មានព្រះភាគ ព្រោះទ្រង់ចែកញែករំលែកនូវធម្មរតនៈ ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់ធ្វើនូវទីបំផុតនៃភព ។ ព្រះនាមថាមានព្រះភាគ ព្រោះទ្រង់បានចម្រើនកាយ គឺរូបនិងនាម ។ ព្រះនាមថា មានព្រះភាគ ព្រោះទ្រង់បានចម្រើនសីល ព្រោះទ្រង់បានចម្រើនចិត្ត ព្រោះទ្រង់បានចម្រើនប្រាជ្ញា ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់បានគប់រកព្រៃតូច និងព្រៃធំ ជា

សេនាសនៈស្ងាត់ មានសំឡេងតិច មានការគឹកកងតិច ប្រាសចាកខ្យល់កាយនៃជន គួរដល់អំពើស្ងាត់របស់មនុស្ស សមគួរដល់កិរិយាពួនសម្ងំ ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេជ្ជបរិក្ខារ ។ មួយទៀត ព្រះនាមថាមានព្រះភាគព្រោះព្រះមានបុណ្យទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្តនិងអធិប្បញ្ញា ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ និងអរូបសមាបត្តិ ៤ ។ មួយទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយយតនៈ ៨ និង អនុបុព្វ-វិហារសមាបត្តិ ៩ ។ មួយទៀតព្រះនាមថា មានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបា-នស្សតិសមាធិនិងអសុភសមាបត្តិ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ មួយវិញទៀត ព្រះនាមថាមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជញ្ញាណ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ និងពុទ្ធធម៌ ៦ ។ ព្រះនាមថា ព្រះមានព្រះភាគនេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្តនិងអាមាត្យថ្វាយ មិនមែនពួកញាតិសាលោហិតថ្វាយ មិន

មែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ឯព្រះនាមថា ព្រះមានព្រះភាគនេះ មានក្នុងទីបំផុតនៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានជោគ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ ( កើត ) ដោយការធ្វើឲ្យជាក់ច្បាស់ព្រមទាំងការបាននូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ ( ទើបមានពាក្យថា ) ព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះនឹងជាអ្នកមានចិត្តខ្ពស់ឯក កម្ចាត់បង់នូវងងឹតបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ភិក្ខុមានស្មារតី មានចិត្តផុតស្រឡះល្អ គប្បីបន្ទោបង់នូវសេចក្តី
ប្រាថ្នាក្នុងអារម្មណ៍ទាំងនុ៎ះចេញ ភិក្ខុនោះ កាលពិចារណាធម៌
ដោយប្រពៃតាមកាលគួរ ភិក្ខុនោះ នឹងជាអ្នកមានចិត្តខ្ពស់ឯក
កម្ចាត់បង់ងងឹតបាន ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ ។

**ចប់ សារីបុត្តសុត្តនិទ្ទេសទី ១៦**

**ចប់ សុត្តនិទ្ទេសទាំង ១៦ ក្នុងអដ្ឋកវគ្គ**

# អដ្ឋកថា

# សារីបុត្តសុត្តនិទ្ទេសទី ១៦

គប្បីជ្រាបអត្ថក្នុងសារីបុត្តសុត្តនិទ្ទេសទី ១៦ ដែលមានពាក្យផ្ដើមថា **ន មេ ទិដ្ឋោ** ដូចតទៅនេះថា

[ ១៨៣ ] ក្នុងបទទាំងនោះ បទថា **ឥតោ បុព្ពេ** បានដល់ មុនអំពីព្រះមុនីយាងចុះត្រង់សង្កស្សនគរនេះ ។ បទថា **វគ្គុវទោ** បានដល់ មានព្រះសូរសៀងដ៏ពីរោះ ។ បទថា **តុសិតា គណិមាគតោ** បានដល់ យាងមកអំពីតុសិត ព្រោះឃ្លាតចាកតុសិត មកកាន់ផ្ទៃមាតា ឈ្មោះថា **គណី** ព្រោះជាគណាចារ្យឬថាយាងមកអំពីទេវលោក ឈ្មោះតុសិតដោយអត្ថថា ជាទីត្រេកអរ ហើយមកជាគណាចារ្យ ឬថាយាងមកជាគណាចារ្យនៃព្រះអរហន្តទាំងឡាយដែលត្រេកអរហើយ ។

[ ១៨៤ ] បទថា **ឥមិនា ចក្ខុនា** បានដល់ ដោយមំសចក្ខុតាមប្រក្រតីដែលទាក់ទងក្នុងអត្តភាពនេះ ។ បទថា **ឥមិនា អត្តភាវេន** បានដល់ ដោយអត្តភាពចុងក្រោយនេះ ។ បទថា **តាវតឹសភវនេ** បានដល់ ក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស ។ បទថា **បារិច្ឆត្តកមូលេ** បានដល់ ខាងក្រោមដើមរលួសផ្អុង ។ បទថា **បណ្ឌុកម្ពលសិលាយំ** បានដល់ លើថ្ម ដូចគ្នានឹងសំពត់កម្ពលពណ៌ក្រហម ។ បទថា **វស្សំ វុដ្ឋោ** បានដល់ ប្រថាប់គង់ចាំវស្សា ។ បទថា **ទេវគណបរិវុតោ** បានដល់ ដែលពួកទេវតា ចោមរោមហើយ ។ បទថា **ឱតិណ្ណោ** គឺ **អវតិណ្ណោ** ។ បទថា **ឥមំ ទស្សនំ បុព្ពេ** បានដល់

វៀរការឃើញគ្រានេះ មិនធ្លាប់ឃើញមកអំពីមុនឡើយ ។ បទថា **ន ទិដ្ឋោ** បានដល់ មិនធ្លាប់ឃើញក្នុងកាលដទៃ ។

[ ១៨៦ ] បទថា **ឧត្តិយស្ស វា** បានដល់ មិនធ្លាប់បានឮអំពីក្សត្រ ត្រាស់ប្រាប់ ក្នុងព្រាហ្មណ៍ជាដើមក៏មានន័យនេះដូចគ្នា ។

[ ១៨៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **មធុរវាចោ** ដូចតទៅនេះថា

ឈ្មោះថា **មធុរវាចោ** ព្រោះព្រះសាស្តាត្រាស់ពីរោះ បរិបូណ៌ដោយព្យញ្ជនៈ ។ ឈ្មោះថា **បេមនីយវាចោ** ព្រោះទ្រង់ត្រាស់ព្រះតម្រាស់ ដែលឲ្យកើត សេចក្តីស្រឡាញ់ គួរដល់សេចក្តីស្រឡាញ់ ។ ឈ្មោះថា **ហទយង្គមវាចោ** ព្រោះទ្រង់ត្រាស់ព្រះតម្រាស់ ប្រព្រឹត្តទៅក្នុងហទយៈ ។ ឈ្មោះថា **ករវិករុតមញ្ជុឃោសោ** ព្រោះទ្រង់មានព្រះសូរសៀងពីរោះ ដូចសត្វករវិក ។ បទថា **វិស្សដ្ឋោ ច** បានដល់ មិនគ្រលរ មិនស្អកស្អាក្នុងទីនោះៗ ។ បទថា **វិញ្ញេយ្យោ ច** បានដល់ ស្តាប់យល់បានងាយ ។ បទថា **មញ្ជុ ច** បានដល់ ទន់ផ្អែម ។ បទថា **សវនីយោ ច** បានដល់ ពីរោះត្រចៀក ។ បទថា **ពិន្ទុ ច** បានដល់ ជាសំឡេងមូល ។ បទថា **អវិសារី ច** បានដល់ មិនបែក ។ បទថា **គម្ភីរោ ច** បានដល់ មិនរាក់ ។ បទថា **និន្នាទិ ច** បានដល់ ជាសំឡេងក្រាំងក្រអៅ ។ បទថា **អស្ស** បានដល់ របស់ព្រះសាស្តាអង្គនោះ ។ បទថា **ពហិទ្ធា បរិសាយ** បានដល់ ខាងក្រៅបរិស័ទ ។ បទថា **ន និច្ឆរតិ** បានដល់ មិនចេញទៅ ព្រោះហេតុអ្វី

ព្រោះព្រះមានព្រះភាគ មានព្រះសូរ សៀងពីរោះបែបនេះ ចូរកុំវិនាសទៅដោយមិនមានហេតុឡើយ ។

បទថា **ព្រហ្មស្សរោ** បានដល់ ជនដទៃមានសំឡេងដាច់ខ្លះ មានសំឡេងស្អកខ្លះ មានសំឡេងដូចក្អែកខ្លះ តែព្រះមានព្រះភាគអង្គនេះមានព្រះសូរសៀងដូចសំឡេងរបស់មហាព្រហ្ម ។ ពិតហើយសំឡេងរបស់មហាព្រហ្មជាក់ច្បាស់ព្រោះមិនប្រឡាក់ដោយប្រមាត់និងស្លេស្ម ។ កម្មដែលទ្រង់ធ្វើទុកក៏ធ្វើឲ្យទីតាំងរបស់សំឡេងឲ្យបរិសុទ្ធិ ព្រោះមានកំណើតបរិសុទ្ធិ សំឡេងដែលតាំងឡើងអំពីព្រះនាភី ( ផ្ចិត ) ទើបជាក់ច្បាស់តាំងឡើងប្រកបដោយអង្គ ៨ ប្រការ ។ ឈ្មោះថា **ករវិកភាណី** ព្រោះមានសំឡេងដូចសត្វករវិក អធិប្បាយថា មានព្រះសូរសៀងពីរោះ ដូចសំឡេងយំនៃសត្វករវិកដែលកំពុងត្រេកអរ ។

បទថា **តារេតិ** បានដល់ ឲ្យផុតទីដែលមិនផុតភ័យ ។ បទថា **ឧត្តារេតិ** បានដល់ ឆ្លងឲ្យដល់ទឹកដីដែលផុតភ័យ ។ បទថា **និត្ថារេតិ** បានដល់ ឆ្លងឲ្យហួសទីដែលមិនផុតភ័យ ។ បទថា **បត្តារេតិ** បានដល់ នាំឆ្លង អធិប្បាយថា ឲ្យឆ្លងដូចដឹកដៃនាំឆ្លង ។ បទទាំងអស់នេះ ជាទីតាំងនៅក្នុងទីដែលផុតភ័យមានទីដែលឆ្លងហើយ ឆ្លងឡើងហើយនោះឯង ព្រោះហេតុនោះទើបព្រះសារីបុត្តត្រូវពោលថា រមែងឲ្យដល់ព្រមនូវទីដ៏ក្សេម ។ បទថា **សត្តេ** បានដល់ វេនេយ្យសត្វ ។ កន្តារគឺជាតិនោះឯង ឈ្មោះថា **ជាតិកន្តារំ** ព្រោះស្អុកខ្លាំងព្រោះមានការវិនាសច្រើននិងព្រោះឆ្លងបានលំបាក ។ នូវជាតិកន្តារនោះ ។

[ ១៨៨ ] បទថា **គណស្ស សុស្សូសតិ** បានដល់ គណៈតែងតាំងចិត្ត

ស្តាប់ ត្រងត្រាប់កំណត់នូវព្រះតម្រាស់របស់ព្រះអង្គ ។ បទថា **សោតំ ឱទហាតិ** បានដល់ តម្កល់សោតបសាទទុក ញុំាងសោតបសាទឲ្យតាំងចំពោះ ព្រោះបំណងនឹងស្តាប់ ។ បទថា **អញ្ញាចិត្តំ ឧបដ្ឋបេតិ** បានដល់ ចូលទៅតាំងចិត្តដើម្បីបំណងនឹងដឹង ។ បទថា **គណំ អកុសលា វុដ្ឋាបេត្វា** បានដល់ ញុំាងពួកជនឲ្យចេញចាកអកុសល ដែលកើតអំពីការមិនឈ្លាស ។ បទថា **កុសលេ បតិដ្ឋាបេតិ** បានដល់ ឲ្យតាំងនៅក្នុងកុសល ដែលកើតអំពីការឈ្លាស ។ បទថា **សង្ឃី** មានវិគ្គហៈថា ឈ្មោះថា **សង្ឃី** ព្រោះមានពួកដោយជាពួកធំ ។ ឈ្មោះថា **គណី** ព្រោះមានគណៈដោយអំណាចបរិស័ទ ។ ឈ្មោះថា **គណាចរិយោ** ព្រោះជាអាចារ្យរបស់គណៈ ។

[ ១៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **សទេវកស្ស លោកស្ស យថា ទិស្សតិ** សេចក្តីថា ព្រះមានព្រះភាគរមែងប្រាកដដល់មនុស្សទាំងឡាយ ដូចប្រាកដដល់លោក ព្រមទាំងទេវលោក ឬប្រាកដដោយប្រការណា ក៏ប្រាកដដោយពិតដោយមិនវិបរិត ។ បទថា **ចក្ខុមា** បានដល់ ព្រះមានព្រះភាគទ្រង់មានចក្ខុឧត្តម ។ បទថា **ឯកោ** បានដល់ ជាបុគ្គលឯកដោយគុណដែលបានដល់បព្វជ្ជាជាដើម ។ បទថា **រតឹ** បានដល់ នូវការត្រេកអរចំពោះនេក្ខម្មៈជាដើម ។

[ ១៩១ ] បទថា **បដិរូបកោ** បានដល់ កុណ្ឌលដែលធ្វើឲ្យឃើញដូចមាស ។ បទថា **មត្តិកាកុណ្ឌលោវ** បានដល់ ដូចកុណ្ឌល ដែលធ្វើដោយដី ។ បទថា **លោហឌ្ឍមាសោវ សុវណ្ណឆន្នោ** បានដល់ ដូចលោហមាសក

ដែលស្រោបដោយមាស ។ បទថា **បរិវារច្ឆន្នា** បានដល់ ចោមរោមដោយបរិវារ ។ បទថា **អន្តោ អសុទ្ធា** បានដល់ សមណព្រាហ្មណ៍ទាំងឡាយដែលមិនបរិសុទ្ធដោយកិលេស មានរាគៈជាដើមខាងក្នុង ។ បទថា **ពហិ សោភ-មានា** បានដល់ ស្អាតតែខាងក្រៅ ដោយចីវរជាដើម ។

បទថា **អកប្បិតឥរិយាបថោ ច** បានដល់ មានព្រះឥរិយាបថមិនបានលះបង់ហើយ ។ បទថា **បណិធិសម្បន្នោ** បានដល់ មានការប្រាថ្នាបរិបូណ៌ ។ បទថា **វិសុទ្ធសទ្ទោ** បានដល់ ទ្រង់មានព្រះកិត្តិសព្ទបរិសុទ្ធ អធិប្បាយថា មានសំឡេងសរសើរ តាមសេចក្ដីពិត ។ បទថា **ភជកិត្តិសទ្ទសិលោកោ** បានដល់ ទ្រង់ប្រព្រឹត្តតាមដែលបានទទួលព្រះកិត្តិយសនិងការសរសើរជាប្រក្រតី ។ បើសួរថា មានព្រះកិត្តិសព្ទដ៏បរិសុទ្ធក្នុងទីណា ឆ្លើយថា ក្នុងទីដែលពោលទុកពិស្ដារហើយ ដោយន័យជាដើមថា ក្នុងភពនៃនាគនិងភពនៃសុបណ្ណ ។ បទថា **តតោ ច ភិយ្យោ** បានដល់ ព្រះមានព្រះភាគទ្រង់ប្រាកដក្រៃលែងជាងប្រការដែលពោលហើយនោះ ដោយអំណាចនៃវេនេយ្យសត្វ ។

[ ១៩២ ] បទថា **សត្តំ រាគតមំ** បានដល់ ការងងឹតព្រោះរាគៈទាំងមូល ។ សូម្បីក្នុងបទថា ការងងឹតព្រោះទោសៈជាដើម ក៏មានន័យដូចគ្នា ។ បទថា **អន្ធករណំ** បានដល់ ធ្វើការបិទបាំងលោកដោយបញ្ញា ។ បទថា **អចក្ខុករណំ** បានដល់ មិនធ្វើនូវបញ្ញាចក្ខុ ។ បទថា **អញ្ញាណករណំ** បានដល់ មិនធ្វើឲ្យដឹង ដោយញាណ ។ បទថា **បញ្ញានិរោធិកំ** បានដល់ ធ្វើឲ្យបញ្ញាចក្ខុវិនាសទៅ ។ បទថា **វិឃាតបក្ខិកំ** បានដល់ ប្រព្រឹត្តទៅក្នុងចំណែកនៃការ

បៀតបៀន ។ បទថា **អនិព្វានសំវត្តនិកំ** បានដល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ដែលជាអមតៈ មិនមានបច្ច័យ ។

[ ១៩៣ ] បទថា **សព្វន្តំ តេន ពោធិញ្ញាណេន ពុជ្ឈិ** បានដល់ ត្រាស់ដឹងធម៌ទាំងពួងនោះ ដោយអំណាចនៃមគ្គញ្ញាណ ៤ នោះ ។ ទ្រង់ដឹង តាមត្រាស់ដឹង ដោយអំណាចនៃបឋមមគ្គ ទ្រង់ដឹងទូទៅ ទ្រង់ចាក់ធ្លុះដោយ ទុតិយមគ្គ ទ្រង់សម្រេច ទ្រង់ត្រាស់ដឹងព្រមទូវបដិវេធដោយអំណាចនៃតតិយមគ្គ ត្រាស់ដឹងដោយប្រពៃ ដោយការចាក់ធ្លុះមិនមានចំណែកសេសសល់ ដោយអំណាចនៃចតុត្ថមគ្គ ។ បទ ៣ គឺ **អធិគច្ឆិផស្សេសិ សច្ឆាកាសិ** គួរ ប្រកបដោយអំណាចនៃផល គឺទ្រង់បានចំពោះដោយអំណាចនៃបឋមផលនិង ទុតិយផល ទ្រង់ពាល់ត្រូវហើយដោយផស្សៈ គឺញាណ ដោយអំណាចនៃ តតិយផល ទ្រង់បានធ្វើឲ្យប្រចក្សដោយអំណាចនៃចតុត្ថផល ។ ម្យ៉ាងទៀត បទទាំង ៣ នោះរមែងប្រើបានជាមួយផលទីមួយៗនោះឯង ។

បទថា **នេក្ខម្មរតឹ** បានដល់ ការត្រេកអរ ដែលអាស្រ័យបព្វជ្ជាជាដើម កើតឡើង ។ បទថា **វិវេករតឹ** បានដល់ ការត្រេកអរដែលកើតឡើង ក្នុង ការស្ងាត់កាយជាដើម ។ បទថា **ឧបសមរតឹ** បានដល់ សេចក្តីត្រេកអរក្នុង ការស្ងប់កិលេស ។ បទថា **សម្ពោធិរតឹ** បានដល់ការត្រេកអរដែលកើតឡើង ដល់បុគ្គលពិចារណាមគ្គ ។

[ ១៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ដូចតទៅនេះថា បទថា **ពហូ-នមិទ ពន្ធានំ** បានដល់ របស់បុគ្គលជាច្រើន មានក្សត្រជាដើម ដែលប្រាថ្នា

ក្នុងសាសនានេះ ។ ពិតហើយសិស្សទាំងឡាយ លោកហៅថា **ពន្ធុ** ព្រោះមានការប្រព្រឹត្តទាក់ទងដោយអាចារ្យ ។ បទថា **អត្ថិ បញ្ហេន អាគមំ** បានដល់ ខ្ញុំព្រះអង្គមានសេចក្តីត្រូវការដោយបញ្ហាទើបមក ឬការមកដោយបញ្ហារបស់បុគ្គលដែលមានសេចក្តីត្រូវការ ឬមានការមកព្រោះបញ្ហា ។

[ ១៩៥ ] ក្នុងបទជាដើមថា **តំ ពុទ្ធំ** សូម្បីមិនមានបទថា **ពុទ្ធោ** ក៏លោកពោលថា **ពុទ្ធោ** ដោយបំណងនឹងសម្តែង ដល់ព្រះពុទ្ធអង្គនោះ ។ បទថា **សយម្ភូ** បានដល់ កើតឯងមិនមានអ្នកទូន្មានប្រៀនប្រដៅ ។ បទថា **អនាចរិយកោ** ជាពាក្យពង្រីកសេចក្តីនៃបទថា **សយម្ភូ** ។ ពិតហើយបុគ្គលណាមិនមានអាចារ្យ ដឹងច្បាស់ ចាក់ធ្លុះនូវអរិយសច្ច ដោយខ្លួនឯង បុគ្គលនោះឈ្មោះថា **សយម្ភូ** ។ បទថា **បុព្វេ អននុស្សុតេសុ** ជាដើម ជាពាក្យប្រកាសនូវអត្ថដែលព្រះអង្គ ជាអ្នកមិនមានអាចារ្យ ។ បទថា **អននុស្សុតេសុ** បានដល់ មិនធ្លាប់ស្តាប់មកអំពីអាចារ្យ ។ បទថា **សាមំ** បានដល់ ព្រះអង្គឯងនោះឯង ។ បទថា **អភិសម្ពុជ្ឈិ** បានដល់ ចាក់ធ្លុះដោយព្រះអង្គឯងយ៉ាងក្រៃលែង ។ បទថា **តត្ថ ច សព្វញ្ញុតំ បាបុណិ** បានដល់ ទ្រង់សម្រេចភាពជាសព្វញ្ញូក្នុងអរិយសច្ចទាំងឡាយនោះ ។ លោកពោលយ៉ាងនោះ ព្រោះព្រះមានព្រះភាគត្រាស់ដឹងអរិយសច្ច ដូចព្រះពុទ្ធទាំងឡាយត្រាស់ដឹងអរិយសច្ចទ្រង់ជាព្រះសព្វញ្ញូ ។ បាឋៈថា **សព្វញ្ញុតំ បត្តោ** ក៏មាន ។

បទថា **ពលេសុ ច វសីភាវំ** បានដល់ ទ្រង់ដល់នូវភាពជាធំក្នុងពលញ្ញាណរបស់ព្រះតថាគត ១០ ប្រការ អធិប្បាយថា បុគ្គលណាមានសភាពយ៉ាងនេះ

បុគ្គលនោះលោកហៅថា **ពុទ្ធោ** ។ ព្រះពុទ្ធជាសត្វវិសេស ជាការបញ្ញត្តឡើង ព្រោះអាស្រ័យព្រះញាណដែលបុគ្គលណាមួយកម្ចាត់មិនបាន ព្រះនិមិត្តដ៏កំពូល ការសម្រេចវិមោក្ខនិងព្រះខន្ធសន្តានដែលអប់រំមកហើយក្នុងធម៌ទាំងពួង ឬជាការបញ្ញត្តឡើង ព្រោះអាស្រ័យការត្រាស់ដឹងអរិយសច្ចដែលជាបទដ្ឋាននៃសព្វញ្ញុតញ្ញាណ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថាប្រកាសភាពជាពុទ្ធៈជាក់ច្បាស់ហើយ ដោយអត្ថ ។

ឥឡូវនេះព្រះសារីបុត្ត កាលនឹងឲ្យជាក់ច្បាស់ដោយព្យញ្ជនៈ ទើបពោលពាក្យថា **ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ** ដូច្នេះជាដើម ។

ក្នុងពាក្យថា ព្រះពុទ្ធ ចុះព្រះនាមថាព្រះពុទ្ធដោយអត្ថដូចម្តេច នោះមានសេចក្តីថា ឈ្មោះថា **ពុទ្ធោ** ព្រោះអត្ថថា ត្រាស់ដឹងអរិយសច្ចទាំងឡាយដូចហៅបុគ្គលដែលចូល ដល់ក្នុងលោកថាអ្នកដឹង ។ ឈ្មោះថា **ពុទ្ធោ** ព្រោះអត្ថថា ឲ្យពួកសត្វត្រាស់ដឹង ដូចហៅខ្យល់ដែលបក់ស្ងួកឈើឲ្យស្ងួតថា ខ្យល់ស្ងួកឈើស្ងួត ។ បទថា **សព្វញ្ញុតាយ ពុទ្ធោ** មាន អធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ដោយបញ្ញាដែលអាចត្រាស់ដឹងនូវធម៌ទាំងពួង ។ បទថា **សព្វទស្សាវិតាយ ពុទ្ធោ** មានអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ឃើញធម៌ទាំងពួងដោយញាណចក្ខុ ។ បទថា **អនញ្ញេយ្យតាយ ពុទ្ធោ** មានអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះត្រាស់ដឹងដោយព្រះអង្គឯងនោះឯង ដោយមិនចាំបាច់មានអ្នកដទៃធ្វើឲ្យត្រាស់ដឹង ។ បទថា **វិសវិតាយ ពុទ្ធោ** មានអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ដោយអត្ថថា ជាអ្នករីកដូចផ្កាឈូកព្រោះរីកដោយគុណ

ផ្សេងៗ ។ ដោយការសម្ដែង ៦ យ៉ាង មានសម្ដែងថា **វិណាសវសង្ខាតេន ពុទ្ធោ** ជាដើម មានអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះជាអ្នកភ្ញាក់ចាកការលក់ គឺកិលេសគ្រប់ប្រភេទ ដោយការលះនូវធម៌ដែលនាំឲ្យចិត្តកម្រើក ដូចបុរសភ្ញាក់ក្នុងទីបំផុតនៃការដេកលក់ ។ បទថា **សង្ខា សង្ខាតំ** ដោយអត្ថដូចគ្នាតែមួយ ។ បទថា **សង្ខាតេន** សេចក្ដីថា ដោយចំណែកនៃវាចា ។ លោកពោលឲ្យវិសេសក្រៃលែងឡើងដោយពាក្យថា **ឯករត្ត** ព្រោះលះកិលេសទាំងពួងមួយអន្លើដោយវាសនា ពោលគឺមិនមានកិលេសចូលទៅបូកលាប ព្រោះមិនមានគ្រឿងបូកលាប គឺតណ្ហានិងគ្រឿងបូកលាប គឺទិដ្ឋិ ។ បទថា **ឯករត្ត-និក្កិលេសោ** បានដល់ ជាអ្នកមិនមានកិលេសដោយកិលេសទាំងពួងដ៏សេសចាករាគៈ ទោសៈនិងមោហៈ ។

បទថា **ឯកាយនមគ្គំ គតោតិ ពុទ្ធោ** មានអធិប្បាយថា ធាតុទាំងឡាយជាប្រយោជន៍ដល់ការទៅ ព្រោះធាតុដែលជាប្រយោជន៍ដល់ការទៅ ជាគ្រឿងឲ្យត្រាស់ដឹង ព្រោះភាពជាប្រយោជន៍ដល់ការត្រាស់ដឹង ព្រោះហេតុនោះទើបឈ្មោះថា **ពុទ្ធោ** ព្រោះយាងទៅកាន់ឯកាយនមគ្គ ។ ម្យ៉ាងទៀតមគ្គដោយឈ្មោះថា **អយន** មានច្រើនឈ្មោះគឺ

> ឈ្មោះថាមគ្គ បានដល់ ផ្លូវ តម្រាយ គន្លង ប្រទេសសម្រាប់ទៅដោយជើង ទីសម្រាប់ដើរ ទីសម្រាប់ដើរទៅដើរមក ទូកស្ពានសម្រាប់ឆ្លងផែ ពោងពាយ[១]។

---

១-បិដកខ្មែរលេខ ៦៨ ឃ្លាប ១៣៦ ។

ក្នុងទីនេះ **ឯកាយនមគ្គ** លោកពោលទុកដោយឈ្មោះថា **មគ្គោ** ដែលពោលទុកហើយ ។ ព្រោះហេតុនោះមគ្គទើបជាផ្លូវតែ១ ។ អធិប្បាយថា មិនមែនផ្លូវ ២ ។ ម្យ៉ាងទៀតឈ្មោះថា ឯកាយនមគ្គ ព្រោះជាផ្លូវដែល**បុគ្គលម្នាក់**គប្បី**ដើរទៅ** ។ ពាក្យថា **បុគ្គលម្នាក់** បានដល់ បុគ្គលដែលស្ងាត់ ព្រោះលះការប្រឡូកប្រឡំដោយពួក ។ ពាក្យថា **ដើរទៅ** បានដល់ គប្បីបដិបត្តិ ។ ម្យ៉ាងទៀត ឈ្មោះថា **អយន** ព្រោះជាគ្រឿងប្រព្រឹត្តទៅ អធិប្បាយថា ទៅកាន់ព្រះនិព្វាន អំពីសង្សារវដ្ត ។ ឈ្មោះថា **ឯកាយន** ព្រោះជាផ្លូវទៅរបស់**បុគ្គលឯកទាំងឡាយ** ។ ពាក្យថា **បុគ្គលឯកទាំងឡាយ** គឺបុគ្គលប្រសើរទាំងឡាយ ។ ដ្បិតថាព្រះសម្មាសម្ពុទ្ធទាំងឡាយ ជាបុគ្គលប្រសើរជាងសត្វទាំងពួង ។ ព្រោះហេតុនោះទើបលោកអធិប្បាយទុកថា មគ្គជាផ្លូវរបស់បុគ្គលឯកទាំងនោះ ជាផ្លូវទៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ។ ម្យ៉ាងទៀត ឈ្មោះថា **អយន** ព្រោះទៅដល់ អធិប្បាយថា ទៅ គឺប្រព្រឹត្តទៅ ។ ឈ្មោះថា **ឯកាយនមគ្គោ** ព្រោះជាផ្លូវទៅក្នុងទីមួយ ។ លោកអធិប្បាយថា មគ្គប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនាតែមួយប៉ុណ្ណោះ មិនប្រព្រឹត្តទៅក្នុងទីដទៃឡើយ ។ ម្យ៉ាងទៀតឈ្មោះថា **ឯកាយន** ព្រោះទៅកាន់ទីតែមួយ លោកអធិប្បាយថា ខាងដើមសូម្បីប្រព្រឹត្តទៅដោយមុខការនានិងន័យផ្សេងៗ តែខាងចុងក៏ទៅកាន់និព្វានតែមួយប៉ុណ្ណោះ ។ ព្រោះហេតុនោះ បទថា **ឯកាយនមគ្គ** ទើបមានអធិប្បាយថា ជាផ្លូវទៅកាន់ព្រះនិព្វានតែម្យ៉ាង ។

បទថា **ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ** បានដល់ ឈ្មោះ

ថា ពុទ្ធោ ព្រោះមិនមែនអ្នកដទៃធ្វើឲ្យត្រាស់ដឹង លោកអធិប្បាយទុកដូចម្ដេច លោកអធិប្បាយទុកថា ឈ្មោះថា **ពុទ្ធោ** ព្រោះត្រាស់ដឹងក្រៃលែងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ដោយព្រះអង្គឯងប៉ុណ្ណោះ ។ ក្នុងបទថា **អពុទ្ធិវិហាតត្តា ពុទ្ធិប្បដិលាភត្តា ពុទ្ធោ** នេះ ជាពាក្យអធិប្បាយរបស់បទថា **ពុទ្ធិ ពុទ្ធំ ពោធោ** នោះឯង ។ ក្នុងបទនោះ លោកពោលដើម្បីឲ្យដឹងថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ប្រកបដោយគុណរបស់ព្រះពុទ្ធ ដូចពោលថា សំពត់ខៀវ សំពត់ក្រហមព្រោះប្រកបដោយគុណនិងលក្ខណៈមានពណ៌ខៀវពណ៌ក្រហម ( នោះឯង ) ។

បន្ទាប់អំពីនោះ បទថា **ពុទ្ធោតិ នេតំ ឆាមំ** លោកពោលទុក ដើម្បីឲ្យដឹងថានេះជាបញ្ញត្តតាមអត្ថ ។ ក្នុងបទនេះមិត្តគឺសម្លាញ់ អាមាត្យគឺអ្នកថែរក្សាញាតិគឺញាតិខាងបិតា សាលោហិតគឺញាតិខាងមាតា សមណៈគឺអ្នកចូលដល់បព្វជ្ជា ព្រាហ្មណ៍គឺជាអ្នកពោលថាចម្រើន ឬអ្នកស្ងប់បាប អ្នកបន្សាត់បាបបានហើយ ទេវតាគឺសក្កទេវរាជជាដើមមួយអន្លើដោយព្រហ្ម ។ បទថា **វិមោក្ខន្តិកំ** មានអធិប្បាយថា វិមោក្ខ គឺអរហត្តមគ្គ ។ ទីបំផុតនៃវិមោក្ខ គឺអរហត្តផល ។ ព្រះនាមមានក្នុងទីបំផុតនៃវិមោក្ខនោះ ឈ្មោះថា វិមោក្ខន្តិកៈ ។ ពិតហើយ ភាពជាព្រះសព្វញ្ញូរមែងសម្រេចដោយអរហត្តមគ្គ តែរមែងសម្រេចបរិបូណ៌បានក្នុងការកើតឡើងនៃអរហត្តផល ។ ព្រោះហេតុនោះ ទើបភាពជាព្រះសព្វញ្ញូ មានក្នុងទីបំផុតនៃវិមោក្ខ ។ នេមិត្តកនាមនោះក៏ជាឈ្មោះ មានក្នុងទីបំផុត នៃវិមោក្ខ ។ ដោយហេតុនោះ ទើបលោកពោលថា **វិមោក្ខន្តិកំ នេតំ**

**ពុទ្ធានំ ភគវន្តានំ** ។ បទថា **ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា** សេចក្តីថា ព្រមគ្នានឹងការបានសព្វញ្ញុតញ្ញាណ ក្នុងខណៈតាមដែលពោលហើយ នាមណ្ឌលពោធិព្រឹក្ស ។ បទថា **សច្ចិកា បញ្ញត្តិ** បានដល់ ជាបញ្ញត្តិកើតឡើង ដោយការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ឬដោយការធ្វើ ឲ្យជាក់ច្បាស់នូវធម៌ទាំងពួង គឺបញ្ញត្តិថា **ពុទ្ធោ** ។ បទថា **ពុទ្ធោ** នេះ ដោយព្យញ្ជនៈបានដល់ ការប្រកាសភាពជាព្រះពុទ្ធ ។

[ ២០១ ] បន្ទាប់អំពីនេះបទចុងក្រោយថា **វិហាស្សំ ភាវំ** រមែងប្រព្រឹត្តទៅតាមបាលីនោះឯង ព្រោះមានន័យដូចពោលហើយក្នុងទីនោះៗ ។

[ ២០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៤ ដូចតទៅនេះថា បទថា **វិជិគុច្ឆតោ** បានដល់ ចង្អៀតចង្អល់ដោយជាតិ ។ បទថា **រិត្តមាសនំ** បានដល់ នូវគ្រែនិងតាំងដ៏ស្ងាត់ ។ បទថា **បព្វតានំ គុហាសុ វា** បានដល់ ក្នុងគុហានៃភ្នំ គួរភ្ជាប់បទថា **រិត្តមាសនំ ភជតោ** ។

[ ២០៣ ] បទថា **ជាតិយា វិជិគុច្ឆតោ** បានដល់ ខ្ពើមនូវជាតិ ។ សូម្បីក្នុងបទថា **ជរាយ ព្យាធិនា** ជាដើម ក៏មានន័យនេះដូចគ្នា ។

[ ២០៤ ] បទថា **ភជតោ** បានដល់ សមគប់ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សេវតោ** ជាដើម ដូចតទៅនេះថា

បទថា **សេវតោ** បានដល់ សេព ។ បទថា **និសេវតោ** បានដល់ សេពដោយប្រពៃ ។ បទថា **សំសេវតោ** បានដល់ សេពរឿយៗ ។ បទថា **បដិសេវតោ** បានដល់ ចូលទៅហើយសេព ។

[ ២០៦ ] បទថា **បញ្ចសបណ្ណាភា** បានដល់ ពោះនៃភ្នំ ។

[ ២០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៥ ដូចតទៅនេះថា បទថា **ឧច្ចាវចេសុ** បានដល់ ថោកទាបនិងប្រណីត ។ បទថា **សយនេសុ** បានដល់ ក្នុងសេនាសនៈមានវិហារជាដើម ។ បទថា **កីវន្តោ** បានដល់ យំ ។ បាឋៈថា **កុវន្តោ** ក៏មានអធិប្បាយថា ព្រោះហេតុនៃការខ្លាចក្នុងទីនោះមានប្រមាណប៉ុនណា ។

[ ២០៩ ] បទថា **កុវន្តោ** បានដល់ ធ្វើនូវសំឡេង ។ បទថា **កូជន្តោ** បានដល់ ធ្វើសំឡេងមិនជាក់ច្បាស់ ។ បទថា **ឆនន្តោ** បានដល់ ធ្វើសំឡេងខ្លាំង ។ បទថា **សទ្ទំ ករោន្តោ** បានដល់ បញ្ចេញសំឡេង ។ បទថា **កតិ** ជាពាក្យសួរ ។ បទថា **កិត្តកា** ជាពាក្យសួរដោយប្រមាណ ។ បទថា **កីវតកា** ជាពាក្យសួរកំណត់ ។ បទថា **កីវពហុកា** ជាពាក្យសួរកំណត់ប្រមាណ ។ បទថា **តេ ភេរវា** បានដល់ ឧបទ្ទវកើតអំពីការខ្លាចទាំងនោះ គឺអារម្មណ៍គួរខ្លាច ។ ព្រះសារីបុត្តឆ្លើយដោយពាក្យថា **សីហា ព្យគ្ឃា ទីបិ** ដូច្នេះជាដើម ដើម្បីសម្តែងអារម្មណ៍ដែលសួរថា ច្រើនប៉ុន្មាន ។

[ ២១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៦ ដូចតទៅនេះថា បទថា **កតិ បរិស្សយា** បានដល់ ឧបទ្ទវ មានប្រមាណប៉ុនណា ។ បទថា **អគតំ ទិសំ** បានដល់ ព្រះនិព្វាន ។ ពិតហើយនិព្វាននោះឈ្មោះថា **អគតំ** ព្រោះមិនធ្លាប់ទៅអំពីមុន ។ ឈ្មោះថា **ទិសា** ព្រោះគួរចង្អុលបង្ហាញ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា **អគតំ ទិសំ** ដូច្នេះ ។ បាលីថា **អមតំទិសំ** ក៏

មាន ។ បទថា **អភិសម្ភវេ** បានដល់ គប្បីយកឈ្នះ ។ បទថា **បន្តម្ហិ** បានដល់ នូវទីបំផុតដែន ។

[២១៤] បទថា **អគតបុព្វា សា ទិសា** បានដល់ ទិសណាមិនធ្លាប់ទៅសូម្បីតែយល់សប្តិ ។ បទថា **ន សា ទិសា គតបុព្វា** បានដល់ ទិសនោះមិនធ្លាប់ទៅ ដោយន័យដូចពោលហើយ ។ បទថា **ឥមិនា ទីឃេន អទ្ធុនា** បានដល់ ដោយកាលវែងនេះ ។

បទថា **សមតិត្តិកំ** បានដល់ ភាជនប្រេងពេញដល់កណ្តាប់មាត់ខាងក្នុង ។ បទថា **អនវសេកំ** បានដល់ ឲ្យហូរចុះមិនបាន គឺបន្ថែមឲ្យពេញទៀតមិនបាន ។ បទថា **តេលបត្តំ** បានដល់ ភាជនប្រេងដែលដាក់ប្រេងហើយ ។ បទថា **បរិហរេយ្យ** បានដល់ គប្បីនាំទៅ គប្បីកាន់យកទៅ ។ បទថា **ឯវំ សចិត្តមនុរក្ខេ** បានដល់ ភិក្ខុដាក់ចិត្តរបស់ខ្លួនដូចភាជនៈពេញដោយប្រេងនោះទុកក្នុងរវាងធម៌ទាំង ២ គឺ ក្នុងគោចរដោយកាយគតាសតិ និងក្នុងសតិដែលសម្បយុត្ត ហើយមិនរាយមាយទៅក្នុងគោចរខាងក្រៅសូម្បីតែមួយសន្ទុះយ៉ាងណា ព្រះយោគាវចរអ្នកឈ្លាសគប្បីរក្សា គប្បីឃុំគ្រងក៏យ៉ាងនោះ ព្រោះអ្វី ព្រោះថា

> ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ( ព្រោះថា ) ចិត្តដែលហ្វឹកហ្វឺនបានហើយរមែងនាំមកនូវសេចក្តីសុខ ។

ព្រោះចិត្តនេះ

អ្នកមានប្រាជ្ញា គួររក្សាចិត្ត ដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះ ទៅតាមសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ ( ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

ព្រោះចិត្តនេះ

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលនៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯងរមែងរួចចាកចំណងនៃមារ ។

តែសម្រាប់បុគ្គលក្រៅអំពីនេះ

ប្រាជ្ញារមែងមិនបរិបូណ៌ ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។

តែសម្រាប់បុគ្គលមានកម្មដ្ឋានជាសម្លាញ់មាំទាំ

ភ័យរមែងមិនមានដល់បុគ្គល អ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ចាំងខ្ចប់មិនបាន មានបុណ្យនិងបាបលះបោល ហើយភ្ញាក់រឭកជានិច្ច ។

ព្រោះហេតុនោះ

អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បានដូច

អ្នកធ្វើព្រួញពត់ព្រួញឲ្យត្រង់[១] ។

កាលធ្វើចិត្តឲ្យត្រង់យ៉ាងនេះ គប្បីតាមរក្សាចិត្តរបស់ខ្លួន ឈ្មោះថារក្សារបស់ខ្លួនរឿយៗ ។ បទថា **បត្ថយានោ ទិសំ អគតបុព្វំ** សេចក្តីថា ព្រះយោគាវចរ កាលប្រាថ្នាទិសដែលមិនធ្លាប់ទៅ ក្នុងសង្សារដែលមានខាងដើមនិងទីបំផុតដែលបុគ្គលណាមួយដឹងមិនបានដោយប្រារព្ធការងារក្នុងកម្មដ្ឋាន គឺកាយគតាសតិនេះ គប្បីរក្សាចិត្តរបស់ខ្លួនដោយន័យដែលពោលហើយ ។

អ្វីឈ្មោះថា ទិស មាតាបិតាជាដើមលោកពោលថាជាទិស ដូចក្នុងគាថា ( សិង្គាលកសូត្រ ) នេះថា

មាតាបិតាជាទិសខាងកើត អាចារ្យជាទិសខាងត្បូង កូនប្រពន្ធ
ជាទិសខាងលិច មិត្តអាមាត្យជាទិសខាងជើង ទាសៈនិងកម្មករ
ជាទិសខាងក្រោម សមណព្រាហ្មណ៍ជាទិសខាងលើ គ្រហស្ថ
ក្នុងត្រកូលដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយ
នុ៎ះ ។

ទិស មានទិសខាងកើតជាដើម លោកពោល ( ទុកក្នុងធទ្ទជាតក ) ថាទិសក្នុងគាថានេះថា

បណ្តាទិសទាំង ១០ នេះគឺ ទិសធំ ៤ ទិសតូច ៤ ទិសខាង
លើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រី ទ្រង់ព្រះសុបិន
ឃើញដីរដ៏ប្រសើរ មានក្អកប្រាំមួយ ឋិតនៅក្នុងទិសណា ។

---

១-គាថាទាំង ៦ នេះ ជាគាថាធម្មបទ ។

និព្វានលោកពោលថាជាទិស ដូចក្នុងគាថា ( សេតកេតុជាតក ) នេះថា

ពួកជនជាគ្រហស្ថ ជាអ្នកឲ្យបាយទឹកនិងសំពត់ ជាអ្នកហៅរក ( នូវអ្នកទទួលទាន ) ណាអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើមពោលនូវបុគ្គលនោះថាជាទិស (ខាងលើ) ម្នាលសេតកេតុ បុគ្គលមានទុក្ខ ត្រឡប់ជាបានសេចក្តីសុខវិញ ព្រោះដល់នូវទិស ( និព្វាន ) ណា ទិសនុ៎ះជាទិសដ៏ប្រសើរ ដូច្នេះ ។

ព្រះនិព្វាននោះលោកបំណាងយកក្នុងទីនេះ ។ ព្រះនិព្វាននោះ នឹងប្រាកដនឹងអះអាងបានដោយបទជាដើមថា **តណ្ហាក្ខយោ វិរាគោ** ដូច្នេះ ព្រោះហេតុនោះ ទើបព្រះនិព្វានហៅថា ទិស ។ និព្វាន លោកហៅថា ទិសមិនធ្លាប់ទៅ ព្រោះពាលបុថុជ្ជនណាមួយ ក្នុងសង្សារដែលមានខាងដើមនិងទីបំផុត ដែលបុគ្គលណាមួយដឹងមិនបាន មិនធ្លាប់ទៅសូម្បីតែក្នុងយល់សប្តិ ។ បុគ្គលប្រាថ្នានិព្វាននោះ គួរធ្វើសេចក្តីព្យាយាម ដោយកាយគតាសតិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វជតោ** ដូច្នេះជាដើមដូចតទៅនេះថា កាលមគ្គជិតនឹងកើត ភិក្ខុឈ្មោះថា **វជតោ** ក្នុងខណៈតាំងនៅឈ្មោះថា **គច្ឆតោ** ព្រោះឃើញផលឈ្មោះថា **អភិក្កមតោ** ។

[ ២១៦ ] បទថា **អន្តេ** បានដល់ តាំងនៅក្នុងទីបំផុត ។ បទថា **បន្តេ** បានដល់ តាំងនៅជ្រៅខាងក្នុងព្រៃស្តុក ។ បទថា **បរិយន្តេ** បានដល់ តាំងនៅក្នុងទីបំផុតជុំវិញព្រោះការឆ្ងាយ ។ បទថា **សេលន្តេ** បានដល់ ក្នុងទីបំផុតនៃភ្នំ ។ បទថា **វនន្តេ** បានដល់ ចំណែកទីបំផុត នៃព្រៃក្រាស់ ។ បទថា

**ឆឆន្តេ** បានដល់ មាត់ស្ទឹង ។ បទថា **ឧឧកន្តេ** បានដល់ ក្នុងទីបំផុតទឹក ។ បទថា **យត្ថ ឆ កសិយតិ ឆ វបិយតិ** បានដល់ ជាទីដែលគេមិនធ្វើការភ្ជួររាស់ មិនធ្វើការសាបព្រោះ ។ តាំងនៅរំលងពួកជន ។ បទថា **មនុស្សានំ អនុបចារេ** បានដល់ ក្នុងសេនាសនៈដែលមនុស្សទាំងឡាយ មិនចូលទៅធ្វើការងារ ដោយការភ្ជួរនិងការសាបព្រោះ ។

[ ២១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៧ ដូចតទៅនេះថា បទថា **ក្យាស្ស ព្យប្បថយោ អស្សុ** បានដល់ ពាក្យរបស់ភិក្ខុនោះដូចម្ដេច ។

[ ២១៨ ] បទថា **មុសា** ក្នុងបទនេះថា **មុសាវាជំ បហាយ** បានដល់ វចីបយោគ ឬកាយប្បយោគ របស់បុគ្គលអ្នកប្រាថ្នានឹងពោលឲ្យខុស កាច់បំបាក់នូវប្រយោជន៍ ( អ្នកដទៃ ) ។ម្យ៉ាងទៀត ចេតនាដែលញ៉ាំងកាយប្បយោគ ឬវចីបយោគរបស់បុគ្គលដែលពោលឲ្យអ្នកដទៃយល់ខុស ឲ្យតាំងឡើងដល់បុគ្គលនោះ ដោយបំណងនឹងពោល ឲ្យឃ្លៀងឃ្លាត ឈ្មោះថា **មុសាវាឆ** ។ ម្យ៉ាងទៀត បទថា **មុសា** បានដល់ រឿងមិនពិត មិនមែន ។ បទថា **វាទោ** បានដល់ និយាយឲ្យគេដឹងតាមសេចក្ដីពិត ដោយជាភាពពិត ។ ម្យ៉ាងទៀត ចេតនាដែលញ៉ាំងការដឹងយ៉ាងនោះ ឲ្យតាំងឡើងដល់បុគ្គលអ្នកបំណងឲ្យអ្នកដទៃដឹងរឿងដែលមិនពិតថាជារឿងពិត ឈ្មោះថា **មុសាវាទោ** ។ មុសាវាទនោះកាច់បំបាក់នូវប្រយោជន៍ណា ព្រោះប្រយោជន៍នោះតិច ក៏មានទោសតិច ព្រោះប្រយោជន៍នោះច្រើនក៏មានទោសច្រើន ។ ម្យ៉ាងទៀតសម្រាប់គ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថាមិនមាន ព្រោះ

មិនបំណាច់ឲ្យទ្រព្យរបស់ខ្លួន មានទោសតិច មុសាវាទដែលបុគ្គលជាសាក្សី និយាយ ដើម្បីកាច់បំបាក់នូវប្រយោជន៍ មានទោសច្រើន សម្រាប់បព្វជិត មុសាវាទ ដែលប្រព្រឹត្តទៅដោយន័យក្នុងការដែលបានប្រេង ឬសប្បិបន្តិចបន្តួច ហើយពោលធ្វើឲ្យបរិបូរណ៍ថា ថ្ងៃនេះប្រេងក្នុងស្រុកហូរដូចស្ទឹងដូច្នេះ ដោយបំណងនឹងកំប្លែង មានទោសតិច សម្រាប់បព្វជិតដែលពោលក្នុងវត្ថុដែលមិនឃើញថាឃើញជាដើម មានទោសច្រើន ។

មុសាវាទនោះ មានអង្គ ៤ គឺរឿងមិនពិត ១ ចិត្តគិតនឹងពោលឲ្យខុស ១ ព្យាយាមនឹងពោលរឿងនោះ ១ អ្នកដទៃដឹងសេចក្ដីនោះ ១ ។

មុសាវាទជាសាហត្ថិកប្បយោគប៉ុណ្ណោះ ។ គប្បីឃើញការប្រកបធ្វើនោះក្នុងការធ្វើកិរិយាឲ្យអ្នកដទៃសម្គាល់ខុស ដោយកាយក្ដី ដោយរបស់ទាក់ទងដោយកាយក្ដី ដោយវាចាក្ដី ។ បើអ្នកដទៃដឹងសេចក្ដីនោះ ដោយកិរិយានោះ ចេតនាដែលញ៉ាំងកិរិយានេះឲ្យតាំងឡើង រមែងសម្រេចជាកម្ម គឺមុសាវាទក្នុងខណៈនោះឯង ។

ឈ្មោះថា **សច្ចវាទី** ព្រោះពោលពិត ឈ្មោះថា **សច្ចសន្ធោ** ព្រោះជាប់ត បន្តនូវពាក្យពិតដោយពាក្យពិត អធិប្បាយថា មិនពោលកុហកក្នុងចន្លោះៗ ។ បុគ្គលខ្លះ ជួនកាលពោលកុហកជួនកាលពោលពិតសច្ចៈនិងសច្ចៈ មិនជាប់តគ្នា ព្រោះសច្ចៈនោះ មានមុសាវាទចូលមកកាត់ត្រង់ចន្លោះៗ ព្រោះហេតុនោះ បុគ្គលនោះមិនឈ្មោះថា **សច្ចសន្ធោ** ។ តែបុគ្គលនេះមិនដូច្នោះ មិននិយាយកុហក សូម្បីព្រោះហេតុតែជីវិត សច្ចៈនិងសច្ចៈតជាប់គ្នា ព្រោះហេតុនោះទើប

ឈ្មោះថា **សច្ចសន្ធោ** ។

បទថា **ថេតោ** បានដល់ មាំទាំ អធិប្បាយថា ជាអ្នកមានវាចាមាំទាំ ។ បុគ្គលម្នាក់មានពាក្យមិនមាំទាំដូចសំពត់ជ្រលក់ដោយរមៀត ដូចបង្គោលដោតត្រង់គំនរអង្កាមនិងដូចត្រឡាចដាក់លើខ្នងសេះ ។ បុគ្គលម្នាក់មានពាក្យមាំទាំដូចគំនូសលើថ្មនិងដូចសសរខឿន សូម្បីយកដាវកាត់ក្បាលក៏មិនពោលពាក្យបែកជា ២ បុគ្គលនេះហៅថា **ថេតោ** ។

បទថា **បច្ចយិកោ** បានដល់ គប្បីកាន់យកបាន អធិប្បាយថា មានពាក្យជឿបាន ។ ពិតហើយបុគ្គលខ្លះជឿមិនបាន ។ កាលមានគេសួរថា ពាក្យនេះអ្នកណានិយាយ កាលគេឆ្លើយថា បុគ្គលនោះពោល ក៏ដល់នូវការពោលថា ពួកអ្នកកុំជឿពាក្យរបស់បុគ្គលនោះ ។ បុគ្គលម្នាក់ជាអ្នកមានពាក្យគួរជឿបាន កាលមានគេសួរថា ពាក្យនេះអ្នកណានិយាយក៏ឆ្លើយថា បុគ្គលនោះនិយាយ បុគ្គលនោះ ក៏ដល់នូវការទទួលថា បើអ្នកនោះនិយាយ ពាក្យនេះក៏យកជាប្រមាណបាន មិនមានអ្វីដែលគួរសាកសួរ ក្នុងឥឡូវនេះពាក្យនេះ យ៉ាងនោះឯង ។ បុគ្គលនេះហៅថា **បច្ចយិកោ** ។ បទថា **អវិសំវាទកោ លោកស្ស** សេចក្តីថា ព្រោះខ្លួនជាអ្នកពោលពាក្យពិតនោះ ទើបមិនឲ្យសត្វលោកយល់ខុស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **បិសុណំ វាចំ បហាយ** ដូចតទៅនេះថា បុគ្គលពោលវាចាណា ចំពោះបុគ្គលណា ធ្វើខ្លួនឲ្យជាទីស្រឡាញ់ ធ្វើអ្នកដទៃឲ្យជាបុគ្គលទទេ ក្នុងហទយៈរបស់បុគ្គលនោះ វាចានោះឈ្មោះថា

**បិសុណាវាចា** ។ វាចាដែលធ្វើខ្លួនខ្លះ អ្នកដទៃខ្លះឲ្យគ្រោតគ្រាតឬជាវាចាដែលគ្រោតគ្រាតឯង មិនពីរោះត្រចៀក មិនសុខផ្លូវចិត្ត ឈ្មោះថា **ផរុសវាចា** ។ ពាក្យរោយរាយ មិនមានប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** ។ ចេតនាដែលជាមូលនៃវាចាទាំងនោះ ក៏បានឈ្មោះថា **បិសុណាវាចា** ជាដើមនោះឯង ក្នុងទីនេះលោកបំណងយកចេតនានោះឯង ។

ចេតនាទាំងនោះ ចេតនាដែលញុំាងកាយប្បយោគនិងវចីបយោគ ឲ្យតាំងឡើងនៃបុគ្គលដែលមានចិត្តសៅហ្មង ដើម្បីទម្លាយអ្នកដទៃ ឬព្រោះបំណងឲ្យគេស្រឡាញ់ខ្លួន ឈ្មោះថា **បិសុណាវាចា** ។ បិសុណាវាចានោះមានទោសតិច ព្រោះបុគ្គល ដែលត្រូវធ្វើការបំបែកមានគុណតិច ឈ្មោះថាមានទោសច្រើន ព្រោះបុគ្គលដែលត្រូវធ្វើការបំបែកមានគុណច្រើន ។

បិសុណាវាចានោះមានអង្គ ៤ គឺអ្នកដទៃដែលត្រូវបំបែក ១ ប្រាថ្នាឲ្យបែកគ្នាដោយគិតថា បុគ្គលនេះនឹងបែកគ្នាយ៉ាងនេះ ឬភាពជាអ្នកប្រាថ្នាឲ្យជាទីស្រឡាញ់ដោយគិតថា អញនឹងជាទីស្រឡាញ់ ជាអ្នកស្និទ្ធស្នាល យ៉ាងនេះ ១ ព្យាយាមធ្វើឲ្យបែកគ្នាអំពីចិត្តនោះ ១ បុគ្គលនោះដឹងសេចក្ដីនោះ ១ ។

បទថា **ឥមេសំ ភេទាយ** បានដល់ ដើម្បីបំបែកបុគ្គលដែលត្រូវហៅថាខាងនេះ ដែលខ្លួនទៅស្ដាប់ពាក្យក្នុងសម្នាក់របស់បុគ្គលនោះមក ។ បទថា **ភិន្នានំ វា សន្ធាតា** បានដល់ កាលមិត្តឬអ្នករួមឧបជ្ឈាយ៍ជាដើមបែកគ្នាដោយហេតុឯណាមួយ បុគ្គលនោះ ចូលទៅរកបុគ្គលទីមួយ ៗ ហើយពោលថា ការបែកគ្នានេះមិនសមគួរដល់ពួកអ្នកដែលកើតក្នុងត្រកូលបែបនេះ

ជាពហូសូតយ៉ាងនេះ ហើយធ្វើការរាប់អានគ្នា ។ បទថា **អនុប្បទាតា** បាន ដល់ ឲ្យកម្លាំងមនុស្សដែលព្រមព្រៀងគ្នា អធិប្បាយថា ឃើញបុគ្គល ២ នាក់ សាមគ្គីគ្នា ហើយពោលពាក្យជាដើមថា សេចក្តីនេះជាការសមគួរដល់ពួកអ្នក ដែលកើតក្នុងត្រកូលបែបនេះ ប្រកបដោយគុណបែបនេះហើយធ្វើឲ្យមាំទាំ ។ ឈ្មោះថា **សមគ្គារាមោ** ព្រោះអត្ថថា បុគ្គលដែលព្រមព្រៀងគ្នា ជាទីមក ត្រេកអររបស់បុគ្គលនោះ អធិប្បាយថា បុគ្គលព្រមព្រៀងគ្នា មិនមានក្នុងទី ណា ក៏គួរមែនមិនប្រាថ្នាសូម្បីតែនៅក្នុងទីនោះ ។ បាលីថា **សមគ្គរាមោ** ដូច្នេះ ក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **សមគ្គរតោ** បានដល់ ត្រេកអរហើយ ក្នុងបុគ្គលដែលព្រមព្រៀងគ្នា អធិប្បាយថា មិនប្រាថ្នានឹងលះបុគ្គលដែលព្រម ព្រៀងទាំងនោះទៅនៅទីដទៃ ។ ឈ្មោះថា **សមគ្គនន្ទី** ព្រោះអត្ថថា ឃើញខ្លះ ឮខ្លះនូវបុគ្គលដែលព្រមព្រៀងគ្នា រមែងត្រេកអរ ។ បទថា **សមគ្គករណឹ វាចំ ភាសិតា** បានដល់ ពោលវាចាសម្តែងគុណនៃការព្រមព្រៀងគ្នា ធ្វើឲ្យ សត្វទាំងឡាយព្រមព្រៀងគ្នា មិនពោលពាក្យក្រៅអំពីនេះ ។

ចេតនាគ្រោតគ្រាតដោយចំណែក ១ ញ៉ាំងកាយប្បយោគនិងវចីបយោគ កាត់នូវចំណែកសំខាន់នៃរាងកាយ ( បេះដូង ) របស់អ្នកដទៃ ឈ្មោះថា **ផរុសវាចា** ។ ប្រយោគដែលកាត់នូវចំណែកសំខាន់របស់រាងកាយ ក៏មិនជា ផរុសវាចា ព្រោះចិត្តទន់ភ្លន់ ។ ពិតហើយមាតាបិតាជួនកាលក៏ពោលនឹងបុត្ត យ៉ាងនេះថា សូមឲ្យចោរកាប់ពួកអាឲ្យជាកំណាត់ៗចុះដូច្នេះ ទាំងដែលមាតា បិតាមិនប្រាថ្នា សូម្បីតែស្លឹកឈូកធ្លាក់លើក្បាលរបស់កូនទាំងនោះ ។ ម្យ៉ាង

*ទៀត អាចារ្យនិងឧបជ្ឈាយ៍ ជួនកាលពោលនឹងសិស្សទាំងឡាយ យ៉ាងនេះថា ហេតុអ្វី ជនទាំងនេះមិនមានហិរិឱត្តប្បៈ ពួកឯងចូរចេញទៅ ។ តាមពិត អាចារ្យនិងឧបជ្ឈាយ៍ ប្រាថ្នាឲ្យអន្តេវាសិកដល់ព្រមដោយអាគមនិងអធិគម ។ ម្យ៉ាងទៀត ព្រោះចិត្តទន់រមែងមិនជាផរុសវាចាយ៉ាងណា ព្រោះពាក្យពោលទន់ភ្លន់ មិនជាផរុសវាចា ក៏មិនមែនយ៉ាងនោះ ។ ពិតហើយ វាចារបស់បុគ្គលដែលបំណងឲ្យគេស្លាប់ថា ចូរឲ្យបុគ្គលនេះដេកឲ្យសប្បាយចុះ ដូច្នេះ មិនមែនផរុសវាចាក៏មិនមែន ព្រោះចិត្តគ្រោតគ្រាត ទើបពាក្យនោះជាផរុសវាចាពិត ។ វាចាមានទោសតិច ព្រោះនិយាយគ្រោតគ្រាតដល់បុគ្គលមានគុណតិច មានទោសច្រើន ព្រោះនិយាយគ្រោតគ្រាត ដល់បុគ្គលមានគុណច្រើន ។*

*ផរុសវាចានោះមានអង្គ ៣ គឺអ្នកដទៃដែលត្រូវជេរ ១ ចិត្តក្រោធ ១ ការជេរ ១ ។ បទថា* **នេលា** *ទោស លោកហៅថា* **ឯល** *។ ឈ្មោះថា* **នេល** *ព្រោះអត្ថថា វាចានោះមិនមានទោស អធិប្បាយថា ឥតទោស ដូចពាក្យថា* **នេល** *ដែលលោកពោលទុកក្នុងសេចក្តីនេះថា* **នេលង្គោ សេតបច្ឆាទោ** *( រថគឺអត្តភាព ) មានអវយវៈឥតទោស មានដំបូលស ដូច្នេះ ។ បទថា* **កណ្ណសុខា** *បានដល់ វាចាជាសុខដល់ត្រចៀកព្រោះពីរោះដោយព្យញ្ជនៈមិនធ្វើឲ្យកើតនូវការចាក់ត្រចៀកដូចចាក់ដោយម្ជុល ។ វាចាឈ្មោះថា* **បេមនីយា** *ព្រោះអត្ថថា មិនឲ្យកើតសេចក្តីក្រោធក្នុងសកលកាយ ឲ្យកើតតែសេចក្តីស្រឡាញ់ ព្រោះពីរោះដោយអត្ថ ។ វាចាឈ្មោះថា* **ហទយង្គមា** *ព្រោះអត្ថ*

ថា ឈមចុះដល់ហទយៈ ចូលទៅដល់ចិត្ត បានដោយងាយមិនទើសទាក់ ។ វាចាឈ្មោះថា **ចោរី** ព្រោះអត្ថថា ជាពាក្យក្នុងក្រុង បរិបូណ៌ដោយគុណ ។ ព្រោះអត្ថថា ជាពាក្យរបស់កុមារល្អ ដូចនារីចម្រើនហើយក្នុងក្រុង ។ ព្រោះអត្ថថា ជាពាក្យរបស់អ្នកក្រុង អធិប្បាយថា ជាពាក្យរបស់បុគ្គលដែលនៅក្នុងក្រុង ។ ពិតហើយ អ្នកក្រុងរមែងជាអ្នកពោលពាក្យសម្តីសមគួរ ពោលនឹងបុរសស្រករឪពុកថាឪពុក ស្រករបងថាបង ។ វាចាឈ្មោះថា **ពហុជនកន្តា** ព្រោះអត្ថថា ពាក្យបែបនោះជាទីស្រឡាញ់របស់ជនច្រើន ។ ឈ្មោះថា **ពហុ-ជនមនាបា** ព្រោះអត្ថថា ជាទីពេញចិត្តរបស់ជនច្រើន ធ្វើនូវការចម្រើនដល់ចិត្ត ដ្បិតជាវាចាគួរស្រឡាញ់ ។ អកុសលចេតនាដែលញុំាងកាយប្បយោគនិងវចីបយោគឲ្យតាំងឡើង ឲ្យអ្នកដទៃដឹងរឿងឥតប្រយោជន៍ ឈ្មោះថា **សម្ផប្បលាបោ** ។ សម្ផប្បលាបនោះ មានទោសតិច ព្រោះអាសេវនៈតិច មានទោសច្រើន ព្រោះអាសេវនៈច្រើន ។

សម្ផប្បលាបមានអង្គ ២ គឺប្រាថ្នាពោលពាក្យមិនមានប្រយោជន៍ មានរឿងភារតយុទ្ធ និងរឿងដណ្តើមនាងសីតាជាដើម ១ ពោលនូវពាក្យបែបនោះ ១ ។

ឈ្មោះថា **កាលវាទី** ព្រោះអត្ថថា ពោលតាមកាលដែលគួរ អធិប្បាយថា ពោលកំណត់កាលដែលគួរពោល ។ ឈ្មោះថា **ភូតវាទី** ព្រោះអត្ថថា និយាយពាក្យពិត ពាក្យមែន ដែលកើតតាមសភាវៈ ។ ឈ្មោះថា **អត្ថវាទី** ព្រោះអត្ថថា ពោលអាស្រ័យប្រយោជន៍ក្នុងបច្ចុប្បន្ននិងភពខាងមុខ ។ ឈ្មោះ

ថា **ធម្មវាទី** ព្រោះអត្ថថា ពោលអាស្រ័យលោកុត្តរធម៌ ៩ ។ ឈ្មោះថា **វិនយវាទី** ព្រោះអត្ថថា ពោលអាស្រ័យសំវរវិន័យនិងបហានវិន័យ ។ វាចាជាគោលហៅថា **និធាន** ។ ឈ្មោះថា **និធានវតី** ព្រោះអត្ថថា និយាយមានគោលអាង ។ អធិប្បាយថា ពោលវាចាដែលគួរចាំទុកក្នុងហទយៈ ។ បទថា **កាលេន** បានដល់ ពោលវាចាបែបនេះដោយគិតថា ខ្ញុំនឹងពោលវាចាមានគោលដូច្នេះ ក៏មិនពោលក្នុងកាលដែលមិនគួរ អធិប្បាយថា ពិចារណាកាលដែលគួរហើយទើបពោល ។ បទថា **សាបទេសំ** សេចក្ដីថា មានប្រៀបធៀបនិងមានហេតុផល ។ បទថា **បរិយន្តវតី** សេចក្ដីថា សម្ដែងព្រំដែន ហើយពោលដោយអាការៈដែលព្រំដែនរបស់វាចានោះប្រាកដ ។ បទថា **អត្ថសញ្ហិតំ** បានដល់ ដល់ព្រមទៅដោយប្រយោជន៍ ព្រោះវាចានោះដែលបុគ្គលចែកដោយន័យមិនមែនតិចមិនអាចនឹងកាន់យកបានអស់ឬបុគ្គលពោលប្រយោជន៍នោះ រមែងពោលដល់ប្រយោជន៍ណា រមែងពោលវាចាដែលប្រកបដោយប្រយោជន៍ ព្រោះប្រកបដោយប្រយោជន៍នោះ លោកអធិប្បាយថា មិនលើកបែបមួយហើយពោលបែបដទៃ ។

បទថា **ចតូហិ វចីសុចរិតេហិ** បានដល់ ដោយការប្រព្រឹត្តល្អដែលប្រកបហើយដោយវាចា ៤ យ៉ាងដូចពោលហើយ ដោយន័យជាដើមថា **មុសាវាទំ បហាយ** ដូច្នេះ ។ បទថា **សមន្នាគតោ** បានដល់ ដែលមិនវិនាស ។ បទថា **ចតុទ្ទោសាបគតំ វាចំ ភាសតិ** បានដល់ ពោលវាចាប្រាសចាក គឺវិនាសចាកទោស ៤ យ៉ាង មានវាចាមិនជាទីស្រឡាញ់ជាដើម ។

[ ២១៩ ] បទថា **អត្ថិ គោចរោ** សេចក្តីថា ព្រះថេរៈបំណាច់នឹងពោលដល់សមណគោចរទើបលើកបទថា **អត្ថិ អគោចរោ អត្ថិ គោចរោ** ដូច្នេះ ។ ពិតហើយ ដូចបុរសដែលឈ្លាសក្នុងផ្លូវ កាលប្រាប់ផ្លូវរមែងប្រាប់ផ្លូវមានភ័យដែលជាផ្លូវមានអន្តរាយគួរវៀរមុនថា ចូរអ្នកវៀរផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្តាំដូច្នេះ ខាងក្រោយ ទើបប្រាប់ផ្លូវត្រង់ដែលជាផ្លូវផុតភ័យដែលគួរកាន់យកយ៉ាងណា ព្រះធម្មសេនាបតីដូចគ្នានឹងបុរសអ្នកឈ្លាសក្នុងផ្លូវក៏យ៉ាងនោះដូចគ្នា ប្រាប់នូវអគោចរដែលព្រះពុទ្ធទ្រង់តិះដៀលគួរលះបង់ជាមុន ហើយបំណាងនឹងប្រាប់គោចរ ជាក្រោយ ទើបពោលពាក្យជាដើមថា **កតមោ អគោចរោ** ដូច្នេះ ។ ពិតហើយផ្លូវដែលបុរសប្រាប់ត្រូវក៏មាន ខុសក៏មាន តែផ្លូវដែលព្រះមុនីត្រាស់ប្រាប់មិនជាផ្លូវខុស មិនជាផ្លូវឃៀងឃ្លាត ដូចវជិរាវុធដែលព្រះឥន្ទ្រគ្រវែងទៅដូច្នោះ រមែងប្រជុំចុះកាន់នគរ គឺនិព្វាននោះឯង ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយខន្ធវារវគ្គ ) ថា ម្នាលតិស្សៈ ពាក្យថាបុរសស្ទាត់ក្នុងផ្លូវនោះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ឬព្រោះការបំពេញកល្យាណធម៌នៃអ្នកលះបាបធម៌បានហើយ ជាវិធីការល្អព្រម ដូចវិធីការតាក់តែងគ្រឿងប្រដាប់ មានតាក់តែងផ្កា គ្រឿងក្រអូបនិងគ្រឿងលាបជាដើម នៃបុគ្គលដែលជម្រះនូវញើសក្អែលនិងធូលី ដោយការផ្ងូតទឹកតាំងអំពីក្បាលចុះមកដូច្នោះ ទើបព្រះសារីបុត្តត្ថេរជាអ្នកបំណាងនឹងប្រាប់អគោចរដែលគួរលះមុន ដូចញើសក្អែលនិងធូលីដែលគួរលះមុន ហើយ

ប្រាប់គោចរក្នុងកាលខាងក្រោយ ដូចវិធីតាក់តែងគ្រឿងប្រដាប់មានផ្កា គ្រឿងក្រអូបនិងគ្រឿងលាបជាដើម របស់បុគ្គលដែលជម្រះញើសក្អែល និងធូលីហើយដូច្នោះ ទើបពោលពាក្យជាដើមថា **គតមោ អគោចរោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **គោចរោ** បានដល់ ដែលសមគួរចូលទៅដើម្បីបិណ្ឌបាតជាដើម បទថា **អគោចរោ** បានដល់ ទីមិនសមគួរចូលទៅ ។ ឈ្មោះថា **វេសិយគោចរោ** ព្រោះអត្ថថា មានស្រីពេស្យាជាគោចរ អធិប្បាយថា ជាទីមនុស្សចូលទៅ ដោយអំណាចមិត្តសន្ថវៈនិងសេចក្ដីស្នេហា ។ ក្នុងបទនោះស្រីអាស្រ័យរូបចិញ្ចឹមជីវិត ឈ្មោះថា **វេសិយ** ។ បុគ្គលចូលទៅរកស្រីទាំងនោះដែលបុគ្គលណាមួយក៏រួមបវេណីបានងាយ ដោយអំណាចមិត្តសន្ថវៈនិងសេចក្ដីស្នេហ៍ស្និទ្ធ ឈ្មោះថាជាអ្នកមានស្រីពេស្យាជាគោចរ ព្រោះហេតុនោះ មិនគួរចូលទៅយ៉ាងនោះ ។ ព្រោះហេតុអ្វី ព្រោះវិបត្តិចាកការរក្សា ។ ពិតហើយភិក្ខុកាលចូលទៅយ៉ាងនោះ សមណធម៌ដែលរក្សាគ្រប់គ្រងមកអស់កាលយូរ រមែងវិនាសទៅដោយថ្ងៃបន្តិចបន្តួចនោះឯង បើមិនវិនាសក៏បានទទួលនូវការតិះដៀល តែបើចូលទៅទាក់ទងដោយការឲ្យទាន គួរតម្កល់ស្មារតីចូលទៅ ។

ស្រីប្ដីស្លាប់ ឬស្រីប្ដីលែង ឈ្មោះថា **វិធវា** គឺស្រីមេម៉ាយ ។

បទថា **ថុល្លកុមារិយោ** បានដល់ ស្រីចាស់ គឺមិនមានភាពជាស្រីក្មេងនៅសល់ ។ បទថា **បណ្ឌកា** បានដល់ ពួកនបុំសកៈ ច្រើនទៅដោយវាចានិយាយអាស្រ័យលោកាមិសៈ មានកិលេសក្រាស់ ក្ដៅក្រហាយមិនស្រាកស្រាន្ត ។

ទោសក្នុងការចូលទៅរកបុគ្គលទាំងពួងនោះ គប្បីជ្រាបដោយន័យដែលពោល ហើយនោះឯង ។ ក្នុងភិក្ខុនីទាំងឡាយ ក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ធម្មតាភិក្ខុទាំងឡាយរមែងជាអ្នកមានព្រហ្មចរិយៈខ្ពស់ ភិក្ខុនីក៏ដូចគ្នា ភិក្ខុភិក្ខុនី ទាំងនោះ ញុំាងសមណធម៌ដែលរក្សាគ្រប់គ្រងហើយ ឲ្យវិនាសទៅដោយថ្ងៃ បន្តិចបន្តួច ដោយការធ្វើសន្ថវៈដល់គ្នានឹងគ្នា តែបើទៅសួររឿងអាពាធ គួរ ទៅ ។ ភិក្ខុគួរទៅដូចគ្នាដើម្បីបានផ្កា ហើយនាំទៅបូជាខ្លះ ដើម្បីឲ្យឱវាទខ្លះ ។ បទថា **បានាគារំ** បានដល់ រោងសុរា តៀមស្រាទាំងនោះរមែងធ្វើអន្តរាយ ដល់ព្រហ្មចរិយៈ ជាទីមិនស្ងាត់ចាកពួកអ្នកលេងសុរា ។ ការចូលទៅក្នុងទីនោះ ដោយការពេញចិត្តជាមួយពួកអ្នកលេងសុរាទាំងនោះមិនគួរ រមែងជាអន្តរាយ ដល់ព្រហ្មចរិយៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **សំសដ្ឋោ វិហរតិ រាជូហិ** ដូចតទៅ នេះថា បទថា **រាជានោ** បានដល់ អ្នកគ្រប់គ្រងរាជសម្បត្តិ អភិសេកហើយ ក្តី មិនទាន់អភិសេកក្តី ។ បុគ្គលប្រកបដោយភាពជាធំដូចគ្នានឹងភាពជាឥស្សរៈ របស់ព្រះរាជាទាំងឡាយហៅថា **រាជមហាមត្តា** ។ អ្នកបួសក្រៅសាសនា មានការយល់ឃើញវិបរិត ហៅថា **តិត្ថិយា** ។ អ្នកឲ្យបច្ច័យដល់តិរ្ថិយទាំង នោះដោយភក្តី ហៅថា **តិត្ថិយសាវកា** អធិប្បាយថា ជាអ្នកប្រឡូកប្រឡំនឹង បុគ្គលទាំងនោះ ។ បទថា **អននុលោមិកេន សំសគ្គេន** មានវិនិច្ឆ័យថា ការ ប្រឡូកប្រឡំដែលជាសត្រូវ មិនសមគួរដល់ត្រៃសិក្ខា ដែលជាហេតុឲ្យភិក្ខុ បានទទួលអន្តរាយចំពោះព្រហ្មចរិយៈការកន្លងល្មើសបញ្ញត្តិនិងការសោបសូន្យ

នៃសល្លេខប្បដិបត្តិ ឈ្មោះថា ការប្រឡូកប្រឡំដែលមិនសមគួរ គឺការសោយសោករួមគ្នា ការត្រេកអររួមគ្នា ការមានសេចក្ដីសុខទុក្ខរួមគ្នាជាមួយព្រះរាជានិងមហាមាត្យរបស់ព្រះរាជា កាលកិច្ចដែលគួរធ្វើកើតឡើង ដល់នូវការខ្វល់ខ្វាយដោយខ្លួន ភាពជាអ្នកមានអាចារៈរួមគ្នា ដោយការពេញចិត្ត ការពេញចិត្តជាមួយសាវករបស់តិរ្ថិយ ការនាំមកនូវភាពជាអ្នកមានអាចារៈរួមគ្នាដោយការពេញចិត្តដូចគ្នា ឬការជិតស្និទ្ធខ្លាំងដោយសេចក្ដីស្នេហា ។ ក្នុងសេចក្ដីនេះ ការប្រឡូកប្រឡំជាមួយព្រះរាជានិងមហាមាត្យរបស់ព្រះរាជា ជាការធ្វើអន្តរាយចំពោះព្រហ្មចរិយៈ ការប្រឡូកប្រឡំជាមួយតិរ្ថិយ ក្រៅអំពីនេះ ជាការកាន់យកនូវលទ្ធិ ជាអ្នកអាចទម្លាយវាទៈរបស់តិរ្ថិយទាំងនោះ ហើយឲ្យកាន់យកលទ្ធិរបស់ខ្លួន ទោះចូលទៅរកក៏គួរ ។ ឥឡូវនេះព្រះសារីបុត្ត ដើម្បីសម្ដែងអគោចរដោយបរិយាយដទៃទើបផ្ដើមពាក្យថា **យានិ វា បន តានិ កុលានិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អស្សទ្ធានិ** បានដល់ វៀរចាកសទ្ធាក្នុងព្រះពុទ្ធជាដើម ។ ត្រកូលទាំងនោះរមែងមិនជឿថា ព្រះពុទ្ធជាសព្វញ្ញូ ព្រះធម៌ជាគ្រឿងនាំសត្វចេញចាកទុក្ខ ព្រះសង្ឃជាអ្នកបដិបត្តិល្អដូច្នេះ ។ បទថា **អប្បសន្នានិ** បានដល់ មិនអាចធ្វើចិត្តឲ្យថ្លៃថ្នូរផង់ មិនឲ្យល្អក់បាន ។ បទថា **អក្កោសកបរិភាសកានិ** បានដល់ ជេរបរិភាស អធិប្បាយថា រមែងជេរដោយអក្កោសវត្ថុ ១០ យ៉ាង គឺ ( ជេរថា ) ឯងជាចោរ ជាបុគ្គលពាល ជាមនុស្សវង្វេង ជាឱដ្ឋ ជាគោ ជាលា ជាបុគ្គលធ្លាក់ក្នុងអបាយ ជាសត្វនរកជាតិរច្ឆាន សុគតិមិនមានដល់ឯងទេ ឯងសង្ឃឹមតែទុគ្គតិប៉ុណ្ណោះនិងជេរដោយ

ធ្វើឲ្យភ័យយ៉ាងនេះថា ណ្ហើយចុះឥឡូវនេះអញនឹងប្រហារ អញនឹងចង អញនឹងសម្លាប់ ។

បទថា **អនត្ថកាមានិ** បានដល់ មិនប្រាថ្នាប្រយោជន៍ប្រាថ្នាសេចក្តីវិនាសតែម្យ៉ាង ។ បទថា **អហិតកាមានិ** បានដល់ ប្រាថ្នាវត្ថុមិនមានប្រយោជន៍តែម្យ៉ាង មិនប្រាថ្នាវត្ថុជាប្រយោជន៍ ។ បទថា **អផាសុកាមានិ** បានដល់ មិនប្រាថ្នានូវការសប្បាយ ប្រាថ្នាការមិនសប្បាយតែម្យ៉ាង ។ បទថា **អយោគក្ខេមកាមានិ** បានដល់ មិនប្រាថ្នាការក្សេម គឺការមិនមានភ័យចាកយោគៈ ៤ ប្រាថ្នាការមានភ័យតែម្យ៉ាង ។ ពួកសាមណេរក៏សង្គ្រោះចូលក្នុងបទនេះថា **ភិក្ខូនំ** ដូច្នេះ ។ សិក្ខមានាក្តីសាមណេរីក្តីសង្គ្រោះចូលក្នុងបទថា **ភិក្ខុនីនំ** ។ ពិតហើយ ត្រកូលទាំងនេះប្រាថ្នាតែសេចក្តីវិនាសដល់បរិស័ទទាំង ៤ ជាអ្នកបួស នឹងអ្នកដល់នូវសរណៈ ឧទ្ទិសព្រះមានព្រះភាគ ។ បទថា **តថារូបានិ កុលានិ** បានដល់ ត្រកូលទាំងឡាយ មានត្រកូលក្សត្រជាដើមបែបនោះ ។ បទថា **សេវតិ** បានដល់ អាស្រ័យរស់នៅ ។ បទថា **ភជតិ** បានដល់ ចូលទៅរក ។ បទថា **បយិរុបាសតិ** បានដល់ ចូលទៅរករឿយៗ ។ បទថា **អយំ វុច្ចតិ** បានដល់ គោចរដែលមិនសមគួរទាំង ៣ ប្រការនេះ គឺជាអ្នកត្រាច់ទៅកាន់ផ្ទះស្រីពេស្យាជាដើម របស់ភិក្ខុដែលត្រាច់រកស្រីពេស្យាជាដើម គោចរមានព្រះរាជាជាដើមរបស់ភិក្ខុដែលច្រឡូកច្រឡំជាមួយព្រះរាជាជាដើម គោចរមានត្រកូលមិនមានសទ្ធាជាដើម របស់ភិក្ខុគប់រកត្រកូលមិនមានសទ្ធាជាដើម គប្បីជ្រាបថា អគោចរ ។

គប្បីជ្រាបអគោចរនោះដោយបរិយាយនេះ ដូចតទៅនេះថា គប្បីជ្រាបអគោចរមានស្រីពេស្យាជាដើមថា ជាអគោចរ ព្រោះអាស្រ័យកាមគុណ ៥ ដូចព្រះមានព្រះភាគត្រាស់ ( ទុកក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ចុះទីមិនមែនជាទីគោចរ ជាដែននៃបុគ្គលដទៃតើដូចម្តេច ។ គឺកាមគុណទាំង ៥ នេះឯង ។ គប្បីជ្រាបអគោចរមានព្រះរាជាជាដើមថាអគោចរ ព្រោះមិនជាឧបនិស្ស័យនៃការប្រកបរឿយៗ ក្នុងឈាន និងព្រោះហេតុនៃការបៀតបៀនដោយវិតក្កដែលជាប់ចំពាក់ក្នុងលាភសក្ការៈនិងជាហេតុឲ្យទិដ្ឋិវិបត្តិ ។ គប្បីជ្រាបអគោចរ មានត្រកូលមិនមានសទ្ធាជាដើម ថាជាអគោចរ ព្រោះនាំនូវការវិនាសនៃសទ្ធានិងការប្រទូស្តផ្លូវចិត្តមកឲ្យ ។

អគោចរ ៤ យ៉ាង មានការចូលទៅកាន់ចន្លោះផ្ទះជាដើម ការឃើញរូបដោយចក្ខុហើយ ដោយការកាន់យកនិមិត្តជាដើម ការបរិភោគភោជនដែលគេឲ្យដោយសទ្ធា ហើយខ្វល់ខ្វាយក្នុងការមើលវត្ថុដែលជាសត្រូវនៃកុសលធម៌ កាមគុណប្រាំគប្បីជ្រាបថាជាអគោចរ ដោយអំណាចការកើតឡើងនៃកិលេស ។

[ ២១៩ ] បទថា **មា ភិក្ខវេ អគោចរេ ចរថ** បានដល់ អ្នកទាំងឡាយកុំត្រាច់ទៅក្នុងទីដែលមិនគួរត្រាច់ទៅ ។ បទថា **បរវិសយេ** បានដល់ ដែនសត្រូវ ។ បទថា **អគោចរេ ភិក្ខវេ ចរតំ** បានដល់ កាលអ្នកទាំងឡាយត្រាច់ទៅក្នុងទីមិនសមគួរ ។ បាលីថា **ចរំ** ក៏មាន ។ បទថា **លច្ឆតិ** បានដល់ នឹងបាន គឺនឹងឃើញ ។ បទថា **មារោ** បានដល់ ទេវបុត្តមារខ្លះ មច្ចុមារខ្លះ ។ បទថា **ឱតារំ** បានដល់ ឱកាស ឱកាសទំនេរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគោចរនិទ្ទេសដូចតទៅនេះថា បទមានបទជាដើមថា **ឆ វេសយគោចរោ ហោតិ** ដូច្នេះ គប្បីជ្រាបដោយផ្ទុយគ្នា តាមដែលបានពោលហើយ ។ តែការផ្សេងគ្នាមានដូចតទៅនេះថា ។ បទថា **ចត្តារោ សតិប្បដ្ឋានា គោចរោ** បានដល់ សតិប្បដ្ឋាន ៤ ជាគោចរ ដោយជាទីសមគួរត្រាច់ទៅ ។ បទថា **សកេ** បានដល់ ជារបស់ខ្លួន ។ បទថា **បេត្តិកេ វិសយេ** បានដល់ ជាដែនដែលមកអំពីបិតា ។

[ ២២១ ] បទថា **អារទ្ធវីរិយស្ស** បានដល់ មានសេចក្តីព្យាយាមដែលបានដល់សម្មប្បធាន ៤ ដែលចូលទៅតាំងទុកហើយ ដោយប្រពៃ ។ បទថា **ថាមវតោ** បានដល់ មានកម្លាំង ។ បទថា **ទឡ្ហបរក្កមស្ស** បានដល់ មានសេចក្តីព្យាយាមមាំ ។ បទថា **យស្សត្ថា បេសិតោ** បានដល់ លះអត្តភាពដើម្បីព្រះអរហត្ត ។ បទថា **អត្ថត្ថេ ច** បានដល់ ក្នុងអរហត្តផល ដែលជាប្រយោជន៍របស់ខ្លួន ។ បទថា **ញាយេ ច** បានដល់ ក្នុងមគ្គ មានអង្គ ៨ ដែលជាអរិយៈ ។ បទថា **លក្ខណេ ច** បានដល់ ក្នុងកាលចាក់ធ្លុះលក្ខណៈមានអនិច្ចលក្ខណៈជាដើម ។ បទថា **ការណេ ច** បានដល់ ក្នុងហេតុ ។ បទថា **ឋានាឋានេ ច** បានដល់ ក្នុងវត្ថុដែលប្រព្រឹត្តទៅបាននិងវត្ថុដែលប្រព្រឹត្តទៅមិនបាន អធិប្បាយថា ក្នុងហេតុនិងមិនមែនហេតុ ។ ឥឡូវនេះព្រះសារីបុត្តដើម្បីសម្តែងឲ្យពិស្តារ ទើបពោលពាក្យថា **សព្វេ សង្ខារា អនិច្ចា** ដូច្នេះជាដើម ។

[ ២២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៨ ដូចតទៅនេះថា បទថា **ឃ-**

**កោធេ និបកោ** បានដល់ ជាបណ្ឌិតដែលមានឯកគ្គតាចិត្ត ។

[ ២២៤ ] បទថា **ជាតរូបស្ស ឱឡារិកម្បិ មលំ ធមតិ** បានដល់ នាំមន្ទិលគ្រោតគ្រាតរបស់មាសចេញទៅដោយប្រើភ្លើង ។ បទថា **សន្ធមតិ** បានដល់ នាំចេញដោយប្រពៃ ។ បទថា **និទ្ធមតិ** បានដល់ នាំចេញទៅ ធ្វើមិនឲ្យកើតទៀត ។ អាចារ្យពួកខ្លះពោលថា **ឈាបេតិ** ( ដុត ) ក៏មាន ។ បទថា **មជ្ឈិមកម្បិ** បានដល់ ល្អិតជាងនោះខ្លះ ។ បទថា **សុខុមកម្បិ** បានដល់ ល្អិតក្រៃលែងខ្លះ ។ បទថា **ឯវមេវ** ជាបទសម្ដែងប្រៀបធៀបឲ្យឃើញច្បាស់ ។ បទថា **អត្តនោ ឱឡារិកេបិ កិលេសេ ធមតិ** បានដល់ នាំកិលេសគ្រោតគ្រាត មានកាយទុច្ចរិតជាដើមចេញទៅដោយការព្យាយាមដុតកិលេស ។ បទថា **មជ្ឈិមកេបិ កិលេសេ** បានដល់ កិលេសយ៉ាងកណ្ដាល រវាងកិលេសគ្រោតគ្រាតនិងកិលេសល្អិត មានកាមវិតក្កជាដើម ។ បទថា **សុខុមកេបិ** បានដល់ នូវកិលេសល្អិតក្រៃលែងមានញាតិវិតក្កជាដើម ។ បទថា **សម្មាទិដ្ឋិយា មិច្ឆាទិដ្ឋី ធមតិ** បានដល់ នាំចេញនូវមិច្ឆាទិដ្ឋិដែលវិបរិតដោយសម្មាទិដ្ឋិដែលសម្បយុត្តដោយមគ្គ មួយអន្លើដោយវិបស្សនា ។ ក្នុងសម្មាសង្កប្បជាដើម ក៏មានន័យនេះដូចគ្នា ។

[ ២២៥ ] ព្រះមានព្រះភាគ កាលព្រះសារីបុត្តសរសើរ ដោយគាថា ៣ ហើយទូលសួរដល់សេនាសន គោចរ សីលនិងវត្តជាដើមដើម្បីជាប្រយោជន៍ដល់សិស្សទាំង ៥០០ ដោយគាថា ៥ ដើម្បីទ្រង់ប្រកាសសេចក្ដីនោះ ទើបទ្រង់ផ្ដើមវិសជ្ជនាដោយន័យថា **វិជិគុច្ឆមានស្ស** ដូច្នេះជាដើម ។

ក្នុងគាថាទាំងនោះគប្បីជ្រាបអត្ថនៃគាថាជាដំបូងថា ម្នាលសារីបុត្ត តថាគត នឹងពោលនូវសេចក្ដីសុខ គឺភាពជាផាសុកនិងធម៌ដែលសមគួរ គឺធម៌ដែលអនុលោមតាមរបស់ភិក្ខុដែលខ្ពើមរអើមដោយជាតិជាដើម ជាអ្នកសេពទីអង្គុយ ទីដេកដ៏ស្ងាត់ ប្រាថ្នានូវសម្ពោធិដល់ភិក្ខុនោះ តាមដែលដឹង គឺតថាគតដឹងយ៉ាងណា ក៏នឹងពោលយ៉ាងនោះ ។

[ ២២៦ ] បទថា **យំ ផាសុវិហារំ** បានដល់ ការនៅជាផាសុក ។

[ ២២៨ ] បទថា **អសប្បាយរូបទស្សនេន** បានដល់ ឃើញរូបមិនជាទីសប្បាយរបស់សមណៈ មានរូបស្ត្រីជាដើម ។

[ ២២៩ ] បទថា **តំ សម្ពោធឹ ពុជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នាដើម្បីត្រាស់ដឹងសម្ពោធិដែលបានដល់មគ្គញាណ ៤ នោះ ។ បទថា **អនុពុជ្ឈិតុ-កាមស្ស** បានដល់ ប្រាថ្នាត្រាស់ដឹងដោយការបដិបត្តិតាមសមគួរ ។ បទថា **បដិវិជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នានឹងធ្វើទុកក្នុងទីចំពោះមុខ ហើយត្រាស់ដឹង ។ បទថា **សម្ពុជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នានឹងត្រាស់ដឹងប្រពៃដោយការមិនឲ្យកិលេសដែលលះបានហើយត្រឡប់មក ។ បទថា **អធិគន្តុកាមស្ស** បានដល់ ប្រាថ្នានឹងដល់ ។ បទថា **សច្ឆិកាតុកាមស្ស** បានដល់ ប្រាថ្នានឹងសម្រេច ដោយការបានចំពោះនិងការធ្វើឲ្យជាក់ច្បាស់ ។ ម្យ៉ាងទៀត បទថា **ពុជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នានឹងដឹង សោតាបត្តិមគ្គញាណ ។ បទថា **អនុពុជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នាដឹងនូវសកទាគាមិមគ្គញាណទៀត ។ បទថា **បដិវិជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នានឹងដឹង ដោយការចាក់ធ្លុះអនាគាមិ-

មគ្គញាណ ។ បទថា **សម្ពុជ្ឈិតុកាមស្ស** បានដល់ ប្រាថ្នាទឹងដឹងដោយប្រពៃនូវអរហត្តមគ្គញាណ ។ បទថា **អធិគន្តុកាមស្ស** បានដល់ ប្រាថ្នាសម្រេចញាណសុម្បីទាំង ៤ ។ បទថា **ផុស្សិតុកាមស្ស** បានដល់ ប្រាថ្នាទឹងពាល់ត្រូវដោយញាណ ។ បទថា **សច្ឆិកាតុកាមស្ស** បានដល់ ប្រាថ្នាធ្វើឲ្យប្រចក្សដោយការពិចារណា ។ បទថា **ចតុន្នំ មគ្គានំ បុព្វភាគេ វិបស្សនា** បានដល់ វិបស្សនាញាណ មានឧទយព្វយញ្ញាណជាដើម កើតឡើងហើយខាងដើមនៃអរិយមគ្គ ៤ ។

[ ២៣១ ] គប្បីជ្រាបអត្ថក្នុងគាថាទី ២ ដូចតទៅនេះថា បទថា **សប្បរិ–យន្តចារី** បានដល់ ប្រព្រឹត្តក្នុងធម៌ជាចំណែកទីបំផុត ៤ យ៉ាង មានសីលជាដើម[១] ។ បទថា **ឱំសាធិចាតានំ** បានដល់ របោមនិងសត្វល្អិតដ៏សេស ។ របោមនិងរុយទាំងនោះរោមក្នុងទីនោះៗ ហើយខាំ ព្រោះហេតុនោះទើបហៅថា **អធិចាតា** ។ បទថា **មនុស្សជស្សានំ** បានដល់ សម្ផស្សកើតអំពីចោរជាដើម ។

[ ២៣៣ ] បទថា **ចត្តារោ បរិយន្តា** បានដល់ ព្រំដែន គឺការកំណត់ ៤ យ៉ាង ។ បទថា **អន្តោ បូតិភាវំ បច្ចវេក្ខមានោ** បានដល់ ពិចារណាមើលនូវភាពគួរខ្ពើម ភាពជាអ្នកវៀរចាកសីលខាងក្នុង ។ បទថា **អន្តោសី–លសំវរបរិយន្តេ ចរតិ** បានដល់ ប្រព្រឹត្ត គឺត្រាច់ទៅក្នុងធម៌ខាងក្នុងកំណត់ដោយសីលសំវរៈ ។ បទថា **មរិយាទំ ន ភិន្ទតិ** បានដល់ មិនធ្វើសីលដែលជាព្រំដែនសីលដែលជាការកំណត់ឲ្យកម្រើក ។ បទថា **អាធិត្តបរិយាយំ**

---

១–សេចក្តីពិស្តារសូមមើលត្រង់ឃ្នាប ២៣៣ ។

**បច្ចវេក្ខមានោ** បានដល់ ពិចារណាអាទិត្តទេសនា ។

បទថា **អក្ខព្ភញ្ជនវណបដិច្ឆាទនបុត្តមំសូបមំបច្ចវេក្ខមានោ** បានដល់ ពិចារណាអាហារប្រៀបដូចប្រេងបន្តក់ភ្លៅរទេះ សំពត់ចាស់រុំដំបៅ របស់អ្នកកើតរោគឃ្លង់ និងសាច់កូន របស់ប្តីប្រពន្ធដែលដើរឆ្លងផ្លូវកន្តារ ។ បទថា **ភន្តេករត្តវិហារំបច្ចវេក្ខមានោ** បានដល់ ពិចារណាភទ្ទេករត្តវិហារធម៌ដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសក ) យ៉ាងនេះថា

បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធដែលកន្លងទៅ ហើយ
មិនគប្បីប្រាថ្នាបញ្ចក្ខន្ធដែលមិនទាន់មកដល់ទេ អ្នកប្រាជ្ញដែល
ស្ងប់ទុក្ខហើយ តែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ
( ជាអ្នកមានព្យាយាមដុតកិលេសជាអ្នកមិនខ្ជិលច្រអូសអស់
យប់និងថ្ងៃនោះឯង ) ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ដូច្នេះ ។

[ ២៣៥ ] បទថា **តា ឧប្បតិត្វា ឧប្បតិត្វាខាទន្តិ** បានដល់ សត្វល្អិតទាំងនោះរមែងហើរពេមខាំស៊ី ។

[ ២៣៦ ] គប្បីជ្រាបអត្ថនៃគាថាទី ៣ ដូចតទៅនេះថា មនុស្សខាងក្រៅទាំងអស់ វៀរសហធម្មិក ៧ ពួក ឈ្មោះថា **បរធម្មិកា** ។ បទថា **កុសលានុឯសី** បានដល់ តាមស្វែងរកកុសលធម៌ ។

[ ២៣៧ ] បទថា **សត្តសហធម្មិកេហបេត្វា** បានដល់ វៀរភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកា ។

[ ២៣៨ ] បទថា **អថាបរានិបិអត្ថិអភិសម្ភោតព្វានិ** បានដល់ មា្យ៉ាង

ទៀត អន្តរាយដទៃដែលភិក្ខុទាំងឡាយគប្បីញាំញីមាន គឺប្រាកដ ។

[ ២៣៩ ] គប្បីជ្រាបសេចក្តីក្នុងគាថាទី ៤ ដូចតទៅនេះថា បទថា **អាតង្កផស្សេន** បានដល់ ត្រូវផស្សៈ គឺរោគពាល់ត្រូវ ។ បទថា **សីតំអច្ចុណ្ហំ** បានដល់ រងាផងក្តៅផង ។ បទថា **សោតេហិផុដ្ឋោពហុធា** បានដល់ ភិក្ខុនោះជាអ្នកដែលផស្សៈទាំងនោះ មានរោគជាដើមពាល់ត្រូវហើយដោយអាការមិនមែនតិច ។ បទថា **អនោកោ** បានដល់ ជាអ្នកមិនឲ្យឱកាសដល់វិញ្ញាណដែលធ្វើកិច្ចតាក់តែងជាដើម ។

[ ២៤១ ] បទថា **អត្តន្តរធាតុបកោបវសេនវា** បានដល់ ដោយអំណាចនៃអាបោធាតុកម្រើក ឬដោយអំណាចនៃធាតុឯណានីមួយ កម្រើកខាងក្នុងរាងកាយ ។ បទថា **ឧណ្ហំ** បានដល់ កម្តៅរមែងកើតដោយអំណាចនៃតេជោធាតុកម្រើកខាងក្នុងរាងកាយ ។

[ ២៤២ ] បទថា **អភិសង្ខារសហគតវិញ្ញាណស្ស** បានដល់ ដល់ចិត្តដែលសម្បយុត្ត ដោយកុសលចេតនានិងអកុសលចេតនា ។ បទថា **ឱកាសំនករោតិ** បានដល់ មិនបើកឱកាស គឺទីតាំងនៅ ។

[ ២៤៣ ] បទថា **អវត្ថិតសមាធានោ** បានដល់ ឈមចុះស៊ប់ ។

[ ២៤៤ ] ព្រះមានព្រះភាគ ទ្រង់ឆ្លើយដោយគាថា ៣ មានពាក្យថា **ភិក្ខុនោវិជិគុច្ឆតោ** ដែលព្រះសារីបុត្តទូលសួរយ៉ាងនេះហើយ កាលទ្រង់ដោះស្រាយបញ្ហាដែលព្រះសារីបុត្តទូលសួរដោយន័យជាដើមថា ភិក្ខុមានចិត្តបញ្ជូនទៅហើយនោះ ត្រូវមានសម្តីដូចម្តេច ទើបត្រាស់ពាក្យជាដើមថា **ថេយ្យំ**

**៦ ការ** ដូច្នេះ ។

ក្នុងបទទាំងនោះបទថា **ជស្សេ** បានដល់ គប្បីពាល់ត្រូវ ។ បទថា **យទា-វិលត្តំមនសោវិជញ្ញា** សេចក្តីថា ភិក្ខុគប្បីដឹងនូវការល្អក់ចិត្ត គប្បីបន្ទោបង់នូវការល្អក់ចិត្តទាំងអស់នោះ ដោយមនសិការថា នេះបក្ខពួករបស់ខ្មៅ ។

[ ២៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **អទិន្នាទានំបហាយ** ដូចតទៅនេះថា ការកាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** ។ ការនាំរបស់អ្នកដទៃទៅ អធិប្បាយថា ការលួច លោកពោលថាជាចោរ ។ ក្នុងបទទាំងនោះបទថា **អទិន្នំ** បានដល់ របស់ដែលអ្នកដទៃហួងហែង ។ អ្នកដទៃដល់នូវភាព ជាអ្នកធ្វើបានតាមប្រាថ្នា មិនត្រូវដាក់អាជ្ញានិងមិនត្រូវពោលតិះដៀលក្នុងរបស់ណា ចេតនាលួចដែលញុំាងនូវសេចក្តីព្យាយាម ដើម្បីកាន់យករបស់ដែលអ្នកដទៃហួងហែងនោះឲ្យតាំងឡើង របស់បុគ្គលដែលមានការដឹងក្នុងរបស់អ្នកដទៃហួងហែង ថាជារបស់អ្នកដទៃហួងហែង ឈ្មោះថា អ-ទិន្នាទាន ។ អទិន្នាទាននោះមានទោសតិចក្នុងរបស់អ្នកដទៃដែលអន់ មានទោសច្រើនក្នុងរបស់ដែលប្រណីត ព្រោះហេតុអ្វី ព្រោះវត្ថុប្រណីត ។ កាលវត្ថុសម្បូរមានទោសច្រើនក្នុងវត្ថុដែលជារបស់បុគ្គលក្រៃលែងដោយគុណ មានទោសតិចក្នុងវត្ថុដែលជារបស់អ្នកមានគុណតិច ជាងអ្នកក្រៃលែងដោយគុណទាំងនោះ ។

អទិន្នាទាននោះ មានអង្គ ៥ គឺរបស់ដែលអ្នកដទៃហួងហែង ១ ដឹងថាជារបស់ដែលអ្នកដទៃហួងហែង ១ ចិត្តគិតនឹងលួច ១ ព្យាយាមនឹងលួច ១ លួច

*បានដោយសេចក្តីព្យាយាមនោះ ១ ។*

*បទថា* **បហាយ** *សេចក្តីថា លះនូវភាពជាអ្នកទ្រុស្តសីលបានដល់ចេតនា ដែលកាន់យករបស់ដែលគេមិនបានឲ្យ ។ បទថា* **បដិវិរតោ** *បានដល់ វៀរ និងវៀរចាកភាពជាអ្នកទ្រុស្តសីលនោះ តាំងអំពីពេលដែលលះបានហើយ ។ ឈ្មោះថា* **ទិន្នាទាយី** *ព្រោះអត្ថថា កាន់យកនូវរបស់ដែលគេឲ្យហើយតែម្យ៉ាង ។ ឈ្មោះថា* **ទិន្នបាដិកង្ខី** *ព្រោះអត្ថថា មានចិត្តសង្ឃឹមបានអំពីរបស់ដែលគេឲ្យ តែម្យ៉ាង ។ ឈ្មោះថា* **ថេន** *ព្រោះអត្ថថា លួច ការមិនលួចឈ្មោះថា* **អថេនេន** *។ ឈ្មោះថា* **សុចិភូតេន** *ព្រោះអត្ថថា មិនមានខ្លួនជាចោរ ។ បទថា* **អត្តនា** *បាន ដល់ ដោយភាពជាខ្លួន ។ លោកអធិប្បាយថា ធ្វើអត្តភាពឲ្យមិនជាចោរ ឲ្យ ស្អាត ។ បន្ទាប់អំពីនេះមានន័យដូចពោលហើយ ។*

*[ ២៤៦ ] ឈ្មោះថា* **មេត្តិ** *ដោយអំណាចនៃមេត្តា អាការនៃមេត្តាឈ្មោះ ថា* **មេត្តាយនា** *។ ភាពដែលចិត្តប្រព្រឹត្តទៅដោយមេត្តា មានការព្រមព្រៀង ដោយមេត្តា ឈ្មោះថា* **មេត្តាយិតត្តំ** *។ ឈ្មោះថា* **អនុទយា** *ព្រោះអត្ថថា អាណិតអាសូរ អធិប្បាយថា រក្សា ។ អាការនៃការអាណិតអាសូរ ឈ្មោះ ថា* **អនុទយនា** *។ ភាពនៃបុគ្គលអាណិតអាសូរ ឈ្មោះថា* **អនុទាយិតត្តំ** *។ ឈ្មោះថា* **ហិតេសិតា** *ដោយអំណាចនៃការរកប្រយោជន៍ឲ្យ ។ ឈ្មោះថា* **អនុកម្បា** *ដោយអំណាចនៃការជួយស្រោចស្រង់ ។ ដោយបទទាំងអស់នេះ លោកពោលថា មេត្តាដែលដល់នូវឧបចារៈនិងអប្បនា ។ គប្បីឃើញភាពដែល មេត្តាបរិបូណ៌ដោយការផ្សាយទៅ ក្នុងបទនេះថា* **វិបុលេន** *។ ចិត្តនោះឈ្មោះ*

ថា **មហគ្គតំ** ដោយអំណាចភូមិ ។ ឈ្មោះថា **អប្បមាណំ** ដោយអំណាចការស្ទាត់ជំនាញ ។ ម្យ៉ាងទៀតឈ្មោះថា **អប្បមាណំ** ដោយអំណាចមានសត្វជាអារម្មណ៍ ។ ឈ្មោះថា **អវេរំ** ដោយការលះសត្រូវ គឺព្យាបាទ ។ ឈ្មោះថា **អព្យាបជ្ឈំ** ព្រោះលះនូវទោមនស្សបាន អធិប្បាយថា មិនមានទុក្ខ ។

[ ២៤៧ ] បទថា **អាវិលំ** បានដល់ មិនថ្លា ។ បទថា **លុឡិតំ** បានដល់ ជាកលល: ( ភក់ ) ។ បទថា **ឃរិតំ** បានដល់ សម្រេចចិត្តមិនបាន ។ បទថា **ឃដ្ដិតំ** បានដល់ ដល់នូវការប៉ះខ្ទប់ដោយអារម្មណ៍ ។ បទថា **ចលិតំ** បានដល់ ញាប់ញ័រ ។ បទថា **ភន្តំ** បានដល់ វិលទៅ ។ បទថា **អវូបសន្តំ** បានដល់ មិនរលត់ ។

[ ២៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងឡាយមានបទថា **យោសោមារោ** ជាដើម ដូចតទៅនេះថា ឈ្មោះថា **មារោ** ព្រោះអត្ថថា បបួលមហាជនឲ្យប្រកបសេចក្ដីវិនាសហើយឲ្យស្លាប់ ។ ឈ្មោះថា **កណ្ហោ** ព្រោះអត្ថថា មានកម្មខ្មៅ ។ ឈ្មោះថា **អធិបតិ** ព្រោះអត្ថថា ជាធំក្នុងកាមាវចរ ។ ឈ្មោះថា **អន្តគូ** ព្រោះឲ្យដល់នូវការស្លាប់ ។ ឈ្មោះថា **នមុចិ** ព្រោះមិនឲ្យរួចផុតទៅបាន ។ ឈ្មោះថា **មារពឡិសំ** ព្រោះអត្ថថា ជាសន្ទូចរបស់មារ ។ ឈ្មោះថា **មារាមិសំ** ព្រោះអត្ថថា ជានុយរបស់មារ ដោយអត្ថថា អាស្រ័យវដ្ដ: ។ ឈ្មោះថា **មារវិសយោ** ព្រោះអត្ថថា ជាវិស័យនៃមារ ដោយអត្ថថា ឲ្យនៅក្នុងអំណាច ។ ឈ្មោះថា **មារនិវាសោ** ព្រោះអត្ថថា ជាលំនៅរបស់មារដោយអត្ថថា ជាអារម្មណ៍ ។ ឈ្មោះថា **មារគោចរោ** ព្រោះអត្ថថា ជាទីគោចរ

របស់មារ ដោយត្រាច់ទៅកាន់កាម ។ ឈ្មោះថា **មារពន្ធំ** ព្រោះអត្ថថា ជាគ្រឿងចងរបស់មារ ដោយអត្ថថាស្រាយចេញបានលំបាក ។ ឈ្មោះថា **ទុក្ខុទ្ធយោ** បានដល់ ជាគ្រឿងចងជាប់ជាមួយទុក្ខ ។

[ ២៤៩ ] បទថា **មូលម្បិតេសំពលិខញ្ញាតិដ្ឋេ** បានដល់ គប្បីជីកឫសមានអវិជ្ជាជាដើម របស់សេចក្ដីក្រោធនិងការមើលងាយអ្នកដទៃទាំងនោះហើយតាំងនៅ ។ បទថា **អទ្ធាភវន្តោអភិសម្ភវេយ្យ** បានដល់ ភិក្ខុកាលបង្ក្រាបគប្បីបង្ក្រាបវត្ថុជាទីស្រឡាញ់និងទីស្អប់ដោយចំណែកមួយប៉ុណ្ណោះក្នុងសេចក្ដីនោះ អធិប្បាយថា មិនគប្បីត្រេកអរក្នុងវត្ថុជាទីស្រឡាញ់ មិនគប្បីស្អប់វត្ថុដែលមិនជាទីស្រឡាញ់ ។

[ ២៥១ ] បទថា **អវិជ្ជាមូលំ** ជាដើម សេចក្ដីថា អវិជ្ជាជាឫសគល់នៃសេចក្ដីក្រោធ ដោយអំណាចឧបនិស្សយប្បច្ច័យនិងសហជាតប្បច្ច័យជាដើម ។ ធម៌ ២ យ៉ាង គឺមិនធ្វើទុកក្នុងចិត្តដោយឧបាយ ១ ការប្រកាន់ខ្លួន ១ ជាឫសគល់នៃសេចក្ដីក្រោធ ដោយអំណាចឧបនិស្សយប្បច្ច័យនោះឯង ។ ធម៌ ៣ យ៉ាងនេះ គឺអហិរិក ១ អនោត្តប្ប ១ ឧទ្ធច្ច ១ ជាឫសគល់នៃសេចក្ដីក្រោធ ដោយអំណាចឧបនិស្សយប្បច្ច័យនិងសហជាតប្បច្ច័យជាដើម ។ សូម្បីបទថា **អតិមានស្ស** ក៏ដូចគ្នា ។

[ ២៥៣ ] បទថា **បញ្ញំបុរក្ខត្វា** បានដល់ ធ្វើបញ្ញាទុកខាងមុខ ។ បទថា **កល្យាណបីតិ** បានដល់ ប្រកបដោយកល្យាណបីតិ ។ បទថា **ចតុរោ-សហេថបរិទេវធម្មេ** បានដល់ គប្បីសង្កត់បរិទេវធម៌ ដែលព្រះមានព្រះភាគ

ត្រាស់ទុកក្នុងគាថាបន្ទាប់ ។

[ ២៥៤ ] បទថា **វិចយពហុលោ** បានដល់ មានការពិចារណាច្រើន ។ បទថា **បវិចយពហុលោ** បានដល់ មានការពិចារណាច្រើនជាពិសេស ។ បទថា **ឱក្ខាយនពហុលោ** បានដល់ មានការឃើញច្រើន ។ បទថា **ស - មេក្ខាយនពហុលោ** បានដល់ មានការស្វែងរកច្រើន ។ បទថា **វិភូតវិហារី** បានដល់ នៅដោយការដឹងដោយធ្វើឲ្យប្រាកដ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អភិក្កន្តេបដិក្កន្តេ** ដូចតទៅនេះថា ការឈានទៅមុខហៅថា **អភិក្កន្តេ** ការឈានទៅក្រោយ ហៅថា **បដិក្កន្តេ** ពាក្យទាំង២នេះ ក៏បានក្នុងឥរិយាបថ ៤ គប្បីជ្រាបសេចក្តីក្នុងការដើរមុន ការនាំកាយទៅខាងមុខ ឈ្មោះថា **អភិក្កន្តេ** ការញ៉ាំងកាយឲ្យថយក្រោយ ឈ្មោះថា **បដិក្កន្តេ** ។ បុគ្គលឈរដោយបង្អោនកាយទៅខាងមុខ ឈ្មោះថា **អភិក្កន្តេ** បង្អោនកាយទៅខាងក្រោយ ឈ្មោះថា **បដិក្កន្តេ** ។ ក្នុងការអង្គុយ បុគ្គលអង្គុយបែរមុខទៅខាងមុខនៃអាសនៈឈ្មោះថា **អភិក្កន្តេ** រំលអវយវៈទៅខាងក្រោយ ឈ្មោះថា **បដិក្កន្តេ** ។ ក្នុងការដេក ក៏ន័យនេះដូចគ្នា ។

បទថា **សម្បជានការីហោតិ** បានដល់ ជាអ្នកមានប្រក្រតី ធ្វើកិច្ចទាំងអស់ដោយសម្បជញ្ញៈ ឬថាជាអ្នកមានប្រក្រតីធ្វើនូវការដឹងខ្លួននោះឯង ។ ពិតហើយបុគ្គលមានសម្បជញ្ញៈនោះ រមែងធ្វើការដឹងខ្លួនក្នុងការឈានទៅមុខជាដើម ជាអ្នកមិនវៀរចាកការដឹងខ្លួន ទោះក្នុងទីណាក៏ដោយ ។

គប្បីជ្រាបសេចក្ដីក្នុងបទថា **អាលោកិតេវិលោកិតេ** ដូចតទៅនេះថា ការសម្លឹងមើលទៅខាងមុខ ឈ្មោះថា **អាលោកិតេ** ការក្រឡេកទៅកាន់ទិសផ្សេងៗឈ្មោះថា **វិលោកិតេ** ។ ជាបុគ្គលឈ្មោះថា មានការឱនចុះ ការងើយ ការបែរត្រឡប់មើលដោយអំណាចការសម្លឹងមើល សូម្បីទិសដទៃទៅខាងក្រោម ខាងលើ ខាងក្រោយ ។ ក្នុងទីនេះ មិនបានកាន់យកឥរិយាបថទាំងនោះ ។ តែដោយសរុបក៏កាន់យក ២ យ៉ាងនេះ ឬកាន់យកទាំងអស់ដោយជាមាតិកានេះប៉ុណ្ណោះ ។

បទថា **សម្មិញ្ជិតេបសារិតេ** បានដល់ ក្នុងការបត់អង្គុញ និងលាតសណ្ដូកនូវអវយវៈទាំងឡាយ ។ គប្បីជ្រាបសេចក្ដីក្នុងបទថា **សង្ឃាដិបត្តចីវរធារណេ** នេះ ដូចតទៅនេះថា ការប្រើប្រាស់ ដោយការស្លៀកនិងការដណ្ដប់នូវសង្ឃាដិ និងចីវរដោយការទទួលភិក្ខាដោយបាត្រ ឈ្មោះថា **ធារណេ** ។ គប្បីជ្រាបសេចក្ដី ក្នុងបទថា **អសិតេ** ដូចតទៅនេះថា បទថា **អសិតេ** បានដល់ ក្នុងការឆាន់បិណ្ឌបាត ។ បទថា **បីតេ** បានដល់ ក្នុងការផឹកបបរជាដើម ។ បទថា **ខាយិតេ** បានដល់ ក្នុងការទំពារបស់ទំពាដែលធ្វើដោយម្សៅជាដើម ។ បទថា **សាយិតេ** បានដល់ ក្នុងការលិទ្ធភក្សុ ទឹកឃ្មុំនិងទឹកអំពៅជាដើម ។ បទថា **ឧច្ចារបស្សាវកម្មេ** បានដល់ ក្នុងការធ្វើការបន្ទោបង់ឧច្ចារៈនិងបស្សាវៈ ។

គប្បីជ្រាបសេចក្ដីក្នុងបទថា **គតេ** ដូចតទៅនេះថា បទថា **គតេ** បានដល់ ក្នុងការទៅ ។ បទថា **ឋិតេ** បានដល់ ក្នុងការឈរ ។ បទថា **និសិន្នេ** បាន

ដល់ ក្នុងការអង្គុយ ។ បទថា **សុត្តេ** បានដល់ ក្នុងការដេក ។ បទថា **ជាគរិតេ** បានដល់ ក្នុងការភ្ញាក់ ។ បទថា **ភាសិតេ** បានដល់ ក្នុងការនិយាយ ។ ក្នុងការនិយាយនោះកាលភិក្ខុកំណត់បានថា កាលសទ្ទាយតនៈដែលជាឧបាទាយ-រូបមិនប្រព្រឹត្តទៅ ឈ្មោះថា ការនិយាយមិនមាន កាលសទ្ទាយតនៈនោះប្រព្រឹត្តទៅការនិយាយក៏ឈ្មោះថាមាន ឈ្មោះថា **ភាសិតេសម្បជានការី** ។ ភិក្ខុសម្តែងធម៌ក្នុងមាតិកាវិមុត្តាយតនៈ គឺការរួបផុតខ្លះ លះតិរច្ឆានកថា ៣២ ពោលកថាអាស្រ័យកថាវត្ថុ ១០ ខ្លះ ក៏ឈ្មោះថា **ភាសិតេសម្បជានការី** ។ បទថា **តុណ្ហីភាវេ** បានដល់ ក្នុងការមិននិយាយ ។ ក្នុងបទថា **តុណ្ហីភាវេ** នេះ ភិក្ខុកំណត់បានថា ក្នុងការប្រព្រឹត្តទៅនៃសទ្ទាយតនៈដែលជាឧបាយរូប ឈ្មោះថាភាពជាអ្នកស្ងៀមរមែងមិនមានក្នុងការមិនប្រព្រឹត្តទៅនៃសទ្ទាយតនៈដែលជាឧបាទាយរូប ឈ្មោះថាភាពជាអ្នកនៅស្ងៀមរមែងមាន ឈ្មោះថា **តុណ្ហីភាវេសម្បជានការី** ។ ភិក្ខុអង្គុយរៀនកម្មដ្ឋានដែលជាទីពេញចិត្តក្នុងអារម្មណ៍ ៣៨ ក្តី ចូលទុតិយជ្ឈានក្តី ឈ្មោះថា **តុណ្ហីភាវេសម្បជានការី** ។ ម្យ៉ាងទៀតក្នុងអធិការនេះ ១ ឥរិយាបថមកហើយក្នុងទីពីរកន្លែង ។ ដំបូងក្នុងបទថា **អភិក្កន្តេបដិក្កន្តេ** នេះ កាលភិក្ខុដើរទៅ ដើរត្រឡប់ទៅកាន់ស្រុកដើម្បីភិក្ខាចារ លោកពោលដល់ឥរិយាបថនោះ ដោយអំណាចការដើរផ្លូវឆ្ងាយ ។ ក្នុងបទថា **គតេឋិតេនិសិន្នេ** នេះ គប្បីជ្រាបថា លោកពោលដោយអំណាចការលើកជើង ដែលជាការដើរបន្តិចបន្តួចក្នុងវិហារ ។ បទថា **ពុទ្ធានុស្សតិវសេន** ជាដើម លោកធ្លាប់ប្រកាសទុកហើយក្នុងទីនោះៗ ។

[ ២៥៦ ] បទថា **អរតិ** ជាពាក្យបដិសេធការត្រេកអរ ។ បទថា **អរតិកា** បានដល់ អាការមិនត្រេកអរ ។ បទថា **អនភិរតិ** បានដល់ ភាវៈនៃបុគ្គលមិនត្រេកអរក្រៃលែង ។ បទថា **អនភិរមនា** បានដល់ អាការនៃការមិនត្រេកអរយ៉ាងក្រៃលែង ។ បទថា **ឧក្កណ្ឋិតា** បានដល់ អាការអផ្សុក ។ បទថា **បរិតស្សិតា** បានដល់ ការរសាប់រសល់ដោយការធុញទ្រាន់ ។

[ ២៥៨ ] បទថា **កឹសូ អសិស្សំ** បានដល់ អាត្មានឹងបរិភោគអ្វី ។ បទថា **កុវំ វា អសិស្សំ** បានដល់ អាត្មានឹងបរិភោគក្នុងទីណា ។ បទថា **ទុក្ខំ វត សេត្ថ កុវជ្ជ សេស្សំ** បានដល់ អាត្មាដេកលំបាកអស់យប់នេះ យប់ដែលនឹងមកដល់ក្នុងថ្ងៃនេះ អាត្មានឹងដេកក្នុងទីណា ។ បទថា **ឯតេ វិតក្កេ** បានដល់ វិតក្ក ៤ យ៉ាង គឺវិតក្កអាស្រ័យបិណ្ឌបាត ២ យ៉ាង អាស្រ័យសេនាសនៈ ២ យ៉ាង ។ បទថា **អនិកេតចារី** បានដល់ ជាអ្នកមិនមានកន្លល់ត្រាច់ទៅ មិនមានតណ្ហាត្រាច់ទៅ ។

[ ២៦០ ] បទថា **ជលកេ វា** បានដល់ លើតាំងដែលមានក្អារកោងជាដើម ។ បទថា **អាគមនរត្តឹ** បានដល់ រាត្រីដែលមកដល់ ។

[ ២៦១ ] បទថា **អាទេវនេយ្យេ** បានដល់ ជាទីតាំង នៃការខ្សឹកខ្សួលជាពិសេស ។ បទថា **បរិទេវនេយ្យេ** បានដល់ ជាទីតាំងនៃការយំរៀបរាប់ទូទៅ ។

[ ២៦៤ ] បទថា **កាលេ** បានដល់ ក្នុងពេលចេញបិណ្ឌបាត អធិប្បាយថា បានដុំបាយ គឺបិណ្ឌបាតឬគ្រឿងស្លៀកដណ្តប់ គឺចីវរក្នុងចីវរកាលដោយ

ធម៌ស្មើ ។ បទថា **មត្តំ ស ជញ្ញា** បានដល់ ភិក្ខុនោះគប្បីដឹងប្រមាណក្នុងការទទួលនិងការបរិភោគ ។ បទថា **ឥធ** បានដល់ ក្នុងសាសនានេះឬបទថា **ឥធ** នោះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា **គោបនត្ថំ** បានដល់ ដើម្បីការគ្រោកអរ លោកអធិប្បាយថា ភិក្ខុគប្បីដឹងប្រមាណដើម្បីការគ្រោកអរនោះ ។ បទថា **សោ តេសុ គុត្តោ** បានដល់ ភិក្ខុនោះសង្រួមក្នុងបច្ច័យទាំងនោះ ។ បទថា **យតចារិ** បានដល់ ជាអ្នកមានការសង្រួមជាគ្រឿងនៅ លោកអធិប្បាយថា រក្សាឥរិយាបថនិងរក្សាកាយទ្វារ វចីទ្វារ មនោទ្វារ ។ បាឋៈថា **យតិចារិ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **រុសិតោ** បានដល់ ត្រូវគេជេរ អធិប្បាយថា ត្រូវគេខ្ញាំងខ្ញប់ ។

បទថា **ទ្វីហិ ការណេហិ មត្តំ ជានេយ្យ** បានដល់ គប្បីស្គាល់ប្រមាណដោយចំណែក ២ ។ បទថា **បដិគ្គហណតោ វា** បានដល់ ដោយវេលាដែលនឹងទទួលរបស់ដែលអ្នកដទៃឲ្យ ។ បទថា **បរិភោគតោ វា** បានដល់ ដោយវេលាដែលនឹងបរិភោគ ។ បទថា **ថោកេបិ ទិយ្យមានេ** បានដល់ កាលទាយកប្រគេនសូម្បីតិចតួច ។ បទថា **កុលានុទយាយ** បានដល់ ព្រោះភាពជាអ្នកករុណាចំពោះត្រកូល ។ បទថា **កុលានុរក្ខាយ** បានដល់ ដើម្បីតាមរក្សាត្រកូល ។ បទថា **បដិគ្គណ្ហាតិ** បានដល់ ទទួលសូម្បីតិចតួច ។ បទថា **ពហុកេបិ ទិយ្យមានេ** បានដល់ កាលទាយកឲ្យសូម្បីច្រើន ។

គប្បីជ្រាបអត្ថក្នុងបទថា **កាយបរិហារិកំ ចីវរំ បដិគ្គណ្ហាតិ** ដូចតទៅនេះថា ឈ្មោះថា **កាយបរិហារិកំ** ព្រោះអត្ថថា បរិហាររាងកាយ ។ ក្នុង

បទថា **កុច្ឆិបរិហារិកំ** មានវិគ្គហៈថា ឈ្មោះថា **កុច្ឆិបរិហារិកំ** ព្រោះអត្ថថា បរិហារផ្ទៃ ។ បរិក្ខារ ៨ គឺត្រៃចីវរ បាត្រ កាំបិតកាត់ ឈើស្ទន់ ម្ជុល វត្ថពន្ធចង្កេះ ធម្មក្រក រមែងគួរដល់ភិក្ខុដែលប្រកបដោយសេចក្ដីសន្ដោសក្នុងបច្ច័យតាមមានតាមបាន សមដូចលោកពោលទុកថា

*បរិក្ខារ ៨ គឺត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធចង្កេះ ធម្មក្រក*

*រមែងគួរដល់ភិក្ខុអ្នកប្រកបសេចក្ដីព្យាយាម ដូច្នេះ ។*

បរិក្ខារទាំងនោះបរិហារកាយផង បរិហារផ្ទៃផង សេចក្ដីនេះដូចម្ដេច នឹងពោលដល់ត្រៃចីវរមុន រមែងបរិហារកាយក្នុងពេលស្លៀកនិងដណ្ដប់ត្រាច់ទៅ ព្រោះហេតុនោះទើបជាការបរិហារកាយ ។ ត្រៃចីវរ រមែងបរិហារផ្ទៃក្នុងពេលដែលយកជាយចីវរត្រងទឹកផឹក និងក្នុងពេលយកចីវរដាក់ផ្លែឈើតូចធំដែលគួរទំពា ព្រោះហេតុនោះទើបជាការបរិហារផ្ទៃ ។ សូម្បីបាត្រ ក៏ជាការបរិហារកាយ ក្នុងពេលយកបាត្រដងទឹកងូតឬដងទឹកធ្វើការសម្អាតកុដិ តែជារបស់បរិហារផ្ទៃក្នុងពេលដែលដាក់អាហារបរិភោគ ។ កាំបិត ជាការបរិហារកាយក្នុងពេលដែលយកកាំបិតកាត់ឈើស្ទន់និងក្នុងពេលសម្អាតជើងគ្រែតាំង កាត់ចីវរនិងកាប់ឈើធ្វើកុដិ ជាការបរិហារផ្ទៃក្នុងពេលកាត់អំពៅ និងកាប់ដូងជាដើម ។ ម្ជុលជាការបរិហារកាយក្នុងពេលដេរចីវរ ជាការបរិហារផ្ទៃក្នុងពេលដែលចាក់នំឬផ្លែឈើយកមកបរិភោគ ។ វត្ថពន្ធចង្កេះបរិហារកាយក្នុងពេលដែលចងកាយត្រាច់ទៅ ជាការបរិហារផ្ទៃក្នុងពេលចងអំពៅជាដើមកាន់យកទៅ ។ ធម្មក្រកបរិហារកាយក្នុងពេលត្រងទឹកងូតនិងក្នុងពេលធ្វើការសម្អាត

សេទាសេទៈ ជាការបរិហារផ្ទៃក្នុងពេលដែលត្រូវទឹកផឹក និងក្នុងពេលយកធម្មក្រកនោះដាក់ល្វ ដាក់អង្គរ ដាក់អំបុកជាដើម ដោយធម្មក្រកនោះឆាន់ ។

បទថា **បដិសង្ខា យោនិសោ** សេចក្តីថា ពិចារណាដោយឧបាយ គឺដោយគន្លង អធិប្បាយថា ពិចារណា ។ ម្យ៉ាងទៀតក្នុងបទនេះគប្បីជ្រាបថា ការពិចារណាតាមដែលពោលហើយដោយន័យជាដើមថា **សីតស្ស បដិឃាតាយ** ជាការពិចារណាដោយឧបាយ ។ ក្នុងបទទាំងនោះ បទថា **ចីវរំ** បានដល់ ចីវរផ្ទាំងណាមួយ បណ្តាអន្តរវាសកជាដើម ។ បទថា **បដិសេវតិ** បានដល់ ប្រើប្រាស់ គឺស្លៀកឬដណ្តប់ ។ បទថា **យាវទេវ** ជាពាក្យកំណត់ដែនរបស់ប្រយោជន៍ ដ្បិតថាប្រយោជន៍ក្នុងការប្រើចីវររបស់ព្រះយោគី មានត្រឹមប៉ុណ្ណេះ គឺដើម្បីកម្ចាត់នូវរងាជាដើម មិនក្រៃលែងជាងនោះ ។ បទថា **សីតស្ស** បានដល់ រងាណាមួយដែលកើតឡើង ដោយអំណាចធាតុខាងក្នុងកម្រើក ឬដោយការប្រែប្រួលរដូវខាងក្រៅ ។

បទថា **បដិឃាតាយ** បានដល់ ដើម្បីកម្ចាត់ ។ ដើម្បីបន្ទោបង់រងា ដោយអាការដែលមិនឲ្យអាពាធកើតឡើងក្នុងរាងកាយ ។

ព្រោះថា កាលរាងកាយត្រូវរងាបៀតបៀន ភិក្ខុដែលមានចិត្តរាយមាយមិនអាចតម្កល់សេចក្តីព្យាយាមដោយឧបាយបាន ព្រោះហេតុនោះទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតថា ភិក្ខុគប្បីប្រើចីវរដើម្បីកម្ចាត់រងាដូច្នេះ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ ក្នុងបទនេះមាន ( ការបរិហាកាយ ) តែម្យ៉ាង ។ បទថា **ឧណ្ហស្ស** បានដល់ កម្តៅរបស់ភ្លើង ។ កម្តៅរបស់ភ្លើងនោះ គប្បីជ្រាប

ថា កើតឡើងព្រោះភ្លើងឆេះព្រៃជាដើម ។ ម្យ៉ាងទៀតគប្បីជ្រាបអត្ថក្នុងបទនេះ ថា **ឌំសមកសវាតាតបសិរីសបសម្ផស្សានំ** ដូចតទៅនេះថា បទថា **ឌំស** បានដល់ រពោម ។ លោកហៅថា **អន្ធមក្ខិកា** ក៏មាន ។ បទថា **មកស** បានដល់ មូសនោះឯង ។ បទថា **វាតា** បានដល់ ខ្យល់លាយដោយធូលី និងមិនលាយដោយធូលី ។ បទថា **អាតបោ** បានដល់ កម្តៅដែលកើតអំពីព្រះអាទិត្យ ។ បទថា **សិរីសប** បានដល់ ទីឃជាតិណាមួយមានពស់ជាដើម ដែលជាសត្វលូនវារទៅ ទីឃជាតិទាំងនោះមានសម្ផស្ស ២ យ៉ាង គឺទត្ថសម្ផស្ស សម្ផស្សដែលត្រូវខាំ ១ ផុដ្ឋសម្ផស្ស សម្ផស្សដែលពាល់ត្រូវ ១ សម្ផស្សទាំងនោះ រមែងមិនបៀតបៀនភិក្ខុដែលអង្គុយដណ្តប់ចីវរ ។ ព្រោះហេតុនោះភិក្ខុប្រើចីវរក៏ដើម្បីការពារសម្ផស្សទាំងនោះក្នុងឋានៈបែបនោះ ។ ម្យ៉ាងទៀត បទថា **យាវទេវ** បានដល់ ដើម្បីសម្តែងកំណត់ដែនរបស់ប្រយោជន៍ដែលពិតប្រាកដ ។ ព្រោះប្រយោជន៍ដែលពិតប្រាកដ គឺការបិទបាំងអវយវៈដែលញុំាងការខ្មាសឲ្យកម្រើក ។ ប្រយោជន៍ក្រៅអំពីនេះរមែងមានម្តងម្កាល ។ ក្នុងបទទាំងនោះ បទថា **ហិរិកោបីនំ** បានដល់ អវយវៈនោះៗ នៅក្នុងទីបង្កៀត ។ ព្រោះកាលអវយវៈណាបើក ហិរិរមែងកម្រើក គឺវិនាស ទើបលោកហៅអវយវៈនោះៗថា **ហិរិកោបីនំ** ព្រោះញុំាងហិរិឲ្យកម្រើក ។ ឈ្មោះថា **ហិរិ-កោបីនបដិច្ឆាទនត្ថំ** ព្រោះអត្ថថា ដើម្បីបិទបាំងអវយវៈដែលញុំាងហិរិឲ្យកម្រើកនោះ ។ បាឋៈថា **ហិរិកោបីនំ បដិច្ឆាទនត្ថំ** ដូច្នេះក៏មាន ។

បទថា **បិណ្ឌបាតំ** បានដល់ អាហារឯណានីមួយ ពិតហើយលោកហៅ

អាហារណាមួយថា **បិណ្ឌបាត** ព្រោះធ្លាក់ទៅក្នុងបាត្ររបស់ភិក្ខុ ដោយភាពជាដុំឬឈ្មោះថាបិណ្ឌបាត ព្រោះដុំបាយធ្លាក់ទៅ អធិប្បាយថា រួបរួមភិក្ខាដែលបានក្នុងទីនោះៗ ។ បទដ៏សេសមានន័យដូចពោលហើយខាងដើមនោះឯង ។

បទថា **សេនាសនំ** បានដល់ ទីដេកនិងទីអង្គុយ ។ ភិក្ខុដេកក្នុងទីណាមួយទោះជាក្នុងវិហារក្ដី ក្នុងបង្អាក្ដី ទីនោះហៅថា **សេន** ។ ភិក្ខុអង្គុយក្នុងទីណាទីនោះហៅថា **អាសន** ។ ទីដេក ទីអង្គុយរួមចូលគ្នា ហៅថា **សេនាសន** ។

បទថា **ឧតុបរិស្សយវិនោទនបដិសល្លានារាមត្ថំ** សេចក្ដីថា ឧតុនោះឯងឈ្មោះថា **ឧតុបរិស្សយ** ព្រោះអត្ថថា ជាអន្តរាយ ។ ដើម្បីបន្ទោបង់អន្តរាយអំពីឧតុនិងដើម្បីសេចក្ដីត្រេកអរក្នុងការពួនសម្ងំ ។ រដូវណាជារដូវមិនសប្បាយធ្វើឲ្យរាងកាយនិងចិត្តខុសប្រក្រតី គប្បីបន្ទោបង់រដូវនោះដោយការប្រើសេនាសនៈ ដើម្បីបន្ទោបង់ឧតុនោះ អធិប្បាយថា ដើម្បីសេចក្ដីសុខដែលជាឯកីភាវៈ ។ លោកពោលការបន្ទោបង់អន្តរាយដែលកើតអំពីឧតុដោយបទជាដើមថា **សីតបដិឃាត** ក៏ពិត តែក្នុងការប្រើចីវរ លោកពោលថា ក៏ព្រោះប្រយោជន៍ដែលពិតប្រាកដ គឺការបិទបាំងអវយវៈដែលធ្វើសេចក្ដីខ្មាសឲ្យកម្រើក ប្រយោជន៍ក្រៅអំពីនោះមានមុតម្ដងម្កាលយ៉ាងណា ក្នុងពាក្យនេះក៏យ៉ាងនោះ គប្បីជ្រាបថាលោកពោលដូច្នេះ សំដៅដល់ប្រយោជន៍ដែលពិតប្រាកដ គឺការបន្ទោបង់អន្តរាយ ដែលកើតអំពីឧតុ ។ ម្យ៉ាងទៀត ឧតុដែលបានពោលហើយនេះ គឺឧតុប៉ុណ្ណោះ ។

តែអន្តរាយមាន ២ យ៉ាង គឺអន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ក្នុង

អន្តរាយ ២ យ៉ាងនោះ អន្តរាយប្រាកដ បានដល់ រាជសីហ៍និងខ្លាធំជាដើម អន្តរាយកំបាំង បានដល់ រាគៈនិងទោសៈជាដើម ។ អន្តរាយទាំងនោះមិនធ្វើនូវការបៀតបៀន ដោយការមិនគ្រប់គ្រងនិងដោយការឃើញរូប មិនជាទីសប្បាយជាដើម ក្នុងសេនាសនៈណាភិក្ខុដឹងហើយពិចារណាយ៉ាងនេះ ប្រើសេនាសនៈនោះគប្បីជ្រាបថា ឈ្មោះថាពិចារណាដោយឧបាយប្រាជ្ញា ហើយប្រើប្រាស់សេនាសនៈដើម្បីបន្ទោបង់អន្តរាយដែលកើតអំពីរដូវ ។

គប្បីជ្រាបអត្ថក្នុងបទនេះថា **គិលានប្បច្ចយភេសជ្ជបរិក្ខារំ** ដូចតទៅថា ឈ្មោះថា **បច្ចយោ** ដោយអត្ថថា ការពារនូវរោគ អធិប្បាយថា ដោយអត្ថថា ដល់នូវភាពជាសត្រូវដល់គ្នានឹងគ្នា ។ បទថា **បច្ចយោ** នេះ ជាឈ្មោះនៃសេចក្តីសុខឯណានីមួយ ។ ការងាររបស់គ្រូពេទ្យ ឈ្មោះថាភេសជ្ជៈ ព្រោះគ្រូពេទ្យ ជាអ្នកអនុញ្ញាត ។ ភេសជ្ជៈ គឺគិលានបច្ច័យនោះឯង ឈ្មោះថា **គិលានប្បច្ចយភេសជ្ជំ** លោកអធិប្បាយថា ការងាររបស់គ្រូពេទ្យ មានប្រេង ទឹកឃ្មុំ ស្ករអំពៅជាដើមឯណានីមួយ ជាទីសប្បាយរបស់អ្នកជំងឺ ។ បទថា **បរិក្ខារោ** របស់ លោកហៅថា បរិក្ខារ ដូចក្នុងប្រយោគជាដើមថា **សត្តហិ នគរបរិក្ខារេហិ សុបរិក្ខត្តំ ហោតិ** នគរនៃស្តេចជាទីបំផុតនៃដែនដែលរៀបចំល្អហើយដោយនគរបរិក្ខារ ៧ យ៉ាងដូច្នេះ ។ គ្រឿងប្រដាប់ហៅថាបរិក្ខារ ដូចក្នុងប្រយោគជាដើមថា **រថោ សីលបរិក្ខារោ ឈានក្ខោ ចក្កវីរិយោ** រថ គឺអរិយមគ្គ ( នោះ ) មានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយៈជាកង់ដូច្នេះ ។ របស់ប្រើហៅថា បរិក្ខារ ដូចក្នុងប្រយោគជាដើមថា **យេ ច**

**ខោ ចិមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា** គ្រឿងបម្រុងជីវិត ( គឺ ចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារណាមួយនេះ ) ដែលបព្វជិតគប្បីប្រមូលមកដូច្នេះ ។ តែក្នុងទីនេះ មកក្នុងអត្ថថារបស់ប្រើប្រាស់ខ្វះ របស់ខ្វះក៏គួរ ។ ម្យ៉ាងទៀត គិលានប្បច្ចយភេសជ្ជៈនោះ ឈ្មោះថាជារបស់នៃជីវិត ព្រោះការពារមិនឲ្យឱកាសដល់អាពាធដែលធ្វើសេចក្តីវិនាសដល់ជីវិត ឈ្មោះថាជារបស់ប្រើប្រាស់ខ្វះ ព្រោះជាហេតុឲ្យជីវិតប្រព្រឹត្តទៅបានយូរ ។ ព្រោះហេតុនោះ ទើបហៅថា **បរិក្ខារោ** ។ ឈ្មោះថា **គិលានប្បច្ចយភេសជ្ជបរិក្ខារោ** ព្រោះអត្ថថា ជាគិលានប្បច្ចយភេសជ្ជៈនិងជាបរិក្ខារ ។ នូវគិលានប្បច្ចយភេសជ្ជបរិក្ខារនោះ ។ លោកអធិប្បាយថា ប្រេង ទឹកឃ្មុំនិងស្ករអំពៅជាដើមដែលគ្រូពេទ្យអនុញ្ញាតហើយណាមួយ ជាទីសប្បាយរបស់អ្នកជំងឺ ឈ្មោះថា ជាជីវិតបរិក្ខារ ។

បទថា **ឧប្បន្នានំ** បានដល់ កើតហើយ ឧប្បត្តិហើយ កើតឡើងហើយ ។ បទថា **ព្យាពាធោ** ក្នុងបទថា **វេយ្យាពាធិកានំ** នេះបានដល់ ធាតុកម្រើក ។ រោគយ្វង់ បូស បូសផ្កាប់មុខជាដើមដែលមានធាតុកម្រើក ជាសមុដ្ឋាន ឈ្មោះថា **វេយ្យាពាធិកា** ព្រោះកើតអំពីធាតុកម្រើក ។ បទថា **វេទនានំ** បានដល់ ទុក្ខវេទនា គឺវេទនាដែលជាផលនៃអកុសល ។ វេទនាដែលកើតព្រោះអាពាធផ្សេងៗទាំងនោះ ។ បទថា **អព្យាបជ្ឈបរមតាយ** បានដល់ ដើម្បីការមិនមានទុក្ខយ៉ាងក្រៃលែង អធិប្បាយថា កម្ចាត់ទុក្ខទាំងអស់បាន ។

[ ២៦៧ ] បទថា **សន្តុដ្ឋោ ហោតិ** បានដល់ សន្តោសដោយបច្ចយ-

សន្តោស ។ បទថា **ឥតរីតរេន ចីវរេន** បានដល់ មិនមែនជាអ្នកសន្តោស ដោយចីវរណាមួយបណ្ដាចីវរសាច់គ្រោតគ្រាត សាច់ម៉ដ្ដ សៅហ្មង ប្រណីត ថ្មីនិងចាស់ដែលពិតជាអ្នកសន្តោសដោយចីវរណាមួយ តាមមានតាមបាន បណ្ដាចីវរដែលបានហើយជាដើម ។ ពិតហើយក្នុងចីវរមានសន្តោស ៣ យ៉ាង គឺយថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។ ក្នុងបិណ្ឌបាតក៏មានន័យនេះដូចគ្នា ។

បទថា **វណ្ណវាទី** សេចក្ដីថា ភិក្ខុមួយរូបជាអ្នកសន្តោសតែមិនពោលគុណរបស់សេចក្ដីសន្តោស មួយរូបជាអ្នកមិនសន្តោស តែពោលគុណរបស់ការសន្តោស មួយរូបជាអ្នកមិនសន្តោសផង មិនពោលគុណនៃការសន្តោសផង មួយរូបជាអ្នកសន្តោសផង ពោលនូវគុណនៃការសន្តោសផង ដើម្បីសម្ដែងដល់ភិក្ខុនោះទើបព្រះសារីបុត្តពោលថា **ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី** ដូច្នេះ ។ បទថា **អនេសនំ** បានដល់ ការស្វែងរកមិនសមគួរ មានប្រការផ្សេងៗ មានប្រភេទដូចជាធ្វើជាទូតនាំសំបុត្រឬនាំដំណឹងជាដើម ។ បទថា **អប្បដិរូបំ** បានដល់ មិនសមគួរ ។ បទថា **អលទ្ធា ច** បានដល់ មិនបានហើយភិក្ខុរូបខ្លះគិតថា អញនឹងបានចីវរដូចម្ដេចហ្ន៎ ចូលទៅជាមួយភិក្ខុអ្នកមានបុណ្យ ធ្វើនូវការកុហក រមែងតក់ស្លុតភ័យខ្លាចយ៉ាងណា ភិក្ខុអ្នកសន្តោសមិនបានចីវរតក់ស្លុតយ៉ាងនោះក៏មិនមែន ។ បទថា **លទ្ធា ច** បានដល់ បានហើយដោយធម៌ស្មើ ។ បទថា **អគធិតោ** បានដល់ ប្រាសចាកសេចក្ដីលោភ ។ បទថា **អមុច្ឆិតោ** បានដល់ មិនវង្វេង ដោយការចង់បានលើសប្រមាណ ។ បទថា

**អនជ្ឈាបន្នោ** បានដល់ មិនត្រូវតណ្ហាក្តួចពន្ធ័ច មិនជាប់ចំពាក់ដោយតណ្ហា ។ បទថា **អាទីនវទស្សាវី** បានដល់ ឃើញទោសក្នុងការស្វែងរក មិនសមគួរ និងក្នុងការបរិភោគដោយចំណង់ ។ បទថា **និស្សរណប្បញ្ញោ** បានដល់ ដឹងនូវគ្រឿងរលាស់ទុក្ខដែលពោលហើយថា **យាវទេវ សីតស្ស បដិឃាតាយ** គ្រាន់តែដើម្បីការពារត្រជាក់ ។

បទថា **ឥតរីតរចីវរសន្តុដ្ឋិយា** បានដល់ ដោយសេចក្តីសន្តោស ក្នុងចីវរឯណាទីមួយ ។ បទថា **នេវត្តានុក្កំសេតិ** បានដល់ មិនលើកខ្លួនថាអាត្មាអញជាអ្នកសមាទានសំពត់បង្សុកូលជាវត្ត អាត្មាអញសមាទានបង្សុកូលិកង្គ-ធុតង្គ តាំងអំពីពេលដែលឧបសម្បទា មិនមានបុគ្គលណាដូចអញ ។ បទថា **ន បរំ វម្ភេតិ** បានដល់ មិនសង្កត់សង្កិនអ្នកដទៃយ៉ាងនេះថា ភិក្ខុដទៃទាំងនោះ មិនសមាទានសំពត់បង្សុកូលជាវត្ត ឬភិក្ខុទាំងនោះ មិនមានសូម្បីត្រឹមតែការសមាទានសំពត់បង្សុកូលជាវត្ត ។

បទថា **យោ ហិ តត្ថ ទក្ខោ** បានដល់ ភិក្ខុណាជាអ្នកខ្មីឃ្មាត ឈ្លាសមុតស្រួចក្នុងការពោលគុណជាដើមក្នុងចីវរសន្តោសនោះ ។ បទថា **អនលសោ** បានដល់ វៀរចាកការខ្ជិលច្រអូសដោយការធ្វើរឿយៗ ។ បទថា **សម្បជានោ បដិស្សតោ** បានដល់ ប្រកបដោយបញ្ញា គឺការដឹងខ្លួននិងដោយសតិ ។ បទថា **បោរាណេ** បានដល់ មិនមែនទើបតែកើតក្នុងឥឡូវនេះ ។ បទថា **អគ្គញ្ញេ** បានដល់ ដែលសន្មតថាជាវង្សដ៏ប្រសើរ ។ បទថា **អរិយវំសេ ឋិតោ** បានដល់ តាំងនៅក្នុងវង្សរបស់ព្រះអរិយៈទាំងឡាយ ។

ម្យ៉ាងទៀតបទថា **អរិយវំសោ** បានដល់ អរិយវង្សទី ៨ នេះ ឈ្មោះថា ជាខ្សែស្រឡាយរបស់ព្រះអរិយៈ ជាបវេណីរបស់ព្រះអរិយៈ ដូចវង្សរបស់ក្សត្រ វង្សរបស់ព្រាហ្មណ៍ វង្សរបស់វេស្សៈ វង្សរបស់សូទ្រៈ វង្សរបស់សមណៈ វង្សរបស់ត្រកូលរាជវង្សដូច្នោះ ។ អរិយវង្សនេះ លោកពោលថា ប្រសើរជាងវង្សទាំងនេះ ដូចក្លិនក្លាំពាក់ជាដើម ប្រសើរជាងក្លិនឈើដែលកើតអំពីឫសជាដើម ។ បុគ្គលដែលមានវង្សនោះដែលជាព្រះអរិយៈទាំងឡាយ បានដល់នរណាខ្លះ គឺព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ សាវករបស់ព្រះតថាគតទាំងឡាយ លោកហៅថាជាព្រះអរិយៈ វង្សរបស់អរិយៈទាំងនោះ ឈ្មោះថាអរិយវង្ស ។ ពិតហើយមុនអំពីនេះក្នុងទីបំផុត ៤ អសង្ខេយ្យនិងមួយសែនកប្បមានព្រះសម្ពុទ្ធកើតឡើង ៤ អង្គ គឺព្រះតណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ ។ ព្រះពុទ្ធទាំងនោះជាអរិយៈ វង្សរបស់អរិយៈទាំងនោះ ឈ្មោះថា អរិយវង្ស ។ តមកខាងក្រោយអំពីព្រះពុទ្ធទាំងនោះ បរិនិព្វានកន្លងទៅមួយអសង្ខេយ្យព្រះពុទ្ធព្រះនាមថា កោណ្ឌញ្ញៈ ទ្រង់កើតឡើង ។ ក្នុងកប្បនេះព្រះពុទ្ធ ៤ អង្គទ្រង់កើតឡើង គឺព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ ព្រះមានព្រះភាគនៃយើង គឺព្រះគោតម វង្សរបស់ព្រះអរិយៈទាំងនេះ ឈ្មោះថា អរិយវង្ស ។ ម្យ៉ាងទៀត វង្សនៃព្រះអរិយៈទាំងឡាយដែលជាព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងសាវករបស់ព្រះពុទ្ធទាំងឡាយ ក្នុងអតីត អនាគតនិងបច្ចុប្បន្ន ឈ្មោះថា អរិយវង្ស ។ តាំងនៅក្នុងអរិយវង្សនោះ ។

បទថា **ឥតរីតរេន បិណ្ឌបាតេន** បានដល់ ដោយបិណ្ឌបាតណាមួយ ។

ក្នុងសេនាសនៈជាដើមក៏មានន័យនេះដូចគ្នា ។

[ ២៦៨ ] បទថា **អាយតនេសុ** បានដល់ ក្នុងអាយតនៈទាំងឡាយមានចក្ខាយតនៈជាដើម ។ បទថា **យតោ** បានដល់ សង្រួមហើយ ។ បទថា **យត្តោ** បានដល់ ជាអ្នកសង្រួមហើយ ។ បទថា **បដិយត្តោ** បានដល់ ជាអ្នកសង្រួមក្រៃលែង ។ បទថា **គុត្តោ** បានដល់ រក្សាហើយ ។ បទថា **គោបិតោ** បានដល់ តម្កល់ទុកហើយ ដូចតម្កល់ទុកក្នុងហិប ។ បទថា **រក្ខិតោ** បានដល់ រក្សាទុកហើយ ។ បទថា **សំវុតោ** បានដល់ បិទហើយដោយការសង្រួមក្នុងទ្វារ ។

[ ២៦៩ ] បទថា **ទុំសិតោ** បានដល់ ត្រូវតិះដៀល ។ បទថា **វម្ភិតោ** បានដល់ គេមិនជ្រះថ្លា ។ បទថា **ឃដ្ដិតោ** បានដល់ ឲ្យដល់នូវទៅនូវការខ្ទាំងខ្ទប់ ។ បទថា **គរហិតោ** បានដល់ ត្រូវគេជាន់ឈ្លី ។ បទថា **ឧបវទិតោ** បានដល់ ត្រូវគេជេរ ។ បទថា **ផរុសេន** បានដល់ ដោយពាក្យកាត់អវយវៈដែលសំខាន់របស់រាងកាយ ។ បទថា **កក្ខឡេន** បានដល់ ទារុណ ។ បទថា **នប្បដិវជ្ជា** បានដល់ មិនគប្បីពោលឆ្លើយឆ្លង ។

[ ២៧០ ] បទថា **ឈានានុយុត្តោ** បានដល់ ប្រកបរឿយៗដោយឈានដែលមិនទាន់កើត ឲ្យកើតឡើងនិងសេពឈានដែលកើតហើយ ។ បទថា **ឧបេក្ខមារព្ភ សមាហិតត្តោ** បានដល់ ជាអ្នកញុំាងឧបេក្ខាក្នុងចតុត្ថជ្ឈានឲ្យកើតហើយមានចិត្តតាំងមាំ ។ បទថា **តក្កាសយំ កុក្កុច្ចញ្ចុបច្ឆិន្ទេ** បានដល់ គប្បីកាត់នូវវិតក្កៈមានកាមវិតក្កជាដើម នូវលំនៅរបស់វិតក្កៈមានកាមសញ្ញាជា

ដើមនិងនូវការរពឹស មានការរពឹសដែជាដើម ។

[ ២៧៣ ] បទថា **អនុប្បន្នស្ស វា បឋមស្ស ឈានស្ស ឧប្បាទាយ** បានដល់ ដើម្បីការកើតឡើងនៃបឋមជ្ឈានដែលមិនទាន់កើត ឬដែលវិនាស ទៅហើយក្នុងអត្តភាពនោះ គឺដើម្បីបានចំពោះក្នុងសន្តានរបស់ខ្លួន ។

គប្បីជ្រាបសេចក្តីក្នុងបទជាដើមថា **ឧប្បន្នំ វា បឋមំ ឈានំ អាសេវតិ** ដូចតទៅនេះថា ក្នុងបទនេះមានសេចក្តីថា សេពដោយអើពើ គឺធ្វើឲ្យស្ទាត់ ចម្រើនគឺធ្វើឲ្យធំ ធ្វើឲ្យច្រើនគឺធ្វើរឿយៗ ។

[ ២៧៤ ] បទថា **ឧបេក្ខា** បានដល់ តត្រមជ្ឈត្តុបេក្ខា ដែលកើតឡើង ក្នុងចតុត្ថជ្ឈាន ។ បទថា **ឧបេក្ខា** ជាបទសម្តែងសភាវៈ ។

បទថា **ឧបេក្ខនា** បានដល់ អាការឃើញដោយការចូលដល់ ។ បទថា **អជ្ឈុបេក្ខនា** បានដល់ ឃើញយ៉ាងក្រៃលែង ។ បទថា **ចិត្តសមតា** បាន ដល់ ភាពដែលចិត្តស្មើ គឺការគ្រប់គ្រាន់ដែលវៀរការខ្វះនិងការលើស ។ បទ ថា **ចិត្តប្បស្សទ្ធតា** បានដល់ ភាពដែលចិត្តមិនរពឹស អធិប្បាយថា ភាព ដែលចិត្តមិនរឹង ។ បទថា **មជ្ឈត្តតាចិត្តស្ស** អធិប្បាយថា ភាពដែលចិត្តជា កណ្តាល មិនមែនសត្វ មិនមែនបុគ្គល ។ បទថា **ចតុត្ថេ ឈានេ ឧបេក្ខំ អារព្ភ** បានដល់ អាស្រ័យតត្រមជ្ឈត្តុបេក្ខាដែលកើតឡើងក្នុងចតុត្ថជ្ឈាន ។ បទថា **ឯកគ្គចិត្តោ** បានដល់ ជាចិត្តដែលប្រព្រឹត្តទៅហើយ ក្នុងអារម្មណ៍ មួយ ។ បទថា **អវិក្ខិត្តចិត្តោ** បានដល់ វៀរចាកឧទ្ធច្ចៈ ជាអ្នកមានចិត្តមិន រាយមាយ ។

[ ២៧៥ ] វិតក្កៈ ៩ មានន័យដូចពោលហើយ ។ បទថា **កាមវិតក្កានំ កាមសញ្ញាសយោ** អធិប្បាយថា កាមសញ្ញាដែលកើតឡើងដល់អ្នកត្រិះរិះដោយកាមវិតក្កៈជាទីអាស្រ័យ ជាឱកាស ជាលំនៅរបស់វិតក្កៈទាំងនោះ ព្រោះហេតុនោះទើបឈ្មោះថា **កាមសញ្ញាសយោ** ក្នុងព្យាបាទវិតក្កជាដើម ក៏មានន័យនេះដូចគ្នា ។

[ ២៧៦ ] បទថា **ចុទិតោ វចីភិ សតិមាភិនន្ទេ** បានដល់ ភិក្ខុត្រូវឧបជ្ឈាយ៍ជាដើមដាស់តឿនដោយវាចា គប្បីជាអ្នកមានសតិត្រេកអរនឹងពាក្យដាស់តឿននោះ ។ បទថា **វាចំ បមុញ្ចេ កុសលំ** បានដល់ បន្លឺវាចាដែលតាំងឡើងដោយញាណ ។ បទថា **នាតិវេលំ** បានដល់ មិនគប្បីបន្លឺវាចាហួសព្រំដែន គឺលើសព្រំដែននៃពេលវេលានិងព្រំដែននៃសីល ។ បទថា **ជនវាទ-ធម្មាយ** បានដល់ ពាក្យរបស់ជន ។ បទថា **ន ចេតយេយ្យ** បានដល់ មិនគប្បីញុំាងនូវការគិតឲ្យកើត ។

[ ២៧៧ ] បទថា **ឥធំ តេ អប្បត្តំ** បានដល់ កម្មនេះជាកម្មមិនដល់លោក ។ បទថា **អសារុប្បំ** បានដល់ ការប្រកបនេះមិនសមគួរដល់លោក ។ បទថា **អសីលដ្ឋំ** សេចក្តីថា ឈ្មោះថា **អសីលដ្ឋំ** ព្រោះអត្ថថា ការប្រកបរបស់លោកមិនតាំងនៅក្នុងសីល អធិប្បាយថា កម្មនេះមិនជាបយោគសម្បត្តិរបស់លោក ដែលតាំងនៅក្នុងសីល ។ អាចារ្យពួកខ្លះសូធ្យថា **អសិលិដ្ឋំ** គឺមិនស្អាត ។ លោកពណ៌នាសេចក្តីថា មានវាចាមិនពីរោះ ។

បទថា **និធីនំ** បានដល់ ឆ្នាំងទ្រព្យដែលពេញដោយប្រាក់និងមាសដែល

គេកប់ទុកក្នុងទីនោះៗ ។ បទថា **បវត្តារំ** បានដល់ ដូចបុគ្គលធ្វើនូវការអនុគ្រោះមនុស្សក្រីក្រ ជាអ្នកមានការរស់នៅខ្វះខាតដោយពោលថា អ្នកចូរមកតាមខ្ញុំ ខ្ញុំនឹងប្រាប់ឧបាយចិញ្ចឹមជីវិត ឲ្យជាសុខដល់អ្នក ហើយនាំទៅកាន់ទីកប់ទ្រព្យ លាដៃប្រាប់ថា ចូរអ្នកកាន់យកទ្រព្យនេះ ចិញ្ចឹមជីវិតហើយនៅជាសុខចុះ ។

បទថា **វជ្ជទស្សិនំ** សេចក្ដីថា អ្នកចង្អុលប្រាប់ទោសមាន ២ ពួក គឺអ្នកចាំស្វែងរកទោសដោយបំណងថា អញនឹងសង្កត់សង្កិនភិក្ខុនោះ ក្នុងកណ្ដាលសង្ឃដោយកម្មមិនសមគួរ ឬដោយការភ្លាំងភ្លាត់នេះ និងបុគ្គលដែលតាំងនៅក្នុងសភាវៈដែលចង្អុលនូវទោសដោយការពិនិត្យមើលទោសនោះៗ ព្រោះភាពជាអ្នកប្រាថ្នាសេចក្ដីចម្រើនដល់បុគ្គលនោះដោយសីលជាដើម ដើម្បីឲ្យដឹងវត្ថុដែលមិនដឹង ដើម្បីអនុគ្រោះវត្ថុដែលដឹងហើយ ក្នុងទីនេះបំណងយកសេចក្ដីនេះ ។ ភិក្ខុមិនគួរក្រោធបុគ្គលដែលឃើញនូវកម្មដែលមិនសមគួរ ឬការខុសភ្លាំងភ្លាត់ហើយប្រាប់គប្បីជាអ្នកមានការត្រេកអរតែម្យ៉ាង គួរសូមថា បពិត្រលោកម្ចាស់ លោកម្ចាស់បានធ្វើកម្មដល់ខ្ញុំយ៉ាងធំ សូមលោកម្ចាស់ តាំងនៅក្នុងឋានៈជាអាចារ្យនិងឧបជ្ឈាយ៍របស់ខ្ញុំ ហើយពោលដាស់តឿនខ្ញុំដោយឱវាទទៀតចុះដូច្នេះ ដូចមនុស្សក្រីក្រមិនក្រោធបុគ្គលអ្នកគំរាម ឬវាយហើយប្រាប់កំណប់ទ្រព្យថា ចូរឯងកាន់យកទ្រព្យនេះចុះ បែរជាសប្បាយចិត្តថែមទៀតដូច្នោះ ។

បទថា **និគ្គយ្ហវាទី** បានដល់ ភិក្ខុរូបខ្លះឃើញនូវកម្មមិនសមគួរ ឬការខុសភ្លាំងភ្លាត់របស់សទ្ធិវិហារិកជាដើមហើយមិនស្ដីថា ដោយគិតថាភិក្ខុរូបនេះ

ឧបដ្ឋាកអាត្មាដោយការឲ្យទឹកខ្ពុរមាត់ជាដើម ដោយគោរព បើអញស្តីថាក៏នឹង មិនឧបដ្ឋាកអញ អញនឹងវិនាសទៅដោយប្រការយ៉ាងនេះ ដូច្នេះមិនឈ្មោះថា **និគ្គយ្ហវាទី** ភិក្ខុនោះរោយនូវសំរាមក្នុងសាសនានេះ ឯភិក្ខុណាឃើញទោស យ៉ាងនោះហើយ គំរាមបណ្តេញ ធ្វើទណ្ឌកម្មនាំចេញអំពីវិហារ ឲ្យសិក្សាតាម សមគួរដល់ទោស ភិក្ខុនេះឈ្មោះថា **និគ្គយ្ហវាទី** ដូចព្រះសម្មាសម្ពុទ្ធដូច្នោះ ។ សមដូចព្រះសាស្តាត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសក ) ថា ម្នាល អានន្ទ តថាគតសង្កត់សង្កិនហើយប្រៀនប្រដៅរឿយៗ ម្នាលអានន្ទ តថាគត បន្សាត់បង់ បំផ្លាញបង់នូវទោសចេញ ហើយប្រៀនប្រដៅថែមទៀត ដោយ គិតថានឹងឲ្យអ្នកទាំងឡាយ មានសារៈ គឺមគ្គផលតាំងនៅក្នុងសន្តានដូច្នេះ ។

បទថា **មេធាវី** បានដល់ បុគ្គលដែលប្រកបដោយបញ្ញាដែលមានឱជៈ គឺធម៌ ។ បទថា **តាទិសំ** បានដល់ គប្បីគប់រក គប្បីចូលទៅជិតបណ្ឌិតបែប នោះ ព្រោះថា កាលអន្តេវាសិកសេពគប់អាចារ្យបែបនោះ រមែងមានតែការ ប្រសើរតែម្យ៉ាង មិនមានសេចក្តីអាក្រក់ មានតែសេចក្តីចម្រើនតែម្យ៉ាង មិន មានសេចក្តីវិនាសដូច្នេះ ។

បទថា **ឱវទេយ្យ** សេចក្តីថា កាលរឿងកើតឡើងហើយ ពោលប្រៀន ប្រដៅ ឈ្មោះថាទូន្មាន កាលរឿងមិនទាន់កើតឡើង ចង្អុលឲ្យឃើញទោស ក្នុងអនាគតដោយពាក្យជាដើមថា ការមិនមានយស គប្បីមានដល់អ្នក ដូច្នេះ ឈ្មោះថាប្រៀនប្រដៅ ការពោលប្រៀនប្រដៅចំពោះមុខ ក៏ឈ្មោះថាទូន្មាន បញ្ជូនទូត ឬពាក្យប្រៀនប្រដៅទៅឯក្រោយ ឈ្មោះថាប្រៀនប្រដៅ ពោល

ប្រៀនប្រដៅត្រឹមតែម្តងឈ្មោះថាទូន្មាន ពោលរឿយៗ ឈ្មោះថាប្រៀនប្រដៅ ឬការទូន្មាននោះឯង ឈ្មោះថាការប្រៀនប្រដៅ ព្រោះហេតុនោះ បុគ្គលគប្បីទូន្មានគប្បីប្រៀនប្រដៅដោយប្រការដូច្នេះ ។ បទថា **អសព្ភា** សេចក្តីថា គប្បីហាមចាកអកុសលធម៌ គប្បីតាំងនៅក្នុងកុសលធម៌ ។ បទថា **សតញ្ហិ សោ បិយោ ហោតិ** បានដល់ បុគ្គលបែបនោះរមែងជាទីស្រឡាញ់របស់សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ។ តែភិក្ខុអ្នកទូន្មានប្រៀនប្រដៅរមែងជាទីស្អប់ខ្ពើមរបស់ភិក្ខុដែលជាអសប្បុរសដែលមិនឃើញធម៌ ជាអ្នកឆ្លងបរលោកមិនបាន ជាអ្នកសម្លឹងចំពោះអាមិស បួសដើម្បីរស់នៅ ពោលចាក់ដោតដោយលំពែងគឺមាត់ថា លោកមិនមែនឧបជ្ឈាយ៍ មិនមែនអាចារ្យរបស់ខ្ញុំទេ ហេតុអ្វីក៏មកប្រៀនប្រដៅពួកខ្ញុំដូច្នេះ ។

[ ២៧៨ ] បទថា **ឯកកម្មំ** បានដល់ មានកម្មតែមួយ មានអបលោកនកម្មជាដើម ។ បទថា **ឯកុទ្ទេសោ** បានដល់ មាននិទានុទ្ទេសជាដើម តែមួយ ។ បទថា **សមសិក្ខតា** បានដល់ មានសិក្ខាស្មើគ្នា ។ បទថា **អាហាតចិត្តតំ** បានដល់ ភាពដែលចិត្តត្រូវសេចក្តីក្រោធពាល់ត្រូវហើយ ។ បទថា **ខិលជាតតំ** បានដល់ ភាវៈនៃការរឹងត្អឹង ។ បទថា **បញ្ចបិ ចេតោខិលេ** បានដល់ ការរឹងត្អឹងនៃចិត្តក្នុងវត្ថុទាំង ៥ គឺក្នុងព្រះពុទ្ធ ១ ក្នុងព្រះធម៌ ១ ក្នុងព្រះសង្ឃ ១ ក្នុងសិក្ខា ១ ក្នុងសព្រហ្មចារី ១ ។

[ ២៧៩ ] បទថា **ញាណសមុដ្ឋិតំ វាចំ** បានដល់ ដែលកើតឡើងព្រោះចិត្តដែលសម្បយុត្តដោយញាណ ។ បទថា **មុញ្ចេយ្យ** បានដល់ គប្បីលែង

បេញទៅ ។ បទថា **អត្ថូបសំហិតំ** បានដល់ ដែលប្រកបដោយអត្ថ ប្រកបដោយហេតុ ។ បទថា **ធម្មូបសំហិតំ** បានដល់ ដែលប្រកបហើយដោយធម៌ ។ បទថា **កាលាតិក្កន្តំ វាចំ ន ភាសេយ្យ** បានដល់ មិនគប្បីពោលវាចាហួសកាល ព្រោះកន្លងកាលនោះទៅហើយ ។ បទថា **វេលាតិក្កន្តំ** បានដល់ មិនគប្បីពោលវាចាហួសព្រំដែន ព្រោះព្រំដែនរបស់វាចា កន្លងទៅហើយ គប្បីជ្រាបព្រំដែននៃកាលដោយបទទាំង ២ ។

បទថា **យោ ច កាលេ អសម្បត្តេ** បានដល់ មិនទាន់ដល់កាលដែលខ្ទួនត្រូវនិយាយ ។ បទថា **អតិវេលំ** បានដល់ និយាយលើសប្រមាណដោយឲ្យកន្លងព្រំដែន ។ បទថា **និហតោ សេតិ** បានដល់ ត្រូវសម្លាប់ ដេកស្លាប់ ។ បទថា **កោកិលាយេវ អត្រជោ** បានដល់ ដូចកូនតាវ៉ៅកើតអំពីតាវ៉ៅដែលក្អែកញីចិញ្ចឹម ។

[ ២៨១ ] បទថា **អថាបរំ** បានដល់ បន្ទាប់អំពីកាលនេះ គឺក្នុងកាលដទៃបន្ទាប់អំពីនេះ ។ បទថា **បញ្ច រជានិ** បានដល់ ធូលី ៥ មានរូបរាគៈជាដើម ។ បទថា **យេសំ សតីមា វិនយាយ សិក្ខេ** បានដល់ គប្បីតាំងសតិសិក្សាត្រៃសិក្ខា ដើម្បីកម្ចាត់រាគៈពួកណា ។ ព្រោះកាលសិក្សាយ៉ាងនេះ គួរសង្កត់សង្កិនតម្រេកក្នុងរូប ។បេ។ និងផស្សៈទាំងឡាយ មិនសង្កត់សង្កិនដទៃ ។

[ ២៨២ ] បទថា **រូបរជោ** បានដល់ ធូលីមានរាគៈជាដើមដែលអាស្រ័យរូបារម្មណ៍កើតឡើង ។ បទថា **សទ្ទរជា** ជាដើម ក៏មានន័យដូចគ្នា ។

[ ២៨៥ ] បន្ទាប់អំពីនោះភិក្ខុសិក្សាដើម្បីកម្ចាត់រាគៈក្នុងធម៌ទាំងនោះ គប្បី

សិក្សាតាមគាថាថា **ឯតេសុ ធម្មេសុ** ជាដើមដោយលំដាប់ ។ ក្នុងគាថានោះ បទថា **ឯតេសុ** បានដល់ ក្នុងរូបជាដើម ។ បទថា **កាលេន សោ សម្មា ធម្មំ បរិវីមំសមានោ** បានដល់ ភិក្ខុនោះកាលកំណត់ ពិចារណាសង្ខតធម៌ទាំងពួងដោយន័យ មានភាពជារបស់មិនទៀងជាដើម តាមកាលដែលលោកពោលដោយន័យជាដើមថា កាលបើចិត្តរាយមាយនេះជាកាលគួរដល់សមថៈ ។ បទថា **ឯកោទិភូតោ វិហនេ តមំ សោ** បានដល់ ភិក្ខុនោះមានឯកគ្គតាចិត្ត គប្បីកម្ចាត់ងងឹតមានមោហៈជាដើមទាំងអស់ចេញបានមិនមានសេចក្ដីសង្ស័យក្នុងសេចក្ដីនេះ ។

[ ២៨៨ ] បទថា **ឧទ្ធតេ ចិត្តេ** បានដល់ កាលចិត្តមិនស្ងប់ដោយអំណាចនៃវីរិយិន្ទ្រិយ ។ ពិតហើយសេចក្ដីព្យាយាមមានកម្លាំង សមាធិទន់ ការរាយមាយរមែងគ្របសង្កត់ ព្រោះសេចក្ដីព្យាយាមជាបក្សពួកនៃការរាយមាយ ។ កាលចិត្តរាយមាយយ៉ាងនេះ ។ បទថា **សមថស្ស កាលោ** បានដល់ ជាកាលនៃការចម្រើនសមាធិ ។ បទថា **សមាហិតេ ចិត្តេ** បានដល់ កាលចិត្តតាំងមាំដោយឧបចារៈនិងអប្បនា ។ ពិតហើយសមាធិមានកម្លាំង រមែងមានសេចក្ដីព្យាយាមថយ ការខ្ជិលច្រអូសរមែងគ្រប់សង្កត់ ព្រោះសមាធិជាបក្សពួកនៃការខ្ជិលច្រអូស ។ សមាធិដែលវីរិយៈចងទុកហើយរមែងមិនធ្លាក់ទៅក្នុងកោសជ្ជៈ ។ វីរិយៈដែលសមាធិចងទុកហើយរមែងមិនធ្លាក់ទៅក្នុងការរាយមាយ ។ ព្រោះហេតុនោះទាំង ២ យ៉ាងនោះ គប្បីធ្វើឲ្យស្មើគ្នា ព្រោះភាពដែលធម៌ទាំង ២ ស្មើគ្នាទើបជាអប្បនា ។ បទថា **វិបស្សនាយ កាលោ** បាន

ដល់ កាលចិត្តតាំងមាំហើយយ៉ាងនេះ ជាកាលនៃវិបស្សនាច្រើនយ៉ាង ដោយអំណាចនៃអនិច្ចាជាដើម ។ សទ្ធាមានកម្លាំងក៏គួរដល់បុគ្គលអ្នកប្រកបសមាធិ កាលសទ្ធាមាំយ៉ាងនេះរមែងដល់អប្បនា ។ ចំណែកក្នុងសមាធិនិងបញ្ញា មានសេចក្តីដូចតទៅនេះថា ឯកគ្គតាចិត្តដែលមានកម្លាំងរមែងគួរដល់បុគ្គលប្រកបសមាធិ ។ ពិតហើយបុគ្គលនោះរមែងដល់អប្បនា ដោយអាការយ៉ាងនេះ ។ បញ្ញាមានកម្លាំង រមែងគួរដល់បុគ្គលអ្នកប្រកបវិបស្សនា ព្រោះបុគ្គលនោះរមែងសម្រេចការចាក់ធ្លុះលក្ខណៈដោយប្រការដូច្នេះ កាលធម៌ទាំង ២ ស្មើគ្នាក៏ជាអប្បនាពិត ។

បទថា **កាលេ បគ្គណ្ហាតិ ចិត្តំ** បានដល់ ក្នុងសម័យណាចិត្តរួញរាព្រោះសេចក្តីព្យាយាមធូរថយជាដើម ក្នុងសម័យនោះព្រះយោគីរមែងលើកចិត្តទុកដោយការឲ្យតាំងនៅក្នុងធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គនិងបីតិសម្ពោ-ជ្ឈង្គ ។ បទថា **និគ្គណ្ហាតិ** បានដល់ ក្នុងសម័យណាចិត្តរាយមាយ ដោយប្រារព្ធការព្យាយាមខ្លាំងពេកជាដើម ក្នុងសម័យនោះព្រះយោគី រមែងសង្កត់ចិត្តទុក ដោយការឲ្យតាំងនៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គនិងឧបេក្ខាសម្ពោជ្ឈង្គ ។ បទថា **សម្បហំសតិ កាលេន** បានដល់ ក្នុងសម័យណាចិត្តមិនមានអស្សាទ ព្រោះការខ្វល់ខ្វាយដ្បិតបញ្ញាតិច ឬព្រោះមិនបានទទួលសេចក្តីសុខ ដែលកើតអំពីសេចក្តីស្ងប់ ក្នុងសម័យនោះ ព្រះយោគីរមែងឲ្យកើតសេចក្តីសង្វេគដោយការពិចារណាសង្វេគវត្ថុ ៨ ប្រការ ។ សង្វេគវត្ថុ ៨ ប្រការ គឺជាតិ ១ ជរា ១ ព្យាធិ ១ មរណៈ ១ រួមជា ៤ ទុក្ខក្នុងអបាយ

ជាគម្រប់ ៥ ទុក្ខមានវដ្តៈជាមូលក្នុងអតីតជាគម្រប់ ៦ ទុក្ខមានវដ្តៈជាមូលក្នុងអនាគតជាគម្រប់ ៧ ទុក្ខ មានការស្វែងអាហារជាមូលក្នុងបច្ចុប្បន្ន ជាគម្រប់ ៨ ។ ព្រះយោគីរមែងធ្វើចិត្តឲ្យកើតសេចក្ដីជ្រះថ្លា ដោយការរឭកដល់គុណព្រះរតនត្រ័យ ។ នេះហៅថា ពង្រីកពង្រាយចិត្តក្នុងកាលគួរ ។

បទថា **កាលេ ចិត្តំ សមាទហេ** បានដល់ ក្នុងសម័យណា កាពដែលសទ្ធានិងបញ្ញា សមាធិនិងវិរិយៈស្មើគ្នា សម័យនោះគប្បីតាំងចិត្ត គឺគប្បីឲ្យដល់អប្បនា ។ បទថា **អជ្ឈុបេក្ខតិ កាលេន** បានដល់ សម័យណា ចិត្តអាស្រ័យសម្មាបដិបត្តិមិនរួញរា មិនរាយមាយ មិនប្រាសចាកអស្សាទ ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ ប្រព្រឹត្តទៅកាន់វិថីនៃសមាធិ សម័យនោះចិត្តរមែងមិនដល់នូវការខ្វល់ខ្វាយក្នុងការលើក សង្កត់ ឲ្យត្រេកអរ ដូចសារថីកាលសេះរត់ស្មើហើយ ក៏មិនចាំបាច់ខ្វល់ខ្វាយដូច្នោះ នេះហៅថា ព្រងើយកន្តើយក្នុងកាលគួរ ។ បទថា **សោ យោគី កាលកោវិទោ** បានដល់ ព្រះយោគីនោះដែលមានប្រការដូចពោលហើយ ជាអ្នកប្រកបហើយក្នុងកម្មដ្ឋាន ជាអ្នកឈ្លាសក្នុងកាលជាទីលើក សង្កត់ ត្រេកអរ តាំងមាំនិងព្រងើយ ។

លោកសួរដល់កាលដែលលើកចិត្តជាដើម ដោយពាក្យជាដើមថា **កិម្ហិ កាលម្ហិ** ដូច្នេះ ។

ឥឡូវនេះ កាលឆ្លើយដល់កាលដែលលើកចិត្តជាដើម ទើបពោលពាក្យថា **លីនេ ចិត្តម្ហិ** ដូច្នេះជាដើម ។ កាលចិត្តដល់នូវការរួញរា ព្រោះការព្យាយាមធូរថយជាដើម ជាកាលដែលគួរលើក ដោយការឲ្យតាំងនៅក្នុងធម្មវិចយ-

សម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គនិងបីតិសម្ពោជ្ឈង្គ ។ បទថា **ឧទ្ធតស្មឹ វិនិគ្គហោ** បានដល់ កាលចិត្តរាយមាយ ព្រោះប្រារព្ធនូវសេចក្តីព្យាយាមខ្លាំងពេក ជាកាលដែលគួរសង្កត់ ដោយបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គនិងឧបេក្ខាសម្ពោជ្ឈង្គ ។ បទថា **និរស្សាទគតំ ចិត្តំ សម្បហំសេយ្យ តាវទេ** បានដល់ ព្រះយោគីគប្បីញុំាងចិត្តដែលវៀរចាកការត្រេកអរ ព្រោះការខ្វល់ខ្វាយផ្លូវបញ្ញាតិច ឬព្រោះមិនបានទទួលសេចក្តីសុខដែលកើតអំពីសេចក្តីស្ងប់ ឲ្យត្រេកអរដោយពិចារណាសង្វេគវត្ថុ ៨ ប្រការ ឬដោយរឭកដល់គុណរបស់ព្រះរតនត្រ័យក្នុងខណៈនោះ ។

បទថា **សម្បហដ្ឋំ យទា ចិត្តំ** បានដល់ ក្នុងកាលណា ចិត្តជាធម្មជាតត្រេកអរតាមន័យដែលពោលហើយនោះឯង ។ បទថា **អលីនំ ភវតិ នុទ្ធតំ** បានដល់ ចិត្តវៀរចាកការរួញរានិងការរាយមាយ ព្រោះចងទុកដោយវីរិយៈនិងសមាធិ ។ បទថា **សមថនិមិត្តស្ស** បានដល់ សមថៈផង និមិត្តផង ឈ្មោះថា សមថនិមិត្ត ។ បទថា **សោ កាលោ** បានដល់ លោកពោលដល់កាលដែលវៀរចាកការរួញរានិងការរាយមាយណាទុក កាលនោះឯង ជាកាល ។ បទថា **អជ្ឈត្តំ រមយេ មនោ** បានដល់ ចិត្តដែលសម្បយុត្ត ដោយឈានគប្បីត្រេកអរ គប្បីឲ្យអភិរម្យក្នុងអារម្មណ៍ខាងក្នុងមានកសិណជាដើម ។ បទថា **ឯតេន មេវុបាយេន** បានដល់ ដោយឧបាយដែលពោលហើយនោះឯង ។ ម អក្ខរៈលោកពោលដោយអំណាចបទសន្ធិ ។ បទថា **អជ្ឈុបេក្ខេយ្យ តាវទេ** បានដល់ ក្នុងកាលណាចិត្តនោះតាំងមាំដោយឧបចារៈនិងអប្បនាហើយ ក្នុង

កាលនោះព្រះយោគីដឹងហើយថា ចិត្តតាំងមាំហើយ មិនធ្វើនូវការខ្វល់ខ្វាយក្នុងការលើក ការសង្កត់និងការឲ្យត្រេកអរ គួរធ្វើការព្រងើយតែម្យ៉ាង ក្នុងខណៈនោះ ។

ឥឡូវនេះ កាលសរុបគាថា ដែលសួរថា **កិម្ហិ កាលម្ហិ បគ្គាហោ** ទើបពោលពាក្យថា **ឯវំ កាលវិទូ ធីរោ** ដូច្នេះ ជាដើម ។ បទថា **កាលេន កាលំ ចិត្តស្ស និមិត្តមុបលក្ខយេ** សេចក្ដីថា គប្បីកំណត់ គប្បីចូលទៅកំណត់នូវអារម្មណ៍របស់ចិត្ត ដែលសម្បយុត្តដោយសមាធិ តាមកាលដែលសមគួរ ។ បទដ៏សេសក្នុងទីទាំងពួងប្រាកដច្បាស់ហើយ ។ ព្រះសារីបុត្តត្ថេរបញ្ចប់ទេសនាដោយកំពូល គឺព្រះអរហត្ត ដោយប្រការដូច្នេះ ។

អដ្ឋកថា សារីបុត្តសុត្តនិទ្ទេសទី ១៦ ចប់

សទ្ធម្មប្បជ្ជោតិកា អដ្ឋកថាខុទ្ទកនិកាយ មហានិទ្ទេស អដ្ឋកវគ្គ ចប់

អដ្ឋកថាមហានិទ្ទេស ចប់ ដោយបរិបូណ៌

# ក្បាលទី ៥៤

# សុត្តន្តបិដក ចាលីប្រែ -៦៥

## សន្ទឹកបង្អួលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| បុរាភេទសុត្តនិទ្ទេសទី ១០ | ២ |
| អដ្ឋកថា បុរាភេទសុត្តនិទ្ទេសទី ១០ | ៧៤ |
| កលហវិវាទសុត្តនិទ្ទេសទី ១១ | ១៤២ |
| អដ្ឋកថា កលហវិវាទសុត្តនិទ្ទេសទី ១១ | ១៩២ |
| ចូឡវិយូហសុត្តនិទ្ទេសទី ១២ | ២០៩ |
| អដ្ឋកថា ចូឡវិយូហសុត្តនិទ្ទេសទី ១២ | ២៤២ |
| មហាវិយូហសុត្តនិទ្ទេសទី ១៣ | ២៥២ |
| អដ្ឋកថា មហាវិយូហសុត្តនិទ្ទេសទី ១៣ | ៣០៦ |


# សុត្តន្តបិដក ចាលីប្រែ -៦៦


| | |
|---|---|
| តុវដកសុត្តនិទ្ទេសទី ១៤ | ៣២០ |
| អដ្ឋកថា តុវដកសុត្តនិទ្ទេសទី ១៤ | ៤១៦ |
| អត្ថរបស់ អារម្ភ សព្ទ | ៤៨២ |
| អត្តទណ្ឌសុត្តនិទ្ទេសទី ១៥ | ៥០៩ |
| អដ្ឋកថា អត្តទណ្ឌសុត្តនិទ្ទេសទី ១៥ | ៥៨៣ |
| សារីបុត្តសុត្តនិទ្ទេសទី ១៦ | ៦១១ |
| អដ្ឋកថា សារីបុត្តសុត្តនិទ្ទេសទី ១៦ | ៧២៣ |
| អត្ថរបស់ បរិក្ខារ សព្ទ | ៧៧៣ |